# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ២

បាលីប្រែ ១ - ២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# វិនយបិដក

## និង

## សមន្តប្បាសាទិកា អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## មហាវិភង្គ

## បារាជិកកណ្ឌ និង តេរសកណ្ឌ

## ២

## បាលីប្រែ ១-២



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី២

# ចារាជិកកណ្ឌ សិក្ខាបទទី ២

[ ៧៩ ] សម័យនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះ មានភិក្ខុច្រើនរូបជាមិត្តសម្លាញ់ គ្រាន់តែជួបឃើញគ្នាខ្លះ ជាមិត្តសម្លាញ់នៅរួបរួមជាមួយគ្នាខ្លះ ធ្វើកុដិប្រក់ដោយស្មៅក្បែរជើងភ្នំឥសិគិលិ ហើយចាំវស្សា ( នៅនោះ ) ។ មានភិក្ខុ ( ១ រូប ) ឈ្មោះធនិយដ៏មានអាយុជាកូនស្មូនឆ្នាំង ធ្វើកុដិតូច ប្រក់ដោយស្មៅ ហើយចាំវស្សានៅនោះដែរ ។ គ្រានោះ ភិក្ខុទាំងនោះ លុះចាំវស្សាគ្រប់៣ ខែហើយក៏រុះរើកុដិស្មៅនោះ ហើយរៀបចំទុកដាក់ស្មៅ និងឈើ ( តាមដោយឡែកស្រួលបួល ) ហើយចេញទៅកាន់ជនបទចារិក ។ ចំណែកខាងឯធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏នៅតែក្នុងទីនោះអស់វស្សានរដូវ ហើយនៅអស់ហេមន្តរដូវ និងគិម្ហរដូវ ក្នុងទីនោះ ( តទៅទៀត ) ។ គ្រានោះ កាលដែលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅ និងពួកអ្នករកឧស នាំគ្នារុះកុដិប្រក់ដោយស្មៅ ( របស់ធនិយភិក្ខុ ) ហើយប្រមូលយកស្មៅ និងឈើទៅអស់ ។ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏រកស្មៅនិងឈើមកហើយសង់កុដិប្រក់ដោយស្មៅជាគម្រប់ពីរដង ។ កាលធនិយភិក្ខុដ៏មានអាយុ ជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក ពួកអ្នករកស្មៅ និងពួកអ្នករកឧស ក៏រុះកុដិស្មៅ ហើយដញ្ជួនយកស្មៅ និងឈើទៅទៀត ជាគម្រប់ពីរដង ។ ធនិយភិក្ខុដ៏មានអាយុ

ជាកូនស្មូនឆ្នាំង ក៏រកស្មៅ និងឈើមកហើយ សង់កុដិស្មៅជាគម្រប់ ៣ ដង កាលធនិយភិក្ខុដ៏មានអាយុ ជាកូនស្មូនឆ្នាំង ចូលទៅបិណ្ឌបាតក្នុងស្រុក ពួកអ្នករកស្មៅ និងពួកអ្នករកឧស ក៏រុះកុដិស្មៅ ហើយជញ្ជូនយកស្មៅ និងឈើទៅទៀតជាគម្រប់ ៣ ដង ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុ ជាកូនស្មូនឆ្នាំងត្រិះរិះថា អញចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅ និងពួកអ្នករកឧស មករុះរើកុដិ ហើយយកស្មៅ និងឈើទៅអស់ ជាបអស់វារៈ ៣ ដងហើយ ឯខ្លួនអញជាអ្នកសិក្សារៀនសូត្រ ដោយពេញលេញឥតមានខ្វះខាត ដោយសិល្បសាស្ត្រណាមួយឡើយ បានចេះប្រាកដក្នុងសិល្បសាស្ត្រខាងការងារស្មូនឆ្នាំង ក្នុងសម្នាក់គ្រូអាចារ្យរបស់ខ្លួនមកហើយដែរ បើដូច្នោះ មានតែអញ ត្រូវជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិតូចមួយឲ្យសុទ្ធដោយដីទាំងអស់ ។ លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុ ជាកូនស្មូនឆ្នាំងក៏ជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិតូចដោយដីសុទ្ធទាំងអស់ រួចហើយយកស្មៅ ឧស និងអាចម៍គោមកដុតកុដិនោះ ( ដើម្បីឲ្យឆ្អិន ) ។ កុដិនោះ មានទ្រង់ទ្រាយល្អគួរចង់មើល គួរឲ្យកើតសេចក្ដីជ្រះថ្លា មានពណ៌ក្រហម ដូចជាពណ៌នៃសត្វមេក្អៀង ។ កុដិនោះ ( កាលបើមានខ្យល់បក់មកត្រូវ ក៏មានសំឡេងលាន់ឮ ) បីដូចជាសំឡេងកណ្ដឹង ។ គ្រានោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ កាលយាងចុះពីភ្នំគិជ្ឈកូដជាមួយនឹងភិក្ខុច្រើនរូប ទ្រង់ទតទៅឃើញកុដិនោះ មានទ្រង់ទ្រាយល្អ គួរចង់មើល គួរឲ្យកើតសេចក្ដីជ្រះថ្លា មានពណ៌ក្រហម លុះទតហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមក ហើយមាន

ព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយ កុដិនោះមានទ្រង់ទ្រាយល្អ គួរចង់មើល គួរឲ្យកើតសេចក្ដីជ្រះថ្លា មានពណ៌ក្រហម ដូចជាពណ៌នៃសត្វមេអំបៅ ឬអ្វី ។ ភិក្ខុទាំងឡាយ ក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងគ្រានោះ ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ ( ការងារ ) របស់មោឃបុរសនោះ ជាការងារមិនសមគួរ មិនមានទំនង មិនមានបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ ម្នាលភិក្ខុទាំងឡាយ ចុះហេតុដូចម្ដេចក៏បានជាមោឃបុរសនោះជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិសុទ្ធដោយដីទាំងអស់ ( ដូច្នោះ ) ម្នាលភិក្ខុទាំងឡាយ សេចក្ដីករុណា សេចក្ដីអនុគ្រោះ និងសេចក្ដីមិនបៀតបៀនដល់ពួកសត្វមានជីវិតទំនងជាមិនមានដល់មោឃបុរសនោះទេដឹង ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ ទៅទម្លាយកុដិនោះចេញ កុំឲ្យបណ្ដាជនជាខាងក្រោយបៀតបៀនបំផ្លាញដល់បាណកជាតិទៀតឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកុដិឲ្យសុទ្ធដោយដីទាំងអស់ទេ បើភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងនោះទទួលពុទ្ធដីកាថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះ រួចហើយ កុដិនោះនៅក្នុងទីណា នាំគ្នាចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏វាយបំបាក់កុដិនោះទៅ ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង សួរភិក្ខុទាំងនោះថា នែលោកទាំងឡាយ ចុះហេតុអ្វីបានជាលោកនាំគ្នាមកវាយបំបាក់កុដិខ្ញុំដូច្នេះ ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ឲ្យវាយបំបាក់ ។ ធនិយភិក្ខុឆ្លើយតបថា អើ លោកដ៏មានអាយុ

ទាំងឡាយ បើព្រះដ៏មានព្រះភាគជាធម្មសាមី ទ្រង់ត្រាស់ឲ្យវាយបំបាក់ និមន្ត វាយបំបាក់ចុះ ។

[ ៨០ ] លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រ មានសេចក្តីត្រិះរិះថា កាលដែលអញចូលទៅបិណ្ឌបាតក្នុងស្រុក មានពួកអ្នករកស្មៅ និងពួកអ្នករកឧសមករុះកុដិដែលប្រក់ដោយស្មៅ ហើយជញ្ជូនយកស្មៅនិងឈើទៅអស់ ដរាបអស់វារៈបីដង កុដិដែលអញធ្វើហើយ ឲ្យស្អុទ្ធដោយដីទាំងអស់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ប្រើឲ្យភិក្ខុវាយបំបាក់ចេញអស់ មានបុរសអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងហ្លួង ( ១ នាក់ ) អញធ្លាប់ស្គាល់ដែរ បើដូច្នោះមានតែអញត្រូវសុំឈើពីអ្នកដែលកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេច ហើយធ្វើកុដិដោយឈើវិញ ។ លំដាប់នោះ ធនិយ-ភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ក៏ចូលទៅរកអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេច លុះចូលទៅដល់ហើយ ក៏និយាយនឹងអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចនោះថា ម្នាលអ្នកដ៏មានអាយុ កាលអាត្មាចូលទៅបិណ្ឌ-បាតក្នុងស្រុក មានពួកអ្នករកស្មៅនិងពួកអ្នករកឧសមករុះកុដិដែលប្រក់ដោយស្មៅហើយជញ្ជូនយកស្មៅ និងឈើទៅអស់ ( តែដូច្នេះឯង ) អស់វារៈបីដងហើយ កុដិដែលអាត្មាធ្វើហើយឲ្យស្អុទ្ធដោយដីទាំងអស់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រើឲ្យភិក្ខុវាយបំបាក់បំបែកចេញអស់ នែអ្នកដ៏មានអាយុ ចូរអ្នកប្រគេនឈើមកអាត្មាៗ ចង់ធ្វើកុដិឈើ ។ អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចឆ្លើយថា បពិត្រលោកដ៏ចម្រើន ឈើដែលខ្ញុំករុណាល្មមគួរ

សមនឹងប្រគេនលោកម្ចាស់នោះគ្មានទេ មានតែឈើព្រះរាជទ្រព្យ សម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការពារអន្តរាយលោកម្ចាស់ បើព្រះរាជាទ្រង់ត្រាស់ឲ្យប្រគេន ( មានអ្វី ) លោកម្ចាស់ឲ្យគេមកនាំយកទៅចុះ ។ ធនិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ស្តេចប្រគេនហើយតើ ។ លំដាប់នោះអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចគិតថា សមណៈទាំងនេះជាសក្យបុត្ត ជាអ្នកប្រព្រឹត្តនូវធម៌ មានសេចក្តីប្រព្រឹត្តស្មើជាប្រក្រតី មានកិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ លោកនិយាយតែពាក្យពិត លោកជាអ្នកមានសីលនិងមានធម៌ដ៏ល្អ សូម្បីស្តេចក៏ជ្រះថ្លានឹងសមណៈទាំងនេះពេញទី ( បើដូច្នេះ ) របស់ដែលគេមិនទាន់ឲ្យ លោកមិនគួរនឹងនិយាយថា គេឲ្យទេ ( លុះគិតដូច្នេះហើយ ) ក៏និយាយនឹងធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ឲ្យគេមកនាំយកឈើនោះទៅចុះ ។ គ្រានោះ ធនិយភិក្ខុដ៏មានអាយុ ជាកូនស្មូនឆ្នាំងឲ្យមនុស្សកាត់ឈើនោះជាកំណាត់តូចកំណាត់ធំ ហើយឲ្យដឹកនាំយកទៅដោយរទេះទាំងឡាយ ហើយបានចាត់ចែងធ្វើកុដិឈើ ។

[ ៨១ ] គ្រានោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ កាលដើរពិនិត្យត្រួតត្រាមើលការងារក្នុងក្រុងរាជគ្រឹះ ក៏ចូលទៅរកអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេច លុះចូលទៅដល់ហើយ ក៏និយាយនឹងអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចនោះថា នែនាយ ឈើព្រះរាជទ្រព្យឯណាសម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការពារអន្តរាយ

ឈើនោះនៅឯណា ។ អ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងរបស់ស្តេចឆ្លើយថា បពិត្រលោកជាម្ចាស់ ឈើនោះស្តេចបានប្រគេនទៅធនិយភិក្ខុជាម្ចាស់ជាកូនស្មូនឆ្នាំងហើយ ។ លំដាប់នោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ មានសេចក្តីតូចចិត្ត ( ដោយគិត ) ថា ចុះហេតុអ្វីក៏បានជាស្តេចប្រគេនឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការពារអន្តរាយទៅធនិយភិក្ខុជាកូនស្មូនឆ្នាំងវិញ ។ គ្រានោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ចូលទៅក្នុងទីដែលព្រះបាទពិម្ពិសារមាគធសេនិយរាជគង់នៅ លុះចូលទៅដល់ហើយក៏ក្រាបទូលថា បានឮថា ឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះនគរ ដែលទុកប្រយោជន៍ការពារអន្តរាយ ព្រះអង្គទ្រង់ប្រគេនទៅធនិយភិក្ខុមែនឬ ។ ព្រះបាទពិម្ពិសារសួរថា អ្នកណានិយាយយ៉ាងនេះ ។ មហាមាត្យឆ្លើយថា បពិត្រព្រះសម្មតិទេព អ្នកកាន់កាប់ថែរក្សាឈើ ។ ព្រះបាទពិម្ពិសារទ្រង់មានព្រះបន្ទូលថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកឯងឲ្យមនុស្សទៅនាំអ្នកកាន់កាប់ថែរក្សាឈើមកមើល ។ លំដាប់នោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងដែនមគធៈ ក៏ឲ្យមនុស្សទៅចាប់ចងអ្នកកាន់កាប់ថែរក្សាឈើហើយនាំមក ។

[ ៨២ ] ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង បានឃើញអ្នកកាន់កាប់ថែរក្សាឈើ ដែលជាប់ក្តីហើយគេកំពុងបណ្តើរទៅ លុះឃើញហើយ ក៏សួរអ្នកកាន់កាប់ថែរក្សាឈើនោះថា ចុះហេតុអ្វីអាវុសោ បានជាអ្នកត្រូវគេចងបណ្តើរទៅដូច្នេះ ។ អ្នកកាន់កាប់ថែរក្សាឈើឆ្លើយថា បពិត្រលោកដ៏

ចម្រើន ព្រោះរឿងឈើនោះ ។ ធនិយភិក្ខុឆ្លើយថា អាវុសោ អ្នកទៅចុះ អាត្មានឹងទៅដែរ ។ អ្នកកាន់កាប់ថែរក្សាឈើឆ្លើយថា លោកម្ចាស់គួរមក ខ្ញុំព្រះករុណាលំបាកមុនហើយ ។ លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រ ក៏ចូលទៅកាន់ព្រះរាជដំណាក់ នៃព្រះបាទពិម្ពិសារមាគធសេនិយរាជ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេបានក្រាលប្រគេន ។ វេលានោះ ព្រះបាទពិម្ពិសារមគធសេនិយរាជ ក៏ចូលទៅត្រង់កន្លែងដែលធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រគង់នៅ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំចំពោះធនិយភិក្ខុដ៏មានអាយុជាកុម្ភការបុត្រ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទពិម្ពិសារមាគធសេនិយរាជ គង់ក្នុងទីដ៏សមគួរហើយ ទើបទ្រង់មានព្រះបន្ទូលសួរធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងថា បពិត្រលោកដ៏ចម្រើន បានឮថា ឈើព្រះរាជទ្រព្យសម្រាប់ជួសជុលព្រះនគរ ដែលទុកបម្រុងការពារអន្តរាយ ខ្ញុំបានប្រគេនលោកពិតមែនឬ ។ ធនិយភិក្ខុឆ្លើយថា ថ្វាយព្រះពរមហារាជ ពិតមែន ។ ព្រះបាទពិម្ពិសារទ្រង់មានព្រះបន្ទូលថា បពិត្រលោកដ៏ចម្រើន ធម្មតាយើងជាស្តេចមានកិច្ចច្រើន ការងារដែលត្រូវធ្វើក៏មានច្រើន បើទុកជាយើងឲ្យមែន ក៏នឹកមិនឃើញដែរ ហេតុនេះសូមលោករំលឹកខ្ញុំផង ។ ធនិយភិក្ខុឆ្លើយថា ថ្វាយព្រះពរមហារាជ សូមព្រះអង្គទ្រង់រំពឹងទៅមើលកាលដែលទ្រង់ទើបបានរាជាភិសេកនោះ ទ្រង់មានព្រះបន្ទូលមានសភាពយ៉ាងនេះថា ស្មៅ ឈើ និងទឹក ខ្ញុំបានឲ្យហើយដល់សមណៈ និងព្រាហ្មណ៍ទាំងឡាយៗ ចូរប្រើប្រាស់ ( នូវស្មៅ ឈើ និងទឹកនោះចុះ ) ។ ព្រះបាទ

ពិម្ពិសារមានព្រះបន្ទូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំនឹកឃើញហើយ ( ប៉ុន្តែ ថា ) សមណៈ និងព្រាហ្មណ៍ទាំងឡាយដែលមានសេចក្តីអៀនខ្មាស សេចក្តីសង្ស័យ និងមានសេចក្តីប្រាថ្នាក្នុងសិក្ខា សមណៈ និងព្រាហ្មណ៍ទាំងនោះ រមែងកើតមានសេចក្តីសង្ស័យ ក្នុងហេតុនីមួយសូម្បីតែបន្តិចបន្តួច ស្មៅ ឈើ និងទឹក ដែលខ្ញុំនិយាយថាឲ្យនោះ គឺឲ្យចំពោះសមណៈ និងព្រាហ្មណ៍ទាំងនោះ ព្រោះថា ស្មៅ ឈើ និងទឹកនោះឯង ដែលមានក្នុងព្រៃឥតមានអ្នកណាហួងហែងឡើយ បពិត្រលោកដ៏ចម្រើន លោកសម្គាល់អាងដោយហេតុបន្តិចបន្តួចនោះ ដើម្បីនាំយកឈើដែលគេមិនបានឲ្យយ៉ាងនេះ មនុស្សទាំង-ឡាយប្រហែលដូចខ្ញុំ នឹងសម្លាប់ ឬចង ឬបំបរបង់នូវសមណៈ ឬព្រាហ្មណ៍ដូចម្តេចកើត បពិត្រលោកដ៏ចម្រើន សូមលោកនិមន្តទៅចុះ លោករួច ( ទោស ) ហើយដោយសាររោម ( គឺ ភេទនៃបព្វជិត ) លោកកុំធ្វើយ៉ាងនេះទៀតឡើយ ។

[ ៨៣ ] មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈជាសក្យបុត្រទាំងនេះ គ្មានសេចក្តីអៀនខ្មាស ជាអ្នកទ្រុស្តសីល និយាយកុហក គួរណាស់តែសមណៈទាំងនេះប្រព្រឹត្តនូវធម៌ មានសេចក្តីប្រព្រឹត្តស្មើជាប្រក្រតី និងប្រព្រឹត្តនូវធម៌ដ៏ប្រសើរ និយាយទៀងត្រង់ មានសីល និងមានធម៌ល្អ ទើបនឹងប្តេជ្ញា ( ខ្លួនជាសមណៈបាន ) ភាវៈនៃសមណៈរបស់លោកទាំងនេះគ្មានទេ ភាវៈនៃធម៌ដ៏ប្រសើររបស់លោកទាំងនេះគ្មានទេ សាមញ្ញគុណរបស់លោកទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់លោក

ទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់លោកទាំងនេះនឹងមានមកអំពីឯណា ព្រហ្មញ្ញគុណរបស់លោកទាំងនេះនឹងមានមកអំពីឯណា លោកទាំងនេះប្រាសហើយចាកសាមញ្ញគុណ លោកទាំងនេះប្រាសហើយចាកព្រហ្មញ្ញ-គុណ សមណៈទាំងនេះហ៊ានបញ្ឆោតដល់ស្តេចផែនដី ចំណាំបើមនុស្សឯទៀត យ៉ាងណាទៅអេះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោសតិះដៀល បន្តុះបង្អាប់ ដូច្នេះហើយ ។ ពួកភិក្ខុឯណាមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស អ្នកអៀនខ្មាស មានសេចក្តីរង្កៀស មានប្រាថ្នាក្នុងសិក្ខា ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វីបានជាធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងទៅយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ស្តេច ( ដូច្នោះ ) ។ គ្រានោះ ភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំងក្នុងវេលានោះថា ធនិយភិក្ខុ ឮថា អ្នកឯងបានយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ព្រះរាជាមែនឬ ។ ធនិយភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ការណ៍នោះពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលធនិយភិក្ខុថា នែមោឃបុរស កម្មនេះ ជាកម្មមិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែមោឃបុរស ហេតុអ្វីក៏បានជាអ្នកឯងទៅយករបស់ដែលគេមិនបានឲ្យ គឺឈើរបស់ព្រះរាជា (ដូច្នោះ) នែមោឃបុរស អំពើនេះ មិនមែនកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិន

ទាន់ជ្រះថ្លា និងមិនមែននាំឲ្យរីងរឹតតែជ្រះថ្លា ដល់ជនទាំងឡាយដែលជ្រះថ្លាស្រាប់នោះទេ នែមោឃបុរស អំពើនេះ ប្រាកដជានាំបណ្ដាលមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លាឲ្យខាតខានមានសេចក្ដីជ្រះថ្លា នឹងនាំបណ្ដាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ ឲ្យបាត់ជ្រះថ្លាទៅវិញ ។ សម័យនោះ មានមហាមាត្យម្នាក់ ពីដើមធ្លាប់ធ្វើជាចៅក្រមចាស់ បានបួសក្នុងសំណាក់ពួកភិក្ខុ ( ភិក្ខុនោះឯង ) បានទៅអង្គុយជិតព្រះដ៏មានព្រះភាគ ។ វេលានោះ ព្រះអង្គទ្រង់មានព្រះបន្ទូលសួរភិក្ខុនោះថា ម្នាលភិក្ខុ ព្រះបាទពិម្ពិសារមាគធសេនិយរាជចាប់ចោរបានហើយ សម្លាប់ក្ដី ឃុំឃាំងក្ដី និរទេសក្ដី ដោយរបស់មានតម្លៃចំនួនប៉ុន្មាន ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដោយរបស់មានតម្លៃចំនួន ១ បាទ ឬគួរដល់ ១ បាទ ឬច្រើនជាង ១ បាទ ។ សម័យនោះឯង ក្នុងក្រុងរាជគ្រឹះគេចាយប្រាក់ ៥ មាសកជា ១ បាទ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង ដោយអនេកបរិយាយ ហើយទ្រង់សម្ដែងនូវទោសនៃការដែលគេពិបាកចិញ្ចឹម ។បេ។ ហើយទ្រង់ត្រាស់សរសើរគុណ នៃការប្រារព្ធព្យាយាម រួចទ្រង់សម្ដែងនូវធម្មីកថា ដ៏សមគួរដល់សិក្ខាបទនោះ ឲ្យមានទំនងតាមសិក្ខាបទនោះចំពោះភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ ។បេ។ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះដូច្នេះថា ភិក្ខុណាមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចំណែកនៃចិត្តលួច ស្ដេចទាំងឡាយចាប់បានចោរហើយ ត្រូវសម្លាប់ក្ដី ឃុំឃាំង

ក្តី និរទេសក្តី ដោយពាក្យថា អាឯងជាចោរ ជាមនុស្សពាលវង្វេង ជាមនុស្ស លួចព្រោះអទិន្នាទានមានសភាពយ៉ាងណា ភិក្ខុកាលដែលកាន់យកទ្រព្យដែល គេមិនបានឲ្យមានសភាពដូច្នោះ ភិក្ខុនេះក្តី ក៏ត្រូវអាបត្តិបារាជិក រកសំវាស គ្មាន ( គឺឥតមានកិរិយានៅរួបរួមគ្នាបាន ) សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ៨៤ ] សម័យនោះ ឆព្វគ្គិយភិក្ខុទាំងឡាយ នាំគ្នាទៅកាន់កំពង់របស់ ជាងជ្រលក់ ហើយលួចយកបង្វេចសំពត់របស់ជាងជ្រលក់ មកកាន់អារាម ហើយចែកគ្នា ។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា ម្នាលអាវុសោ លោក ទាំងឡាយជាអ្នកមានបុណ្យច្រើន ចីវរកើតឡើងដល់លោកច្រើន ។ ឆព្វ- គ្គិយភិក្ខុឆ្លើយថា ម្នាលភិក្ខុអាវុសោ បុណ្យរបស់យើងមានមកពីណា អម្បាញ់- មិញយើងទៅឯកំពង់របស់ជាងជ្រលក់ ហើយយើងបានលួចយកបង្វេចសំពត់ របស់ជាងជ្រលក់មកទេតើ ។ ភិក្ខុទាំងឡាយនិយាយថា អាវុសោ សិក្ខាបទ ព្រះបរមគ្រូទ្រង់បញ្ញត្តរួចហើយតើ ចុះហេតុអ្វីបានជាលោកនាំគ្នាទៅលួចបង្វេច សំពត់របស់ជាងជ្រលក់មក ។ ឆព្វគ្គិយភិក្ខុឆ្លើយតបថា ម្នាលអាវុសោ សិក្ខា បទព្រះបរមគ្រូជាម្ចាស់ទ្រង់បញ្ញត្តរួចហើយក៏ពិតមែន តែថា សិក្ខាបទនោះទ្រង់ បញ្ញត្តចំពោះតែក្នុងស្រុក ត្រង់ក្នុងព្រៃទ្រង់មិនបញ្ញត្តទេ ។ ភិក្ខុទាំងនោះនិយាយ ថា អាវុសោ សិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តហើយក្នុងស្រុកនោះក៏ប្រាកដដូច ជាក្នុងព្រៃដូច្នោះដែរ មិនមែនឬអ្វី នែអាវុសោ អំពើដែលលោកធ្វើនេះ មិន សមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី

មិនគួរធ្វើឡើយ នែអាវុសោទាំងឡាយ ចុះហេតុដូចម្តេច ក៏បានជាលោកនាំគ្នា ទៅលួចបង្វេចសំពត់របស់ជាងជ្រលក់មក ម្នាលអាវុសោ កម្មនេះមិនមែននាំឲ្យ កើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យរឹងរឹត តែកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលមានសេចក្តីជ្រះថ្លាហើយនោះទេ ម្នាលអាវុសោ កម្មនេះប្រាកដជានាំបណ្តាលឲ្យមនុស្សពួកខ្លះដែលមិនទាន់ជ្រះថ្លា ឲ្យខានបានកើតសេចក្តីជ្រះថ្លា នឹងនាំបណ្តាលមនុស្សពួកខ្លះដែលជ្រះថ្លាហើយ ឲ្យត្រឡប់ជាវាយមាយរសាយបាត់សេចក្តីជ្រះថ្លាទៅវិញ ។ គ្រានោះ ភិក្ខុទាំង-ឡាយនោះក៏តិះដៀលឆព្វគ្គិយភិក្ខុដោយអនេកបរិយាយ ហើយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះឆព្វគ្គិយភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកឯងនាំគ្នាទៅកាន់កន្លែងដែលជាងជ្រលក់គេលាតត្រដាងសំពត់ ហើយបានលួចបង្វេចសំពត់របស់ជាងជ្រលក់ មែនឬ ។ ឆព្វគ្គិយភិក្ខុឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលឆព្វគ្គិយភិក្ខុថា នែមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ ជាអំពើមិនសមគួរ មិនត្រូវទំនង មិនត្រូវបែបផែន មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើឡើយ នែមោឃបុរសទាំងឡាយ ចុះហេតុអ្វីបានជាអ្នកនាំគ្នាទៅលួចបង្វេចសំពត់របស់ជាងជ្រលក់ នែមោឃបុរស អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លានោះទេ ។បេ។ នឹងនាំបណ្តាលឲ្យជនពួកខ្លះដែលជ្រះថ្លាហើយ ត្រឡប់ជាវាយមាយរសាយបាត់

សេចក្តីជ្រះថ្លាទៅវិញ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលធនិយភិក្ខុ ដោយព្រះពុទ្ធដីកាជាអនេកបរិយាយ ហើយទ្រង់សម្តែងទោសនៃការដែលគេពិបាកចិញ្ចឹម ។បេ។ ទើបទ្រង់ត្រាស់សរសើរគុណនៃការប្រារព្ធនូវព្យាយាម រួចហើយទ្រង់សម្តែងនូវធម្មីកថា ដ៏សមគួរដល់សិក្ខាបទនោះៗ ឲ្យមានទំនងតាមសិក្ខាបទនោះៗ ចំពោះភិក្ខុទាំងឡាយ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ ។បេ។ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះថា ភិក្ខុណាមួយកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយចំណែកនៃចិត្តលួច អំពីស្រុកក្តី ព្រៃក្តី ស្តេចទាំងឡាយចាប់បានចោរហើយ ត្រូវសម្លាប់ក្តី ឃុំឃាំងក្តី និរទេសក្តី ដោយពាក្យថា ឯងជាចោរ ជាមនុស្សពាលវង្វេង ជាមនុស្សលួច ព្រោះអទិន្នាទាន មានសភាពយ៉ាងណា ភិក្ខុកាលដែលកាន់យកទ្រព្យដែលគេមិនឲ្យ មានសភាពយ៉ាងនោះ ភិក្ខុនេះក្តី ក៏ត្រូវអាបត្តិបារាជិករកសំវាសគ្មាន ( គឺឥតមានកិរិយានៅរួបរួមគ្នាបាន ) ។

[ ៨៥ ] ត្រង់ពាក្យថា ណាមួយ សេចក្តីថា ឯណា ប្រាកដដូចជាឯណា ។បេ។ ភិក្ខុនេះ តថាគតហៅថា ណាមួយ ។ ត្រង់ពាក្យថា ភិក្ខុ ។បេ។ សេចក្តីថា ភិក្ខុនេះតថាគតអធិប្បាយក្នុងសេចក្តីនេះ ។ ដែលឈ្មោះថា ស្រុក ( នោះ ) គឺស្រុកដែលមានខ្ទមមួយក្តី ស្រុកដែលមានខ្ទមពីរក្តី ស្រុកដែលមានខ្ទមបីក្តី ស្រុកដែលមានខ្ទមបួនក្តី ស្រុកដែលមានមនុស្សក្តី ស្រុកដែលឥតមនុស្សក្តី ស្រុកដែលមានរបង ឬកំពែងក្តី ស្រុកដែលឥតរបង ឬកំពែងក្តី ស្រុកដែលគេទើបនឹងតាំងនៅថ្មី ( មានផ្ទះពីរបី ) ដូចជាគោឈរក្តី ពុំនោះ

សោត ប្រទេសណាដែលមានពួកឈ្មួញបានអាស្រ័យនៅលើសជាង ៤ ខែ ឡើងទៅ ប្រទេសនោះ ក៏លោកហៅថា ស្រុក ។ ដែលឈ្មោះថា ឧបចារនៃស្រុក ( នោះ ) គឺទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្រែបធរណីទ្វារស្រុកដែលមានរបង ឬកំពែង បោលទៅ ( ឬ ) ទីធ្លាក់ចុះនៃដុំដី របស់មជ្ឈិមបុរសឈរប្រែបឧបចារផ្ទះនៃស្រុកដែលឥតរបង ឬកំពែង បោលទៅ ។ ដែលឈ្មោះថា ព្រៃ ( នោះ ) គឺទីដ៏សេសលើកលែងតែស្រុក និងឧបចារនៃស្រុកចេញ ឈ្មោះថា ព្រៃ ។ ដែលឈ្មោះថាទ្រព្យដែលគេមិនបានឲ្យ ( នោះ ) គឺរបស់ណាដែលគេមិនបានឲ្យ មិនទាន់លះបង់ឲ្យ មិនទាន់ដាក់ចិត្តឲ្យ គេរក្សាទុក គេគ្រប់គ្រងទុក គេនៅប្រកាន់ គេនៅហួងហែង ទ្រព្យនោះឈ្មោះថា ទ្រព្យដែលគេមិនបានឲ្យ ។ ត្រង់បទថា ដោយចំណែកនៃចិត្តលួច សេចក្តីថា ភិក្ខុ មានចិត្តជាអ្នកលួច គឺថា ភិក្ខុមានចិត្តបម្រុងនឹងលួច ។

[ ៨៦ ] ត្រង់បទថា គប្បីកាន់យក សេចក្តីថា ភិក្ខុគប្បីចាប់យក គប្បីនាំទៅ គប្បីលួចយក គប្បីឲ្យកម្រើកឥរិយាបថ គប្បីឲ្យឃ្លាតចាកទី គប្បីឈានកន្លងនូវទីដែលកំណត់ ។

[ ៨៧ ] ដែលឈ្មោះថា មានសភាពយ៉ាងណា ( នោះ ) គឺទ្រព្យចំនួន ១ បាទ ឬទ្រព្យគួរដល់តម្លៃ ១ បាទ ឬថា ក្រៃលែងជាងមួយបាទឡើងទៅ ។ ដែលឈ្មោះថា ស្តេចទាំងឡាយ ( នោះ ) គឺស្តេចជាធំលើប្រឹថពីទាំងអស់ ស្តេចជាធំក្នុងប្រទេស ពួកអ្នកត្រួតមណ្ឌល ( ចៅហ្វាយខេត្ត ) ពួកអ្នកបរិភោគស្រុកជាលំដាប់ ( ចៅហ្វាយស្រុក ) ពួកអ្នកកាត់ក្តី ពួក

មហាមាត្យ ពុំនោះសោត ពួកឥស្សរជនណា ជាអ្នកត្រួតត្រាក្នុងការកាប់សម្លាប់ ពួកឥស្សរជនទាំងនោះ ឈ្មោះថា ស្តេច ។ ដែលឈ្មោះថា ចោរ ( នោះ ) គឺអ្នកណាដែលកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ មានតម្លៃប្រមាណ ៥ មាសក ឬច្រើនជាង ៥ មាសកឡើងទៅ ដោយចំណែកនៃចិត្តលួច អ្នកនោះ ឈ្មោះថា ចោរ ។ ត្រង់ពាក្យថា គប្បីសម្លាប់ក្តី សេចក្តីថា គប្បីសម្លាប់ ដោយដៃក្តី ដោយជើងក្តី ដោយរំពាត់ខ្សែតីក្តី ដោយផ្តៅក្តី ដោយដំបងវែងក្តី ដោយកាប់កាត់ក្តី ។ ត្រង់ពាក្យថា គប្បីចងក្តី សេចក្តីថា គប្បីចងដោយ ចំណង គឺខ្សែក្តី ដោយចំណង គឺខ្នោះក្តី ដោយចំណង គឺច្រវាក់ក្តី ដោយ បង្ខាំងទុកក្នុងផ្ទះក្តី ដោយបង្ខាំងទុកក្នុងក្រុងក្តី ដោយបង្ខាំងទុកក្នុងស្រុកក្តី ដោយ បង្ខាំងទុកក្នុងនិគមក្តី ឬគប្បីធ្វើនូវការឃុំឃាំងដោយបុរស ។ ត្រង់ពាក្យថា គប្បី បំបរបង់ក្តី ឬថាគប្បីនិរទេសក្តី សេចក្តីថា គប្បីបំបរបង់ចាកស្រុកក្តី ចាកនិគម ក្តី ចាកក្រុងក្តី ចាកជនបទក្តី ចាកប្រទេសក្នុងជនបទក្តី ។ ត្រង់ពាក្យ ៤ ម៉ាត់ ថា អ្នកឯងជាចោរ អ្នកឯងជាពាល អ្នកឯងជាបុគ្គលវង្វេង អ្នកឯងជាអ្នក លួចនេះ ជាពាក្យជេរប្រទេច ។

[ ៨៨ ] ដែលឈ្មោះថា មានសភាពដូច្នោះ ( នោះ ) គឺទ្រព្យចំនួន ១ បាទ ឬទ្រព្យគួរដល់តម្លៃ ១ បាទ ឬថា ក្រៃលែងជាង ១ បាទឡើងទៅ ។ ត្រង់ពាក្យថា កាលកាន់យក សេចក្តីថា កាលចាប់យក កាលនាំទៅ កាល លួច កាលឲ្យកម្រើកឥរិយាបថ កាលឲ្យឃ្លាតចាកទី កាលឲ្យកន្លងហួសទី ដែលកំណត់ ។

[ ៨៩ ] ត្រង់បទថា ភិក្ខុនេះដែរ គឺពោលប្រៀបធៀបនឹងភិក្ខុដែលមានក្នុងសិក្ខាបទមុន ។ ត្រង់ពាក្យថា ជាបារាជិក អធិប្បាយជាសេចក្តីឧបមាថា ជម្មតាស្លឹកឈើទុំដែលជ្រុះចាកទងហើយ មិនអាចត្រឡប់ទៅជាមានពណ៌ខៀវវិញបាន ដូចម្តេចមិញ ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យចំនួន ១ បាទ ឬគួរដល់តម្លៃ ១ បាទ ឬថា ក្រៃលែងជាង ១ បាទឡើងទៅ ដោយចំណែកនៃចិត្តលួច ក៏មិនមែនជាសមណៈ មិនមែនជាពូជវង្សរបស់ព្រះពុទ្ធជាសក្យបុត្រដូច្នោះដែរ ព្រោះហេតុនោះ បានជាព្រះតថាគតហៅ ភិក្ខុនោះ ជាបារាជិក ។ ត្រង់បទថា រកសំវាសគ្មាន ( នោះ ) សេចក្តីថា សង្ឃកម្មជាមួយគ្នា ឧទ្ទេសជា-មួយគ្នា ការសិក្សាស្មើគ្នា នេះឈ្មោះថា សំវាស សំវាសនោះមិនមានជាមួយនឹងភិក្ខុដែលត្រូវអាបត្តិបារាជិកនោះឡើយ ព្រោះហេតុនោះ បានជាព្រះតថាគតហៅថា រកសំវាសគ្មាន ។

[ ៩០ ] ( មាតិកាពាយឈ្មោះទ្រព្យ ) ទ្រព្យដែលស្ថិតនៅក្នុងដី ស្ថិតនៅលើគោក ស្ថិតនៅឰដ៏អាកាស ស្ថិតនៅលើធ្នើរ ស្ថិតនៅក្នុងទឹក ស្ថិតនៅក្នុងទូក ស្ថិតនៅលើយាន ស្ថិតនៅលើភារៈ ស្ថិតនៅក្នុងច្បារ ស្ថិតនៅក្នុងវត្ត ស្ថិតនៅក្នុងស្រែ ស្ថិតនៅក្នុងទីដី ស្ថិតនៅក្នុងស្រុក ស្ថិតនៅក្នុងព្រៃ ទឹក ឈើស្ងួន ដើមឈើ របស់ដែលគេកំពុងនាំទៅ របស់ដែលគេផ្ញើ ទីដែលហូតពន្ធ ( គយ ) សត្វមានជីវិត គឺមនុស្ស សត្វគ្មានជើង សត្វជើងពីរ សត្វជើង ៤ សត្វជើងច្រើន អ្នកកំណត់របស់ដើម្បីឲ្យគេលួច អ្នករក្សារបស់ផ្ញើទុកមួយរំពេច កិរិយាលួចយកដោយបបួលគ្នា សង្កេតកម្ម និមិត្តកម្ម ។

[ ៩១ ] ដែលឈ្មោះថា ទ្រព្យស្ថិតនៅក្នុងដី ( នោះ ) គឺទ្រព្យដែលគេកប់លាក់ទុកក្នុងដី ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចនូវទ្រព្យដែលស្ថិតនៅក្នុងដី ហើយស្វែងរកគ្នាឲ្យបានពីរនាក់ក្តី ស្វែងរកចបក្តី កញ្ជើក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាត់នូវឈើ ឬវល្លិដែលកើតក្នុងទីនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុជីក ឬកកាយ ឬគាស់នូវអាចម៍ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុចាប់ពាល់នូវឆ្នាំង ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើកត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តបញ្ចូលនូវភាជនៈរបស់ខ្លួនទៅ ហើយចាប់ពាល់នូវវត្ថុមានតម្លៃប្រមាណ ៥ មាសក ឬក្រៃលែងជាង ៥ មាសកឡើងទៅ ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើកត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យឲ្យចូលទៅក្នុងភាជនៈរបស់ខ្លួនក្តី កាត់ដាច់នូវក្តាប់ដៃក្តី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវភណ្ឌៈដែលគេដោតក្រងដោយខ្សែគឺសង្វារក្តី ខ្សែកក្តី ខ្សែចង្កេះក្តី សំពត់សាដកក្តី ឈ្នួតក្តី ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើកត្រូវអាបត្តិថុល្លច្ច័យ ។ ចាប់ត្រង់ទីបំផុត ហើយលើកឡើង ត្រូវអាបត្តិថុល្លច្ច័យ ។ កាលបើប៉ះទង្គុករួចនាំយកចេញ ត្រូវអាបត្តិថុល្លច្ច័យ ។ ដោយហោចទៅសូម្បីតែឲ្យផុតអំពីមាត់ឆ្នាំង ប្រមាណប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តផឹកនូវសប្បិក្តី ប្រេងក្តី ទឹកឃ្មុំក្តី ទឹកអំពៅក្តី ជារបស់មានតម្លៃប្រមាណ ៥ មាសក ឬក្រៃលែងជាង ៥ មាសកឡើងទៅ ដោយប្រយោគតែមួយ ត្រូវអាបត្តិបារាជិក ។ ភិក្ខុទម្លាយក្តី ចាក់ចោលក្តី ដុតចោលក្តី ធ្វើ ( នូវវត្ថុមានសប្បិជាដើមនោះ ) ឲ្យជារបស់ប្រើប្រាស់មិនកើតក្តី ក្នុងទីនោះ

ឯង ត្រូវអាបត្តិទុក្កដ ។

[ ៩២ ] ដែលឈ្មោះថា ទ្រព្យស្ថិតនៅលើគោក ( នោះ ) គឺទ្រព្យដែលគេតម្កល់ទុកលើទីគោក ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចទ្រព្យដែលស្ថិតនៅលើទីគោក ហើយស្វែងរកគ្នាឲ្យបានពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ឲ្យកម្រើកត្រូវអាបត្តិថុល្លច្ច័យ ឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

[ ៩៣ ] ដែលឈ្មោះថា ទ្រព្យស្ថិតនៅឰដ៏អាកាស ( នោះ ) គឺកណ្ឌៈដែលទៅឰដ៏អាកាស ទោះសត្វក្ងោកក្តី ចចាតក្តី ទទាក្តី ចាបក្តី ឬជាសំពត់សាដកក្តី ឈ្នួតក្តី ប្រាក់ក្តី មាសក្តី ដែលដាច់ធ្លាក់ចុះ ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចនូវកណ្ឌៈដែលស្ថិតនៅឰដ៏អាកាស ហើយស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ។ ផ្តាច់បង់នូវដំណើរ ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

[ ៩៤ ] ដែលឈ្មោះថា ទ្រព្យស្ថិតនៅលើផ្ទៃរ ( នោះ ) គឺកណ្ឌៈដែលតម្កល់នៅលើផ្ទៃរ ( អធិប្បាយថា ) ទ្រព្យដែលគេតម្កល់ទុកលើគ្រែក្តី លើតាំងក្តី ឬទ្រព្យដែលគេពាក់លើឈើស្នៀងសម្រាប់ពាក់ចីវរក្តី លើខ្សែសម្រាប់ពាក់ចីវរក្តី លើចម្រឹងជញ្ជាំងក្តី លើដៃកែវក្តី ដែលគេព្យួរទុកលើដើមឈើក្តីដោយហោចទៅទ្រព្យដែលគេតម្កល់ទុកលើជើងបាត្រក៏ដោយ ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចកណ្ឌៈដែលស្ថិតនៅលើផ្ទៃរ ហើយស្វែងរកគ្នាឲ្យ

បានជាពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

[ ៩៥ ] ដែលឈ្មោះថា ទ្រព្យស្ថិតនៅក្នុងទឹក ( នោះ ) គឺកណ្ឌៈដែលគេតម្កល់ទុកក្នុងទឹក ។ ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចកណ្ឌៈដែលស្ថិតនៅក្នុងទឹក ហើយស្វែងរកគ្នាឲ្យបានជាពីរនាក់ក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ ។ មុជចុះក្តី ងើបឡើងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ផ្កាឧប្បលក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូក-សក្តី ក្រអៅឈូកក្តី ត្រីក្តី អណ្តើកក្តី ដែលកើតក្នុងទឹកនោះ មានតម្លៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

[ ៩៦ ] គេច្លង ( នូវទីមានទឹកមានស្ទឹងនិងទន្លេជាដើម ) ដោយរបស់អ្វី របស់នោះឈ្មោះថា ទូក ។ ទ្រព្យដែលគេដាក់ទុកនៅក្នុងទូក ឬលើទូក ឈ្មោះថា ទ្រព្យស្ថិតនៅក្នុងទូក ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចយកទ្រព្យដែលស្ថិតនៅក្នុងទូក ហើយស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ចាប់ពាល់ ( ទ្រព្យនោះ ) ត្រូវអាបត្តិទុក្កដ ។ ( ធ្វើទ្រព្យនោះ ) ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ( ធ្វើទ្រព្យនោះ ) ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចយកទូក ហើយ

ស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ ( ទូកនោះ ) ត្រូវអាបត្តិទុក្កដ ។ ធ្វើទូកនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ស្រាយចំណង ត្រូវអាបត្តិទុក្កដ ។ ស្រាយចំណងរួចហើយ ចាប់ត្រូវ (ទូក) ត្រូវអាបត្តិទុក្កដ ។ ( ធ្វើទូក ) ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។( ធ្វើទូក ) ឲ្យអណ្តែតច្រាសទឹកក្តី បណ្តោយទឹកក្តី ទទឹងទឹកក្តី ដោយហោចទៅ សូម្បីធ្វើឲ្យឃ្លាតចាកទី ប៉ុនចម្រៀកសក់ ត្រូវអាបត្តិបារាជិក ។

[ ៩៧ ] អង្រឹងស្នែង រថ រទេះ រថទ្រទ្រង់គ្រឿង ឈ្មោះថា យាន ។ ទ្រព្យដែលដាក់ក្នុងយានឬលើយាន ឈ្មោះថា ទ្រព្យស្ថិតនៅលើយាន ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលស្ថិតនៅលើយាន ហើយស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចយកយាន ហើយស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់យាននោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើយាននោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើយាននោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

[ ៩៨ ] ទ្រព្យដែលនៅលើក្បាល ( ទូល ) នៅលើ-ក ( ទ្រព្យដែលរែក ឬលី ) នៅលើចង្កេះ ( កណ្តៀត ) និងទ្រព្យដែលយួរនឹងដៃ ឈ្មោះថាភារៈ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ភារៈដែលនៅលើក្បាល ត្រូវ

អាបត្តិទុក្កដ ។ ធ្វើភារៈនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ភារៈនោះចុះមកដល់ត្រឹម-ក ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ភារៈដែលនៅលើ-ក ត្រូវអាបត្តិទុក្កដ ។ ធ្វើភារៈនោះកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ចុះមកដល់ត្រឹមចង្កេះ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ភារៈដែលនៅលើចង្កេះ ត្រូវអាបត្តិទុក្កដ ។ ធ្វើភារៈនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ចុះមកកាន់ជាប់នឹងដៃ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យ-ចិត្តដាក់ចុះនូវភារៈដែលនៅក្នុងដៃមកលើផែនដី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តកាន់យកទ្រព្យអំពីផែនដីទៅ ត្រូវអាបត្តិបារាជិក ។

[ ៩៩ ] សួនផ្កាឈើ ចំការផ្លែឈើ ឈ្មោះថា អារាម ( សួនច្បារ ) ទ្រព្យដែលបុគ្គលតម្កល់ទុកក្នុងសួនច្បារ មាន ៤ កន្លែង គឺក្នុងដី ១ លើគោក ១ ឯអាកាស ១ លើធ្នើរ ១ ឈ្មោះថា ទ្រព្យស្ថិតនៅក្នុងសួនច្បារ ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យនៅក្នុងសួនច្បារ ហើយស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ឫសឈើក្តី សម្បកឈើក្តី ស្លឹកឈើក្តី ផ្កាឈើក្តី ផ្លែឈើក្តី ដែលដុះក្នុងសួនច្បារនោះ ទោះមានតម្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកទៅក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុចោទប្រកាន់យកសួនច្បារ ត្រូវ

អាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់សួនច្បារសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់សួនច្បារដាក់ធុរៈថា សួនច្បារមុខជានឹងមិនបានមកអញវិញទេ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ ( គឺកាលដែលជំនុំជម្រះក្នុងជំនុំសង្ឃ ឬក្នុងរាជត្រកូល ហើយសូកពួកអ្នកវិនិច្ឆ័យឲ្យយកសាក្សីកោង ធ្វើម្ចាស់សួនច្បារឲ្យចាញ់ ) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ ( គឺបើពួកអ្នកវិនិច្ឆ័យ កាត់សេចក្តីនោះតាមធម៌វិន័យជាសត្ថុសាសនា ហើយត្រឡប់ចាញ់លើខ្លួនឯងវិញ ) ត្រូវអាបត្តិថុល្លច្ច័យ ។

[ ១០០ ] ទ្រព្យដែលបុគ្គលតម្កល់ទុកក្នុងវិហារ ( វត្ត ) មាន ៤ កន្លែង គឺក្នុងដី ១ លើគោក ១ ឯអាកាស ១ លើធ្នើរ ១ ឈ្មោះថា ទ្រព្យនៅក្នុងវត្ត ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលស្ថិតនៅក្នុងវត្ត ហើយស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុចោទប្រកាន់យកវត្ត ត្រូវអាបត្តិទុក្កដ ។ ធ្វើម្ចាស់វត្តឲ្យកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់វត្តដាក់ធុរៈថា វត្តមុខជាមិនបានមកអញវិញទេ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ ( គឺកាលដែលជំនុំជម្រះក្នុងជំនុំសង្ឃ ឬរាជត្រកូល ភិក្ខុបានសូកដល់ពួកអ្នកវិនិច្ឆ័យឲ្យកាត់សេចក្តីដោយមិនយុត្តិធម៌ ) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់វិញ ( គឺពួកអ្នកវិនិច្ឆ័យកាត់ក្តីដោយយុត្តិធម៌ថា ឲ្យភិក្ខុចាញ់វិញ ) ត្រូវអាបត្តិ

ថុល្លច្ច័យ ។

[ ១០១ ] ស្រូវទាំងឡាយ ៧ យ៉ាង មានស្រូវសាលីជាដើមក្តី ផ្លែឈើទាំងឡាយ មានសណ្តែករាជមាសជាដើមក្តី ដុះក្នុងទីណា ទីនោះឈ្មោះថា ខេត្ត ( ស្រែ ) ។ ទ្រព្យដែលបុគ្គលតម្កល់ទុកក្នុងស្រែមាន ៤ កន្លែង គឺក្នុងដី ១ លើគោក ១ ឯអាកាស ១ លើផ្ទៃ ១ ឈ្មោះថា ទ្រព្យនៅក្នុងស្រែ ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យនៅក្នុងស្រែដូច្នេះ ហើយស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក។ ភិក្ខុមានថេយ្យ-ចិត្តចាប់ពាល់ស្រូវទាំងឡាយ មានស្រូវសាលីជាដើមក្តី ផ្លែឈើទាំងឡាយ មានសណ្តែករាជមាសជាដើមក្តី ដែលដុះក្នុងស្រែនោះ មានតម្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកទៅក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុបោះប្រកាន់យកស្រែ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់ស្រែកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់ស្រែដាក់ធុរៈថា ស្រែមុខជានឹងមិនបានមកអញវិញទេ ដូច្នេះ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ ( គឺកាលដែលជំនុំជម្រះក្នុងជំនុំសង្ឃ ឬក្នុងរាជត្រកូលហើយសូកពួកអ្នកវិនិច្ឆ័យឲ្យយកសាក្សីកោង ធ្វើម្ចាស់ស្រែឲ្យចាញ់ ) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ ( គឺបើពួកអ្នកវិនិច្ឆ័យកាត់ក្តី

នោះតាមធម៌ជាសត្ថុសាសនា ហើយត្រឡប់ជាចាញ់លើខ្លួនឯងវិញ ) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុបង្ខិតគោលក្តី ខ្សែក្តី របងក្តី ទំនប់ក្តី ត្រូវអាបត្តិទុក្កដ ។ នៅតែប្រយោគមួយមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ ។ លុះប្រយោគមួយនោះមកដល់ ត្រូវអាបត្តិបារាជិក ។

[ ១០២ ] ទីសួនច្បារ និងទីវត្តឈ្មោះថា វត្ថុ ( ទីដី ) ។ ទ្រព្យដែលគេតម្កល់ទុកក្នុងទីដី មាន ៤ កន្លែង គឺក្នុងដី ១ លើគោក ១ ឯអាកាស ១ លើផ្ទៃ ១ ឈ្មោះថា ទ្រព្យស្ថិតនៅក្នុងទីដី ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលគេតម្កល់ទុកក្នុងទីដី ហើយស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុចោទប្រកាន់យកទីដី ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់ដីកើតសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ បើម្ចាស់ដីដាក់ធុរៈថា ដីមុខជាមិនបានមកអញវិញទេ ដូច្នេះ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យឲ្យម្ចាស់របស់ចាញ់ ( គឺ កាលដែលជំនុំជម្រះក្នុងជំនុំសង្ឃ ឬក្នុងរាជត្រកូល ហើយសូកពួកអ្នកវិនិច្ឆ័យឲ្យយកសាក្សីកោង ធ្វើម្ចាស់ដីឲ្យចាញ់ ) ត្រូវអាបត្តិបារាជិក ។ ភិក្ខុធ្វើការវិនិច្ឆ័យចាញ់ម្ចាស់របស់ ( គឺបើពួកអ្នកវិនិច្ឆ័យនោះកាត់តាមធម៌វិន័យជាសត្ថុសាសនា ហើយត្រឡប់ជាចាញ់ខ្លួនឯងវិញ ) ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុបង្ខិតគោលក្តី ខ្សែក្តី របងក្តី កំពែងក្តី ត្រូវអាបត្តិទុក្កដ ។ នៅតែប្រយោគមួយមិនទាន់មកដល់ ត្រូវអាបត្តិថុល្លច្ច័យ ។

លុះប្រយោគមួយនោះមកដល់ ត្រូវអាបត្តិបារាជិក ។

[ ១០៣ ] ទ្រព្យដែលគេតម្កល់ទុកក្នុងស្រុកមាន ៤ កន្លែង គឺក្នុងដី ១ លើគោក ១ ឯអាកាស ១ លើធ្នើរ ១ ឈ្មោះថា ទ្រព្យស្ថិតនៅក្នុងស្រុក ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលស្ថិតនៅក្នុងស្រុក ដូច្នេះហើយ ស្វែងរកគ្នាឲ្យបានជាគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។

[ ១០៤ ] ដែលហៅថា ព្រៃ គឺទីណាដែលពួកមនុស្សហួងហែងរក្សា ទីនោះឈ្មោះ ព្រៃ ។ ទ្រព្យដែលបុគ្គលតម្កល់ទុកក្នុងព្រៃមាន ៤ កន្លែង គឺ ក្នុងដី ១ លើគោក ១ ឯអាកាស ១ លើធ្នើរ ១ ឈ្មោះថា ទ្រព្យស្ថិតនៅក្នុង ព្រៃ ។ ភិក្ខុមានថេយ្យចិត្តគិតថា អញនឹងលួចទ្រព្យដែលស្ថិតនៅក្នុងព្រៃ ដូច្នេះ ហើយស្វែងរកគ្នាឲ្យបានគម្រប់ពីរនាក់ក្តី ដើរទៅម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ ។ ចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិ ថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមាន ថេយ្យចិត្ត ហើយចាប់ពាល់ឈើក្តី វល្លិ៍ក្តី ស្មៅក្តី កើតក្នុងព្រៃនោះ មានតម្លៃ ប្រមាណ ៥ មាសកក្តី ដែលលើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើ របស់នោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើរបស់នោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។

[ ១០៥ ] ទឹកដែលមាននៅក្នុងភាជនៈក្តី ក្នុងស្រះក្តី ក្នុងបឹងក្តី ឈ្មោះ

ជាទឹក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ទឹកនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទឹកនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទឹកនោះឲ្យហូរឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ទឹកដែលមានតម្លៃប្រមាណ ៥ មាសកក្តី ថ្លៃលើសពី ៥ មាសកក្តី ឲ្យចូលទៅក្នុងភាជនៈរបស់ខ្លួន ត្រូវអាបត្តិទុក្កដ ។ ធ្វើទឹកនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទឹកនោះឲ្យបានតម្កល់ក្នុងភាជនៈរបស់ខ្លួន ត្រូវអាបត្តិបារាជិក ។ ភិក្ខុទម្លុះភ្លឺស្រែគេ ត្រូវអាបត្តិទុក្កដ ។ ទម្លុះភ្លឺស្រែហើយបង្ហូរយកទឹកមានតម្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិបារាជិក ។ ភិក្ខុបង្ហូរយកទឹកមានតម្លៃលើសពី ១ មាសកក្តី ថយពី ៥ មាសកចុះមកក្តី ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុបង្ហូរយកទឹកមានតម្លៃ ១ មាសកក្តី ថយចុះពី ១ មាសកមកក្តី ត្រូវអាបត្តិទុក្កដ ។

[ ១០៦ ] ( ឈើសម្រាប់ជម្រះធ្មេញ ) ទោះគេកាត់ហើយក្តី គេមិនបានកាត់ក្តី ហៅថា ឈើស្ងួន ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ឈើស្ងួនដែលមានតម្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។

[ ១០៧ ] ឈើណាជាគ្រឿងប្រើប្រាស់ ដែលមានពួកមនុស្សថែរក្សាទុក ឈើនោះឈ្មោះថា ដើមឈើ ។ ភិក្ខុមានថេយ្យចិត្តកាត់ឈើនោះ ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រហារ ។ នៅប្រហារម្តងទៀតមិនទាន់មកដល់ ( គឺថា

នៅតែប្រហារម្តងទៀតនឹងដាច់ ) ត្រូវអាបត្តិថុល្លច្ច័យ ។ លុះប្រហារម្តងទៀតមកដល់ ( គឺថា បានកាត់ដាច់ហើយ ) ត្រូវអាបត្តិបារាជិក ។

[ ១០៨ ] ទ្រព្យដែលបុគ្គលដទៃកំពុងនាំទៅ ឈ្មោះថា ទ្រព្យដែលគេកំពុងនាំទៅ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើទ្រព្យនោះឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថា អញនឹងលួចយកទ្រព្យ ព្រមទាំងអ្នកនាំទ្រព្យ ហើយឲ្យមនុស្សនោះដើរទៅ ១ ជំហានដំបូង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យមនុស្សនោះដើរទៅបាន ២ ជំហាន ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យ-ចិត្តគិតថា អញនឹងយករបស់ដែលជ្រុះចុះ ហើយធ្វើរបស់គេឲ្យជ្រុះ ឬឲ្យធ្លាក់ចុះត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់របស់ដែលជ្រុះនោះ មានតម្លៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ធ្វើឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។

[ ១០៩ ] ទ្រព្យដែលគេផ្ញើទុក ឈ្មោះថា បញ្ញើ ។ ម្ចាស់បញ្ញើនិយាយថា លោកចូរឲ្យទ្រព្យមកខ្ញុំ ភិក្ខុពោលថា អាត្មាមិនបានទទួលទុកទេ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យម្ចាស់របស់គេកើតសេចក្តីសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្ចាស់របស់ដាក់ធុរៈថា ( ភិក្ខុនេះ ) នឹងមិនឲ្យអញវិញទេ ( ភិក្ខុនោះ ) ត្រូវអាបត្តិបារាជិក ។ ភិក្ខុពឹងក្រមវិនិច្ឆ័យឲ្យសម្រេចសេចក្តីឲ្យម្ចាស់បញ្ញើចាញ់ ត្រូវអាបត្តិបារាជិក ។ កាលក្រមវិនិច្ឆ័យសម្រេចសេចក្តីដោយធម៌ ភិក្ខុត្រឡប់ចាញ់វិញ ត្រូវអាបត្តិថុល្លច្ច័យ ។

[ ១១០ ] ទីសម្រាប់ហូតពន្ធដែលព្រះបរមក្សត្រទ្រង់បញ្ញត្តថា ជនណានាំរបស់ចូលទៅក្នុងទីនោះៗ គឺក្នុងទីក្នុំខណ្ឌក្តី ក្នុងទីកំពង់ទឹកក្តី ក្នុងទីទៀបទ្វារស្រុកក្តី ពួករាជបុរសត្រូវយកពន្ធពីជននោះ ឈ្មោះថា គយ ។ ភិក្ខុចូលទៅក្នុងខេត្តគយនោះហើយ មានថេយ្យចិត្ត ចាប់ពាល់នូវទ្រព្យដ៏គួរដល់ព្រះរាជានឹងយកពន្ធ មានតម្លៃប្រមាណ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុញុាំងរបស់នោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុឈានជំហានទី ១ ឲ្យកន្លងខេត្តគយទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុឈានជំហានទី ២ ឲ្យកន្លងខេត្តគយទៅ ត្រូវអាបត្តិបារាជិក ។ ភិក្ខុស្ថិតនៅខាងក្នុងខេត្តរបស់គយ ហើយបោះផ្តោងរបស់ឲ្យធ្លាក់ចុះទៅខាងក្រៅខេត្តរបស់គយ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំទ្រព្យរត់ពន្ធ ( ដោយវាងខេត្តគយ ) ត្រូវអាបត្តិទុក្កដ ។

[ ១១១ ] សត្វ គឺមនុស្ស ហៅថា សត្វមានជីវិត ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់មនុស្សនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតចាកទីទៅ ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថា អញនឹងនាំមនុស្សដើរទៅដោយជើង ហើយឲ្យឈានជំហានទី ១ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ២ ទៅ ត្រូវអាបត្តិបារាជិក ។

[ ១១២ ] ពស់ ត្រី ហៅថា សត្វគ្មានជើង ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវសត្វគ្មានជើង មានតម្លៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក ។

[ ១១៣ ] មនុស្ស សត្វស្វាប ហៅថា សត្វមានជើងពីរ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវសត្វជើងពីរនោះ ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថាអញនឹងនាំបណ្ដើរសត្វជើង ២ ទៅដោយជើង ហើយឲ្យឈានជំហានទី ១ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ២ ត្រូវអាបត្តិបារាជិក ។

[ ១១៤ ] ដំរី សេះ អូដ្ឋ គោ លា ជាពួកសត្វចិញ្ចឹមហៅថាសត្វមានជើង ៤ ។ ភិក្ខុមានថេយ្យចិត្ត ចាប់ពាល់សត្វជើង ៤ នោះ ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតចាកទី ត្រូវបារាជិក ។ ភិក្ខុគិតថាអញនឹងនាំបណ្ដើរនូវសត្វជើង ៤ ទៅដោយជើង ហើយឲ្យឈានជំហានទី ១ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ២ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ៣ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឈានជំហានទី ៤ ទៅ ត្រូវអាបត្តិបារាជិក ។

[ ១១៥ ] ខ្ទួយ ក្អែប ជន្លេនមាស ហៅថា ពួកសត្វមានជើងច្រើន ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់សត្វមានជើងច្រើននោះ មានតម្លៃ ៥ មាសកក្ដី ហួសពី ៥ មាសកក្ដី ត្រូវអាបត្តិទុក្កដ ។ ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតចាកទី ត្រូវអាបត្តិបារាជិក ។ ភិក្ខុគិតថាអញនឹងនាំបណ្ដើរសត្វមានជើងច្រើនទៅដោយជើង ហើយញុំាងសត្វមានជើងច្រើនឲ្យឈានទៅ ត្រូវអាបត្តិថុល្លច្ច័យ គ្រប់ជំហាន ។ ញុំាងជើងទីបំផុតរបស់សត្វនោះឲ្យឈានទៅ ត្រូវអាបត្តិបារាជិក ។

[ ១១៦ ] ភិក្ខុគយគន់ទ្រព្យដែលគេទុកដាក់ធ្វេសប្រហែស ហើយប្រាប់ ( ភិក្ខុដទៃ ) ថា លោកចូរលួចទ្រព្យឈ្មោះនេះមក ( ភិក្ខុនោះ ) ហៅថា អ្នកកំណត់របស់ឲ្យគេលួច ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុអ្នកទទួលបង្គាប់នោះលួចយកទ្រព្យបានមក ត្រូវអាបត្តិបារាជិកទាំងពីររូប ។

[ ១១៧ ] ភិក្ខុអ្នកថែទាំរក្សាទ្រព្យ ដែលគេនាំមកផ្ញើទុកមួយដំណើរ ហៅថា អ្នករក្សាបញ្ញើ ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់នូវទ្រព្យមានតម្លៃ ៥ មាសកក្តី លើសពី ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យផុតឋានទី ត្រូវអាបត្តិបារាជិក ។

[ ១១៨ ] ដែលហៅថា កិរិយាលួចយកដោយបបួលគ្នា ( នោះ ) គឺភិក្ខុដែលរួមគំនិតចូលគ្នាច្រើនរូប ភិក្ខុ ១ រូបទៅលួចយកទ្រព្យបានមក ត្រូវអាបត្តិបារាជិកទាំងអស់គ្នា ។

[ ១១៩ ] ភិក្ខុធ្វើសញ្ញាកំណត់ពេលឲ្យលួច ហៅថា សង្កេតកម្ម ភិក្ខុប្រើភិក្ខុឲ្យទៅលួចថា អ្នកចូរលួចយកទ្រព្យនោះដោយសង្កេតនោះ ក្នុងពេលព្រឹកក្តី ល្ងាចក្តី យប់ក្តី ថ្ងៃក្តី ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលួចទ្រព្យនោះបានមកតាមសង្កេតនោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុទៅលួចទ្រព្យនោះមុនសង្កេតនោះក្តី ក្រោយក្តី ភិក្ខុអ្នកប្រើដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិ បារាជិកតែភិក្ខុអ្នកលួច ។

[ ១២០ ] ភិក្ខុធ្វើនិមិត្តគ្រឿងសម្គាល់ឲ្យលួច ហៅថា និមិត្តកម្ម គឺភិក្ខុបង្គាប់ភិក្ខុផងគ្នាថា ខ្ញុំនឹងប៉ប្រិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី អ្នកចូរ

លួចយកទ្រព្យនោះមកតាមនិមិត្តនោះ ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ លួចទ្រព្យនោះបានមកតាមនិមិត្តនោះ ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុអ្នកទទួលបង្គាប់ទៅលួចទ្រព្យនោះបានមកមុននិមិត្តនោះក្តី ក្រោយក្តី ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។

[ ១២១ ] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះសម្គាល់ទ្រព្យនោះបានហើយ ទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះសម្គាល់ទ្រព្យនោះបានហើយ ទៅលួចទ្រព្យដទៃបានមកវិញ ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះត្រឡប់សម្គាល់ទ្រព្យដទៃវិញ តែទៅលួចទ្រព្យបានមក ត្រូវពានលើទ្រព្យដែលភិក្ខុប្រើនោះ ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកចូរលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះ សម្គាល់នូវទ្រព្យដទៃទៅលួចបានទ្រព្យដទៃមកវិញ ភិក្ខុអ្នកបង្គាប់ដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅប្រាប់តដល់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះឯងទៅប្រាប់

តដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះ ចូរទៅលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើដើមត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ទី ១ នោះ ទៅប្រាប់ភិក្ខុអ្នកទទួលបង្គាប់ទី ២ ភិក្ខុអ្នកទទួលបង្គាប់ទី ១ នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រាប់ ។ ( ភិក្ខុអ្នកទទួលបង្គាប់ទី ២ ទៅប្រាប់ដល់អ្នកទទួលបង្គាប់ទី ៣ ) ភិក្ខុអ្នកទទួលបង្គាប់ទី ៣ ព្រមទទួលនឹងទៅលួច ភិក្ខុអ្នកបង្គាប់ដំបូង ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុអ្នកទទួលបង្គាប់ទី ៣ នោះទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងអស់គ្នា ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅប្រាប់តដល់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះឯងទៅប្រាប់តដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះ ចូរទៅលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើដើមត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ទី ១ នោះទៅប្រើភិក្ខុដទៃ ( គឺអ្នកទទួលបង្គាប់ទី ៣ វិញ ) ខ្ទនអ្នកទទួលបម្រើទី ១ នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រើ-ត ។ អ្នកទទួលបង្គាប់ទី ៣ ទទួលនឹងទៅលួច អ្នកទទួលបង្គាប់ទី ៣ នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈទទួល ។ អ្នកទទួលបង្គាប់ទី ៣ នោះទៅលួចទ្រព្យនោះបានមក អ្នកប្រើដើមមិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកទទួលបង្គាប់ទី ១ និងភិក្ខុអ្នកលួចទី ៣ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅលួចទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដក្នុងខណៈប្រើ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅហើយត្រឡប់មកវិញប្រាប់ថា ខ្ញុំមិនអាចនឹងទៅលួចយកទ្រព្យនោះមកទេ ។ ភិក្ខុអ្នកបង្គាប់ប្រើម្តងទៀតថា លោកអាចលួចយកបានក្នុងពេលណា ចូរលួចទ្រព្យនោះក្នុងពេលនោះចុះ ភិក្ខុអ្នកបង្គាប់នោះត្រូវអាបត្តិ

ទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់លួចយកទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកបង្គាប់នោះ លុះដល់បង្គាប់ភិក្ខុនោះហើយ មានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយវិញ តែមិនទាន់បានប្រាប់ភិក្ខុនោះថា អ្នកកុំលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់នោះទៅលួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរនាក់ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកបង្គាប់នោះ ត្រូវអាបត្តិទុក្កដក្នុងខណៈបង្គាប់ ។ ភិក្ខុអ្នកបង្គាប់នោះ លុះដល់បង្គាប់ភិក្ខុនោះហើយ មានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយវិញ ត្រឡប់ហាមឃាត់ថា លោកកុំលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់នោះមិនព្រមត្រឡប់ខានលួចតាម ពោលតបថា លោកបង្គាប់ខ្ញុំហើយ រួចទៅលួចយកទ្រព្យនោះបានមក ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកលួច ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរលួចយកទ្រព្យឈ្មោះនេះមក ភិក្ខុអ្នកបង្គាប់នោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកបង្គាប់នោះ លុះដល់បង្គាប់ភិក្ខុនោះហើយ មានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយវិញ ត្រឡប់ឃាត់ថា លោកកុំទៅលួចឡើយ ភិក្ខុអ្នកទទួលបង្គាប់ទទួលពាក្យថា ប្រពៃហើយ ក៏លែងទៅលួច ភិក្ខុទាំងពីររូបមិនត្រូវអាបត្តិឡើយ ។

[ ១២២ ] ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិបារាជិក គឺទ្រព្យដែលអ្នកដទៃហួងហែងរក្សា ១ សម្គាល់ថាទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានតម្លៃច្រើនចំនួន ៥ មាសក ឬ

លើសពី ៥ មាសក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិបារាជិក ។ ( បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ញុំាងរបស់នោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិថុល្លច្ច័យ គឺទ្រព្យដែលអ្នកដទៃហួងហែងរក្សា ១ សម្គាល់ថា ទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានតម្លៃតិចប្រមាណលើសពី ១ មាសក ឬថយពី ៥ មាសកចុះមក ១ មានថេយ្យចិត្តកើតឡើងប្រាកដ ១ ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិថុល្លច្ច័យ ។ ( បើមិនទាន់ញុំាងរបស់នោះឲ្យឃ្លាតចាកទីទេ ) ភិក្ខុចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ ញុំាងរបស់នោះឲ្យកម្រើក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេ មិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃហួងហែងរក្សា ១ សម្គាល់ថា ទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានតម្លៃតិចប្រមាណ ១ មាសក ឬថយពី ១ មាសក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ ១ ញុំាងរបស់នោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិទុក្កដ ។ ( សូម្បីមិនទាន់ឲ្យឃ្លាតចាកទី ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើកក៏ត្រូវអាបត្តិទុក្កដ ។

[ ១២៣ ] ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេ មិនបានឲ្យដោយអាការ ៦ យ៉ាង ត្រូវអាបត្តិបារាជិក គឺមិនបានសម្គាល់ថា ជារបស់ខ្លួន ១ មិនបានកាន់យកដោយវិស្សាសៈ ១ មិនបានកាន់យកជារបស់ខ្ចី ១ បរិក្ខារមានតម្លៃច្រើនប្រមាណ ៥ មាសក ឬលើសពី ៥ មាសក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ

១ ញុាំងរបស់នោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិបារាជិក ។ ( បើមិនទាន់ញុាំងរបស់នោះឲ្យឃ្លាតផុតចាកទីទេ ) ភិក្ខុចាប់ពាល់ត្រូវអាបត្តិទុក្កដ ។ ញុាំងរបស់នោះឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយអាការ ៦ យ៉ាង ត្រូវអាបត្តិថុល្លច្ច័យ ។ គឺមិនបានសម្គាល់ថាជារបស់ខ្លួន ១ មិនបានកាន់យកដោយស្និទ្ធស្នាល ១ មិនបានកាន់យកជារបស់ខ្ចី ១ បរិក្ខារមានតម្លៃតិចប្រមាណលើសពី ១ មាសក ឬថយពី ៥ មាសកមក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ ១ ញុាំងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិថុល្លច្ច័យ ។ ( បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ ) ភិក្ខុចាប់ពាល់ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកម្រើក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់ មិនបានឲ្យដោយអាការ ៦ យ៉ាង ត្រូវអាបត្តិទុក្កដ ។ គឺមិនបានសម្គាល់ថាជារបស់ខ្លួន ១ មិនបានកាន់យកដោយស្និទ្ធស្នាល ១ មិនបានកាន់យកជារបស់ខ្ចី ១ បរិក្ខារមានតម្លៃតិចប្រមាណ ១ មាសក ឬថយពី ១ មាសកមក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ ១ ញុាំងទ្រព្យនោះឲ្យឃ្លាតផុតចាកទី ១ ត្រូវអាបត្តិទុក្កដ ។ ( បើមិនទាន់ឲ្យឃ្លាតផុតចាកទីទេ ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ធ្វើរបស់នោះឲ្យកម្រើក ក៏ត្រូវអាបត្តិទុក្កដ ។

[ ១២៤ ] ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់ មិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងរក្សា ១ សម្គាល់ថាជាទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានតម្លៃច្រើនប្រមាណ ៥ មាសក ឬលើសពី ៥ មាសក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ ១ ញុាំងទ្រព្យនោះ

ឲ្យឃ្លាតផុតបាកទី ១ ត្រូវអាបត្តិទុក្កដ ។ ( បើមិនទាន់ឲ្យឃ្លាតផុតបាកទីទេ ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ញុំាងទ្រព្យនោះឲ្យកម្រើក ក៏ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់ មិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងរក្សា ១ សម្គាល់ថាទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានតម្លៃតិចប្រមាណលើសពី ១ មាសក ឬថយពី ៥ មាសកចុះមក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតបាកទី ១ ត្រូវអាបត្តិទុក្កដ ។ ( បើមិនទាន់ឲ្យឃ្លាតផុតបាកទីទេ ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ញុំាងទ្រព្យនោះឲ្យកម្រើក ក៏ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាន់យកទ្រព្យដែលម្ចាស់របស់ មិនបានឲ្យដោយអាការ ៥ យ៉ាង ត្រូវអាបត្តិទុក្កដ គឺទ្រព្យដែលអ្នកដទៃមិនបានហួងហែងរក្សា ១ សម្គាល់ថាទ្រព្យមានអ្នកដទៃហួងហែងរក្សា ១ បរិក្ខារមានតម្លៃតិចប្រមាណ ១ មាសក ឬថយពី ១ មាសកចុះមក ១ មានថេយ្យចិត្តតាំងឡើងប្រាកដ ១ ញុំាងទ្រព្យនោះឲ្យឃ្លាតផុតបាកទី ១ ត្រូវអាបត្តិទុក្កដ ។ ( បើមិនទាន់ឲ្យឃ្លាតផុតបាកទីទេ ) ភិក្ខុចាប់ពាល់ ក៏ត្រូវអាបត្តិទុក្កដ ។ ធ្វើទ្រព្យនោះឲ្យកម្រើក ក៏ត្រូវអាបត្តិទុក្កដ ។

[ ១២៥ ] ភិក្ខុកាន់យកដោយសម្គាល់ថាជារបស់ខ្លួន កាន់យកដោយស្និទ្ធស្នាលនឹងគ្នា កាន់យកជារបស់ខ្ចីគ្នា កាន់យករបស់ដែលពួកប្រេតហួងហែងរក្សា កាន់យករបស់ដែលសត្វតិរច្ឆានហួងហែងរក្សា កាន់យកដោយសម្គាល់ថាជារបស់បង្សុកូល ភិក្ខុឆ្កួត ភិក្ខុអ្នកដើមបញ្ញត្តិ ( អម្បាលនេះ ) មិនត្រូវអាបត្តិ

ឡើយ ។

## អទិន្នាទាន បឋមភាណវារៈ ចប់ ។

( មាតិកានុក្រម បញ្ជីរឿងតាមរបៀបដែលនឹងសម្តែងតទៅ ដូចមានខាងក្រោមនេះ )

[ ១២៦ ] រឿងភិក្ខុ ៥ រូបលួចកណ្ឌៈរបស់ជាងជ្រលក់ រឿងភិក្ខុ ៤ រូបលួចគ្រឿងកម្រាល រឿងភិក្ខុ ៥ រូបលួចទ្រព្យក្នុងវេលាយប់ ( ដោយចំណាំទុកពីថ្ងៃ ) រឿងភិក្ខុ ៥ រូបលួចទ្រព្យគេដែលខ្ជះកំពុងជួយនាំទៅ រឿងភិក្ខុ ៥ រូបពោលតែពាក្យថា ( តែគ្មានថេយ្យចិត្ត ) រឿងភិក្ខុ ២ រូបទៀត រើសសំពត់សាជក និងឈ្នួតដែលបើុងទៅដោយខ្យល់ រឿងភិក្ខុ ១ ទស់យកសំពត់បង្សុកូលអំពីសាកអសុកដែលមិនទាន់បែកធ្លាយ រឿងភិក្ខុ ១ រូបលួចប្តូរស្លាកចីវរ រឿងព្រះអានន្ទត្ថេរប្រទ្បុំស្បៀកស្បង់របស់ភិក្ខុដទៃក្នុងរោងភ្លើង រួមទាំងរឿងភិក្ខុ ៥ ពួកដែលធាន់រំពាសត្វផង ត្រូវជា ១០ រឿងភិក្ខុ ៥ រូបមិនមានហេតុ កុហកយកខាទនីយភោជនីយាហារ ដែលគេចែកដល់សង្ឃ រឿងភិក្ខុ ៥ រូបលួចបាយ សាច់ នំ ស្ករក្រាម នំអន្សម ក្នុងវេលាស្រុកអត់បាយ រឿងពួកភិក្ខុលួចបរិក្ខារព្រមទាំងថង់យាម រឿងពួកភិក្ខុលួចពូករបស់សង្ឃ និងចីវរលើខ្សែស្បៀង រឿងភិក្ខុលួចចីវរក្នុងវិហារ ហើយមិនហ៊ានចេញទៅក្រៅ រឿងភិក្ខុធាន់ខាទនីយរបស់ភិក្ខុជាសម្លាញ់ ព្រោះសេចក្តីស្និទ្ធស្នាល រឿងភិក្ខុ ២ រូបទៀត

យកខាទនីយរបស់ភិក្ខុដទៃឆាន់ ដោយសម្គាល់ថាជារបស់ខ្លួន រឿងភិក្ខុ ៧ ពួកប្រកែកមិនទទួលខ្លួនថាលួចយក រឿងភិក្ខុ ៧ ពួកតាំងចិត្តលួចយកពិត រឿងភិក្ខុ ៧ រូបលួចយកខាទនីយរបស់សង្ឃ រឿងភិក្ខុ ២ រូបទៀតលួចផ្កា រឿងភិក្ខុ ៣ រូបទៅនិយាយយករបស់អំពីត្រកូលឧបដ្ឋាកនៃភិក្ខុដទៃ តាមពាក្យដែលលោកម្ចាស់ត្រកូលផ្តាំ រឿងភិក្ខុ ៣ រូបយកកែវមណីរំលងគយ រឿងពួកភិក្ខុដោះជ្រូកជាប់អន្ទាក់លែង រឿងពួកភិក្ខុដោះម្រឹគជាប់អន្ទាក់លែង រឿងពួកភិក្ខុដោះត្រីជាប់លបលែង រឿងភិក្ខុ ១ រូបលួចប្រមៀលកណ្ឌៈនៅក្នុងយាន រឿងភិក្ខុ ២ រូបលួចយកដុំសាច់ រឿងភិក្ខុ ២ ពួកលួចយកឈើក្បូនរបស់គេ រឿងភិក្ខុ ១ បង្សុកូលយកសំពត់សាដករបស់គេ រឿងភិក្ខុ ២ រូបរើសយកសំពត់សាដកអណ្តែតទឹក រឿងភិក្ខុ ១ រូបលួចផឹកសប្បិ រឿងពួកភិក្ខុចូលដៃគ្នាលួចទ្រព្យគេ ហើយចែកគ្នាមិនពេញ ៥ មាសកម្នាក់ រឿងភិក្ខុ ៤ រូបលួចជញ្ជាតិម្នាក់ ១ ក្តាប់ វេលាក្រុងសាវត្ថីអត់បាយ រឿងភិក្ខុ ២ ពួកបង្សុកូលយកសាច់ដែលសល់អំពីចោរបរិភោគ រឿងភិក្ខុ ២ រូបលួចស្មៅគេ រឿងភិក្ខុ ៧ ពួកយកខាទនីយរបស់សង្ឃចែកគ្នាឆាន់ រឿងភិក្ខុ ៧ ពួកមិនហ៊ានទទួលខាទនីយដែលមនុស្សមិនមែនម្ចាស់ប្រគេន រឿងភិក្ខុយកឈើរបស់សង្ឃធ្វើជញ្ជាំងកុដិដោយគិតថាខ្ចី រឿងភិក្ខុលួចទឹកសង្ឃ រឿងភិក្ខុលួចដីស្អិតសង្ឃ រឿងភិក្ខុ ២ រូបលួចស្មៅយាប្លងរបស់សង្ឃ រឿងភិក្ខុ ៧ រូបលួចគ្រឿងសេនាសនៈរបស់សង្ឃ រឿងភិក្ខុយកសេនាសនៈសម្រាប់វិហារ មានម្ចាស់ទៅប្រើប្រាស់ហើយបោល រឿងភិក្ខុ ១ ពួកព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យខ្ចីគ្រឿងសេនាសនៈ

របស់គេប្រើប្រាស់បាន រឿងពួកភិក្ខុនីជាសិស្សរបស់ថុល្លនន្ទាភិក្ខុនីក្នុងក្រុងចម្ប៉ា និងក្រុងរាជគ្រឹះទៅនិយាយយកបបរលាយល្ងប្រឡាំងដោយសណ្ដែកបាយ និងក្បាលទឹកឃ្មុំក្នុងត្រកូលឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី រឿងអជ្ជុកត្ថេរក្នុងក្រុងវេសាលី ចែកមត៌កដល់ក្មួយគហបតី រឿងបិលិន្ទវច្ឆត្ថេរក្នុងក្រុងពារាណសី នាំយកក្មេងពីរនាក់របស់ឧបដ្ឋាកអំពីដៃចោរបានមកដោយឫទ្ធិ រឿងភិក្ខុជាសម្លាញ់នឹងគ្នា ២ នាក់ក្នុងក្រុងកោសម្ពី រើសរម្មកជ្រកគិតថានឹងឲ្យដល់ម្ចាស់ រឿងភិក្ខុជាសទ្ធិវិហារិករបស់ទឡ្ហិកត្ថេរក្នុងក្រុងសាគលលួចយកឈ្នួតរបស់គេ ។

[ ១២៧ ] សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយទៅកាន់ទីកន្លែងហាលកណ្ឌៈនៃជាងជ្រលក់ ហើយលួចយកទ្រព្យរបស់ជាងជ្រលក់ ។ ភិក្ខុអម្បាលនោះមានសេចក្ដីសង្ស័យថា សិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ យើងទាំងឡាយ ត្រូវអាបត្តិបារាជិកហើយ ឬហ្ន៎ ។ ទើបក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

[ ១២៨ ] សម័យនោះ មានភិក្ខុ ១ រូបទៅកាន់កន្លែងហាលកណ្ឌៈនៃជាងជ្រលក់ បានឃើញសំពត់មានតម្លៃច្រើន ហើយញ៉ាំងថេយ្យចិត្តឲ្យកើតឡើង ។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា អញត្រូវអាបត្តិបារាជិកហើយឬហ្ន៎ ។ ទើបក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើថេយ្យចិត្តកើតឡើងប៉ុណ្ណោះ អ្នកមិនត្រូវអាបត្តិអ្វីឡើយ ។ សម័យនោះមានភិក្ខុ ១ រូប ទៅកាន់កន្លែងហាលកណ្ឌៈនៃជាងជ្រលក់ ឃើញសំពត់មាន

តម្លៃច្រើន មានថេយ្យចិត្តគិតលួច ហើយចាប់ពាល់សំពត់នោះ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ ទៅកាន់កន្លែងហាលកណ្តុះនៃជាងជ្រលក់ បានឃើញសំពត់មានតម្លៃច្រើន មានថេយ្យចិត្តគិតលួច ហើយធ្វើសំពត់នោះឲ្យកម្រើក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់កន្លែងហាលកណ្តុះនៃជាងជ្រលក់ បានឃើញសំពត់មានតម្លៃច្រើន មានថេយ្យចិត្តគិតលួច ហើយញ៉ាំងសំពត់នោះឲ្យឃ្លាតផុតចាកទី ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១២៩ ] សម័យនោះឯង មានភិក្ខុ ១ រូប អ្នកត្រាច់ទៅបិណ្ឌបាតបានឃើញកម្រាលដ៏ប្រសើរមានតម្លៃច្រើន ហើយញ៉ាំងថេយ្យចិត្តឲ្យកើតឡើង ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើថេយ្យចិត្តកើតឡើងប៉ុណ្ណោះ អ្នកមិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុ ១ រូបអ្នកត្រាច់ទៅបិណ្ឌបាត បានឃើញកម្រាលដ៏ប្រសើរមានតម្លៃច្រើន មានថេយ្យចិត្តគិតលួច ហើយចាប់ពាល់ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។បេ។ ភិក្ខុមានថេយ្យចិត្តធ្វើរបស់នោះឲ្យកម្រើក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុមានថេយ្យចិត្ត ញ៉ាំងរបស់

នោះ ឲ្យឃ្លាតផុតចាកទី ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៣០ ] សម័យនោះឯង មានភិក្ខុ ១ រូបឃើញទ្រព្យក្នុងវេលាថ្ងៃ ហើយបានធ្វើនិមិត្តសម្គាល់ថា អញនឹងលួចយកទ្រព្យនោះក្នុងវេលាយប់ ។ ភិក្ខុនោះកាលបើសម្គាល់ទ្រព្យនោះបានហើយ ក៏លួចយកទ្រព្យនោះមក ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។បេ។ ភិក្ខុសម្គាល់ទ្រព្យនោះបាន ( ក្នុងវេលាថ្ងៃហើយ ដល់វេលាយប់ ) លួចយកទ្រព្យដទៃបានមកវិញ ។បេ។ ( វេលាថ្ងៃ ) សម្គាល់ទ្រព្យដទៃទេ ( តែដល់វេលាយប់ ) ត្រឡប់លួចបានទ្រព្យនោះមក ។បេ។ សម្គាល់ទ្រព្យដទៃបានហើយ ទៅលួចយកទ្រព្យដទៃបានមក ។បេ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូបឃើញទ្រព្យក្នុងវេលាថ្ងៃ ហើយបានធ្វើនិមិត្តសម្គាល់ថា អញនឹងលួចយកទ្រព្យនោះក្នុងវេលាយប់ ។ ភិក្ខុនោះសម្គាល់ទ្រព្យនោះបានហើយ ( វេលាយប់ ) ត្រឡប់លួចបានទ្រព្យរបស់ខ្លួនមកវិញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។

[ ១៣១ ] សម័យនោះឯង មានភិក្ខុ ១ រូប ទូលនាំយកទ្រព្យរបស់អ្នកដទៃទៅឲ្យគេ ( វេលាកំពុងដើរ ) កើតមានថេយ្យចិត្ត ហើយចាប់ពាល់របស់តាំងនៅលើក្បាល ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវ

អាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។បេ។ ភិក្ខុមានថេយ្យចិត្ត ហើយធ្វើរបស់នោះឲ្យកម្រើក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់របស់ចុះមកត្រង់ក ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់ពាល់ភារៈដែលតាំងនៅលើ-ក ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយធ្វើភារៈនោះឲ្យកម្រើក ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់ភារៈចុះមកត្រង់ចង្កេះ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយចាប់ពាល់ភារៈដែលតាំងនៅលើចង្កេះ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយធ្វើភារៈឲ្យកម្រើក ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយបានកាន់យកដោយដៃ ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយដាក់ភារៈដែលតាំងនៅនឹងដៃមកលើផ្ទៃផែនដី ។បេ។ ភិក្ខុមានថេយ្យចិត្តគិតលួច ហើយបានចាប់យករបស់អំពីផែនដី ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៣២ ] សម័យនោះឯង មានភិក្ខុ ១ រូបហាលចីវរក្នុងទីវាល ហើយចូលទៅកាន់វិហារ ។ មានភិក្ខុឯទៀតទុកដាក់ចីវរនោះដោយគិតថា កុំឲ្យចីវរនេះបាត់ទៅឡើយ ។ ភិក្ខុនោះចេញពីវិហារទៅហើយ សួរភិក្ខុនោះថា អាវុសោ ចីវររបស់ខ្ញុំ លោកណាលួចយកទៅ ។ ភិក្ខុនោះពោលតបយ៉ាងនេះថា ( ចីវរលោក ) យើងលួចយកហើយ ។ ភិក្ខុម្ចាស់ចីវរនោះចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គ

ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្រាន់តែថាដោយពាក្យ ( តែគ្មានថេយ្យចិត្តទេ ) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើត្រឹមតែថាដោយពាក្យអ្នកមិនត្រូវអាបត្តិអ្វីឡើយ ។ សម័យនោះ មានភិក្ខុ ១ រូបទុកដាក់ចីវរលើតាំង ។បេ។ ទុកដាក់សំពត់និសីទនៈលើតាំង ។បេ។ ទុកដាក់បាត្រក្រោមតាំង ហើយចូលទៅកាន់វិហារ ។ មានភិក្ខុឯទៀតទុកដាក់បាត្រនោះ ដោយគិតថា កុំឲ្យបាត្រនេះបាត់ទៅឡើយ ។ ភិក្ខុម្ចាស់បាត្រនោះចេញពីវិហារហើយ ទៅសួរភិក្ខុនោះថា អាវុសោ បាត្ររបស់ខ្ញុំលោកណា លួចយកទៅ ។ ភិក្ខុនោះ ពោលតបយ៉ាងនេះថា ( បាត្ររបស់លោក ) យើងលួចយកហើយ ។ ភិក្ខុម្ចាស់បាត្រចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើត្រឹមតែពោលពាក្យទេ មិនត្រូវអាបត្តិអ្វីឡើយ ។ សម័យនោះឯង មានភិក្ខុនី ១ រូប ហាលចីវរនឹងរបង ហើយចូលទៅកាន់វិហារ ។ មានភិក្ខុនីឯទៀតទុកដាក់ចីវរនោះ ដោយគិតថា កុំឲ្យចីវរនេះបាត់ទៅឡើយ ។ ភិក្ខុនីជាម្ចាស់ចីវរនោះចេញពីវិហារទៅ ហើយសួរភិក្ខុនីនោះថា នាង ចីវររបស់ខ្ញុំអ្នកណាលួចយកបាត់ទៅ ។ ភិក្ខុនីនោះពោលតបយ៉ាងនេះថា ( ចីវរនាង ) យើងលួចយកហើយ ។ ភិក្ខុនីម្ចាស់ចីវរនោះចោទប្រកាន់ភិក្ខុនីនោះថា នាងមិនមែនជាសមណីទេ ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ ។ ទើបភិក្ខុនីនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយ បានប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងឡាយ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើត្រឹមតែពោលពាក្យទេ ( ភិក្ខុនីនេះ ) មិនត្រូវអាបត្តិអ្វីឡើយ ។

[ ១៣៣ ] សម័យនោះឯង មានភិក្ខុ ១ រូប ឃើញសំពត់សាដក បើងទៅដោយខ្យល់កំបុតត្បូង ក៏បានរើសយកដោយគិតថា អញនឹងឲ្យដល់ជនទាំងឡាយជាម្ចាស់សំពត់ ។ ពួកម្ចាស់សំពត់ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានសេចក្ដីគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានថេយ្យចិត្តគិតលួចទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនមានថេយ្យចិត្ត ឥតមានអាបត្តិអ្វីឡើយ ។ សម័យនោះឯង មានភិក្ខុ ១ រូបមានថេយ្យចិត្ត ហើយបានរើសយកឈ្នួតក្បាលរបស់គេដែលបើងទៅដោយខ្យល់កំបុតត្បូង ដោយគិតថា ក្រែងម្ចាស់របស់ទាំងឡាយឃើញមុន ( ហើយយកទៅ ) ។ ពួកម្ចាស់របស់ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានចិត្តគិត ដូចម្ដេច ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានថេយ្យចិត្តមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៣៤ ] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ទីស្មសាន ហើយបានកាន់យកសំពត់បង្សុកូលអំពីសរីរៈខ្មោចដែលមិនទាន់បែកធ្លាយ ។ ក៏ក្នុងសរីរៈខ្មោចនោះមានប្រេតមកអាស្រ័យនៅ ។ គ្រានោះ ប្រេតនោះបាននិយាយ

នឹងភិក្ខុនោះយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន លោកកុំយកសាដករបស់ខ្ញុំឡើយ ។ ភិក្ខុនោះមិនអើពើនឹងពាក្យប្រេតនោះ ក៏ចេះតែកាន់យកទៅ ។ ខណៈនោះសរីរៈនោះក្រោកឡើង ហើយដេញជាប់តាមក្រោយខ្នងភិក្ខុនោះ ។ លំដាប់នោះឯង ភិក្ខុនោះរត់ចូលទៅក្នុងវិហារហើយបិទទ្វារ ។ សរីរៈនោះ ក៏ដួលខ្ទាក់ក្នុងទីនោះឯង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែតទៅ ពួកភិក្ខុកុំគប្បីកាន់យកសំពត់បង្សុកូលអំពីសរីរៈខ្មោចដែលមិនទាន់បែកធ្លាយ ភិក្ខុណាកាន់យក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

[ ១៣៥ ] សម័យនោះឯង មានភិក្ខុ ១ រូប កាលគេកំពុងចែកចីវរដើម្បីសង្ឃ មានថេយ្យចិត្តគិតលួចហើយបានផ្លាស់ស្លាកខ្លួន លួចយកចីវរភិក្ខុដទៃ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៣៦ ] សម័យនោះឯង ព្រះអានន្ទដ៏មានអាយុសម្គាល់ស្បង់របស់ភិក្ខុដទៃថាជារបស់ខ្លួន ហើយស្លៀកក្នុងរោងភ្លើង ។ គ្រានោះឯង ភិក្ខុម្ចាស់ស្បង់នោះ បានសួរព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោ អានន្ទ ហេតុអ្វីបានជាលោកស្លៀកស្បង់របស់ខ្ញុំ ។ ព្រះអានន្ទនិយាយតបថា អាវុសោ ខ្ញុំសម្គាល់ថាជារបស់ខ្ញុំ ។ ពួកភិក្ខុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុអ្នកកាន់យកដោយសម្គាល់ថា ជារបស់ខ្លួនទេ ។

[ ១៣៧ ] សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ចុះចាកភ្នំគិជ្ឈកូដ បានឃើញរំពាសត្វសីហៈហើយយកមកចម្អិនចែកជាគ្នាឆាន់ ។ ភិក្ខុទាំងនោះ មានសេចក្ដីសង្ស័យ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការឆាន់រំពាសត្វសីហៈមិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុទាំងឡាយច្រើន ចុះអំពីភ្នំគិជ្ឈកូដ ហើយបានឃើញរំពាសត្វខ្លាធំ ។បេ។ ឃើញរំពាសត្វខ្លាដំបង ។បេ។ ឃើញរំពាសត្វខ្លារខិន ។បេ។ ឃើញរំពាសត្វឆ្កែព្រៃ ហើយនាំគ្នាយកមកចម្អិនបរិភោគ ។ ភិក្ខុទាំងឡាយនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុជារបស់សត្វតិរច្ឆាន មិនត្រូវអាបត្តិឡើយ ។

[ ១៣៨ ] សម័យនោះឯង មានភិក្ខុ ១ រូប កាលគេកំពុងចែកបាយដល់សង្ឃ ខ្វននិយាយថា លោកចូរឲ្យ ១ ចំណែកទៀតដើម្បីភិក្ខុដទៃ ថាដូច្នោះហើយ ក៏កាន់យកបាយដោយឥតមានមូល ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហកប៉ុណ្ណោះ ។ សម័យនោះឯង មានភិក្ខុ ១ រូប កាលគេកំពុងចែកខាទនីយាហារដល់សង្ឃ ។បេ។ កាលគេកំពុងចែកនំដល់សង្ឃ ។បេ។ កាលគេកំពុងចែកអំពៅដល់សង្ឃ ។បេ។ កាលគេកំពុងចែកផ្លែទន្លាប់ដល់សង្ឃ បានពោលថា លោកចូរឲ្យ១ចំណែកដើម្បីភិក្ខុឯទៀតផង ថាដូច្នោះហើយក៏កាន់យកចំណែកនោះដោយឥតមានមូល ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា

ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដីងខ្ទួនហើយ ពោលពាក្យកុហកប៉ុណ្ណោះ ។

[ ១៣៩ ] សម័យនោះឯង មានភិក្ខុ ១ រូប ចូលទៅកាន់ផ្ទះដែលគេដាំបាយ ក្នុងវេលាស្រុកអត់បាយ មានថេយ្យចិត្តហើយបានលួចយកបាយពេញ ១ បាត្រ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ចូលទៅកាន់ផ្ទះសម្រាប់ចម្អិនសាច់លក់ក្នុងវេលាស្រុកអត់បាយ ហើយមានថេយ្យចិត្តលួចយកសាច់ដាក់ពេញ ១ បាត្រ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ចូលទៅកាន់ផ្ទះធ្វើនំក្នុងវេលាស្រុកអត់បាយ ហើយមានថេយ្យចិត្តបានលួចយកនំដាក់ពេញ ១ បាត្រ ។បេ។ មានថេយ្យចិត្តហើយលួចយកនំក្រៀបដាក់ពេញ ១ បាត្រ ។បេ។ មានថេយ្យចិត្តហើយបានលួចយកនំអន្សមដាក់ពេញ ១ បាត្រ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៤០ ] សម័យនោះឯង មានភិក្ខុ ១ រូបឃើញបរិក្ខារក្នុងវេលាថ្ងៃហើយធ្វើនិមិត្តទុកថា អញនឹងលួចយកក្នុងវេលាយប់ ។ ភិក្ខុនោះសម្គាល់របស់នោះបានហើយ លួចយករបស់នោះបានមក ។បេ។ សម្គាល់របស់នោះបានហើយ លួចបានរបស់ដទៃមកវិញ ។បេ។ សម្គាល់របស់ដទៃទេ ត្រឡប់

លួចបានរបស់នោះមកវិញ ។បេ។ សម្គាល់របស់ដទៃ លួចបានរបស់ដទៃមក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ឃើញបរិក្ខារក្នុងវេលាថ្ងៃហើយបានធ្វើនិមិត្តទុកថា អញនឹងលួចយកក្នុងវេលាយប់។ ភិក្ខុនោះសម្គាល់របស់នោះបានហើយ ត្រឡប់លួចបានបរិក្ខាររបស់ខ្លួនឯងមកវិញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។

[ ១៤១ ] សម័យនោះឯង មានភិក្ខុ ១ រូប ឃើញថង់យាមនៅលើតាំងហើយគិតថា កាលអញយកថង់យាមអំពីទីនេះមុខជានឹងត្រូវអាបត្តិបារាជិកហើយរំកិលយកថង់យាមនោះ ព្រមទាំងតាំងទៅផង ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៤២ ] សម័យនោះឯង ភិក្ខុ ១ រូបមានថេយ្យចិត្តហើយលួចយកពូករបស់សង្ឃ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៤៣ ] សម័យនោះឯង ភិក្ខុ ១ រូបមានថេយ្យចិត្ត ហើយលួចយកចីវរដែលពាក់លើខ្សែស្បៀង ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៤៤ ] សម័យនោះឯង មានភិក្ខុ ១ រូបលួចយកចីវរក្នុងវិហារហើយគិតថា កាលអញចេញអំពីវិហារនេះទៅ អញនឹងត្រូវអាបត្តិបារាជិក

មិនមាន ហើយពុំបានចេញអំពីវិហារឡើយ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូល សេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ មោឃបុរសនោះ គប្បីចេញទៅក្តី មិនគប្បីចេញទៅក្តី គង់តែត្រូវ អាបត្តិបារាជិកដែរ ។

[ ១៤៥ ] សម័យនោះឯង មានភិក្ខុ ២ រូបជាសម្លាញ់នឹងគ្នា ភិក្ខុ ១ រូបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ឯភិក្ខុទី ២ កាលគេចែកខាទនីយាហារ ដល់សង្ឃ ក៏បានកាន់យកចំណែករបស់ភិក្ខុជាសម្លាញ់ ហើយបរិភោគដោយ សេចក្តីស្និទ្ធស្នាលនឹងគ្នា ។ ភិក្ខុសម្លាញ់នោះដឹងហើយចោទប្រកាន់ភិក្ខុនោះ ថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាប ទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គកាន់យកដោយសេចក្តីស្និទ្ធស្នាល នឹងគ្នា ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើកាន់យកដោយសេចក្តីស្និទ្ធ-ស្នាលដូច្នោះ អ្នកមិនត្រូវអាបត្តិឡើយ ។

[ ១៤៦ ] សម័យនោះឯង ភិក្ខុច្រើនរូប ធ្វើនូវចីវរកម្ម ។ កាលគេ ចែកខាទនីយាហារដល់សង្ឃ ខាទនីយាហារជាចំណែករបស់ភិក្ខុទាំងអស់នោះ គេក៏បាននាំយកទៅទុកដាក់មួយកន្លែងហើយ ។ មានភិក្ខុ ១ រូប សម្គាល់ ចំណែករបស់ភិក្ខុឯទៀតថាជារបស់ខ្លួនហើយឆាន់អស់ទៅ ។ ភិក្ខុម្ចាស់របស់ ដឹងហើយចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមាន

ដល់ភិក្ខុដែលសម្គាល់ថាជារបស់ខ្លួន ។ សម័យនោះឯង ភិក្ខុច្រើនរូបធ្វើនូវចីវរកម្ម ។ កាលគេចែកខាទនីយាហារដល់សង្ឃ ភិក្ខុយកបាត្រភិក្ខុឯទៀតមកទទួលយកចំណែករបស់ភិក្ខុឯទៀត ហើយយកទៅទុក ។ ភិក្ខុម្ចាស់បាត្រសម្គាល់ថាជារបស់ខ្លួនហើយឆាន់អស់ទៅ ។ ភិក្ខុនោះដឹងហើយ ចោទប្រកាន់ភិក្ខុម្ចាស់បាត្រនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលសម្គាល់ថាជារបស់ខ្លួន ។

[ ១៤៧ ] សម័យនោះឯង ពួកចោរលួចស្វាយ បេះផ្លែស្វាយបានហើយ វេចជាសម្ពាយស្ពាយដើរទៅ ។ ពួកមនុស្សជាម្ចាស់ស្វាយនាំគ្នាដេញតាមចោរអម្បាលនោះ ។ ពួកចោរឃើញម្ចាស់ស្វាយទាំងឡាយដេញតាមក៏ទម្លាក់សម្ពាយស្វាយរត់ចោលទៅ ។ ភិក្ខុទាំងឡាយសម្គាល់សម្ពាយស្វាយនោះជារបស់បង្សុកូល ហើយទស់ឆាន់ទៅ ។ ពួកម្ចាស់ស្វាយចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមានចិត្តគិតដូចម្តេច ។ ភិក្ខុទាំងឡាយនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយសម្គាល់ថាជារបស់បង្សុកូល ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសម្គាល់ថាជារបស់បង្សុកូលឡើយ ។ សម័យនោះឯង ពួកចោរលួចព្រីង ។បេ។ ពួកចោរលួចខ្នុរសម្

។បេ។ ពួកចោរលួចខ្នុរណាំង ។បេ។ ពួកចោរលួចត្នោតទុំ ។បេ។ ពួកចោរលួចអំពៅ ។បេ។ ពួកចោរលួចផ្លែទន្លាប់ នាំគ្នាលួចបេះផ្លែទន្លាប់ទាំងឡាយបានហើយវេចជាសម្ពាយស្ពាយដើរទៅ ។ ពួកម្ចាស់ទន្លាប់ដេញតាមពួកចោរអម្បាលនោះ ។ ចោរទាំងឡាយឃើញពួកម្ចាស់ទន្លាប់ហើយទម្លាក់សម្ពាយចោលរត់ទៅ ។ ភិក្ខុទាំងឡាយឃើញ សម្គាល់នូវសម្ពាយនោះថាជារបស់បង្សុកូល ហើយនាំគ្នាទស់ឆាន់ទៅ ។ ពួកជនជាម្ចាស់នាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសម្គាល់ថាជារបស់បង្សុកូល ។

[ ១៤៨ ] សម័យនោះឯង ពួកចោរលួចស្វាយ បេះផ្លែស្វាយបានហើយវេចជាសម្ពាយស្ពាយដើរទៅ ។ ពួកម្ចាស់ស្វាយដេញតាមចោរទាំងអម្បាលនោះ ។ ចោរទាំងឡាយឃើញពួកម្ចាស់ស្វាយ ហើយទម្លាក់សម្ពាយចោលរត់ទៅ ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ស្វាយគេឃើញមុន ទើបនាំគ្នាឆាន់អស់ទៅ ។ ពួកម្ចាស់ស្វាយនាំគ្នាចោទប្រកាន់ពួកភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ពួកចោរលួចព្រីង ។បេ។ ពួកចោរលួចខ្នុរសម្ល ។បេ។ ពួកចោរលួចផ្លែខ្នុរណាំង ។បេ។ ពួកចោរលួចផ្លែត្នោតទុំ ។បេ។ ពួកចោរលួចអំពៅ ។បេ។ ពួកចោរលួចផ្លែទន្លាប់

លួចបេះផ្លែទន្ទាប់ទាំងឡាយបានហើយ វេចជាសម្ពាយស្ពាយដើរទៅ ។ ម្ចាស់ទន្ទាប់ទាំងឡាយដេញតាមពួកចោរអម្បាលនោះ ។ ចោរទាំងឡាយ ឃើញម្ចាស់ទន្ទាប់ហើយ ទម្លាក់សម្ពាយចោល ហើយរត់ទៅ ។ ភិក្ខុទាំងឡាយមានថេយ្យចិត្តគិតថា ក្រែងម្ចាស់ទន្ទាប់ទាំងឡាយគេមកឃើញមុន ទើបនាំគ្នាឆាន់អស់ទៅ ។ ម្ចាស់ទន្ទាប់ទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

[ ១៤៩ ] សម័យនោះឯង ភិក្ខុ ១ រូប មានថេយ្យចិត្តលួចយកស្វាយរបស់សង្ឃ ។បេ។ លួចយកព្រីងរបស់សង្ឃ ។បេ។ លួចយកផ្លែខ្នុរសម្លរបស់សង្ឃ ។បេ។ លួចយកផ្លែខ្នុរណាំងរបស់សង្ឃ ។បេ។ លួចយកផ្លែត្នោតទុំរបស់សង្ឃ ។បេ។ លួចយកអំពៅរបស់សង្ឃ ។បេ។ មានថេយ្យ-ចិត្តហើយលួចយកផ្លែទន្ទាប់របស់សង្ឃ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៥០ ] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់សួនផ្កា ហើយមានថេយ្យចិត្តលួចយកផ្កាមានតម្លៃ ៥ មាសកដែលម្ចាស់គេបានបេះទុក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់សួនផ្កា ហើយមានថេយ្យចិត្តលួចបេះផ្កាមានតម្លៃ ៥ មាសក ។ ភិក្ខុនោះមានសេចក្តី

សង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៥១ ] សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ស្រុកតូចមួយ ហើយបាននិយាយនឹងភិក្ខុ ១ រូបថា អាវុសោ លោកផ្តាំខ្ញុំហើយ ខ្ញុំនឹងទៅប្រាប់ត្រកូលជាឧបដ្ឋាករបស់លោក ។ ភិក្ខុនោះទៅហើយបានឲ្យត្រកូលនោះយកសំពត់សាដក ១ មក ហើយប្រើប្រាស់ដោយខ្លួនឯង ។ ភិក្ខុអ្នកជិតដិតនឹងត្រកូលដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថា អ្នកផ្តាំខ្ញុំហើយ ខ្ញុំនឹងប្រាប់ដូច្នេះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ស្រុកតូចមួយ ។ ភិក្ខុឯទៀតបាននិយាយពាក្យនេះនឹងភិក្ខុនោះថា អាវុសោ ខ្ញុំផ្តាំហើយ លោកប្រាប់ត្រកូលឧបដ្ឋាករបស់ខ្ញុំចុះ ។ ភិក្ខុនោះទៅហើយ ឲ្យត្រកូលឧបដ្ឋាកនោះយកសំពត់សាដក ១ គូមក ហើយប្រើប្រាស់សំពត់សាដក ១ ដោយខ្លួនឯង រួចឲ្យសំពត់សាដក ១ ដល់ភិក្ខុអ្នកជិតដិតនឹងត្រកូលនោះ ។ ភិក្ខុនោះដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ តែភិក្ខុកុំគប្បីពោលថា លោកខ្ញុំផ្តាំហើយ ប្រាប់ចុះដូច្នេះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង មានភិក្ខុ ១ រូបទៅកាន់ស្រុក

តូចមួយ ហើយបាននិយាយពាក្យនេះនឹងភិក្ខុឯទៀតថា ម្នាលអាវុសោ លោកផ្ដាំ នឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ត្រកូលឧបដ្ឋាករបស់លោក ។ ឯភិក្ខុនោះ ក៏បាននិយាយយ៉ាងនេះថា ខ្ញុំបានផ្ដាំនឹងលោកហើយ លោកប្រាប់ចុះ ។ ភិក្ខុនោះទៅហើយឲ្យត្រកូលឧបដ្ឋាកនោះយកសប្បិ ១ អាឡ្ហកៈ ( មាត្រាវាល់ក្នុងដែនមគធៈ ៤ នាឡិជា ១ អាឡ្ហកៈ ) ស្ករអំពៅ ១ តុលៈ ( ទម្ងន់ ២០ តម្លឹង ) អង្ករ ១ ទោណៈ (គ្រឿងវាល់ ៤ អាឡ្ហកៈ ត្រូវជា ១ ទោណៈ ) មកហើយបរិភោគដោយខ្លួនឯង ។ ភិក្ខុអ្នកជិតដិតនឹងត្រកូលនោះដឹងហើយ ចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថា លោកផ្ដាំនឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ដូច្នេះ ម្យ៉ាងទៀត កុំគប្បីពោលថា ខ្ញុំផ្ដាំនឹងលោកហើយ លោកប្រាប់ចុះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

[ ១៥២ ] សម័យនោះឯង បុរសម្នាក់នាំយកកែវមណីមានតម្លៃច្រើន ហើយដើរទៅកាន់ផ្លូវឆ្ងាយជាមួយនឹងភិក្ខុឯទៀត ។ លំដាប់នោះ បុរសនោះឃើញទីគយហើយដាក់កែវមណីក្នុងថង់យាមរបស់ភិក្ខុនោះៗ អត់ដឹងឡើយ លុះកន្លងផុតពីគយហើយ ក៏យកកែវមណីពីថង់យាមមកវិញ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្ដេច ។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានដឹង

សោះឡើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមិនដឹង ។ សម័យនោះឯង បុរសម្នាក់នាំយកកែវមណីមានតម្លៃច្រើនដើរទៅកាន់ផ្លូវឆ្ងាយជាមួយនឹងភិក្ខុឯទៀត ។ លំដាប់នោះ បុរសនោះឃើញទីគយហើយ ក៏ធ្វើអាការហាក់ដូចជាឈឺ ហើយបានប្រគល់បង្វេចកែវមណីរបស់ខ្លួនដល់ភិក្ខុនោះ ។ គ្រានោះឯង បុរសនោះដើររំលងហួសពីគយទៅហើយ បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ ចូរលោកយកបង្វេចរបស់ខ្ញុំមក ខ្ញុំមិនឈឺទេ ។ ភិក្ខុនោះសួរថា អាវុសោ ចុះហេតុអ្វីបានជាអ្នកធ្វើអាការយ៉ាងនេះ ។ ទើបបុរសនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនោះ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច ។ ភិក្ខុនោះទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងសោះឡើយ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមិនដឹង ។ សម័យនោះឯង មានភិក្ខុ ១ រូបដើរទៅកាន់ផ្លូវឆ្ងាយជាមួយនឹងឈ្មួញរទេះ ។ បុរសម្នាក់ក៏លួងលោមភិក្ខុនោះដោយអាមិស លុះឃើញទីគយហើយ បានឲ្យកែវមណីមានតម្លៃច្រើនដល់ភិក្ខុនោះដោយពាក្យថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់យកកែវមណីនេះ ឲ្យរំលងទីគយទៅផង ។ ភិក្ខុនោះយកកែវមណីនោះ រំលងទីគយទៅក្នុងកាលនោះឯង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៥៣ ] សម័យនោះឯង មានភិក្ខុ ១ រូប ដោះលែងជ្រូកជាប់

អន្ទាក់ ដោយសេចក្តីករុណា ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច ។ ភិក្ខុនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានសេចក្តីប្រាថ្នាដោយសេចក្តីករុណា ( ហើយដោះលែងទៅ ) ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុអ្នកមានសេចក្តីប្រាថ្នាដោយសេចក្តីករុណាទេ ។ សម័យនោះឯង មានភិក្ខុ ១ រូប ឃើញជ្រូកជាប់អន្ទាក់ ក៏មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់គេឃើញមុន ហើយដោះលែងជ្រូកនោះទៅ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប ដោះលែងសត្វម្រឹគជាប់អន្ទាក់ ដោយសេចក្តីករុណា ។បេ។ ភិក្ខុឃើញម្រឹគជាប់អន្ទាក់មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់គេឃើញមុន ហើយដោះលែងម្រឹគនោះទៅ ។បេ។ ភិក្ខុដោះលែងត្រីទាំងឡាយដែលជាប់លបដោយសេចក្តីករុណា ។បេ។ ភិក្ខុឃើញត្រីទាំងឡាយជាប់លបមានថេយ្យចិត្តថា ក្រែងពួកម្ចាស់គេឃើញមុន ហើយដោះលែងត្រីនោះទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៥៤ ] សម័យនោះឯង មានភិក្ខុ ១ រូប ឃើញទ្រព្យនៅក្នុងយាន ហើយគិតថា បើអញយកចាកទីនេះមុខជានឹងត្រូវអាបត្តិបារាជិក ទើបឈូសប្រមៀលឲ្យធ្លាក់ចុះ ហើយក៏កាន់យកទៅ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ១៥៥ ] សម័យនោះឯង មានភិក្ខុ ១ រូប បានរើសយកដុំសាច់ដែលសត្វអាតពាំយកទៅ ដោយគិតថា អញនឹងប្រគល់ឲ្យពួកម្ចាស់សាច់ៗ ពួកម្ចាស់សាច់នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានថេយ្យចិត្ត ។ សម័យនោះឯង មានភិក្ខុ ១ រូប ឃើញដុំសាច់ដែលសត្វអាតពាំយកទៅ មានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់គេឃើញមុន ហើយក៏កាន់យកដុំសាច់នោះទៅ ។ ពួកម្ចាស់សាច់នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៥៦ ] សម័យនោះឯង មនុស្សទាំងឡាយចងក្បូន ហើយបណ្តែតតាមស្ទឹងអចិរវតី ។ កាលចំណងក្បូនដាច់ ឈើទាំងឡាយ ក៏អណ្តែតខ្ចាត់ខ្ចាយទៅ ។ ភិក្ខុទាំងឡាយសម្គាល់ថា ជារបស់បង្សុកូលហើយនាំគ្នាស្រង់យកឡើង ។ ពួកម្ចាស់ក្បូននាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសម្គាល់ថាជារបស់បង្សុកូល ។ សម័យនោះឯង មនុស្សទាំងឡាយចងក្បូន ហើយបណ្តែតតាមស្ទឹងអចិរវតី ។ កាលចំណងក្បូនដាច់ ឈើទាំងឡាយក៏អណ្តែតខ្ចាត់ខ្ចាយទៅ ។ ភិក្ខុទាំងឡាយ មានថេយ្យចិត្តគិតថា

ក្រែងម្ចាស់ឈើគេឃើញមុន ហើយស្រង់យកឡើង ពួកម្ចាស់ឈើនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុទាំងអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

[ ១៥៧ ] សម័យនោះឯង មានបុរសគង្វាលគោម្នាក់ ពាក់សំពត់សាដកនឹងដើមឈើ ហើយក៏ដើរទៅបន្ទោបង់ឧច្ចារៈ ។ ភិក្ខុ ១ រូបសម្គាល់ថាជារបស់បង្សុកូល ហើយក៏កាន់យកទៅ ។ គ្រានោះ បុរសគង្វាលគោនោះចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុដែលសម្គាល់ថាជារបស់បង្សុកូល ។

[ ១៥៨ ] សម័យនោះឯង កាលភិក្ខុ ១ រូបកំពុងឆ្លងស្ទឹង សំពត់សាដកក៏របូតអំពីដៃជាងជ្រលក់ទាំងឡាយ ហើយទៅជាប់នឹងជើងភិក្ខុ ។ ភិក្ខុនោះបានកាន់យកសំពត់សាដកនោះ ដោយគិតថា អញនឹងឲ្យដល់ម្ចាស់ទាំងឡាយ ។ ពួកម្ចាស់សំពត់សាដកក៏នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ភិក្ខុ ដែលមិនមានថេយ្យចិត្ត ។ សម័យនោះឯង កាលភិក្ខុ ១ រូបកំពុងឆ្លងស្ទឹង សំពត់សាដករបូតអំពីដៃនៃជាងជ្រលក់ទាំងឡាយ ហើយសោត់ទៅជាប់នឹងជើងភិក្ខុ ។ ភិក្ខុនោះមានថេយ្យចិត្តគិតថា ក្រែងពួកម្ចាស់សំពត់សាដកឃើញមុន ហើយក៏កាន់យក

ទៅ ។ ម្ចាស់សំពត់សាដកទាំងឡាយ នាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៥៩ ] សម័យនោះឯង ភិក្ខុ ១ រូបបានឃើញថ្នាំងដាក់សប្បិ ហើយបានឆាន់បន្តិចៗ មួង ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។

[ ១៦០ ] កាលនោះ ភិក្ខុទាំងឡាយច្រើនរូបបាននិយាយបបួលគ្នាថា យើងទាំងឡាយនឹងទៅលួចទ្រព្យ ហើយនាំគ្នាទៅ ។ ភិក្ខុ ១ រូបលួចទ្រព្យបានមក ។ ភិក្ខុទាំងឡាយនោះបាននិយាយគ្នាយ៉ាងនេះថា ពួកយើងមិនត្រូវអាបត្តិបារាជិកទេ លោកណាលួចបានមក លោកនោះត្រូវអាបត្តិបារាជិក ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ។ កាលនោះ ភិក្ខុទាំងឡាយច្រើនរូបបបួលគ្នាលួចទ្រព្យបានមកហើយក៏ចែកគ្នា។ កាលដែលភិក្ខុអម្បាលនោះកំពុងចែកគ្នា ភិក្ខុ ១ រូបៗ បានចំណែកមិនពេញ ៥ មាសក ។ ភិក្ខុទាំងនោះបាននិយាយយ៉ាងនេះថា យើងទាំងឡាយមិនត្រូវអាបត្តិបារាជិកទេ ។ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយអ្នកទាំងឡាយត្រូវអាបត្តិបារាជិកហើយ ។

[ ១៦១ ] សម័យនោះ ភិក្ខុ ១ រូប កាលក្រុងសាវត្ថីកើតទុរ្ភិក្ស អត់

បាយ ( ភិក្ខុនោះ ) មានថេយ្យចិត្តហើយលួចយកអន្នរបស់អ្នកផ្សារ ប្រមាណ ១ ក្លាប់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះ ភិក្ខុ ១ រូប កាលក្រុងសាវត្ថីកើតទុរ្ភិក្ស អត់បាយ មានថេយ្យចិត្ត ហើយលួចយកសណ្តែកបាយរបស់អ្នកផ្សារ ១ ក្លាប់ ។បេ។ សណ្តែកពជមាស ១ ក្លាប់ ។បេ។ ល្ង ១ ក្លាប់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៦២ ] សម័យនោះ ពួកចោរសម្លាប់មេគោ ស៊ីសាច់ហើយក៏ទុកដាក់សាច់ដ៏សេសសល់ក្នុងព្រៃអន្ធវន ទៀបក្រុងសាវត្ថី ហើយនាំគ្នាទៅ ។ ភិក្ខុទាំងឡាយសម្គាល់ថា ជារបស់បង្សុកូល ហើយនាំគ្នាកាន់យកសាច់នោះបរិភោគទៅ ។ ពួកចោរនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសម្គាល់ថា ជារបស់បង្សុកូល ។ សម័យនោះ ពួកចោរសម្លាប់ជ្រូកស៊ីសាច់ ហើយទុកដាក់សាច់ដ៏សេសសល់ក្នុងព្រៃអន្ធវន ទៀបក្រុងសាវត្ថី ហើយនាំគ្នាទៅ ។ ភិក្ខុទាំងឡាយសម្គាល់ថា ជារបស់បង្សុកូល ហើយនាំគ្នាកាន់យកសាច់នោះមកឆាន់ ។ ពួកចោរនាំគ្នាចោទប្រកាន់ភិក្ខុអម្បាលនោះថា លោកទាំងឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអម្បាលនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលសម្គាល់

ថា ជារបស់បង្សុកូល ។

[ ១៦៣ ] កាលណោះ ភិក្ខុ ១ រូប ទៅកាន់ស្រែស្មៅ ( ចម្ការស្មៅ ) មានថេយ្យចិត្តហើយ បានលួចយកស្មៅដែលគេប្រុតទុក មានតម្លៃ ៥ មាសក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៦៤ ] សម័យនោះ ភិក្ខុ ១ រូប ទៅកាន់ស្រែស្មៅ មានថេយ្យ-ចិត្តហើយលួចប្រុតយកស្មៅគេមានតម្លៃ ៥ មាសក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៦៥ ] សម័យនោះ ភិក្ខុទាំងឡាយជាអាគន្តុកៈ ( ភិក្ខុអ្នកមកថ្មី ) ញុំាងគ្នានឹងគ្នាឲ្យចែកផ្លែស្វាយរបស់សង្ឃ ហើយបរិភោគទៅ ។ ភិក្ខុម្ចាស់អាវាសទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុជាអាគន្តុកៈអម្បាលនោះថា លោកទាំង-ឡាយមិនមែនជាសមណៈទេ ។ ភិក្ខុអាគន្តុកៈអម្បាលនោះ មានសេចក្តីសង្ស័យ ។ ទើបនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកគិតដូចម្តេច ។ ភិក្ខុអម្បាលនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងឡាយមានចិត្តប្រាថ្នាដើម្បីនឹងបរិភោគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយអាបត្តិមិនមានដល់ភិក្ខុដែលប្រាថ្នាដើម្បីនឹងបរិភោគទេ ។ សម័យនោះ ភិក្ខុទាំងឡាយជាអាគន្តុកៈ ញុំាងគ្នានឹងគ្នាឲ្យចែកផ្លែព្រីងរបស់សង្ឃ ។បេ។ ផ្លែខ្នុរ

សម្ងរបស់សង្ឃ ។បេ។ ផ្លែខ្នុរណាំងរបស់សង្ឃ ។បេ។ ផ្លែត្នោតទុំរបស់សង្ឃ ។បេ។ អំពៅរបស់សង្ឃ ។បេ។ ផ្លែទន្លាប់របស់សង្ឃ ហើយនាំគ្នាបរិភោគទៅ ។ ពួកភិក្ខុដែលជាម្ចាស់អាវាស នាំគ្នាចោទប្រកាន់ភិក្ខុអាគន្តុកៈអម្បាលនោះថា លោកទាំងឡាយ មិនមែនជាសមណៈទេ ។ ភិក្ខុអាគន្តុកៈអម្បាលនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលប្រាថ្នាដើម្បីនឹងបរិភោគទេ ។

[ ១៦៦ ] សម័យនោះ ពួកមនុស្សអ្នករក្សាស្វាយនាំគ្នាប្រគេនផ្លែស្វាយដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយសង្ស័យមិនហ៊ានទទួល ដោយគិតថា មនុស្សអម្បាលនេះ ជាឥស្សរៈត្រឹមតែរក្សាថែទាំប៉ុណ្ណោះ មនុស្សអម្បាលនេះមិនជាឥស្សរៈដើម្បីនឹងឲ្យបានទេ ។ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើទានដែលបុគ្គលអ្នករក្សាគេឲ្យហើយ ( ភិក្ខុអ្នកទទួល ) មិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មនុស្សអ្នករក្សាព្រីងទាំងឡាយ ។បេ។ អ្នករក្សាខ្នុរសម្ងទាំងឡាយ ។បេ។ អ្នករក្សាខ្នុរណាំងទាំងឡាយ ។បេ។ អ្នករក្សាផ្លែត្នោតទុំទាំងឡាយ ។បេ។ អ្នករក្សាអំពៅទាំងឡាយ ។បេ។ អ្នករក្សាផ្លែទន្លាប់ទាំងឡាយ បានប្រគេនផ្លែទន្លាប់ទាំងឡាយ ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយសង្ស័យមិនហ៊ានទទួល ដោយគិតថា មនុស្សអម្បាលនេះ ជាឥស្សរៈត្រឹមតែរក្សាប៉ុណ្ណោះ មនុស្សអម្បាលនេះមិនជាឥស្សរៈដើម្បីនឹងឲ្យទេ ។ ទើបនាំគ្នាក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុ ព្រោះទានដែលអ្នកថែរក្សាឲ្យនោះទេ ។

[ ១៦៧ ] សម័យនោះ ភិក្ខុ ១ រូបឱ្យឈើរបស់សង្ឃយកទៅឧបត្ថម្ភ ( ជួសជុល ) ជញ្ជាំងវិហាររបស់ខ្លួន ។ ភិក្ខុទាំងឡាយនាំគ្នាចោទប្រកាន់ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គតាំងចិត្តថាជារបស់ខ្ចី ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើកាន់យកជារបស់ខ្ចីដូច្នោះ អ្នកមិនមានអាបត្តិឡើយ ។

[ ១៦៨ ] សម័យនោះ ភិក្ខុ ១ រូបមានថេយ្យចិត្ត ហើយបានលួចយកទឹករបស់សង្ឃ ។បេ។ មានថេយ្យចិត្តហើយលួចយកដីរបស់សង្ឃ ។បេ។ មានថេយ្យចិត្តហើយបានលួចយកស្មៅយាប្ចងរបស់សង្ឃ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូបមានថេយ្យចិត្តហើយលួចដុតស្មៅយាប្ចងរបស់សង្ឃ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិទុក្កដ ។

[ ១៦៩ ] សម័យនោះ ភិក្ខុ ១ រូប មានថេយ្យចិត្ត ហើយលួចយកគ្រែរបស់សង្ឃ ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ភិក្ខុ ១ រូប មានថេយ្យចិត្តហើយលួចយកតាំងរបស់សង្ឃ ។បេ។ ពូករបស់សង្ឃ

។បេ។ ខ្នើយរបស់សង្ឃ សន្ទះទ្វាររបស់សង្ឃ ។បេ។ សន្ទះបង្អួចរបស់សង្ឃ ។បេ។ ឈើបន្តង់របស់សង្ឃ ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកត្រូវអាបត្តិបារាជិកហើយ ។

[ ១៧០ ] សម័យនោះ ភិក្ខុទាំងឡាយយកសេនាសនៈរបស់ឧបាសកម្នាក់ ដែលគេទុកជារបស់សម្រាប់ប្រើប្រាស់ក្នុងវត្ត ទៅប្រើប្រាស់ក្នុងទីដទៃៗ គ្រានោះ ឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកដ៏ចម្រើនទាំងឡាយ មិនសមនឹងមកយករបស់គេសម្រាប់ទុកប្រើប្រាស់ក្នុងទីដទៃ ទៅប្រើប្រាស់ក្នុងទីដទៃវិញ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រឿងប្រើប្រាស់របស់គេក្នុងទីដទៃ ភិក្ខុមិនគប្បីយកទៅប្រើប្រាស់ក្នុងទីដទៃទេ តែភិក្ខុណាយកទៅប្រើប្រាស់ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះ ភិក្ខុទាំង-ឡាយប្រុងនឹងនាំយកអាសនៈសម្រាប់អង្គុយក្នុងរោងឧបោសថ តែមានសេចក្តីសង្ស័យមិនហ៊ាននាំយកទៅ ហើយក៏អង្គុយផ្ទាល់លើផែនដី ។ ខ្លួនក្តី ចីវរក្តី ក៏ប្រឡាក់ទៅដោយធូលី ។ ភិក្ខុទាំងឡាយយកសេចក្តីនុ៎ះក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយខ្ចីរបស់ទាំងនោះទៅប្រើប្រាស់បាន ។

[ ១៧១ ] សម័យនោះឯង ភិក្ខុនី ១ រូបជាសិស្សរបស់ថុល្លនន្ទាភិក្ខុនីនៅក្នុងក្រុងចម្បា ទៅកាន់ត្រកូលជាឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី ហើយបង្គាប់ត្រកូលនោះថា ថុល្លនន្ទាភិក្ខុនីជាម្ចាស់ ចង់ឆាន់បបរ ដែលលាយសណ្តែក

និងល្វ ហើយក៏យកទៅបរិភោគដោយខ្លួនឯង ។ ថុល្លនន្ទាភិក្ខុនីនោះដឹង ហើយ ចោទប្រកាន់សិស្សនោះថា នាងឯងមិនមែនជាសមណីទេ ។ ភិក្ខុនី នោះ មានសេចក្តីសង្ស័យ ។ ទើបភិក្ខុនីនោះ នាំយករឿងនុ៎ះទៅតំណាល ប្រាប់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីនាំយករឿងនុ៎ះទៅប្រាប់ដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុនាំយករឿងនុ៎ះទៅក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែ អាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហក ។ សម័យនោះឯង ភិក្ខុនី ១ រូប ជាសិស្សថុល្លនន្ទាភិក្ខុនីនៅក្នុងក្រុងរាជគ្រឹះ ទៅកាន់ត្រកូលជា ឧបដ្ឋាករបស់ថុល្លនន្ទាភិក្ខុនី ហើយបង្គាប់ត្រកូលនោះថា ថុល្លនន្ទាភិក្ខុនីជាម្ចាស់ ចង់ឆាន់នំមានរសឆ្ងាញ់ក្រៃពេក ហើយក៏យកទៅបរិភោគ ដោយខ្លួនឯង ។ ថុល្លនន្ទាភិក្ខុនីនោះដឹងហើយ ចោទប្រកាន់សិស្សនោះថា នាងឯងមិនមែនជា សមណីទេ ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិ បាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហក ។

[ ១៧២ ] សម័យនោះឯង ក្មេងពីរនាក់ គឺកូនប្រុស ១ ក្មួយប្រុស ១ របស់គហបតីជាឧបដ្ឋាករបស់អដ្ឋកត្ថេរដ៏មានអាយុ ក្នុងក្រុងវេសាលី ។ គ្រានោះ គហបតីនោះ បាននិយាយពាក្យនេះនឹងអដ្ឋកត្ថេរដ៏មានអាយុថា បពិត្រ លោកដ៏ចម្រើន ជំនុំក្មេងទាំងពីរនាក់នេះ ក្មេងណាមានសទ្ធាជ្រះថ្លា ព្រះករុណា គប្បីប្រាប់ឱកាសនេះដល់ក្មេងនោះ ។ គហបតីនោះ ធ្វើកាលកិរិយាទៅ ។

សម័យនោះឯង ក្មួយរបស់គហបតីនោះ មានសទ្ធាជ្រះថ្លា ។ លំដាប់នោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បានប្រាប់ឱកាសនោះដល់ទារកដែលជាក្មួយនោះ ។ ទារកដែលជាក្មួយនោះ ក៏បានបីបាច់រក្សានូវទ្រព្យ និងចាត់ចែងនូវទានដោយសម្បត្តិនោះ ។ លំដាប់នោះ កូនរបស់គហបតីនោះបាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន អ្នកណាជាអ្នកទទួលមត៌ករបស់បិតា កូន ឬក្មួយ ។ ព្រះអានន្ទនិយាយតបថា ម្នាលអ្នកដ៏មានអាយុ កូនទើបត្រូវទទួលទ្រព្យមត៌ករបស់បិតាបាន ។ កូនរបស់គហបតីនោះបាននិយាយតទៅទៀតថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់អជ្ជុកត្ថេរនេះប្រាប់សម្បត្តិរបស់ខ្ញុំដល់បងប្អូនជីដូនមួយរបស់ខ្ញុំហើយ ។ ព្រះអានន្ទពោលថា ម្នាលអ្នកដ៏មានអាយុ អជ្ជុកត្ថេរដ៏មានអាយុនេះ មិនមែនជាសមណៈទេ ។ គ្រានោះ ព្រះអជ្ជុកត្ថេរដ៏មានអាយុ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ លោកចូរឲ្យសេចក្តីវិនិច្ឆ័យដល់ខ្ញុំចុះ ។ សម័យនោះឯង ព្រះឧបាលីដ៏មានអាយុ ជាបក្ខពួករបស់ព្រះអជ្ជុកត្ថេរដ៏មានអាយុ ។ លំដាប់នោះ ព្រះឧបាលីដ៏មានអាយុ បាននិយាយពាក្យនេះនឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអាវុសោអានន្ទ ភិក្ខុណាដែលម្ចាស់ទ្រព្យផ្តាំទុកថា លោកចូរប្រាប់ឱកាសនេះដល់អ្នកនេះ ហើយភិក្ខុនោះ ទៅប្រាប់ដល់អ្នកនោះ ភិក្ខុនោះត្រូវអាបត្តិអ្វី ។ ព្រះអានន្ទឆ្លើយតបទៅវិញថា បពិត្រលោកដ៏ចម្រើន ភិក្ខុនោះមិនត្រូវអាបត្តិអ្វីបន្តិចទេ ដោយហោចទៅតែអាបត្តិទុក្កដក៏មិនត្រូវដែរ ។ ព្រះឧបាលីឆ្លើយថា ម្នាលអាវុសោ ព្រះអជ្ជុកត្ថេរដ៏មានអាយុនេះ ម្ចាស់ទ្រព្យ

បានផ្តាំទុកថា លោកចូរប្រាប់ឱកាសនេះដល់ជនឈ្មោះនេះ ។ ក៏បានប្រាប់ដល់អ្នកនោះមែន ម្នាលអាវុសោ អជ្ជុកត្ថេរដ៏មានអាយុមិនត្រូវអាបត្តិទេ ។

[ ១៧៣ ] សម័យនោះឯង ក្នុងក្រុងពារាណសី ពួកចោរនាំគ្នាប្លន់ត្រកូលឧបដ្ឋាករបស់ព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុ ហើយក៏នាំយកកូនក្មេងពីរនាក់ទៅ ។ លំដាប់នោះ ព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុ សម្តែងឫទ្ធិទៅនាំយកក្មេងទាំងពីរនាក់នោះបានមកហើយទុកក្នុងប្រាសាទ ។ មនុស្សទាំងឡាយបានឃើញក្មេងទាំងពីរនាក់នោះហើយ និយាយថា នេះជាឫទ្ធានុភាពរបស់លោកម្ចាស់បិលិន្ទវច្ឆត្ថេរ ហើយក៏នាំគ្នាជ្រះថ្លានឹងព្រះបិលិន្ទវច្ឆត្ថេរដ៏មានអាយុពេកណាស់ ។ ភិក្ខុទាំងឡាយនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា បិលិន្ទវច្ឆត្ថេរដ៏មានអាយុមិនសមគួរនឹងទៅនាំយកក្មេងពីរនាក់ ដែលពួកចោរវានាំយកទៅហើយ ។ ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុអ្នកមានឫទ្ធិទេ ព្រោះវិស័យនៃឫទ្ធិ ។

[ ១៧៤ ] សម័យនោះឯង ភិក្ខុពីររូបជាសម្លាញ់គ្នា ឈ្មោះបណ្ឌកៈ ១ កបិលៈ ១ ។ ភិក្ខុ ១ រូបនៅស្រុកក្រៅ ១ រូបនៅក្នុងក្រុងកោសម្ពី ។ គ្រាដែលភិក្ខុនោះចេញពីស្រុកក្រៅ ទៅកាន់ក្រុងកោសម្ពី កាលកំពុងឆ្លងទឹកស្ទឹងក្នុងរវាងពាក់កណ្តាលផ្លូវ កន្សោមខ្លាញ់របូតអំពីដៃនៃមនុស្សអ្នកសម្លាប់ជ្រូកទាំងឡាយ ទៅជាប់នៅជើងរបស់ភិក្ខុនោះ ។ ភិក្ខុនោះ បានកាន់យកដោយគិតថា នឹងឲ្យដល់ជនទាំងឡាយជាម្ចាស់វិញ ។ ពួកម្ចាស់នាំគ្នាចោទប្រកាន់

ភិក្ខុនោះថា លោកមិនមែនជាសមណៈទេ ។ ស្រីគង្វាលគោម្នាក់ឃើញភិក្ខុនោះ ឆ្ងងទឹកស៊ឹងរួចហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ លោកចូរមក សេពមេថុនធម្មនឹងខ្ញុំ ។ ភិក្ខុនោះគិតថា អញមិនមែនជាសមណៈតាមប្រក្រតីទេ ទើបព្រមសេពមេថុនធម្មនឹងស្រីនោះ ហើយទៅកាន់ក្រុងកោសម្ពី ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា នែភិក្ខុទាំងឡាយ ភិក្ខុនោះមិនត្រូវអាបត្តិបារាជិកព្រោះអទិន្នាទានទេ ត្រូវអាបត្តិបារាជិក ព្រោះសេពមេថុនធម្ម ។

[ ១៧៥ ] សម័យនោះឯង ភិក្ខុជាសទ្ធិវិហារិករបស់ព្រះទឡ្ហិកត្ថេរដ៏មានអាយុ ក្នុងសាគលនគរ មានសេចក្តីមិនសប្បាយមកបៀតបៀន ក៏ទៅលួចយកឈ្នួតរបស់អ្នកផ្សារ ហើយបាននិយាយពាក្យនេះនឹងព្រះទឡ្ហិកត្ថេរដ៏មានអាយុយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំមិនមែនជាសមណៈទេ ខ្ញុំនឹងសឹក (ឥឡូវនេះ) ។ ព្រះទឡ្ហិកត្ថេរ បានសួរថា ម្នាលអាវុសោ អំពើដូចម្តេចដែលអ្នកធ្វើហើយ ។ ភិក្ខុនោះប្រាប់ថា បពិត្រលោកដ៏ចម្រើន ខ្ញុំលួចយកឈ្នួតរបស់អ្នកផ្សារ ។ ព្រះទឡ្ហិកត្ថេរ ក៏ឲ្យយកឈ្នួតនោះមកហើយ កាត់ថ្លៃ ។ ឈ្នួតនោះកាត់ថ្លៃទៅ តម្លៃមិនដល់ ៥ មាសក ។ ព្រះទឡ្ហិកត្ថេរប្រាប់ថា ម្នាលអាវុសោ អ្នកមិនត្រូវអាបត្តិបារាជិកទេ ដូច្នេះហើយ ក៏បានសម្តែងធម្មីកថា ។ ឯភិក្ខុនោះ មានសេចក្តីត្រេកអរក្រៃពេក ។

**ទុតិយបារាជិក ចប់**

# អដ្ឋកថា
# អធិដ្ឋានធានសិក្ខាបទវណ្ណនា

## រឿង ធនិយភិក្ខុកុម្ភការបុត្រ

ឥឡូវនេះ ដល់លំដាប់ពណ៌នាទុតិយបារាជិក ដែលព្រះជិនស្រី មិនមានបុគ្គលជាគម្រប់ពីរ ទ្រង់ប្រកាសហើយ ព្រោះហេតុនោះ ពាក្យណាដែលគប្បីដឹងបានងាយ និងបានប្រកាសទុកក្នុងខាងដើម ការពណ៌នាទុតិយ-បារាជិកនោះ នឹងវៀរពាក្យនោះចេញទាំងអស់ដូចតទៅ

[ ៧៩ ] និក្ខេបបទថា **តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ** ខ្ញុំនឹងពោលតទៅថា បទថា **រាជគហេ** បានដល់នគរមានឈ្មោះយ៉ាងនោះ ។ ពិតហើយ ក្រុងនោះហៅថា រាជគ្រឹះ ព្រោះជាក្រុងដែលព្រះរាជាទាំងឡាយ មានព្រះបាទមន្ធាតុ និងព្រះបាទមហាគោវិន្ទជាដើមទ្រង់គ្រប់គ្រង ។ ក្នុងពាក្យថា រាជគ្រឹះនេះ អាចារ្យទាំងឡាយពណ៌នាប្រការដទៃខ្លះ ។ នឹងមានប្រយោជន៍អ្វី ដោយប្រការទាំងនោះ ។ ពាក្យថា រាជគ្រឹះនេះ ជាឈ្មោះរបស់នគរនោះ ។ តែនគរនោះ ជានគរក្នុងសម័យពុទ្ធកាល និងចក្រពត្តិកាល ។ ក្នុងកាលដ៏សេស ជាក្រុងស្ងាត់ ត្រូវយក្ខហួងហែង គឺជាព្រៃ ជាទីនៅរបស់ពួកយក្ខទាំងនោះ ព្រះឧបាលិត្ថេរកាលសម្តែងគោចរគ្រាមយ៉ាងនោះហើយ ទើបសម្តែងទីកន្លែងដែលទ្រង់ប្រថាប់ ។

ពីរបទថា **គិជ្ឈកូដេ បព្វតេ** សេចក្តីថា ឯភ្នំនោះ គេតែងហៅថា គិជ្ឈកូដ ព្រោះមានហ្វូងត្មាតនៅលើកំពូល ឬ មានកំពូលស្រដៀងត្មាត ។

បទថា **សម្ពហុលា** សេចក្តីថា ដោយបរិយាយនៃព្រះវិន័យ ភិក្ខុ ៣ អង្គ ហៅថា ភិក្ខុជាច្រើន លើសជាងនោះហៅថា សង្ឃ ដោយបរិយាយនៃព្រះសូត្រ ភិក្ខុ ៣ អង្គ គង់ហៅថា ៣ អង្គនោះឯង តាំងអំពី ៣ អង្គឡើងទៅ ទើបហៅថា ភិក្ខុជាច្រើន ។ ចំណែកភិក្ខុជាច្រើនក្នុងទីនេះ គប្បីជ្រាបថា ច្រើនដោយគ្នា ព្រោះបរិយាយនៃព្រះសូត្រ ។

ជនទាំងឡាយ ដែលមិនធ្លាប់ស្និទ្ធស្នាលគ្នា គឺមិនមែនមិត្តដែលស្និទ្ធ លោកហៅថា សម្មាញ់ដោយការឃើញ ។ ពិតហើយ ភិក្ខុទាំងនោះ លោកហៅថា សម្មាញ់ដោយការឃើញ ព្រោះបានឃើញគ្នាក្នុងទីនោះៗ ។ ជនទាំងឡាយដែលស្និទ្ធស្នាលគ្នា គឺជាមិត្តជិតស្និទ្ធ លោកហៅថា មិត្តសេពគប់ ។ ពិតហើយ ភិក្ខុទាំងនោះ សេពគប់គ្នាហើយ គឺកំពុងសេពគប់គ្នាយ៉ាងល្អ លោកហៅថា មិត្តសេពគប់ ព្រោះធ្វើសេចក្តីស្និទ្ធស្នាល នៅរួមជាមួយគ្នា និងបរិភោគជាមួយគ្នា ។

បទថា **ឥសិគិលិបស្សេ** សេចក្តីថា ក្នុំឈ្មោះឥសិគិលិ ។ ក្បែរភ្នំឥសិគិលិនោះ ។ បានឮថា ក្នុងអតីតកាលដ៏យូរលង់ ព្រះបច្ចេកពុទ្ធប្រមាណ ៥០០ អង្គ ត្រាច់ទៅបិណ្ឌបាតក្នុងជនបទទាំងឡាយ មានកាសី និងកោសល ជាដើម ពេលក្រោយភត្ត លោកមកប្រជុំគ្នាត្រង់ភ្នំនោះ ញុំាំងកាលឲ្យកន្លងទៅដោយសមាបត្តិ ។ មនុស្សទាំងឡាយ ឃើញលោកចូលទៅប៉ុណ្ណោះ មិនឃើញចេញមកឡើយ ព្រោះហេតុនោះ ទើបនិយាយគ្នាថា ភ្នំនេះលេបឥសីទាំងនេះ ព្រោះអាស្រ័យហេតុនោះ ទើបភ្នំនោះបានឈ្មោះថា ឥសិគិលិនោះ

ឯង ។ ទីក្បែរភ្នំនោះ គឺជើងភ្នំ ។

## ភិក្ខុចាំវស្សាមិនមានសេនាសនៈត្រូវអាបត្តិទុក្កដ

ភិក្ខុកាលចាំវស្សា សូម្បីបដិបត្តិតាមបដិបទារបស់ព្រះនាលកៈ ក៏ត្រូវចាំវស្សាក្នុងសេនាសនៈ ព្រមទាំងរបៀង ដែលប្រក់ដោយគ្រឿងប្រក់ ៥ យ៉ាងណាមួយប៉ុណ្ណោះ ។ ពិតហើយ ព្រះដ៏មានព្រះភាគបានត្រាស់ពាក្យនេះទុកថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវចូលវស្សា ដោយឥតមានទីសេនាសនៈទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ ។ ព្រោះហេតុនោះ ក្នុងវេលាជិតវស្សា បើបានសេនាសនៈ ការដែលបានយ៉ាងនោះជាការល្អ បើមិនបានទេ ត្រូវស្វែងរក ហត្ថកម្មធ្វើ បើមិនបានហត្ថកម្ម គួរធ្វើដោយខ្លួនឯង ។ ចំណែកភិក្ខុដែលមិនមានសេនាសនៈ មិនគួរចូលចាំវស្សាឡើយ ។ សេចក្តីនេះជាធម៌ដែលសមគួរ ។ ព្រោះហេតុនោះ ទើបភិក្ខុទាំងនោះធ្វើកុដិស្មៅ កំណត់ទីស្នាក់ពេលយប់ និងពេលថ្ងៃជាដើមទុកហើយ អធិដ្ឋានកតិកាវត្ត និងខន្ធកវត្ត សិក្សាក្នុងត្រៃសិក្ខា ហើយនៅចាំវស្សា ។

ពីរបទថា **អាយស្មាបិ ធនិយោ** សេចក្តីថា មិនមែនតែព្រះថេរៈទាំងនោះតែម្យ៉ាងទេ សូម្បីធនិយភិក្ខុដែលជាដើមបញ្ញត្តនៃសិក្ខាបទនេះ ក៏បានធ្វើដូចគ្នា ។

បទថា **កុម្ភការបុត្តោ** គឺជាកូនរបស់ស្មូនឆ្នាំង ។ ពិតហើយ ពាក្យថា **ធនិយ** ជាឈ្មោះរបស់លោក តែបិតារបស់លោក ជានាយស្មូនឆ្នាំង ដោយហេតុនោះ ទើបលោកឈ្មោះថា ធនិយភិក្ខុកូនស្មូនឆ្នាំង ។

ពីរបទថា **វស្សំ ឧបគច្ឆិ** សេចក្ដីថា ធនិយភិក្ខុធ្វើកុដិស្មៅហើយ ក៏នៅចាំវស្សាក្នុងទីកន្លែងជាមួយនឹងព្រះថេរៈទាំងនោះឯង ។

ពីរបទថា **វស្សំ វុត្ថា** សេចក្ដីថា ភិក្ខុទាំងនោះចូលវស្សាក្នុងថ្ងៃបុរិមវស្សា ហើយបវារណាក្នុងថ្ងៃមហាបវារណា តាំងពីថ្ងៃបាដិបទ ( ១ រោច ) ទៅ លោកហៅថា អ្នកចេញវស្សាហើយ ។ ជាអ្នកចេញវស្សាហើយដោយវិធីយ៉ាងនោះ ។

ពីរបទថា **តិណកុដិយោ ភិន្ទិត្វា** សេចក្ដីថា ភិក្ខុទាំងនោះមិនបានទម្លាយកុដិឲ្យជាលម្អិតតូចធំ ដោយការប្រហារដោយដំបងជាដើមឡើយ តែបានរើស្បូវ និងវល្លិ៍ជាដើមចេញ ដោយរបៀបវត្ត ។ ពិតហើយ ភិក្ខុណាបានធ្វើកុដិទុក ក្នុងទីបំផុតដែនវិហារ ភិក្ខុនោះ បើពួកភិក្ខុម្ចាស់កន្លែង មានក៏គួរលាភិក្ខុម្ចាស់អាវាសនោះ គប្បីពោលថា បើភិក្ខុអង្គណាអាចនឹងមើលថែកុដិនេះបាន សូមលោកប្រគល់ឲ្យដល់លោកអង្គនោះចុះ ដូច្នេះហើយ សឹមចៀសចេញទៅ ។ បើភិក្ខុណាធ្វើកុដិទុកក្នុងព្រៃ មិនបានរក្សា ភិក្ខុនោះគិតថា សេនាសនៈនឹងជារបស់បរិភោគដល់ភិក្ខុដទៃ គួររៀបចំទុកដាក់ សឹមទៅ ។ អធិប្បាយថា ភិក្ខុទាំងនោះ ធ្វើកុដិទុកក្នុងព្រៃហើយ កាលមិនមានអ្នកថែរក្សា ក៏គួរប្រមូលស្មៅ និងឈើទុក ។ ម្យ៉ាងទៀត ស្មៅ និងឈើដែលរក្សាទុកហើយ សត្វទាំងឡាយ មានកណ្ដៀរជាដើមនឹងស៊ីមិនបាន ទាំងភ្លៀងក៏លិចមិនបានដោយប្រការណា ក៏គួររក្សាទុកដោយប្រការនោះ គួរបំពេញគមិកវត្ត ( វត្តអ្នកដើរផ្លូវ ) ឲ្យបរិបូណ៌ ដោយគិតថា ស្មៅ និងឈើនោះ

នឹងជាឧបការៈដល់សព្រហ្មចារីទាំងឡាយ ដែលមកដល់ទីកន្លែងនេះ ហើយបំណាច់នឹងទៅ ដូច្នេះ ទើបគួរចៀសចេញទៅ ។

ពីរបទថា **ជនបទចារិកំ បក្កមឹសុ** សេចក្តីថា ភិក្ខុទាំងនោះបានទៅកាន់ជនបទតាមការពេញចិត្តរៀងៗ ខ្លួន ។ បទជាដើមថា **អាយស្មា ធនិយោ កុម្ភការបុត្តោ តត្ថេវ វស្សំ វសិ** ធនិយភិក្ខុកុម្ភការបុត្រនៅចាំវស្សាត្រង់ជើងភ្នំគិជ្ឈកូដនោះឯង មានអត្ថប្រាកដជាក់ច្បាស់ហើយ ។

បទថា **យាវតតិយកំ** ប្រែថា អស់វារៈ ៣ ដង ។

បទថា **អនវយោ** ប្រែថា ជាអ្នកមិនខ្វះខាត ។ លុប **ឧ** អក្ខរៈចេញដោយអំណាចសន្ធិ ។ អធិប្បាយថា ជាអ្នកមានសិល្បៈបរិបូណ៌ មិនខ្វះខាតក្នុងការងារគ្រប់យ៉ាង ដែលពួកស្មូនឆ្នាំងគប្បីធ្វើ ។

បទថា **សកេ** ប្រែថា រៀងៗ ខ្លួន ។

បទថា **អាចរិយកេ** ប្រែថា ក្នុងការងារនៃអាចារ្យ ។

បទថា **កុម្ភការកម្មេ** ប្រែថា ក្នុងការងាររបស់ពួកស្មូនឆ្នាំង ។ អធិប្បាយថា ក្នុងការងារដែលពួកស្មូនឆ្នាំងគប្បីធ្វើ ។ ដោយបទថា **កុម្ភការកម្មេ** នោះ គឺ ធនិយភិក្ខុសម្តែងដល់ការងារនៃអាចារ្យរបស់ខ្លួនដោយសរុប ។

បទថា **បរិយោទាតសិប្បោ** គឺជាអ្នកសម្រេចសិប្បៈ អធិប្បាយថា កាលបើអញមិនមានការខ្វះខាត អញក៏ជាអ្នកមានសិប្បៈ នឹងរកអ្នកដទៃប្រៀបស្មើមិនបាន ។

បទថា **សព្វមត្តិកាមយំ** សេចក្ដីថា ធនិយភិក្ខុនោះ ធ្វើគ្រឿងផ្ទះដ៏សេសទាំងអស់ មានជញ្ជាំង ក្បឿង និងគ្រឿងឈើជាដើមឲ្យសម្រេចដោយដីទាំងអស់ វៀរលែងតែសន្ទះទ្វារ គន្ទឹះទ្វារ និងសន្ទះបង្អួច ។ ច្រើនបទថា **តិណាញ្ច កដ្ឋញ្ច គោមយញ្ច សង្ឃដ្ដិត្វា តំ កុដិកំ បចិ** សេចក្ដីថា ធនិយភិក្ខុធ្វើគ្រឿងផ្ទះឲ្យសម្រេចដោយដីសុទ្ធ ហើយជូតដោយបាតដៃ ធ្វើឲ្យស្ងួត ហើយយកដីក្រហម ផ្សំដោយប្រេង បូកលាបឲ្យរលោង ទើបញាត់ទាំងខាងក្នុង និងខាងក្រៅឲ្យពេញដោយស្មៅជាដើម ហើយដុតកុដិនោះដោយវិធីដុតដីឲ្យឆ្អិនដោយល្អ ។ ឯកុដិនោះ បានជារបស់ដុតហើយដោយអាការយ៉ាងនោះ ។

បទថា **អភិរូបា** ប្រែថា មានរូបស្អាត ។

បទថា **បាសាទិកា** ប្រែថា នាំឲ្យកើតសេចក្ដីជ្រះថ្លា ។

បទថា **លោហិតកា** ប្រែថា មានពណ៌ក្រហម ។

បទថា **កិង្កិណិកសទ្ទោ** ប្រែថា បានដល់ សំឡេងដូចកណ្ដឹង ។ បានឮថា កណ្ដឹងដែលគេធ្វើដោយរតនៈផ្សេងៗ រមែងមានសំឡេង យ៉ាងណា កុដិនោះ ក៏មានសំឡេងដូច្នោះ ព្រោះត្រូវខ្យល់ដែលបក់ចូលទៅតាមចន្លោះបង្អួចជាដើមប៉ះខ្ទប់ហើយ ។ ដោយបទថា **កិង្កិណិកសទ្ទោ** នោះ គឺលោកសម្ដែងដល់កុដិនោះឆ្អិនល្អទាំងខាងក្នុង និងខាងក្រៅ ។ ចំណែកក្នុងមហាអដ្ឋកថា លោកពោលទុកថា ភាជនៈសំរឹទ្ធឈ្មោះថា **កិង្កិណិក** ព្រោះដូច្នោះ ភាជនៈសំរឹទ្ធដែលត្រូវខ្យល់ប៉ះហើយ មានសំឡេងយ៉ាងណា កុដិនោះ

ត្រូវខ្យល់ប៉ះហើយ មានសំឡេងយ៉ាងនោះ ។

ក្នុងពាក្យថា **កឹ ឯតំ ភិក្ខវេ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបហើយ តែដើម្បីទ្រង់តាំងរឿងនោះ ទើបត្រាស់សួរ ។

ច្រើនបទថា **ភគវតោ ឯតមត្ថំ អារោចេសុំ** សេចក្តីថា ភិក្ខុទាំងឡាយបានក្រាបទូលសេចក្តី ដែលធនិយភិក្ខុធ្វើកុដិសម្រេចដោយដីសុទ្ធដល់ព្រះដ៏មានព្រះភាគតាំងពីដើម ។

បទថា **ករិស្សតិ** នេះ ក្នុងប្រយោគថា ម្នាលភិក្ខុទាំងឡាយ ហេតុអ្វីទើបមោឃបុរសនោះជាន់ភក់ ធ្វើកុដិសម្រេចដោយដីសុទ្ធទៅវិញ ជាពាក្យអនាគត ចុះក្នុងអត្ថអតីត អធិប្បាយថា បានធ្វើហើយ ។ លក្ខណៈនៃការពោលកិរិយាអនាគត ចុះក្នុងអត្ថអតីតនោះ អ្នកសិក្សាគួរស្វែងរកអំពីគម្ពីរសព្ទសាស្ត្រចុះ ។

ក្នុងពាក្យថា ម្នាលភិក្ខុទាំងឡាយ ការអាណិតអាសូរ ការអនុគ្រោះ ការមិនបៀតបៀន មិនមានដល់មោឃបុរសនោះឡើយ នេះមានវិនិច្ឆ័យដូច្នេះថា ការតាមរក្សា ឈ្មោះថា **អនុទ្ទយា** ព្រះដ៏មានព្រះភាគ រមែងសម្តែងចំណែកខាងដើមនៃមេត្តា ដោយបទថា **អនុទ្ទយា** នោះ ។

ចិត្តទោរទន់ ព្រោះទុក្ខរបស់អ្នកដទៃ ឈ្មោះថា **អនុកម្បា** ។ ការមិនបៀតបៀន ឈ្មោះថា **អវិហេសា** ព្រះដ៏មានព្រះភាគ ទ្រង់រមែងសម្តែងចំណែកខាងដើមនៃករុណា ដោយពីរបទថា **អនុកម្បា** និង **អវិហេសា** នោះ ។ ទ្រង់ត្រាស់ពាក្យអធិប្បាយទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាល

ធនិយភិក្ខុមោឃបុរសនោះបៀតបៀន គឺធ្វើសត្វតូចៗ ជាច្រើនឲ្យវិនាសទៅ ព្រោះជីកដី ជាន់កក់ និងដុតភ្លើង ការអាណិតអាសូរ ការអនុគ្រោះ ការមិនបៀតបៀន ត្រឹមតែជាចំណែកខាងដើមនៃមេត្តា និងករុណាក្នុងសត្វទាំងឡាយនោះ ឈ្មោះថា មិនមានឡើយ គឺការអាណិតអាសូរជាដើម ឈ្មោះថា សូម្បីមានប្រមាណតិចតួចក៏មិនមាន ។

ច្រើនបទថា **មា បច្ឆិមា ជនតា បាណេសុ បាតព្យតំ អាបជ្ជិ** សេចក្ដីថា ពពួកជនជាន់ក្រោយ កុំដល់នូវការបៀតបៀនពួកសត្វឡើយ ។ មានពាក្យអធិប្បាយថា ពពួកជនជាន់ក្រោយ យកតម្រាប់តាមថា សូម្បីក្នុងសម័យពុទ្ធកាល ភិក្ខុទាំងឡាយបានធ្វើកម្មយ៉ាងនេះហើយ កាលភិក្ខុធ្វើបាណាតិបាតក្នុងសត្វទាំងឡាយ ក្នុងឋានៈដូច្នេះ ក៏មិនមានទោសដូច្នេះ កាលនឹងលើកយកព្រះថេរៈនេះជាទិដ្ឋានុគតិ កុំសិក្សាក្នុងកម្មដែលគប្បីបៀតបៀន គឺធ្វើពួកសត្វឲ្យលំបាក ដូចព្រះថេរៈនោះធ្វើហើយ ។

## អាបត្តិទុក្កដមានដល់ភិក្ខុដែលធ្វើកុដិដោយដី

ព្រះដ៏មានព្រះភាគ កាលទ្រង់តិះដៀលធនិយភិក្ខុយ៉ាងនោះហើយ ទើបទ្រង់បញ្ញត្តការធ្វើកុដិដូច្នោះតទៅថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរធ្វើកុដិសម្រេចដោយដីសុទ្ធទេ កាលទ្រង់បញ្ញត្តហើយ ទើបទ្រង់ដាក់អាបត្តិ ព្រោះការធ្វើកុដិ សម្រេចដោយដីសុទ្ធថា ភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ព្រោះហេតុនោះ ភិក្ខុអង្គណា សូម្បីមិនទាន់បានបៀតបៀននូវពពួកសត្វ ព្រោះកិច្ច មានការជីកដីជាដើម ធ្វើកុដិដូច្នោះ សូម្បីភិក្ខុអង្គនោះ ក៏ត្រូវអាបត្តិ

ទុក្កដ ។ តែភិក្ខុដែលដល់នូវការបៀតបៀនសត្វ ព្រោះកិច្ច មានការជីកដីជាដើម រមែងត្រូវអាបត្តិតាមដែលទ្រង់បញ្ញត្ត ព្រោះវត្ថុដែលខ្លួនកន្លងល្មើសនោះឯង ។ ធនិយភិក្ខុឈ្មោះថា មិនត្រូវអាបត្តិ ព្រោះជាបុគ្គលដើមបញ្ញត្តិក្នុងសិក្ខាបទនេះ ។ ភិក្ខុដ៏សេសដែលកន្លងល្មើសសិក្ខាបទ ធ្វើខ្លួនឯងក្តី បានកុដិដែលអ្នកដទៃធ្វើហើយនៅក្នុងកុដិនោះក្តី ត្រូវអាបត្តិទុក្កដដោយពិត ។ ឯកុដិដែលធ្វើផ្សំដោយទព្វសម្ភារៈ ទោះជាផ្សំដោយអាការណាមួយក៏ដោយ រមែងគួរ ។ កុដិដែលសម្រេចដោយដីសុទ្ធនោះឯង មិនគួរ បើកុដិនោះធ្វើដោយឥដ្ឋ ដោយអាការដូចគ្នានឹងរោងស្នាក់ ដែលធ្វើដោយឥដ្ឋ ក៏គួរ ។

## ព្រះដ៏មានព្រះភាគត្រាស់ឱ្យបំផ្លាញអកប្បិយកុដិ

ប្រែនបទថា **ឯវម្ភន្តេតិ ខោ ។បេ។ តំ កុដិកំ ភិន្ទឹសុ** សេចក្តីថា ភិក្ខុទាំងនោះ ទទួលពុទ្ធាណត្តិហើយ ក៏យកឈើ និងដុំថ្ម ទម្លាយកុដិនោះឲ្យខ្ទេចខ្ទីហើយ ។

ក្នុងពាក្យថា **អថខោ អាយស្មា ធនិយោ** ជាដើម មានសេចក្តីសង្ខេបដូចតទៅនេះថា ធនិយភិក្ខុអង្គុយសម្រាកពេលថ្ងៃ នៅក្បែរៗ នោះ ទើបបានមក ព្រោះសំឡេងនោះ ហើយសួរភិក្ខុទាំងនោះថា អាវុសោ ពួកលោកទម្លាយកុដិរបស់ខ្ញុំដើម្បីអ្វី បានឮថា ព្រះដ៏មានព្រះភាគត្រាស់ឲ្យពួកខ្ញុំទម្លាយ ទើបព្រមទទួល ព្រោះជាអ្នកប្រដៅងាយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគត្រាស់ឲ្យទម្លាយកុដិដែលព្រះថេរៈនេះ ធ្វើដោយឧស្សាហ៍យ៉ាងធំក្រៃលែង ដើម្បីជាលំនៅរបស់ខ្លួន

សូម្បីការប្រើប្រាស់ ( វត្ថុ ដូចជា បន្ទះទ្វារជាដើម ) ដែលនៅប្រើការបាន ក្នុងកុដិនេះរបស់ព្រះថេរៈ នៅមានមិនមែនឬ ។

ឆ្លើយថា មានក៏ពិត សូម្បីយ៉ាងនោះ ព្រះដ៏មានព្រះភាគយល់ក្នុងព្រះទ័យថា កុដិដែលធនិយភិក្ខុធ្វើនេះ ជារបស់មិនសមគួរ ទើបត្រាស់ឲ្យទម្លាយកុដិនោះចោល គឺទ្រង់ត្រាស់ឲ្យទម្លាយចោល ព្រោះជាទង់របស់តិរ្ថិយ ។

ក្នុងអធិការពោលដោយការទម្លាយកុដិនេះ មានវិនិច្ឆ័យប៉ុណ្ណេះ ។ ឯក្នុងអដ្ឋកថា អាចារ្យទាំងឡាយ ពោលហេតុច្រើនយ៉ាងដទៃទៀតជាដើមថា ដើម្បីអាណិតអាសូរសត្វ ដើម្បីត្រូវការរក្សាបាត្រ និងចីវរ ដើម្បីរារាំងភាពជាអ្នកមានសេនាសនៈច្រើន ។ ព្រោះដូច្នោះ ក្នុងឥឡូវនេះ ភិក្ខុអង្គណាជាពហុស្សូត ដឹងព្រះវិន័យ ឃើញភិក្ខុអង្គដទៃ ដែលកាន់បរិក្ខារជាអកប្បិយៈកំពុងត្រាច់ទៅ គួរឲ្យលោកកាត់ ឬទម្លាយបរិក្ខារដែលមិនគួរនោះចេញ ភិក្ខុអង្គនោះ បុគ្គលណាមួយលើកទោសឡើងពោលមិនបាន ចោទមិនបាន ឲ្យរឭកនូវកំហុសមិនបាន ទាំងបុគ្គលណាមួយ ក៏មិនអាចពោលដល់លោកថា លោកធ្វើឲ្យបរិក្ខាររបស់ខ្ញុំវិនាសហើយ ចូរឲ្យបរិក្ខារនោះដល់ខ្ញុំវិញ ។

## វិនិច្ឆ័យក្នុងចាលិមុត្តក
## រឿង ការប្រើជត្រ និង ចីវរ

ក្នុងអធិការពោលដោយទុតិយបារាជិកនេះ មានវិនិច្ឆ័យបរិក្ខារដែលជាកប្បិយៈ និងអកប្បិយៈក្រៅអំពីបាលីដូចតទៅនេះថា

បុគ្គលពួកខ្លះយកអំបោះ ៥ ពណ៌ ដេរឆត្រស្ទឹកត្នោតឲ្យជាប់គ្នា ទាំង

ខាងក្នុងខាងក្រៅ ហើយធ្វើឲ្យមានពណ៌វិលើបរលោង ឆត្រដូច្នោះ មិនគួរ តែបើយកអំបោះឯណានីមួយ ទោះខៀវ ឬលឿង ដែលមានពណ៌តែមួយ៉ាង ដេរភ្ជាប់គ្នាទាំងខាងក្នុង និងខាងក្រៅ ឬចងគ្រោងឆត្រភ្ជាប់នឹងដង ក៏គួរ ។ ឯការដេរ និងការចងរួមគ្នានោះ ដើម្បីធ្វើឲ្យរឹងមាំ ក៏គួរ បើដើម្បីធ្វើឲ្យមានពណ៌ចើតឆាយមិនគួរ ក្នុងសន្ទឹកឆត្រ បើកាត់ជាក្បាច់ធ្មេញមករក្តី រូបព្រះចន្ទពាក់កណ្តាលក្តី មិនគួរ ។ ត្រង់ដងឆត្រ បើមានរូបក្អមទឹកក្តី រូបសត្វសាហាវក្តី ដូចដែលគេធ្វើទុកក្នុងសសរផ្ទះមិនគួរ ។ បើត្រង់ដងទាំងអស់ គេយកដែកចារគូសក្បាច់ក្បូរទុកសោត សូម្បីក្បាច់ក្បូរនោះក៏មិនគួរ ។ រូបក្អមក្តី រូបសត្វសាហាវក្តី គួរទម្លាយជាមុន សឹមប្រើ ។ គួរកោសក្បាច់-ក្បូរនោះចេញ ឬយកអំបោះរុំដងចេញ ។ តែត្រង់គល់ដង សូម្បីមានសណ្ឋានដូចផ្សិតក្បាលពស់ក៏គួរ ។ ពួកជាងធ្វើឆត្រយកខ្សែចងរង្វង់របស់ឆត្រ ចងភ្ជាប់ទៅនឹងដង ដើម្បីការពារមិនឲ្យរយីករយាក ព្រោះត្រូវខ្យល់បក់ ។ ក្នុងទីដែលចងទុកនោះ គេលើកតាំងក្បាច់ក្បូរនោះទុក ដូចវល័យ ( កម្រង ) ក្បាច់ក្បូរនោះគួរ ។ ពួកភិក្ខុយកអំបោះពណ៌ផ្សេងៗ ដេរជារូបដូចជារូបក្អែបជាប់នឹងសំពត់បន្ថែមក្តី ធ្វើរូបប្លែកៗ ដែលដេរដោយម្ជុលឯណាមួយទុកក្តី រូបផ្កាងសក់ ឬរូបប្រវាក់ទុកត្រង់ទីបំផុត ឬត្រង់ជាយសំពត់ ដើម្បីលម្អសំពត់ វិធីដែលពោលមកហើយជាដើមទាំងអស់នោះ រមែងមិនគួរ ។ ការដេរដោយម្ជុលតាមប្រក្រតីនោះឯង ទើបគួរ ។ គេធ្វើក្តុំ និងអន្ទាក់ក្តុំទុក ៨ ជ្រុងខ្លះ ១៦ ជ្រុងខ្លះ ដែលក្តុំ និងអន្ទាក់ក្តុំនោះ ក៏រចនារូបផ្សេងៗ មានរូបដូចចេតិយ

ឈ្មោះអគ្គិយ រូបដំបង និងរូបអន្ទងជាដើមទុក ដេរលើកជារូបក្អែកក្តាមទុក វិធីធ្វើទាំងអស់មិនគួរ ធ្វើក្តី និងអន្ទាក់ក្តីទុកត្រឹម ៤ ជ្រុងប៉ុណ្ណោះគួរ ។

## វិធី ចោកគក់ និងជ្រលក់ចីវរ

អំបោះជាយ និងកំណួច ជារបស់ដែលដឹងបានលំបាកក្នុងកាលជ្រលក់ចីវរ ( លំបាកជ្រលក់ ) ហើយសមគួរ ( មិនបាច់ជ្រលក់ក៏បាន ) ។ បើដាក់ចីវរចុះក្នុងទឹកផ្សេងៗ មានទឹកម្សៅផ្អូម និងទឹកបាយជាដើម មិនគួរ តែក្នុងវេលាធ្វើចីវរ បើដាក់ចុះដើម្បីបោកក្អែលដៃ និងប្រេះមួលជាដើម និងក្នុងវេលាដែលចីវរស្មោកគ្រោក ទោះដាក់ដើម្បីបោកឲ្យស្អាតក៏គួរ បើដាក់របស់ក្រអូប ល័ក្ត ឬប្រេងចុះក្នុងទឹកជ្រលក់ មិនគួរ ។ ភិក្ខុជ្រលក់ចីវរ មិនគួរយកស័ង្ខ ឬកែវមណី ឬវត្ថុឯណានីមួយវាយចីវរឡើយ មិនគួរលុតជង្គង់ទាំងពីរត្រង់ផែនដី ហើយយកដៃទាំងពីរចាប់ចីវរ ត្រដុសត្រង់ស្នូកជ្រលក់ តែបើដាក់ចីវរទុកត្រង់ស្នូក ឬលើបន្ទះក្តារ ហើយចាប់ជាយទាំងពីររួមគ្នាទុក យកដៃវាយ សមគួរ ។ សូម្បីការវាយនោះ ក៏មិនគួរយកកណ្តាប់ដៃវាយឡើយ តែព្រះថេរៈក្នុងកាលមុនទាំងឡាយ មិនបានដាក់ចីវរសូម្បីត្រង់ស្នូកជ្រលក់ឡើយ គឺមួយអង្គយកដៃចាប់ចីវរឈរ មួយអង្គទៀត ដាក់ចីវរលើដៃ ហើយទើបយកដៃវាយ មិនគួរវាយសរសៃអំបោះត្រង់ជាយចីវរឡើយ ។ ក្នុងវេលាជ្រលក់រួចហើយ គួរកាត់ចោល ។ ចំណែកអំបោះដែលព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវខ្សែសម្រាប់ចងជាយចីវរ ដូច្នេះនោះ គួរធ្វើឲ្យជាអន្ទាក់ចងទុកត្រង់អនុវាត

ដើម្បីសន្ទឹងចីវរក្នុងវេលាជ្រលក់ ។ សូម្បីត្រង់ក្ដាំដែលមានក្បាច់ក្បូរ ឬចិតឲ្យផុសដើម្បីធ្វើឲ្យស្អាត មិនគួរ ត្រូវទម្លាយជាមុនសិន ទើបគួរប្រើប្រាស់ ។

## បរិក្ខារដែលគួរប្រើ និង មិនគួរប្រើ

ឯបាត្រ ឬស្ពោកបាត្រ បើយកដែកចារគូរក្បាច់ក្បូរ ឬគូរទុកទាំងខាងក្នុង និងខាងក្រៅក៏ដោយ ក្បាច់ក្បូរនោះ មិនគួរ បើលើកបាត្រឡើងក្រឡឹងឲ្យរលោង ហើយទើបដុត ដោយគិតថា នឹងធ្វើឲ្យមានពណ៌ដូចកែវមណី មិនគួរ ។ ចំណែកបាត្រដែលមានពណ៌ដូចប្រេង គួរ ។ បើក្នុងជើងបាត្រដែលមានរូបភាពបុរសជាដើម មិនគួរ បើជារូបធ្មេញមករ គួរ ។

សម្រាប់ធម្មក្រក និងឆត្រ បើមានក្បាច់ក្បូរខាងលើ ឬខាងក្រោម ឬខាងក្នុងបំពង់ធម្មក្រកក៏ដោយ មិនគួរ ។ តែឆត្រនោះ ទោះមានក្បាច់ក្បូរត្រង់រឹមជុំវិញឆត្រ គួរ ។

ដើម្បីឲ្យវត្ថពន្ធចង្កេះស្អាត និងវាយឲ្យរីកឡើងជាពីរជង ក្នុងទីនោះៗ គឺធ្វើឲ្យប៉ោងឡើង ជាក្បាច់ភ្នែកក្ដាម សេចក្ដីនោះមិនគួរ ។ តែត្រង់ចុងសងខាង បើវាយឲ្យប៉ោងឡើងជាពីរជង ដើម្បីភាពរឹងមាំនៃជាយសំពត់ គួរ ។ ចំណែកជាយសំពត់ នឹងធ្វើរូបប្លែកៗ ឯណានីមួយ ជារូបក្អមក៏ដោយ រូបក្បាលមករក៏ដោយ រូបក្បាលពស់ទឹកក៏ដោយ មិនគួរ ។ សូម្បីវត្ថពន្ធចង្កេះដែលគេរចនាក្បាច់ភ្នែកដំរី ឬដែលគេដំធ្វើជារូបក្ដិផ្កាជាដើមក្នុងទីនោះៗ មិនគួរ ។ តែបើដំធ្វើជាក្បាច់ព្រុយបបែលក៏ដោយ ជាស្លឹកលម៉ើក៏ដោយ ជាផ្ទាំងសំពត់ដែលរលីងក៏ដោយ ត្រង់ៗ ប៉ុណ្ណោះ គួរ ។ វត្ថពន្ធចង្កេះ ជាយ ១

សមគួរ សូម្បីមានជាយ ២-៣-៤ ក៏សមគួរ លើសជាងនោះទៅ មិនគួរ ។ វត្ថពន្ធចង្កេះដែលធ្វើដោយខ្សែមួយសរសៃប៉ុណ្ណោះ ទើបគួរ បើមានសណ្ឋានដូចខ្សែសង្វារ សូម្បីមួយសរសៃក៏មិនគួរ ។ តែជាយរបស់វាមានសណ្ឋានដូចសង្វារក៏គួរ ។ វត្ថពន្ធចង្កេះដែលគេយកខ្សែច្រើនសរសៃ ផ្គុំគ្នាទុក ហើយយកខ្សែមួយសរសៃទៀត រុំព័ទ្ធគ្រប់ៗ ចន្លោះ មិនគួរ ហៅថា ជាវត្ថពន្ធចង្កេះដែលមានខ្សែច្រើនសរសៃ ។ ការចងវត្ថពន្ធចង្កេះ ដែលមានខ្សែច្រើនសរសៃនោះ គួរ ។

ត្រង់ក្រវិលរបស់វត្ថពន្ធចង្កេះ បើមានរូបប្លែកៗ ឯណានីមួយ មានរូបមង្គល ៨ ( គឺសង្ខ ចក្រ ក្អមទឹកដែលពេញ ស៊ីងគយា កូនគោមានសិរីកង្វេរ ទង់ សំពត់ប្រណីត ) ជាដើម មិនគួរ បើមានត្រឹមតែស្នាមល្មមៗ ជាគ្រឿងកំណត់ គួរ ។ ក្នុងជាយទាំងពីររបស់ក្រវិល គេធ្វើជារូបក្អមទឹកទុក ដើម្បីធ្វើឲ្យរឹងមាំ រូបក្អមនេះក៏គួរ ។

## ក្លាក់ថ្នាំបន្តក់ភ្នែកដែលគួរប្រើ និង មិនគួរប្រើ

ឯក្លាក់ថ្នាំបន្តក់ភ្នែក បើមានរូបស្ត្រី បុរស សត្វចតុប្បាទ និងរូបបក្សីក៏ដោយ ទោះមានរូបប្លែកៗ ប្រភេទដទៃ មានភ្ញីផ្កា ភ្ញីវល្លិ ធ្មេញមករគោមូត្រ និងរូបព្រះចន្ទពាក់កណ្ដាលក៏ដោយ មិនគួរ ។ រូបត្រង់ក្លាក់ថ្នាំបន្តក់ភ្នែក គួរកោស ឬចៀរចេញ ឬយកអំបោះរុំទុក ដោយអាការដែលរូបប្រាកដមិនបាន គប្បីប្រើប្រាស់ចុះ ។ ចំណែកក្លាក់ថ្នាំបន្តក់ភ្នែក ៤ ជ្រុង ៨ ជ្រុង ឬ ១៦ ជ្រុងត្រង់ ៗ ប៉ុណ្ណោះ ទើបគួរ ។ ខាងក្រោមក្លាក់ថ្នាំបន្តក់ភ្នែកនោះ ទោះ

មានគូទខ្ទៅមូលៗ ទុកត្រឹម ២-៣ ជាន់ក៏គួរ ។ សូម្បីត្រង់មាត់ក្វាក់ថ្នាំបន្តក់ភ្នែកនោះ ទោះមានគូទខ្ទៅមូលៗ ត្រឹមមួយកន្លែងដើម្បីមូលគម្របបិទក៏គួរ ។ សូម្បីចង្កឹះថ្នាំបន្តក់ភ្នែក មានក្បាច់ក្បូរដែលមានពណ៌រលើបរលោង មិនគួរ ។ សូម្បីថង់ដាក់ក្វាក់ថ្នាំបន្តក់ភ្នែក មានក្បាច់ក្បូរ មានពណ៌រលើបរលោងដោយអំបោះមានពណ៌ផ្សេងៗ ប្រភេទណាមួយ មិនគួរ ។

## ស្រោមសោ និងបកិណ្ណកបរិក្ខារ

សូម្បីស្រោមសោ ក៏មានន័យដូច្នេះដូចគ្នា ។ ត្រង់តួសោ បើមានក្បាច់ក្បូរ ដែលមានពណ៌រលើបរលោង មិនគួរ ។ ឯស្រោមកាំបិតកោរក៏ដូចគ្នា ។ម្យ៉ាងទៀត ត្រង់ស្រោមកាំបិតកោរនេះ ទោះធ្វើអំពីអ្វីក៏ដោយ ដែលដេរដោយអំបោះមានពណ៌តែមួយ ឯណានីមួយ គួរ ។

សូម្បីដែកចារ ដែលមានក្បាច់ផុសមូលៗ ឬវត្ថុដទៃដែលមានពណ៌រលើបរលោងក៏ដោយ មិនគួរ ។ ចំណែកត្រង់កដែកចារ ទោះមានក្បាច់ក្បូរជាគ្រឿងកំណត់ គួរ ។

ឯកន្ត្រៃ បើដាក់ពកកែវ ឬក្បាច់ផុសប្រភេទណានីមួយទុកក៏ដោយ មិនគួរ ។ ចំណែកដង បើមានក្បាច់ល្អមជាគ្រឿងកំណត់ គួរ ។ កាំបិតកាត់ក្រចកដែលគេធ្វើឲ្យមានស្នាមគំនូសទុកប៉ុណ្ណោះ ព្រោះដូច្នោះ ការធ្វើឲ្យមានស្នាមគំនូសនោះ រមែងគួរ ។

ឯឈើក្លួតភ្លើងបន្ទះឈ្មោលក្តី បន្ទះញីក្តី កូនធ្នូក្តី លើខ្នង ( ឈើក្លួតភ្លើងនោះ ) ក្តី បើមានក្បាច់ក្បូរឯណានីមួយ ដូចជា ភ្ញីផ្កាជាដើម ដែល

មានពណ៌រលើបរលោង មិនគួរ ។ ចំណែកត្រង់កណ្ដាលដង មានវង់មូល ត្រង់វង្វង់នោះ ទោះមានធ្មួតល្មមជាគ្រឿងកំណាត់ក៏គួរ ។ ពួកជនធ្វើចន្ទាស សម្រាប់ចាប់ម្ជុលទុក ។ ត្រង់ចន្ទាសសម្រាប់ចាប់ម្ជុលនោះ បើមានក្បាច់ក្បូរ ឯណានីមួយ ដូចជា ក្បាច់ធ្មេញមករជាដើម ដែលមានពណ៌រលើបរលោង មិនគួរ ។ តែដើម្បីឲ្យចាប់ម្ជុលជាប់ នឹងមានត្រឹមតែមាត់ក៏បាន មាត់មករ នោះ រមែងគួរ ។

សូម្បីកាំបិតសម្រាប់កាត់ឈើជម្រះធ្មេញ មានក្បាច់ក្បូរឯណានីមួយ ដែលមានពណ៌រលើបរលោង មិនគួរ ។ ទាំងសងខាង ឬម្ខាងៗ ( របស់កាំបិតនោះ ) បើយកលោហៈដែលជាកប្បិយៈចងទុកជា ៤ ជ្រុង ឬជា ៨ ជ្រុងត្រង់ៗ នោះឯង ទើបគួរ ។

សូម្បីត្រង់ឈើប្រត់ បើមានក្បាច់ក្បូរឯណានីមួយ ដែលមានពណ៌រលើបរលោង មិនគួរ ។ ខាងក្រោម ទោះមានក្បាច់គូទខ្ទៅមូលៗ ទុកមួយកន្លែង ឬពីរកន្លែង និងខាងលើ ទោះមានត្រឹមតែរូបផ្សិតក្បាលពស់ក្រពុំទុក ក៏គួរ ។

បណ្ដាភាជនៈប្រេង រូបដ៏សេសទាំងអស់ដែលមានក្បាច់ក្បូរ រលើបរលោងត្រង់ភាជនៈក្ដី នាឡិក្ដី សម្បកឃ្មោកក្ដី ផ្ដិលមានទ្រង់ទ្រាយដូចផ្លែកន្ទួតព្រៃក្ដី វៀររូបស្ត្រី និងបុរសចេញ រមែងគួរ ។

ក្នុងបណ្ដារបស់របរប្រើប្រាស់ផ្សេងៗ ទាំងនេះ គឺគ្រែ តាំង ពូក ខ្នើយ កម្រាលផែនដី កំណាត់ជូតជើង ពូកក្រាលទីចង្ក្រម អំបោស ជាលសម្រាប់

ដាក់សំរាម ស្នូកជ្រលក់សំពត់ ត្រឡោកផឹកទឹក ក្អមទឹក ក្បៀនជូតជើង តាំងក្តារ ជើងវល័យ ជើងទម្រឈើស្តឹង គម្របបាត្រ ផ្ចិតវាលវីជនី ទោះបីមានក្បាច់ក្បូរ មានពណ៌រលើបរលោង មានភ្ញីផ្កាជាដើមទាំងអស់ក៏គួរ ។

ចំណែកក្នុងសេនាសនៈ ត្រង់បន្ទះទ្វារ និងបន្ទះបង្អួចជាដើម ទោះបីមានក្បាច់ក្បូរ មានពណ៌រលើបរលោង ដែលសម្រេចដោយកែវទាំងអស់ ក៏គួរ ។ ក្នុងសេនាសនៈមិនមានក្បាច់ក្បូរ ក៏គួរ ។ ក្នុងសេនាសនៈមិនមានក្បាច់ក្បូរណាៗ ដែលគួរហាមទុក វៀរលែងតែសេនាសនៈដែលខុស ។

## សេនាសនៈដែលខុស គួរកម្ទេចចោល

សេនាសនៈដែលពួកភិក្ខុជាភេជលុក្ខៈ ធ្វើទុកក្នុងដែនរបស់ម្ចាស់ដែនដទៃ ហៅថាសេនាសនៈដែលខុស ។ ព្រោះដូច្នោះ ពួកភិក្ខុដែលសាងសេនាសនៈដូច្នោះ ដែលភិក្ខុជាម្ចាស់ទីកន្លែង គប្បីជាស់តឿនថា ពួកលោកកុំសាងសេនាសនៈទុកក្នុងកន្លែងរបស់ខ្ញុំឡើយ ( បើ ) មិនស្តាប់នៅតែចចេសធ្វើ នោះឯង គប្បីជាស់តឿនដដែលទៀតថា ពួកលោកកុំធ្វើយ៉ាងនេះ កុំធ្វើអន្តរាយដល់ឧបោសថ និងបវារណារបស់ពួកខ្ញុំ កុំបំបែកសាមគ្គី សេនាសនៈដែលពួកអ្នកកសាងហើយ នឹងមិនតាំងនៅក្នុងទីដែលពួកអ្នកសាងទុកឡើយ បើនៅតែសាងតាមអំពើចិត្តតទៅទៀត វេលាណាម្ចាស់របស់ទីកន្លែងនោះ មានលជ្ជីបរិស័ទកើនចម្រើនឡើង ទាំងអាចបានពាក្យវិនិច្ឆ័យដែលត្រូវតាមធម៌ វេលានោះ គួរបញ្ជូនដំណឹងដល់ភិក្ខុទាំងនោះថា ចូរជញ្ជូនយកទីលំនៅ របស់ពួកអ្នកទៅចុះ កាលបើបញ្ជូនដំណឹងដល់ទៅ ៣

ជនហើយ ភិក្ខុទាំងនោះរើចេញទៅ សេចក្ដីនុ៎ះជាការល្អ ។ បើមិនព្រមរើទៅសោត សេនាសនៈដ៏សេស គួរកម្ទេចចោល វៀរលែងតែព្រះពោធិព្រឹក្ស និងចេតិយ ហើយកុំកម្ទេចឲ្យទៅជារបស់ដែលប្រើការមិនបាន ។ ម្យ៉ាងទៀត គួរនាំវត្ថុផ្សេងៗ មានគ្រឿងប្រក់ជំបូលដែរណែង បង្អួច និងឥដ្ឋជាដើមចេញទៅតាមលំដាប់ ហើយគួរបញ្ជូនដំណឹងដល់ភិក្ខុទាំងនោះថា សូមជញ្ជូនទព្វសម្ភារៈរបស់ពួកអ្នកទៅចុះ បើជញ្ជូនទៅសោត សេចក្ដីនោះជាការល្អ បើមិនជញ្ជូនទៅទេ កាលសម្ភារៈទាំងនោះពុកផុយទៅ ព្រោះសន្សើម ភ្លៀង និងកម្ដៅថ្ងៃជាដើមក្ដី ពួកចោរលួចយកទៅក្ដី ត្រូវភ្លើងឆេះក្ដី ពួកភិក្ខុជាម្ចាស់ទីកន្លែងបុគ្គលណាមួយ នឹងពោលទោសមិនបាន ទាំងមិនអាចនឹងចោទថា ពួកលោកធ្វើឲ្យទព្វសម្ភារៈរបស់ពួកខ្ញុំវិនាសហើយ ឬថា ត្រូវពិន័យឲ្យពួកលោកសងដូច្នេះ ។ ឯកិច្ចណាដែលភិក្ខុជាម្ចាស់ទីកន្លែងធ្វើហើយ កិច្ចនោះ គឺ ពួកលោកធ្វើត្រឹមត្រូវហើយ ដូច្នេះឯង ។

បាលីមុត្តកវិនិច្ឆ័យ ចប់

# ធនិយភិក្ខុដើមសាងកុដិឈើ

[ ៨០ ] ដើម្បីសម្តែងដល់ការរំពឹង និងភាពឧស្សាហ៍ ដើម្បីសាងកុដិទៀតនោះឯងរបស់ធនិយភិក្ខុ ក្នុងកាលកុដិត្រូវកម្ទេចហើយយ៉ាងនោះ ទើបព្រះធម្មសង្គាហកាចារ្យបានពោលពាក្យថា **អថខោ អាយស្មតោ** ជាដើម ។

ក្នុងពាក្យថា **អាយស្មតោ** ជាដើម មានវិនិច្ឆ័យដូច្នេះថា បទថា **ទារុគហោគណកោ** បានដល់ នាយក្នាក់ងាររក្សាឈើ ក្នុងឃ្លាំងឈើរបស់ស្តេច ។

បទថា **ទេវគហណទារូនិ** បានដល់ ឈើដែលទាហានស្តេចចាប់ចងទុក អធិប្បាយថា ឈើដែលព្រះរាជាទ្រង់រក្សាទុក ។

បទថា **នគរបដិសង្ខារិកានិ** បានដល់ ឈើជាគ្រឿងឧបករណ៍សម្រាប់ទំនុកបម្រុងព្រះនគរ ។

ពីរបទថា **អាបទត្ថាយ និក្ខិត្តានិ** អធិប្បាយថា បានដល់ ឈើដែលរក្សាទុកដើម្បីការពារវិបត្តិនៃវត្ថុទាំងឡាយ មានខ្លោងទ្វារ ប៉មព្រះរាជវាំង និងរោងដំរីជាដើម ព្រោះត្រូវភ្លើងឆេះ ព្រោះការចាស់ទ្រុឌទ្រោម ឬព្រោះការឈ្លានពានរបស់ព្រះរាជាដែលជាសត្រូវជាដើម ដែលលោកហៅថា អន្តរាយ។

ពីរបទថា **ខណ្ឌាខណ្ឌិកំ ឆេទាបេត្វា** សេចក្តីថា ធនិយភិក្ខុកំណត់ប្រមាណកុដិរបស់ខ្លួនហើយ ប្រាប់ឲ្យធ្វើការកាត់ឈើដើមខ្លះត្រង់ចុង ដើមខ្លះត្រង់កណ្តាល ដើមខ្លះត្រង់គល់ឲ្យជាកំណាត់តូចធំ ( ដាក់ពេញរទេះនាំទៅធ្វើកុដិឈើហើយ ) ។

[ ៨១ ] ពាក្យថា **វស្សការ** ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។

បទថា **មគធមហាមត្តោ** បានដល់ មហាមាត្យ គឺដែលប្រកបដោយលំដាប់ឥស្សរិយយសដ៏ធំក្នុងមគធរដ្ឋ ឬ អមាត្យធំរបស់ស្តេច ផែនដីនគរមគធៈ អធិប្បាយថា ជាអមាត្យធំ ។

បទថា **អនុសញ្ញាយមានោ** សេចក្តីថា វស្សការព្រាហ្មណ៍ទៅពិនិត្យមើលក្នុងទីនោះៗ ។ បទថា **ភណេ** សេចក្តីថា ជាពាក្យរបស់ឥស្សរជន ហៅអ្នកដែលតាំងនៅក្នុងឋានៈទាប ។ ពីរបទថា **ពន្ធំ អាណាបេសិ** សេចក្តីថា ព្រាហ្មណ៍ សូម្បីដោយប្រក្រតីក៏ជាអ្នកមានសេចក្តីប្រណែន ក្នុងនាយក្នាក់ងាររក្សាឈើនោះឯង លុះព្រាហ្មណ៍បានស្តាប់ព្រះរាជតម្រាស់ថា ចូរឲ្យមនុស្សនាំខ្លួនមក ដូច្នេះ តែព្រោះរាជាទ្រង់មិនបានបញ្ជាថា ចូរឲ្យហៅបុរសនោះមក ដូច្នោះ ទើបធ្វើការចាប់ចងនាយក្នាក់ងារអ្នករក្សាឈើនោះ ត្រង់ដៃ និងជើងទាំងពីរ ហើយគិតថា នឹងឲ្យដាក់ទោស ទើបចងទុក ។

[ ៨២ ] ក្នុងពាក្យថា **អទ្ទសា ខោ អាយស្មា ធនិយោ** នោះ សួរថា ធនិយភិក្ខុបានឃើញនាយក្នាក់ងារអ្នករក្សាឈើ ត្រូវអ្នកជំចងនាំទៅ ដោយអាការ ដូចម្តេច ?

ឆ្លើយថា បានឮថា ធនិយភិក្ខុនោះ ជ្រាបថា រឿងនេះកើតព្រោះឈើដែលនាយក្នាក់ងារនាំទៅប្រគេនដោយលេសរបស់ខ្លួន គិតថា នាយក្នាក់ងារម្នាក់នេះ នឹងត្រូវសម្លាប់ ឬដាក់ខ្នោះឃ្នាងអំពីរាជត្រកូល ព្រោះហេតុនៃឈើទាំងឡាយដោយឥតសង្ស័យ ទើបគិតឡើងក្នុងវេលានោះថា អញម្នាក់ប៉ុណ្ណោះ នឹងដោះនាយក្នាក់ងារម្នាក់នោះបាន ហើយត្រាច់ឃ្លាំស្តាប់ដំណឹងនៃ

នាយក្នាក់ងារនោះជានិច្ចកាលនោះឯង ព្រោះដូច្នោះ ទើបធនិយភិក្ខុបានទៅជួបនាយក្នាក់ងារម្នាក់នោះក្នុងខណៈនោះឯង ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលទុកថា **អថខោ អាយស្មា ធនិយោ** ដូច្នេះជាដើម ។

ពីរបទថា **ទារូនំ កិច្ចា** សេចក្តីថា ព្រោះហេតុនៃឈើទាំងឡាយ ។

ពីរបទថា **បុរាហំ ហាញ្ញាមិ** សេចក្តីថា ខ្ញុំត្រូវបណ្តេញចេញពីបុរី ។ អធិប្បាយថា លោកម្ចាស់គួរទៅ ទាន់ពេលដែលខ្ញុំមិនទាន់ត្រូវបណ្តេញចេញ។ ស័ព្ទថា **ឥង្ឃ** ក្នុងពាក្យថា **ឥង្ឃ ភន្តេ សរាបេហិ** នេះ ជានិបាត ចុះក្នុងអត្ថថា ទាក់ទង ។ បទថា **បឋមាភិសិត្តោ** សេចក្តីថា កាលព្រះអង្គសោយរាជ្យតាំងពីដំបូង ។

ច្រើនបទថា **ឯវរូបឹ វាចំ ភាសិតា** សេចក្តីថា កាលព្រះអង្គទ្រង់អភិសេកមុនដំបូងនោះឯង ទ្រង់បានបន្លឺព្រះវាចាដូច្នេះថា ស្មៅ ឈើ និងទឹករបស់ខ្ញុំប្រគេនដល់សមណព្រាហ្មណ៍ទាំងឡាយហើយដូច្នេះសូមសមណព្រាហ្មណ៍ទាំងឡាយ មេត្តាប្រើប្រាស់ចុះ អធិប្បាយថា សូមថ្វាយព្រះពរ ព្រះអង្គបានត្រាស់វាចាណាទុក ព្រះវាចានោះ ព្រះអង្គត្រាស់ខ្លួនឯងហើយ ឥឡូវនេះ ទ្រង់រឭកបានឬទេ ។

បានឮថា ព្រះរាជាទាំងឡាយ គ្រាន់តែអភិសេកឡើងគ្រងរាជ្យសម្បត្តិប៉ុណ្ណោះ ក៏ទ្រង់បញ្ជាឲ្យដើរវាយស្គរធម្មភេរីប្រកាសថា ស្មៅ ឈើ និងទឹកខ្ញុំប្រគេនដល់សមណព្រាហ្មណ៍ទាំងឡាយហើយ សូមសមណព្រាហ្មណ៍ទាំងឡាយ មេត្តាប្រើប្រាស់ចុះ ដូច្នេះ ធនិយភិក្ខុនេះពោលសំដៅយកព្រះតម្រាស់

នោះ ។

ច្រើនបទថា **តេសំ មយា សន្តាយ ភាសិតំ** អធិប្បាយថា ញោម បានពោលពាក្យយ៉ាងនោះ សំដៅដល់ការនាំយកស្មៅ ឈើ និងទឹកទៅរបស់ សមណព្រាហ្មណ៍ទាំងនោះ ដែលមានសេចក្តីវៀស សូម្បីក្នុងហេតុបន្តិច បន្តួច ដែលជាអ្នកស្ងប់ និងបន្សាត់បាបហើយ មិនបានសំដៅយកការនាំទៅ របស់បុគ្គលដូចលោកម្ចាស់ឡើយ ។

ច្រើនបទថា **តញ្ច ខោ អរញ្ញេ អបរិគ្គហិតំ** សេចក្តីថា ព្រះបាទ ពិម្ពិសារទ្រង់សម្តែងព្រះបំណងថា ការនោះ ញោមពោលសំដៅយកស្មៅ ឈើ និងទឹកឯណាៗ ដែលមិនបានហួងហែង ដែលមាននៅក្នុងព្រៃឯណោះទេ ។

ក្នុងពាក្យថា **លោមេន ត្វំ មុត្តោសិ** នេះ មានវិនិច្ឆ័យដូច្នេះថា គុណ-ជាតដូចជារោម ឈ្មោះថា រោម ឯរោមនោះ គឺអ្វី គឺបព្វជ្ជាភេទ ។ ព្រះបាទ ពិម្ពិសារទ្រង់ត្រាស់ទុកដូចម្តេច ត្រាស់អធិប្បាយទុកយ៉ាងនេះថា ប្រៀបដូច ពួកអ្នកលេងប្រឹក្សាគ្នាថា ពួកយើងនឹងទំពាស៊ីសាច់ ហើយទើបចាប់ពពែ មួយក្បាល មានរោមដ៏មានតម្លៃច្រើនទុក បុរសអ្នកចេះដឹងម្នាក់ឃើញពពែ ដែលត្រូវចាប់ទុកនោះ ទើបគិតថា សាច់ពពែនេះ មានតម្លៃត្រឹមមួយកហា-បណៈ តែរោមរបស់វា មួយសរសៃៗ មានតម្លៃច្រើនកហាបណៈ ទើបបាន ឲ្យពពែ ដល់ពួកអ្នកលេងពីរក្បាលដែលមិនមានរោម ហើយគប្បីទទួលយក ពពែមួយ ដែលមានរោមនោះទៅ ដោយអាការយ៉ាងនេះ ទើបពពែមួយនោះ រួចផុតដោយរោម ព្រោះអាស្រ័យបុរសចេះដឹង សេចក្តីនេះយ៉ាងណា

ខ្ជួនលោកម្ចាស់ ក៏ដូច្នោះដូចគ្នា ជាអ្នកត្រូវសម្លាប់ និងចាប់ចង ព្រោះធ្វើកម្មនេះ តែព្រោះលោកម្ចាស់មានទង់ជ័យព្រះអរហន្ត មានសភាពដែលសប្បុរសមិនគប្បីមើលងាយបាន និងព្រោះលោកម្ចាស់បួសក្នុងព្រះសាសនាទ្រទ្រង់ទុកនូវទង់ជ័យនៃព្រះអរហន្ត ជាភេទអ្នកបួស ហេតុនោះ ទើបលោកម្ចាស់រួចខ្លួនដោយពេក គឺភេទអ្នកបួសនេះ ដូចពពែរួចខ្លួនដោយរោម ព្រោះអាស្រ័យបណ្ឌិតបុរស ដូច្នោះ ។

[ ៨៣ ] ពីរបទថា **មនុស្សា ឧជ្ឈាយន្តិ** សេចក្តីថា កាលព្រះរាជាទ្រង់ប្រាប់ក្នុងបរិស័ទ មនុស្សទាំងឡាយក្នុងទីកន្លែងនោះៗ កាលបានស្តាប់ព្រះរាជតម្រាស់ ចំពោះព្រះភក្ត្រ និងកំបាំងព្រះភក្ត្រហើយ រមែងសម្លឹងទោស គឺប្រមាថ បានដល់មើលងាយ ក៏សម្លឹងមើលព្រះថេរៈនោះម្យ៉ាងទៀត ដោយអត្ថថា រមែងគិតក្នុងផ្លូវអាក្រក់ ។

បទថា **ខីយន្តិ** សេចក្តីថា រមែងពោល គឺសម្លឹងទោសរបស់ព្រះថេរៈនោះ ។

បទថា **វិបាចេន្តិ** សេចក្តីថា ផ្សាយរឿងឲ្យទូលាយចេញទៅ គឺផ្សព្វផ្សាយឲ្យរីកចេញទៅក្នុងទីគ្រប់កន្លែង ។ ឯអ្នកសិក្សាគួរជ្រាបអត្ថនេះ តាមគន្លងគម្ពីរសព្ទសាស្ត្រ ។

ម្យ៉ាងទៀត ក្នុងពាក្យថា **ឧជ្ឈាយន្តិ** ជាដើមនេះ មានយោជនាដូច្នេះថា គឺមនុស្សទាំងឡាយ កាលគិតដល់រឿងរ៉ាវជាដើមថា សមណសក្យបុត្រនេះជាអ្នកមិនមានខ្មាស ដូច្នេះ ឈ្មោះថា រមែងសម្លឹងទោស កាលពោលពាក្យ

ជាដើមថា សមណសក្យបុត្រទាំងនេះ មិនមានគុណជារបស់សមណៈ ដូច្នេះ ឈ្មោះថា រមែងនិន្ទា កាលផ្សព្វផ្សាយដំណឹងឲ្យទូលំទូលាយចេញទៅក្នុងទីកន្លែងនោះៗ ជាដើមថា សមណសក្យបុត្រទាំងនេះប្រាសចាកភាពជាសមណៈហើយ ដូច្នេះ ឈ្មោះថា រមែងបន្តុះបង្អាប់ ។ បន្ទាប់អំពីនោះទៅ ក៏គួរជ្រាបយោជនានៃបទទាំងនេះតាមសមគួរដល់បទដែលមកហើយក្នុងទីនោះៗ ដោយន័យនេះ ។

បណ្តាបទទាំងនោះ បទថា **ព្រហ្មចារិនោ** គឺអ្នកប្រព្រឹត្តប្រសើរ ក្នុងភាពជាសមណៈ ឈ្មោះសាមញ្ញៈ ។ ភាពជាបុគ្គលប្រសើរ ឈ្មោះព្រហ្មញ្ញៈ ។ ឯពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

ពាក្យថា **រញ្ញោ ទារូនិ** ជាដើម មានវិនិច្ឆ័យដូច្នេះថា អត្ថថាបានកាន់យកឈើរបស់ស្តេចដែលមិនបានព្រះរាជទាន ដូច្នេះ មានការសម្ងំទោសជាអត្ថ ម្យ៉ាងទៀត ដើម្បីសម្តែងដល់ឈើដែលមិនបានព្រះរាជទាន ដែលធនិយភិក្ខុបានកាន់យកហើយនោះ ទើបលោកពោលថា ឈើរបស់ស្តេចជាដើម ។ អ្នកសិក្សាទាំងឡាយ កាលមិនប្រឡំសេចក្តីផ្សេងគ្នានៃវចនៈ ក៏គួរជ្រាបអត្ថដូចអធិប្បាយមកដូច្នេះឯង ។

## ទន្ទប្រជុំសង្ឃបញ្ញត្តសិក្ខាបទ

ពីរបទថា **បុរាណវោហារិកោ មហាមត្តោ** សេចក្តីថា មហាមាត្យដែលដល់នូវការរាប់ថា ចៅក្រម ព្រោះត្រូវតែងតាំងទុកក្នុងវោហារ គឺការកាត់ក្តី ក្នុងកាលមុនអំពីភាពជាភិក្ខុ គឺក្នុងកាលនៅជាគ្រហស្ថ ។

ប្រែនបទថា **អជានា ភគវា តំ ភិក្ខុំ ឯតទវោច** អធិប្បាយថា ព្រះដ៏មានព្រះភាគ ទ្រង់រមែងជ្រាបនូវលោកបញ្ញត្តិដោយព្រះអង្គឯង ទ្រង់រមែងជ្រាបនូវព្រះបញ្ញត្តិនៃព្រះពុទ្ធទាំងឡាយក្នុងអតីតថា ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ទ្រង់រមែងបញ្ញត្តបារាជិកដោយទ្រព្យប៉ុណ្ណេះ ចុល្លច្ច័យដោយទ្រព្យប៉ុណ្ណេះ ទុក្កដដោយទ្រព្យប៉ុណ្ណេះ តែទោះជាដូច្នោះ បើព្រះអង្គទ្រង់មិនប្រៀបធៀបជាមួយមនុស្សដែលដឹងបញ្ញត្តផ្លូវលោកពួកដទៃហើយ ទ្រង់បញ្ញត្តបារាជិកដោយទ្រព្យត្រឹម ១ បាទ ក៏នឹងគប្បីមានអ្នកពោលតិះដៀលព្រះអង្គព្រោះហេតុប៉ុណ្ណោះថា ឈ្មោះថា សីលសំវរៈរបស់ភិក្ខុមួយអង្គក៏ប្រមាណមិនបាន រាប់មិនបាន ទូលំទូលាយពន់ពេក ដូចមហាប្រឹថពី សមុទ្រ និងអាកាស ព្រះដ៏មានព្រះភាគមកញុំាងសីលសំវរៈឲ្យវិនាសបង់ ដោយទ្រព្យត្រឹមតម្លៃ ១ បាទ បន្ទាប់អំពីនោះ ភិក្ខុទាំងឡាយដែលមិនដឹងកម្លាំងព្រះបញ្ញាញាណរបស់ព្រះតថាគត គប្បីញុំាងសិក្ខាបទឲ្យកម្រើក សិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយ ក៏មិនគប្បីតាំងនៅក្នុងទីដ៏សមគួរ ។ តែកាលទ្រង់ប្រៀបជាមួយមនុស្សដែលដឹងបញ្ញត្តផ្លូវលោកហើយ ទើបទ្រង់បញ្ញត្តសិក្ខាបទ ការនិន្ទានោះរមែងមិនមាន រមែងមានតែអ្នកពោលយ៉ាងនេះដោយពិតថា សូម្បីអ្នកគ្រប់គ្រងផ្ទះទាំងនេះ ក៏គង់សម្លាប់ចោរខ្លះ ឃុំឃាំងទុកខ្លះ និរទេសចោលខ្លះ ព្រោះទ្រព្យត្រឹម ១ បាទ ហេតុអ្វី ព្រះដ៏មានព្រះភាគទ្រង់មិនញុំាងបព្វជិតឲ្យវិនាស ព្រោះបព្វជិតមិនគួរលួចទ្រព្យរបស់អ្នកដទៃ សូម្បីត្រឹមស្មៅមួយសរសៃឡើយ ភិក្ខុទាំងឡាយក៏នឹងដឹងកម្លាំងព្រះញាណរបស់ព្រះតថាគតផង

សិក្ខាបទដែលទ្រង់បញ្ញត្តទុកហើយ ក៏មិនកម្រើកផង នឹងតាំងនៅក្នុងទីដ៏គួរ។ ព្រោះដូច្នោះ ទ្រង់មានព្រះបំណង នឹងផ្ទៀងផ្ទាត់ជាមួយអ្នកចេះដឹងបញ្ញត្តផ្លូវលោកហើយ ទើបទ្រង់បញ្ញត្ត ទ្រង់ឆ្លៀងមើលបរិស័ទគ្រប់ពួកក្រុម គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ទតឃើញភិក្ខុនោះដែលអង្គុយនៅក្នុងទីមិនឆ្ងាយ បានត្រាស់ពាក្យនេះនឹងភិក្ខុនោះ ( គឺបានត្រាស់ពាក្យនេះ ) ថា ម្នាលភិក្ខុ ព្រះរាជាដែលជាធំនៃមគធរដ្ឋ ដល់ព្រមដោយសេនា ទ្រង់ព្រះនាមថា ពិម្ពិសារ ចាប់ចោរបានហើយ ទ្រង់សម្លាប់ខ្លះ ទ្រង់ដាក់ពន្ធនាគារខ្លះ និរទេសចោលខ្លះ ព្រោះទ្រព្យប្រមាណប៉ុន្មានណាហ្ន៎ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **មាគធោ** បានដល់ ជាធំនៃអ្នកដែនមគធៈ។ បទថា **សេនិយោ** បានដល់ ដែលដល់ព្រមដោយសេនា ។ ពាក្យថា **ពិម្ពិសារោ** ជាព្រះនាមាភិធេយ្យ ( ឈ្មោះកំណើត ) របស់ព្រះរាជា អង្គនោះ ។

បទថា **បព្វាជេតិ វា** សេចក្ដីថា ទ្រង់ឲ្យចេញទៅអំពីដែន ។ បទដ៏សេសក្នុងពាក្យនេះមានអត្ថរាក់ទាំងអស់ ។

ពីរបទថា **បញ្ចមាសកោ បាទោ** សេចក្ដីថា គ្រានោះ ក្នុងក្រុងរាជគ្រឹះ ២០ មាសក ជា ១ កហាបណៈ ព្រោះដូច្នោះ ទើប ៥ មាសកជា ១ បាទ ។ ដោយលក្ខណៈនោះ ចំណែកទី ៤ របស់កហាបណៈ គប្បីជ្រាបថាជា ១ បាទ ក្នុងជនបទទាំងពួង ឯបាទនោះឯង គប្បីជ្រាបដោយអំណាចនៃនីលកហាបណបុរាណ មិនគប្បីជ្រាបដោយអំណាចនៃកហាបណៈក្រៅអំពីនេះ មានរុទ្រទាមកកហាបណៈជាដើម ។

ព្រះពុទ្ធទាំងឡាយ ក្នុងអតីតកាល ក៏ទ្រង់បញ្ញត្តបារាជិក ដោយតម្លៃ ១ បាទនោះ សូម្បីព្រះពុទ្ធទាំងឡាយ ដែលនឹងមានក្នុងអនាគតក៏ទ្រង់នឹងបញ្ញត្តបារាជិកដោយតម្លៃ ១ បាទនោះ ។ ពិតហើយ ការផ្សេងគ្នាក្នុងវត្ថុបារាជិក ឬ ក្នុងបារាជិក របស់ព្រះពុទ្ធគ្រប់អង្គ រមែងមិនមាន ។ វត្ថុនៃបារាជិក ៤ ក៏ដូចគ្នាទាំងអស់ បារាជិក ៤ ក៏ដូចគ្នាទាំងអស់ មិនមានតិច ឬច្រើនជាងនេះ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់តិះដៀលធនិយភិក្ខុហើយ កាលទ្រង់បញ្ញត្តទុតិយបារាជិកដោយបទនោះឯង ទើបត្រាស់ពាក្យថា **យោ បន ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ** ជាដើម កាលទុតិយបារាជិកដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តធ្វើឲ្យមាំទាំ ដោយអំណាចនៃការខ្វះមូលយ៉ាងនេះហើយ រឿងរជកភណ្ឌិកដទៃទៀត ក៏បានកើតឡើងដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ។ ដើម្បីសម្តែងការកើតឡើងនៃរឿងនោះ ទើបព្រះធម្មសង្គាហកាចារ្យបានពោលពាក្យនេះទុកថា ឯសិក្ខាបទនេះ គឺព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។

អត្ថនៃរឿងនោះ និងការសម្ពន្ធគ្នានៃអនុប្បញ្ញត្ត គប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងបឋមបារាជិកវណ្ណនានោះឯង ។ គ្រប់ៗ សិក្ខាបទបន្ទាប់អំពីសិក្ខាបទនេះទៅ គប្បីជ្រាបដូចក្នុងសិក្ខាបទនេះ ។ ពិតហើយ ពាក្យណាមួយ ដែលខ្ញុំពោលទុកហើយខាងដើម ខ្ញុំនឹងវៀរបង់ពាក្យនោះទាំងអស់ ហើយពណ៌នាចំពោះពាក្យដែលមិនធ្លាប់មានខាងក្រោយ ដែលខ្ពស់ឡើងៗ ទៅប៉ុណ្ណោះ ។ បើខ្ញុំពណ៌នាពាក្យដែលមានន័យដូចពោលហើយ នោះៗ

ដដែលទៀត កាលណាខ្ញុំនឹងដល់ទីបញ្ចប់នៃការពណ៌នាបាន ព្រោះដូច្នោះ អ្នកសិក្សាទាំងឡាយ គួរកំណត់ពាក្យដែលពោលទុកហើយអំពីមុននោះៗ ទាំងអស់ឲ្យល្អ ហើយជ្រាបអត្ថ និងយោជនាក្នុងពាក្យនោះៗ ។ ម្យ៉ាងទៀត ពាក្យឯណានីមួយដែលមិនទាន់ជាប់មានផង មានអត្ថមិនទាន់ភ្លឺច្បាស់ផង ខ្ញុំឯងនឹងពណ៌នាពាក្យទាំងអស់នោះ ។

បឋមបញ្ញត្តិក្នុងទុតិយបារាជិក ចប់

# អនុប្បញ្ញត្តិទុតិយបារាជិក

[ ៨៤ ] ពីរបទថា **រជកត្ថរណំ គន្ត្វា** សេចក្តីថា ទៅកាន់ត្រង់កំពង់ហាលសំពត់របស់ជាងជ្រលក់ ។ ពិតហើយ កំពង់នោះ ហៅថា ទីលានហាលសំពត់របស់ជាងជ្រលក់ ព្រោះត្រង់កំពង់នោះ ជាកន្លែងពួកជាងជ្រលក់លាតសំពត់ហាលទុក ។

បទថា **រជកភណ្ឌកំ** បានដល់ កញ្ចប់របស់ពួកជាងជ្រលក់ ។ វេលាល្ងាចពួកជាងជ្រលក់ កាលត្រឡប់ចូលទៅកាន់ក្រុង ចងសំពត់ច្រើនផ្ទាំងរួមជាកញ្ចប់ទុក ពួកធញ្ញគិយភិក្ខុកាលជាងជ្រលក់ទាំងនោះមិនឃើញ ព្រោះការធ្វេសប្រហែស ក៏បានលួច អធិប្បាយថា លួចយកកញ្ចប់មួយអំពីកញ្ចប់នោះទៅ ។

# អធិប្បាយ
# សិក្ខាបទវិភង្គនៃទុតិយបារាជិក

[ ៨៥ ] មានពាក្យអធិប្បាយយ៉ាងនេះថា **គាមោ ឆាម** ព្រះដ៏មានព្រះភាគត្រាស់ហើយ ដើម្បីសម្តែងប្រភេទនៃស្រុក និងព្រៃ ដែលព្រះអង្គត្រាស់ហើយក្នុងពាក្យនេះថា អំពីស្រុកក្តី អំពីព្រៃក្តី ។ ក្នុងពាក្យថា ស្រុកសូម្បីមានខ្ទមមួយជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ក្នុងភូមិណាមានខ្ទមមួយប៉ុណ្ណោះ ឈ្មោះថា មានផ្ទះមួយ ដូចក្នុងមលយជនបទ ស្រុកនេះឈ្មោះថា ស្រុកមានខ្ទមមួយ ។ ស្រុកដទៃក៏គួរជ្រាបដោយន័យនេះឯង ។ ស្រុកណាជាតំបន់ដែលយក្ខហួងហែង ព្រោះមិនមានពួកមនុស្សដោយប្រការទាំងពួង ឬពួកមនុស្សចង់ត្រឡប់មកទៀត ដោយហេតុខ្វះនោះឯង ក៏ចៀសទៅចេញអំពីស្រុកណា ស្រុកនោះឈ្មោះថា មិនមានមនុស្ស ។ ស្រុកណាដែលគេធ្វើកំពែង រៀបដោយឥដ្ឋជាដើមទុក ដោយហោចសូម្បីហ៊ុមដោយបន្ទា និងមែកឈើ ស្រុកនោះឈ្មោះថា មានរបងព័ទ្ធ ។ ស្រុកណាដែលពួកមនុស្សមិនបានតាំងអាស្រ័យនៅ ដោយអំណាចជាទីកន្លែងស្នាក់នៅរួមគ្នាក្បែរផ្លូវជាដើម តែធ្វើផ្ទះទុក ២-៣ ខ្នង ហើយចូលអាស្រ័យនៅក្នុងទីនោះៗ ដូចគោជេកនៅក្នុងទីនោះៗ ២-៣ ក្បាល ដូច្នោះ ស្រុកនោះឈ្មោះថា ស្រុកថ្មី ដូចជា កន្លែងគោសម្រាកជាដើម ។ បណ្តាពួកអ្នកជួញថ្មើរជើង និងឈ្មួញរទេះ ជាដើមពួកណានីមួយ ឈ្មោះថា សត្ថៈ ។ ម្យ៉ាងទៀត ក្នុងសិក្ខាបទនេះ និគមក្តីស្រុកក្តី គប្បីជ្រាបថា លោកកាន់យកដោយ **គាម** សព្ទនោះ ។

## អធិប្បាយ ឧបចារស្រុក និង ដុះជាដើម

ពាក្យថា ឧបចារស្រុកជាដើម ទ្រង់ត្រាស់ដើម្បីកំណត់ព្រៃ ។

បទពីរថា **ឥន្ទខីលេ ឋិតស្ស** សេចក្តីថា បានដល់ បុរសដែលឈរត្រង់សសរខឿន រួមក្នុងកន្លែងស្រុកដែលមានសសរខឿនពីរដើម ដូចអនុរាធបុរី ដូច្នោះ ។ ពិតហើយ សសរខឿនខាងក្រៅនៃអនុរាធបុរីនោះ ដោយអភិធម្មន័យ រមែងដល់នូវការរាប់ថាជាព្រៃ ។ ម្យ៉ាងទៀត បានដល់ បុរសដែលឈរត្រង់កណ្តាលនៃស្រុកដែលមានសសរខឿនមួយ ឬ ដែលឈរនៅត្រង់កណ្តាលនៃទ្វារស្រុក ។ ពិតហើយ ក្នុងស្រុកណាមិនមានសសរខឿន ត្រង់កណ្តាលនៃទ្វារស្រុក ក្នុងស្រុកនោះឯង ហៅថា សសរខឿន ។ ព្រោះហេតុនោះ ទើបខ្ញុំពោលទុកថា បានដល់ បុរសដែលឈរនៅត្រង់កណ្តាលនៃទ្វារស្រុក ។

បទថា **មជ្ឈិមស្ស** សេចក្តីថា បានដល់ បុរសមានកម្លាំងកណ្តាល មិនមែនបុរសខ្នាតកណ្តាលដែលមានកម្លាំងល្មមប្រមាណឡើយ គឺបុរសដែលមានកម្លាំងតិចក៏មិនមែនដែរ ទាំងមិនមែនបុរសដែលមានកម្លាំងច្រើន អធិប្បាយថា បានដល់ បុរសដែលមានកម្លាំងកណ្តាលមនុស្ស ។

បទថា **លេឌ្ឌុបាតោ** បានដល់ ទីដែលធ្លាក់នៃដុំដីដែលគេមិនបានបោលទៅ ដូចជាមាតុគ្រាម បោលឲ្យពួកក្អែកហើរទៅ ទើបលើកដៃឡើង បោះដុំដីទៅត្រង់ប៉ុណ្ណោះឡើយ ឬដូចពួកភិក្ខុបាចទឹក ទៅក្នុងឱកាសដែលកំណត់ឧទកុក្ខេបសីមាឡើយ តែគ្រវែងទៅដូចបុរសកំលោះៗ នឹងល្បងកម្លាំងរបស់ខ្លួន ទើបលាដៃចេញ គ្រវែងដុំដីទៅ ដូច្នោះ ។ តែមិនគួរកំណត់យកទីដែលដុំដីធ្លាក់ហើយរមៀលទៅនោះឡើយ ។

ក្នុងពាក្យថា បុរសខ្នាតកណ្តាលដែលឈរនៅត្រង់ឧបចារផ្ទះនៃស្រុកដែលមិនបានព័ទ្ធរបង បោលដុំដីធ្លាក់ទៅនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បុរសខ្នាតកណ្តាលដែលឈរនៅត្រង់ទីទឹកធ្លាក់នៃសំយាបផ្ទះ បោះចង្អេរ ឬអង្រែឲ្យធ្លាក់ទៅ ឈ្មោះថា ឧបចារផ្ទះ ។ ក្នុងអដ្ឋកថាកុរុន្ទី លោកពោលទុកថា បុរសខ្នាតកណ្តាល ដែលឈរនៅត្រង់ទីឧបចារផ្ទះនោះ គ្រវែងដុំដីទៅ ដុំដីនោះធ្លាក់ត្រឹមណា ឈ្មោះថា ឧបចារស្រុក ។ សូម្បីក្នុងអដ្ឋកថាមហាបច្ចរី លោកក៏ពោលទុកដូច្នោះដូចគ្នា ។ម្យ៉ាងទៀត ក្នុងមហាអដ្ឋកថា លោកតាំងមាតិកាទុកថា ឈ្មោះថា ផ្ទះ ឈ្មោះថា ឧបចារផ្ទះ ឈ្មោះថា ស្រុក ឈ្មោះថា ឧបចារស្រុក ហើយពោលថា ខាងក្នុងទីទឹកស្រក់នៃសំយាបផ្ទះ ឈ្មោះថា ផ្ទះ ។ ចំណែកទីធ្លាក់នៃទឹកលាងចាន ដែលមាតុគ្រាមឈរនៅត្រង់ទ្វារជះបោលធ្លាក់មក និងទីធ្លាក់នៃចង្អេរ ឬអំបោសដែលមាតុគ្រាមដូចគ្នាឈរខាងក្នុងផ្ទះបោះចេញទៅខាងក្រៅតាម ប្រក្រតី និងរបងដែលគេព័ទ្ធត្រង់ជ្រុងទាំងពីរទិសខាងមុខផ្ទះ តាំងទ្វារមានរនុកទុកត្រង់កណ្តាល ធ្វើសម្រាប់រាំងពួកគោចូលទៅទាំងអស់នេះ ឈ្មោះថា ឧបចារផ្ទះ ។ ខាងក្នុងលេឌ្ឌុបាតរបស់បុរសមានកម្លាំងថ្នាក់កណ្តាល ដែលឈរត្រង់ឧបចារផ្ទះនោះ ( គ្រវែងទៅ ) ឈ្មោះថា ស្រុក ។ ខាងក្នុងលេឌ្ឌុបាតដទៃអំពីនោះ ឈ្មោះថា ឧបចារស្រុក ។ ពាក្យដែលលោកពោលទុកក្នុង មហាអដ្ឋកថានេះ រមែងជាប្រមាណក្នុងពាក្យនេះថា បុរសមានកម្លាំងថ្នាក់ កណ្តាល ដែលឈរត្រង់ឧបចារផ្ទះនៃស្រុកដែលមិនមានរបង គ្រវែងដុំដីទៅ ។ ដូចពាក្យដែលលោកពោលទុកក្នុង

មហាអដ្ឋកថានេះ រមែងបានជាប្រមាណក្នុងទីនេះ យ៉ាងណា អដ្ឋកថាវាទក្តី ថេរវាទក្តី ដែលខ្ញុំនឹងពោលខាងក្រោយ ក៏គប្បីឃើញដោយភាពជាប្រមាណក្នុងទីទាំងពួង ដូច្នោះ ។

សួរថា ឯពាក្យដែលលោកពោលទុកក្នុងមហាអដ្ឋកថានេះ នោះប្រាកដដូចជាជំទាស់នឹងព្រះបាលី ព្រោះក្នុងព្រះបាលី ទ្រង់ត្រាស់ត្រឹមប៉ុណ្ណោះថា មជ្ឈិមបុរសដែលមានកម្លាំង ឈរត្រង់ឧបចារផ្ទះ គ្រវែងដុំដីធ្លាក់ទៅ ។ តែក្នុងមហាអដ្ឋកថា លោកធ្វើលេឌ្ឌុបាតនោះ ឲ្យដល់នូវការរាប់ថា ស្រុក ហើយពោលឧបចារស្រុក បន្ទាប់អំពីលេឌ្ឌុបាតនោះចេញទៅ ។

ខ្ញុំនឹងពោលឆ្លើយថា ពាក្យទាំងអស់នោះឯង លោកពោលទុកក្នុងព្រះបាលីហើយ ចំណែកសេចក្តីអធិប្បាយក្នុងព្រះបាលីនេះ អ្នកសិក្សាគួរជ្រាប ។ ឯការអធិប្បាយនោះ អដ្ឋកថាចារ្យទាំងឡាយប៉ុណ្ណោះយល់ច្បាស់ ។ ព្រោះហេតុនោះ លក្ខណៈនៃឧបចារផ្ទះ សូម្បីមិនបានត្រាស់ទុកក្នុងព្រះបាលីថា អ្នកឈរនៅត្រង់ឧបចារផ្ទះ ដូច្នេះ លោកក៏កាន់យកដោយអំណាចនៃលក្ខណៈដែលពោលទុកក្នុងអដ្ឋកថា យ៉ាងណា សូម្បីលក្ខណៈនៃឧបចារផ្ទះដ៏សេសក៏គួរកាន់យកដូច្នោះ ។ ក្នុងស័ព្ទថា គាមូបចារនោះ ក៏គួរជ្រាបន័យដូច្នេះថា ឈ្មោះថា ស្រុកក្នុងសិក្ខាបទនេះ មាន ២ ប្រភេទ គឺស្រុកដែលមានរបង ១ ស្រុកដែលមិនមានរបង ១ ក្នុងស្រុក ២ ប្រភេទនោះ របងនោះឯងជាដែនកំណត់របស់ស្រុកដែលមានរបង ។ ព្រោះហេតុនោះ ទើបក្នុងព្រះបាលីទ្រង់មិនត្រាស់ដែនកំណត់ទុកមួយផ្នែក តែបានត្រាស់ទុកថា បុរសដែលមានកម្លាំង

កណ្តាលឈរនៅត្រង់សសរខឿន នៃស្រុកដែលមានរបង គប្បីវែងដុំដីធ្លាក់ទៅ ឈ្មោះថា ឧបចារស្រុក ។ ចំណែកដែនកំណត់ស្រុក នៃស្រុកដែលមិនមានរបងក៏គួរពោលទុកដែរ ។ ព្រោះដូច្នោះ ដើម្បីសម្តែងដែនកំណត់ស្រុក នៃស្រុកដែលមិនមានរបងនោះ ទើបទ្រង់ត្រាស់ទុកថា បុរសដែលមានកម្លាំងកណ្តាលឈរនៅត្រង់ទីឧបចារផ្ទះ នៃស្រុកដែលមិនមានរបង គប្បីវែងដុំដីទៅ ( ឈ្មោះថា ឧបចារស្រុក ) ដើម្បីសម្តែងដែនកំណត់របស់ស្រុកទុកហើយនោះឯង លក្ខណៈនៃឧបចារស្រុក បុគ្គលណាមួយ ក៏អាចជ្រាបបានដោយន័យដូចពោលទុកហើយអំពីមុននោះឯង ព្រោះដូច្នោះ ទើបទ្រង់មិនត្រាស់ទុកដដែលទៀតថា បុរសមានកម្លាំងកណ្តាលឈរនៅត្រង់ឧបចារផ្ទះនោះ បោលដុំដីទៅ ។ ចំណែកអាចារ្យណាពោលលេឌ្ឌុបាត របស់បុរសមានកម្លាំងកណ្តាលដែលឈរនៅត្រង់ទីឧបចារផ្ទះនោះឯងថា ជាឧបចារស្រុក ដូច្នេះ ឧបចារផ្ទះ របស់អាចារ្យនោះ រមែងជាន់ជាមួយពាក្យថា ស្រុក ព្រោះហេតុនោះ វិភាគនេះ គឺផ្ទះ ឧបចារផ្ទះ ស្រុក ឧបចារស្រុក រមែងមិនលាយឡំគ្នា ។ ចំណែកវិនិច្ឆ័យក្នុង ផ្ទះ ឧបចារផ្ទះ ស្រុក និងឧបចារស្រុក អ្នកសិក្សាគួរជ្រាបដោយការមិនលាយឡំគ្នា ( ដូចដែលលោកពោលទុក ) ក្នុងវិកាលេគាមប្បវេសនសិក្ខាបទជាដើម ព្រោះដូច្នោះ ស្រុក និងឧបចារៈ ក្នុងអទិន្នាទានសិក្ខាបទនេះ អ្នកសិក្សាគួរប្រៀបធៀបបាលី និងអដ្ឋកថាហើយជ្រាបតាមន័យដែលពោលទុកហើយនោះចុះ ។ ម្យ៉ាងទៀត សូម្បីស្រុកណាអំពីមុន ជាស្រុកធំ ក្រោយមក កាលត្រកូលទាំងឡាយសាបសូន្យទៅ ក្លាយ

ជាស្រុកតូចតាច ស្រុកនោះគួរកំណត់ដោយលេឌ្ឌុបាតអំពីឧបចារផ្ទះ ដូចគ្នា ។ ចំណែកកំណត់ខេត្តដើមរបស់ស្រុកនោះ ទាំងដែលមានរបង ទាំងដែលមិនមានរបង នឹងកាន់យកជាប្រមាណមិនបានឡើយ ដូច្នេះឯង ។

## អធិប្បាយ កំណត់ខេត្តព្រៃ

ព្រៃដ៏សេស ក្នុងអទិន្នាទានសិក្ខាបទនេះ វៀរស្រុក និងឧបចារស្រុក ដែលមានលក្ខណៈតាមដែលលោកពោលទុកដូច្នេះថា ដែលឈ្មោះថា ព្រៃ គឺវៀរស្រុក និងឧបចារស្រុកចេញ គប្បីជ្រាបថា ឈ្មោះថា ព្រៃ ។ តែក្នុងគម្ពីរអភិធម្ម ព្រះដ៏មានព្រះភាគត្រាស់ទុកថា ពាក្យថា ព្រៃនោះ បានដល់ ទីខាងក្រៅអំពីសសរខឿនចេញទៅ ទាំងអស់នោះឈ្មោះថា ព្រៃ ។ ព្រះអង្គត្រាស់ទុកក្នុងអរញ្ញសិក្ខាបទ សេនាសនៈ ដោយហោចចម្ងាយប្រមាណ ៥០០ ធ្នូ ឈ្មោះថា សេនាសនៈព្រៃ ។ គប្បីជ្រាបថា សេនាសនៈព្រៃនោះ រាប់អំពីសសរខឿនចេញទៅ មានរយៈចម្ងាយប្រមាណ ៥០០ ធ្នូ ដោយធ្នូរបស់អាចារ្យដែលលោកលើកឡើងទុក ។

ព្រះដ៏មានព្រះភាគ កាលទ្រង់ចែកអត្ថនៃពាក្យនេះថា អំពីស្រុកក្តី អំពីព្រៃក្តី ដោយន័យដូចដែលពោលទុកហើយ ក្នុងព្រះបាលីយ៉ាងនោះ ទើបទ្រង់សម្តែងចំណែកទាំង ៥ ទុក ដើម្បីរាំងការអាងលេស និងឱកាសរបស់ពួកបាបភិក្ខុថា ផ្ទះ ឧបចារផ្ទះ ស្រុក ឧបចារស្រុក ( និង ) ព្រៃ ។ ព្រោះដូច្នោះ គប្បីជ្រាបថា កាលភិក្ខុលួចរបស់ដែលមានម្ចាស់ តាំងអំពីតម្លៃមួយបាទឡើងទៅ ក្នុងផ្ទះក្តី ឧបចារផ្ទះក្តី ស្រុកក្តី ឧបចារស្រុកក្តី ព្រៃក្តី ត្រូវ

អាបត្តិបារាជិកដូចគ្នា ។

ឥឡូវនេះ ដើម្បីសម្តែងអត្ថនៃពាក្យជាដើមថា គប្បីកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឲ្យ ដោយចំណែកនៃចិត្តលួច ដូច្នេះ ទើបទ្រង់ត្រាស់ថា **អទិន្នំ ឆាម** ជាដើម ។ ក្នុងពាក្យថា **អទិន្នំ ឆាម** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា ក្នុងទន្តបោណសិក្ខាបទ សូម្បីទ្រព្យរបស់ខ្លួន ដែលមិនទាន់ទទួលប្រគេន ដែលជាកប្បិយៈ តែជារបស់ដែលមិនគួរទំពាស៊ី ហៅថា របស់ដែលគេមិនទាន់បានឲ្យ ។ តែក្នុងសិក្ខាបទនេះ ទ្រព្យឯណានីមួយ ដែលអ្នកដទៃហួងហែង ដែលមានម្ចាស់ ហៅថា ទ្រព្យដែលម្ចាស់មិនបានឲ្យ ។ ទ្រព្យនោះដែលម្ចាស់មិនបានឲ្យដោយកាយ ឬវាចា ព្រោះហេតុនោះ ទើបឈ្មោះថា ទ្រព្យដែលម្ចាស់មិនបានឲ្យ ។ ឈ្មោះថា ដែលម្ចាស់មិនបានលះបង់ ព្រោះថា ម្ចាស់មិនទាន់បានលះបង់ផុតអំពីដៃរបស់ខ្លួន ឬអំពីទីកន្លែងដែលតាំងនៅអំពីដើម ។ ឈ្មោះថា ម្ចាស់ទ្រព្យមិនទាន់បានលះបង់ ព្រោះថា សូម្បីទ្រព្យតាំងនៅក្នុងទីដើមហើយ តែម្ចាស់ទ្រព្យក៏មិនទាន់បានលះបង់ ព្រោះមិនទាន់អស់អាល័យ ។ ឈ្មោះថា ដែលម្ចាស់ទ្រព្យរក្សា ព្រោះជាទ្រព្យដែលម្ចាស់នៅរក្សាទុក ដោយនៅរៀបចំការរក្សា ។ ឈ្មោះថា ដែលម្ចាស់ទ្រព្យនៅគ្រប់គ្រងនៅឡើយ ព្រោះជាទ្រព្យដែលម្ចាស់ទុកក្នុងទីទាំងឡាយមានទ្វារជាដើម ហើយគ្រប់គ្រង ។ ឈ្មោះថា ដែលម្ចាស់ទ្រព្យនៅប្រកាន់ថាជារបស់អញ ព្រោះជាទ្រព្យដែលម្ចាស់នៅប្រកាន់កម្មសិទ្ធិថា ជារបស់អញ ដោយការប្រកាន់ថា ទ្រព្យអញ ដោយអំណាចតណ្ហាថា ទ្រព្យនេះរបស់

អញ ។ ឈ្មោះថា ដែលអ្នកដទៃហួងហែង ព្រោះថា ជាទ្រព្យដែលជនដទៃ ដែលជាម្ចាស់ទាំងនោះ នៅហួងហែង ដោយកិច្ច មានការមិនទាន់លះបង់ នៅរក្សា និងគ្រប់គ្រងនៅឡើយជាដើមនោះ ។ ទ្រព្យនោះ ឈ្មោះថា ម្ចាស់មិនបានឲ្យ ។

ក្នុងបទថា **ថេយ្យសង្ខាតំ** នេះ មានវិនិច្ឆ័យដូច្នេះថា ចោរ ឈ្មោះថា អ្នកលួច ភាពនៃអ្នកលួច ឈ្មោះថា **ថេយ្យំ** ។ បទថា **ថេយ្យំ** នេះ ជាឈ្មោះនៃចិត្តគិតនឹងលួច ។ ពីរបទថា **សង្ខា សង្ខាតំ** នោះ ដោយអត្ថ គឺដូចគ្នា ។ បទថា **សង្ខាតំ** នោះ ជាឈ្មោះនៃចំណែក ដូច **សង្ខាត** សព្ទក្នុងឧទាហរណ៍ទាំងឡាយថា **សញ្ញានិទានា ហិ បបញ្ចសង្ខា** ព្រោះធម៌ជាចំណែកនៃការយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ ដូច្នេះជាដើម ។ ចំណែកនោះផង ភាពជាចោរផង ព្រោះដូច្នោះ ទើបឈ្មោះថា **ថេយ្យសង្ខាតំ** អធិប្បាយថា ចំណែកនៃចិត្ត ១ ដួង ដែលជាចំណែកនៃចិត្តលួច ។ ឯពាក្យថា **ថេយ្យសង្ខាតំ** នេះ ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញដោយអត្ថថា **ថេយ្យសង្ខាតេន** ប្រែថា ដោយចំណែកនៃភាពជាចោរដូច្នេះ ។

ឯភិក្ខុណា រមែងកាន់យក ( ទ្រព្យដែលម្ចាស់មិនបានឲ្យ ) ដោយចំណែកនៃចិត្តលួច ភិក្ខុនោះរមែងជាអ្នកមានចិត្តនៃភាពជាចោរ ព្រោះដូច្នោះ ដើម្បីមិនលំបាកគិតដល់ព្យញ្ជនៈ សម្តែងចំពោះអត្ថប៉ុណ្ណោះ គប្បីជ្រាបថា ព្រះដ៏មានព្រះភាគត្រាស់បទភាជនីយ៍នៃបទថា **ថេយ្យសង្ខាតំ** នោះ ទុកយ៉ាង

នេះថា បុគ្គលមានចិត្តនៃភាពជាចោរ គឺមានចិត្តលួចដូច្នេះ ។

## អធិប្បាយ មាតិកា ៦ បទ

[ ៨៦ ] ក្នុងពាក្យថា **អាធិយេយ្យំ ។បេ។ សង្កេតំ វីតិនាមេយ្យ** នេះ បណ្ឌិតគប្បីជ្រាបថា បទដំបូង ព្រះដ៏មានព្រះភាគត្រាស់ដោយអំណាចការបន្ទំយក បទទី ២ ត្រាស់ដោយអំណាចនៃភិក្ខុដែលនាំយកទ្រព្យបុគ្គលពួកដទៃទៅ បទទី ៣ ត្រាស់ដោយអំណាចនៃទ្រព្យដែលគេកប់ទុក បទទី ៤ ត្រាស់ដោយអំណាចនៃទ្រព្យដែលមានវិញ្ញាណ បទទី ៥ ត្រាស់ដោយអំណាចនៃទ្រព្យដែលគេរក្សាទុកលើគោកជាដើម បទទី ៦ ត្រាស់ដោយអំណាចនៃសេចក្តីកំណត់ចំណាំ ឬដោយអំណាចនៃដែនគយ ។ មួយ៉ាងទៀត ក្នុងពាក្យថា **អាធិយេយ្យំ** ជាដើមនេះ កាលប្រកបសេចក្តីរមែងមានដោយអំណាចទ្រព្យតែមួយខ្លះ ដោយអំណាចទ្រព្យផ្សេងៗ ខ្លះ ។ ឯការប្រកបដោយអំណាចវត្ថុតែមួយ រមែងប្រើបានដោយទ្រព្យដែលមានវិញ្ញាណប៉ុណ្ណោះ ។ ការប្រកបដោយអំណាចវត្ថុផ្សេងៗ ដោយទ្រព្យដែលលាយឡំគ្នា ទាំងមានវិញ្ញាណ ទាំងមិនមានវិញ្ញាណ ។ បណ្តាការប្រកបដោយអំណាចវត្ថុមួយនិងវត្ថុផ្សេងៗ នោះ ការប្រកបដោយអំណាចវត្ថុផ្សេងៗ បណ្ឌិតគួរជ្រាបដោយន័យយ៉ាងនេះមុន ។

## អធិប្បាយ ការលួច ៦ យ៉ាង

បទថា **អាធិយេយ្យំ** សេចក្តីថា ភិក្ខុបន្ទំយកចម្ការ ត្រូវអាបត្តិទុក្កដ ញុំាងការសង្ស័យឲ្យកើតឡើងដល់ម្ចាស់ទ្រព្យ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្ចាស់

ទ្រព្យដាក់ធុរៈថា ចម្ការនេះមិនជារបស់អញទ្បើយ ត្រូវអាបត្តិបារាជិក ។

បទថា **ហរេយ្យ** សេចក្តីថា ភិក្ខុមានថេយ្យចិត្តនាំទ្រព្យរបស់អ្នកដទៃទៅ ស្ទាបអង្អែលភារៈលើក្បាល ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ចុះមកកាន់ក ត្រូវអាបត្តិបារាជិក ។

បទថា **អវហរេយ្យ** សេចក្តីថា ភិក្ខុទទួលបញ្ញើទុក ម្ចាស់ទ្រព្យមកទារថា ទ្រព្យដែលខ្ញុំផ្ញើទុកមាន លោកម្ចាស់ចូរឲ្យទ្រព្យដល់ខ្ញុំ ហើយពោលបដិសេធថា អាត្មាមិនបានទទួលទុក ត្រូវអាបត្តិទុក្កដ ។ ញុំាងការសង្ស័យឲ្យកើតដល់ម្ចាស់ទ្រព្យ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្ចាស់ទ្រព្យដាក់ធុរៈថា ភិក្ខុអង្គនេះមិនឲ្យដល់អញវិញទ្បើយ ត្រូវអាបត្តិបារាជិក ។

ពីរបទថា **ឥរិយាបថំ វិកោបេយ្យ** សេចក្តីថា ភិក្ខុគិតថា អញនឹងនាំទៅទាំងទ្រព្យទាំងមនុស្ស ឲ្យឈានជំហានទី ១ ទៅ ត្រូវអាបត្តិថុល្លច្ច័យ ឲ្យឈានជំហានទី ២ ទៅ ត្រូវអាបត្តិបារាជិក ។

ពីរបទថា **ឋានា ចាវេយ្យ** សេចក្តីថា ភិក្ខុមានថេយ្យចិត្ត ចាប់ប៉ះទ្រព្យដែលតាំងនៅលើគោក ត្រូវអាបត្តិទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យឃ្លាតចាកទី ត្រូវអាបត្តិបារាជិក ។

ពីរបទថា **សង្កេតំ វីតិនាមេយ្យ** សេចក្តីថា ភិក្ខុញុំាងជំហានទី ១ ឲ្យឈានកន្លងទីកំណត់ទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឲ្យជំហានទី ២ ឈានកន្លងទៅ ត្រូវអាបត្តិបារាជិក ។ម្យ៉ាងទៀត ញុំាងជំហានទី ១ ឲ្យឈានកន្លងដែនគយទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ញុំាងជំហានទី ២ ឲ្យកន្លងទៅ

ត្រូវអាបត្តិបារាជិក ដូច្នេះឯង ។ នេះជាការប្រែកបដោយអំណាចនានាភណ្ឌៈ ក្នុងបទថា **អាទិយេយ្យ** ជាដើមនេះ ។

ចំណែកការប្រែកបដោយអំណាចឯកភណ្ឌៈ គប្បីជ្រាបដូច្នេះថា ទាសៈក្តី សត្វតិរច្ឆានក្តី ដែលមានម្ចាស់ ភិក្ខុបន្ទំយកក្តី លួចទៅក្តី ឆទៅក្តី ឲ្យឥរិយាបថកម្រើកក្តី ឲ្យឃ្លាតចាកឋានក្តី ឲ្យឈានកន្លងទីកំណត់ទៅក្តី ដោយន័យ មានបន្ទំយកជាដើម តាមដែលពោលទុកហើយ ។ នេះជាការប្រែកបដោយអំណាចឯកភណ្ឌៈ ក្នុងបទថា **អាទិយេយ្យ** ជាដើមនេះ ។

ម្យ៉ាងទៀត បណ្ឌិតបរិយាយបទទាំងឡាយ ៦ នេះ គប្បីប្រមូលបញ្ចកៈ ៥ ពួកមកហើយសម្តែងអវហារ ២៥ យ៉ាង ។ ព្រោះកាលបរិយាយយ៉ាងនេះ រមែងជាការបរិយាយអទិន្នាទានបារាជិកនេះ ដោយល្អហើយ ។ តែក្នុងទីនេះ អដ្ឋកថាទាំងពួងលំបាកស្មុគស្មាញ មានវិនិច្ឆ័យយល់បានលំបាក ។ សេចក្តីពិតជាដើមនោះ ក្នុងបណ្តាអដ្ឋកថាទាំងពួង អដ្ឋកថាចារ្យរួមអង្គនៃអវហារទាំងឡាយ ដែលព្រះដ៏មានព្រះភាគត្រាស់ទុកហើយ ក្នុងព្រះបាលីដោយន័យថា ភិក្ខុកាន់យកទ្រព្យដែលគេមិនបានឲ្យ ដោយអាការ ៥ ត្រូវអាបត្តិបារាជិក ទាំងវត្ថុនោះ ជាទ្រព្យដែលអ្នកដទៃហួងហែង ដូច្នេះជាដើម ក្នុងទីកន្លែងខ្លះសម្តែងទុកក្នុងបញ្ចកៈមួយ ក្នុងទីខ្លះសម្តែងទុកក្នុងពីរបញ្ចកៈក្តួបចូលជាមួយគ្នានៃអង្គអវហារទាំងឡាយ ដែលមកហើយថា **ឆហាការេហិ** ដោយអាការ ៦ ដូច្នេះ ។ តែបញ្ចកៈទាំងនេះ មិនមែនជាបញ្ចកឡើយ ព្រោះក្នុងពួកដែលអវហាររមែងសម្រេចបាន ដោយបទមួយៗ នោះ លោកហៅថា

បញ្ចក: ។ ក្នុងពាក្យថា **បញ្ចហាការេហិ** នេះ អវហារតែមួយប៉ុណ្ណោះរមែងសម្រេចបានដោយបទទាំងអស់ ។ ក្នុងបញ្ចក:ទាំងឡាយណា ដែលលោកសំដៅយកក្នុងបទទាំង ៦ នោះ ខ្ញុំសម្តែងទុកហើយ តែខ្ញុំមិនបានប្រកាសអត្ថនៃបញ្ចក:ទាំងអស់នោះទុកក្នុងទីនេះ អដ្ឋកថាទាំងពួងស្មុគស្មាញពន់ពេក មានវិនិច្ឆ័យយល់បានដោយលំបាក ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ គប្បីកំណត់អវហារ ២៥ ប្រការទាំងនេះ ដែលខ្ញុំប្រមូលបញ្ចក: ៥ ពួកមកហើយសម្តែងទុកដោយល្អ ។

## អវហារ ២៥

ដែលឈ្មោះថា បញ្ចក: ៥ គឺពួកនៃអវហារ ៥ ដែលកំណត់ដោយកណ្ឌ:ផ្សេងគ្នាជាខាងដើម ១ ពួកនៃអវហារ ៥ ដែលកំណត់ដោយកណ្ឌ:ប្រភេទតែមួយជាខាងដើម ១ ពួកនៃអវហារ ៥ ដែលកំណត់ដោយអវហារដែលកើតហើយដោយដៃរបស់ខ្លួនជាខាងដើម ១ ពួកអវហារ ៥ ដែលកំណត់ដោយបុព្វប្បយោគជាដើម ១ ពួកនៃអវហារ ៥ ដែលកំណត់ដោយការលួច ដោយអាការជាចោរជាខាងដើម ១ ។ បណ្តាបញ្ចក:ទាំង ៥ នោះនានាកណ្ឌបញ្ចក: និងឯកកណ្ឌបញ្ចក: រមែងបានដោយ អំណាចនៃបទទាំងនេះ គឺ **អាទិយេយ្យ** បន្លំយក ១ **ហរេយ្យ** លួចទៅ ១ **អវហរេយ្យ** ឆយក ១ **ឥរិយាបថំ វិកោបេយ្យ** ញុំាងឥរិយាបថឲ្យកម្រើក ១ **ឋានា ចាវេយ្យ** គប្បីឲ្យកម្រើកឃ្លាតចាកទី ១ បញ្ចក:ទាំង២ នោះ អ្នកសិក្សាគប្បីជ្រាបដោយន័យដូចខ្ញុំប្រកបសម្តែងទុកហើយខាងដើមនោះឯង ។ ចំណែកបទ

*ទី ៦ ថា* **សង្កេតំ វីតិនាមេយ្យំ** *( គប្បីឲ្យកន្លងទីកំណត់ ) នោះ ជាទ្រព្យទូទៅដល់បរិកប្បាវហារ និងនិស្សគ្គិយាវហារ ។ ព្រោះដូច្នោះ គប្បីប្រកបបទទី ៦ នោះចូលដោយអំណាចបទ ដែលបាននៅក្នុងបញ្ចកៈទី ៣ និងទី ៥ ។ នានាភណ្ឌបញ្ចកៈ និងឯកភណ្ឌបញ្ចកៈ ខ្ញុំបានពោលទុកហើយ ។*

## សាហត្ថិកបញ្ចក មានអវហារ ៥ យ៉ាង

*សាហត្ថិកបញ្ចកៈ ដូចម្តេច គឺសាហត្ថិកបញ្ចកៈ មានអវហារ ៥ យ៉ាង ដូច្នេះ គឺសាហត្ថិក កាន់យកដោយដៃរបស់ខ្លួនឯង ១ អាណត្តិក បង្គាប់បញ្ជា ១ និស្សគ្គិយ បោះ ឬចោលវត្ថុទៅ ១ អត្ថសាធក ញុំាងអត្ថឲ្យសម្រេច ១ ធុរនិក្ខេប ម្ចាស់ទ្រព្យដាក់ធុរៈ ១ ។*

*បណ្តាអវហារ ៥ យ៉ាងនោះ ដែលឈ្មោះថា សាហត្ថិក បានដល់ភិក្ខុលួចទ្រព្យរបស់អ្នកដទៃដោយដៃរបស់ខ្លួនឯង ។ ដែលឈ្មោះថា អាណត្តិក បានដល់ ភិក្ខុប្រើអ្នកដទៃថា ចូរលួចទ្រព្យរបស់មនុស្សឈ្មោះនោះ ។ ឈ្មោះថា និស្សគ្គិយ រមែងបានការប្រកបបទនេះថា គប្បីឲ្យកន្លងដែនកំណត់ រួមនឹងពាក្យនេះថា ភិក្ខុឈរនៅខាងក្នុងដែនគយ បោះទ្រព្យឲ្យធ្លាក់ខាងក្រៅដែនគយ ត្រូវអាបត្តិបារាជិក ដូច្នេះ ។ ដែលឈ្មោះថា អត្ថសាធក បានដល់ភិក្ខុប្រើថា អ្នកអាចលួចទ្រព្យឈ្មោះនោះមកបានក្នុងពេលណា ចូរលួចមកក្នុងពេលនោះ ។ បណ្តាភិក្ខុអ្នកប្រើ និងភិក្ខុអ្នកលួច បើភិក្ខុអ្នកទទួលប្រើមិនមានអន្តរាយក្នុងចន្លោះ លួចទ្រព្យនោះបានមក ភិក្ខុអ្នកប្រើរមែងត្រូវអាបត្តិបារាជិកក្នុងខណៈដែលប្រើនោះឯង ចំណែកភិក្ខុអ្នកលួច ត្រូវអាបត្តិ*

បារាជិកក្នុងវេលាលួចបានមក នេះឈ្មោះថា អត្ថសាធក ។ ចំណែកធុរនិក្ខេប គប្បីជ្រាបដោយអំណាចទ្រព្យដែលគេផ្ញើទុកដូច្នេះឯង ពាក្យដែលអធិប្បាយមកនេះ ឈ្មោះថា សាហត្ថិកបញ្ចកៈ ។

## បុព្វប្បយោគបញ្ចក មានអវហារ ៥ យ៉ាង

បុព្វប្បយោគបញ្ចកៈ ដូចម្ដេច គឺបុព្វប្បយោគបញ្ចកៈ មានអវហារដទៃ ៥ យ៉ាងទៀតដូច្នេះ គឺបុព្វប្បយោគ-ប្រកបខាងដើម ១ សហបយោគ-ប្រកបព្រមគ្នា ១ សំវិធាវហារ-ការបបួលទៅលួច ១ សង្កេតកម្ម-ណាត់កំណត់សញ្ញាគ្នា ១ និមិត្តកម្ម-ការធ្វើនិមិត្ត ១ បណ្ដាអវហារទាំង ៥ នេះ បុព្វប្បយោគគប្បីជ្រាបដោយអំណាចការប្រើ ។ សហបយោគ គប្បីជ្រាបដោយអំណាចការឲ្យឃ្លាតចាកទី អវហារទាំង ៣ ក្រៅពីនេះ គប្បីជ្រាបដោយន័យដែលមកហើយក្នុងព្រះបាលីនោះឯង ។ ពាក្យអធិប្បាយមកនេះ ឈ្មោះថា បុព្វប្បយោគបញ្ចកៈ ។

## ថេយ្យាវហារបញ្ចក មានអវហារ ៥ យ៉ាង

ថេយ្យាវហារបញ្ចក ដូចម្ដេច គឺថេយ្យាវហារបញ្ចក មានអវហារដទៃ ៥ យ៉ាងទៀតដូច្នេះ គឺ ថេយ្យាវហារ-លួចដោយភាពជាចោរ ១ បសយ្ហាវហារ-លួចដោយការសង្កត់សង្កិន ១ បរិកប្បាវហារ-លួចតាមកំណត់ទុក ១ បដិច្ឆន្នាវហារ-លួចដោយកិរិយាបិទបាំង ១ កុសាវហារ-លួចដោយការប្ដូរស្លាក ១ អវហារទាំង ៥ នេះ ខ្ញុំនឹងពណ៌នាក្នុងរឿងការប្ដូរស្លាកមួយរឿង ( ខាងមុខ ) ថា ភិក្ខុអង្គណាមួយ កាលចីវរសង្ឃដែលចីវរភាជកភិក្ខុកំពុង

បែក មានថេយ្យចិត្តបូរស្វាក ហើយទទួលចីវរទៅ ដូច្នេះ ។ ពាក្យដែលអធិប្បាយមកនេះ ឈ្មោះថា ថេយ្យាវហារបញ្ចកៈ ។ គប្បីប្រមូលបញ្ចកៈទាំងឡាយនេះ ហើយជ្រាបអវហារ ២៥ ប្រការនេះ ដោយប្រការដូច្នេះ ។

ឯព្រះវិនយធរដែលឈ្លាសក្នុងបញ្ចកៈទាំង ៥ នេះ មិនគប្បីប្រញាប់ប្រញាល់វិនិច្ឆ័យអធិករណ៍ដែលកើតឡើងហើយ គប្បីពិនិត្យមើលឋានៈ ៥ ប្រការ ដែលបុរាណាចារ្យទាំងឡាយសំដៅទុកហើយថា

ព្រះវិនយធរដែលឈ្លាស គប្បីថ្លឹងថ្លែងឋានៈ ៥ ប្រការ
គឺវត្ថុ កាល ទេស តម្លៃ និងការប្រើប្រាស់ជាគម្រប់ ៥
ហើយគប្បីទ្រទ្រង់អត្ថរបស់ក្តីទុក ដូច្នេះ ។

## អធិប្បាយ ឋានៈ ៥ ប្រការ

បណ្តាឋានៈទាំង ៥ នោះ ឋានៈថា វត្ថុ បានដល់ ភណ្ឌៈ កាលភិក្ខុអ្នកលួច សូម្បីទទួលពាក្យពិតថា ភណ្ឌៈឈ្មោះនេះ ខ្ញុំលួចទៅពិត ព្រះ-វិនយធរមិនគប្បីលើកអាបត្តិឡើង កាត់អាបត្តិភ្លាមៗ ឡើយ គប្បីពិចារណាថា ភណ្ឌៈនោះមានម្ចាស់ ឬមិនមានម្ចាស់ សូម្បីក្នុងភណ្ឌៈដែលមានម្ចាស់គប្បីពិចារណាថា ម្ចាស់ទ្រព្យមានអាល័យឬទេ ឬដាច់អាល័យហើយ ។ បើភិក្ខុលួចក្នុងវេលាដែលម្ចាស់ទ្រព្យទាំងនោះនៅមានអាល័យ វិនយធរគប្បីគិតតម្លៃ កាត់អាបត្តិ ។ បើលួចក្នុងវេលាដែលម្ចាស់ទ្រព្យមិនមានអាល័យមិនគប្បីកាត់អាបត្តិបារាជិកឡើយ ។ តែកាលម្ចាស់ភណ្ឌៈ ឲ្យនាំភណ្ឌៈមកសង គប្បីឲ្យសងភណ្ឌៈ ។ នេះជាការប្រតិបត្តិក្នុងរឿងនេះ ។

# រឿង ភិក្ខុលួចចីវរ

ដើម្បីសម្តែងអត្ថនេះ គួរនាំរឿងមកសាធកដូច្នេះថា បានឮថា ក្នុងរជ្ជកាល នៃព្រះបាទកាតិយរាជ្យ មានភិក្ខុមួយអង្គដាក់សំពត់កាសាវៈមានពណ៌លឿង ប្រវែង ៧ ហត្ថ ត្រង់ចង្កូយស្មា ហើយចូលទៅកាន់លានព្រះចេតិយអំពីទិសទក្សិណ ដើម្បីបូជាព្រះមហាចេតិយ ។ ខណៈនោះឯង ព្រះរាជាក៏យាងមកដើម្បីថ្វាយបង្គំព្រះចេតិយ ។ ពេលនោះ កាលកំពុងដេញកៀរមហាជនទៅ ភាពពពាក់ពពូននៃមហាជន បានមានឡើងហើយ ។ គ្រានោះឯងភិក្ខុអង្គនោះ ត្រូវភាពប្របូកប្របល់នៃមហាជនបៀតបៀនហើយ មិនបានដឹងថា សំពត់កាសាវៈជ្រុះទៅអំពីចង្កូយស្មាឡើយ ក៏បានដើរចេញទៅ ។ កាលដើរចេញទៅហើយ មិនឃើញសំពត់កាសាវៈ ក៏ដាក់ធុរៈថា នរណានឹងរកសំពត់កាសាវៈឃើញ ក្នុងកាលពួកមហាជនពពាក់ពពូនដូច្នេះ ឥឡូវនេះសំពត់កាសាវៈនោះ មិនមែនរបស់អញឡើយ ដូច្នេះហើយ ក៏ដើរចេញទៅ ។ គ្រានោះ មានភិក្ខុមួយអង្គដើរមកខាងក្រោយ បានឃើញសំពត់កាសាវៈនោះហើយ ក៏បានយកដោយថេយ្យចិត្ត តែត្រឡប់មានវិប្បសារី ទើបកើតគំនិតឡើងថា ឥឡូវនេះ អញមិនមែនសមណៈ អញនឹងសឹក ហើយទើបគិតថានឹងសួរព្រះវិនយធរទាំងឡាយមើល ទើបដឹងបាន ។ ដោយសម័យនោះ មានភិក្ខុទ្រទ្រង់បរិយត្តិទាំងពួង ឈ្មោះចូឡសុមនត្ថេរ ជាបាមោក្ខាចារ្យខាងព្រះវិន័យ គង់នៅក្នុងមហាវិហារ ភិក្ខុអង្គនោះចូលទៅរកព្រះថេរៈ ហើយថ្វាយបង្គំ សុំឱកាសហើយ ទើបសាកសួរនូវការក្តៅក្រហាយរបស់ខ្លួន ។ ព្រះថេរៈជ្រាបសេចក្តីដែលសំពត់កាសាវៈ គឺភិក្ខុអ្នកមកខាងក្រោយអង្គនោះ កាន់យក

ក្នុងកាលពួកមហាជនបែកគ្នាទៅហើយ គិតថា គ្រានេះ ក៏មានឱកាសក្នុងការបានសំពត់កាសាវៈនេះ ទើបបានពោលថា បើអ្នកនាំភិក្ខុដែលជាម្ចាស់សំពត់កាសាវៈមកបានសោត ខ្ញុំអាចធ្វើទីពឹងឲ្យដល់អ្នកបាន ។ ភិក្ខុអង្គនោះប្រាប់ថា ខ្ញុំនឹងឃើញភិក្ខុអង្គនោះបានដូចម្តេច លោកម្ចាស់ ព្រះថេរៈប្រាប់ថា លោកចូរទៅស៊ើបសួរក្នុងទីនោះចុះ ។ ភិក្ខុអង្គនោះ កាលរកមើលក្នុងមហាវិហារទាំង ៥ កន្លែង ក៏មិនបានជួបឡើយ ។ ពេលនោះ ព្រះថេរៈសួរភិក្ខុអង្គនោះថា ពួកភិក្ខុនាំមកអំពីទិសណាច្រើន ភិក្ខុនោះប្រាប់ថា មកអំពីទិសទក្សិណលោកម្ចាស់ ព្រះថេរៈប្រាប់ថា បើដូច្នោះ លោកចូរវាស់សំពត់កាសាវៈទាំងបណ្តោយ និងទាំងទទឹង ហើយរក្សាទុក កាលរក្សាទុកហើយចូរស៊ើបសួរតាមលំដាប់វិហារខាងទិសទក្សិណ ហើយនាំភិក្ខុអង្គនោះមក ។ ភិក្ខុអង្គនោះ ធ្វើតាមពាក្យប្រាប់នោះហើយ ក៏បានជួបភិក្ខុអង្គនោះ ហើយបាននាំមកកាន់សម្នាក់ព្រះថេរៈ ។ ព្រះថេរៈសួរថា នេះសំពត់កាសាវៈរបស់លោកម្ចាស់ឬ ភិក្ខុម្ចាស់ចីវរប្រាប់ថា មែន លោកម្ចាស់ ព្រះថេរៈសួរថា លោកធ្វើឲ្យធ្លាក់ក្នុងទីណា ភិក្ខុអង្គនោះ ក៏ប្រាប់រឿងទាំងអស់ហើយ ។ ព្រះថេរៈបានស្តាប់ការដាក់ធុរៈដែលភិក្ខុនោះធ្វើហើយ ទើបសួរភិក្ខុដែលកាន់យកសំពត់ក្រៅពីនេះថា លោកបានឃើញសំពត់នេះទីណា ទើបបានកាន់យក ភិក្ខុនោះក៏ប្រាប់រឿងទាំងអស់ ។ បន្ទាប់អំពីនោះ ទើបព្រះថេរៈពោលនឹងភិក្ខុដែលកាន់យកសំពត់នោះថា លោកបានកាន់យកដោយចិត្តបរិសុទ្ធហើយ លោកមិនត្រូវអាបត្តិឡើយ ព្រោះកាន់យកដោយថេយ្យចិត្ត ទើបលោកត្រូវអាបត្តិ

ទុក្កដ កាលសម្តែងអាបត្តិទុក្កដនោះហើយ នឹងជាអ្នកមិនមានអាបត្តិ ។ម្យ៉ាងទៀត លោកចូរធ្វើសំពត់កាសាវៈមួយផ្ទាំងនេះឲ្យជារបស់ខ្លួន ហើយប្រគេនដល់ភិក្ខុអង្គនោះចុះ ។ ភិក្ខុអង្គនោះ បានជួបនូវការចូរស្រោលចិត្តដ៏ក្រៃលែងដូចបានស្រោចដោយទឹកអមតៈ ដូច្នោះ ព្រះវិនយធរ គប្បីពិសោធដល់វត្ថុយ៉ាងនេះ ។

ឋានៈថា កាល គឺកាលដែលលួច ។ ព្រោះថា ភណ្ឌៈនោះៗ គ្រាខ្លះមានតម្លៃល្មមសមគួរ គ្រាខ្លះមានតម្លៃថ្លៃ ព្រោះដូច្នោះ ភណ្ឌៈនោះៗ ព្រះវិនយធរគប្បីកាត់អាបត្តិតាមតម្លៃទ្រព្យក្នុងកាលដែលភិក្ខុលួច ។ គប្បីជ្រាបដល់កាលយ៉ាងនេះ ។

ឋានៈថា បទេស គឺប្រទេសដែលលួច ។ ឯភណ្ឌៈនោះ ភិក្ខុលួចក្នុងប្រទេសណា ព្រះវិនយធរគប្បីកាត់អាបត្តិតាមតម្លៃទ្រព្យក្នុងប្រទេសនោះៗឯង ព្រោះថា ក្នុងប្រទេសដែលជាទីកើតរបស់ភណ្ឌៈៗ រមែងមានតម្លៃល្មមសមគួរ ក្នុងប្រទេសដទៃ រមែងមានតម្លៃថ្លៃ ។

ដើម្បីសម្តែងសេចក្តីនេះ គួរសាធករឿងដូចតទៅនេះថា បានឮថា ក្នុងប្រទេសជិតមាត់សមុទ្រ មានភិក្ខុមួយអង្គបានផ្លែដូងមានសណ្ឋានល្អ ទើបឲ្យក្រឡឹងធ្វើជាត្រឡោកទឹកដែលគួរពេញចិត្ត ដូចគ្នានឹងសម្បកស័ង្ខ ហើយដាក់ទុកត្រង់ទីប្រទេសនោះៗ ឯង ទើបបានទៅកាន់ចេតិយគិរីវិហារ ។ គ្រានោះមានភិក្ខុអង្គដទៃបានទៅកាន់ប្រទេសក្បែរមាត់សមុទ្រ ស្នាក់នៅត្រង់វិហារនោះលុះឃើញត្រឡោកនោះ ទើបបានកាន់យកដោយថេយ្យចិត្ត ហើយក៏មកកាន់

ចេតិយគិរីវិហារនោះឯង ។ កាលភិក្ខុអង្គនោះ ហុតបបរនៅត្រង់ចេតិយគិរីវិហារនោះ ភិក្ខុម្ចាស់ត្រឡោកបានឃើញត្រឡោកនោះ ទើបពោលថា លោកម្ចាស់បានត្រឡោកនេះមកអំពីទីណា ភិក្ខុដែលកាន់មកនោះឆ្លើយថា ខ្ញុំនាំមកអំពីប្រទេសជិតឆ្នេរសមុទ្រ ។ ភិក្ខុម្ចាស់ត្រឡោកនោះពោលថា ត្រឡោកនេះមិនមែនរបស់លោកម្ចាស់ទេ លោកម្ចាស់កាន់យកដោយភាពជាចោរ ដូច្នេះហើយ ទើបបានទទង់ទាញក្នុងជំនុំសង្ឃ ។ ក្នុងគិរីវិហារចេតិយនោះ ភិក្ខុទាំងឡាយក៏មិនបានទទួលភាពជាក់ច្បាស់ ទើបបាននាំត្រឡប់មកកាន់មហាវិហារ ។ ភិក្ខុទាំងឡាយឲ្យវាយស្គរប្រកាសក្នុងមហាវិហារ ហើយធ្វើការប្រជុំក្បែរមហាចេតិយ ផ្ដើមវិនិច្ឆ័យក្ដី ។ ព្រះថេរៈដែលទ្រទ្រង់វិន័យទាំងឡាយ ក៏បានបញ្ញត្តអវហារទុកហើយ ឯភិក្ខុអ្នកឈ្លាសក្នុងព្រះវិន័យឈ្មោះអាភិធម្មិកគោទត្តត្ថេរក៏មាននៅក្នុងសន្និបាតនោះដែរ ។ ព្រះថេរៈនោះពោលយ៉ាងនេះថា ភិក្ខុអង្គនេះ លួចត្រឡោកក្នុងទីណា ភិក្ខុទាំងឡាយប្រាប់ថា លោកលួចត្រង់ប្រទេសក្បែរមាត់សមុទ្រ ព្រះថេរៈសួរថា ឯប្រទេសនោះត្រឡោកនេះ មានតម្លៃប៉ុន្មាន ភិក្ខុទាំងឡាយប្រាប់ថា មិនមានតម្លៃអ្វីឡើយ ព្រះថេរៈពោលថា សេចក្ដីពិតប្រទេសនោះ ពួកអ្នកស្រុកកាប់ដូងស៊ីសាច់ខាងក្នុង ហើយក៏ចោលត្រឡោក ឯត្រឡោកនោះខ្ចាត់ខ្ចាយដើម្បីជាឧស ( ប៉ុណ្ណោះ ) ។ ព្រះថេរៈសួរតទៅថា ហត្ថកម្មក្នុងត្រឡោកនេះរបស់ភិក្ខុអង្គនេះមានតម្លៃប៉ុន្មាន ភិក្ខុទាំងឡាយប្រាប់ថា មានតម្លៃមួយមាសក ឬក្រោមមួយមាសក ព្រះថេរៈសួរថា មានក្នុងទីណាខ្លះ ដែលព្រះសម្មាសម្ពុទ្ធ

ទ្រង់បញ្ញត្តបារាជិកទុក ព្រោះមួយមាសក ឬថយចុះជាងមួយមាសក ពោល យ៉ាងនេះហើយ មានសាធុការព្រមគ្នាថា សាធុ សាធុ លោកម្ចាស់ពោល ប្រពៃហើយ វិនិច្ឆ័យត្រឹមត្រូវល្អហើយ ។ គ្រានោះ ព្រះបាទភាតិយរាជ ទ្រង់ក៏ចេញអំពីព្រះនគរដើម្បីថ្វាយបង្គំព្រះចេតិយ បានស្តាប់សំឡេងនោះ ទើបត្រាស់សួរថា នេះរឿងអ្វីហ្ន៎ កាលបានដឹងរឿងទាំងអស់តាមលំដាប់ហើយ ទើបទ្រង់ប្រាប់ឲ្យដើរវាយស្គរប្រកាសក្នុងព្រះនគរថា បើយើងនៅមានជីវិត អធិករណ៍របស់ពួកភិក្ខុខ្លះ ពួកភិក្ខុនីខ្លះ ពួកគ្រហស្ថខ្លះ ដែលព្រះអាភិធម្មិកគោទត្តត្ថេរកាត់សម្រេចហើយ ជាការវិនិច្ឆ័យត្រឹមត្រូវល្អ យើងនឹងដាក់រាជអាជ្ញាដល់បុគ្គល ដែលមិនតាំងនៅក្នុងពាក្យវិនិច្ឆ័យរបស់លោក ។ គប្បីជ្រាបដល់ប្រទេសយ៉ាងនេះ ។

## វិនយធរគួរជ្រាបតម្លៃ និងការប្រើប្រាស់

បាទៈថា តម្លៃ គឺតម្លៃទ្រព្យ ។ ព្រោះថា ភណ្ឌៈថ្មីរមែងមានតម្លៃ ខាងក្រោយមក តម្លៃរមែងស្រុតចុះ ។ ដូចបាត្រដែលធ្វើថ្មី រមែងមានតម្លៃដល់ ៨-១០ កហាបណៈ ក្រោយមក បាត្រនោះ មានប្រហោងធ្លុះ ឬត្រូវចោះ និងចំណងថ្នេរ រមែងមានតម្លៃតិច ដូច្នេះ ។ ព្រោះដូច្នោះ ព្រះវិនយធរមិនគប្បីវាយតម្លៃទ្រព្យដោយតម្លៃតាមប្រក្រតីជានិច្ចទៅនោះឡើយ ។

បាទៈថា ការប្រើប្រាស់ គឺការប្រើប្រាស់ភណ្ឌៈ ។ ព្រោះថា តម្លៃនៃភណ្ឌៈ មានកាំបិតជាដើម រមែងស្រុតតម្លៃចុះព្រោះការប្រើប្រាស់ ។ ព្រោះដូច្នោះ ព្រះវិនយធរគួរពិចារណាយ៉ាងនេះ គឺបើភិក្ខុអង្គខ្លះលួចកាំបិតរបស់

បុគ្គលណាមួយមក ដែលមានតម្លៃមួយបាទ បណ្តាម្ចាស់ទ្រព្យ និងបុគ្គល មិនមែនម្ចាស់កាំបិត ព្រះវិនយធរគប្បីសួរម្ចាស់កាំបិតថា អ្នកទិញកាំបិតនេះ មកដោយតម្លៃប៉ុន្មាន ម្ចាស់កាំបិតប្រាប់ថា មួយបាទ លោកម្ចាស់ ។ ព្រះ វិនយធរសួរថា លោកទិញមកហើយរក្សាទុក ឬប្រើខ្លះដែរ បើម្ចាស់កាំបិត ប្រាប់ថា ខ្ញុំប្រើកាត់ឈើស្ងួនខ្លះ អាចម៍ល័ក្តជ្រលក់ខ្លះ ឧសដុតបាត្រខ្លះ ដូច្នេះសោត គ្រានោះ ព្រះវិនយធរគប្បីជ្រាបថា កាំបិតនោះជារបស់ចាស់ មានតម្លៃស្រុតទៅ កាំបិតមានតម្លៃធ្លាក់ចុះ យ៉ាងណា ថ្នាំបន្តក់ភ្នែកក្តី ចង្កឹះ ថ្នាំបន្តក់ភ្នែកក្តី សោត្តី រមែងមានតម្លៃធ្លាក់ចុះ ដូច្នោះ ព្រោះហេតុត្រឹមតែ ដុសជូត ធ្វើឲ្យស្អាតដោយស្លឹកឈើ អង្កាម ឬដោយថ្មសំលៀងត្រឹមតែម្តង ។ ជុំសំណររមែងមានតម្លៃធ្លាក់ចុះ ព្រោះការកាត់ដោយធ្មេញមករខ្លះ ព្រោះត្រឹម តែការដុសខាត់ខ្លះ សំពត់ងូតទឹក រមែងតម្លៃធ្លាក់ទៅ ព្រោះការស្លៀកដណ្តប់ ត្រឹមតែម្តងខ្លះ ព្រោះត្រឹមតែពាក់ទុកលើចង្កួយស្មាខ្លះ ឬលើក្បាលខ្លះ ដោយ សំដៅដល់ការប្រើប្រាស់ខ្លះ វត្ថុទាំងឡាយមានអង្ករជាដើម រមែងមានតម្លៃ ថយចុះទៅ ព្រោះការអុំខ្លះ ព្រោះការរើសម្តងមួយគ្រាប់ ឬពីរគ្រាប់ចេញពី អង្ករនោះខ្លះ ដោយហោចទៅ ព្រោះការរើសដុំថ្ម និងដុំក្រួសបោលម្តងមួយដុំ ខ្លះ វត្ថុទាំងឡាយ មានទឹកដោះថ្លា និងប្រេងជាដើម រមែងមានតម្លៃធ្លាក់ទៅ ព្រោះការផ្ទេរពីភាជនៈដទៃខ្លះ ដោយហោចទៅ ព្រោះត្រឹមតែរើសរុយ ឬ ស្រមោចក្រហមចេញអំពីទឹកដោះថ្លានោះខ្លះ ដុំស្ករអំពៅរមែងមានតម្លៃធ្លាក់ ចុះ ព្រោះត្រឹមតែយកក្រចកចុចមើល ដើម្បីដឹងការមានរសផ្អែម ហើយកាន់

យកដោយអនុមាន ។ ព្រោះដូច្នោះ វត្ថុប្រភេទណាមួយ ដែលមានតម្លៃដល់មួយបាទ ដែលម្ចាស់ទ្រព្យធ្វើឲ្យមានតម្លៃធ្លាក់ចុះទៅ ព្រោះការប្រើប្រាស់ដោយន័យដូចពោលហើយនោះឯង ព្រះវិនយធរមិនគួរកាត់អាបត្តិកិច្ចដែលលួចកណ្ឌៈនោះដល់បារាជិក គប្បីជ្រាបដល់ការប្រើប្រាស់យ៉ាងនេះ ។

ព្រះវិនយធរអ្នកឈ្លាស គប្បីស្ទាបស្ទង់ឋានៈ ៥ នេះ យ៉ាងនេះហើយ គប្បីទ្រទ្រង់នូវអត្ថក្តី គឺគប្បីតាំងទុកនូវអាបត្តិ គរុកាបត្តិ ឬលហុកាបត្តិ ក្នុងស្ថានទីដែលគួរ ដូច្នេះ ។

វិនិច្ឆ័យបទទាំងនេះ គឺ បន្ទំ នាំយក លួច ឲ្យឥរិយាបថកម្រើក ឲ្យឃ្លាតចាកស្ថាន ឲ្យកន្លងហួសដែនកំណត់ ចប់ហើយ ។

## អធិប្បាយ ទ្រព្យដែលគួរដល់ទុតិយបារាជិក

[ ៨៧ ] ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់ចែកបទ មានបទថា **យថារូបេ អធិដ្ឋានេ** ជាដើម ទើបត្រាស់ពាក្យថា **យថារូបន្នាម** ដូច្នេះ នឹងវិនិច្ឆ័យក្នុងពាក្យថា **យថារូបំ** ជាដើមនេះថា ទ្រព្យមានតាមកំណើត ឈ្មោះថា ទ្រព្យបែបណា ។ ឯទ្រព្យមានតាមកំណើតនោះ រមែងមានតាំងពីមួយបាទឡើងទៅ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា មួយបាទក្តី គួរដល់មួយបាទក្តី ច្រើនជាងមួយបាទក្តី ។ ក្នុងសព្ទថា **បាទ** ជាដើមនោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងចំពោះអកប្បិយកណ្ឌប៉ុនចំណែកទី ៤ នៃកហាបណៈ ដោយ **បាទ** សព្ទ ទ្រង់សម្តែងកប្បិយកណ្ឌបានតម្លៃមួយបាទ ដោយ **បាទារហ** សព្ទ ទ្រង់សម្តែងកប្បិយកណ្ឌ និងអកប្បិយកណ្ឌទាំងពីរ

យ៉ាង ដោយ **អតិរេកចាគ** សព្ទ ។ វត្ថុល្មមដល់ទុតិយបារាជិក គឺទ្រង់សម្តែងហើយដោយអាការទាំងពួង ដោយសព្ទត្រឹមប៉ុណ្ណោះ ។ ព្រះរាជាជាម្ចាស់ផែនដីទាំងមូល គឺជាចក្រពត្តិក្នុងទ្វីប ដូចជាព្រះបាទអសោក ឈ្មោះថា សកលបឋវិរាជ ឬបុគ្គលណាមួយដទៃ ដែលជាព្រះរាជាក្នុងទ្វីបតែមួយ ដូចជាព្រះរាជាសីហឡ បុគ្គលនោះក៏ឈ្មោះថា សកលបឋវិរាជ ។

ព្រះរាជាដែលជាធំ ព្រោះប្រទេសនៃទ្វីបឯណាមួយ ដូចជា ព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិកោសលជាដើម ឈ្មោះថា បទេសរាជ ។ ជនពួកណាគ្រប់គ្រងមណ្ឌលណាមួយ សូម្បីក្នុងប្រទេសនៃទ្វីប ជនទាំងនោះឈ្មោះថា អ្នកគ្រប់គ្រងមណ្ឌល ។

ម្ចាស់នៃស្រុកក្នុងតំបន់តូចៗ ក្នុងចន្លោះនៃព្រះរាជាពីរអង្គ ឈ្មោះថា អ្នកគ្រប់គ្រងចន្លោះដែន ។ អមាត្យអ្នកវិនិច្ឆ័យក្តី ឈ្មោះថា ចៅក្រម ។ ចៅក្រមទាំងនោះអង្គុយក្នុងសាលាធម្មសភា កាត់ទោស មានកាត់ដៃ និងជើងរបស់ពួកចោរជាដើម តាមសមគួរដល់កំហុស ។ ចំណែកជនណាមានឋានន្តរៈជាអមាត្យ ឬរាជបុត្រជាអ្នកធ្វើខុស ចៅក្រមរមែងស្នើជនទាំងនោះដល់ព្រះរាជា មិនបានវិនិច្ឆ័យក្តីខ្លួនឯងឡើយ ។ អមាត្យធំដែលបានឋានន្តរៈ ឈ្មោះថា មហាមាត្យ ។ មហាមាត្យទាំងនោះ រមែងអង្គុយធ្វើរាជកិច្ចក្នុងគាម ឬក្នុងនិគមនោះៗ ។

ដោយបទថា **យេ វា បន** ( នេះ ) ព្រះដ៏មានព្រះភាគទ្រង់សម្តែងថា ជនពួកណាដទៃដែលអាស្រ័យរាជត្រកូល ឬអាស្រ័យភាពជាធំរបស់ខ្លួនឯង

រមែងសម្រេចការងារដោយខ្លួនឯងបាន ជនទាំងអស់នោះ ចាត់ជាព្រះរាជាក្នុងអត្ថនេះ ( ដែរ ) ។

បទថា **ហនេយ្យុំ** បានដល់ គប្បីវាយ និងគប្បីកាត់ ។

បទថា **បព្វាជេយ្យុំ** បានដល់ គប្បីបណ្តេញ និងគប្បីពោលបរិភាសយ៉ាងនេះថា ឯងជាចោរ ដូច្នេះជាដើម ។ ព្រោះហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា ទុំះជាការជេរ ។

[ ៨៩ ] ពីរបទថា **បុរិមំ ឧបាទាយ** មានអត្ថថា សម្តីងដល់បុគ្គលអ្នកសេពមេថុនធម្ម ត្រូវអាបត្តិបារាជិក ។ ពាក្យដ៏សេសរាប់ថាជាក់ច្បាស់ទាំងអស់ ព្រោះមានន័យដូចពោលហើយខាងដើម និងព្រោះបទនេះមានអត្ថរាក់ហើយ ដូច្នេះឯង ។

សិក្ខាបទវិភង្គនៃទុតិយបារាជិក ចប់

# អធិប្បាយ
# បទភាជនីយ៍នៃទុតិយបារាជិក

[ ៩០ ] ព្រះដ៏មានព្រះភាគ កាលទ្រង់ចែកសិក្ខាបទដែលទ្រង់ឧទ្ទេសហើយ តាមលំដាប់បទយ៉ាងនោះហើយ ឥឡូវនេះ ទើបទ្រង់តាំងមាតិកាដោយន័យ ជាដើមថា **ភុម្មដ្ឋំ ថលដ្ឋំ** ហើយត្រាស់វិភង្គនៃបទភាជនីយ៍នោះដោយន័យ មានពាក្យថា **ភុម្មដ្ឋំ នាម ភណ្ឌំ ភូមិយំ និក្ខិត្តំ ហោតិ** ជាដើម ដើម្បីសម្តែងភណ្ឌៈដែលនឹងគប្បីកាន់យក ដែលព្រះអង្គសម្តែងការកាន់យកដោយសង្ខេប ដោយមាន ៦ បទ មានបទថា **អាទិយេយ្យ** ជាដើមហើយ ទ្រង់សម្តែងដោយសង្ខេបដូចគ្នាថា មួយបាទក្តី គួរដល់មួយបាទក្តី លើសជាងមួយបាទក្តី ដោយពិស្តារ ដោយអាការដែលភណ្ឌៈនោះតាំងនៅក្នុងទីណាមួយ ទើបដល់ការតាំងនៅបាន ដើម្បីបិទឱកាសនៃលេសរបស់បាបភិក្ខុទាំងឡាយ ក្នុងអនាគត ។

## ទ្រព្យដែលស្ថិតនៅក្នុងផែនដី

[ ៩១ ] វិនិច្ឆ័យកថា ព្រមដោយការពណ៌នាបទដែលជ្រាលជ្រៅ ក្នុងពាក្យថា **និខាតំ**[១] ជាដើមនោះ គប្បីជ្រាបដូច្នេះថា បទថា **និខាតំ** បានដល់ដែលកប់ទុកក្នុងផែនដី ។

បទថា **បដិច្ឆន្នំ** បានដល់ ដែលគេបិទបាំងទុកដោយវត្ថុ មានដី និងឥដ្ឋជាដើម ។ ពាក្យថា **ភុម្មដ្ឋំ ភណ្ឌំ ។បេ។ គច្ឆតិ វា អាបត្តិ ទុក្កដស្ស** សេចក្តីថា ភិក្ខុណាជីងឧបាយខ្វះៗ យ៉ាងនោះឯង ដែលភណ្ឌៈនោះ ឈ្មោះថា

១- បិដកថា និក្ខិត្តំ ។ យកតាមអដ្ឋកថា ។

តាំងនៅក្នុងផែនដី ព្រោះជារបស់ដែលគេកប់ ឬបិទបាំងយ៉ាងនោះ ជាអ្នកមានថេយ្យចិត្តថា អញនឹងលួច ហើយក្រោកឡើងទៅក្នុងចំណែកនៃរាត្រី ។ ភិក្ខុនោះសូម្បីទៅមិនដល់ទីនៃភណ្ឌៈ រមែងត្រូវអាបត្តិទុក្កដ ព្រោះកាយ-វិការ និងវចីវិការទាំងពួង ។

## អធិប្បាយ អាបត្តិដែលជាបុព្វយោគនៃបារាជិក

សួរថា ត្រូវដូចម្តេច ឆ្លើយថា ត្រូវយ៉ាងនេះគឺ ពិតហើយ ភិក្ខុនោះកាលក្រោកឡើងដើម្បីលួចទ្រព្យនោះ ឲ្យអវយវៈតូចធំណាមួយកម្រើក រមែងត្រូវអាបត្តិទុក្កដ ព្រោះអវយវៈកម្រើកគ្រប់ៗ គ្រា រៀបចំសំពត់ស្បៀក និងសំពត់ដណ្តប់ ក៏ត្រូវទុក្កដគ្រប់វារៈដែលដៃកម្រើក ។ ភិក្ខុមួយអង្គមិនអាចនាំទ្រព្យដែលកប់ទុកមានចំនួនច្រើនចេញទៅបាន ទើបគិតថា អញនឹងស្វែងរកគ្នីគ្នា ដូច្នេះ ហើយដើរទៅកាន់សម្នាក់របស់សម្លាញ់ខ្លះ ទើបបើកទ្វារ ក៏ត្រូវអាបត្តិទុក្កដ គ្រប់ៗ ជំហាន និងគ្រប់ៗ ដៃដែលកម្រើក តែមិនត្រូវអាបត្តិព្រោះបិទទ្វារ ឬព្រោះកាយកម្ម និងវចីកម្មដទៃ ដែលមិនជាការឧបការៈដល់ការទៅ ។ លោកដើរទៅកាន់ឱកាសដែលភិក្ខុអង្គនោះសិង ហើយហៅភិក្ខុនោះថា លោកម្ចាស់មានឈ្មោះនេះ ប្រាប់បំណងនោះឲ្យជ្រាប ទើបបបួលថា លោកម្ចាស់ មក យើងទៅជាមួយគ្នាចុះ រមែងត្រូវអាបត្តិទុក្កដគ្រប់ៗ ម៉ាត់ ។ ភិក្ខុអង្គនោះ ក្រោកឡើងតាមពាក្យបបួលរបស់លោក សូម្បីភិក្ខុអង្គនោះ ក៏ត្រូវអាបត្តិទុក្កដ ។ កាលលោកក្រោកឡើងបំណងនឹងដើរទៅកាន់សម្នាក់នៃភិក្ខុ ( ដើមគំនិត ) នោះ រៀបចំស្បៀកសំពត់ និងសំពត់ដណ្តប់ បិទទ្វារ

ហើយដើរទៅជិតភិក្ខុ ( អ្នកដើមគំនិត ) នោះ ក៏ត្រូវអាបត្តិទុក្កដ ព្រោះបង់បោយ និងឈានជើងគ្រប់ៗ គ្រាទៅ ។ ភិក្ខុអង្គនោះសួរភិក្ខុផ្ដើមគំនិតនោះថា ភិក្ខុឈ្មោះនោះ និងឈ្មោះនោះ នៅទីណា លោកម្ចាស់ចូរហៅភិក្ខុឈ្មោះនោះ និងភិក្ខុឈ្មោះនោះមកចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដគ្រប់ៗ ម៉ាត់ ។ កាលភិក្ខុគ្រប់អង្គមកព្រមគ្នាហើយ ក៏បបួលថា ខ្ញុំជួបកំណប់ទ្រព្យបែបនេះក្នុងកន្លែងឈ្មោះនោះ ពួកយើងចូរមក ទៅយកទ្រព្យនោះ ហើយនឹងបំពេញ បុណ្យផង រស់នៅយ៉ាងសប្បាយផង ដូច្នេះ ក៏ត្រូវអាបត្តិទុក្កដគ្រប់ៗ ម៉ាត់ ។ លោកបានសម្លាញ់យ៉ាងនោះហើយ ទើបស្វែងរកចប បើភិក្ខុអង្គនោះ មានចបសម្រាប់ខ្ទួនសោត ទើបពោលថា ខ្ញុំនឹងនាំចបនោះមក ខណៈដើរទៅកាន់យក និងនាំមក រមែងត្រូវអាបត្តិទុក្កដ ព្រោះបង់បោយ និងឈានជំហានគ្រប់ៗ គ្រាទៅ ។ បើចបមិនមាន ក៏ទៅសូមភិក្ខុ ឬគ្រហស្ថដទៃ និងកាលសូម ក៏ពោលកុហកថា សូមឲ្យចបដល់ខ្ញុំ ខ្ញុំត្រូវការចប ខ្ញុំមានកិច្ចខ្លះដែលត្រូវធ្វើ កិច្ចនោះសម្រេចហើយ នឹងនាំមកសង ដូច្នេះ ត្រូវអាបត្តិទុក្កដគ្រប់ៗ ម៉ាត់ ។ បើមានប្រឡាយដែលនឹងត្រូវជម្រះឲ្យស្អាតសោត លោកទោះបីពោលពាក្យកុហកថា ការឆ្ការដីក្នុងវត្តដែលត្រូវធ្វើមាន ពាក្យពោលណាមួយដែលជាពាក្យកុហក រមែងត្រូវអាបត្តិបាចិត្តិយព្រោះពាក្យពោលនោះៗ ។ តែក្នុងមហាអដ្ឋកថា លោកកាត់អាបត្តិទុក្កដទាំងអស់ ទាំងពាក្យពិត ទាំងពាក្យមិនពិតនោះឯង ។ ពាក្យដែលពោលទុកក្នុងមហាអដ្ឋកថានេះ គប្បីជ្រាបថាសរសេរទុកដោយការភ្លាំងភ្លាត់ ។ ដែលឈ្មោះថា ទុក្កដ ក្នុងឋានៈនៃបាចិត្តិយ

ដែលជាបុព្វយោគនៃអទិន្នាទាន មិនមានឡើយ ។ បើចបមិនមានដង ភិក្ខុពោលថា នឹងធ្វើដង ហើយសំលៀងកាំបិត ឬពូថៅចេញដើរទៅ ដើម្បីកាប់ដងចបនោះ កាលទៅហើយ ក៏កាប់ឈើស្ងួត ចាំង ឈូស រមែងត្រូវអាបត្តិទុក្កដ ព្រោះកម្រើកដៃ និងឈានជើងគ្រប់ៗ ជំហានទៅ ។ បើលោកកាប់ឈើដែលស្រស់ ត្រូវអាបត្តិបាចិត្តិយ បន្ទាប់អំពីនោះទៅ ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ។ តែក្នុងសង្ខេបអដ្ឋកថា និងមហាបច្ចរី លោកកាត់អាបត្តិទុក្កដដល់ភិក្ខុអ្នកស្វែងរកកាំបិត និងពូថៅ ដើម្បីកាប់ឈើ និងវល្លិ៍ដែលកើតក្នុងទីនោះៗ ។ លោកពោលទុកក្នុងមហាបច្ចរីថា បើភិក្ខុទាំងនោះគិតយ៉ាងនេះថា ពួកយើងកាលសូមកាំបិត ពូថៅ និងចប នឹងមិនមានសេចក្តីសង្ស័យ ពួកយើងស្វែងរកឲ្យជួបដែកហើយ សឹមធ្វើ ដូច្នេះហើយក្រោយមក ទើបដើរទៅកាន់អណ្តូងរ៉ែដែក ហើយជីកផែនដីដើម្បីត្រូវការរ៉ែដែក ។ កាលពួកលោកជីកផែនដី ដែលជាអកប្បិយក៏ត្រូវអាបត្តិបាចិត្តិយព្រមទាំងទុក្កដដ៏ច្រើន ក្នុងបាលីបទេសនេះ អាបត្តិបាចិត្តិយ ព្រមទាំងអាបត្តិទុក្កដជាច្រើនរមែងមាន យ៉ាងណា ក្នុងបាលីបទេសគ្រប់អន្លើក៏ដូច្នោះ ក្នុងឋានៈនៃបាចិត្តិយរមែងមិនផុតអំពីទុក្កដ ។ បើពួកលោកជីកផែនដី ដែលជាកប្បិយវិញ ក៏ត្រូវអាបត្តិទុក្កដជាច្រើនដូចគ្នា ។ កាលកាន់យករ៉ែ ហើយបន្ទាប់អំពីនោះ ក៏ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ព្រោះកិរិយាដែលធ្វើគ្រប់យ៉ាង ។ សូម្បីស្វែងរកកញ្ចើក៏ត្រូវអាបត្តិទុក្កដ ព្រោះដៃកម្រើក និងជំហានតាមន័យដែលពោលមកហើយនោះឯង ។ ត្រូវអាបត្តិបាចិត្តិយព្រោះពោល

កុហក ។ ព្រោះមានបំណងនឹងធ្វើកញ្ជើ ត្រូវអាបត្តិបាចិត្តិយ ព្រោះកាត់វល្លិ៍ ពាក្យទាំងអស់ដូចពណ៌នាមកនេះ គប្បីជ្រាបដោយន័យមុននោះឯង ។

ត្រើនបទថា **គច្ឆតិ វា អាបត្តិ ទុក្កដស្ស** សេចក្ដីថា ភិក្ខុអ្នកស្វែងរកសម្ភារៈ ចប និងកញ្ជើបានហើយយ៉ាងនោះ ដើរទៅកាន់ទីកប់ទ្រព្យ រមែងត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន ។ បើដើរទៅកើតកុសលចិត្តឡើងថា អញបានកំណប់ទ្រព្យនេះហើយ នឹងធ្វើពុទ្ធបូជា ធម្មបូជា ឬសង្ឃភត្ត ដូច្នេះហើយ មិនត្រូវអាបត្តិព្រោះការដើរទៅដោយកុសលចិត្ត ។

សួរថា ព្រោះហេតុអ្វី ទើបមិនត្រូវអាបត្តិ ឆ្លើយថា ព្រោះព្រះដ៏មានភាគត្រាស់ហើយថា ភិក្ខុមានថេយ្យចិត្ត ត្រាច់ស្វែងរកមិត្រសម្លាញ់ក្ដី ស្វែងរកចប កញ្ជើក្ដី ដើរទៅក្ដី ត្រូវអាបត្តិទុក្កដ ដូច្នេះ ទើបមិនត្រូវអាបត្តិដល់បុគ្គលមិនមានថេយ្យចិត្តក្នុងទីទាំងពួង ដូចក្នុងការដើរទៅ កាន់ទីកប់ទ្រព្យនេះ ដូច្នោះ ភិក្ខុចៀសចេញអំពីផ្លូវ ហើយធ្វើផ្លូវដើម្បីដើរទៅកាន់រណ្ដៅទ្រព្យ កាត់ភូតគាមត្រូវបាចិត្តិយ កាត់ឈើងាប់ ត្រូវអាបត្តិទុក្កដ ។

ពីរបទថា **តត្ថ ជាតកំ** គឺដែលកើតនៅលើថ្នាំង ដែលតាំងទុកយូរហើយ ។ បទពីរថា **កដ្ឋំ វា លតំ វា** សេចក្ដីថា មិនមែនកាត់ចំពោះឈើនិងវល្លិ៍តែម្យ៉ាងប៉ុណ្ណោះឡើយ កាលភិក្ខុកាត់រុក្ខជាតិ មានស្មៅ ដើមឈើនិងវល្លិ៍ជាដើម ប្រភេទណាមួយ ដែលនៅស្រស់ក៏ដោយ ស្ងួតក៏ដោយ ត្រូវអាបត្តិទុក្កដដូចគ្នា ព្រោះជាសហបយោគ ។

# អាបត្តិទុក្កដ ៨ យ៉ាង

ពិតហើយ ព្រះថេរៈទាំងឡាយ ប្រមូលឈ្មោះទុក្កដ ៨ យ៉ាងនោះមកសម្តែងទុកក្នុងទីនេះហើយ គឺ បុព្វយោគទុក្កដ ១ សហបយោគទុក្កដ ១ អនាមាសទុក្កដ ១ ទុរុបចិណ្ណទុក្កដ ១ វិនយទុក្កដ ១ ញាតទុក្កដ ១ ញត្តិ-ទុក្កដ ១ បដិស្សវទុក្កដ ១ បណ្តាទុក្កដ ៨ យ៉ាងនោះ ទុក្កដដែលព្រះដ៏មានព្រះភាគត្រាស់ទុកយ៉ាងនេះថា ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចនូវទ្រព្យដែលស្ថិតនៅក្នុងដី ហើយស្វែងរកគ្នាឲ្យបានពីរនាក់ក្តី ស្វែងរកចបក្តី កញ្ជើក្តី ដើរទៅតែឯងក្តី ត្រូវអាបត្តិទុក្កដ នេះឈ្មោះថា បុព្វបយោគទុក្កដ ។ ពិតហើយ ក្នុងព្រះតម្រាស់ដែលត្រាស់ទុកនេះ ក្នុងឋានៈនៃទុក្កដ ជាទុក្កដ ក្នុងឋានៈនៃបាចិត្តិយ ក៏ជាបាចិត្តិយដោយពិត ។

ទុក្កដដែលត្រាស់ទុកដូច្នេះថា ភិក្ខុកាត់នូវឈើ ឬវល្លិ៍ដែលកើតក្នុងទីនោះ ត្រូវអាបត្តិទុក្កដ នេះឈ្មោះថា សហបយោគទុក្កដ ។ ក្នុងព្រះតម្រាស់ដែលត្រាស់ទុកនេះ វត្ថុនៃបាចិត្តិយ និងវត្ថុនៃទុក្កដ ក៏បានតាំងនៅក្នុងឋានៈនៃទុក្កដដូចគ្នា ។ ព្រោះហេតុអ្វី ព្រោះការលួចប្រព្រឹត្តទៅព្រមគ្នានឹងសេចក្តីព្យាយាម ។

ម្យ៉ាងទៀត ទុក្កដដែលទ្រង់បញ្ញត្តដល់ភិក្ខុដែលប៉ះពាល់រតនៈ ១០ យ៉ាង ស្រូវ ៧ ប្រការ និងគ្រឿងសស្ត្រាវុធទាំងអស់ជាដើមនេះ ឈ្មោះថា អនាមាសទុក្កដ ។

ទុក្កដដែលទ្រង់បញ្ញត្តទុកដល់ភិក្ខុ ដែលចាប់ពាល់បណ្តាផ្លែឈើទាំង-ឡាយ មានចេក និងដូងជាដើម ផ្លែដែលកើតក្នុងទីនោះ នេះឈ្មោះថា ទុរុ-

បបិណ្ឌទុក្កដ ។

ម្យ៉ាងទៀត ទុក្កដដែលទ្រង់បញ្ញត្តទុកដល់ភិក្ខុដែលត្រាច់បិណ្ឌបាត មិនទទួលប្រគេន ឬមិនលាងបាត្រ ក្នុងកាលមានលម្អងធូលីធ្លាក់ចូលទៅក្នុងបាត្រ ក៏ទទួលភិក្ខាក្នុងបាត្រ នេះឈ្មោះថា វិនយទុក្កដ ។

ទុក្កដឈ្មោះថា ពួកភិក្ខុបានស្តាប់ ( រឿងព្យាយាមដើម្បីបំបែកសង្ឃ ) ហើយមិនពោល ត្រូវអាបត្តិទុក្កដ នេះឈ្មោះថា ញាតទុក្កដ ។

ទុក្កដដែលត្រាស់ទុកថា ត្រូវទុក្កដព្រោះញត្តិ ក្នុងបណ្តាសមនុភាសនៈ ១១ យ៉ាងនេះ ឈ្មោះថា ញត្តិទុក្កដ ។

ទុក្កដដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សា របស់ភិក្ខុនោះមិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យប្តេជ្ញាផង នេះឈ្មោះថា បដិស្សវទុក្កដ ។

ចំណែកសហបយោគទុក្កដ ( គឺត្រូវអាបត្តិទុក្កដ ដោយសេចក្តីព្យាយាមព្រម ) ដូចតទៅនេះថា ព្រោះហេតុនោះ ទើបខ្ញុំពោលថា កាលភិក្ខុកាត់វុក្ខជាតិ មានស្មៅក្តី ដើមឈើក្តី វល្លិ៍ក្តី ជាដើមប្រភេទណាមួយ ទោះស្រស់ឬស្ងួត ត្រូវអាបត្តិទុក្កដដូចគ្នា ព្រោះជាសហបយោគ ។ បើភិក្ខុនោះកាត់វុក្ខជាតិ មានស្មៅ ដើមឈើ និងវល្លិ៍ជាដើម ដែលកើតឡើងក្នុងទីនោះលដ្ឋីធមិរមែងឈមចុះ ការសម្រេមកើតឡើង លោកសម្តែងទុក្កដ ព្រោះការកាត់ជាបច្ច័យហើយ រមែងរួចផុត ។ បើលោកមិនដាក់ធុរៈ នៅមានការព្យាយាមជីកដីនោះឯង ទុក្កដព្រោះការកាត់ រមែងរម្ងាប់ទៅ លោករមែងតាំង

នៅក្នុងទុក្កដព្រោះការជីក ព្រោះថា ភិក្ខុកាលជីកផែនដីជាអកប្បិយ រមែងត្រូវទុក្កដនោះឯង ក្នុងអធិការពោលដោយការជីកដីនេះ ព្រោះជាសហ-បយោគ ។ បើលោកជីកក្នុងគ្រប់ទិសស្រេចបាច់ហើយ រហូតដល់ទីតាំងផ្ទាំងទ្រព្យ លជ្ជីធម៌ឈមចុះ លោកសម្តែងទុក្កដ ព្រោះការជីកជាបច្ច័យចេញហើយ រមែងរួចផុត ( អាបត្តិ ) បាន ។

បទថា **វិយូហតិ វា** សេចក្តីថា បើភិក្ខុនៅមានការខ្នះខ្នែងដូចដើម កាយដីធ្វើជាគំនរក្នុងចំណែកម្ខាង **ខណនទុក្កដ** គឺទុក្កដព្រោះការជីករមែងរម្ងាប់ទៅ លោករមែងតាំងនៅក្នុង **វិយូហនទុក្កដ** គឺទុក្កដព្រោះការកកាយ ។ កាលលោកធ្វើអាចម៍ដីនោះឲ្យ ជាគំនរក្នុងទីនោះៗ រមែងត្រូវទុក្កដគ្រប់ៗប្រយោគ ។ តែបើលោកធ្វើជាគំនរហើយ ដាក់ធុរៈចោល ដល់នូវលជ្ជីធម៌សម្តែង **វិយូហនទុក្កដ** ហើយរមែងផុត ( អំពីអាបត្តិ ) បាន ។

បទថា **ឧទ្ធរតិ វា** សេចក្តីថា បើភិក្ខុនៅមានសេចក្តីព្យាយាមកោយអាចម៍ដីឡើងឲ្យធ្លាក់ទៅខាងក្រៅ **វិយូហនទុក្កដ** រមែងរម្ងាប់ទៅ លោករមែងតាំងនៅក្នុង **ឧទ្ធរណទុក្កដ** គឺទុក្កដព្រោះការកោយឡើង ។ កាលលោកប្រើចបក្តី ដែទាំងពីរក្តី កញ្ជើក្តី បាចអាចម៍ដីឲ្យធ្លាក់ទៅក្នុងទីនោះៗ រមែងត្រូវទុក្កដគ្រប់ប្រយោគ តែបើលោកនាំអាចម៍ដីទាំងអស់ចេញទៅហើយ រហូតដល់ធ្វើផ្ទាំងទ្រព្យឲ្យតាំងនៅលើគោក ជួបលជ្ជីធម៌ កាលសម្តែងនូវ **ឧទ្ធរណទុក្កដ** ហើយ រមែងផុត ( អំពីអាបត្តិ ) បាន ។ តែបើលោកនៅមានការខ្នះខ្នែងនោះឯង ចាប់ពាល់ផ្ទាំងទ្រព្យ **ឧទ្ធរណទុក្កដ** រមែងរម្ងាប់ទៅ

លោករមែងតាំងនៅក្នុង **អាមសកទុក្កដ** គឺទុក្កដព្រោះការចាប់ពាល់ប៉ុណ្ណោះ ។ កាលចាប់ពាល់ហើយ ជួបនូវលជ្ជីធម៌ សម្តែង **អាមសកទុក្កដ** ចេញហើយ រមែងរួចផុត ( ចាកអាបត្តិ ) បាន ។ បើលោកនៅមានសេចក្តីខ្នះខ្នែងតទៅទៀត ធ្វើផ្ទាំងទ្រព្យឲ្យកម្រើក **អាមសកទុក្កដ** រមែងរម្ងាប់ទៅ លោករមែងតាំងនៅក្នុងថុល្លច្ច័យ ដូចដែលទ្រង់ត្រាស់ទុកថា ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ដូច្នេះ ។

# អធិប្បាយ ពាក្យថា ទុក្កដ និងថុល្លច្ច័យ

ទុក្កដ និងថុល្លច្ច័យទាំងពីរ ដែលត្រាស់ទុកក្នុងព្រះបាលីនោះ មានអត្ថចំពោះពាក្យដូចតទៅនេះ បណ្តាទុក្កដ និងថុល្លច្ច័យទាំងពីរនេះ គប្បីជ្រាបទុក្កដទី ១ មុន ការធ្វើអាក្រក់ គឺការធ្វើឲ្យខុសអំពីកិច្ចដែលព្រះសាស្តាត្រាស់ ព្រោះដូច្នោះ ទើបឈ្មោះថា ទុក្កដ ។ម្យ៉ាងទៀត ដែលឈ្មោះថា ទុក្កដ ព្រោះអត្ថវិគ្គហៈទាំងនេះខ្លះៗ ថា ការធ្វើអាក្រក់ គឺកិរិយានោះមិនត្រូវប្រក្រតី រមែងមិនស្អាតក្នុងចំណោមនៃកិរិយារបស់ភិក្ខុ ។ ពិតហើយ សូម្បីព្រះដ៏មានព្រះភាគក៏បានត្រាស់ពាក្យនេះថា

> សិក្ខាបទណា ដែលតថាគតហៅថា ទុក្កដ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសម្តែងតទៅនេះ ។ អំពើអាក្រក់ណា ទោះខុសក្តី ធ្លាំធ្លងក្តី ភ្លាំងភ្លាត់ក្តី មនុស្សទាំងឡាយ ធ្វើអំពើបាបណាមួយ ទោះក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី អ្នកប្រាជ្ញទាំងឡាយ តែងហៅថា អំពើអាក្រក់ ព្រោះហេតុដូច្នោះ

សិក្ខាបទនោះ តថាគតហៅថា ទុក្កដ ។

ចំណែកវីតិក្កមក្រៅអំពីនេះ ឈ្មោះថា ថុល្លច្ច័យ ព្រោះជាកម្មគ្រោតគ្រាត និងព្រោះជាទោស មានប្រកបគ្នាក្នុងពាក្យថា ថុល្លច្ច័យនេះ អ្នកសិក្សាគួរជ្រាប ដូចក្នុងពាក្យថា ទុគ្គតិ ក្នុងសម្បរាយភព និងកម្មនោះ ជារបស់មានផលក្តៅក្រហាយជាដើម ។ ពិតហើយ បណ្តាទោសដែលទឹងគប្បីសម្តែងក្នុងសម្នាក់របស់ភិក្ខុមួយអង្គ ទោសដែលគ្រោតគ្រាតជានិច្ចដោយថុល្លច្ច័យនោះ រមែងមិនមាន ព្រោះហេតុនោះ ទើបខ្ញុំពោលថា ដែលឈ្មោះថា ថុល្លច្ច័យ ព្រោះជាកម្មគ្រោតគ្រាត និងព្រោះភាពជាទោស ។ ពិតហើយ ពាក្យនេះ ព្រះដ៏មានព្រះភាគ បានត្រាស់ហើយថា

> សិក្ខាបទណា ដែលតថាគតហៅថា ថុល្លច្ច័យ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសម្តែងតទៅនេះ ។ ភិក្ខុណាសម្តែង ( អាបត្តិ ) ក្នុងទីជិតនៃភិក្ខុមួយរូប ឬក៏ភិក្ខុណាទទួលអាបត្តិនោះ ទោស ( របស់ភិក្ខុអ្នកទទួល ) មិនមែនមានដូចជាភិក្ខុអ្នកសម្តែងនោះឡើយ ព្រោះហេតុដូច្នោះ សិក្ខាបទនុ៎ះ ទើបតថាគតហៅថា ថុល្លច្ច័យ ។

កាលភិក្ខុធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យគ្រប់ៗ ប្រយោគ ។ តែបើលោកធ្វើឲ្យកម្រើកហើយ ឈានចុះកាន់លជ្ជីធម៌ សម្តែងថុល្លច្ច័យចេញហើយ រមែងរួចផុតបាន ។ ឯអាបត្តិដែលកើតមុនៗ ព្រោះធ្វើឲ្យកម្រើកនេះ រមែងរម្ងាប់ទៅ តាំងអំពីសហបយោគនោះឯង ។ ក្នុងកុរុន្ទីអដ្ឋកថាដែលពោលថា

ឯទុក្កដ និងបាចិត្តិយពួកណា ក្នុងបុព្វយោគ ភិក្ខុនោះសម្តែងសហបយោគ ហើយឈានចុះកាន់លដ្ឋិធម៌ហើយត្រូវទុក ( គឺមិនទាន់រម្ងាប់ ? ) ទុក្កដ និង បាចិត្តិយទាំងអស់នោះ គួរសម្តែង ។ ចំណែកទុក្កដសូម្បីមានចំនួនច្រើន ព្រោះកាត់ស្មៅ ដើមឈើ និងវល្លិ៍ជាដើមដែលកើតឡើងហើយក្នុងទីនោះ ដែលជាសហបយោគ រមែងរម្ងាប់ទៅ ព្រោះដល់នូវការជីកដី ។ អាបត្តិ ទុក្កដព្រោះជីកដីមួយប៉ុណ្ណោះមាន ទុក្កដជាច្រើនព្រោះការជីក រមែងរម្ងាប់ទៅ ព្រោះដល់នូវការកាយ អាបត្តិទុក្កដជាច្រើនព្រោះការកាយ រមែងរម្ងាប់ទៅ ព្រោះដល់នូវការកោយឡើង អាបត្តិទុក្កដជាច្រើន ព្រោះការកោយឡើង រមែងរម្ងាប់ទៅ ព្រោះដល់នូវការចាប់ពាល់ អាបត្តិទុក្កដជាច្រើន ព្រោះការ ចាប់ពាល់រមែងរម្ងាប់ទៅ ព្រោះដល់នូវការឲ្យកម្រើក ។ កាលបើលដ្ឋិធម៌ កើតឡើងក្នុងខណៈជីកដីជាដើម អាបត្តិសូម្បីមានច្រើនក៏ដោយចុះ លោក សម្តែងត្រឹមតែមួយប៉ុណ្ណោះ រមែងរួចផុតបាន ។ ពិតហើយ ដែលបានឈ្មោះ ជាការរម្ងាប់នៃអាបត្តិដែលកើតឡើងមុននេះ មកហើយក្នុងសូត្រ ក្នុងអនុ-សាវនាទាំងឡាយនោះឯង យ៉ាងនេះថា ទុក្កដ ព្រោះញត្តិ ថុល្លច្ច័យ ព្រោះ ទុតិយកម្មវាចា រមែងរម្ងាប់ទៅ ។ តែការរម្ងាប់នៃអាបត្តិដែលកើតឡើងមុន ក្នុងទុតិយបារាជិកនេះ អ្នកសិក្សាគួរកាន់យកដោយប្រមាណនៃព្រះអដ្ឋកថា-ចារ្យនេះឯង ។

## ឋាននៃទ្រព្យ ៦ យ៉ាង

ប្រើនបទថា **ឋានា ចាវេតិ អាបត្តិ ចារាជិកស្ស** សេចក្តីថា ភិក្ខុ

ណាធ្វើឲ្យកម្រើកហើយ ក៏មិនឈានចុះកាន់លជ្ជីធម៌ឡើយ ញ៉ាំងផ្ទាំងទ្រព្យនោះឲ្យឃ្លាតចាកស្ថាន ដោយហោចសូម្បីត្រឹមមួយសរសៃសក់ ភិក្ខុនោះត្រូវអាបត្តិបារាជិកនោះឯង ។ ឯការញ៉ាំងទ្រព្យឲ្យឃ្លាតចាកទីក្នុងពាក្យថា **ឋានា ចាវេតិ** នេះ គប្បីជ្រាបដោយអាការ ៦ ។ អាការ ៦ ដូចម្តេច ភិក្ខុចាប់មាត់ផ្ទាំង ទាញរំកិលមកត្រង់មុខរបស់ខ្លួន ញ៉ាំងទីបំផុតខាងឯណោះឲ្យកន្លងឱកាសទីបំផុតខាងនេះដែលប៉ះត្រូវហើយ សូម្បីប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ១ ភិក្ខុចាប់យ៉ាងនោះហើយ រុញទៅខាងមុខ ញ៉ាំងទីបំផុតខាងនេះឲ្យហួសឱកាសទីបំផុតខាងណោះប៉ះត្រូវហើយ សូម្បីប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ១ ភិក្ខុទាញទៅខាងឆ្វេង ញ៉ាំងទីបំផុតខាងស្តាំ ឲ្យកន្លងឱកាសទីបំផុតខាងឆ្វេងប៉ះត្រូវហើយ សូម្បីប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ១ ភិក្ខុទាញទៅខាងស្តាំ ញ៉ាំងទីបំផុតខាងឆ្វេងកន្លងឱកាសទីបំផុតខាងស្តាំប៉ះត្រូវហើយ សូម្បីប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ១ ភិក្ខុលើកឡើងខាងលើឲ្យផុតពីផ្ទៃដី សូម្បីប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ១ ភិក្ខុជីកជីសន្ធត់ចុះក្រោម ញ៉ាំងមាត់ផ្ទាំងខាងលើឲ្យកន្លងឱកាសដែលបាតផ្ទាំងប៉ះត្រូវហើយ សូម្បីប៉ុនចុងសក់ ត្រូវអាបត្តិបារាជិក ១ ។

ការឲ្យឃ្លាតចាកស្ថានសម្រាប់ផ្ទាំងដែលតាំងនៅក្នុងស្ថានណាមួយ គប្បីជ្រាបដោយអាការ ៦ យ៉ាងនេះ ដោយប្រការដូច្នេះ ។ បើបុគ្គលនោះធ្វើអន្ទាក់ត្រង់កណ្តាប់មាត់ផ្ទាំង ហើយបោះបង្គោលលោហៈ ឬបង្គោលឈើខ្លឹមមានគគីរជាដើមចុះក្នុងផែនដី ហើយយកខ្សែប្រវាក់ ចងលាមត្រង់បង្គោល

នោះតាំងទុក ផ្ទាំងដែលចងលាមដោយខ្សែមួយសរសៃក្នុងទិសមួយ រមែងបានស្ពាន ២ ។ ចងលាមដោយខ្សែច្រើនសរសៃក្នុងទិស ២-៣-៤ រមែងបានស្ពាន ៣-៤-៥ ។ បណ្ដាផ្ទាំងដែលចងលាមទុកត្រង់បង្គោលតែមួយជាដើមនោះ ភិក្ខុលើកបង្គោលដំបូងនៃផ្ទាំង ដែលចងលាមទុកត្រង់បង្គោលតែមួយឡើងក្ដី កាត់ប្រវាក់ក្ដី ត្រូវថុល្លច្ច័យ ។ ក្រោយមក ឲ្យផ្ទាំងឃ្លាតចាកស្ពានសូម្បីត្រឹមមួយចុងសក់ ដោយន័យតាមដែលពោលហើយនោះឯង ត្រូវអាបត្តិបារាជិក ។ បើលើកផ្ទាំងឡើងដំបូង ត្រូវអាបត្តិថុល្លច្ច័យ ។ ខាងក្រោយឲ្យបង្គោលឃ្លាតចាកស្ពានសូម្បីត្រឹមមួយចុងសក់ក្ដី កាត់ប្រវាក់ក្ដី ត្រូវអាបត្តិបារាជិក ។ ក្នុងការញ៉ាំងទីបំផុតនៃផ្ទាំងដែលលាមទុកត្រង់បង្គោល ២-៣-៤ បង្គោលឲ្យឃ្លាតចាកស្ពាន ក៏ត្រូវបារាជិកដោយឧបាយនោះ ។ ក្នុងបង្គោលដ៏សេសទាំងឡាយ គប្បីជ្រាបថា ជាថុល្លច្ច័យ បើមិនមានបង្គោល គេធ្វើវង្វង់កងទុកត្រង់ចុងប្រវាក់ ហើយទើបស៊កចូលទៅត្រង់ឫសឈើដែលកើតក្នុងទីនោះ ភិក្ខុលើកផ្ទាំងឡើងមុន ខាងក្រោយ ទើបកាត់ឫសឈើ ហើយនាំវង្វង់កងចេញ ត្រូវអាបត្តិបារាជិក ។ បើមិនកាត់ឫសឈើ តែឲ្យវង្វង់កងរូតបន្ទិតទៅខាងណោះ និងខាងណេះ នៅរក្សានៅឡើយ ។ សូម្បីមិនទាន់នាំចេញអំពីឫសឈើ គ្រាន់តែយកដៃចាប់បង្អើបឲ្យផុតទៅក្នុងអាកាស ក៏ត្រូវអាបត្តិបារាជិក ។ សេចក្ដីប្លែកគ្នាក្នុងអធិការពោលអំពីផ្ទាំង ដែលគេស៊កចូលទុកត្រង់ឫសឈើនេះ មានប្រមាណប៉ុណ្ណោះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ឯជនពួកខ្លះដាំដើមជ្រៃជាដើមទុកខាងលើផ្ទាំង ដើម្បីជា

គ្រឿងសម្គាល់ ។ ឫសឈើជាប់ប្រទាក់ថ្នាំងតាំងនៅ ។ ភិក្ខុគិតថា នឹងកាត់ឫសឈើលួចថ្នាំងទៅ កំពុងកាត់ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគ ។ កាត់ហើយធ្វើឱកាសឲ្យថ្នាំងឃ្លាតចាកស្ថានសូម្បីមួយចុងសក់ត្រូវអាបត្តិបារាជិក ។ កាលកំពុងកាត់ឫសឈើនោះឯង ថ្នាំងរបូតរមៀលទៅកាន់ទីទំនាប នៅរក្សានៅឡើយ កាលលើកឡើងចាកស្ថានដែលថ្នាំងរមៀលទៅ ត្រូវអាបត្តិបារាជិក ។ កាលកាត់ឫសឈើទាំងឡាយហើយ ថ្នាំងតាំងនៅបានដោយឫស ១ ភិក្ខុនោះគិតថា កាលកាត់ឫសឈើនេះហើយ ថ្នាំងនឹងធ្លាក់ទៅ ទើបកាត់ឫសឈើនោះ លុះកាត់ដាច់ ត្រូវអាបត្តិបារាជិក ។ បើថ្នាំងតាំងនៅដោយឫសតែមួយប៉ុណ្ណោះ ដូចជ្រូកត្រូវចងទុកត្រង់អន្ទាក់ ដូច្នោះ វត្ថុដទៃដែលជាប់មិនមានសូម្បីកាលឫសនោះ លុះកាត់ដាច់ហើយ ក៏ត្រូវបារាជិក ។ បើគេដាក់ដុំថ្មមួយផ្ទាំងធំសង្កត់ទុកលើថ្នាំង ភិក្ខុមានបំណងនឹងយកកំណាត់ឈើគាស់ដុំថ្មនោះចេញ ទើបកាត់ដើមឈើដែលកើតនៅលើថ្នាំងចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាត់ដើមឈើជាដើម ដែលដុះនៅក្បែរថ្នាំងនោះ ហើយនាំចេញ ខណៈកាត់ដើមឈើជាដើមនោះ មិនត្រូវអាបត្តិបាចិត្តិយ ព្រោះដើមឈើជារបស់កើតនៅលើថ្នាំងនោះ ។

ពីរបទថា **អត្តនោ ភាជនំ** សេចក្តីថា បើភិក្ខុមិនអាចនឹងលើកយកថ្នាំងឡើងបាន ទើបស៊កភាជនៈរបស់ខ្លួនចូលទៅ ដើម្បីដួសយកទ្រព្យដែលនៅក្នុងថ្នាំង មានថេយ្យចិត្ត ចាប់ត្រូវទ្រព្យខាងក្នុងថ្នាំង គួរដល់តម្លៃ ៥ មាសកក្តី លើសជាង ៥ មាសកក្តី ត្រូវអាបត្តិទុក្កដ ។ ឯការកំណត់ដែលលោក

ពោលទុកហើយក្នុងព្រះបាលីនេះ ដើម្បីកំណត់អាបត្តិបារាជិក ។ កាលភិក្ខុចាប់ត្រូវទ្រព្យតិចជាង ៥ មាសកដោយថេយ្យចិត្ត ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។

ក្នុងពាក្យថា **ជង្ឃាបេតិ** នេះ សេចក្ដីថា ភិក្ខុប្រមូលទ្រព្យឲ្យជាប់គ្នាហើយស៊កកាជនះរបស់ខ្លួនចូលទៅជរាបណា ភិក្ខុនោះ លោកហៅថា ធ្វើឲ្យកម្រើកត្រឹមនោះ ។ ម្យ៉ាងទៀត បើកាយប្រមូលទៅខាងនោះ និងខាងនេះឈ្មោះថា ធ្វើឲ្យកម្រើកដូចគ្នា ភិក្ខុនោះ រមែងត្រូវអាបត្តិថុល្លច្ច័យ ។ ក្នុងកាលណា ភិក្ខុកាត់ការជាប់គ្នានៃទ្រព្យឲ្យជាប់គ្នាហើយ ទ្រព្យដែលនៅក្នុងឆ្នាំង ក៏មាននៅក្នុងឆ្នាំងនោះឯង ទ្រព្យដែលនៅក្នុងកាជនៈ ក៏មាននៅក្នុងកាជនៈប៉ុណ្ណោះ ក្នុងកាលនោះ ទ្រព្យឈ្មោះថា មាននៅក្នុងកាជនៈរបស់ខ្លួនហើយ កាលភិក្ខុធ្វើយ៉ាងនោះហើយ ទោះបីមិនបាននាំកាជនៈចេញអំពីឆ្នាំងក្ដី ត្រូវអាបត្តិបារាជិក ។

ក្នុងពាក្យថា **មុដ្ឋឹ វា ឆិន្ទតិ** នេះ សេចក្ដីថា កហាបណៈដែលលៀនចេញតាមប្រហោងម្រាមដៃហើយ មិនប៉ះកហាបណៈដែលនៅក្នុងឆ្នាំងដោយវិធីណា ភិក្ខុធ្វើការក្ដាប់យកដោយវិធីនោះ ឈ្មោះថា ក្ដាប់យក ភិក្ខុនោះ ក៏ត្រូវអាបត្តិបារាជិក ។

បទថា **សុត្តារូឡ្ហំ** បានដល់ ទ្រព្យដែលដោតទុកដោយអំបោះ ។ ពាក្យថា **សុត្តារូឡ្ហំ** នេះ ជាឈ្មោះរបស់គ្រឿងប្រដាប់ដែលដោតទុកដោយអំបោះខ្លះ ដែលសម្រេចដោយអំបោះខ្លះ ។ គ្រឿងប្រដាប់ទាំងឡាយ មានសង្វារជាដើម ដែលសម្រេចដោយមាសខ្លះក៏មាន ដែលសម្រេចដោយរូបិយ

ខ្លះក៏មាន ដែលសម្រេចដោយអំបោះខ្លះក៏មាន សូម្បីដោតគជ់ជាដើម ក៏ដល់នូវការសង្គ្រោះចូលក្នុងសង្ខារជាដើមនោះឯង ។ សំពត់សម្រាប់ជូតក្បាលលោកហៅថា **វេឋនៈ** ។ ភិក្ខុមានថេយ្យចិត្តចាប់ពាល់បណ្តាទ្រព្យដែលដោតទុកដោយអំបោះជាដើមនោះឯណាមួយ ត្រូវទុក្កដ ។ ធ្វើឲ្យកម្រើក ត្រូវថុល្លច្ច័យ ។ ចាប់ចុងសង្វារហើយ មិនបានធ្វើឲ្យអណ្តែតក្នុងអាកាស គ្រាន់តែលើកឡើង ( ចុងម្ខាងមិនទាន់ផុតដី ) ត្រូវថុល្លច្ច័យ ។

ក្នុងបទថា **យំសណ្ឋា ឆិយារតិ** នេះ មានវិនិច្ឆ័យដូច្នេះថា ក្នុងសង្ខេបអដ្ឋកថា និងមហាបច្ចរីជាដើម លោកពោលទុកថា កាលភិក្ខុទាញថ្នាំងដែលមានមាត់ស្មើ ដែលគេដាក់ត្រួតលើថ្នាំងដែលពេញ ចេញអំពីគ្នាក្តី ឬទាញសង្វារជាដើម ដែលគេដាក់ទុកក្នុងថ្នាំង ធ្វើចុងម្ខាងទុកត្រង់បាត ធ្វើចុងម្ខាងទុកត្រង់មាត់ចេញទៅក្តី ត្រូវអាបត្តិថុល្លច្ច័យ កាលឲ្យផុតមាត់ថ្នាំងត្រូវអាបត្តិបារាជិក ។ ចំណែកកណ្ឌៈណាដែលគេដាក់ទុកក្នុងថ្នាំងទទេ ឬថ្នាំងទំនេរ ក្នុងឱកាសដែលកណ្ឌៈពាល់ត្រូវប៉ុណ្ណោះ ជាឋានរបស់កណ្ឌៈ ថ្នាំងទាំងមូល មិនបានជាឋានឡើយ ព្រោះហេតុនោះ កាលភិក្ខុទាញកណ្ឌៈនោះចេញទៅ ប្រមាណត្រឹមចុងសក់ ផុតពីឱកាសដែលកណ្ឌៈនោះតាំងនៅ ត្រូវអាបត្តិបារាជិកភ្លាម ។ តែកាលភិក្ខុលើកឡើងត្រង់ៗ អំពីថ្នាំងដែលពេញ ឬមិនពេញ កាលកណ្ឌៈនោះផុតបាកឱកាសទីបំផុតខាងក្រោម ត្រូវអាបត្តិបារាជិក ។

កណ្ឌៈឯណានីមួយ ដែលល្មមត្រូវអាបត្តិបារាជិក ដែលគេដាក់ទុកក្នុងថ្នាំង កាលភិក្ខុឲ្យកម្រើកនៅក្នុងថ្នាំងទាំងអស់ និងកាលទាញគ្រឿងប្រដាប់

មានសង្ខារជាដើមចេញទៅ មិនទាន់ហួសមាត់ថ្នាំងដរាបណា តាំងនៅជាបុល្លច្ច័យដរាបនោះឯង ព្រោះថា ថ្នាំងទាំងមូល ជាឋានរបស់កណ្ឌៈនោះ ។

ចំណែកក្នុងមហាអដ្ឋកថា លោកពោលទុកថា ទីដែលគេតាំងទុកប៉ុណ្ណោះជាឋាន ថ្នាំងទាំងមូលមិនបានជាឋានទេ ព្រោះហេតុនោះ កាលភិក្ខុឲ្យផុតចាកឋានដើមដែលគេតាំងទុកទៅ សូម្បីត្រឹមមួយចុងសក់ ក៏ត្រូវបារាជិកក្នុងនោះឯង ។ ពាក្យក្នុងមហាអដ្ឋកថានោះជាប្រមាណ ។ ចំណែកពាក្យអដ្ឋកថាក្រៅពីនេះ លោកពោលតាមន័យនៃការមូរចីវរ ដែលពាក់នៅលើខ្សែស្បៀងរបស់ភិក្ខុដែលមិនបានធ្វើឲ្យទៅក្នុងអាកាស ។ ពាក្យដែលពោលទុកក្នុងសង្ខេបអដ្ឋកថាជាដើមនោះ មិនគួរកាន់យក ព្រោះវិនយធរគួរតាំងនៅក្នុងឋានៈដែលធ្ងន់ក្នុងកាលវិនិច្ឆ័យវិន័យដែលមកដល់ហើយ ។ សេចក្ដីនេះ ជាធម្មតាក្នុងវិន័យ ។ម្យ៉ាងទៀត ថ្នាំងទាំងមូលមិនជាឋាននៃកណ្ឌៈដែលឋិតនៅខាងក្នុងថ្នាំង យ៉ាងណា ពាក្យនៃសង្ខេបអដ្ឋកថាជាដើមនោះ បណ្ឌិតគប្បីជ្រាបយ៉ាងនោះ ព្រោះបាលីថា ភិក្ខុធ្វើទ្រព្យឲ្យចូលទៅក្នុងភាជនៈរបស់ខ្លួនក្ដី ក្ដាប់យកក្ដី ដូច្នេះឯង ។

## អធិប្បាយ ភិក្ខុលួចបឹតទឹកដោះថ្លាជាដើម

ក្នុងមហាអដ្ឋកថា លោកពោលទុកថា កាលភិក្ខុផឹករបស់រាវឯណាមួយមានទឹកដោះថ្លាជាដើមនោះ ចំណុះដែលលោកផឹកហើយដោយប្រយោគតែមួយ ត្រូវអាបត្តិបារាជិក ។ តែក្នុងអដ្ឋកថាទាំងឡាយ មានមហាបច្ចរីជាដើមលោកសម្ដែងវិភាគនេះទុកថា កាលភិក្ខុផឹកមិនដកមាត់ចេញ ហើយទឹកដោះថ្លា

ជាដើមដែលចូលទៅក្នុងបំពង់កមិនទាន់គ្រប់តម្លៃមួយបាទ រួមនឹងទឹកដោះដែលនៅក្នុងមាត់ផង ទើបបានមួយបាទ នៅរក្សានៅឡើយ តែក្នុងពេលដែលទឹកដោះថ្លាជាដើមគ្រប់តម្លៃក្នុងបំពង់កនោះឯង រមែងត្រូវ អាបត្តិបារាជិក ។ បើភិក្ខុកាត់ដោយការបិទបបូរមាត់ទាំងពីរខាង ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។ សូម្បីកាលផឹកដោយទងឧប្បល បំពង់ឫស្សី និងបំពង់បបុសជាដើម បើទឹកដោះថ្លាដែលនៅក្នុងបំពង់កបានតម្លៃមួយបាទ ត្រូវអាបត្តិបារាជិក ។ បើរួមជាមួយទឹកដោះដែលនៅក្នុងមាត់ ទើបបានតម្លៃមួយបាទ កាលទឹកដោះថ្លាជាដើមនោះ បើភិក្ខុកំណត់កាត់ដោយបបូរមាត់ទាំងពីរ ឲ្យការជាប់គ្នាជាមួយនឹងទឹកដោះ ដែលនៅក្នុងទងឧប្បលជាដើមដាច់ពីគ្នា ត្រូវអាបត្តិបារាជិក ។ បើរួមជាមួយទឹកដោះដែលនៅក្នុងទងឧប្បលជាដើម ទើបបានតម្លៃមួយបាទ ត្រូវអាបត្តិបារាជិក ក្នុងកាលចំណុះដែលភិក្ខុយកដៃបិទទង ឧប្បលជាដើមទុក ។ តែកាលទឹកដោះថ្លាជាដើម ដែលមានតម្លៃមួយបាទមិនទាន់ហូរចូលទៅក្នុងបំពង់ក ទាំងទឹកដោះដែលនៅក្នុងទងឧប្បលជាដើម ទាំងក្នុងមាត់មានតម្លៃលើសមួយបាទ តែជារបស់ទាក់ទងគ្នាតាំងនៅ នៅរក្សានៅឡើយ ដូច្នេះ ។ ពាក្យទាំងអស់ដែលពោលក្នុងមហាបច្ចរីជាដើមនោះ រមែងសមន័យនេះថា ភិក្ខុធ្វើឲ្យទ្រព្យចូលក្នុងភាជនៈរបស់ខ្លួនក្តី ក្តាប់យកក្តី ដូច្នេះ ព្រោះហេតុនោះ ( ពាក្យដែលលោកពោលទុកក្នុងអដ្ឋកថា មានមហាបច្ចរីជាដើមនោះ ) គឺលោកពោលសម្តែងទុកប្រពៃហើយ ។ ក្នុងកណ្ឌៈដែលទាក់ទងដូចគ្នា មានន័យប៉ុណ្ណោះសិន ។

បើភិក្ខុយកដែក្តី បាត្រក្តី ភាជនៈឯណាមួយ មានថាសជាដើមក្តីជួស ផឹកទឹកដោះថ្លាជាដើម នឹងគ្រប់តម្លៃមួយបាទក្នុងប្រយោគណា កាលធ្វើប្រយោគនោះហើយ ត្រូវអាបត្តិបារាជិក ។ បើទឹកដោះថ្លាជាដើម ជារបស់មានតម្លៃច្រើន ទាំងជារបស់ដែលអាចកាន់យកបានតម្លៃមួយបាទ ដោយត្រឹមប្រយោគមួយ ដូច្នេះ សូម្បីដោយស្វាបព្រាក្នុងកាលម្តងប៉ុណ្ណោះ ត្រូវអាបត្តិបារាជិក ។

ម្យ៉ាងទៀត កាលភិក្ខុសង្កត់ភាជនៈឲ្យលិចចុះ ហើយជួសយកទឹកដោះថ្លាជាដើមនោះ នៅជាប់គ្នាដរាបណា នៅរក្សាត្រឹមនោះ ត្រូវអាបត្តិបារាជិកដោយការដាច់ផុតមាត់ថ្នាំង ឬដោយការលើកឡើង ។ ឯទឹកដោះថ្លា ឬប្រេង ឬទឹកឃ្មុំ និងទឹកអំពៅដែលថ្លាដូចប្រេងនោះឯង ភិក្ខុផ្អៀងថ្នាំងឲ្យហូរចូលភាជនៈរបស់ខ្លួនកាលណា កាលនោះ ការជាប់គ្នារមែងមិនមាន ព្រោះរបស់ទាំងនោះជារបស់ថ្លា ព្រោះដូច្នោះ កាលទឹកដោះថ្លាជាដើមដែលបានតម្លៃមួយបាទ ដោយគ្រាន់តែហូរចេញអំពីមាត់ថ្នាំង ត្រូវអាបត្តិបារាជិក ។ ចំណែកទឹកឃ្មុំ និងទឹកអំពៅ ដែលគេរម្ងាស់តម្កល់ទុក ស្អិតស្រដៀងនឹងជ័រឈើ ជារបស់គួរទាញទៅមកបាន កាលសេចក្តីរង្កៀសកើតឡើង ភិក្ខុអាចរុញទៅវិញបាន ព្រោះជារបស់ជាប់គ្នានោះឯង ។ ទឹកឃ្មុំ និងទឹកអំពៅប្រភេទនោះ សូម្បីចេញអំពីមាត់ថ្នាំង ចូលទៅក្នុងភាជនៈហើយ ក៏ឈ្មោះថា នៅរក្សា ព្រោះជារបស់ស្អិតជាប់គ្នាតែមួយ លុះតែដាច់អំពីកណ្តាប់មាត់ហើយ ទើបត្រូវអាបត្តិបារាជិក ។ សូម្បីភិក្ខុណា ប្រើសំពត់សាច់ក្រាស់ឯណានីមួយ

ដែលអាចបឺតទឹកដោះថ្លា ឬប្រេងបាន ក្នុងតម្លៃមួយបាទយ៉ាងពិតប្រាកដចូល ក្នុងថ្នាំងរបស់អ្នកដទៃដោយថេយ្យចិត្ត លុះផុតអំពីដៃ ភិក្ខុនោះក៏ត្រូវអាបត្តិបារាជិក ។ ក្នុងមហាអដ្ឋកថាពោលទុកថា ភិក្ខុដឹងថា ឥឡូវនេះ គេនឹងដាក់ប្រេង មានថេយ្យចិត្តដាក់កណ្ឌៈឯណាមួយចូលក្នុងថ្នាំងទទេ បើកណ្ឌៈនោះនឹងបឺតបានតម្លៃ ៥ មាសក ក្នុងកាលប្រេងគេដាក់ក្នុងថ្នាំងនោះហើយ កាលកណ្ឌៈនោះ គ្រាន់តែបឺតប្រេងនោះហើយ ត្រូវអាបត្តិបារាជិក ។ តែពាក្យនោះរមែងទាស់នឹងពាក្យវិនិច្ឆ័យ ពោលអំពីការធ្វើប្រឡាយស្ងួតឲ្យត្រង់ក្នុងបឹងដែលរីងស្ងួត ក្នុងមហាអដ្ឋកថានោះឯង ពិតហើយ លក្ខណៈនៃអវហារក្នុងពាក្យនេះ មិនប្រាកដ ព្រោះហេតុនោះ ទើបមិនគួរកាន់យក ។ ចំណែកក្នុងអដ្ឋកថាមហាបច្ចរីជាដើម លោកកាត់អាបត្តិបារាជិកក្នុងកាលលើកកណ្ឌៈនោះឡើង ។ ពាក្យនោះគួរកាន់យក ។ ភិក្ខុដាក់កណ្ឌៈ មានស្បែកជាដើមក្នុងថ្នាំងទទេរបស់អ្នកដទៃ ដើម្បីនឹងរក្សាទុក កាលម្ចាស់គេចាក់ប្រេងចូលក្នុងថ្នាំងនោះហើយ ( ភិក្ខុ ) បារម្ភថា បើបុគ្គលនោះដឹង គេនឹងចាប់អញ ទើបភិក្ខុលើកឡើងនូវកណ្ឌៈដែលបឺតប្រេងនោះទុក ហើយបានតម្លៃមួយបាទ ដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក បើលើកឡើងដោយចិត្តបរិសុទ្ធ កាលអ្នកដទៃយកទៅ របស់នោះជាភណ្ឌទេយ្យ ។ អធិប្បាយថា ទ្រព្យណារបស់អ្នកដទៃបាត់ទៅ ត្រូវសងតម្លៃរបស់វត្ថុនោះ ឬសងរបស់នោះឯង ឈ្មោះថា ភណ្ឌទេយ្យ ។ បើមិនសង ត្រូវអាបត្តិបារាជិក ក្នុងកាលម្ចាស់របស់ដាក់ធុរៈ ។ តែបើអ្នកដទៃដាក់ទឹកដោះថ្លា ឬប្រេងចុះក្នុងថ្នាំងរបស់ភិក្ខុនោះ ភិក្ខុម្ចាស់ថ្នាំង

នេះ ក៏ដាក់កណ្ឌៈដែលបឺតប្រេងបានចុះក្នុងថ្នាំងនោះដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក តាមន័យដែលពោលហើយនោះឯង ។ ភិក្ខុដឹងថា ទឹកដោះថ្លា ឬប្រេងដែលអ្នកដទៃដាក់ក្នុងថ្នាំងទទេរបស់ខ្លួន ទើបដាក់កណ្ឌៈចូលទៅដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិកក្នុងខណៈដែលលើកឡើង តាមន័យមុនដូចគ្នា ។ បើមានចិត្តបរិសុទ្ធដាក់ចូលទៅ ក្រោយមក ទើបលើកឡើងដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិកដូចគ្នា ។ មានចិត្តបរិសុទ្ធពិត លើកឡើងមិនជាអវហារ មិនជាកណ្ឌទេយ្យ ។ តែក្នុងមហាបច្ចរីពោលទុកត្រឹមតែអនាបត្តិប៉ុណ្ណោះ ។ ក្នុងកុរុន្ទីពោលទុកថា ភិក្ខុអាក់អន់ចិត្តពោលថា លោកចាក់ប្រេងចុះក្នុងថ្នាំងរបស់ខ្ញុំធ្វើអ្វី ដូច្នេះហើយ លើកកណ្ឌៈឡើង បោះចោលទៅ មិនជាកណ្ឌទេយ្យ ។ ភិក្ខុប្រាថ្នាឲ្យប្រេងហូរ ទើបចាប់ត្រង់កណ្ដាប់មាត់ ផ្អៀងថ្នាំងដោយថេយ្យចិត្ត កាលប្រេងហូរទៅបានតម្លៃមួយបាទ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តពិត ធ្វើថ្នាំងឲ្យប្រេះស្រាំ ដោយគិតថា ប្រេងនឹងហូរទៅចុះ កាលប្រេងហូរទៅបានតម្លៃមួយបាទ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តនោះឯង ធ្វើថ្នាំងឲ្យធ្លុះ ផ្កាប់ ផ្ងារ ឬផ្អៀង ។ ឯពាក្យនេះជាឋានៈគួរឆ្ងល់ ព្រោះដូច្នោះ គួរសង្កេតឲ្យល្អ ។

ក្នុងពាក្យថា ផ្កាប់ ជាដើមនេះ មានវិនិច្ឆ័យដូចតទៅនេះថា ប្រហោងមាត់ចុះ ទៅខាងក្រោម ឈ្មោះថា ផ្កាប់ ។ មាត់ឡើងខាងលើ ឈ្មោះថា ផ្ងារ ។ ប្រហោងមាត់ទៅចំហៀងដូចត្រឡោក ឈ្មោះថា ផ្អៀង ។ បណ្ដាការផ្កាប់ជាដើមនោះ កាលប្រេងមានតម្លៃដល់មួយបាទ ហូរចេញតាមប្រហោង

ខាងក្រោម ដែលខ្ចូនចោះពីខាងក្រៅ សូម្បីមិនទាន់ហូរចេញទៅខាងក្រៅ ក៏ត្រូវអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ព្រោះថា ប្រេងនោះហូរនៅខាងក្នុងប៉ុណ្ណោះ ក៏ឈ្មោះថាហូរចេញទៅខាងក្រៅ នឹងរាប់ថា នៅខាងក្នុងថ្នាំងមិនបាន គឺមិនតាំងនៅក្នុងថ្នាំង ។ កាលប្រេងបានតម្លៃដល់មួយបាទ ហូរចេញទៅខាងក្រៅប្រហោង ដែលខ្ចូនចោះពីខាងក្នុង ត្រូវអាបត្តិបារាជិក ។ កាលប្រេងបានតម្លៃដល់មួយបាទ ហូរចេញទៅខាងក្រៅ តាមប្រហោងខាងលើដែលខ្ចូនចោះដោយអាការណាមួយក៏ដោយ ត្រូវអាបត្តិបារាជិក ។ ក្នុងអដ្ឋកថាទាំងឡាយពោលទុកថា សេចក្តីពិត ប្រេងនោះមិនទាន់ហូរអំពីខាងក្នុងទៅខាងក្រៅដរាបណា ក៏បានឈ្មោះថា នៅខាងក្នុងថ្នាំងដរាបនោះឯង ។ ព្រះវិនយធរគប្បីកាត់អាបត្តិ ( បារាជិក ) ដោយអំណាចប្រេង ដែលហូរចេញត្រង់កណ្តាលអំបែងនៃប្រហោងដែលនៅត្រង់កណ្តាល ។ ក្នុងពាក្យដែលពោលទុកក្នុងអដ្ឋកថាទាំងឡាយនោះ រមែងសមគ្នានឹងការទម្លាយទំនប់របស់ស្រះ ក្នុងកាលភិក្ខុចោះប្រហោងតាំងពីខាងក្នុង និងខាងក្រៅ វៀរត្រង់កណ្តាលទុក ។ តែកាលភិក្ខុចោះប្រហោង ចាប់តាំងពីខាងក្នុងហើយ ព្រះវិនយធរគួរកាត់អាបត្តិដោយប្រហោងខាងក្រៅ កាលចោះប្រហោងចាប់ផ្តើមអំពីខាងក្រៅហើយ គួរកាត់អាបត្តិដោយប្រហោងខាងក្នុង ពាក្យដែលលោកពោលទុកក្នុងប្រហោងដែលកំណាត់ត្រង់កណ្តាលនេះ ដូចពណ៌នាមកនេះសមគួរ ។

ឯភិក្ខុណានាំចេញនូវជើងទ្រ ឬរង្វេលនៃថ្នាំងដោយថេយ្យចិត្តថា ថ្នាំង

នឹងរមៀលទៅ កាលថ្នាំងរមៀលទៅ ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត កាលភិក្ខុជីងការដែលគេនឹងបង្ហូរប្រេងដាក់ ធ្វើស្នាមប្រេះ ឬប្រហោងនៃថ្នាំងទទេទុក ជាកណ្ឌទេយ្យ ដោយប្រមាណនៃប្រេងដែលហូរចេញមកខាងក្រោយ តែក្នុងអដ្ឋកថាទាំងឡាយ កន្លែងខ្លះរចនាទុកថា ត្រូវអាបត្តិបារាជិក ដូច្នេះក៏មាន តែការសរសេរនោះ ជាការភ្លាំងភ្លាត់ ។ ភិក្ខុធ្វើឈើ ឬថ្ម ហាក់ដូចជាខ្ទេចខ្ទុកមិនល្អ ឬតាំងឈើ និងថ្មឲ្យជារបស់ដែលខ្ទេចតាំងទុក មិនល្អខាងលើនៃថ្នាំងពេញ ដោយថេយ្យចិត្តថា ថ្មនឹងធ្លាក់ទៅត្រូវថ្នាំងបែក ប្រេងនឹងហូរចេញអំពីថ្នាំងនោះ ។ ប្រសិនបើឈើ ឬថ្មនោះនឹងត្រូវធ្លាក់យ៉ាងពិតប្រាកដ កាលភិក្ខុធ្វើយ៉ាងនោះ ជាអាបត្តិបារាជិកក្នុងខណៈធ្វើស្រេច ។ បើធ្វើយ៉ាងនោះខាងលើនៃថ្នាំងទទេ ឈើ ឬថ្មនោះធ្លាក់ទៅបំបែកក្នុងកាលដែលថ្នាំងនោះពេញក្នុងពេលជាក្រោយ ជាកណ្ឌទេយ្យ ។ ពិតហើយ ក្នុងឋានៈដូច្នេះ មិនទាន់ជាបារាជិកខាងដើមនោះឯង ព្រោះប្រយោគដែលភិក្ខុធ្វើហើយក្នុងកាលដែលរបស់មិនមាន ។ តែជាកណ្ឌទេយ្យ ព្រោះធ្វើរបស់ឲ្យខូច ។ កាលគេឲ្យសង មិនសងគេ ត្រូវបារាជិក ព្រោះការដាក់ភារៈនៃម្ចាស់ទ្រព្យទាំងឡាយ ។ ភិក្ខុធ្វើប្រឡាយត្រង់ដោយថេយ្យចិត្តថា ថ្នាំងនឹងរមៀលទៅ ឬទឹកនឹងញុំាំងប្រេងឲ្យហៀរឡើង ថ្នាំងរមៀលទៅក្តី ប្រេងហៀរឡើងក្តី ត្រូវអាបត្តិបារាជិក ក្នុងវេលាដែលធ្វើឲ្យត្រង់ ។ ពិតហើយ ប្រយោគដូច្នេះៗ ដល់នូវការសង្គ្រោះបានក្នុងបុព្វបយោគាវហារ ។ កាលប្រឡាយស្ងួតដែលភិក្ខុធ្វើឲ្យត្រង់ទុកហើយ ទឹកមកក្នុងកាលជាក្រោយ ថ្នាំងរមៀលទៅក្តី ប្រេង

ហៀរឡើងក្តី ជាភណ្ឌទេយ្យ ។ ព្រោះហេតុអ្វី ព្រោះមិនមានប្រយោគ គឺការឲ្យឃ្លាតចាកឋាន ។ លក្ខណៈនៃប្រយោគ គឺការឲ្យឃ្លាតចាកឋាននោះមានច្បាស់ហើយក្នុងរបស់ដែលតាំងនៅក្នុងទូក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងឡាយ មានបទថា **តត្ថេវ ភិន្ទតិ វា** ជាដើម លោកពោលទុកក្នុងអដ្ឋកថាដូច្នេះថា

បទថា **ភិន្ទតិ វា** ដោយអត្ថថា ដំបំបែកដោយដំបង ។ បទថា **ឆឌ្ឌេតិ វា** ដោយអត្ថថា ចាក់ទឹក ឬខ្សាច់ចូលក្នុងប្រេង ឲ្យប្រេងហៀរឡើង ។ ពាក្យថា **ឈាបេតិ វា** ដោយអត្ថថា នាំឧសមកហើយ ញ៉ាំងភ្លើងឲ្យឆេះ ។

បទថា **អបរិភោគំ វា ករោតិ** ដោយអត្ថថា ធ្វើឲ្យជារបស់ទំពា ឬផឹកមិនបាន គឺញ៉ាំងឧច្ចារៈក្តី បស្សាវៈក្តី ថ្នាំពិសក្តី កាកសំណល់ក្តី សាកសពក្តី ឲ្យធ្លាក់ចូលទៅ ។

បទថា **អាបត្តិ ទុក្កដស្ស** ដោយអត្ថថា ត្រូវទុក្កដព្រោះមិនមានការឲ្យឃ្លាតចាកឋាន ។ ញាណវិសេសនេះ ឈ្មោះថា ពុទ្ធវិស័យ ។ សូម្បីត្រូវទុក្កដក៏ពិត តែកាលម្ចាស់របស់ឲ្យសង ជាភណ្ឌទេយ្យ ។ ក្នុង ៤ បទនោះ ពីរបទខាងដើមមិនសមគួរ ព្រោះពីរបទនោះជាលក្ខណៈតែមួយ ដូចគ្នានឹងការធ្វើស្នាមប្រេះរបស់ថ្នាំង និងការធ្វើប្រឡាយឲ្យត្រង់ ។ ចំណែកពីរបទខាងក្រោយ សូម្បីញ៉ាំងវត្ថុឲ្យឃ្លាតចាកឋាន ក៏អាចធ្វើបាន ព្រោះដូច្នោះទើបអាចារ្យមួយពួកពោលវិនិច្ឆ័យក្នុងពាក្យនេះទុកយ៉ាងនេះថា

បានឮថា ក្នុងអដ្ឋកថា ពាក្យថា ត្រូវអាបត្តិទុក្កដ ព្រោះមិនមានការឲ្យ

ឃ្លាតចាកឋាននេះ លោកពោលសំដៅយកពីរបទខាងក្រោយ ។ ពិតហើយ ភិក្ខុមិនធ្វើឲ្យឃ្លាតចាកឋានឡើយ គប្បីដុតក្តី គប្បីធ្វើឲ្យជារបស់ប្រើប្រាស់មិនបានក្តី ដោយថេយ្យចិត្ត ឬព្រោះចង់ឲ្យវិនាស តែក្នុងពីរបទខាងដើម កាលភិក្ខុទម្លាយ ឬចាក់ចោលដោយន័យដែលពោលហើយ ការឲ្យឃ្លាតចាកឋាន រមែងមាន ព្រោះដូច្នោះ កាលធ្វើយ៉ាងនោះ ជាភណ្ឌទេយ្យ ព្រោះបំណងឲ្យវិនាស ត្រូវអាបត្តិបារាជិក ដោយថេយ្យចិត្តដូច្នេះឯង ។

បើមានពាក្យជំទាស់ថា ពាក្យនោះមិនប្រពៃ ព្រោះលោកពោលទុកក្នុងបាលីថា ត្រូវអាបត្តិទុក្កដ ។

គប្បីឆ្លើយថា មិនមែនជាពាក្យមិនប្រពៃឡើយ ព្រោះមានអត្ថដែលគប្បីកាន់យកដោយប្រការដទៃ ។

ពិតហើយ ក្នុងផ្នែកនៃថេយ្យចិត្ត ក្នុងព្រះបាលី អាចារ្យមួយពួកពោលយ៉ាងនេះថា ពាក្យថា **ភិន្ទតិ វា** នោះ ដោយអត្ថថា លាយដោយទឹក ។ បទថា **ឆឌ្ឌេតិ វា** នោះ ដោយអត្ថថា ចាក់ខ្សាច់ក្តី ឧច្ចារៈក្តី បស្សាវៈក្តី ចូលក្នុងភេសជ្ជៈ មានប្រេងជាដើមនោះ ដូច្នេះ ។ ចំណែកខ្លឹមសារក្នុងពាក្យនេះ ដូច្នេះថា ភិក្ខុមិនបំណងឲ្យឃ្លាតចាកឋាន ទម្លាយតែម្យ៉ាង ដូចភិក្ខុដុតស្មៅក្នុងវិនីតវត្ថុ ។ តែភេសជ្ជៈ មានប្រេងជាដើម រមែងហូរចេញបាន ព្រោះឆ្នាំងធ្លាយហើយ ។ ឬក្នុងភេសជ្ជៈទាំងនោះ ភេសជ្ជៈណាជារបស់ស្ងួត ភេសជ្ជៈនោះនឹងជាប់គ្នា តាំងនៅបាន ។ ម្យ៉ាងទៀត ភិក្ខុមិនបំណងនឹងចាក់ប្រេងឡើយ ចាក់ទឹក ឬខ្សាច់ជាដើមចូលក្នុងឆ្នាំងនោះតែម្យ៉ាង ប្រេង ឈ្មោះថា ភិក្ខុនោះចាក់ចោល ព្រោះបានចាក់ទឹក ឬខ្សាច់ជាដើមនោះចូលទៅ ។

ព្រោះដូច្នោះ ដោយអំណាចវោហារ ទើបលោកហៅថា ទម្លាយក្តី ចាក់ក្តី អ្នកសិក្សាគប្បីកាន់យកសេចក្តី នៃបទទាំងនេះ ដូចពោលមកដូច្នេះ ។

ចំណែកក្នុងផ្នែកនៃភាពជាបុគ្គលប្រាថ្នានឹងឲ្យវិនាស ត្រូវអាបត្តិទុក្កដ ពាល់ត្រូវ ដោយប្រការក្រៅអំពីនេះ ។ ពិតហើយ កាលលោកពោលអធិប្បាយសេចក្តីយ៉ាងនេះ បាលី និងអដ្ឋកថា គឺលោកសង្កេតពិនិត្យពោលល្អហើយ ដោយខាងដើម និងខាងចុង ។ តែមិនគួរធ្វើការពេញចិត្ត ដោយពាក្យអធិប្បាយត្រឹមប៉ុណ្ណោះ គប្បីចូលទៅអង្គុយជិតអាចារ្យទាំងឡាយ ហើយជ្រាបសេចក្តីវិនិច្ឆ័យចុះ ។

ទ្រព្យដែលស្ថិតនៅក្នុងផែនដី ចប់

## ទ្រព្យដែលតាំងនៅលើគោក

[ ៩២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលតាំងនៅលើគោក ។ ពីរបទថា **ថលេ និក្ខិត្តំ** សេចក្តីថា បានដល់ ទ្រព្យដែលគេទុកលើផែនដីក្តី លើផ្ទៃប្រាសាទ និងលើភ្នំជាដើម កន្លែងណាមួយ ដែលបិទបាំងក្តី មិនបិទបាំងក្តី គប្បីជ្រាបថា ទ្រព្យដែលតាំងនៅលើគោក ។ បើទ្រព្យនោះ គេធ្វើជាគំនរទុក គប្បីសម្រេចតាមពាក្យវិនិច្ឆ័យ ដែលពោលទុកក្នុងការធ្វើទ្រព្យ ឲ្យនៅក្នុងភាជនៈ និងការក្តាប់យកខាងក្នុងថ្នាំង ។ បើទ្រព្យនោះជាប់ជាមួយគ្នា មានជ័រពាក់ និងជ័រស្រល់ជាដើម គប្បីសម្រេចតាមពាក្យវិនិច្ឆ័យដែលពោលទុក

ក្នុងទឹកឃ្មុំ និងទឹកអំពៅ ដែលម្ចាស់ផ្ទិនហើយ ។ បើទ្រព្យជារបស់ធ្ងន់ ជាបន្ទះលោហៈក្តី ស្ករអំពៅក្តី វត្ថុ មានប្រេង ទឹកឃ្មុំ និងទឹកដោះជូរក្តី ដែលទាក់ទងដោយធុរៈ គប្បីសម្រេចវិនិច្ឆ័យតាមដែលពោលទុកហើយ ក្នុងការញ៉ាំងផ្ទាំងឲ្យឃ្លាតចាកឋាន និងគប្បីកំណត់ការផ្សេងរបស់ឋាន នៃទ្រព្យដែលគេចងទុកដោយប្រវ៉ាក់ ។ ចំណែកភិក្ខុកាន់យកវត្ថុ មានសំពត់បាវារ សំពត់កម្រាល និងសំពត់សាដកជាដើម ដែលគេក្រាលទុក ទាញមកត្រង់ៗ កាលជាយសំពត់ខាងនោះ កន្លងហួសឱកាសត្រង់ជាយសំពត់ខាងនេះពាល់ត្រូវទៅ ត្រូវអាបត្តិបារាជិក ។ ក្នុងគ្រប់ៗ ទិស ក៏គួរកំណត់ដោយអាការយ៉ាងនេះ ។ ភិក្ខុខ្ចប់ហើយលើកឡើង កាលធ្វើឲ្យអណ្តែតទៅលើអាកាសត្រឹមមួយចុងសក់ ត្រូវអាបត្តិបារាជិក ។ ពាក្យដ៏សេសមានន័យដូចពោលហើយ ដូច្នេះឯង ។

កថាពោលដោយទ្រព្យនៅលើគោក ចប់

# ទ្រព្យដែលនៅក្នុងអាកាស

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលនៅក្នុងអាកាស ។ សម្រាប់ក្ងោកគប្បីជ្រាបការកំណត់ដោយឋាន ដោយអាការ ៦ យ៉ាង គឺខាងមុខកំណត់ដោយចំពុះ ខាងក្រោយ កំណត់ដោយចុងកន្ទុយ សងខាងទាំងពីរកំណត់ដោយចុងស្លាប ខាងក្រោម កំណត់ដោយចុងក្រចក ខាងលើ កំណត់ដោយចុងសិរ ។ ភិក្ខុគិតថា នឹងចាប់ក្ងោកដែលមានម្ចាស់ ដែល ( ហើរ )

នៅ ក្នុងអាកាស ឈរនៅខាងមុខក្តី លាដៃក្តី ។ ក្អែកត្រដាងស្លាបនៅលើ អាកាសនោះឯង បិទស្លាប ហើយឈប់ហើរ ឈរនៅ ត្រូវអាបត្តិទុក្កដដល់ ភិក្ខុនោះ មិនឲ្យក្អែកនោះកម្រើក យកដៃស្ទាបអង្អែល ត្រូវអាបត្តិទុក្កដដូច គ្នា មិនឲ្យឃ្លាតចាកឋាន ឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ចំណែកនឹង យកដៃចាប់ក្តី មិនចាប់ក្តី ឲ្យចុងកន្ទុយកន្ទង់ឱកាសដែលចំពុះពាល់ត្រូវ ឬឲ្យ ចំពុះកន្ទង់ឱកាសដែលចុងកន្ទុយពាល់ត្រូវ បើក្អែកនោះ បានតម្លៃមួយបាទ សោត ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត ឲ្យចុងស្លាបខាងស្តាំកន្ទង់ឱកាស ដែលចុងស្លាបខាងឆ្វេងតាំងនៅក្តី ឲ្យចុងស្លាបខាងឆ្វេងកន្ទង់ឱកាសដែលចុង ស្លាបខាងស្តាំតាំងនៅក្តី ក៏ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត ឲ្យចុងសិរកន្ទង់ ឱកាសដែលចុងក្រចកពាល់ត្រូវក្តី ឲ្យចុងក្រចកកន្ទង់ឱកាសដែលសិរតាំង នៅក្តី ត្រូវអាបត្តិបារាជិក ។ ក្អែកហើរទៅក្នុងអាកាស ទំត្រង់បណ្តាអវយវៈ មានក្បាលជាដើមណាមួយ អវយវៈនោះជាឋានរបស់ក្អែកនោះ ព្រោះហេតុនោះ ភិក្ខុនោះ សូម្បីកាលធ្វើក្អែកមួយនោះ ដែលទំនៅត្រង់ដៃឲ្យរេទៅ ឈ្មោះថា ធ្វើឲ្យកម្រើកពិត ហើយបើលោកយកដៃម្ខាងទៀត ចាប់ឲ្យកម្រើកចាកឋាន ត្រូវអាបត្តិបារាជិក ។ ភិក្ខុលូកដៃម្ខាងទៀតចូលទៅជិត ក្អែកលោតទៅទំ ត្រង់ដៃនោះខ្លួនឯង មិនត្រូវអាបត្តិ ។ ភិក្ខុមានថេយ្យចិត្ត ដឹងថា ក្អែកទំ ត្រង់អវយវៈ ឈានជំហានទី ១ ត្រូវអាបត្តិថុល្លច្ច័យ ជំហានទី ២ ត្រូវអាបត្តិ បារាជិក ។ ក្អែកទំលើផែនដី រមែងបានឋាន ៣ ដោយអំណាចជើងទាំង ២ និងចុងកន្ទុយ ។ បើភិក្ខុលើកក្អែកនោះឡើង ត្រូវអាបត្តិថុល្លច្ច័យ ដរាប

ដល់វេលាដែលឋានសូម្បីត្រឹមតែ ១ ឋាននៅពាល់ត្រូវផែនដី ។ កាលក្ងោក នោះគ្រាន់តែភិក្ខុឲ្យផុតចាកផែនដី ត្រឹមមួយចុងសក់ ក៏ត្រូវអាបត្តិបារាជិក ។ ភិក្ខុលើកក្ងោកដែលនៅក្នុងទ្រុងឡើង ព្រមទាំងទ្រុងត្រូវអាបត្តិបារាជិក ។ តែបើក្ងោកនោះមិនបានតម្លៃដល់មួយបាទសោត គប្បីកាត់អាបត្តិតាមតម្លៃគ្រប់ៗអន្លើ ។ ភិក្ខុមានថេយ្យចិត្ត ធ្វើក្ងោកដែលកំពុង ដើរខាងក្នុងសួនឲ្យភិតភ័យដេញវាដើរចេញទៅក្រៅសួន ដោយឲ្យជើង ១ កន្លងខេត្តដែលកំណត់នៃទ្វារត្រូវអាបត្តិបារាជិក ។ ពិតហើយ ខាងក្នុងសួន មានឋានរបស់ក្ងោកនោះដូចក្រោលជាឋានរបស់គោដែលនៅក្នុងក្រោល ដូច្នោះ ។ តែកាលភិក្ខុយកដៃចាប់ ធ្វើឲ្យវាហើរទៅក្នុងអាកាសសូម្បីក្នុងសួន ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។ បើភិក្ខុញុំាងក្ងោកដែលកំពុងដើរក្នុងស្រុកឲ្យកន្លងហួសរបងនៃស្រុកទៅ ត្រូវអាបត្តិបារាជិក ។ ក្ងោកដែលចេញទៅលេងនៅក្នុងឧបចារស្រុក ឬឧបចារសួនខ្លួនឯង ភិក្ខុមានថេយ្យចិត្ត ញុំាងក្ងោកឲ្យភ័យដោយឈើ ឬដោយអំបែង ធ្វើឲ្យក្ងោកបែរមុខចូលទៅព្រៃ ។ ក្ងោកហើរទៅទំខាងក្នុងស្រុក ឬខាងក្នុងសួន ឬលើដំបូលនៅរក្សានៅឡើយ ។ តែបើក្ងោកបែរមុខចូលព្រៃហើយហើរទៅក្តី ដើរទៅក្តី កាលមិនមានបំណងថា អញឲ្យវាចូលទៅ ហើយនឹងចាប់យក ត្រូវអាបត្តិបារាជិក ក្នុងកាលត្រឹមតែវាហើរឡើងផុតផែនដីសូម្បីប៉ុនចុងសក់ ឬក្នុងជំហានទី ២ ព្រោះហេតុអ្វី ព្រោះទីដែលឈរប៉ុណ្ណោះជាឋានរបស់ក្ងោកដែលចេញផុតអំពីស្រុកហើយ ។ សូម្បីក្នុងបក្សីទាំងឡាយមានសត្វចចាតជាដើម ក៏គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះឯង ។

បទថា **សាដកំ វា** សេចក្តីថា ភិក្ខុយកដៃចាប់សាដកដែលរឹងដោយមេ្សៅ ដែលរសាត់ទៅក្នុងអាកាស អណ្តែតមកត្រង់ចំពោះមុខ ត្រង់ជាយសំពត់ម្ខាង ដូចជាសំពត់ដែលគេសន្ធឹងទុកលើផែនដី ត្រូវខ្យល់ក្តួចដូច្នោះ កាលមិនបានធ្វើឋានឲ្យកម្រើកទៅខាងនោះ និងខាងនេះឡើយ ត្រូវអាបត្តិទុក្កដ ព្រោះវៀរការដើរ កាលមិនធ្វើឲ្យកម្រើកចាកឋាន នៅរក្សានៅឡើយ ព្រោះធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ឲ្យឃ្លាតចាកឋាន ត្រូវអាបត្តិបារាជិក ។ ឯការកំណត់ឋាននៃសាដកនោះ គប្បីជ្រាបដោយអាការ ៦ យ៉ាង ដូចការកំណត់ឋាននៃក្អែកដូច្នោះ ។ ចំណែកសំពត់សាដកដែលមិនរឹង លុះភិក្ខុចាប់ត្រង់ជាយសំពត់ម្ខាងប៉ុណ្ណោះ ជាយទី ២ ក៏ធ្លាក់ចុះទៅគរលើផែនដី សំពត់សាដកនោះ មានឋាន ២ គឺដៃ ១ ផែនដី ១ ។ ភិក្ខុធ្វើសំពត់សាដកនោះតាម ដែលចាប់យកហើយនោះឯង ឲ្យឃ្លាតចាកប្រទេសនៃឱកាសដែលខ្លួនចាប់យកពីដំបូង ត្រូវអាបត្តិថុល្លច្ច័យ ក្រោយមក យកដៃទី ២ ឬជើង លើកឡើងផុតអំពីផែនដី ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត ដំបូងលើកឡើងចាកផែនដី ត្រូវអាបត្តិថុល្លច្ច័យ ក្រោយមក ឲ្យឃ្លាតចាកប្រទេសនៃឱកាសដែលខ្លួនចាប់យក ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត ភិក្ខុកាលមិនលែងការចាប់លាតដៃចុះទៅត្រង់ៗ ប្រមូលសំពត់ឲ្យនៅត្រង់ផែនដី ទើបយកដៃនោះឯងលើកសំពត់ឡើង ត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងសំពត់ជូតកាល ក៏គប្បីជ្រាបវិនិច្ឆ័យដូច្នេះឯង ។

ច្រើនបទថា **ហិរញ្ញំ វា សុវណ្ណំ វា ឆិជ្ជមានំ** សេចក្តីថា គ្រឿង

ប្រដាប់ មានខ្សែកជាដើមរបស់ពួកមនុស្ស ដែលតាក់តែងក្ដី មាសសន្ទឹកនៃពួកជាងមាសដែលកាត់ចម្រៀកមាសដាច់ធ្លាក់ទៅក្ដី ។ បើភិក្ខុមានថេយ្យចិត្តយកដៃចាប់យកគ្រឿងប្រដាប់ ឬ បន្ទះមាស ដែលដាច់ធ្លាក់អណ្ដែតមកតាមអាកាសនោះ ការចាប់នោះឯងជាឋាន យកដៃចេញអំពីប្រទេសដែលខ្លួនចាប់យក ត្រូវបារាជិក ។ យកដៃលើកគ្រឿងប្រដាប់ មានខ្សែកជាដើម ដែលធ្លាក់ចុះទៅក្នុងចីវរឡើង ត្រូវអាបត្តិបារាជិក បើមិនបានលើកឡើង តែដើរទៅ ត្រូវបារាជិកក្នុងជំហានទី ២ ។ សូម្បីក្នុងអលង្ការ មានខ្សែកជាដើមដែលធ្លាក់ចូលទៅក្នុងបាត្រ ក៏មានន័យយ៉ាងនេះឯង ។ យកដៃចាប់យកគ្រឿងអលង្ការមានខ្សែកជាដើម ដែលធ្លាក់ចុះត្រង់ក្បាលក្ដី ត្រង់មុខក្ដី ត្រង់ជើងក្ដី ត្រូវអាបត្តិបារាជិក បើមិនបានចាប់យក ហើយដើរទៅ ត្រូវអាបត្តិបារាជិកក្នុងជំហានទី ២ ។ម្យ៉ាងទៀត អលង្ការ មានខ្សែកជាដើមនោះ ធ្លាក់ទៅក្នុងទីណាមួយ ព្រោះឱកាសដែលគ្រឿងប្រដាប់ជាដើមតាំងនៅក្នុងទីនោះ ជាឋានរបស់អលង្ការជាដើមនោះ អង្គាវយវៈទាំងអស់ក្ដី បាត្រ និងចីវរក្ដី មិនបានជាឋានឡើយ ដូច្នេះឯង ។

ទ្រព្យស្ថិតនៅលើអាកាស ចប់

## ទ្រព្យដែលនៅលើផ្ទៃរ

[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងកណ្ឌៈដែលតាំងនៅលើផ្ទៃរ ។ កណ្ឌៈ

ដែលគេទុកលើគ្រែ និងតាំងជាដើម ជារបស់គួរចាប់ពាល់ក្តី មិនគួរចាប់ពាល់ក្តី កាលភិក្ខុចាប់ពាល់ដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដ ។ ឯក្នុងកណ្ឌៈដែលគេទុកលើគ្រែ និងតាំងនេះ គួរជ្រាបវិនិច្ឆ័យតាមន័យដែលពោលទុកក្នុងកណ្ឌៈ ដែលតាំងនៅលើគោក ។ ចំណែកសេចក្តីប្លែកគ្នា គប្បីជ្រាបដូច្នេះថា បើសាដកដែលរឹងដោយបាយម៉ាន ដែលគេសន្ធឹងទុកលើគ្រែ ឬតាំង ត្រង់កណ្តាល មិនប៉ះផ្ទៃគ្រែ ត្រូវតែជើងគ្រែប៉ុណ្ណោះ គប្បីជ្រាបដោយអំណាចនៃជើងទាំង ៤ របស់គ្រែនោះ ។ ពិតហើយ កាលសំពត់សាដកនោះ គ្រាន់តែភិក្ខុឲ្យកន្លងហួសឱកាសដែលប៉ះត្រូវខាងលើនៃជើងគ្រែប៉ុណ្ណោះ រមែងត្រូវអាបត្តិបារាជិក ព្រោះឲ្យឃ្លានកន្លងនោះ ។ តែកាលភិក្ខុលួចទៅ ព្រមទាំងគ្រែនិងតាំង គប្បីជ្រាបឋានដោយអំណាចឱកាសជើងគ្រែ និងតាំងស្ថិតនៅ ។

បទថា **ចីវរវំសេ វា** សេចក្តីថា លើស្នួ ឬលើតម្អក់ដែលគេចងតាំងទុក ដើម្បីជាប្រយោជន៍ដល់ការពាក់ចីវរ ។ ព្រោះឱកាសដែលពាល់ត្រូវជាស្ថានរបស់ចីវរដែលពាក់លើស្នួនោះ ដែលយកជាយទុកខាងក្រៅ យកផ្នត់ទុកខាងក្នុង ស្នួចីវរទាំងអស់មិនបានជាឋានឡើយ ព្រោះហេតុនោះ កាលភិក្ខុចាប់ចីវរនោះទាញមកត្រង់ផ្នត់ ទាញមកដោយថេយ្យចិត្ត ឲ្យឱកាសដែលឋិតនៅលើស្នួផ្នែកខាងក្រៅ កន្លងហួសប្រទេសដែលស្នួចីវរប៉ះត្រូវផ្នែកខាងក្នុងទៅ ត្រូវអាបត្តិបារាជិក ដោយការទាញមកត្រឹមមួយធ្នាប់ ឬពីរធ្នាប់ប៉ុណ្ណោះ ( តាមទំហំស្នួ ) ន័យក្នុងភិក្ខុដែលចាប់ត្រង់ជាយទាញមក ក៏ដូចគ្នានេះ ។ តែកាលភិក្ខុរូតទៅខាងឆ្វេង ឬខាងស្តាំលើស្នួចីវរនោះឯង កាលចីវរនោះ

គ្រាន់តែកន្ទង់ឋាននៃជាយខាងស្តាំ ដោយជាយខាងឆ្វេង ឬគ្រាន់តែកន្ទង់ឋាននៃជាយខាងឆ្វេង ដោយជាយខាងស្តាំទៅ ត្រូវអាបត្តិបាចិត្តិយ ដោយការរូតទៅត្រឹម ១០ ធ្នាប់ ឬ ១២ ធ្នាប់ប៉ុណ្ណោះ ( តាមប្រវែងចីវរនៅបណ្តាយស្នូ ) ។ កាលភិក្ខុលើកឡើងត្រូវអាបត្តិបាចិត្តិយ ដោយការលើកផុតឡើងត្រឹមតែមួយចម្រៀកសក់ ។ កាលភិក្ខុស្រាយចីវរ ដែលគេយកខ្សែចងព្យួរទុក ទោះប៉ះត្រូវស្នូចីវរក្តី មិនប៉ះត្រូវក្តី ត្រូវអាបត្តិទុក្កដ កាលស្រាយចេញរួចស្រេច ត្រូវអាបត្តិបាចិត្តិយ ។ ពិតហើយ ចីវរនោះ គ្រាន់តែស្រាយចេញប៉ុណ្ណោះ រមែងដល់នូវការរាប់ថា ផុតចាកឋាន ។ កាលភិក្ខុស្រាយចីវរដែលគេចងទុកត្រង់ស្នូចេញ ត្រូវអាបត្តិទុក្កដ ចីវរនោះ គ្រាន់តែស្រាយចេញហើយ ក៏ត្រូវអាបត្តិបាចិត្តិយ ។ ក្នុងចីវរដែលគេធ្វើជាអន្ទាក់រក្សាទុក ភិក្ខុកាត់អន្ទាក់ចេញក្តី ស្រាយចេញក្តី ដោះចុងស្នូខ្មាង ហើយសម្រូតចេញក្តី ត្រូវអាបត្តិទុក្កដ កាលអន្ទាក់នោះ គ្រាន់តែដាច់ក្តី គ្រាន់តែស្រាយចេញហើយក្តី គ្រាន់តែរូតចេញផុតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុមិនបានធ្វើយ៉ាងនោះឡើយ រូតទៅរូតមកលើស្នូចីវរ នៅរក្សានៅឡើយ ។ ពិតហើយ ស្នូចីវរទាំងអស់ជាឋានរបស់អន្ទាក់ ។ ព្រោះហេតុអ្វី ព្រោះការរូតត្រឡប់ទៅត្រឡប់មកលើស្នូចីវរនោះ ជារបស់ធម្មតា ។ បើភិក្ខុយកដៃចាប់ចីវរនោះ ធ្វើឲ្យអណ្តែតទៅក្នុងអាកាស ត្រូវអាបត្តិបាចិត្តិយ ត្រឹមតែឱកាសត្រូវនឹងឱកាសដែលតាំងនៅជាឋានរបស់ចីវរដែលគេពាក់ទុក ។ វិនិច្ឆ័យក្នុងចីវរប្រភេទនោះ គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងចីវរដែលបត់

ពាក់ទុក ។ ចំណែកចីវរណា ជារបស់ប៉ះត្រូវផែនដីដោយជាយម្ខាង ឋានចីវរនោះមាន ២ ដោយអំណាចឱកាសដែលប៉ះនឹងស្ដួចីវរ និងប៉ះជាមួយផែនដី ។ ក្នុងចីវរដែលប៉ះផែនដីដោយជាយម្ខាងនោះ គប្បីជ្រាបវិនិច្ឆ័យតាមន័យដែលពោលហើយ ក្នុងសំពត់សាដកដែលមិនរឹងនោះឯង ។ សូម្បីក្នុងខ្សែស្បៀងចីវរក៏គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះឯង ។ ចំណែកភណ្ឌៈដែលគេព្យួរទុកលើតម្កក់ ទោះជាផ្ទាំងថ្នាំក្តី ថង់ថ្នាំក្តី បើតាំងនៅមិនប៉ះជញ្ជាំង ឬផែនដី កាលភិក្ខុរូតខ្សែព្រាក់ព្យួរចេញ កាលភណ្ឌៈនោះ គ្រាន់តែចេញផុតចុងតម្កក់ទៅ ត្រូវអាបត្តិបារាជិក បើខ្សែសម្រាប់ពាក់ព្យួរជារបស់រឹង បើភិក្ខុលើកភណ្ឌៈឡើង ធ្វើឲ្យខ្សែដែលរឹងនោះហើបផុតទៅក្នុងឱកាស កាលខ្សែដែលរឹងនោះ មិនទាន់ផុតអំពីចុងតម្កក់ក៏ដោយ ក៏ត្រូវអាបត្តិបារាជិក ។ បើភណ្ឌៈជារបស់ជាប់នៅនឹងជញ្ជាំង ភិក្ខុទាញភណ្ឌៈនោះចេញអំពីចុងតម្កក់ ត្រូវអាបត្តិថុល្លច្ច័យ រួចទើបដោះចេញពីជញ្ជាំង ត្រូវអាបត្តិបារាជិក ។ ដូចគ្នានេះដែរ បើភិក្ខុដោះពីជញ្ជាំងមុន រួចទើបដោះពីតម្កក់ក៏ន័យដូចគ្នា ។ បើភិក្ខុមិនអាចដោះភណ្ឌៈដែលចូនចេញបានខ្លួនឯង ទើបរុញផ្ទប់ទៅនឹងជញ្ជាំង ហើយដោះចេញពីតម្កក់ កាលភណ្ឌៈនោះ ភិក្ខុមិនឲ្យឃ្លាតពីជញ្ជាំង គ្រាន់តែដោះចេញអំពីតម្កក់បានប៉ុណ្ណោះ ត្រូវអាបត្តិបារាជិក ។ ព្រោះថា ឋានដែលខ្លួនធ្វើមិនចាត់ថាជាឋាន ។ តែសម្រាប់ភណ្ឌៈដែលតាំងនៅលើផែនដី មានពីរឋានប៉ុណ្ណោះ ។ វិនិច្ឆ័យក្នុងភណ្ឌៈដែលឋិតនៅលើផែនដីនោះ ខ្ញុំបានពោលទុកហើយ ឯភណ្ឌៈណាគេដាក់សង្រែកព្យួរទុក កាលភិក្ខុស្រាយភណ្ឌៈនោះចេញ

អំពីសង្រែកក្តី ស្រាយកណ្ឌះទាំងនោះទាំងសង្រែកចេញអំពីតម្លក់ក្តី ត្រូវអាបត្តិបារាជិក សូម្បីសេចក្តីផ្សេងគ្នានៃឋានក្នុងកណ្ឌះដែលគេដាក់សង្រែកព្យួរទុកនោះ ក៏គប្បីជ្រាបដូចកណ្ឌះដែលជាប់ជញ្ជាំង និងផែនដី ។

ចម្រឹងដែលគេជំជាប់ជញ្ជាំងក្តី ខ្នងដែលកើតក្នុងជញ្ជាំងនោះខ្លួនឯងក្តី ឈ្មោះថា **ភិត្តិខីល** ចម្រឹងជញ្ជាំង ។ ចំណែកនាគទន្ត ចម្រឹងដែលមានសណ្ឋានដូចភ្លុកដំរី ហៅថា ដៃកែវ គេដាក់ជំទុកត្រង់ជញ្ជាំងដូចគ្នា កណ្ឌះដែលគេព្យួរទុកលើចម្រឹងជញ្ជាំង និងដៃកែវនោះ គប្បីជ្រាបវិនិច្ឆ័យតាមន័យដែលពោលទុកហើយ ក្នុងកណ្ឌះដែលព្យួរទុកលើតម្លក់ ។ ឯលំពែង ឬស្នូ និងខ្សែតីកន្ទុយសត្វដែលគេលើកឡើងពាក់ទុកលើចម្រឹងជញ្ជាំង ឬដៃកែវ ២-៣ ដែលរៀងជាប់គ្នាជាលំដាប់ ភិក្ខុចាប់ត្រង់ចុង ឬត្រង់ដងទាញមកកន្លងទីត្រឹមតែ ឱកាសដែលចម្រឹងជញ្ជាំង ឬដៃកែវណាមួយពាល់ត្រូវប៉ុណ្ណោះ ត្រូវអាបត្តិបារាជិក ។ ព្រោះថា ត្រឹមឱកាសដែលពាល់ត្រូវប៉ុណ្ណោះ រមែងជាឋានរបស់លំពែង ស្នារ និងខ្សែតីកន្ទុយសត្វ ឯចម្រឹងជញ្ជាំង ឬដៃកែវទាំងអស់មិនចាត់ជាឋានឡើយ ភិក្ខុឈរបែរមុខទៅជញ្ជាំង ចាប់ត្រង់កណ្តាលលំពែងមក ត្រឹមតែចំណែកខាងក្រៅ កន្លងឱកាសត្រង់ចំណែកខាងក្នុងពាល់ត្រូវ ត្រូវអាបត្តិបារាជិក ។ កាលភិក្ខុរំកិលទៅខាងមុខ ក៏មានន័យដូចគ្នា ។ កាលភិក្ខុយកដៃចាប់លើកឡើង ធ្វើឲ្យអណ្តែតទៅលើអាកាស ត្រឹមមួយចុងសក់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុទាញលំពែងជាដើមនោះ ដែលគេដាក់ទុកជាប់នឹងជញ្ជាំង អូសតាមជញ្ជាំងមក កាលលោកឲ្យគល់កន្លងហួសឱកាសដែលចុង

ពាល់ត្រូវ ឬឱកាសដែលជងពាល់ត្រូវ ត្រូវអាបត្តិបារាជិក ។ ភិក្ខុឈរបែរមុខទៅជញ្ជាំង ទាញមកឲ្យទីបំផុតនៃចំណែកម្ខាងកន្ទងហួសឱកាស ដែលចំណែកម្ខាងទៀតប៉ះត្រូវ ត្រូវអាបត្តិបារាជិក ។ កាលលើកឡើងត្រង់ៗ ធ្វើឲ្យអណ្ដែតទៅក្នុងឱកាសត្រឹមចុងសក់ ត្រូវអាបត្តិបារាជិក ។

ពីរបទថា **រុក្ខេ វា លគ្គិតំ** បានដល់ ភណ្ឌៈដែលគេលើកឡើងព្យួរទុកត្រង់ដើមត្នោតជាដើម ។ គប្បីជ្រាបវិនិច្ឆ័យតាមន័យដែលពោលហើយក្នុងភណ្ឌៈដែលព្យួរទុកលើតម្កក់ជាដើមនោះឯង ។ កាលភិក្ខុអង្រួនធ្លាយត្នោតដែលនៅលើដើមត្នោតនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ កាលផ្លែនោះជ្រុះចាកទងវត្ថុនៃបារាជិកនឹងគ្រប់តម្លៃក្នុងផ្លែណា ត្រូវអាបត្តិបារាជិក ។ ភិក្ខុកាត់ធ្លាយត្នោត ត្រូវអាបត្តិបារាជិក ។ ចំណែកធ្លាយត្នោតដែលគេលើកពាក់ទុកក្នុងប្រគាបធាង បាន ២ ឋាន គឺឋានដែលពាក់ទុក ១ ឋាន គឺទង ១ ។ វិនិច្ឆ័យក្នុងឋាន ២ នោះ គប្បីជ្រាបតាមន័យដែលពោលហើយ ។ ចំណែកភិក្ខុណាលើកពាក់ទុកត្រង់ប្រគាបខ្លួនឯង ហើយទើបកាត់ ព្រោះខ្លាចក្រែងកាត់ដាច់ធ្លាក់ចុះមកឮសំឡេង លុះកាត់ស្រេចហើយ ភិក្ខុនោះ ត្រូវអាបត្តិបារាជិក ។ ព្រោះថា ឋានដែលខ្លួនធ្វើ មិនរាប់ថាជាឋានឡើយ ។ ក្នុងផ្កា និងផ្លែរបស់ដើមឈើទាំងពួង គប្បីជ្រាបវិនិច្ឆ័យដោយឧបាយនេះ ។

ក្នុងបទថា **បត្តាធារកេបិ** នេះ មានវិនិច្ឆ័យដូច្នេះថា កាលជើងទម្រធ្វើអំពីឈើក្ដី ធ្វើអំពីវល្លិ៍ក្ដី ជើងកំណាត់ឈើក្ដី ដែលតាំងបាត្រប្រភេទណាមួយ សូម្បីកំប្រោងក្ដី គ្រប់យ៉ាងដល់នូវការរាប់ថា ជើងទម្របាត្រទាំងអស់

ត្រឹមឱកាសដែលបាត្រពាល់ត្រូវនោះឯង ជាឋានរបស់បាត្រ ដែលគេតម្កល់ទុកលើទម្របាត្រនោះ ។ ក្នុងជើងឈើរបស់បាត្រនោះ មានកំណត់ឋានដោយអាការ ៥ យ៉ាង ។ ភិក្ខុចាប់បាត្រដែលតាំងនៅលើជើងឈើនោះត្រង់មាត់ ហើយអូសទៅខាងណាទីមួយ ក្នុងទិសទាំង ៤ ឲ្យចំណែកខាងដទៃកន្លងឱកាសត្រង់ចំណែកខាងណាមួយពាល់ត្រូវទៅ ត្រូវអាបត្តិបារាជិក ។ កាលលើកឡើងលើត្រឹមមួយចុងសក់ ត្រូវអាបត្តិបារាជិក ។ តែគប្បីវាយតម្លៃទ្រព្យ កាត់អាបត្តិគ្រប់ៗ អន្ទើ ។ កាលភិក្ខុលួចបាត្រ ព្រមទាំងជើងទម្រ ក៏មានន័យដូចគ្នាដូច្នេះឯង ។

កថាពោលដោយទ្រព្យដែលឋិតនៅលើធ្នើរ ចប់

## ទ្រព្យដែលឋិតនៅក្នុងទឹក

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅក្នុងទឹក ប្រើនបទថា **ឧទកេ និក្ខិត្តំ ហោតិ** សេចក្តីថា កណ្ឌៈដែលពួកជនអ្នកខ្លាចអំពីរាជភ័យជាដើម ធ្វើការបិទឲ្យល្អក្នុងវត្ថុទាំងឡាយ មានភាជនៈស្ពាន់ និងលោហៈជាដើម ដែលមិនខូចខាតដោយទឹកជាធម្មតា ហើយរក្សាទុកក្នុងទឹកដែលមិនហូរក្នុងស្រះបោក្ខរណីជាដើម ។ ត្រឹមតែឱកាសដែលតាំងនៅជាឋានរបស់ទ្រព្យដែលឋិតនៅក្នុងទឹកនោះ ទឹកទាំងអស់មិនចាត់ជាឋានឡើយ ។

ប្រែនបទថា **គច្ឆតិ វា អាបត្តិ ទុក្កដស្ស** សេចក្តីថា កាលភិក្ខុដើរទៅក្នុងទឹកដែលមិនជ្រៅ ត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន ។ ក្នុងទឹកជ្រៅ កាលធ្វើសេចក្តីព្យាយាមដោយដៃក្តី ដោយជើងក្តី ធ្វើសេចក្តីព្យាយាមទាំងដៃទាំងជើងក្តី ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ សូម្បីការមុជចុះ និងផុសឡើងដើម្បីលួចយកផ្កាំង ក៏មានន័យដូចគ្នានេះ ។ បើភិក្ខុឃើញភ័យខ្វះៗ មានពស់ទឹកក្តី ត្រីកាចក្តី ខ្លាចហើយក៏គេចទៅក្នុងចន្លោះ មិនត្រូវអាបត្តិ ។ ក្នុងអាការមានការចាប់ពាល់ជាដើម គប្បីជ្រាបវិនិច្ឆ័យដោយន័យដែលពោលហើយក្នុងផ្កាំង ដែលនៅក្នុងផែនដីនោះឯង ។ ចំណែកការប្តូរកន្លែង មានដូច្នេះថា ក្នុងកុម្ភណ្ឌកថានោះ ភិក្ខុជីកទាញទៅលើផែនដី ក្នុងឧទកដ្ឋកថានេះ ភិក្ខុសង្កត់ឲ្យលិចចុះក្នុងភក់ ។ ចំណែកការកំណត់ឋាន រមែងមានដោយអាការ ៦ ដោយប្រការដូច្នេះ ។ ក្នុងផ្កាឧប្បលជាដើម វត្ថុនៃបារាជិក គ្រប់ក្នុងផ្កាណា កាលផ្កានោះគ្រាន់តែភិក្ខុផ្តាច់ហើយ ត្រូវអាបត្តិបារាជិក ។ បណ្តាឧប្បលជាតិទាំងនេះ សម្បកជុំវិញនៃដើមឧប្បលជាតិទាំងឡាយ មិនទាន់ដាច់ទៅដរាបណា នៅរក្សានៅឡើយ ។ ចំណែកបទុមជាតិ កាលទងដាច់ហើយ សរសៃតូចៗ ខាងក្នុងមិនទាន់ដាច់ ក៏រក្សាទុកមិនបាន ។ ផ្កាឧប្បលជាដើមដែលម្ចាស់រៀបចំទុក ផ្កាណា នឹងញ៉ាំងវត្ថុបារាជិកឲ្យគ្រប់បាន កាលផ្កានោះ ភិក្ខុលើកឡើងហើយ ត្រូវអាបត្តិបារាជិក ។ ផ្កាឧប្បលជាដើម ដែលគេចងជាបាច់ៗ ទុក វត្ថុបារាជិកគ្រប់ក្នុងបាច់ណា កាលបាច់នោះភិក្ខុលើកឡើងហើយ ត្រូវអាបត្តិបារាជិក ។ ផ្កាឧប្បលជាដើម ជារបស់ទាក់ទងដោយ

ការៈ ( មានអម្រែកជាដើម ) កាលភិក្ខុឲ្យការៈនោះឃ្លាតចាកឋាន ដោយអាការណាមួយ នៃអាការ ៦ ត្រូវអាបត្តិបារាជិក តាមន័យដែលពោលហើយក្នុងថ្នាំងដែលតាំងនៅលើផែនដី ។ ផ្កាឧប្បលជាដើម មានទងវែង គេចងត្រង់ផ្កា ឬត្រង់ទងឲ្យជាបាច់ ក្រាលស្មៅលើខ្សែលើខ្នងទឹកដាក់ទុក ឬលាមទុក កំណត់ការឲ្យឃ្លាតចាកឋាននៃផ្កាឧប្បលជាដើមនោះ គប្បីជ្រាបដោយអាការ ៦ គឺបណ្តោយ កំណត់ដោយចុងផ្កា និងចុងបំផុតនៃគល់ ទទឹងកំណត់ទីបំផុតសងខាង ខាងក្រោមកំណត់ដោយឱកាសដែលទល់ ខាងលើកំណត់ដោយខ្នងនៃផ្កាដែលនៅខាងលើ ។ បើភិក្ខុណាធ្វើឲ្យក្រពួញ ឲ្យរលកកើតឡើង ញុំាងបាច់ផ្កាលែគេដាក់លើផ្ទៃទឹក ឲ្យឃ្លាតចាកឋានដើមត្រឹមមួយចុងសក់ ភិក្ខុនោះ ត្រូវអាបត្តិបារាជិក ។ តែបើលោកកំណត់ទុកថា ដល់ទីនោះហើយ អញនឹងកាន់យកដូច្នេះ នៅរក្សានៅឡើយ កាលលោកលើកឡើងក្នុងទីដែលផ្កាអណ្តែតទៅដល់ហើយ ត្រូវអាបត្តិបារាជិក ។ ទឹកទាំងមូលជាឋានរបស់ផ្កាដែលលើកឡើងផុតទឹកហើយ ។ បើភិក្ខុដកផ្កានោះលើកឡើងត្រង់ៗ កាលទីបំផុតរបស់គល់ផុតអំពីទឹកត្រឹមមួយចុងសក់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុបាច់ផ្កាឲ្យទ្រេតទៅ ហើយទាញមកខាងៗ ទើបដកឡើង ទឹកមិនមែនជាឋាន កាលផ្កានោះគ្រាន់តែភិក្ខុដកឡើងហើយ ត្រូវអាបត្តិបារាជិក ។ ក្នុងអដ្ឋ-កថាមហាបច្ចរីជាដើម ពោលពីរពាក្យនេះថា ផ្កាដែលចងជាបាច់ៗ គេចងតម្កល់ទុកក្នុងទឹកក្តី ត្រង់ដើមឈើក្តី ត្រង់គុម្ពឈើក្តី កាលភិក្ខុមិនស្រាយចំណងចេញ ធ្វើឲ្យអណ្តែតទៅខាងនោះ ខាងនេះ ជាថុល្លច្ច័យ កាលចំណង

គ្រាន់តែរបូតចេញ ត្រូវអាបត្តិបារាជិក ។ ភិក្ខុស្រាយចំណងមុន ហើយនាំទៅឯក្រោយ ក្នុងផ្កាដែលគេចងនេះ កំណត់ដោយអាការ ៦ យ៉ាង ។

សម្រាប់ភិក្ខុដែលប្រាថ្នានឹងកាន់យកផ្កាឈូកក្នុងគុម្ពឈូក ព្រមទាំងគុម្ពគប្បីជ្រាបកំណត់ឋានខាងលើ និងទទឹង ដោយអំណាចនៃទឹក ដែលទងផ្កានិងទងស្លឹកពាល់ត្រូវ ។ កាលលោកមិនបានដកគុម្ពឈូកនោះឡើង តែប្រមូលផ្កា ឬស្លឹកមកចំពោះមុខខ្លួន ត្រូវអាបត្តិថុល្លច្ច័យ លុះដកឡើង ត្រូវអាបត្តិបារាជិក ។ បើលោកមិនញ៉ាំងទងផ្កា និងទងស្លឹកឲ្យឃ្លាតចាកឋាន ដកគុម្ពឈូកឡើងមុន ត្រូវអាបត្តិថុល្លច្ច័យ កាលទងនៃផ្កា និងស្លឹក លោកឲ្យឃ្លាតចាកឋានក្នុងកាលខាងក្រោយ ត្រូវអាបត្តិបារាជិក ។ ចំណែកភិក្ខុដែលកាន់យកផ្កាក្នុងគុម្ពឈូក ដែលគេដកឡើងហើយ គប្បីវាយតម្លៃកណ្ឌៈកាត់អាបត្តិ ។ សូម្បីក្នុងផ្កាដែលចងជាបាច់ គរជាគំនរ និងដែលទាក់ទងក្នុងភារៈដែលទុកក្រៅស្រះ ក៏មានន័យដូចគ្នា ។ មើមឈូកក្តី ក្រអៅក្តី វត្ថុបារាជិកនឹងគ្រប់ដោយមើម ឬក្រអៅណា កាលភិក្ខុដកមើម ឬក្រអៅនោះឡើង ត្រូវអាបត្តិបារាជិក ។ ក្នុងមើម និងក្រអៅឈូកនេះ គប្បីកំណត់ឋានដោយអំណាចឱកាសដែលភក់ពាល់ត្រូវ ។ ក្នុងមហាអដ្ឋកថានោះឯងពោលទុកថា កាលភិក្ខុដកមើម ឬក្រអៅទាំងនោះឡើង ខ្នែងក្រអៅតូចៗ មិនទាន់ដាច់ ក៏នៅរក្សានៅឡើយ ស្លឹកក្តី ផ្កាក្តី កើតត្រង់ថ្នាំង ឬ មើមមានស្លឹក និងផ្កានោះក៏នៅរក្សានៅឡើយ ដូច្នេះ ។ ឯត្រង់ក្បាលមើមជារបស់មានបន្លា ដូចមុនត្រង់ផ្ទៃមុខរបស់ពួកមនុស្សកំពុងពេញកំលោះ ក្រមុំ ដូច្នោះ បន្លានេះរក្សា

មិនបាន ព្រោះមិនមែនជារបស់វែង ។ ពាក្យដ៏សេសមានន័យដូចពោលទុកហើយ ក្នុងផ្កាឧប្បល ( ព្រលិត ) ជាដើមនោះឯង ។ ទឹកទាំងមូលក្នុងជលាល័យទាំងឡាយ មានបឹងជាដើម ជាឋានរបស់ត្រី និងអណ្ដើកដែលមានម្ចាស់ ។ ព្រោះហេតុនោះ ភិក្ខុណាយកត្រកក្ដី ទ្រូក្ដី ដៃក្ដី ចាប់ត្រីដែលមានម្ចាស់ ក្នុងទីដែលគេហួងហែង វត្ថុបារាជិកគ្រប់ដោយត្រីមួយណា កាលត្រីមួយនោះ គ្រាន់តែលើកឡើងអំពីទឹក សូម្បីត្រឹមមួយចម្រៀកសក់ ភិក្ខុនោះត្រូវអាបត្តិបារាជិក ។ ត្រីខ្លះកាលត្រូវចាប់ រត់ទៅខាងនោះ និងខាងនេះលោតឡើងទៅកាន់អាកាស ធ្លាក់ចុះទៅ ត្រង់មាត់ច្រាំង កាលភិក្ខុចាប់យកត្រីដែលនៅក្នុងអាកាស ឬដែលធ្លាក់ទៅត្រង់ច្រាំងនោះ ត្រូវអាបត្តិបារាជិកដូចគ្នា ។ កាលភិក្ខុចាប់យកអណ្ដើកដែលវារទៅរកអាហារស៊ីខាងក្រៅមាត់ស្រះ ក៏មានន័យដូចគ្នា ។ កាលភិក្ខុឲ្យសត្វទឹកផុតចាកទឹក ត្រូវអាបត្តិបារាជិក ។

## សម័យក្រោយពុទ្ធកាលមហាជនជីកស្រះចិញ្ចឹមត្រី

ជនទាំងឡាយនៅក្នុងជនបទនោះៗ អាស្រ័យប្រឡាយសម្រាប់បង្ហូរទឹករបស់ស្រះធំ ដែលទូទៅដល់ជនទាំងពួង ជីកព្រែកទឹកដូចគ្នានឹងស្ទឹងតូចៗដែលទូទៅដល់ជនទាំងពួងដូចគ្នា ។ ពួកមហាជនបានធ្វើប្រឡាយតូចៗ អំពីព្រែកទឹកដែលស្រដៀងនឹងស្ទឹងនោះទៅ ហើយជីកជាស្រះតូចទុកដើម្បីប្រយោជន៍ដល់ការប្រើប្រាស់រៀងៗ ខ្លួន ត្រង់ចុងនៃប្រឡាយ ។ ហើយជនទាំងនោះ ត្រូវការទឹកក្នុងពេលណា ក្នុងពេលនោះ ទើបជម្រះប្រឡាយតូចក្នុង

ស្រះ និងព្រៃកឲ្យស្អាត ហើយបញ្ជោតប្រឡាយសម្រាប់បង្ហូរទឹកទៅ ។ ត្រីទាំងឡាយចេញអំពីស្រះធំនោះ ព្រមគ្នានឹងទឹកទៅដល់ស្រះតូច ដោយលំដាប់ហើយ ។ ជនទាំងឡាយមិនហាមបុគ្គលដែលចាប់ត្រីក្នុងស្រះធំ និងព្រៃកនោះឡើយ ។ តែមិនព្រម គឺហាមមិនឲ្យចាប់ត្រីទាំងឡាយដែលចូលទៅក្នុងប្រឡាយ និងស្រះតូចរៀងៗ ខ្លួន ។

## ភិក្ខុចាប់ត្រីដែលគេចិញ្ចឹមកាត់អាបត្តិតាមតម្លៃ

ភិក្ខុណា ចាប់ត្រីក្នុងទីទាំងនោះ ក្នុងស្រះធំ ឬប្រឡាយសម្រាប់បង្ហូរទឹក ឬក្នុងព្រៃក ភិក្ខុនោះ ព្រះវិនយធរគប្បីឲ្យកាត់អាបត្តិដោយអវហារ ។ តែកាលចាប់ត្រីដែលចូលទៅក្នុងប្រឡាយតូច ឬស្រះតូចហើយ គប្បីកាត់អាបត្តិដោយអំណាចនៃតម្លៃត្រីដែលចាប់បាន ។ បើត្រីដែលកំពុងចាប់អំពីប្រឡាយតូច និងស្រះតូចនោះ លោតឡើងទៅក្នុងអាកាស ឬធ្លាក់ចុះមកត្រង់ច្រាំង កាលភិក្ខុចាប់យកត្រីនោះ ដែលនៅក្នុងអាកាស ឬដែលនៅលើច្រាំងផុតអំពីទឹកហើយ អវហារមិនមាន ។ ព្រោះហេតុអ្វី ព្រោះថា ជនទាំងនោះ ជាម្ចាស់ត្រីដែលនៅត្រង់ទីហួងហែងរបស់ខ្លួនប៉ុណ្ណោះ ។ ពិតហើយ កតិកាបែបនេះ ជាកតិកាក្នុងជនបទទាំងនោះ ។ សូម្បីក្នុងអណ្ដើកក៏មានន័យដូចគ្នា ។ តែបើត្រីដែលត្រូវចាប់ហែលឡើងអំពីស្រះតូច ទៅក្នុងប្រឡាយតូច កាលភិក្ខុចាប់ត្រីនោះក្នុងប្រឡាយតូចនោះ ជាអវហារពិត ។ តែមិនជាអវហារដល់ភិក្ខុដែលចាប់ត្រី ដែលហែលឡើងអំពីប្រឡាយតូច ចុះទៅកាន់ព្រៃក និងហែលឡើងអំពីព្រៃកនោះ ទៅក្នុងស្រះធំហើយ ។ ភិក្ខុយកគ្រាប់

បាយបញ្ឆោតត្រីអំពីស្រះតូច ឲ្យទៅកាន់ប្រឡាយ ហើយចាប់យក ជាអវហារដល់ភិក្ខុនោះពិត ។ តែមិនជាអវហារដល់ភិក្ខុដែលបញ្ឆោតពីប្រឡាយនោះទៅក្នុងព្រែក ហើយចាប់យក ។ ជនពួកខ្លះនាំយកត្រីអំពីទីសាធារណៈដល់ជនទាំងពួង កន្លែងខ្លះនោះឯង បង្ខាំងទុកក្នុងស្រះតូចត្រង់សួន ហើយសម្លាប់ម្តងពីរ ម្តងបី ដើម្បីប្រយោជន៍ដល់សម្លរាល់ថ្ងៃ ។ កាលភិក្ខុចាប់ត្រីបែបនោះដែលនៅក្នុងទឹកក្តី លើអាកាសក្តី មាត់ច្រាំងណាមួយក្តី ជាអវហារពិត ។ សូម្បីអណ្តើកក៏មានន័យដូចគ្នា ។

ក្នុងរដូវប្រាំង ខ្សែទឹកក្នុងស្ទឹងអស់ទៅ ទឹករមែងដក់នៅក្នុងរណ្តៅកន្លែងខ្លះ មនុស្សទាំងឡាយបាចផ្លែឈើពុល និងថ្នាំពុលជាដើមចូល ដើម្បីឲ្យត្រីទាំងឡាយក្នុងរណ្តៅនោះវិនាស ។ ត្រីទាំងឡាយស៊ីផ្លែឈើពុល និងថ្នាំពុលជាដើមនោះ ហើយងាប់ផ្ងារពោះ អណ្តែតលើទឹក ។ ភិក្ខុណាទៅក្នុងទីនោះ ហើយចាប់យកដោយធ្វើទុកក្នុងចិត្តថា ម្ចាស់ត្រីមិនទាន់មកដរាបណា អញនឹងចាប់យកត្រីទាំងនេះដរាបនោះ ភិក្ខុនោះ ព្រះវិនយធរគប្បីកាត់អាបត្តិតាមតម្លៃ បើភិក្ខុកាន់យកដោយបង្សុកូលសញ្ញា មិនជាអវហារឡើយ តែបើម្ចាស់ត្រី ឲ្យសង ជាភណ្ឌទេយ្យ ។ មនុស្សទាំងឡាយបាចថ្នាំបំពុលត្រី ហើយនាំគ្នាត្រឡប់ទៅ នាំភាជនៈមកដាក់ឲ្យពេញ ហើយទៅ ។ ពួកជនទាំងនោះនៅមានអាល័យថា ពួកយើងនឹងត្រឡប់មកវិញទៀត ដរាបណា ត្រីទាំងនោះនៅរាប់ថា ជាត្រីមានម្ចាស់ដរាបនោះ ។ តែកាលណា ពួកជនទាំងនោះអស់អាល័យ ចៀសទៅដោយដាក់ចិត្តថា ពួកយើងល្មមហើយ ចាប់ពីពេលនោះ

ទៅ បើភិក្ខុកាន់យកដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដ តែមិនជាអាបត្តិដល់ភិក្ខុដែលមានបង្សុកូលសញ្ញា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងវារីជាតិគ្រប់ប្រភេទ ដូចត្រី និងអណ្តើក ដូច្នេះ ។

កថាពោលដោយទ្រព្យដែលនៅក្នុងទឹក ចប់

## ទ្រព្យដែលស្ថិតនៅក្នុងទូក

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលស្ថិតនៅក្នុងទូកថា ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងទូកជាលំដាប់ដំបូង ទើបត្រាស់ថា **នាវា នាម យាយ តរតិ** ដូច្នេះ ព្រោះដូច្នោះ ក្នុងអធិការពោលដោយទ្រព្យ ដែលស្ថិតនៅក្នុងទូកនេះ ពាហនៈសម្រាប់ឆ្លងទឹក ដោយហោចសូម្បីស្នូកជ្រលក់សំពត់ក្តី ក្បូនឫស្សីក្តី គប្បីជ្រាបថា ទូកទាំងអស់ ។ ចំណែកក្នុងការកំណត់សីមា ទូកកម្រោលដែលភិក្ខុជាប់ខាងក្នុងក្តី រៀបចំធ្វើដោយបន្ទះក្តារក្តី ដោយកំណត់យ៉ាងទាបបំផុត ផ្ទុកមនុស្សឆ្លងត្រើយបាន ៣ នាក់ ទើបប្រើបាន ។ តែក្នុងនាវត្ថាធិការនេះ ផ្ទុកមនុស្សបានសូម្បីតែម្នាក់ ក៏លោកហៅថា ទូកដូចគ្នា ។

ភណ្ឌៈឯណាមួយ ទាក់ទងនឹងតួទូកក្តី មិនទាក់ទងតួទូកក្តី ឈ្មោះថា ភណ្ឌៈដែលទុកក្នុងទូក ។ លក្ខណៈការលួចភណ្ឌៈដែលទុកក្នុងទូកនោះ គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងភណ្ឌៈដែលតាំងនៅលើគោកនោះ

*ឯង ។ ការស្វែងរកគ្នីគ្នា ការដើរទៅ ការចាប់ពាល់ និងការធ្វើឲ្យកម្រើក ក្នុងពាក្យជាដើមថា* **ឆាវំ អវហរិស្សាមិ** *មានន័យដូចពោលហើយនោះឯង ។ ចំណែកក្នុងពាក្យថា* **ពន្ធំ មោចេតិ** *នេះ មានវិនិច្ឆ័យដូច្នេះថា ទូកណា កាលស្រាយចំណងហើយ ក៏នៅមិនឃ្លាតចាកឋាន ចំណងរបស់ទូកនោះ នៅស្រាយមិនចេញដរាបណា នៅជាទុក្កដដរាបនោះ តែកាលស្រាយចេញ ហើយ ត្រូវអាបត្តិថុល្លច្ច័យក៏មាន ត្រូវអាបត្តិបារាជិកក៏មាន ។ ពាក្យនោះនឹង មានច្បាស់ខាងមុខ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ពណ៌នាចំពោះបាលីមានប្រមាណប៉ុណ្ណេះសិន ។*

# វិនិច្ឆ័យចាលីមុត្តក

*ចំណែកវិនិច្ឆ័យក្រៅបាលី ក្នុងអធិការពោលដោយទូកនេះ មានដូច្នេះ ថា សម្រាប់ទូកដែលចងចតទុកក្នុងខ្សែទឹកហូរ មានឋាន ១ គឺ ចំណង ប៉ុណ្ណោះ ។ កាលចំណងនោះគ្រាន់តែស្រាយចេញហើយ ត្រូវអាបត្តិបារាជិក ការប្រែកបក្នុងចំណងនោះ បានពោលទុកខាងដើមនោះឯង ចំណែកក្នុងទូក ដែលគេពន្ធចទុក ទូករសាត់ទៅរហូតប្រទេសត្រឹមប៉ុនណា ប្រទេសនៃទឹក នោះៗ ជាឋានរបស់ទូកនោះៗ ព្រោះហេតុនោះ កាលភិក្ខុស្ទាឡើងខាងលើក្តី សន្កត់ឲ្យលិចចុះទៅខាងក្រោមក្តី កន្ទងឱកាសដែលទូកពាល់ត្រូវក្នុងទិសទាំង ៤ ក្តី ត្រូវអាបត្តិបារាជិក ក្នុងខណៈដែលកន្ទងហួសឋានទៅ ។ បើទូកមិន បានចង ចតនៅតាមធម្មតារបស់ទូកក្នុងទឹកនឹង កាលភិក្ខុទាញទៅខាងមុខក្តី ទៅខាងក្រោយក្តី ទៅខាងឆ្វេង និងខាងស្តាំក្តី គ្រាន់តែទីដែលតាំងនៅក្នុងទឹក*

ក្នុងឋានមួយៗ កន្ទង់ហួសឱកាសដែលម្ខាងពាល់ត្រូវទៅ ត្រូវអាបត្តិបារាជិក ។ កាលលើកឡើងខាងលើឲ្យផុតអំពីទឹក ត្រឹមមួយចុងសក់ ត្រូវអាបត្តិបារាជិក កាលសន្ធត់ចុះខាងក្រោម ឲ្យកណ្តាប់មាត់កន្ទង់ឱកាស ដែលពោះទូកពាល់ត្រូវទៅ ត្រូវអាបត្តិបារាជិក ។ សម្រាប់ទូកដែលចងត្រង់មាត់ច្រាំង ចតនៅក្នុងទឹកនឹងមានឋាន ២ គឺចំណង ១ ឱកាសដែលចត ១ ជាដំបូងភិក្ខុស្រាយទូកនោះចេញអំពីគ្រឿងចង ត្រូវអាបត្តិថុល្លច្ច័យ ។ ក្រោយមក ឲ្យឃ្លាតចាកឋានដោយអាការឯណាមួយ នៃអាការ ៦ ត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងការឲ្យឃ្លាតចាកឋានមុន ស្រាយចំណងជាក្រោយ ក៏មានន័យដូចគ្នានេះ ។ ឱកាសដែលពាល់ត្រូវ ជាឋានរបស់ទូកដែលរុញឡើងដាក់ផ្ងារទុកលើគោក ។ កំណត់ឋានរបស់ទូកនោះ គប្បីជ្រាបដោយអាការ ៥ យ៉ាង តែឱកាសដែលក្របមាត់ពាល់ត្រូវប៉ុណ្ណោះ ជាឋានរបស់ទូកដែលគេផ្កាប់ទុក អ្នកសិក្សាគប្បីជ្រាបការកំណត់ឋានរបស់ទូកនោះ ដោយអាការ ៥ យ៉ាង ហើយជ្រាបថា ត្រូវអាបត្តិបារាជិក ក្នុងកាលទូកគ្រាន់តែកន្ទង់ហួសឱកាសដែលពាល់ត្រូវណាមួយ និងខាងលើទៅត្រឹមមួយចម្រៀកសក់ ។ ឯឱកាសដែលឈើបង្គង់ពាល់ត្រូវប៉ុណ្ណោះ ជាឋានរបស់ទូកដែលគេរុញឡើងលើគោក ហើយដាក់លើបង្គង់ ២ ។ ព្រោះដូច្នោះ វិនិច្ឆ័យក្នុងទូកដែលគេដាក់លើបង្គង់នោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសំពត់សាដកសាច់រឹង ដែលពាក់ទុកចំពោះលើចុងជើងគ្រែ និងក្នុងលំពែង ខ្សែតីកន្ទុយសត្វ ដែលគេដាក់លើដៃកែវ ។ តែបើទូកចងខ្សែ មិនមែនត្រឹមតែឱកាសដែលទូកពាល់ត្រូវប៉ុណ្ណោះ

ទេជាឋាននោះ សូម្បីខ្សែដែលគេមិនទាន់បានស្រាយ ប្រមាណ ៦០-៧០ ព្យាម ដែលជាប់ពីទូកមកពាក់នឹងបង្គោលដែលបោះចុះក្នុងដីលើគោក មួយ អន្ទើដោយខ្សែ ( ក៏ជាឋានដែរ ) គប្បីជ្រាបថា បណ្តោយត្រឹមទីចំណែកខាងក្រោយនៃឱកាសដែលទូកប៉ះផែនដី និងចាប់ពីចុងខ្សែមកជាឋានមុន ចំណែកទទឹង ប្រមាណទីបំផុតជុំវិញដែលទូក និងខ្សែប៉ះផែនដីជាឋាន ។ កាលភិក្ខុទាញទូកនោះទៅតាមបណ្តោយក្តី តាមទទឹងក្តី គ្រាន់តែឲ្យចំណែកដែលប៉ះផែនដីម្ខាងហួសឱកាស ត្រង់ចំណែកម្ខាងពាល់ត្រូវ ត្រូវអាបត្តិបារាជិក កាលលើកឡើងខាងលើ ឲ្យផុតអំពីផែនដី ព្រមទាំងខ្សែត្រឹមមួយចុងសក់ ត្រូវអាបត្តិបារាជិក ។

ម្យ៉ាងទៀត ភិក្ខុណា មានថេយ្យចិត្តឡើងទៅកាន់ទូកដែលចតត្រង់កំពង់ យកច្នៅល ឬច្រវាចែវទៅ ភិក្ខុនោះ ត្រូវអាបត្តិបារាជិក ។ តែបើភិក្ខុបើកឆត្រ ឬយកជើងទាំងពីរជាន់ចីវរ ហើយយកដៃទាំងពីរលើកឡើង ធ្វើក្តោងឲ្យជក់ខ្យល់ កម្លាំងខ្យល់បក់មកនាំទូកទៅ ទូកនោះ គឺលួចទៅដោយខ្យល់នោះឯង ។ អវហារមិនមានដល់បុគ្គល តែការព្យាយាមមាន ការព្យាយាមនោះ មិនមែនជាការព្យាយាមក្នុងការដែលឲ្យឃ្លាតចាកឋានឡើយ ។ បើទូកនោះរសាត់ទៅយ៉ាងនោះ ភិក្ខុវៀរមិនឲ្យរសាត់ទៅតាមប្រក្រតីចេញ នាំទៅកាន់ចំណែកនៃទិសដទៃ ត្រូវអាបត្តិបារាជិក ។ ទូកដែលស្មុះទៅដល់កំពង់ក្នុងស្រុកឯណាមួយខ្លួនឯង ភិក្ខុមិនឲ្យឃ្លាតចាកឋាន លក់ដូរហើយក៏ទៅ មិនជាអវហារឡើយ តែជាភណ្ឌទេយ្យ ដូច្នេះឯង ។

ទ្រព្យដែលស្ថិតនៅក្នុងទូក ចប់

## ទ្រព្យដែលតាំងនៅក្នុងយាន

[ ៩៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលតាំងនៅក្នុងយានថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងយានមុន ទើបត្រាស់ថា **យានំ នាម វយ្ហំ** ជាដើម ។ ក្នុង ពាក្យថា **វយ្ហំ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា យានដែលបិទបាំងដោយបន្ទះក្តារខាងលើ ដូចមណ្ឌបក្តី ដែលគេធ្វើបិទហ៊ុមទាំងអស់ក្តី ឈ្មោះថា អង្រឹងស្នែង ។ គ្រែដែលគេដាក់គន្លឹះ ដែលសម្រេចដោយមាសនិងប្រាក់ជាដើមត្រង់សងខាង ហើយធ្វើដោយន័យដូច ស្វាបគ្រុឌ ឈ្មោះថា គ្រែស្នែង ។ រថ និងរទេះប្រាកដច្បាស់ហើយ ដូច្នេះ ។ កណ្ឌៈដែលមានវិញ្ញាណ ឬមិនមានវិញ្ញាណ ដែលគេរក្សាទុកដោយអំណាចជាគំនរជាដើម ក្នុងបណ្តាអង្រឹងស្នែងជាដើមនោះឯណាមួយ កាលភិក្ខុឲ្យឃ្លាតចាកឋានដោយថេយ្យចិត្ត គប្បីជ្រាបថា ត្រូវបារាជិក ដោយន័យដូចពោលទុកហើយ ក្នុងកណ្ឌៈដែលតាំងនៅក្នុងទូក ឬតាំងនៅលើគោក ។ ឯការប្លែកគ្នាមានដូច្នេះថា បើភិក្ខុយកកញ្ជើទទួលយកទ្រព្យ មានអង្ករជាដើម ដែលតាំងនៅលើយានសូម្បីមិនលើកកញ្ជើឡើង កាលទះកញ្ជើ ធ្វើឲ្យទ្រព្យ មានអង្ករជាដើមដែលនៅជាប់ជាមួយគ្នា ត្រូវអាបត្តិបារាជិក ។ ន័យនេះដែរ រមែងប្រើបានសូម្បីក្នុងទ្រព្យដែលតាំងនៅលើគោកជាដើម ។ កិច្ចទាំងឡាយ មានការស្វែងរកមិត្រភក្តិជាដើម ក្នុងពាក្យថា យើងនឹងលួចយាន មានន័យដូចពោលហើយនោះឯង ។

ក្នុងពាក្យថា **ឋានា ចាវេតិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា សម្រាប់យានដែលទឹមដោយគោពីរ មានឋាន ១០ គឺជើងទាំង ៨ របស់គោទាំងពីរ

និងកង់ ២ កាលភិក្ខុមានថេយ្យចិត្តឡើងរទេះនោះ អង្គុយលើទូករទេះបរទៅ ក្នុងកាលគោទាំងពីរលើកជើងឡើង ជាថុល្លច្ច័យ និងកាលឱកាសត្រឹមមួយចម្រៀកសក់ហួសទៅដោយប្រទេស ដែលកង់ទាំងពីរប៉ះផែនដី ត្រូវអាបត្តិបារាជិក ។ បើគោទាំងពីរដឹងថា មនុស្សនេះមិនមែនម្ចាស់របស់អញ ហើយទម្លាក់នឹមចោល មិនព្រមអូសទៅ ឈប់ក្តី រើបម្រះក្តី នៅរក្សានៅឡើយ កាលភិក្ខុចាប់គោទាំងពីរទឹមឲ្យចូលទៅត្រង់ៗ ហើយដាក់នឹមទឹមឲ្យមាំចាក់ដោយជន្ទួញបរទៅទៀត កាលគោទាំងនោះលើកជើងឡើង ត្រូវអាបត្តិថុល្លច្ច័យ តាមន័យដែលពោលហើយនោះឯង ក្នុងកាលកង់នោះវិលទៅ ត្រូវអាបត្តិបារាជិក ។ បើក្នុងផ្លូវមានកក់ កង់ម្ខាងជាប់ហើយក្នុងកក់ គោទាញកង់មួយទៀតឲ្យវិល អវហារមិនទាន់មានឡើយ ព្រោះកង់ម្ខាងទៀតតាំងនៅនៅឡើយ ។ តែកាលភិក្ខុចាប់គោទាំងពីរទឹមឲ្យត្រង់ ហើយបរទៅទៀត កាលកង់ដែលឈប់ស្ងៀម វិលហួសឱកាសដែលពាល់ត្រូវ ត្រឹមមួយចម្រៀកសក់ ត្រូវអាបត្តិបារាជិក ។ គប្បីជ្រាបការផ្សេងគ្នានៃឋានរបស់យានដែលទឹម ដោយឧបាយនេះ គឺយានដែលទឹមដោយពាហនៈ ៤ មានឋាន ១៨ ដែលទឹមដោយពាហនៈ ៨ មានឋាន ៣៤ ។ ចំណែកយានណាដែលមិនបានទឹម គេប្រើជន្ទល់ទល់ត្រង់ទូក ១ និងជន្ទល់ខាងក្រោយពីរដែលចតទុកយាននោះមានឋាន ៥ ដោយអំណាចនៃជន្ទល់ ៣ និងកង់ ២ បើជន្ទល់ទល់ត្រង់នឹមគេពុះជាចំពាមត្រង់ខាងក្រោម មានឋាន ៦ ។ ចំណែកយានដែលមិនបានទល់ខាងក្រោយ ទល់ត្រង់ទូកប៉ុណ្ណោះ មានឋាន ៣ ខ្លះ ៤ ខ្លះ

ដោយអំណាចនៃជន្ទល់ ។ សម្រាប់យានដែលគេយកទូកពាក់ទុកលើក្តារ ឬលើឈើ មានឋាន ៣ ។ យានដែលគេយកទូកពាក់ទុកត្រង់ផែនដីក៏ដូចគ្នា ។ បើភិក្ខុទាញ ឬលើកយាននោះឲ្យឃ្លាតចាកឋានទៅខាងមុខ និងខាងក្រោយ ត្រូវអាបត្តិថុល្លច្ច័យ បើឋានដែលកង់ទាំងពីរ ចតកន្ទងហួសទៅត្រឹមមួយចម្រៀកសក់ ត្រូវអាបត្តិបារាជិក ។ សម្រាប់យានដែលដោះកង់ចេញ ហើយយកចុងភ្លៅទាំងពីរពាក់ទុកលើឈើ មានឋាន ២ ។ ភិក្ខុកាលទាញ ឬលើកយាននោះ ឲ្យកន្ទងហួសឱកាសដែលភ្លៅពាល់ត្រូវ ត្រូវអាបត្តិបារាជិក ។ យានដែលគេដាក់ទុកលើផែនដី មានឋាន ៥ ដោយអំណាចនៃទីចត និងទូក និងឈើទល់ភ្លៅ ៤ កំណាត់ ។ បើភិក្ខុចាប់យាននោះ ត្រង់ទូកអូសទៅ កាលចំណែកទីបំផុតខាងមុខ និងចំណែកបំផុតខាងក្រោយនៃឈើទល់ភ្លៅឃ្លាតអំពីគ្នា ត្រូវអាបត្តិបារាជិក ។ កាលចាប់ត្រង់ឈើទល់ភ្លៅអូសទៅ កាលចំណែកខាងក្រោយ និងចំណែកខាងមុខរបស់ឈើទល់ភ្លៅឃ្លាតអំពីគ្នា ត្រូវអាបត្តិបារាជិក ។ កាលចាប់ត្រង់ប្រែកអូសទៅចំហៀង ក្នុងកាលដែលឈើទល់ភ្លៅនោះឯង ដែលនៅត្រង់ទទឹងឃ្លាតចាកឋានគ្នាទៅ ត្រូវអាបត្តិបារាជិក ។ កាលចាប់ត្រង់កណ្តាលលើកឡើង កាលឱកាសត្រឹមមួយចម្រៀកសក់ផុតអំពីផែនដី ត្រូវអាបត្តិបារាជិក ។ បើមិនមានឈើជន្ទល់ភ្លៅ គេក៏ធ្វើប្រែកឲ្យប៉ុនគ្នា ហើយបោះត្រង់កណ្តាលស៊ីកភ្លៅចូលទៅ យាននោះតាំងនៅប៉ះត្រូវផែនដីទាំងអស់ ដោយជុំវិញផែនដីខាងក្រោម ។ ក្នុងយាននោះគប្បីជ្រាបថា ត្រូវអាបត្តិបារាជិក ដោយអំណាចកន្ទងហួសឋានដែលប៉ះត្រូវទាំង ៤ ទិស និងខាងលើ ។ កង់ដែលគេយកដុំដាក់លើផ្ទៃផែនដី មាន

តែមួយឋានប៉ុណ្ណោះ ។ ការកំណត់កន្លែងនោះ គប្បីជ្រាបដោយអាការ ៥ យ៉ាង កន្លែងដែលដាក់ឲ្យម្ខាងនៃកន្លែង និងជុំប៉ះនឹងដី ( គឺផ្តេកបះម្ខាង ) មានឋានពីរ ។ កាលភិក្ខុយកជើងជាន់ចំណែកដែលផុតពីដីនៃកន្លែង ឲ្យប៉ះត្រូវផែនដី ហើយចាប់ត្រង់កាំ ឬត្រង់ខ្នងកន្លែងលើកឡើង ទីដែលខ្លួនធ្វើមិនចាត់ជាឋាន ព្រោះហេតុនោះ កាលចំណែកដ៏សេសដែលតាំងនៅនោះ គ្រាន់តែកន្លងទៅ ត្រូវអាបត្តិបារាជិក សូម្បីកន្លែងដែលគេដាក់ផ្អែកជញ្ជាំងទុក ក៏មានឋាន ២ បណ្តាឋានទាំងពីរនោះ កាលភិក្ខុធ្វើឲ្យផុតពីជញ្ជាំងគ្រាដំបូង ត្រូវថុល្លច្ច័យ ខាងក្រោយ ក្នុងកាលលើកឡើងផុតពីផែនដី ត្រឹមតែមួយចម្រៀកសក់ ត្រូវអាបត្តិបារាជិក ។ តែបើភិក្ខុលើកឲ្យផុតពីផែនដីមុន បើឋានដែលតាំងនៅត្រង់ជញ្ជាំងមិនកម្រើក ក៏មានន័យនេះឯង ។ បើភិក្ខុចាប់ត្រង់កាំ ទាញទៅខាងក្រោមទីបំផុតខាងលើនៃឱកាសដែលប៉ះត្រូវជញ្ជាំង កន្លងផុតចំណែកខាងក្រោម ត្រូវអាបត្តិបារាជិក ។ យានដែលកំពុងធ្វើដំណើរទៅ ម្ចាស់យានចុះចាកយាន គេចចេញទៅផ្លូវដទៃ ដោយករណីណាមួយ បើភិក្ខុអង្គដទៃដើរតាមផ្លូវមក ឃើញយានមិនមានការរក្សា ទើបគិតថា យើងនឹងលួចយកយាន ហើយឡើងជិះ ។ គោទាំងឡាយនាំចៀសចេញទៅ វៀរចាកការព្យាយាមរបស់ភិក្ខុនោះឯង មិនជាអវហារ ។ ពាក្យដ៏សេសដូចគ្នានឹងពោលទុកហើយក្នុងទូក ដូច្នេះឯង ។

ទ្រព្យដែលស្ថិតនៅក្នុងយាន ចប់

# ទ្រព្យដែលស្ថិតនៅក្នុងភារៈ

[ ៩៨ ] បន្ទាប់អំពីកណ្ឌៈដែលតាំងនៅក្នុងយាននេះទៅ ភារៈនោះឯង ឈ្មោះថា **ភារដ្ឋំ** កណ្ឌៈដែលតាំងនៅក្នុងភារៈ ។ ភារៈនោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងទុក ៤ ប្រការ ដោយអំណាចនៃសីសភារៈជាដើម ។ ក្នុងកណ្ឌៈដែលតាំងនៅក្នុងភារៈនោះ គប្បីជ្រាបការកំណត់អវយវៈ មានក្បាលជាដើម ដើម្បីការមិនវង្វេងច្រល់ក្នុងភារៈទាំងឡាយ មានសីសភារៈជាដើម ។ បណ្តាអវយវៈទាំងនោះ គប្បីជ្រាបការកំណត់សីសភារៈមុន ខាងក្រោមផ្នែកខាងមុខ មានរណ្តៅក ខាងក្រោយរបស់បុគ្គលពួកខ្លះ មានកន្ទុយអណ្តើកសងខាងនៃកនោះសក់របស់បុគ្គលពួកខ្លះ ដុះលយចុះមក ហៅថា គុម្ពត្រចៀក ចំណែកខាងក្រោមនៃសក់ទាំងនោះផង កំណត់ខាងលើអំពីនោះឡើងទៅផង ឈ្មោះថា ក្បាល ។ ភារៈដែលឋិតនៅក្នុងចន្លោះនេះ ឈ្មោះថា **សីសភារ** ភារៈលើក្បាល ។ អវយវៈដែលឈ្មោះថា **ក** ត្រង់ចំហៀងសងខាង ខាងក្រោម រាប់ពីគុម្ពត្រចៀកចុះទៅ ខាងលើ រាប់ពីកែងដៃឡើងមក ( ខាងមុខ ខាងក្រោយ ) ខាងក្រោម ចាប់អំពីរណ្តៅក និងចុងកន្ទុយអណ្តើកចុះទៅ ខាងលើ រាប់អំពីក្រយៅកណ្តាលខ្នង និងចុងដង្ហើមឡើងមក ភារៈដែលតាំងនៅក្នុងចន្លោះនេះ ឈ្មោះថា **ខន្ធភារ** ភារៈលើ ក ។

( ភារៈលើចង្កេះ ) ខាងក្រោម តាំងអំពីក្រយៅកណ្តាលខ្នង ខាងមុខពីចុងដង្ហើមចុះដល់ចុងក្រចកជើង នេះជាការកំណត់នៃចង្កេះ ភារៈដែលតាំងនៅក្នុងសរីរៈដោយជុំវិញ ក្នុងចន្លោះនេះ ឈ្មោះថា **កដិភារ** ភារៈលើចង្កេះ។

( ភារៈដែលយួរ ) ខាងក្រោម ចាប់អំពីកែងដៃចុះទៅ រហូតដល់ចុង

ក្របក នេះជាការកំណត់នៃរបស់ដែលយួរ ។ ភារៈដែលតាំងនៅក្នុងចន្លោះនេះ ឈ្មោះថា **ឱលម្ពក** ភារៈដែលយួរ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យជាលំដាប់ទៅ ក្នុងពាក្យថា **សីសេ ភារំ** ជាដើម ដូច្នេះថា ភិក្ខុណា ដែលពួកម្ចាស់ទ្រព្យមិនបានប្រាប់ថា លោកម្ចាស់ចូរកាន់យកកណ្ឌៈនេះទៅក្នុងទីនេះ ភិក្ខុនិយាយខ្លួនឯងថា អ្នកចូរប្រគល់កណ្ឌៈឈ្មោះនេះ ឲ្យដល់អាត្មាៗ នឹងនាំយកកណ្ឌៈរបស់ពួកអ្នកទៅ ដូច្នេះ ហើយយកក្បាលទូលកណ្ឌៈរបស់ពួកជនទាំងនោះទៅ ស្ទាបអង្អែលកណ្ឌៈនោះដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដ កាលមិនទាន់ឲ្យកន្លងឋានរបស់សីសៈតាមដែលពោលហើយ គ្រាន់តែទាញផ្លាស់ប្តូរទៅខាងនោះខ្លះ ខាងនេះខ្លះត្រូវថុល្លច្ច័យ កាលកណ្ឌៈនោះ លុះលោកដាក់ចុះកាន់ក សូម្បីពួកម្ចាស់ទ្រព្យមានការគិតថា ចូរនាំទៅចុះ ដូច្នេះ សូម្បីយ៉ាងនោះ ក៏ត្រូវបារាជិក ព្រោះខ្លួនមិនបានត្រូវពួកម្ចាស់ទ្រព្យប្រាប់អំពីមុន ។ម្យ៉ាងទៀត បើភិក្ខុមិនបានដាក់ចុះមកកាន់ក តែឲ្យផុតចាកក្បាល ត្រឹមតែមួយចម្រៀកសក់ ក៏ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត សម្រាប់ភារៈ ២ ចំណែក ១ ចំណែកតាំងនៅលើក្បាល ១ ចំណែកតាំងនៅត្រង់ខ្នង ក្នុងភារៈទាំង ២ នោះ គប្បីជ្រាបវិនិច្ឆ័យ ដោយអំណាចនៃឋាន ២ ។ តែការចង្អុលបង្ហាញនេះ បានប្រារព្ធដោយអំណាចនៃភារៈ មានសីសភារៈសុទ្ធៗ ជាដើមប៉ុណ្ណោះ ។ ម្យ៉ាងទៀត សូម្បីក្នុងខន្ធភារៈជាដើមក៏មានវិនិច្ឆ័យដូចដែលពោលទុកក្នុងសីសភារៈនេះ ។

ចំណែកក្នុងពាក្យថា **ហត្ថេ ភារំ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា

កណ្ដៈដែលយួរទៅ ហៅថា **ហត្ថភារ** ព្រោះជារបស់ដែលកាន់ទៅដោយដៃ ភារៈនោះ ទោះជារបស់ដែលកាន់យកអំពីផ្ទៃដីអំពីមុន ឬជារបស់ដែលកាន់យកអំពីក្បាលជាដើម ដោយចិត្តបរិសុទ្ធក៏ដោយ ក៏ដល់នូវការរាប់ថា ជាហត្ថភារៈដូចគ្នា ។ កាលភិក្ខុឃើញព្រៃស្ទុក ដូច្នោះ ទើបដាក់ភារៈនោះចុះត្រង់ផែនដី ឬត្រង់គុម្ពឈើជាដើម ដោយថេយ្យចិត្ត កាលភារៈនោះគ្រាន់តែផុតអំពីដៃ ត្រូវអាបត្តិបារាជិក ។

ឯក្នុងពាក្យថា **ភូមិតោ គណ្ហាតិ** នេះ មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុដាក់ភារៈទាំងនោះណាមួយចុះលើផែនដី ដោយចិត្តបរិសុទ្ធ ព្រោះហេតុ មានអាហារព្រឹកជាដើម ហើយត្រឡប់លើកឡើងទៀត ដោយថេយ្យចិត្ត សូម្បីត្រឹមមួយចម្រៀកសក់ ក៏ត្រូវអាបត្តិបារាជិក ដូច្នេះឯង ។

ទ្រព្យដែលតាំងនៅក្នុងភារៈ ចប់

# ទ្រព្យស្ថិតនៅក្នុងអារាម

[ ៩៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យ ដែលតាំងនៅក្នុងសួនតទៅថា ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងសួនជាបឋម ទើបត្រាស់ថា **អារាមោ នាម បុប្ផារាមោ នាម ផលារាមោ** ដូច្នេះ ។ បណ្តាសួនទាំងនោះ សួនជាទីរីកនៃផ្កាទាំងឡាយ មានផ្កាម្លិះជាដើម ឈ្មោះថា សួនផ្កា ។ ចំណែកសួនជាទីចេញនៃផ្លែទាំងឡាយ មានផ្លែស្វាយជាដើម ឈ្មោះថា សួនផ្លែឈើ ។ វិនិច្ឆ័យកណ្ឌៈដែលគេរក្សាទុកក្នុងសួន ដោយឋាន ៤ មានន័យដូចពោលហើយ ក្នុងកណ្ឌៈដែលតាំងនៅលើផ្ទៃដីជាដើមនោះឯង ។ ចំណែកវិនិច្ឆ័យក្នុងកណ្ឌៈដែលកើតក្នុងសួននោះ គប្បីជ្រាបដូច្នេះថា ឫសឈើប្រភេទណាមួយ មានឫសស្បូវក្លាំង និងស្លឹកគ្រៃជាដើម ឈ្មោះថា **មូលំ** កាលភិក្ខុដកឫសនោះកាន់យកក្តី កាន់យកឫសដែលគេដកទុកហើយក្តី វត្ថុនៃបារាជិកនឹងគ្រប់ដោយឫសណា កាលឫសនោះ ដែលលោកកាន់យកហើយ ត្រូវអាបត្តិបារាជិក ។ សូម្បីមើមដំឡូង ក៏សង្គ្រោះចូលដោយឫសដូចគ្នា កាលភិក្ខុដកមើមឡើង បើមើមនោះមិនទាន់ដាច់ មានប្រមាណបន្តិចបន្តួច ត្រូវអាបត្តិថុល្លច្ច័យ ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងក្រអៅឈូកនោះឯង ។

បទថា **តចំ** បានដល់ សម្បកឈើប្រភេទណាមួយ ដែលល្មមប្រើប្រកបដើម្បីជាភេសជ្ជៈ ឬដើម្បីជាគ្រឿងជ្រលក់ ។ បើភិក្ខុស្ទោះសម្បកឈើនោះ ឬកាន់យកសម្បកឈើដែលគេស្ទោះទុកហើយ ត្រូវអាបត្តិបារាជិក ដោយន័យដែលពោលទុកហើយ ក្នុងឫសឈើនោះឯង ។

បទថា **បុប្ផំ** បានដល់ ផ្កាប្រភេទណាមួយ មានម្ទេះលា ម្ទេះរួតជាដើមៗ បើភិក្ខុបេះយកផ្កាឈើនោះ ឬកាន់យកផ្កាដែលគេបេះទុកហើយ ត្រូវអាបត្តិបារាជិក ដោយន័យដែលពោលទុកហើយក្នុងផ្កាព្រលិត និងផ្កាឈូកនោះឯង ។ ពិតហើយ សូម្បីផ្កាទាំងឡាយ មានទង ឬជាង មិនទាន់ដាច់នៅឡើយ ក៏នៅរក្សានៅឡើយ តែសម្រាប់ផ្កាពួកខ្លះ មានសរសៃនៅក្នុងទង សរសៃនោះរក្សាមិនបាន ។

បទថា **ផលំ** បានដល់ ផ្លែប្រភេទណាមួយ មានផ្លែស្វាយ និងផ្លែត្នោតជាដើម ។ វិនិច្ឆ័យសម្រាប់ភិក្ខុដែលកាន់យកផ្លែឈើនោះអំពីដើមឈើ ខ្ញុំបានពោលទុកហើយ ក្នុងកថាពោលដោយភណ្ឌៈដែលពាក់ទុកលើដើមឈើ ផ្លែឈើដែលគេបេះទុក សង្គ្រោះចូលដោយភណ្ឌៈ ដែលតាំងនៅលើផែនដីជាដើមផងដែរ ។

ពីរបទថា **អារាមំ អភិយុញ្ជតិ** សេចក្តីថា ភិក្ខុនិយាយកុហកបំពានយកសួន ដែលជារបស់អ្នកដទៃថា នេះជាសួនរបស់អាត្មា ដូច្នេះ ត្រូវអាបត្តិទុក្កដ ព្រោះជាប្រយោគនៃអទិន្នាទាន ។

ប្រើនបទថា **សាមិកស្ស វិមតឹ ឧប្បាទេតិ** សេចក្តីថា ភិក្ខុញុំាងសេចក្តីសង្ស័យឲ្យកើតឡើងដល់ម្ចាស់សួន ព្រោះភាពជាអ្នកឈ្លាសក្នុងការវិនិច្ឆ័យ ឬព្រោះអាស្រ័យបុគ្គលដែលមានកម្លាំងជាដើម ។ សេចក្តីនេះដូចម្តេច គឺសេចក្តីពិត ម្ចាស់ទ្រព្យឃើញភិក្ខុនោះ ជាអ្នកខ្នះខ្នែងក្នុងការវិនិច្ឆ័យយ៉ាងនោះ ទើបគិតថា អញនឹងអាចធ្វើសួននេះឲ្យត្រឡប់មកជារបស់អញ

ឬអត់ហ្ន៎ កាលសេចក្តីសង្ស័យកើតឡើងដល់ម្ចាស់ទ្រព្យនោះ រមែងឈ្មោះថា ត្រូវភិក្ខុនោះឲ្យកើតឡើងហើយ ដោយអាការដូចពោលមកនេះ ព្រោះហេតុនោះ ភិក្ខុនោះ រមែងត្រូវអាបត្តិថុល្លច្ច័យ ។

ពីរបទថា **ធុរំ និក្ខិបតិ** សេចក្តីថា កាលណាម្ចាស់ទ្រព្យដាក់ធុរៈហើយ ដោយគិតថា ភិក្ខុនេះ គ្រោតគ្រាតពន់ពេក គប្បីធ្វើនូវអន្តរាយដល់ជីវិត និងព្រហ្មចរិយៈរបស់អញ ឥឡូវនេះ អញមិនត្រូវការសួននេះទេ កាលនោះ ភិក្ខុអ្នកបំពាន រមែងត្រូវបារាជិក សូម្បីខ្លួនជាអ្នកធ្វើការដាក់ធុរៈខ្លួនឯងក៏ដោយ ។ តែបើម្ចាស់ទ្រព្យដាក់ធុរៈហើយក៏ដោយ ភិក្ខុបំពានមិនទាន់ដាក់ធុរៈនៅមានសេចក្តីឧស្សាហ៍ ដើម្បីនឹងឲ្យទៅម្ចាស់វិញ ដោយគិតថា អញជិះជាន់ម្ចាស់សួននេះឲ្យធ្ងន់ហើយ ធ្វើឲ្យចុះចាញ់នូវអំណាចរបស់អញ រួចតាំងម្ចាស់សួននោះទុកក្នុងភាពជាអ្នកបម្រើ ហើយទើបសង ដូច្នេះ នៅរក្សានៅឡើយ ។ បើភិក្ខុអ្នកបំពាន កាលជណ្តើមយកហើយ ក៏ដាក់ធុរៈ ដោយគិតថា ឥឡូវនេះ អញនឹងមិនសងសួននោះដល់ម្ចាស់ទ្រព្យនេះឡើយ ចំណែកម្ចាស់ទ្រព្យមិនដាក់ធុរៈ នៅស្វែងរកបក្ខពួក ទាំងរង់ចាំពេលវេលា ដោយគិតថា អញបានលជ្ជីបរិស័ទជាមុនសិន ខាងក្រោយទើបនឹងដឹង ដូច្នេះ ញុំាងភាពជាអ្នកមានការឧស្សាហ៍ ដើម្បីឲ្យសងវិញ ក៏នៅរក្សានោះឯង តែកាលណាភិក្ខុអ្នកបំពាននោះដាក់ធុរៈ ដោយគិតថា អញនឹងមិនសង ទាំងម្ចាស់ទ្រព្យក៏ដាក់ធុរៈ អញនឹងបានសំណាង ទាំងពីរចំណែកដាក់ធុរៈ ដូចពោលមកនេះ កាលនោះ ភិក្ខុអ្នកបំពាន ត្រូវអាបត្តិបារាជិក ។ តែបើភិក្ខុកាលបំពានហើយ ក៏ធ្វើការវិនិច្ឆ័យខ្លួនឯង បើវិនិច្ឆ័យមិនទាន់សម្រេច ទាំង

ម្ចាស់ទ្រព្យមិនទាន់បានដាក់ធុរៈ នៅដឹងនៅឡើយថា ខ្ញុំមិនមែនជាម្ចាស់ទ្រព្យឡើយ បានកាន់យកផ្កា ឬផ្លែខ្លះ អំពីសួននោះ វិនយធរគប្បីកាត់អាបត្តិតាមតម្លៃភណ្ឌៈ ។

បទថា **ធម្មំ ចរន្តោ** បានដល់ ភិក្ខុអ្នកបំពានណា ធ្វើការកាត់សេចក្ដីក្នុងពួកភិក្ខុ ឬក្នុងរាជត្រកូល ។

ពីរបទថា **សាមិកំ បរាជេតិ** សេចក្ដីថា ភិក្ខុអ្នកបំពាននោះ ឲ្យសំណូកដល់ពួកចៅក្រម ហើយអាងសាក្សីកោង រមែងឈ្នះម្ចាស់សួន ។

ពីរបទថា **អាបត្តិ បារាជិកស្ស** សេចក្ដីថា មិនមែនត្រូវអាបត្តិបារាជិកចំពោះភិក្ខុដែលប្រកបក្ដីនោះតែប៉ុណ្ណោះ ពួកភិក្ខុដែលជាចៅក្រមកោងក្ដី ដែលជាសាក្សីកោងក្ដី ដែលក្លែងដំណើរក្ដី ឲ្យសម្រេចប្រយោជន៍ដល់ភិក្ខុអ្នកបំពាននោះ ក៏ត្រូវអាបត្តិបារាជិកទាំងអស់ ។ ឯក្នុងពាក្យថា **ធម្មំ ចរន្តោ** នេះ គប្បីជ្រាបការបរាជ័យដោយអំណាចម្ចាស់ទ្រព្យដាក់ធុរៈប៉ុណ្ណោះ ពិតហើយ ម្ចាស់ទ្រព្យមិនទាន់ដាក់ធុរៈ ចាត់ថា នៅមិនទាន់ចាលចាញ់នោះឯង ។

ច្រើនបទថា **ធម្មំ ចរន្តោ បរជ្ជតិ** សេចក្ដីថា បើខ្លួនឯងដល់នូវការបរាជ័យ ព្រោះពាក្យចៅក្រមដែលប្រព្រឹត្តទៅដោយធម៌ដោយវិន័យ ដោយសត្ថុសាសនា ។ ដោយប្រការយ៉ាងនេះ ភិក្ខុអ្នកបំពាននោះ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះការចោទបំពានម្ចាស់ទ្រព្យ ដោយការពោលកុហកជាបច្ច័យដូច្នេះឯង ។

ទ្រព្យដែលស្ថិតនៅក្នុងអារាម ចប់

# ទ្រព្យដែលស្ថិតនៅក្នុងវិហារ

[ ១០០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យ ដែលឋិតនៅក្នុងវិហារតទៅថា ទ្រព្យដែលរក្សាទុកដោយឋាន ៤ មានន័យដូចពោលហើយនោះឯង ។ ឯវិនិច្ឆ័យក្នុងការបំពានយកទ្រព្យ ដែលស្ថិតនៅក្នុងវិហារនេះ គប្បីជ្រាបដូច្នេះថា កាលភិក្ខុបំពានយកវិហារក្ដី បរិវេណក្ដី អាវាសក្ដី ទាំងធំ ទាំងតូច ដែលគេប្រគេនពួកភិក្ខុ ឧទ្ទិសដល់សង្ឃ មកអំពីទិសទាំង ៤ បំពានមិនឡើង ទាំងមិនអាចដណ្ដើមយកបាន ។ ព្រោះហេតុអ្វី ព្រោះមិនមានការដាក់ធុរៈនៃភិក្ខុទាំងពួង ។ ពិតហើយ ភិក្ខុទាំងអស់ដែលនៅក្នុងទិសទាំង ៤ មិនអាចធ្វើការដាក់ធុរៈក្នុងវិហារជាដើម ដែលជារបស់សង្ឃនេះបានឡើយ ។ តែភិក្ខុអ្នកបំពានយកទ្រព្យរបស់គណៈ ដែលមានគណៈអ្នកពោលទីឃនិកាយជាដើម ឬរបស់ឧបាសកខ្លះ រមែងអាចធ្វើគណៈ និងបុគ្គលខ្លះទាំងនោះឲ្យដាក់ធុរៈបាន ព្រោះដូច្នោះ ក្នុងទ្រព្យរបស់គណៈ និងបុគ្គលខ្លះនោះ គប្បីជ្រាបវិនិច្ឆ័យដោយន័យដូចពោលទុកហើយ ក្នុងសួននោះឯង ។

ទ្រព្យដែលស្ថិតនៅក្នុងវិហារ ចប់

# ទ្រព្យដែលស្ថិតនៅក្នុងស្រែ

[ ១០១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកណ្ឌៈដែលតាំងនៅក្នុងស្រែ តទៅថា ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងស្រែមុន ទើបត្រាស់ថា **ខេត្តំ ឆាម យត្ថ បុព្វណ្ណំ វា អបរណ្ណំ វា ជាយតិ ។** បណ្តាបុព្វណ្ណជាតិជាដើមនោះ ស្រូវ ៧ ប្រការ មានស្រូវសាលីជាដើម ឈ្មោះថា បុព្វណ្ណជាតិ ។ ពូជទាំង-ឡាយ មានសណ្តែកបាយ និងសណ្តែករាជមាសជាដើម ឈ្មោះថា អប-រណ្ណជាតិ ។ ចម្ការអំពៅជាដើម ក៏សង្រ្គោះចូលក្នុងបទថា អបរណ្ណជាតិនេះ ដូចគ្នា ។ កណ្ឌៈដែលគេរក្សាទុកដោយឋាន ៤ ក្នុងទ្រព្យដែលតាំងនៅក្នុង ស្រែនេះ ក៏មានន័យដូចពោលហើយនោះឯង ។

ចំណែកក្នុងកណ្ឌៈ ដែលកើតឡើងក្នុងស្រែនោះ មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុដណ្តើមយកធញ្ញជាតិ មានកួរស្រូវសាលីជាដើមក្តី ប្រើដៃនោះឯង ក្តិចយកក្តី ប្រើកណ្តៀវប្រូតយកត្រង់កួរនីមួយៗ ក្តី ឬដកម្តងច្រើនៗ ក្តី វត្ថុ នៃបារាជិកនឹងគ្រប់ក្នុងគ្រាប់ ក្នុងកួរ ក្នុងក្តាប់ ឬក្នុងផ្លែ មានសណ្តែកបាយ និងសណ្តែករាជមាសជាដើមណាមួយ កាលគ្រប់ជាដើមនោះៗ គ្រាន់តែ លោកឲ្យដាច់ចាកទង ត្រូវអាបត្តិបារាជិក ។ ចំណែកដើមក្តី សរសៃក្តី សម្បកក្តី ដែលមិនទាន់ដាច់ មានប្រមាណតិចតួច ក៏នៅរក្សានៅឡើយ ជញ្ជាំងស្រូវសាលីជារបស់វែង ដើមរបស់កួរស្រូវសាលី មិនទាន់ដាច់ចេញ អំពីជញ្ជាំង ខាងក្នុងត្រឹមណា នៅរក្សាដរាបនោះ កាលផ្ទៃខាងក្រោមរបស់ ដើមដាច់ផុតអំពីជញ្ជាំងស្រូវហើយ សូម្បីត្រឹមមួយចម្រៀកសក់ ព្រះវិនយធរ គប្បីកាត់អាបត្តិ ដោយអំណាចទ្រព្យនោះ ។ បើភិក្ខុប្រើកណ្តៀវប្រូតយក

កាលដើមស្រូវនៅក្នុងដៃ សូម្បីដាច់ហើយត្រង់កណ្ដាល បើក្ដួរទាំងឡាយនៅប្រទាក់គ្នានៅឡើយ នៅរក្សានៅដូចមុន តែកាលបើលោកជម្រះឲ្យដាច់លើកឡើង សូម្បីត្រឹមមួយចម្រៀកសក់ បើវត្ថុបារាជិកគ្រប់ ត្រូវអាបត្តិបារាជិក ។ កាលភិក្ខុកាន់យកស្រូវសាលីដែលម្ចាស់ប្រូតទុក ព្រមទាំងកណ្ដាប់ក្ដី ធ្វើឲ្យជ្រុះចំបើងក្ដី វត្ថុបារាជិកគ្រប់ដោយក្ដួរណា កាលក្ដួរនោះដែលលោកកាន់យកហើយ ត្រូវអាបត្តិបារាជិក ។ បើលោកកំណត់ទុកថា អញនឹងបោកស្រូវសាលីនេះ ហើយអុំយកតែគ្រាប់ស្រូវប៉ុណ្ណោះ ដូច្នេះ នៅរក្សានៅឡើយ កាលលោកឲ្យឃ្លាតចាកឋាន ព្រោះការបោក និងអុំ មិនទាន់ត្រូវអាបត្តិបារាជិកឡើយ ក្រោយមក កាលលោកគ្រាន់តែកើបដាក់ភាជនៈ ត្រូវអាបត្តិបារាជិក ។ ចំណែកការបំពានយកក្នុងកណ្ឌៈដែលតាំងនៅក្នុងស្រែនេះ មានន័យដូចពោលហើយនោះឯង ។

ក្នុងការបន្និតបង្គោលជាដើម មានវិនិច្ឆ័យដូច្នេះថា ដែលឈ្មោះថាផែនដី ជារបស់កាត់ថ្លៃមិនបាន ព្រោះហេតុនោះ បើភិក្ខុធ្វើប្រទេសនៃផែនដីសូម្បីត្រឹមមួយចម្រៀកសក់ឲ្យជារបស់ខ្លួន ដោយបង្គោលមួយប៉ុណ្ណោះ ពួកម្ចាស់ទ្រព្យឃើញក្ដី មិនឃើញក្ដី ឯបង្គោលនោះ ទោះចារឹកឈ្មោះក្ដី មិនចារឹកក្ដី លុះភិក្ខុរំកិលស្រេច ក៏ត្រូវអាបត្តិបារាជិកដល់លោកផង ដល់ភិក្ខុទាំងពួង ដែលមានឆន្ទៈរួមជាមួយលោកផង តែបើស្រែនោះជារបស់ដែលគប្បីបន្និតយកបានដោយបង្គោល ២ កាលបន្និតបង្គោលទី ១ ត្រូវអាបត្តិថុល្លច្ច័យ បង្គោលទី ២ ត្រូវអាបត្តិបារាជិក ។ បើជារបស់ដែលគប្បី

បន្ថិតយកបានដោយបង្គោល ៣ បង្គោលទី ១ ត្រូវអាបត្តិទុក្កដ បង្គោលទី ២ ត្រូវអាបត្តិថុល្លច្ច័យ បង្គោលទី ៣ ត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងបង្គោលច្រើនក៏គប្បីជ្រាបជាអាបត្តិទុក្កដ ក្នុងបង្គោលខាងដើមៗ វៀរបង្គោល ២ ខាងចុង ត្រូវអាបត្តិថុល្លច្ច័យ ដោយបង្គោល ១ និងបង្គោលមួយទៀតខាងចុងបំផុតត្រូវអាបត្តិបារាជិក ដោយប្រការដូច្នេះ ។ ឯបារាជិកនោះឯងរមែងមានដោយការដាក់ធុរៈរបស់ម្ចាស់ទ្រព្យ ។ ក្នុងការបន្ថិតទាំងពួង មានការបន្ថិតដោយខ្សែជាដើមក៏យ៉ាងនេះ ។

បទថា **វត្ថុំ វា** សេចក្តីថា ភិក្ខុមានបំណងនឹងឲ្យអ្នកដទៃយល់ថា ស្រែនេះជារបស់អញ សន្ទឹងខ្សែក្តី ដោតឈើប្រត់ចុះក្តី ត្រូវអាបត្តិទុក្កដ បើភិក្ខុធ្វើទុកក្នុងចិត្តថា ឥឡូវនេះ អញនឹងធ្វើឲ្យជារបស់អញ ដោយប្រយោគ ២ ក្នុងប្រយោគទី ១ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងប្រយោគទី ២ ត្រូវអាបត្តិបារាជិក ។

បទថា **វតិំ វា** សេចក្តីថា ភិក្ខុមានបំណងនឹងធ្វើស្រែរបស់អ្នកដទៃឲ្យជារបស់ខ្លួន ដោយអំណាចនៃការព័ទ្ធរបង ទើបបោះបង្គោលចុះ ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ កាលប្រយោគ ១ មិនទាន់សម្រេចត្រូវអាបត្តិថុល្ល-ច្ច័យ កាលប្រយោគនោះសម្រេចហើយ ត្រូវអាបត្តិបារាជិក ។ បើលោកមិនអាចធ្វើដោយប្រយោគមានប្រមាណប៉ុណ្ណេះ តែអាចធ្វើឲ្យជារបស់ខ្លួនបានដោយធ្វើរបងទុកដោយមែកឈើប៉ុណ្ណោះ សូម្បីក្នុងការដាក់មែកឈើចុះ ក៏មានន័យដូចគ្នា ។ ភិក្ខុអាចព័ទ្ធដោយវត្ថុឯណាមួយ ធ្វើឲ្យជារបស់ខ្លួនបានដោយប្រការយ៉ាងនេះ ក្នុងវត្ថុនោះៗ គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដ ដោយ

ប្រយោគដើមៗ ត្រូវអាបត្តិថុល្លច្ច័យដោយប្រយោគ ១ នៃប្រយោគ ២ ក្នុងទីបំផុត ត្រូវអាបត្តិបារាជិក ដោយប្រយោគក្រោយគេ ។

បទថា **មរិយាទំ វា** សេចក្តីថា ភិក្ខុមានបំណងនឹងឲ្យអ្នកដទៃយល់ស្រែរបស់អ្នកដទៃថា នេះជាស្រែរបស់អញ ទើបបង្ខិតភ្លឺស្រែរបស់ខ្លួនចូលទៅ ដោយភ្លឺស្រែ ( របស់ ) ខ្លួនចូលក្នុងស្រែរបស់អ្នកដទៃ ឬយកអាចម៍ដីឬដីស្អិតជាដើមបន្ថែមធ្វើឲ្យទូលាយចេញទៅ ឬភ្លឺស្រែដែលមិនទាន់បានធ្វើឡើងត្រូវទុកដក្នុងប្រយោគដើមៗ ត្រូវថុល្លច្ច័យព្រោះប្រយោគមួយ បណ្តាប្រយោគ ២ ខាងចុង ត្រូវអាបត្តិបារាជិក ដោយប្រយោគក្រៅអំពីនេះដូច្នេះ ។

ទ្រព្យស្ថិតនៅក្នុងស្រែ ចប់

# ទ្រព្យដែលស្ថិតនៅក្នុងទីដី

[ ១០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យ ដែលនៅលើដីដូចតទៅថា ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងដីមុន ទើបត្រាស់ថា **វត្ថុ ឆាម អារាមវត្ថុ វិហារវត្ថុ** ដូច្នេះ ។ បណ្តាដីសួនជាដើមនោះ ទីដែលគេមិនបានដាំពូជ ឬដើមឈើដែលគួរដាំឡើយ កាប់ឆ្ការដីតែម្យ៉ាង ឬព័ទ្ធដោយរបង ៣ ប្រភេទៗណាមួយ ដើម្បីជាប្រយោជន៍ដល់សួនផ្កាជាដើម ឈ្មោះថា អារាមវត្ថុ ។ ទីកន្លែងដែលគេរៀបចំដើម្បីប្រយោជន៍ដល់បរិវេណវិហារ និងអាវាសទីមួយៗដោយន័យនោះៗ ឯង ឈ្មោះថា វិហារវត្ថុ ។ ទីកន្លែងណាក្នុងកាលមុន ជាអារាម និងជាវិហារ ក្រោយមក គេបោះបង់ទៅ តាំងនៅត្រឹមតែដី មិនសម្រេចកិច្ចនៃអារាម និងវិហារ ទីកន្លែងនោះ ក៏សង្រ្គោះដោយការសង្រ្គោះចូលក្នុងអារាមវត្ថុ និងវិហារវត្ថុដូចគ្នា ។ ចំណែកវិនិច្ឆ័យក្នុងទ្រព្យដែលនៅលើដីសួន និងដីវិហារនេះ ដូចគ្នានឹងទីដែលពោលហើយក្នុងស្រែនោះឯង ។

ទ្រព្យដែលស្ថិតនៅក្នុងទីដី ចប់

[ ១០៣ ] ពាក្យដែលគួរពោលក្នុងកណ្ឌៈ ដែលស្ថិតនៅក្នុងស្រុក ខ្ញុំបានពោលហើយខាងដើម ។

# ទ្រព្យដែលស្ថិតនៅក្នុងព្រៃ

[ ១០៤ ] វិនិច្ឆ័យទ្រព្យដែលតាំងនៅក្នុងព្រៃ គប្បីជ្រាបដូច្នេះថា ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងព្រៃមុន ទើបត្រាស់ថា **អរញ្ញំ នាម យំ មនុស្សានំ បរិគ្គហិតំ ហោតិ តំ អរញ្ញំ** ដូច្នេះ ។ ក្នុងពាក្យថា **អរញ្ញំ** នោះ មានវិនិច្ឆ័យដូច្នេះថា ដែលបានឈ្មោះថា ព្រៃ ដែលពួកមនុស្សហួងហែងក៏មាន មិនហួងហែងក៏មាន ក្នុងអធិការនេះ លោកបំណងយកព្រៃដែលគេហួងហែង មានការរក្សាជាដែនដែលពួកមនុស្សមិនអាចកាន់យកឈើឬវល្លិ៍ជាដើម ដោយវៀរចាកតម្លៃ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ព្រៃជាទីដែលពួកមនុស្សហួងហែង ហើយត្រាស់ទៀតថា ឈ្មោះថា ព្រៃ ដូច្នេះ ។

ដោយពាក្យថា ព្រៃនោះ លោកសម្តែងអត្ថនេះទុកដូច្នេះថា ភាពជាទីហួងហែង មិនរាប់ថា ជាលក្ខណៈរបស់ព្រៃឡើយ តែទីដែលជាព្រៃ ដោយលក្ខណៈរបស់ខ្លួន ហើយពួកមនុស្សហួងហែង ឈ្មោះថា ព្រៃក្នុងអត្ថនេះ ។ វិនិច្ឆ័យក្នុងទ្រព្យដែលតាំងនៅក្នុងព្រៃនោះ ក៏ដូចគ្នានឹងការពោលហើយ ក្នុងទ្រព្យដែលតាំងនៅក្នុងសួនជាដើម ។

បណ្តាដើមឈើដែលកើតក្នុងព្រៃនោះ បើដើមឈើដែលមានតម្លៃច្រើនត្រឹមតែមួយដើមក្នុងព្រៃនេះ គ្រាន់តែភិក្ខុកាត់ដាច់ហើយ ក៏ត្រូវអាបត្តិបារាជិកម្យ៉ាងទៀត ក្នុងបទថា **លតំ វា** នេះ ផ្តៅក្តី វល្លិ៍ក្តី ឈ្មោះថា វល្លិ៍ទាំងអស់ ។ បណ្តាផ្តៅ និងវល្លិ៍ទាំងនោះ ផ្តៅ ឬវល្លិ៍ណា ជារបស់ដែលវែងវារឡើងទៅ ឬរុំដើមឈើធំ និងគុម្ពឫស្សី វល្លិ៍នោះ ភិក្ខុកាត់គល់ហើយក្តី

ឬកាត់ត្រង់ចុងក្តី ក៏មិនញុំាងអវហារឲ្យកើតឡើងបាន ។ បើវល្លិ៍មិនរុំ ( ដើមឈើ ) កាលភិក្ខុកាត់ទាំងចុង ទាំងគល់ កាលនោះ រមែងញុំាង អវហារឲ្យកើតបាន ។ ចំណែកដែលរុំព័ទ្ធ ( ដើមឈើ ) បើភិក្ខុពន្លាទាញចេញផុតអំពីដើមឈើ រមែងញុំាងអវហារឲ្យកើតឡើងបាន ។ ស្មៅក្តី ស្លឹកឈើក្តីទាំងអស់នេះ លោកសង្គ្រោះចូលដោយសព្ទថា ស្មៅ ក្នុងបទថា **តិណំ វា** នេះ ភិក្ខុកាន់យកស្មៅនោះដែលអ្នកដទៃកាត់ទុកដើម្បីប្រយោជន៍ ដល់គ្រឿងប្រក់ផ្ទះជាដើម ឬដែលខ្លួនឯងកាត់យក ព្រះវិនយធរគប្បីកាត់អាបត្តិតាមតម្លៃភណ្ឌៈ និងមិនមែនកាត់អាបត្តិចំពោះតែកាន់យកស្មៅ និងស្លឹកឈើតែម្យ៉ាងប៉ុណ្ណោះឡើយ កាលកាន់យកសម្បក និងក្រមរជាដើមដទៃ ប្រភេទណាមួយក៏គប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ ។ កាលភិក្ខុកាន់យកវត្ថុ មានសម្បកឈើជាដើម ដែលពួកម្ចាស់ទ្រព្យនៅមានសេចក្តីអាល័យ គប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ សូម្បីដើមឈើដែលគេកាប់ទុកចោលយូរហើយ ក៏មិនគួរកាន់យក ។ ចំណែកដើមឈើណា ដែលគេកាត់ត្រង់ចុង និងគល់ហើយ មែករបស់ដើមឈើនោះពុកផុយខ្លះ ក្រមរទាំងឡាយរង្គោះរង្គើខ្លះ កាលកាន់យកដោយគិតថា ដើមឈើនេះ ពួកម្ចាស់បោះបង់ចោលហើយ ដូច្នេះ គួរ ។ ដើមឈើដែលដាក់គ្រឿងចំណាំទុក កាលណា សញ្ញាត្រូវក្រមរដុះជិត កាលនោះនឹងកាន់យក គួរ ។ មនុស្សទាំងឡាយកាត់ដើមឈើ ដើម្បីប្រយោជន៍ដល់ផ្ទះជាដើម កាលណា គេធ្វើផ្ទះជាដើមនោះស្រេចហើយ ហើយចូលនៅអាស្រ័យ កាលនោះ ឈើទាំងឡាយរមែងវិនាសទៅព្រោះភ្លៀង និងកម្តៅ

ថ្ងៃនៅក្នុងព្រៃ ។ ភិក្ខុប្រទះឃើញឈើដូច្នេះ កាន់យក ដោយគិតថា គេបោះបង់ចោលហើយដូច្នេះ គួរ ព្រោះហេតុអ្វី ព្រោះថា ឈើទាំងនោះ មេព្រៃមិនមានឥស្សរៈ ។ ឈើទាំងឡាយដែលជនពួកណា ឲ្យទេយ្យធម៌ដល់មេព្រៃហើយ ទើបកាត់ ជនទាំងនោះឯង ជាឥស្សរៈនៃឈើទាំងនោះ ហើយជនទាំងនោះក៏ចោលឈើទាំងនោះ ពួកគេជាអ្នកមិនមានអាល័យក្នុងឈើទាំងនោះ ព្រោះហេតុនោះ ភិក្ខុទោះកាន់យកឈើដូច្នោះ ក៏គួរ ។ ភិក្ខុអង្គណា ឲ្យទេយ្យធម៌ដល់មេព្រៃ មុននឹងចូលព្រៃ ឲ្យវេយ្យាវច្ចៈកាន់យកឈើទាំងឡាយបានតាមសេចក្តីត្រូវការ ការដែលភិក្ខុអង្គនោះ មិនទៅកាន់ទីរក្សា ( កន្លែងត្រួតពិនិត្យ ) របស់អ្នករក្សាព្រៃទាំងនោះ ទៅដោយផ្លូវតាមដែលពេញចិត្តក៏គួរ ។ បើកាលលោកចូលទៅ មិនបានឲ្យទេយ្យធម៌ ធ្វើទុកក្នុងចិត្តថាខណៈចេញមកនឹងឲ្យដូច្នេះ ឲ្យកាន់យកឈើទាំងឡាយ ហើយខណៈចេញមក ឲ្យទេយ្យធម៌ដែលគួរឲ្យដល់ពួកមេព្រៃទាំងនោះហើយ សមគួរពិត ។ បើលោកធ្វើការចងចិត្តទុក ហើយទើបទៅ កាលអ្នករក្សាព្រៃ មិនទារថាលោកម្ចាស់ ចូរឲ្យ លោកឆ្លើយថា អាត្មានឹងឲ្យ កាលគេទារទៀតថា ចូរឲ្យគួរឲ្យនោះឯង បើមានបុគ្គលខ្លះឲ្យទ្រព្យរបស់ខ្លួន ហើយនិយាយ ( ជាមួយមេព្រៃ ) ថា ពួកលោកចូរឲ្យភិក្ខុទៅចុះ ដូច្នេះ ភិក្ខុទៅតាមការធានាដែលខ្លួនបានហើយនោះឯង គួរ ។ តែបើបុគ្គលមានជាតិជាឥស្សរៈ មិនបានឲ្យទ្រព្យឡើយ ហាមថា ពួកលោកកុំទទួលតម្លៃបង់ពន្ធ សម្រាប់ពួកភិក្ខុ ដូច្នេះ តែពួកមេព្រៃនិយាយថា បើពួកយើងមិនទទួលយកទ្រព្យពួកភិក្ខុ និងតាបស

ទេ នឹងបានទ្រព្យអំពីណា ឲ្យមកចុះ លោកម្ចាស់ ដូច្នេះ ភិក្ខុគួរឲ្យដូចគ្នា ។ ចំណែកភិក្ខុអង្គណា កាលអ្នករក្សាព្រៃដេកលក់ ឬរវល់ខ្វល់ខ្វាយក្នុងការលេង ឬចៀសចេញទៅក្នុងទីណាមួយ មកដល់ហើយ ស្រែកហៅថា អ្នករក្សាព្រៃនៅទីណា ដូច្នេះ កាលមិនជួប ទើបទៅ ភិក្ខុអង្គនោះ ជាកណ្ឌ-ទេយ្យ ។ ចំណែកភិក្ខុអង្គណា កាលទៅដល់ទីកន្លែងរក្សាហើយ តែជាប់ដាក់ចិត្តក្នុងកម្មដ្ឋានជាដើម ឬបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃ ជ្រុលធ្វងហួសទៅព្រោះរឭកមិនបាន ភិក្ខុអង្គនោះជាកណ្ឌទេយ្យដូចគ្នា ។ សូម្បីភិក្ខុអង្គណាទៅដល់ទីកន្លែងនោះហើយ មានចោរ ដំរី ពាឡម្រឹគ ឬភ្លៀងប្រាកដឡើង កាលភិក្ខុអង្គនោះប្រញាប់ប្រញាល់កន្លងហួសទីនោះទៅ ព្រោះនឹងផុតចាកឧទ្ទវនោះ នៅរក្សានៅឡើយ តែក៏ជាកណ្ឌទេយ្យ ។ ដែលបានឈ្មោះថា ទីកន្លែងរក្សាក្នុងព្រៃនេះ ជាភារៈធ្ងន់ពេក សូម្បីទីកន្លែង គយ ( ក៏ដូចគ្នា ) ។ ពិតហើយ ភិក្ខុកាលមិនឈានជើងចូលទៅកាន់ដែនគយ លបចៀសចេញទៅ នឹងត្រូវត្រឹមតែទុក្កដប៉ុណ្ណោះ តែបើលោកលបចៀសចេញអំពីទីរក្សាព្រៃនេះទៅ ដោយថេយ្យចិត្ត ទោះទៅដោយផ្លូវអាកាសក៏ដោយ ត្រូវអាបត្តិបារាជិកដោយពិត ព្រោះហេតុនោះ ភិក្ខុមិនគួរជាអ្នកប្រមាទក្នុងស្ថានទីរក្សាព្រៃ ដូច្នេះឯង ។

ទ្រព្យដែលស្ថិតនៅក្នុងព្រៃ ចប់

# ពោលអំពីទឹក

[ ១០៥ ] អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងទឹកដូច្នេះ បទថា **ភាជនគតំ** បានដល់ ទឹកដែលគេដាក់ក្នុងភាជនៈទាំងឡាយ មានថ្លាងទឹកជាដើម ក្នុងវេលាដែលរកទឹកបានលំបាក ។ កាលភិក្ខុផ្អៀងភាជនៈដែលគេដាក់ទឹកនោះក្តី ធ្វើឲ្យជាប្រហោងធ្លុះក្តី ស៊កភាជនៈរបស់ខ្លួនចូលទៅ ទទួលយកទឹកដែលមាននៅ ក្នុងភាជនៈរបស់ជនទាំងនោះ និងក្នុងស្រះបោក្ខរណី ឬអណ្តូង គប្បីជ្រាបវិនិច្ឆ័យដោយន័យដូចពោលទុកក្នុងសប្បិ និង ប្រេងនោះឯង ។ ចំណែកក្នុងការបោះភ្លឺស្រែ មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុបោះភ្លឺស្រែដែលមានភួតគាមកើតឡើងក្នុងភ្លឺស្រែនោះ ត្រូវអាបត្តិទុក្កដ ព្រោះជាប្រយោគនៃអទិន្នាទាន ។ ឯទុក្កដនោះ រមែងត្រូវគ្រប់ៗ គ្រាដែលជីកបោះ ។ ភិក្ខុឈរខាងក្នុង ហើយបែរមុខទៅខាងក្រៅបោះ វិនយធរគប្បីដាក់អាបត្តិ ដោយចំណែកខាងក្រៅ កាលឈរខាងក្រៅ ហើយបែរមុខចូលទៅខាងក្នុងបោះ គប្បីកាត់អាបត្តិដោយចំណែកខាងក្នុង ។ កាលលោកបោះបែរមុខទៅទាំងខាងក្នុង និងខាងក្រៅ គឺឈរនៅត្រង់កណ្តាលទម្លាយភ្លឺស្រែនោះ គប្បីកាត់អាបត្តិចំណែកត្រង់កណ្តាល ។

ភិក្ខុធ្វើភ្លឺឲ្យធ្លុះធ្លាយហើយ ទើបស្រែកហៅហ្វូងគោក្តី ឲ្យក្មេងអ្នកស្រុកស្រែកហៅមកក្តី ហ្វូងគោទាំងនោះជាន់ភ្លឺស្រែដាច់ដោយក្រចក ភ្លឺស្រែ ឈ្មោះថា ភិក្ខុអង្គនោះ ទម្លាយហើយ ។ ភិក្ខុធ្វើភ្លឺស្រែឲ្យធ្លុះធ្លាយ ហើយកៀងគោចូលទៅក្នុងទឹកក្តី ប្រើពួកក្មេងអ្នកស្រុកឲ្យកៀងចូលទៅក្តី រលកដែលគោទាំងនោះ ធ្វើឲ្យកើតឡើង ទម្លាយភ្លឺស្រែទៅ ។ ម្យ៉ាងទៀត ភិក្ខុនិយាយ

បបួលពួកក្មេងអ្នកស្រុកថា ចូរនាំគ្នាលេងទឹកចុះ ឬសម្លុតពួកក្មេងដែលកំពុងលេងឲ្យភ័យ រលកដែលក្មេងទាំងនោះធ្វើឲ្យតាំងឡើង ទម្លាយភ្លឺស្រែ ភិក្ខុកាត់ដើមឈើដែលនៅក្នុងទឹកក្តី ប្រើឲ្យអ្នកដទៃកាត់ក្តី រលកដែលដើមឈើរលំចុះនោះ តាំងឡើង ទម្លាយភ្លឺស្រែទៅ ឈ្មោះថា ភិក្ខុអង្គនោះឯង ជាអ្នកទម្លាយភ្លឺស្រែ ។ ភិក្ខុធ្វើភ្លឺឲ្យធ្លុះធ្លាយ ហើយបិទទឹកដែលគេបង្ហូរចេញទៅ ឬបិទប្រឡាយសម្រាប់បង្ហូរទឹកចេញអំពីស្រះដើម្បីរក្សាស្រះក្តី ធ្វើភ្លឺ ឬសម្អាតប្រឡាយឲ្យត្រង់ដោយអាការដែលធ្វើទឹកឲ្យហូរទៅកាន់ទីដទៃ ទោះហូរចូលទៅក្នុងស្រះនេះក្តី ឬក៏ធ្លាយស្រះរបស់ខ្លួនដែលនៅខាងលើស្រះនៃអ្នកដទៃនោះក្តី ទឹកដែលជោរជន់ហៀរឡើង ហូរក្លួចយកភ្លឺទៅ ភ្លឺ ឈ្មោះថា ភិក្ខុនោះឯង ជាអ្នកទម្លាយហើយក្នុងទីទាំងពួង ព្រះវិនយធរ គប្បីកាត់ដោយអវហារ តាមសមគួរដល់តម្លៃទឹកដែលហូរចេញទៅ កាលភិក្ខុបើកប្រឡាយសម្រាប់បង្ហូរទឹកចេញទៅ ក៏មានន័យនេះដូចគ្នា ។

ម្យ៉ាងទៀត បើភិក្ខុនោះធ្វើទំនប់ឲ្យទ្រុឌទ្រោមហើយ ហ្វូងគោដែលដើរមកតាមធម្មតារបស់ខ្លួននោះឯង ឬពួកក្មេងអ្នកស្រុកដែល ( ភិក្ខុ ) មិនបានបង្គាប់ ជួយគ្នាដេញឲ្យឡើងទៅ យកក្រចកជើងទម្លាយទំនប់ក្តី ហ្វូងគោដែលពួកក្មេងអ្នកស្រុក ដែលភិក្ខុមិនបានបង្គាប់ ដេញកៀងឲ្យចុះទៅក្នុងទឹកតាមធម្មតារបស់ខ្លួនឯង ធ្វើឲ្យរលកទឹកកើតឡើងក្តី ពួកក្មេងអ្នកស្រុកនាំគ្នាចូលទៅលេងទឹកដោយខ្លួនឯង ធ្វើឲ្យរលកតាំងឡើងក្តី ដើមឈើ ( ដែលដុះនៅ ) ខាងក្នុងទឹក ដែលត្រូវជនពួកដទៃកាត់ដាច់រលំ ហើយធ្វើរលក

ឲ្យតាំងឡើង លោកនោះៗ ទម្លាយទំនប់ទៅក្តី បើកិក្ខុធ្វើទំនប់ឲ្យធ្លុះធ្លាយ បិទកន្លែងដែលគេបង្ហូរទឹកចេញទៅ ឬប្រឡាយសម្រាប់បង្ហូរទឹកនៃស្រះរីងស្ងួតលើកក្ដី ឬចាត់ចែងប្រឡាយដែលស្ងួត ឲ្យត្រង់ផ្លូវទឹកហូរទៅទីដទៃ ក្រោយមក ក្នុងកាលភ្លៀងធ្លាក់ ទឹកហូរព្រោះទម្លាយទំនប់ទៅក្នុងទីគ្រប់ៗ កន្លែង ជាភណ្ឌទេយ្យ ។ ចំណែកកិក្ខុណា ទម្លាយមាត់បឹងស្ងួតក្នុងរដូវប្រាំង ឲ្យរាបរហូតដល់ផ្ទៃដី ក្រោយមក ក្នុងកាលភ្លៀងធ្លាក់ ទឹកដែលហូរមកម្ដងហើយម្ដងទៀត ក៏ហូរច្រងទៅ កិក្ខុនោះ ជាភណ្ឌទេយ្យ ។ សន្ទូងមានប្រមាណប៉ុន្មានណាដែលកើតឡើង ព្រោះមានទឹកនោះជាបច្ច័យ កិក្ខុកាលមិនសងតម្លៃជំនួស ស្មើតម្លៃមួយបាទ ឬច្រើនជាងមួយបាទអំពីសន្ទូង ( ដែលខូច ) នោះមិនរាប់ថា ជាសមណៈ ព្រោះម្ចាស់សន្ទូងជាក់ធុរៈ ។ តែពួកអ្នកស្រុកទាំងអស់ជាឥស្សរៈនៃទឹក ក្នុងបឹងទូទៅដល់ជនទាំងពួង ជនទាំងនោះ ស្ទូងសន្ទូងទាំងឡាយក្នុងបឹងនោះផង ។ ទឹកក៏ហូរចេញអំពីប្រឡាយធំនៃបឹងទៅក្នុងចំណោមស្រែទាំងឡាយ ដើម្បីចិញ្ចឹមសន្ទូង ។ ប្រឡាយធំនោះ ក៏ជាសាធារណៈដល់ជនទាំងពួង ក្នុងវេលាទឹកហូរជានិច្ច ។ ចំណែកពួកជនធ្វើប្រឡាយតូចៗ ចេញអំពីប្រឡាយធំនោះ ហើយបង្ហូរទឹកឲ្យចូលទៅក្នុងស្រែរៀងៗ ខ្លួន មិនអនុញ្ញាតឲ្យអ្នកដទៃកាន់យកទឹកក្នុងប្រឡាយតូចរបស់ខ្លួននោះឡើយ ក្នុងកាលមានទឹកតិចក្នុងរដូវប្រាំង ទើបបែងចែកទឹកដល់គ្នានិងគ្នាតាមវារៈ ។ បុគ្គលណា កាលដល់វារៈទឹក មិនបានទឹក សន្ទូងរបស់បុគ្គលនោះរមែងក្រៀមស្ងួតទៅ ព្រោះហេតុនោះ អ្នកដទៃមិនអាចទទួលយកទឹកក្នុងវារៈរបស់អ្នកដទៃបានឡើយ ។ បណ្ដាប្រឡាយតូចជាដើមនោះ កិក្ខុ

ណាបង្ហូរទឹកអំពីប្រឡាយតូច ឬអំពីស្រែរបស់ជនពួកដទៃ ឲ្យចូលទៅកាន់អណ្តូង ឬស្រែរបស់ខ្លួន ឬរបស់អ្នកដទៃដោយថេយ្យចិត្តក្តី ឲ្យទឹកហូរទៅកាន់មាត់ព្រៃក្តី ភិក្ខុនោះ ជាអវហារពិត ។ ចំណែកភិក្ខុណា គិតថា យូរៗអញនឹងមានទឹកត្រឹមតែម្តង ហើយសន្ទូងនេះក៏ក្រៀមស្វិត ទើបបើកផ្លូវរបស់ទឹកដែលកំពុងហូរចូលទៅក្នុងស្រែរបស់ជនដទៃ ហើយឲ្យហូរចូលទៅកាន់ស្រែរបស់ខ្លួន ភិក្ខុនោះជាអវហារដូចគ្នា ។ បើទឹកមិនទាន់ហូរចេញអំពីបឹង ឬមិនទាន់ហូរទៅដល់មាត់អណ្តូងរបស់អ្នកដទៃ ភិក្ខុធ្វើប្រឡាយស្ងួតនោះឯងក្នុងទីនោះៗ ដោយអាការដែលទឹកកំពុងហូរមក នឹងមិនហូរចូលទៅក្នុងស្រែរបស់ពួកជនដទៃ ហូរចូលទៅស្រែរបស់ខ្លួនប៉ុណ្ណោះ កាលទឹកមិនទាន់ហូរចេញមក តែភិក្ខុបានធ្វើទំនប់ទប់មុនហើយ ក៏ជាការដែលលោកធ្វើទុកល្អហើយ កាលទឹកហូរចេញមកហើយ បើភិក្ខុធ្វើទំនប់ទុក ជាភណ្ឌទេយ្យ ។ តែកាលភិក្ខុទៅកាន់ស្រះធំ ហើយបើកមុខប្រឡាយ សម្រាប់បង្ហូរទឹកចេញខ្លួនឯង ឲ្យទឹកហូរចូលទៅកាន់ស្រែរបស់ខ្លួន មិនជាអវហារ ព្រោះហេតុអ្វីព្រោះថា ខ្លួនអាស្រ័យស្រះធំ ទើបធ្វើស្រែ តែក្នុងកាល កុរុន្ទីអដ្ឋកថាជាដើមពោលថា ជាអវហារ ពាក្យដែលលោកពោលទុកនោះ រមែងមិនសមដោយលក្ខណៈនេះថា វត្ថុ កាល និងទេសជាដើម ព្រោះហេតុនោះ ពាក្យដែលលោកពោលទុកក្នុងមហាអដ្ឋកថានោះឯង ប្រពៃហើយ ដូច្នេះ ។

ពោលអំពីទឹក ចប់

# ពោលអំពីឈើស្ងួន

[១០៦] ឈើជម្រះធ្មេញ អ្នកសិក្សាគប្បីវិនិច្ឆ័យតាមន័យ ដែលវិនិច្ឆ័យទុកក្នុងកណ្ឌៈស្ថិតនៅក្នុងសួន ចំណែកសេចក្តីវិសេសក្នុងឈើជម្រះធ្មេញនេះ មានដូចតទៅថា វេយ្យាវច្ចករណា ជាបុគ្គលដែលសង្ឃបិញ្ចឹមទុកដោយតម្លៃឈ្នួល រមែងនាំឈើជម្រះធ្មេញមកប្រគេនរាល់ៗ ថ្ងៃ ឬតាមវារៈបក្ខ និងខែ វេយ្យាវច្ចករនោះ នាំឈើជម្រះធ្មេញនោះមក កាត់ហើយ មិនទាន់ប្រគេនភិក្ខុសង្ឃដរាបណា ឈើជម្រះធ្មេញនោះ ក៏នៅជារបស់វេយ្យាវច្ចករដែលនាំមកនោះដរាបនោះឯង ។ ព្រោះហេតុនោះ ភិក្ខុកាលកាន់យកឈើជម្រះធ្មេញនោះ ដោយថេយ្យចិត្ត គប្បីកាត់អាបត្តិតាមតម្លៃវត្ថុ ។ម្យ៉ាងទៀត មានរបស់គរុកណ្ឌដែលកើតឡើងក្នុងអារាមនោះ ភិក្ខុកាលកាន់យករបស់គរុកណ្ឌនោះ ដែលភិក្ខុសង្ឃរក្សាគ្រប់គ្រង ក៏គប្បីកាត់អាបត្តិតាមតម្លៃកណ្ឌៈ ។ ក្នុងឈើជម្រះធ្មេញដែលកាត់ហើយ និងមិនទាន់បានកាត់ ដែលជារបស់គណៈ បុគ្គល និងគ្រហស្ថក្តី ក្នុងកណ្ឌៈដែលកើតឡើងក្នុងអារាម និងឧទ្យានជាដើមរបស់គណៈ បុគ្គល និងគ្រហស្ថទាំងនោះក្តី ក៏មានន័យនេះដូចគ្នា ។ សាមណេរទាំងឡាយ កាលនាំឈើជម្រះធ្មេញមកប្រគេនដល់ភិក្ខុសង្ឃតាមវារៈ រមែងនាំមកប្រគេនដល់អាចារ្យ និងឧបជ្ឈាយ៍ ( របស់ខ្លួន ) ។ សាមណេរទាំងនោះ កាលកាត់ឈើជម្រះធ្មេញនោះហើយ មិនទាន់ប្រគេនសង្ឃដរាបណា ឈើជម្រះធ្មេញទាំងអស់នោះ ក៏នៅជារបស់សាមណេរនោះឯងដរាបនោះ ព្រោះហេតុនោះ ភិក្ខុកាលកាន់យកឈើជម្រះធ្មេញនោះដោយថេយ្យចិត្ត ក៏គប្បីកាត់អាបត្តិតាមតម្លៃកណ្ឌៈ ។ តែកាលណា សាមណេរ

ទាំងនោះកាត់ឈើជម្រះធ្មេញហើយ បានប្រគេនសង្ឃហើយ តែនៅរក្សាទុកក្នុងរោងឈើជម្រះធ្មេញ ដោយគិតក្នុងចិត្តថា សូមភិក្ខុសង្ឃប្រើប្រាស់តាមសប្បាយ ដូច្នេះ ។ តាំងអំពីកាលនោះទៅ មិនជាអវហារ តែក៏គួរជ្រាបទំនៀម ។ ពិតហើយ ភិក្ខុអង្គណាចូលទៅក្នុងចំណោមសង្ឃរាល់ថ្ងៃ ភិក្ខុអង្គនោះគួរកាន់យកឈើជម្រះធ្មេញបាន ត្រឹមមួយថ្ងៃ មួយកំណាត់ប៉ុណ្ណោះ ចំណែកភិក្ខុអង្គណា មិនចូលទៅក្នុងចំណោមសង្ឃរាល់ថ្ងៃ សម្រាកនៅក្នុងផ្ទះបំពេញព្យាយាម នឹងប្រាកដខ្លួនបានតែក្នុងទីស្ដាប់ធម៌ ឬក្នុងរោងឧបោសថ ភិក្ខុអង្គនោះគួរកំណត់ប្រមាណ ហើយរក្សាឈើជម្រះធ្មេញ ៤-៥ កំណាត់ទុក ត្រង់លំនៅរបស់ខ្លួនទំពាចុះ ។ កាលឈើជម្រះធ្មេញទាំងនោះអស់ទៅហើយ បើក្នុងរោងឈើជម្រះធ្មេញនៅមានច្រើន ក៏គួរនាំមកទំពាបានទៀត បើលោកមិនកំណត់ប្រមាណ នៅតែនាំមកសោត កាលឈើជម្រះធ្មេញទាំងនោះមិនទាន់អស់ទៅ តែក្នុងរោងអស់ទៅ គ្រានោះ ព្រះថេរៈទាំងឡាយពួកខ្លះ ទើបពោលថា ពួកភិក្ខុអ្នកនាំឈើជម្រះធ្មេញទៅ ចូរនាំមកសង ភិក្ខុពួកខ្លះពោលថា ចូរទំពាទៅចុះ ពួកសាមណេរគប្បីជញ្ជូនមកប្រគេនទៀត ព្រោះហេតុនោះ ទើបគួរកំណត់ប្រមាណ ដើម្បីការពារនូវការឈ្លោះគ្នា តែមិនមានទោសក្នុងការកាន់យកទេ ។ សូម្បីភិក្ខុអ្នកដើរផ្លូវ គួរដាក់ឈើជម្រះធ្មេញ ១-២ កំណាត់ក្នុងថង់យាម ហើយសឹមទៅ ដូច្នេះឯង ។

ពោលអំពីឈើសួន់ ចប់

# ពោលអំពីដើមឈើមានម្ចាស់

[ ១០៧ ] បទថា **វនប្បតិ** បានដល់ ដើមឈើជាធំក្នុងព្រៃ ពាក្យថា **វនប្បតិ** នោះ ជាឈ្មោះរបស់ដើមឈើដែលចម្រើនបំផុតក្នុងព្រៃ ។ ឯដើមឈើដែលពួកមនុស្សហួងហែងទាំងអស់ មានស្វាយ ខ្នុរសម្ង និងខ្នុរណាំងជាដើម លោកបំណាងយកក្នុងអធិការនេះ ។ ឬបើពួកមនុស្សដាំដីប្ញី ឬវល្លិ៍ជាដើមទុកត្រង់ដើមឈើណា ដើមឈើនោះ កាលភិក្ខុកាត់ បើក្រមរក្តីសរសៃក្តី សម្បកក្តី ស្រាយក្តី សូម្បីមួយដើមទៅជាប់គ្នានោះឯង រលំចុះលើផែនដី ក៏នៅរក្សានៅឡើយ ចំណែកដើមឈើណា សូម្បីកាត់ដាច់ហើយក៏នៅឈរត្រង់ៗ នោះឯង ព្រោះមានវល្លិ៍ ឬមែកឈើដោយជុំវិញទង់ទាញឬកាល រលំចុះទៅមិនទាន់ដល់ផែនដី ក្នុងដើមឈើនោះ មិនមានការចៀសវាង គឺជាអវហារនោះឯង ។ ដើមឈើណា ដែលភិក្ខុយករណាកាត់ដាច់ហើយ ក៏នៅតាំងនៅក្នុងទីនោះឯង ហាក់ដូចជាមិនដាច់ដូច្នោះ សូម្បីក្នុងដើមឈើនោះ ក៏មានន័យដូចគ្នា ។ ចំណែកភិក្ខុណា ធ្វើដើមឈើឲ្យខ្សោយកម្លាំង ក្រោយមក ទើបអង្រួនឲ្យដួលចុះមកក្តី ឲ្យអ្នកដទៃអង្រួនក្តី កាត់ដើមឈើដទៃ ជិតដើមឈើនោះឲ្យដួលសង្កត់ឯងក្តី ឲ្យអ្នកដទៃកាត់សង្កត់ក្តី កៀងពួកស្វាឲ្យទៅឡើងលើដើមឈើនោះក្តី ប្រើអ្នកដទៃឲ្យកៀងឡើងទៅក្តី កៀងពួកជ្រើងឲ្យឡើងលើដើមនោះក្តី ប្រាប់អ្នកដទៃឲ្យកៀងឡើងទៅក្តីជ្រើងទាំងនោះ ធ្វើដើមឈើនោះឲ្យរលំ អវហារ រមែងមានដល់ភិក្ខុអង្គនោះដូចគ្នា ។

តែកាលលោកធ្វើដើមឈើឲ្យទុព្វលហើយ មានអ្នកដទៃដែលភិក្ខុមិន

បានប្រើ ប្រានដើមឈើនោះឲ្យរលំក្តី យកដើមឈើសង្កត់ឲ្យដួលខ្ទនឯងក្តី ពួកស្វា ឬជ្រូសឡើងទុំតាមធម្មតារបស់ខ្ទនក្តី មានអ្នកដទៃដែលលោកមិនបានប្រើ ឡើងទៅខ្ទនឯងក្តី លោកកាប់ក្ការត្រោយផ្លូវខ្យល់ឯងក្តី ខ្យល់ដែលមានកម្លាំងបក់មកធ្វើឲ្យរលំចុះ ជាភណ្ឌទេយ្យ ក្នុងទីគ្រប់អន្លើ ។ ក្នុងអធិការការក្ការផ្លូវខ្យល់ ក្នុងកាលខ្យល់មិនទាន់បក់មក សមដោយកិច្ចទាំងឡាយមានការធ្វើប្រឡាយដែលស្ទួតឲ្យត្រង់ជាដើម មិនសមដោយប្រការដទៃឡើយ ។ ភិក្ខុបោះដើមឈើហើយ យកសស្ត្រាសៀតចូលក្តី ដុតដោយភ្លើងក្តី បោះធ្មុងដែលមានពិសក្តី ដើមឈើនោះ រមែងងាប់ទៅ ដោយប្រការណាក្នុងការធ្វើទាំងអស់នោះ ជាភណ្ឌទេយ្យដូចគ្នា ដូច្នេះឯង ។

ពោលអំពីដើមឈើមានម្ចាស់ ចប់

# ពោលអំពីអ្នកនាំទ្រព្យទៅ

[ ១០៨ ] ក្នុងកណ្ឌៈដែលមានអ្នកនាំទៅ មានវិនិច្ឆ័យដូច្នេះ កណ្ឌៈដែលអ្នកដទៃនាំទៅ ឈ្មោះថា **ហារណក** ។

ពីរបទថា **ថេយ្យចិត្តោ អាមសតិ** សេចក្តីថា ភិក្ខុឃើញជនដទៃដែលមានសីសភារៈជាដើម ទូលយកទ្រព្យដើរទៅ ហើយគិតក្នុងចិត្តថា អញនឹងដណ្តើមយកទ្រព្យនោះទៅ ទើបប្រញាប់ទៅស្ទាបអង្អែល ត្រឹមតែការស្ទាបអង្អែលប៉ុណ្ណោះ ភិក្ខុត្រូវអាបត្តិទុក្កដ ។

បទថា **ផន្ទាបេតិ** សេចក្តីថា ភិក្ខុធ្វើការទាញមក និងទាញទៅ តែម្ចាស់ទ្រព្យមិនព្រមលែង ព្រោះធ្វើឲ្យកម្រើកនោះ ត្រូវអាបត្តិថុល្លច្ច័យ ។

ពីរបទថា **ឋានា ចាវេតិ** សេចក្តីថា ភិក្ខុទាញមកឲ្យផុតពីដៃម្ចាស់ទ្រព្យ ព្រោះហេតុដែលឲ្យផុតនោះ ភិក្ខុត្រូវអាបត្តិបារាជិក ។ តែបើម្ចាស់នៃកណ្ឌៈក្រោកឡើង ហើយវាយតប់ភិក្ខុនោះ បង្គាប់ឲ្យដាក់កណ្ឌៈនោះ ហើយទើបយកវិញ ភិក្ខុត្រូវអាបត្តិបារាជិក ព្រោះការកាន់យកគ្រាដំបូងនោះឯង ។ កាលភិក្ខុកាត់ ឬស្រាយគ្រឿងអលង្ការអំពីក្បាលក្តី ត្រចៀកក្តី កក្តី ដៃក្តី កាន់យក គ្រាន់តែភិក្ខុស្រាយឲ្យផុតអំពីអវយវៈ មានក្បាលជាដើម ក៏ត្រូវអាបត្តិបារាជិក ។ តែភិក្ខុមិនបាននាំកងដៃ ឬគ្រឿងប្រដាប់ត្រង់ដើមដៃចេញ គ្រាន់តែរូតទៅខាងចុងដៃឲ្យរំកិលទៅមកៗ ឬធ្វើឲ្យហើបទៅក្នុងអាកាស នៅរក្សានៅឡើយ គ្រឿងប្រដាប់មានកងដៃជាដើម មិនត្រូវអាបត្តិបារាជិក ដូចក្នុងវង្វង់កងត្រង់គល់ឈើ និងស្នួចីវរដូច្នោះ ព្រោះហេតុអ្វី ព្រោះថា ដៃដែលពាក់គ្រឿងប្រដាប់ ជារបស់មានវិញ្ញាណ ពិតហើយ គ្រឿងប្រដាប់ មានកង

ដៃជាដើម ដែលពាក់នៅក្នុងចំណែកនៃអវយវៈមានវិញ្ញាណ មិនទាន់នាំចេញអំពីដៃនោះបានដរាបណា ក៏មាននៅក្នុងដៃនោះឯងដរាបនោះ ។ ក្នុងវង់ចិញ្ចៀនដែលពាក់ត្រង់ម្រាមដៃ ក្នុងគ្រឿងប្រដាប់ជើង និងប្រដាប់ចង្កេះក៏មានន័យនេះដូចគ្នា ។ ចំណែកភិក្ខុណាជណ្តើមយកសំពត់សាដក ដែលអ្នកដទៃកំពុងស្លៀក ហើយអ្នកដទៃនោះ ក៏មិនលែងឲ្យរបូតចេញដោយរហ័ស ព្រោះមានការខ្មាស ភិក្ខុដែលជាចោរទាញជាយម្ខាង អ្នកដទៃ ( គឺម្ចាស់សំពត់ ) ក៏ទាញត្រង់ជាយម្ខាងទៀត នៅរក្សានៅឡើយ ។ កាលសំពត់នោះផុតអំពីដៃរបស់អ្នកដទៃ ភិក្ខុនោះត្រូវអាបត្តិបារាជិក ។ បើសំពត់សាដកដែលភិក្ខុទាញមកដាច់ជាពីរ មួយចំណែកនៅក្នុងដៃម្ចាស់ មួយចំណែកនៅក្នុងដៃភិក្ខុ បើសំពត់មួយចំណែកនោះបានតម្លៃមួយបាទ ត្រូវអាបត្តិបារាជិកដូចគ្នា ។

បទថា **សហភណ្ឌហារកំ** សេចក្តីថា ភិក្ខុគិតថា អញនឹងនាំភណ្ឌៈព្រមទាំងអ្នកជញ្ជូនភណ្ឌៈទៅ ដូច្នេះហើយ ទើបគំរាមអ្នកជញ្ជូនភណ្ឌៈថា ឯងចូរទៅអំពីទីនេះ ។ បុគ្គលអ្នកជញ្ជូនភណ្ឌៈទៅនោះភ័យខ្លាច ទើបបែរមុខទៅកាន់ទិសតាមដែលភិក្ខុជាចោរបំណង ឈានជំហានទី ១ ទៅ ភិក្ខុជាចោរត្រូវអាបត្តិថុល្លច្ច័យ ឈានជំហានទី ២ ត្រូវអាបត្តិបារាជិក ។

បទថា **ធាតាបេតិ** សេចក្តីថា បើភិក្ខុជាចោរឃើញអាវុធក្នុងដៃរបស់បុគ្គលដែលជញ្ជូនភណ្ឌៈទៅ ជាអ្នកមានការស្រៀវខ្លាច ប្រាថ្នានឹងធ្វើអាវុធឲ្យធ្លាក់ទៅ ហើយកាន់យកអាវុធនោះ ទើបថយចេញទៅក្នុងចំណែកម្ខាង សម្គុត

ធ្វើឲ្យអាវុធធ្លាក់ទៅ គ្រាន់តែអាវុធជ្រុះអំពីដៃរបស់អ្នកដទៃហើយ ត្រូវអាបត្តិបារាជិក ។ ចំណែកពាក្យថា ធ្វើទ្រព្យឲ្យធ្លាក់ទៅ ត្រូវអាបត្តិទុក្កដជាដើម ព្រះអង្គត្រាស់ទុកហើយ ដោយអំណាចការកំណត់ចំណាំ ។ ពិតហើយ ភិក្ខុអង្គណាកំណត់ទុកថា អញនឹងធ្វើឲ្យទ្រព្យធ្លាក់ទៅ ហើយនឹងកាន់យកទ្រព្យដែលអញពេញចិត្ត ដូច្នេះហើយ ទើបធ្វើឲ្យធ្លាក់ទៅ ភិក្ខុអង្គនោះត្រូវអាបត្តិទុក្កដ ព្រោះធ្វើទ្រព្យនោះឲ្យធ្លាក់ទៅ និងព្រោះការចាប់ពាល់ទ្រព្យនោះ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះធ្វើឲ្យកម្រើក ត្រូវបារាជិក ព្រោះធ្វើទ្រព្យដល់តម្លៃមួយបាទឲ្យឃ្លាតចាកឋាន ។ កាលភិក្ខុត្រូវបុគ្គលអ្នកដឹកនាំទ្រព្យទៅប្រាទនឲ្យដួលចុះ ក្រោយមក ទើបលែងទ្រព្យនោះ ភាពជាសមណៈមិនមានឡើយ ។ ចំណែកភិក្ខុអង្គណាឃើញបុគ្គលអ្នកដឹកនាំទ្រព្យ កំពុងឈានដើរទៅ ទើបដេញតាមទៅបណ្ដើរ ស្រែកបណ្ដើរថា ឈប់ ឈប់ ដាក់ទ្រព្យចុះ ធ្វើឲ្យអ្នកដឹកនាំទ្រព្យដាក់ទ្រព្យចុះ ភិក្ខុអង្គនោះ ក៏ត្រូវអាបត្តិបារាជិក ក្នុងកាលគ្រាន់តែទ្រព្យផុតទៅអំពីដៃរបស់អ្នកដឹកនាំ ព្រោះពាក្យបញ្ជានោះជាហេតុ ។ ចំណែកភិក្ខុអង្គណានិយាយថា ឈប់ ឈប់ តែមិនបានពោលថា ដាក់ទ្រព្យចុះ ហើយបុគ្គលអ្នកដឹកនាំទ្រព្យទៅក្រៅអំពីនេះ ទើបងាកមើលភិក្ខុដែលជាចោរនោះ ហើយគិតថា បើភិក្ខុចោរអង្គនោះមកដល់ខ្លួនអញ នឹងគប្បីសម្លាប់អញចោលក៏បាន តែនៅមានការជាប់ជំពាក់ ទើបបានលាក់ទ្រព្យនោះទុកក្នុងព្រៃស្ដុក ដោយគិតក្នុងចិត្តថា នឹងត្រឡប់មកយកវិញ ដូច្នេះហើយ ចៀសទៅ ភិក្ខុមិនទាន់ត្រូវអាបត្តិបារាជិក ព្រោះមានការធ្វើឲ្យធ្លាក់ជាបច្ច័យ តែកាលភិក្ខុមកដល់កាន់យកដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិកក្នុងខណៈលើកឡើង ។

បើភិក្ខុជាចោរនោះ មានវិតក្កគិតយ៉ាងនេះថា ទ្រព្យនេះ អញធ្វើឲ្យធ្លាក់ទៅប៉ុណ្ណោះ ឈ្មោះថា បានធ្វើឲ្យជារបស់អញហើយ ក្នុងចន្លោះដែលគិតនោះ ទើបកាន់យកទ្រព្យនោះ ដោយសម្គាល់ជារបស់ខ្លួន នៅរក្សានៅឡើយ ព្រោះការកាន់យកនោះ តែជាភណ្ឌទេយ្យ ។ កាលម្ចាស់ទ្រព្យនិយាយថា លោកម្ចាស់ចូរសង កាលមិនសងត្រូវអាបត្តិបារាជិក ក្នុងកាលម្ចាស់ទ្រព្យដាក់ធុរៈ ។ កាលភិក្ខុកាន់យកដោយបង្សុកូលសញ្ញាថា ម្ចាស់ភណ្ឌៈនោះចោលទ្រព្យនេះទៅ ឥឡូវនេះ គេមកហួងហែងទ្រព្យនេះ ក៏មានន័យដូចគ្នា ។

ក្នុងមហាអដ្ឋកថា ពោលទុកថា បើម្ចាស់ទ្រព្យកំពុងពិនិត្យមើលដោយហេតុ ត្រឹមពាក្យដែលភិក្ខុចោរនិយាយថា ឈប់ ឈប់ ប៉ុណ្ណោះ ឃើញភិក្ខុចោរនោះហើយ ដាក់ធុរៈ ដោយគិតថា ឥឡូវនេះ វាមិនមែនរបស់អញ អស់ការជាប់ជំពាក់ ចោលហើយ គេចទៅ កាលភិក្ខុកាន់យកទ្រព្យនោះដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដក្នុងកាលលើកឡើង កាលម្ចាស់ទ្រព្យឲ្យសង គប្បីសង បើមិនសង ត្រូវអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ព្រោះគេចោលរបស់នោះ ដោយប្រយោគរបស់ភិក្ខុនោះ ។ តែក្នុងអដ្ឋកថាទាំង-ឡាយដទៃ មិនមានពាក្យវិចារណ៍ឡើយ ។ វិនិច្ឆ័យក្នុងភិក្ខុដែលកាន់យកដោយសម្គាល់ថា ជារបស់ខ្លួនក្តី ដោយបង្សុកូលសញ្ញាក្តី ដោយន័យមុននោះឯងក៏ដូចគ្នា ។

ពោលអំពីអ្នកនាំទ្រព្យទៅ ចប់

# ពោលអំពីទ្រព្យដែលគេផ្ញើ

[ ១០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរបស់ផ្ញើ ដូច្នេះថា ព្រោះការពោលកុហកទាំងដឹងខ្លួនថា ខ្ញុំមិនបានទទួលទុកទេ ដូច្នេះ ត្រូវអាបត្តិទុក្កដ ព្រោះជាបុព្វប្រយោគនៃអទិន្នាទាន ។ ត្រូវអាបត្តិទុក្កដនោះឯង ដល់ភិក្ខុដែលពោលពាក្យជាដើមថា អ្នកឯងនិយាយអ្វី ពាក្យនេះមិនសមគួរដល់ខ្ញុំផង ទាំងមិនសមគួរដល់អ្នកផង ។ ម្ចាស់ទ្រព្យញ៉ាំងសេចក្តីសង្ស័យឲ្យកើតឡើងថា អញបានផ្ញើទ្រព្យទុក ក្នុងដៃភិក្ខុនេះក្នុងទីកំបាំង មនុស្សដទៃមិនមាននរណាដឹង លោកនឹងឲ្យដល់អញ ឬមិនឲ្យទេហ្ន៎ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ម្ចាស់ទ្រព្យឃើញសភាពដែលភិក្ខុនោះជាបុគ្គលកាចជាដើម ទើបដាក់ធុរៈថា ភិក្ខុអង្គនេះនឹងមិនសងដល់អញទេ ។ ក្នុងភិក្ខុ និងម្ចាស់ភណ្ឌៈនោះ បើភិក្ខុនៅមានសេចក្តីឧស្សាហ៍ក្នុងការសងថា អញនឹងធ្វើឲ្យគេលំបាក ហើយសឹមឲ្យនៅរក្សានៅឡើយ ។ បើលោកមិនមានសេចក្តីឧស្សាហ៍ក្នុងការសង តែម្ចាស់របស់ភណ្ឌៈនៅមានសេចក្តីឧស្សាហ៍ក្នុងការទទួល នៅរក្សាដូចគ្នា ។ តែបើភិក្ខុមិនឧស្សាហ៍ក្នុងការសងនោះ ម្ចាស់របស់ភណ្ឌៈដាក់ធុរៈថា ភិក្ខុនោះនឹងមិនសងអញឡើយ ភិក្ខុត្រូវអាបត្តិបារាជិក ព្រោះដាក់ធុរៈទាំងពីរចំណែកដោយប្រការដូច្នេះ ។ បើភិក្ខុនិយាយតែមាត់ថា នឹងសង តែចិត្តមិនសងកាលបើដូច្នេះ ក៏ត្រូវអាបត្តិបារាជិក ព្រោះម្ចាស់ទ្រព្យដាក់ធុរៈ តែមិនត្រូវអាបត្តិដល់ភិក្ខុដែលផ្លាស់ប្តូរភណ្ឌៈ គឺរបស់ផ្ញើនោះ ដែលជនដទៃប្រគល់ទុកក្នុងដៃរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ការគ្រប់គ្រងអំពីឋាន ដោយភាពជាប្រទេសនេះ មិនបានគ្រប់គ្រងរក្សា នាំទៅរក្សាទុកក្នុងទីសុវត្ថិភាព ។ អវហារ

រមែងមិនមានដល់ភិក្ខុដែលឲ្យឃ្លាតចាកឋាន សូម្បីដោយថេយ្យចិត្ត ។ ព្រោះហេតុអ្វី ព្រោះជារបស់ដែលគេផ្ញើទុកក្នុងដៃរបស់ខ្លួន តែជាកណ្ឌទេយ្យ ។ កាលភិក្ខុដែលប្រើប្រាស់ដោយថេយ្យចិត្ត ក៏មានន័យដូចគ្នា ។ សូម្បីការកាន់យកជារបស់ខ្លី ក៏ដូចគ្នាដូច្នេះ ។ ពាក្យថា **ឆម្មំ ចរណ្ឌោ** ជាដើម ក៏មានន័យដូចពោលហើយដូចគ្នា ។ ពណ៌នាព្រះបាលីប៉ុណ្ណេះសិន ។

# បាលីមុត្តកវិនិច្ឆ័យ

ចំណែកវិនិច្ឆ័យក្រៅព្រះបាលី ក្នុងរបស់ផ្ញើនេះ លោកពោលទុកហើយដោយអំណាចនៃចតុក្កៈ មានបត្តចតុក្កៈជាដើមយ៉ាងនេះថា បានឮថា ភិក្ខុមួយអង្គ ញ៉ាំងចិត្តលោកឲ្យកើតឡើងក្នុងបាត្រ ដែលមានតម្លៃច្រើនរបស់អ្នកដទៃប្រាថ្នានឹងលួចបាត្រនោះ ទើបកំណត់ទីដែលគេដាក់បាត្រនោះទុកបានយ៉ាងល្អហើយទើបដាក់បាត្ររបស់ខ្លួនទុកជិតបាត្រនោះឯង ។ ក្នុងសម័យជិតភ្លឺ ទើបលោកមកឲ្យប្រាប់ធម៌ ហើយប្រាប់ព្រះមហាថេរៈដែលកំពុងសិងយ៉ាងនេះថា ខ្ញុំសូមថ្វាយបង្គំលោកម្ចាស់ ព្រះថេរៈសួរថា លោកជានរណា ទើបលោកឆ្លើយថា ខ្ញុំជាភិក្ខុអាគន្តុកៈ លោកម្ចាស់ គិតថា នឹងលាទៅអំពីព្រលឹមនេះឯង ហើយបាត្ររបស់ខ្ញុំ មានខ្សែយោគដូច្នេះ មានស្លាកដូច្នេះ ទុកត្រង់ទីនោះ ខ្ញុំគួរបានបាត្រនោះ ព្រះថេរៈចូលទៅចាប់យកបាត្រនោះ លើកឡើងភិក្ខុជាចោរត្រូវអាបត្តិបារាជិក ។ បើលោកខ្លាច ហើយគេចទៅក្នុងកាលព្រះថេរៈមកហើយ សួរថា លោកជានរណា មកខុសកាល ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ទើបគេចទៅ ។ តែមិនត្រូវដល់ព្រះថេរៈ ព្រោះលោកមាន

ចិត្តបរិសុទ្ធ ។ ព្រះថេរៈគិតក្នុងចិត្តថា អញនឹងហុចបាត្រនោះ តែបែរជាយកបាត្រដទៃ សូម្បីក្នុងបាត្រនោះ ក៏មានន័យនេះដូចគ្នា ។ តែន័យនេះរមែងសមក្នុងកាលព្រះថេរៈហុចបាត្រដទៃ ដែលដូចបាត្រនោះ ដូចរឿងមនុស្សដែលមានរូបរាងដូចគ្នា ក្នុងមនុស្សវិគ្គហសិក្ខាបទដូច្នោះ ។ ចំណែកក្នុងកុរុន្ទីពោលទុកថា គប្បីកាត់អាបត្តិដោយការឈានជើងទៅ ។ ពាក្យដែលលោកពោលទុកក្នុងកុរុន្ទីនោះ រមែងសមក្នុងកាលព្រះថេរៈហុចបាត្រដទៃ តែមិនដូចបាត្រនោះឡើយ ព្រះថេរៈសម្គាល់ថា ជាបាត្រមួយនោះ តែបានហុចបាត្ររបស់ខ្លួនឲ្យទៅ មិនត្រូវអាបត្តិបារាជិកដល់ភិក្ខុជាចោរឡើយ ព្រោះបាត្រនោះម្ចាស់ឲ្យ ព្រោះខ្លួនកាន់យកដោយចិត្តមិនបរិសុទ្ធ ត្រូវអាបត្តិទុក្កដ ។ ព្រះថេរៈសម្គាល់ថា ជាបាត្រនោះ តែបានហុចបាត្ររបស់ភិក្ខុដែលជាចោរនោះឯងឲ្យទៅ ក្នុងអធិការពោលដោយការហុចបាត្ររបស់ភិក្ខុដែលជាចោរនេះ មិនត្រូវអាបត្តិបារាជិកដល់ភិក្ខុដែលជាចោរ ព្រោះបាត្រនោះជារបស់ខ្លួន ព្រោះខ្លួនកាន់យកដោយចិត្តមិនបរិសុទ្ធ ត្រូវអាបត្តិទុក្កដ ។ ជាអនាបត្តិដល់ព្រះថេរៈក្នុងទីទាំងពួង ។

ភិក្ខុអន្តដទៃគិតថា នឹងលួចបាត្រ ហើយថ្វាយបង្គំព្រះថេរៈដែលកំពុងសិងយ៉ាងនោះឯង ហើយត្រូវព្រះថេរៈសួរថា លោកជានរណា ភិក្ខុនោះប្រាប់ថា ខ្ញុំជាភិក្ខុឈឺលោកម្ចាស់ មេត្តាឲ្យបាត្រមួយដល់ខ្ញុំ ខ្ញុំទៅកាន់ទ្វារស្រុកហើយ នឹងនាំភេសជ្ជៈមក ។ ព្រះថេរៈកំណត់ថា ក្នុងទីនេះ មិនមានភិក្ខុឈឺនេះនឹងជាចោរ ហើយពោលថា ចូរនាំបាត្រនេះទៅ បានហុចបាត្ររបស់ភិក្ខុ

ដែលជាគូពៀរវេរបស់ខ្លួន ( បាត្ររបស់ភិក្ខុជាសត្រូវនឹងព្រះថេរៈ ) ឲ្យទៅ ត្រូវអាបត្តិបារាជិកទាំងពីរអង្គ ក្នុងខណៈដែលលើកឡើងនោះឯង ។ សូម្បីកាលព្រះថេរៈចាំបានច្បាស់ថា ជាបាត្ររបស់ភិក្ខុដែលមានពៀរ ហើយលើកបាត្ររបស់ភិក្ខុដទៃឡើង ក៏មានន័យនេះដូចគ្នា ។ បើព្រះថេរៈចាំបានច្បាស់ថា បាត្រមួយនេះរបស់ភិក្ខុដែលមានពៀរ តែបានលើកយកបាត្ររបស់ភិក្ខុដែលជាចោរនោះឯងឲ្យទៅ ត្រូវអាបត្តិបារាជិកដល់ព្រះថេរៈ ត្រូវអាបត្តិទុក្កដដល់ភិក្ខុចោរ ដោយន័យដូចពោលហើយនោះឯង។ បើព្រះថេរៈសម្គាល់ថា បាត្រមួយនេះរបស់ភិក្ខុដែលមានពៀរនឹងភិក្ខុដែលជាចោរនោះ ទើបឲ្យបាត្ររបស់ខ្លួនទៅ ត្រូវអាបត្តិទុក្កដទាំងពីរអង្គ ដោយន័យដូចពោលហើយនោះឯង ។ ព្រះមហាថេរៈមួយអង្គនិយាយនឹងភិក្ខុឧបដ្ឋាកថា លោកចូរកាន់យកបាត្រ និងចីវរ យើងនឹងទៅបិណ្ឌបាតក្នុងស្រុកឈ្មោះនោះ ។ ភិក្ខុកំលោះកាន់បាត្រដើរទៅខាងក្រោយព្រះថេរៈ ញ៉ាំងថេយ្យចិត្តឲ្យកើតឡើងហើយ បើរំកិលភារៈលើក្បាល ចុះមកត្រង់ក មិនត្រូវអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ព្រោះបាត្រ និងចីវរនោះ លោកកាន់ទៅតាមពាក្យបញ្ជា តែបើលោកគេចចេញអំពីផ្លូវ ចូលព្រៃទៅ គប្បីកាត់អាបត្តិដោយជំហាន បើលោកត្រឡប់បែរមុខទៅកាន់វិហារ គេចទៅចូលវិហារហើយ ទើបទៅ ត្រូវអាបត្តិបារាជិកក្នុងខណៈឈានកន្លងឧបចារៈទៅ ។ បើលោកបែរមុខទៅកាន់ស្រុក គេចទៅអំពីទីដែលព្រះមហាថេរៈផ្លាស់ប្តូរសំពត់ស្បៀក សំពត់ដណ្តប់ ត្រូវអាបត្តិបារាជិក ក្នុងខណៈឈានកន្លងឧបចារស្រុកទៅ ។ តែបើទាំងពីរអង្គត្រាច់

បិណ្ឌបាត ឆាន់ហើយក្តី កាន់យកចេញទៅក្តី ចំណែកព្រះថេរៈពោលនឹងភិក្ខុកំលោះនោះទៀតថា លោកចូរកាន់យកបាត្រ និងចីវរ យើងនឹងទៅកាន់វិហារ ហើយភិក្ខុកំលោះអង្គនោះក៏ផ្លាស់ការៈលើក្បាល ចុះមកត្រង់ក ក្នុងទីកន្លែងនោះ ដោយន័យមុននោះឯង នៅរក្សានៅឡើយ បើគេចចេញអំពីផ្លូវចូលព្រៃទៅ គប្បីកាត់អាបត្តិតាមជំហាន ។ តែបើលោកបែរមុខទៅកាន់ស្រុកហើយចៀសចេញទៅ ត្រូវអាបត្តិបារាជិក ក្នុងខណៈឈានកន្លងឧបចារស្រុក ។ តែបើលោកបែរមុខទៅកាន់វិហារខាងមុខគេចទៅ តែមិនឈរ មិនអង្គុយក្នុងវិហារ ទៅដោយថេយ្យចិត្ត នៅមិនទាន់ស្ងប់នោះឯង ត្រូវអាបត្តិបារាជិកក្នុងខណៈឈានកន្លងឧបចារវិហារ ។ ចំណែកភិក្ខុអង្គណា លោកមិនបានប្រើជួយកដោយខ្លួនឯង ក្នុងកាលរំកិលការៈលើក្បាល ចុះមកត្រង់កជាដើម ភិក្ខុអង្គនោះ ត្រូវអាបត្តិបារាជិក ពាក្យដ៏សេសដូចគ្នានឹងពាក្យមុននោះឯង ។

ចំណែកភិក្ខុណា ដែលព្រះថេរៈប្រាប់ថា លោកចូរទៅកាន់វិហារឈ្មោះនោះ ហើយបោក ឬជ្រលក់ចីវរ ហើយចូរមក ដូច្នេះ លោកទទួលថា សាធុ ហើយកាន់យកទៅ មិនត្រូវអាបត្តិបារាជិកដល់ភិក្ខុអង្គនោះ ព្រោះញុំាងថេយ្យចិត្តឲ្យកើតឡើង ហើយផ្លាស់ការៈលើក្បាលចុះមកត្រង់កជាដើម ក្នុងវាងផ្លូវ ។ កាលចៀសចេញអំពីផ្លូវ គប្បីកាត់អាបត្តិលោកដោយជំហាន លោកទៅកាន់វិហារនោះហើយ ស្នាក់នៅក្នុងវិហារនោះឯង ប្រើប្រាស់ឲ្យចាស់ទៅដោយថេយ្យចិត្ត ឬក៏ពួកចោរលួចយកចីវរនោះ របស់ព្រះថេរៈនោះទៅ មិនជាអវហារ តែជាភណ្ឌទេយ្យ ។ កាលលោកចេញអំពីវិហារនោះមក

ក៏ន័យនេះឯង ។ ចំណែកភិក្ខុណា លោកមិនបានប្រើ កាលព្រះថេរៈធ្វើនិមិត្ត ហើយ ឬខ្លួនឯងកំណត់បាន ឃើញចីវរសៅហ្មងហើយ ទើបពោលថា សូមប្រគល់ចីវរចុះ លោកម្ចាស់ ខ្ញុំនឹងទៅកាន់ស្រុកឈ្មោះនោះ ជ្រលក់ហើយនឹងនាំមក ដូច្នេះហើយ កាន់យកទៅ កាលថេយ្យចិត្តកើតឡើងហើយ ផ្លាស់ភារៈលើក្បាលចុះមកត្រង់កជាដើមក្នុងចន្លោះផ្លូវ ត្រូវអាបត្តិបារាជិក ព្រោះហេតុអ្វី ព្រោះចីវរនោះ ខ្លួនកាន់យកដោយលោកមិនបានប្រើ លុះលោកគេចចេញអំពីផ្លូវក្តី ត្រឡប់មកកាន់វិហារនោះឯង ហើយឈានកន្លងដែនវិហារទៅក្តី ក៏ត្រូវអាបត្តិបារាជិក ដែលមានន័យដូចពោលហើយនោះឯង ។ ក្នុងកាលថេយ្យចិត្តកើតឡើងដល់ភិក្ខុទៅហើយត្រង់ស្រុកនោះ ជ្រលក់ចីវរហើយត្រឡប់មក ក៏មានន័យនេះដូចគ្នា ។ តែភិក្ខុនោះទៅក្នុងវិហារណា ក៏ស្នាក់នៅក្នុងវិហារនោះ ឬក្នុងវិហារក្នុងចន្លោះផ្លូវ ឬត្រឡប់ទៅកាន់វិហារ ( ដើម ) នោះឯង ហើយស្នាក់នៅ មិនឲ្យឈានកន្លងដែនឧបចារៈក្នុងទិសមួយនៃវិហារនោះទៅក្តី ប្រើប្រាស់ឲ្យចាស់ទៅដោយថេយ្យចិត្តក្តី ពួកចោរលួចយកចីវរនោះ របស់ភិក្ខុនោះទៅក្តី ចីវរបាត់បង់ទៅប្រការឯណាមួយក្តី ជាភណ្ឌទេយ្យ ។ តែកាលលោកឈានកន្លងដែនឧបចារសីមាទៅ ត្រូវអាបត្តិបារាជិក ។

ចំណែកភិក្ខុណា កាលព្រះថេរៈធ្វើនិមិត្ត ទើបសួរលោកថា មេត្តាឲ្យចុះ លោកម្ចាស់ ខ្ញុំនឹងជ្រលក់មកប្រគេន ដូច្នេះហើយ សួរថា ខ្ញុំនឹងទៅជ្រលក់ក្នុងទីណា លោកម្ចាស់ ចំណែកព្រះថេរៈពោលនឹងភិក្ខុអាគន្តុកនោះថា លោកចូរទៅជ្រលក់ក្នុងទីដែលលោកប្រាថ្នាចុះ ។ ភិក្ខុអាគន្តុកនេះឈ្មោះថា ទូត

ដែលលោកបញ្ជូនទៅ ។ ភិក្ខុនេះកាលគេចទៅដោយថេយ្យចិត្ត ក៏មិនគួរកាត់អាបត្តិដោយអវហារ ។ តែកាលលោកគេចទៅដោយថេយ្យចិត្តក្តី ឲ្យវិនាសដោយការប្រើប្រាស់ ឬដោយប្រការដទៃក្តី រមែងជាភណ្ឌទេយ្យដូចគ្នា ។ ភិក្ខុផ្ញើបរិក្ខារណាមួយ ទុកក្នុងដៃរបស់ភិក្ខុដោយប្រាប់ថា លោកចូរឲ្យដល់ភិក្ខុឈ្មោះនោះ ក្នុងវិហារឈ្មោះនោះ ។ វិនិច្ឆ័យក្នុងកាលថេយ្យចិត្តកើតឡើងដល់ភិក្ខុដែលទទួលបរិក្ខារនោះ ក្នុងទីទាំងពួងក៏ដូចគ្នានឹងការពោលទុកហើយក្នុងពាក្យនេះថា លោកចូរទៅកាន់វិហារឈ្មោះនោះ ហើយបោក ឬជ្រលក់ចីវរ ហើយចូរមក ដូច្នេះ ។ ភិក្ខុមួយអង្គទៀត ប្រាថ្នានឹងបញ្ជូន ( បរិក្ខារ ) ទៅ ទើបធ្វើនិមិត្តដោយន័យថា នរណាហ្ន៎ ព្រមទៅ ។ ឯក្នុងទីនោះ មានភិក្ខុមួយអង្គពោលថា ឲ្យមកចុះលោកម្ចាស់ ខ្ញុំនឹងទៅ ដូច្នេះហើយ ក៏ទទួលយក ( បរិក្ខារនោះ ) ទៅ ។ វិនិច្ឆ័យក្នុងកាលថេយ្យចិត្តកើតឡើង ដល់ភិក្ខុអ្នកទទួលបរិក្ខារនោះក្នុងទីទាំងពួង ដូចពោលទុកហើយ ក្នុងពាក្យនេះថា មេត្តាឲ្យចីវរចុះ លោកម្ចាស់ ខ្ញុំទៅកាន់ស្រុកឈ្មោះនោះ ជ្រលក់ហើយ នឹងនាំមកដូច្នេះ ។

ព្រះថេរៈ បានសំពត់ដើម្បីប្រយោជន៍ដល់ចីវរហើយ ក៏រក្សាទុកក្នុងត្រកូលឧបដ្ឋាក ។ បើអន្តេវាសិករបស់ព្រះថេរៈនោះ ប្រាថ្នានឹងលួចយកសំពត់ទៅ ទើបទៅក្នុងត្រកូលនោះ ហើយនិយាយដូចខ្លួនត្រូវព្រះថេរៈប្រើឲ្យទៅថា ពួកលោកចូរឲ្យសំពត់នោះ ឧបាសិកាជឿពាក្យរបស់ភិក្ខុអង្គនោះ ហើយ បានយកសំពត់ដែលឧបាសករក្សាទុកមកឲ្យក្តី ឧបាសក ឬបុគ្គល

ណាដទៃ ( ជឿពាក្យរបស់ភិក្ខុអង្គនោះហើយ ) បាននាំយកសំពត់ដែលឧបាសិការក្សាទុកមកឲ្យក្តី ។ ភិក្ខុអង្គនោះ ត្រូវអាបត្តិបារាជិកក្នុងខណៈលើកឡើងនោះ ។ តែបើពួកឧបដ្ឋាករបស់ព្រះថេរៈពោលថា ពួកយើងនឹងប្រគេនសំពត់នេះ ហើយក៏រក្សាសំពត់របស់ខ្លួនទុក បើអន្តេវាសិករបស់ព្រះថេរៈនោះប្រាថ្នានឹងលួចយកសំពត់នោះ ទើបទៅក្នុងត្រកូលនោះ ហើយពោលថា ពួកលោកប្រាថ្នានឹងប្រគេនសំពត់ដល់ព្រះថេរៈ ចូរឲ្យសំពត់នោះចុះ ។ ហើយឧបដ្ឋាកទាំងនោះ ជឿអន្តេវាសិកទាំងនោះ ហើយពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំតាំងចិត្តទុកថា និមន្តលោកម្ចាស់ឲ្យធាន់ហើយ នឹងប្រគេន ទើបបានរក្សាទុក និមន្តលោកម្ចាស់ទទួលយកទៅចុះ ហើយប្រគេនទៅ មិនត្រូវអាបត្តិបារាជិក ព្រោះសំពត់នោះ ម្ចាស់ទ្រព្យប្រគេនហើយ តែត្រូវអាបត្តិទុក្កដ ព្រោះលោកកាន់យកដោយចិត្តមិនបរិសុទ្ធ និងជាភណ្ឌទេយ្យ ។

ភិក្ខុដើរទៅកាន់ស្រុក ប្រាប់ដល់ភិក្ខុថា មនុស្សមានឈ្មោះនេះ នឹងប្រគេនសំពត់ងូតទឹកភ្លៀងដល់ខ្ញុំ លោកគប្បីទទួលយកសំពត់មួយផ្ទាំងនោះហើយរក្សាទុកផង ។ ភិក្ខុអង្គនោះទទួលថា សាធុ ហើយរក្សាសំពត់សាដកដែលមានតម្លៃច្រើន ដែលភិក្ខុនោះឲ្យទុក និងសំពត់សាដកដែលមានតម្លៃតិចដែលខ្លួនបានហើយ ភិក្ខុនោះមកហើយ ដឹងថា សំពត់ដែលខ្លួនបាន មានតម្លៃច្រើន ឬមិនដឹងក៏ដោយ ពោលថា លោកចូរឲ្យសំពត់ងូតទឹកភ្លៀងដល់ខ្ញុំចុះ លោកឆ្លើយថា សំពត់សាដកដែលលោកបានមក មានសាច់គ្រោតគ្រាត ចំណែកសំពត់សាដករបស់ខ្ញុំ មានតម្លៃច្រើន ទាំងពីរផ្ទាំង ខ្ញុំរក្សាទុកក្នុង

ឱកាសឈ្មោះនោះហើយ សូមចូលទៅយកចុះ ។ កាលភិក្ខុដែលសួរនោះចូលទៅយកសំពត់សាដកសាច់គ្រោតគ្រាតហើយ ភិក្ខុអ្នករក្សាទុកកាន់យកសំពត់សាដកមួយផ្ទាំងទៀត ត្រូវអាបត្តិបារាជិកក្នុងខណៈលើកឡើង បើភិក្ខុដែលរក្សាសំពត់ទុកនោះ បានចារឹកឈ្មោះរបស់ខ្លួនទុកក្នុងសំពត់សាដករបស់ភិក្ខុដែលមកសួរនោះ ហើយឈ្មោះរបស់ភិក្ខុដែលមកសួរនោះ ទុកក្នុងសាដករបស់ខ្លួន ហើយពោលថា លោកចូរទៅអានឈ្មោះ ហើយកាន់យកចុះដូច្នេះ ។ សូម្បីក្នុងសំពត់សាដកដែលពោលនោះ ក៏ន័យនេះដូចគ្នា ។

ចំណែកភិក្ខុម្ចាស់អាវាសអង្គណា រក្សាសំពត់សាដកដែលខ្លួនឯង និងអាគន្តុកភិក្ខុនោះបានមករួមគ្នាទុកហើយ និយាយនឹងអាគន្តុកៈនោះយ៉ាងនោះថា សំពត់សាដកដែលលោក និងខ្ញុំបាន ទាំងពីរផ្ទាំងរក្សាទុកខាងក្នុងបន្ទប់ លោកចូរទៅជ្រើសរើសយកសំពត់ដែលលោកប្រាថ្នាចុះ ។ ហើយអាគន្តុកភិក្ខុនោះកាន់យកសំពត់សាដកសាច់គ្រោតគ្រាត ដែលភិក្ខុម្ចាស់អាវាសបានមកនោះឯង ព្រោះការខ្មាសបាប ។ ក្នុងភិក្ខុអាគន្តុកៈ និងភិក្ខុម្ចាស់កន្លែងនោះ កាលភិក្ខុម្ចាស់កន្លែងកាន់យកសំពត់សាដកក្រៅអំពីនេះ ដែលសល់អំពីភិក្ខុអាគន្តុកៈជ្រើសរើសហើយ មិនត្រូវអាបត្តិ ។

អាគន្តុកភិក្ខុ កាលពួកភិក្ខុម្ចាស់កន្លែងធ្វើចីវរកម្ម ទុកដាក់បាត្រ និងចីវរក្នុងទីជិត យល់ថា ពួកភិក្ខុម្ចាស់កន្លែងទាំងនោះ នឹងរក្សាទុក ទើបទៅផ្ញូតទឹក ឬទៅក្នុងទីដទៃទៀត ។ បើភិក្ខុម្ចាស់កន្លែង ឃុំគ្រងបាត្រ និងចីវរនោះទុក សេចក្ដីនោះជាការល្អ បើមិនគ្រប់គ្រងទុកទេ កាលបាត្រ និងចីវរនោះ

បាត់បង់ទៅ ក៏មិនជាសំណង ។ បើអាគន្តុកភិក្ខុនោះពោលថា សូមរក្សាបាត្រ និងចីវរនេះទុកផង លោកម្ចាស់ ហើយទៅ ភិក្ខុម្ចាស់កន្លែងក្រៅអំពីនេះមិនជ្រាប ព្រោះរវល់ក្នុងកិច្ច គប្បីជ្រាបន័យដូចគ្នានេះ ។ បើភិក្ខុម្ចាស់កន្លែងទាំងនោះ កាលអាគន្តុកភិក្ខុពោលថា សូមរក្សាបាត្រ និងចីវរនេះទុកផង លោកម្ចាស់ ភិក្ខុម្ចាស់កន្លែងបដិសេធថា ខ្ញុំកំពុងរវល់ ហើយភិក្ខុអាគន្តុកៈគិតថា លោកទាំងនេះនឹងទុកដាក់ពិតប្រាកដ មិនជាប់ជំពាក់ចិត្ត ហើយចេញទៅ គប្បីជ្រាបន័យដូចគ្នានេះ ។ បើភិក្ខុម្ចាស់កន្លែងត្រូវអាគន្តុកភិក្ខុអង្គនោះសំណូមពរ ឬមិនសំណូមពរក៏ដោយ និយាយថា ពួកខ្ញុំទុកដាក់ឲ្យ ចូរលោកទៅចុះ ដូច្នេះ ត្រូវរក្សាបាត្រ និងចីវរនោះទុក បើមិនរក្សាទុកសោត បាត្រ និងចីវរ រមែងជាសំណង ។ ព្រោះហេតុអ្វី ព្រោះថា បាត្រ និងចីវរនោះពួកលោកទទួលទុកហើយ ។

ភិក្ខុអង្គណា ជាភណ្ឌាគារិក ( អ្នករក្សាឃ្លាំង ) វេលាទៀបភ្លឺនោះឯង បានប្រមូលបាត្រ និងចីវររបស់ភិក្ខុទាំងឡាយ ទៅទុកក្នុងប្រាសាទជាន់ក្រោម មិនបានបិទទ្វារ ទាំងមិនបានប្រាប់ដល់ភិក្ខុទាំងនោះ ត្រាច់ទៅបិណ្ឌបាតក្នុងទីឆ្ងាយ បើចោរលួចយកបាត្រ និងចីវរទាំងនោះទៅសោត មិនជាសំណងដល់លោក ។

ចំណែកភណ្ឌាគារិកភិក្ខុអង្គណា ត្រូវពួកភិក្ខុពោលថា លោកដ៏ចម្រើនលោកយកបាត្រ ចីវរចុះមក ឥឡូវនេះ ដល់ពេលចាប់ស្លាក ទើបសួរថា ពួកលោកប្រជុំ ព្រមគ្នាហើយឬ ។

កាលលោកទាំងនោះប្រាប់ថា ប្រជុំព្រមហើយ លោកម្ចាស់ ទើបបាន ជញ្ជូនយកបាត្រ និងចីវរចេញមកទុក ហើយបិទទ្វារឃ្លាំង ហើយប្រាប់ថា ពួកលោកកាន់យកបាត្រ និងចីវរ ហើយគប្បីបិទទ្វារខាងក្រោមប្រាសាទជាមុន សឹមទៅ ដូច្នេះហើយក៏ទៅ ក្នុងពួកភិក្ខុទាំងនោះ ភិក្ខុមួយអង្គមានជាតិជាអ្នកខ្ជិល កាលភិក្ខុទាំងឡាយទៅហើយ ខាងក្រោយ ទើបជូតក្អែក ក្រោកឡើងដើរទៅកាន់ទីដែលមានទឹក ឬទីលុបមុខ ។ ខណៈនោះ ពួកចោរប្រទះឃើញ ទើបលួចយកបាត្រ និងចីវររបស់លោកទៅ ជាការដែលពួកចោរលួចទៅដោយល្អ មិនជាភណ្ឌទេយ្យដល់ភណ្ឌាគារិកភិក្ខុឡើយ ។ បើភិក្ខុអង្គខ្លះមិនបានប្រាប់ដល់ភណ្ឌាគារិកឡើយ ក៏ទុកដាក់ចីវររបស់ខ្លួនក្នុងឃ្លាំង កាលបរិក្ខារនោះបាត់បង់ទៅ ក៏មិនជាភណ្ឌទេយ្យដល់ភណ្ឌាគារិកភិក្ខុ ។ តែបើភណ្ឌារិកភិក្ខុឃើញបរិក្ខារនោះហើយ គិតថា រក្សាទុកក្នុងទីមិនគួរ ទើបយកទៅរក្សាទុក កាលបរិក្ខារនោះបាត់បង់ទៅ ការសងរមែងមានដល់ភណ្ឌារិកភិក្ខុអង្គនោះ ។ បើភណ្ឌាគារិកភិក្ខុ ត្រូវភិក្ខុអ្នកយកទ្រព្យទៅផ្ញើពោលថា ខ្ញុំទុកដាក់បរិក្ខារឈ្មោះនេះហើយ លោកម្ចាស់ សូមជួយមើលឲ្យផង លោកទទួលថា បាន ឬដឹងថា ទុកដាក់មិនល្អ ទើបរក្សាទុកក្នុងទីដទៃ កាលបរិក្ខារនោះ បាត់បង់ទៅ ជាសំណងដល់ភណ្ឌាគារិកភិក្ខុនោះដូចគ្នា ។ តែបើលោកបដិសេធថា ខ្ញុំមិនដឹងទេ មិនជាសំណងឡើយ ។ ចំណែកភិក្ខុណា កាលភណ្ឌាគារិកភិក្ខុឃើញនោះឯង រក្សាទុកទាំងមិនឲ្យភណ្ឌាគារិកភិក្ខុទទួលដឹងបរិក្ខាររបស់ភិក្ខុបាត់ទៅ ជាការបាត់ទៅដោយល្អ ។ បើភណ្ឌាគារិកភិក្ខុរក្សា

បរិក្ខារនោះទុកក្នុងទីកន្លែងដទៃ កាលបាត់បង់ទៅ ជាសំណាង ដូច្នេះ ។

# ចោរលួចទ្រព្យសង្ឃក្នុងឃ្លាំង

បើឃ្លាំងនៅល្អ បរិក្ខារទាំងពួងរបស់សង្ឃ និងរបស់ចេតិយ គេរក្សាទុកក្នុងឃ្លាំងនោះឯង ។ តែកណ្ឌាគារិកភិក្ខុ ជាមនុស្សល្ងង់ មិនឈ្លាស បើកទ្វារចោល ទៅដើម្បីស្តាប់ធម្មកថា ឬដើម្បីធ្វើកិច្ចឯណាមួយ ខណៈនោះ ពួកចោរឃើញហើយ លួចកណ្ឌៈទៅប៉ុន្មាន កណ្ឌៈប៉ុណ្ណោះ ជាសំណាងដល់លោក ។ កាលកណ្ឌារិកភិក្ខុ ចេញអំពីកណ្ឌាគារទៅចង្ក្រមនៅខាងក្រៅ ឬបើកទ្វារឲ្យរហើយ ឬអង្គុយប្រកបសមណធម៌ក្នុងកណ្ឌាគារនោះឯង ឬអង្គុយលេងក្នុងកណ្ឌាគារនោះឯង រវល់ដោយកម្មឯណាមួយ ឬជាអ្នកឈឺបន្ទោបង់ឧច្ចារបស្សាវៈ កាលឧបចារៈក្នុងទីនោះឯងមាន តែទៅខាងក្រៅ ឬធ្វេសប្រហែសដោយអាការដទៃណាមួយ ពួកចោរបើកទ្វារ ឬចូលតាមទ្វារដែលបើកចោលនោះឯង ឬកាត់ជញ្ជាំង លួចកណ្ឌៈទៅប៉ុន្មាន ព្រោះការធ្វេសប្រហែសរបស់លោកជាបច្ច័យ កណ្ឌៈប៉ុណ្ណោះជាសំណាងដល់ភិក្ខុនាយឃ្លាំងនោះឯង ។ ចំណែកអាចារ្យពួកខ្លះពោលថា ក្នុងវេលាក្តៅ នឹងបើកបង្អួចដេកក៏គួរ ។ តែកាលបន្ទោបង់ឧច្ចារបស្សាវៈហើយ ទៅក្នុងទីដទៃ ក្នុងកាលឧបចារៈនោះមិនមាន រាប់ថា ផុតវិស័យ ព្រោះលោកតាំងនៅក្នុងចំណែកជាអ្នកជំងឺ ព្រោះហេតុនោះ មិនជាសំណាង ។ ចំណែកភិក្ខុណា ត្រូវកម្តៅខាងក្នុងបៀតបៀន ទើបបិទទ្វារឲ្យជារបស់រក្សាល្អ ហើយចេញទៅខាងក្រៅ ។ ពួកចោរចាប់ភិក្ខុនោះបាន ហើយបញ្ជាថា ចូរបើកទ្វារ លោកមិនគួរបើក រហូតដល់

៣ ដង ។ កាលពួកចោរនាំពូថៅជាដើម គំរាមថា បើលោកមិនព្រមបើក ពួកយើងនឹងសម្លាប់ចោលផង ដោយទម្លាយទ្វារលួចបរិក្ខារទៅផង ទើបលោកបើកឲ្យ ដោយធ្វើទុកក្នុងចិត្តថា បើអញស្លាប់ សេនាសនៈសង្ឃ ក៏វិនាស មិនមានគុណឡើយ ដូច្នេះ រមែងគួរ ។ ក្នុងអធិការនេះ អាចារ្យពួកខ្លះពោលថា មិនមែនជាសំណាង ព្រោះផុតវិស័យ ។ បើភិក្ខុអាគន្តុកៈអង្គខ្លះបើកសោ ឬបើកទ្វារទុក ពួកចោរលួចកណ្ឌៈទៅប៉ុនណា កណ្ឌៈប៉ុណ្ណោះ ជាសំណាងដល់អាគន្តុកៈនោះ ។ គន្លឹះយន្ត និងសោជារបស់ដែលសង្ឃទុក ឲ្យដើម្បីប្រយោជន៍ដល់ការរក្សាឃ្លាំង ។ ភណ្ឌាគារិកភិក្ខុ ដាក់ត្រឹមតែគន្លឹះហើយសិង ។ ពួកចោរបើកចូលទៅលួចបរិក្ខារ ជាសំណាងដល់លោកពិត ។ តែបើភណ្ឌាគារិកភិក្ខុនោះ ដាក់រនុក និងសោ ហើយសិង បើពួកចោរមកបញ្ជាថា ចូរបើក លោកបដិបត្តិក្នុងពាក្យរបស់ពួកចោរនោះ តាមន័យមុននោះឯង ។ កាលភិក្ខុរក្សាឃ្លាំងនោះ រក្សាយ៉ាងនោះហើយ ទើបដេក ពួកចោរទម្លាយជញ្ជាំង ឬដំបូល ឬជីកដីចូលលួចទៅ មិនជាសំណាងដល់លោកឡើយ ។ បើព្រះថេរៈដទៃនៅក្នុងភណ្ឌាគារ កាលទ្វារបើក លោកកាន់យកបរិក្ខារចំណែកផ្ទាល់ខ្លួនទៅ ភណ្ឌាគារិកមិនប្រយ័ត្នទ្វារ ក្នុងកាលព្រះថេរៈទាំងនោះទៅហើយ បើរបស់ណាមួយក្នុងឃ្លាំងនោះត្រូវលួចទៅ ជាសំណាងដល់ភិក្ខុអ្នករក្សាឃ្លាំងប៉ុណ្ណោះ ព្រោះអ្នករក្សាឃ្លាំងជាធំ ។ ចំណែកពួកព្រះថេរៈគប្បីជាបក្ខពួក ។ នេះជាសាមីចិកម្មក្នុងរឿងឃ្លាំងនោះ ។ តែបើភិក្ខុអ្នករក្សាឃ្លាំងប្រាប់ថា សូមពួកលោកឈរទទួលបរិក្ខាររបស់ពួកលោកខាងក្រៅ

ចុះ កុំចូលមកឡើយ ហើយព្រះថេរៈឡេះឡោះមួយអង្គ ក្នុងពួកព្រះថេរៈទាំងនោះ មួយអន្ទើដោយសាមណេរ និងឧបដ្ឋាកទាំងឡាយ បើកឃ្លាំងចូលទៅអង្គុយ និងដេក ភណ្ឌៈបាត់បង់ទៅប៉ុនណា ជាសំណងដល់ព្រះថេរៈនោះទាំងអស់ ។ ចំណែកភណ្ឌាគារិកភិក្ខុ និងព្រះថេរៈដ៏សេស គប្បីជាបក្ខពួក ។ ភណ្ឌាគារិកភិក្ខុនោះឯង បបួលពួកសាមណេរឡេះឡោះ និងពួកឧបដ្ឋាកទៅអង្គុយ និងដេកក្នុងឃ្លាំង ទ្រព្យណាក្នុងឃ្លាំងនោះបាត់ទៅ របស់ទាំងអស់នោះ ជាសំណងដល់ភណ្ឌាគារិកភិក្ខុប៉ុណ្ណោះ ។ ព្រោះហេតុនោះ ភណ្ឌាគារិកភិក្ខុប៉ុណ្ណោះគួរស្នាក់នៅក្នុងឃ្លាំងនោះ ។ ភិក្ខុដ៏សេស គួរនៅស្នាក់នៅត្រង់មណ្ឌប ឬគល់ឈើ ឬមិនគួរស្នាក់នៅក្នុងឃ្លាំងដោយប្រការ ដូច្នេះ ។

ម្យ៉ាងទៀត ភិក្ខុពួកណា ទុកដាក់បរិក្ខាររបស់ពួកភិក្ខុដែលជាសភាគៈគ្នាទុកក្នុងបន្ទប់ ដែលជាលំនៅវៀងៗ ខ្លួន កាលបរិក្ខារបាត់ទៅ ភិក្ខុពួកណារក្សាទុក ជារបស់សំណងដល់ភិក្ខុទាំងនោះឯង ។ ចំណែកភិក្ខុក្រៅអំពីនេះគួរជាបក្ខពួក ។ តែបើសង្ឃប្រាប់ឲ្យប្រគេនបបរ និងភត្តដល់ភណ្ឌាគារិកភិក្ខុក្នុងវិហារនោះឯង ហើយភណ្ឌាគារិកភិក្ខុអង្គនោះ ចូលទៅកាន់ស្រុកដើម្បីភិក្ខាចារ ទ្រព្យបាត់ទៅ ភណ្ឌាគារិកភិក្ខុអង្គនោះឯងជាអ្នកសង ។ សូម្បីភិក្ខុដែលទទួលនាទីយាមវិហារ ដែលពួកភិក្ខុអ្នកចូលទៅត្រាច់បិណ្ឌបាត តែងតាំងទុកដើម្បីរក្សាអតិរេកចីវរ បានបបរ និងភត្ត ឬអាហារដូចគ្នា ក៏នៅតែទៅបិណ្ឌបាត ទ្រព្យណាក្នុងវិហារនោះបាត់ទៅ ទ្រព្យទាំងអស់នោះ ភិក្ខុនោះត្រូវសង ។ ទ្រព្យនោះឯង មិនមែនគ្រាន់តែសងតែម្យ៉ាងនោះទេ របស់ណា

បាត់ទៅ ព្រោះការប្រមាទរបស់ភិក្ខុអ្នកយាមវិហារនោះជាបច្ច័យ ទ្រព្យទាំងនោះជារបស់ដែលត្រូវសងដល់លោក ដូចភណ្ឌាគារិកភិក្ខុដូច្នោះ ។ បើជាវិហារធំ កាលភិក្ខុដើរទៅដើម្បីរក្សាត្រង់ចំណែកមួយ ទ្រព្យដែលរក្សាទុកក្នុងមួយកន្លែងទៀត ពួកចោរយកទៅ រមែងមិនជាសំណង ព្រោះជាហេតុផុតវិស័យ ។ ក្នុងទីដូច្នោះ លោកគួររក្សាបរិក្ខារទាំងឡាយទុកក្នុងប្រជុំនៃភិក្ខុទាំងពួង ហើយអង្គុយកណ្ដាលវិហារ ឬគប្បីតាំងភិក្ខុអ្នកទទួលនាទីយាមវិហារទុក ២-៣ អង្គ ។ បើភិក្ខុទាំងឡាយមិនជាអ្នកប្រមាទ ឃ្មាំរវាំងប្រយ័ត្នខាងនេះ និងខាងនោះ ទ្រព្យណាមួយបាត់ទៅ ក៏មិនជាវត្ថុដែលត្រូវសងដល់ភិក្ខុទាំងនោះ ។ ទ្រព្យដែលពួកចោរចងភិក្ខុ អ្នកទទួលនាទីរក្សាវិហារទុក ហើយយកទៅក្ដី ទ្រព្យដែលត្រូវលួចទៅដោយផ្លូវដទៃ កាលភិក្ខុទទួលនាទីយាមវិហារ ដើរជ្រួសផ្លូវពួកចោរទៅក្ដី មិនជាសំណងដល់លោកទាំងនោះ ។ បើយាគូ និងភត្ត ឬអាហារដែលគប្បីប្រគេនក្នុងវិហារ មិនមានដល់ភិក្ខុដែលទទួលនាទីរក្សាវិហារ នឹងតាំងស្លាកយាគូ ២-៣ កន្លែង ដែលបែងអំពីលាភដែលភិក្ខុទាំងនោះគប្បីបាន ហើយសលាកភត្តល្មមដល់ភិក្ខុអ្នកនៅចាំវិហារទាំងនោះក៏គួរ តែមិនគួរតាំងឲ្យជាប្រចាំ ។ ព្រោះថា ពួកអ្នកស្រុក នឹងមានការក្ដៅក្រហាយថា ពួកភិក្ខុអ្នកទទួលនាទីចាំវិហារប៉ុណ្ណោះ រមែងឆាន់ភត្តរបស់ពួកយើង ។ ព្រោះហេតុនោះ ទើបគួរផ្លាស់ប្ដូរវារៈគ្នា ។ បើពួកភិក្ខុដែលជាសភាគៈគ្នា របស់ភិក្ខុអ្នកទទួលវារៈយាមវិហារទាំងនោះ នាំសលាកភត្តមកប្រគេន សេចក្ដីនោះជាការល្អ បើមិននាំមកប្រគេន គួរឲ្យភិក្ខុទាំង-

ឡាយទទួលភារៈ ហើយឲ្យនាំមកប្រគេនចុះ ។ បើភិក្ខុដែលទទួលនាទីរក្សាវិហារ កាលបានទទួលស្លាកយាគូ ២-៣ កន្លែង និងសលាកភត្ត ៤-៥ កន្លែងជានិច្ច នៅតែទៅបិណ្ឌបាត ទ្រព្យបាត់បង់ទៅទាំងអស់ ជាសំណាងដល់លោក ដូចភណ្ឌាគារិកភិក្ខុ ដូច្នោះ បើភត្ត ឬតម្លៃសម្រាប់ភត្តរបស់សង្ឃដែលគប្បីប្រគេនដល់ភិក្ខុអ្នកយាមវិហារមិនមាន ភិក្ខុទទួលយកតាមវារៈយាមវិហារហើយ ទើបឲ្យនិស្សិតវៀងៗ ខ្លួន ជួយបដិបត្តិ នឹងមិនទទួលយកវារៈដែលមកដល់ រមែងមិនបាន គួរធ្វើដូចភិក្ខុដទៃធ្វើដូច្នោះឯង ។ តែបើភិក្ខុណាមិនមានសម្លាញ់ ឬមិត្រ មិនមានភិក្ខុដែលពេញចិត្តគ្នា ដែលនឹងនាំភត្តមកឲ្យ ភិក្ខុទាំងឡាយមិនគួរឲ្យវារៈដល់ភិក្ខុបែបនោះ ។ ភិក្ខុទាំងឡាយតាំងចំណែកណាទុកក្នុងវិហារ ដើម្បីប្រយោជន៍ជាស្បៀង គួរតាំងភិក្ខុដែលទទួលយកចំណែកនោះ ចិញ្ចឹមជីវិត ( ឲ្យជាអ្នកទទួលវារៈ ) ។ ភិក្ខុណាមិនទទួលយកចំណែកនោះចិញ្ចឹមជីវិត មិនគួរឲ្យភិក្ខុនោះទទួលវារៈ ។ ភិក្ខុទាំងឡាយតែងតាំងភិក្ខុទុកក្នុងវិហារ ដើម្បីឲ្យរក្សាផ្លែឈើតូចធំ លុះបដិបត្តិរក្សាហើយ ក៏បែកគ្នាឆាន់តាមគ្រានៃផ្លែឈើ ។ ភិក្ខុដែលឆាន់ផ្លែឈើទាំងនោះ គួរតាំងឲ្យទទួលវារៈ ។ ភិក្ខុអ្នកមិនអាស្រ័យ ( ផ្លែឈើនោះ ) ចិញ្ចឹមជីវិត មិនគួរឲ្យទទួលវារៈ ។ ភិក្ខុទាំងឡាយតែងតាំងភិក្ខុទុកដើម្បីឲ្យរក្សាសេនាសនៈ គ្រែ តាំង និងគ្រឿងកម្រាល គួរតាំងភិក្ខុដែលនៅក្នុងអាវាសចំណែកភិក្ខុដែលកាន់អព្ភោកាសិកធុតង្គក្តី កាន់យករុក្ខមូលិកធុតង្គក្តី មិនគួរឲ្យទទួលវារៈ អាចារ្យពួកខ្លះពោលថា ភិក្ខុមួយអង្គដែលជានវកភិក្ខុ តែលោក

ជាពហុស្សូត បង្រៀនធម៌ ឲ្យនូវការសាកសួរ ប្រាប់បាលី សម្ដែងធម្មកថា ដល់ភិក្ខុជាច្រើនផង ជួយការៈរបស់សង្ឃផង ភិក្ខុនេះ កាលចាន់លាភក្ដី នៅក្នុងអាវាសក្ដី មិនគួរឲ្យទទួលភារៈ គួរជ្រាបថា ជាបុគ្គលវិសេស ។ តែភិក្ខុដែលរក្សារោងឧបោសថ ឬទីរក្សាព្រះបដិមា គួរឲ្យបបរ និងភត្តជាទ្វេគុណ អន្ដរមួយនាឡិរាល់ថ្ងៃ ត្រៃចីវរប្រចាំឆ្នាំ កប្បិយភណ្ឌដែលមានតម្លៃ ១០-២០ កហាបណៈ ។ កាលភិក្ខុបានទទួលបបរ និងភត្តនោះឯង ទ្រព្យណាមួយក្នុងរោងឧបោសថ ឬទីរក្សាព្រះបដិមានោះបាត់បង់ទៅ ព្រោះការប្រមាទ ជាសំណងដល់ភិក្ខុទាំងអស់ តែទ្រព្យដែលពួកចោរចងខ្នងលោកទុក ហើយរឹបជាន់យកទៅដោយកម្លាំង រមែងមិនជាទ្រព្យដែលត្រូវសងសម្រាប់លោក ។ ការឲ្យរក្សាទ្រព្យរបស់ចេតិយទុករួមជាមួយទ្រព្យរបស់ចេតិយខ្លួនឯង ឬជាមួយទ្រព្យរបស់សង្ឃ ក្នុងរោងឧបោសថជាដើមនោះ សមគួរ តែការដែលនឹងឲ្យរក្សាទ្រព្យ របស់សង្ឃទុករួមជាមួយទ្រព្យរបស់ចេតិយ មិនសមគួរ ។ តែទ្រព្យឯណាដែលជារបស់សង្ឃ ដែលរក្សាជាមួយទ្រព្យរបស់ចេតិយ ទ្រព្យរបស់សង្ឃនោះ កាលឲ្យរក្សារបស់ចេតិយទុកហើយ ក៏ជាការរក្សាទុកល្អហើយនោះឯង ព្រោះដូច្នោះ ការរក្សាទុកយ៉ាងនោះ គួរ ។ កាលភិក្ខុរក្សាទីកន្លែងទាំងឡាយ មានរោងឧបោសថទាំងឡាយតាមបក្ខវារៈ ទ្រព្យដែលបាត់ទៅ ព្រោះអំណាចការប្រមាទ រមែងជាសំណងដូចគ្នា ដូច្នេះឯង ។

ពោលអំពីទ្រព្យដែលគេផ្ញើ ចប់

# ពោលអំពីដែនគយ

[ ១១០ ] ជនទាំងឡាយ រមែងបង់ភាសីអំពីទីនោះ ព្រោះហេតុនោះ ទីនោះ ឈ្មោះថា **សុង្កឃាត** ទីជាដែនបង់ភាសី ។ ពាក្យថា **សុង្កឃាត** ជាឈ្មោះរបស់ដែនគយ ។ ពិតហើយ ដែនគយនោះ លោកហៅថា **សុង្កឃាត** ព្រោះជាទីដែលជនទាំងឡាយ កាលមិនព្រមឲ្យរបស់គួរជាភាសី ជាតម្លៃភាសី នាំចេញទៅអំពីទីនោះ ឈ្មោះថា ផ្តាច់ពន្ធ គឺញុំាងសួយរបស់ព្រះរាជាឲ្យសាបសូន្យទៅ ។ ពីរបទថា **តត្រ បវិសិត្វា** សេចក្តីថា ចូលទៅក្នុងដែនគយ ដែលព្រះរាជាទ្រង់ធ្វើការកំណត់ទុកក្នុងទីទាំងឡាយ មានប្រកក្នុំជាដើមនោះ ។

ពីរបទថា **រាជគ្គំ ភណ្ឌំ** បានដល់ ភណ្ឌៈដែលគួរដល់ព្រះរាជា ។ អធិប្បាយថា ភាសីមានតម្លៃ ៥ មាសក ឬច្រើនជាង ៥ មាសក ជារបស់ដែលខ្លួនគួរថ្វាយដល់ព្រះរាជាអំពីភណ្ឌៈណា គឺភណ្ឌៈនោះ ។ បាឋៈថា **រាជគ្គំ** ក៏មាន ។ អត្ថយ៉ាងនេះដូចគ្នា ។ ភិក្ខុមានថេយ្យចិត្ត គឺញុំាងថេយ្យចិត្តឲ្យកើតឡើងថា អញនឹងមិនឲ្យពន្ធដល់ព្រះរាជាអំពីភណ្ឌៈនេះ ហើយស្ទាបអង្អែលភណ្ឌៈនោះ ត្រូវអាបត្តិទុក្កដ ហុចអំពីទីដែលដាក់ទុកក្នុងថង់យាម ឬចងជាប់ត្រង់ជើង ទុកក្នុងទីបិទបាំង ត្រូវថុល្លច្ច័យ កិរិយាដែលឲ្យឃ្លាតចាកឋាន ឈ្មោះថា មិនទាន់មាន ព្រោះដែននៃបារាជិក ព្រះដ៏មានព្រះភាគ ទ្រង់កំណត់ដោយដែនគយ ភិក្ខុញុំាងជំហានទី ២ ឲ្យកន្លងដែនកំណត់គយទៅ ត្រូវអាបត្តិបារាជិក ។

ពីរបទថា **ពហិ សុង្កឃាតំ ឋាបេតិ** សេចក្តីថា ភិក្ខុនៅខាងក្នុងនោះ

ឯង ឃើញរាជបុរសទាំងឡាយក្មេងខ្លួន ទើបបោះទៅ ដើម្បីឲ្យធ្លាក់ទៅខាងក្រៅ បើកណ្ឌៈនោះធ្លាក់ចុះបានពិតប្រាកដ លុះរបូតផុតអំពីដៃ ភិក្ខុត្រូវអាបត្តិបារាជិក ។ បើកណ្ឌៈនោះប៉ះដើមឈើ ឬជន្លត់ឈើ ឬត្រូវកម្លាំងខ្យល់ខ្លាំងក្តួចទៅធ្លាក់នៅខាងក្នុងដែននោះឯងទៀត នៅរក្សានៅឡើយ ។ លោកចាប់បោះទៅទៀត ត្រូវអាបត្តិបារាជិក តាមន័យដែលពោលហើយខាងដើមនោះឯង ។ បើកណ្ឌៈនោះធ្លាក់ត្រង់ផែនដី ហើយរមៀលចូលមកខាងក្នុងទៀតលោកត្រូវអាបត្តិបារាជិកដូចគ្នា ។ ចំណែកក្នុងកុរុន្ទី និងសង្ខេបអដ្ឋកថាពោលទុកថា បើកណ្ឌៈនោះធ្លាក់ខាងក្រៅ ឈប់ហើយ ទើបរមៀលចូលទៅលោកត្រូវអាបត្តិបារាជិក ។ បើមិនទាន់ឈប់ ហើយរមៀលចូលទៅ នៅរក្សានៅឡើយ ។ ភិក្ខុនៅខាងក្នុងប្រើដៃ ឬជើង ឬឈើច្រត់ ធ្លុះឲ្យរមៀលទៅ ឬឲ្យអ្នកដទៃប្រមៀលទៅ បើកណ្ឌៈនោះមិនឈប់ រមៀលចេញទៅត្រូវបារាជិក ។ កណ្ឌៈនោះឈប់ខាងក្នុងហើយ ទើបចេញទៅខាងក្រៅ នៅរក្សានៅឡើយ ។ កណ្ឌៈដែលភិក្ខុទុកខាងក្នុង ដោយគិតថា នឹងរមៀលទៅឯង ឬឲ្យអ្នកដទៃធ្វើឲ្យរមៀល ក្រោយមក ទ្រព្យនោះក៏រមៀលឯង ឬអ្នកដទៃប៉ះឲ្យរមៀលចេញទៅខាងក្រៅ នៅរក្សានៅឡើយដូចគ្នា ។ តែក្នុងកណ្ឌៈដែលភិក្ខុទុកដោយចិត្តបរិសុទ្ធ ហើយរមៀលចេញទៅយ៉ាងនោះ មិនមានពាក្យដែលគប្បីពោលឡើយ ។ ភិក្ខុធ្វើកញ្ចប់ពីរកញ្ចប់ ឲ្យជាប់គ្នាតែមួយទុកក្នុងរវាងដែនរបស់គយ បើតម្លៃពន្ធក្នុងកញ្ចប់ក្រៅបានតម្លៃមួយបាទសូម្បីយ៉ាងនោះ កញ្ចប់ក្នុងនៅរក្សាទុកបាន ព្រោះទាក់ទងដោយការជាប់គ្នា

ជាមួយកញ្ចប់ក្រៅពីនោះ ។ តែបើលោកផ្លាស់កញ្ចប់ដែលនៅក្នុងទៅខាងក្រៅ ត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងអម្រែកដែលភិក្ខុធ្វើឲ្យជាប់គ្នា ហើយដាក់ទុក ក៏មានន័យដូចគ្នា ។ តែបើកណ្តៈនោះ ជារបស់ដែលមិនបានចង គ្រាន់តែពាក់លើចុងដងរែកប៉ុណ្ណោះ ត្រូវអាបត្តិបារាជិក ។ ភិក្ខុដាក់ក្នុងយាន ឬលើខ្នងសេះជាដើមដែលកំពុងទៅ ដោយគិតក្នុងចិត្តថា កណ្តៈនេះសេះនឹងត្រូវនាំចេញទៅខាងក្រៅ កាលកណ្តៈនោះ ត្រូវនាំចេញទៅហើយ អវហាររមែងមិនមាន សូម្បីកណ្តទេយ្យក៏មិនមាន ។ ព្រោះហេតុអ្វី ព្រោះព្រះរាជាកំណត់ទុកថា ចូរបបួតពន្ធដល់មនុស្សដែលចូលមកក្នុងទីនេះ ពិតហើយ កណ្តៈនេះភិក្ខុតាំងទុកក្រៅដែនគយ ហើយលោកមិនបាននាំទៅ ព្រោះដូច្នោះ ទើបមិនជាកណ្តទេយ្យ មិនត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងកណ្តៈដែលដាក់ក្នុងយានកំពុងចតជាដើម កាលយានជាដើមនោះទៅ វៀរប្រយោគរបស់ភិក្ខុនោះ សូម្បីមានថេយ្យចិត្ត អវហាររមែងមិនមានដូចគ្នា តែបើភិក្ខុដាក់ហើយ បរយានជាដើមទៅឲ្យឈានកន្លងទៅក្តី ឈរខាងមុខហើយ ហៅសេះថា មកចុះ រើយ ដូច្នេះ ព្រោះភាពដែលខ្លួនសន្សំទុកក្នុងមន្តទាំងឡាយ មានមន្តហៅដំរីជាដើមក្តី ត្រូវអាបត្តិបារាជិក ក្នុងខណៈឈានកន្លងដែនទៅ ។ ក្នុងឯឡកលោមសិក្ខាបទ មិនត្រូវអាបត្តិក្នុងឋានៈនេះ គឺភិក្ខុឲ្យអ្នកដទៃនាំរោមចៀមទៅ ក្នុងសិក្ខាបទនេះត្រូវអាបត្តិបារាជិក ។ ក្នុងឯឡកលោមសិក្ខាបទនោះ ភិក្ខុដាក់រោមចៀមក្នុងយាន ឬ កណ្តៈរបស់ជនដទៃដែលមិនដឹង ឲ្យកន្លង ៣ យោជន៍ទៅ រោមចៀមជានិស្សគ្គិយ ព្រោះហេតុនោះ ភិក្ខុត្រូវបាចិត្តិយ ក្នុង

សិក្ខាបទនេះ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុបង់ពន្ធត្រង់ដែនគយ មុនហើយ សឹមទៅ គួរ ។

ភិក្ខុមួយអង្គធ្វើការចងចិត្តទុកហើយទៅ ដោយគិតថា បើមេគយទារថា លោកម្ចាស់ចូរឲ្យតម្លៃពន្ធ អញក៏នឹងឲ្យ បើពួកគយមិនទារ អញនឹងទៅ ដូច្នេះ មេគយម្នាក់បានឃើញភិក្ខុអង្គនោះ ទើបពោលថា ភិក្ខុអង្គនេះ នឹងទៅ ពួកលោកចូរដកតម្លៃពន្ធភិក្ខុនោះ ។ មេគយម្នាក់ទៀត ពោលឡើងថា បព្វជិតមានតម្លៃពន្ធអំពីណា និមន្តទៅចុះ ដូច្នេះ ជាការបានការអនុញ្ញាត ភិក្ខុគួរទៅចុះ ។ ភិក្ខុទាំងឡាយដែលមិនទាន់បានបង់តម្លៃពន្ធជាមុន ទៅមិនគួរ ព្រោះហេតុនោះ កាលភិក្ខុពោលថា ទទួលយកចុះ ឧបាសក ដូច្នេះក្តី កាលមេគយនិយាយថា កាលយើងដកតម្លៃពន្ធរបស់ភិក្ខុ នឹងត្រូវយកបាត្រ និងចីវរ នឹងមានប្រយោជន៍អ្វី ដោយបាត្រ និងចីវរនោះ និមន្តទៅចុះ ដូច្នេះក្តី ជាការបានអនុញ្ញាតដូចគ្នា ។ បើពួកគយដេកលក់ក្តី លេងបាស្កាក្តី ឬទៅក្នុងទីណាអស់ក្តី ហើយភិក្ខុនេះស្រែកហៅថា ពួកលោកគយទៅណាអស់ហើយ ក៏មិនប្រទះ គឺ បានអនុញ្ញាតដូចគ្នា បើភិក្ខុទៅដល់ដែនកាស៊ីហើយ ភ្លេចខ្លួន គិតដល់រឿងណាមួយក្តី កំពុងស្វាធ្យាយក្តី តាមប្រកបមនសិការក្តី ត្រូវភយន្តរាយមានចោរ ដំរី រាជសីហ៍ និងខ្លាធំជាដើម ស្ទុះដេញជាប់តាមទៅក្តី ឃើញមេឃខ្មៅឡើងហើយ បំណងនឹងចូលទៅសាលាខាងមុខក្តី កន្លងស្ថានទីនោះទៅ ជាការបានគោលអាងដូចគ្នា ។

ក្នុងពាក្យថា ភិក្ខុនាំទ្រព្យរត់ពន្ធរំលងដែនគយនេះ លោកពោលទុក

ក្នុងកុរុន្ទីអដ្ឋកថាថា ភិក្ខុឈានចុះកាន់ឧបចារៈ ហើយចៀសទៅក៏ដោយ ក៏ជាអវហារនោះឯង ។ តែក្នុងមហាអដ្ឋកថា ពោលទុកថា កាលភិក្ខុសម្លឹងឃើញទោសតែម្យ៉ាងថា ពួករាជបុរសបៀតបៀនអ្នករត់ពន្ធ ដូច្នេះ ទើបឈានចុះកាន់ឧបចារៈ ហើយគេចចេញទៅ ត្រូវអាបត្តិទុក្កដ កាលមិនបានឈានចូលដែន គេចវាងទៅ មិនត្រូវអាបត្តិ ។ ពាក្យក្នុងមហាអដ្ឋកថានេះ រមែងសមដោយព្រះបាលី ។ ក្នុងដែនគយនេះ គួរកំណត់ឧបចារៈទុក ២ លេឌ្ឌុ-បាត ដូច្នេះឯង ។

ពោលអំពីដែនគយ ចប់

## ពោលអំពីសត្វមានជីវិត

[១១១] បន្ទាប់អំពីកថាពោលដោយដែនគយនេះទៅ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសត្វមានជីវិត ដែលល្មមគួរដល់អវហារដោយចំណែកមួយ ទើបត្រាស់ថា **មនុស្សទាណោ** ជាដើម ។ កាលភិក្ខុលួចមនុស្សដែលនៅមានជីវិតនោះ ដែលជាអ្នកជា ( ទាសៈដែលម្ចាស់ឲ្យរួចពីបំណុល ) មិនជាអវហារឡើយ ។ សូម្បីមនុស្សជាអ្នកជាណា ត្រូវមាតា ឬបិតាយកទៅបញ្ចាំទុក ឬខ្លួនឯងយកខ្លួនជាការធានាទុក ហើយបានកាន់យកទ្រព្យ ៥០-៦០ កហាបណៈទៅ កាលភិក្ខុលួចយកមនុស្សដែលជាអ្នកជានោះទៅ ក៏មិនជាអវហារ ។ ចំណែកទ្រព្យ រមែងបន្ថែមការប្រាក់ឡើងក្នុងស្ថានដែលគេទៅ តែកាលភិក្ខុលួចទាសៈនោះឯង ជាទាសៈដែលកើតក្នុងផ្ទះ ទាសៈដែលលោះយកមក និងទាសៈដែលត្រូវនាំមកជាឈ្លើយ រមែងជាអវហារ ។ ពិតហើយ ព្រះដ៏មានព្រះភាគ ទ្រង់សំដៅយកទាសៈដែលកើតក្នុងផ្ទះម្ចាស់បំណុលនោះឯង ទើបត្រាស់ទុកថា សត្វមានជីវិត តថាគតហៅមនុស្សដែលនៅមានជីវិតដូច្នេះ ។

### ទាសៈ ៣ ពួក

បណ្ដាទាសៈទាំងនេះ ទាសៈដែលកើតក្នុងផ្ទៃទាសីក្នុងផ្ទះ គប្បីជ្រាបថា **អន្តោជាតក** ទាសៈដែលកើតខាងក្នុង ទាសៈដែលទិញមកដោយទ្រព្យ គប្បីជ្រាបថា **ធនក្កីតក** ទាសៈដែលលោះមកដោយទ្រព្យ បុគ្គលដែលត្រូវគៀងមកអំពីប្រទេសផ្សេង ធ្វើជាទាសៈ គប្បីជ្រាបថា **ករមរានីត** ទាសៈដែលនាំមកជាឈ្លើយ ភិក្ខុគិតថា អញនឹងលួចមនុស្សដែលមានជីវិតបែបនេះ

ទៅ ហើយចាប់ពាល់ ត្រូវអាបត្តិទុក្កដ ។ កាលលោកចាប់ត្រង់ដៃ ឬជើង លើកឡើង ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ លោកប្រាថ្នានឹងលើកគេចទៅ ឲ្យកន្លងចាកទីដែលឈរនៅ សូម្បីត្រឹមមួយចម្រៀកសក់ទៅ ត្រូវអាបត្តិបារាជិក ។ លោកចាប់ត្រង់សក់ ឬដើមដៃទាំងពីរទាញទៅ គប្បីកាត់អាបត្តិតាមជំហាន ។ ភិក្ខុគិតថា អញនឹងនាំដើរទៅ សម្គុត ឬវាយបណ្តើរ ពោលថា ឯងចូរទៅអំពីទីនេះ ។ កាលបុគ្គលនោះ ទៅកាន់ទិសាភាគ តាមដែលភិក្ខុនោះបញ្ជា ត្រូវអាបត្តិបារាជិកក្នុងជំហានទី ២ ។ ភិក្ខុពួកណា មានធុរៈរួមជាមួយភិក្ខុនោះ ត្រូវអាបត្តិបារាជិកក្នុងខណៈដូចគ្នានៃភិក្ខុនោះទាំងអស់ ។ ភិក្ខុឃើញដល់ទាសៈហើយ សួរដល់សុខទុក្ខ ឬមិនសួរក៏ដោយ ពោលថា ឯងចូរទៅ ចូរគេចទៅនៅជាសុខចុះ ។ បើទាសៈនោះ គេចទៅសោត ក្នុងជំហានទី ២ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុអន្លដទៃពោលនឹងទាសៈនោះដែលចូលមកកាន់សម្នាក់របស់ខ្លួនថា ឯងចូរគេចទៅ ។ បើភិក្ខុរាប់រយអង្គនិយាយនឹងទាសៈដែលចូលមកកាន់សម្នាក់រៀងៗ ខ្លួនតាមលំដាប់ ក៏ត្រូវអាបត្តិបារាជិកគ្រប់អង្គទាំងអស់ ។ ចំណែកភិក្ខុអង្គណា និយាយនឹងទាសៈដែលកំពុងតែរត់ទៅនោះឯងថា ឯងចូរគេចទៅទាន់ម្ចាស់របស់ឯង មិនទាន់ចាប់ឯងបាន ភិក្ខុអង្គនោះ មិនត្រូវអាបត្តិបារាជិកឡើយ តែបើលោកពោលនឹងទាសៈដែលកំពុងដើរសន្សឹមៗ ទៅ ឲ្យទាសៈនោះប្រញាប់ប្រញាល់រត់ទៅតាមពាក្យរបស់ភិក្ខុនោះ ត្រូវអាបត្តិបារាជិក បើភិក្ខុ ឃើញទាសៈដែលគេចទៅកាន់ស្រុក ឬដែនដទៃហើយ ដេញឲ្យគេចទៅអំពីទីនោះ ត្រូវអាបត្តិបារាជិក

ដូចគ្នា ។ ឈ្មោះថា អទិន្នាវមែងរួចផុតបានដោយបរិយាយ ។ ពិតហើយ ភិក្ខុអង្គណា ពោលយ៉ាងនេះថា ហេតុអ្វីឯងនៅទីនេះ ឯងគេចទៅមិនគួរឬ ឬពោលថា ឯងទៅក្នុងទីណាមួយហើយ មានជីវិត យ៉ាងសប្បាយមិនគួរឬ ឬពោលថា ពួកទាសៈ និងទាសីនាំគ្នាគេចទៅកាន់ ដែនឈ្មោះនោះហើយ រមែងរស់នៅយ៉ាងសប្បាយក្តី ហើយពួកទាសៈបាន ស្តាប់ពាក្យរបស់ភិក្ខុនោះ ក៏គេចទៅ រមែងមិនជាអវហារ ។ ចំណែកភិក្ខុណាពោលថា ពួកអាត្មានឹងទៅកាន់ដែនឈ្មោះនោះ អ្នកទៅក្នុងប្រទេសនោះហើយ រស់នៅយ៉ាងសប្បាយ បើពួកអ្នកទៅព្រមជាមួយពួកអាត្មា នឹងមិនមានសេចក្តីលំបាកដោយស្បៀងដើរផ្លូវជាដើមក្នុងរវាងផ្លូវ ដូច្នេះហើយ នាំយកទាសៈដែលមកព្រមនឹងខ្លួនទៅ ភិក្ខុនោះ មិនត្រូវអាបត្តិបារាជិកដោយថេយ្យចិត្ត ទាំងមិនមែនជាអវហារឡើយ ដោយអំណាចនៃការដើរផ្លូវ ។ បើមានពួកចោរស្ទាក់នៅក្នុងចន្លោះផ្លូវ សូម្បីភិក្ខុពោលថា រុំយ ពួកចោរស្ទាក់ហើយ ឯងចូរប្រញាប់គេចទៅ ចូរប្រញាប់មក ដូច្នេះ អាចារ្យទាំងឡាយក៏មិនកាត់ជាអវហារ ព្រោះលោកពោលដើម្បីឲ្យរួចផុតអន្តរាយអំពីចោរ ដូច្នេះ ។

ពោលអំពីសត្វមានជីវិត ចប់

# ពោលអំពីសត្វគ្មានជើង

[ ១១២ ] បណ្តាសត្វឥតជើងទាំងឡាយ ដែលឈ្មោះថាពស់មានម្ចាស់ គឺពស់ដែលពួកអាយលម្ពាយជាដើមចាប់ទុក កាលឲ្យលេងសិល្បៈ រមែងបានតម្លៃមើល កន្ទះបាទខ្លះ មួយបាទខ្លះ មួយកហាបណៈខ្លះ កាលនឹងលែងចេញ ក៏ទទួលយកមាស និងប្រាក់ ហើយទើបលែងចេញ ។ ម្ចាស់ពស់ទាំងនោះទៅកាន់ឱកាសដែលភិក្ខុអង្គខ្លះអង្គុយ ហើយដាក់ទ្រុងពស់ទុក ដេកលក់ទៅក្តី ទៅក្នុងទីណាមួយដទៃក្តី ។ បើភិក្ខុនោះចាប់ទ្រុងនោះក្នុងស្ថានទីនោះ ដោយថេយ្យចិត្ត ត្រូវទុក្កដ ធ្វើឲ្យកម្រើកត្រូវថុល្លច្ច័យ ឲ្យឃ្លាតចាកឋានត្រូវអាបត្តិបារាជិក ។ បើលោកបើកទ្រុង ហើយចាប់ពស់ត្រង់ក ត្រូវអាបត្តិទុក្កដ លើកពស់ឡើងត្រូវថុល្លច្ច័យ កាលលើកឲ្យត្រង់ឡើងលើ គ្រាន់តែកន្ទុយពស់ផុតអំពីបាតទ្រុងត្រឹមមួយចុងសក់ ត្រូវអាបត្តិបារាជិក ។ បើលោកទាញសម្រូតទៅកៀន លុះកន្ទុយពស់ផុតអំពីមាត់ទ្រុងទៅ ត្រូវអាបត្តិបារាជិក ។ លោកបើកមាត់ទ្រុងចេញបន្តិច ហើយវាយ ឬស្រែកហៅឈ្មោះថា វ៉ុយ ចូរលូនចេញមក ហើយឲ្យលូនចេញមក ត្រូវអាបត្តិបារាជិក ។ កាលបើកចេញយ៉ាងនោះហើយ ទើបធ្វើសំឡេងកង្កែបយំ ឬធ្វើសំឡេងកណ្តុរយំ ឬរោយលាចក្តី ហើយស្រែកហៅចេញឈ្មោះ ឬផ្ទាត់ម្រាមដៃក្តី កាលពស់លូនចេញទៅ ដោយកិរិយាធ្វើសំឡេងជាដើមយ៉ាងនោះ ត្រូវអាបត្តិបារាជិក ។ កាលលោកមិនបានបើកមាត់ទ្រុង តែបានធ្វើកិរិយាយ៉ាងនោះ ពស់ឃ្លានខ្លាំងទើបអើតក្បាលឡើងបុកគម្របទ្រុង ធ្វើប្រហោង ហើយលូនគេចទៅ ត្រូវអាបត្តិបារាជិកដូចគ្នា ។ តែកាលលោកបើកមាត់ហើយ ពស់លូនចេញខ្លួន

ឯង រមែងជាកណ្ឌទេយ្យ ។ បើលោកបើកមាត់ក៏ដោយ មិនបានបើកក៏ដោយ តែបានធ្វើជាសំឡេងកង្អែប និងសំឡេងកណ្ដុរយំ ឬរោយលាជតែម្យ៉ាង ប៉ុណ្ណោះ មិនបានស្រែកហៅប្រាវព្វឈ្មោះ ឬមិនបានផ្ទាត់ម្រាមដៃ ព្រោះឃ្លាន ខ្លាំង ពស់គិតថា នឹងស៊ីកង្អែបជាដើម ទើបលូនចេញគេចទៅ ជាកណ្ឌទេយ្យ ដូចគ្នា ។ ក្នុងអធិការនេះ ត្រីតែម្យ៉ាង មកហើយ ដោយ **អបទ** សព្ទ ។ ពាក្យគប្បីពោលក្នុងត្រីនេះ ខ្ញុំបានពោលទុកហើយ ក្នុងកណ្ឌៈតាំងនៅក្នុងទឹក នោះឯង ។

**ពោលអំពីសត្វគ្មានជើង ចប់**

# ពោលអំពីសត្វជើងពីរ

[ ១១៣ ] បណ្តាសត្វជើងពីរទាំងឡាយ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងជំពូកសត្វជើងពីរ ដែលបុគ្គលណាមួយ អាចលួចយកទៅបាន ទើបត្រាស់ពាក្យថា **មនុស្សា បក្ខជាតា** ជាដើម ។ ចំណែកពួកទេវតា បុគ្គលណាមួយ មិនអាចលួចយកទៅបាន ។ ដែលឈ្មោះថា បក្សី ព្រោះអត្ថថា សត្វទាំងនោះ មានស្លាបកើតហើយ ។ សត្វមានស្លាបទាំងនោះមាន ៣ ពួក គឺមានរោម ជាស្លាបមួយពួក មានស្បែកជាស្លាបមួយពួក មានឆ្អឹងជាស្លាបមួយពួក បណ្តាសត្វទាំងនោះ ក្ងោក និងមាន់ជាដើម គប្បីជ្រាបថា មានរោមជាស្លាប ប្រចៀវជាដើម គប្បីជ្រាបថា មានស្បែកជាស្លាប កំភេមជាដើម គប្បីជ្រាបថា មានឆ្អឹងជាស្លាប ។ ក្នុងអធិការនេះ មនុស្ស និងបក្សីទាំងអស់នោះ មកហើយដោយ **ទ្វិបទ** សព្ទ សុទ្ធៗ ។ ចំណែកពាក្យដែលគប្បីពោលទុកក្នុងសត្វជើងពីរនេះ ខ្ញុំបានពោលទុកហើយ ក្នុងកណ្ឌៈដែលនៅក្នុងអាកាស និងសត្វមានជីវិតនោះឯង ដូច្នេះ ។

ពោលអំពីសត្វជើងពីរ ចប់

# ពោលអំពីសត្វជើង ៤

[ ១១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្វជើង ៤ ថា ប្រភេទនៃសត្វជើង ៤ ទាំងអស់ ដែលសល់មកអំពីព្រះបាលី គប្បីជ្រាបថា បសុសត្វ គឺសត្វចិញ្ចឹម ។ សត្វទាំងឡាយ មានដំរីជាដើម ប្រាកដច្បាស់ហើយ ។ បណ្ដាសត្វ មានដំរីជាដើមនោះ កាលភិក្ខុចាប់ពាល់ដំរីដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដ ធ្វើឲ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ចំណែកភិក្ខុអង្គណា មានកម្លាំងខ្លាំង ប្រើក្បាលទូលយកកូនដំរីដែលនៅតូច ត្រង់ផ្ចិតដំរីឡើង ព្រោះការស្រវឹងក្នុងកម្លាំង ឲ្យជើងទាំង ៤ និងប្រមោយផុតអំពីដីត្រឹមមួយចម្រៀកសក់ ភិក្ខុអង្គនោះ ត្រូវអាបត្តិបារាជិក ។ តែដំរីខ្លះ គេចងទុកក្នុងរោងដំរី ដំរីខ្លះឈរ មិនបានចងឡើយ ដំរីខ្លះឈរខាងក្នុងលំនៅ ដំរីខ្លះឈរត្រង់លានព្រះរាជវាំង ។

បណ្ដាដំរីទាំងនោះ ដំរីដែលចងត្រង់កទុកក្នុងរោងដំរី មានឋាន ៥ គឺ ចំណងត្រង់ក និងជើងទាំង ៤ ។ សម្រាប់ដំរីដែលគេយកសោដែក ចងទុកត្រង់ក និងជើងម្ខាង មានឋាន ៦ ។ ដំរីដែលគេចងទុកត្រង់ក និងជើងទាំងពីរ មានឋាន ៧ ។ គប្បីជ្រាបការធ្វើឲ្យកម្រើក និងឲ្យឃ្លាតចាកឋាន ដោយអំណាចនៃឋានទាំងនោះ ។ រោងដំរីទាំងមូលជាឋានរបស់ដំរីដែលគេមិនបានចង ក្នុងកាលឲ្យឈានកន្លងអំពីរោងដំរីនោះទៅ ត្រូវអាបត្តិបារាជិក ។ ផ្ទៃដីដែលនៅខាងក្នុងលំនៅទាំងមូលនោះឯង ជាឋានរបស់ដំរីដែលឈរខាងក្នុងលំនៅ ក្នុងកាលឲ្យកន្លងទ្វារលំនៅរបស់ដំរីនោះទៅ ត្រូវអាបត្តិបារាជិក ។ ព្រះនគរទាំងមូល ជាឋានរបស់ដំរីដែលឈរក្នុងលានព្រះរាជវាំង ក្នុងកាល

ឲ្យដីរនោះកន្លងទ្វារព្រះនគរទៅ ត្រូវអាបត្តិបារាជិក ។ ទីឈរនោះឯង ជាឋានរបស់ដីរដែលឈរខាងក្រៅព្រះនគរ ។ ភិក្ខុកាលលួចដីរនោះទៅ គប្បីកាត់អាបត្តិដោយជំហាន ។ សម្រាប់ដីរដែលដេក មានឋាន ១ ប៉ុណ្ណោះ ។ កាលភិក្ខុដេញដីរឲ្យក្រោកឡើង ដោយថេយ្យចិត្ត លុះដីរក្រោកឡើងហើយ ត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងសេះក៏មានវិនិច្ឆ័យដូចគ្នានេះឯង តែបើសេះនោះ ត្រូវគេលាមទុកត្រង់ជើងទាំង ៤ គប្បីជ្រាបថា មានឋាន ៨ ។ សូម្បីក្នុងអូដ្ឋក៏មានន័យដូច្នេះ ។ សូម្បីគោខ្វះ ជាសត្វដែលគេចងទុកជិតផ្ទះ គោខ្វះឈរ មិនបានចងឡើយ តែគោខ្វះ គេចងទុកក្នុងក្រោល គោខ្វះក៏ឈរមិនបានចងទុកឡើយ ។

បណ្តាគោទាំងនោះ គោដែលគេចងទុកជិតផ្ទះ មានឋាន ៥ គឺជើងទាំង ៤ និងចំណង ១ ។ ផ្ទះទាំងមូល ជាឋានរបស់គោដែលមិនបានចង ។ គោដែលគេចងទុកក្នុងក្រោល មានឋាន ៥ ។ ក្រោលទាំងមូលជាឋានរបស់គោដែលមិនបានចង ។ ភិក្ខុឲ្យគោនោះកន្លងហួសទ្វារក្រោលទៅ ត្រូវអាបត្តិបារាជិក ។ កាលភិក្ខុទម្លាយក្រោលលួចទៅ ឲ្យកន្លងហួសទ្វារក្រោលទៅ ត្រូវអាបត្តិបារាជិក ។ ភិក្ខុបើកទ្វារ ឬទម្លាយក្រោល ហើយឈរនៅខាងក្រៅ ហើយហៅគោចំណោម បញ្ឆោឲ្យគោចេញ ត្រូវអាបត្តិបារាជិក ។ សម្រាប់ភិក្ខុបង្ហាញមែកឈើដែលកាច់បាន ឲ្យគោឃើញ គោចេញមក ក៏មានន័យដូចគ្នានេះឯង ។ ភិក្ខុមិនបានបើកទ្វារ ក្រោលក៏មិនបានទម្លាយ គ្រាន់តែអង្រួនមែកឈើដែលកាច់បាន ហើយហៅគោមក គោលោតចេញមកដោយ

ការស្រែកឃ្វាន ត្រូវអាបត្តិបារាជិកដូចគ្នា ។ តែបើលោកបើកទ្វារ ឬទម្លាយក្រោលហើយ គោក៏ចេញមកខ្លួនឯង ជាភណ្ឌទេយ្យ ។ លោកបើកទ្វារ ឬមិនបានបើកក៏ដោយ ទម្លាយក្រោល ឬមិនបានទម្លាយក៏ដោយ គ្រាន់តែអង្រួនមែកឈើដែលកាច់បានតែម្យ៉ាង មិនបានហៅគោ គោដើរចេញមក ឬលោតចេញមក ព្រោះការស្រែកឃ្វាន ជាភណ្ឌទេយ្យដូចគ្នា ។ គោដែលគេលាមទុកកណ្ដាលស្រុក ឈរមួយ ដេកមួយ ។ គោដែលឈរមានឋាន ៥ គោដែលដេកមានឋាន ២ គប្បីជ្រាបការធ្វើឲ្យកម្រើក និងឃ្លាតចាកឋានដោយអំណាចនៃឋានទាំងនោះ ។ ភិក្ខុអង្គណាមិនបានដេញ ឲ្យគោដែលដេកក្រោកឡើង តែឲ្យសម្លាប់ក្នុងទីនោះឯង ជាភណ្ឌទេយ្យដល់ភិក្ខុអង្គនោះ ។ ឯស្រុកទាំងមូលជាឋានរបស់គោដែលឈរនៅក្នុងស្រុក ដែលបានប្រកបទ្វារព័ទ្ធទុកយ៉ាងល្អ សម្រាប់គោដែលឈរ ឬត្រាច់ទៅក្នុងស្រុក ដែលមិនបានព័ទ្ធរបង ស្ថានទីដែលជើងទាំង ៤ ជាន់ទៅ ជាន់មកនោះឯងជាឋាន ។ សូម្បីក្នុងសត្វទាំងឡាយ មានលា និងបសុសត្វជាដើមក៏មានវិនិច្ឆ័យដូចគ្នា ។

## ពោលអំពីសត្វជើង ៤ ចប់

## ពោលអំពីសត្វមានជើងច្រើន

[ ១១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្វមានជើងច្រើនថា បើវត្ថុបារាជិកពេញដោយក្អែបមួយ កាលភិក្ខុលួចក្អែបមួយនោះទៅដោយជើង ត្រូវអាបត្តិថុល្លច្ច័យ ៩៩ ត្រូវអាបត្តិបារាជិក ១ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

កថាពោលអំពីសត្វមានជើងច្រើន ចប់

## ពោលអំពីភិក្ខុកំណាត់ទ្រព្យឱ្យគេលួច

[ ១១៦ ] ដែលឈ្មោះថា ភិក្ខុដែលកំណាត់របស់ឲ្យគេលួច ព្រោះអត្ថថា ប្រព្រឹត្តថោកទាប ។ លោកអធិប្បាយថា រមែងតាមចូលទៅខាងក្នុងក្នុងទីកន្លែងនោះៗ ។

បទថា **ឱចរិត្វា** សេចក្តីថា ឃ្លាំកំណត់ គឺឃ្លាំសង្កេតមើល ។

បទថា **អាចិក្ខតិ** សេចក្តីថា ភិក្ខុក្លែងប្រាប់ទ្រព្យដែលរក្សាទុកមិនល្អក្នុងត្រកូលរបស់ជនដទៃ ឬក្នុងវិហារជាដើម ដែលមិនបានប្រុងប្រៀបក្នុងការរក្សាទុកដល់ភិក្ខុអន្តដទៃ ដែលអាចធ្វើចោរកម្មបាន ។

ច្រើនបទថា **អាបត្តិ ឧភិន្នំ ចារាជិកស្ស** សេចក្តីថា ភិក្ខុទាំងពីរអង្គត្រូវអាបត្តិបារាជិកយ៉ាងនេះ គឺក្នុងទ្រព្យដែលត្រូវលួចបានពិតប្រាកដ ភិក្ខុអ្នកបង្គាប់ ត្រូវក្នុងខណៈបង្គាប់ ភិក្ខុអ្នកទទួលបង្គាប់ក្រៅអំពីនេះ ត្រូវក្នុងខណៈ

ធ្វើឲ្យឃ្លាតចាកឋាន ។ ចំណែកភិក្ខុអន្ធណា ធ្វើបរិយាយដោយន័យជាដើម ថា ក្នុងផ្ទះមិនមានមនុស្សប្រុស គេរក្សាទ្រព្យឈ្មោះនោះទុកក្នុងទីមួយ មិនបានប្រុងប្រៀបក្នុងការរក្សាទុក ទាំងទ្វារក៏មិនបានបិទ អាចនឹងលួចយកទៅបាន តាមផ្លូវដែលទៅហើយនោះឯង ឈ្មោះថា បុគ្គលណាមួយ ដែលនឹងគប្បីទៅលួចយកទ្រព្យនោះ មកចិញ្ចឹមជីវិត ដូចជាកូនប្រុសមិនមាន ។ ភិក្ខុអន្ធដទៃបានស្តាប់ពាក្យនោះហើយ គិតថា ឥឡូវនេះ អញនឹងទៅលួចយក ( ទ្រព្យនោះ ) ទើបដើរទៅលួច ត្រូវអាបត្តិបារាជិក ដល់ភិក្ខុអន្ធនោះ ក្នុងខណៈដែលធ្វើឲ្យឃ្លាតចាកឋាន ។ ចំណែកភិក្ខុអន្ធនេះ មិនត្រូវអាបត្តិ ។ ពិតហើយ ភិក្ខុអ្នកធ្វើបរិយាយនោះ រមែងផុតចាកអទិន្នាទាន ដោយបរិយាយដូច្នេះ ។

ពោលអំពីភិក្ខុកំណត់ទ្រព្យឲ្យគេលួច ចប់

# ពោលអំពីភិក្ខុទទួលបញ្ញើ

[ ១១៧ ] ឈ្មោះថា ភិក្ខុទទួលបញ្ញើ ព្រោះអត្ថថា រក្សាទ្រព្យដែលគេនាំមកផ្ញើ ។ ភិក្ខុអង្គណាដែលជនដទៃពោលថា បពិត្រលោកម្ចាស់ ជួយមើលថែទ្រព្យនេះមួយរយៈ ទម្រាំខ្ញុំធ្វើកិច្ចឈ្មោះនេះហើយ ត្រឡប់មក បានរក្សាទ្រព្យដែលគេនាំមកក្នុងទីលំនៅរបស់ខ្លួន ។ ពាក្យថា **ឱណិរក្ខោ** នោះជាឈ្មោះរបស់ភិក្ខុដែលទទួលរបស់ផ្ញើនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ដែលឈ្មោះថា ភិក្ខុអ្នកទទួលបញ្ញើ បានដល់ ភិក្ខុអ្នករក្សាទ្រព្យដែលគេនាំមកផ្ញើ ដូច្នេះ ។ ក្នុងរឿងនោះ ភិក្ខុអ្នកទទួលបញ្ញើ មិនបានស្រាយកញ្ចប់ទ្រព្យ ដែលម្ចាស់ទ្រព្យចងទុកជាចំណាំឡើយ ដោយចំណែកច្រើនកាត់តែបាវ ឬកញ្ចប់ខាងក្រោមចេញហើយ កាន់យកត្រឹមតែបន្តិចបន្តួច ធ្វើការដេរជាដើមឲ្យដូចប្រក្រតីដើមវិញ សម្រាប់ភិក្ខុដែលគិតថាអញនឹងកាន់យកដោយអាការយ៉ាងនេះ ហើយធ្វើការចាប់ពាល់ជាដើម គប្បីជ្រាបថា ត្រូវអាបត្តិតាមសមគួរ ដូច្នេះឯង ។

អំពីភិក្ខុទទួលបញ្ញើ ចប់

## ពោលអំពីការបបួលគ្នាលួច

[ ១១៨ ] ការបបួលគ្នាលួច ឈ្មោះថា **សំវិធាវហារ** មានពាក្យអធិប្បាយថា ការលួចដែលធ្វើដោយការរួមគំនិតគ្នានិងគ្នា ។

បទថា **សំវិទហិត្វា** សេចក្តីថា ប្រឹក្សាគ្នា ដោយភាពជាអ្នករួមធុរៈគ្នា គឺដោយភាពជាអ្នករួមអធ្យាស្រ័យគ្នា ។

## ភិក្ខុច្រើនអង្គបបួលគ្នាទៅលួចទ្រព្យ

វិនិច្ឆ័យក្នុងសំវិធាវហារនោះ ដូច្នេះ ភិក្ខុច្រើនអង្គរួមគ្នា បបួលគ្នាថា ពួកយើងនឹងទៅផ្ទះឈ្មោះនោះ នឹងទម្លាយជំបូល ឬជញ្ជាំង ឬនឹងកាត់ទី ត លួចរបស់ ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុមួយអង្គលួចទ្រព្យបាន ក្នុងខណៈលើកកណ្ឌៈនោះឡើង ត្រូវអាបត្តិបារាជិកទាំងអស់អង្គ ។ ពិតហើយ សូម្បីក្នុងគម្ពីរបរិវារ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះថា ជន គឺភិក្ខុ ៤ អង្គ បបួលគ្នាលួចគរុភណ្ឌ ភិក្ខុ ៣ អង្គ ត្រូវអាបត្តិបារាជិក ភិក្ខុ ១ អង្គមិនត្រូវបារាជិកទេ ប្រស្នានេះលោកអ្នកឈ្លាសវៃទាំងឡាយ បានគិតមកហើយ អត្ថនៃពាក្យទាំងនោះ គប្បីជ្រាបដូច្នេះថា ភិក្ខុ ៤ អង្គ គឺអាចារ្យ និងអន្តេវាសិកជាអ្នកប្រាថ្នានឹងលួចគរុភណ្ឌ តម្លៃ ៦ មាសក ក្នុងភិក្ខុ ៤ អង្គនោះ អាចារ្យប្រាប់ថា លោកចូរលួច ១ មាសក លោកចូរលួច ១ មាសក លោកចូរលួច ១ មាសក ខ្ញុំនឹងលួច ៣ មាសក បណ្តាអន្តេវាសិកទាំងឡាយ អន្តេវាសិកមួយអង្គពោលថា លោកម្ចាស់ចូរលួច ៣ មាសក លោកចូរលួច ១ មាសក លោកចូរលួច ១ មាសក ខ្ញុំនឹងលួច ១ មាសក សូម្បីអន្តេវាសិក ២ អង្គក្រៅអំពីនេះ ក៏បានពោលយ៉ាងនោះដូចគ្នា ។ បណ្តាភិក្ខុ ៤

អង្គនោះ មាសក ១ របស់អន្តេវាសិកមួយអង្គៗ ជាសាហត្ថិកអវហារ ( លួចផ្ទាល់ដៃ ) ជាអាបត្តិទុក្កដដល់អន្តេវាសិកទាំង ៣ អង្គនោះ ដោយ ដោយមាសក ១ នោះ ។ ៥ មាសក ជាអាណត្តិកអវហារ ( គឺប្រើគេ ) ត្រូវអាបត្តិបារាជិកដល់អន្តេវាសិកទាំង ៣ អង្គ ដោយ ៥ មាសកនោះ ។ ចំណែក ៣ មាសករបស់អាចារ្យ ជាសាហត្ថិក ជាអាបត្តិថុល្លច្ច័យដល់អាចារ្យ ដោយ ៣ មាសកនោះ ។ ៣ មាសកជាអាណត្តិក សូម្បី ៣ មាសកនោះ ត្រូវថុល្លច្ច័យដូចគ្នា ។ ពិតហើយ ក្នុងអទិន្នាទានសិក្ខាបទនេះ សាហត្ថិក មិនជាអង្គរបស់អាណត្តិក ឬអាណត្តិក មិនជាអង្គរបស់សាហត្ថិក។ តែសាហត្ថិក គប្បីកាត់អាបត្តិរួមនឹងសាហត្ថិកបាន អាណត្តិក គប្បីដាក់អាបត្តិរួមនឹងអាណត្តិយបាន ។ ព្រោះហេតុនោះ ទើបលោកពោលថា

ជន គឺភិក្ខុ ៤ អង្គ បបួលគ្នាលួចគរុភណ្ឌ ភិក្ខុ ៣ អង្គ
ត្រូវអាបត្តិបារាជិក ភិក្ខុ ១ អង្គមិនត្រូវបារាជិកទេ ប្រស្នា
នេះ លោកអ្នកឈ្លាសវៃទាំងឡាយ បានគិតមកហើយ ។

ម្យ៉ាងទៀត ដើម្បីឲ្យអស់ចម្ងល់ក្នុងសំវិធាវហារ គប្បីកំណត់ចតុក្កៈនេះ ដោយអត្ថ គឺទ្រព្យ ១ មានឋាន ១ ទ្រព្យ ១ មានឋានច្រើន ទ្រព្យច្រើនមានឋាន ១ ទ្រព្យច្រើនមានឋានច្រើន ។ ក្នុងចតុក្កៈនោះ ពាក្យថា ទ្រព្យ ១ មានឋាន ១ នោះ គឺភិក្ខុច្រើនអង្គ ឃើញរបស់មានតម្លៃ ៥ មាសក ដែលគេទុកមិនល្អ ត្រង់រានផ្សារនៃត្រកូលមួយ ទើបប្រាប់ភិក្ខុមួយអង្គថា លោកចូរទៅលួចទ្រព្យនោះ ត្រូវអាបត្តិបារាជិកដល់ភិក្ខុទាំងអស់ ក្នុង

ខណៈដែលលើកកណ្ឌៈឡើងនោះ ។

ពាក្យថា ទ្រព្យ ១ មានឋានច្រើននោះ គឺភិក្ខុច្រើនអង្គ ឃើញមាសក ដែលគេទុកមិនល្អ លើរានផ្សារ ៥ បន្ទះ មួយបន្ទះៗ ១ មាសកនៃត្រកូល មួយ ទើបប្រាប់ភិក្ខុមួយអង្គថា លោកចូរទៅលួចមាសកទាំងនោះ ត្រូវ អាបត្តិបារាជិកគ្រប់ៗ អង្គ ក្នុងខណៈដែលលើកមាសកទី ៥ ឡើង ។

ពាក្យថា ទ្រព្យច្រើនមានឋាន ១ នោះ គឺភិក្ខុច្រើនអង្គឃើញរបស់ មានតម្លៃ ៥ មាសក ឬច្រើនជាង ៥ មាសក ជាទ្រព្យមនុស្សច្រើននាក់ ដែលទុកមិនល្អក្នុងទីតែមួយ ទើបប្រាប់ភិក្ខុមួយអង្គថា លោកចូរទៅលួចទ្រព្យ នោះ ត្រូវអាបត្តិបារាជិកដល់ភិក្ខុគ្រប់អង្គ ក្នុងខណៈលើកកណ្ឌៈនោះឡើង ។

ពាក្យថា ទ្រព្យច្រើន មានឋានច្រើននោះ គឺភិក្ខុច្រើនអង្គ ឃើញ មាសករបស់ត្រកូល ៥ មួយត្រកូលៗ មាន ១ មាសក ទុកមិនល្អ លើ បន្ទះក្តារ ៥ បន្ទះ មួយបន្ទះៗ ១ មាសក ទើបប្រាប់ភិក្ខុមួយអង្គថា លោក ចូរទៅលួចមាសកទាំងនោះ ត្រូវអាបត្តិបារាជិកដល់ភិក្ខុគ្រប់អង្គ ក្នុងខណៈ ដែលលើកមាសកទី ៥ ឡើង ដោយប្រការដូច្នេះ ។

អំពីការបបួលគ្នាលួច ចប់

# ពោលអំពីសង្កេតកម្ម

[ ១១៩ ] ការធ្វើសញ្ញាឲ្យដឹង ឈ្មោះថា **សង្កេតកម្ម**។ អធិប្បាយថា ការឲ្យសញ្ញាដល់គ្នា ដោយអំណាចការកំណត់វេលា ។ ក្នុងសង្កេតកម្មនេះ កាលភិក្ខុអ្នកប្រើប្រាប់ថា លោកចូរលួចក្នុងពេលមុនអាហារ ភិក្ខុអ្នកទទួលប្រើ ទោះលួចក្នុងវេលាមុនអាហារថ្ងៃនេះក្តី ស្អែកនេះក្តី ឬក្នុងឆ្នាំមុខក្តី ការខុសសង្កេតរមែងមិនមាន ត្រូវអាបត្តិបារាជិកទាំង ២ អង្គ តាមន័យដូចពោលហើយ ក្នុងភិក្ខុអ្នកកំណត់ទ្រព្យឲ្យគេលួចនោះឯង ។ តែកាលភិក្ខុអ្នកប្រើប្រាប់ថា លោកចូរលួចក្នុងពេលមុនអាហារថ្ងៃនេះ ភិក្ខុអ្នកទទួលប្រើលួចក្នុងថ្ងៃស្អែក ទ្រព្យនោះ គឺភិក្ខុអ្នកទទួលប្រើលួចមកខាងក្រោយ ហួសវេលាកំណត់ ដែលភិក្ខុអ្នកប្រើកំណត់ទុកថា ថ្ងៃនេះ បើភិក្ខុអ្នកប្រើប្រាប់ថា ចូរលួចក្នុងពេលមុនអាហារស្អែកនេះ ភិក្ខុអ្នកទទួលប្រើ លួចក្នុងពេលមុនអាហារថ្ងៃនេះ ទ្រព្យនោះ គឺភិក្ខុអ្នកទទួលប្រើលួចមកមុន មិនទាន់ដល់កំណត់នោះ ដែលអ្នកប្រើកំណត់ថា ស្អែកនេះ ត្រូវអាបត្តិបារាជិក ចំពោះតែភិក្ខុអ្នកលួច ដែលលួចដោយអវហារយ៉ាងនោះប៉ុណ្ណោះ មិនត្រូវអាបត្តិដល់ភិក្ខុអ្នកប្រើដែលជាដើមហេតុ ។ ក្នុងកាលភិក្ខុអ្នកប្រើប្រាប់ថា ចូរលួចក្នុងពេលមុនអាហារស្អែកនេះ ចំណែកភិក្ខុអ្នកទទួលប្រើ លួចក្នុងថ្ងៃនេះឯង ឬក្នុងវេលាក្រោយអាហារស្អែកនេះ គប្បីជ្រាបថា លួចមកមុនពេល និងក្រោយពេលការកំណត់នោះ ។ ក្នុងវេលាក្រោយអាហារ ពេលយប់ និងពេលថ្ងៃក៏មានន័យដូចគ្នានេះ ។ ក្នុងសង្កេតកម្មនោះ គប្បីជ្រាបការកំណត់ និងការខុសកំណត់ដោយអំណាចនៃពេលវេលា មានបុរិមយាម មជ្ឈិមយាម បច្ឆិម-

យាម កាឡបក្ខ ជុណ្ហបក្ខ ខែ រដូវ និងឆ្នាំជាដើម ។

សួរថា កាលភិក្ខុអ្នកប្រើប្រាប់ថា ចូរលួចក្នុងពេលមុនអាហារ ភិក្ខុអ្នកទទួលប្រើកំពុងព្យាយាម ដោយគិតថា នឹងលួចក្នុងពេលមុនអាហារនោះឯង ហើយទ្រព្យនោះ គឺលោកលួចមកបាន ក្នុងវេលាក្រោយអាហារ ក្នុងអវហារនេះ ដូចម្តេចដែរ ឆ្លើយថា ព្រះមហាសុមត្ថេរពោលទុកថា នុ៎ះជាប្រយោគក្នុងវេលាមុនអាហារដោយពិត ព្រោះហេតុនោះ ភិក្ខុអ្នកប្រើជាដើមហេតុរមែងចៀសមិនផុត ។ ចំណែកព្រះមហាបទុមត្ថេរពោលថា ឈ្មោះថា ខុសកំណត់ ព្រោះកន្លងកំណត់កាលទៅ ព្រោះហេតុនោះ ភិក្ខុអ្នកប្រើជាដើមហេតុទើបរួចខ្លួន ។

ពោលអំពីសង្កេតកម្ម ចប់

# ពោលអំពីនិមិត្តកម្ម

[ ១២០ ] ការធ្វើនិមិត្តឯណាមួយ ដើម្បីឲ្យកើតការកំណត់ដឹង ឈ្មោះថា **និមិត្តកម្ម** និមិត្តកម្មនោះ ព្រះដ៏មានព្រះភាគត្រាស់ទុក ៣ យ៉ាង ដោយន័យជាដើមថា អញ្ញនឹងមិចក្នែកក្តី ។ ឯការធ្វើនិមិត្តដទៃ មានជាអនេកប្បការ មានការកម្រើកដៃ ទះដៃ ផ្ទាត់ម្រាមដៃ ងក់ក្បាល ក្អក គ្រហែម គប្បីសង្គ្រោះចូលក្នុងនិមិត្តកម្មនេះ ចំណែកពាក្យដ៏សេសក្នុងនិមិត្តនេះ មានន័យដូចពោលហើយ ក្នុងសង្កេតកម្មនោះឯង ។

ពោលអំពីការធ្វើនិមិត្ត ចប់

# ពោលអំពីការប្រើ

[ ១២១ ] ឥឡូវនេះ ដើម្បីការអស់សង្ស័យក្នុងសង្កេតកម្ម និងនិមិត្តកម្មទាំងនេះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា **ភិក្ខុំ អាណាបេតិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ប្រើនបទថា **សោ តំ មញ្ញមានោ** សេចក្តីថា ភិក្ខុអ្នកលួចនោះយល់ទ្រព្យដែលភិក្ខុអ្នកប្រើ ប្រាប់ធ្វើនិមិត្តជាគ្រឿងចំណាំទុកថា ជាទ្រព្យនោះ ទើបលួចទ្រព្យនោះឯង ត្រូវអាបត្តិបារាជិកទាំង ២ អង្គ ។

ប្រើនបទថា **សោ តំ មញ្ញមានោ អញ្ញំ** សេចក្តីថា ភិក្ខុអ្នកលួចនោះ យល់ទ្រព្យដែលភិក្ខុអ្នកប្រើ ប្រើឲ្យលួចថា ជាទ្រព្យនោះ តែលួចទ្រព្យដទៃដែលគេរក្សាទុកក្នុងទីនោះឯង ភិក្ខុអ្នកប្រើដែលជាហេតុ មិនត្រូវអាបត្តិ ។

ប្រើនបទថា **អញ្ញំ មញ្ញមានោ តំ** សេចក្តីថា ភិក្ខុអ្នកលួចយល់ទ្រព្យដទៃ ដែលភិក្ខុអ្នកប្រើធ្វើនិមិត្តជាគ្រឿងចំណាំ ប្រាប់យ៉ាងនេះថា ទ្រព្យនេះមានតម្លៃតិច តែទ្រព្យដទៃដែលគេទុកក្នុងទីជិតទ្រព្យនោះឯង ជាទ្រព្យដែលមានតម្លៃច្រើន ដូច្នេះ ទើបលួចទ្រព្យនោះឯង ត្រូវអាបត្តិបារាជិកទាំងពីរអង្គ ។

ប្រើនបទថា **អញ្ញំ មញ្ញមានោ អញ្ញំ** សេចក្តីថា ភិក្ខុអ្នកលួចនោះរមែងយល់ដោយន័យមុននោះឯងថា ទ្រព្យដទៃនេះ ដែលគេរក្សាទុកក្នុងទីជិតទ្រព្យនោះឯង ជាទ្រព្យមានតម្លៃច្រើន ដូច្នេះ បើទ្រព្យដែលលួចមកនោះជាទ្រព្យដទៃនោះឯង ត្រូវអាបត្តិបារាជិកដល់អ្នកលួចប៉ុណ្ណោះ ។

ក្នុងពាក្យថា **ឥត្ថន្នាមស្ស ចាវទ** ជាដើម មានវិនិច្ឆ័យដូច្នេះថា គប្បីឃើញអាចារ្យមួយអង្គ អន្តេវាសិក ៣ អង្គ មានឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត និងសង្ឃរក្ខិត ។

បណ្តាបទទាំងនោះ ត្រើនបទថា **ភិក្ខុ ភិក្ខុំ អាណាបេតិ** សេចក្តីថា អាចារ្យកំណត់ទ្រព្យឯណាមួយ ក្នុងទីណាមួយ ហើយប្រាប់ពុទ្ធរក្ខិតឲ្យលួចទ្រព្យនោះ ។

ពីរបទថា **ឥត្ថន្នាមស្ស ចាវទ** សេចក្តីថា ( អាចារ្យប្រើថា ) នៃពុទ្ធរក្ខិត ចូរលោកទៅប្រាប់សេចក្តីនុ៎ះដល់ធម្មរក្ខិតភិក្ខុ ។

ត្រើនបទថា **ឥត្ថន្នាមោ ឥត្ថន្នាមស្ស ចាវទតុ** សេចក្តីថា សូម្បីធម្មរក្ខិតភិក្ខុ ចូរទៅប្រាប់សង្ឃរក្ខិតភិក្ខុ ។

ត្រើនបទថា **ឥត្ថន្នាមោ ឥត្ថន្នាមំ ភណ្ឌំ អវហរតុ** សេចក្តីថា ធម្មរក្ខិតភិក្ខុ ត្រូវពុទ្ធរក្ខិតប្រាប់យ៉ាងនេះថា ភិក្ខុឈ្មោះនេះ ( គឺសង្ឃរក្ខិត ) ចូរលួចទ្រព្យឈ្មោះនេះ ហើយ ( ធម្មរក្ខិត ) ប្រាប់សង្ឃរក្ខិតថា ចូរលួចទ្រព្យឈ្មោះនេះ ពិតហើយ បណ្តាពួកយើងទាំងពីរ សង្ឃរក្ខិតភិក្ខុប៉ុណ្ណោះជាមនុស្សមានជាតិក្លាហាន អាចក្នុងកម្មនេះ ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** សេចក្តីថា ត្រូវអាបត្តិទុក្កដដល់អាចារ្យដែលប្រាប់យ៉ាងនេះមុន បើពាក្យប្រើនោះប្រព្រឹត្តទៅតាមបំណង ត្រូវអាបត្តិថុល្លច្ច័យ ដែលលោកកាត់អាបត្តិទុកខាងមុខនោះឯង រមែងមានក្នុងខណៈប្រើ បើទ្រព្យនោះនឹងត្រូវលួចបានពិតប្រាកដ បារាជិកដែលត្រាស់ទុកខាងមុខ

ថា គ្រប់អង្គត្រូវអាបត្តិបារាជិក ដូច្នេះ រមែងមានដល់អាចារ្យនេះ ក្នុងខណៈនោះឯង ព្រោះព្រះតម្រាស់ដែលត្រាស់ទុកនោះ យុត្តិនេះ បណ្ឌិតគប្បីជ្រាបក្នុងទីទាំងពួង ដោយប្រការយ៉ាងនេះ ។

ប្រើនបទថា **សោ ឥតរស្ស អារោចេតិ** សេចក្តីថា ភិក្ខុអ្នកទទួលប្រើប្រាប់ថា ពុទ្ធរក្ខិតភិក្ខុប្រាប់ធម្មរក្ខិតភិក្ខុ ហើយធម្មរក្ខិតភិក្ខុប្រាប់សង្ឃរក្ខិតភិក្ខុថា អាចារ្យរបស់ពួកយើង ពោលយ៉ាងនេះថា បានឮថា ចូរលោកលួចទ្រព្យឈ្មោះនេះ បានឮថា បណ្តាយើងទាំងពីរ ខ្ញុំនលោកជាបុរសក្លាហាន ដូច្នេះ ត្រូវអាបត្តិទុក្កដដល់លោកទាំងនោះ ព្រោះមានការប្រាប់តគ្នា ដោយអាការយ៉ាងនោះជាបច្ច័យ ។

ពីរបទថា **អវហារកោ បដិគ្គណ្ហាតិ** សេចក្តីថា សង្ឃរក្ខិតភិក្ខុទទួលថា ប្រពៃណាស់ ខ្ញុំនឹងលួច ។

ប្រើនបទថា **មូលដ្ឋស្ស អាបត្តិ ថុល្លច្ចយស្ស** សេចក្តីថា លុះសង្ឃរក្ខិតភិក្ខុទទួលពាក្យ អាចារ្យត្រូវអាបត្តិថុល្លច្ច័យ ព្រោះមនុស្សជាច្រើនត្រូវអាចារ្យដឹកនាំហើយក្នុងបាប ដូច្នេះ ។

ប្រើនបទថា **សោ តំ ភណ្ឌំ** សេចក្តីថា បើភិក្ខុឈ្មោះនោះ គឺសង្ឃរក្ខិតភិក្ខុលួចទ្រព្យនោះបានមកសោត ត្រូវអាបត្តិបារាជិកទាំងអស់ គឺទាំង ៤ អង្គ ហើយមិនមែនបារាជិកដល់ភិក្ខុ ៤ អង្គតែម្យ៉ាងឡើយ សមណៈរាប់ពាន់ក៏ដោយ ដែលប្រើបន្តគ្នាទៅ មិនធ្វើឲ្យខុសសង្កេតដោយឧបាយយ៉ាងនេះ ត្រូវអាបត្តិបារាជិកគ្រប់គ្នាទាំងអស់នោះឯង ។

ក្នុងទុតិយវារៈ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ច្រើនបទថា **សោ អញ្ញំ អាណាបេតិ** សេចក្ដីថា ភិក្ខុនោះ គឺព្រះពុទ្ធរក្ខិតដែលអាចារ្យប្រើទុកហើយ តែមិនជួបធម្មរក្ខិត ឬជាអ្នកមិនចង់ប្រាប់ ទើបចូលទៅរកសង្ឃរក្ខិតភិក្ខុតែម្ដង ហើយប្រាប់ថា អាចារ្យរបស់ពួកយើង ប្រើយ៉ាងនេះថា បានឮថា ចូរលោកលួចទ្រព្យឈ្មោះនេះមក ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** សេចក្ដីថា ពុទ្ធរក្ខិតភិក្ខុ ឈ្មោះថា ត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យមុន ។

ច្រើនបទថា **បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស** សេចក្ដីថា គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុអ្នកប្រើដែលជាដើមគេនោះឯង ក្នុងកាលសង្ឃ-រក្ខិតទទួលហើយ ។ បើសង្ឃរក្ខិតភិក្ខុនោះ លួចទ្រព្យនោះបានមក ត្រូវអាបត្តិបារាជិកទាំងពីរអង្គ គឺពុទ្ធរក្ខិតភិក្ខុ ១ សង្ឃរក្ខិតភិក្ខុអ្នកលួច ១ តែសម្រាប់អាចារ្យដែលជាដើមបញ្ជា មិនត្រូវអាបត្តិបារាជិក ព្រោះខុសសង្កេត មិនត្រូវអាបត្តិដល់ធម្មរក្ខិតភិក្ខុ ព្រោះមិនបានដឹង ។ ចំណែកពុទ្ធរក្ខិតភិក្ខុ ធ្វើសួស្តីដល់ភិក្ខុ ទាំងពីរអង្គហើយ ខ្លួនឯងវិនាស ។

បណ្ដាអាណត្តិវារៈទាំង ៤ បទ បន្ទាប់ពីទុតិយវារៈនេះទៅ គប្បីជ្រាបវិនិច្ឆ័យក្នុងអាណត្តិវារៈប្រការទី ១ មុនសិន ។

ច្រើនបទថា **សោ គន្ត្វា បុន បច្ចាគច្ឆតិ** សេចក្ដីថា ភិក្ខុអ្នកទទួលប្រើនោះ ទៅកាន់ទីដែលទ្រព្យតាំងនៅហើយ ឃើញមានការរក្សាទុក ទាំងខាងក្នុង និងខាងក្រៅ មិនអាចលួចយកបាន ទើបត្រឡប់មក ។

ច្រើនបទថា **យទា សក្កោសិ តទា** សេចក្ដីថា ភិក្ខុអ្នកប្រើនោះ

ប្រើជាថ្មីថា ទ្រព្យដែលលោកលួចមកហើយក្នុងថ្ងៃនេះប៉ុណ្ណោះឬ ទើបជាការលួច ទៅចុះលោកៗ អាចលួចបានមកក្នុងកាលណា ក៏ចូរលួចទ្រព្យនោះមកក្នុងកាលនោះ ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** សេចក្ដីថា ព្រោះប្រើទៀតយ៉ាងនោះ ក៏ត្រូវអាបត្តិទុក្កដប៉ុណ្ណោះ ។ បើទ្រព្យនោះរមែងជារបស់ដែលនឹងលួចបានមកពិតប្រាកដ ឈ្មោះថា ចេតនាដែលឲ្យសម្រេចប្រយោជន៍ ក៏ដូចគ្នានឹងផលដែលកើតក្នុងលំដាប់នៃមគ្គ ព្រោះដូច្នោះ ភិក្ខុអ្នកប្រើនេះ ត្រូវអាបត្តិបារាជិកក្នុងខណៈប្រើនោះឯង ។ បើភិក្ខុអ្នកលួច ទោះលួចទ្រព្យនោះបានមក ដោយកន្លងទៅ ៦០ ឆ្នាំ ភិក្ខុអ្នកប្រើ ទោះធ្វើកាលកិរិយា ឬសឹកទៅក្នុងចន្លោះនោះឯង ក៏មិនឈ្មោះថា ជាសមណៈធ្វើកាលកិរិយា ឬសមណៈសឹកទៅទេ តែសម្រាប់ភិក្ខុអ្នកលួច រមែងត្រូវអាបត្តិបារាជិកក្នុងខណៈលួចនោះឯង ។

ក្នុងទុតិយវារៈ ព្រោះភិក្ខុប្រើដែលជាមូលហេតុ ពោលពាក្យនោះតិចៗ មិនបានប្រកាសឲ្យបានឮ ឬមិនបានប្រកាសឲ្យបានឮពាក្យប្រើដូច្នេះថា អ្នកកុំលួច ព្រោះអ្នកជាដើមហេតុនោះ ជាមនុស្សត្រចៀកធ្ងន់ ដូច្នោះ ភិក្ខុអ្នកប្រើដែលជាដើមហេតុ ទើបមិនរួចផុត ។ ចំណែកក្នុងតតិយវារៈ ឈ្មោះថា ផុតព្រោះលោកប្រកាសឲ្យបានឮ ។ ក្នុងចតុត្ថវារៈ សូម្បីទាំងពីរអង្គផុតបាន ព្រោះភិក្ខុអ្នកប្រើដែលជាហេតុនោះ ប្រកាសឲ្យបានឮ ហើយព្រោះភិក្ខុអ្នកទទួលប្រើក្រៅអំពីនេះ ទទួលពាក្យថា សាធុ ហើយក៏វៀរចេញ ដោយប្រការដូច្នេះ ។

ពោលអំពីការប្រើ ចប់

## អាការនៃអវហារ ៥ យ៉ាង

[ ១២២ ] ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងអង្គនៃអទិន្នាទានដែលត្រាស់ទុក ដោយអំណាចនៃកិរិយាដែលឲ្យឃ្លាតចាកឋានក្នុងទ្រព្យដែលតាំងនៅក្នុងផែនដីជាដើមនោះៗ និងការផ្សេងគ្នានៃអាបត្តិ និងការផ្សេងគ្នានៃវត្ថុ ទើបត្រាស់ពាក្យជាដើមថា **បញ្ចហាការេហិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **បញ្ចហាការេហិ** បានដល់ ដោយហេតុ ៥ យ៉ាង មានពាក្យអធិប្បាយថា ដោយអង្គ ៥ ក្នុងពាក្យថា **បញ្ចហា-ការេហិ** ជាដើមនោះ មានអត្ថសង្ខេបដូចតទៅនេះថា បារាជិក រមែងមានដល់ភិក្ខុដែលកាន់យកទ្រព្យ ម្ចាស់ទ្រព្យមិនបានឲ្យ ដោយអាការ ៥ យ៉ាងដែលត្រាស់ទុកដោយន័យជាដើមថា ទ្រព្យដែលអ្នកដទៃហួងហែង ១ ព្រោះមិនគ្រប់អង្គ ៥ នោះ ទើបមិនត្រូវអាបត្តិបារាជិក ។ ក្នុងពាក្យនោះ មានអាការ ៥ ទាំងនេះ គឺទ្រព្យដែលអ្នកដទៃហួងហែង ១ ដឹងថា ទ្រព្យដែលអ្នកដទៃហួងហែង ១ ភាពដែលបរិក្ខារមានតម្លៃច្រើន ចំនួន ៥ មាសកឬច្រើនជាង ៥ មាសក ១ មានថេយ្យចិត្ត ១ ការធ្វើឲ្យឃ្លាតចាកឋាន ១ ។ ចំណែកក្នុងបរិក្ខារដែលមានតម្លៃតិច មិនគ្រប់ ៥ មាសក លោកសម្តែងថុល្លច្ច័យ និងទុក្កដទុក ដោយការផ្សេងគ្នានៃវត្ថុ ដោយវារៈទាំងពីរ ដទៃចាកអាការ ៥ យ៉ាងនេះ ។

## អាការ ៦ យ៉ាង ដែលឲ្យភិក្ខុត្រូវអាបត្តិថារាជិក

[ ១២៣ ] សូម្បីក្នុងវារៈទាំង ៣ ដែលទ្រង់ត្រាស់ដោយន័យជាដើមថា **ឆហាការេហិ** គួរជ្រាបអាការ ៦ យ៉ាងនេះ គឺមិនបានសម្គាល់ថា ជា

របស់ខ្លួន ១ មិនបានកាន់យកដោយវិស្សាស ១ មិនបានកាន់យកជារបស់ខ្ចី ១ បរិក្ខារមានតម្លៃច្រើន ប្រមាណ ៥ មាសក ឬលើសពី ៥ មាសក ១ មានថេយ្យចិត្ត ១ ញ៉ាំងរបស់នោះឲ្យផុតឃ្លាតចាកឋាន ១ ។ បណ្ដាវារៈទាំង ៣ នេះ ក្នុងបឋមវារៈ លោកកាត់អាបត្តិជាបារាជិក ទុតិយវារៈ និងតតិយវារៈ លោកកាត់អាបត្តិជាថុល្លច្ច័យ និងទុក្កដ ដោយការផ្សេងគ្នានៃវត្ថុ ។

[ ១២៤ ] ចំណែកក្នុងការផ្សេងគ្នានៃវត្ថុ ដែលមាននៅក្នុងវារៈទាំង ៣ ដទៃអំពី ៣ វារៈនោះ លោកកាត់អាបត្តិទុក្កដតែម្យ៉ាង ព្រោះជាទ្រព្យដែលជនដទៃមិនហួងហែង ។ ទ្រព្យដែលលោកពោលក្នុង ៣ វារៈនោះ មិនមែនទ្រព្យដែលអ្នកដទៃហួងហែង និងជាវត្ថុដែលមិនទាន់មានការគ្រប់គ្រងក៏ដោយ ជារបស់ដែលគេចោលហើយ មិនមានតម្លៃ មិនមានម្ចាស់ទ្រព្យ ឬជាទ្រព្យរបស់ខ្លួនក៏ដោយ វត្ថុទាំងពីរ រមែងដល់នូវការរាប់ថា មិនមែនរបស់ដែលអ្នកដទៃហួងហែង ។ ក្នុងទ្រព្យពីរយ៉ាងនេះ មានសេចក្ដីសម្គាល់ថា ទ្រព្យដែលអ្នកដទៃហួងហែង ១ កាន់យកដោយថេយ្យចិត្ត ១ ព្រោះហេតុនោះ ទើបលោកពោលអនាបត្តិ ទុកដូច្នេះឯង ។

## អនាបត្តិវារៈ

[១២៥] ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងការផ្សេងគ្នានៃអាបត្តិដោយអំណាចផ្សេងគ្នានៃវត្ថុ និងដោយចំណាចនៃចិត្តយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងអនាបត្តិ ទើបត្រាស់ពាក្យថា **អនាបត្តិ សកសញ្ញិស្ស** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សកសញ្ញិស្ស** បានដល់ ភិក្ខុដែលមានការសម្គាល់ថា ជារបស់ខ្លួន គឺដែលមានការសម្គាល់យ៉ាងនេះថា ភណ្ឌៈនេះជារបស់អញ កាលកាន់យកនូវភណ្ឌៈរបស់អ្នកដទៃ មិនត្រូវអាបត្តិ ព្រោះការកាន់យក គួរឲ្យទ្រព្យដែលខ្លួនកាន់យកហើយនោះ សងដល់អ្នកដទៃវិញ បើត្រូវពួកម្ចាស់ទ្រព្យទារថា ចូរឲ្យទ្រព្យខ្ញុំវិញ បើលោកមិនសង ត្រូវអាបត្តិបារាជិក ក្នុងកាលម្ចាស់ទ្រព្យទាំងនោះដាក់ធុរៈ ។

បទថា **វិស្សាសគ្គាហេ** បានដល់ មិនត្រូវអាបត្តិ ព្រោះការកាន់យកដោយស្និទ្ធស្នាល តែគួរដឹងលក្ខណៈនៃការកាន់យកដោយសេចក្តីស្និទ្ធស្នាលដោយសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកដោយសេចក្តីស្និទ្ធរបស់មិត្រ ប្រកបដោយអង្គ ៥ គឺមិត្រដែលគ្រាន់តែបានឃើញគ្នាម្តងមួយគ្រា ១ មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន ១ មិត្រដែលបាននិយាយបើកឱកាសគ្នាតាមត្រូវការ ១ មិត្រនោះមានជីវិតរស់នៅ ១ ភិក្ខុដឹងថា បើអាត្មាអញកាន់យកវត្ថុណាមួយហើយ មិត្រនោះមានសេចក្តីត្រេកអរ ១ ។

បណ្តាបទទាំងនោះ បទថា **សន្ទិដ្ឋោ** បានដល់ មិត្រដែលគ្រាន់តែឃើញគ្នាម្តងម្កាល ។ បទថា **សម្ភត្តោ** បានដល់ មិត្រជាទីស្និទ្ធស្នាល ។

បទថា **អាលបិតោ** បានដល់ បុគ្គលដែលមិត្រប្រាប់ទុកថា លោកត្រូវការរបស់ណាដែលជារបស់ខ្ញុំ លោកគប្បីកាន់យករបស់នោះចុះ មិនមានហេតុក្នុងកាលដែលលោកសុំអនុញ្ញាតមុន ទើបកាន់យកឡើយ ។ សូម្បីមិត្រ

ដែលដេក ដោយការដេកដែលមិនក្រោកឡើង មិនទាន់ដល់នូវការដាច់នៃជីវិតិន្ទ្រិយដរាបណា ឈ្មោះថា នៅមានជីវិតដរាបនោះ ។

ប្រើនបទថា **គហិតេ ច អត្តមនោ** សេចក្តីថា កាលអញកាន់យកហើយ មិត្រអញនឹងពេញចិត្ត ។ កាលភិក្ខុដឹងថា កាលអញកាន់យកទ្រព្យរបស់អ្នកដទៃដែលមានសភាពបែបនេះហើយ បុគ្គលនោះនឹងត្រេកអរទើបកាន់យក រមែងសមគួរ ។ ព្រះដ៏មានព្រះភាគត្រាស់អង្គទាំង ៥ នេះទុកដោយអំណាចនៃការរួបរួម ដោយមិនមានចំណែកសេសសល់ ។ តែការកាន់យកដោយវិស្សាស រមែងឡើងដោយអង្គ ៣ គឺធ្លាប់ឃើញគ្នាមកនៅមានជីវិតនៅឡើយ ដឹងថា កាលអញកាន់យកហើយ មិត្រនោះនឹងពេញចិត្ត ១ ធ្លាប់សេពគប់គ្នាមកនៅមានជីវិតនៅឡើយ កាលដឹងថា កាលអញកាន់យកហើយ មិត្រនោះនឹងត្រេកអរ ១ ធ្លាប់ឲ្យឱកាសទុកនៅមានជីវិតនៅឡើយ ដឹងថា កាលអញកាន់យកហើយ មិត្រនោះនឹងពេញចិត្ត ១ ។ ចំណែកមិត្រណានៅមានជីវិតនៅឡើយ តែកាលកាន់យកហើយ មិត្រនោះមិនត្រេកអរ ទ្រព្យរបស់មិត្រនោះ គឺភិក្ខុកាន់យកហើយដោយការមិនស្និទ្ធស្នាលក៏គួរសងដល់ម្ចាស់ដើម កាលនឹងសងទ្រព្យ គួរសងឲ្យដល់ពួកជនដែលជាធំក្នុងទ្រព្យ របស់បុគ្គលនោះមុន ទោះជាគ្រហស្ថ ឬបព្វជិតក៏ដោយ ទ្រព្យរបស់មិត្រ ដែលមិនត្រេកអរក៏គួរសងដល់បុគ្គលនោះឯង ។

ចំណែកភិក្ខុណា ត្រេកអរក្នុងកាលជាដំបូងនោះឯង ដោយការបន្លឺវាចាថា លោកកាលកាន់យកទ្រព្យរបស់ខ្ញុំ ឈ្មោះថា ប្រពៃហើយ ឬត្រឹមតែ

ចិត្តប្បាទប៉ុណ្ណោះ ក្រោយមក កើតសេចក្តីក្រោធដោយហេតុណាមួយ ភិក្ខុនោះរមែងមិនបានដើម្បីឲ្យនាំមកសង ។ សូម្បីភិក្ខុអង្គណា មិនបំណងនឹងឲ្យ តែទទួលពាក្យទុកដោយចិត្ត មិនពោលពាក្យណាមួយ សូម្បីភិក្ខុអង្គនោះ ក៏រមែងមិនបានដើម្បីនឹងឲ្យនាំមកសង ។ ចំណែកភិក្ខុណា កាលមិត្រភិក្ខុផងគ្នាពោលថា ទ្រព្យរបស់លោកខ្ញុំកាន់យកហើយ ឬខ្ញុំប្រើប្រាស់ហើយ ទើបពោលថា ទ្រព្យនោះ លោកកាន់យក ឬប្រើប្រាស់ហើយក៏ដោយ តែទ្រព្យនោះ ខ្ញុំរក្សាទុកដោយករណីឯណាមួយពិតៗ លោកគួរធ្វើទ្រព្យនោះ ឲ្យជាប្រក្រតីដើម ដូច្នេះ ភិក្ខុនេះគប្បីនាំមកសង ។

បទថា **តាវកាលិកេ** សេចក្តីថា សម្រាប់ភិក្ខុដែលកាន់យក ដោយគិតយ៉ាងនេះថា អញនឹងសង នឹងធ្វើសំណង មិនត្រូវអាបត្តិ ព្រោះកាន់យកជារបស់ខ្ចី ។ តែទ្រព្យដែលភិក្ខុកាន់យកហើយ បើបុគ្គល ឬគណៈដែលជាម្ចាស់ទ្រព្យអនុញ្ញាតឲ្យថា ទ្រព្យនោះ ចូរជារបស់លោកដូចគ្នា សេចក្តីនេះជាការល្អ បើមិនអនុញ្ញាតទុកសោត កាលគេឲ្យសង គួរសង ។ ចំណែកទ្រព្យរបស់សង្ឃ គួរសងដូចគ្នា ។

ឯបុគ្គលដែលកើតក្នុងបេតវិស័យក្តី ប្រេតដែលធ្វើកាលហើយក្តី កើតក្នុងអត្តភាពនោះឯងក្តី ទេវតាទាំងឡាយ មានទេវតាជាន់ចាតុម្មហារាជិកាក្តីទាំងអស់ ដល់នូវការរាប់ថា **ប្រេត** ដូចគ្នាក្នុងពាក្យថា **បេតបរិគ្គហេ** នេះមិនត្រូវអាបត្តិ ក្នុងទ្រព្យដែលប្រេតទាំងនោះហួងហែង ។ ពិតហើយ សូម្បីសក្កទេវរាជដាក់រានលក់ត្រង់ផ្សារ នៅអង្គុយ កាលភិក្ខុបានទិព្វចក្ខុ ដឹងថា

ជាសក្កទេវរាជ បើសក្កទេវរាជនោះ ស្រែកឃាត់ថា កុំកាន់យក កុំកាន់យក ភិក្ខុកាន់យកសំពត់សាដក សូម្បីមានតម្លៃរាប់សែន ដើម្បីប្រយោជន៍ដល់ចីវររបស់ខ្លួនទៅ ការកាន់យកនោះ រមែងគួរ ។ ចំណែកក្នុងសាដកដែលពួកជនធ្វើពលីកម្ម ឧទ្ទិសដល់ពួកទេវតា ពាក់ទុកត្រង់ដើមឈើជាដើម មិនមានពាក្យដែលគួរពោលឡើយ ។

បទថា **តិរច្ឆានគតបរិគ្គហេ** បានដល់ មិនត្រូវអាបត្តិ ព្រោះទ្រព្យពួកសត្វតិរច្ឆានហួងហែង ។ ពិតហើយ សូម្បីពួកស្តេចនាគ ឬសុបណ្ណ-មាណព កាឡាខ្លួនជាមនុស្ស ដាក់រានក្នុងផ្សារ មានភិក្ខុអង្គខ្លះមកកាន់យកទ្រព្យរបស់ស្តេចនាគ ឬរបស់ស្តេចគ្រុឌនោះ អំពីរានផ្សារទៅ ដោយន័យមុននោះឯង ការកាន់យកនោះ រមែងគួរ ។ រាជសីហ៍ ឬខ្លាធំ សម្លាប់ម្រឹគនិងក្របីជាដើម តែមិនទាន់ទំពាស៊ី ត្រូវការស្រេកឃ្លានបៀតបៀន មិនគប្បីឃាត់ក្នុងខាងដើមនោះឯង ព្រោះវានឹងគប្បីធ្វើសេចក្តីវិនាស តែបើរាជសីហ៍ជាដើមទំពាស៊ីសាច់ជាដើមទៅបន្តិចហើយ អាចហាមបាន ( គឺដេញបាន ) ទោះហាមហើយ កាន់យកក៏គួរ ។ សូម្បីពួកបក្សីមានស្ទាំងជាដើមពាំយករំពាហើរទៅ ទោះដេញឲ្យវាទម្លាក់ដុំសាច់ធ្លាក់ទៅ ហើយកាន់យកក៏គួរ ។

បទថា **បំសុកូលសញ្ញិស្ស** សេចក្តីថា សម្រាប់ភិក្ខុដែលមានការសម្គាល់យ៉ាងនេះថា ទ្រព្យនេះ មិនមានម្ចាស់ ប្រឡាក់ដោយធូលី មិនត្រូវអាបត្តិព្រោះការកាន់យក តែបើទ្រព្យនោះមានម្ចាស់សោត បើគេឲ្យសង ក៏គួរសង ។

បទថា **ឧម្មត្តកស្ស** សេចក្ដីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលឆ្កួត ដូចមានពោលហើយខាងដើម ។

បទថា **អាទិកម្មិកស្ស** សេចក្ដីថា មិនត្រូវអាបត្តិដល់ធនិយភិក្ខុដែលជាអាទិកម្មិក ( បុគ្គលដើមបញ្ញត្តិ ) ក្នុងសិក្ខាបទនេះ ។ តែសម្រាប់ធព្វគ្គិយភិក្ខុជាដើម ដែលជាចោរលួចសំពត់របស់ជាងជ្រលក់ជាដើមដ៏សេសប្រព្រឹត្តជាអាបត្តិនោះឯង ដូច្នេះ ។

## បកិណ្ណកកថា

ក្នុងបកិណ្ណកៈនេះ គឺសមុដ្ឋាន ១ កិរិយា ១ សញ្ញា ១ សចិត្តក ១ លោកវជ្ជ ១ កម្ម ១ កុសល ១ វេទនា ១ ។

បណ្ឌិតគប្បីជ្រាបពាក្យទាំងអស់ ដោយន័យដែលពោលទុកហើយ ក្នុងបឋមបារាជិកសិក្ខាបទនោះឯងថា សិក្ខាបទនេះ មានសមុដ្ឋាន ៣ គឺជាសាហត្ថិក កើតតាមកាយ និងចិត្ត ជាអាណត្តិក កើតតាមវាចា និងចិត្ត ជាសាហត្ថិក និងអាណត្តិក កើតតាមកាយ តាមវាចា និងតាមចិត្ត និងកើតព្រោះធ្វើ ពិតហើយ កាលធ្វើប៉ុណ្ណោះ ទើបត្រូវអាបត្តិនោះ កាលមិនធ្វើ មិនត្រូវឡើយ ជាសញ្ញាវិមោក្ខ ព្រោះផុតដោយមិនមានការសម្គាល់ថា អញនឹងកាន់យកទ្រព្យដែលម្ចាស់មិនបានឲ្យ ជាសចិត្តក ជាលោកវជ្ជ និងជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ភិក្ខុត្រេកអរ ឬភ័យ ឬជាកណ្ដាល ទើបត្រូវអាបត្តិនោះ ព្រោះហេតុនោះ ទើបសិក្ខាបទនេះ មានវេទនា ៣ ។

**បទភាជនីយ៍ទុតិយបារាជិក ចប់**

# អធិប្បាយ

# វិធីតវត្ថុក្នុងទុតិយចាតុភាជិក

[ ១២៧ ] ក្នុងគាថានៃវិនីតវត្ថុ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា រឿងឆព្វគ្គិយភិក្ខុ ខ្ញុំបានពោលទុកហើយ ក្នុងអនុប្បញ្ញត្តិនោះឯង ។

[ ១២៨ ] ក្នុងរឿងទី ២ មានវិនិច្ឆ័យដូច្នេះថា ដែលឈ្មោះថា ចិត្តរបស់ពួកបុថុជ្ជន លះប្រក្រតីទៅដោយអំណាចកិលេស មានរាគៈជាដើមរមែងស្ទុះទៅ គឺច្នេះច្នាទៅ បានដល់ ញាប់ញ័រទៅ ។ បើព្រះដ៏មានព្រះភាគសូម្បីវៀរការទម្លាយតាមកាយទ្វារ និងវចីទ្វារចេញ ទ្រង់គប្បីបញ្ញត្តអាបត្តិដោយហេតុត្រឹមតែចិត្តុប្បាទ ( ត្រឹមតែការកើតឡើងនៃចិត្ត ) នរណាអាចធ្វើខ្លួនមិនឲ្យត្រូវអាបត្តិបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិ ព្រោះត្រឹមតែការគិតក្នុងចិត្ត ។ តែភិក្ខុមិនគួរប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត គួរហាមចិត្តទុកក្នុងកម្លាំងនៃការពិចារណានោះឯង ។ រឿងការចាប់ពាល់សំពត់ ធ្វើឲ្យសំពត់កម្រើក ធ្វើឲ្យសំពត់ឃ្លាតចាកឋាន មានអត្ថងាយយល់ហើយនោះឯង ។

[ ១២៩-២៣១ ] ចំណែករឿងទាំងឡាយ បន្ទាប់អំពីរឿងដែលធ្វើសំពត់ឲ្យឃ្លាតចាកឋាននោះទៅ មានរឿងភិក្ខុមានថេយ្យចិត្ត ចាប់ទ្រព្យនោះឡើងអំពីផែនដីជាទីបំផុត មានអត្ថងាយយល់ហើយទាំងអស់ ។

[ ១៣២ ] ក្នុងរឿងភិក្ខុ ត្រឹមតែពោលតែពាក្យ មានវិនិច្ឆ័យដូច្នេះថា បទថា **អាធិយិ** សេចក្តីថា ភិក្ខុម្ចាស់ចីវរចាប់ហើយ គឺទាញទុក ពោលថា លោកជាចោរ ។ ចំណែកភិក្ខុលួចចីវរ កាលត្រូវភិក្ខុម្ចាស់ចីវរសួរថា ចីវរ

របស់ខ្ញុំ នរណាលួចទៅ ទើបបានឲ្យពាក្យប្តេជ្ញា ដោយស្មើនឹងសំណួរថា ខ្ញុំលួចទៅ ។ ពិតហើយ បើភិក្ខុម្ចាស់ចីវរពោលថា ចីវររបស់ខ្ញុំ អ្នកណាកាន់យក អ្នកណានាំទៅ អ្នកណារក្សាទុក ភិក្ខុនេះឆ្លើយថា ខ្ញុំកាន់យកក្តី នាំទៅក្តី ខ្ញុំរក្សាទុកពិតប្រាកដ ។ ធម្មតា មាត់ គឺទុកដើម្បីប្រយោជន៍ដល់ការបរិភោគ និងដើម្បីប្រយោជន៍ដល់ការនិយាយ តែវៀរថេយ្យចិត្ត ក៏មិនជាអវហារ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិ ព្រោះត្រឹមតែថាដោយពាក្យ ដូច្នេះ ។ អធិប្បាយថា មិនត្រូវអាបត្តិ ព្រោះត្រឹមតែពោលដោយវាចា ។

[ ១៣៣ ] រឿងបន្ទាប់ពីរឿងនេះទៅ ដែលមានរឿងភិក្ខុរើសសំពត់ជូតក្បាលជាទីបំផុត មានសេចក្តីងាយយល់ហើយទាំងអស់នោះឯង ។

[ ១៣៤ ] ក្នុងរឿងសាកសពដែលនៅស្រស់ មានវិនិច្ឆ័យដូច្នេះថា បទថា **អធិវត្ថោ** សេចក្តីថា ប្រេតកើតឡើងក្នុងសាកសពនោះឯង ព្រោះការជាប់ជំពាក់ក្នុងសាដក ។

បទថា **អនាទិយន្តោ** សេចក្តីថា ភិក្ខុមិនជឿពាក្យរបស់ប្រេតនោះ ឬមិនធ្វើការអើពើ ។

ប្រើនបទថា **តំ សរីរំ ឧដ្ឋហិត្វា** សេចក្តីថា ប្រេតញ៉ាំងសាកសពនោះឲ្យក្រោកឡើង ដោយអានុភាពរបស់ខ្លួន ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលទុកថា សាកសពនោះក្រោកឡើង ( ដើរតាមក្រោយភិក្ខុនោះ ) ។

ពីរបទថា **ទ្វារំ ថកេសិ** សេចក្តីថា វិហាររបស់ភិក្ខុមានក្នុងទីជិតព្រៃស្មសាននោះឯង ព្រោះហេតុនោះ ភិក្ខុជាអ្នកខ្លាចដោយប្រក្រតី ទើបរត់ចូលទៅក្នុងវិហារនោះឯង ហើយបិទទ្វារ ។

ពីរបទថា **តត្ថេវ បរិបតិ** សេចក្តីថា កាលភិក្ខុបិទទ្វារហើយ ប្រេតជាអ្នកអស់សេចក្តីអាល័យក្នុងសំពត់សាដក ទើបលះបង់សាកសពនោះហើយទៅតាមយថាកម្ម ព្រោះហេតុនោះ សរីរសពនោះ ក៏ដួលចុះ មានពាក្យអធិប្បាយថា ធ្លាក់ទៅក្នុងទីនោះឯង ។

ពីរបទថា **អភិន្នេ សរីរេ** សេចក្តីថា ឯសំពត់បង្សុកូល ត្រង់សពដែលមិនទាន់បែកធ្លាយ ភិក្ខុមិនគួរកាន់យក កាលភិក្ខុកាន់យក ឧបទ្រវបែបនេះរមែងមាន ហើយភិក្ខុត្រូវអាបត្តិទុក្កដ តែបើកាន់យកត្រង់សពដែលបែកធ្លាយហើយ គួរ ។

ឯសពដែលរាប់ថា បែកធ្លាយហើយ ដោយហេតុមានប្រមាណត្រឹមណា ឆ្លើយថា ដោយហេតុ មានប្រមាណត្រឹមចំពុះ ឬចង្កូមដែលសត្វទាំងឡាយ មានក្អែក ត្រដក់ ស្ទារ ឆ្កែ ចចកជាដើម កកេរហើយបន្តិចបន្តួចចំណែកអវយវៈរបស់សពណាដែលដួលដុះ គ្រាន់តែមានស្បែករលាត់ដោយការធូត ស្បែកមិនទាន់ដាច់ចេញ សពនោះរាប់ថានៅស្រស់នោះឯង តែកាលស្បែកដាច់ចេញហើយ រាប់ថា បែកធ្លាយហើយ ។ សូម្បីសពណា ក្នុងវេលាមានជីវិតនោះឯង មានរោគឃ្លង់ និងរោគពកបែក ឬដំបៅបែកសុសទូទៅ សូម្បីសពនេះក៏ឈ្មោះថា បែកហើយ ។ តាំងអំពីថ្ងៃទី ៣ ទៅ សរីរៈ

ដែលដល់នូវភាពជាសាកសព ដែលហើមប៉ោងជាដើម រាប់ថាជាសពដែលបែកធ្លាយហើយដោយពិត ។

ម្យ៉ាងទៀត សូម្បីក្នុងសពដែលមិនទាន់បែក ដោយប្រការទាំងពួង តែអ្នកមើលថែរក្សាព្រៃស្មសាន ឬមនុស្សដទៃឲ្យកាន់យក គួរ ។ បើមិនបានមនុស្សដទៃ គួរយកសស្ត្រា ឬវត្ថុណាមួយ ធ្វើឲ្យជាដំបៅ ហើយសឹមកាន់យក ។ តែក្នុងសាកសពដែលមានភេទផ្ទុយគ្នា ភិក្ខុគួរតាំងសតិទុក ផ្គងសមណសញ្ញាឲ្យកើតឡើង ធ្វើឲ្យជាដំបៅត្រង់ក្បាល ឬត្រង់ខ្នងដៃ និងខ្នងជើង ហើយកាន់យក សមគួរ ។

[ ១៣៥ ] ក្នុងរឿងដែលជាលំដាប់នៃសរីរៈ ដែលមិនទាន់បែកធ្លាយនោះ មានវិនិច្ឆ័យដូច្នេះថា ច្រើនបទថា **កុសំ សង្កាមេត្វា ចីវរំ អគ្គហេសិ** សេចក្ដីថា ភិក្ខុលួចដោយកុសាវហារ ក្នុងបណ្ដាថេយ្យាវហារ បសយ្ហាវហារ បរិកប្បាវហារ បដិច្ឆន្នាវហារ និងកុសាវហារ ទើបបានសម្ដែងទុកហើយត្រឹមតែឈ្មោះ ក្នុងការពណ៌នាអត្ថនៃបទនេះថា **អាទិយេយ្យ** ក្នុងខាងដើម ។ ហើយគប្បីជ្រាបការផ្សេងគ្នានៃអវហារទាំងនេះ ដូចពោលតទៅនេះថា

## អវហារ ៥ យ៉ាង

ពិតហើយ ភិក្ខុអង្គណាមួយ ពួនធ្វើចោរកម្ម មានការកាត់ទីតនៃជញ្ជាំងជាដើម លួចទ្រព្យដែលមានម្ចាស់ ក្នុងវេលាយប់ ឬវេលាថ្ងៃ ឬឆបោកយកដោយរង្វាស់រង្វាល់កោង និងកហាបណៈក្លែងក្លាយជាដើម អវហាររបស់ភិក្ខុអង្គនោះឯង ដែលកាន់យកទ្រព្យនោះ គប្បីជ្រាបថា ជាថេយ្យាវហារ ឯភិក្ខុ

ណា គំរាមកំហែងអ្នកដទៃ គឺបំពានយកដោយកម្លាំង ឬសម្លុតគំរាម គឺសម្តែងភ័យ កាន់យកទ្រព្យរបស់ជនទាំងនោះ ដូចពួកចោរដែលសម្លាប់ឈ្លើយ ធ្វើបទូសកម្ម មានសម្លាប់អ្នកដើរផ្លូវ និងសម្លាប់អ្នកស្រុកជាដើម ( និង ) ដូចឥស្សរជន មានព្រះរាជា និងមហាមាត្យរបស់ព្រះរាជាជាដើម ធ្វើការរឹបជាន់យកផ្ទះរបស់អ្នកដទៃ ដោយអំណាចសេចក្តីក្រោធ និងប្រើអំណាច ទារពលី លើសជាងពលីដែលខ្លួនកំណត់ អវហាររបស់ភិក្ខុនោះដែលកាន់យកយ៉ាងនោះ គប្បីជ្រាបថា ជាបសយ្ហាវហារ ចំណែកអវហាររបស់ភិក្ខុ ដែលកំណត់ទុក ហើយកាន់យក លោកហៅថា បរិប្បាវហារ ។ បរិប្បាវហារនោះ មាន ២ យ៉ាង ទាក់ទងដោយការកំណត់ទ្រព្យ និងកំណត់ឱកាស ។

ក្នុងបរិកប្ប ២ យ៉ាងនោះ កំណត់ដោយទ្រព្យ គប្បីជ្រាបយ៉ាងនេះថា ភិក្ខុអង្គខ្លះ ក្នុងសាសនានេះ ត្រូវការដោយសំពត់សាដក ទើបចូលទៅកាន់បន្ទប់ តាំងចិត្តទុកថា បើជាសាដក អញនឹងកាន់យក បើជាអំបោះ អញនឹងមិនកាន់យក ហើយកាន់យកថង់ទៅក្នុងវេលារាត្រី ។ បើក្នុងថង់នោះជាសាដក ត្រូវអាបត្តិបារាជិក ក្នុងខណៈដែលលើកឡើងនោះឯង បើមានអំបោះនៅរក្សានៅឡើយ ។ លោកនាំចេញទៅខាងក្រៅ ស្រាយចេញ ដឹងថា ជាអំបោះ នាំមកទុកក្នុងទីដើមវិញ នៅរក្សានៅឡើយដូចគ្នា បើដឹងថា ជាអំបោះ ហើយដើរទៅដោយគិតថា របស់ណាដែលអញលួចបាន ក៏ត្រូវកាន់យករបស់នោះ គប្បីកាត់អាបត្តិដោយជំហានដាក់លើផែនដី ហើយកាន់យក ត្រូវអាបត្តិបារាជិក ក្នុងខណៈលើកឡើង ។ លោកត្រូវពួកម្ចាស់ទ្រព្យស្រែក

អ៊ូអរឡើងថា ចោរ ចោរ ហើយចោលគេចទៅ នៅរក្សានៅឡើយ ពួកម្ចាស់ទ្រព្យឃើញហើយកាន់យកទៅ យ៉ាងនោះជាការល្អ បើអ្នកដទៃណាមួយកាន់យក ជាភណ្ឌទេយ្យដល់ភិក្ខុនោះ ។ ក្រោយមក កាលពួកម្ចាស់ទ្រព្យត្រឡប់ទៅហើយ ភិក្ខុឃើញរបស់នោះក្នុងទីនោះឯង ទើបកាន់យកដោយគិតថា របស់នេះអញនាំចេញមកពីមុន ឥឡូវនេះ ជារបស់អញទេតើ ដូច្នេះនៅរក្សានៅឡើយ តែជាភណ្ឌទេយ្យ ។ កាលភិក្ខុកំណត់ទុកហើយ កាន់យកដោយន័យជាដើមថា បើជាអំបោះអញនឹងកាន់យក បើជាសាដកអញមិនកាន់យកទេ បើជាទឹកដោះថ្លា អញនឹងកាន់យក បើជាប្រេងអញមិនកាន់យកទេ ដូច្នេះ មានន័យដូចគ្នានោះឯង ។

ចំណែកក្នុងមហាបច្ចរីអដ្ឋកថាជាដើម ពោលទុកថា បើភិក្ខុមានសេចក្តីត្រូវការដោយសំពត់សាដក កាន់យកថង់សំពត់សាដកនោះឯង ចេញទៅទុកខាងក្រៅ ស្រាយចេញហើយ ឃើញថា នេះជាសាដក ហើយទៅគប្បីកាត់អាបត្តិដោយជំហានដូចគ្នា ក្នុងមហាបច្ចរីអដ្ឋកថាជាដើមនេះ បរិកប្បឈ្មោះថា រមែងប្រាកដ ព្រោះលោកបានកំណត់ទ្រព្យទុកថា បើជាសាដកអញនឹងកាន់យក បរិកប្បាវហារ ឈ្មោះថា មិនប្រាកដ ព្រោះឃើញហើយទើបលួច ។ តែក្នុងមហាអដ្ឋកថា លោកកាត់អាបត្តិអវហារដល់ភិក្ខុដែលលើកឡើងនូវទ្រព្យដែលខ្លួនកំណត់ទុក ដែលខ្លួនមើលមិនឃើញ តែគង់តាំងនៅក្នុងភាពជាទ្រព្យដែលខ្លួនកំណត់ទុកហើយនោះឯង ។ ព្រោះហេតុនោះទើបបរិកប្បាវហារ ឈ្មោះថា ប្រាកដក្នុងមហាអដ្ឋកថានោះ ។ អវហារដែល

ពោលក្នុងមហាអដ្ឋកថានោះ សមដូចព្រះបាលីថា **តំ មញ្ញមានោ តំ អវហរិ** សម្គាល់ថា ជារបស់នោះ លួចរបស់នោះ ដូច្នេះឯង ។ បណ្តាបរិកប្បទាំង ២ នោះ បរិកប្បណាដែលប្រព្រឹត្តទៅដោយន័យជាដើមថា បើជាសាដក អញនឹងកាន់យក ដូច្នេះ បរិកប្បនេះ ឈ្មោះថា ភណ្ឌបរិកប្ប ។

ចំណែកកំណត់ដោយឱកាស គប្បីជ្រាបយ៉ាងនេះថា ភិក្ខុឡេះឡោះអង្គខ្លះ ក្នុងសាសនានេះ ចូលទៅកាន់បរិវេណរបស់អ្នកដទៃ ឬផ្ទះរបស់ត្រកូល ឬរោងដែលជាទីធ្វើការងារ ក្នុងព្រៃក្តី ហើយអង្គុយក្នុងទីនោះ ដោយការប្រាស្រ័យសន្ទនា ឆ្មៀងមើលបរិក្ខារដែលជាទីតាំងនៃការលោភឯណាមួយ ។ កាលរំពៃមើល ប្រទះឃើញហើយ ទើបបានធ្វើការកំណត់ចំណាំទុក ដោយអំណាចទីកន្លែង មានទ្វារ បន្ទប់ ខាងក្រោមប្រាសាទ បរិវេណខ្លោងទ្វារ និងគល់ឈើជាដើម ហើយកំណត់ចំណាំទុកថា បើពួកជនឃើញអញក្នុងចន្លោះនេះ អញនឹងសងដល់ជនទាំងនោះៗ ឯង ធ្វើអាការជាកាន់យកដើម្បីមើលគ្រាប់ទៅ បើពួកម្ចាស់ទ្រព្យមិនឃើញសោត អញក៏នឹងលួចយក ដូច្នេះ កាលភិក្ខុកាន់យកទ្រព្យនោះ កន្លងដែនកំណត់ទុកទៅ ត្រូវអាបត្តិបារាជិក ។ បើលោកកំណត់ដែនឧបចារៈទុក ដើរបែរមុខទៅតាមនោះឯង មនសិការកម្មដ្ឋានជាដើមក្តី បញ្ជូនចិត្តទៅកាន់ទីដទៃក្តី ឈានកន្លងដែនឧបចារៈទៅទាំងមិនមានសតិ ជាភណ្ឌទេយ្យ ។ កាលលោកទៅដល់ទីនោះហើយ មានចោរ ដំរី ពាឡម្រឹគ ភ្លៀងធ្លាក់ឡើង ហើយភិក្ខុឈានកន្លងស្ថានទីនោះទៅដោយរហ័ស ព្រោះប្រាថ្នានឹងផុតអំពីឧបទ្រវនោះ ជាភណ្ឌទេយ្យដូចគ្នា ។

ក្នុងពាក្យនេះ អាចារ្យពួកខ្លះពោលថា ព្រោះក្នុងខាងដើមនោះឯង លោកកាន់យកដោយថេយ្យចិត្ត ព្រោះដូច្នោះ ទើបរក្សាមិនបាន ជាអវហារនោះឯង ។ នេះជាន័យក្នុងមហាអដ្ឋកថាប៉ុណ្ណោះ ។ ចំណែកក្នុងមហាបច្ចរី ពោលថា បើភិក្ខុអង្គនោះ ឡើងជិះដីរ ឬសេះ ខាងក្នុងដែនកំណត់ មិនដេញដីរ ឬសេះ ដីរ ឬសេះនោះទៅខ្លួនឯង លោកមិនឲ្យអ្នកដទៃដេញ សូម្បីកន្លងដែនកំណត់ទៅ រមែងមិនត្រូវអាបត្តិបារាជិក ត្រឹមតែជាភណ្ឌទេយ្យប៉ុណ្ណោះ ។ ក្នុងបរិកប្ប ២ យ៉ាងនោះ បរិកប្បដែលប្រព្រឹត្តទៅថា បើពួកជនឃើញអាញក្នុងចន្លោះនេះ អាញនឹងសងដល់ជនទាំងនោះឯង ធ្វើអាកប្បកិរិយា ជាកាន់យកដើម្បីនឹងមើល ហើយត្រាច់ទៅ នេះឈ្មោះថា ឱកាសបរិកប្ប ។ អវហាររបស់ភិក្ខុដែលកំណត់ទុក ហើយកាន់យក ដោយអំណាចនៃបរិកប្បទាំង ២ នេះ ដូចពណ៌នាមកនេះ គប្បីជ្រាបថា ជាបរិកប្បាវហារ ។

ចំណែកការបិទបាំងទុក ហើយទើបលួច ឈ្មោះថា បដិច្ឆន្នាវហារ ។ បដិច្ឆន្នាវហារនោះ គប្បីជ្រាបយ៉ាងនេះថា ភិក្ខុអង្គណា កាលពួកមនុស្សកំពុងលេង ឬកំពុងចូលទៅក្នុងសួនជាដើម ឃើញទ្រព្យ គឺគ្រឿងអលង្ការដែលគេដោះទុក ទើបយកធូលី ឬស្លឹកឈើបិទបាំងទុក ដោយគិតក្នុងចិត្តថា បើអាញឱនចុះកាន់យក ពួកមនុស្សនឹងដឹងអាញថា សមណៈកាន់យកអ្វី ហើយគប្បីបៀតបៀនអាញ ទើបគិតថា ពេលក្រោយ អាញនឹងកាន់យក ដូច្នេះ ការលើកទ្រព្យឡើងនូវទ្រព្យដោយហេតុ មានប្រមាណប៉ុណ្ណោះ មិនទាន់មានដល់ភិក្ខុអង្គនោះ ព្រោះហេតុនោះ ទើបមិនទាន់ជាអវហារមុន ។

តែពេលណា ពួកមនុស្សទាំងនោះបំណងនឹងចូលទៅខាងក្នុងស្រុក កាលរកទ្រព្យនោះមិនឃើញ ទើបគិតថា ឥឡូវនេះ ព្រលប់ហើយ ចាំស្អែកសិនចុះ ពួកយើងនឹងដឹង ហើយក៏ទៅទាំងនៅមានសេចក្ដីអាល័យនោះឯង ខណៈនោះ កាលភិក្ខុនោះលើកទ្រព្យនោះឡើង ត្រូវអាបត្តិបារាជិកក្នុងខណៈដែលលើកឡើង ។ តែបើកាលភិក្ខុកាន់យកក្នុងវេលាដែលបិទបាំងទុកហើយនោះឯង ដោយសកសញ្ញាថា ជារបស់អញ ឬដោយបង្សុកូលសញ្ញាថា ឥឡូវនេះ មនុស្សទាំងនោះទៅហើយ ពួកគេបានចោលទ្រព្យនេះហើយ ជាភណ្ឌទេយ្យៗ កាលមនុស្សទាំងនោះត្រឡប់មកក្នុងថ្ងៃទី ២ ពិនិត្យរកមើលហើយក៏មិនឃើញ ទើបដាក់ធុរៈត្រឡប់ទៅ ទ្រព្យដែលលោកកាន់យកជាភណ្ឌទេយ្យដូចគ្នា ។ ព្រោះហេតុអ្វី ព្រោះថា ពួកម្ចាស់មិនឃើញទ្រព្យ ដោយការព្យាយាមរបស់ភិក្ខុនោះ ។ ចំណែកភិក្ខុណាឃើញទ្រព្យមានសភាពបែបនោះ ដែលតាំងនៅក្នុងទីដើមនោះឯង មិនបានបិទបាំងទុក តែមានថេយ្យចិត្ត យកជើងជាន់ឲ្យលិចចុះក្នុងភក់ ឬក្នុងខ្សាច់ លុះភិក្ខុសង្កត់ឲ្យលិចចុះប៉ុណ្ណោះ ត្រូវអាបត្តិបារាជិក ។

ការប្ដូរស្លាកហើយលួច លោកហៅថា **កុសាវហារ** កុសាវហារនោះគប្បីជ្រាបដូច្នេះថា ភិក្ខុអង្គណា កាលចីវរភាជកភិក្ខុកំពុងរៀបចំដាក់ស្លាកចែកចីវរ ប្រាថ្នានឹងនាំចំណែករបស់ភិក្ខុដទៃ ដែលមានតម្លៃច្រើន ដែលតាំងនៅជិតចំណែករបស់ខ្លួនទៅ ប្រាថ្នានឹងដាក់បន្ទះស្លាកដែលចីវរភាជកភិក្ខុទុកក្នុងចំណែករបស់ខ្លួន ចូលទៅក្នុងចំណែករបស់ភិក្ខុដទៃ ទើបលើកឡើង នៅ

រក្សានៅឡើយ ។ លោកដាក់ចុះក្នុងចំណែករបស់ភិក្ខុដទៃ ក៏នៅរក្សានៅឡើយដូចគ្នា តែក្នុងវេលាណាលោកដាក់បទ្ទុះស្លាកចុះហើយ លើកស្លាករបស់ភិក្ខុដទៃឡើងអំពីចំណែកភិក្ខុដទៃ វេលានោះ គ្រាន់តែលោកលើកឡើង ក៏ត្រូវអាបត្តិបារាជិក ។ បើលោកលើកបទ្ទុះស្លាកឡើងអំពីចំណែករបស់ភិក្ខុដទៃមុន ព្រោះប្រាថ្នានឹងដាក់ចុះក្នុងចំណែករបស់ខ្លួន ក្នុងខណៈដែលលើកឡើងនៅរក្សានៅឡើយ ក្នុងខណៈដែលដាក់ចុះ ក៏នៅរក្សានៅឡើយ ហើយលើកបទ្ទុះស្លាករបស់ខ្លួនឡើង អំពីចំណែករបស់ខ្លួន ក្នុងខណៈដែលលើកឡើងនោះឯង នៅរក្សានៅឡើយ កាលលើកបទ្ទុះស្លាកនោះឡើង ហើយដាក់ចុះក្នុងចំណែករបស់ភិក្ខុដទៃ លុះផុតអំពីដៃ ក៏ត្រូវអាបត្តិបារាជិក ។ តែបើបទ្ទុះស្លាកដែលដាក់ក្នុងចំណែកទាំងពីរមើលមិនឃើញ ក្រោយមក កាលភិក្ខុដ៏សេសទៅហើយ នវកភិក្ខុក្រៅអំពីនេះសួរថា លោកម្ចាស់ បទ្ទុះស្លាករបស់ខ្ញុំមិនប្រាកដ ។ ទើបភិក្ខុជាថេរៈពោលថា អាវុសោ សូម្បីរបស់ខ្ញុំក៏មិនប្រាកដដែរ នវកភិក្ខុសួរថា លោកម្ចាស់ ចំណែករបស់ខ្ញុំដូចម្តេច ទើបភិក្ខុជាថេរៈបង្ហាញចំណែករបស់ខ្លួនថា នេះចំណែករបស់លោក កាលនវកភិក្ខុអង្គនោះប្រកែក ឬមិនប្រកែកក៏ដោយ ទទួលយកចំណែកនោះទៅ ភិក្ខុក្រៅពីនេះ ( គឺព្រះថេរៈ ) លើកចំណែករបស់នវកភិក្ខុនោះឡើង ត្រូវអាបត្តិបារាជិកក្នុងខណៈដែលលើកឡើង ។ ទោះបីនវកភិក្ខុនោះប្រាប់លោកថា ខ្ញុំមិនព្រមឲ្យចំណែករបស់ខ្ញុំដល់លោកម្ចាស់ទេ លោកម្ចាស់ដឹងចំណែករបស់ខ្លួនហើយសូមកាន់យកចុះ ភិក្ខុជាថេរៈសូម្បីដឹងថា នេះមិនមែនចំណែករបស់អញ

បានកាន់យកចំណែករបស់នវកភិក្ខុអង្គនោះឯង ត្រូវអាបត្តិបារាជិកក្នុងខណៈដែលលើកឡើង ។ តែបើនវកភិក្ខុគិតថា នឹងមានប្រយោជន៍អ្វី ដោយការទាស់ទែងគ្នានេះថា នេះចំណែករបស់លោក នេះចំណែករបស់ខ្ញុំ ទើបពោលថា ទោះជាចំណែករបស់ខ្ញុំក៏ដោយ របស់លោកក៏ដោយ ចំណែកណាល្អ សូមលោកម្ចាស់កាន់យកចំណែកនោះចុះ ដូច្នេះ លោកឈ្មោះថា កាន់យកចំណែកដែលគេឲ្យហើយ ទើបមិនមានអវហារក្នុងការកាន់យកនេះ ។ បើភិក្ខុនោះខ្លាចចំពោះការវិវាទគ្នា ដែលត្រូវពួកភិក្ខុជាស់តឿនថា ចូរលោកទទួលយកចំណែកតាមដែលលោកពេញចិត្តចុះ ក៏វៀរចំណែកដែលល្អរបស់ខ្លួន កាន់យកចំណែកដែលអាក្រក់នោះឯងទៅ ក្រោយមក កាលភិក្ខុជាថេរៈកាន់យកចំណែកដែលសល់ អំពីការជ្រើសរើសហើយ ក៏មិនជាអវហារដូចគ្នា ដូច្នេះឯង ។

វិនីតវត្ថុក្នុងទុតិយបារាជិក ចប់

# កថាសរុបរឿងទូទៅ

អដ្ឋកថាចារ្យទាំងឡាយ ពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ការចែកចីវរតែម្យ៉ាងប៉ុណ្ណោះ មកហើយដោយអំណាចការប្តូរស្លាកក្នុងទីនេះៗ តែគួរនាំការកើតឡើងនៃបច្ច័យទាំង ៤ និងការចែកមកសម្តែងទុកផងដែរ ។ កាលពោលទុកយ៉ាងនោះហើយ ទើបពោលកថាប្រារព្ធចីវរដែលកើតឡើងតាំងអំពីពេទ្យជីវកកោមារភច្ចនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ទ្រង់ទទួលយកសំពត់សិវេយ្យកមួយគូរបស់ខ្ញុំព្រះអង្គ សូមទ្រង់អនុញ្ញាតគហបតិចីវរដល់ភិក្ខុសង្ឃផង ដូច្នេះ ដោយពិស្តារក្នុងចីវរក្ខន្ធកៈ ពោលបិណ្ឌបាតកថា ផ្តើមអំពីសូត្រនេះថា សម័យនោះឯង ក្រុងរាជគ្រឹះ កើតទុរ្ភិក្ស ( អត់បាយ ) មនុស្សទាំងឡាយ មិនអាចនឹងធ្វើសង្ឃភត្តបាន ហើយក៏ប្រាថ្នានឹងធ្វើឧទ្ទេសភត្ត និមន្តនភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត និងបាដិបទិកភត្ត ដូច្នេះ ដោយពិស្តារក្នុងសេនាសនក្ខន្ធកៈ ពោលសេនាសនកថា ផ្តើមអំពីរឿងឆព្វគ្គិយភិក្ខុយ៉ាងនេះថា សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុ ជួសជុលវិហារធំមួយ ដែលមាននៅក្នុងទីបំផុតដែន ដោយគិតគ្នាថា ពួកយើងនឹងនៅចាំវស្សាក្នុងវិហារធំនេះ ។ ពួកឆព្វគ្គិយភិក្ខុ បានឃើញពួកសត្តរសវគ្គិយភិក្ខុ កំពុងតែជួសជុលវិហារ ដូច្នេះ ដោយពិស្តារក្នុងសេនាសនក្ខន្ធកៈនោះឯង នឹងពោលអំពីភេសជ្ជកថា មានទឹកដោះថ្លាជាដើម ក្នុងទីបំផុតនៃសេនាសនកថានោះដោយពិស្តារ ។ ឯខ្ញុំនឹងពោលកថាទាំងអស់នោះ ក្នុងអាគតដ្ឋាននៃកថានោះៗ ឯង ។ កាលខ្ញុំពោលយ៉ាងនោះ ហេតុ ឈ្មោះថា ខ្ញុំពោលស្រេចហើយ ខាងដើមនោះឯង ។

[ ១៣៦ ] រឿងពេងភ្លើង បន្ទាប់អំពីរឿងនេះទៅ មានអត្ថងាយយល់ហើយ ។

[ ១៣៧ ] ក្នុងវិឃាសវត្ថុ ៥ រឿង មានវិនិច្ឆ័យដូច្នេះថា ភិក្ខុទាំងឡាយនោះ ឲ្យអនុបសម្បន្នធ្វើឲ្យជារបស់គួរ ហើយឆាន់ ។ តែកាលភិក្ខុកាន់យកដុំសាច់ដែលជារបស់សល់ គប្បីកាន់យកដុំសាច់ ដែលសត្វទាំងនោះស៊ីសល់ហើយ ។ បើអាចឲ្យសត្វទាំងនោះដែលកំពុងស៊ី បោះបង់ចោលហើយកាន់យក សូម្បីសាច់ដែលជាសំណល់នោះក៏គួរ ។ តែមិនគួរកាន់យកដើម្បីប្រយោជន៍ដល់ការគ្រប់គ្រងខ្លួន និងដើម្បីភាពជាអ្នកមានករុណាក្នុងសត្វដទៃ ។

[ ១៣៨ ] ក្នុងរឿងចែកបាយ របស់គួរទំពា នំ ទឹកអំពៅ និងផ្លែទន្ទាប់ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអាងបុគ្គលដែលមិនមានខ្លួន ( ដែលមិនបានមក ) ថា ចូរលោកឲ្យចំណែកដល់ភិក្ខុអង្គដទៃទៀត ។

ពីរបទថា **អមូលកំ អគ្គហេសិ** សេចក្តីថា លោកបានពោលមុសាវាទកាន់យកចំណែកដែលមិនមានខ្លួនបុគ្គលជាមូលតែម្យ៉ាង ។ លោកមិនបានកាន់យកចំណែកនោះដោយថេយ្យចិត្តឡើយ ព្រោះហេតុនោះឯង ទើបព្រះដ៏មានព្រះភាគមិនត្រាស់សួរថា អ្នកមានចិត្តដូចម្តេច ត្រាស់ថា ត្រូវអាបត្តិបាចិត្តិយ ។ ពិតហើយ កាលភិក្ខុពោលថា ចូរលោកឲ្យចំណែកដល់ភិក្ខុអង្គមួយអង្គដទៃទៀត វត្ថុនៃបារាជិករមែងមិនប្រាកដ ហើយព្រះពុទ្ធទាំងឡាយរមែងមិនត្រាស់សួរក្នុងឋានៈដូច្នេះ ។ តែបើពាក្យនោះគប្បីជាវត្ថុនៃបារាជិក

សោត គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដប៉ុណ្ណោះ ដូចអាបត្តិទុក្កដ ព្រោះការបំពានយកសួន ដូច្នោះ ការសង្ខេបក្នុងរឿងនេះ មានប្រមាណប៉ុណ្ណោះ ។

ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបដូច្នេះថា វត្ថុណាជារបស់មាននៃសង្ឃប៉ុណ្ណោះ កាលវត្ថុនោះ គឺភិក្ខុដែលសង្ឃសន្មត ឬមិនបានសន្មតក៏ដោយ កំពុងចែក កាលភិក្ខុពោលថា ចូរលោកឲ្យចំណែកដល់ភិក្ខុមួយអង្គទៀត គឺលើកយកបុគ្គលដែលមិនមានខ្លួនយ៉ាងនោះ កាន់យកដោយការពោលកុហកតែម្យ៉ាង ត្រូវអាបត្តិបាចិត្តិយផង ជាភណ្ឌទេយ្យផង ។ កាលភិក្ខុកាន់យកដោយថេយ្យចិត្ត ក៏មានន័យនេះដូចគ្នា ។ ភិក្ខុណាមិនបានអាងបុគ្គល ពោលថា ចូរលោកឲ្យមួយចំណែកទៀត ហើយកាន់យកក្ដី រាប់វស្សាកោងកាន់យកក្ដី ភិក្ខុអង្គនោះ គប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ ។ ចំណែកទ្រព្យណាជារបស់ពួកគ្រហស្ថ ដែលគេចែកប្រគេនសង្ឃក្នុងផ្ទះ ឬក្នុងអារាម ( សួន ) របស់គ្រហស្ថទាំងនោះ កាលបើទ្រព្យនោះ ដែលម្ចាស់ទ្រព្យក្ដី ជនដទៃដែលជាម្ចាស់ទ្រព្យបង្គាប់យ៉ាងនេះថា ចូរលោកប្រគេនដល់ភិក្ខុនេះក្ដី ហើយកំពុងប្រគេន បើភិក្ខុពោលថា ចូរលោកឲ្យមួយចំណែកទៀត ហើយកាន់យកដោយថេយ្យចិត្ត មិនត្រូវអាបត្តិបារាជិក និងមិនជាភណ្ឌទេយ្យ ។ តែជាភណ្ឌទេយ្យ ដល់ភិក្ខុដែលកាន់យក ដោយវស្សាកោង ។ បើទ្រព្យនោះដែលជនដទៃជាម្ចាស់ទ្រព្យមិនបានបង្គាប់យ៉ាងនេះថា ចូរប្រគេនដល់ភិក្ខុនេះ កំពុងប្រគេន កាលភិក្ខុអាងបុគ្គល កាន់យកតាមន័យមុននោះឯង ត្រូវអាបត្តិបាចិត្តិយផង ជាភណ្ឌទេយ្យផង ។ កាលភិក្ខុពោលថា ចូរឲ្យមួយចំណែក

ទៀត ហើយកាន់យកដោយថេយ្យចិត្តក្តី កាន់យកដោយរាប់វិស្សាសោនក្តី គប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ ។ ឯវិនិច្ឆ័យនេះ បុគ្គលណា ក៏អាចដឹងបាន ក្នុងអដ្ឋកថាឈ្មោះកុរុន្ទី តែក្នុងអដ្ឋកថាដទៃៗ ដឹងបានលំបាក ថែមទាំងមានវិរុទ្ធ ( ការពោលក្លាត់ ) ផងដែរ ។

ពីរបទថា **អគ្ឃលក់ំ អគ្គហោសិ** សេចក្តីថា កាលពួកម្ចាស់ទ្រព្យប្រគេន ភិក្ខុកាន់យកបាន ។

ប្រើនបទថា **អនាបត្តិ ភិក្ខុ ចារាជិកស្ស** សេចក្តីថា ទ្រព្យដែលពួកម្ចាស់ទ្រព្យប្រគេនហើយ ភិក្ខុកាន់យកបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះ មិនត្រូវអាបត្តិ ។

ប្រើនបទថា **អាបត្តិ សម្បជានមុសាវាទេ ចាចិត្តិយស្ស** សេចក្តីថា ព្រោះសម្បជានមុសាវាទ ដែលភិក្ខុអង្គនោះពោល ទើបព្រះមានព្រះភាគកាត់អាបត្តិបាចិត្តិយ ដូចក្នុងរឿងបបរ ដែលចម្អិនដោយរបស់បីយ៉ាងខាងមុខ ។

ចំណែកក្នុងការកាន់យក គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា អាហារ មានបាយជាដើមរបស់សង្ឃ ដែលសម្មតិភិក្ខុ ឬជនទាំងឡាយ មានអារាមិកជាដើម ដែលសង្ឃបង្គាប់ទុក កំពុងប្រគេន និងអាហារ មានបាយជាដើមជារបស់ពួកគ្រហស្ថ ដែលម្ចាស់ទ្រព្យ ឬជនដទៃ ដែលម្ចាស់ទ្រព្យបង្គាប់កំពុងប្រគេន កាលភិក្ខុពោលថា ចូរលោកឲ្យចំណែកដល់ភិក្ខុមួយអង្គទៀត ហើយកាន់យកជាភណ្ឌទេយ្យ ។ កាលភិក្ខុកាន់យកអាហារ មានបាយជាដើមដែលជនដទៃ កំពុងប្រគេន គប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ ។ កាលអាហារមានបាយជាដើម

ដែលអសម្មតិភិក្ខុ គឺភិក្ខុដែលសង្ឃមិនបានសន្មត ឬបុគ្គលដែលជាម្ចាស់ទ្រព្យមិនបានបង្គាប់ កំពុងប្រគេន ភិក្ខុកាលពោលថា ចូរលោកឲ្យមួយ ចំណែកទៀត ហើយកាន់យកក្តី រាប់វស្សាកោងកាន់យកក្តី គប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ ក្នុងខណៈដែលលើកចំណែកនោះឡើងនោះឯង ដូចក្នុងបត្តចតុក្កៈដូច្នោះ ។ អាហារ មានបាយជាដើមដែលពួកជនក្រៅអំពីនេះប្រគេន កាលភិក្ខុកាន់យកដោយអាការយ៉ាងនោះ ជាកណ្ឌទេយ្យ ។ ចំណែកទ្រព្យរបស់គ្រហស្ថ ដែលម្ចាស់ទ្រព្យគេបង្គាប់ថា សូមលោកម្ចាស់ប្រគេនដល់ភិក្ខុនេះក្តី ម្ចាស់ទ្រព្យប្រគេនឯងក្តី គឺប្រគេនដោយល្អហើយ ដូច្នេះឯង ។ ក្នុងអធិការពោលដោយវត្ថុ មានបាយជាដើមនេះ មានសារៈអំពីពាក្យវិនិច្ឆ័យក្នុងអដ្ឋកថាទាំងពួងមានប្រមាណប៉ុណ្ណេះ ។

[ ១៣៩ ] ក្នុងរឿងទាំងឡាយ មានរឿងរានលក់បាយជាដើម មានវិនិច្ឆ័យដូច្នេះថា រោងសម្រាប់ចម្អិនបាយលក់ដូរ ឈ្មោះថា **ឱទនិយឃរ** ។ រោងសម្រាប់ស្ងសាច់លក់ ឈ្មោះថា **សូឆាឃរ** ។ រោងសម្រាប់បង់ ឬចៀនរបស់ទំពាលក់ ឈ្មោះថា **បូវឃរ** ( រោងលក់នំ ) ។ ពាក្យដ៏សេសក្នុងរឿងរោងលក់បាយជាដើមនេះ មានប្រាកដច្បាស់ហើយ ក្នុងរឿងបរិក្ខារនោះឯង ។

[ ១៤១ ] ក្នុងរឿងតាំង មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គនោះកំណត់ចំណាំថង់យាមទុក ហើយទើបឲ្យតាំងរំកិលទៅ ដោយគិតថា អញនឹងកាន់យកថង់យាមដែលមកដល់ទីនេះ ។ ព្រោះហេតុនោះ ក្នុងការរំកិលតាំងទៅ ទើប

អវហារមិនមានដល់ភិក្ខុអង្គនោះ ។ តែលោកកាត់អាបត្តិបារាជិក ក្នុងការរំកិល ទៅហើយកាន់យកអំពី ឱកាសដែលកំណត់ទុក ។ ភិក្ខុកាលនាំទៅយ៉ាងនោះ បើមិនមានថេយ្យចិត្តក្នុងតាំង ព្រះវិនយធរគប្បីវាយតម្លៃថង់យាម កាត់អាបត្តិ ។ បើមានថេយ្យចិត្តក្នុងតាំងផង គួរវាយតម្លៃទាំងពីរយ៉ាង កាត់អាបត្តិ ។

[ ១៤២-១៤៤ ] ៣ រឿង មានរឿងពូកជាដើម ប្រាកដច្បាស់ហើយនោះឯង ។

[១៤៥-១៤៦]៣ រឿង មានរឿងការកាន់យកដោយសេចក្ដីស្និទ្ធស្នាលជាដើម មិនប្រព្រឹត្តជាអាបត្តិ ព្រោះការកាន់យក កាលពួកម្ចាស់ទ្រព្យឲ្យសង ជាកណ្ឌទេយ្យ ។ ចំណែកទ្រព្យភិក្ខុដែលចូលទៅបិណ្ឌបាត ភិក្ខុមួយអង្គដែលនៅខាងក្នុងឧបចារសីមាប៉ុណ្ណោះ ទទួលយក ទើបគួរ ។ តែបើពួកទាយកផ្ញើងដល់ពួកភិក្ខុដែលនៅខាងក្រៅឧបចារៈថា លោកម្ចាស់ទាំងឡាយទទួលយកចុះ ភិក្ខុទាំងឡាយមកហើយ ក៏ធាន់ដោយពាក្យផ្ញើងយ៉ាងនេះសូម្បីពួកភិក្ខុដែលនៅខាងក្នុងស្រុកទទួលយក ក៏គួរ ។ ពាក្យដ៏សេស ក្នុងរឿងទាំង ៣ នេះ មានអត្ថរាក់ហើយទាំងអស់ ។

[១៤៧]ក្នុង ៧ រឿង មានរឿងលួចផ្លែស្វាយជាដើម មានវិនិច្ឆ័យដូច្នេះថា មិនត្រូវអាបត្តិ ព្រោះកាន់យកដោយបង្សុកូលសញ្ញា បើពួកម្ចាស់ទ្រព្យឲ្យសង ជាកណ្ឌទេយ្យ បើបរិភោគដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក ។

[ ១៤៨ ] ក្នុងរឿងទាំងឡាយ មានរឿងពួកចោរលួចស្វាយជាដើមនោះ មានវិនិច្ឆ័យដូចតទៅនេះថា ទាំងពួកម្ចាស់ទ្រព្យ ក៏មានការអាល័យ ទាំងពួក

ចោរ ក៏មានការអាល័យ កាលភិក្ខុឆាន់ដោយបង្សុកូលសញ្ញា ជាកណ្ឌទេយ្យ កាលកាន់យកដោយថេយ្យចិត្ត ជាអវហារក្នុងខណៈដែលលើកឡើងនោះឯង ភិក្ខុនោះ ព្រះវិនយធរគប្បីវាយតម្លៃទ្រព្យកាត់អាបត្តិ ។ ពួកម្ចាស់ទ្រព្យនៅមានសេចក្តីអាល័យ តែពួកចោរអស់សេចក្តីអាល័យ ក៏មានន័យដូចគ្នា ។ ពួកម្ចាស់ទ្រព្យអស់អាល័យ ពួកចោរនៅមានសេចក្តីអាល័យ លាក់ទុកក្នុងទីស្តុកនៃកន្លែងណាមួយ ដោយគិតថា នឹងកាន់យកទៀត ដូច្នេះហើយ ទៅ ក៏មានន័យដូចគ្នា ។ បើជនទាំងពីរចំណែកអស់សេចក្តីអាល័យ ភិក្ខុទំពាស៊ីដោយបង្សុកូលសញ្ញា មិនត្រូវអាបត្តិ បើទំពាស៊ីដោយថេយ្យចិត្ត ត្រូវអាបត្តិទុក្កដ ។

[ ១៤៩ ] ចំណែកក្នុងស្វាយជាដើមរបស់សង្ឃ មានវិនិច្ឆ័យដូច្នេះថា ផ្លែឈើ មានស្វាយជាដើម ដែលកើតនៅក្នុងអារាមរបស់សង្ឃ ឬដែលគេនាំមកប្រគេនក្តី ដែលមានតម្លៃ ៥ មាសក ឬច្រើនជាង ៥ មាសក កាលភិក្ខុលួចទៅ ត្រូវអាបត្តិបារាជិក ។ ក្នុងបច្ចន្តជនបទ កាលពួកអ្នកស្រុកភៀសខ្លួនទៅ ព្រោះឧបទ្រវ គឺចោរ ពួកភិក្ខុលះបង់វិហារ ហើយទៅ ទាំងនៅមានភាពឧស្សាហ៍នោះឯង ដោយគិតថា កាលជនបទស្ងប់ហើយ ពួកយើងនឹងត្រឡប់មក ។ ពួកភិក្ខុទៅដល់វិហារដូច្នោះ គិតថា ផ្លែឈើទាំង-ឡាយ មានស្វាយទុំជាដើម ជារបស់ដែលគេលះបង់ហើយ ទើបឆាន់ដោយបង្សុកូលសញ្ញា មិនត្រូវអាបត្តិ បើឆាន់ដោយថេយ្យចិត្ត ជាអវហារ ។ ភិក្ខុអង្គនោះ ព្រះវិនយធរ គប្បីវាយតម្លៃទ្រព្យ កាត់អាបត្តិ ។

ចំណែកក្នុងមហាបច្ចរី និងក្នុងសង្ខេបអដ្ឋកថា ពោលទុកដោយមិនប្លែកគ្នាថា កាលភិក្ខុឆាន់ផ្លែឈើតូច-ធំ ក្នុងវត្តដែលគេបោះបង់ចោលដោយថេយ្យចិត្ត មិនត្រូវអាបត្តិបារាជិក ព្រោះហេតុអ្វី ព្រោះថា ផ្លែឈើទាំងឡាយក្នុងវត្តដែលគេបោះបង់ចោល ជារបស់ពួកភិក្ខុដែលមកហើយនោះឯងៗ ឯហេតុគ្រាន់តែមានសេចក្ដីឧស្សាហ៍ប៉ុណ្ណោះ ជាប្រមាណក្នុងផ្លែឈើ ដែលជារបស់នៃគណៈ និងដែលជារបស់ចំពោះបុគ្គល ។ តែបើភិក្ខុឲ្យផ្លែស្វាយទុំជាដើម អំពីផ្លែឈើដែលជារបស់គណៈ ឬរបស់បុគ្គលនោះ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល ត្រូវអាបត្តិទុក្កដ ព្រោះកុលទូសកសិក្ខាបទ ។ ភិក្ខុកាលឲ្យដោយថេយ្យចិត្ត គប្បីកាត់អាបត្តិតាមតម្លៃ ។ សូម្បីក្នុងផ្លែឈើដែលជារបស់សង្ឃ ក៏មានន័យដូចគ្នា ។ កាលភិក្ខុឲ្យផ្លែស្វាយទុំជាដើម ដែលគេកំណត់ទុកដើម្បីប្រយោជន៍ដល់សេនាសនៈ ដើម្បីសង្គ្រោះត្រកូល ត្រូវអាបត្តិទុក្កដ ។ កាលឲ្យព្រោះភាពដែលខ្លួនជាឥស្សរៈ ត្រូវអាបត្តិថុល្លច្ច័យ កាលឲ្យដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក ។ បើវត្ថុនៃបារាជិកមិនទាន់គ្រប់ គប្បីកាត់អាបត្តិតាមតម្លៃ ។ បើភិក្ខុអង្គុយឆាន់ខាងក្រៅឧបចារសីមា ព្រោះភាពដែលខ្លួនជាឥស្សរៈ ក៏ជាសំណង ។ ផ្លែឈើដែលភិក្ខុវាយជួងប្រកាសវេលា ហើយទំពាស៊ី ដោយធ្វើទុកក្នុងចិត្តថា របស់នេះគួរដល់អញដូច្នេះ ក៏ជាការទំពាស៊ីហើយដោយល្អ ។ ផ្លែឈើដែលភិក្ខុមិនវាយជួង គ្រាន់តែប្រកាសពេលតែម្យ៉ាង ហើយឆាន់ក្ដី វាយជួងតែម្យ៉ាង តែមិនប្រកាសពេលឆាន់ក្ដី មិនគោះរគាំង មិនប្រកាសពេលឆាន់ក្ដី ដឹងថា មិនមានភិក្ខុពួក

ដទៃហើយ ឆាន់ដោយគិតថា ផ្លែឈើនេះ គួរដល់អញដូច្នេះក្តី ជាការឆាន់ល្អហើយដូចគ្នា ។

[ ១៥០ ] រឿងសួនផ្កា ២ រឿង ប្រាកដច្បាស់ហើយនោះឯង ។

[ ១៥១ ] ក្នុង ៣ រឿង របស់ភិក្ខុដែលពោលតាមពាក្យប្រាប់ មានវិនិច្ឆ័យដូច្នេះថា បទពីរថា **វុត្តោ វជ្ជេមិ** សេចក្តីថា ខ្ញុំជាអ្នកដែលលោកប្រាប់ហើយ នឹងប្រាប់តាមពាក្យរបស់លោក ។

ត្រើនបទថា **អនាបត្តិ ភិក្ខុ ចារាជិកស្ស** សេចក្តីថា សំពត់សាដកដែលពួកម្ចាស់ទ្រព្យប្រគេនហើយ ទើបមិនត្រូវអាបត្តិ ។

ត្រើនបទថា **ន ច ភិក្ខុវេ វុត្តោ វជ្ជេមីតិ វត្តព្វោ** សេចក្តីថា ភិក្ខុអន្លដទៃដែលភិក្ខុមួយអង្គទៀត មិនគប្បីពោលយ៉ាងនេះថា ខ្ញុំជាអ្នកដែលលោកប្រាប់ហើយ នឹងប្រាប់តាមពាក្យរបស់លោក ។ ឯភិក្ខុនឹងធ្វើការកំណត់ពោលថា ខ្ញុំនឹងកាន់យកសំពត់សាដកនេះតាមពាក្យរបស់លោក គួរ ។

ពីរបទថា **វុត្តោ វជ្ជេហិ** សេចក្តីថា លោកជាអ្នកដែលខ្ញុំប្រាប់ហើយ ចូរប្រាប់តាមពាក្យរបស់ខ្ញុំ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។ ភិក្ខុនឹងធ្វើការកំណត់ពោលក្នុង ២ រឿងនេះ ក៏គួរ ។ ពិតហើយ ភិក្ខុរមែងជាអ្នកផុតពីការតិះដៀលដោយហេតុ មានប្រមាណប៉ុណ្ណោះ ។

[ ១៥២ ] ក្នុងរឿងដែលមាននៅក្នុងចំណោមនៃរឿងកែវមណី ៣ រឿង មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **នាហំ អកល្លកោ** សេចក្តីថា ខ្ញុំមិនមែនជាអ្នកមានអាពាធឡើយ ។ ពាក្យដ៏សេសប្រាកដច្បាស់ហើយនោះឯង ។

[ ១៥៣ ] ក្នុងរឿងសូករ គឺជ្រូក ២ រឿង គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ឈ្មោះថា មិនប្រព្រឹត្តជាអាបត្តិដល់ភិក្ខុមួយអង្គ ព្រោះលោកឃើញថា ជ្រូកនេះមានការស្រេកឃ្លានគ្របសង្កត់ ហើយដោះលែងទៅ ដោយភាពជាអ្នកមានករុណាដោយពិត សូម្បីដូច្នោះ បើពួកម្ចាស់ទ្រព្យមិនយល់ព្រម ជាភណ្ឌទេយ្យ គួរនាំជ្រូកដែលស្លាប់ធំជាងនោះមកសង ឬឲ្យទ្រព្យដែលមានតម្លៃប៉ុណ្ណោះក៏បាន បើលោកមិនឃើញពួកម្ចាស់អន្ទាក់ក្នុងទីណាមួយ គប្បីដាក់សំពត់កាសាវៈ ឬកាជនៈដែលមានតម្លៃប៉ុណ្ណោះ ទុកក្នុងទីដែលពួកម្ចាស់ទ្រព្យនោះមកហើយ នឹងឃើញបានដោយជុំវិញនៃអន្ទាក់ ហើយសឹមទៅ ។ តែត្រូវអាបត្តិដល់ភិក្ខុដែលដោះលែងទៅ ដោយថេយ្យចិត្តពិត បណ្តាសូករទាំងនេះ សូករខ្លះយកជើងទាញអន្ទាក់ កាលអន្ទាក់ដាច់ហើយ ឈរនៅដោយកិរិយាឈរ ដែលមានការឲ្យឃ្លាតចាកឋានបានជាធម្មតា ដូចទូកដែលចងទុកត្រង់ក្រសែទឹកហូរ ខ្លាំង ដូច្នោះ ជ្រូកខ្លះឈរតាមធម្មតារបស់ខ្លួន ជ្រូកខ្លះដេក ជ្រូកខ្លះជាសត្វដែលអន្ទាក់កោង ចងទុកហើយ ។ ដែលឈ្មោះថា អន្ទាក់កោង បានដល់ អន្ទាក់ដែលមានឈើដងធ្នូ ឬតម្កក់ ឬកំណាត់ឈើដទៃណាមួយជាប់ត្រង់ចុង និងជាអន្ទាក់ដែលពាក់ត្រង់ដើមឈើជាដើម ក្នុងទីនោះៗ មិនឲ្យជ្រូកដើរទៅបាន ។ ក្នុងជ្រូកទាំងនោះ ជ្រូកដែលទាញអន្ទាក់នៅឈរ មានឋានមួយប៉ុណ្ណោះ គឺត្រង់ចំណងអន្ទាក់ ។ ពិតហើយ ជ្រូកនោះ កាលអន្ទាក់របូត ឬអន្ទាក់ដាច់ រមែងគេចទៅបាន ។ ជ្រូកដែលឈរតាមធម្មតារបស់ខ្លួន មានឋាន ៥ គឺត្រង់ចំណង ១ និងជើងទាំង ៤

ជ្រូកដែលដេកមានឋាន ២ គឺត្រង់ចំណាំង ១ ទីដេក ១ ។ ជ្រូកដែលជាប់អន្ទាក់ ទៅក្នុងទីណា ទីនោះឯងជាឋាន ។ ព្រោះហេតុនោះ ភិក្ខុ ១០ អង្គក្តី ២០ អង្គក្តី ១០០ អង្គក្តី កាលលែងជ្រូកនោះផុតទៅអំពីឋាននោះៗ រមែងត្រូវអាបត្តិបារាជិក ដូចភិក្ខុច្រើនអង្គឃើញទាសៈម្នាក់ប៉ុណ្ណោះ មកហើយក្នុងទីនោះៗ ហើយឲ្យគេចទៅ ត្រូវអាបត្តិបារាជិក ដូច្នោះ ។ ចំណែកការឲ្យជ្រូកទាំង ៣ ខាងដើមបម្រះទៅ និងឲ្យឃ្លាតចាកឋាន គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងកថា ពោលដោយសត្វជើង ៤ ។ កាលភិក្ខុឲ្យលែងជ្រូកដែលខ្ទេខាំទៅ ដោយការុញ្ញាធិប្បាយ ( សេចក្តីករុណា ) ជាកណ្ឌទេយ្យ ដោយថេយ្យចិត្ត ជាបារាជិក តែបើភិក្ខុដើរតាមផ្លូវទៅ ហើយញាំងជ្រូកដែលមិនទាន់ដល់ទីតាំងនៃអន្ទាក់ ឬទីជិតខ្ទេឲ្យគេចទៅមុន មិនជាអវហារ ។ បើភិក្ខុអង្គណាឲ្យចំណី និងទឹកដល់ជ្រូកដែលជាប់អន្ទាក់ហើយ ឲ្យមានកម្លាំង ហើយធ្វើការបង្អើល ដោយតាំងចិត្តថា វានឹងភ័យ ហើយគេចទៅ បើជ្រូកគេចទៅ ភិក្ខុនោះ ត្រូវបារាជិក ។ សូម្បីកាលភិក្ខុធ្វើអន្ទាក់ឲ្យទ្រុឌទ្រោម ហើយដេញឲ្យគេចទៅ ដោយសំឡេងបង្អើល ក៏មានន័យដូចគ្នា ។ ចំណែកភិក្ខុណា ឲ្យចំណី និងទឹក ហើយទៅ ដោយធ្វើទុកក្នុងចិត្តថា ជ្រូកនឹងមានកម្លាំង ហើយគេចទៅ បើជ្រូកគេចទៅ ជាកណ្ឌទេយ្យដល់ភិក្ខុអង្គនោះ បើភិក្ខុធ្វើអន្ទាក់ឲ្យទ្រុឌទ្រោម ហើយទៅ ក៏មានន័យដូចគ្នានេះ ។ ភិក្ខុដាក់កាំបិត ឬបន្ទាត់ភ្លើងទុកជិតអន្ទាក់ ដោយគិតថា កាលអន្ទាក់ត្រូវកាំបិតកាត់ដាច់ ឬត្រូវភ្លើងឆេះ ជ្រូកនឹងគេចឯង ជ្រូកឲ្យអន្ទាក់រំកិលទៅមក ហើយគេចទៅ

បាន ក្នុងកាលអន្ទាក់ត្រូវកាត់ដាច់ ឬត្រូវភ្លើងឆេះ ជាកណ្ឌទេយ្យដល់ភិក្ខុអង្គនោះដោយពិត ។ ភិក្ខុធ្វើឲ្យអន្ទាក់ ព្រមទាំងជងរលំ ក្រោយមក ជ្រូកញាំញីអន្ទាក់នោះទៅ ជាកណ្ឌទេយ្យ ។ ជ្រូកជាសត្វត្រូវអន្លង់ប់ទាំងឡាយសង្កត់ហើយ កាលភិក្ខុប្រាថ្នានឹងឲ្យជ្រូកនោះគេចទៅ ទើបលើកអន្លប់ឡើងដោយសេចក្តីករុណា ជាកណ្ឌទេយ្យ លើកឡើងដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក ។ បើអន្លប់នោះ លុះភិក្ខុលើកឡើងហើយ សូករនៅតែមិនទៅក្រោយមក ទើបទៅ ជាកណ្ឌទេយ្យប៉ុណ្ណោះ ។ ភិក្ខុញាំងអន្លប់ដែលគេលើកឡើងបង្អាឲ្យធ្លាក់ចុះ ក្រោយមក ជ្រូកមកជាន់អន្លប់នោះ ហើយទៅ ជាកណ្ឌទេយ្យ ។ កាលភិក្ខុជួយលើកឡើងនូវជ្រូកដែលធ្លាក់រណ្តៅហើយ ដោយសេចក្តីករុណា ជាកណ្ឌទេយ្យ លើកឡើងដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក ។ ភិក្ខុញាំងរណ្តៅឲ្យពេញ ឲ្យប្រើមិនបាន ក្រោយមក ជ្រូកជាន់រណ្តៅនោះ ហើយទៅ ជាកណ្ឌទេយ្យ ។ ភិក្ខុជួយជ្រូកដែលចម្រូងមុតហើយ ដោយសេចក្តីករុណា ជាកណ្ឌទេយ្យ លើកឡើងដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក ។ ភិក្ខុដកចម្រូងគ្រវាត់ចោល ជាកណ្ឌទេយ្យ ។

ម្យ៉ាងទៀត កាលពួកអ្នកស្រុកដាក់អន្ទាក់ ឬអន្លប់ទុកក្នុងជីវត្ត ភិក្ខុគួរឃាត់ថា ទីនេះជាកន្លែងគប្បីអាស្រ័យរបស់ពួកម្រឹគ ពួកអ្នកកុំធ្វើយ៉ាងនេះក្នុងទីនេះឡើយ បើពួកអ្នកស្រុកពោលថា សូមលោកម្ចាស់នាំចេញទៅចុះ ភិក្ខុឲ្យនាំទៅក៏គួរ ។ បើគេនាំចេញទៅខ្លួនឯង ជាការល្អពិត ។ បើម្ចាស់អន្ទាក់គេមិននាំចេញទៅឯង ទាំងមិនព្រមឲ្យអ្នកដទៃនាំចេញ និងសូមការរក្សា

ហើយនាំចេញទៅក៏គួរ ។ ក្នុងវេលារក្សាសន្ទូង ពួកអ្នកស្រុករមែងធ្វើអន្ទាក់ និងគ្រឿងដាក់សត្វទាំងឡាយ មានអន្លប់ជាដើមទុកក្នុងស្រែ ដោយពោលថា ពួកយើងនឹងរក្សាសន្ទូងផង ស៊ីសាច់ផង ។ កាលរដូវសន្ទូងកន្លងទៅហើយ ពួកអ្នកស្រុកមិនមានសេចក្តីអាល័យចៀសទៅ ភិក្ខុនឹងលែងជ្រូកដែលជាប់ ឬដែលធ្លាក់ហើយក្នុងអន្ទាក់ ឬអន្លប់ជាដើមនោះ គួរ ។

វិនិច្ឆ័យក្នុងរឿង ២ រឿង ក៏ដូចគ្នានឹងការដែលពោលទុកហើយ ក្នុងរឿងជ្រូកនោះឯង ។ សូម្បីក្នុងរឿងត្រី ២ រឿង ក៏មានន័យដូចគ្នា ។

ចំណែកការប្លែកគ្នា មានដូចតទៅនេះថា កាលភិក្ខុបើកមាត់ទ្រូចេញខាងក្រោយ ទើបស្រាយសន្ទូះចេញ ឬធ្វើឲ្យមានប្រហោងត្រង់ចំហៀង ហើយគោះឲ្យត្រីចេញអំពីទ្រូ ត្រូវអាបត្តិបារាជិក ។ ត្រូវអាបត្តិបារាជិកដល់ភិក្ខុដែលបង្ហាញគ្រាប់បាយនោះឯង បញ្ឆោតត្រីឲ្យគេចទៅ ។ កាលលើកត្រីឡើង ព្រមទាំងទ្រូ ក៏ត្រូវអាបត្តិបារាជិក ។ ភិក្ខុបើកមាត់ទ្រូចេញតែម្យ៉ាង ខាងក្រោយទើបស្រាយសន្ទូះចេញ ឬធ្វើជាប្រហោង ហើយត្រីទាំងឡាយក៏គេចទៅតាមធម្មតារបស់ខ្លួន ជាភណ្ឌទេយ្យ ។ ភិក្ខុធ្វើយ៉ាងនេះហើយទើបបង្ហាញគ្រាប់បាយបញ្ឆោតត្រី ត្រីទាំងឡាយគេចទៅ ដើម្បីអាហារ ជាភណ្ឌទេយ្យដូចគ្នា ។ ភិក្ខុបើកមាត់ទ្រូចេញ ខាងក្រោយមិនបានស្រាយសន្ទូះចេញ ទាំងមិនបានធ្វើជាប្រហោងត្រង់ទីទាំងសងខាង យកតែគ្រាប់បាយបង្ហាញបញ្ឆោតតែម្យ៉ាង ចំណែកត្រីទាំងឡាយ ព្រោះត្រូវសេចក្តីឃ្លានគ្របសង្កត់ ទើបយកក្បាលត្បុលធ្វើជាប្រហោង ហើយគេចចេញទៅ ដើម្បី

អាហារ ជាកណ្ឌទេយ្យដូចគ្នា ។ ភិក្ខុបើកមាត់ទ្រូទេ ឬខាងក្រោយស្រាយសន្ទះចេញ ឬធ្វើជាប្រហោងត្រីទាំងឡាយហែលទៅហែលមក ដល់មាត់ប្រើសហើយ ក៏គេចទៅតាមសន្ទះ និងប្រហោង ជាកណ្ឌទេយ្យដូចគ្នា ។ ភិក្ខុចាប់ទ្រូទេ បោះទៅលើគុម្ពឈើ ជាកណ្ឌទេយ្យដូច្នេះឯង ។

[ ១៥៤ ] កណ្ឌៈលើយាន ក៏ដូចគ្នានឹងកណ្ឌៈក្នុងថង់យាមដែលដាក់នៅលើតាំងនោះឯង ។

[ ១៥៥-១៥៨ ] ក្នុងរឿងដុំសាច់ មានវិនិច្ឆ័យដូច្នេះថា បើភិក្ខុទទួលយក ( ចម្រៀកសាច់ ) ក្នុងអាកាស ត្រង់ទីភិក្ខុទទួលយកនោះឯងជាឋាន ។ គប្បីកំណត់ឋាននោះដោយអាការ ៦ ហើយជ្រាបការឲ្យឃ្លាតចាកឋាន ។ ពាក្យដ៏សេសក្នុងរឿងដុំសាច់នេះ និងក្នុងរឿងក្បូនជាច់ រឿងបុរសឃ្វាលគោ និងរឿងសាដករបស់ជាងជ្រលក់ គប្បីវិនិច្ឆ័យដោយន័យនៃរឿង មានរឿងពួកចោរលួចស្វាយជាដើម ។

[ ១៥៩ ] ក្នុងរឿងថ្នាំង មានវិនិច្ឆ័យដូច្នេះថា ភិក្ខុណាកាន់យកទឹកដោះថ្លា និងប្រេងជាដើមដែលមានតម្លៃមិនគ្រប់មួយបាទ ដោយធ្វើទុកក្នុងចិត្តថា អញនឹងមិនធ្វើយ៉ាងនេះទៀត តាំងនៅក្នុងសំវរៈ សូម្បីក្នុងថ្ងៃទី ២ ជាដើម កាលកើតគំនិតឡើងទៀត ក៏ធ្វើការដាក់ធុរៈយ៉ាងនោះឯងទៀត ខណៈឆាន់ ក៏ឆាន់ទឹកដោះថ្លា និងប្រេងជាដើមនោះទាំងអស់ មិនត្រូវអាបត្តិបារាជិកឡើយ លោកត្រូវអាបត្តិទុក្កដ ឬថុល្លច្ច័យ និងជាកណ្ឌទេយ្យផងដែរ ។ ភិក្ខុនេះក៏បានធ្វើយ៉ាងនោះដូចគ្នា ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់

ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ។ កាលភិក្ខុមិនធ្វើការដាក់ធុរៈ តែឆាន់ទឹកដោះថ្លា និងប្រេងជាដើមនោះ សូម្បីបន្តិចម្តងៗ ដោយតាំងចិត្តថា អញនឹងឆាន់រាល់ៗ ថ្ងៃ ដូច្នេះ ក្នុងថ្ងៃណាតម្លៃគ្រប់មួយបាទ ក្នុងថ្ងៃនោះត្រូវអាបត្តិបារាជិក ។

[ ១៦០ ] រឿងបបួលគ្នាលួច គប្បីជ្រាបតាមន័យនៃការវិនិច្ឆ័យ ដែលពោលហើយក្នុងសំវិធានវហារ ។

[ ១៦១ ] រឿងភិក្ខុលួចអង្ករមួយក្តាប់ គប្បីជ្រាបតាមន័យនៃការវិនិច្ឆ័យដែលពោលហើយ ក្នុងរឿងទាំងឡាយ មានរឿងរោងលក់បាយជាដើម ។

[ ១៦២ ] រឿងពួកចោរសម្លាប់មេគោ និងចោរសម្លាប់ជ្រូកស៊ីសាច់ គប្បីជ្រាបតាមន័យនៃការវិនិច្ឆ័យដែលពោលហើយ ក្នុងរឿងទាំងឡាយ មានរឿងចោរលួចផ្លែស្វាយជាដើម ។

[ ១៦៣-១៦៤ ] រឿងភិក្ខុលួចស្មៅ ២ រឿង មានអត្ថងាយហើយ ។

[ ១៦៥ ] ក្នុងរឿងទាំងឡាយ មានរឿងឲ្យចែកផ្លែស្វាយជាដើម មានវិនិច្ឆ័យដូច្នេះថា ភិក្ខុទាំងនោះ បានទៅកាន់អាវាសក្បែរស្រុកមួយកន្លែង ដែលមានកំណត់ចំនួនភិក្ខុទុក ។ ពួកភិក្ខុដែលនៅក្នុងអាវាសនោះឯង កាលនឹងឆាន់ផ្លែឈើតូច-ធំ ក្នុងកាលអាគន្តុកៈទាំងនោះមកហើយ មិនបានប្រាប់កប្បិយការកៈថា ពួកអ្នក ចូរប្រគេនផ្លែឈើដល់ព្រះថេរៈទាំងឡាយ ។ គ្រានោះ ទើបភិក្ខុទាំងនោះពោលថា ស្វាយរបស់សង្ឃមានដល់ពួកខ្ញុំឬ ទើបឲ្យគោះរគាំងចែកគ្នា បានប្រគេនចំណែកដល់ភិក្ខុម្ចាស់ទីកន្លែងទាំងនោះតាម

លំដាប់វស្សា សូម្បីខ្លួនឯងក៏ឆាន់ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ដល់អាគន្តុកៈទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ដើម្បីឆាន់ មិនត្រូវអាបត្តិឡើយ ។ ព្រោះហេតុនោះ ឥឡូវនេះ ក្នុងអាវាសណា ភិក្ខុម្ចាស់អាវាសមិនប្រគេនដល់ពួកអាគន្តុកភិក្ខុ ហើយកាលដល់រដូវផ្លែឈើ ឃើញថា អាគន្តុកភិក្ខុពួកដទៃមិនមាន ខ្លួនឯងក៏ឆាន់ដោយកិរិយាដែលជាចោរ កាលដែលពួកអាគន្តុកភិក្ខុ គោះរគាំងឡើងហើយ ចែកគ្នាឆាន់ក្នុងអាវាសដូច្នោះ រមែងគួរ ។ ចំណែកក្នុងដើមឈើណា ពួកភិក្ខុម្ចាស់អាវាសរក្សាដើមឈើទាំងឡាយ កាលដល់រដូវផ្លែឈើ ក៏ចែកគ្នាឆាន់ ទាំងនាំទៅប្រើក្នុងបច្ច័យ ៤ ដោយប្រពៃ ពួកអាគន្តុកភិក្ខុមិនមានឥស្សរៈក្នុងដើមឈើនោះ ។ ដើមឈើពួកណា ដែលទាយកកំណត់ប្រគេនទុក ដើម្បីប្រយោជន៍ដល់ចីវរ ពួកអាគន្តុកភិក្ខុមិនមានឥស្សរៈក្នុងដើមឈើទាំងនោះ ។ សូម្បីក្នុងដើមឈើទាំងឡាយ ដែលទាយកកំណត់ប្រគេនទុក ដើម្បីបច្ច័យដ៏សេស ក៏មានន័យដូចគ្នា ។ ចំណែកដើមឈើពួកណា ដែលទាយកមិនបានកំណត់ទុកយ៉ាងនោះ ហើយពួកភិក្ខុម្ចាស់អាវាសក៏រក្សាគ្រប់គ្រងដើមឈើទាំងនោះទុក ទាំងឆាន់ដោយកិរិយាដែលជាចោរ ក្នុងដើមឈើទាំងនោះ អាគន្តុកៈទាំង-ឡាយ មិនគួរតាំងនៅក្នុងកតិការបស់ពួកភិក្ខុម្ចាស់អាវាស ។ ដើមឈើណា ដែលទាយកប្រគេនទុកដើម្បីឲ្យជាប្រយោជន៍ដល់ការបរិភោគផ្លែ ហើយពួកអាវាសិកភិក្ខុក៏រក្សាគ្រប់គ្រងដើមឈើទាំងនោះទុក នាំទៅប្រើប្រាស់ដោយប្រពៃ ក្នុងដើមឈើនោះៗ ឯង អាគន្តុកភិក្ខុទាំងឡាយ គួរតាំងនៅក្នុងកតិកា

របស់អាវាសិកភិក្ខុទាំងនោះ ។

ចំណែកក្នុងមហាបច្ចរី ពោលទុកថា កាលភិក្ខុឆាន់ផ្លែឈើដែលទាយក ប្រគេនដើម្បីបច្ច័យ ៤ ដោយថេយ្យចិត្ត គប្បីឲ្យវាយតម្លៃទ្រព្យ កាត់អាបត្តិ កាលចែកគ្នាឆាន់ ដោយអំណាចការបរិភោគ ជាភណ្ឌទេយ្យ បណ្តាផ្លែឈើ ទាំងនេះ កាលភិក្ខុចែកគ្នាឆាន់ផ្លែឈើដែលទាយកកំណត់ទុកដើម្បីប្រយោជន៍ ដល់សេនាសនៈ ដោយអំណាចនៃការបរិភោគ ត្រូវអាបត្តិថុល្លច្ច័យផង ជាភណ្ឌទេយ្យផង ។

ផ្លែឈើដែលទាយកឧទ្ទិសប្រគេន ដើម្បីប្រយោជន៍ដល់ចីវរ គួរបង្អោន ចូលទៅក្នុងចីវរប៉ុណ្ណោះ ។ បើជាវត្តដែលមានភិក្ខាហាររកបានដោយ លំបាក ភិក្ខុទាំងឡាយ រមែងលំបាកដោយបិណ្ឌបាត ចំណែកចីវររកបានងាយ នឹង ធ្វើអបលោកនកម្ម ដើម្បីសេចក្តីល្អដល់សង្ឃ ហើយបង្អោនចូលទៅក្នុង បិណ្ឌបាត ក៏គួរ ។ កាលលំបាកដោយសេនាសនៈ ឬគិលានប្បច្ច័យ ទោះ ធ្វើអបលោកនកម្ម ដើម្បីការឃើញប្រពៃនៃសង្ឃ ហើយបង្អោនចូលទៅដើម្បី ប្រយោជន៍ដល់សេនាសនៈ និងគិលានប្បច្ច័យ ក៏គួរ ។ សូម្បីក្នុងផ្លែឈើ ដែលទាយកឧទ្ទិសប្រគេនទុក ដើមប្រយោជន៍ដល់បិណ្ឌបាត និងដើម្បី ប្រយោជន៍ដល់គិលានប្បច្ច័យ ក៏មានន័យដូចគ្នា ។ ចំណែកទ្រព្យដែលទាយក ឧទ្ទិសប្រគេនទុក ដើម្បីប្រយោជន៍ដល់សេនាសនៈ ជាគរុភណ្ឌ គួររក្សាគ្រប់ គ្រប់ទ្រព្យនោះទុក ហើយបង្អោនចូលទៅ ដើម្បីប្រយោជន៍ដល់សេនាសនៈ នោះប៉ុណ្ណោះ បើជាវត្តដែលរកអាហារបានដោយលំបាក ភិក្ខុទាំងឡាយ នឹង

ចិញ្ចឹមអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតមិនបាន ក្នុងវត្ត ឬដែនទេះ វិហារ របស់ពួកភិក្ខុដែលកៀសខ្លួនទៅក្នុងទីដទៃ ព្រោះរាជភ័យ រោគភ័យ និងចោរ-ភ័យជាដើម រមែងធ្លុះធ្លាយទៅ ជនពួកដទៃ រមែងធ្វើដើមត្នោត និងដើមដូង ជាដើមឲ្យវិនាសទៅ ចំណែកភិក្ខុអាស្រ័យសេនាសនបច្ច័យហើយ រមែងអាច ចិញ្ចឹមអត្តភាពឲ្យប្រព្រឹត្តទៅបាន ក្នុងកាលមានសភាពបែបនេះ សូម្បីចំណាយ សេនាសនៈ ហើយបរិភោគ ដើម្បីប្រយោជន៍ដល់ការរក្សាសេនាសនៈ ព្រះ ដ៏មានព្រះភាគទ្រង់អនុញ្ញាតទុកហើយ ព្រោះដូច្នោះ វៀរសេនាសនៈដែលល្អ ទុក ១-២ ខ្នង សេនាសនៈក្រៅអំពីនេះ តាំងពីសេនាសនៈដើមដល់សេនា-សនៈចុង ទោះបីចំណាយដើម្បីប្រយោជន៍ដល់បិណ្ឌបាត ក៏គួរ តែមិនគួរ បង្អោនចូលទៅធ្វើឲ្យដាច់វត្ថុដែលជាតម្លៃដើមៗ ចំណែកក្នុងចំការដែលទាយក កំណត់ប្រគេនទុកដើម្បីប្រយោជន៍ដល់បច្ច័យ ៤ មិនគួរធ្វើអបលោកនកម្ម តែ បើបង្អោនចូលទៅដើម្បីប្រយោជន៍ដល់បច្ច័យដែលនៅខ្វះខាត រមែងសមគួរ ។ គួររក្សាចំការទុក ទោះបីចំណាយថ្លៃឈ្នួលទៅឲ្យរក្សាទុក ក៏គួរ ។ ចំណែក ជនពួកណាបានទទួលថ្លៃឈ្នួល ធ្វើផ្ទះនៅចាំក្នុងចំការនោះឯង បើជនទាំង នោះប្រគេនដូង ឬផ្លែត្នោតទុំដល់ភិក្ខុទាំងឡាយដែលមកហើយ ជនអ្នកចាំ ចំការទាំងនោះ រមែងបានដើម្បីប្រគេនផ្លែឈើចំពោះដែលសង្ឃអនុញ្ញាតដល់ ពួកគាត់ថា ពួកអ្នកនឹងស៊ីផ្លែឈើ មានប្រមាណប៉ុណ្ណេះបានរាល់ថ្ងៃ ដូច្នេះ ។ ការដែលភិក្ខុទទួលយកផ្លែឈើរបស់ជនទាំងនោះ ដែលប្រគេនច្រើនក្រៃលែង ឡើងទៅជាងផ្លែឈើដែលសង្ឃអនុញ្ញាតនោះ រមែងមិនគួរ ។ ឯបុគ្គលណា

បានទទួលតម្លៃសួនហើយ រមែងប្រគេនចំពោះកប្បិយកណ្ឌប៉ុណ្ណោះដល់សង្ឃ ដើម្បីប្រយោជន៍ដល់បច្ច័យ ៤ បុគ្គលនេះរមែងបានដើម្បីប្រគេនផ្លែឈើច្រើនបាន ។ សូម្បីចំការដែលទាយកទុកប្រគេនដល់ព្រះចេតិយ ដើម្បីប្រយោជន៍ដល់ប្រទីប ឬដើម្បីការបដិសង្ខរណៈ ( ជួសជុល ) របស់ដែលធ្លុះធ្លាយបែកបាក់ សង្ឃគួររក្សាទុក សូម្បីចំណាយតម្លៃឈ្នួលខ្លះ ក៏គួរឲ្យរក្សាទុក ។ ចំណែកក្នុងចំការដែលទាយក ប្រគេនដល់ព្រះចេតិយនេះ ចំណាយតម្លៃដែលជារបស់ចេតិយខ្លះ ដែលជារបស់សង្ឃខ្លះ គួរ ។

[ ១៦៦ ] ការប្រគេនផ្លែឈើដែលមានក្នុងចំការនោះ( ដល់ភិក្ខុទាំង-ឡាយដែលមកហើយ ) របស់ពួកជនដែលស្នាក់នៅក្នុងសួននោះឯងក្តី អ្នករក្សាសួនដោយតម្លៃក្តី ហើយប្រគេនតែកប្បិយកណ្ឌ ( ដល់សង្ឃ ) គប្បីជ្រាបដូចដែលពោលហើយនោះឯង ។

ក្នុងពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិ ព្រោះបុគ្គលរក្សាប្រគេន ដែលមាននៅក្នុងរឿងទាំងឡាយ មានរឿងអ្នករក្សាស្វាយជាដើម មានវិនិច្ឆ័យដូច្នេះថា សួរថា អ្នករក្សាប្រគេនប៉ុនណា ទើបគួរ ប្រគេនប៉ុនណាមិនគួរ ឆ្លើយថា ព្រះមហាសុមត្ថេរពោលទុកមុនថា ផ្លែឈើណាដែលអ្នករក្សាកំណត់ប្រគេនដោយពាក្យថា សូមលោកម្ចាស់កាន់យកផ្លែឈើមានប្រមាណប៉ុណ្ណោះរាល់ៗ ថ្ងៃចុះ ផ្លែឈើនោះឯង រមែងគួរ អ្នករក្សាប្រគេនលើសទៅជាងនោះ មិនគួរ ។ ចំណែកព្រះមហាបទុមត្ថេរ ពោលថា បញ្ជីដែលពួកអ្នករក្សាកត់ត្រាទុក ឬធ្វើសញ្ញាជាគ្រឿងចំណាំប្រគេនទុក នឹងមាន

ប្រយោជន៍អ្វី អ្នករក្សាទាំងនោះ ក៏ជាឥស្សរៈនៃផ្លែឈើ ដែលអ្នករក្សាលះបង់ហើយ ក្នុងដៃរបស់ពួកគាត់ ព្រោះហេតុនោះ ផ្លែឈើដែលអ្នករក្សានោះប្រគេន សូម្បីច្រើនក៏គួរ ។

ចំណែកក្នុងអដ្ឋកថាកុរុន្ទី ពោលថា ពួកក្មេងកំលោះរបស់អ្នកស្រុករមែងរក្សាចំការ ឬផ្លែឈើតូច-ធំដទៃទុក ផ្លែឈើតូច-ធំដែលយុវជន ទាំងនោះប្រគេន រមែងគួរ តែភិក្ខុមិនគួរប្រើឲ្យពួកក្មេងនាំមក ហើយទើបទទួលការប្រគេនផ្លែឈើរបស់ជនអ្នកស៊ីឈ្នួលរក្សាចំការរបស់សង្ឃ និងចេតិយនោះឯង រមែងគួរ ការប្រគេនរបស់ជនអ្នកស៊ីឈ្នួលរក្សា ត្រឹមចំណែករបស់ខ្លួន ទើបគួរ ។

ក្នុងមហាបច្ចរី ពោលថា ពួកអ្នកស៊ីឈ្នួលចាំចំការរបស់គ្រហស្ថប្រគេនផ្លែឈើណាដល់ភិក្ខុទាំងឡាយ ផ្លែឈើនោះរមែងគួរ ពួកអ្នករក្សាចំការរបស់ភិក្ខុសង្ឃចែកផ្លែឈើណាអំពីតម្លៃឈ្នួលរបស់ខ្លួនប្រគេន ផ្លែឈើនោះក៏គួរ សូម្បីបុគ្គលណាបានទទួលឈ្នួលហើយ ទើបរក្សាចំការ ត្រឹមពាក់កណ្តាល ឬដើមឈើប្រកេទខ្លះប៉ុណ្ណោះ ការប្រគេនផ្លែឈើអំពីដើមឈើដែលខ្លួនរក្សានោះឯងរបស់បុគ្គលនោះ ក៏គួរ តែសម្រាប់បុគ្គលដែលជួលចំការ នឹងប្រគេនផ្លែឈើទាំងអស់ក៏គួរ ។ ពាក្យដែលលោកពោលមកទាំងអស់នោះផ្សេងគ្នាដោយព្យញ្ជនៈ តែដោយអត្ថក៏ដូចគ្នានោះឯង ព្រោះ ដូច្នោះអ្នកសិក្សាគួរជ្រាបសេចក្តីអធិប្បាយហើយ សឹមកាន់យក ។

[ ១៦៧ ] ក្នុងរឿងភិក្ខុខ្ទីឈើ មានវិនិច្ឆ័យដូច្នេះថា ច្រើនបទថា

**តាវកាលិកោ អហំ ភគវា** សេចក្ដីថា ភិក្ខុនោះប្រាជ្ញានឹងក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមានការគិតនឹងសូមខ្ចី ដូច្នេះ ទើបបានក្រាបទូលហើយ ។ ពាក្យថា **តាវកាលិកចិត្តោ** នេះ លោកពោលអធិប្បាយទុកថា ខ្ញុំព្រះអង្គ មានការគិតយ៉ាងនេះថា នឹងនាំមកសងវិញ ព្រះដ៏មានព្រះភាគត្រាស់ថា អ្នកឯងមិនត្រូវអាបត្តិ ព្រោះសូមខ្ចី ។

## បាលីមុត្តកវិនិច្ឆ័យ

ក្នុងរឿងឈើនេះ មានបាលីមុត្តកវិនិច្ឆ័យដូចតទៅនេះថា បើសង្ឃប្រើឲ្យភិក្ខុធ្វើការងាររបស់សង្ឃ ទោះជារោងឧបោសថក្ដី រោងឆាន់ក្ដី ភិក្ខុត្រូវសួរការកសង្ឃជាមុន ទើបគួរសូមខ្ចីទៅ ក្នុងឈើជាទព្វសម្ភារៈ ដែលរក្សាទុកដើម្បីសាងរោងឧបោសថជាដើម ។ ចំណែកទព្វសម្ភារៈដែលជារបស់សង្ឃឯណា មិនបានគ្រប់គ្រងថែរក្សាទុក រមែងសើមក្នុងកាលភ្លៀងធ្លាក់ និងស្ងួតព្រោះកម្ដៅថ្ងៃ ភិក្ខុទោះនាំទព្វសម្ភារៈទាំងអស់នោះមក ធ្វើជាលំនៅរបស់ខ្លួនក៏គួរ កាលសង្ឃឲ្យសង គួរសងដោយទព្វសម្ភារៈ ឬដោយតម្លៃ បើមិនអាចសម្រុះសម្រួលគ្នាបាន ភិក្ខុគួរពោលថា បពិត្រលោកម្ចាស់ សេនាសនៈដែលខ្ញុំធ្វើដោយទព្វសម្ភារៈរបស់សង្ឃ សូមលោកម្ចាស់ទាំងឡាយប្រើប្រាស់ដោយបរិភោគជារបស់សង្ឃចុះ ។ តែភិក្ខុនេះប៉ុណ្ណោះ ជាឥស្សរៈនៃសេនាសនៈនេះ ។ បើសសរថ្មក្ដី សសរឈើក្ដី សន្ទះទ្វារក្ដី បង្អួចក្ដី មិនគ្រប់គ្រាន់សោត នឹងសូមខ្ចីរបស់សង្ឃ ធ្វើឲ្យជាប្រក្រតី ក៏គួរ ។ ក្នុងទព្វសម្ភារៈដទៃ ក៏មានន័យដូចគ្នា ។

**បាលីមុត្តកវិនិច្ឆ័យ ចប់**

[ ១៦៨ ] ក្នុងរឿងភិក្ខុលួចយកទឹករបស់សង្ឃ មានវិនិច្ឆ័យដូច្នេះថា ក្នុងកាលណាទឹករមែងជារបស់ដែលរកបានដោយក្រ ក្នុងកាលនោះ ជនទាំង-ឡាយ រមែងនាំទឹកមកចម្ងាយ ១ យោជន៍ខ្លះ កន្លះយោជន៍ខ្លះ ក្នុងទឹកដែលគេហួងហែងបែបនេះ រមែងជាអវហារ ។ ពួកជនរមែងចម្អិនបបរ និងបាយឲ្យសម្រេចបានដោយទឹកណាដែលគេនាំមក ឬដែលដក់នៅក្នុងជលាល័យទាំងឡាយ មានស្រះបោក្ខរណីទាំងឡាយ ទាំងធ្វើជាទឹកផឹក និងទឹកប្រើប្រាស់តែម្យ៉ាង មិនបានធ្វើជាទឹកប្រើប្រាស់ផ្តេសផ្តាសដទៃឡើយ កាលភិក្ខុកាន់យកទឹកនោះដោយថេយ្យចិត្ត រមែងជាអវហារ ។ ចំណែកភិក្ខុកាន់យកទឹកមួយក្អម ឬពីរក្អម អំពីទឹកណា ដើម្បីលាងអាសនៈ ស្រោចដើមពោធិ៍ ធ្វើការបូជាដោយទឹក ( និង ) ដើម្បីដាំទឹកជ្រលក់ គួរបដិបត្តិក្នុងទឹកនោះដោយអំណាចនៃកតិការបស់សង្ឃនោះឯង ភិក្ខុដែលទទួលយកទឹកច្រើនទៅ ឬដាក់វត្ថុទាំងឡាយ មានដីឥដ្ឋជាដើមចុះទៅដោយថេយ្យចិត្ត ព្រះវិនយធរគប្បីវាយតម្លៃទ្រព្យ កាត់អាបត្តិ ។ បើពួកអាវាសិកភិក្ខុធ្វើកតិកាវត្តទុកយ៉ាងតឹងរ៉ឹង មិនអនុញ្ញាតឲ្យភិក្ខុដទៃប្រើលាងរបស់របរ ឬប្រើជ្រលក់ចីវរ តែខ្លួនឯងកាន់យកធ្វើកិច្ចគ្រប់យ៉ាង កាលភិក្ខុដទៃមិនឃើញ ពួកអាគន្តុកភិក្ខុមិនត្រូវតាំងនៅក្នុងកតិការបស់អាវាសិកភិក្ខុទាំងនោះ គប្បីប្រើលាងរបស់របរ មានប្រមាណប៉ុនគ្នានឹងអាវាសិកភិក្ខុប្រើប្រាស់លាងនោះឯង ។ បើសង្ឃមានស្រះបោក្ខរណី ឬមានអណ្តូងទឹក ២-៣ កន្លែងសោត ហើយសង្ឃក៏ធ្វើកតិកាទុកថា ភិក្ខុទាំងឡាយ គួរងូតទឹកក្នុងស្រះបោក្ខរណី និងអណ្តូងនេះ គួរដងផឹក

អំពីអណ្តូងនេះ គួរធ្វើការប្រើប្រាស់កិច្ចគ្រប់យ៉ាង ក្នុងស្រះបោក្ខរណី និង អណ្តូងទឹកនេះ ពួកភិក្ខុអាគន្តុកៈ គួរធ្វើកិច្ចទាំងអស់ ដោយកតិកាវត្តនោះឯង ក្នុងស្រះបោក្ខរណីជាដើមណា មិនមានកតិកា ការប្រើប្រាស់កិច្ចគ្រប់យ៉ាង ក្នុងស្រះបោក្ខរណីជាដើមនោះ រមែងគួរដូច្នេះឯង ។

ក្នុងរឿងដីឥដ្ឋ មានវិនិច្ឆ័យដូច្នេះថា ក្នុងទីណាដីឥដ្ឋជារបស់រកបាន លំបាក ឬដីឥដ្ឋមានពណ៌ មានប្រការផ្សេងៗ ដែលមហាជនជញ្ជូនមកគរទុក ក្នុងទីនោះ សូម្បីដីឥដ្ឋបន្តិចបន្តួចក៏មានតម្លៃដល់ ៥ មាសក ព្រោះហេតុនោះ ទើបត្រូវអាបត្តិបារាជិក ។ មយ៉ាងទៀត កាលការងាររបស់សង្ឃ និងការងារ ក្នុងព្រះចេតិយសម្រេចហើយ ការដែលភិក្ខុសួរសង្ឃជាមុន សឹមកាន់យក ឬខ្ចី គួរ ។ ក្នុងកំបោរក្តី ក្នុងចិត្រកម្ម និងវណ្ណកម្មក្តី ក៏មានន័យដូចគ្នា ។

ក្នុងរឿងភិក្ខុលួចដុតស្មៅ មានវិនិច្ឆ័យដូច្នេះថា ក្នុងស្មៅដែលភិក្ខុយក ភ្លើងដុត ត្រូវអាបត្តិទុក្កដ ព្រោះមិនមានការឲ្យឃ្លាតចាកទី តែជាកណ្ឋទេយ្យ ។ សង្ឃរក្សាផ្ទៃដីដែលដាំស្មៅទុក ហើយប្រើស្មៅនោះប្រក់លំនៅរបស់សង្ឃ គ្រាខ្វះ សង្ឃរមែងមិនអាចរក្សាបានទៀត ។ គ្រានោះ មានភិក្ខុមួយរូបរក្សា ទុក ដោយបំណងវត្តជាធំ ។ ស្មៅនោះជារបស់សង្ឃដូចគ្នា ។ បើមិនមាន បុគ្គលណារក្សា សង្ឃគួរប្រាប់ភិក្ខុមួយរូបថា លោកជួយរក្សាឲ្យល្អ បើភិក្ខុ អង្គនោះប្រាថ្នានឹងចែករំលែកសោត សង្ឃទោះបីចែករំលែកឲ្យ ក៏គួរឲ្យភិក្ខុ អង្គនោះរក្សា ។ បើលោកសូមបន្ថែមចំណែកដែលចែកសោត សង្ឃគួរឲ្យ ដោយពិត ។ ភិក្ខុសូមបន្ថែមឡើងទៀត សង្ឃគួរពោលថា ចូរលោកទៅ

រក្សា ហើយយកស្មៅទាំងអស់ប្រក់សេនាសនៈរបស់ខ្លួនចុះ ។ ព្រោះហេតុអ្វី ព្រោះថា កាលស្មៅវិនាស ក៏មិនមានប្រយោជន៍ ។ តែភិក្ខុទាំងឡាយ កាលនឹងឲ្យ មិនគួរឲ្យទាំងដីដែលជាគរុភណ្ឌ គួរឲ្យត្រឹមតែស្មៅប៉ុណ្ណោះ ។ កាលភិក្ខុអង្គនោះរក្សាទុកហើយ ប្រើប្រក់សេនាសនៈរបស់ខ្លួន បើសង្ឃនៅអាចរក្សាបានទៀត សង្ឃគួរពោលនឹងភិក្ខុអង្គនោះថា លោកមិនចាំបាច់រក្សាឡើយ សង្ឃនឹងរក្សាឯង ដូច្នេះ ។

[ ១៦៩ ] ៧ រឿង មានរឿងភិក្ខុលួចគ្រែរបស់សង្ឃជាដើម ប្រាកដច្បាស់ហើយនោះឯង ។ បើភិក្ខុលួចសសរថ្មក្តី សសរឈើក្តី ឬទ្រព្យណាមួយដទៃដែលមិនបានមកក្នុងព្រះបាលី ដែលមានតម្លៃដល់មួយបាទ ត្រូវអាបត្តិ បារាជិកដូចគ្នា ។

ក្នុងផ្ទះសម្រាប់ធ្វើសេចក្តីព្យាយាម មានវិនិច្ឆ័យដូច្នេះ កាលភិក្ខុរើជញ្ជាំងក្តី របងក្តីនៃស្ថានទី មានបរិវេណជាដើម ដែលត្រូវម្ចាស់ទ្រព្យបោះបង់រាត់រាយ ហើយលួចយកទព្វសម្ភារៈ មានឥដ្ឋជាដើមទៅ ក៏មានន័យនេះដូចគ្នា ព្រោះហេតុអ្វី ព្រោះថា ភិក្ខុទាំងឡាយ គ្រាខ្លះ រមែងនៅគ្រប់គ្រងសេនាសនៈ ដែលឈ្មោះថា ជារបស់សង្ឃ គ្រាខ្លះ ក៏មិននៅគ្រប់គ្រង ។ កាលភិក្ខុលួចយកបរិក្ខារណាមួយ ក្នុងទីទាំងឡាយ មានវត្តដែលបោះបង់បោលហើយជាដើម ក្នុងកាលពួកអ្នកជនបទភៀសខ្លួនទៅ ព្រោះចោរភ័យក្នុងជាយដែន ក៏មានន័យនេះដូចគ្នា ។ ចំណែកភិក្ខុណា នាំទព្វសម្ភារៈទៅប្រើប្រាស់ម្តងម្កាល អំពីវត្តដែលគេបោះបង់ចោលហើយនោះ និងក្នុងកាលវត្ត

មានភិក្ខុត្រឡប់មកនៅ ភិក្ខុទាំងឡាយ ប្រាប់ភិក្ខុទាំងនោះឲ្យនាំមកសង គួរសង ។ បើភិក្ខុទាំងឡាយ នាំសម្ភារៈឈើជាដើម អំពីវត្តដែលគេបោះបង់ហើយនោះ មកធ្វើជាសេនាសនៈ ទ្រព្យដែលពួកភិក្ខុនាំមកនោះ ឬសេនាសនៈ ដែលមានតម្លៃស្មើគ្នានឹងទ្រព្យនោះ គួរសងដូចគ្នា ។ កាលអ្នកជនបទមិនទាន់អស់អាល័យ ភៀសខ្លួនទៅ ដោយគិតថា ពួកយើងនឹងត្រឡប់មកនៅគ្រប់គ្រងទៀត សេនាសនៈដែលជារបស់គណៈ ឬរបស់បុគ្គល គឺនៅជាកម្មសិទ្ធរបស់អ្នកភៀសខ្លួននៅឡើយ ។ បើអ្នកភៀសខ្លួនទាំងនោះអនុញ្ញាតឲ្យ មិនមានកិច្ចដែលត្រូវសង ។ ចំណែកទព្វសម្ភារៈរបស់សង្ឃ ចាត់ជាគរុភណ្ឌ ព្រោះដូច្នោះ គួរចាត់ការសងដូចគ្នា រឿងគ្រឿងប្រើប្រាស់ក្នុងវិហារមានអត្ថជាក់ច្បាស់ហើយ ។

[ ១៧០ ] ក្នុងពុទ្ធានុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យនាំទៅប្រើប្រាស់បានម្តងម្កាល ដូច្នេះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុណាខ្ចីគ្រែ ឬតាំងរបស់សង្ឃទៅប្រើប្រាស់ ដោយការប្រើប្រាស់ដូចរបស់សង្ឃ មួយខែខ្លះ ពីរខែខ្លះ ក្នុងទីកន្លែងជាផាសុករបស់ខ្លួន កាលភិក្ខុទាំងឡាយដែលចាស់ជាងមកហើយ ក៏ប្រគេន មិននាំមកសង ។ កាលគ្រែ និងតាំងនោះបាត់ទៅខ្លះ បែកបាក់ទៅខ្លះ អ្នកដទៃលួចទៅដោយភាពជាចោរខ្លះ រមែងមិនជាសំណងដល់ភិក្ខុអង្គនោះឡើយ ។ តែកាលលោកនៅហើយ នឹងទៅ គួររក្សាទុកក្នុងទីដើមវិញ ។ ចំណែកភិក្ខុណាប្រើប្រាស់ ដោយការប្រើប្រាស់ជារបស់បុគ្គល មិនបានប្រគេន ដល់ភិក្ខុទាំងឡាយជាថេរៈដែលមកហើយ ( កាល

គ្រែ និងតាំងនោះវិនាសទៅខ្លះ បែកបាក់ទៅខ្លះ អ្នកដទៃលួចទៅដោយភាពជាចោរខ្លះ ) រមែងជាសំណងសម្រាប់ភិក្ខុនោះ ។ ក្នុងសង្ខេបអដ្ឋកថា ពោលទុកថា ភិក្ខុនាំទៅកាន់អាវាសដទៃ ហើយប្រើប្រាស់ បើក្នុងអាវាសនោះ ភិក្ខុដែលចាស់ជាង មកបង្គាប់ឲ្យភិក្ខុនោះចេញទៅ គួរពោលថា ខ្ញុំនាំគ្រែ និងតាំងនេះមកអំពីអាវាសឈ្មោះនោះ ខ្ញុំនឹងទៅ ខ្ញុំនឹងរៀបចំគ្រែ និងតាំងនោះឲ្យជាប្រក្រតី ។ បើភិក្ខុចាស់ជាងនោះពោលថា ខ្ញុំនឹងឲ្យជាប្រក្រតីខ្លួនឯងនឹងធ្វើឲ្យជាការៈនៃ ភិក្ខុចាស់នោះ ទៅ ក៏គួរ ។

[ ១៧១ ] ក្នុងរឿងអន្តេវាសិករបស់ថុល្លនន្ទាភិក្ខុនី នៅក្រុងចម្ប៉ា មានវិនិច្ឆ័យដូច្នេះថា បបរ ដែលពួកជនដាក់អបរណ្ណជាតិ ដែលមានរសឆ្ងាញ់ណាមួយ មួយអន្ទើដោយប្រេងល្ង និងអង្ករ ហើយផ្សំដោយវត្ថុ ៣ យ៉ាង គឺប្រេងល្ង អង្ករ និងសណ្តែកបាយក្តី ប្រេងល្ង អង្ករ សណ្តែករាជមាសក្តី ប្រេងល្ង អង្ករ និងសណ្តែកខ្មៅក្តី ឈ្មោះថា **តេកដុល** គឺបបរដែលផ្សំដោយវត្ថុ ៣ យ៉ាង ។ បានឮថា ពួកជនរមែងប្រកបបបរឈ្មោះតេលដុកៈនោះ ដោយវត្ថុ ៣ យ៉ាង មានសប្បិ ទឹកឃ្មុំ និងស្ករជាដើម ក្នុងទឹកដោះដែលក្តៅជាចំណែកទី ៤ ។

ក្នុងរឿងកូនសិស្សរបស់ថុល្លនន្ទាថេរី ក្នុងក្រុងរាជគ្រឹះ មានវិនិច្ឆ័យដូច្នេះថា នំដែលមានរសឆ្ងាញ់ក្រៃលែង លោកហៅថា **មធុគោឡក** អាចារ្យពួកខ្លះពោលថា នំសម្បុកឃ្មុំក៏មាន ។ ពាក្យដ៏សេស ក្នុងរឿង ២ នេះ គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងរឿងចែកបាយនោះឯង ។

[ ១៧២ ] ក្នុងរឿងអដ្ដកត្ថេរ មានវិនិច្ឆ័យដូច្នេះថា បទថា **ឃរតរយោគ** សេចក្តីថា គហបតីនោះឈឺ បានប្រាប់ទុកហើយ ។

ត្រើនបទថា **អាយស្មា ឧបាលិ អាយស្មតោ អដ្ឋុកស្ស បក្ខោ** សេចក្តីថា ព្រះឧបាលីមិនមែនជាបក្ខពួក ( របស់អដ្ដកភិក្ខុនោះ ) ដោយអំណាចដល់នូវការលំអៀងឡើយ ដោយពិតនោះ បណ្ឌិតគប្បីជ្រាបថា ព្រះថេរៈជាបក្ខពួក ( របស់អដ្ដកភិក្ខុនោះ ) ដោយការអនុគ្រោះបុគ្គលដែលជាលជ្ជី និងអនុគ្រោះព្រះវិន័យ ព្រោះដឹងថា លោកមិនត្រូវអាបត្តិ ។ ពាក្យដ៏សេសក្នុងរឿងអដ្ដកត្ថេរនេះ មានអត្ថរាក់ហើយ ។

[ ១៧៣ ] ក្នុងរឿងព្រះបិលិន្ទវច្ឆត្ថេរ មានវិនិច្ឆ័យដូច្នេះថា ពីរបទថា **ចោរេហិ ឧបទ្ទុតំ** សេចក្តីថា ពួកចោរប្លន់ហើយ ។

ត្រើនបទថា **ឥទ្ធិយា អានេត្វា បាសាទេ ឋបេសិ** សេចក្តីថា បានឮថា ព្រះថេរៈបានឃើញត្រកូលនោះ ដល់ព្រមដោយព្រួញ គឺសេចក្តីសោកវិលវល់ត្រឡប់ទៅត្រឡប់មក ទើបអធិដ្ឋានប្រាសាទរបស់ជនទាំងនោះឯងដោយឫទ្ធិរបស់ខ្លួនថា ចូរប្រាកដមានក្នុងទីជិតកុមារទាំងឡាយ ដោយធម៌អនុគ្រោះ ដើម្បីសេចក្តីករុណា ដើម្បីប្រយោជន៍ដល់ការតាមរក្សាសេចក្តីជ្រះថ្លានៃត្រកូលនោះ ។ កុមារទាំងពីរចាំបានថា ជាប្រាសាទរបស់ពួកយើង ទើបឡើងទៅ ។ លំដាប់នោះ ព្រះថេរៈបានរំសាយឫទ្ធិហើយ ។ សូម្បីប្រាសាទក៏តាំងនៅក្នុងទីរបស់ខ្លួនដូចដើម ។ តែជម្ពូសន្តាហកាចារ្យទាំងឡាយ ពោលទុកដោយអំណាចវោហារថា ព្រះថេរៈនាំកុមារពីរនាក់នោះមកដោយឫទ្ធិ ហើយ

ទុកក្នុងប្រាសាទ ។

បទថា **ឥទ្ធិវិសយេ** គឺមិនត្រូវអាបត្តិ ព្រោះអធិដ្ឋានឫទ្ធិដូច្នេះ ។ ឯឫទ្ធិ គឺការសម្តែងផ្សេងៗ រមែងមិនសមគួរ ដូច្នេះឯង ។

[ ១៧៤-១៧៥ ] ក្នុងរឿងចុងក្រោយ មានអត្ថងាយទាំងអស់ហើយ ។

ទុតិយបារាជិកវណ្ណនា ក្នុងវិនយវណ្ណនា

ឈ្មោះ សមន្តបាសាទិកា ចប់

# គាថាសរុបទុតិយបារាជិកសិក្ខាបទ

ក្នុងទុតិយបារាជិកសិក្ខាបទនេះ មានអនុសាសនី ដូចតទៅនេះថា ទុតិយបារាជិកសិក្ខាបទណា ដែលព្រះជិនស្រី មិនមានបុគ្គលជាគម្រប់ ២ ដែលមានកិលេសបន្សាត់បង់ហើយ ទ្រង់ប្រកាសហើយ ក្នុងព្រះសាសនានេះ សិក្ខាដទៃណាដ៏សេស ដែលមានន័យកំបាំងដ៏ច្រើន មានអត្ថ និងវិនិច្ឆ័យជ្រាលជ្រៅ ស្មើដោយទុតិយបារាជិកសិក្ខាបទនេះ រមែងមិនមាន ព្រោះហេតុនោះ កាលរឿងកើតឡើងហើយ ភិក្ខុដែលដឹងព្រះវិន័យ នឹងធ្វើការវិនិច្ឆ័យក្នុងរឿងដែលកើតឡើងហើយនោះ ដោយសេចក្ដីអនុគ្រោះដល់ព្រះវិន័យ គប្បីពិចារណាព្រះបាលី និងអដ្ឋកថា ព្រមទាំងអធិប្បាយឲ្យបានសព្វគ្រប់ កុំជាអ្នកប្រមាទក្នុងការវិនិច្ឆ័យចុះ ក្នុងកាលណាមួយ មិនគប្បីធ្វើការអាចហ៊ាន ក្នុងការកាត់អាបត្តិ គួរដាក់ចិត្តថា អញនឹងឃើញអនាបត្តិ ។ ម្យ៉ាងទៀត សូម្បីឃើញអាបត្តិហើយ ក៏កុំអាលនិយាយផ្ដេសផ្ដាសជាមុន គប្បីពិចារណា ឬពិភាក្សាជាមួយលោកអ្នកចេះដឹងទាំងឡាយ សឹមកាត់អាបត្តិនោះ ។ ប្រការមួយទៀត ភិក្ខុទាំងឡាយ ដែលជាបុថុជ្ជនក្នុងសាសនានេះ រមែងឃ្លាតចាកគុណ គឺភាពជាសមណៈ ដោយអំណាចនៃចិត្តដែលប្រែប្រួលរហ័ស សូម្បីក្នុងរឿងដែលគួរ ព្រោះហេតុនោះ ភិក្ខុអ្នកឈ្លាស កាលសម្លឹងឃើញបរិក្ខាររបស់អ្នកដទៃ គប្បីឃើញដូចពស់ដែលមានពិសខ្លាំងក្លា និងដូចភ្លើង គប្បីចាប់ពាល់ចុះ ។

# វិនយបិដក

## ចាតាឯកកណ្ឌ សិក្ខាបទទី ៣

[ ១៧៦ ] សម័យនោះ ព្រះសម្ពុទ្ធដ៏មានជោគទ្រង់គង់នៅក្នុងកូដាគារ-សាលា ( សាលា គឺផ្ទះមានកំពូល ) ក្បែរព្រៃមហាវនទៀបក្រុងវេសាលី ។ កាលនោះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងអសុភកថា ទ្រង់សម្តែងរៀបរាប់អំពីអសុភ ទ្រង់សម្តែងគុណនៃការចម្រើនអសុភកម្មដ្ឋាន ទ្រង់សម្តែងគុណនៃអសុភសមាបត្តិក្នុងអសុភកម្មដ្ឋានជាញឹកញយ ដោយបរិយាយដ៏ច្រើន ។ លំដាប់នោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតចង់គេចចាកអារម្មណ៍សម្ងំនៅអស់កាលកន្លះខែ ( ក្នុងកម្មដ្ឋាន ) កុំឲ្យអ្នកណាមួយចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុ ១ រូបជាអ្នកនាំបិណ្ឌបាតទៅឲ្យតថាគត ។ ទើបពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ឯវំភន្តេ ( យ៉ាងហ្នឹងព្រះអង្គ ) តាំងពីកាលនោះមក មិនមានអ្នកណាមួយចូលទៅគាល់ព្រះដ៏មានព្រះភាគឡើយ វៀរលែងតែភិក្ខុមួយរូប ជាអ្នកនាំបិណ្ឌបាតទៅថ្វាយព្រះអង្គ ។ ភិក្ខុទាំងឡាយគិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់សម្តែងអសុភកថា ទ្រង់សម្តែងរៀបរាប់អំពីអសុភ ទ្រង់សម្តែងគុណនៃការចម្រើនអសុភកម្មដ្ឋាន ទ្រង់សម្តែងគុណនៃអសុភសមាបត្តិ ក្នុងអសុភកម្មដ្ឋានជាញឹកញយៗ ដោយបរិយាយមិនតែមួយ លុះគិតដូច្នេះហើយ ក៏នាំគ្នាប្រកបសេចក្តីព្យាយាមក្នុងការចម្រើនអសុភកម្មដ្ឋានជាច្រើនបែប ច្រើនវិធី ។ ពួកភិក្ខុទាំងនោះ កើតសេចក្តីទុក្ខ

នឿយណាយ ខ្ពើមរអើមនឹងរាងកាយរបស់ខ្លួនឯង មានគួរនាដូចជាស្រីក្រមុំ ឬប្រុសកំលោះ ជាអ្នកមានកិរិយាស្អិតស្អាងជាប្រក្រតី លុះបានងូតទឹកកក់ក្បាលហើយ រមែងជាទុក្ខ នឿយណាយ ខ្ពើមរអើមសាកអសុភពស់ សាកអសុភឆ្កែ ឬសាកអសុភមនុស្ស ដែលគេព្យួរនឹង ក យ៉ាងណាមិញ ពួកភិក្ខុទាំងនោះក៏ជាទុក្ខនឿយណាយ ខ្ពើមរអើមនឹងកាយរបស់ខ្លួនយ៉ាងនោះឯង ទើបផ្តាច់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្តាច់ជីវិតគ្នាទៅវិញទៅមកខ្លះ ភិក្ខុខ្លះចូលទៅរកសមណកុត្តកឈ្មោះមិគលណ្ឌិកហើយ ពោលយ៉ាងនេះថា នែអ្នកដ៏មានអាយុ យើងសូមអង្វរអ្នកៗ ចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រ និងចីវរទាំងនេះនឹងបានជារបស់អ្នក ។ គ្រានោះឯង សមណកុត្តកឈ្មោះមិគលណ្ឌិកទទួលស៊ីឈ្នួលយកបាត្រ និងចីវរហើយ ទើបផ្តាច់បង់ជីវិតភិក្ខុទាំងឡាយជាច្រើនរូប ហើយកាន់ដាវប្រឡាក់ឈាម ដើរទៅកាន់ស្ទឹងឈ្មោះវគ្គុមុទា កាលដែលសមណកុត្តកឈ្មោះមិគលណ្ឌិក កំពុងលាងដាវប្រឡាក់ឈាមនោះ ( គាត់ ) ក៏មានសេចក្តីសង្ស័យ ក្តៅក្រហាយស្តាយក្រោយក្នុងកាលនោះ ដោយគិតឃើញថា ការនេះមិនមែនជាលាភរបស់អញទេតើ នឹងថាត់ថា ជាលាភរបស់អញមិនបានឡើយ ជាតិជាមនុស្សអញបានដោយក្រណាស់ ជាតិជាមនុស្សឈ្មោះថា អញបានដោយងាយមិនមែនឡើយ អញបានបាបច្រើនណាស់ ព្រោះអញបានផ្តាច់បង់ជីវិតពួកភិក្ខុអ្នកមានសីល មានធម៌ល្អ ។ លំដាប់នោះ ទេវតាជាពួករបស់មារ ដើរមកលើទឹកមិនមានបែកធ្លាយ បាននិយាយពាក្យនេះនឹងសមណកុត្តកឈ្មោះមិគលណ្ឌិកថា ល្អហើយៗ អ្នកសប្បុរស ការ

នេះជាលាភរបស់អ្នកហើយ អ្នកសប្បុរស ជាតិជាមនុស្សអ្នកក៏បានដោយប្រពៃហើយ អ្នកសប្បុរស អ្នកបានប្រទះបុណ្យច្រើនហើយ អ្នកសប្បុរស ព្រោះអ្នកបានញុំាងជនទាំងឡាយ ដែលមិនទាន់ឆ្លងសង្សារវដ្ត ឲ្យឆ្លងផុតទៅបាន ។ គ្រានោះឯង សមណកុត្តកឈ្មោះ មិគលណ្ឌិក ក៏នឹកអរថា ឮថា ( ការនេះ ) ជាលាភរបស់អញ ឮគេថា ជាតិជាមនុស្ស អញបានដោយល្អហើយ ឮគេថា អញបានប្រទះបុណ្យជាច្រើន ឮគេថា អញបានញុំាងជនទាំងឡាយដែលមិនទាន់ឆ្លង ( សង្សារវដ្ត ) ឲ្យឆ្លងផុតទៅបាន លុះគិតដូច្នេះហើយ ក៏កាន់ដាវមុតដើរចេញពីវិហារចូលទៅកាន់វិហារ ចេញពីបរិវេណចូលទៅកាន់បរិវេណ ហើយពោលយ៉ាងនេះថា លោកណាមិនទាន់ឆ្លង ( សង្សារវដ្ត ) ខ្ញុំនឹងឲ្យលោកណាឆ្លងសង្សារវដ្តបាន ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយណាដែលមិនទាន់ប្រាសចាករាគៈ សេចក្តីខ្លាច សេចក្តីញាប់ញ័រ និងសេចក្តីព្រឺរោម ក៏មានដល់ភិក្ខុទាំងនោះជាប្រាកដក្នុងសម័យនោះ ។ ចំណែកភិក្ខុទាំងឡាយណា ដែលប្រាសចាករាគៈហើយ សេចក្តីខ្លាច សេចក្តីញាប់ញ័រ និងសេចក្តីព្រឺរោម ក៏មិនមានដល់ភិក្ខុទាំងនោះក្នុងសម័យនោះឡើយ ។ គ្រានោះ សមណកុត្តកឈ្មោះមិគលណ្ឌិក ក៏ផ្តាច់បង់ជីវិតភិក្ខុក្នុងមួយថ្ងៃ ១ រូបក៏មាន ក្នុង ១ ថ្ងៃផ្តាច់បង់ជីវិតភិក្ខុពីររូបក៏មាន ១ ថ្ងៃ ផ្តាច់បង់ជីវិតភិក្ខុបីរូបក៏មាន ១ ថ្ងៃផ្តាច់បង់ជីវិតភិក្ខុបួនរូបក៏មាន ១ ថ្ងៃផ្តាច់បង់ជីវិតភិក្ខុប្រាំរូបក៏មាន ។បេ។ ១ ថ្ងៃផ្តាច់បង់ជីវិតភិក្ខុដប់រូបក៏មាន ១ ថ្ងៃផ្តាច់បង់ជីវិតភិក្ខុម្ភៃរូបក៏មាន ១ ថ្ងៃផ្តាច់ជីវិតភិក្ខុសាមសិបរូបក៏មាន មួយថ្ងៃផ្តាច់បង់ជីវិតភិក្ខុ

សែសិបរូបក៏មាន មួយថ្ងៃផ្តាច់បង់ជីវិតភិក្ខុហាសិបរូបក៏មាន មួយថ្ងៃផ្តាច់បង់ជីវិតភិក្ខុហុកសិបរូបក៏មាន ។

[ ១៧៧ ] គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីសម្ងំក្នុងព្រះកម្មដ្ឋាន ដោយកន្លងកន្លះខែនោះទៅ ទើបទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុដោយព្រះពុទ្ធដីកាថា ដូចម្តេចហ្ន៎ អានន្ទ បានជាភិក្ខុសង្ឃហាក់ដូចជាស្តួចស្តើងទៅ ។ ទើបព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពិតដូចព្រះពុទ្ធដីកាណាស់ ព្រោះព្រះដ៏មានព្រះភាគ ទ្រង់សម្តែងអសុភកថាដោយបរិយាយជាច្រើន ទ្រង់សរសើររៀបរាប់អំពីអសុភ ទ្រង់សរសើរគុណអសុភភាវនា ទ្រង់សរសើរគុណនៃអសុភសមាបត្តិ ក្នុងអសុភកម្មដ្ឋានជាញឹកញយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងនោះ ក៏គិតគ្នាថា ព្រះដ៏មានព្រះភាគទ្រង់សម្តែងអសុភកថាដោយបរិយាយដ៏ច្រើន ទ្រង់សរសើររៀបរាប់អំពីអសុភកថា ទ្រង់សរសើរគុណអសុភភាវនា ទ្រង់សរសើរគុណនៃការប្រកបដោយអសុភកម្មដ្ឋានជាញឹកញយ ហើយ ( នាំគ្នា ) ប្រកបសេចក្តីព្យាយាមក្នុងអសុភភាវនា ជាច្រើនវិធីណាស់ ។ ទើបភិក្ខុទាំងនោះ ជាទុក្ខ នឿយ-ណាយ ខ្ពើមឆ្អើមនឹងកាយរបស់ខ្លួន ប្រៀបដូចជាស្រីក្រមុំ ឬបុរសក្មេងកំលោះ មានជាតិជាអ្នកស្អិតស្អាង លុះងូតទឹកកក់ក្បាលហើយ រមែងជាទុក្ខនឿយណាយ ខ្ពើមឆ្អើមសាកអសុភពស់ក្តី សាកអសុភឆ្កែក្តី សាកអសុភមនុស្សក្តី ដែលចងភ្ជាប់នឹង ក មានឧបមាយ៉ាងណាមិញ ភិក្ខុទាំងអម្បាលនោះ កាលជាទុក្ខនឿយណាយ ខ្ពើមឆ្អើមនឹងកាយរបស់ខ្លួន ក៏មានឧបមេយ្យ

យ៉ាងនោះ ទើបផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងក៏មាន ខ្លះផ្លាស់គ្នាឲ្យផ្តាច់បង់ជីវិតទៅវិញទៅមកក៏មាន រូបខ្លះបានចូលទៅរកសមណកុត្តកឈ្មោះមិគលណ្ឌិក ហើយពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នក អ្នកចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រ និងចីវរនេះនឹងបានជារបស់អ្នក បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង សមណកុត្តកឈ្មោះមិគលណ្ឌិក លុះបានទទួលស៊ីឈ្នួលយកបាត្រ និងចីវរហើយ ទើបផ្តាច់បង់ជីវិតភិក្ខុមួយរូបមួយថ្ងៃក៏មាន ។បេ។ មួយថ្ងៃផ្តាច់បង់ជីវិតភិក្ខុហុកសិបរូបក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ ភិក្ខុសង្ឃនេះ គប្បីស្ថិតស្ថេរនៅបានដោយហេតុណា សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហេតុនោះដទៃទៀត ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ ភិក្ខុទាំងអម្បាលម៉ានដែលអាស្រ័យនៅក្នុងក្រុងវេសាលី អ្នកចូរឲ្យភិក្ខុអម្បាលនោះទាំងអស់ប្រជុំគ្នាក្នុងឧបដ្ឋានសាលាចុះ ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មាន-ព្រះភាគថា ព្រះករុណាព្រះអង្គ ដូច្នេះហើយ ភិក្ខុទាំងឡាយមានប្រមាណប៉ុន្មាន ដែលអាស្រ័យនៅក្នុងក្រុងវេសាលី ព្រះអានន្ទក៏បង្គាប់ភិក្ខុអម្បាលនោះទាំងអស់ឲ្យប្រជុំគ្នាក្នុងឧបដ្ឋានសាលា[១] ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាព្រមហើយ ព្រះករុណាម្ចាស់ សូមព្រះដ៏មានព្រះភាគទ្រង់

---

១- សាលាជាទីបម្រើ គឺសាលាសម្រាប់ប្រើប្រាស់ ដោយកិច្ចផ្សេងៗ មានធាន់ចង្ហាន់ជាដើម ។

សម្គាល់កាលដ៏សមគួរ ក្នុងកាលឥឡូវនេះ ។

[ ១៧៨ ] គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់យាងចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់ប្រថាប់លើអាសនៈដែលគេតាក់តែងថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ប្រថាប់ស្រេចហើយ ទើបត្រាស់នឹងភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅ នាំមកនូវសេចក្តីសុខផង តែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងៗ ឲ្យសាបសូន្យទៅផង ឲ្យស្ងប់រម្ងាប់ផង ដោយទំនងដ៏សមគួរ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចកម្ទេចធូលីដែលខ្យល់បក់ក្ជួចឡើងក្នុងខែ ដែលជាចុងគិម្ហន្តរដូវ គឺខែអាសាឍ្ហ មហាអកាលមេឃ ( ភ្លៀងធំបង្អុរចុះ ខុសកាលវេលា ) តែងញ៉ាំងកម្ទេចធូលីនោះឲ្យអន្តរធាន ឲ្យស្ងប់ទៅបាន ដោយទំនងដ៏សមគួរ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបានអប់រំ ធ្វើឲ្យច្រើនជាប្រក្រតីហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅនាំមកនូវសេចក្តីសុខផង តែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រម្ងាប់ទៅ ដោយទំនងដ៏សមគួរ ក៏មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចម្រើនហើយ តើដូចម្តេច ដែលបុគ្គលធ្វើឲ្យច្រើនជា

ប្រក្រតីហើយ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅនាំមកនូវសេចក្តីសុខផង តែងញ៉ាំងអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់រម្ងាប់ទៅដោយទំនង ដ៏សមគួរ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ទីជិតនៃដើមឈើក្តី ទៅកាន់ផ្ទះដ៏ស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តម្កល់សតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ភិក្ខុនោះមានសតិ ដកដង្ហើមចេញ មានសតិ ដកដង្ហើមចូល កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាដកដង្ហើមចូលខ្លី ( ភិក្ខុ ) សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចេញ សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចូល សិក្សាថា អាត្មារម្ងាប់កាយសង្ខារ ( គឺខ្យល់អស្សាស-បស្សាសៈ ) សឹមដកដង្ហើមចេញ សិក្សាថា អាត្មានឹងរម្ងាប់កាយសង្ខារ សឹមដកដង្ហើមចូល សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវបីតិ ( គឺសេចក្តីឆ្អែតកាយឆ្អែតចិត្ត ) សឹមដកដង្ហើមចេញ សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវបីតិ សឹមដកដង្ហើមចូល សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវសុខ ( គឺសុខកាយសុខចិត្ត ) សឹមដកដង្ហើមចេញ សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវសុខ សឹមដកដង្ហើមចូល សិក្សាថា អាត្មានឹងកំណត់ដឹងច្បាស់នូវ

ចិត្តសង្ខារ ( គឺវេទនា និងសញ្ញា ) សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្តសង្ខារ សឹមដកដង្ហើមចូល សិក្សាថា អញនឹងរម្ងាប់ចិត្តសង្ខារ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងរម្ងាប់ចិត្តសង្ខារ សឹមដកដង្ហើមចូល សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចេញ សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវចិត្ត សឹមដកដង្ហើមចូល សិក្សាថា អញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងធ្វើចិត្តឲ្យរីករាយ សឹមដកដង្ហើមចូល សិក្សាថា អញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងតាំងចិត្តខ្ជាប់ សឹមដកដង្ហើមចូល សិក្សាថា អញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងដោះចិត្តឲ្យផុតស្រឡះ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពជារបស់មិនទៀង សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពឥតរាគៈ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណាដោយសភាពរលត់ទៅ សឹមដកដង្ហើមចូល សិក្សាថា អញនឹងពិចារណារឿយៗ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់ សឹមដកដង្ហើមចេញ សិក្សាថា អញនឹងពិចារណារឿយៗ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់ សឹមដកដង្ហើមចូល ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលបាន

ចម្រើនហើយយ៉ាងនេះ ដែលបុគ្គលធ្វើឲ្យច្រើនហើយយ៉ាងនេះ ជាធម៌ល្អិតផង ជាធម៌ឧត្តមផង ជាធម៌មិនច្រឡូកច្រឡំ គឺជាធម៌ដោយឡែកផង ជាគ្រឿងនៅនាំមកនូវសេចក្តីសុខផង តែងញុំាងអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងៗ ឲ្យសាបសូន្យទៅ ឲ្យស្ងប់ទៅ ដោយទំនងដ៏សមគួរ ។

[ ១៧៩ ] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សាកសួរភិក្ខុទាំងឡាយក្នុងគ្រានោះថា ម្នាលភិក្ខុទាំង-ឡាយ បានឮថា ពួកភិក្ខុផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្ទាស់គ្នាឲ្យផ្តាច់បង់ជីវិតទៅវិញទៅមកខ្លះ ភិក្ខុខ្លះចូលទៅរកសមណកុត្តកឈ្មោះមិគលណ្ឌិកហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នកៗ ចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រ និងចីវរទាំងនេះនឹងបានជារបស់អ្នក ( យ៉ាងនេះ ) ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏ទ្រង់ព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើដែលអ្នកទាំងឡាយបានធ្វើហើយនេះ មិនសម មិនទំនង មិនគួរ មិនមែនជាកិច្ចរបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេចបានជាពួកភិក្ខុទាំងនោះទៅផ្តាច់បង់ជីវិតខ្លួនដោយខ្លួនឯងខ្លះ ផ្ទាស់គ្នាឲ្យផ្តាច់ជីវិតទៅវិញទៅមកខ្លះ ភិក្ខុខ្លះចូលទៅរកសមណកុត្តកឈ្មោះមិគលណ្ឌិក ហើយពោលយ៉ាងនេះថា ម្នាលអាវុសោ ពួកយើងសូមអង្វរអ្នកៗ ចូរផ្តាច់បង់ជីវិតពួកយើងចុះ បាត្រនិងចីវរនេះនឹងបានជារបស់អ្នក ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លា

។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្លែងផ្តាច់បង់រាងកាយ របស់មនុស្សឲ្យឃ្លាតចាកជីវិតក្តី ទោះបីស្វែងរកគ្រឿងសស្ត្រាវុធ ( ឲ្យគេសម្លាប់ ) រាងកាយមនុស្សនោះក្តី ភិក្ខុនេះឯងហៅថា ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[ ១៨០ ] សម័យនោះឯង មានឧបាសកម្នាក់មានជំងឺ ។ ប្រពន្ធរបស់ឧបាសកនោះ មានរូបល្អស្រស់បស់មុខគួរឲ្យគយគន់ ជាទីនាំមកនូវសេចក្តីជ្រះថ្លា ពួកឆព្វគ្គិយភិក្ខុមានចិត្តប្រតិព័ទ្ធចំពោះស្រីនោះ ។ គ្រានោះ សេចក្តីបរិវិតក្កៈនេះបានមានដល់ពួកឆព្វគ្គិយភិក្ខុដូច្នេះថា ម្នាលអាវុសោទាំងឡាយ បើឧបាសកនោះនឹងរស់នៅ ពួកយើងមុខជានឹងមិនបានស្រីនោះទេ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើង ( នាំគ្នា ) ពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសកនោះ ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាចូលទៅកាន់ទីដែលឧបាសកនោះនៅ លុះចូលទៅដល់ហើយក៏និយាយពាក្យនេះនឹងឧបាសកនោះថា ម្នាលឧបាសក អ្នកឯងបានធ្វើអំពើល្អមកហើយ បានធ្វើកុសលមកហើយ បានធ្វើកម្មជាគ្រឿងការពារភ័យរួចអស់ហើយ អ្នកឯងមិនដែលធ្វើបាបមិនដែលធ្វើអំពើលាមក មិនដែលធ្វើអំពើអាក្រក់ អំពើល្អអ្នកបានធ្វើហើយ បាបអ្នកមិនធ្លាប់ធ្វើឡើយ អ្នកឯងមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ អ្នកធ្វើកាលកិរិយារំលាងខន្ធស្លាប់ចាកមនុស្សលោកនេះទៅកាន់បរលោក នឹងកើតក្នុងមនុស្សសុគតិ ឬស្ថានសួគ៌ អ្នក

នឹងបានផ្អែតស្កប់ស្កល់ ( នឹងបានឲ្យស្រីអប្សរទាំងឡាយ ) បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វក្នុងស្ថានសួគ៌នោះ ។ គ្រានោះឯង ឧបាសកនោះគិតថា លោកម្ចាស់ទាំងឡាយនិយាយ ( នេះ ) ពិតណាស់ ដ្បិតខ្លួនអញជាមនុស្ស បានធ្វើអំពើល្អមកហើយ បានធ្វើកុសលមកហើយ បានធ្វើវិធីការពារភ័យ ( ក្នុងអបាយភូមិ ) ហើយ បាបអញមិនដែលធ្វើឡើយ អំពើអាក្រក់ក៏អញមិនដែលធ្វើ មិនធ្លាប់ធ្វើអំពើអាក្រក់សោះ អំពើប្រពៃអញបានធ្វើហើយ បាបអញមិនធ្លាប់ធ្វើឡើយ អញមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អញស្លាប់ទៅប្រសើរជាងរស់នៅ អញធ្វើកាលកិរិយារំលាងខន្ធស្លាប់ចាកមនុស្សលោកនេះទៅកាន់បរលោក នឹងកើតក្នុងមនុស្សសុគតិឬស្ថានសួគ៌ អញមុខជានឹងបានផ្អែតស្កប់ស្កល់ ( ឲ្យស្រីទេពអប្សរទាំងឡាយ ) បម្រើដោយកាមគុណទាំង ៥ ដែលជាទិព្វក្នុងស្ថានសួគ៌នោះ ។ ឧបាសកនោះបរិភោគភោជនទាំងឡាយដែលមិនសប្បាយ ( គឺអាហារដែលស្លែងនាំឲ្យកើតរោគ ) ទំពាស៊ីតែខាទនីយ ( គ្រឿងទំពា ) ដែលមិនសប្បាយផង ជញ្ជាប់ជញ្ជក់តែវត្ថុសម្រាប់ជញ្ជាប់ជញ្ជក់ដែលមិនសប្បាយផង ផឹកទឹកដែលមិនសប្បាយផង។ កាលឧបាសកនោះបរិភោគភោជនដែលមិនសប្បាយតែម្យ៉ាងផង កាលទំពាស៊ីខាទនីយវត្ថុដែលមិនសប្បាយផង កាលជញ្ជាប់ជញ្ជក់វត្ថុសម្រាប់ជញ្ជាប់ជញ្ជក់មិនសប្បាយផង ផឹកទឹកដែលមិនសប្បាយផង អាពាធដ៏ក្លៀវក្លាក៏កើតឡើង ។ ឧបាសកនោះ ក៏ធ្វើកាលកិរិយាស្លាប់ទៅដោយអាពាធនោះឯង ។ ទើបប្រពន្ធរបស់ឧបាសកនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួក

សមណៈទាំងនេះជាសក្យបុត្រ ជាបុគ្គលឥតខ្មាស ជាមនុស្សទ្រុស្តសីល មាន ប្រក្រតីពោលពាក្យមុសា ពួកសមណៈទាំងនេះនឹងប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្ត ធម៌ ជាអ្នកប្រព្រឹត្តរៀបរយ ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ជាអ្នកពោលពាក្យ សត្យ ជាអ្នកមានសីល ជាអ្នកមានកល្យាណធម៌ ដូចម្តេចបាន ភាពសមណៈ របស់ភិក្ខុទាំងនេះគ្មានទេ ព្រហ្មចរិយធម៌របស់ភិក្ខុទាំងនេះក៏គ្មានទេ សាមញ្ញ-គុណរបស់សមណៈទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណៈ ទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពី ណា ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះនឹងមានមកពីណា សមណៈទាំង នេះប្រាសចាកសាមញ្ញគុណហើយ សមណៈទាំងនេះប្រាសចាកព្រហ្មញ្ញគុណ ហើយ ( ព្រោះ ) សមណៈទាំងនេះបានពណ៌នាគុណនៃសេចក្តីស្លាប់ដល់ ស្វាមីរបស់អញ ស្វាមីរបស់អញ គឺសមណៈទាំងនេះសម្លាប់ហើយ ។ ទាំង ពួកមនុស្សឯទៀត ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈពួកនេះ ជាសក្យបុត្រ ជាមនុស្សឥតខ្មាស ជាមនុស្សទ្រុស្តសីល ពោលតែពាក្យមុសា ពួកសមណៈទាំងនេះប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តរាបសា ប្រព្រឹត្ត ព្រហ្មចរិយធម៌ ពោលពាក្យសច្ចៈ មានសីល មានកល្យាណធម៌ ដូចម្តេចបាន ( ព្រោះ ) សាមញ្ញគុណរបស់សមណៈទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់ សមណៈទាំងនេះក៏គ្មានទេ សាមញ្ញគុណរបស់សមណៈទាំងនេះ វិនាសអស់ ហើយ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ សាមញ្ញគុណ របស់សមណៈទាំងនេះនឹងមានមកពីណា ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះ

នឹងមានមកពីណា ពួកសមណៈទាំងនេះប្រាសចាកសាមញ្ញគុណហើយ ពួកសមណៈទាំងនេះ ប្រាសចាកព្រហ្មញ្ញគុណហើយ ( ព្រោះ ) សមណៈទាំងនេះបានពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសក ឧបាសកដែលស្លាប់ពីព្រោះតែសមណៈទាំងនេះ ។ ភិក្ខុទាំងឡាយបានឮមនុស្សពួកនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុម្តេច បានជាពួកឆព្វគ្គិយភិក្ខុទៅពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសក ( ដូច្នោះ ) ។ គ្រានោះឯង ពួកភិក្ខុទាំងនោះ បានក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះបរមសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសកមែនឬ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ( អំពើដែលអ្នកទាំងអស់គ្នាធ្វើហើយនុ៎ះ ) មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើសោះ ម្នាលមោឃបុរសទាំងឡាយ ហេតុម្តេច បានជាអ្នកទាំងឡាយទៅពណ៌នាគុណនៃសេចក្តីស្លាប់ដល់ឧបាសក ( ដូច្នោះ ) ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ក្លែងផ្តាច់បង់រាងកាយរបស់មនុស្សឲ្យឃ្លាតចាកជីវិតក្តី ទោះបីស្វែងរកគ្រឿងសស្ត្រាវុធ ( ឲ្យគេសម្លាប់ ) រាងកាយមនុស្សនោះក្តី ពណ៌នា

គុណនៃសេចក្តីស្លាប់ក្តី ឬនិយាយណែនាំដើម្បីសេចក្តីស្លាប់ថា នែបុរសដ៏ចម្រើន អ្នកមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងរស់នៅ ( ភិក្ខុ ) មានចិត្តគិតដូច្នេះ មានសេចក្តីត្រិះរិះក្នុងចិត្តដូច្នេះ គប្បីពណ៌នាគុណនៃសេចក្តីស្លាប់ ឬគប្បីណែនាំដើម្បីសេចក្តីស្លាប់ដោយអនេកបរិយាយ ភិក្ខុនេះក្តី ហៅថា ត្រូវអាបត្តិបារាជិក មិនមានសំវាសឡើយ ។

[ ១៨១ ] ត្រង់ពាក្យថា ភិក្ខុណាមួយ ( ក្នុងបេយ្យាលទាំងពីរ មានសេចក្តីអធិប្បាយដូចក្នុងបារាជិកកណ្ឌទី ១ ) ។ ត្រង់បទថា ក្លែង ( នោះ ) គឺដឹងជាក់ច្បាស់ហើយក្លែងសម្លាប់ ។ ដែលហៅថា រាងកាយនៃមនុស្ស ( នោះ ) គឺបឋមចិត្តណាដែលកើតឡើងហើយ បឋមវិញ្ញាណណាដែលកើតឡើងប្រាកដហើយក្នុងផ្ទៃនៃមាតាដរាបដល់ពេលស្លាប់ ក្នុងរវាងកាលប៉ុណ្ណោះនេះឯងហៅថា រាងកាយរបស់មនុស្ស ។ ត្រង់ពាក្យថា ផ្តាច់បង់ចាកជីវិត គឺចូលទៅផ្តាច់បង់ ញ៉ាំងឥន្ទ្រិយ គឺជីវិតឲ្យរលត់ទៅ គឺថាញ៉ាំងសន្តតិ ( ខ្សែ-តនៃចិត្ត ) ឲ្យកម្រើក ។ ត្រង់ពាក្យថា ទោះបីស្វែងរកគ្រឿងសស្ត្រាវុធ ( ឲ្យគេសម្លាប់ ) រាងកាយមនុស្សនោះក្តី សេចក្តីថា គឺគប្បីស្វែងរកដាវក្តីលំពែងក្តី ច្បូកក្តី ឈើស្រួចក្តី អន្ទង់ក្តី ថ្មក្តី កាំបិតក្តី ថ្នាំពិសក្តី ខ្សែក្តី ។

[ ១៨២ ] ត្រង់ពាក្យថា ពណ៌នាគុណនៃសេចក្តីស្លាប់ក្តី សេចក្តីថា សម្តែងទោសក្នុងកិរិយារស់នៅ ពោលសរសើរគុណក្នុងការស្លាប់ ។

[ ១៨៣ ] ត្រង់ពាក្យថា និយាយណែនាំដើម្បីសេចក្តីស្លាប់ក្តី សេចក្តី

ថា និយាយណែនាំថា អ្នកចូរនាំគ្រឿងសស្ត្រាមកក្តី ថាអ្នកចូរស៊ីថ្នាំពិសក្តី ថាអ្នកចូរចងរឹតដោយខ្សែហើយធ្វើមរណកាលទៅក្តី ( យ៉ាងនេះហៅថានិយាយណែនាំដើម្បីសេចក្តីស្លាប់ ) ។

[ ១៨៤ ] ត្រង់ពាក្យថា នែបុរសដ៏ចម្រើន ( នេះ ) ជាឈ្មោះនៃពាក្យអាលបន ( ពាក្យសម្រាប់ហៅរក ) ថា ម្នាលបុរសដ៏ចម្រើន ។ ត្រង់ពាក្យថា អ្នកមានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ អ្នកស្លាប់ទៅប្រសើរជាងកិរិយារស់នៅ មានអធិប្បាយថា ជីវិតរបស់ពួកមនុស្សកម្សត់ បើធៀបផ្ទឹមនឹងជីវិតរបស់ពួកមនុស្សស្តុកស្តម្ភ ( ក៏ឃើញថា ) ជាជីវិតលាមក ជីវិតរបស់ពួកមនុស្សឥតទ្រព្យ បើធៀបផ្ទឹមនឹងជីវិតរបស់ពួកមនុស្សមានទ្រព្យ ( ក៏ឃើញថា ) ជាជីវិតលាមក ជីវិតរបស់មនុស្សទាំងឡាយ បើធៀបផ្ទឹមគ្នានឹងជីវិតរបស់ទេវតាទាំងឡាយ ( ក៏ឃើញថា ) ជាជីវិតលាមក ( យ៉ាងនេះ ) ហៅថា ជីវិតលាមក ។ ជីវិតរបស់មនុស្សដាច់ដៃ ដាច់ជើង ដាច់ទាំងដៃទាំងជើង មនុស្សដាច់ត្រចៀក មនុស្សដាច់ច្រមុះ មនុស្សដាច់ទាំងត្រចៀកទាំងច្រមុះ( ទាំងនេះ ) ហៅថា ជីវិតអាក្រក់ ។ អ្នកមានប្រយោជន៍អ្វីនឹងជីវិតដ៏លាមកនេះ និងជីវិតដ៏អាក្រក់នេះ អ្នកស្លាប់ទៅ ប្រសើរជាងរស់នៅ ។ ត្រង់ពាក្យថា មានចិត្តគិតដូច្នេះ សេចក្តីថា ធម្មជាតណាជាចិត្ត ធម្មជាតនោះជាមនោ ធម្មជាតណាជាមនោ ធម្មជាតនោះ គឺ ចិត្ត ។ ត្រង់ពាក្យថា មានសេចក្តីត្រិះរិះក្នុងចិត្តដូច្នេះ សេចក្តីថា មានសេចក្តីសម្គាល់ក្នុងសេចក្តីស្លាប់ មានចេតនាចង់ឲ្យស្លាប់ មានសេចក្តីប៉ុនប៉ងចង់ឲ្យស្លាប់ ។ ត្រង់ពាក្យ

ថា ដោយអនេកបរិយាយ គឺដោយអាការទាំងឡាយខ្ពស់ និងទាប ( ដោយឧបាយច្រើនយ៉ាង ) ។ ត្រង់ពាក្យថា ពណ៌នាគុណនៃសេចក្តីស្លាប់ក្តី អធិប្បាយថា ភិក្ខុសម្តែងទោសក្នុងការរស់នៅ ពោលសរសើរគុណក្នុងការស្លាប់ទៅដូច្នេះថា អ្នកស្លាប់អំពីលោកនេះ គឺអ្នករំលោងខ្លួនស្លាប់ទៅកាន់បរលោក នឹងកើតក្នុងមនុស្សស្រុគតិ ឬស្ថានសួគ៌ អ្នកនឹងបានឆ្អែតស្កប់ស្កល់ ( ឲ្យស្រីទេពអប្សរទាំងឡាយ ) បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វក្នុងស្ថានសួគ៌នោះ ។

[ ១៨៥ ] ត្រង់ពាក្យថា ឬនិយាយណែនាំដើម្បីសេចក្តីស្លាប់ សេចក្តីថា ( និយាយដឹកនាំ ) ថា អ្នកចូរនាំគ្រឿងសស្ត្រាមកក្តី អ្នកចូរស៊ីថ្នាំពិសក្តី អ្នកចូរចងរឹតដោយខ្សែហើយធ្វើកាលកិរិយាទៅក្តី អ្នកចូរលោតទម្លាក់ទៅក្នុងបឹងក្តី អណ្តូងក្តី ជ្រោះក្តី ។

[ ១៨៦ ] ត្រង់ពាក្យថា ភិក្ខុនេះក្តី មានសេចក្តីអធិប្បាយដូចខាងដើម ( ត្រង់បារាជិកកណ្ឌទី ១ ) ។ ត្រង់ពាក្យថា ត្រូវអាបត្តិបារាជិក អធិប្បាយថា ថ្មក្រាស់បែកជាពីរចំណែក ជាវត្ថុភ្ជាប់គ្នាមិនបានទៀត យ៉ាងណាមិញ ភិក្ខុក្លែងផ្តាច់បង់រាងកាយរបស់មនុស្សឲ្យចាកជីវិត មិនមែនជាសមណៈ មិនមែនជាសក្យបុត្រ មានឧបមេយ្យដូច្នោះឯង ព្រោះហេតុនោះ ទើបហៅថា ត្រូវអាបត្តិបារាជិក ។ ត្រង់ពាក្យថា រកសំវាសគ្មាន សេចក្តីថា កម្មជាមួយគ្នា ឧទ្ទេសជាមួយគ្នា សិក្ខាស្មើគ្នា នេះហៅថា មានសំវាស ភិក្ខុនោះ គ្មានសំវាសដូច្នោះទេ ព្រោះហេតុនោះ ទើបហៅថា រកសំវាសគ្មាន ។

[ ១៨៧ ] ភិក្ខុស្ថិតនៅក្នុងទីជិត ( តាំងចិត្តនឹងសម្លាប់មនុស្ស ) ដោយខ្លួនឯង ដោយប្រើបម្រើ ដោយប្រើបម្រើតៗគ្នា ដោយបម្រើទៅធ្វើការខុសសង្កេត ដោយបម្រើទៅហើយត្រឡប់មកវិញ ភិក្ខុនៅក្នុងទីមិនកំបាំងសម្គាល់ថាកំបាំង នៅក្នុងទីកំបាំងសម្គាល់ថាមិនកំបាំង នៅក្នុងទីមិនកំបាំងសម្គាល់ថាមិនកំបាំង នៅក្នុងទីកំបាំងសម្គាល់ថាកំបាំង ភិក្ខុពណ៌នា ( សេចក្ដីស្លាប់ ) ដោយកាយ ពណ៌នាដោយវាចា ពណ៌នាដោយកាយ និងវាចា ពណ៌នាដោយប្រើបម្រើ ពណ៌នាដោយចារឹកអក្សរ ជីករណ្ដៅ ធ្វើបង្អែកបន្កប់ចម្រូង ឲ្យភេសជ្ជៈ សម្លាប់ដោយរូប សម្លាប់ដោយសំឡេង សម្លាប់ដោយក្លិន សម្លាប់ដោយរស សម្លាប់ដោយសម្ផស្ស សម្លាប់ដោយធម៌ បង្គាប់ឲ្យស្លាប់ ប្រៀនប្រដៅដើម្បីឲ្យស្លាប់ ធ្វើសង្កេតកម្ម ធ្វើនិមិត្តកម្ម ។

[ ១៨៨ ] ត្រង់ពាក្យថា ដោយខ្លួនឯង គឺភិក្ខុសម្លាប់ ( គេ ) ខ្លួនឯង ដោយកាយក្ដី ដោយអាវុធដែលជាប់នឹងកាយក្ដី ដោយគ្រឿងប្រយោលក្ដី ។ ត្រង់ពាក្យថា ស្ថិតនៅក្នុងទីជិត សេចក្ដីថា ស្ថិតនៅ ( ក្នុងទីជិត ) ក៏បង្គាប់ថា អ្នកចូរចាក់យ៉ាងនេះ អ្នកចូរប្រហារយ៉ាងនេះ អ្នកចូរសម្លាប់យ៉ាងនេះ ។

[ ១៨៩ ] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្ដាច់បង់ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទទួលបង្គាប់នោះចំណាំមនុស្សនោះបាន ហើយផ្ដាច់បង់ជីវិតមនុស្សនោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្ដាច់បង់ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សបាន ( ប៉ុន្តែ ) ទៅផ្ដាច់បង់

ជីវិតមនុស្សដទៃវិញ ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិឡើយ ភិក្ខុអ្នកសម្លាប់ត្រូវអាបត្តិបារាជិក ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សដទៃវិញ ( ប៉ុន្តែ ) ទៅផ្តាច់បង់ជីវិតមនុស្សនោះ ( គឺមនុស្សដែលអ្នកប្រើប្រាប់ឲ្យសម្លាប់នោះ ) ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្តាច់បង់ជីវិតមនុស្សឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់ចំណាំមនុស្សដទៃវិញ (លុះវេលា) ទៅផ្តាច់បង់ៗ ជីវិតមនុស្សដទៃនោះ ( បើធ្វើខុសបង្គាប់ដូច្នេះ ) ភិក្ខុអ្នកបង្គាប់មិនត្រូវអាបត្តិឡើយ ភិក្ខុអ្នកសម្លាប់ ត្រូវអាបត្តិបារាជិក ។

[ ១៩០ ] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរប្រាប់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះប្រាប់ដល់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរផ្តាច់បង់ជីវិត បុគ្គលឈ្មោះនេះដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅប្រាប់អ្នកឯទៀតវិញ ( ដូច្នេះ ) ក៏ត្រូវអាបត្តិទុក្កដដែល ។ ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់ ភិក្ខុអ្នកប្រើដើមត្រូវអាបត្តិថុល្លច្ច័យ ។ លុះភិក្ខុអ្នកសម្លាប់បានផ្តាច់បង់ជីវិតបុគ្គលនោះសម្រេចត្រូវអាបត្តិបារាជិកគ្រប់ទាំងបួនរូប ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅប្រាប់ភិក្ខុឈ្មោះនេះ ឲ្យភិក្ខុឈ្មោះនេះ ទៅប្រាប់ភិក្ខុឈ្មោះនេះថា ភិក្ខុឈ្មោះនេះចូរទៅផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅបង្គាប់ភិក្ខុឯទៀតវិញ ( ធ្វើខុសបង្គាប់ដូច្នេះ ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុអ្នកសម្លាប់នោះ បានផ្ដាច់បង់ជីវិតបុគ្គលនោះសម្រេច ភិក្ខុអ្នកបង្គាប់ដើម មិនត្រូវអាបត្តិឡើយ ត្រូវអាបត្តិបារាជិកតែភិក្ខុអ្នកបង្គាប់ និងភិក្ខុអ្នកសម្លាប់ ។

[ ១៩១ ] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរផ្ដាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកទទួលបង្គាប់នោះទៅហើយត្រឡប់មកប្រាប់វិញថា ខ្ញុំមិនអាចនឹងផ្ដាច់បង់ជីវិតបុគ្គលនោះទេ ។ ភិក្ខុនោះ បង្គាប់ទៀតថា លោកអាចវេលាណា លោកចូរទៅផ្ដាច់បង់ជីវិតគេវេលានោះចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះភិក្ខុអ្នកទទួលបង្គាប់នោះ បានផ្ដាច់បង់ជីវិតបុគ្គលនោះសម្រេច ក៏ត្រូវអាបត្តិបារាជិកទាំងពីររូប ។

[១៩២]ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅផ្ដាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះលុះបង្គាប់ភិក្ខុផងគ្នានោះហើយ ក៏ស្រាប់តែកើតសេចក្ដីក្ដៅក្រហាយ ( ស្ដាយក្រោយ ) តែនឹងបានប្រាប់ឲ្យដឹងថា លោកកុំទៅសម្លាប់ដូច្នេះក៏ទេ ។ ភិក្ខុអ្នកទទួលបង្គាប់ លុះផ្ដាច់បង់ជីវិតបុគ្គលនោះស្រេច ក៏ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅផ្ដាច់បង់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ( តែ ) ភិក្ខុនោះលុះបង្គាប់រួចហើយក៏ស្រាប់តែកើតសេចក្ដីក្ដៅក្រហាយ ( ស្ដាយក្រោយ ) ទើបប្រាប់វិញថា លោកកុំទៅសម្លាប់ឡើយ ។ ភិក្ខុនោះអាងថា លោកបង្គាប់ខ្ញុំហើយ ក៏ទៅផ្ដាច់ជីវិតបុគ្គលនោះទៅ ( យ៉ាងនេះ ) ភិក្ខុអ្នកប្រើដើមមិនត្រូវអាបត្តិទេ ត្រូវអាបត្តិបារាជិកតែអ្នកសម្លាប់ ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា លោកចូរទៅផ្ដាច់ជីវិតបុគ្គលឈ្មោះនេះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះភិក្ខុនោះ

បង្គាប់ ហើយក៏កើតសេចក្ដីក្ដៅក្រហាយ ( ស្ដាយក្រោយ ) ទើបប្រាប់វិញថា លោកកុំទៅសម្លាប់ឡើយ ។ ភិក្ខុអ្នកសម្លាប់នោះទទួលថា សាធុ ហើយឈប់វិញ ( ដូច្នេះ ) មិនត្រូវអាបត្តិទាំងពីររូប ។

[ ១៩៣ ] ភិក្ខុសម្គាល់ទីដែលមិនស្ទាត់ ថាទីស្ទាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះអញត្រូវតែសម្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ទីដែលស្ទាត់ថាទីមិនស្ទាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះសូមឲ្យវិនាសទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ទីដែលមិនស្ទាត់ថាទីមិនស្ទាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ សូមវិនាសទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ទីដែលស្ទាត់ថាស្ទាត់ ទើបពោលថា ឱ បុគ្គលឈ្មោះនេះ សូមឲ្យវិនាសទៅចុះ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។

[ ១៩៤ ]ដែលហៅថា ពណ៌នាដោយកាយ ( នោះ ) គឺភិក្ខុធ្វើវិការដោយកាយដូច្នេះ បុគ្គលណា ស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬនឹងបានយសស័ក្តិ ឬនឹងទៅកាន់ស្ថានសួគ៌ ( ភិក្ខុធ្វើយ៉ាងនេះ ) ត្រូវអាបត្តិទុក្កដ ។ ( បើមនុស្សស្ដាប់សេចក្ដីពណ៌នានោះហើយ ) ញ៉ាំងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយកិរិយាពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា ពោលពណ៌នាដោយវាចា ( នោះ ) គឺភិក្ខុពោលដោយវាចាថា បុគ្គលណាស្លាប់យ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ( បើមនុស្សស្ដាប់សេចក្ដីពណ៌នា

នោះហើយ ) ញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ដោយកិរិយាពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើបុគ្គលនោះ ) ស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា ពោលពណ៌នាដោយកាយ និងវាចា ( នោះ ) គឺភិក្ខុធ្វើវិការដោយកាយផង ពោលដោយវាចាផង ដូច្នេះថា បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ( បើមនុស្សស្តាប់សេចក្តីពណ៌នានោះហើយ ) ញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ដោយកិរិយាពោលពណ៌នានោះ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ បើបុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[ ១៩៥ ] ដែលហៅថា ពោលពណ៌នាដោយប្រើបម្រើ ( នោះ ) គឺភិក្ខុប្រាប់ដំណឹងដល់បម្រើថា បុគ្គលណាស្លាប់យ៉ាងនេះ បុគ្គលនោះ នឹងបានទ្រព្យ ឬបានយសស័ក្តិ ឬពុំនោះទៅកាន់ស្ថានសួគ៌ ដូច្នេះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ ( បើ ) បុគ្គលនោះ បានស្តាប់ដំណឹងរបស់បម្រើ ហើយគិតថា អញនឹងស្លាប់ ហើយក៏ញុំាងទុក្ខវេទនាឲ្យកើតឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) បុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា ពណ៌នាដោយវិធីសរសេរអក្សរ ( នោះ ) គឺភិក្ខុឆ្លាក់អក្សរ ( ជាសេចក្តី ) ថា បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដគ្រប់ៗ អក្ខរៈ ។ ( បុគ្គលនោះ ) ឃើញអក្សរចារឹកហើយគិតថា អញនឹងស្លាប់ទៅ ហើយញុំាងទុក្ខវេទនាឲ្យ

កើតឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) បុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[ ១៩៦ ] ដែលហៅថា រណ្តៅ ( នោះ ) គឺភិក្ខុជីករណ្តៅចំពោះមនុស្ស ដោយតាំងចិត្តថា អ្នកណាមួយធ្លាក់ទៅគង់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ កាលបើអ្នកណាមួយធ្លាក់ទៅហើយ កើតទុក្ខវេទនាឡើង ( ដល់អ្នកនោះ ) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ បើអ្នកនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុជីករណ្តៅមិនចំពោះ ( មនុស្ស ឬអមនុស្ស ) ដោយគិតថា ជនណាមួយធ្លាក់ទៅគង់ស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ( បើ ) មនុស្សធ្លាក់ទៅក្នុងរណ្តៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ កាលមនុស្សនោះធ្លាក់ទៅ កើតទុក្ខវេទនាឡើង ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើមនុស្សនោះ ) ស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ( បើ ) យក្ខក្តី ប្រេតក្តី សត្វតិរច្ឆានដែលមានរាងកាយដូចមនុស្សក្តី ធ្លាក់ទៅក្នុងរណ្តៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ កាលបើជនមានយក្ខជាដើមនោះធ្លាក់ទៅ ហើយកើតទុក្ខវេទនា ភិក្ខុក៏ត្រូវអាបត្តិទុក្កដដែរ ។ ( បើ ) ជនមានយក្ខជាដើមនោះស្លាប់ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) សត្វតិរច្ឆានធ្លាក់ទៅក្នុងរណ្តៅនោះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ កាលបើធ្លាក់ទៅហើយកើតទុក្ខវេទនា ត្រូវអាបត្តិទុក្កដ ។ ( បើ ) វាស្លាប់ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។

[ ១៩៧ ] ដែលហៅថា បង្អែក ( នោះ ) គឺភិក្ខុបង្កប់សស្ត្រាក្នុងទីសម្រាប់ផ្អែកក្តី លាបដោយថ្នាំពិសក្តី ធ្វើឲ្យទ្រុឌទ្រោមក្តី បង្កប់សស្ត្រាក្នុង

ត្រពាំងក្តី ក្នុងអណ្តូងក្តី ក្នុងជ្រោះក្តី ដោយគិតថា មនុស្សណាមួយនឹងធ្លាក់ទៅស្លាប់ដោយគ្រឿងប្រហារនេះ ត្រូវអាបត្តិទុក្កដ ។ បើមនុស្សនោះមានទុក្ខវេទនាកើតឡើងដោយសស្ត្រាក្តី ដោយថ្នាំពិសក្តី ដោយដំណើរដែលធ្លាក់ចុះទៅ ( តាមធម្មតា ) ក្តី ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ បើមនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[ ១៩៨ ] ដែលហៅថា បង្កប់ចម្រូង ( នោះ ) គឺភិក្ខុបង្កប់ដាវក្តី លំពែងក្តី ច្បូកក្តី ឈើស្រួចក្តី អន្ទូងក្តី ថ្មក្តី កាំបិតក្តី ថ្នាំពិសក្តី ខ្សែក្តី ដោយគិតថា មនុស្សណាមួយនឹងស្លាប់ដោយវត្ថុមានដាវជាដើមនេះ ( យ៉ាងនេះ ) ត្រូវអាបត្តិទុក្កដ ។ ( បើ ) មនុស្សនោះញុំាងទុក្ខវេទនាឲ្យកើតឡើងដោយគិតថា អញនឹងស្លាប់ដោយវត្ថុ មានដាវជាដើមនោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[ ១៩៩ ] ដែលហៅថា ភេសជ្ជៈ ( នោះ ) គឺភិក្ខុឲ្យសប្បិក្តី នវនីតក្តី ប្រេងក្តី ទឹកឃ្មុំក្តី ស្ករអំពៅក្តី ដោយតាំងចិត្តថា មនុស្សដែលជញ្ជក់ជញ្ជាប់ ( ស៊ី ) ភេសជ្ជៈមានសប្បិជាដើមនោះហើយ គង់នឹងស្លាប់ ដូច្នេះត្រូវអាបត្តិទុក្កដ ។ កាលបើមនុស្សស៊ីភេសជ្ជៈ មានសប្បិជាដើមនោះហើយកើតទុក្ខវេទនា ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[ ២០០ ] ដែលហៅថា សម្លាប់ដោយរូប ( នោះ ) គឺភិក្ខុនាំយករូបដែលមិនគាប់ចិត្ត មុខគួរឲ្យខ្លាច ភិតភ័យ ស្ញប់ស្ញែង ដោយតាំងចិត្តថា

មនុស្សណាមួយមកឃើញរូបនេះហើយ នឹងតក់ស្លុតស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ( បើ ) មនុស្សឃើញរូបនោះហើយតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) មនុស្សស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយករូបដែលជាទីគាប់ចិត្ត គួរឲ្យស្រឡាញ់ពេញចិត្ត ដោយបំណងថា មនុស្សណាមួយមកឃើញរូបនេះហើយ តែមិនបាន ( រូបនេះ ) មុខជានឹងសង្រេងសង្រែរីងរៃស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ( បើ ) មនុស្សឃើញរូបនោះហើយក្រៀមក្រំព្រោះមិនបាន ( តាមប្រាថ្នា ) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយសំឡេង ( នោះ ) គឺភិក្ខុនាំយកសំឡេងមិនជាទីគាប់ចិត្ត មុខគួរឲ្យខ្លាច ភិតភ័យស្ញប់ស្ញែង ដោយបំណងថា មនុស្សណាមួយ បានឮសំឡេងនេះហើយ នឹងតក់ស្លុតស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះមនុស្សឮសំឡេងនោះហើយតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយកសំឡេងជាទីគាប់ចិត្ត មុខគួរស្រឡាញ់ ចូលចាប់ដួងចិត្ត ដោយបំណងថា មនុស្សណាមួយបានឮសំឡេងនេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះចង់បានមិនបាន ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះមនុស្សឮសំឡេងនោះហើយក្រៀមក្រំចិត្ត ព្រោះចង់បានមិនបាន ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) មនុស្សនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយក្លិន ( នោះ ) គឺភិក្ខុនាំយកក្លិនមិនគាប់ចិត្ត មុខគួរខ្ពើមឆ្អើម ដោយបំណងថា មនុស្សណាមួយហិតក្លិនហើយ គង់នឹងស្លាប់ ព្រោះជារបស់គួរ

ខ្ពើម គួរឆ្អើម ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ កាលបើគេហិតក្លិននោះហើយ មានទុក្ខវេទនាកើតឡើង ព្រោះខ្ពើម ព្រោះឆ្អើម ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយកក្លិនជាទីគាប់ចិត្តចូលទៅដោយបំណងថា មនុស្សណាមួយ បានហិតក្លិននេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះចង់បានមិនបាន ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេហិតក្លិននោះហើយក្រៀមក្រំព្រោះមិនបាន ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយរស ( នោះ ) គឺភិក្ខុនាំយករសដែលមិនជាទីគាប់ចិត្ត មុខគួរខ្ពើមឆ្អើម ដោយតាំងចិត្តថា មនុស្សណាមួយបានជញ្ជក់ជញ្ជាប់រសនេះហើយ នឹងស្លាប់ ព្រោះជារសគួរខ្ពើមឆ្អើម ដូច្នេះត្រូវអាបត្តិទុក្កដ ។ កាលបើគេជញ្ជក់ជញ្ជាប់រសនោះហើយ មានទុក្ខវេទនាកើតឡើង ព្រោះជារបស់គួរខ្ពើមឆ្អើម ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះគេស្លាប់ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយករសជាទីគាប់ចិត្ត ដោយបំណងថា មនុស្សណាមួយបានជញ្ជក់ជញ្ជាប់រសនេះហើយ នឹងក្រៀមក្រំស្លាប់ ព្រោះមិនបាន( ដូចបំណង ) ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេជញ្ជក់ជញ្ជាប់រសនោះហើយ កើតក្រៀមក្រំ ព្រោះមិនបាន ( តាមបំណង ) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថាសម្លាប់ដោយសម្ផស្សនោះ គឺភិក្ខុនាំយកផោដ្ឋព្វៈមិនជាទីគាប់ចិត្ត ដែលមានសម្ផស្សនាំមកនូវសេចក្តីទុក្ខ ដែលមានសម្ផស្សរឹង ដោយបំណងថា មនុស្សណាមួយ បានពាល់ត្រូវសម្ផស្សនេះ មុខជានឹងស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ។

( បើ ) ទុក្ខវេទនាកើតឡើងដល់បុគ្គលដែលបានពាល់ត្រូវសម្ផស្សនោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះគេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំយកផោដ្ឋព្វៈជាទីគាប់ចិត្ត ដែលមានសម្ផស្សជាសុខ ដែលមានសម្ផស្សទន់ ដោយបំណងថា បុគ្គលណាមួយ មកពាល់ត្រូវសម្ផស្សនេះហើយ នឹងក្រៀមក្រំស្លាប់ព្រោះមិនបាន ( តាមប្រាថ្នា ) ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេពាល់ត្រូវសម្ផស្សនោះហើយ កើតក្រៀមក្រំ ព្រោះមិនបាន ( តាមប្រាថ្នា ) ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា សម្លាប់ដោយធម៌នោះ គឺភិក្ខុពោលអំពីរឿងនរកនៃសត្វដែលទៅកើតក្នុងនរក ដោយបំណងថា មនុស្សណាមួយ បានស្តាប់រឿងនរកនេះហើយ នឹងតក់ស្លុតហើយស្លាប់ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ លុះគេបានស្តាប់រឿងនរកនោះហើយ កើតតក់ស្លុត ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ភិក្ខុពោលអំពីរឿងស្ថានសួគ៌ នៃបុគ្គលដែលបានធ្វើកម្មដ៏ល្អ ដោយបំណងថា មនុស្សណាមួយ បានស្តាប់និទានអំពីស្ថានសួគ៌នេះហើយ នឹងអត់ជង្រើមស្លាប់ ដូច្នេះ ភិក្ខុត្រូវអាបត្តិទុក្កដ ។ លុះគេបានស្តាប់និទានអំពីស្ថានសួគ៌នោះហើយ ញុំាងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងអត់ជង្រើមស្លាប់ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ ( បើ ) គេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[ ២០១ ] ដែលហៅថា បង្គាប់ឲ្យស្លាប់ ( នោះ ) គឺមានមនុស្សសួរភិក្ខុៗ ឆ្លើយថា អ្នកឯងចូរស្លាប់ទៅយ៉ាងនេះចុះ ព្រោះបុគ្គលណាមួយស្លាប់

ទៅយ៉ាងនេះ បុគ្គលនោះនឹងបានទ្រព្យ ឬបានយសស័ក្តិ ឬទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ បុគ្គលនោះ ញ៉ាំងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់តាមបង្គាប់នោះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះគេស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។ ដែលហៅថា ប្រៀនប្រដៅដើម្បីឲ្យស្លាប់ ( នោះ ) គឺគេមិនបានសួរភិក្ខុទេ តែភិក្ខុនិយាយថា អ្នកចូរស្លាប់យ៉ាងនេះចុះ ( ព្រោះ ) បុគ្គលណាស្លាប់ទៅយ៉ាងនេះ បុគ្គលនោះ នឹងបានទ្រព្យ ឬបានយសស័ក្តិ ឬ ទៅកាន់ស្ថានសួគ៌ ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ ព្រោះពាក្យប្រៀនប្រដៅប៉ុណ្ណោះ ទើបបុគ្គលនោះញ៉ាំងទុក្ខវេទនាឲ្យកើតឡើង ដោយគិតថា អញនឹងស្លាប់ ដូច្នេះ ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ។ លុះបុគ្គលនោះស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក ។

[ ២០២ ] ដែលហៅថា ធ្វើសង្កេតកម្ម ( នោះ ) គឺភិក្ខុកំណត់វេលាថា លោកចូរទៅផ្តាច់បង់ជីវិតបុគ្គលនោះ តាមសេចក្តីកំណត់នោះ ទោះនៅវេលាមុនបាយក្តី ក្រោយបាយក្តី យប់ក្តី ថ្ងៃក្តី ដូច្នេះ ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះ តាមសេចក្តីកំណត់នោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ( បើ ) ភិក្ខុទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះ មុនក្តី ក្រោយក្តី អំពីកំណត់នោះ ភិក្ខុអ្នកប្រើដើម មិនត្រូវអាបត្តិទេ ឯអ្នកសម្លាប់ត្រូវអាបត្តិបារាជិក ។ ដែលហៅថា ធ្វើនិមិត្តកម្ម ( នោះ ) គឺភិក្ខុធ្វើនិមិត្តសញ្ញា ដូច្នេះថា ( បើ ) ខ្ញុំប៉ប្រិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងក់ក្បាលក្តី លោកចូរផ្តាច់បង់ជីវិតបុគ្គលនោះតាមនិមិត្តសញ្ញានោះ

ចុះ ( ធ្វើនិមិត្តសញ្ញាប៉ុណ្ណោះ ) ត្រូវអាបត្តិទុក្កដ ។ ( បើ ) ភិក្ខុអ្នកទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះ តាមនិមិត្តសញ្ញានោះ ត្រូវអាបត្តិបារាជិកទាំងពីររូប ។ ( បើ ) ភិក្ខុអ្នកទទួលបង្គាប់ទៅផ្តាច់បង់ជីវិតបុគ្គលនោះមុនឬក្រោយនិមិត្តសញ្ញានោះ ភិក្ខុអ្នកប្រើខាងដើម មិនត្រូវអាបត្តិឡើយ ឯអ្នកសម្លាប់ ត្រូវអាបត្តិបារាជិក ។

[ ២០៣ ] ភិក្ខុមិនក្លែង ១ ភិក្ខុមិនដឹង ១ ភិក្ខុមិនប្រាថ្នាឲ្យស្លាប់ ១ ភិក្ខុឆ្កួត ១ ភិក្ខុមានចិត្តរវើរវាយ ១ ភិក្ខុមានវេទនាគ្របសង្កត់ ១ ភិក្ខុដើមបញ្ញត្តិ ១ ( ភិក្ខុទាំងនេះ ) មិនត្រូវអាបត្តិទេ ។

## ចប់ បឋមភាណវារក្នុងមនុស្សវិគ្គហបារាជិក ។

( មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសម្តែងតទៅដូចមានខាងក្រោយនេះ )

[ ២០៤ ] រឿងភិក្ខុពណ៌នាសេចក្តីស្លាប់ រឿងភិក្ខុអង្គុយសង្កត់ក្មេង រឿងអង្រែ និងត្បាល់ រឿងបិតា និងបុត្របួសឯចាស់ រឿងសាច់ជាប់បំពង់ក រឿងភិក្ខុបិណ្ឌបាតបានចង្ហាន់លាយថ្នាំពិស រឿងភិក្ខុបីពួកធ្វើការកសាងទីលំនៅ រឿងភិក្ខុបីពួកទៀតធ្វើការកសាងដោយឥដ្ឋ រឿងកាំបិតព្រា រឿងបង្គន់ រឿងរន្ទា រឿងឡើងភ្នំ រឿងទត្តថ្នាំឲ្យបេញញើស រឿងប្របាច់ រឿងផ្លូតទឹក រឿងលាបប្រេង រឿងភិក្ខុធ្វើភិក្ខុមានជំងឺឲ្យក្រោក រឿងភិក្ខុផ្ទួលភិក្ខុមានជំងឺ រឿងភិក្ខុសម្លាប់ភិក្ខុដោយបាយ និងទឹក រឿងស្រីមានផ្ទៃពោះព្រោះសហាយ រឿង

ស្រីរួមប្តី រឿងភិក្ខុសម្លាប់ម្តាយ និងកូនទាំងពីរនាក់ រឿងស្រីពីរនាក់រំលូតកូនតែមិនស្លាប់ រឿងកម្តៅផ្ទៃពោះ រឿងស្រីអារ រឿងស្រីមានកូន រឿងភិក្ខុចាក់ក្រឡេក រឿងខ្មោចចូលភិក្ខុ រឿងភិក្ខុបញ្ជូនភិក្ខុទៅកាន់ទីមានខ្មោចលង រឿងភិក្ខុចំណាំភិក្ខុជាសត្រូវហើយប្រហារ រឿងភិក្ខុពោលពីស្ថានសួគ៌និងនរក រឿងភិក្ខុស្រុកអាឡវីបីរូបនាំគ្នាកាប់ដើមឈើ រឿងភិក្ខុបីរូបទៀតដុតភ្លើងព្រៃ រឿងភិក្ខុនិយាយនឹងមនុស្សសម្លាប់ចោរ រឿងប្រេងខ្លាញ់គោ និងថ្នាំត្រាំទុកយូរ ។

[ ២០៥ ] សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ទើបភិក្ខុទាំង-ឡាយពណ៌នាគុណនៃសេចក្តីស្លាប់ ដល់ភិក្ខុមានជំងឺនោះ ដោយចិត្តអាណិតអាសូរ ។ ភិក្ខុនោះ ក៏ធ្វើមរណកាលទៅ ។ ទើបភិក្ខុទាំងនោះមានសេចក្តីសង្ស័យថា យើងទាំងឡាយត្រូវអាបត្តិបារាជិកទេដឹង ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងកាលនោះឯង ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវអាបត្តិបារាជិកហើយ ។

[ ២០៦ ] សម័យនោះឯង មានភិក្ខុមួយរូបកាន់បិណ្ឌចារិកវត្ត អង្គុយសង្កត់ក្មេងដែលគេដណ្តប់ដោយកំណាត់សំពត់នៅលើតាំងស្លាប់ទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អាត្មាត្រូវអាបត្តិបារាជិកទេដឹង ។ ទើបភិក្ខុនោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនទាន់បានពិនិត្យទេ កុំអាលអង្គុយលើអាសនៈ ភិក្ខុណាអង្គុយ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ ។

[ ២០៧ ] សម័យនោះឯង មានភិក្ខុមួយរូបឲ្យគេក្រាលអាសនៈក្នុងរោងភត្តត្រង់ចន្លោះផ្ទះ ហើយបានឈោងទៅចាប់អង្រែមួយត្រង់កន្លែងដែលគេបញ្ឈរអង្រែ ។ អង្រែជាគម្រប់ពីរ រលំទៅសង្កត់លើក្បាលទារកម្នាក់ ។ ទារកនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនបានក្លែងទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនក្លែង មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូប ឲ្យគេក្រាលអាសនៈក្នុងរោងភត្តត្រង់ចន្លោះផ្ទះ បានទៅជាន់ឈើដែលគេសម្រាប់តម្កល់ត្បាល់ ឲ្យវិលទៅសង្កត់ទារកម្នាក់ស្លាប់ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនក្លែង មិនត្រូវអាបត្តិទេ ។

[ ២០៨ ] សម័យនោះឯង បិតា និងបុត្របានចេញបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ។ កាលដល់ពេលចង្ហាន់គេបានប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចម្រើន លោកឪពុកនិមន្តទៅចុះ ព្រះសង្ឃនឹងអង្គាសលោកឪពុក ( ថាហើយក៏ ) ចាប់ខ្នងច្រានទៅ ។ ភិក្ខុជាបិតានោះ ក៏ដួលស្លាប់ ។ ភិក្ខុជាកូននោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តដូចម្តេច ។ ភិក្ខុនោះ ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គឥតមានបំណងឲ្យស្លាប់ទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនមានបំណងឲ្យស្លាប់ទេ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង បិតា និងបុត្របានមកបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ។

កាលដល់ពេលឆាន់គេប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចម្រើន លោកឪពុកនិមន្តទៅចុះ សង្ឃរនឹងអង្គាសលោកឪពុក ( ថាហើយ ) មានបំណងចង់ឲ្យស្លាប់ ក៏ចាប់ខ្នងច្រានទៅ ។ ភិក្ខុជាបិតានោះក៏ដួលចុះហើយស្លាប់ទៅ ។ ភិក្ខុជាបុត្រនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង បិតា និងបុត្របានចេញបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ។ កាលដល់ពេលចង្ហាន់ គេបានប្រាប់ហើយ ភិក្ខុជាបុត្របាននិយាយនឹងភិក្ខុជាបិតាថា បពិត្រលោកឪពុកដ៏ចម្រើន លោកឪពុកនិមន្តទៅចុះ សង្ឃរនឹងអង្គាសលោកឪពុក ( ថាហើយ ) មានបំណងចង់ឲ្យស្លាប់ ទើបចាប់ខ្នងច្រានទៅ ។ ភិក្ខុជាបិតានោះក៏ដួលទៅ តែមិនស្លាប់ ។ ភិក្ខុជាបុត្រនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២០៩ ] សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ចង្ហាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក ។ មានភិក្ខុមួយរូបទៀត បានវាយចំបំពង់កនៃភិក្ខុនោះ ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុអ្នកវាយនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនមានបំណងចង់ឲ្យស្លាប់ទេ មិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុមួយរូបកំពុងឆាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក ។ មានភិក្ខុមួយទៀតចង់សម្លាប់ ទើបវាយចំបំពង់កនៃភិក្ខុនោះ ។ ក៏ធ្លាក់សាច់ដោយទាំងឈាម

មកផង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានភិក្ខុមួយរូបកំពុងធាន់ សាច់ក៏ស្ទាក់ជាប់ក្នុងបំពង់ក ។ មានភិក្ខុមួយរូបទៀត មានប្រាថ្នាចង់ឲ្យស្លាប់ ទើបវាយបំពង់កនៃភិក្ខុនោះ ។ ក៏ធ្លាក់សាច់ដោយទាំងឈាមមកផង តែភិក្ខុនោះមិនស្លាប់ ។ ភិក្ខុអ្នកវាយនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២១០ ] សម័យនោះឯង មានបិណ្ឌចារិកភិក្ខុមួយរូប បានចម្អិនលាយដោយថ្នាំពិស ហើយនាំចេញទៅ បានប្រគេនភោជនដ៏ឧត្តមដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងនោះក៏ ( នាំគ្នាធាន់ ) ពុលស្លាប់អស់ទៅ ។ ភិក្ខុអ្នកប្រគេនបិណ្ឌបាតនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់សួរថា នែភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងសោះ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនដឹង មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូប មានប្រាថ្នាចង់ល្បងលេង បានឲ្យថ្នាំពិសដល់ភិក្ខុមួយរូប ។ ភិក្ខុនោះស្លាប់ ។ ភិក្ខុអ្នកឲ្យនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងល្បងលេងទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២១១ ] សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី នាំគ្នារៀបចំទីវត្ត ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចថ្មទៅ ភិក្ខុនៅខាងលើទទួលថ្មមិនមាំ ក៏របូតធ្លាក់មកចំក្បាលភិក្ខុអ្នកនៅខាងក្រោម ។ ភិក្ខុត្រូវថ្មធ្លាក់លើនោះក៏ស្លាប់ទៅ ។ ភិក្ខុអ្នកទទួលថ្មមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង ។ សម័យនោះឯង ពួកភិក្ខុស្រុកអាឡវី ( នាំគ្នា ) រៀបចំទីវត្ត ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចថ្មទៅលើ ។ ភិក្ខុអ្នកនៅខាងលើ មានបំណងចង់សម្លាប់ ក៏ទម្លាក់ថ្មមកចំក្បាលភិក្ខុអ្នកនៅខាងក្រោម ។ ភិក្ខុនោះស្លាប់ ។ ភិក្ខុអ្នកទម្លាក់ថ្មនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី ( នាំគ្នា ) រៀបចំទីវត្ត ។ មានភិក្ខុមួយរូប ( ធ្វើការ ) នៅខាងក្រោមបានហុចថ្មទៅ ។ ភិក្ខុនៅខាងលើមានបំណងចង់សម្លាប់ ( ភិក្ខុនៅខាងក្រោម ) ទើបទម្លាក់ថ្មមកចំក្បាលភិក្ខុនៅខាងក្រោមនោះ ។ ភិក្ខុនោះមិនស្លាប់ ។ ភិក្ខុអ្នកទម្លាក់ថ្មនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី ( នាំគ្នា ) លើកជញ្ជាំងវិហារ ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចឥដ្ឋទៅខាងលើ ។ ឥដ្ឋដែលភិក្ខុនៅខាងលើចាប់មិនមាំ ក៏ធ្លាក់មកចំក្បាលភិក្ខុអ្នកនៅខាងក្រោម។ ភិក្ខុនោះស្លាប់ ។ ភិក្ខុទទួលឥដ្ឋនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង ។ សម័យនោះឯង ពួក

ភិក្ខុនៅក្នុងដែនអាឡវី ( នាំគ្នា ) កជញ្ជាំងវិហារ ។ មានភិក្ខុមួយរូបនៅខាងក្រោមហុចឥដ្ឋទៅ ។ ភិក្ខុ ( អ្នកទទួលឥដ្ឋ ) នៅខាងលើមានបំណងចង់សម្លាប់ ក៏ទម្លាក់ឥដ្ឋមកចំក្បាលភិក្ខុអ្នកនៅខាងក្រោម ។ ភិក្ខុនោះស្លាប់ ។បេ។ ភិក្ខុនោះមិនស្លាប់ ។ ភិក្ខុអ្នកទម្លាក់ឥដ្ឋនោះមានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ពួកភិក្ខុនៅប្រទេសអាឡវី ( នាំគ្នា ) ធ្វើនវ-កម្ម ( ការកសាង ) មានភិក្ខុមួយរូបទៀតនៅខាងក្រោមហុចកាំបិតព្រាទៅខាងលើ ។ កាំបិតព្រាដែលភិក្ខុនៅខាងលើចាប់មិនជាប់ ក៏របូតមកចំក្បាលភិក្ខុនៅខាងក្រោម ។ ភិក្ខុនោះធ្វើកាលកិរិយាទៅ ។ ភិក្ខុអ្នកទទួលកាំបិតនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះមិនបានក្លែង ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី ( នាំគ្នា ) ធ្វើនវកម្ម ។ មានភិក្ខុមួយរូបនៅខាងក្រោម ហុចកាំបិតព្រាទៅខាងលើ ។ ភិក្ខុនៅខាងលើមានបំណងចង់សម្លាប់( ភិក្ខុនៅខាងក្រោម ) ទើបទម្លាក់កាំបិតព្រាចំក្បាលភិក្ខុនៅខាងក្រោម ។ ភិក្ខុនោះ ធ្វើកាលកិរិយាទៅ ។បេ។ ភិក្ខុនោះ មិនបានធ្វើកាលកិរិយា ។ ភិក្ខុអ្នកទម្លាក់កាំបិតនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ពួកភិក្ខុនៅដែនអាឡវី ( នាំគ្នា ) ធ្វើនវកម្ម ។ មានភិក្ខុមួយរូបនៅខាងក្រោម ហុចបង្គន់វិហារទៅខាងលើ ។ បង្គន់ដែលភិក្ខុនៅខាងលើចាប់មិនមាំ ក៏ធ្លាក់មកចំក្បាលភិក្ខុអ្នក

នៅខាងក្រោម ។ ភិក្ខុនោះ ក៏ធ្វើកាលកិរិយាទៅ ។ ភិក្ខុអ្នកទម្លាក់នោះមាន សេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិទេ ព្រោះ មិនបានក្លែង ។ សម័យនោះឯង ពួកភិក្ខុនៅប្រទេសអាឡវី ( នាំគ្នា ) ធ្វើ នវកម្ម ។ មានភិក្ខុមួយរូបនៅខាងក្រោម ហុចបង្គន់ទៅខាងលើ ។ ភិក្ខុនៅ ខាងលើមានបំណងចង់សម្លាប់ ( ភិក្ខុនៅខាងក្រោម ) ទើបទម្លាក់បង្គន់មក ចំក្បាលភិក្ខុនៅខាងក្រោម ។ ភិក្ខុនោះធ្វើកាលកិរិយាទៅ ។បេ។ ភិក្ខុនោះ មិនបានធ្វើកាលកិរិយា ។ ភិក្ខុអ្នកទម្លាក់បង្គន់នោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិ ថុល្លច្ច័យ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី ( នាំគ្នា ) ធ្វើនវកម្ម ចងរន្ទា ។ មានភិក្ខុមួយរូបបាននិយាយនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរក្នុងទីនោះ ហើយចងរន្ទាទៅ ។ ភិក្ខុនោះឈរនៅក្នុងទីនោះ ចង រន្ទា ក៏ភ្លាត់ធ្លាក់មកហើយធ្វើកាលកិរិយាទៅ ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្តី សង្ស័យ ។បេ។ ទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹង សម្លាប់ទេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ពួកភិក្ខុនៅដែនអាឡវី កាលនឹងធ្វើនវកម្ម ( បាននាំគ្នា ) ចងរន្ទា ។ មានភិក្ខុមួយរូប មានបំណងនឹងសម្លាប់ ទើប និយាយនឹងភិក្ខុមួយរូបថា ម្នាលអាវុសោ លោកចូរឈរនៅទីនោះចងរន្ទាទៅ ។ ភិក្ខុនោះឈរនៅទីនោះ កំពុងតែចងរន្ទា ក៏ភ្លាត់ធ្លាក់ចុះមក ធ្វើមរណកាលទៅ

។បេ។ ( មានភិក្ខុមួយរូបទៀត ) ភ្លាត់ធ្លាក់ដែរ តែមិនបានធ្វើមរណកាលទេ ។ លោកដែលបន្ទាប់នោះមានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែអាបត្តិថុល្លច្ច័យ ។

[ ២១២ ] សម័យនោះឯង មានភិក្ខុមួយរូបប្រក់វិហារហើយចុះមក ។ មានភិក្ខុមួយរូបទៀតបាននិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរចុះខាងនេះ ។ ភិក្ខុនោះ កាលចុះមកតាមផ្លូវនោះ ក៏ធ្លាក់ធ្វើមរណកាលទៅ ។ ភិក្ខុអ្នកបន្ទាប់នោះ មានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់អ្នកដែលមិនមានបំណងនឹងសម្លាប់ទេ ។ សម័យនោះឯង មានភិក្ខុមួយរូបប្រក់វិហារហើយចុះមក ។ មានភិក្ខុមួយរូបទៀតមានបំណងនឹងសម្លាប់ ទើបនិយាយនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរចុះខាងនេះ។ ភិក្ខុនោះកាលចុះតាមផ្លូវនោះមក ក៏ធ្លាក់ចុះធ្វើមរណកាលទៅ ។បេ។ ( មានភិក្ខុមួយរូបទៀត ) ធ្លាក់ចុះហើយ តែមិនបានធ្វើមរណកាល ។ ភិក្ខុអ្នកបន្ទាប់នោះ មានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២១៣ ] សម័យនោះឯង មានភិក្ខុមួយរូបមានសេចក្ដីអផ្សុកមកបៀតបៀន ឡើងទៅកាន់លើភ្នំគិជ្ឈកូដ ក៏ទម្លាក់ខ្លួនចុះមកក្នុងជ្រោះសង្កត់លើជាងត្បាញផែងម្នាក់ស្លាប់ទៅ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំគប្បី ទម្លាក់សម្លាប់ខ្លួនឯង ភិក្ខុណាទម្លាក់សម្លាប់ខ្លួនឯង ( ភិក្ខុនោះ )

ត្រូវអាបត្តិទុក្កដ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ( នាំគ្នា ) ឡើងទៅកាន់ភ្នំគិជ្ឈកូដហើយប្រមៀលថ្មលេង ។ ថ្មនោះធ្លាក់មកសង្កត់អ្នកគង្វាលគោម្នាក់ស្លាប់ទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុមិនត្រូវប្រមៀលថ្មដើម្បីជាល្បែងលេងទេ ភិក្ខុណាប្រមៀល ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ ។

[ ២១៤ ] សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ទើបភិក្ខុទាំង-ឡាយនាំគ្នាឲ្យភិក្ខុនោះធ្មួង ។ ភិក្ខុនោះធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយ មានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះធ្មួង ។ ភិក្ខុនោះធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបកើតរោគក្តៅក្បាល ។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះនត្ថុថ្នាំ ។ ភិក្ខុនោះធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ( បើ ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូប មានរោគក្តៅក្បាល ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះនត្ថុថ្នាំ ។ ភិក្ខុនោះក៏ធ្វើ

មរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ។ ភិក្ខុទាំងឡាយនាំគ្នាប្រាប់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ( បើ ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយ មានបំណងនឹងសម្លាប់ ទើបនាំគ្នាប្រាប់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះផ្ចូតទឹក ។ ភិក្ខុនោះ ក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ( បើ ) មិនមានបំណងនឹងសម្លាប់ទេ មិនត្រូវអាបត្តិឡើយ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយ មានបំណងនឹងសម្លាប់ ទើបឲ្យភិក្ខុនោះស្រង់ទឹក ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ទើបភិក្ខុទាំងឡាយយកប្រេង

មកលាបភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយ មានបំណងនឹងសម្លាប់ ទើប ( នាំគ្នា ) យកប្រេងមកលាបភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ទើបភិក្ខុទាំងឡាយឲ្យភិក្ខុនោះក្រោកឡើង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ( បើ ) មិនមានបំណងនឹងសម្លាប់ ឥតមានអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបញ៉ាំងភិក្ខុនោះឲ្យស្ទុះក្រោកឡើង ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយចាប់ភិក្ខុនោះផ្តួល ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ( បើ ) មិនមានបំណងនឹងសម្លាប់ ឥតមានអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយ

រូបមានជំងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើប ( នាំគ្នា ) ផ្តល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណ-កាល ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយបានឲ្យបាយដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ( បើ ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ បានឲ្យបាយដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយ បានឲ្យទឹកសម្រាប់ផឹកដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយមានបំណងនឹងសម្លាប់ ទើបឲ្យទឹកសម្រាប់ផឹកដល់ភិក្ខុនោះ ។ ភិក្ខុនោះក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះមិនបានធ្វើមរណកាល ។ ពួកភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

មិនត្រូវអាបត្តិបារាជិកទេ ។ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។

[ ២១៥ ] សម័យនោះឯង មានស្រីម្នាក់ព្រាត់ប្រាសចាកប្តីមកយូរហើយ ទើបមានគភ៌នឹងសហាយ ។ ស្រីនោះបាននិយាយនឹងភិក្ខុជាជីតុន[១] ថា សូមទានមេត្តាចុះលោកម្ចាស់សូមទានប្រាប់ថ្នាំរំលូតគភ៌ (ឲ្យទានខ្ញុំករុណា) ។ ភិក្ខុនោះទទួលថា ស្រួលហើយប្អូនស្រី ហើយក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ទារក ( ដែលនៅក្នុងគភ៌ ) ក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ ( តែ ) ប្រពន្ធម្នាក់នោះជាស្រីអារ ម្នាក់ទៀតជាស្រីមានកូន ។ ស្រីអារនិយាយនឹងភិក្ខុជាជីតុនថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន មុខតែនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមទានមេត្តាចុះលោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌វាចេញ ។ ភិក្ខុទទួលថា ស្រួលហើយប្អូនស្រី ( ថាហើយ ) ក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ទារក ( ដែលនៅក្នុងគភ៌ ) ក៏ធ្វើមរណកាលទៅ ។ ឯម្តាយមិនបានធ្វើមរណកាលទេ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ ប្រពន្ធម្នាក់ជាស្រីអារ ម្នាក់ជាស្រីមានកូន ។ ឯស្រីអារនិយាយនឹងភិក្ខុជាជីតុនថា បពិត្រលោកម្ចាស់ បើស្រីនោះ

---

១ ភិក្ខុអ្នកចូលទៅកាន់ត្រកូល គឺភិក្ខុដែលជិតដិតស្និទ្ធស្នាលនឹងត្រកូល ។

សម្រាលកូន គេនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមទានមេត្តាចុះលោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌វាចេញ ។ ភិក្ខុជាជីតុនទទួលថា ស្រួលហើយប្អូនស្រី ( ថាហើយ ) ក៏បានឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ម្តាយក៏ធ្វើមរណកាលទៅ ។ ឯទារកមិនធ្វើមរណកាលទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានបុរសម្នាក់មានប្រពន្ធពីរ ប្រពន្ធម្នាក់ជាស្រីអារ ម្នាក់ទៀតជាស្រីមានកូន ។ ស្រីអារនិយាយនឹងភិក្ខុជាជីតុនថា បពិត្រលោកម្ចាស់ បើស្រីនោះសម្រាលកូន គេនឹងបានជាធំលើទ្រព្យសម្បត្តិទាំងអស់ សូមទានមេត្តាចុះលោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌វាចេញ ។ ភិក្ខុទទួលថា ស្រួលហើយប្អូនស្រី ( ថាហើយ ) ក៏ឲ្យថ្នាំរំលូតគភ៌ដល់ស្រីនោះ ។ ម្តាយ និងកូនទាំងពីរនាក់ក៏ធ្វើមរណកាលទៅ ។បេ។ ម្តាយ និងកូនទាំងពីរនាក់មិនបានធ្វើមរណកាល ។ ភិក្ខុមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានស្រីម្នាក់មានគភ៌ បាននិយាយនឹងភិក្ខុជាជីតុនថា សូមទានមេត្តាចុះ លោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌ ( ដល់ខ្ញុំ ) ។ ភិក្ខុនោះ ពោលថា នែប្អូនស្រី បើដូច្នោះ នាងចូរច្របាច់ពោះទៅ ។ ស្រីនោះក៏ច្របាច់ពោះរំលូតគភ៌មក ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីម្នាក់មានគភ៌ បាននិយាយនឹងភិក្ខុជាជីតុនថា សូមទាន

មេត្តាចុះលោកម្ចាស់ សូមទានប្រាប់ថ្នាំរំលូតគភ៌ ( ឲ្យទានខ្ញុំព្រះករុណា ) ភិក្ខុនោះប្រាប់ថា នែប្អូនស្រី បើដូច្នោះ នាងចូរកម្តៅផ្ទៃពោះទៅ ។ នាងនោះក៏កម្តៅគភ៌រំលូតកូនមក ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានស្រីអារម្នាក់ បាននិយាយនឹងកុលុបកភិក្ខុ ជា ( ជីតុន ) ថា សូមទានមេត្តាចុះលោកម្ចាស់ ខ្ញុំគប្បីសម្រាលកូនដោយថ្នាំណា ( ស្រួល ) មេត្តាប្រាប់ថ្នាំនោះ ( ដល់ខ្ញុំ ) ។ ភិក្ខុនោះទទួលថា ស្រួលហើយប្អូនស្រី ( ថាហើយ ) ក៏បានឲ្យថ្នាំដល់នាងនោះ ។ នាងនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមានកូន បាននិយាយនឹងភិក្ខុជាជីតុនថា សូមទានមេត្តាចុះលោកម្ចាស់ ខ្ញុំមិនសម្រាលកូនដោយថ្នាំណា សូមលោកម្ចាស់ឲ្យថ្នាំនោះ ( ដល់ខ្ញុំ ) ។ លោកនោះ ទទួលថា ស្រួលហើយប្អូនស្រី ( ថាហើយ ) ក៏បានឲ្យថ្នាំដល់ស្រីនោះ ។ នាងនោះ ក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិទុក្កដ ។

[ ២១៦ ] សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបានចាក់ក្រឡេកភិក្ខុ (មួយរូប) ដែលរាប់បញ្ចូលក្នុងពួកសត្តរសវគ្គិយភិក្ខុ ដោយចុងម្រាមដៃ ។ ភិក្ខុនោះ ( រសើបភ័យខ្លាំង ) តក់ស្លុតផុតដង្ហើមស្លាប់ទៅ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ

មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិបាចិត្តិយ ។

[ ២១៧ ] សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុគិតគ្នាថា យើងនឹងធ្វើកម្ម[1] ( គិតហើយ ) ក៏ចាប់សង្កត់សម្រុញឆព្វគ្គិយភិក្ខុ មួយរូបទាល់តែស្លាប់ទៅ ។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះ មានសេចក្តីសង្ស័យកើតឡើង ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិបាចិត្តិយ ។

[ ២១៨ ] សម័យនោះឯង មានភិក្ខុមួយរូបជាពេទ្យចាប់ខ្មោច បានផ្តាច់បង់ជីវិតយក្ខមួយ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យកើតឡើង ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២១៩ ] សម័យនោះឯង មានភិក្ខុមួយរូប បានបញ្ជូនភិក្ខុមួយរូបទៅកាន់វិហារដែលមានយក្ខកាច ( អាស្រ័យនៅ ) ។ ពួកយក្ខក៏ ( នាំគ្នា ) ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ ឯភិក្ខុដែលជាអ្នកបញ្ជូន ក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ក៏បញ្ជូនភិក្ខុមួយរូបទៅកាន់វិហារដែលមានយក្ខកាច ។ ពួកយក្ខក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។បេ។ ពួកយក្ខមិនបានផ្តាច់បង់ជីវិតភិក្ខុនោះទេ ។ ឯភិក្ខុជាអ្នកបញ្ជូននោះក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ភិក្ខុមួយ

---

[1]- ធ្វើបាបឲ្យលំបាក ។

រូប បញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវលំបាកមានសត្វសាហាវ ។ សត្វសាហាវទាំងឡាយក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ ភិក្ខុអ្នកបញ្ជូនមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងសម្លាប់ បានបញ្ជូនភិក្ខុមួយរូប ទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាលមានសត្វសាហាវ ។ សត្វសាហាវទាំងឡាយក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។បេ។ ពួកសត្វសាហាវមិនបានផ្តាច់ជីវិតភិក្ខុនោះទេ ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូប បានបញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់សង្វែង មានចោរ ( អាស្រ័យនៅ ) ។ ពួកចោរក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ក៏បញ្ជូនភិក្ខុមួយរូបទៅកាន់ផ្លូវឆ្ងាយដាច់សង្វែង ដែលមានចោរ ( អាស្រ័យនៅ ) ។ ពួកចោរក៏ផ្តាច់បង់ជីវិតភិក្ខុនោះទៅ ។បេ។ ពួកចោរមិនបានផ្តាច់បង់ជីវិតភិក្ខុនោះទេ ។ ភិក្ខុអ្នកបញ្ជូននោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២២០ ] សម័យនោះឯង មានភិក្ខុមួយរូប ចំណាំភិក្ខុជាសត្រូវនោះបាន ហើយក៏ទៅផ្តាច់បង់ជីវិតភិក្ខុជាសត្រូវនោះទៅ ។ ចំណាំភិក្ខុជាសត្រូវ

នោះបាន តែទៅផ្តាច់បង់ជីវិតភិក្ខុដទៃវិញ ។ ចូលចិត្តថាជាភិក្ខុដទៃ តែទៅផ្តាច់បង់ជីវិតភិក្ខុជាសត្រូវនោះវិញ ។ សម្គាល់ថាជាភិក្ខុដទៃ ក៏ទៅផ្តាច់បង់ជីវិតភិក្ខុដទៃ ( នោះ ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ២២១ ] សម័យនោះឯង មានភិក្ខុមួយរូបខ្មោចចូល ។ មានភិក្ខុមួយរូបទៀត បានវាយភិក្ខុនោះ ។ ភិក្ខុក៏ធ្វើមរណកាលទៅ ។ ភិក្ខុដែលវាយនោះ ក៏មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបខ្មោចចូលដែរ ។ មានភិក្ខុមួយរូបទៀតមានបំណងនឹងសម្លាប់ បានវាយភិក្ខុនោះ ។ ភិក្ខុនោះ ក៏ធ្វើមរណកាលទៅ ។បេ។ ភិក្ខុនោះ មិនបានធ្វើមរណកាល ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២២២ ] សម័យនោះឯង មានភិក្ខុមួយរូបពោលសគ្គកថា ( ថ្លែងអំពីស្ថានសួគ៌ ) ដល់បុគ្គលដែលបានធ្វើអំពើល្អ ។ បុគ្គលដែលបានស្តាប់នោះ ក៏អត់ដង្ហើមធ្វើមរណកាលទៅ ។ ភិក្ខុអ្នកសម្តែងមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ទើបសម្តែងសគ្គកថា ដល់បុគ្គលដែលបានធ្វើអំពើល្អមកហើយ ។ បុគ្គលនោះក៏អត់ដង្ហើមធ្វើមរណកាលទៅ ។បេ។ បុគ្គលនោះបានអត់ដង្ហើមដែរ តែមិន

បានធ្វើមរណកាលទេ ។ ឯភិក្ខុអ្នកសម្តែងមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង មានភិក្ខុមួយរូបសម្តែងនិរយកថា ( តំណាលអំពីនរក ) នៃសត្វដែលទៅកើតក្នុងនរក ។ ភិក្ខុអ្នកស្តាប់នោះ តក់ស្លុត ហើយធ្វើនូវមរណកាលទៅ ។ ភិក្ខុអ្នកសម្តែងនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានប្រាថ្នានឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង មានភិក្ខុមួយរូបមានប្រាថ្នានឹងសម្លាប់ ទើបពោលនិរយកថានៃសត្វដែលទៅកើតក្នុងនរក ។ បុគ្គលនោះតក់ស្លុតហើយធ្វើមរណកាលទៅ ។បេ។ បុគ្គលនោះតក់ស្លុត តែមិនបានធ្វើមរណកាលឡើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២២៣ ] សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី កាលធ្វើនវកម្ម ទើបនាំគ្នាកាប់ដើមឈើ ។ មានភិក្ខុមួយរូបបាននិយាយនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរទ្រង់ទីនេះកាប់ឈើទៅ ។ ដើមឈើក៏រលំសង្កត់ភិក្ខុនោះដែលកំពុងឈរកាប់ស្លាប់ក្នុងទីនោះទៅ ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនប្រាថ្នានឹងសម្លាប់មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ពួកភិក្ខុនៅស្រុកអាឡវី កាលនឹងធ្វើនវកម្មបាននាំគ្នាកាប់ដើមឈើ ។ មានភិក្ខុមួយរូបមានបំណងនឹងសម្លាប់ ទើបនិយាយនឹងភិក្ខុមួយរូបទៀតថា ម្នាលអាវុសោ លោកចូរឈរត្រង់ទីនេះ

កាប់ឈើទៅ ។ ដើមឈើក៏រលំសង្កត់ភិក្ខុនោះដែលកំពុងឈរកាប់ស្លាប់ក្នុងទីនោះទៅ ។បេ។ ដើមឈើរលំសង្កត់មិនស្លាប់ ។ ភិក្ខុអ្នកបង្គាប់នោះមានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២២៤ ] សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយនាំគ្នាដុតភ្លើងព្រៃ ។ មនុស្ស ( ដែលនៅក្នុងព្រៃ ) ត្រូវភ្លើងឆេះស្លាប់ ( ជាច្រើននាក់ ) ។ ភិក្ខុទាំងនោះ ក៏មានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ មិនត្រូវអាបត្តិទេ ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមានបំណងនឹងសម្លាប់ក៏នាំគ្នាដុតភ្លើងព្រៃ ។ មនុស្សទាំងឡាយត្រូវភ្លើងព្រៃឆេះស្លាប់ ( ជាច្រើននាក់ ) ។បេ។ ពួកមនុស្សត្រូវភ្លើងព្រៃឆេះតែមិនស្លាប់ ។ ពួកភិក្ខុទាំងនោះ ក៏មានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២២៥ ] សម័យនោះឯង មានភិក្ខុមួយរូបដើរទៅកាន់ទីសម្លាប់ចោរ ហើយបាននិយាយនឹងពេជ្ឈឃាតថា ម្នាលអាវុសោ អ្នកកុំធ្វើឲ្យបុរសនេះលំបាកឡើយ អ្នកចូរផ្ដាច់បង់ជីវិតដោយប្រហារត្រឹមតែម្ដងទៅ ។ ពេជ្ឈឃាតទទួលពាក្យថា ស្រួលហើយ លោកម្ចាស់ ( ថាហើយ ) ក៏ផ្ដាច់បង់ជីវិត ( ចោរ ) ដោយប្រហារតែត្រឹមម្ដង ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យ

នោះឯង មានភិក្ខុមួយរូបដើរទៅកាន់ទីសម្លាប់ចោរ ហើយបាននិយាយនឹងពេជ្ឈឃាតថា ម្នាលអាវុសោ អ្នកកុំធ្វើបុរសនេះឲ្យលំបាកឡើយ ចូរអ្នកផ្តាច់បង់ជីវិតដោយប្រហារតែត្រឹមម្តងទៅ ។ ពេជ្ឈឃាតឆ្លើយថា ខ្ញុំព្រះករុណា មិនធ្វើតាមពាក្យលោកទេ ( ថាហើយ ) ក៏ផ្តាច់បង់ជីវិតបុរសនោះទៅ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ២២៦ ] សម័យនោះឯង មានបុរសម្នាក់គេកាត់ដៃកាត់ជើង ( មកនៅ ) ក្នុងផ្ទះត្រកូល មានពួកញាតិមកប្រជុំគ្នាព្យាបាល ។ មានភិក្ខុមួយរូបបាននិយាយនឹងពួកមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចង់ឲ្យបុរសនេះស្លាប់ទេ ។ ពួកមនុស្សឆ្លើយតបថា ករុណា យើងចង់ឲ្យគាត់ស្លាប់ដែរ ។ ភិក្ខុនោះប្រាប់ថា បើដូច្នោះ អ្នកទាំងឡាយចូរឲ្យគាត់ផឹកខ្លាញ់ទឹកដោះគោទៅ ។ ពួកមនុស្សក៏ឲ្យបុរសនោះផឹកខ្លាញ់ទឹកដោះគោ ។ បុរសនោះក៏ធ្វើមរណកាលទៅ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះឯង មានបុរសម្នាក់គេកាត់ដៃកាត់ជើង ( មកនៅ ) ក្នុងផ្ទះត្រកូល ពួកញាតិក៏ប្រជុំគ្នាមកព្យាបាល ។ មានភិក្ខុនី ( មួយរូប ) និយាយនឹងពួកមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចង់ឲ្យបុរសនេះស្លាប់ឬទេ ។ ពួកមនុស្សឆ្លើយថា ករុណា លោកម៉ែម្ចាស់ យើងចង់ឲ្យស្លាប់ដែរ ។ ភិក្ខុនីនោះប្រាប់ថា បើដូច្នោះ អ្នកទាំងឡាយចូរឲ្យគាត់ផឹកថ្នាំត្រាំដោយអំបិលទៅ ។ មនុស្សទាំង

នោះក៏ឲ្យបុរសនោះផឹកថ្នាំត្រាំដោយអំបិលនោះ ។ បុរសនោះធ្វើមរណកាលទៅ ។ ភិក្ខុនីនោះមានសេចក្តីសង្ស័យ ។ លំដាប់នោះឯង ភិក្ខុនីនោះបានប្រាប់ដំណើរនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីក៏តំណាលសេចក្តីនុ៎ះដល់ភិក្ខុទាំង-ឡាយ ។ ពួកភិក្ខុក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីនោះ ត្រូវអាបត្តិបារាជិកហើយ ។

បារាជិកទី ៣ ចប់

# អដ្ឋកថា

# មនុស្សវិគ្គហសិក្ខាបទវណ្ណនា

## រឿង ភិក្ខុច្រើនរូបក្បែរព្រៃមហាវន

*តតិយបារាជិកណា ដែលព្រះពុទ្ធដ៏បរិសុទ្ធ ក្នុងទ្វារទាំង ៣ ទ្រង់ប្រកាសហើយ ឥឡូវនេះ ដល់លំដាប់ការពណ៌នានៃតតិយបារាជិកនោះហើយ ព្រោះហេតុនោះ ពាក្យថា ពាក្យណាដែលនឹងគប្បីដឹងបានងាយ និងពាក្យណា ដែលខ្ញុំបានប្រកាសទុកហើយក្នុងកាលមុន ការពណ៌នាក្នុងតតិយបារាជិកនឹងវៀរពាក្យនោះចេញ ដូច្នេះឯង ។*

*[ ១៧៦ ] ព្រះបាលីឧក្ខេបវចនៈថា* **តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ** *ជាដើម ខ្ញុំនឹងពោលតទៅនេះ ។*

## អធិប្បាយ រឿង ក្រុងវេសាលី

*បទថា* **វេសាលិយំ** *សេចក្ដីថា ជិតនគរមានឈ្មោះយ៉ាងនោះ គឺមានរោហារប្រព្រឹត្តទៅ ដោយអំណាចឥត្ថីលិង្គ ។ ពិតហើយ នគរនោះ ហៅថា* **វេសាលី** *ព្រោះជាក្រុងដែលធំទូលាយ ដោយពង្រីកកំពែង គឺកំពែងដល់ទៅ ៣ ដង ។ សេចក្ដីសង្ខេបក្នុងតតិយបារាជិកនេះ មានប៉ុណ្ណេះ ។ ចំណែកសេចក្ដីពិស្ដារនៃបទថា* **វេសាលី** *នោះ ដែលបុគ្គលប្រាថ្នាអនុបុព្វីកថា គប្បីកាន់យកអំពីវណ្ណនានៃរតនសូត្រ ក្នុងអដ្ឋកថានៃខុទ្ទកបាឋៈ ឈ្មោះបរមត្ថ-*

ដោតិកាចុះ ។ ឯនគរនេះ គប្បីជ្រាបថា ជាក្រុងដែលដល់នូវភាពជាទូលាយ ដោយអាការទាំងពួង ក្នុងកាលព្រះសម្មាសម្ពុទ្ធ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ហើយប៉ុណ្ណោះ ។ ព្រះឧបាលិត្ថេរ កាលសម្ដែងគោចរគ្រាមយ៉ាងនោះហើយ ទើបពោលទីកន្លែងដែលព្រះដ៏មានព្រះភាគប្រថាប់ ទុកថា **មហាវនេ កូដា-គារសាលាយំ** ( ត្រង់កូដាគារសាលា ក្នុងព្រៃមហាវ័ន ) ។

បណ្ដាព្រៃមហាវ័ន និងកូដាគារសាលានោះ ព្រៃធំ មានឱកាសជាទីកំណត់កើតឯង មិនបានដាំ ឈ្មោះថា ព្រៃមហាវ័ន ។ ចំណែកព្រៃមហាវ័នជិតក្រុងកបិលពស្តុ ទាក់ទងនឹងព្រៃហិមពាន្ត មិនមានឱកាសជាទីកំណត់ រហូតទល់មហាសមុទ្រ ។ ព្រៃមហាវ័ននេះ មិនមែនដូច្នោះឡើយ គឺជាព្រៃធំ មានឱកាសជាទីកំណត់ ព្រោះដូច្នោះ ទើបឈ្មោះថា ព្រៃមហាវ័ន ។ ចំណែកកូដាគារសាលា ដែលដល់ព្រមដោយអាការទាំងពួង ដែលសាងឲ្យមានកំពូល មានទ្រង់ទ្រាយស្រដៀងនឹងសត្វហង្ស ធ្វើផ្ទះកំពូលទុកខាងក្នុង នាអារាម ដែលសាងទុកអាស្រ័យព្រៃមហាវ័ន គប្បីជ្រាបថា ជាព្រះគន្ធកុដិសម្រាប់ព្រះមានព្រះភាគ ។

ច្រើនបទថា **អនេកបរិយាយេន អសុភកថំ កថេតិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងកថា ជាទីតាំងនៃការនឿយណាយក្នុងកាយដែលប្រព្រឹត្តទៅដោយអំណាចនៃការសម្លឹងឃើញអាការ ដែលមិនស្អាត ដោយហេតុជាអនេក ។ ទ្រង់សម្ដែងដូចម្ដេច ទ្រង់សម្ដែងថា មាននៅក្នុងកាយនេះ គឺសក់ រោម ។បេ។ មូត្រ ។ ពាក្យទាំងនេះ មានអធិប្បាយដូចម្ដេច មាន

អធិប្បាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ កាលសម្លឹងរកមើលដោយការយល់គ្រប់យ៉ាង ក្នុងកឡេវរ មានប្រមាណមួយព្យាម នឹងមិនឃើញវត្ថុណាមួយ ទោះជាកែវមុក្តា ឬកែវមណី កែវពិទូរ្យ ឬក្រស្នា ខ្លឹមចន្ទន៍ ឬកំញាន កប៌ូរ ឬបណ្តាគ្រឿងក្រអូប មានលម្អិតសម្រាប់អប់ជាដើម ឯណាមួយ តាមដែលជារបស់ស្អាត សូម្បីមានប្រមាណតិចតួច ដោយពិតនោះ នឹងឃើញតែរបស់មិនស្អាត មានប្រការផ្សេងៗ មានសក់ និងរោមជាដើមប៉ុណ្ណោះ ដែលមានក្លិនស្អុយក្រៃលែង គួរខ្ពើមរអើម មានការឃើញមិនជាសិរី ព្រោះហេតុនោះ ទើបមិនគួរធ្វើការពេញចិត្ត ឬសេចក្តីស្រឡាញ់ក្នុងកាយនេះ ដោយពិតនោះ ដែលបានឈ្មោះថា សក់ទាំងឡាយណា ដែលដុះលើក្បាលដ៏ជាអវយវៈឧត្តម ទោះសក់ទាំងនោះ ក៏ជារបស់មិនស្អាតដូចគ្នា មិនស្អាតផង ជាបដិកូលផង ដូច្នេះ ភាពដែលសក់ទាំងនោះជារបស់មិនល្អ មិនស្អាត ជារបស់បដិកូលនោះ គប្បីជ្រាបដោយហេតុ ៥ យ៉ាង គឺដោយពណ៌ខ្លះ ដោយសណ្ឋានខ្លះ ដោយក្លិនខ្លះ ដោយទីអាស្រ័យខ្លះ ដោយឱកាសខ្លះ ការដែលចំណែកទាំងឡាយ មានរោមជាដើម ជារបស់មិនល្អ មិនស្អាត និងជារបស់បដិកូល ក៏គប្បីជ្រាបដោយអាការយ៉ាងនេះឯង ។ ការសង្ខេបក្នុងអធិការនៃតតិយបារាជិកនេះ មានប្រមាណប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គឯណោះចុះ ។ ព្រះមានព្រះភាគត្រាស់អសុភកថា ក្នុងកោដ្ឋាសនីមួយៗ ដោយអនេកបរិយាយ មានប្រភេទនៃកោដ្ឋាសនីមួយៗ ៥ ដោយ

ប្រការដូច្នេះ ។

បទថា **អសុភាយ វណ្ណំ ភាសតិ** សេចក្តីថា ព្រះដ៏មានព្រះភាគទ្រង់តាំងអសុភមាតិកា ដោយអំណាចឧទ្ធុមាតកអសុភជាដើមហើយ កាលទ្រង់ចែក គឺទ្រង់ពណ៌នារៀបរាប់អសុភមាតិកានោះ ដោយបទភាជនីយ៍ ទើបត្រាស់គុណានិសង្សនៃអសុភ ។

បទថា **អសុភភាវនាយ វណ្ណំ ភាសតិ** សេចក្តីថា ការអប់រំ គឺការនាការចម្រើនចិត្ត ដែលកាន់យកអាការដែលមិនស្អាត ក្នុងកោដ្ឋាសទាំងឡាយ មានសក់ជាដើម ឬក្នុងអសុភ មានឧទ្ធុមាតកអសុភជាដើម ឬក្នុងវត្ថុខាងក្នុង និងខាងក្រៅទាំងឡាយប្រព្រឹត្តទៅយ៉ាងនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងអានិសង្សនៃអសុភភាវនានោះ ទើបត្រាស់សរសើរ គឺទ្រង់ប្រកាសគុណ ។ ទ្រង់ត្រាស់ដូចម្តេច ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយចំពោះនូវអសុភភាវនាក្នុងវត្ថុ មានសក់ជាដើមក្តី ក្នុងវត្ថុ មានឧទ្ធុមាតកអសុភជាដើមក្តី រមែងបានចំពោះនូវបឋមជ្ឈាន ដែលលះអង្គ ៥ ប្រកបដោយអង្គ ៥ មានលម្អ ៣ យ៉ាង និងដល់ព្រមដោយលក្ខណៈ ១០ ភិក្ខុនោះអាស្រ័យប្រអប់ ពោល គឺបឋមជ្ឈាននោះ ចម្រើនវិបស្សនា រមែងសម្រេចអរហត្ត ដែលជាប្រយោជន៍ឧត្តម ។

## បឋមជ្ឈានមានលក្ខណៈ ១០ និងលម្អ ៣

បណ្តាលម្អ ៣ និងលក្ខណៈ ១០ នោះ លក្ខណៈ ១០ នៃបឋមជ្ឈាននេះ គឺការបរិសុទ្ធនៃចិត្ត អំពីធម៌ដែលជាអន្តរាយ ១ ការបដិបត្តិសមាធិនិមិត្ត

ដែលជាកណ្តាល ១ ការស្ទុះទៅនៃចិត្តក្នុងសមាធិនិមិត្តនោះ ១ ការព្រងើយនៃចិត្តដែលបរិសុទ្ធ ១ ការព្រងើយនៃចិត្តដែលដំណើរដល់ការស្ងប់ ១ ការព្រងើយនៃចិត្តដែលប្រាកដដោយអារម្មណ៍តែមួយ ១ ការផូរផង់ដោយអត្ថ គឺការមិនប្រែប្រួលនៃធម៌ទាំងឡាយ ដែលកើតក្នុងឈានចិត្តនោះ ១ ការផូរផង់ដោយអត្ថ គឺភាពដែលឥន្ទ្រិយទាំងឡាយ មានរសតែមួយ ១ ការផូរផង់ដោយអត្ថ គឺការប្រព្រឹត្តទៅនៃសេចក្តីព្យាយាម ដែលសមគួរដល់សមាធិបញ្ញា និងឥន្ទ្រិយ ដែលជាធម៌មិនប្រែប្រួល និងមានរសតែមួយនោះ ១ ការផូរផង់ដោយអត្ថ គឺការស្ទុះស្ទាល ១ ។

បាលីក្នុងវិស័យ ជាទីបើកផ្សារលក្ខណៈ ១០ នោះ ដូច្នេះថា គឺអ្វីជាខាងដើម អ្វីជាកណ្តាល អ្វីជាខាងចុងនៃបឋមជ្ឈាន ការបរិសុទ្ធនៃបដិបទាជាខាងដើម ការចម្រើនឡើងនៃឧបេក្ខាជាកណ្តាល ការផូរផង់ជាខាងចុងនៃបឋមជ្ឈាន ។

ការបរិសុទ្ធនៃបដិបទា ជាខាងដើមនៃបឋមជ្ឈាន លម្អខាងដើមមានលក្ខណៈប៉ុន្មាន មានលក្ខណៈ ៣ ធម៌ណាដែលជាអន្តរាយរបស់ចិត្តនោះ ចិត្តរមែងបរិសុទ្ធចាកធម៌នោះ ចិត្តរមែងឈានចុះកាន់សមាធិនិមិត្ត ដែលជាកណ្តាល ព្រោះសភាពជាធម្មជាតបរិសុទ្ធ ចិត្តស្ទុះទៅក្នុងសមាធិនិមិត្ត ( ដែលជាគោចរនៃអប្បនា ) នោះ ព្រោះភាពជាធម្មជាតឈានទៅហើយ ។ ចិត្តបរិសុទ្ធចាកធម៌ដែលជាអន្តរាយ ១ ចិត្តឈានចុះកាន់សមាធិនិមិត្តដែលជាកណ្តាល ព្រោះសភាពជាធម្មជាតបរិសុទ្ធ ១ ចិត្តស្ទុះទៅក្នុងសមាធិនិមិត្ត

នោះ ព្រោះជាធម្មជាតឈានទៅ ១ ជាបដិបទាវិសុទ្ធិដែលជាខាងដើមនៃបឋមជ្ឈាន លម្អខាងដើមមានលក្ខណៈទាំង ៣ នេះ ។ ព្រោះហេតុនោះ ទើបបឋមជ្ឈាន លោកពោលថា ជាធម្មជាតស្អាតខាងដើម និងដល់ព្រមដោយលក្ខណៈ ៣ ។

ការចម្រើនឡើងនៃឧបេក្ខា ជាលម្អត្រង់កណ្តាលនៃបឋមជ្ឈាន មានលក្ខណៈប៉ុន្មាន លម្អត្រង់កណ្តាលមានលក្ខណៈ ៣ ។ ចិត្តបរិសុទ្ធ រមែងព្រងើយ ចិត្តឈានដល់ការស្ងប់ រមែងព្រងើយ ចិត្តប្រាកដដោយអារម្មណ៍តែមួយ រមែងព្រងើយកន្តើយ ។ ចិត្តបរិសុទ្ធព្រងើយកន្តើយ ១ ចិត្តឈានដល់ការស្ងប់ព្រងើយកន្តើយ ១ ចិត្តប្រាកដដោយអារម្មណ៍តែមួយព្រងើយកន្តើយ ១ ជាការចម្រើនឡើងនៃឧបេក្ខា ដែលជាកណ្តាលនៃបឋមជ្ឈាន លម្អត្រង់កណ្តាលមានលក្ខណៈទាំង ៣ នេះឯង ។ ព្រោះហេតុនោះ ទើបបឋមជ្ឈាន លោកពោលថា ជាគុណជាតិស្អាតក្នុងកណ្តាល និងដល់ព្រមដោយលក្ខណៈ ៣ ។

ការផូរផង់ ជាលម្អខាងចុងនៃបឋមជ្ឈាន មានលក្ខណៈប៉ុន្មាន លម្អខាងចុងមានលក្ខណៈ ៤ ។ សេចក្តីផូរផង់ដោយអត្ថ គឺការមិនរំលងត្រឡប់នៃធម៌ទាំងឡាយ ដែលកើតក្នុងឈានចិត្តនោះ ១ សេចក្តីផូរផង់ដោយអត្ថ គឺឥន្ទ្រិយទាំងឡាយមានរសតែមួយ ១ សេចក្តីផូរផង់ដោយអត្ថ គឺការប្រព្រឹត្តទៅនៃសេចក្តីព្យាយាម ដែលសមគួរដល់សមាធិ បញ្ញា និងឥន្ទ្រិយ ដែលជាធម៌មិនរំលងត្រឡប់ និងមានរសតែមួយ ១ សេចក្តីផូរផង់ដោយអត្ថ គឺការ

ស្និទ្ធស្នាល ១ ។ សេចក្តីផូរផង់ជាលម្អខាងចុងនៃបឋមជ្ឈានមានលក្ខណៈ ៤ ដូច្នេះ ។ ព្រោះហេតុនោះ ទើបបឋមជ្ឈានលោកហៅថា ជាគុណជាតិស្អាតខាងចុង និងដល់ព្រមដោយលក្ខណៈ ៤ ។ ចិត្តដែលដល់នូវភាពជាធម្មជាត ៣ យ៉ាង មានលម្អ ៣ យ៉ាង ដល់ព្រមដោយលក្ខណៈ ១០ រមែងជាចិត្តដល់ព្រមដោយវិតក្កៈ ដល់ព្រមដោយវិចារៈ បីតិ និងសុខ ដល់ព្រមដោយការតាំងមាំនៃចិត្តដល់ព្រមដោយសទ្ធា និងជាចិត្តដែលដល់ព្រមដោយវិរិយៈ សតិ សមាធិ និងបញ្ញា ដោយប្រការដូច្នេះ ។

បទថា **អានិសំ្ស អានិសំ្ស អសុភសមាបត្តិយា វណ្ណំ ភាសតិ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សរសើរ គឺត្រាស់អានិសង្ស ទ្រង់ប្រកាសគុណនៃអសុភសមាបត្តិ ព្រោះទ្រង់ធ្វើការកំណត់អាងដល់រឿយៗ ថា យ៉ាងនោះខ្លះ យ៉ាងនេះខ្លះ ។ ត្រាស់ដូចម្តេច ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំង-ឡាយ កាលភិក្ខុមានចិត្តអប់រំដោយអសុភសញ្ញារឿយៗ ចិត្តរមែងរាថយ រួញចូល វិលត្រឡប់ចាកការគិតចូលទៅជិតដោយមេថុនធម្ម គឺមិនរវើរវាយ រមែងតាំងនៅដោយឧបេក្ខា ឬដោយភាពជារបស់បដិកូល ម្នាលភិក្ខុទាំង-ឡាយ ប្រៀបដូចស្លាបមាន់ក្តី ចម្រៀកសរសៃក្តី ដែលបុគ្គលដាក់ចូលទៅក្នុងភ្លើង រមែងរាថយ រួញចូល រមួរចូល គឺ មិនលាចេញ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុមានចិត្តអប់រំដោយអសុភសញ្ញារឿយៗ ចិត្តរមែងរាថយ រួញចូល វិលត្រឡប់អំពីការចូលទៅកៀកកិតដោយមេថុនធម្ម គឺមិនរាយមាយ ទៅដូច្នោះដូចគ្នា ។

បទថា **ឥច្ឆាមហំ ភិក្ខវេ អឌ្ឍមាសំ បដិសល្លិយិតុំ** សេចក្ដីថា ម្នាល ភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងចៀសចេញ គឺសម្ងំនៅម្នាក់ឯងអស់កាលកន្លះខែ ។

បទថា **នម្ហិ កោនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាត-នីហារកេន** សេចក្ដីថា ភិក្ខុណា មិនធ្វើបយុត្តវាចា ( វាចាដែលទាក់ទងដោយបច្ច័យ ) ដោយខ្លួន នាំបិណ្ឌបាតដែលគេរៀបចំដើម្បីប្រយោជន៍ដល់តថាគត ក្នុងត្រកូលមានសទ្ធា បង្អោនចូលមកដល់តថាគត វៀរលែងតែភិក្ខុដែលនាំបិណ្ឌបាតចូលទៅឲ្យមួយរូបប៉ុណ្ណោះ បុគ្គលដទៃណាមួយ ជាភិក្ខុក្ដីគ្រហស្ថក្ដី កុំចូលទៅរកតថាគតឡើយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ឆ្លើយថា បានឮថា ក្នុងអតីតកាលដ៏យូរលង់ណាស់មកហើយ មាននាយព្រានម្រឹគប្រមាណ ៥០០ នាក់ យកកំណាត់ឈើ និងសំណាញ់ដែលជាគ្រឿងចាប់សត្វដ៏ច្រើនព័ទ្ធព្រៃ នាំគ្នាសើចសប្បាយ រួមជាពួកជាមួយគ្នានោះឯង សម្រេចការចិញ្ចឹមជីវិតដោយកម្ម គឺការសម្លាប់ម្រឹគ និងបក្សី រហូតអស់ជីវិត ហើយកើតក្នុងនរក ។ ព្រានម្រឹគទាំងនោះ ឆេះក្នុងនរកនោះហើយ កើតក្នុងពួកមនុស្ស ព្រោះកុសលកម្មឯណាមួយ ដែលខ្លួនធ្វើទុកហើយ ក្នុងកាលខាងដើមនោះឯង ទើបបានបព្វជ្ជា និងឧបសម្បទាក្នុងសម្នាក់របស់ព្រះមានព្រះភាគទាំងអស់ ដោយអំណាចឧបនិស្ស័យនៃសុចរិតកម្ម ។ អបរាបរចេតនារបស់ព្រានម្រឹគទាំងនេះ ក៏នៅមិនទាន់បានឲ្យផល ព្រោះអកុសលកម្ម ដែល

ជាមូលនោះ បានធ្វើឱកាសដើម្បីចូលទៅកាត់ផ្តាច់ជីវិត ដោយការព្យាយាមរបស់ខ្លួនឯង និងដោយព្យាយាមរបស់បុគ្គលដទៃ ក្នុងកាលខាងក្នុងកន្លះខែនោះ ព្រះមានព្រះភាគ ទ្រង់ទតឃើញការដាច់ទៅនៃជីវិតនោះហើយ ។ ដែលឈ្មោះថា វិបាកកម្ម បុគ្គលណាមួយ ក៏មិនអាចនឹងឃាត់បានដែរ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុជាបុថុជ្ជនក៏មាន ជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រពក៏មាន ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុទាំងឡាយដែលជាព្រះខីណាស្រព មិនមានបដិសន្ធិ អរិយសាវកទាំងឡាយក្រៅអំពីនេះ ជាបុគ្គលមានគតិទៀង គឺមានសុគតិជាទីទៅក្នុងខាងមុខ គតិរបស់ពួកភិក្ខុដែលនៅជាបុថុជ្ជន មិនពិតប្រាកដ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះខ្លាចចំពោះមរណភ័យ ព្រោះការស្រឡាញ់ ដោយអំណាចការពេញចិត្តក្នុងអត្តភាព និងមិនអាចជម្រះគតិឲ្យបរិសុទ្ធបាន ណ្ហើយចុះ តថាគតនឹងសម្តែងអសុភកថា ដើម្បីលះសេចក្តីសេចក្តីស្រឡាញ់ ដោយអំណាចការពេញចិត្តដល់ភិក្ខុទាំងនោះៗ កាលបានស្តាប់អសុភកថានោះហើយនឹងធ្វើការជម្រះគតិឲ្យបរិសុទ្ធបាន ព្រោះជាបុគ្គលប្រាសចាកការជាប់ជំពាក់ដោយអំណាចការពេញចិត្តក្នុងអត្តភាពហើយ នឹងកាន់យកបដិសន្ធិក្នុងស្ថានសួគ៌ បព្វជ្ជាក្នុងសម្នាក់របស់តថាគត នឹងជាគុណជាតិមានប្រយោជន៍ ដល់ភិក្ខុទាំងនោះដោយអាការយ៉ាងនេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងអសុភកថា ដោយមាតិកាកម្មដ្ឋាន ដើម្បីអនុគ្រោះដល់ភិក្ខុទាំងនោះ មិនមែនសម្តែងដោយបំណងក្នុងការពណ៌នាដល់គុណនៃសេចក្តីស្លាប់

ឡើយ ។ កាលទ្រង់សម្តែងហើយ ព្រះដ៏មានព្រះភាគ មានព្រះតម្រិះយ៉ាងនេះថា បើភិក្ខុទាំងឡាយ ឃើញតថាគតក្នុងកន្ទះខែនេះសោត ភិក្ខុទាំងនោះនឹងមកប្រាប់តថាគតថា ថ្ងៃនេះ ភិក្ខុស្លាប់មួយអង្គ ថ្ងៃនេះ ស្លាប់ពីររូប ។បេ។ ថ្ងៃនេះស្លាប់ ១០ រូប ដូច្នេះ ឯវិបាកកម្មនេះ បុគ្គលដទៃណាមួយ ឬតថាគតក៏មិនអាចឃាត់បាន តថាគតឯង ទោះបីបានស្តាប់ពាក្យនោះហើយ នឹងធ្វើអ្វីកើត នឹងមានប្រយោជន៍អ្វីដល់តថាគត ដោយការស្តាប់ពាក្យដែលឥតប្រយោជន៍ មានតែការវិនាសមិនជាប្រយោជន៍ ណ្ហើយចុះ តថាគតនឹងចូលទៅកាន់ទីដែលភិក្ខុទាំងឡាយមិនឃើញ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងពួនសម្ងំនៅរហូតកន្ទះខែ បុគ្គលណាមួយ កុំចូលទៅរកតថាគតឡើយ វៀរតែភិក្ខុអ្នកនាំបិណ្ឌបាត ចូលទៅមួយរូបប៉ុណ្ណោះ ។

ចំណែកអាចារ្យដទៃខ្លះពោលថា ព្រះពុទ្ធទាំងឡាយ ត្រាស់យ៉ាងនោះហើយ ទើបបានចៀសទៅពួនសម្ងំដើម្បីវៀរនូវពាក្យតិះដៀលរបស់អ្នកដទៃ សេចក្តីថា ពួកជនដទៃនឹងពោលនិន្ទាព្រះមានព្រះភាគថា ព្រះមានព្រះភាគអង្គនេះ ជាសព្វញ្ញូ ទ្រង់បានទាំងប្តេជ្ញាថា តថាគតជាអ្នកញ៉ាំងចក្រ គឺព្រះសទ្ធម្មដ៏បវរឲ្យវិលទៅ ទ្រង់មិនអាចនឹងហាមសាវកទាំងឡាយរបស់ព្រះអង្គដែលពឹងគ្នានិងគ្នា ឲ្យសម្លាប់គ្នា តើនឹងហាមបុគ្គលដទៃឯណាបាន ក្នុងការដែលអ្នកដទៃពោលតិះដៀលនោះ បណ្ឌិតទាំងឡាយនឹងពោលដោះស្រាយថា ព្រះមានព្រះភាគ ទ្រង់ប្រកបការពួនសម្ងំ មិនមែនទ្រង់ជ្រាបការប្រព្រឹត្តទៅ

នេះឡើយ សូម្បីបុគ្គលដែលទូលប្រាប់ព្រះអង្គពួកខ្លះក៏មិនមាន បើទ្រង់គប្បីជ្រាបសោត ទ្រង់នឹងហាមដោយពិត ។ តែទ្រង់មានសេចក្តីប្រាថ្នាជាបឋមនោះឯង រមែងជាហេតុក្នុងពាក្យនេះបាន ។

សព្ទថា **អស្សុធ** ក្នុងពាក្យថា **ឆាស្សុធ** នេះ ជានិបាត ចុះក្នុងអត្ថគ្រាន់តែធ្វើបទឲ្យពេញ ឬក្នុងអត្ថ គឺការឃាត់ថា បុគ្គលណាមួយ កុំចូលទៅគាល់ព្រះមានព្រះភាគឡើយ ។

អសុភកាវនានុយោគនោះ មានពិធីការធ្វើផ្សេងៗ ដោយហេតុទាំងឡាយមានពណ៌ និងសណ្ឋានជាដើមសន្ទឹកសន្ធាប់ ព្រោះហេតុនោះ ទើបឈ្មោះថា **អនេកាការវោការ** ( មានវិធីធ្វើផ្សេងៗ ជាច្រើន ) ។ មានពាក្យអធិប្បាយថា ប្រឃុកប្រឃល់លាយឡំគ្នាដោយអាការជាច្រើន គឺលាយឡំគ្នាដោយហេតុច្រើនយ៉ាង ។ អនេកាការវោការនោះ បានដល់អ្វី បានដល់ អសុភកាវនានុយោគ ។ ដែលតាមក្របរៀយៗ ក្នុងការចម្រើនអសុភកម្មដ្ឋាន មានវិធីការផ្សេងៗ ជាច្រើន ។

ពីរបទថា **អនុយុត្តា វិហរន្តិ** សេចក្តីថា ភិក្ខុទាំងនោះប្រកប គឺព្យាយាម ។ បទថា **អដ្ដិយន្តិ** សេចក្តីថា រមែងជាបុគ្គលដល់នូវសេចក្តីទុក្ខ គឺមានសេចក្តីលំបាកដោយកាយនោះ ។

បទថា **ហរាយន្តិ** ប្រែថា រមែងនឿយណាយ ។

បទថា **ជិគុច្ឆន្តិ** ប្រែថា ជាអ្នកកើតការខ្ពើមរអើមឡើងឯង ។

បទថា **ឧហាកោ** ប្រែថា កំលោះក្រមុំ ។

បទថា **យុវា** ប្រែថា បុគ្គលប្រកបដោយភាពជាកំលោះ ។

បទថា **មណ្ឌនកជាតិយោ** ប្រែថា ជាអ្នកចូលចិត្តតែងខ្លួនជាប្រក្រតី ។

ពីរបទថា **សីសំ ន្ហាតោ** ប្រែថា ងូតទឹក ព្រមទាំងកក់ក្បាល ។

ក្នុងពីរពាក្យថា **ទហរោ យុវា** នេះ ព្រះឧបាលិត្ថេរសម្តែងភាពជាបុគ្គលដំបូង ដែលជាកំលោះក្រមុំ ដោយពាក្យថា **ទហរ** ។ ពិតហើយ សត្វទាំងឡាយក្នុងបឋមវ័យ ជាក្រមុំ កំលោះ រមែងមានប្រក្រតី ជាអ្នកចូលចិត្តតែងខ្លួនដោយពិសេស ។ ព្រះឧបាលិត្ថេរសម្តែងដល់វេលាដែលខ្វល់ខ្វាយក្នុងការតែងខ្លួន ដោយពាក្យទាំងពីរថា **សីសំ ន្ហាតោ** នេះ ។ ពិតហើយ ទោះបីកំលោះក្រមុំធ្វើការឯណាមួយ ហើយមានរាងកាយសៅហ្មង ក៏មិនមែនជាអ្នកមិនខ្វល់ខ្វាយ ក្នុងការតែងខ្លួនឡើយ ។ កំលោះក្រមុំទាំងនោះ ងូតទឹកកក់សក់ស្រេចហើយ ទើបតាមប្រកបក្នុងការតែងខ្លួននោះឯង រមែងមិនប្រាថ្នានឹងឃើញរបស់ស្មោកគ្រោក មានសាកសពពស់ជាដើម ។

ខណៈនោះ កំលោះក្រមុំនោះ គប្បីជាទុក្ខចង្អៀតចង្អល់ ខ្ពើមឆ្អើមដោយសាកសពពស់ សាកសពឆ្កែ ឬសាកសពមនុស្ស ដែលពាក់ទុកត្រង់ក គឺមានបុគ្គលដែលជាសត្រូវឯណាមួយនោះឯង នាំមកចង គឺ ចងទុកត្រង់កយ៉ាងណា ភិក្ខុទាំងនោះ ក៏ជាទុក្ខចង្អៀតចង្អល់ ខ្ពើមឆ្អើមដោយរាងកាយរបស់ខ្លួន យ៉ាងនោះដូចគ្នា ជាអ្នកប្រាថ្នានឹងលះរាងកាយរបស់ខ្លួនចោល ព្រោះជាអ្នកប្រាសចាកការជាប់ជំពាក់ ដោយអំណាចការពេញចិត្ត ដូចបុរសនោះ ដែលប្រាថ្នានឹងលះបង់សាកសពនោះ ដូច្នោះ ទើបកាន់យកសស្ត្រា ហើយ

ផ្តាច់ជីវិតខ្លួនឯងខ្លះ ពីងគ្នានិងគ្នាឲ្យផ្តាច់ជីវិតខ្លះ ដោយពោលយ៉ាងនេះថា ចូរលោកសម្លាប់ខ្ញុំឲ្យដាច់ជីវិត ខ្ញុំនឹងផ្តាច់លោកឲ្យដាច់ជីវិត ។

ពាក្យថា **មិគលណ្ឌិក** ក្នុងពីរបទថា **មិគលណ្ឌិកម្បិ សមណកុត្តកំ** នេះ ជាឈ្មោះរបស់បុគ្គលនោះ ។

បទថា **សមណកុត្តកោ** បានដល់ ដែលមានភេទដូចជាសមណៈ ។ បានឮថា មិគលណ្ឌិកនោះកោរក្បាល ទុកត្រង់បង្កើយបន្តិច ស្លៀកសំពត់កាសាវៈមួយផ្ទាំង មួយផ្ទាំងទៀត ពាក់ត្រង់ចង្កេះស្មា ចូលអាស្រ័យវិហារនោះឯង រស់នៅដោយភាពជាអ្នកស៊ីដែល ។ ភិក្ខុទាំងឡាយ ចូលទៅរកមិគលណ្ឌិកដែលទ្រទ្រង់ភេទសមណៈនោះ ហើយពោលយ៉ាងនោះ ។

សព្ទថា **សាធុ** ជានិបាត ចុះក្នុងអត្ថសំណូមពរ ។ **នោ** ជាទុតិយាវិភត្តិពហុវចនៈ ។ មានពាក្យអធិប្បាយថា សាធុ បា ចូរអ្នកជួយផ្តាច់ជីវិតពួកខ្ញុំចុះ បណ្តាភិក្ខុទាំងនោះ ភិក្ខុដែលជាអរិយៈ មិនធ្វើបាណាតិបាត មិនបបួលបុគ្គលដទៃផង មិនអនុញ្ញាតផង ។ ចំណែកភិក្ខុដែលជាបុថុជ្ជន ធ្វើបានគ្រប់យ៉ាង ។

បទថា **លោហិតកំ** ប្រែថា ប្រឡាក់ឈាម ។ ស្ទឹងដែលគេសន្មតគ្នាថា ជាបុណ្យរបស់សត្វលោក ហៅថា **វគ្គុ** ក្នុងពាក្យថា **យេន វគ្គុមុទា** នេះ ។ បានឮថា មិគលណ្ឌិកនោះទៅកាន់ស្ទឹងនោះ ដោយសម្គាល់ថា នឹងបន្សាត់ គឺលាងបាបក្នុងស្ទឹងនោះ ។

ពីរបទថា **អហុទេវ កុក្កុច្ចំ** សេចក្តីថា បានឮថា បណ្តាភិក្ខុទាំងនោះ

ភិក្ខុអង្គុយឆ្ងាយៗ មិនបានធ្វើកាយវិការ ឬវចីវិការ គ្រប់អង្គទាំងអស់ មានសតិដឹងខ្លួន ដេកផ្អៀងខាងស្តាំ ។ កាលមិគលណ្ឌិកនោះតាមរឭកដល់ការមិនធ្វើកាយវិការ និងវចីវិការនោះ មានការក្តៅក្រហាយចិត្តហើយនោះឯង ។ បាបទោះបីមានប្រមាណតិច ឈ្មោះថា បុគ្គលលះបានហើយ ដោយអានុភាពនៃស៊ីន រមែងមិនមាន ។

ពាក្យថា **អហុ វិប្បដិសារោ** នោះ លោកពោលទុកដើម្បីកំណត់ការក្តៅក្រហាយចិត្តនោះឯង ។ មានសេចក្តីក្តៅក្រហាយ ព្រោះវិប្បដិសារៈ មិនមែនក្តៅក្រហាយតាមផ្លូវព្រះវិន័យឡើយ ។

លោកពោលពាក្យថា **អលាភា វត មេ** ជាដើម ដើម្បីសម្តែងអាការគឺការប្រព្រឹត្តទៅនៃសេចក្តីក្តៅក្រហាយ ។

បណ្តាបទទាំងនោះ ពាក្យថា **អលាភា វត មេ** សេចក្តីថា មិគលណ្ឌិកនោះ រាវែកចិត្តថា ឥឡូវនេះ ឈ្មោះថា លាភ គឺប្រយោជន៍ និងសេចក្តីសុខរបស់អញ រមែងមិនមានតទៅ ។ ឯមិគលណ្ឌិកបញ្ជាក់សេចក្តីនោះឯងឲ្យធ្ងន់ ដោយពាក្យថា លាភរបស់អញមិនមានហ្ន៎នេះ ។ ពិតហើយ ក្នុងពាក្យថា **ន វត មេ លាភា** នេះ មានអធិប្បាយដូច្នេះថា បើមានបុគ្គលណាមួយគប្បីពោលថា ជាលាភរបស់លោក ពាក្យនោះខុស លាភរបស់អញរមែងមិនមានឡើយ ។

បទថា **ទុល្លទ្ធំ វត មេ** សេចក្តីថា ភាពជាមនុស្សនេះ ដែលអញបានហើយ ដោយកុសលានុភាព ឈ្មោះថា អញបានមិនល្អហ្ន៎ ។ មិគលណ្ឌិក

នោះរមែងសន្ធត់ជូនក្នុងអត្ថនោះឯង ដោយពាក្យនេះថា អញបានមិនល្អហ្ន៎ ។ ពិតហើយ ក្នុងពាក្យថា **ន វត មេ សុលទ្ធំ** នេះ មានអធិប្បាយដូច្នេះថា បើបុគ្គលណាមួយគប្បីពោលថា លោកបានល្អហើយ ពាក្យនោះខុស អញមិនបានល្អហ្ន៎ ។

ពីរបទថា **អបុញ្ញំ បសុតំ** សេចក្ដីថា របស់ដែលមិនមែនបុណ្យ អញសន្សំ គឺធ្វើឲ្យកើតឡើងហើយ ។ បើមានអ្នកសួរថា ព្រោះហេតុអ្វី គប្បីឆ្លើយថា ព្រោះអញបានសម្លាប់ភិក្ខុទាំងឡាយដែលជាអ្នកមានសីល មានកល្យាណធម៌ឲ្យដាច់ចាកជីវិត ។ ពាក្យនោះ មានអធិប្បាយថា ព្រោះអញបានផ្ដាច់ភិក្ខុទាំងឡាយដែលជាអ្នកមានសីល មានកល្យាណធម៌ គឺជាអ្នកមានឧត្តមធម៌ មានធម៌ដ៏ប្រសើរ ព្រោះភាពជាអ្នកមានសីលនោះឯងឲ្យដាច់ជីវិត ។

ពីរបទថា **អញ្ញតរា មារកាយិកា** សេចក្ដីថា កូនទេវតាមួយអង្គមិនប្រាកដឈ្មោះ ជាបក្ខពួកនៃមារ ប្រព្រឹត្តតាមមារ គិតថា មិគលណ្ឌិកនេះនឹងមិនក្លាហាន កន្លងអន្ទាក់របស់មារ គឺ វិស័យរបស់មារទៅបាន ដោយឧបាយយ៉ាងនេះ ដូច្នេះហើយ ទើបតាក់តែងកាយ ដោយគ្រឿងអាភរណៈទាំងពួង កាលនឹងសម្ដែងអានុភាពរបស់ខ្លួន ទើបដើរលើទឹកមក ដោយមិនឲ្យទឹកបែក ដូចដើរទៅមកលើផែនដី ដូច្នោះ បានពោលពាក្យនោះ នឹងមិគលណ្ឌិកសមណកុត្តកៈ ។

សព្ទថា **សាធុ សាធុ** ជានិបាតចុះក្នុងអត្ថ គឺការត្រេកអរ ព្រោះហេតុនោះ ក្នុងព្រះបាលីនេះ ទើបពោលត្រួតពីរដងយ៉ាងនេះឯង ។

ពីរបទថា **អតិណ្ណេ តារេសិ** សេចក្តីថា លោកជួយចម្លងពួកភិក្ខុដែលឆ្លងមិនទាន់ផុតឲ្យផុត គឺជួយដោះឲ្យផុតចាកសង្សារ ដោយការផ្តាច់បង់អំពីជីវិត ។ បានឮថា ទេវតាដែលមានបញ្ញាថោកថយនោះ មានលទ្ធិ គឺទិដ្ឋិដូច្នេះថា បុគ្គលទាំងឡាយដែលមិនទាន់ស្លាប់ ឈ្មោះថា មិនទាន់ផុតចាកសង្សារ អ្នកដែលស្លាប់ហើយ ទើបផុត ព្រោះហេតុនោះ ទេវតាដែលមានលទ្ធិយ៉ាងនោះ ក៏ដូចជាមនុស្សព្រៃ ( គឺស្រែកឲ្យតែឮដូចសំឡេងសត្វ ) ដែលនឹងដោះខ្លួនចាកសង្សារ ដូច្នោះ បានប្រកប គឺដឹកនាំមិគលណ្ឌិកនោះក្នុងការឲ្យជួយដាក់ គឺផ្តាច់ជីវិតនោះ ទើបពោលយ៉ាងនោះ ។

គ្រានោះឯង មិគលណ្ឌិកសមណកុត្តកៈ សូម្បីជាបុគ្គលមានការក្តៅក្រហាយកើតឡើងយ៉ាងខ្លាំងក្លាដរាបនោះក៏ដោយ កាលឃើញអានុភាពរបស់ទេវតានោះ ក៏ដល់នូវការជឿជាក់ថា ទេវតានេះ បានពោលយ៉ាងនេះ ប្រ-យោជន៍គប្បីយ៉ាងនេះឯងដោយពិត ហើយពោលពាក្យជាដើមថា នេះជាលាភរបស់អញ ទើបចេញអំពីវិហារចូលទៅកាន់វិហារ ចេញពីបរិវេណចូលទៅកាន់បរិវេណ ហើយពោលយ៉ាងនេះ គឺចូលទៅកាន់វិហារ និងបរិវេណនោះ ហើយបើកទ្វារចូលទៅខាងក្នុង ពោលនឹងភិក្ខុទាំងឡាយយ៉ាងនេះថា លោកម្ចាស់អង្គណា មិនទាន់ឆ្លងផុត ខ្ញុំនឹងជួយចម្លង ។

ពីរបទថា **ហោតិយេវ ភយំ** សេចក្តីថា មានចិត្តតក់ស្លុត ព្រោះអាស្រ័យសេចក្តីស្លាប់ ។

បទថា **ឆម្ភិតត្តំ** សេចក្តីថា មានរាងកាយញ័ររំប្រប់ តាំងអំពីបេះដូង

ជាដើម ។ អាចារ្យមួយពួកពោលថា ការមានរាងកាយរឹង ព្រោះខ្លាចខ្លាំង ដូច្នេះក៏មាន ។ ពិតហើយ ការមានរាងរឹងដូចសសរ លោកហៅថា ការស្រៀវខ្លាច ។ ការមានរោមបះឡើងជាដើម ឈ្មោះថា ការព្រឺរោម ។ ឯព្រះខីណាស្រពទាំងឡាយ រមែងមិនឃើញសត្វស្លាប់ឡើយ ព្រោះលោកឃើញល្អហើយ ដោយភាពជារបស់សូន្យចាកសត្វ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា អន្តរាយ មានការភ័យខ្លាចជាដើមទាំងនោះ មិនមានដល់ព្រះ-ខីណាស្រពទាំងនោះ ។ មិគលណ្ឌិកនោះ បានសម្លាប់ភិក្ខុមានប្រមាណ ៥ រយអង្គ ទាំងអស់នោះឲ្យដាច់ជីវិតដោយអំណាចការរាប់យ៉ាងនេះ គឺបានសម្លាប់ភិក្ខុឲ្យដាច់ជីវិត ១ ថ្ងៃមួយអង្គខ្លះ ២ អង្គខ្លះ ។បេ។ ៦០ អង្គខ្លះ ។

## ព្រះមានព្រះភាគទ្រង់ជ្រាបថាភិក្ខុសង្ឃស្ដើងទៅ

[ ១៧៧ ] ពីរបទថា **បដិសល្លានា វុដ្ឋិតោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ជ្រាបភិក្ខុមានប្រមាណ ៥០០ អង្គនោះ ដល់នូវមរណភាព ទើបយាងចេញអំពីភាពជាបុគ្គលម្នាក់ឯងនោះ សូម្បីទ្រង់ជ្រាប ក៏ហាក់ដូចជាមិនជ្រាប ទើបត្រាស់ហៅព្រះអានន្ទមក ដើម្បីឲ្យរឿងផ្តើមឡើង ។

បទថា **កិន្នុខោ អានន្ទ តនុភូតោ វិយ ភិក្ខុសង្ឃោ** សេចក្តីថា ទ្រង់ត្រាស់ថា ម្នាលអានន្ទ ក្នុងកាលមុននេះ ពួកភិក្ខុជាច្រើន រមែងមកកាន់ទីឧបដ្ឋាក ដោយរួមជាពួក ១ រៀនយកឧទ្ទេស បរិបុច្ឆា និងស្វាធ្យាយ អាកាមរមែងប្រាកដរុងរឿងដូចៗ គ្នា តែឥឡូវនេះ ដោយកន្លងទៅត្រឹមតែកន្លះខែ ភិក្ខុសង្ឃដូចជាតិចទៅ គឺហាក់ដូចជាស្តើងទៅ តិចទៅ ថយចុះទៅ

សល់តិចទៅ មានហេតុអ្វីឬ ពួកភិក្ខុចៀសទៅក្នុងទិសទាំងឡាយឬ ។

លំដាប់នោះ ព្រះអានន្ទមិនកំណត់ហេតុដែលភិក្ខុទាំងនោះ ដល់នូវមរណភាពព្រោះផលនៃកម្ម តែមកកំណត់ព្រោះការព្យាយាមប្រកបក្នុងអសុភកម្មដ្ឋានជាបច្ច័យ ទើបក្រាបទូលពាក្យជាដើមថា **តថា ហិ បន ភន្តេ ភគវា** ដូច្នេះ កាលនឹងទូលសូមកម្មដ្ឋានដទៃ ដើម្បីឲ្យភិក្ខុទាំងឡាយសម្រេចអរហត្តផល ទើបក្រាបទូលពាក្យជាដើមថា **សាធុ ភន្តេ ភគវា** ដូច្នេះ ។ ពាក្យនោះមានអត្ថថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះមានព្រះភាគ មេត្តាត្រាស់ប្រាប់ការណ៍ដទៃដែលជាហេតុឲ្យភិក្ខុសង្ឃតាំងនៅក្នុងអរហត្តផល ។ អធិប្បាយថា ពិតហើយ កម្មដ្ឋានដែលជាគុណជាតិឈមចុះកាន់ព្រះនិព្វាន ដូចកំពង់ជាទីឈមចុះកាន់មហាសមុទ្រដទៃក៏មានច្រើន ដោយប្រភេទ គឺអនុស្សតិ ១០ កសិណ ១០ ចតុធាតុវវដ្ឋាន ៤ ព្រហ្មវិហារ ៤ និងអានាបានស្សតិ ១ ។ សូមព្រះដ៏មានព្រភាគ ទ្រង់លួងលោមភិក្ខុទាំងឡាយឲ្យស្រោកស្រៀយក្នុងព្រះកម្មដ្ឋានទាំងនោះ ហើយត្រាស់ព្រះកម្មដ្ឋានឯណាមួយចុះ ។

លំដាប់នោះ ព្រះមានព្រះភាគ មានបំណងធ្វើដូច្នោះ កាលបញ្ជូនព្រះថេរៈទៅ ទើបទ្រង់ត្រាស់ថា **តេនហិ អានន្ទ** ដូច្នេះ ។

បណ្ដាបទទាំងនោះ ពីរបទថា **វេសាលឹ ឧបនិស្សាយ** សេចក្ដីថា ភិក្ខុមានប្រមាណប៉ុនណា អាស្រ័យក្រុងវេសាលីដោយជុំវិញ ក្នុងទីមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ ចូរអ្នកផ្ដៀងភិក្ខុទាំងអស់នោះ ឲ្យប្រជុំគ្នា ។

បទថា **សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា** សេចក្តីថា ទៅកាន់ទីដែលខ្លួនគួរនឹងទៅឯង ហើយក្នុងទីដទៃ បញ្ជូនភិក្ខុកំលោះទៅជំនួស ចាត់ពួកភិក្ខុឲ្យប្រជុំគ្នា មិនឲ្យសេសសល់ ត្រង់ឧបដ្ឋានសាលា ដោយមួយសន្ទុះប៉ុណ្ណោះ ។

ក្នុងបទថា **យស្សិ ទានិ ភន្តេ ភគវា កាលំ មញ្ញតិ** អធិប្បាយដូច្នេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុសង្ឃប្រជុំគ្នាហើយ នេះជាកាលទ្រង់ធ្វើធម្មកថាដើម្បីប្រទានអនុសាសនីដល់ភិក្ខុទាំងឡាយ សូមទ្រង់ជ្រាបកាលនៃកិច្ចដែលទ្រង់គួរធ្វើក្នុងកាលឥឡូវនេះចុះ ។

## អធិប្បាយ អានាបានស្សតិសមាធិ

[ ១៧៨ ] បទថា **អថខោ ភគវា ។បេ។ ភិក្ខូ អាមន្តេសិ អយម្បិ ខោ ភិក្ខវេ** សេចក្តីថា កាលព្រះមានព្រះភាគឲ្យឱវាទដាស់តឿនហើយ កាលត្រាស់ប្រាប់ បរិយាយដទៃអំពីអសុភកម្មដ្ឋាន ដែលត្រាស់ប្រាប់ហើយក្នុងកាលមុន ដើម្បីសម្រេចអរហត្តដល់ភិក្ខុទាំងឡាយ ទើបត្រាស់ថា **អានាបានស្សតិសមាធិ** ជាដើម ។ ឥឡូវនេះ ព្រោះថា ព្រះមានព្រះភាគត្រាស់បាលីនេះ ដើម្បីទ្រង់សម្តែងព្រះកម្មដ្ឋាន ដែលជាគុណជាតិស្ងប់ និងប្រណីតពិតៗ ដល់ភិក្ខុទាំងឡាយ ដូច្នោះ ខ្ញុំនឹងធ្វើការពណ៌នាក្នុងព្រះបាលីនេះ តាមលំដាប់អត្ថយោជនា មិនលះបោលឲ្យខូចសេចក្តីឡើយ ។

បណ្តាបទទាំងនោះ បទថា **អយម្បិ ខោ ភិក្ខវេ** ជាដើមនេះ មានយោជនាដូចតទៅនេះជាមុនថា ម្នាលភិក្ខុទាំងឡាយ អសុភភាវនាតែម្យ៉ាង

ប៉ុណ្ណោះ រមែងប្រព្រឹត្តទៅដើម្បីលះកិលេសក៏មិនមែនទេ មួយវិញទៀត អានា-បានស្សតិសមាធិនេះឯង ដែលភិក្ខុអប់រំ ធ្វើឲ្យច្រើនហើយ រមែងជាគុណស្ងប់ប្រណីត ត្រជាក់ ជាសុខ និងញ៉ាំងបាបអកុសលធម៌ដែលកើតឡើងហើយ ឲ្យអន្តរធាន ស្ងប់ទៅដោយឆាប់រហ័ស ក្នុងពាក្យថា **អានាបានស្សតិសមាធិ** ជាដើមនេះ មានការពិពណ៌នាអត្ថដូចតទៅនេះថា សតិកំណត់ដង្ហើមចេញ-ចូល ឈ្មោះថា អានាបានស្សតិ ។ សមដូចពាក្យដែលព្រះធម្មសេនា-បតីសារីបុត្រពោលទុកក្នុងបដិសម្ភិទាមគ្គថា ខ្យល់ដង្ហើមចូល ឈ្មោះថា **អាន** មិនមែនបស្សាសៈ ខ្យល់ដង្ហើមចេញ ឈ្មោះថា **បាន** មិនមែនអស្សាសៈ សតិចូលទៅតាំងទុកដោយអំណាចខ្យល់ដង្ហើមចូល សតិចូលទៅតាំងទុកដោយអំណាចខ្យល់ដង្ហើមចេញ រមែងប្រាកដដល់បុគ្គលដែលដកដង្ហើមចូល រមែងប្រាកដដល់បុគ្គលដែលដកដង្ហើមចេញ ។

សេចក្ដីដែលចិត្តមានអារម្មណ៍ ១ ដែលកើតឡើងព្រមទាំងសតិ ដែលកំណត់ខ្យល់ចូល-ចេញនោះ ឈ្មោះថា សមាធិ ។ ឯទេសនានេះ លោកពោលទុកដោយមាតិកា គឺសមាធិ មិនមែនដោយមាតិកា គឺសតិឡើយ ។ ព្រោះដូច្នោះ ក្នុងបទថា **អានាបានស្សតិសមាធិ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា សមាធិដែលប្រកបដោយអានាបានស្សតិ ឬសមាធិក្នុងអានាបានស្សតិ ឈ្មោះថា អានាបានស្សតិសមាធិ ។ បទថា **ភាវិតោ** ប្រែថា ឲ្យកើតឡើង ឬឲ្យចម្រើនហើយ ។ បទថា **ពហុលីកតោ** ប្រែថា ធ្វើរឿយៗ ។

ពីរបទថា **សន្តោ ចេវ បណីតោ ច** គឺជាគុណជាតិស្ងប់ផង ជាគុណ-

ជាតិប្រណីតផងនោះឯង ។ ក្នុងបទទាំងពីរ គប្បីជ្រាបការពិតប្រាកដដោយ **ឯវ** សព្ទ ។ លោកពោលអធិប្បាយដូចម្តេច លោកពោលអធិប្បាយថា ពិតហើយ អានាបានស្សតិសមាធិនេះ ជាធម៌មិនស្ងប់ ឬមិនប្រណីតដោយបរិយាយណាមួយ ដូចអសុភកម្មដ្ឋាន ដែលជាកម្មដ្ឋានស្ងប់ និងប្រណីតដោយអំណាចការចាក់ធ្លុះតែម្យ៉ាង តែមិនស្ងប់ មិនប្រណីត ដោយអំណាចអារម្មណ៍ ព្រោះមានអារម្មណ៍គ្រោតគ្រាត និងព្រោះមានអារម្មណ៍បដិកូលដូច្នោះឡើយ ម្យ៉ាងទៀត អានាបានស្សតិសមាធិនេះស្ងប់ គឺរម្ងាប់ស្ងៀម ព្រោះមានអារម្មណ៍ ស្ងប់ផង មានអង្គ គឺការចាក់ធ្លុះស្ងប់ផង ប្រណីត គឺមិនធ្វើឲ្យខូចកិត្តិយស ព្រោះមានអារម្មណ៍ប្រណីតផង ព្រោះមានអង្គប្រណីតផង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា ស្ងប់ និងប្រណីត ។

ក្នុងពាក្យថា **អសេចនកោ ច សុខោ ច វិហារោ** នេះ មានវិនិច្ឆ័យដូច្នេះថា អានាបានស្សតិសមាធិនោះ មិនមានទោសជាគ្រឿងលិចស្រោច ព្រោះដូច្នោះ ទើបឈ្មោះថា ត្រជាក់ គឺមិនមានគ្រឿងស្រោចលាយឡំមួយផ្នែកដោយឡែក មិនទូទៅ ។ ម្យ៉ាងទៀត ការស្ងប់ដោយបរិកម្ម ឬដោយឧបចារៈក្នុងអានាបានស្សតិសមាធិនេះមិនមាន ។ អធិប្បាយថា ជាធម៌ស្ងប់និងប្រណីតដោយសភាពរបស់ខ្លួននោះឯង ចាប់ផ្តើមអំពីការផ្តើមដាក់ចិត្ត ។ តែអាចារ្យពួកខ្លះពោលថា បទថា **អសេចនកោ** សេចក្តីថា មិនមានគ្រឿងលិចស្រោច គឺមានឱជៈ មានរស់ឆ្ងាញ់ដោយសភាវៈនោះឯង ។ ដោយអត្ថដូចពោលមកនេះ អានាបានស្សតិសមាធិនេះ បណ្ឌិតគប្បីជ្រាបថា ត្រជាក់

និងនៅជាសុខ ព្រោះប្រព្រឹត្តទៅដើម្បីឲ្យបានសេចក្ដីសុខផ្លូវកាយ និងផ្លូវចិត្ត ក្នុងខណៈដែលចូលដល់ហើយ ។

បទថា **ឧប្បន្នុប្បន្នេ** ដោយអត្ថថា ដែលមិនទាន់សង្កត់សង្កិនបាន ។

បទថា **ឋាបកោ** ដោយអត្ថថា អាក្រក់លាមក ។ ពីរបទថា **អកុសលេ ធម្មេ** បានដល់ ធម៌ដែលកើតអំពីការមិនឈ្លាស ។ ពីរបទថា **ឋានសោ អន្តរធាបេតិ** សេចក្ដីថា រមែងឲ្យអន្តរធានទៅ គឺសង្កត់ទុកបានដោយរួសរាន់នោះឯង ។

បទថា **វូបសមេតិ** សេចក្ដីថា រមែងឲ្យស្ងប់ទៅដោយល្អ ។ម្យ៉ាងទៀត អធិប្បាយថា អានាបានស្សតិសមាធិនេះ រមែងដល់នូវការចម្រើនដោយអរិយមគ្គដោយលំដាប់ ព្រោះមានចំណែកនៃការចាក់ធ្លុះ រមែងកាត់ដាច់ដោយល្អ គឺរមែងស្ងប់រៀបរយបាន ។

ពាក្យថា **សេយ្យថាបិ** នេះ ជាពាក្យសម្ដែងឧបមា ។

ប្រើនបទថា **គិម្ហានំ បច្ឆិមេ មាសេ** បានដល់ ក្នុងខែអាសាឍ ។

បទថា **ឩហតំ រជោជល្លំ** សេចក្ដីថា ធូលី និងលម្អង ត្រូវខ្យល់បក់ផាត់ហុយឡើងខាងលើ គឺអណ្ដែតឡើងលើអាកាសចាកផែនដី ដែលបែកក្រហែង ព្រោះក្របកគោ និងក្របី ដែលជាន់ ដែលស្ងួតព្រោះខ្យល់ និងកម្ដៅថ្ងៃអស់កន្លះខែ ។

ពពកកើតឡើងពេញអាកាសទាំងអស់ ហើយឲ្យភ្លៀងធ្លាក់រហូតពេញកន្លះខែ ក្នុងជុណ្ហបក្ខនៃខែអាសាឍ ឈ្មោះថា ភ្លៀងធំដែលធ្លាក់ក្នុងសម័យ

មិនមែនរដូវកាល ។ ពិតហើយ ភ្លៀងនោះ លោកបំណងយកក្នុងអធិការនេះថា **អកាលមេឃ** ព្រោះកើតឡើងក្នុងវេលាពុំជូកាល ។

ប្រើនបទថា **ឋានសោ អន្តរធាបេតិ វូបសមេតិ** សេចក្ដីថា ភ្លៀងធំដែលធ្លាក់ក្នុងសម័យមិនមែនរដូវកាលនោះ រមែងបក់យកធូលី និងលម្អងនោះៗ ទៅ មិនឲ្យមើលឃើញ គឺផាត់ឲ្យលិចចូលទៅក្នុងផែនដី ដោយឆាប់រហ័សនោះឯង ។

ក្នុងបទថា **ឯវមេវ ខោ** នេះ ជាពាក្យប្រៀបធៀបការឧបមេយ្យ ។ បន្ទាប់អំពីពាក្យថា **ឯវមេវ ខោ** នោះទៅ មានន័យដូចពោលមកហើយនោះឯង ។ ក្នុងពាក្យថា **កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា បទថា **កថំ** ជាពាក្យសួរ គឺភាពជាបុគ្គលប្រាថ្នានឹងញុំាងអានាបានស្សតិសមាធិការនាឲ្យពិស្ដារ ដោយប្រការផ្សេងៗ ។

បទថា **ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ** ជាពាក្យសម្ដែងលម្អិតធម៌ដែលត្រូវសួរ ព្រោះភាពជាអ្នកប្រាថ្នានឹងញុំាងអានាបានស្សតិសមាធិនោះឲ្យពិស្ដារ ដោយប្រការផ្សេងៗ សូម្បីក្នុងបទទី ២ ក៏មានន័យនេះ ។

ក្នុងបទថា **កថំ ភាវិតោ ច** ជាដើមនេះ មានសេចក្ដីសង្ខេបដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលភិក្ខុអប់រំហើយ ដោយប្រការណា ដោយអាការណា ដោយវិធីដូចម្ដេច ធ្វើឲ្យច្រើនហើយ ដោយប្រការដូចម្ដេច ទើបជាគុណជាតិស្ងប់ ប្រណីត ត្រជាក់ ជាសុខ និងញុំាងបាបអកុសលធម៌ដែលកើតឡើងហើយ ឲ្យអន្តរធានទៅ ដោយឆាប់រហ័ស ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ញ៉ាំងអត្ថនោះឲ្យពិស្តារ ទើបត្រាស់ថា **ឥធ ភិក្ខវេ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឥធ ភិក្ខវេ ភិក្ខុ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ។ ពិតហើយ **ឥធ** សព្ទ ក្នុងបទថា **ភិក្ខវេ** នេះ សម្ដែងសាសនាដែលជាទីអាស្រ័យរបស់បុគ្គល ដែលឲ្យអានាបានស្សតិសមាធិកើតឡើង ដោយប្រការទាំងពួង និងបដិសេធភាពមិនជាដូច្នោះ នៃសាសនាដទៃ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលសុភទ្ទ សមណៈ ( ទី ១ ) ក៏មានតែក្នុងសាសនានេះ សមណៈទី ២ ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ ក៏មានតែក្នុងសាសនានេះ សមណៈទី ៤ ក៏មានតែក្នុងសាសនានេះ បរប្បវាទ ( វាទៈនៃគ្រូដទៃ ) អំពីសម្នាក់នៃបុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ ( នេះ ) ។

បទថា **អរញ្ញគតោ វា ។បេ។ សុញ្ញាគារគតោ វា** នេះ សម្ដែងការដែលភិក្ខុនោះជ្រើសយកសេនាសនៈដែលសមគួរដល់ការចម្រើនអានាបានស្សតិសមាធិ ។ ព្រោះថា ចិត្តរបស់ភិក្ខុនេះ ធ្លាប់រាយមាយទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមអស់កាលដ៏យូរ ទើបមិនចង់ឈានឡើងកាន់អារម្មណ៍របស់អានាបានស្សតិសមាធិ យ៉ាំតែនឹងស្ទុះទៅក្រៅផ្លូវតែម្យ៉ាង ដូចរថដែលគេទឹមដោយគោជ្រលែង ដូច្នោះ ។ ព្រោះដូច្នោះ អ្នកចិញ្ចឹមគោ ត្រូវការហ្វឹកកូនគោជ្រលែង ដែលកំពុងបៅដោះទាំងអស់របស់មេគោជ្រលែង ធំចម្រើនហើយ គប្បីបំបែកចាកមេ បោះបង្គោលធំទុកក្នុងចំណែកមួយ ហើយ

យកខ្សែចងត្រង់បង្គោលនោះ គ្រានោះ កូនគោនោះបម្រះទៅខាងនោះ ខាងនេះ មិនអាចគេចទៅបាន គប្បីឈរផ្អែក ឬដេកផ្អែកបង្គោលនោះឯង សេចក្តីនេះ យ៉ាងណា ភិក្ខុអង្គនោះ ក៏យ៉ាងនោះដូចគ្នា បំណងនឹងទូន្មានចិត្ត ដែលត្រូវទោសប្រទូស្តហើយ ដែលចម្រើនដោយការបៀរសនៃអារម្មណ៍ មានរូបជាដើមអស់កាលដ៏យូរហើយ គប្បីបំបែកចាកអារម្មណ៍ មានរូបជាដើម ហើយចូលទៅកាន់ព្រៃ ឬគល់ឈើ ឬផ្ទះស្ងាត់ ហើយគប្បីយកខ្សែ គឺសតិចងត្រង់បង្គោល គឺខ្យល់អស្សាសៈ និងបស្សាសៈនោះ កាលបើដូច្នោះ ចិត្តរបស់ភិក្ខុនោះ សូម្បីច្រឆ្ងាទៅផ្លូវនោះ និងផ្លូវនេះក៏ដោយ កាលមិនបានទទួលអារម្មណ៍ ដែលធ្លាប់ស្និទ្ធស្នាលមកក្នុងកាលមុន មិនអាចនឹងកាត់ខ្សែ គឺសតិគេចទៅបាន រមែងឈប់ស្ងៀម និងអែបស្និទ្ធក្នុងអារម្មណ៍នោះឯង ដោយអំណាចឧបចារៈ និងអប្បនា ។ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយ ពោលថា

> នរជនកាលបង្វឹកកូនគោ គប្បីចងភ្ជាប់ត្រង់បង្គោល យ៉ាងណា ភិក្ខុក្នុងសាសនានេះ គប្បីយកសតិចងចិត្តរបស់ខ្លួនឲ្យមាំត្រង់អារម្មណ៍ ដូច្នោះ ។

សេនាសនៈនោះ រមែងជាទីដែលសមគួរដល់ការចម្រើនអានាបានស្សតិសមាធិនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ទើបខ្ញុំពោលថា ពាក្យនេះសម្តែងការដែលភិក្ខុនោះ ជ្រើសរើសសេនាសនៈ ដែលសមគួរដល់ការចម្រើនអានាបានស្សតិសមាធិ ។ម្យ៉ាងទៀត ព្រោះអានាបានស្សតិកម្មដ្ឋាន

នេះ ជាកំពូលក្នុងប្រភេទនៃកម្មដ្ឋាន ជាបទដ្ឋាននៃការសម្រេចគុណវិសេស និងជាសុខវិហារធម៌ក្នុងបច្ចុប្បន្នរបស់ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវកពុទ្ធ ដែលព្រះយោគាវចរមិនលះស្រុក ដែលអឺងកងដោយសំឡេងស្ត្រី បុរស ដំរី និងសេះជាដើម និងចម្រើនឲ្យដល់ព្រម ធ្វើមិនបានងាយឡើយ ព្រោះសំឡេងជាសត្រូវចំពោះឈាន តែក្នុងព្រៃដែលមិនមែនស្រុក ព្រះយោគាវចរកំណត់កម្មដ្ឋាននេះហើយ ញុំាងចតុត្ថជ្ឈានដែលមានខ្យល់ដង្ហើមចូល-ចេញ ជាអារម្មណ៍ឲ្យកើតហើយ ធ្វើឈាននោះឯងឲ្យជាបាទពិចារណាសង្ខារទាំងឡាយ បានសម្រេចអរហត្តដែលជាផលដ៏ឧត្តម ធ្វើបានងាយ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងសេនាសនៈដែលសមដល់ភិក្ខុនោះ ទើបត្រាស់ពុទ្ធវចនៈជាដើមថា **អរញ្ញគតោ វា** ដូច្នេះ ។ ព្រោះថា ព្រះមានព្រះភាគប្រៀបដូចអាចារ្យដែលទ្រទ្រង់នូវវិទ្យាគុណ ដឹងទីជ័យភូមិ ។ អាចារ្យដែលទ្រទ្រង់វិជ្ជា ស្គាល់ដី ដែលជាដីសម្រាប់សាងព្រះនគរហើយ ពិចារណាដោយល្អិតល្អន់ ហើយចង្អុលថា សូមព្រះរាជាទ្រង់សាងព្រះនគរក្នុងទីនេះ កាលនគរសម្រេចហើយ ដោយសួស្តី រមែងបានមហាសក្ការៈអំពីរាជត្រកូល យ៉ាងណា ព្រះមានព្រះភាគអង្គនោះ ទ្រង់ពិចារណាសេនាសនៈដែលសមគួរដល់ព្រះយោគាវចរហើយ ទ្រង់រមែងចង្អុលថា កម្មដ្ឋានដែលកុលបុត្រមានសេចក្តីព្យាយាម គប្បីព្យាយាមក្នុងទីនេះ បន្ទាប់មក កាលព្រះយោគាវចរប្រកបកម្មដ្ឋាននៅក្នុងសេនាសនៈនេះហើយ សម្រេចអរហត្តដោយលំដាប់ រមែងបានមហាសក្ការៈ

ថា ព្រះមានព្រះភាគអង្គនោះ ជាសម្មាសម្ពុទ្ធពិតហ្ន៎ ដូច្នោះដូចគ្នា ។ ឯភិក្ខុនេះ លោកពោលថា ដូចជាខ្លាធំ ដូចស្តេចខ្លាធំ ពួនអាស្រ័យគុម្ពស្មៅ ព្រៃស្តុក ឬញកភ្នំនៅក្នុងព្រៃ រមែងចាប់ពួកម្រឹគ មានក្របីព្រៃ ប្រើស ( ឬ ក្តាន់ ) និងជ្រូកជាដើម( ជាអាហារ )យ៉ាងណា ភិក្ខុព្យាយាមប្រកបកម្មដ្ឋានក្នុងសេនាសនៈមានព្រៃជាដើមនេះ ក៏ដូច្នោះ បណ្ឌិតគប្បីជ្រាបថា រមែងកាន់យកបាននូវសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ និងអរិយផល ដោយលំដាប់ ។ ព្រោះដូច្នោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

ដែលឈ្មោះថា ខ្លាធំ រមែងចាប់ពពួកម្រឹគ ( ជាអាហារ )
យ៉ាងណា ពុទ្ធបុត្រ ដែលប្រកបសេចក្តីព្យាយាម ចម្រើន
វិបស្សនានេះក៏ដូចគ្នា ចូលទៅកាន់ព្រៃហើយ រមែងកាន់
យកបាននូវផលដ៏ឧត្តម ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអរញ្ញសេនាសនៈដែលជាភូមិគួរដល់ការប្រកបជវនប្បញ្ញា ដើម្បីការចម្រើនទៅមុខដល់ព្រះយោគាវចរនោះ ទើបទ្រង់ត្រាស់ពុទ្ធវចនៈ មានជាដើមថា **អរញ្ញគតោ វា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **អរញ្ញគតោ វា** សេចក្តីថា ទៅកាន់ព្រៃដែលងាយស្រួលដល់ការស្ងាត់កន្លែងណាមួយ ក្នុងបណ្តាព្រៃដែលមានលក្ខណៈដូចពោលទុកយ៉ាងនេះថា ដែលឈ្មោះថា ព្រៃ បានដល់ ទីខាងក្រៅអំពីសសរខឿនចេញទៅ ទាំងអស់នោះឈ្មោះថា ព្រៃ និងថា សេនាសនៈ

ដោយហោចចម្ងាយប្រមាណ ៥០០ ជួរធ្នូ ឈ្មោះថា សេនាសនៈព្រៃ ។

បទថា **រុក្ខមូលគតោ វា** សេចក្ដីថា ទៅកាន់ទីជិតគល់ឈើ ។

បទថា **សុញ្ញាគារគតោ វា** សេចក្ដីថា ទៅកាន់ទីឱកាសស្ងាត់ដែលទំនេរ ។ តែក្នុងអធិការនេះ សូម្បីភិក្ខុវៀរព្រៃ និងគល់ឈើជាដើមចេញ ទៅកាន់សេនាសនៈ ៧ យ៉ាងដ៏សេស ក៏គួរហៅថា ទៅកាន់ផ្ទះស្ងាត់ ។

ព្រះមានព្រះភាគ កាលទ្រង់ចង្អុលសេនាសនៈដ៏សមគួរដល់ការចម្រើនអានាបានស្សតិដែលសមគួរដល់រដូវទាំង ៣ និងសមគួរដល់ធាតុ និងចរិយាដល់ភិក្ខុយ៉ាងនោះហើយ កាលទ្រង់ចង្អុលឥរិយាបថដែលស្ងប់ ដែលជាចំណែកនៃការមិនរួញរា និងមិនរាយមាយ ទើបត្រាស់ថា **និសីទតិ** ដូច្នេះ ។ ខាងក្រោយ កាលទ្រង់សម្ដែងការៈនៃការអង្គុយជារបស់មាំទាំ ដើម្បីខ្យល់អស្សាសៈ បស្សាសៈប្រព្រឹត្តទៅស្រួល និងឧបាយជាគ្រឿងកំណត់ចាប់អារម្មណ៍ដល់ភិក្ខុនោះ ទើបត្រាស់ព្រះពុទ្ធវចនៈជាដើមថា **បល្លង្កំ អាភុជិត្វា** ដូច្នេះ ។

បណ្ដាទបទាំងនោះ បទថា **បល្លង្កំ** បានដល់ អង្គុយពត់ជើងទាំងពីរដោយជុំវិញ ( គឺអង្គុយពែនភ្នែន ) ។

បទថា **អាភុជិត្វា** ប្រែថា បទចូល ។

បទថា **ឧជុំ កាយំ បណិធាយ** សេចក្ដីថា តម្រង់កាយចំណែកលើឲ្យត្រង់ គឺឲ្យឆ្អឹងទ្រនុងខ្នង ១៨ កំណាត់ តម្រួតត្រង់លើគ្នា ។ ពិតហើយ កាលភិក្ខុនោះអង្គុយ ដោយអាការយ៉ាងនោះហើយ ស្បែក សាច់ សរសៃ

រមែងមិនវៀច វេលានោះ វេទនាទាំងឡាយ ដែលនឹងគប្បីកើតឡើងដល់ភិក្ខុក្នុងខណៈៗ ព្រោះការមិនត្រង់នៃស្បែក សាច់ និងសរសៃទាំងនោះ ជាបច្ច័យនោះឯង រមែងមិនកើតឡើង ។ កាលវេទនាទាំងនោះ មិនកើតឡើង ចិត្តក៏មានអារម្មណ៍តែមួយ កម្មដ្ឋានមិនធ្លាក់ទៅ ចូលដល់នូវការចម្រើនរុងរឿង ។

បទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** សេចក្តីថា តាំងសតិឆ្ពោះកម្មដ្ឋានម្យ៉ាងទៀត ក្នុងពាក្យថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** នេះ គប្បីឃើញអត្ថតាមន័យ ដូចព្រះធម្មសេនាបតីសារីបុត្រ ពោលទុកក្នុងបដិសម្ភិទានោះឯង យ៉ាងនេះថា ពាក្យថា **បរិ** មានការកំណត់កាន់យកជាអត្ថ សព្ទថា **មុខំ** មានការនាំចេញជាអត្ថ សព្ទថា **សតិ** មានការចូលទៅតាំងទុកជាអត្ថ ព្រោះហេតុនោះ ទើបលោកពោលថា តាំងសតិទុកចំពោះមុខ ។ ក្នុងបទថា **បរិមុខំ សតឹ** នោះ មានសេចក្តីសង្ខេបដូច្នេះថា ធ្វើសតិជាគ្រឿងនាំចេញ ដែលខ្លួនកំណត់កាន់យកហើយ ។

## អធិប្បាយ វិធីអប់រំសតិ ៣២ យ៉ាង

ពាក្យថា **សោ សតោវ អស្សសតិ** សេចក្តីថា ភិក្ខុនោះអង្គុយយ៉ាងនោះ និងតាំងសតិទុកយ៉ាងនោះហើយ កាលមិនលះសតិនោះ ឈ្មោះថា មានសតិ ដកដង្ហើមចូល ឈ្មោះថា មានសតិដកដង្ហើមចេញ ។ មានពាក្យអធិប្បាយថា ជាអ្នកអប់រំសតិ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអាការជាគ្រឿងអប់រំសតិទាំងនោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា **ទីឃំ វា អស្សសន្តោ** ជាដើម ។

សមដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកក្នុងវិភង្គចំពោះពាក្យពីរនេះថា **សោ សតោវ អស្សសតិ សតោ បស្សសតិ** ក្នុងបដិសម្ភិទាមគ្គ ពោលថា ភិក្ខុរមែងជាអ្នកអប់រំសតិដោយអាការ ៣២ យ៉ាង គឺសតិរបស់ភិក្ខុដែលដឹងសភាពដែលចិត្តមានអារម្មណ៍ ១ មិនរាយមាយ ដោយអំណាចខ្យល់ដង្ហើមចូលវែង រមែងតាំងមាំ ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិដោយសតិនោះ ដោយញាណនោះ សតិរបស់ភិក្ខុដឹងសភាពដែលចិត្តមានអារម្មណ៍ ១ មិនរាយមាយ ដោយអំណាចខ្យល់ដង្ហើមចេញវែង រមែងតាំងមាំ ។ ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិដោយសតិនោះ ដោយញាណនោះ ។បេ។ សតិរបស់ភិក្ខុអ្នកដឹងភាពដែលចិត្តមានអារម្មណ៍ ១ មិនរាយមាយ ដោយអំណាចភាពជាអ្នកពិចារណាឃើញការលះបង់ខ្យល់ដង្ហើមចូល ... ដោយអំណាចជាអ្នកពិចារណាឃើញការលះបង់ខ្យល់ដង្ហើមចេញ រមែងតាំងមាំ ។ ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិ ដោយសតិនោះ ដោយញាណនោះ ។

## មតិខ្យល់ដង្ហើមចូល-ចេញ តាមព្រះសូត្រ

បណ្ដាបទទាំងនោះ ពីរបទថា **ទីឃំ វា អស្សសន្តោ** បានដល់ កាលខ្យល់ដង្ហើមចូលវែងប្រព្រឹត្តទៅ ក្នុងអដ្ឋកថាព្រះវិន័យ ពោលថា ខ្យល់ដែលចេញទៅខាងក្រៅ ឈ្មោះថា **អស្សាសៈ** គឺខ្យល់ដង្ហើមចេញ ខ្យល់ដែលចូលទៅខាងក្នុង ឈ្មោះថា **បស្សាសៈ** គឺខ្យល់ដង្ហើមចូល ចំណែកក្នុងអដ្ឋកថានៃព្រះសូត្រទាំងឡាយ មកដោយបញ្ច្រាសលំដាប់គ្នា ។

បណ្ដាខ្យល់ទាំងពីរនោះ ក្នុងវេលាដែលគព្ភសេយ្យកសត្វទាំងពួង

ចេញចាកផ្ទៃម្ដាយ ខ្យល់ខាងក្នុងរមែងចេញទៅខាងក្រៅមុន ក្រោយមក ខ្យល់ខាងក្រៅ នាំយកលម្អងដែលល្អិតចូលទៅខាងក្នុងប៉ះខ្ចប់ពិតានហើយ ក៏រលត់ទៅ គប្បីជ្រាបខ្យល់អស្សាសៈ និងបស្សាសៈយ៉ាងនេះមុន ។ ចំណែកខ្យល់ដង្ហើមចូល-ចេញទាំងនោះ វែង និងខ្លី គប្បីជ្រាបដោយអំណាចនៃកាល ។ ឧបមាដូចទឹក ឬខ្សាច់ផ្សាយចេញទៅរយៈប៉ុនណា គឺឱកាសតាំងនៅ គេហៅថា ទឹកវែង ខ្សាច់វែង ទឹកខ្លី ខ្សាច់ខ្លី ដូច្នោះ យ៉ាងណា ខ្យល់ដង្ហើមចូល-ចេញដែលល្អិតរហូតអស់ ក៏ដូច្នោះ ដូចប្រទេសដែលវែងក្នុងខ្លួនដំរី និងខ្លួនពស់ ពោល គឺអត្តភាពរបស់ដំរី និងពស់ទាំងនោះ ខ្យល់ចូលសន្សឹមៗ ពេញហើយ ក៏សន្សឹមៗ ចេញទៅ ព្រោះដូច្នោះ ទើបលោកហៅថា វែង ខ្យល់ដង្ហើមចូល-ចេញ ញុំាងប្រទេសដែលខ្លី ពោល គឺអត្តភាពនៃឆ្កែ និងទន្សាយជាដើមឲ្យពេញរហ័ស ហើយក៏ចេញរហ័សដូចគ្នា ព្រោះដូច្នោះ ទើបលោកហៅថា ខ្លី ។ បណ្ដាពួកមនុស្សៗ ជំពូកខ្លះ ខ្យល់ដង្ហើមចូល-ចេញវែង ដោយអំណាចរយៈកាល ដូចដំរី និងពស់ជាដើម ពួកខ្លះខ្យល់ដង្ហើមចូល-ចេញខ្លី ដូចឆ្កែ និងទន្សាយជាដើម ព្រោះដូច្នោះ ខ្យល់ដង្ហើមចូល-ចេញទាំងនោះ របស់មនុស្សទាំងនោះ ដោយអំណាចកាលដែលចេញ-ចូល ស៊ីពេលយូរ គប្បីជ្រាបថា វែង ចេញ-ចូល រយៈពេលតិច គប្បីជ្រាបថា ខ្លី ។

ក្នុងខ្យល់ដង្ហើមចូល-ចេញនោះ ភិក្ខុនោះ កាលដកដង្ហើមចូល-ចេញវែង ដោយអាការ ៩ យ៉ាង រមែងដឹងច្បាស់ថា អញដកដង្ហើមចូល-ចេញ

វែង ។ កាលលោកដឹងច្បាស់យ៉ាងនេះ គប្បីជ្រាបថា ការចម្រើនកាយា-នុបស្សនាសតិប្បដ្ឋាន រមែងសម្រេចដោយអាការមួយ ដូចព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងបដិសម្ភិទាមគ្គថា សួរថា ភិក្ខុកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចូលវែង ។បេ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អញដកដង្ហើមចេញខ្លីដូចម្តេច ឆ្លើយថា ភិក្ខុកាលដកង្ហើមចូលវែង រមែងដកដង្ហើមចូលក្នុងខណៈដែលរាប់ថា វែង កាលដកដង្ហើមចេញវែង រមែងដកដង្ហើមចេញក្នុងខណៈដែលរាប់ថា វែង កាលខ្យល់ដង្ហើមចូល-ចេញវែង រមែងដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ ក្នុងខណៈដែលរាប់ថា វែង ឆន្ទៈ រមែងកើតដល់ភិក្ខុ កាលដកដង្ហើមចូល-ចេញវែង ដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ ក្នុងខណៈដែលរាប់ថា វែង ភិក្ខុកាលខ្យល់ដង្ហើមចូលវែងល្អិតជាងនោះ ដោយអំណាចឆន្ទៈ រមែងដកដង្ហើមចូល ក្នុងខណៈដែលរាប់ថា វែង កាលខ្យល់ដង្ហើមចេញវែងល្អិតជាងនោះ ដោយអំណាចឆន្ទៈ រមែងដកដង្ហើមចេញ ក្នុងខណៈដែលរាប់ថា វែង កាលដកដង្ហើមចូល-ចេញល្អិតជាងនោះ ដោយអំណាចឆន្ទៈ រមែងដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ ក្នុងខណៈដែលរាប់ថា វែង បាមោជ្ជរមែងកើតឡើងដល់ភិក្ខុ កាលដកដង្ហើមចូល-ចេញវែងល្អិតជាងនោះ ដោយអំណាចឆន្ទៈ ដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ ក្នុងខណៈដែលរាប់ថា វែង កាលដកដង្ហើមចូលវែងល្អិតជាងនោះ ដោយអំណាចបាមោជ្ជ រមែងដកដង្ហើមចូល ក្នុងខណៈដែលរាប់ថា វែង កាលខ្យល់ដង្ហើមចេញវែងល្អិតជាងនោះ ដោយអំណាចបាមោជ្ជ រមែងដកដង្ហើម

ចេញ ក្នុងខណៈដែលរាប់ថា វែង ។បេ។ កាលដកដង្ហើមចូល-ចេញវែង ដែលល្អិតជាងនោះ ដោយអំណាចបាមោជ្ជ រមែងដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ ក្នុងខណៈដែលរាប់ថា វែង ចិត្តរបស់ភិក្ខុកាលដកដង្ហើមចូល-ចេញវែងល្អិតជាងនោះ ដោយអំណាចបាមោជ្ជ ដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ ក្នុងខណៈដែលរាប់ថា វែង រមែងចៀសចេញអំពីការដកដង្ហើមចូល-ចេញវែង ឧបេក្ខារមែងតាំងនៅ កាយ គឺខ្យល់ដង្ហើមចូល-ចេញវែង ដោយអាការ ៩ យ៉ាងនេះរមែងប្រាកដ សតិជាអនុបស្សនាញាណ កាយប្រាកដ មិនមែនសតិ សតិប្រាកដផង ជាតួសតិផង ភិក្ខុរមែងពិចារណាឃើញកាយនោះដោយសតិនោះ ដោយញាណនោះ ព្រោះហេតុដូច្នោះ ទើបលោកពោលថា ការចម្រើនសតិប្បដ្ឋាន គឺការពិចារណាឃើញកាយក្នុងកាយ ដូច្នេះ ។

សូម្បីក្នុងបទដែលកំណត់ដោយខ្យល់ខ្លី ក៏មានន័យដូចគ្នា ។ ចំណែកការប្លែកគ្នា មានដូច្នេះថា ក្នុងបទដែលកំណត់ដោយខ្យល់វែងនោះ លោកពោលថា កាលខ្យល់ដង្ហើមចូលវែង រមែងដកដង្ហើមចូល ក្នុងខណៈដែលរាប់ថា វែង ដូច្នេះ យ៉ាងណា ក្នុងបទដែលកំណត់ដោយខ្យល់ខ្លីនេះ ក៏មានពាក្យដែលមកក្នុងបាលីថា កាលដកដង្ហើមចូលខ្លី រមែងដកដង្ហើមចូល ក្នុងខណៈដែលរាប់ថា តិចតួច ដូច្នោះ។ ព្រោះដូច្នោះ គប្បីប្រកបដោយអំណាចនៃបទដែលកំណត់ថាខ្លីនោះ រហូតដល់ពាក្យថា ព្រោះហេតុនោះ ទើបលោកពោលថា ការចម្រើនសតិប្បដ្ឋាន គឺការពិចារណាឃើញកាយក្នុងកាយ ។ ភិក្ខុនេះ កាលដឹងច្បាស់ដកដង្ហើមចូល-ចេញ ដោយអាការ ៩ យ៉ាងនេះ

ដោយអំណាចកាលវែង និងដោយអំណាចកាលបន្តិចបន្តួច ដូចពណ៌នាមក ដូច្នេះ បណ្ឌិតគប្បីជ្រាបថា ភិក្ខុកាលដកដង្ហើមចូលវែង រមែងដឹងច្បាស់ថា អញដកដង្ហើមចូលវែង ។បេ។ ឬកាលដកដង្ហើមចេញខ្លី រមែងដឹងច្បាស់ថា អញដកដង្ហើមចេញខ្លី ដូច្នេះ ។ម្យ៉ាងទៀត កាលភិក្ខុនោះ ដឹងយ៉ាងនេះថា

វណ្ណៈ ( គឺអាការ ) ទាំង ៤ គឺខ្យល់ដង្ហើមចូលវែង
និងខ្លី សូម្បីខ្យល់ដង្ហើមចេញក៏ដូច្នោះ រមែងប្រព្រឹត្តទៅ
ចំពោះត្រង់ចុងច្រមុះរបស់ភិក្ខុ ដូច្នេះឯង ។

បទថា **សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ ។បេ។ បស្សសិស្សាមីតិ សិក្ខតិ** អធិប្បាយថា ភិក្ខុរមែងសិក្សាថា អញនឹងធ្វើខាងដើម កណ្តាល និងខាងចុងនៃគំនរខ្យល់ដង្ហើមចូលទាំងអស់ឲ្យដឹងច្បាស់ គឺធ្វើឲ្យប្រាកដនូវខ្យល់ដង្ហើមចូល ( និង ) សិក្សាថា អញនឹងធ្វើខាងដើម កណ្តាល និងខាងចុងនៃគំនរខ្យល់ដង្ហើមចេញទាំងអស់ឲ្យដឹងច្បាស់ គឺធ្វើឲ្យប្រាកដនូវខ្យល់ដង្ហើមចេញ ។ កាលភិក្ខុធ្វើឲ្យដឹងច្បាស់ គឺធ្វើឲ្យប្រាកដដោយអាការយ៉ាងនោះ រមែងដកដង្ហើមចូល-ចេញ ដោយចិត្តដែលសម្បយុត្តដោយញាណ ព្រោះដូច្នោះ ទើបលោកហៅថា រមែងសិក្សាថា អញនឹងដកដង្ហើមចូល-ចេញ ។

ពិតហើយ ខាងដើម ក្នុងគំនរខ្យល់ដង្ហើមចូល ឬក្នុងគំនរខ្យល់ដង្ហើមចេញ ដែលសុះទៅយ៉ាងល្អិត រមែងប្រាកដដល់ភិក្ខុមួយអង្គ តែត្រង់កណ្តាល និងខាងចុងមិនប្រាកដ ភិក្ខុអាចកំណត់បានចំពោះខាងដើមប៉ុណ្ណោះ រមែងលំបាកត្រង់កណ្តាល និងខាងចុង អង្គខ្លះទៀត រមែងប្រាកដត្រង់កណ្តាល

តែខាងដើម ខាងចុងមិនប្រាកដ លោកអាចកំណត់បានចំពោះត្រង់កណ្តាល ប៉ុណ្ណោះ ភិក្ខុនោះអាចកំណត់បានចំពោះកណ្តាលប៉ុណ្ណោះ រមែងលំបាកត្រង់ ខាងដើម និងខាងចុង អង្គខ្លះទៀត រមែងប្រាកដត្រង់ខាងចុង តែខាងដើម និងកណ្តាលមិនប្រាកដ ភិក្ខុអាចកំណត់បានចំពោះខាងចុងប៉ុណ្ណោះ រមែង លំបាកត្រង់ខាងដើម និងកណ្តាល ។ អង្គខ្លះទៀត រមែងប្រាកដបានទាំង អស់ លោកអាចកំណត់បានទាំងអស់ រមែងមិនលំបាកក្នុងចំណែកណាមួយ ឡើយ ។ ព្រះមានព្រះភាគ កាលទ្រង់ចង្អុលបង្ហាញថា ភិក្ខុគប្បីជាបុគ្គល ដូច្នោះ ទើបត្រាស់ថា ភិក្ខុគប្បីសិក្សាថា អញនឹងដឹងច្បាស់នូវគំនរខ្យល់ ទាំងពួង ដកដង្ហើមចូល រមែងសិក្សា អញនឹងដឹងច្បាស់គំនរខ្យល់ទាំងពួង ដកដង្ហើមចេញ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សិក្ខតិ** សេចក្តីថា រមែងព្យាយាម គឺ ព្យាយាមយ៉ាងនោះ ។ ម្យ៉ាងទៀត ក្នុងបទថា **សិក្ខតិ** នេះ គប្បីឃើញអត្ថ យ៉ាងនេះថា ការសង្រួមរបស់ភិក្ខុដែលមានសភាពបែបនោះ ឈ្មោះថា អធិ- សីលសិក្ខា ក្នុងអធិការពោលដោយអានាបានស្សតិការនានេះ សមាធិរបស់ ភិក្ខុដែលមានសភាពយ៉ាងនោះ ឈ្មោះថា អធិចិត្តសិក្ខា បញ្ញារបស់ភិក្ខុនោះ ឈ្មោះថា អធិប្បញ្ញាសិក្ខា លោករមែងសិក្សា គឺរមែងសេព ចម្រើន ធ្វើឲ្យ ច្រើននូវសិក្ខា ៣ យ៉ាង ដូចពណ៌នាមកនេះ ដោយសតិនោះ ដោយ មនសិការនោះ ក្នុងអារម្មណ៍នោះ ។ ព្រោះថា ដោយន័យមុន បណ្តាពីរន័យ នោះ ភិក្ខុគប្បីដកដង្ហើមចូល-ចេញតែម្យ៉ាងប៉ុណ្ណោះ មិនចាំបាច់ធ្វើកិច្ចដទៃ

ណាមួយឡើយ តែចាប់ផ្ដើមពីពេលដែលដឹងច្បាស់នូវខ្យល់ដង្ហើមចូល-ចេញនេះទៅ គួរធ្វើសេចក្ដីព្យាយាមក្នុងអាការ ដែលញាណកើតឡើងជាដើម ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា ក្នុងន័យមុននោះ ព្រះមានព្រះភាគត្រាស់បាលីទុក ដោយអំណាចជាវត្តមានាវិភត្តិថា គប្បីដឹងច្បាស់ថា អញដកដង្ហើមចូល គប្បីដឹងច្បាស់ថា អញដកដង្ហើមចេញប៉ុណ្ណោះ ហើយលើកព្រះបាលីឡើងដោយអំណាច ពាក្យដែលជាអនាគតកាល ដោយន័យជាដើមថា ភិក្ខុគប្បីសិក្សាថា អញនឹងដឹងច្បាស់នូវគំនរខ្យល់ទាំងពួង ដកដង្ហើមចូលដូច្នេះ ដើម្បីទ្រង់សម្ដែងអាការដែលឲ្យញាណកើតឡើងជាដើមដែលគួរធ្វើ ចាប់តាំងអំពីកាលនេះទៅ ។

បទថា **បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ ។បេ។ បស្សសិស្សាមីតិ សិក្ខតិ** សេចក្ដីថា ភិក្ខុគប្បីសិក្សាថា អញនឹងជាអ្នកស្ងប់ គឺរម្ងាប់ រំលត់ បានដល់ ឲ្យកាយសង្ខារដែលគ្រោតគ្រាតស្ងប់ទៅ ដកដង្ហើមចូល-ចេញ ។ ក្នុងពាក្យថា នឹងជាអ្នករម្ងាប់កាយសង្ខារ ដែលគ្រោតគ្រាតនោះ គប្បីជ្រាបខ្យល់ដែលជារបស់គ្រោតគ្រាត និងល្អិត និងការរម្ងាប់យ៉ាងនេះ គឺក្នុងកាលមុន គឺក្នុងវេលាដែលភិក្ខុនេះ មិនទាន់បានកំណត់កម្មដ្ឋានកាយ និងចិត្ត នៅមានសេចក្ដីក្រវល់ក្រវាយ គឺនៅគ្រោតគ្រាត កាលកាយនិងចិត្ត ដែលជារបស់គ្រោតគ្រាតមិនទាន់ស្ងប់ សូម្បីខ្យល់ដង្ហើមចូល-ចេញក៏ជារបស់គ្រោតគ្រាត គឺប្រព្រឹត្តទៅលើសកម្លាំង ប្រមុះមិនគ្រប់គ្រាន់ដកដង្ហើម ត្រូវឈរបញ្ចេញខ្យល់ដង្ហើមចូលខ្លះ ចេញខ្លះ តាមមាត់ កាលណា

កាយក្តី ចិត្តក្តី ជារបស់ដែលភិក្ខុកំណត់ហើយ កាលនោះ ទើបកាយ និង ចិត្តនោះ ជារបស់ស្ងប់រម្ងាប់ ។ កាលកាយ និងចិត្តនោះស្ងប់ហើយ ខ្យល់ដង្ហើមចូល-ចេញ រមែងប្រព្រឹត្តទៅល្អិត គឺជាសភាពដល់នូវអាការដែលនឹងត្រូវដញ្ជឹងគិតថា មាន ឬមិនមានហ្ន៎ ។ ប្រៀបដូចខ្យល់ដង្ហើមចូល-ចេញ របស់បុរសដែលរត់ចុះអំពីភ្នំ ឬបុរសដាក់របស់ធ្ងន់ចុះអំពីក្បាល ហើយឈររមែងជារបស់គ្រោតគ្រាត ច្រមុះមិនល្មមនឹងខ្យល់ត្រូវដកដង្ហើមចូលខ្លះ ចេញខ្លះតាមមាត់ តែកាលណា បុរសនោះបន្ទោបង់សេចក្តីក្រវល់ក្រវាយនោះហើយ ងូត និងផឹកទឹកហើយ យកសំពត់សើមដណ្តប់ត្រង់ទ្រូង ដេកសម្រាកក្នុងម្លប់ឈើត្រជាក់ៗ កាលនោះ ទើបខ្យល់ដង្ហើមចូល-ចេញ របស់បុរសនោះជារបស់ល្អិត គឺដល់អាការដែលនឹងត្រូវដញ្ជឹងគិតថា មាន ឬមិនមានហ្ន៎ យ៉ាងណា ក្នុងកាលមុន គឺក្នុងខណៈដែលភិក្ខុនេះ មិនទាន់បានកំណត់កម្មដ្ឋាន កាយ និងចិត្ត ។បេ។ គឺដល់នូវអាការដែលត្រូវគិតថា មាន ឬមិនមានហ្ន៎ យ៉ាងនោះដូចគ្នា ។ សេចក្តីនេះ ព្រោះហេតុអ្វី ព្រោះសេចក្តីយ៉ាងនោះ ក្នុងកាលមុន គឺក្នុងកាលដែលភិក្ខុមិនទាន់បានកំណត់កម្មដ្ឋាន ការគិត ការប្រមូលមក មនសិការ និងពិចារណាថា អញនឹងរម្ងាប់កាយសង្ខារចំណែកគ្រោត-គ្រាត ដូច្នេះ មិនមានដល់ភិក្ខុនោះឡើយ តែក្នុងកាលដែលលោកកំណត់ហើយ ទើបមាន ។ ព្រោះហេតុនោះ ក្នុងវេលាដែលកំណត់កម្មដ្ឋាន ទើបកាយ-សង្ខាររបស់ភិក្ខុនោះ ជារបស់ល្អិតជាងវេលាដែលមិនទាន់បានកំណត់ ។ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា

កាលកាយ និងចិត្តនៅរសាប់រសល់នៅឡើយ កាយសង្ខារ រមែងប្រព្រឹត្តទៅលើសប្រមាណ កាលកាយ និងចិត្តមិនរសាប់រសល់ កាយសង្ខាររមែងប្រព្រឹត្តទៅល្អិត ។

កាយសង្ខារ ក្នុងកាលកំណត់ក៏នៅគ្រោតគ្រាត ក្នុងឧបចារៈនៃបឋមជ្ឈានល្អិត ។ សូម្បីក្នុងឧបចារៈនៃបឋមជ្ឈាននោះក៏នៅគ្រោតគ្រាត ក្នុងបឋមជ្ឈានល្អិត ។ ក្នុងបឋមជ្ឈាន និងក្នុងឧបចារៈនៃទុតិយជ្ឈាននៅគ្រោតគ្រាត ក្នុងទុតិយជ្ឈានល្អិត ។ ក្នុងទុតិយជ្ឈាន និងក្នុងឧបចារៈនៃ តតិយជ្ឈានក៏នៅគ្រោតគ្រាត ក្នុងតតិយជ្ឈានល្អិត ។ ក្នុងតតិយជ្ឈាន និងឧបចារៈនៃចតុត្ថជ្ឈានក៏នៅគ្រោតគ្រាត ក្នុងចតុត្ថជ្ឈានល្អិតក្រៃលែង រហូតមិនប្រព្រឹត្តទៅនោះឯង ។ ពាក្យនេះ ជាមតិរបស់ទីឃនិកាយាចារ្យ និងសំយុត្ត-និកាយាចារ្យមុន ។ ចំណែកមជ្ឈិមកាយាចារ្យទាំងឡាយ រមែងប្រាថ្នាភាពល្អិតជាងនោះ ក្នុងឧបចារៈនៃឈានខ្ពស់ឡើងៗ ជាងឈានជាន់ទាបៗ យ៉ាងនេះ គឺកាយសង្ខារដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈាននៅជារបស់គ្រោតគ្រាត ក្នុងឧបចារៈនៃទុតិយជ្ឈាន ទើបរាប់ថា ល្អិត ដូច្នេះជាដើម ។ តាមមតិរបស់អាចារ្យទាំងឡាយនោះឯង គួរជ្រាបដូច្នេះថា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងវេលាដែលមិនទាន់បានកំណត់ ( កម្មដ្ឋាន ) រមែងរម្ងាប់ទៅក្នុងវេលាដែលកំណត់ហើយ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងវេលាដែលបានកំណត់ រមែងរម្ងាប់ទៅក្នុងឧបចារៈនៃបឋមជ្ឈាន ។បេ។ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងឧបចារៈនៃចតុត្ថជ្ឈាន រមែងរម្ងាប់ទៅក្នុងចតុត្ថជ្ឈាន ។ ក្នុងសមថៈមាន

ន័យប៉ុណ្ណោះជាបឋម ។

ចំណែកក្នុងវិបស្សនា គប្បីជ្រាបន័យដូច្នេះថា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងកាលនៅមិនទាន់បានកំណត់នៅគ្រោតគ្រាត ក្នុងការកំណត់មហាភូតរូបល្អិត សូម្បីការកំណត់មហាភូតរូបនោះក៏នៅគ្រោតគ្រាត ក្នុងការកំណត់ឧបាទាយរូបល្អិត សូម្បីការកំណត់ឧបាទាយរូបនោះក៏នៅគ្រោតគ្រាត ក្នុងការកំណត់រូបទាំងអស់ល្អិត សូម្បីការកំណត់រូបទាំងអស់នោះក៏នៅគ្រោតគ្រាត ក្នុងការកំណត់អរូបល្អិត សូម្បីការកំណត់អរូបនោះក៏នៅគ្រោតគ្រាត ក្នុងការកំណត់រូប និងអរូបល្អិត សូម្បីការកំណត់រូប និងអរូបនោះក៏នៅគ្រោតគ្រាត ក្នុងការកំណត់បច្ច័យល្អិត សូម្បីការកំណត់បច្ច័យនោះក៏នៅគ្រោតគ្រាត ក្នុងការឃើញនាមរូប ព្រមទាំងបច្ច័យល្អិត សូម្បីការឃើញនាមរូបព្រមទាំងបច្ច័យនោះក៏នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលប្រកបដោយលក្ខណៈ និងអារម្មណ៍ល្អិត សូម្បីក្នុងវិបស្សនាដែលប្រកបលក្ខណៈ និងអារម្មណ៍នោះក៏នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលមានកម្លាំងខ្សោយ ក្នុងវិបស្សនាដែលមានកម្លាំង ទើបរាប់ថាល្អិត ។ ក្នុងវិបស្សនាន័យនោះ គប្បីជ្រាបការស្ងប់ទៅនៃខ្យល់អស្សាសៈ និងបស្សាសៈមុនៗ ដោយខ្យល់អស្សាសៈ និងបស្សាសៈក្រោយៗ ដោយន័យដូចពោលហើយ ក្នុងកាលមុននោះឯង ។ ក្នុងពាក្យថា រម្ងាប់កាយសង្ខារដែលគ្រោតគ្រាតនេះ គប្បីជ្រាបភាពដែលខ្យល់គ្រោតគ្រាត និងល្អិតស្ងប់ទៅ ដោយន័យដូចពណ៌នាមកដូច្នេះឯង ។

ចំណែកក្នុងបដិសម្ភិទាមគ្គ ព្រះធម្មសេនាបតីសារីបុត្រពោលអត្ថនៃបទ

នោះ ព្រមទាំងពាក្យសួរ និងពាក្យឆ្លើយឲ្យភ្លឺច្បាស់យ៉ាងនេះថា

បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយសង្ខារ ទើបដកដង្ហើមចូល តើដូចម្ដេច ។

កាយសង្ខារ តើដូចម្ដេច ។ ពួកខ្យល់ដង្ហើមចេញវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ពួកខ្យល់ដង្ហើមចូលវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ពួកខ្យល់ដង្ហើមចេញខ្លី ដង្ហើមចូលខ្លី ឬដង្ហើមចេញ សម្រាប់បុគ្គលអ្នកកំណត់ដឹងនូវកាយទាំងពួង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ បុគ្គលកាលរម្ងាប់ រំលត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ការឱនការផ្ងាក ការទម្រេត ការឈម ការរញ្ជួយ ការអន្ទះសា ការកម្រើក ការញាប់ញ័រណានៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់ នូវកាយ-សង្ខារ ទើបដកដង្ហើមចូល ការមិនឱន ការមិនផ្ងាក ការមិនទម្រេត ការមិនឈម ការមិនរញ្ជួយ ការមិនអន្ទះសា ការមិនកម្រើក ការមិនញាប់ញ័រណា

នៃកាយដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារដ៏ល្អិតសុខុម មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថាអាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល បានឮថា បុគ្គលសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូលដោយអាការយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់មិនទាន់មាន ការប្រាកដនៃដង្ហើមចេញ និងដង្ហើមចូលក៏មិនទាន់មាន ការប្រាកដនៃអានាបានស្សតិក៏មិនទាន់មាន ទាំងការប្រាកដនៃអានាបា-នស្សតិសមាធិក៏មិនទាន់មានទេ បណ្ឌិតទាំងឡាយ រមែងមិនចូលកាន់សមាបត្តិនោះផង មិនចេញចាកសមាបត្តិនោះផង ឮថា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ក៏មាន ការប្រាកដនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលក៏មាន ការប្រាកដនៃអានាបានស្សតិក៏មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិក៏មាន ទើបបណ្ឌិតទាំងឡាយចូលកាន់សមាបត្តិនោះផង ចេញចាកសមាបត្តិនោះផង ដំណើរនោះប្រៀបដូចជាអ្វី ប្រៀបដូចជារគាំងដែលគេគោះ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃសំឡេងដ៏គ្រោតគ្រាត កាលបើសំឡេងគ្រោតគ្រាតរលត់ហើយ បន្ទាប់

មក សំឡេងដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃសំឡេងដ៏ល្អិត កាលសំឡេងដ៏ល្អិតរលត់ហើយ បន្ទាប់មក ចិត្តក៏រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះចិត្តមាននិមិត្តដ៏ល្អិតជាអារម្មណ៍ មានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជាខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាត កាលបើខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាតរលត់ហើយ បន្ទាប់មក ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត កាលបើខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិតរលត់ហើយ បន្ទាប់មក ចិត្តក៏មិនដល់នូវសេចក្ដីរាយមាយក្នុងកាលខាងក្រោយ ព្រោះចិត្តយកនិមិត្តនៃខ្យល់ដង្ហើមចេញ និងដង្ហើមចូលដ៏ល្អិតជាអារម្មណ៍ក៏យ៉ាងនោះដែរ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ក៏មាន ការប្រាកដនៃខ្យល់ដង្ហើមចេញ និងដង្ហើមចូលក៏មាន ការប្រាកដនៃអានាបានស្សតិក៏មាន ការប្រាកដនៃអានាបានស្សតិសមាធិក៏មាន បណ្ឌិតទាំងឡាយ រមែងចូលកាន់សមាបត្តិនោះផង រមែងចេញចាកសមាបត្តិនោះផង កាយ គឺខ្យល់ដង្ហើមចេញ និងដង្ហើមចូលរបស់បុគ្គល កាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថា ឧបដ្ឋាន ។ សតិ ឈ្មោះថា អនុបស្សនាញាណ

កាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថា សតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលរមែងពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះ លោកពោលថា កាយេកាយានុបស្សនាសតិប្បដ្ឋានភាវនា គឺ ការពិចារណា ដូច្នេះ ។

ក្នុងបទថា **បស្សម្ភយំ កាយសង្ខារំ** នេះ មានការពណ៌នាតាមលំដាប់បទនៃបឋមចតុក្កៈ ដែលត្រាស់ទុកដោយអំណាចនៃកាយានុបស្សនាត្រឹមតែប៉ុណ្ណេះសិន ។ តែព្រោះក្នុងអធិការនេះ ចតុក្កៈនេះប៉ុណ្ណោះ ត្រាស់ទុកដោយអំណាចនៃកម្មដ្ឋានរបស់កុលបុត្រដែលផ្តើមធ្វើ ។

ចំណែក ៣ ចតុក្កៈទៀតក្រៅអំពីនេះ ត្រាស់ទុកដោយអំណាចវេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនារបស់កុលបុត្រ ដែលសម្រេចឈានហើយក្នុងបឋមចតុក្កៈនេះ ដូច្នោះ ពុទ្ធបុត្រអ្នកប្រាថ្នានឹងចម្រើនកម្មដ្ឋាននេះហើយ សម្រេចព្រះអរហត្ត មួយអន្លើនឹងបដិសម្ភិទាដោយវិបស្សនាដែលមានអានាបានចតុត្ថជ្ឈានជាបទដ្ឋាន គួរជ្រាបកិច្ចដែលខ្លួនគួរធ្វើមុនទាំងអស់តាំងអំពីដើម ក្នុងអធិការនៃអានាបានស្សតិកម្មដ្ឋាននេះឯង ដោយអំណាចនៃកុលបុត្រអ្នកផ្តើមបំពេញ ។

## កុលបុត្រអ្នករៀនកម្មដ្ឋាន ត្រូវធ្វើសីលឱ្យបរិសុទ្ធសិន

កុលបុត្រគួរជម្រះសីល ៤ ឲ្យបរិសុទ្ធជាមុន ។ ក្នុងសីលនោះ មានវិធីជម្រះឲ្យបរិសុទ្ធ ៣ យ៉ាង គឺមិនត្រូវអាបត្តិ ១ ចេញអំពីអាបត្តិដែលត្រូវហើយ ១ មិនសៅហ្មងដោយកិលេសទាំងឡាយ ១ ។ ពិតហើយ ភាវនា

រមែងសម្រេចដល់កុលបុត្រអ្នកមានសីលបរិសុទ្ធយ៉ាងនោះ ។ កុលបុត្រគួរបំពេញក្នុងសីលដែលលោកហៅថា អភិសមាចារិកសីល ឲ្យបរិបូណ៌ជាមុនសិន ដោយអំណាចវត្តទាំងនេះ គឺចេតិយង្គណវត្ត ពោធិយង្គណវត្ត ឧបជ្ឈាយវត្ត អាចរិយវត្ត ជន្តាឃរវត្ត ( វត្តក្នុងរោងភ្លើង ) ឧបោសថាគារវត្ត ខន្ធកវត្ត ៨២ មហាវត្ត ១៤ ។ ពិតហើយ កុលបុត្រណា គប្បីពោលថា អញកំពុងរក្សាសីល កម្មដោយអភិសមាចារិកវត្ត នឹងមានប្រយោជន៍អ្វី ប្រការដែលសីលរបស់កុលបុត្រនឹងបរិបូណ៌បាននោះ មិនមែនជាឋានៈដែលនឹងមានបាន ។ តែកាលអភិសមាចារិកវត្តបរិបូណ៌ សីលក៏បរិបូណ៌ ។ កាលសីលបរិបូណ៌ សមាធិរមែងកាន់យកបន្ទប់ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ប្រព្រឹត្តមិនស្មើក្នុងពួកសព្រហ្មចារីបុគ្គលសោះ នឹងបំពេញអភិសមាចារិកធម៌បាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញអភិសមាចារិកធម៌ហើយ នឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះរមែងមិនមានទេ បើមិនបានបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលក្ខន្ធបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញសីលក្ខន្ធហើយ នឹងបំពេញសមាធិក្ខន្ធបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបានបំពេញសមាធិក្ខន្ធហើយ នឹងបំពេញបញ្ញាខន្ធបាន ហេតុនុ៎ះ រមែងមិនមានទេ រឿងនេះគួរឲ្យពិស្តារ ។ ព្រោះហេតុដូច្នោះ កុលបុត្រនេះ គួរបំពេញវត្ត មានចេតិយង្គណវត្តជាដើម ដែលលោកហៅថា អភិសមាចារិកវត្តឲ្យបរិបូណ៌ដោយល្អជាមុនសិន ខាង

មុខអំពីការជម្រះសីលឲ្យបរិសុទ្ធនោះ ក៏គួរកាត់បលិពោធ ( ការកង្វល់ ) ឯណានីមួយដែលមាន ក្នុងបណ្ដាបលិពោធ ១០ ដែលអាចារ្យទាំងឡាយពោលយ៉ាងនេះថា

បលិពោធ ១០ យ៉ាងនោះ គឺអាវាស ១ ត្រកូល ១ លាភ ១ គណៈ ១ ការងារជាគម្រប់ប្រាំ ១ អទ្ធាន ( គឺការដើរផ្លូវឆ្ងាយ ) ១ ញាតិ ១ អាពាធ ១ គន្ថៈ ( គឺការរៀនបរិយត្តិ ) ១ ឥទ្ធិឫទ្ធិ ១ ។ កុលបុត្រដែលកាត់បលិពោធបានយ៉ាងនេះហើយ ទើបគួររៀនកម្មដ្ឋាន ។

## កម្មដ្ឋាន ២ យ៉ាង

កម្មដ្ឋាននេះ មាន ២ យ៉ាង គឺសព្វត្ថកម្មដ្ឋាន ១ បារិហារិយកម្មដ្ឋាន ១ ។

បណ្ដាកម្មដ្ឋាន ២ យ៉ាងនោះ ដែលឈ្មោះថា សព្វត្ថកម្មដ្ឋាន បានដល់ មេត្តាក្នុងពួកភិក្ខុជាដើម និងមរណស្សតិ ។ អាចារ្យមួយពួកពោលថា អសុភសញ្ញាក៏មាន ។ ពិតហើយ ភិក្ខុអ្នកចម្រើនកម្មដ្ឋានដំបូង ត្រូវកាត់បលិពោធជាមុន ហើយសឹមចម្រើនមេត្តាទៅក្នុងពួកភិក្ខុ ដែលនៅក្នុងសីមាលំដាប់នោះ គប្បីចម្រើនទៅក្នុងពួកទេវតា ដែលនៅក្នុងសីមា បន្ទាប់អំពីនោះ គប្បីចម្រើនទៅក្នុងឥស្សរជន ក្នុងគោចរគ្រាម បន្ទាប់អំពីនោះ គប្បីចម្រើនទៅក្នុងសព្វសត្វ រហូតដល់អ្នកស្រុក ក្នុងគោចរគ្រាមនោះ ។ ពិតហើយ ភិក្ខុនោះ ធ្វើពួកជនដែលនៅរួមគ្នាឲ្យកើតមានចិត្តទន់ភ្លន់ ព្រោះមេត្តាក្នុងពួកភិក្ខុ ។ វេលានោះ លោកនឹងមានការនៅជាសុខ ។ លោករមែងជា

បុគ្គលដែលពួកទេវតាមានចិត្តទោរទន់ ព្រោះមេត្តាក្នុងពួកទេវតា ដែលនៅក្នុងសីមាធ្វើការរក្សាយ៉ាងល្អ ដោយការរក្សាដែលត្រូវតាមធម៌ ។ សូម្បីបុគ្គលដែលជាឥស្សរជនទាំងឡាយ ដែលមានចិត្តសន្តានទន់ភ្លន់ ព្រោះមេត្តាក្នុងឥស្សរជន ក្នុងគោចរគ្រាម និងធ្វើការរក្សាការពារយ៉ាងល្អ ដោយការរក្សាដែលត្រូវតាមធម៌ និងជាបុគ្គលដែលអ្នកស្រុកទាំងនោះ មានចិត្តត្រូវអប់រំឲ្យជ្រះថ្លា ព្រោះមេត្តាក្នុងពួកអ្នកស្រុក ក្នុងគោចរគ្រាមនោះ មិនមើលងាយត្រាច់ទៅ ។ ជាអ្នកត្រាច់ទៅ មិនត្រូវបុគ្គលណាមួយបៀតបៀនក្នុងទីគ្រប់កន្លែង ព្រោះមេត្តាក្នុងសព្វសត្វ ។ម្យ៉ាងទៀត ភិក្ខុកាលគិតថា អញនឹងត្រូវស្លាប់ពិត ដោយមរណស្សតិ លះការស្វែងរកដែលមិនសមគួរចោល ជាអ្នកមានសេចក្ដីសង្វេគ ចម្រើនខ្ពស់ឡើងជាលំដាប់ រមែងជាបុគ្គលមានការប្រព្រឹត្តមិនធូរថយ ។ តណ្ហារមែងមិនកើតឡើង សូម្បីក្នុងអារម្មណ៍ដែលជាទិព្វ ព្រោះអសុភសញ្ញា ។ ព្រោះហេតុនោះ គុណធម៌ទាំង ៣ ( គឺមេត្តា ១ មរណស្សតិ ១ អសុភសញ្ញា ១ ) នោះ របស់ភិក្ខុនោះ លោកហៅថា សព្វត្ថកម្មដ្ឋាន ព្រោះអធិប្បាយថា ជាកម្មដ្ឋានដែលកុលបុត្រគប្បីប្រាថ្នា គឺគប្បីត្រូវការក្នុងទីគ្រប់កន្លែង ព្រោះជាធម៌មានឧបការៈច្រើន និងព្រោះជាបទដ្ឋាននៃការតាមប្រកបរឿយៗ នូវសេចក្ដីព្យាយាម តាមដែលបំណងដោយន័យដូចពណ៌នាមក ដូច្នេះ ។

បណ្ដាអារម្មណ៍ ៣៨ ប្រការ កម្មដ្ឋានណាដែលអនុលោមតាមចរិតនៃកុលបុត្រណា កម្មដ្ឋាននោះ លោកហៅថា បារិហារិយកម្មដ្ឋាន ព្រោះជាកម្ម-

ដ្ឋានដែលកុលបុត្រនោះ គួរបរិហារជានិច្ច ដោយន័យតាមដែលពោល ហើយនោះឯង តែក្នុងតតិយបារាជិកនេះ អានាបានកម្មដ្ឋាននេះឯង លោកហៅថា បារិហារិយកម្មដ្ឋាន ។ ក្នុងអធិការពោលដោយអានាបានកម្មដ្ឋាននេះ មានសេចក្ដីសង្ខេបប៉ុណ្ណោះ ។ ចំណែកសេចក្ដីពិស្ដារ អ្នកសិក្សាដែលត្រូវការកថាពោលដោយការជម្រះសីលឲ្យបរិសុទ្ធ និងកថាពោលដោយលះបលិពោធគប្បីកាន់យកអំពីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គចុះ ។

ម្យ៉ាងទៀត កុលបុត្រដែលមានសីលបរិសុទ្ធ និងលះបលិពោធបានហើយយ៉ាងនោះ កាលនឹងរៀនកម្មដ្ឋាននេះ គួររៀនយកក្នុងសម្នាក់ពុទ្ធបុត្រដែលឲ្យចតុត្ថជ្ឈានកើតឡើង ដោយកម្មដ្ឋាននេះឯង ហើយចម្រើនវិបស្សនាបានសម្រេចភាពជាព្រះអរហន្ត ។ បើមិនបានព្រះខីណាស្រពនោះ គួររៀនយកក្នុងសម្នាក់ព្រះអនាគាមី កាលមិនបានក្នុងព្រះអនាគាមីនោះ ក៏គួររៀនយកក្នុងសម្នាក់ព្រះសកទាគាមី បើមិនបានព្រះសកទាគាមីនោះ ក៏គួររៀនយកក្នុងសម្នាក់ព្រះសោតាបន្ន កាលមិនបានក្នុងព្រះសោតាបន្ននោះ ក៏គួររៀនយកក្នុងសម្នាក់របស់លោកអ្នកបានចតុត្ថជ្ឈាន ដែលមានអានាបានជាអារម្មណ៍ បើមិនមានលោកអ្នកបានចតុត្ថជ្ឈាននោះ ក៏គួររៀនយកក្នុងសម្នាក់របស់វិនិច្ឆយាចារ្យ ដែលមិនលះបង់បាលី និងអដ្ឋកថា ។ ពិតហើយ ព្រះអរិយ-បុគ្គលទាំងឡាយ មានព្រះអរហន្តជាដើម រមែងប្រាប់ចំពោះមគ្គ ដែលខ្លួនបានសម្រេចហើយប៉ុណ្ណោះ ។ ចំណែកវិនិច្ឆយាចារ្យនេះ ជាអ្នកមិនឡេះឡោះកំណត់អារម្មណ៍ដែលជាទីសប្បាយ និងមិនសប្បាយ ក្នុងអារម្មណ៍ទាំងពួង

ហើយទើបប្រាប់ ដូចអ្នកនាំទៅកាន់ផ្លូវដ៏រីធំ ក្នុងទីព្រៃស្តុកដូច្នោះ ។

## កម្មដ្ឋានមានសន្ធិ ៥ យ៉ាង

ក្នុងអធិការពោលដោយការរៀនកម្មដ្ឋាននោះ មានអនុបុព្វិកថាដូចតទៅ ភិក្ខុនោះ គួរជាអ្នកមានការប្រព្រឹត្តស្រោល សម្បូរដោយវិន័យ និងមារយាទ ចូលទៅរកអាចារ្យដែលមានប្រការដូចពោលហើយ គប្បីរៀនកម្មដ្ឋាន មានសន្ធិ ៥ ក្នុងសម្នាក់របស់អាចារ្យនោះ អ្នកមានចិត្តដែលខ្លួនឲ្យត្រេកអរដោយវត្ត និងបដិបទា ។ ក្នុងពាក្យថា កម្មដ្ឋានមានសន្ធិ ៥ នោះ សន្ធិមាន ៥ យ៉ាងនេះ គឺ **ឧគ្គហា** ការរៀន ១ **បរិបុច្ឆា** ការសាកសួរ ១ **ឧបដ្ឋាន** ការប្រាកដ ១ **អប្បនា** ការចុះស៊ប់ ១ **លក្ខណា:** ការកំណត់ចំណាំ ១ ។

ក្នុងឧគ្គហ:ជាដើមនោះ ការរៀនកម្មដ្ឋាន ឈ្មោះថា ឧគ្គហ: ការសាកសួរកម្មដ្ឋាន ឈ្មោះថា បរិបុច្ឆា ។ ការប្រាកដនៃកម្មដ្ឋាន ឈ្មោះថា ឧបដ្ឋាន ។ ការចុះស៊ប់នៃកម្មដ្ឋាន ឈ្មោះថា អប្បនា ។ លក្ខណ:នៃកម្មដ្ឋាន ឈ្មោះថា លក្ខណ: ។ មានពាក្យអធិប្បាយថា ការពិចារណានៃសភាវកម្មដ្ឋានថា កម្មដ្ឋាននេះ មានលក្ខណ:យ៉ាងនេះ ។ ភិក្ខុកាលរៀនកម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាងនេះ ខ្លួនឯងក៏មិនលំបាក ទាំងមិនត្រូវបៀតបៀនអាចារ្យឲ្យលំបាកផង ព្រោះដូច្នោះ គួរប្រាប់អាចារ្យឲ្យបង្រៀនតែបន្តិចបន្តួច ស្វាធ្យាយអស់វេលាដ៏ច្រើន កាលរៀនកម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាងនោះហើយ បើក្នុងអាវាសនោះមានសេនាសន:ជាដើម ជាទីសប្បាយសោត គួរនៅក្នុងអាវាសនោះឯង បើក្នុងអាវាសនោះ មិនមានសេនាសន:ជាទីសប្បាយសោត គួរ

លាអាចារ្យ បើជាអ្នកមានបញ្ញាទន់ខ្សោយ គួរទៅចម្ងាយមួយយោជន៍ យ៉ាងឆ្ងាយ បើជាអ្នកមានបញ្ញាចាស់ក្លា ក៏គួរទៅឆ្ងាយ ( ជាងនោះ ) បាន ហើយចូលទៅកាន់សេនាសនៈ ដែលប្រកបដោយអង្គ ៥ វៀរសេនាសនៈ ដែលមានទោស ១៨ យ៉ាង ហើយស្នាក់នៅក្នុងសេនាសនៈនោះ លះ បលិពោធ ១០ ចោល ឆាន់កត្តាហារស្រេចហើយ បន្ទោបង់សេចក្តីស្រវឹង ក្នុងអាហារ ធ្វើចិត្តឲ្យក្លៀវក្លា ដោយការអនុស្សរណៈដល់គុណព្រះរតនត្រ័យ មិនភ្លេចកម្មដ្ឋានសូម្បីមួយបទ ដែលរៀនយកអំពីអាចារ្យ គប្បីមនសិការ អានាបានស្សតិកម្មដ្ឋាននេះ ។ ក្នុងវិស័យនៃតតិយបារាជិកនេះ មានសេចក្តី សង្ខេបប្រមាណប៉ុណ្ណេះ ។ ឯសេចក្តីពិស្តារ អ្នកសិក្សាដែលត្រូវការកថាមគ្គ នេះ គប្បីកាន់យកក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គចុះ ។

## វិធីមនសិការអានាបានស្សតិកម្មដ្ឋាន ៨ យ៉ាង

ក្នុងពាក្យដែលខ្ញុំពោលថា គប្បីមនសិការអានាបានស្សតិកម្មដ្ឋាននេះ មានមនសិការវិធីដូចតទៅនេះថា ការរាប់ ការតាមចង ការពាល់ត្រូវ ការ ឈប់ ការកំណត់ ការផ្លាស់ប្តូរ ការបរិសុទ្ធ និងការឃើញធម៌ទាំងនោះជាក់ ច្បាស់ ។

ការរាប់នោះឯង ឈ្មោះថា **គណនា** ។ ការកំណត់តាមទៅ ឈ្មោះថា **អនុពន្ធនា** ។ ឋានដែលខ្យល់ពាល់ត្រូវ ឈ្មោះថា **ផុសនា** ។ ការតាំងមាំ ឈ្មោះថា **ឋបនា** ។ ការឃើញច្បាស់ ឈ្មោះថា **សល្លក្ខណា** ។ មគ្គ ឈ្មោះថា **វិវដ្ដនា** ។ ផល ឈ្មោះថា **បារិសុទ្ធិ** ។ ការពិចារណា ឈ្មោះថា

តេសញ្ច បដិបស្សទ្ធា។

# អធិប្បាយ គណនាវិធី

បណ្ដាមនសិការវិធី មានការរាប់ជាដើមនោះ កុលបុត្រអ្នកផ្ដើមបំពេញនេះ គួរមនសិការកម្មដ្ឋាននេះ ដោយការរាប់ជាបឋម ។ កាលនឹងរាប់ មិនគួរឈប់រាប់ក្រោម ៥ មិនគួររាប់ឲ្យលើសជាង ១០ មិនគួរសម្ដែង ( ការរាប់ ) ឲ្យដាច់ក្នុងចន្លោះ ព្រោះកាលឈប់រាប់ទាបជាង ៥ ចិត្តុប្បាទ រមែងជ្រួលច្របល់ក្នុងឱកាសចង្អៀត ដូចហ្វូងគោដែលប្រមូលឃាំងទុកក្នុងក្រោលដែលចង្អៀត ដូច្នោះ ។ កាលរាប់លើសជាង ១០ ទៅ ចិត្តុប្បាទក៏រវល់នៅដោយការរាប់ប៉ុណ្ណោះ ។ ដើម្បីសម្ដែង ( ការរាប់ ) ឲ្យដាច់ក្នុងចន្លោះ ចិត្តរមែងកម្រើកទៅថា កម្មដ្ឋានរបស់អញដល់ទីបំផុតឬអត់ហ្ន៎ ។ ព្រោះដូច្នោះត្រូវវៀរទោសទាំងនេះចេញហើយ សឹមរាប់ ។ កាលនឹងរាប់ ដំបូង គួររាប់ដោយវិធីរាប់យឺតៗ គឺរាប់ដូចវិធីមនុស្សវាល់ស្រូវ ។ ពិតហើយ អ្នកវាល់ស្រូវ វាល់ពេញនាឡិហើយ ប្រាប់ថា ១ ទើបចាក់ចុះ កាលវាល់ពេញទៀតជួបសំរាមឯណានីមួយ រើសចោលហើយ ទើបប្រាប់ថា ១-១ ។ ក្នុងពាក្យថា ២-២ ជាដើមក៏មានន័យនេះ ។ កុលបុត្រនេះក៏យ៉ាងនោះដូចគ្នា បណ្ដាខ្យល់ដង្ហើមចូល-ចេញ ចំណែកណាប្រាកដ គប្បីចាប់យកចំណែកនោះហើយគប្បីកំណត់ខ្យល់ដែលកំពុងចូងទៅៗ តាំងអំពីដើមថា ១-១ ទៅ រហូតដល់ ១០-១០ កាលកុលបុត្រនោះរាប់ដោយវិធីយ៉ាងនេះ ខ្យល់អស្សាសៈបស្សាសៈដែលកំពុងចូងចេញ និងចូងចូល រមែងប្រាកដ ។

លំដាប់នោះ កុលបុត្រនេះ គួរលះវិធីរាប់យឺតៗ គឺរាប់ដូចវិធីអ្នកវាល់ស្រូវនោះចោល ហើយគប្បីរាប់ដោយវិធីរហ័សៗ គឺរាប់ដូចវិធីនាយគោបាលពិតហើយ នាយគោបាលអ្នកឈ្លាស យកដុំក្រួសដាក់ថ្នក់ ដៃកាន់ខ្សែ និងឈើរំពាត់ ទៅកាន់ក្រោលអំពីព្រលឹម វាយគោត្រង់ខ្នងហើយ អង្គុយលើសសរសេទ្រូះក្រោល រាប់មេគោដែលមកដល់ទ្វារហើយ ហើយដាក់ដុំក្រួសចុះទៅថា ១-២ ជាដើម ហ្វូងគោដែលនៅលំបាកក្នុងឱកាសដែលចង្អៀត អស់កាលរាត្រី ៣ យាម កាលចេញ ( អំពីក្រោល ) ប្រជ្រៀតគ្នានឹងគ្នាប្រញាប់ចេញជាក្រុមៗ ។ នាយគោបាលនោះ រមែងរាប់យ៉ាងរហ័សនោះឯងថា ៣-៤-៥-១០ ជាដើម ។ សូម្បីកុលបុត្រនេះ រាប់ដោយន័យមុន ដូចពោលមកហើយយ៉ាងនេះ ខ្យល់អស្សាសៈ និងបស្សាសៈ រមែងសញ្ចរទៅមកយ៉ាងរហ័ស ។ លំដាប់នោះ កិក្ខុដឹងថា ខ្យល់អស្សាសៈ និងបស្សាសៈ រមែងសញ្ចរទៅមកយ៉ាងរហ័ស ហើយមិនកាន់យកខ្យល់ខាងក្នុង និងខ្យល់ខាងក្រៅ គប្បីកំណត់ចំពោះខ្យល់ដែលមកដល់ប្រហោងប៉ុណ្ណោះ រាប់យ៉ាងរហ័សនោះឯងថា ១-២-៣-៤-៥ ។ ១-២-៣-៤-៥-៦ ។ ១-២-៣-៤-៥-៦-៧ ។ ១-២-៣-៤-៥-៦-៧-៨ ។ ១-២-៣-៤-៥-៦-៧-៨-៩ ។ ១-២-៣-៤-៥-៦-៧-៨-៩-១០ ។

ព្រោះថា ក្នុងកម្មដ្ឋានដែលទាក់ទងដោយការរាប់ ចិត្តរមែងមានអារម្មណ៍មួយបាន ដោយកម្លាំងនៃការរាប់ប៉ុណ្ណោះ ដូចការបតទូកទុកក្នុងក្រសែទឹកហូរខ្លាំង ដោយអំណាចការយកថ្នោលទប់ ដូច្នោះ ។ កាលលោករាប់រហ័សៗ

យ៉ាងនេះ កម្មដ្ឋានរមែងប្រាកដ ដូចជាដំណើរទៅមិនដាច់ខ្សែ ។ វេលានោះ កាលភិក្ខុដឹងថា កម្មដ្ឋានដំណើរទៅមិនដាច់ខ្សែហើយ កុំកំណត់ខាងក្នុង និងខាងក្រៅ គប្បីរាប់រហ័សៗ តាមន័យមុននោះឯង ។ កាលលោកបញ្ជូនចិត្តចូលទៅព្រមគ្នានឹងខ្យល់ ដែលចូលទៅខាងក្នុង ឋានខាងក្នុងត្រូវខ្យល់ប៉ះខ្ទប់ហើយ រមែងហាក់ដូចជាពេញដោយខ្លាញ់ខាប់ ដូច្នោះ ។ កាលនាំចិត្តចេញមកព្រមជាមួយខ្យល់ដែលចេញមកខាងក្រៅ ចិត្តរមែងផ្សាយទៅក្នុងអារម្មណ៍យ៉ាងច្រើនខាងក្រៅ តែការនោះរមែងសម្រេចដល់អ្នកតាំងសតិទុកក្នុងឱកាសដែលខ្យល់ពាល់ត្រូវកំពុងចម្រើនប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបខ្ញុំពោលថា កុំកំណត់ខ្យល់ទាំងខាងក្នុង និងខាងក្រៅ គប្បីរាប់រហ័សៗ តាមន័យមុននោះឯង ។

សួរថា នឹងគប្បីរាប់ខ្យល់អស្សាសៈ និងបស្សាសៈនោះយូរប៉ុនណា ឆ្លើយថា គប្បីរាប់ទៅរហូតទាល់តែសតិវៀរចាកការរាប់ និងតាំងមាំនៅក្នុងអារម្មណ៍ គឺខ្យល់អស្សាសៈ និងបស្សាសៈ ។ ព្រោះថា ការរាប់ក៏ដើម្បីកាត់វិតក្កៈដែលស្ទុះទៅខាងក្រៅនោះឯង ហើយតម្កល់សតិទុកក្នុងអារម្មណ៍ គឺខ្យល់អស្សាសៈ និងបស្សាសៈប៉ុណ្ណោះ ។

## អធិប្បាយ ខាងដើម កណ្តាល និងខាងចុង

ព្រះយោគាវចរ កាលមនសិការដោយការរាប់យ៉ាងនោះហើយ គប្បីមនសិការដោយការតាមចង ។ កិរិយាដែលឈប់សម្រាកការរាប់ ហើយបញ្ជូនសតិទៅតាមខ្យល់អស្សាសៈ និងបស្សាសៈជាប់តគ្នាទៅ ឈ្មោះថា

ការតាមចង ។ ឯការបញ្ជូនសតិទៅតាមនោះ មិនមែនដោយអំណាចការទៅតាមខាងដើម កណ្ដាល និងខាងចុង ( នៃខ្យល់អស្សាសៈ ) ឡើយ ។ ពិតហើយ នាភី ( ផ្ចិត ) ជាខាងដើមនៃខ្យល់ដង្ហើមចេញទៅខាងក្រៅ ហទយៈ ( បេះដូង ) ជាកណ្ដាល នាសិក ( ច្រមុះ ) ជាខាងចុង ចុងច្រមុះជាខាងដើមនៃខ្យល់ចូលទៅខាងក្នុង ហទយៈជាកណ្ដាល នាភីជាខាងចុង ។ កាលព្រះយោគាវចរនោះទៅតាមខាងដើម កណ្ដាល និងខាងចុង ( នៃខ្យល់អស្សាសៈ និងបស្សាសៈ ) នោះ ចិត្តដែលដល់នូវការរាយមាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីក្រវល់ក្រវាយ និងដើម្បីការញាប់ញ័រ ។ ដូចព្រះធម្មសេនាបតីសារីបុត្រពោលថា កាលភិក្ខុផ្ចង់ស្មារតីទៅ កាន់ខ្យល់ដកដង្ហើមចេញ ខាងដើម កណ្ដាល និងខាងចុង កាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្នុង កាលភិក្ខុផ្ចង់ស្មារតីទៅ កាន់ខ្យល់ដកដង្ហើមចូល ខាងដើម កណ្ដាល និងខាងចុង កាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្ត ដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ ។ ព្រោះដូច្នោះ ព្រះយោគាវចរកាលមនសិការដោយការតាមចង មិនគប្បីមនសិការដោយអំណាចខាងដើម កណ្ដាល និងខាងចុង យ៉ាងទៀត គប្បីមនសិការដោយអំណាចការពាល់ត្រូវ និងដោយអំណាចការឈប់ ព្រោះថា មិនមានការធ្វើមនសិការមួយផ្នែក ដោយអំណាចនៃការពាល់ត្រូវ និងការឈប់ ដូចគ្នាដោយអំណាចនៃការរាប់ និងការតាមចងឡើយ ។ តែព្រះយោគាវចរ

កាលកំពុងរាប់ក្នុងឋានដែលខ្យល់ពាល់ត្រូវហើយនោះឯង ឈ្មោះថា មនសិការដោយការរាប់ និងការពាល់ត្រូវ ព្រះយោគាវចរកាលបញ្ឈប់ការរាប់ក្នុងឋានដែលខ្យល់ពាល់ត្រូវហើយនោះឯង ប្រើសតិតាមចងខ្យល់អស្សាសៈ និងបស្សាសៈនោះ និងតាំងចិត្តទុកដោយអំណាចអប្បនា លោកហៅថា មនសិការដោយការតាមចង ការពាល់ត្រូវ និងការបញ្ឈប់ ។ អត្ថនេះគប្បីជ្រាបដោយការឧបមា ដូចនាយខ្វិន និងអ្នករក្សាទ្វារ ដែលពោលទុកក្នុងអដ្ឋកថា និងដោយការឧបមាដូចរណា ដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងបដិសម្ភិទាមគ្គ ។

បណ្ដាឧបមា ៣ នោះ ការឧបមាដូចមនុស្សខ្វិនយោលទោង មានឧបមាដូច្នេះថា ប្រៀបដូចមនុស្សខ្វិនយោលទោងឲ្យដល់មាតា និងបុត្រដែលកំពុងជិះទោង ហើយអង្គុយត្រង់គល់សសរទោងក្នុងទីនោះឯង កាលក្ដារទោងយោលទៅដោយលំដាប់ រមែងឃើញទីបំផុតទាំងសងខាង និងត្រង់កណ្ដាល តែមិនបានខ្វល់ខ្វាយដើម្បីនឹងមើលទីបំផុតទាំងសងខាង និងត្រង់កណ្ដាល យ៉ាងណា ភិក្ខុនេះក៏យ៉ាងនោះដូចគ្នា ឈរត្រង់ទីជិតគល់សសរដែលចូលទៅចងទុកដោយអំណាចសតិ ហើយយោលទោង គឺខ្យល់ដង្ហើមចូល-ចេញ អង្គុយនៅដោយសតិ ក្នុងនិមិត្តនោះឯង បញ្ជូនសតិទៅតាមខាងដើម កណ្ដាល និងខាងចុងនៃខ្យល់ដង្ហើមចូល-ចេញ ក្នុងឋានដែលខ្យល់ពាល់ត្រូវហើយ ទើបបក់ជូនមក និងជូនទៅដោយលំដាប់ ហើយតាំងសតិជាកណ្ដាលទុកក្នុងនិមិត្តនោះ មិនខ្វល់ខ្វាយដើម្បីនឹងមើលខ្យល់ទាំងនោះ ។

នេះជាការឧបមាដូចមនុស្សខ្វិន ។

ចំណែកឧបមាដូចមនុស្សរក្សាទ្វារ មានដូចតទៅនេះថា អ្នករក្សាទ្វារ នឹងមិនពិនិត្យពិច័យបុរសទាំងឡាយ ទាំងខាងក្នុង និងខាងក្រៅនគរថា លោកជានរណា មកអំពីណា នឹងទៅណា ឬក្នុងដៃរបស់លោកមានអ្វី សេចក្ដីពិតពួកមនុស្សដើរទៅទាំងខាងក្នុង និងខាងក្រៅព្រះនគរទាំងនោះ មិនមែនកិច្ចរបស់ឆ្មាំទ្វារនោះ តែឆ្មាំទ្វាររមែងពិនិត្យពិច័យចំពោះបុគ្គលអ្នកមកដល់ទ្វារហើយប៉ុណ្ណោះ សេចក្ដីនេះយ៉ាងណា ខ្យល់ដែលចូលទៅខាងក្នុង និងខ្យល់ដែលចេញទៅខាងក្រៅ រមែងមិនជាកិច្ចរបស់ភិក្ខុនេះដូច្នោះដូចគ្នា នឹងជាកិច្ចចំពោះតែខ្យល់ដែលមកដល់ប្រហោងហើយប៉ុណ្ណោះ នេះជាឧបមាដូចអ្នករក្សាទ្វារ ។

ចំណែកឧបមាដូចរណា គួរជ្រាបតាំងអំពីដើមទៅ ។ សមដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលថា

> កាលបុគ្គលមិនស្គាល់ នូវអនារម្មណ៍របស់ចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺនិមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងមិនបាន កាលបុគ្គលដឹង នូវអនារម្មណ៍នៃចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺនិមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងបាន ។

សួរថា ធម៌ ៣ ប្រការនេះ នឹងមិនជាអារម្មណ៍នៃចិត្ត ១ ដួង ហើយធម៌ ៣ ប្រការនេះនឹងមិនប្រាកដក៏ទេ ចិត្តនឹងមិនដល់នូវការរាយមាយ បធាន

( សេចក្តីព្យាយាម ) រមែងប្រាកដ ឯព្រះយោគាវចរនឹងធ្វើប្រយោគឲ្យសម្រេច បានត្រាស់ដឹងគុណវិសេសដូចម្តេច ធ្វើយថា ប្រៀបដូចដើមឈើដែលគេទុកលើផ្ទៃដីដែលរាបស្មើ បុរសយករណាអារដើមឈើនោះ សតិរបស់បុរសរមែងប្រាកដដោយអំណាចនៃធ្មេញរណា ដែលពាល់ត្រូវឈើ ហើយបុរសនោះរមែងមិនដាក់ចិត្តដល់ធ្មេញរណា ដែលហួសទៅ ឬហួសមក ទាំងធ្មេញរណាដែលហួសទៅ ឬហួសមក នឹងមិនប្រាកដក៏ទេ បធាន ( គឺការព្យាយាមក្នុងការកាត់ដើមឈើ ) រមែងប្រាកដ ហើយបុរសនោះ រមែងឲ្យប្រយោគ ( គឺកិរិយាដែលកាត់ដើមឈើនោះ ) សម្រេចបាន ។ និមិត្ត គឺសតិជាគ្រឿងចូលទៅចងទុក ប្រៀបដូចដើមឈើដែលគេដាក់លើទីរាបស្មើ ខ្យល់ដង្ហើមចូល-ចេញ ប្រៀបដូចធ្មេញរណា ។ ភិក្ខុនោះតាំងសតិទុកមាំត្រង់ចុងច្រមុះ ឬត្រង់បបូរមាត់ រមែងមិនដាក់ចិត្តដល់ខ្យល់ដង្ហើមចូល-ចេញ ដែលហួសទៅ ឬហួសមក ខ្យល់ដង្ហើមចូល-ចេញ ដែលចូលមក ឬចូលទៅ នឹងមិនប្រាកដក៏ទេ បធាន រមែងប្រាកដ ហើយភិក្ខុនោះ រមែងឲ្យប្រយោគសម្រេចបានផង បាននូវគុណវិសេសផង ដូចបុរសតាំងសតិទុក ដោយអំណាចនៃធ្មេញរណា ដែលពាល់ត្រូវដើមឈើ គេរមែងមិនបានដាក់ចិត្តដល់ធ្មេញរណា ដែលហួសមក ឬហួសទៅ ទាំងធ្មេញរណាដែលហួសមក ឬហួសទៅ មិនប្រាកដក៏ទេ បធាន គឺការព្យាយាមរមែងប្រាកដ ហើយបុរសនោះ រមែងធ្វើប្រយោគឲ្យសម្រេចបាន ដូច្នោះ ។ ពាក្យថា បធាន សេចក្តីថា ប្រធានដូចម្តេច កាយក្តី ចិត្តក្តី នៃភិក្ខុដែលប្រារព្ធសេចក្តីព្យាយាម រមែង

គួរដល់ការងារ នេះជាបធាន ។ បយោគដូចម្តេច ភិក្ខុអ្នកប្រារព្ធសេចក្តីព្យាយាម រមែងលះឧបក្កិលេសបាន វិតក្កៈរមែងស្ងប់ទៅ នេះជាប្រយោគ ។ គុណវិសេសដូចម្តេច ភិក្ខុអ្នកប្រារព្ធសេចក្តីព្យាយាម រមែងលះសំយោជនៈបាន អនុស័យរមែងអស់ទៅ នេះជាគុណវិសេស ។ ធម៌ ៣ ប្រការនេះ រមែងជាអារម្មណ៍នៃចិត្តតែ ១ ធម៌ ៣ ប្រការនេះ មិនប្រាកដក៏មិនមែន ចិត្តរមែងមិនដល់នូវការរាយមាយ បធានរមែងប្រាកដផង ព្រះយោគាវចរធ្វើឲ្យបយោគ ( ការតាមប្រកបភាវនា ) សម្រេចបានផង បានត្រាស់ដឹងគុណវិសេសផង ។

> អានាបានស្សតិ បុគ្គលណាបានបំពេញហើយ ចម្រើនហើយ
> ដោយប្រពៃ សន្សំហើយដោយលំដាប់ ឲ្យដូចព្រះពុទ្ធទ្រង់
> សម្តែងទុកហើយ បុគ្គលនោះ រមែងញុំាងលោកនេះឲ្យភ្លឺ
> ច្បាស់ ដូចជាព្រះចន្ទ ដែលផុតស្រឡះចាកពពក ។

នេះជាការឧបមាដូចរណា ។ ក្នុងការឧបមាដូចរណានេះ គប្បីជ្រាបថា ហេតុត្រឹមតែមិនដាក់ចិត្ត ដោយអំណាចខ្យល់ដង្ហើមចូល-ចេញ ដែលច្រូងទៅមកៗ ប៉ុណ្ណោះ ជាប្រយោជន៍ដល់ភិក្ខុនោះ កាលភិក្ខុអង្គខ្លះ មនសិការនិមិត្តរមែងកើតឡើងដោយមិនយឺតយូរឡើយ ហើយឋបនា ពោលគឺ អប្បនា ដែលប្រកបដោយអង្គឈានដ៏សេស ក៏រមែងសម្រេច ។ តែសម្រាប់ភិក្ខុអង្គខ្លះ មានចាប់តាំងអំពីមនសិការដោយអំណាចការរាប់នោះឯង គឺតាំងអំពីពេលធ្វើទុកក្នុងចិត្ត ដោយអំណាចការរាប់ កាលការក្រវល់ក្រវាយផ្លូវកាយ

ស្ងប់ទៅដោយអំណាចខ្យល់ដង្ហើមចូល-ចេញ ដែលគ្រោតគ្រាតរលត់ទៅ ដោយលំដាប់ កាយក្តី ចិត្តក្តី រមែងជារបស់ស្រាល រាងកាយរមែងហាក់ដូច ដល់នូវអាការអណ្តែតឡើងទៅក្នុងអាកាស ដូចភិក្ខុមានកាយសោប់សេល់ កាលអង្គុយលើគ្រែ ឬតាំង គ្រែ និងតាំងរមែងទន់អែនទៅ គ្រឿងកម្រាល រមែងជ្រួញរួញ ។ តែកាលលោកមានកាយមិនសោប់សេល់ អង្គុយចុះ គ្រែ និងតាំងរមែងមិនទោរទន់ មិនអែន គ្រឿងកម្រាលក៏មិនជ្រួញរួញ គ្រែ តាំង ហាក់ដូចជាពេញដោយសំឡី ព្រោះហេតុអ្វី ព្រោះថា កាយមិនសោប់សេល់ រមែងជារបស់ស្រាលដូច្នោះ ។ កាលខ្យល់អស្សាសៈ និងបស្សាសៈដែល គ្រោតគ្រាតរលត់ទៅហើយ ចិត្តរបស់ភិក្ខុនោះមាននិមិត្ត គឺខ្យល់អស្សាសៈ និងបស្សាសៈ ដែលល្អិតជាអារម្មណ៍ រមែងប្រព្រឹត្តទៅ សូម្បីចិត្តដួងនោះ រលត់ទៅហើយ ចិត្តបន្តៗ មក ដែលមានអារម្មណ៍ គឺនិមិត្តដែលល្អិត រហូត ល្អិតជាងចិត្តនោះ រមែងប្រព្រឹត្តទៅនោះឯង ។

សួរថា ចិត្តដួងបន្ទាប់ៗ មក រមែងប្រព្រឹត្តទៅដូចម្តេច ឆ្លើយថា ប្រៀប ដូចបុរស កាលយកដុំដែកមួយដុំធំវាយដួង ដោយការវាយត្រឹមម្តង សំឡេង ខ្លាំងគប្បីកើតឡើង ចិត្តរបស់បុរសនោះដែលមានសំឡេងខ្លាំង ( គ្រោតគ្រាត ) ជាអារម្មណ៍គប្បីប្រព្រឹត្តទៅ កាលសំឡេងខ្លាំងប្រព្រឹត្តទៅ បន្ទាប់អំពីនោះ ចិត្តដែលមានសំឡេងល្អិតជាអារម្មណ៍គប្បីប្រព្រឹត្តទៅ កាលចិត្តដែលមាន និមិត្ត គឺសំឡេងល្អិតជាអារម្មណ៍នោះរលត់ទៅហើយ ចិត្តដួងតៗ ទៅ ដែល មានអារម្មណ៍ គឺនិមិត្តដែលល្អិត រហូតល្អិតជាងចិត្ត មាននិមិត្ត គឺសំឡេង

ល្អិតជាអារម្មណ៍នោះ រមែងប្រព្រឹត្តទៅនោះឯង យ៉ាងណា ចិត្តមាននិមិត្ត គឺខ្យល់អស្សាសៈ និងបស្សាសៈជាអារម្មណ៍នោះ បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅយ៉ាងនោះ សេចក្តីនេះសមដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលថា ប្រៀបដូចបុរសវាយជួង ( សំឡេងខ្លាំង គឺសំឡេងគ្រោតគ្រាត រមែងលាន់ឮទៅមុន ) ដូច្នេះជាដើម ។ គួរឲ្យពិស្តារ ។ ដូចកម្មដ្ឋានដទៃៗ រមែងប្រាកដច្បាស់ខ្ពស់ឡើងទៅៗ យ៉ាងណា អានាបានស្សតិកម្មដ្ឋាននេះមិនជាយ៉ាងនោះឡើយ ។ តែអានាបានស្សតិកម្មដ្ឋាននេះ កាលភិក្ខុចម្រើនទៅៗ ក្នុងលំដាប់ខ្ពស់ឡើងទៅ រមែងជារបស់ល្អិត គឺមិនដល់នូវការប្រាកដ ។ កាលកម្មដ្ឋាននោះមិនប្រាកដយ៉ាងនោះ ភិក្ខុនោះមិនគួរក្រោកឡើងអំពីអាសនៈទះបន្ទះស្បែកចេញទៅឡើយ ។ មិនគួរក្រោកឡើង ដោយគិតថា អញគប្បីធ្វើដូចម្តេច អញនឹងសួរអាចារ្យ ឬថា ឥឡូវនេះ កម្មដ្ឋានរបស់អញវិនាសហើយ ។ ពិតហើយ កាលលោកឲ្យឥរិយាបថកម្រើក ហើយដើរទៅ កម្មដ្ឋានរមែងប្រាកដជារបស់ថ្មីៗ រឿយៗ ទៅ ព្រោះហេតុនោះ គួរអង្គុយដូចដើមនោះឯង នាំកម្មដ្ឋានមកអំពីទីពាល់ត្រូវតាមប្រក្រតី ។

## ឧបាយជាហេតុនាំអានាបានស្សតិកម្មដ្ឋានមក

ក្នុងអធិការពោលដោយអានាបានស្សតិកម្មដ្ឋាននេះ មានឧបាយជាគ្រឿងនាំមកដូចតទៅនេះថា ពិតហើយ ភិក្ខុនោះ ដឹងថា កម្មដ្ឋានមិនប្រាកដ គួរពិចារណាសិក្សាយ៉ាងនេះថា ឈ្មោះថា ខ្យល់ដង្ហើមចូល-ចេញនេះ មានក្នុងទីណា មិនមានក្នុងទីណា របស់បុគ្គលណាមាន របស់បុគ្គលណាមិនមាន

ក្រោយមក កាលភិក្ខុនោះ ពិចារណាយ៉ាងនេះ ក៏ដឹងបានថា ខ្យល់ដង្ហើមចូល-ចេញនេះ ( របស់ទារកដែលនៅ ) ក្នុងផ្ទៃមាតាមិនមាន ពួកជនអ្នកមុជទឹកក៏មិនមាន ពួកអសញ្ញីសត្វ មនុស្សស្លាប់ អ្នកចូលចតុត្ថជ្ឈាន បុគ្គលដែលដល់ព្រមដោយរូបកព និងអរូបកព អ្នកចូលនិរោធ ក៏មិនមានដូចគ្នា ហើយគប្បីដាស់តឿនខ្លួនឯងដោយខ្លួនឯងយ៉ាងនេះថា នែបណ្ឌិត ខ្លួនអ្នកមិនមែន ជាអ្នកនៅក្នុងផ្ទៃរបស់មាតា មិនមែនអ្នកមុជទឹក មិនមែនជាអសញ្ញីសត្វ មិនមែនមនុស្សស្លាប់ មិនមែនអ្នកចូលចតុត្ថជ្ឈាន មិនមែនអ្នកដល់ព្រមដោយរូបកព និងអរូបកព មិនមែនអ្នកចូលនិរោធ មិនមែនឬ ខ្លួនអ្នកនៅមានខ្យល់ដង្ហើមចូល-ចេញពិតៗ តែខ្លួនអ្នកមិនអាចកំណត់បាន ព្រោះនៅមានបញ្ញាទន់ខ្សោយ ។

ក្រោយមក ភិក្ខុនោះ គួរតាំងចិត្តដោយអំណាចទីខ្យល់ពាល់ត្រូវដោយប្រក្រតីនោះឯង ឲ្យមនសិការប្រព្រឹត្តទៅ ។ ពិតហើយ ខ្យល់ដង្ហើមចូល-ចេញនេះ ប៉ះខ្ទប់ក្ពោងច្រមុះរបស់អ្នកមានច្រមុះវែង ហើយកន្លងទៅប៉ះខ្ទប់បបូរមាត់ខាងលើរបស់អ្នកមានច្រមុះខ្លីកន្លងទៅ ។ ព្រោះដូច្នោះ ទើបភិក្ខុនោះ គួរតាំងនិមិត្តទុកថា ខ្យល់ដង្ហើមចូល-ចេញ រមែងប៉ះខ្ទប់ឋានឈ្មោះនេះ ។ សេចក្ដីពិត ព្រះមានព្រះភាគទ្រង់អាស្រ័យអំណាចប្រយោជន៍នេះឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោល នូវអានាបានស្សតិរបស់ភិក្ខុវង្វេងស្មារតី មិនប្រកបដោយបញ្ញាដឹងសព្វទេ ។

ពិតហើយ កម្មដ្ឋានឯណានីមួយ រមែងសម្រេចដល់អ្នកមានសតិ មាន

ការដឹងខ្លួនប៉ុណ្ណោះ សូម្បីដូច្នោះ កម្មដ្ឋានដទៃក្រៅអំពីអានាបានស្សតិកម្មដ្ឋាន នេះ រមែងប្រាកដបានដល់បុគ្គលដែលកំពុងមនសិការ ។ តែអានាបានស្សតិ កម្មដ្ឋាននេះជាការៈធ្ងន់ ចម្រើនសម្រេចបានលំបាក ទាំងជាភូមិនៃមនសិការ របស់មហាបុរសទាំងឡាយ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធបុត្រប៉ុណ្ណោះ មិនមែនជាកម្មដ្ឋានតូចតាច ទាំងមិនបានជាកម្មដ្ឋានដែលសត្វតូចតាចសេព ឡើយ ជាកម្មដ្ឋានស្ងប់ និងល្អិត ដោយប្រការដែលមហាបុរសទាំងឡាយ រមែងធ្វើទុកក្នុងចិត្ត ព្រោះដូច្នោះ ក្នុងអានាបានស្សតិកម្មដ្ឋាននេះ ពឹងផ្អែកលើ សតិ និងបញ្ញាដែលមានកម្លាំង ។ ដូចក្នុងវេលាដេរប៉ះសំពត់សាដកសាច់ រអិល សូម្បីម្ជុលក៏ត្រូវការម្ជុលតូច សូម្បីអំបោះដែលដោតក្នុងគូទម្ជុល ក៏ចាំ បាច់ត្រូវមានសរសៃល្អិតជាងនោះ យ៉ាងណា ក្នុងវេលាចម្រើនកម្មដ្ឋាននេះ ដែលដូចគ្នានឹងសំពត់សាដកសាច់រអិលនោះដូចគ្នា សតិមានចំណែកប្រៀប ដូចម្ជុលក្តី បញ្ញាដែលសម្បយុត្តដោយសតិនោះ មានចំណែកប្រៀបដូចអំបោះ ដោតក្នុងម្ជុលក្តី ចាំបាច់ត្រូវមានកម្លាំង ។

ឯភិក្ខុដែលប្រកបដោយសតិ និងបញ្ញានោះហើយ មិនចាំបាច់ស្វែងរក ខ្យល់ដង្ហើមចូល-ចេញនោះអំពីឱកាស ដែលខ្យល់ពាល់ត្រូវដោយប្រក្រតី ។ ប្រៀបដូចអ្នកស្រែភ្ជួរស្រែហើយ លែងគោឲ្យបែរមុខទៅកាន់ទីរកស៊ី ហើយ គប្បីអង្គុយសម្រាកត្រង់ម្លប់ឈើ គ្រានោះ ពួកគោទាំងនោះរបស់បុរសនោះ ក៏ចូលព្រៃដោយរហ័ស អ្នកស្រែដែលឈ្លាស បំណាងនឹងចាប់គោទាំងនោះ មកទឹមភ្ជួរទៀត មិនចាំបាច់ដើរតាមគន្លងគោទាំងនោះចូលទៅកាន់ព្រៃឡើយ

ដោយពិត បុរសនោះ គ្រាន់តែកាន់យកខ្សែ និងជន្ទញដើរតម្រង់ទៅកាន់កំពង់ទឹកដែលគោទាំងនោះចុះនោះឯង អង្គុយ ឬដេកចាំ ។ វេលានោះ បុរសនោះបានឃើញគោទាំងនោះ ដែលត្រាច់ទៅក្នុងពេលថ្ងៃ ហើយចុះទៅកាន់កំពង់ទឹក ងូត និងផឹកហើយ ឡើងមកឈរ ទើបយកខ្សែចង ហើយយកជន្ទញចាក់នាំទៅទឹម ( ភ្ជួរ ) នាំទៅធ្វើការងារទៀត យ៉ាងណា ភិក្ខុនោះក៏យ៉ាងនោះដូចគ្នា មិនចាំបាច់ស្វែងរកខ្យល់ដង្ហើមចូល-ចេញ ក្រៅអំពីឱកាសដែលខ្យល់ប៉ះត្រូវដោយប្រក្រតី តែគប្បីកាន់យកខ្សែ គឺសតិ និងជន្ទញ គឺបញ្ញា ហើយតាំងចិត្តទុកក្នុងឱកាសដែលខ្យល់ពាល់ត្រូវជាប្រក្រតី ញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅ ។ ព្រោះថា កាលភិក្ខុមនសិការយ៉ាងនោះ ក្នុងកាលមិនយូរឡើយ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ នឹងប្រាកដដូចពួកគោ ប្រាកដត្រង់កំពង់ចុះផឹកទឹក ដូច្នោះ ។ ក្នុងលំដាប់នោះ ភិក្ខុគប្បីកាន់យកខ្សែ គឺសតិចងប្រកបទុកក្នុងទីនោះឯង ហើយចាក់ដោយជន្ទញ គឺបញ្ញា តាមប្រកបកម្មដ្ឋានទៀត ។ កាលភិក្ខុព្យាយាមប្រកបយ៉ាងនោះ ក្នុងកាលមិនយូរឡើយ និមិត្តនឹងប្រាកដ ។

អាចារ្យពួកខ្លះពោលថា ឯនិមិត្តនេះរមែងមិនដូចគ្នា ដល់ព្រះយោគីគ្រប់អង្គ ។ម្យ៉ាងទៀត និមិត្តនោះ រមែងប្រាកដដល់ព្រះយោគាវចរអង្គខ្លះ ដូចប៉ុយគ ដូចប៉ុយសំឡី និងដូចខ្សែខ្យល់ ឲ្យកើតសុខសម្ផស្ស ។

ចំណែកវិនិច្ឆ័យក្នុងអដ្ឋកថា មានដូចតទៅនេះថា ពិតហើយ និមិត្តនេះរមែងប្រាកដដល់ព្រះយោគាវចរអង្គខ្លះ ដូចផ្កាយ ដូចកម្រងកែវមណី ដូច

កម្រងកែវមុក្តា អង្គខ្លះ ប្រាកដជារបស់មានសម្ផស្សគ្រោតគ្រាត ដូចគ្រាប់កប្បាស និងដូចជក់ខ្ទឹមឈើ អង្គខ្លះប្រាកដដូចខ្សែសង្វារដែលវែង ដូចកម្រងផ្កាផ្កាំ និងដូចកម្សួលផ្សែង អង្គខ្លះដូចសរសៃពីងពាងដែលសន្ធឹង ដូចស្រទាប់ពពក ដូចផ្កាឈូក ដូចកង់រថ ដូចមណ្ឌលព្រះចន្ទ និងដូចមណ្ឌលព្រះអាទិត្យដូច្នោះ ។

ឯកម្មដ្ឋាននេះ ជាការដូចគ្នាពិតៗ តែប្រាកដដោយភាពផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ដូចបណ្តាភិក្ខុច្រើនអង្គផងគ្នា អង្គុយស្វាធ្យាយព្រះសូត្រកាលភិក្ខុមួយអង្គពោលថា ព្រះសូត្រនេះប្រាកដដល់ពួកលោកដូចម្តេច មួយអង្គពោលថា ប្រាកដដល់ខ្ញុំដូចស្ទឹងហូរធ្លាក់អំពីកំពូលភ្នំធំ មួយអង្គទៀតពោលថា រមែងប្រាកដដល់ខ្ញុំ ដូចជួរព្រៃមួយកន្ទែង ភិក្ខុអង្គដទៃពោលថារមែងប្រាកដដល់ខ្ញុំ ដូចរុក្ខជាតិដែលដល់ព្រមដោយការៈ គឺផ្លែដែលមានម្ទប់ត្រជាក់សម្បូរដោយមែក ពិតហើយ ព្រះសូត្ររបស់ភិក្ខុទាំងនោះ ជាសូត្រដូចគ្នានោះឯង តែប្រាកដដោយភាពជារបស់ផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នាដូច្នោះ ។ សេចក្តីពិត កម្មដ្ឋាននេះកើតអំពីសញ្ញា មានសញ្ញាជាដើមហេតុមានសញ្ញាជាដែនកើត ព្រោះដូច្នោះ គប្បីជ្រាបថា រមែងប្រាកដដោយការផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ។

បណ្តាខ្យល់ដង្ហើមចូល-ចេញ និងនិមិត្តនេះ ចិត្តដែលមានខ្យល់ដង្ហើមចូលជាអារម្មណ៍ ក៏ម្យ៉ាងដោយឡែក ចិត្តដែលមានខ្យល់ដង្ហើមចេញជាអា-រម្មណ៍ ក៏ម្យ៉ាងដោយឡែក ចិត្តដែលមាននិមិត្តជាអារម្មណ៍ ក៏ម្យ៉ាងដោយ

ឡែក ។ ពិតហើយ កម្មដ្ឋានរបស់ភិក្ខុដែលមិនមានធម៌ ៣ យ៉ាងនេះ រមែងមិនដល់អប្បនា មិនដល់ឧបចារៈ ។ ចំណែកកម្មដ្ឋានរបស់ភិក្ខុ មានធម៌ ៣ យ៉ាងនេះ រមែងដល់អប្បនា និងឧបចារៈផង ។ សមដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលថា

កាលបុគ្គលមិនស្គាល់ នូវអនារម្មណ៍របស់ចិត្តតែមួយ
ការបម្រើនទូវធម៌ ៣ ប្រការ គឺនិមិត្ត ១ អស្សាសៈ ១
បស្សាសៈ ១ គេរមែងមិនបាន កាលបុគ្គលដឹង នូវ
អនារម្មណ៍នៃចិត្តតែមួយ ការបម្រើនទូវធម៌ ៣ ប្រការ
គឺនិមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងបាន ។

ទីឃនិកាយាចារ្យទាំងឡាយ បានពោលយ៉ាងនេះជាបឋមថា កាលនិមិត្តប្រាកដហើយយ៉ាងនោះ ភិក្ខុនោះគួរទៅកាន់សម្នាក់របស់អាចារ្យ រួចប្រាប់ថា និមិត្តឈ្មោះនេះ រមែងប្រាកដដល់ខ្ញុំ ។ ចំណែកអាចារ្យមិនគួរពោលថា នុ៎ះជានិមិត្ត ឬថា មិនមែននិមិត្ត គួរពោលថា យ៉ាងហ្នឹងឯង លោកហើយគប្បីពោលថា ចូរលោកមនសិការរឿយៗ ចុះ ។ ពិតហើយ បើអាចារ្យពោលថា ជានិមិត្ត ភិក្ខុនោះគប្បីដល់នូវការរាថយ បើអាចារ្យពោលថា មិនមែននិមិត្ត ភិក្ខុក៏នឹងជាអ្នកអស់សង្ឃឹម ហើយលិចចុះ ព្រោះដូច្នោះ មិនគួរនិយាយទាំងពីរយ៉ាងនោះ គួរប្រកបភិក្ខុនោះទុកក្នុងមនសិការនោះឯង ។ ឯមជ្ឈិមនិកាយាចារ្យទាំងឡាយ បានពោលថា ភិក្ខុ កាលអាចារ្យពោលថា នេះជានិមិត្តណាលោក ចូរលោកមនសិការកម្មដ្ឋានរឿយៗ ចុះ ។

ក្រោយមក ភិក្ខុអង្គនោះ គប្បីតាំងចិត្តទុកក្នុងនិមិត្តនោះឯង ។ ចាប់ផ្តើមអំពីបដិភាគនិមិត្តកើតឡើងនេះ ភាវនានេះរបស់ភិក្ខុអង្គនោះ រមែងមានដោយអំណាចការតាំងទុក ដោយប្រការយ៉ាងនេះ ។ សមដូចពាក្យដែលបុរាណាចារ្យទាំងឡាយពោលថា

ព្រះយោគីដែលជាធីរជន កាលតាំងចិត្តទុកក្នុងនិមិត្ត
ចម្រើនខ្យល់ដង្ហើមចូល-ចេញ ដែលមានអាការផ្សេងៗ
ឈ្មោះថា រមែងចងចិត្តរបស់ខ្លួនទុក ។

ចាប់ផ្តើមតាំងអំពីនិមិត្តប្រាកដ ដោយន័យដូចពោលហើយនោះ នីវរណៈទាំងឡាយ គឺព្រះយោគីនោះសង្កត់បានដោយពិត កិលេសទាំងឡាយស្ងប់រម្ងាប់ សតិចូលទៅតាំងមាំនោះឯង ចិត្តក៏តាំងមាំដូចគ្នា ។

ពិតហើយ ចិត្តនេះ ឈ្មោះថា ជាធម្មជាតតាំងមាំដោយអង្គ ២ គឺ ដោយការលះនីវរណៈក្នុងឧបចារភូមិ ឬដោយការប្រាកដនៃអង្គក្នុងបដិលាភភូមិ ។ បណ្តាភូមិ ២ យ៉ាងនោះ ដែលឈ្មោះថា ឧបចារភូមិ បានដល់ឧបចារសមាធិ ។ ដែលឈ្មោះថា បដិលាភភូមិ បានដល់ អប្បនាសមាធិ ។

សួរថា សមាធិទាំង ២ នោះ មានការធ្វើផ្សេងគ្នាដូចម្តេច ឆ្លើយថា ឧបចារសមាធិ ស្ទុះទៅក្នុងកុសលវិថី ហើយក៏ធ្លាក់ចុះកាន់ភវង្គ ។ អប្បនាសមាធិ កាលព្រះយោគីអង្គុយចុះស៊ប់អស់មួយថ្ងៃ ស្ទុះទៅក្នុងកុសលវិថីសូម្បីអស់មួយថ្ងៃ ក៏មិនធ្លាក់ចុះកាន់ក្នុងភវង្គ ។ បណ្តាសមាធិ ២ យ៉ាងនេះ ចិត្តរមែងជាធម្មជាតតាំងមាំដោយឧបចារសមាធិ ព្រោះនិមិត្តប្រាកដ ។ ក្រោយ

មក ភិក្ខុនេះមិនគប្បីមនសិការនិមិត្តនោះដោយពណ៌ ទាំងមិនគប្បីពិចារណា ដោយលក្ខណៈ ។ មួយទៀត ភិក្ខុកុំប្រមាទ គួររក្សានិមិត្តទុក ដូចមហេសីរបស់ក្សត្រទ្រង់រក្សាគភ៌នៃស្តេចចក្រពត្តិ និងដូចអ្នកស្រែរក្សាក្ដួរនៃស្រូវសាលី និងស្រូវជំណើប ដូច្នោះ ។ ពិតហើយ និមិត្តដែលរក្សាទុកបាន រមែងឲ្យនូវផលដល់ភិក្ខុ ។

> កាលព្រះយោគីរក្សានិមិត្តទុកបាន នឹងមិនមានការវិនាសចាកឧបចារជ្ឈានដែលខ្លួនបានហើយ កាលមិនមានការរក្សា ( និមិត្ត ) ឈានដែលខ្លួនបានហើយ ក៏នឹងវិនាសទៅ ដូច្នេះ ។

ក្នុងអធិការនៃអានាបានស្សតិកម្មដ្ឋាន មានឧបាយសម្រាប់រក្សាដូចតទៅថា ភិក្ខុនោះ គួរវៀរអសប្បាយ ៧ យ៉ាងនេះ គឺអាវាស ១ គោចរ ១ ការសន្ទនា ១ បុគ្គល ១ ភោជន ១ រដូវ ១ ឥរិយាបថ ១ ហើយសេពសប្បាយ ៧ យ៉ាងទាំងនោះឯង មនសិការនិមិត្តនោះរឿយៗ ។

ព្រះយោគីនោះ កាលធ្វើនិមិត្តឲ្យមាំទាំ ដោយការសេពសប្បាយយ៉ាងនោះហើយ គួរផ្ចាំការចម្រើនដុះដាលឲ្យបរិបូណ៌ បំពេញសេចក្តីព្យាយាមមិនលះចោលអប្បនាកោសល ១០ យ៉ាង គឺធ្វើវត្ថុឲ្យស្អាតបាត ១ ផ្គួងឥន្ទ្រិយឲ្យប្រព្រឹត្តទៅស្មើ ១ ឈ្លាសក្នុងនិមិត្ត ១ សង្កត់ចិត្តក្នុងសម័យដែលគួរសង្កត់ ១ ផ្គងចិត្តក្នុងសម័យដែលផ្គង ១ លួងលោមចិត្តឲ្យរីករាយក្នុងសម័យដែលគួរលួងលោម ១ សម្លឹងមើលចិត្តក្នុងសម័យដែលគួរសម្លឹង ១

វៀរបុគ្គលដែលមានចិត្តមិនតាំងមាំ ១ សេពគប់បុគ្គលដែលមានចិត្តតាំងមាំ ១ បង្អោនទៅក្នុងសមាធិនោះ ១ ។

កាលព្រះយោគីនោះ ព្យាយាមប្រកបដោយន័យដូចពោលមកយ៉ាងនេះ មនោទ្វារាវជ្ជនៈ មាននិមិត្តជាអារម្មណ៍ កាត់កវង្គហើយ ក៏កើតឡើងក្នុងខណៈដែលគួរពោលថា អប្បនានឹងកើតឡើងក្នុងកាលឥឡូវនេះ កាលមនោ-ទ្វារាវជ្ជនៈនោះរលត់ទៅ បណ្តាជវនទាំងឡាយ ៤-៥ ទាញយកអារម្មណ៍នោះឯងស្ទុះទៅ ជវនដួងដំបូងឈ្មោះបរិកម្ម ទី ២ ឈ្មោះឧបចារៈ ទី ៣ ឈ្មោះអនុលោម ទី ៤ ឈ្មោះគោត្រភូ ទី ៥ ឈ្មោះអប្បនា ម្យ៉ាងទៀត ដួងទី ១ ហៅថា បរិកម្ម និងឧបចារៈ ទី ២ ហៅថាអនុលោម ទី ៣ ហៅថា គោត្រភូ ទី ៤ ហៅថា អប្បនាចិត្ត ។ ពិតហើយ ជវនដួងទី ៤ ប៉ុណ្ណោះ ជួនកាលទី ៥ រមែងប្រព្រឹត្តទៅ មិនដល់ដួងទី ៦-៧ ព្រោះអាសន្នភវង្គ ( ភវង្គជិតអប្បនា ) ធ្លាក់ទៅ ។

ចំណែកព្រះគោទត្តត្ថេរ អ្នកជំនាញអភិធម្មពោលថា កុសលធម៌ទាំងឡាយ រមែងជាធម៌មានកម្លាំងដោយអាសេវនប្បច្ច័យ ព្រោះដូច្នោះ ជវនរមែងដល់ទី ៦-៧ ។ ពាក្យនោះ ត្រូវជំទាស់ក្នុងអដ្ឋកថាទាំងឡាយ ។ ក្នុងជវនចិត្តទាំងនោះ ចិត្តដែលជាបុព្វភាគជាកាមាវចរ ចំណែកអប្បនាចិត្តជារូបាវចរ ។ បឋមជ្ឈានលះអង្គ ៥ ប្រកបដោយអង្គ ៥ សម្បូរដោយលក្ខណៈ ១០ មានលម្អ ៣ គឺព្រះយោគីនេះចាក់ធ្លុះហើយ ដោយន័យដូចពោលមកដូច្នេះ ។ កិច្ចញុំាងអង្គឈានទាំងឡាយ មានវិតក្កៈជាដើមឲ្យស្ងប់រម្ងាប់ក្នុង

អារម្មណ៍នោះឯង រមែងបានឈានទី ២-៣ និងទី ៤ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ លោករមែងជាអ្នកដល់នូវទីបំផុតនៃការនា ដោយអំណាចនៃការបញ្ឈប់ ។ ក្នុងអធិការនេះ មានសង្ខេបកថាប៉ុណ្ណេះ អ្នកសិក្សាដែលចង់បានសេចក្ដីពិស្ដារ គប្បីកាន់យកអំពីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គចុះ ។

ចំណែកក្នុងកាយានុបស្សនានេះ ភិក្ខុអ្នកបានចតុត្ថជ្ឈានហើយយ៉ាងនោះ មានបំណងចម្រើនកម្មដ្ឋាន ដោយអំណាចការកំណត់ និងការផ្លាស់ប្ដូរ ហើយសម្រេចសេចក្ដីបរិសុទ្ធ ធ្វើឈាននោះឯងឲ្យដល់នូវការជំនាញ ( វសី ) ដោយអាការ ៥ យ៉ាង ពោល គឺ **អាវជ្ជនវសី** ការរាវរក **សមាបជ្ជនវសី** ការចូលសមាបត្តិ **អធិដ្ឋានវសី** ការតាំងចិត្តទុក **វុដ្ឋានវសី** ការចេញ និង **បច្ចវេក្ខណវសី** ការពិចារណា ហើយកំណត់រូប និងអរូបថា រូបមានអរូបជាប្រធាន ឬអរូបមានរូបជាប្រធាន ហើយផ្ដើមចម្រើនវិបស្សនា ។

សួរថា ផ្ដើមតាំងវិបស្សនាដូចម្ដេច ឆ្លើយថា ពិតហើយ ព្រះយោគីនោះ កាលចេញអំពីឈានហើយ កំណត់អង្គឈាន រមែងឃើញហទយវត្ថុដែលជាទីអាស្រ័យនៃអង្គឈានទាំងនោះ រមែងឃើញភូតរូបដែលជាទីអាស្រ័យនៃហទយវត្ថុនោះ និងរមែងឃើញករជកាយទាំងមូល ដែលជាទីអាស្រ័យនៃភូតរូបទាំងនោះ ។ ក្នុងលំដាប់នៃការឃើញនោះ លោករមែងកំណត់រូប និងអរូបថា អង្គឈាន ចាត់ជាអរូប ( ហទយៈ )វត្ថុជាដើមចាត់ជារូប ។ មួយវិញទៀត ភិក្ខុនោះ កាលចេញអំពីសមាបត្តិហើយ កំណត់ភូតរូបទាំង ៤ ដោយអំណាចបឋវីធាតុជាដើម ក្នុងបណ្ដាចំណែកទាំងឡាយ

មានសក់ជាដើម និងរូបដែលអាស្រ័យភូតរូបនោះ រមែងឃើញវិញ្ញាណ ព្រមទាំងសម្បយុត្តធម៌ មានរូបតាមដែលខ្លួនកំណត់ហើយជាអារម្មណ៍ ឬ មានរូប វត្ថុ និងទ្វារ តាមដែលកំណត់ហើយជាអារម្មណ៍ ។ លំដាប់នោះ លោករមែងកំណត់ថា ភូតរូបជាដើម ចាត់ជារូប វិញ្ញាណព្រមទាំងសម្ប-យុត្តធម៌ ចាត់ជាអរូប ។ម្យ៉ាងទៀត ភិក្ខុកាលចេញអំពីសមាបត្តិហើយ រមែងឃើញថា ករជកាយ និងចិត្ត ជាទីកើតឡើងនៃខ្យល់អស្សាសៈ និង បស្សាសៈ ឧបមាដូចស្នប់របស់ជាងមាសកំពុងសប់ ខ្យល់រមែងសញ្ចរទៅ មក ព្រោះអាស្រ័យការសប់ និងការព្យាយាមដែលកើតអំពីការសប់នោះ របស់បុរស យ៉ាងណា ខ្យល់ដង្ហើមចូល-ចេញ រមែងចូលចេញ ព្រោះអា-ស្រ័យកាយ និងចិត្ត ដូច្នោះដូចគ្នា ។ លំដាប់នោះ លោកកំណត់ខ្យល់ ដង្ហើមចូល-ចេញ និងកាយថាជារូប កំណត់ចិត្តនោះ និងធម៌ដែលសម្ប-យុត្តជាមួយនឹងចិត្តថា ជាអរូប ។ កាលភិក្ខុកំណត់នាមរូបដោយអាការយ៉ាង នោះហើយ រមែងស្វែងរកបច្ច័យនៃនាមរូបនោះ ។ ហើយភិក្ខុកាលស្វែងរក ក៏បានឃើញបច្ច័យ មានអវិជ្ជា និងតណ្ហាជាដើមនោះហើយ រមែងឆ្លងសេចក្តី សង្ស័យ ប្រារព្ធការប្រព្រឹត្តទៅនៃនាមរូប ក្នុងកាលទាំង ៣ ចេញបាន ។

ភិក្ខុនោះ ឆ្លងសេចក្តីសង្ស័យបានហើយ លើកត្រៃលក្ខណ៍ឡើងដោយ អំណាចការពិចារណាកលាបៈ លះវិបស្សនូបក្កិលេស ១០ យ៉ាង មាន ឱភាសជាដើម ដែលកើតឡើងហើយ ក្នុងចំណែកខាងដើម ដោយឧទយព្វ-យានុបស្សនា ( ការពិចារណាឃើញការកើត និងការរលត់ ) កំណត់

បដិបទាញាណដែលផុតចាកឧបក្កិលេសថា ជាមគ្គ លះការកើតចោល ដល់នូវភង្គានុបស្សនា( ការពិចារណាឃើញការរលត់ ) ទៀយណាយប្រាសចាកតម្រេក ផុតទៅក្នុងសព្វសង្ខារ ដែលប្រាកដដោយភាពជារបស់គួរខ្លាច ដោយពិចារណាឃើញការរលត់ជាប់តគ្នាទៅ បានសម្រេចអរិយមគ្គទាំង ៤ តាមលំដាប់ ហើយតាំងនៅក្នុងអរហត្តផល ដល់នូវទីបំផុតនៃបច្ចវេក្ខណញាណ ១៩ យ៉ាង ជាអគ្គទក្ខិណេយ្យក្នុងលោក ព្រមទាំងទេវលោក ។ ឯការចម្រើនអានាបានស្សតិសមាធិរបស់ភិក្ខុ ដែលប្រកបក្នុងអានាបានស្សតិនោះ ចាប់ផ្ដើមអំពីការរាប់ រហូតដល់មគ្គផលជាទីបំផុត ចប់បរិបូណ៌ត្រឹមប៉ុណ្ណេះឯង ។ នេះពណ៌នាបឋមចតុក្កៈដោយប្រការគ្រប់យ៉ាង ។

ព្រោះក្នុងចតុក្កៈ ៣ ក្រៅអំពីនេះ ដែលឈ្មោះថា ន័យនៃការចម្រើនកម្មដ្ឋានមួយផ្នែករមែងមិនមាន ព្រោះដូច្នោះ អ្នកសិក្សាគួរជ្រាបអត្ថនៃចតុក្កៈ ៣ ទាំងនោះ ដោយន័យនៃការពណ៌នាតាមបទនោះឯង ។

បទថា **បីតិប្បដិសំវេទី** សេចក្ដីថា ភិក្ខុសិក្សាថា អញនឹងធ្វើបីតិ ឲ្យដឹងច្បាស់ គឺធ្វើឲ្យប្រាកដ ដកដង្ហើមចូល-ចេញ ។ បណ្ដាបីតិ និងសុខទាំងនោះ បីតិ ត្រូវបានភិក្ខុដឹងច្បាស់ហើយ ដោយអាការ ២ យ៉ាង គឺដោយអារម្មណ៍ និងដោយការមិនវង្វេង ។

សួរថា បីតិ ឈ្មោះថា ភិក្ខុដឹងច្បាស់ហើយ ដោយអារម្មណ៍ដូចម្ដេច ឆ្លើយថា ភិក្ខុនោះរមែងចូលឈានទាំង ២ ( បឋមជ្ឈាន និងទុតិយជ្ឈាន ) ដែលមានបីតិ បីតិឈ្មោះថា ភិក្ខុនោះ ដឹងច្បាស់ហើយដោយអារម្មណ៍ ដោយ

ការបានឈានក្នុងខណៈចូលសមាបត្តិ ព្រោះអារម្មណ៍ជាធម្មជាតិដែលភិក្ខុនោះ ដឹងច្បាស់ហើយ ។

សួរថា បីតិ ឈ្មោះថា ភិក្ខុដឹងច្បាស់ហើយ ដោយការមិនវង្វេងដូចម្តេច ឆ្លើយថា ភិក្ខុនោះចូលឈានទាំង ២ ដែលមានបីតិ ចេញអំពីឈានហើយ រមែងពិចារណាបីតិដែលសម្បយុត្តដោយឈាន ដោយការអស់ទៅការសូន្យទៅ បីតិ ឈ្មោះថា ភិក្ខុអង្គនោះដឹងច្បាស់ហើយ ដោយការមិនវង្វេង ព្រោះចាក់ធ្លុះលក្ខណៈ ក្នុងខណៈនៃវិបស្សនា ។ សេចក្តីនេះ សមដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលក្នុងបដិសម្ភិទាមគ្គថា

> កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង បីតិ និងបាមោជ្ជៈរមែងកើតឡើង ។បេ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង បីតិ និងបាមោជ្ជៈរមែងកើតឡើង ។បេ។ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញខ្លី ដោយអំណាចនៃដង្ហើមចូលខ្លី ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចូល របស់អ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចេញ របស់អ្នក កាល

រម្ងាប់នូវកាយសង្ខារ ដោយអំណាចនៃដង្ហើមចូល របស់អ្នកកាលរម្ងាប់នូវកាយសង្ខារ បីតិ និងបាមោជ្ជៈ គឺធម្មជាតិជាគ្រឿងរីករាយ និងរីករាយខ្លាំង ការត្រេកអរ ត្រេកអរខ្លាំង ការស្រស់ស្រាយ ស្រស់ស្រាយខ្លាំង ភាពនៃចិត្តខ្ពស់ឡើង ភាពនៃចិត្តអរសប្បាយ រមែងកើតឡើង នេះឈ្មោះថា បីតិ ដែលបុគ្គលដឹងច្បាស់ហើយ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ បីតិនោះឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចូលវែង សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញខ្លី ដោយអំណាចនៃដង្ហើមចូលខ្លី ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកំណត់ដឹង នូវកាយទាំងពួង ដោយអំណាចនៃដង្ហើមចេញ របស់អ្នកកាលរម្ងាប់នូវកាយសង្ខារ ដោយអំណាចនៃដង្ហើមចូល របស់អ្នកកាលរម្ងាប់ នូវកាយសង្ខារ

សតិក៏តម្កល់មាំ បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ កាលបុគ្គលរំពឹង បីតិនោះ ឈ្មោះថា គេដឹងច្បាស់ហើយ កាលបុគ្គលដឹង ... កាលឃើញ កាលពិចារណា កាលអធិដ្ឋានដោយចិត្ត កាលជឿស៊ប់ដោយសទ្ធា កាលផ្គងនូវវីរិយៈ កាលប្រុងទុកនូវសតិ កាលតម្កល់នូវចិត្ត កាលដឹងច្បាស់ដោយបញ្ញា កាលត្រាស់ដឹង នូវធម៌ដែលគួរត្រាស់ដឹង កាលកំណត់ដឹង នូវធម៌ដែលគួរកំណត់ដឹង កាលលះនូវធម៌ដែលគួរលះ កាលចម្រើននូវធម៌ដែលគួរចម្រើន កាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ បីតិនោះឈ្មោះថា គេដឹងច្បាស់ហើយ ដោយអាការយ៉ាងនេះ ។

បទដ៏សេស គប្បីជ្រាបដោយអត្ថតាមន័យនេះនោះឯង ។ តែក្នុងពីរបទនេះ គ្រាន់តែមានសេចក្ដីប្លែកគ្នាដូចតទៅនេះថា គប្បីជ្រាបភាពជាអ្នកដឹងច្បាស់នូវសុខដោយអំណាចនៃឈាន ៣ គប្បីជ្រាបភាពជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ដោយអំណាចនៃឈានទាំង ៤ ។ ខន្ធ ២ មានវេទនាជាដើម ឈ្មោះថា ចិត្តសង្ខារ ។ បណ្ដាពីរបទនេះ ក្នុងសុខបដិសំវេទិបទ ព្រះសារីបុត្រពោលទុកក្នុងបដិសម្ភិទាមគ្គ ដើម្បីសម្ដែងភូមិនៃវិបស្សនាថា ពាក្យថា **សុខ** បានដល់ សុខ ២ យ៉ាង គឺកាយិកសុខ ១ ចេតសិកសុខ ១ ។

ពីរបទថា **បស្សម្ភយំ ចិត្តសង្ខារំ** សេចក្ដីថា រម្ងាប់ គឺរំលត់ចិត្តសង្ខារ

ដែលគ្រោតគ្រាតចេញ ។ ការរំលត់ចិត្តសង្ខារនោះ គប្បីជ្រាបដោយពិស្ដារ តាមន័យដែលពោលហើយ ក្នុងកាយសង្ខារនោះឯង ។

ម្យ៉ាងទៀត បណ្ដាបទទាំងនេះ ក្នុងបីតិបទ លោកពោលវេទនា ដោយបីតិជាប្រធាន ក្នុងសុខបដិសំវេទិបទ លោកពោលវេទនា ដោយសរុបនោះឯង ក្នុងចិត្តសង្ខារបទទាំង ២ គឺលោកពោលវេទនាដែលសម្បយុត្ត ដោយសញ្ញា ព្រោះព្រះបាលីថា សញ្ញា និងវេទនា ជាចេតសិក ធម៌ទាំងនេះ ទាក់ទងដោយចិត្ត ជាចិត្តសង្ខារ ដូច្នេះ ចតុក្កៈនេះបណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់ដោយវេទនានុបស្សនាន័យ ដោយប្រការយ៉ាងនេះ ។

សូម្បីក្នុងចតុក្កៈទី ៣ មានវិនិច្ឆ័យដូច្នេះថា បណ្ឌិតគប្បីជ្រាបភាពជាអ្នកដឹងច្បាស់នូវចិត្តដោយអំណាចឈាន ៤ ។

ពីរបទថា **អភិប្បមោទយំ ចិត្តំ** សេចក្ដីថា ភិក្ខុគប្បីសិក្សាថា អញនឹងញុំាងចិត្តឲ្យត្រេកអរ គឺឲ្យរីករាយ បានដល់ ឲ្យស្រស់ស្រាយ ដកដង្ហើមចូល-ចេញ ។ ក្នុងពីរបទនោះ ការត្រេកអរ រមែងមានដោយអាការ ២ យ៉ាង គឺដោយអំណាចសមាធិ និងដោយអំណាចវិបស្សនា ។

សួរថា ការត្រេកអរ រមែងមានដោយអំណាចសមាធិដូចម្ដេច ឆ្លើយថា ភិក្ខុរមែងចូលឈានទាំង ២ ( បឋមជ្ឈាន និងទុតិយជ្ឈាន ) ដែលមានបីតិ ។ ភិក្ខុនោះ រមែងឲ្យចិត្តត្រេកអរដោយបីតិដែលសម្បយុត្តក្នុងខណៈនៃសមាបត្តិ ។

សួរថា ការត្រេកអរ រមែងមានដោយអំណាចវិបស្សនាដូចម្ដេច ឆ្លើយ

*ថា ភិក្ខុកាលចូលឈានទាំង ២ ដែលមានបីតិ ចេញអំពីឈាន ហើយពិចារណានូវបីតិដែលសម្បយុត្តដោយឈាន ដោយការអស់ទៅ ការសូន្យទៅ ។ ភិក្ខុធ្វើបីតិដែលសម្បយុត្តដោយឈានឲ្យជាអារម្មណ៍ ក្នុងខណៈនៃវិបស្សនាយ៉ាងនោះហើយ ឲ្យចិត្តរីករាយ ត្រេកអរ ។ អ្នកបដិបត្តិយ៉ាងនោះលោកហៅថា គប្បីសិក្សាថា អញនឹងញុំាងចិត្តឲ្យត្រេកអរ ដកដង្ហើមចូល និងដកដង្ហើមចេញ ។*

*ពីរបទថា* **សមាទហំ ចិត្តំ** *សេចក្តីថា តម្កល់ចិត្តទុកស្មើ គឺតាំងចិត្តទុកស្មើក្នុងអារម្មណ៍ ដោយអំណាចនៃឈាន មានបឋមជ្ឈានជាដើម ឬថា កាលភិក្ខុចូលឈានទាំងនោះ ហើយចេញអំពីឈាន ពិចារណានូវចិត្តដែលសម្បយុត្តដោយឈាន ដោយការអស់ទៅ ការសូន្យទៅ ការដែលចិត្តមានអារម្មណ៍មួយជួរខណៈ ( ខណិកសមាធិ ) រមែងកើតឡើង ព្រោះការចាក់ធ្លុះលក្ខណៈក្នុងខណៈនៃវិបស្សនា ភិក្ខុដែលតម្កល់ចិត្តទុកស្មើ គឺតាំងចិត្តទុកស្មើក្នុងអារម្មណ៍ ដោយអំណាចនៃសភាពដែលចិត្តមានអារម្មណ៍មួយជួរខណៈដែលកើតឡើងហើយយ៉ាងនោះ លោកក៏ហៅថា គប្បីសិក្សាថា អញនឹងតម្កល់ចិត្តទុកមាំ ដកដង្ហើមចូល-ចេញ ។*

*ពីរបទថា* **វិមោចយំ ចិត្តំ** *សេចក្តីថា កាលដោះ កាលលែងចិត្តឲ្យផុតចាកនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន គឺកាលដោះលែងចិត្តឲ្យផុតចាកវិតក្កៈដោយទុតិយជ្ឈាន ចាកបីតិដោយតតិយជ្ឈាន ចាកសុខ និងទុក្ខ ដោយចតុត្ថជ្ឈាន ឬកាលលោកចូលឈានទាំងនោះ ហើយចេញមកពិចារណានូវ*

ចិត្តដែលសម្បយុត្តដោយឈាន ដោយការអស់ទៅ ការសូន្យទៅ ក្នុងខណៈនៃវិបស្សនា ភិក្ខុនោះ ដោះ គឺលែងចិត្តឲ្យផុតអំពីនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ដោះ គឺលែងចិត្តឲ្យផុតអំពីសុខសញ្ញា ដោយទុក្ខានុបស្សនា អំពីអត្តសញ្ញា ដោយអនត្តានុបស្សនា អំពីនន្ទិ ( ការត្រេកត្រអាល ) ដោយនិព្វិទានុបស្សនា អំពីរាគៈ ដោយវិរាគានុបស្សនា អំពីសមុទយៈ ( គឺតណ្ហាដែលញ៉ាំងទុក្ខឲ្យកើត ) ដោយនិរោធានុបស្សនា ( ការពិចារណាឃើញធម៌ដែលជាគ្រឿងរំលត់ ) អំពីអាទាន ( ការប្រកាន់ ) ដោយបដិនិស្សគ្គានុ-បស្សនា ( ធម៌ជាគ្រឿងលះបង់នូវឧបធិ ) ដកដង្ហើមចូល-ចេញ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា គប្បីសិក្សាថា អញនឹងដោះចិត្តឲ្យរួច ( ចាកនីវរណធម៌ជាដើម ) ដកដង្ហើមចូល-ចេញ ។ ចតុក្កៈនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់ដោយអំណាចនៃចិត្តានុបស្សនាយ៉ាងនេះ ។

ចំណែកក្នុងចតុក្កៈទី ៤ មានវិនិច្ឆ័យដូច្នេះថា ក្នុងបទថា **អនិច្ចានុ-បស្សី** នេះ គប្បីជ្រាប **អនិច្ចំ** ( របស់មិនទៀង ) គប្បីជ្រាប **អនិច្ចតា** ( ភាពជារបស់មិនទៀង ) គប្បីជ្រាប **អនិច្ចតានុបស្សនា** ( ការពិចារណាឃើញរបស់មិនទៀង ) គប្បីជ្រាប **អនិច្ចានុបស្សី** ( បុគ្គលពិចារណាឃើញរបស់មិនទៀង ) ជាមុនសិន ។

ក្នុងលក្ខណៈ ៤ យ៉ាង មាន **អនិច្ចំ** ជាដើមនោះ ដែលឈ្មោះថា **អនិច្ចំ** បានដល់ បញ្ចក្ខន្ធ ព្រោះហេតុអ្វី ព្រោះថា បញ្ចក្ខន្ធ មានការកើត

ឡើង មានការសូន្យទៅ និងមានការប្រព្រឹត្តទៅដោយប្រការដទៃ ។

ដែលឈ្មោះថា **អនិច្ចតា** បានដល់ ការដែលបញ្ចក្ខន្ធទាំងនោះឯង មានការកើតឡើង មានការសូន្យទៅ និងមានការប្រព្រឹត្តទៅដោយអាការដទៃ ឬមានហើយ ត្រឡប់ជាមិនមាន អធិប្បាយថា បញ្ចក្ខន្ធទាំងនោះកើតឡើងហើយ មិនតាំងនៅដោយអាការនោះឯង រលត់ព្រោះការបែកធ្លាយទៅមួយជួរខណៈ ។

ដែលឈ្មោះថា **អនិច្ចានុបស្សនា** បានដល់ ការពិចារណាឃើញក្នុងបញ្ចក្ខន្ធទាំងឡាយ មានរូបជាដើមថា មិនទៀង ដោយអំណាចនៃភាពជារបស់មិនទៀងនោះ ។

ដែលឈ្មោះថា **អនិច្ចានុបស្សី** បានដល់ ព្រះយោគាវចរអ្នកប្រកបដោយអនុបស្សនា ព្រោះហេតុនោះ ព្រះយោគាវចរ ដែលកើតហើយយ៉ាងនេះ ដកដង្ហើមចូល និងដកដង្ហើមចេញ បណ្ឌិតគប្បីជ្រាបក្នុងអធិការនេះថា គប្បីសិក្សាថា អញនឹងពិចារណាឃើញថា មិនទៀង ដកដង្ហើមចូល-ចេញ ។

ចំណែកវិរាគៈ ក្នុងបទថា **វិរាគានុបស្សី** នេះ មាន ២ យ៉ាង គឺ **ខយវិរាគ** បានដល់ ប្រាសចាកតម្រេក គឺការអស់ទៅ ១ **អច្ចន្តវិរាគ** ប្រាសចាកតម្រេកដោយចំណែកមួយ បណ្ដាវិរាគៈ ២ យ៉ាងនោះ ការរលត់ទៅមួយខណៈៗ នៃសង្ខារទាំងឡាយ ឈ្មោះថា **ខយវិរាគ** ។ ព្រះនិព្វានឈ្មោះថា **អច្ចន្តវិរាគ** ។ វិបស្សនា និងមគ្គ ដែលប្រព្រឹត្តទៅដោយអំណាចនៃការឃើញវិរាគៈទាំង ២ យ៉ាងនោះ ឈ្មោះថា **វិរាគានុបស្សនា** ( ការ

ពិចារណាឃើញការប្រាសចាកតម្រេក ) ។ ព្រះយោគាវចរ ជាអ្នកប្រកប ដោយអនុបស្សនាទាំង ២ យ៉ាងនោះ ដកដង្ហើមចូល-ចេញ បណ្ឌិតគប្បីជ្រាប ថា គប្បីសិក្សាថា អញនឹងពិចារណាឃើញវិរាគៈ ដកដង្ហើមចូល-ចេញ ។ សូម្បីក្នុងបទថា **និរោធានុបស្សី** ក៏មានន័យដូចគ្នា ។

**បដិនិស្សគ្គ** ( ការលះបង់ឧបធិ ) ក្នុងបទថា **បដិនិស្សគ្គានុបស្សី** ក៏មាន ២ យ៉ាង គឺ **បរិច្ចាគបដិនិស្សគ្គ** ការលះបង់ គឺការលះចោល ១ **បក្ខន្ទនបដិនិស្សគ្គ** ការលះបង់ គឺការស្ទុះទៅ ១ ។ ការពិចារណាឃើញ គឺការលះបង់នោះឯង ឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ។ ពាក្យថា **បដិ-និស្សគ្គានុបស្សនា** នោះ ជាឈ្មោះនៃវិបស្សនា និងមគ្គ ។ ពិតហើយ វិបស្សនា ព្រះមានព្រះភាគត្រាស់ហៅថា ការលះបង់ គឺការលះ ព្រោះលះ កិលេសទាំងឡាយ ព្រមទាំងខន្ធាភិសង្ខារ ដោយអំណាចតទង្គប្បហាន និង ត្រាស់ថា ការលះបង់ គឺការស្ទុះទៅ ព្រោះស្ទុះទៅក្នុងព្រះនិព្វាន ដែលផុត អំពីសង្ខារនោះ ហេតុដែលបង្អោនទៅក្នុងព្រះនិព្វាននោះ ព្រោះឃើញទោស នៃសង្ខតធម៌ ។ មគ្គ ព្រះមានព្រះភាគត្រាស់ហៅថា ការលះបង់ គឺការលះ ព្រោះលះកិលេស ព្រមទាំងខន្ធាភិសង្ខារ ដោយអំណាចសមុច្ឆេទប្បហាន និងត្រាស់ថា ការលះបង់ គឺការស្ទុះទៅ ព្រោះស្ទុះទៅក្នុងព្រះនិព្វាន ដោយ ការធ្វើឲ្យជាអារម្មណ៍ ។ ឯវិបស្សនាញាណ និងមគ្គញ្ញាណទាំង ២ ព្រះមាន ព្រះភាគត្រាស់ហៅថា **អនុបស្សនា** ព្រោះសម្លឹងឃើញញាណខាងដើមៗ ក្នុងខាងក្រោយនោះឯង ។ ភិក្ខុជាអ្នកប្រកបដោយបដិនិស្សគ្គានុបស្សនាទាំង

២ យ៉ាងនោះ ដកដង្ហើមចូល-ចេញ បណ្ឌិតគប្បីជ្រាបថា គប្បីសិក្សាថា អញនឹងជាអ្នកមានប្រក្រតីសម្លឹងឃើញញាណ ឈ្មោះថា បដិនិស្សគ្គៈជាខាងក្រោយ ដកដង្ហើមចូល-ចេញ ដូច្នេះ ។

ពាក្យថា **ឯវំ ភាវិតោ** សេចក្តីថា ចម្រើនហើយដោយអាការយ៉ាងនេះ គឺដោយអាការ ១៦ យ៉ាង ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

អធិប្បាយ អានាបានស្សតិសមាធិ ចប់

## ទ្រង់ប្រជុំសង្ឃបញ្ញត្តតតិយបារាជិកសិក្ខាបទ

[ ១៧៩ ] ក្នុងពាក្យថា **អថខោ ភគវា** ជាដើម មានសេចក្តីសង្ខេប ដូចតទៅនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់លួងលោមភិក្ខុទាំងឡាយឲ្យធូរស្បើយ ដោយអានាបានស្សតិសមាធិកថាយ៉ាងនេះហើយ ក្នុងលំដាប់នោះ ទ្រង់ត្រាស់ប្រជុំភិក្ខុសង្ឃ ព្រោះកើតរឿងដែលភិក្ខុទាំងឡាយ ផ្តាច់ជីវិតគ្នានិងគ្នា ដែលជាហេតុញុំាងឲ្យកើតផល និងជាហេតុដំបូងនៃការបញ្ញត្តតតិយបារាជិកសិក្ខាបទនេះហើយ ត្រាស់សួរ និងទ្រង់តិះដៀលក្នុងការផ្តាច់ជីវិតនោះ ការផ្តាច់ជីវិតខ្លួនឯង និងការប្រើឲ្យមិគលណ្ឌិកសមណកុត្តកៈផ្តាច់ជីវិតខ្លួន រមែងមិនជាវត្ថុនៃបារាជិក ដូច្នោះ ទើបទ្រង់វៀរការផ្តាច់ជីវិត ២ យ៉ាងនោះចេញ ទ្រង់កាន់យកការផ្តាច់ជីវិតគ្នានិងគ្នា ដែលជាវត្ថុនៃបារាជិកតែម្យ៉ាង ទ្រង់បញ្ញត្តបារាជិកសិក្ខាបទ ត្រាស់ព្រះពុទ្ធវចនៈ មានពាក្យថា ភិក្ខុណាមួយក្លែងផ្តាច់បង់រាងកាយរបស់មនុស្សឲ្យឃ្លាតចាកជីវិតក្តី ដូច្នេះជាដើម ក្នុងព្រះបាលីនេះ ព្រះដ៏មានព្រះភាគមិនត្រាស់ថា **មោឃបុរិសា** ត្រាស់ថា **តេ ភិក្ខុ** ព្រោះភិក្ខុទាំងនោះលាយឡំដោយព្រះអរិយបុគ្គល ។

## អធិប្បាយ អនុប្បញ្ញត្តិនៃតតិយបារាជិក

[ ១៨០ ] កាលតតិយបារាជិក ដែលព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តធ្វើឲ្យមាំទាំ ដោយអំណាចនៃការដាច់មូល ដោយប្រការដូច្នេះហើយ រឿងពណ៌នាគុណនៃសេចក្តីស្លាប់ដទៃទៀតក៏បានកើតឡើង ដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ កាលសម្តែងការកើតឡើងនៃរឿងនោះ ទើបព្រះឧបាលិត្ថេរពោលថា **ឯវញ្ចិទំ ភគវតា** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **បដិពទ្ធចិត្តា** សេចក្ដីថា អ្នកមានចិត្តជាប់ជំពាក់ដោយឆន្ទរាគៈ អធិប្បាយថា ជាអ្នកមានសេចក្ដីស្រឡាញ់ខ្លាំង គឺមានការសម្ងំ ។

ពីរបទថា **មរណវណ្ណំ សំវណ្ណេម** សេចក្ដីថា អញនឹងចង្អុលទោសក្នុងការរស់នៅ ហើយពណ៌នាគុណ គឺសម្ដែងអានិសង្សនៃសេចក្ដីស្លាប់ ។

ក្នុងបទថា **កតកល្យាណោ** ជាដើម មានអត្ថចំពោះបទដូចតទៅនេះថា សុចរិតកម្ម គឺកម្មស្អាតដែលអ្នកធ្វើហើយ ព្រោះហេតុនោះ អ្នករមែងជាបុគ្គលឈ្មោះថា មានសុចរិតកម្មដែលធ្វើហើយ ។ មួយវិញទៀត កុសលគឺកម្មដែលមិនមានទោស ដែលអ្នកធ្វើហើយ ព្រោះហេតុនោះ អ្នក ឈ្មោះថា មានកុសលដែលធ្វើហើយ ។ ភាពជាអ្នកខ្លាច ពោល គឺការខ្លាចឯណារមែងកើតឡើងដល់សត្វទាំងឡាយ ក្នុងកាលមរណកាលមកដល់បុគ្គលនោះ គ្រឿងតទល់ គឺកម្មជាគ្រឿងរារាំងអំពីភាពជាបុគ្គលខ្លាចនោះ ក៏អ្នកធ្វើហើយ ព្រោះហេតុនោះ អ្នកឈ្មោះថា មានគ្រឿងតទល់អំពីភាពជាអ្នកខ្លាចដែលធ្វើហើយ ។ បាបកម្ម គឺកម្មលាមក អ្នកមិនបានធ្វើហើយ ព្រោះហេតុនោះ អ្នកឈ្មោះថា ជាអ្នកមិនធ្វើបាប ។ កម្មរបស់បុគ្គលល្មោភ គឺកម្មដ៏ទារុណ បានដល់ កម្មជាគ្រឿងទ្រុស្តសីល អ្នកក៏មិនបានធ្វើ ព្រោះហេតុនោះ អ្នកឈ្មោះថា មិនបានធ្វើកម្មរបស់បុគ្គលល្មោភ ។ កម្មគ្រោតគ្រាត គឺកម្មលាមកដែលជាទីក្រាស់ឡើងនៃកិលេស មានលោភៈជាដើម ក៏អ្នកមិនបានធ្វើ ព្រោះហេតុនោះ អ្នក ឈ្មោះថា ជាបុគ្គលមិនបានធ្វើកម្មដែលថោក

ទាប ។ ពាក្យថា អ្នកមានកម្មស្អាតបានធ្វើហើយជាដើមនេះ យើងទាំង-ឡាយរមែងពោល ព្រោះហេតុអ្វី ព្រោះសុចរិតកម្មគ្រប់ប្រការ ក៏អ្នកធ្វើហើយ បាបកម្មគ្រប់ប្រការក៏អ្នកមិនបានធ្វើហើយ ព្រោះហេតុនោះ ទើបអាត្មាទាំងឡាយ ពោលនឹងអ្នកថា ប្រយោជន៍អ្វីរបស់អ្នកដោយជីវិត ដែលឈ្មោះថា អាក្រក់ថោកទាប ព្រោះត្រូវរោគគ្របសង្កត់ ដែលឈ្មោះថាជាទុក្ខ ព្រោះច្រើនទៅដោយទុក្ខនេះ ការស្លាប់របស់អ្នកប្រសើរជាងការរស់នៅ ។ ព្រោះដូច្នោះ ទើបមានអធិប្បាយថា ការស្លាប់របស់អ្នកល្អជាងការរស់នៅ ។ ព្រោះហេតុអ្វី ព្រោះថា អ្នកជាបុគ្គលធ្វើកាលកិរិយាហើយ គឺមានការស្លាប់ហើយ អធិប្បាយថា ធ្វើកាលកិរិយា គឺស្លាប់ហើយអំពីលោកនេះ បន្ទាប់អំពីស្លាប់ព្រោះកាយបែកធ្លាយ នឹងចូលដល់សុគតិសួគ៌ ហើយអ្នកចូលដល់យ៉ាងនោះ នឹងឆ្អែត ដល់ព្រមដោយកាមគុណ ៥ គឺចំណែកនៃវត្ថុកាម ៥ មានរូបជាទីពេញចិត្តជាដើមដ៏ជាទិព្វ ដែលកើតឡើងក្នុងទេវលោកនោះ ញុំាងអត្តភាពឲ្យត្រាច់ទៅ អធិប្បាយថា នឹងជាបុគ្គលប្រកបព្រម គឺដល់ព្រម ( ដោយកាមគុណ ៥ គឺចំណែកនៃវត្ថុកាម ៥ ដែលជាទិព្វកើតឡើងក្នុងទេវលោកនោះ ) នឹងត្រាច់ទៅខាងនេះ និងខាងនេះ គឺនឹងនៅ ឬនឹងអភិរម្យ ។

បទថា **អសប្បាយានិ** សេចក្តីថា ភោជនាហារទាំងឡាយណា ដែលខ្វះឲ្យដល់ការអស់ទៅនៃជីវិតយ៉ាងរហ័ស ភោជនាហារទាំងនោះ ឈ្មោះថាមិនឧបការៈ គឺមិនធ្វើសេចក្តីចម្រើនឲ្យ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃតតិយបារាជិក

[ ១៨១ ] បទថា **សញ្ចិច្ច** នេះ ជាសព្ទ **ហានុនសញ្ចិច្ច** បទ ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ក្នុងមាតិកាថា **សញ្ចិច្ច មនុស្សវិគ្គហំ** ថា **សំ** ក្នុងបទថា **សញ្ចិច្ច** នោះ ជាឧបសគ្គ ។ ពាក្យថា **សញ្ចិច្ច** នេះ ជាពាក្យបង្ហាញដល់បុព្វកាលកិរិយា រួមនឹង **សំ** ឧបសគ្គនោះ ។ អត្ថនៃបទថា **សញ្ចិច្ច** នោះថា មានបំណង គឺក្លែង ។ ភិក្ខុណាក្លែងផ្តាច់ ភិក្ខុនោះជាអ្នកដឹងខ្លួន គឺដឹងព្រម ហើយការដឹងនោះរបស់ភិក្ខុនោះជាការក្លែង គឺប្រព្រឹត្តកន្លង ព្រោះហេតុនោះ ដើម្បីមិនធ្វើការអើពើក្នុងព្យញ្ជនៈ សម្តែងតែអត្ថប៉ុណ្ណោះ ទើបព្រះឧបាលិត្ថេរពោលបទភាជនីយ៍នៃបទថា **សញ្ចិច្ច** នោះយ៉ាងនេះថា កំពុងដឹង ដឹងព្រម ក្លែង គឺកន្លងល្មើស ។

បណ្តាបទទាំងនោះ បទថា **ជានន្តោ** គឺកំពុងដឹងថា សត្វមានជីវិត ។

បទថា **សញ្ជានន្តោ** គឺដឹងព្រមថា អញនឹងផ្តាច់ចាកជីវិត អធិប្បាយថា កំពុងដឹងព្រម និងអាការដែលដឹងថា សត្វមានជីវិតនោះឯង ។

បទថា **ចេច្ច** សេចក្តីថា ផ្តោតចិត្ត គឺដោតចិត្ត ដោយអំណាចចេតនានឹងសម្លាប់ ។

បទថា **អភិវិតរិត្វា** សេចក្តីថា បញ្ជូនចិត្តដែលអស់សេចក្តីសង្ស័យទៅញាំញីដោយអំណាចសេចក្តីព្យាបាទ ។

ដោយបទថា **វីតិក្កមោ** មានពាក្យអធិប្បាយដែលលោកពោលថា ការកន្លងល្មើសនៃចិត្ត ឬបុគ្គលដែលប្រព្រឹត្តទៅហើយយ៉ាងនោះ នេះជាការ

អធិប្បាយដ៏កំពូលនៃ **សញ្ចិច្ច**។

ឥឡូវនេះ ព្រះឧបាលិត្ថេរពោលពាក្យជាដើមថា ឈ្មោះថា កាយមនុស្ស ដើម្បីនឹងសម្ដែងអត្តភាពរបស់មនុស្ស ដែលព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងពាក្យថា ផ្ដាច់បង់កាយមនុស្សឲ្យវិនាសចាកការរស់នៅនេះ តាំងអំពីបឋមខណៈ ។

បណ្ដាបទទាំងនោះ ត្រើនបទថា **យំ មាតុកុច្ឆិស្មឹ** ព្រះឧបាលិត្ថេរពោលដើម្បីសម្ដែងអត្តភាពដែលល្អិតបំផុត ដោយអំណាចនៃពួកសត្វដែលដេកក្នុងគភ៌ ។ បដិសន្ធិចិត្ត ឈ្មោះថា បឋមចិត្ត ។ បទថា **ឧប្បន្នំ** បានដល់កើត ។ បទថា **បឋមំ វិញ្ញាណំ ចាតុភូតំ** នេះ ជាពាក្យលម្អិតនៃពាក្យថា **បឋមចិត្តំ ឧប្បន្នំ** នោះឯង ។ បណ្ដាពាក្យទាំងនោះ ពាក្យថា ចិត្តដួងដំបូង ( ដែលឧប្បត្តិកឡើង ) ក្នុងផ្ទៃមាតានោះឯង ដែលលោកសម្ដែងបដិសន្ធិនៃសត្វដែលមានខន្ធ ៥ ទាំងអស់ ។ ព្រោះហេតុនោះ កាយមនុស្សដែលជាដំបូងបំផុតនេះ គឺចិត្តដួងដំបូងនោះ ១ អរូបក្ខន្ធ ៣ ដែលទាក់ទងដោយចិត្តនោះ ១ កលលរូបដែលកើតព្រមនឹងចិត្តនោះ ១ ។ បណ្ដាអរូបក្ខន្ធ និងកលលរូបនៃចិត្តដួងដំបូងនោះ រូបចំនួន ៣០ ដោយអំណាចនៃកាយទសកៈ ១០ វត្ថុទសកៈ ១០ និងភាវទសកៈ ១០ នៃស្ត្រី ឬបុរស រូប ២០ ដោយអំណាចនៃកាយទសកៈ ១០ និងវត្ថុទសកៈ ១០ នៃពួកខ្ទើយ ឈ្មោះថា កលលរូប ។ បណ្ដាស្ត្រី បុរស និងខ្ទើយនោះ កលលរូបរបស់ស្ត្រី និងបុរស មានទំហំប៉ុនតំណក់ប្រេងល្ង ដែលជ្រលក់ឡើងដោយចុងរោមម្ខាងនៃរោមទ្រាយ ជារបស់ថ្លា ពិតហើយ ក្នុងអដ្ឋកថា លោកពោលពាក្យនេះថា

តំណក់ប្រេងល្ង ឬទឹកដោះថ្លា មិនល្អក់កករ យ៉ាងណា រូបមានចំណែកប្រៀបដូចពណ៌នោះ ហៅថា កលលរូប ។

អត្តភាពរបស់សត្វមានអាយុ ១២០ ឆ្នាំតាមប្រក្រតី ដែលដល់នូវការធំធាត់ដោយលំដាប់ក្នុងរវាងនេះ គឺចាប់ផ្តើមពីវត្ថុបដិចបន្ធចនោះ រហូតដល់ពេលស្លាប់ នេះឈ្មោះថា កាយមនុស្ស ។

ពីរបទថា **ជីវិតា វោរោបេយ្យ** សេចក្តីថា គប្បីផ្តាច់ចាកជីវិតដោយការសង្កត់ ប្របាច់ ឬដោយការដាក់ថ្នាំ ក្នុងកាលដែលនៅជាកលលៈក្តី ឬដោយសេចក្តីព្យាយាមដែលសមគួរដល់រូបនោះៗ ក្នុងកាលបន្ទាប់អំពីកលលៈនោះទៅក្តី ។ ដែលបានឈ្មោះថា ផ្តាច់បង់ចាកជីវិត ដោយអត្ថ គឺការបួលទៅកាត់ឥន្ទ្រិយ គឺជីវិតនោះឯង ព្រោះដូច្នោះ ក្នុងវារៈនៃការចែកបទទាំង ២ ថា ផ្តាច់បង់ចាកជីវិតនោះ ទើបព្រះឧបាលិត្ថេរពោលថា បួលទៅកាត់ គឺបួលទៅកាត់ឥន្ទ្រិយ គឺផ្តាច់ជីវិត ធ្វើការរស់នៅឲ្យដាច់ ។ ការបួលទៅកាត់ និងបួលទៅផ្តាច់ការបន្តការរស់នៅនៃឥន្ទ្រិយ គឺជីវិត លោកពោលថា រមែងបួលទៅកាត់ បួលទៅផ្តាច់ឥន្ទ្រិយ គឺជីវិត ក្នុងបទភាជនីយ៍នោះ ។ សេចក្តីនោះលោកសម្តែងដោយបទថា ធ្វើការបន្តឲ្យដាច់ខ្សែ ។

បទថា **វិកោបេតិ** គឺផ្តាច់បេញ ។ ក្នុងបទថា **ជីវិតិន្ទ្រិយ** នោះ ឥន្ទ្រិយ គឺជីវិតមាន ២ យ៉ាង គឺរូបជីវិតិន្ទ្រិយ ១ អរូបជីវិតិន្ទ្រិយ ១ ។ ក្នុងឥន្ទ្រិយ ២ យ៉ាងនោះ អរូបជីវិតិន្ទ្រិយ មិនមានសេចក្តីព្យាយាម បុគ្គលណាមួយមិនអាចផ្តាច់បង់អរូបជីវិតិន្ទ្រិយនោះបានឡើយ ។ តែក្នុងរូបជីវិតិន្ទ្រិយមាន គឺ

បុគ្គលអាចផ្ដាច់បង់បាន ។ កាលផ្ដាច់បង់រូបជីវិតិន្ទ្រិយនោះ ឈ្មោះថា ផ្ដាច់បង់អរូបជីវិតិន្ទ្រិយផងដែរ ។ ពិតហើយ អរូបជីវិតិន្ទ្រិយនោះ រមែងរលត់ព្រមនឹងរូបជីវិតិន្ទ្រិយនោះឯង ព្រោះមានការប្រព្រឹត្តទៅទាក់ទងដោយរូបជីវិតិន្ទ្រិយនោះ ។

សួរថា កាលផ្ដាច់បង់ជីវិតិន្ទ្រិយនោះ រមែងផ្ដាច់ត្រង់អតីត ឬដែលជាអនាគត ឬបច្ចុប្បន្ន ឆ្លើយថា មិនមែនអតីត មិនមែនអនាគត ។ ក្នុងជីវិតិន្ទ្រិយ ២ ប្រការនោះ ប្រការ ១ រលត់ទៅហើយ ប្រការ ១ មិនទាន់កើតឡើង ព្រោះដូច្នោះ ឈ្មោះថា មិនមានទាំង ២ ប្រការ ព្រោះជារបស់ដែលមិនមាន ទើបការព្យាយាមមិនមាន ព្រោះការព្យាយាមមិនមាន ទើបមិនអាចផ្ដាច់បាន ប្រការ ១ ។ ពិតហើយ ពាក្យនេះ ព្រះធម្មសេនាបតីសារីបុត្រក៏បានពោលថា សត្វដែលរស់នៅហើយ ក្នុងខណៈចិត្តដែលជាអតីត មិនមែនរស់នៅ នឹងមិនរស់នៅ ។ សត្វនឹងរស់នៅ ក្នុងខណៈចិត្តជាអនាគត មិនរស់នៅ មិនរស់នៅហើយ ។ សត្វកំពុងរស់នៅ ក្នុងខណៈចិត្តជាបច្ចុប្បន្ន មិនបានរស់នៅហើយ នឹងមិនរស់នៅ ព្រោះដូច្នោះ ជីវិតរមែងរស់នៅក្នុងខណៈចិត្តណា សេចក្ដីព្យាយាមជារបស់សមគួរក្នុងខណៈចិត្តនោះ ព្រោះហេតុនោះ បុគ្គលឈ្មោះថា រមែងផ្ដាច់ជីវិតិន្ទ្រិយដែលជាបច្ចុប្បន្ន ។

ឈ្មោះថា ជីវិតិន្ទ្រិយជាបច្ចុប្បន្ននេះ មាន ៣ យ៉ាង គឺខណៈបច្ចុប្បន្ន ១ សន្តតិបច្ចុប្បន្ន ១ អទ្ធាបច្ចុប្បន្ន ១ ។ ក្នុងខណៈ ៣ យ៉ាងនោះ បច្ចុប្បន្នដែលដល់ព្រមដោយការកើត ការវិនាស និងការបែកធ្លាយ ឈ្មោះ

បច្ចុប្បន្នក្ខណៈ បុគ្គលណាមួយមិនអាចនឹងផ្តាច់បច្ចុប្បន្នក្ខណៈនោះបានឡើយ ព្រោះហេតុអ្វី ព្រោះថា រលត់ទៅឯងនោះឯង ។ ( ខណៈចិត្ត ) ៧-៨ ជវនៈវារៈ ដែលប្រព្រឹត្តទៅដោយអំណាចសភាគៈសន្តតិហើយរលត់ទៅ ឈ្មោះសន្តតិបច្ចុប្បន្ន កាលបុគ្គលមកអំពីទីក្តៅ ចូលកាន់បន្ទប់តូច ហើយអន្ធយអន្ធការ គឺភាពងងឹតនៅមានត្រឹមណា ឬថា កាលបុគ្គលមកអំពីទីត្រជាក់អង្គុយក្នុងបន្ទប់តូច រដូវដែលមានពីមុន មិនទាន់រម្ងាប់ទៅ ដោយការប្រាកដនៃរដូវ ដែលជាវិសភាគៈគ្នាត្រឹមណា ក្នុងចន្លោះនេះ លោកហៅថា សន្តតិបច្ចុប្បន្នត្រឹមនោះ ។ ចំណែកតាំងអំពីបដិសន្ធិ ទៅទល់នឹងចុតិ នេះឈ្មោះថា អទ្ធាបច្ចុប្បន្ន ។ បុគ្គលអាចផ្តាច់ជីវិត ២ នៃជីវិតិន្ទ្រិយដែលជាសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ននោះបានខ្លះ សួរថា អាចផ្តាច់បានដូចម្តេច ឆ្លើយថា ពិតហើយ កាលបុគ្គលធ្វើការព្យាយាមក្នុងជីវិត ២ នៃសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ននោះ ក្រុមនៃរូប ១០ ប្រការ ដែលកំណត់ដោយជីវិត បានសេចក្តីព្យាយាមហើយ កាលរលត់ រមែងជាបច្ច័យនៃសន្តានដែលទុព្វល មានកម្លាំងវិនាសអស់ទៅហើយ បន្ទាប់អំពីនោះ សន្តតិបច្ចុប្បន្ន ឬអទ្ធាបច្ចុប្បន្ន មិនទាន់ដល់កាលដែលកំណត់ទុក រមែងរលត់ទៅក្នុងចន្លោះនោះ ដោយប្រការណា បុគ្គលអាចផ្តាច់នូវជីវិតិន្ទ្រិយ ២ ក្រុម ដែលជាសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ននោះបានខ្លះ ដោយប្រការនោះ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថា ពាក្យថា ធ្វើការបន្តឲ្យដាច់ខ្សែនេះ លោកពោលសំដៅយកបច្ចុប្បន្ន ២ នេះឯង ។

ដើម្បីប្រកាសសេចក្ដីនេះ គួរជ្រាបបាណៈ គួរជ្រាបបាណាតិបាត គួរជ្រាបបាណាតិបាតី គួរជ្រាបប្រយោគនៃបាណាតិបាត ។

បណ្ដាបាណៈជាដើមទាំងនោះ ដែលឈ្មោះថា បាណៈ ដោយវោហារ បានដល់ សត្វ ដោយបរមត្ថ បានដល់ ជីវិតិន្ទ្រិយ ។ ពិតហើយ បុគ្គលដែលញុំាងជីវិតិន្ទ្រិយឲ្យធ្លាក់កន្លងទៅ លោកពោលថា ញុំាងសត្វមានជីវិតឲ្យធ្លាក់កន្លងទៅ ។ ជីវិតិន្ទ្រិយនោះ មានប្រការដូចពោលហើយនោះឯង ។ បាណាតិបាតនោះ គឺបុគ្គលញុំាងប្រយោគដែលចូលទៅកាត់បង់នូវជីវិតិន្ទ្រិយឲ្យតាំងឡើងដោយចេតនាណា ចេតនានោះ ឈ្មោះថា វធកចេតនា លោកហៅថា បាណាតិបាត ( ចេតនាជមិជាហេតុផ្ដាច់បង់ជីវិតសត្វដែលមានបាណៈ ) ។ បុគ្គលដែលដល់ព្រមដោយចេតនាដូចពោលហើយ គប្បីឃើញថា ជាអ្នកផ្ដាច់បង់សត្វដែលមានបាណៈ ។

## ប្រយោគនៃបាណាតិបាត ៦ យ៉ាង

ដែលឈ្មោះថា ប្រយោគនៃបាណាតិបាតនោះ បានដល់ ប្រយោគនៃបាណាតិបាត ៦ យ៉ាង គឺសាហត្ថិកប្បយោគ ១ អាណត្តិកប្បយោគ ១ និស្សគ្គិយប្បយោគ ១ ថាវរប្បយោគ ១ វិជ្ជាមយប្បយោគ ១ ឥទ្ធិមយប្បយោគ ១ ។ បណ្ដាប្រយោគទាំងនោះ ការប្រហារដោយកាយ ឬរបស់ដែលទាក់ទងដោយកាយ នៃបុគ្គលអ្នកសម្លាប់ឲ្យស្លាប់ដោយខ្លួនឯង ឈ្មោះថា **សាហត្ថិប្បយោគ** ។ ការប្រើថា លោកចូរចាក់ ឬប្រហារឲ្យស្លាប់ដោយឧបាយយ៉ាងនេះរបស់បុគ្គលអ្នកប្រើគេ ឈ្មោះថា **អាណាត្តិកប្បយោគ**។

ការពួយគ្រឿងប្រហារ មានព្រួញ លំពែងយន្ត និងថ្មយន្តជាដើមទៅដោយកាយ ឬរបស់ដែលជាប់នឹងកាយ នៃបុគ្គលដែលបំណងនឹងសម្លាប់បុគ្គលដែលនៅទីឆ្ងាយ ឈ្មោះថា **និស្សគ្គិយប្បយោគ ។** ការជីករណ្ដៅដាក់ក្ដារឲ្យធ្លាក់ ដាក់គ្រឿងប្រហារទុកក្នុងទីជិត និងការដាក់ថ្នាំ ( ពិស ) នៃបុគ្គលដែលបំណងនឹងសម្លាប់ដោយគ្រឿងឧបករណ៍ ដែលមិនឃ្លាតចាកទី ឈ្មោះថា **ថាវរប្បយោគ ។** ប្រយោគទាំង ៤ នេះ នឹងមានច្បាស់ដោយពិស្ដារក្នុងអដ្ឋកថានៃបាលីខាងមុខនោះឯង ចំណែកវិជ្ជាមយប្បយោគ និងឥទ្ធិមយប្បយោគ មិនបានមកក្នុងបាលី ។ គប្បីជ្រាបប្រយោគទាំង ២ នោះយ៉ាងនេះ ។ ឯដោយសង្ខេប ការរាយមន្តដើម្បីឲ្យគេស្លាប់ ឈ្មោះថា **វិជ្ជាមយប្បយោគ ។** តែក្នុងអដ្ឋកថាទាំងឡាយ លោកសម្ដែងវិជ្ជាមយប្បយោគទុកយ៉ាងនេះថា វិជ្ជាមយប្បយោគដូចម្ដេច ពួកគ្រូអថ៌ន រមែងប្រកបអថ៌ន កាលក្រុងត្រូវឡោមព័ទ្ធ ឬកាលសង្គ្រាមចូលប្រឈមមុខគ្នា រមែងបង្កើតសេចក្ដីចង្រៃ សេចក្ដីឧបទ្រព រោគ ជំងឺតម្កាត់ឲ្យកើតឡើងក្នុងពួកបច្ចាមិត្រដែលជាសត្រូវ រមែងធ្វើឲ្យកើតរោគបុកសៀត ឲ្យជារោគក្អួតចង្អោរ ដើម្បីការពារ ពួកគ្រូអថ៌នរមែងប្រកបអថ៌នយ៉ាងនេះ ពួកអ្នកទ្រទ្រង់វិទ្យាគុណ រាយវេទហើយ កាលទីក្រុងត្រូវឡោមព័ទ្ធ ។បេ។ រមែងធ្វើឲ្យកើតរោគចុះរាគ ដូច្នោះហើយ ពោលរឿងជាច្រើនរបស់មនុស្សទាំងឡាយ ដែលត្រូវគ្រូអថ៌ន និងពួកអ្នកទ្រទ្រង់វិទ្យាគុណសម្លាប់ នឹងមានប្រយោជន៍អ្វីដោយរឿងទាំងនោះ ឯលក្ខណៈក្នុងវិជ្ជាមយប្បយោគនេះ មានដូច្នេះថា ការរាយមន្តដើម្បីឲ្យគេស្លាប់ ឈ្មោះ

ថា **វិជ្ជាមយប្បយោគ** ។ ការប្រកបឫទ្ធិដែលកើតអំពីកម្ម ឈ្មោះថា **ឥទ្ធិ-មយប្បយោគ** ។ ពិតហើយ ឈ្មោះថា ឫទ្ធិដែលកើតអំពីផលនៃកម្មនេះ មានច្រើនយ៉ាង គឺឫទ្ធិនាគរបស់ពួកនាគ ឫទ្ធិគ្រុឌរបស់ពួកគ្រុឌ ទេវឫទ្ធិរបស់ពួកទេវតា រាជឫទ្ធិរបស់ព្រះរាជា ។ បណ្ដាឫទ្ធិនាគជាដើមនោះ គប្បីជ្រាបឫទ្ធិនាគរបស់ពួកនាគ ដែលមានពិសក្នុងខណៈឃើញ ចឹក ខាំ និងពាល់ត្រូវ ខណៈធ្វើការបៀតបៀនសត្វដទៃ ព្រោះឃើញ ចឹក ខាំ ពាល់ត្រូវ គប្បីជ្រាប ឫទ្ធិគ្រុឌរបស់ពួកគ្រុឌ ក្នុងការឆក់នាគប្រវែងប្រមាណ ១៣២ ព្យាមឡើងអំពីមហាសមុទ្រ ។ ចំណែកពួកយក្ខ កាលមកមិនប្រាកដ កាលប្រហារក៏មិនប្រាកដ តែសត្វដែលពួកយក្ខទាំងនោះប្រហារហើយ រមែងស្លាប់ក្នុងទីនោះឯង គប្បីជ្រាបឫទ្ធិយក្ខរបស់ពួកយក្ខទាំងនោះ ព្រោះហេតុនោះ គប្បីជ្រាបទេវឫទ្ធិ ព្រោះការស្លាប់របស់ពួកកុម្ភណ្ឌ ដែលព្រះបាទវេស្សវណសម្លឹងមើលដោយនយនាវុធ ក្នុងកាលមុនខ្លួនលោកជាព្រះសោតាបន្ន និងព្រោះឫទ្ធានុភាពរៀងៗ ខ្លួននៃពួកទេវតាដទៃ ។ គប្បីជ្រាបរាជឫទ្ធិ ព្រោះការហោះទៅបានក្នុងអាកាសជាដើមរបស់ស្ដេចចក្រពត្តិ មួយអន្លើដោយបរិស័ទ ព្រោះការផ្សាយព្រះរាជអំណាចទៅជាដើមក្នុងទីមួយយោជន៍ ទាំងខាងក្រោម និងខាងលើរបស់ព្រះបាទអសោក និងព្រោះការសម្លាប់នូវកុដុម្ពិកៈ ឈ្មោះចូឡ-សុមនៈ ដោយការដំចង្កូមនៃព្រះរាជាសីហឡ ឈ្មោះបិតុរាជ ដូច្នេះឯង ។

ចំណែកអាចារ្យពួកខ្លះសម្ដែងព្រះសូត្រទាំងឡាយជាដើមថា ម្នាលភិក្ខុទាំងឡាយ រឿងដទៃនៅមានទៀត សមណៈ ឬព្រាហ្មណ៍ដែលមានឫទ្ធិ ដល់

នូវភាពជាអ្នកជំនាញនៃចិត្ត រមែងជាអ្នកសម្លឹងទារកដែលនៅក្នុងផ្ទៃរបស់ស្រីដទៃ ដោយចិត្តដ៏លាមកថា ធ្វើម្ដេចហ្ន៎ ស្រីម្នាក់នេះ មិនគប្បីប្រសូតទារកដែលនៅក្នុងផ្ទៃនោះដោយសួស្ដី ម្នាលភិក្ខុទាំងឡាយ សូម្បីយ៉ាងនេះ ក៏ជាការបៀតបៀនសត្វដែលនៅក្នុងគភ៌ ដូច្នេះហើយ ពោលដល់កម្ម គឺការបៀតបៀនសត្វដទៃដោយការនាមយប្ញទ្ធិ និងប្រាថ្នាសេចក្ដីវិនាសទៅនៃឫទ្ធិ ទាំងការបៀតបៀនសត្វដទៃ ដូចការបែកនៃក្អមទឹក ដែលគេបោះឡើងទៅលើផ្ទះដែលត្រូវភ្លើងឆេះ ដូច្នោះ ។ ពាក្យដែលពោលមកនោះ ត្រឹមតែការប្រាថ្នារបស់គេចិអាចារ្យទាំងនោះប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ព្រោះមិនសម ដោយ **កុសលត្តិក វេទនត្តិក វិតក្កត្តិក** និង **បរិត្តត្តិក** សេចក្ដីនេះដូចម្ដេច ដែលឈ្មោះថា ការនាមយប្ញទ្ធិនេះ ក្នុងកុសលត្តិកៈ ជាកុសលផង ជាអព្យាកតៈផង បាណាតិបាតជាអកុសល ក្នុងវេទនត្តិកៈសម្បយុត្តដោយអទុក្ខមសុខ បាណាតិបាតសម្បយុត្តដោយទុក្ខ ក្នុងវិតក្កត្តិកៈ ជាអវិតក្កអវិចារៈ បាណាតិបាត ជាសវិតក្កសវិចារៈ ក្នុងបរិត្តត្តិកៈ ជាមហគ្គតៈ បាណាតិបាត ជាបរិត្ត ។

## អធិប្បាយ វត្ថុដែលជាគ្រឿងប្រហារ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សត្ថហារកំ វាស្ស បរិយេសេយ្យ** ដូច្នេះ តទៅនេះថា គ្រឿងប្រហារណា រមែងនាំចេញ ហេតុនោះ គ្រឿងប្រហារនោះ ឈ្មោះថា របស់នាំចេញ ។ សួរថា នាំចេញនូវអ្វី ឆ្លើយថា នាំចេញនូវជីវិត ។ ម្យ៉ាងទៀត គ្រឿងប្រហារណា ដែលបុគ្គលនាំទៅ ហេតុ

នោះ គ្រឿងប្រហារនោះ ឈ្មោះថា វត្ថុដែលបុគ្គលគប្បីនាំទៅ អធិប្បាយថា គ្រឿងប្រហារ ដែលបុគ្គលគប្បីរៀបចំទុក សស្ត្រានោះផង ជាវត្ថុនាំចេញផង ហេតុនោះ ឈ្មោះថា សស្ត្រាដែលនាំចេញ ។

បទថា **អស្ស** បានដល់ កាយរបស់មនុស្ស ។

បទថា **បរិយេសេយ្យ** សេចក្ដីថា គប្បីធ្វើដោយប្រការដែលខ្លួននឹងបាន ។ អធិប្បាយថា គប្បីរៀបចំទុក ។ ដោយពាក្យថា **សត្ថហារកំ វាស្ស បរិយេសេយ្យ** នេះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងថាវប្បយោគ ។ កាលកាន់យកអត្ថដោយប្រការដទៃក្រៅអំពីនេះហើយ ភិក្ខុនឹង គប្បីត្រូវអាបត្តិបារាជិក ដោយហេតុត្រឹមតែសស្ត្រាដែលខ្លួនស្វែងរកមកហើយប៉ុណ្ណោះ ។ សេចក្ដីពិត សេចក្ដីនោះមិនត្រឹមត្រូវ តែក្នុងព្រះបាលី ព្រះឧបាលីមិនអើពើព្យញ្ជនៈទាំងពួង ដើម្បីនឹងសម្ដែងចំពោះសស្ត្រា ដែលសង្គ្រោះចូលក្នុងថាវប្បយោគ ក្នុងពាក្យថា **សត្ថហារកំ** នេះប៉ុណ្ណោះ ទើបពោលទុកក្នុងបទភាជនីយ៍ថា **អសឹ វា ។បេ។ រជ្ជុំ វា** ដូច្នេះ ។ បណ្ដាគ្រឿងប្រហារទាំងនោះ គ្រឿងប្រហារដែលមានមុខមុត ប្រភេទណានីមួយ ដែលក្រៅអំពីពោលហើយ គប្បីជ្រាបថា ជាសស្ត្រា ។ និងគប្បីជ្រាបថា សង្គ្រោះដំបង ដុំថ្ម ថ្នាំពិស និងខ្សែចូលជាសស្ត្រាផងដែរ ព្រោះជាគ្រឿងផ្ដាច់ជីវិតឲ្យវិនាស ។

[ ១៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **មរណវណ្ណំ វា** នេះ ដូចតទៅនេះ ភិក្ខុ សូម្បីសម្ដែងទោសក្នុងការរស់នៅ ដោយន័យមានពាក្យថា នឹងមានប្រយោជន៍អ្វី ដោយការរស់នៅដ៏អាក្រក់លាមកដូច្នេះរបស់អ្នក ដែល

មិនបានដើម្បីបរិភោគភោជនដែលល្អ ដូច្នេះជាដើម ឬពោលសរសើរគុណនៃសេចក្តីស្លាប់ ដោយន័យ មានពាក្យថា ឧបាសក អ្នកឯងជាបុគ្គលបានធ្វើកល្យាណកម្មទុកហើយ ។បេ។ បាបអ្នកមិនបានធ្វើឡើយ ការស្លាប់របស់អ្នកល្អជាងការរស់នៅ អ្នកស្លាប់អំពីអត្តភាពនេះហើយ ។បេ។ នឹងញុំាងខ្លួនឲ្យត្រាច់ទៅ គឺនឹងមានស្រីទេពអប្សរចោមរោម ដល់នូវសេចក្តីសុខ ក្នុងសួននន្ទនវ័ន ដូច្នេះជាដើម ឈ្មោះថា ពណ៌នាគុណនៃសេចក្តីស្លាប់នោះឯង ដូច្នោះ ។ ទើបព្រះឧបាលិត្ថេរពោលបទភាជនីយ៍ ញែកបំបែកជា ២ ចំណែក ថា ចង្អុលទោសក្នុងការរស់នៅ ១ សរសើរគុណក្នុងការស្លាប់ ១ ។

[ ១៨៣ ] ពាក្យថា **មរណាយ វា សមាទបេយ្យ** សេចក្តីថា គប្បីដឹកនាំជួយរកឧបាយដើម្បីប្រយោជន៍ការស្លាប់ ។ ចំណែកពាក្យថា ចូរអ្នកលោតទម្លាក់អណ្តូងឲ្យស្លាប់ ឬលោតទម្លាក់ជ្រោះឲ្យស្លាប់ជាដើម ដែលព្រះឧបាលិត្ថេរមិនបានពោលទុក ក្នុងពាក្យជាដើមថា **សត្ថំ វា អាហារ** ដូច្នេះទាំងអស់ ក៏គប្បីជ្រាបថា លោកពោលទុកហើយ ដោយអត្ថនោះឯង ព្រោះជាពាក្យដែលមានន័យដូចពោលហើយខាងមុខ ។ ពិតហើយ បុគ្គលណាមួយក៏មិនអាចពោលពាក្យដឹកនាំគ្រប់យ៉ាង ដោយឥតសេសសល់បានឡើយ ។

[ ១៨៤ ] បទថា **ឥតិចិត្តមនោ** សេចក្តីថា ភិក្ខុមានចិត្តយ៉ាងនេះ មានមនោយ៉ាងនេះ ។ អធិប្បាយថា ភិក្ខុនោះមានចេតនាចង់ឲ្យស្លាប់ មានសេចក្តីប៉ុនប៉ងចង់ឲ្យស្លាប់ ដូចពោលហើយក្នុងពាក្យនេះថា ការស្លាប់របស់អ្នកល្អជាងការរស់នៅ ព្រោះក្នុងបទថា **ចិត្តមនោ** នេះ **មន** សព្ទ លោក

ពោលហើយ ដើម្បីសម្តែងអត្ថនៃ **ចិត្ត** តែចិត្ត និងមនោ ទាំង ២ នេះ ដោយអត្ថ គឺដូចគ្នានោះឯង ព្រោះដូច្នោះ ដើម្បីសម្តែងការមិនផ្សេងគ្នា ដោយអត្ថនៃចិត្ត និងមនោនោះ ទើបព្រះឧបាលិត្ថេរពោលថា ធម្មជាតឯណាជាចិត្ត ធម្មជាតនោះឯង គឺមនោ ធម្មជាតឯណាជាមនោ ធម្មជាតនោះឯង គឺចិត្ត ។ ចំណែកអត្ថ មិនទាន់បានពោលជាបឋមឡើយ ព្រោះដក **ឥតិ** ចេញ ។ **ឥតិ** គប្បីទាញមកដោយអំណាចជាម្ចាស់ ក្នុងបទថា **ចិត្តសង្កប្បោ** នេះ ។

ពិតហើយ បទថា **ចិត្តសង្កប្បោ** នេះ សូម្បីមិនបានត្រាស់យ៉ាងនេះថា **ឥតិចិត្តសង្កប្បោ** ក៏គប្បីជ្រាបថា ជាការត្រាស់ហើយ ដោយភាពជាប្រធាននោះឯង ។ ពិតហើយ កាលលោកសម្តែងចំពោះអត្ថនោះនៃបទថា **ចិត្តសង្កប្បោ** នោះ ទើបពោលពាក្យថា **មរណសញ្ញី** ( មានការសម្គាល់ក្នុងការស្លាប់ ) ជាដើម ។ តែពាក្យថា **សង្កប្បោ** នេះ ក្នុងបទថា **ចិត្ត-សង្កប្បោ** នោះ មិនបានជាឈ្មោះរបស់វិតក្កៈ ដែលពិតនោះ ពាក្យនោះជាពាក្យហៅកម្ម ត្រឹមតែការចាត់ចែង ហើយការចាត់ចែងនោះ រមែងដល់នូវការសង្គ្រោះដោយអត្ថ ការចងចិត្ត និងការបំណងក្នុងអត្ថនេះ ព្រោះហេតុនោះ អ្នកសិក្សាគប្បីឃើញអត្ថយ៉ាងនេះថា ឈ្មោះថា បុគ្គលមានចិត្តសង្កប្ប ព្រោះអត្ថវិគ្គហៈថា លោកមានការចាត់ចែងប្លែក គឺមានប្រការផ្សេងៗ ។ ពិតហើយ សូម្បីបទភាជនីយ៍នៃបទថា **ចិត្តសង្កប្បោ** នេះ ព្រះឧបាលិត្ថេរក៏ពោលដោយអំណាចនៃអត្ថការផ្តោតចិត្ត និងសេចក្តីបំណង ។ តែក្នុងអធិការនេះ វិតក្កៈគប្បីជ្រាបថា ជាសេចក្តីបំណង ។

ពីរបទថា **ឧច្ចាវចេហិ អាកាវេហិ** សេចក្តីថា ដោយឧបាយទាំងឡាយដែលធំ និងធំដោយលំដាប់ ។ បណ្តាការពណ៌នាគុណនៃសេចក្តីស្លាប់ និងការដឹកនាំក្នុងការស្លាប់ទាំងនោះ ក្នុងការពណ៌នាគុណនៃការស្លាប់មុន **អវចាការតា** គប្បីជ្រាបដោយអំណាចការបង្ហាញទោសក្នុងការរស់នៅ **ឧច្ចាការតា** គប្បីជ្រាបដោយអំណាចការសរសើរគុណនៃសេចក្តីស្លាប់ ។ ចំណែកក្នុងការដឹកនាំ **ឧច្ចាការតា** គប្បីជ្រាបដោយអំណាចការដឹកនាំក្នុងសេចក្តីស្លាប់ ព្រោះហេតុទាំងឡាយ មានក្តាប់ដៃ និងបត់ជង្គង់ជាដើម **អវចាការតា** គប្បីជ្រាបដោយអំណាចការដាក់ថ្នាំពិសចូលក្នុងក្រចកដៃរបស់បុគ្គលអ្នកបរិភោគរួមគ្នា ហើយដឹកនាំក្នុងសេចក្តីស្លាប់ជាដើម ។

[ ១៨៥ ] ក្នុងពាក្យថា **សោព្ភេ វា នរកេ វា បបាតេ វា** មានវិនិច្ឆ័យដូច្នេះ អណ្តូងដែលជ្រៅដែលមានប្រាំងចោតដោយជុំវិញ ឈ្មោះថា **សោព្ភ**។ ដែលឈ្មោះថា **នរក** បានដល់ ជ្រលងធំដែលកើតឯង ក្នុងកាលផែនដីប្រេះក្រហែងក្នុងទីនោះៗ ដែលជាទីធ្លាក់ដ៏រីទៅខ្លះ ពួកចោរលាក់ខ្លួនខ្លះ ។ ឈ្មោះថា **បបាត** បានដល់ ប្រទេសដែលដាច់តែម្ខាងក្នុងចន្លោះភ្នំ ឬក្នុងចន្លោះលើគោក ។

[ ១៨៦ ] ពីរបទថា **បុរិមេ ឧបាទាយ** សេចក្តីថា ទ្រង់ប្រៀបធៀបបុគ្គលដែលសេពមេថុនធម្ម និងអ្នកដែលកាន់យកទ្រព្យដែលម្ចាស់គេមិនបានឲ្យ ហើយត្រូវអាបត្តិបារាជិក ពាក្យដ៏សេសប្រាកដច្បាស់ហើយនោះឯង ព្រោះមានន័យដូចពោលហើយអំពីមុន និងព្រោះមានអត្ថងាយយល់ហើយដូច្នេះឯង ។

សិក្ខាបទវិភង្គនៃតតិយបារាជិក ចប់

# អធិប្បាយ
# បទភាជនីយ៍នៃតតិយចាតុក្កៈ

[ ១៨៧-១៨៨ ] ព្រះឧបាលិត្ថេរ កាលចែកសិក្ខាបទ ដែលព្រះដ៏មានព្រះភាគទ្រង់ឧទ្ទេសទុកហើយតាមលំដាប់បទយ៉ាងនេះ ឥឡូវនេះ កាលនឹងតាំងមាតិកា សម្តែងមនុស្សវិគ្គហបារាជិកដោយពិស្តារ ដោយន័យជាដើមថា **សាមំ អធិដ្ឋាយ** ដូច្នេះទៀត ដើម្បីឲ្យភិក្ខុទាំងឡាយកាន់យកន័យ ដោយអាការគ្រប់យ៉ាង និងដើម្បីការពារឱកាសរបស់បាបបុគ្គលទាំងឡាយ ក្នុងអនាគត ព្រោះថា មនុស្សវិគ្គហបារាជិក ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងក្នុងបទភាជនីយ៍ខាងដើមដោយសង្ខេបប៉ុណ្ណោះ ទ្រង់មិនបានលើកអាបត្តិឡើងកាត់ ហើយដាក់បែបផែនទុកដោយពិស្តារឡើយ ភិក្ខុទាំងឡាយមិនអាចនឹងកាន់យកន័យទុកដោយអាការទាំងពួង ក្នុងអត្ថដែលទ្រង់សម្តែងទុកដោយសង្ខេប សូម្បីបាបបុគ្គលទាំងឡាយ ក្នុងអនាគតក៏មានឱកាស ទើបពោលពាក្យថា **សាមន្តិ សយំ ហនតិ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ មានពាក្យសម្រាប់វិនិច្ឆ័យ ព្រមដោយការពណ៌នាបទ ដែលលំបាកដូចតទៅនេះថា បទថា **កាយេន** សេចក្តីថា ដោយដៃ ជើង កណ្តាប់ដៃ ឬក្បាលជន្គង់ ឬដោយអវយវៈតូច-ធំ ឯណានីមួយ ។

បទថា **កាយប្បដិពទ្ធេន** សេចក្តីថា ដោយគ្រឿងប្រហារ មានដាវជាដើមដែលជាប់នឹងកាយ ។

បទថា **និស្សគ្គិយេន** សេចក្តីថា ដោយគ្រឿងប្រហារ មានព្រួញ និងលំពែងជាដើមដែលផុតចាកកាយ ឬចាករបស់ដែលជាប់ដោយកាយ ដោយ

លំដាប់នៃពាក្យមានប្រមាណប៉ុណ្ណោះ ប្រយោគទាំង ២ គឺសាហត្ថិកប្បយោគ និងនិស្សគ្គិយប្បយោគ ឈ្មោះថា លោកពោលហើយ ។ ក្នុងប្រយោគទាំង ២ នោះ ក្នុងមួយប្រយោគមាន ២ យ៉ាង ដោយចែកជាប្រយោគចំពោះ និងមិនចំពោះ ។

បណ្តាប្រយោគចំពោះ និងមិនចំពោះ គប្បីជ្រាបវិនិច្ឆ័យក្នុងប្រយោគចំពោះដូចតទៅនេះថា ភិក្ខុប្រហារចំពោះបុគ្គលណា ដោយការស្លាប់របស់បុគ្គលនោះឯង ភិក្ខុនោះរមែងត្រូវកម្មពន្ធ គឺចំណងកម្ម ។ ក្នុងប្រយោគដែលមិនចំពោះយ៉ាងនេះថា បុគ្គលណាមួយចូរស្លាប់ដូច្នេះ ដោយការស្លាប់របស់បុគ្គលណាមួយ ព្រោះការប្រហារជាបច្ច័យ ភិក្ខុរមែងត្រូវកម្មពន្ធ ។ ទាំង ២ ប្រយោគ បុគ្គលត្រូវប្រហារនឹងស្លាប់ក្នុងខណៈគ្រាន់តែត្រូវប្រហារ ឬនឹងស្លាប់ ក្នុងកាលខាងក្រោយដោយរោគនោះក៏ដោយ ភិក្ខុរមែងត្រូវចំណងកម្មក្នុងខណៈដែលបុគ្គលស្លាប់ត្រូវប្រហារនោះឯង ។ តែកាលភិក្ខុឲ្យប្រហារដោយសេចក្តីបំណងដើម្បីការស្លាប់ កាលបុគ្គលត្រូវប្រហារមិនស្លាប់ដោយការប្រហារនោះ ទើបឲ្យការប្រហារដោយចិត្តដួងដទៃតទៅ បើបុគ្គលដែលត្រូវប្រហារស្លាប់ដោយការប្រហារគ្រាដំបូង ក្នុងកាលខាងក្រោយ ភិក្ខុត្រូវកម្មពន្ធ ក្នុងវេលាប្រហារ គ្រាដំបូងប៉ុណ្ណោះ បើស្លាប់ដោយការប្រហារគ្រាទី ២ មិនជាបាណាតិបាត កាលបុគ្គលត្រូវប្រហារស្លាប់ដោយការប្រហារទាំង ២ លើក ភិក្ខុក៏ត្រូវកម្មពន្ធ ដោយការប្រហារគ្រាដំបូងនោះឯង បើមិនស្លាប់ដោយការប្រហារទាំងពីរលើក ក៏មិនមានបាណាតិបាតដូចគ្នា ។ ក្នុងការដែលមនុស្សច្រើននាក់ធ្វើការប្រហារដល់បុគ្គលម្នាក់ក៏មានន័យនេះ សូម្បីក្នុង

ការដែលមនុស្សច្រើននាក់ធ្វើនូវការប្រហារនោះ បុគ្គលដែលត្រូវគេប្រហារស្លាប់ដោយការប្រហាររបស់បុគ្គលណា កម្មពន្ធ រមែងមានដល់បុគ្គលនោះប៉ុណ្ណោះ ដូច្នេះឯង ។

## អំពីអនន្តរិយកម្ម និងបារាជិក

ម្យ៉ាងទៀត ក្នុងអធិការនៃតតិយបារាជិកនេះ ដើម្បីការឈ្លាសក្នុងកម្ម និងអាបត្តិ គប្បីជ្រាបដោយរឿងឯឡកចតុក្កៈ ។ ពិតហើយ ភិក្ខុអង្គណា ឃើញចៀមដេកនៅក្នុងទីមួយកន្លែង ដោយគិតក្នុងចិត្តថា អញនឹងមកសម្លាប់ក្នុងពេលយប់ ។ ហើយមាតាក្តី បិតារបស់ភិក្ខុនោះក្តី ឬព្រះអរហន្តដណ្តប់សំពត់កាសាវៈពណ៌លឿង ហើយដេកនៅក្នុងឱកាសដែលចៀមដេក ។ ភិក្ខុមកវេលាយប់ ធ្វើទុកក្នុងចិត្តថា អញនឹងសម្លាប់ចៀមឲ្យស្លាប់ ដូច្នេះ ទើបសម្លាប់មាតាបិតា ឬព្រះអរហន្តឲ្យស្លាប់ ។ ព្រោះមានចេតនាថា អញនឹងសម្លាប់វត្ថុនេះឲ្យស្លាប់ ទើបភិក្ខុជាអ្នកសម្លាប់ផង ពាល់ត្រូវអនន្តរិយកម្មផង ត្រូវអាបត្តិបារាជិកផង ។ បើមានជនអាគន្តុកៈដទៃមកដេក ។ ភិក្ខុធ្វើទុកក្នុងចិត្តថា អញនឹងសម្លាប់ចៀមឲ្យស្លាប់ ទើបសម្លាប់ជនអាគន្តុកៈនោះស្លាប់ បាត់ជា ឃាតកផង ត្រូវអាបត្តិបារាជិកផង តែមិនត្រូវអនន្តរិយកម្ម ។ បើយក្ខ ឬប្រេតមកដេក ភិក្ខុនោះធ្វើទុកក្នុងចិត្តថា អញនឹងសម្លាប់ចៀមឲ្យស្លាប់ ទើបសម្លាប់យក្ខ ឬប្រេតនោះស្លាប់ ជាឃាតក តែមិនត្រូវអនន្តរិយកម្ម និងមិនត្រូវអាបត្តិបារាជិក ត្រូវតែអាបត្តិថុល្លច្ច័យប៉ុណ្ណោះ ។ បើមិនមានបុគ្គលណាមួយដេក មានតែចៀមប៉ុណ្ណោះ ភិក្ខុសម្លាប់ចៀមនោះ ជាឃាតកផង

ត្រូវអាបត្តិបាចិត្តិយផង ។ ភិក្ខុណាគិតក្នុងចិត្តថា អញនឹងសម្លាប់មាតា បិតា និងព្រះអរហន្ត ណាមួយ ឲ្យស្លាប់ដូច្នេះហើយ ក៏សម្លាប់បណ្ដាជនទាំងនោះឯង ណាមួយឲ្យស្លាប់ ភិក្ខុនោះ ជាឃាតកផង ជាអនន្តរិយកម្មផង ត្រូវអាបត្តិបារាជិកផង ។ ភិក្ខុគិតក្នុងចិត្តថា អញនឹងសម្លាប់មាតាបិតា និងព្រះអរហន្តទាំងនោះឯង ណាមួយឲ្យស្លាប់ ហើយសម្លាប់អាគន្តុកជនដទៃឲ្យស្លាប់ ឬសម្លាប់យក្ខ ប្រេត ឬចៀមស្លាប់ អ្នកសិក្សាគប្បីជ្រាប ( អាបត្តិ គឺបារាជិក ថុល្លច្ច័យ និងបាចិត្តិយ ) ក្នុងន័យដូចពោលហើយខាងដើមនោះឯង ។ តែក្នុងវិស័យនៃការសម្លាប់សត្វ មានអាគន្តុកជនជាដើមនេះ ចេតនារមែងជារបស់ទារុណ ដូច្នេះ ។

ក្នុងវិស័យនៃតតិយបារាជិកនេះ អ្នកសិក្សាគួរជ្រាបរឿងទាំងឡាយផ្សេងទៀត មានពំនូកចំបើងជាដើម ។ ពិតហើយ ភិក្ខុណា គិតក្នុងចិត្តថា អញនឹងជូតដាវ ឬលំពែងដែលប្រឡាក់ឈាម ហើយចាក់ចូលទៅក្នុងពំនូកចំបើងស្លាប់មាតាក្តី បិតាក្តី ព្រះអរហន្តក្តី មនុស្សអាគន្តុកៈក្តី យក្ខក្តី ប្រេតក្តី សត្វតិរច្ឆានក្តី ដែលដេកនៅក្នុងពំនូកចំបើងនោះ ភិក្ខុនោះ ដោយអំណាចនៃវោហារ ហៅថា ឃាតកបាន តែព្រោះមិនមានវធកចេតនា ទើបភិក្ខុមិនត្រូវកម្មពន្ធ ទាំងមិនត្រូវអាបត្តិ ។ ចំណែកភិក្ខុណា កាលកំពុងចាក់ ( ដាវ ឬលំពែងនោះ ) ចូលទៅដោយអាការយ៉ាងនោះ កំណត់បានថា ប៉ះនឹងរាងកាយ ក៏ចាក់ចូលទៅសម្លាប់ឲ្យស្លាប់ ដោយគិតថា ប្រហែលជាមានសត្វនៅខាងក្នុង សត្វនោះចូរស្លាប់ចុះ ។ កម្មពន្ធផង អាបត្តិរបស់ភិក្ខុនោះផង គប្បី

ជ្រាបដោយសមគួរដល់រឿងទាំងនោះ ។ កាលភិក្ខុចាក់ចូលទៅដើម្បីរក្សាទុកក្នុងពាំទូកចំបើងនោះក្តី ពួយចូលទៅត្រង់គុម្ពឈើក្នុងព្រៃជាដើមក្តី ក៏មានន័យដូច្នេះ ។

ភិក្ខុណា គិតថា អញនឹងសម្លាប់ចោរឲ្យស្លាប់ ហើយក៏សម្លាប់បិតាដែលកំពុងដើរទៅដោយដូចជាចោរ ភិក្ខុនោះរមែងត្រូវអនន្តរិយកម្មផង ត្រូវបារាជិកផង ។ ចំណែកភិក្ខុណាឃើញអ្នកចម្បាំងដទៃ និងបិតាដែលកំពុងធ្វើការ ( ច្បាំង ) នៅក្នុងសេនាចំណែកសត្រូវ ទើបបាញ់ព្រួញផ្ដោះទៅរកអ្នកចម្បាំង ដោយគិតក្នុងចិត្តថា ព្រួញទម្លុះអ្នកចម្បាំងនោះហើយ នឹងទម្លុះបិតារបស់អញចុះ ។ ភិក្ខុអង្គនោះ រមែងឈ្មោះថា បិតុឃាត ( អ្នកសម្លាប់បិតា ) ក្នុងកាលព្រួញស៊ុះទៅតាមបំណង ។ ភិក្ខុគិតក្នុងចិត្តថា កាលអ្នកចម្បាំងត្រូវព្រួញទម្លុះហើយ បិតារបស់អញនឹងគេចទៅ ដូច្នេះហើយ ទើបបាញ់ព្រួញទៅ ព្រួញមិនរត់ទៅតាមបំណង បែរជាធ្វើឲ្យបិតាស្លាប់ ភិក្ខុអង្គនោះ លោកហៅថា បិតុឃាតដោយអំណាចនៃវោហារ តែមិនជាអនន្តរិយ-កម្ម ដោយប្រការដូច្នេះឯង ។

បទថា **អធិដ្ឋហិត្វា** បានដល់ ឈរនៅក្នុងទីជិត ។ បទថា **អាណាបេតិ** បានដល់ ភិក្ខុអ្នកប្រើ ប្រើចំពោះ ឬមិនចំពោះ បណ្ដាការប្រើចំពោះ មិនចំពោះនោះ កាលពួកសេនាខាងសត្រូវប្រាកដឡើងចំពោះហើយ កាលភិក្ខុប្រើ ប្រើមិនចំពោះថា លោកចូរទម្លុះយ៉ាងនេះ ចូរប្រហារយ៉ាងនេះ ចូរសម្លាប់យ៉ាងនេះ ជាបាណាតិបាតដល់ភិក្ខុទាំងពីរអង្គ មានប្រមាណស្មើនឹង

ចំនួនសត្រូវដែលភិក្ខុអ្នកទទួលបញ្ជាសម្លាប់ ។ បណ្ដាភិក្ខុអ្នកប្រើ និងអ្នកទទួលប្រើនោះ បើភិក្ខុអ្នកប្រើ មានមាតា និងបិតាផង ភិក្ខុអ្នកប្រើ រមែងត្រូវអនន្តរិយកម្មផង បើមានព្រះអរហន្តផងភិក្ខុទាំងពីរអង្គ រមែងត្រូវអនន្តរិយកម្ម ។ បើភិក្ខុអ្នកទទួលប្រើប៉ុណ្ណោះ មានមាតា និងបិតា ( ក្នុងលានចម្បាំង ) ភិក្ខុអ្នកទទួលប្រើប៉ុណ្ណោះឯង រមែងត្រូវអនន្តរិយកម្ម ។ តែកាលភិក្ខុអ្នកប្រើ ប្រើចំពោះថា លោកចូរទម្លុះ ចូរប្រហារ ចូរសម្លាប់អ្នកចម្បាំងឈ្មោះនោះ ខ្ពស់ ទាប មានអាវពណ៌ក្រហម មានអាវពណ៌ខៀវ ដែលអង្គុយលើ កដំរី ឬអង្គុយត្រង់កណ្ដាល ( គឺខ្នងដំរី ) បើភិក្ខុអ្នកទទួលប្រើនោះ សម្លាប់អ្នកចម្បាំងនោះឯង ជាបាណាតិបាតទាំងពីរអង្គ ហើយក្នុងរឿងនៃអនន្តរិយកម្ម រមែងត្រូវអនន្តរិយកម្មដូចគ្នាទាំងពីរអង្គ ។ បើភិក្ខុអ្នកទទួលប្រើសម្លាប់មនុស្សដទៃស្លាប់ បាណាតិបាត រមែងមិនមានដល់ភិក្ខុអ្នកប្រើ ។ អាណត្តិកប្បយោគ គឺលោកពោលទុកហើយ ដោយពាក្យថា **អធិដ្ឋហិត្វា អាណាបេតិ** ជាដើមនោះ ។

## អធិប្បាយ ឋាន ៥ និងឋាន ៦

ក្នុងអាណត្តិកប្បយោគនោះ ដូច្នេះថា

ភិក្ខុពិចារណាដោយភាពឈ្លាស គប្បីថ្លឹងថ្លែងឋាន ៥ ប្រការ គឺ វត្ថុ កាល ឱកាស អាវុធ និងឥរិយាបថ ហើយគប្បីទ្រទ្រង់ទុកនូវអត្ថសេចក្ដីនោះចុះ ។

ន័យម្យ៉ាងទៀត

ហេតុធ្វើឲ្យការប្រើពិតប្រាកដ ( សម្រេចបាន ) មាន ៦ យ៉ាង គឺវត្ថុ កាល ឱកាស អាវុធ ឥរិយាបថ និងកិរិយាវិសេស ។

បណ្ដាហេតុទាំង ៦ នោះ ពាក្យថា **វត្ថុ** បានដល់ សត្វដែល គប្បីត្រូវសម្លាប់ឲ្យស្លាប់ ។

ពាក្យថា **កាល** បានដល់ កាល មានព្រឹក និងល្ងាចជាដើម និង កាល មានវ័យជាកំលោះក្រមុំ មានកម្លាំងកំហែង និងមានសេចក្ដីព្យាយាម ជាដើម ។

ពាក្យថា **ឱកាស** បានដល់ ទីកន្លែង មានស្រុក ព្រៃ ទ្វារផ្ទះ កណ្ដាល ផ្ទះ ផ្លូវរថ ឬផ្លូវបែកជា ៣ ជាដើម ។

ពាក្យថា **អាវុធ** បានដល់ អាវុធ គឺដាវ ព្រួញ ឬលំពែងជាដើម ។

ពាក្យថា **ឥរិយាបថ** បានដល់ ឥរិយាបថយ៉ាងនេះ គឺការដើរ ឬអង្គុយ ជាដើមរបស់បុគ្គលដែលត្រូវសម្លាប់ឲ្យស្លាប់ ។

ពាក្យថា **កិរិយាវិសេស** បានដល់ កិរិយាដែលធ្វើ មានចាក់ កាត់ ទម្លាយ បកស្បែកក្បាលឲ្យរលីងដូចស័ង្ខជាដើម ។

## អធិប្បាយ វត្ថុ

បើភិក្ខុអ្នកទទួលបញ្ជា ធ្វើឲ្យវត្ថុភ្លាត់ទៅ បែរជាទៅសម្លាប់អ្នកដទៃក្រៅ អំពីបុគ្គលដែលអ្នកប្រើ ប្រើឲ្យសម្លាប់ ដូចជាប្រើថា លោកចូរប្រហារ ខាងមុខឲ្យស្លាប់ បែរទៅសម្លាប់ពីក្រោយ ឬចំហៀងៗ ឬត្រង់អវយវៈ ឯណាមួយឲ្យស្លាប់ទៅ កម្មពន្ធរមែងមិនមានដល់អ្នកប្រើ កម្មពន្ធរមែងមាន

ដល់ភិក្ខុអ្នកទទួលប្រើប៉ុណ្ណោះ ។ ម្យ៉ាងទៀត ភិក្ខុទទួលប្រើមិនធ្វើវត្ថុឲ្យភ្ញាត់ទៅ សម្លាប់បុគ្គលនោះស្លាប់ តាមដែលបញ្ជាទុក កម្មពន្ធរមែងមានដល់ភិក្ខុទាំងពីរអង្គ គឺដល់អ្នកប្រើក្នុងខណៈដែលប្រើ អ្នកទទួលប្រើ ក្នុងខណៈដែលប្រហារ ។ ក្នុងរឿងវត្ថុនេះ ការប្លែកគ្នានៃកម្ម និងការប្លែកគ្នានៃអាបត្តិរមែងមាន ព្រោះការប្លែកគ្នានៃវត្ថុ ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងខុសសង្កេតក្នុងវត្ថុយ៉ាងនោះសិន ។

## អធិប្បាយ កាល

ចំណែកក្នុងកាល មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គណា បានទទួលពាក្យប្រើថា ចូរលោកសម្លាប់ក្នុងវេលាព្រឹក មិនកំណត់ថា ថ្ងៃនេះ ឬថ្ងៃស្អែក ។ ភិក្ខុអ្នកទទួលប្រើនោះ សម្លាប់ក្នុងវេលាព្រឹក ក្នុងកាលណាមួយ ការខុសសង្កេតរមែងមិនមាន ។ ឯភិក្ខុអង្គណា បានទទួលបញ្ជាថា ចូរលោកសម្លាប់ក្នុងវេលាព្រឹកថ្ងៃនេះ ភិក្ខុអ្នកទទួលបញ្ជានោះ សម្លាប់ក្នុងវេលាថ្ងៃត្រង់ ឬវេលាល្ងាច ឬព្រឹកថ្ងៃស្អែក រមែងខុសសង្កេត សម្រាប់ភិក្ខុអ្នកប្រើ មិនមានកម្មពន្ធ ។ សូម្បីក្នុងកាលភិក្ខុអ្នកព្យាយាមសម្លាប់ក្នុងពេលព្រឹក តែដល់ថ្ងៃត្រង់ទើបសម្លាប់បាន ក៏មានន័យដូចគ្នា បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងខុសសង្កេតក្នុងប្រភេទនៃកាលទាំងពួង ដោយន័យនេះ ។

## អធិប្បាយ ឱកាស

ក្នុងឱកាស មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គណាប្រើថា ចូរលោកសម្លាប់បុគ្គលនោះ ដែលឈរនៅក្នុងស្រុកឲ្យស្លាប់ ភិក្ខុអ្នកទទួលប្រើនោះ សម្លាប់

បុគ្គលនោះ ក្នុងទីណាមួយ រមែងមិនខុសសង្កេត ។ ចំណែកភិក្ខុអង្គណា ប្រើកំណត់ទុកថា ចូរសម្លាប់ក្នុងស្រុកប៉ុណ្ណោះ តែភិក្ខុអ្នកទទួលប្រើនោះ សម្លាប់ក្នុងព្រៃ ម្យ៉ាងទៀត ភិក្ខុប្រើថា ចូរសម្លាប់ក្នុងព្រៃ តែភិក្ខុអ្នកទទួល ប្រើសម្លាប់ក្នុងស្រុក ភិក្ខុប្រើថា ចូរសម្លាប់ត្រង់ទ្វារខាងក្នុងស្រុក ភិក្ខុអ្នក ទទួលប្រើ ទៅសម្លាប់ក្នុងកណ្តាលផ្ទះ រមែងខុសសង្កេត ។ បណ្ឌិតគប្បី ជ្រាបការត្រូវសង្កេត និងខុសសង្កេត ក្នុងការផ្សេងគ្នានៃឱកាសទាំងពួង ដោយន័យនេះ ។

## អធិប្បាយ អាវុធ

ក្នុងអាវុធ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គណា ប្រើថា ចូរលោកយក អាវុធសម្លាប់ មិនកំណត់ទុកថា ដាវ ឬព្រួញ ភិក្ខុអ្នកទទួលប្រើនោះ យក អាវុធប្រភេទណាមួយទៅសម្លាប់ រមែងមិនខុសសង្កេត ។ ចំណែកភិក្ខុអង្គ ណាប្រើថា ចូរយកដាវសម្លាប់ តែភិក្ខុអ្នកទទួលប្រើនោះ ប្រើព្រួញសម្លាប់ ឬប្រើថា ចូរយកដាវមួយនេះសម្លាប់ ភិក្ខុអ្នកទទួលប្រើយកដាវដទៃ ឬប្រើ ថា ចូរយកដាវដ៏មុតមួយនេះប៉ុណ្ណោះសម្លាប់ តែភិក្ខុអ្នកទទួលប្រើ ប្រើដាវ ក្រៅអំពីនេះ ឬប្រើបាតដៃ ឬប្រើចំពុះសត្វ ឬប្រើដងដាវសម្លាប់ រមែងខុស សង្កេត បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងខុសសង្កេត ក្នុងការផ្សេងគ្នា នៃអាវុធទាំងពួង ដោយន័យនេះ ។

## អធិប្បាយ ឥរិយាបថ

ក្នុងឥរិយាបថ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គណាប្រើថា ចូរលោក

សម្លាប់បុគ្គលនោះ ដែលកំពុងដើរឲ្យស្លាប់ ភិក្ខុអ្នកទទួលប្រើនោះ សម្លាប់បុគ្គលដែលកំពុងដើរទៅស្លាប់ រមែងមិនខុសសង្កេត ។ បើភិក្ខុអ្នកប្រើ ប្រើថា ចូរលោកសម្លាប់បុគ្គលដែលកំពុងដើរប៉ុណ្ណោះ តែភិក្ខុអ្នកទទួលប្រើសម្លាប់បុគ្គល ដែលកំពុងអង្គុយ ឬភិក្ខុអ្នកប្រើ ប្រើថា ចូរលោកសម្លាប់បុគ្គលដែលអង្គុយប៉ុណ្ណោះ តែភិក្ខុអ្នកទទួលប្រើ សម្លាប់បុគ្គលដែលកំពុងដើរ រមែងខុសសង្កេត ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងខុសសង្កេតក្នុងការផ្សេងគ្នានៃឥរិយាបថទាំងពួង ដោយន័យនេះ ។

# អធិប្បាយ កិរិយាវិសេស

ក្នុងកិរិយាវិសេស មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអង្គណាប្រើថា ចូរលោកចាក់ឲ្យស្លាប់ ភិក្ខុអ្នកទទួលប្រើនោះ ចាក់ឲ្យស្លាប់ រមែងមិនខុសសង្កេត ។ ឯភិក្ខុអង្គណាប្រើថា ចូរចាក់ឲ្យស្លាប់ តែភិក្ខុអ្នកទទួលប្រើនោះ កាត់ ( ជាកំណាត់ ) ឲ្យស្លាប់នោះឯង រមែងខុសសង្កេត ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងខុសសង្កេត ក្នុងការផ្សេងគ្នានៃកិរិយាវិសេសទាំងពួង ដោយន័យនេះ ។

ចំណែកភិក្ខុអង្គណា ប្រើមិនកំណត់ ដោយអំណាចភេទថា ចូរលោកសម្លាប់បុគ្គលដែលខ្ពស់ ទាប ខ្មៅ ស ស្គម ធាត់ ឲ្យស្លាប់ ហើយភិក្ខុអ្នកទទួលប្រើ សម្លាប់បុគ្គលណាមួយដូច្នោះស្លាប់ រមែងមិនខុសសង្កេត ត្រូវបារាជិកទាំងពីរអង្គ ។ តែបើភិក្ខុអ្នកប្រើនោះ ប្រើឲ្យសម្លាប់ខ្លួនលោក ហើយភិក្ខុអ្នកទទួលប្រើ សម្លាប់ភិក្ខុអ្នកប្រើនោះឯង ដោយគិតថា អ្នកប្រើនេះឯង

ដែលមានសភាពដូច្នេះ សម្រាប់ភិក្ខុអ្នកប្រើ ត្រូវអាបត្តិទុក្កដ ភិក្ខុអ្នកសម្លាប់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុអ្នកប្រើ ប្រើឲ្យសម្លាប់ខ្លួនលោក ភិក្ខុអ្នកទទួលប្រើ សម្លាប់បុគ្គលដទៃ ភិក្ខុអ្នកប្រើ រមែងរួចផុត ( អំពីអាបត្តិ ) ត្រូវអាបត្តិ បារាជិកដល់ភិក្ខុអ្នកសម្លាប់ប៉ុណ្ណោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះ មិនបានកំណត់ឱកាសទុក ។ តែបើភិក្ខុអ្នកប្រើ ប្រើឲ្យសម្លាប់ខ្លួនលោក ក៏ កំណត់ឱកាសទុកថា ចូរលោកសម្លាប់បុគ្គលបែបនេះ ដែលអង្គុយលើ អាសនៈព្រះថេរៈ ឬលើអាសនៈមជ្ឈិមភិក្ខុ ឬដែលសម្រាកពេលយប់ ឬ សម្រាកពេលថ្ងៃ ឈ្មោះនោះឲ្យស្លាប់ តែក្នុងឱកាសនោះមានភិក្ខុអង្គដទៃ អង្គុយជំនួស បើភិក្ខុអ្នកទទួលបញ្ជាសម្លាប់ភិក្ខុដែលមកអង្គុយនោះស្លាប់ ភិក្ខុ អ្នកសម្លាប់រមែងមិនផុត ( អំពីអាបត្តិ ) ដោយពិត ភិក្ខុអ្នកប្រើក៏មិនផុតដូច គ្នា សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបានកំណត់ឱកាសទុក ។ តែភិក្ខុ អ្នកទទួលប្រើ សម្លាប់បុគ្គលវៀរចាកឱកាសដែលភិក្ខុអ្នកប្រើកំណត់ទុក ភិក្ខុ អ្នកប្រើរមែងផុត ( អំពីអាបត្តិ ) ន័យដូចអធិប្បាយមកនេះ អដ្ឋកថាចារ្យ ពោលទុកជាគោលដោយល្អ ក្នុងមហាអដ្ឋកថា ព្រោះដូច្នោះ បណ្ឌិតមិនគួរ ធ្វើការមិនអើពើក្នុងអត្ថដូចពោលមក ដូច្នេះ ។

# អធិប្បាយ ទូតកថា

[ ១៨៩ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុង ៤ វារៈថា **ភិក្ខុ ភិក្ខុំ អាណាបេតិ** ជាដើម ដែលព្រះឧបាលិត្ថេរពោលទុក ដើម្បីសម្តែងលម្អិតបទមាតិកា មានពាក្យថា **ទូតេន** នេះ ។

បទថា **សោ តំ មញ្ញមានោ** សេចក្តីថា ភិក្ខុអង្គណាដែលភិក្ខុអ្នកប្រើប្រាប់ថា ចូរសម្លាប់បុគ្គលឈ្មោះនេះ ភិក្ខុអ្នកទទួលប្រើអង្គនោះយល់ថាបុគ្គលនោះពិត ទើបសម្លាប់បុគ្គលនោះឯង ឲ្យឃ្លាតចាកជីវិត ត្រូវអាបត្តិបារាជិកទាំងពីរអង្គ ។

បទថា **តំ មញ្ញមានោ អញ្ញំ** សេចក្តីថា ភិក្ខុអ្នកទទួលប្រើ យល់បុគ្គលដែលភិក្ខុអ្នកប្រើ ប្រើឲ្យផ្តាច់ជីវិត តែបែរទៅជាសម្លាប់បុគ្គលដទៃឲ្យស្លាប់ ភិក្ខុអ្នកប្រើខាងដើមមិនត្រូវអាបត្តិ ។

បទថា **អញ្ញំ មញ្ញមានោ តំ** សេចក្តីថា ភិក្ខុអង្គណា ដែលភិក្ខុអ្នកប្រើ ប្រើទុកហើយ លោកឃើញបុគ្គលដែលជាសម្លាញ់ដែលមានកម្លាំងរបស់ភិក្ខុអ្នកប្រើនោះ ដែលឈរនៅក្នុងទីជិត ទើបគិតថា បុគ្គលនេះ រមែងគំរាមដោយកម្លាំងរបស់ភិក្ខុអ្នកប្រើនេះ អញនឹងសម្លាប់បុគ្គលនេះឲ្យស្លាប់ជាមុនសិន កាលនឹងប្រហារ យល់ថា បុគ្គលដែលប្រើឲ្យសម្លាប់ គឺមនុស្សក្រៅអំពីនេះពិតប្រាកដ ដែលបួរគ្នាមកឈរនៅក្នុងទីនេះជំនួសថាជាសម្លាញ់ ទើបបានផ្តាច់ជីវិត ត្រូវអាបត្តិបារាជិកទាំងពីរអង្គនោះឯង ។ បទថា **អញ្ញំ អញ្ញមានោ អញ្ញំ** សេចក្តីថា ភិក្ខុអ្នកទទួលប្រើ គិតដោយន័យមុននោះឯងថា អញនឹងសម្លាប់ បុគ្គលដែលជាសម្លាញ់នេះរបស់ភិក្ខុអ្នកប្រើនោះឲ្យស្លាប់ជា

មុនហើយក៏សម្លាប់បុគ្គលដែលជាសម្លាញ់នោះឯង ឲ្យស្លាប់ត្រូវអាបត្តិបារាជិកដល់អ្នក ទទួលប្រើនោះប៉ុណ្ណោះ ។

[ ១៩០ ] ក្នុងពាក្យជាដើមថា **ឥត្ថន្នាមស្ស ពាវទ** ក្នុងនិទ្ទេសវារៈនៃបទថា ដោយការនាំពាក្យបន្តៗ គ្នាមកនៃអ្នកទទួលប្រើ មានវិនិច្ឆ័យដូច្នេះថា គប្បីឃើញថា អាចារ្យ ១ អង្គ អន្តេវាសិក ៣ អង្គ មានឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត និងសង្ឃរក្ខិត ។

បណ្តាបទទាំងនោះ បទថា **ភិក្ខុ ភិក្ខុំ អាណាបេតិ** សេចក្តីថា អាចារ្យមានបំណងឲ្យសម្លាប់បុគ្គលណាមួយ ទើបប្រាប់សេចក្តីនោះ ហើយប្រើពុទ្ធរក្ខិត ។

ពីរបទថា **ឥត្ថន្នាមស្ស ពាវទ** សេចក្តីថា ( អាចារ្យប្រើថា ) នៃពុទ្ធរក្ខិត ចូរលោកទៅប្រាប់សេចក្តីនោះដល់ធម្មរក្ខិត ។

បទថា **ឥត្ថន្នាមោ ឥត្ថន្នាមស្ស ពាវទតុ** សេចក្តីថា សូមឲ្យធម្មរក្ខិតប្រាប់ដល់សង្ឃរក្ខិត ( តទៅ ) ។

បទថា **ឥត្ថន្នាមោ ឥត្ថន្នាមំ ជីវិតា វោរោបេតុ** សេចក្តីថា ធម្មរក្ខិតត្រូវលោកប្រើទុកយ៉ាងនោះហើយ ក៏ប្រើសង្ឃរក្ខិត ( តទៅ ) ថា ចូរផ្តាច់ជីវិតបុគ្គលឈ្មោះនេះ ព្រោះថា បណ្តាយើងទាំងពីរ ខ្លួនលោកនេះឯង ជាអ្នកមានជាតិក្លាហាន អាចក្នុងកម្មនេះ ។

បទថា **អាបត្តិ ទុក្កដស្ស** សេចក្តីថា ត្រូវអាបត្តិទុក្កដដល់អាចារ្យអ្នកប្រើយ៉ាងនោះមុន ។

បទថា **សោ ឥតរស្ស អារោចេតិ** សេចក្តីថា ពុទ្ធរក្ខិតប្រាប់ធម្មរក្ខិត ធម្មរក្ខិតប្រាប់សង្ឃរក្ខិតថា អាចារ្យរបស់ពួកយើងប្រើមកយ៉ាងនេះថា បានឮថា ចូរលោកផ្តាច់ជីវិតបុគ្គលឈ្មោះនេះ បានឮថា បណ្តាយើងទាំងពីរលោកជាបុរសក្លាហាន ត្រូវអាបត្តិទុក្កដដល់ភិក្ខុទាំង ៣ នោះ ដោយការប្រាប់តគ្នានោះជាបច្ច័យ ។

ពីរបទថា **វធកោ បដិគ្គណ្ហាតិ** សេចក្តីថា សង្ឃរក្ខិតទទួលថា សាធុ ខ្ញុំនឹងសម្លាប់ ។

បទថា **មូលដ្ឋស្ស អាបត្តិ ថុល្លច្ចយស្ស** សេចក្តីថា កាលពាក្យប្រើនោះ គ្រាន់តែសង្ឃរក្ខិតទទួលហើយ អាចារ្យត្រូវអាបត្តិថុល្លច្ច័យ ព្រោះមហាជនដែលអាចារ្យនោះ ដឹកនាំក្នុងអំពើបាបនោះឯង ។

ពីរបទថា **សោ តំ** សេចក្តីថា បើភិក្ខុនោះ គឺសង្ឃរក្ខិតផ្តាច់បុគ្គលនោះចាកជីវិតសោត ត្រូវអាបត្តិបារាជិកទាំងអស់ គឺទាំង ៤ អង្គ ហើយមិនមែនត្រឹមតែ ៤ អង្គប៉ុណ្ណោះទេ កាលធ្វើមិនឲ្យខុសសង្កេត ប្រើតាមលំដាប់ដោយឧបាយនេះ សមណៈរាប់រយ ឬសមណៈរាប់ពាន់ក៏ដោយ ត្រូវអាបត្តិបារាជិកទាំងអស់ ។

ក្នុងនិទ្ទេសនៃបទវិសក្កិយទូត មានវិនិច្ឆ័យដូច្នេះថា បទថា **សោ អញ្ញំ អាណាបេតិ** សេចក្តីថា ភិក្ខុនោះ គឺពុទ្ធរក្ខិតដែលអាចារ្យប្រើទុក មិនជួបធម្មរក្ខិត ឬជាអ្នកមិនចង់ប្រាប់ ទើបចូលទៅរកសង្ឃរក្ខិត ហើយធ្វើឲ្យខុសសង្កេត ប្រាប់ថា អាចារ្យរបស់យើងប្រើយ៉ាងនេះថា បានឮថា ចូរ

លោកផ្តាច់ជីវិតបុគ្គលឈ្មោះនេះ ។ ពិតហើយ ភិក្ខុនេះលោកហៅថា **វិសង្កេ-យទូត** ព្រោះធ្វើឲ្យខុសសង្កេតនោះឯង ។

បទថា **អាបត្តិ ទុក្កដស្ស** គឺត្រូវអាបត្តិទុក្កដដល់ពុទ្ធរក្ខិតខណៈប្រាប់។

បទថា **បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស** នោះ គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុអ្នកប្រើខាងដើមតែម្យ៉ាង ក្នុងកាលសង្ឃរក្ខិតទទួលពាក្យ ។ បើយ៉ាងនោះ អាបត្តិព្រោះការទទួលមិនមាន តែក្នុងការទទួលពាក្យបន្ត នឹងពេញចិត្តក្នុងការសម្លាប់ ក៏គង់ត្រូវអាបត្តិ ហេតុអ្វី មិនត្រូវអាបត្តិព្រោះទទួលទៅសម្លាប់នោះ ព្រោះហេតុនោះ អាបត្តិទុក្កដមានដល់ភិក្ខុដែលទទួលនោះឯង ដោយហេតុនោះឯង ទើបព្រះមានព្រះភាគមិនត្រាស់ពាក្យថា **មូលដ្ឋស្ស** ក្នុងន័យនេះ ។ ហើយក្នុងន័យមុនក៏គប្បីជ្រាបទុក្កដនេះដល់ភិក្ខុអ្នកទទួលពាក្យដូចគ្នា ។ តែព្រោះមានឱកាស ទើបទ្រង់មិនត្រាស់ទុក្កដនេះទុក ។ ព្រោះដូច្នោះ ភិក្ខុណាមួយទទួលពាក្យត្រូវអាបត្តិដល់ភិក្ខុនោះៗ ព្រោះមានការទទួលនោះជាបច្ច័យពិត នេះជាការពេញចិត្តរបស់យើងទាំង-ឡាយ ក្នុងរឿងនេះឯង ។ ក្នុងមនុស្សវិគ្គហៈនេះ យ៉ាងណា សូម្បីក្នុងអទិន្នាទាន ក៏ដូច្នោះដែរ ។ បើសង្ឃរក្ខិតនោះផ្តាច់ជីវិតបុគ្គលនោះបាន ត្រូវអាបត្តិ បារាជិកទាំង ២ អង្គ គឺពុទ្ធរក្ខិតអ្នកប្រើ និងសង្ឃរក្ខិតអ្នកសម្លាប់ មិនត្រូវអាបត្តិបារាជិកដល់អាចារ្យអ្នកប្រើខាងដើម ព្រោះការប្រើនោះខុសសង្កេត មិនត្រូវអាបត្តិដោយប្រការទាំងពួងដល់ធម្មរក្ខិត ព្រោះមិនដឹង ។ ឯពុទ្ធរក្ខិតធ្វើសេចក្តីសួស្តីដល់ភិក្ខុទាំង ២ អង្គ ហើយវិនាសខ្លួនឯង ដូច្នេះឯង។

[ ១៩១ ] *ក្នុងនិទ្ទេសនៃគតបច្ចាគតទូត មានវិនិច្ឆ័យដូច្នេះថា បទថា* **សោ គន្ត្វា បុន បច្ចាគច្ឆតិ** *សេចក្ដីថា ភិក្ខុអ្នកទទួលប្រើនោះ ទៅកាន់ទីជិតនៃបុគ្គលដែលខ្លួនគប្បីផ្ដាច់ជីវិតនោះ កាលមិនអាចផ្ដាច់ជីវិតបុគ្គលនោះបាន ព្រោះបុគ្គលនោះ មានការរក្សាការពារទុកល្អហើយ ទើបត្រឡប់មក ។*

*បទថា* **យទា សក្កោសិ តទា តំ** *សេចក្ដីថា ភិក្ខុអ្នកប្រើនោះ ប្រើជាថ្មីថា ត្រូវសម្លាប់ក្នុងថ្ងៃនេះតែម្យ៉ាងឬ ទើបហៅថាសម្លាប់ ទៅចុះ លោកអាចក្នុងកាលណា ចូរផ្ដាច់ជីវិតបុគ្គលនោះកាលនោះចុះ ។*

*ពីរបទថា* **អាបត្តិ ឧភិន្នំ** *សេចក្ដីថា ព្រោះប្រើម្ដងទៀតយ៉ាងនោះ រមែងត្រូវទុក្កដដូចគ្នា ។ បើបុគ្គលនោះ ជាបុគ្គលត្រូវស្លាប់ពិតប្រាកដសោតចេតនាដែលញ៉ាំងអត្ថឲ្យសម្រេច រមែងដូចគ្នានឹងផលដែលកើតក្នុងលំដាប់នៃមគ្គ ព្រោះដូច្នោះ ទើបភិក្ខុអ្នកប្រើនេះត្រូវអាបត្តិបារាជិកក្នុងខណៈប្រើនោះឯង ។ បើភិក្ខុអ្នកសម្លាប់ៗ បុគ្គលនោះបាន ដោយកន្លងទៅ ៦០ ឆ្នាំសោតភិក្ខុអ្នកប្រើ ទោះធ្វើកាលកិរិយា ឬសឹកក្នុងវេលានោះ មិនឈ្មោះថា សមណៈធ្វើកាលកិរិយា ឬសមណៈសឹកឡើយ ។ បើអ្នកប្រើសំដៅយកមាតាបិតា ឬព្រះអរហន្ត ប្រើយ៉ាងនោះ ក្នុងវេលាជាគ្រហស្ថ ហើយទើបបួស បុគ្គលអ្នកទទួលប្រើសម្លាប់បុគ្គលនោះបាន ក្នុងកាលបុគ្គលអ្នកប្រើនោះបួសហើយ បុគ្គលអ្នកប្រើ រមែងជាបុគ្គលសម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្តតាំងពីក្នុងវេលានៅជាគ្រហស្ថម្ល៉េះ ព្រោះហេតុនោះ បព្វជ្ជា ឬឧបសម្បទារមែងមិនឡើង ( ជាភិក្ខុ ឬសាមណេរ ) ឡើយ ។ បើបុគ្គលដែលគប្បី*

សម្លាប់ក្នុងខណៈប្រើទៅជាបុថុជ្ជននៅឡើយ តែបានជាព្រះអរហន្ត ក្នុងវេលាដែលអ្នកទទួលប្រើសម្លាប់ ឬម្យ៉ាងទៀត បុគ្គលដែលត្រូវសម្លាប់នោះ បានការប្រហារអំពីអ្នកទទួលប្រើ ហើយអាស្រ័យសទ្ធា មានទុក្ខជាមូល ចម្រើនវិបស្សនាសម្រេចអរហត្ត ហើយធ្វើកាលកិរិយាទៅ ព្រោះអាពាធនោះឯង អ្នកប្រើរមែងជាបុគ្គលសម្លាប់ព្រះអរហន្តក្នុងខណៈប្រើនោះឯង ចំណែកអ្នកសម្លាប់ រមែងត្រូវអាបត្តិបារាជិក ក្នុងខណៈធ្វើសេចក្ដីព្យាយាមក្នុងទីទាំងពួងនោះឯង ។

[ ១៩២ ] ក្នុងបណ្ដាទាំង ៣ វារៈ ដែលព្រះឧបាលិត្ថេរពោលទុកដើម្បីសម្ដែងការត្រូវសង្កេត និងខុសសង្កេតក្នុងបទមាតិកា ដែលត្រាស់ដោយអំណាចទូតទាំងអស់នោះ ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមវារៈមុន ។ ភិក្ខុអ្នកប្រើខាងដើមពោលពាក្យនោះតិចៗ ឬព្រោះភិក្ខុអ្នកទទួលប្រើនោះ ជាមនុស្សថ្លង់ ទើបប្រកាសឲ្យបានឮពាក្យប្រើនេះថា ចូរអ្នកកុំសម្លាប់មនុស្សថ្លង់ស្ដាប់មិនបាន ព្រោះហេតុនោះ ទើបភិក្ខុអ្នកប្រើខាងដើមមិនផុតអំពីអាបត្តិ ។ ក្នុងទុតិយវារៈ ផុតចាកអាបត្តិបាន ព្រោះលោកប្រកាសឲ្យបានឮ ។ ចំណែកក្នុងតតិយវារៈ សូម្បីទាំងពីរអង្គក៏ផុតបាន ព្រោះភិក្ខុដែលជាអ្នកប្រើខាងដើមនោះប្រកាសឲ្យ ( ភិក្ខុអ្នកទទួលប្រើ ) បានឮ និងព្រោះភិក្ខុអ្នកទទួលប្រើនេះ ទទួលពាក្យថា សាធុ ហើយវៀរចេញដូច្នេះឯង ។

ទូតកថា ចប់

# រឿង ដែលមិនស្ងាត់សម្គាល់ថាស្ងាត់

[ ១៩៣ ] ក្នុង **អរហោ រហោសញ្ញិនិទ្ទេស** ជាដើម មានវិនិច្ឆ័យដូច្នេះ បទថា **អរហោ** បានដល់ ចំពោះមុខ ។ បទថា **រហោ** បានដល់ កំបាំងមុខ ។ បណ្ដាជនពីរនាក់ ( គឺបុគ្គលមានការសម្គាល់ចំពោះមុខ ថា កំបាំងមុខ និងបុគ្គលមានការសម្គាល់កំបាំងមុខ ថាចំពោះមុខនោះ ) ភិក្ខុណា កាលភិក្ខុអ្នកមានពៀរនឹងគ្នា មកព្រមនឹងភិក្ខុទាំងឡាយ ហើយអង្គុយនៅខាងមុខនោះឯង ក្នុងវេលាឧបដ្ឋាក មិនជ្រាបការដែលភិក្ខុនោះមក ព្រោះទោស គឺភាពងងឹត ពេញចិត្តការស្លាប់របស់ភិក្ខុដែលមានពៀរនឹងគ្នានោះ ទើបពោលពាក្យដូច្នេះថា ធ្វើម្ដេចហ្ន៎ ភិក្ខុមានឈ្មោះយ៉ាងនេះ ត្រូវសម្លាប់ ហេតុអ្វី ទើបពួកចោរមិនសម្លាប់ភិក្ខុនោះ ទើបពស់មិនខាំភិក្ខុនោះ បុគ្គលណាមួយ មិនយកសស្ត្រា ឬថ្នាំពិសមកដាក់ដល់ភិក្ខុនោះ ភិក្ខុនេះ ឈ្មោះថា បុគ្គលមានការសម្គាល់ចំពោះមុខ ថាកំបាំងមុខ ហើយនិយាយ ។ អធិប្បាយថា បុគ្គលមានការសម្គាល់ក្នុងចំពោះមុខ ថាកំបាំងមុខ ។ ចំណែកភិក្ខុណា ឃើញភិក្ខុមានពៀរនឹងគ្នានោះអង្គុយខាងមុខ ជាបុគ្គលមានសេចក្ដីសម្គាល់ថា លោកអង្គុយនៅទីនេះឯង ពោលវាចាឡើងតាមន័យមុននោះឯង ក្នុងកាលភិក្ខុនោះទៅព្រមនឹងភិក្ខុទាំងឡាយដែលឧបដ្ឋាកហើយ ត្រឡប់ទៅវិញ ភិក្ខុនេះ ឈ្មោះថា ជាអ្នកមានសេចក្ដីសម្គាល់ក្នុងទីកំបាំងមុខ ថាចំពោះមុខហើយពោល ។ បុគ្គលដែលមានការសម្គាល់ក្នុងទីចំពោះមុខ ថាចំពោះមុខ និងបុគ្គលដែលមានការសម្គាល់ក្នុងទីកំបាំង ថាទីកំបាំង អ្នកសិក្សាគប្បីជ្រាបដោយឧបាយនេះឯង ។ ហើយគប្បី ជ្រាបថា ត្រូវអាបត្តិទុក្កដគ្រប់ៗ ពាក្យ

ពោលដល់ភិក្ខុទាំង ៤ អង្គ ។

## ពណ៌នា សេចក្តីស្លាប់ដោយកាយជាដើម

[ ១៩៤ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃមាតិកា ៥ មាន ពណ៌នាដោយកាយជាដើម ដែលព្រះឧបាលីពោលទុកដើម្បីសម្តែងវិភាគនៃ ការពណ៌នាសេចក្តីស្លាប់ ។

បទថា **កាយេន វិការំ ករោតិ** សេចក្តីថា បុគ្គលនោះនឹងដឹងបានថា អត្ថ គឺសេចក្តីនេះ ដែលបុគ្គលនេះពោលថា បុគ្គលណាប្រើសស្រ្តាសម្លាប់ ខ្លួនឲ្យស្លាប់ក្តី ទំពាស៊ីថ្នាំពិសឲ្យស្លាប់ក្តី យកខ្សែចងកឲ្យស្លាប់ក្តី លោត អណ្តូងទឹកឲ្យស្លាប់ក្តី បានឮថា បុគ្គលនោះនឹងបានទ្រព្យ បានយស ឬទៅ កាន់ស្ថានសួគ៌ ដូច្នេះ ដោយប្រការណា ភិក្ខុសម្តែងដោយប្រការនោះ ដោយ អវយវៈទាំងឡាយ មានមេដៃជាដើម ។

បទថា **វាចាយ ភណតិ** សេចក្តីថា ភិក្ខុបន្លឺវាចាពោលអត្ថនោះឯង ។ វារៈទី ៣ ជាការពោលហើយ ដោយអំណាចនៃវារៈទាំង ២ ( កាយ និង វាចា ) ។ គ្រប់ៗ វារៈ កាត់អាបត្តិទុក្កដគ្រប់ៗ ប្រយោគនៃការពណ៌នា ត្រូវអាបត្តិថុល្លច្ច័យដល់ភិក្ខុអ្នកពណ៌នា ក្នុងខណៈសេចក្តីទុក្ខកើតឡើងដល់ បុគ្គលនោះ កាលបុគ្គលដែលខ្លួនពណ៌នាដោយចំពោះស្លាប់ទៅ ត្រូវអាបត្តិ បារាជិកដល់ភិក្ខុអ្នកពណ៌នាក្នុងខណៈដែលពណ៌នានោះឯង ។ បើបុគ្គលនោះ មិនដឹង សេចក្តីនោះ បុគ្គលដទៃដឹងហើយ គិតថា អញបានឧបាយជាហេតុ កើតសុខហើយហ្ន៎ ដូច្នេះ ស្លាប់ទៅ ព្រោះការពណ៌នានោះ មិនត្រូវអាបត្តិ ។

កាលភិក្ខុធ្វើការពណ៌នាសំដៅចំពោះបុគ្គលពីរនាក់ បុគ្គលម្នាក់ដឹងហើយស្លាប់ទៅ ត្រូវអាបត្តិបារាជិក បើស្លាប់ទាំងពីរនាក់ ត្រូវបារាជិកផង ជាគំនរអកុសល ( ដ៏ធំ ) ផង ។ ក្នុងមហាជនដ៏ច្រើន ក៏មានន័យដូច្នេះ ភិក្ខុត្រាច់ពណ៌នាសេចក្ដីស្លាប់មិនចំពោះ បុគ្គលណាមួយដឹងការពណ៌នានោះហើយស្លាប់ទៅ បុគ្គលទាំងអស់នោះ ឈ្មោះថា ភិក្ខុអង្គនោះសម្លាប់ហើយ ។

[ ១៩៥ ] ក្នុងការពណ៌នាដោយទូត មានវិនិច្ឆ័យដូច្នេះថា ភិក្ខុត្រូវអាបត្តិទុក្កដ ដោយគ្រាន់តែប្រាប់ដំណឹងថា ចូរលោកទៅកាន់ផ្ទះ ឬស្រុកឈ្មោះនោះ ហើយពណ៌នាគុណនៃសេចក្ដីស្លាប់ ដល់បុគ្គលមានឈ្មោះយ៉ាងនោះឯង ។ ទូតដែលភិក្ខុបញ្ជូនទៅ ដើម្បីប្រយោជន៍ដល់បុគ្គលណា កាលសេចក្ដីទុក្ខកើតដល់បុគ្គលនោះ ភិក្ខុអ្នកប្រើខាងដើមត្រូវអាបត្តិថុល្លច្ច័យ កាលបុគ្គលនោះស្លាប់ ត្រូវអាបត្តិបារាជិក ។ អ្នកទទួលប្រើគិតថា ឥឡូវនេះ អញដឹងផ្លូវស្លូតនេះហើយ មិនប្រាប់ដល់បុគ្គលនោះ ប្រាប់តែញាតិ ឬ សាច់សាលោហិតរបស់ខ្លួន កាលបុគ្គលទាំងនោះស្លាប់ ជាការខុសសង្កេត ភិក្ខុអ្នកប្រើខាងដើមរួចខ្លួន ។ អ្នកទទួលប្រើគិតយ៉ាងនោះឯង ធ្វើកិច្ចដែលពោលទុកក្នុងការពណ៌នា ហើយស្លាប់ទៅ ខុសសង្កេតដូចគ្នា ។ តែកាលភិក្ខុប្រាប់ដំណឹងមិនចំពោះ ជាបាណាតិបាតប្រមាណ ប៉ុនចំនួនមនុស្សដែលស្លាប់ទៅដោយការពណ៌នារបស់អ្នកទទួលប្រើ ។ បើមាតា និងបិតាស្លាប់ទៅ ក៏ត្រូវអនន្តរិយកម្ម ។

ក្នុងការពណ៌នាដោយចារឹកអក្សរ មានវិនិច្ឆ័យដូច្នេះ បទថា **លេខំ ឆិន្ទតិ**

សេចក្ដីថា ភិក្ខុសរសេរអក្សរត្រង់ស្លឹកឈើក្ដី ត្រង់ស្លឹករឹតក្ដី ថា បុគ្គលណា ប្រើសស្ត្រាសម្លាប់ខ្លួនឲ្យស្លាប់ក្ដី លោតក្នុងជ្រោះឲ្យស្លាប់ក្ដី ដោយឧបាយដទៃ មានការលោតចូលភ្លើង និងលោតទឹកជាដើមក្ដី បុគ្គលនោះនឹងបានវត្ថុនេះ ឬ ។បេ។ ដែលជាការពេញចិត្តរបស់បុគ្គលនោះ ។ សូម្បីក្នុងការសរសេរសំបុត្រដែលមិនចោះចំពោះនេះ បណ្ឌិតគប្បីជ្រាបថា ត្រូវអាបត្តិទុក្កដ ថុល្លច្ច័យ និងបារាជិក ដោយន័យដូចពោលហើយនោះឯង ។

កាលភិក្ខុសរសេរអក្សរដោយចំពោះ ខ្លួនសរសេរចំពោះបុគ្គលណា ព្រោះបុគ្គលនោះឯងស្លាប់ ត្រូវអាបត្តិបារាជិក បើសរសេរសំបុត្រចំពោះច្រើននាក់ ជាបាណាតិបាតមានប្រមាណស្មើនឹងចំនួនបុគ្គលដែលស្លាប់ទៅ បើមាតា និងបិតាស្លាប់ ត្រូវអនន្តរិយកម្ម ។ សូម្បីក្នុងសំបុត្រដែលសរសេរមិនចំពោះ ក៏មានន័យនេះឯង ។ ភិក្ខុកាលកើតសេចក្ដីក្ដៅក្រហាយឡើងថា មនុស្ស សត្វជាច្រើននឹងស្លាប់ ទើបដុតស្លឹករឹតនោះចោល ឬធ្វើដោយប្រការដែលអក្សរទាំងឡាយមិនប្រាកដ រមែងរួចផុតបាន ។ បើស្លឹករឹតនោះជារបស់បុគ្គលដទៃ ភិក្ខុទោះសរសេរអក្សរចោះចំពោះក្ដី ឬសរសេរមិនចំពោះក្ដី ដាក់ក្នុងទីដែលខ្លួនកាន់យកមក រមែងរួចផុត ។ បើស្លឹករឹតនោះជារបស់ដែលគេទិញមកដោយតម្លៃ ភិក្ខុឲ្យស្លឹករឹតដល់ម្ចាស់របស់ស្លឹករឹត ហើយឲ្យតម្លៃដល់ជនដែលខ្លួនទទួលយកតម្លៃអំពីដៃហើយ រមែងផុតបាន ។ បើភិក្ខុច្រើនអង្គរួមគ្នា ជាអ្នកមានអធ្យាស្រ័យដូចគ្នាថា ពួកយើងនឹងសរសេរពណ៌នាគុណនៃសេចក្ដីស្លាប់ ដូច្នេះ ភិក្ខុមួយអង្គឡើងដើមត្នោត ហើយកាត់ស្លឹកត្នោត មួយ

អង្គនាំមក មួយអង្គធ្វើឲ្យជាស្លឹករឹត មួយអង្គសរសេរ ។ មួយអង្គទៀត បើការសរសេរដោយដែកចារ ក៏យកខ្ទុកម្រក្សណ៍លាប កាលលាបហើយ រៀបស្លឹករឹតនោះចូលក្នុងចំណង ភិក្ខុទាំងអស់យកទៅដាក់ត្រង់សភា ឬត្រង់រានផ្សារ ឬក្នុងទីដែលមហាជនជាច្រើនមកដេរដាស ដើម្បីប្រជុំគ្នាមើលអក្សរដែលលោកសរសេរក្នុងស្លឹករឹតនោះ ។ មហាជនអានហើយ បើបុគ្គលម្នាក់ស្លាប់ទៅសោត ភិក្ខុទាំងអស់ ត្រូវបារាជិក ។ បើស្លាប់ច្រើននាក់សោត ក៏មានន័យដូចគ្នា តាមដែលពោលហើយនោះឯង ។ តែកាលកើតសេចក្តីក្តៅក្រហាយឡើង បើភិក្ខុទាំងនោះ យកស្លឹករឹតនោះទុកក្នុងហិប បើមានអ្នកដទៃប្រទះឃើញស្លឹករឹតនោះហើយ នាំចេញមកបង្ហាញដល់មហាជនទៀត ភិក្ខុទាំងអស់នោះ មិនរួចអំពីអាបត្តិឡើយ រឿងហិបលើកទុកសិនចុះ សូម្បីពួកភិក្ខុគ្រវែងស្លឹករឹតនោះចោល លាងក្នុងស្ទឹងក្តី សមុទ្រក្តី ហែកជាកំណាត់តូចធំក្តី យកភ្លើងដុតចោលក្តី ក៏មិនរួចផុត ដរាបណាតួអក្សរនៅប្រាកដក្នុងស្លឹករឹតដែលអាចតគ្នាមើលបាន ដែលលាងមិនល្អ ឬដុតមិនល្អ ។ តែបើធ្វើឲ្យអក្សរទាំងឡាយមិនប្រាកដ ទើបរួចខ្លួនបាន ដូច្នេះ ។

## អធិប្បាយ ការជីករណ្តៅ

[ ១៩៦ ] ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃមាតិកា មានរណ្តៅជាដើម ដែលព្រះឧបាលីពោលដើម្បីសម្តែងវិភាគនៃថាវរប្បយោគ ។

បទថា **មនុស្សំ ឧទ្ទិស្ស ឱបាតំ ខណតិ** សេចក្តីថា ភិក្ខុជីករណ្តៅឧទ្ទិសចំពោះមនុស្សខ្លះ ដោយតាំងចិត្តថា បុគ្គលឈ្មោះនេះ ចូរធ្លាក់ស្លាប់ក្នុងទី

ដែលបុគ្គលនោះត្រាច់ទៅតាមដំណើរ ។ ជាដំបូង បើភិក្ខុជីកជាតបឋវី ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគដល់ភិក្ខុអ្នកជីក ព្រោះជាប្រយោគនៃបាណាតិបាត ព្រោះបុគ្គលដែលភិក្ខុឧទ្ទិសចំពោះនោះដល់នូវសេចក្តីទុក្ខ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះបុគ្គលនោះស្លាប់ ត្រូវអាបត្តិបារាជិក បើបុគ្គលដទៃធ្លាក់ទៅស្លាប់ មិនត្រូវអាបត្តិ ។ បើជីកមិនឧទ្ទិសចំពោះ ដោយគិតថា បុគ្គលណានីមួយក៏ចូរស្លាប់ចុះ ជាបាណាតិបាតតាមចំនួនសត្វដែលធ្លាក់ទៅស្លាប់ ត្រូវអនន្តរិយកម្ម ព្រោះវត្ថុនៃអនន្តរិយកម្ម ត្រូវថុល្លច្ច័យ និងបាចិត្តិយ ព្រោះវត្ថុនៃថុល្លច្ច័យ និងបាចិត្តិយ ។

សួរថា ចេតនាក្នុងការជីករណ្តៅនោះមានច្រើន ត្រូវអាបត្តិបារាជិក ដោយចេតនាណា ឆ្លើយថា លោកពោលទុកក្នុងមហាអដ្ឋកថា ជាបឋមថា កាលភិក្ខុជីករណ្តៅ ទាំងដោយជម្រៅ ទាំងដោយចំណែកទទឹង និងបណ្តោយ បានប្រមាណ ( គឺទំហំ ) ហើយកាប់ប្រមូល ប្រើបង្គីសម្រាប់ដាក់អាចម៍ដីយោងឡើង ចេតនាដែលញ៉ាំងអត្ថឲ្យសម្រេច ដែលជាហេតុឲ្យតាំងឡើង ដូចគ្នានឹងផលក្នុងលំដាប់នៃមគ្គ សូម្បីកន្លងទៅដល់រយឆ្នាំ ទើបមានសត្វធ្លាក់ស្លាប់ក្តី ត្រូវអាបត្តិបារាជិក ដោយចេតនាជាហេតុឲ្យតាំងឡើងនោះឯង ចំណែកក្នុងមហាបច្ចរី និងក្នុងសង្ខេបអដ្ឋកថា លោកពោលថា កាលភិក្ខុប្រើចបប្រហារ ( កាប់ ) សូម្បីមួយចប ដោយគិតថា បុគ្គលនឹងធ្លាក់ត្រង់រណ្តៅនេះស្លាប់ ដូច្នេះ បើមានបុគ្គលណាមួយ ភ្លាត់ធ្លាក់ចូលទៅក្នុងរណ្តៅនោះស្លាប់ ត្រូវអាបត្តិបារាជិកដូចគ្នា ចំណែកពួកព្រះថេរៈដែលជំនាញក្នុង

ព្រះសូត្រ សំដៅយកចេតនាដែលជាហេតុឲ្យតាំងឡើង ( ជាគោល ) ។

ភិក្ខុមួយអង្គជីករណ្តៅ ហើយប្រើភិក្ខុមួយអង្គទៀតថា ចូរនាំបុគ្គលឈ្មោះនោះមក ហើយប្រានឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនេះ ។ ភិក្ខុដទៃនោះញ៉ាំងបុគ្គលនោះឲ្យស្លាប់ ត្រូវអាបត្តិបារាជិកទាំងពីរអង្គ ញុំាំងអ្នកដទៃឲ្យធ្លាក់ស្លាប់ ខ្លួនឯងធ្លាក់ទៅស្លាប់ បុគ្គលដទៃធ្លាក់ទៅស្លាប់តាមធម្មតារបស់ខ្លួន គ្រប់ករណី មានការខុសសង្កេត ភិក្ខុដែលជាអ្នកផ្តើមធ្វើរបស់ខ្លួន ។ សូម្បីក្នុងរណ្តៅដែលភិក្ខុជីកទុកដោយគិតថា ភិក្ខុឈ្មោះនោះ នឹងនាំបុគ្គលឈ្មោះនេះមកឲ្យ ( ធ្លាក់ ) ស្លាប់ ក្នុងរណ្តៅនេះ ក៏មានន័យនេះដូចគ្នា ។ ភិក្ខុជីកទុកដោយគិតថា មនុស្សទាំងឡាយដែលចង់ស្លាប់ នឹងស្លាប់ក្នុងរណ្តៅនេះចុះ ត្រូវអាបត្តិបារាជិក ព្រោះមនុស្សម្នាក់ស្លាប់ ជាគំនរអកុសល ព្រោះមនុស្សច្រើននាក់ស្លាប់ ត្រូវអនន្តរិយកម្ម ព្រោះមាតាបិតាស្លាប់ ត្រូវថុល្លច្ច័យ និងបាចិត្តិយ ព្រោះវត្ថុថុល្លច្ច័យ និងបាចិត្តិយ ។ ភិក្ខុជីកទុកដោយគិតថា ជនណាមួយ មានបំណងនឹងសម្លាប់នរណាឲ្យស្លាប់ នឹងប្រានជនទាំងនោះឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនេះ ដូច្នេះ ពួកបុគ្គលនោះប្រានឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនោះ កាលស្លាប់ម្នាក់ ត្រូវអាបត្តិបារាជិក កាលមនុស្សច្រើននាក់ស្លាប់ ជាគំនរអកុសល ជាអនន្តរិយកម្មជាដើម ព្រោះវត្ថុនៃអនន្តរិយកម្មជាដើម ។ សូម្បីព្រះអរហន្តទាំងឡាយ ក៏ដល់នូវការសង្គ្រោះចូលក្នុងន័យក្រោយនេះផងដែរ ។ តែន័យដំបូង កិរិយាដែលព្រះអរហន្តទាំងនោះ នឹងធ្លាក់ទៅ ព្រោះភាពជាអ្នកប្រាថ្នានឹងស្លាប់ រមែងមិនមាន ព្រោះហេតុនោះ ទើបព្រះអរហន្ត

ទាំងឡាយ លោកមិនសង្គ្រោះចូលដែរនោះ ។ សូម្បីក្នុងន័យទាំងពីរ កាលបុគ្គលធ្លាក់ទៅតាមធម្មតារបស់ខ្លួន រមែងមានការខុសសង្កេត ។ ភិក្ខុគិតថា ជនពួកណាមួយ នឹងប្រានបុគ្គលដែលមានពៀររបស់ខ្លួន ឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនេះ ហើយជីកទុក កាលពួកជនដែលមានពៀរនឹងគ្នា ប្រានបុគ្គលដែលមានពៀរនឹងគ្នាឲ្យធ្លាក់ស្លាប់ក្នុងរណ្តៅនោះ បើស្លាប់ម្នាក់ ត្រូវអាបត្តិបារាជិក បើស្លាប់ច្រើននាក់ ជាគំនរអកុសល កាលមាតា ឬបិតា ឬព្រះអរហន្ត ត្រូវពួកជនអ្នកមានពៀរនាំមកសម្លាប់ក្នុងរណ្តៅនោះ ត្រូវអនន្តរិយកម្ម កាលមាតាជាដើមទាំងនោះស្លាប់តាមធម្មតារបស់ខ្លួន រមែងខុសសង្កេត ។

ចំណែកភិក្ខុអង្គណា ជីកទុកមិនបានចំពោះ ដោយប្រការទាំងពួងថា ជនពួកណាមួយ ជាអ្នកចង់ស្លាប់ក្តី មិនចង់ស្លាប់ក្តី ជាអ្នកមានបំណងសម្លាប់បុគ្គលដទៃក្តី មិនមានបំណងសម្លាប់ក្តី ចូរធ្លាក់ស្លាប់ចុះ ឬត្រូវប្រានឲ្យធ្លាក់ទៅស្លាប់ក្នុងរណ្តៅនេះ ភិក្ខុនោះ រមែងជាកម្មពន្ធ និងត្រូវអាបត្តិតាមសមគួរ ព្រោះការស្លាប់របស់បុគ្គលដែលស្លាប់ទៅនោះ ។ បើស្ត្រីមានគភ៌ធ្លាក់ទៅស្លាប់ទាំងកូន ជាបាណាតិបាតពីរ ។ ចំពោះសត្វក្នុងគភ៌ប៉ុណ្ណោះវិនាសទៅ ជាបាណាតិបាតតែមួយ សត្វក្នុងគភ៌មិនវិនាស តែមាតាស្លាប់ ជាបាណាតិបាតតែមួយដូចគ្នា ។ បុគ្គលដែលត្រូវពួកចោរដេញតាម ធ្លាក់ស្លាប់ទៅ ត្រូវអាបត្តិបារាជិកដល់ភិក្ខុដែលជីករណ្តៅដូចគ្នា ។ ពួកចោរធ្លាក់ចូលទៅស្លាប់ក្នុងរណ្តៅនោះ ត្រូវបារាជិកដូចគ្នា ។ ពួកចោរនាំបុគ្គលដែលធ្លាក់ទៅក្នុងរណ្តៅនោះចេញទៅខាងក្រៅ ហើយសម្លាប់ ត្រូវអាបត្តិបារាជិកដូចគ្នា ។ សួរ

ថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះបុគ្គលនោះត្រូវបោរបាប់បាន ព្រោះធ្លាក់ទៅក្នុងរណ្តៅនេះ ។ បុគ្គលដែលធ្លាក់រណ្តៅឡើងអំពីរណ្តៅបាន ហើយស្លាប់ទៅដោយជំងឺនោះឯង ត្រូវអាបត្តិបារាជិកដូចគ្នា ។ កាលកន្លងមកច្រើនឆ្នាំហើយទើបស្លាប់ព្រោះជំងឺនោះឯង ដែលកម្រើកឡើងទៀត ត្រូវអាបត្តិបារាជិកដូចគ្នា រោគដទៃកើតបន្ថែមឡើងដល់បុគ្គលអ្នកឈឺនោះ ដោយរោគដែលកើតឡើង ព្រោះមានការធ្លាក់ទៅក្នុងរណ្តៅនោះជាបច្ច័យនោះឯង តែរោគដែលកើតឡើងព្រោះធ្លាក់រណ្តៅជារបស់មានកម្លាំងជាង កាលបុគ្គលនោះ ស្លាប់ព្រោះរោគដែលកើតឡើងនោះ ភិក្ខុជីករណ្តៅរមែងមិនផុតអំពីអាបត្តិ ។ បើរោគដែលកើតខាងក្រោយ ជារបស់មានកម្លាំងសោត កាលបុគ្គលនោះស្លាប់ព្រោះរោគដែលកើតឡើងខាងក្រោយ ភិក្ខុរមែងរួចចាកអាបត្តិ បើបុគ្គលនោះស្លាប់ដោយរោគទាំងពីរប្រភេទ មិនផុតអំពីអាបត្តិឡើយ ។ មនុស្សដែលបដិសន្ធិក្នុងរណ្តៅនោះ កើតហើយ មិនអាចនឹងឡើងបាន ក៏ស្លាប់ទៅ ត្រូវអាបត្តិបារាជិកដូចគ្នា ។

## មតិរបស់ព្រះថេរៈ ២ អង្គ

ព្រះឧបតិស្សត្ថេរពោលថា បើយក្ខជាដើមធ្លាក់ទៅស្លាប់ក្នុងរណ្តៅដែលភិក្ខុជីកចំពោះមនុស្ស មិនត្រូវអាបត្តិ ។ មនុស្សជាដើមធ្លាក់ស្លាប់នៅក្នុងរណ្តៅ ដែលភិក្ខុជីកចំពោះយក្ខជាដើម ក៏មានន័យដូចគ្នា ។ គ្រាន់តែត្រូវអាបត្តិទុក្កដដល់ភិក្ខុអ្នកជីកចំពោះយក្ខជាដើម ព្រោះការជីកខ្លះ ព្រោះញ៉ាំងទុក្ខឲ្យកើតឡើងដល់យក្ខជាដើមនោះខ្លះ ។ ព្រោះ ( យក្ខជាដើម )

ស្លាប់ ត្រូវអាបត្តិថុល្លច្ច័យ ឬបាចិត្តិយ តាមអំណាចនៃវត្ថុនោះឯង ។ សត្វធ្លាក់ចូលក្នុងរណ្ដៅដែលភិក្ខុជីកមិនបានចំពោះ ដោយរូបយក្ខក្ដី រូបប្រេតស្លាប់ទៅក្ដី ដោយរូបសត្វតិរច្ឆាន ( គឺសាកសពប្រេតជាសត្វតិរច្ឆាន ) រូបដែលធ្លាក់ទៅប៉ុណ្ណោះ រមែងជាប្រមាណ ព្រោះដូច្នោះ ទើបត្រូវអាបត្តិថុល្លច្ច័យ ។

ចំណែកព្រះបុស្សទេវត្ថេរពោលថា រូបដែលស្លាប់ជាប្រមាណ ព្រោះដូច្នោះ ទើបត្រូវត្រឹមអាបត្តិបាចិត្តិយ ។ សូម្បីក្នុងសត្វដែលធ្លាក់ទៅដោយរូបសត្វតិរច្ឆាន ហើយស្លាប់ដោយរូបយក្ខ និងរូបប្រេត ក៏មានន័យដូចគ្នា ។ ភិក្ខុជីករណ្ដៅលក់ ឬឲ្យទទេដល់ភិក្ខុដទៃ ភិក្ខុនោះឯងគង់ត្រូវអាបត្តិ និងជាកម្មពន្ធ ព្រោះមានបុគ្គលធ្លាក់ស្លាប់ជាបច្ច័យ ភិក្ខុដែលបានរណ្ដៅនោះមិនមានទោស ដូច្នេះ ។ ភិក្ខុអ្នកទទួលរណ្ដៅហើយ គិតថា រណ្ដៅនេះសត្វធ្លាក់ទៅគង់អាចឡើងបាន នឹងមិនវិនាស នឹងស្រវាឡើងបានងាយ ទើបធ្វើរណ្ដៅនោះឲ្យជ្រៅថែមទៀត ឬឲ្យរាក់ឡើង ឲ្យវែង ឬខ្លី ឲ្យទូលាយ ឬបង្រួមឲ្យតូច រមែងត្រូវអាបត្តិ និងជាកម្មពន្ធដូចគ្នាទាំងពីរអង្គ ។ កាលកើតវិប្បដិសារីឡើងថា មនុស្សសត្វស្លាប់ច្រើនណាស់ ទើបលុបរណ្ដៅឲ្យពេញដោយដី ។ បើលុបឲ្យពេញហើយ សត្វណាមួយជាប់ដីនោះស្លាប់ ក៏មិនផុតពីអាបត្តិ ។ កាលភ្លៀងធ្លាក់មានភក់ បើសត្វណាមួយ ជាប់ស្លាប់ក្នុងភក់នោះក្ដី ដើមឈើរលំក្ដី ខ្យល់បក់ក្ដី ទឹកភ្លៀងតក់ក្ដី នាំយកមនុស្សទៅ ឬពួកអ្នកជីកដីដើម្បីដំឡូង ជីកជាអន្លង់ទុកក្នុងទីនោះ បើសត្វណាមួយ ជាប់ឬធ្លាក់ស្លាប់ ទៅក្នុងរណ្ដៅនោះ ភិក្ខុខាងដើមរមែងមិនផុតអំពីអាបត្តិ តែក្នុងឱកាស

នោះ ភិក្ខុធ្វើជាបឹង ឬ ស្រះឈូកធំ ប្រតិស្ឋានជាចេតិយ ដាំដើមពោធិ៍ ឬឲ្យសាងវត្ត ឬឲ្យធ្វើផ្លូវរទេះ ហើយទើបរួចផុតអំពីអាបត្តិបាន ។ ក្នុងកាលណាដើមឈើជាដើមក្នុងរណ្តៅដែលលុបពេញ ធ្វើឲ្យណែនហើយ ឫស និងឫសចាក់ស្រេះចូលគ្នា កើតជាតបឋវី ក្នុងកាលនោះក៏រួចផុតអាបត្តិបាន ឬ បើទឹកហូរមកប្រោះរណ្តៅនោះក្លាយជាស៊ឹង យ៉ាងនោះក៏ផុតបានឯង ។ អធិប្បាយការជីករណ្តៅ មានប្រមាណប៉ុណ្ណេះ ។

## អធិប្បាយ អំពីអន្ទាក់

គប្បីជ្រាបវិនិច្ឆ័យក្នុងអន្ទាក់ជាដើម ដែលអនុលោមដល់រណ្តៅនោះដូចតទៅនេះថា ភិក្ខុអង្គណា ដាក់អន្ទាក់ទុកក្នុងកាលមុន ដោយគិតថា សត្វទាំងឡាយនឹងជាប់ក្នុងអន្ទាក់នេះស្លាប់ កាលអន្ទាក់ផុតទៅអំពីដៃ គប្បីជ្រាបថាត្រូវអាបត្តិបារាជិក អនន្តរិយកម្ម ថុល្លច្ច័យ និងបាចិត្តិយ ដល់ភិក្ខុនោះដោយអំណាចសត្វដែលជាប់ ( អន្ទាក់នោះ ) ។

ក្នុងអន្ទាក់ដែលភិក្ខុឧទ្ទិសចំពោះ មានវិនិច្ឆ័យដូច្នេះថា អន្ទាក់ដែលភិក្ខុឧទ្ទិសចំពោះសត្វមួយណា បើសត្វដទៃក្រៅពីសត្វមួយនោះមកជាប់ មិនត្រូវអាបត្តិ ។ កាលភិក្ខុលក់អន្ទាក់ទៅដោយតម្លៃ ឬឲ្យទទេក៏ដោយ កម្មពន្ធរមែងមានដល់ភិក្ខុម្ចាស់ដើមដូចគ្នា ។ បើភិក្ខុអ្នកទទួលអន្ទាក់ដាក់អន្ទាក់ឃ្លាតចាកទីដែលបាន ឬឃើញពួកសត្វដើរទៅក្បែរៗ ទើបធ្វើរបាំងទុក កៀងសត្វឲ្យចូលទៅត្រង់ចំពោះមុខ ឬរៀបចំដងអន្ទាក់ឲ្យរឹងមាំ ឬចងខ្សែអន្ទាក់ឲ្យ

មាំទាំឡើង ឬដំបង្គោលថែមឲ្យមាំទាំ ភិក្ខុទាំងពីររូបនោះមិនផុតពីអាបត្តិទេ កាលបើកើតសេចក្ដីក្ដៅក្រហាយឡើង ទើបភិក្ខុសម្រូតអន្ទាក់ឲ្យរបូតចេញហើយ ។ បុគ្គលដទៃឃើញអន្ទាក់តម្រោះហើយនោះ ក៏ដំឡើងជាថ្មីទៀត សត្វទាំងឡាយដែលជាប់ ហើយស្លាប់ទៅ ភិក្ខុម្ចាស់ដើមមិនផុតចាកអាបត្តិទេ ។ បើជងអន្ទាក់ដែលភិក្ខុម្ចាស់ដើមនោះ មិនបានធ្វើទុកឯង តែដាក់ក្នុងទីដែលខ្លួនទទួលមក រមែងផុតអាបត្តិបាន ។ ភិក្ខុកាត់ជងអន្ទាក់ដែលកើតក្នុងទីនោះចោល រមែងផុតអាបត្តិ តែបើភិក្ខុរក្សាជងអន្ទាក់ ដែលខ្លួនធ្វើឯង រមែងមិនផុតចាកអាបត្តិ ។ ពិតហើយ បើភិក្ខុដទៃកាន់យកជងអន្ទាក់នោះទៅដាក់ទៀតសោត បើសត្វទាំងឡាយស្លាប់ទៅ ព្រោះមានការដាក់អន្ទាក់នោះជាបច្ច័យ ភិក្ខុម្ចាស់ដើម រមែងមិនផុតចាកអាបត្តិ ។ បើភិក្ខុដុតជងអន្ទាក់នោះធ្វើឲ្យកើតជាធ្យូង ហើយចោលទៅ កាលសត្វទាំងឡាយ បានការប្រហារដោយដុំធ្យូងនោះស្លាប់ទៅ រមែងមិនផុតចាកអាបត្តិ តែបើដុត ឬធ្វើឲ្យវិនាសទៅដោយប្រការទាំងពួង រមែងផុតចាកអាបត្តិ ។ ភិក្ខុទុកខ្សែអន្ទាក់ដែលអ្នកដទៃវេញស្រេចហើយ ក្នុងទីដែលខ្លួនទទួលមក រមែងផុតចាកអាបត្តិ ។ ភិក្ខុបានខ្សែមកហើយ រុះធ្លុងដែលគេវេញទុកដោយខ្លួនឯង ឬធ្វើខ្សែដែលខ្លួនបានសម្បកព្រាលមកហើយ វេញឲ្យជាកំណាត់តូច-ធំ រមែងផុតចាកអាបត្តិ ។ តែកាលភិក្ខុរក្សាខ្សែដែលខ្លួននាំព្រាលមកអំពីព្រៃវេញទុក រមែងមិនរួចផុតចាកអាបត្តិ តែបើដុត ឬធ្វើឲ្យខ្ទេចខ្ទីដោយប្រការទាំងពួង រមែងផុតបាន ។

# ការដាក់អន្តប់

កិក្ខុកាលរៀបចំធ្វើអន្តប់ ដាក់បន្ទះអន្តប់លើជើងទាំង ៤ លើកដុំថ្មឡើង ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ។ កាលភិក្ខុរៀបចំស្រេចបាច់ហើយ អន្តប់ផុតទៅអំពីដៃ គប្បីជ្រាបថា ត្រូវអាបត្តិបារាជិកជាដើម តាមសមគួរដល់ប្រយោគ ដែលធ្វើចំពោះ និងមិនចំពោះ ដោយអំណាចនៃពួកសត្វ ដែលគប្បីត្រូវសង្កត់ពិតប្រាកដ ។ កាលភិក្ខុចំណាយអន្តប់ដោយតម្លៃ ឬឲ្យទៅគេក្តី កម្មពន្ធ រមែងមានដល់ភិក្ខុដែលជាម្ចាស់ដើមនោះឯង ។ បើភិក្ខុអ្នកទទួលអន្តប់លើកអន្តប់ដែលធ្លាក់ឡើងដំឡើង ឬលើកដុំថ្មដទៃឡើង ធ្វើឲ្យធ្ងន់ជាងមុន ឬឃើញពួកសត្វដើរទៅក្បែរៗ ធ្វើរបាំងទុក កៀងសត្វឲ្យចូលទៅចំអន្តប់ ភិក្ខុទាំងពីររូប រមែងមិនផុត ។ បើភិក្ខុកើតការក្តៅក្រហាយឡើង ទើបតម្លោះអន្តប់ឲ្យធ្លាក់ ហើយចេញទៅ ភិក្ខុដទៃឃើញអន្តប់ដែលធ្លាក់ហើយ ក៏ដំឡើងជាថ្មី ភិក្ខុម្ចាស់ដើមមិនផុតពីអាបត្តិឡើយ ។ ភិក្ខុដាក់ដុំថ្មក្នុងទីដែលខ្លួនទទួលមក និង ដាក់ជើងអន្តប់ទុកក្នុងទីដែលខ្លួនទទួលមក ឬផុតដោយន័យ ដូចពោលទុកហើយ ក្នុងជងអន្ទាក់ រមែងផុតពីអាបត្តិបាន ។

សូម្បីកាលភិក្ខុបោះចម្រូង លុះធ្វើការរៀបចំគ្រប់យ៉ាងស្រេចបាច់ហើយ ផុតអំពីដៃ គប្បីជ្រាបថា ត្រូវបារាជិកជាដើម ដោយសមគួរដល់ប្រយោគ ដែលធ្វើចំពោះ និងមិនចំពោះ ដោយអំណាចនៃពួកសត្វដែលធ្លាក់ចុះទៅលើចម្រូងនោះឯង ។ កាលភិក្ខុលក់លំពែង ឬឲ្យទទេក៏ដោយ កម្មពន្ធ រមែងមានដល់ភិក្ខុម្ចាស់ដើមដូចគ្នា ។ បើភិក្ខុបានចម្រូងហើយ សម្រួចឲ្យមុតដោយគិតថា សត្វទាំងឡាយនឹងស្លាប់ដោយការប្រហារតែម្តងប៉ុណ្ណោះ ឬ

រៀបចំចម្រូងឲ្យទាល ដោយគិតថា សត្វទាំងឡាយនឹងស្លាប់ជាទុក្ខ ឬកំណត់ថា ចម្រូងខ្ពស់ពេក ត្រូវជំឲ្យទាបចុះ ឬកំណត់ថា ចម្រូងទាបពេក លើកឲ្យខ្ពស់ឡើងទៀត ឬពត់ត្រង់គល់ឲ្យត្រង់ ឬពត់ទីដែលត្រង់ ឲ្យរៀបបន្តិច ភិក្ខុទាំងពីររូបមិនផុតពីអាបត្តិឡើយ ។ បើភិក្ខុឃើញថា ទុកក្នុងទីមិនសមគួរ ហើយយកទៅដោតទុកក្នុងទីដទៃ បើចម្រូងនោះជារបស់ដែលលោកស្វែងរកមកធ្វើទុកតាំងអំពីដើម ដើម្បីសម្លាប់សត្វ ភិក្ខុម្ចាស់ដើមមិនផុតចាកអាបត្តិ តែកាលមិនបានស្វែងរក បានរបស់ដែលគេធ្វើទុកស្រាប់នោះឯង លើកឡើង ភិក្ខុម្ចាស់ដើមរមែងរួចផុត ។ កាលភិក្ខុកើតសេចក្តីក្តៅក្រហាយឡើង លោកដាក់ចម្រូងទុកក្នុងទីដែលខ្លួនទទួលមក ឬដុតចោលដោយន័យដូចពោលទុកហើយ ក្នុងជនអន្ទាក់ រមែងរួចផុតចាកអាបត្តិបាន ។

## ការដាក់សស្ត្រាក្នុងទីបង្អែក

[ ១៩៧ ] ក្នុងពាក្យថា **អបស្សេនេ សត្ថំ វា** នេះ មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា បង្អែក បានដល់ គ្រែក្តី តាំងក្តី ក្តារសម្រាប់ផ្អែកក្តី ដែលប្រើជានិច្ច ឬសសរសម្រាប់ផ្អែករបស់ភិក្ខុដែលអង្គុយផ្អែក ក្នុងទីសម្រាកពេលថ្ងៃ ឬដើមឈើដែលដុះនៅក្នុងទីនោះ ឬដើមឈើសម្រាប់គោងរបស់ភិក្ខុដែលឈរផ្អែកនៅក្នុងទីចង្ក្រម ឬក្តារសម្រាប់គោង វត្ថុ មានគ្រែជាដើមទាំងអស់នោះ ដែលឈ្មោះថា បង្អែក ព្រោះអត្ថថា ជាទីតាំងនៃការផ្អែក ( ជាទីតាំងនៃការមើលមិនឃើញ ) ។ ភិក្ខុធ្វើដូចបុគ្គលចាក់ ឬកាប់បុគ្គលដែលមិនឃើញ ដាក់បណ្តាសស្ត្រាប្រភេទណាមួយ មានកាំបិត ពូថៅ លំពែង ដែកស្រួច និង

បន្ទាជាដើម ទុកក្នុងទីសម្រាប់ផ្អែកនោះ ត្រូវអាបត្តិទុក្កដ កាលបុគ្គលមិនមាន សេចក្តីសង្ស័យ អង្គុយ ឬដេក ឬផ្អែកក្នុងស្ថានទីប្រើជាប្រចាំ ព្រោះញ៉ាំង ទុក្ខឲ្យកើតឡើង ដោយមានការមុតសស្ត្រាជាបច្ច័យ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងពេលគេស្លាប់ ត្រូវអាបត្តិបារាជិក ។ បើភិក្ខុដែលមានពៀររបស់ភិក្ខុអង្គ ដទៃ ត្រាច់ចារិកទៅក្នុងវិហារ ប្រទះឃើញសស្ត្រានោះហើយ ត្រេកអរថា ប្រហែលសស្ត្រានេះ ជារបស់ដែលភិក្ខុអង្គនេះដាក់ទុក ដើម្បីជាគ្រឿងប្រហារ សាធុ ចូរស្លាប់ចុះ ដើរទៅ ត្រូវអាបត្តិទុក្កដ ។ តែបើភិក្ខុដែលមានពៀរអង្គ នោះ គិតថា កាលភិក្ខុធ្វើសស្ត្រានោះទុកយ៉ាងនោះហើយ ឈ្មោះថា លោក ធ្វើទុកល្អហើយ ទើបធ្វើកម្មណាមួយ ក្នុងការធ្វើសស្ត្រាឲ្យមុតខ្លាំងជាដើម ត្រូវអាបត្តិបារាជិកដល់ភិក្ខុអ្នកមានពៀរអង្គនោះ តែបើភិក្ខុអ្នកមានពៀរឃើញ ថា ភិក្ខុអង្គនោះដាក់សស្ត្រាទុកក្នុងទីមិនសមគួរ ទើបលើកឡើងមកទុកក្នុងទី ដទៃ កាលភិក្ខុធ្វើហើយដាក់ដើម្បីប្រយោជន៍នោះឯង ភិក្ខុម្ចាស់ដើមរមែងមិន ផុតពីអាបត្តិ ។ ភិក្ខុបានសស្ត្រាហើយ ទុកតាមប្រក្រតីដើម រមែងផុតចាក អាបត្តិ ។ ភិក្ខុនាំសស្ត្រានោះចេញទៅចោល ហើយយកសស្ត្រាដទៃដែលមុត ជាងមកដាក់ជំនួស ភិក្ខុម្ចាស់ដើមរមែងមិនផុតអាបត្តិដូចគ្នា ។

## ការដាក់ថ្នាំពិសក្នុងភេសជ្ជៈ

ក្នុងការលាបថ្នាំពិស មានវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិទុក្កដ ព្រោះ បុគ្គលនោះ ត្រេកអរនឹងសេចក្តីស្លាប់ រហូតដល់ន័យនេះដូចគ្នា ។ បើភិក្ខុ អង្គនោះកំណត់បានថា ដុំថ្នាំពិសតូចពេក ទើបធ្វើឲ្យធំឡើង ឬកំណត់បានថា

ថ្នាំពិសធំពេក ឬធំជ្រុលពេក ទើបធ្វើតូច ឬស្រាល ឬធ្វើឲ្យក្រាស់ ឬក្រាស់ពេក ទើបធ្វើឲ្យស្តើងចុះ ហើយរោលឲ្យក្តៅដោយភ្លើង ឬធ្វើឲ្យសឹកទៅខាងក្រោម ឬខាងលើ ត្រូវអាបត្តិបារាជិកដល់ភិក្ខុអង្គនោះ ភិក្ខុឃើញថា ជុំថ្នាំពិសនេះទុកក្នុងទីមិនសមគួរ ទើបចិតចេញឲ្យស្តើងគ្រប់ចំណែកនោះឯង ហើយជូត ( ធ្វើឲ្យរលោង ) យកទៅដាក់ក្នុងទីដទៃ កាលភិក្ខុចម្អិនកេសជ្ជៈដោយខ្លួនឯង ហើយបង់ថ្នាំពិសចូលផង ភិក្ខុម្ចាស់ដើមរមែងមិនផុតពីអាបត្តិ បើខ្លួនឯងមិនបានធ្វើរមែងផុតពីអាបត្តិ តែបើភិក្ខុអង្គនោះឃើញថា ថ្នាំពិសនេះតិចពេក ទើបនាំយកថ្នាំពិសដទៃមកដាក់បន្ថែម ត្រូវអាបត្តិបារាជិកដល់ ភិក្ខុម្ចាស់ដើមនៃថ្នាំពិសដែលជាហេតុឲ្យគេស្លាប់ ។ បើគេស្លាប់ទៅ ព្រោះថ្នាំពិសដែលជារបស់ភិក្ខុទាំងពីរអង្គ ក៏ត្រូវអាបត្តិបារាជិកដល់ភិក្ខុទាំងពីរអង្គ ។ ភិក្ខុឃើញថា ថ្នាំពិសនេះអស់ឫទ្ធិហើយ ទើបនាំថ្នាំពិសនោះចេញហើយដាក់ថ្នាំពិសរបស់ខ្លួនឯងជំនួស ត្រូវអាបត្តិបារាជិកដល់ភិក្ខុនោះប៉ុណ្ណោះ ភិក្ខុម្ចាស់ដើមរួចខ្លួនពីអាបត្តិ ។

## ការដាក់អាវុធក្រោមគ្រែ ឬ តាំង

ពីរបទថា **ឧក្ខលំ វា ករោតិ** សេចក្តីថា ភិក្ខុកាត់គ្រែ និងតាំងខាងក្រោមមេគ្រែ ឬកាត់ផ្តៅ និងខ្សែដែលគេវេញ ធ្វើឲ្យសល់បន្តិចបន្តួចប៉ុណ្ណោះ ទើបស៊កអាវុធទុកខាងក្រោម ភិក្ខុកាត់ចំណែកដទៃនៃវត្ថុ មានក្តារសម្រាប់ផ្អែកជាដើម ដែលមានដើមឈើ និងក្តារសម្រាប់តោងក្នុងទីចង្ក្រម ខាងចុងចេញ ហើយយកអាវុធស៊កទុកខាងក្រោម ដោយបំណងថា បុគ្គលនឹងធ្លាក់

ស្លាប់ត្រង់អាវុធនេះ ។ ភិក្ខុនាំគ្រែ តាំង ឬក្តារសម្រាប់ផ្អែកមកដាក់ជិតអណ្តូងជាដើម ដោយមនុស្សគ្រាន់តែអង្គុយ ឬផ្អែកត្រង់គ្រែជាដើមនោះ ក៏នឹងធ្លាក់ចុះទៅ ឬធ្វើស្ពានសម្រាប់ដើរទៅមកលើអណ្តូងជាដើម ធ្វើឲ្យទុព្វល កាលភិក្ខុធ្វើហើយយ៉ាងនោះ ត្រូវអាបត្តិទុក្កដ ព្រោះញ៉ាំងទុក្ខឲ្យកើតដល់បុគ្គល ត្រូវអាបត្តិថុល្លច្ច័យ ព្រោះបុគ្គលនោះស្លាប់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនាំភិក្ខុផងគ្នាទៅហើយ ឲ្យផ្អែកលើមាត់អណ្តូងជាដើម ដោយគិតថា ភិក្ខុឃើញហើយ ភ័យរន្ធត់ ព្រោះខ្លាចធ្លាក់ស្លាប់ ដូច្នេះ ភិក្ខុធ្លាក់ទៅ យ៉ាងនោះមែនៗ ត្រូវអាបត្តិទុក្កដ ព្រោះញ៉ាំងទុក្ខឲ្យកើតឡើង ត្រូវអាបត្តិថុល្លច្ច័យ ព្រោះភិក្ខុនោះស្លាប់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុប្រានភិក្ខុអង្គនោះឲ្យធ្លាក់ទៅ ប្រើអ្នកដទៃឲ្យប្រានធ្លាក់ទៅ អ្នកដទៃមិនបានប្រើឡើយ ប្រានឲ្យធ្លាក់ទៅដោយខ្លួនឯង អមនុស្សប្រានឲ្យធ្លាក់ទៅ ធ្លាក់ទៅព្រោះត្រូវខ្យល់បក់ ធ្លាក់ទៅតាមធម្មតារបស់ខ្លួន ព្រោះបុគ្គលនោះស្លាប់គ្រប់ករណី ត្រូវអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ព្រោះស្លាប់នៅជិតមាត់អណ្តូងជាដើម ដោយប្រយោគរបស់ភិក្ខុដែលផ្តើមគំនិតនោះ ។

# ការបង្កប់ដាវ

[ ១៩៨ ] ការដាក់ ( ដាវជាដើម ) ទុកក្នុងទីជិត ឈ្មោះថា ការលួចដាក់ ។ ក្នុងការលួចដាក់នោះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុណាពណ៌នាគុណនៃសេចក្តីស្លាប់ ដោយន័យជាដើមថា បុគ្គលណាស្លាប់ដោយដាវនេះ បុគ្គលនោះនឹងបានទ្រព្យក្តី ពោលថា បុគ្គលចង់ស្លាប់ ចូរស្លាប់ដោយដាវនេះក្តី

ពោលថា បុគ្គលចង់ស្លាប់ ចូរឲ្យគេសម្លាប់ដោយដាវនេះក្តី ហើយលួចដាក់ដាវ ត្រូវអាបត្តិទុក្កដដល់ភិក្ខុអង្គនោះ ។ បុគ្គលដែលចង់ស្លាប់ ប្រើដាវនោះប្រហារខ្លួនឯងក្តី មានបំណងប្រើឲ្យអ្នកដទៃសម្លាប់ថា ចូរយកដាវនោះប្រហារអ្នកដទៃក្តី ដោយការប្រហារទាំងពីរយ៉ាង ត្រូវអាបត្តិថុល្លច្ច័យ ដល់ភិក្ខុលួចដាក់ ព្រោះញ៉ាំងទុក្ខឲ្យកើតដល់បុគ្គលដទៃ ព្រោះបុគ្គលនោះស្លាប់ត្រូវអាបត្តិបារាជិក ។ បើភិក្ខុដាក់មិនចំពោះ ជាគំនរអកុសល ព្រោះមនុស្សសត្វដ៏ច្រើនស្លាប់ ត្រូវអាបត្តិបារាជិកជាដើម ព្រោះវត្ថុនៃបារាជិកជាដើម ។ ភិក្ខុនោះ កាលកើតសេចក្តីក្តៅក្រហាយឡើង ទើបយកដាវទៅទុកក្នុងទីដែលខ្លួនទទួលមក រមែងរួចផុត ។ ដាវជារបស់ភិក្ខុដែលទិញមក ភិក្ខុសងដាវឲ្យដល់ម្ចាស់របស់ដាវ ទទួលយកតម្លៃមកអំពីដៃរបស់បុគ្គលនោះហើយ រមែងរួចផុត ។ បើភិក្ខុយកបន្ទះលោហៈ ផាល ឬចប ទៅឲ្យជាងធ្វើដាវសោត ឬកាន់យកកណ្ឌៈណាមកឲ្យធ្វើដាវ កាលរំលាយឲ្យទៅជាកណ្ឌៈដើមវិញទើបរួចផុត ។ បើភិក្ខុញ៉ាំងដាវដែលយកចប មកឲ្យជាងធ្វើឲ្យវិនាសទៅហើយធ្វើឲ្យជាផាលសោត កាលសត្វជាច្រើន បានប្រហារដោយផាលស្លាប់ទៅ ភិក្ខុនោះ រមែងមិនផុតចាកបាណាតិបាត ។ បើភិក្ខុឲ្យរំលាយលោហៈហើយឲ្យជាងធ្វើជាដាវ ដើម្បីការបង្កប់នោះឯង កាលដាវដែលលោកយកចុងដែកកោស ហើយធ្វើឲ្យកម្ទេចដែកខ្ទាត់ខ្ចាយទៅ ទើបភិក្ខុរួចផុតពីអាបត្តិបាន ។ បើជាដាវដែលភិក្ខុច្រើនរូបរួមអធ្យាស្រ័យគ្នាធ្វើ ដូចក្នុងសីហគីតដែលសរសេរពណ៌នា ( គុណនៃសេចក្តីស្លាប់ ) ទុកដូច្នោះឯង ។ វិនិច្ឆ័យដល់

កម្មពន្ធ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងស្ទឹករឹតនោះឯង ។ ក្នុងលំពែង និងច្បូកក៏មានន័យនេះ ។ ក្នុងចម្រូង និងអន្ទូង មានវិនិច្ឆ័យដូចដែលពោលហើយ ក្នុងជង្អន្ទាក់ ។ ក្នុងជុំថ្ម ក៏យ៉ាងនោះ ។ ក្នុងសស្ត្រា ក៏មានវិនិច្ឆ័យដូចជាវនោះឯង ។

## ការដាក់ថ្នាំពិសជាដើម

បទថា **វិសំ វា** សេចក្តីថា កាលភិក្ខុលួចដាក់ថ្នាំពិស គប្បីជ្រាបថា ត្រូវអាបត្តិបារាជិកជាដើម ក្នុងវត្ថុនៃបារាជិកជាដើម ដោយគួរដល់ការចំពោះ និងមិនចំពោះ ដោយអំណាចនៃវត្ថុ ។ ក្នុងថ្នាំពិសដែលភិក្ខុទិញមក រក្សាទុក ភិក្ខុធ្វើឲ្យជាប្រក្រតីដើម ដោយន័យមុនហើយ ទើបនឹងរួចផុត ។ កាលភិក្ខុផ្សំថ្នាំពិសចូលជាមួយភេសជ្ជៈខ្លួនឯង ភិក្ខុធ្វើមិនឲ្យជាថ្នាំពិសហើយ ទើបរួចផុតបាន ។ ក្នុងខ្សែ មានវិនិច្ឆ័យដូចគ្នានឹងខ្សែអន្ទាក់នោះឯង ។

[ ១៩៩ ] ក្នុងភេសជ្ជៈ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុណា កាលភិក្ខុដែលមានពៀរគ្រុនសន្និ ឬរោគមានចំណែកជាពិសកើតឡើង មានបំណងនឹងឲ្យស្លាប់ ប្រាប់ថា វត្ថុ មានទឹកដោះថ្លាជាដើមជាទីសប្បាយ ដូច្នេះ ទើបប្រគេនភេសជ្ជៈដែលមិនជាទីសប្បាយ ឬក្រអៅឈូក ឫសឈើ និងផ្លែឈើ ប្រភេទដទៃណាមួយ គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុនោះ ព្រោះប្រគេនភេសជ្ជៈយ៉ាងនោះ ត្រូវអាបត្តិថុល្លច្ច័យ និងបារាជិក ព្រោះញុំាងទុក្ខឲ្យកើតដល់ភិក្ខុដទៃ និងព្រោះភិក្ខុនោះស្លាប់ ។ ត្រូវអនន្តរិយកម្ម ក្នុងវត្ថុនៃអនន្តរិយកម្ម ។

# ការសម្លាប់ដោយរូប និងសំឡេងជាដើម

[ ២០០ ] ក្នុងការនាំរូបចូលទៅ មានវិនិច្ឆ័យដូច្នេះ បទថា **ឧបសំហរតិ** សេចក្ដីថា ភិក្ខុនាំមនុស្សដទៃ ដែលមានរូបមិនគួរពេញចិត្តទុកក្នុងទីជិតបុគ្គលនោះ ឬភិក្ខុក្លែងភេទជាយក្ខ និងប្រេតជាដើមដោយខ្លួនឯង ហើយឈរ កាលនាំរូបចូលទៅ ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ក្នុងការញ៉ាំងភ័យឲ្យកើតឡើងដល់ជនដទៃ ព្រោះឃើញរូបនោះ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះបុគ្គលនោះស្លាប់ ត្រូវអាបត្តិបារាជិក ។ តែបើរូបនោះឯង រមែងជាទីពេញចិត្តរបស់បុគ្គលខ្លះសោត ហើយបុគ្គលនោះ រមែងស្គមស្គាំងស្លាប់ ព្រោះមិនបាន ( រូបនោះ ) រមែងខុសសង្កេត ។ សូម្បីក្នុងរូបដែលជាទីពេញចិត្ត ក៏មានន័យដូចគ្នានេះ ។

បណ្ដារូបដែលជាទីពេញចិត្តទាំងនោះ ពោលដោយពិសេស រូបបុរស រមែងជាទីពេញចិត្តរបស់ស្ត្រី ហើយរូបស្ត្រី រមែងជាទីពេញចិត្តរបស់ពួកបុរស ។ ភិក្ខុតាក់តែងរូបនោះហើយ នាំចូលទៅ គឺធ្វើត្រឹមតែឲ្យបុគ្គលនោះឃើញប៉ុណ្ណោះ តែមិនព្រមឲ្យមើលយូរៗ ។ បុគ្គលនោះ រមែងស្គាំងស្គមស្លាប់ ព្រោះមិនបាន ( រូបនោះ ) ភិក្ខុត្រូវអាបត្តិបារាជិក បើបុគ្គលនោះភ័យស្លាប់ រមែងខុសសង្កេត ។ តែបើភិក្ខុមិនពិចារណាថា បុគ្គលនោះ នឹងភ័យស្លាប់ ឬនឹងស្គាំងស្គមស្លាប់ ព្រោះមិនបានរូបនោះ នាំចូលទៅ ដោយគិតតែម្យ៉ាងថា បុគ្គលនោះឃើញហើយ នឹងស្លាប់ដូច្នេះ កាលបុគ្គលនោះភ័យស្លាប់ ឬស្គាំងស្គមស្លាប់ ត្រូវអាបត្តិបារាជិកដូចគ្នា ។ សូម្បីកិច្ចទាំងឡាយ មានការនាំសំឡេងចូលទៅជាដើម ក៏គប្បីជ្រាបដោយឧបាយនេះឯង ។

ពិតហើយ ក្នុងសំឡេងជាដើមនេះ ( មានសេចក្តីប្លែកគ្នា ) តែម្យ៉ាង គឺ ( អារម្មណ៍ខាងក្រៅ ) មានសំឡេងរបស់អមនុស្សជាដើម គប្បីជ្រាបថា ជាហេតុឲ្យកើតសេចក្តីភ័យខ្លាច ជាវត្ថុដែលមិនពេញចិត្ត សំឡេងបុរសស្រ្តី និងសំឡេងអ្នកចម្រៀងដែលពីរោះជាដើម គប្បីជ្រាបថា ធ្វើនូវការរីករាយចិត្តឲ្យជាសំឡេងដែលពេញចិត្ត ក្លិននៃឫសឈើជាដើមរបស់ដើមឈើដែលពុល ក្នុងព្រៃហិមពាន្ត និងក្លិននៃសាកសព គប្បីជ្រាបថា ជាក្លិនដែលមិនពេញចិត្ត ក្លិនដែលកើតអំពីឫសឈើ មានក្រស្នា និងកំញានជាដើម គប្បីជ្រាបថា ជាក្លិនដែលពេញចិត្ត រសដែលកើតអំពីឫសឈើដែលបដិកូលជាដើម គប្បីជ្រាបថា ជារសដែលមិនពេញចិត្ត រសដែលកើតអំពីឫសឈើដែលមិនបដិកូលជាដើម គប្បីជ្រាបថា ជារសដែលពេញចិត្ត ការប៉ះពាល់ថ្នាំពិស និងសម្ផស្សខ្ញែធំជាដើម គប្បីជ្រាបថា ជាផោដ្ឋព្វៈដែលមិនពេញចិត្ត សម្ផស្ស សំពត់កម្ពល សំពត់រោមហង្ស និងសំឡីជាដើម គប្បីជ្រាបថា ជាផោដ្ឋព្វៈ ដែលពេញចិត្ត ។

## ការនាំធម្មារម្មណ៍ចូលទៅ

ក្នុងការនាំធម្មារម្មណ៍ចូលទៅ មានវិនិច្ឆ័យដូច្នេះថា ធម្មទេសនា គប្បីជ្រាបថា ធម៌ ។ ម្យ៉ាងទៀត ធម្មារម្មណ៍ ដែលផ្សេងគ្នាដោយវិបត្តិក្នុងនរក និងសម្បត្តិក្នុងសួគ៌ ដោយអំណាចនៃទេសនា ( គប្បីជ្រាបថាធម៌ ) ។

បទថា **នេរយិកស្ស** បានដល់ ពោលពណ៌នារឿងនរក មានចំណង ៥ ប្រការ និង កម្មករណៈជាដើម ដល់សត្វដែលខ្វះសំវរៈ ធ្វើបាបកម្មដែល

គួរកើតក្នុងនរក ។ បើបុគ្គលនោះស្តាប់និរយកថានោះ ភ័យស្លាប់ ភិក្ខុអ្នកពោល ត្រូវអាបត្តិបារាជិក ។ តែបើបុគ្គលនោះស្តាប់ហើយ ស្លាប់ទៅតាមធម្មតារបស់ខ្លួន មិនត្រូវអាបត្តិ ។ ភិក្ខុសម្តែងនិរយកថា ដោយតាំងចិត្តថា បុគ្គលនេះបានស្តាប់និរយកថានេះហើយ នឹងមិនធ្វើកម្ម មានសភាពបែបនេះ នឹងវៀរចាក លែងធ្វើ បុគ្គលនោះស្តាប់និរយកថានោះ ភ័យស្លាប់ មិនត្រូវអាបត្តិ ។

បទថា **សគ្គកថំ** បានដល់ កថាពណ៌នាសម្បត្តិនៃរបស់មានវិញ្ញាណ មានទេពនាដកាជាដើម និងរបស់មិនមានវិញ្ញាណ មានទន្ទនវ័នឧទ្យានជាដើម បុគ្គលនោះ បានស្តាប់សគ្គកថានោះ បង្អោនចិត្តទៅក្នុងស្ថានសួគ៌ ចង់បានសម្បត្តិនោះឆាប់ៗ ញុំាងទុក្ខឲ្យកើតឡើង ដោយប្រើសស្ត្រា បរិភោគថ្នាំពិស អត់អាហារ និងអត់ដង្ហើមជាដើម ត្រូវអាបត្តិថុល្លច្ច័យ ដល់ភិក្ខុអ្នកពោល បុគ្គលនោះស្លាប់ទៅ ត្រូវអាបត្តិបារាជិក ។ តែបើបុគ្គលនោះស្តាប់ហើយ តាំងនៅរហូតអស់អាយុ ទើបស្លាប់តាមធម្មតានៃខ្លួន មិនមានអាបត្តិ ។ ភិក្ខុពោលដោយតាំងចិត្តថា បុគ្គលនេះបានស្តាប់សគ្គកថានេះហើយ នឹងធ្វើបុណ្យ បុគ្គលនោះស្តាប់សគ្គកថានោះហើយ អត់ដង្ហើម ធ្វើកាលកិរិយា មិនត្រូវអាបត្តិ ។

[ ២០១ ] ក្នុងការប្រាប់ មានវិនិច្ឆ័យដូច្នេះ ពីរបទថា **បុដ្ឋោ ភណាតិ** សេចក្តីថា ភិក្ខុត្រូវគេសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ បុគ្គលស្លាប់ដូចម្តេច ទើបបានទ្រព្យ ឬនឹងកើតក្នុងស្ថានសួគ៌ ដូច្នេះ ទើបប្រាប់ ។

ក្នុងការប្រៀនប្រដៅ មានវិនិច្ឆ័យដូច្នេះ បទថា **អបុដ្ឋោ** បានដល់ គេមិនបានសួរយ៉ាងនោះ ប្រាប់ខ្លួនឯងនោះឯង ។

[ ២០២ ] សង្កេតកម្ម និងនិមិត្តកម្ម គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងអទិន្នាទានកថា ។

## អនាបត្តិវារកថា

[ ២០៣ ] ព្រះឧបាលិត្ថេរ កាលសម្ដែងប្រភេទរបស់អាបត្តិ ដោយប្រការផ្សេងៗ យ៉ាងនោះហើយ ឥឡូវនេះ កាលនឹងសម្ដែងអនាបត្តិ ទើបពោលពាក្យថា **អនាបត្តិ អសញ្ចិច្ច** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **អសញ្ចិច្ច** បានដល់ មិនបានគិតថា អញនឹងសម្លាប់បុគ្គលនេះ ដោយសេចក្ដីព្យាយាមនេះ ។ ពិតហើយ កាលបុគ្គលដទៃស្លាប់ទៅដោយព្យាយាមដែលខ្លួនមិនបានគិតយ៉ាងនោះ មិនត្រូវអាបត្តិ ។ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់បុគ្គលមិនក្លែង ។

បទថា **អជានន្តស្ស** បានដល់ មិនដឹងថា បុគ្គលនេះ នឹងស្លាប់ដោយសេចក្ដីព្យាយាមនេះ កាលអ្នកដទៃស្លាប់ទៅដោយសេចក្ដីព្យាយាម មិនត្រូវអាបត្តិ ។ ដូចព្រះមានព្រះភាគត្រាស់ទុកក្នុងរឿងចម្អាន់បិណ្ឌបាតលាយដោយថ្នាំពិសថា ម្នាលភិក្ខុ អាបត្តិមិនមានដល់បុគ្គលមិនដឹង ។

បទថា **ន មរណាធិប្បាយស្ស** បានដល់ មិនប្រាថ្នានឹងឲ្យស្លាប់ ។ ពិតហើយ បុគ្គលដទៃស្លាប់ដោយសេចក្ដីព្យាយាមណា កាលបុគ្គលនោះ ត្រូវសម្លាប់ស្លាប់ ដោយសេចក្ដីព្យាយាមនោះ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិន

បំណាចឲ្យស្លាប់ ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អាបត្តិមិនមានដល់ បុគ្គលមិនមានបំណងនឹងឲ្យស្លាប់ ។ ភិក្ខុច្ឆតជាដើម មានន័យដូចពោល ហើយពីមុននោះឯង ។ ឯភិក្ខុទាំងឡាយសម្លាប់គ្នានិងគ្នាជាដើម បញ្ញត្តក្នុង សិក្ខាបទនេះ មិនត្រូវអាបត្តិដល់ភិក្ខុទាំងនោះ ។ តែត្រូវអាបត្តិដល់ភិក្ខុទាំង-ឡាយដ៏សេស មានភិក្ខុពណ្ណនាគុណនៃសេចក្តីស្លាប់ជាដើម ។

## បកិណ្ណកកថា

ក្នុងសមុដ្ឋានជាដើម មានវិនិច្ឆ័យដូច្នេះថា សិក្ខាបទនេះ មានសមុដ្ឋាន ៣ គឺកើតអំពីកាយ និងចិត្ត ១ កើតអំពីវាចា និងចិត្ត ១ កើតអំពីកាយ វាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជា កាយកម្ម វចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ។ ពិតហើយ ព្រះរាជា ទ្រង់ឡើងកាន់ព្រះបន្ទំដ៏មានសិរី សោយសុខក្នុងរាជសម្បត្តិ កាលរាជបុរស ក្រាបទូលថា បពិត្រព្រះសម្មតិទេព ចោរត្រូវនាំមកហើយ ទ្រង់ត្រាស់ទាំង រីករាយថា ចូរសម្លាប់វាចុះ ព្រះរាជានោះ បណ្ឌិតគប្បីជ្រាបថា ត្រាស់ដោយ ព្រះទ័យអាស្រ័យទោមនស្សនោះឯង ។ ព្រះទ័យដែលអាស្រ័យទោមនស្ស នោះ បុថុជ្ជនទាំងឡាយដឹងបានលំបាក ព្រោះលាយឡំដោយសេចក្តីសុខ និងព្រោះមិនជាប់តគ្នា ( ក្នុងវិថីនៃទោមនស្ស ) ដោយប្រការដូច្នេះឯង ។

**បទភាជនីយនៃតតិយបារាជិក ចប់**

# អធិប្បាយ
# វិធីតវត្ថុក្នុងតតិយចាតាជិក

[ ២០៥ ] ក្នុងរឿងជាបឋម ក្នុងគាថានៃវិនីតវត្ថុទាំងឡាយ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ការុញ្ញេន** សេចក្តីថា ភិក្ខុទាំងនោះឃើញសេចក្តីទុក្ខព្រោះជំងឺយ៉ាងខ្លាំងក្លារបស់ភិក្ខុនោះហើយ កើតសេចក្តីករុណាឡើង និងជាអ្នកមានបំណងចង់ឲ្យស្លាប់ តែមិនជ្រាបថា ភិក្ខុនោះមានបំណងចង់ស្លាប់ ទើបបានពណ៌នាគុណសេចក្តីស្លាប់យ៉ាងនេះថា លោកជាអ្នកមានសីល បានធ្វើកុសលទុកហើយ ហេតុអ្វី កាលនឹងស្លាប់ ទើបភ័យខ្លាចទៅវិញ ដែលឈ្មោះថា ស្ថានសួគ៌របស់អ្នកមានសីល ជារបស់ទាក់ទងដោយហេតុត្រឹមតែសេចក្តីស្លាប់ប៉ុណ្ណោះ មិនមែនឬ ភិក្ខុនោះក៏ផ្តាច់អាហារ ព្រោះការពណ៌នា ( គុណនៃសេចក្តីស្លាប់ ) របស់ភិក្ខុទាំងនោះ ហើយក៏ស្លាប់ទៅក្នុងចន្លោះឯង ព្រោះហេតុនោះ ទើបភិក្ខុទាំងនោះត្រូវអាបត្តិ ។ តែព្រះឧបាលិត្ថេរពោលទុកដោយអំណាចវោហារថា ភិក្ខុទាំងនោះបានពណ៌នាគុណនៃសេចក្តីស្លាប់ដោយសេចក្តីករុណា ព្រោះដូច្នោះ ឥឡូវនេះ ភិក្ខុដែលជាបណ្ឌិត ក៏មិនគួរពណ៌នាគុណនៃសេចក្តីស្លាប់យ៉ាងនោះ ដល់ភិក្ខុអ្នកអាពាធ ។ ពិតហើយ បើភិក្ខុអាពាធនោះស្តាប់ការពណ៌នារបស់ភិក្ខុនោះហើយ មរណភាពក្នុងចន្លោះក្នុងកាលអាយុនៅសល់ត្រឹមមួយជួរវារៈនៃជវន ដោយសេចក្តីព្យាយាម មានការអត់អាហារជាដើមសោត ភិក្ខុនោះ ឈ្មោះថា ភិក្ខុនេះឯងសម្លាប់ហើយ ។ តែគួរប្រៀនប្រដៅដោយន័យនេះថា ការកើតឡើងនៃមគ្គ និងផលរបស់អ្នកមានសីលមិនជារបស់គួរអស្ចារ្យឡើយ ព្រោះដូច្នោះ លោកមិនគួរធ្វើការជាប់

ជំពាក់ក្នុងទីកន្លែង មានវិហារជាដើម គួរតាំងសតិចំពោះក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងក្នុងកាយ ធ្វើសេចក្តីមិនប្រមាទក្នុងមនសិការ ។ សូម្បីកាលភិក្ខុពណ៌នាគុណនៃសេចក្តីស្លាប់ហើយ ភិក្ខុណាមិនធ្វើសេចក្តីព្យាយាមណាៗ ព្រោះការពណ៌នានោះ ស្លាប់ទៅតាមធម្មតារបស់ខ្លួនតាមអាយុ និងតាមសន្តតិ ( នៃអាយុ ) ភិក្ខុពណ៌នា ព្រះវិនយធរ មិនគួរកាត់អាបត្តិ ព្រោះសេចក្តីស្លាប់របស់ភិក្ខុនោះជាបច្ច័យដូច្នេះឯង ។

[ ២០៦ ] ក្នុងពាក្យថា **ន ច ភិក្ខវេ អប្បដិវេក្ខិត្វា** ជាដើមនេះ ( មានហើយ ) ក្នុងរឿងទី ២ មានវិនិច្ឆ័យដូច្នេះ សួរថា អាសនៈដូចម្តេច ត្រូវពិចារណា ដូចម្តេច មិនត្រូវពិចារណា ឆ្លើយថា អាសនៈសុទ្ធៗ មិនមានគ្រឿងកម្រាលខាងលើ និងអាសនៈដែលគេក្រាលចំពោះមុខភិក្ខុដែលកំពុងឈរមើល មិនចាំបាច់ពិចារណា គួរអង្គុយបាន ។ សូម្បីលើអាសនៈដែលអ្នកស្រុកគេយកដៃទះៗ ហើយប្រគេនថា សូមនិមន្តអង្គុយលើអាសនៈនេះចុះលោកម្ចាស់ ដូច្នេះ ក៏គួរអង្គុយបាន ។ សូម្បីភិក្ខុច្រើនអង្គមកអង្គុយមុនហើយខាងក្រោយ ទើបឡើងទៅខាងលើ ឬថយចុះមកខាងក្រោម មិនមានកិច្ចដែលត្រូវពិចារណា ។ សូម្បីលើអាសនៈដែលគេយកសំពត់ស្តើងៗ ក្រាលឲ្យមើលឃើញផ្ទៃ ខាងក្រោមបាន មិនមានកិច្ចដែលនឹងត្រូវពិចារណា ។ ឯអាសនៈណា ជារបស់ដែលគេយកសំពត់បាវារ និងសំពត់កោជវៈជាដើមក្រាលទុកជាមុននោះឯង ភិក្ខុគួរយកដៃស្ទាបកំណត់មើលអាសនៈសិន សឹមអង្គុយ ។ តែក្នុងមហាបច្ចរី ពោលថា ក្នុងអាសនៈណាដែលគេយកសំពត់សាដក ដែលក្រាស់ក្រាលទុក ស្នាមជ្រួញរមែងមិនប្រាកដ អាសនៈនោះមិន

ចាំបាច់ពិចារណា ។

[២០៧] ក្នុងរឿងអវ៉ែទ្រ មានវិនិច្ឆ័យដូច្នេះ បទថា **អសញ្ចិច្ចោ** បានដល់បុគ្គលមិនមានចេតនានឹងសម្លាប់ ពិតហើយ ភិក្ខុនោះ មានសេចក្ដីប្រកបក្លាំងក្លាត់ទៅ ព្រោះដូច្នោះ ទើបភិក្ខុក្រាបទូលថា ខ្ញុំព្រះអង្គមិនបានក្លែង ។ រឿងត្បាល់ មានអត្ថជាក់ច្បាស់ហើយ ។

[២០៨] រឿងដំបូង ក្នុងរឿងពួកភិក្ខុចាស់ មានវិនិច្ឆ័យដូច្នេះថា ( ភិក្ខុជាបុត្រ បានពោលនឹងភិក្ខុជាបិតា ) ថា លោកកុំបានធ្វើឲ្យភិក្ខុសង្ឃកើតកង្វល់ ដូច្នេះ ទើបប្រាន ( ភិក្ខុជាបិតា ) ទៅ ។

ក្នុងរឿងទី ២ មានវិនិច្ឆ័យដូច្នេះថា ( ភិក្ខុដែលជាបុត្រត្រូវសព្រហ្មចារី ) ពោលចំអកចំអន់នៅក្នុងកណ្ដាលជំនុំសង្ឃខ្លះ ក្នុងពួកគណៈខ្លះថា បុត្ររបស់ព្រះថេរៈកញ្ចាស់ ( ភិក្ខុនោះ ) ធុញទ្រាន់ដោយពាក្យសម្ដីនោះ ទើបប្រាន ( ភិក្ខុជាបិតា ) ទៅដោយគិតថា លោកឪកញ្ចាស់នេះ ចូរស្លាប់ទៅចុះ ។

ក្នុងរឿងទី ៣ មានវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិថុល្លច្ច័យដល់ភិក្ខុជាបុត្រ ព្រោះញុំាងទុក្ខឲ្យកើតដល់ភិក្ខុជាបិតានោះ ។

[២០៩] ៣ រឿងបន្ទាប់អំពីនោះទៅ មានអត្ថជាក់ច្បាស់ទាំងអស់ហើយ ។

[ ២១០ ] ក្នុងរឿងបិណ្ឌបាតលាយដោយថ្នាំពិស មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអ្នកបំពេញសារាណីយធម៌នោះ ប្រគេនបិណ្ឌបាតចំណែកដ៏ឧត្តមដល់សព្រហ្មចារីទាំងឡាយជាមុន ទើបឆាន់ ។ ព្រោះហេតុនោះ ទើបព្រះឧបាលិត្ថេរពោលថា បានប្រគេនបិណ្ឌបាតដ៏ឧត្តមនោះ ។

បទថា **អគ្គការិកំ** បានដល់ បិណ្ឌបាតដែលបានមកគ្រាដំបូង ធ្វើឲ្យជាចំណែកដ៏ឧត្តម ម្យ៉ាងទៀត អធិប្បាយថា បិណ្ឌបាតដ៏កំពូល គឺដែលប្រណីតៗ ។ ឯកិរិយាដែលធ្វើឲ្យជាចំណែកដ៏ឧត្តម ពោល គឺការឲ្យរបស់ភិក្ខុនោះ បុគ្គលណាមួយមិនអាចប្រគេនបាន ។ ពិតហើយ សូម្បីបិណ្ឌបាត ( តាមប្រក្រតី ) ភិក្ខុក៏បានប្រគេនតាំងអំពីដើមអាសនៈព្រះថេរៈរៀងទៅ ។

ពីរបទថា **តេ ភិក្ខូ** បានដល់ ភិក្ខុទាំងនោះ គឺភិក្ខុឆាន់បិណ្ឌបាតតាំងពីដើមអាសនៈព្រះថេរៈចុះទៅ ។ បានឮថា ភិក្ខុទាំងនោះបានស្លាប់ទាំងអស់គ្រប់អង្គ ។ ពាក្យដ៏សេសក្នុងរឿងនេះ ជាក់ច្បាស់ទាំងអស់ ។ ឯភិក្ខុបានបិណ្ឌបាតដ៏ប្រណីត ដោយគោរពក្នុងត្រកូលពួកមិច្ឆាទិដ្ឋិ ដែលមិនមានសទ្ធា មិនទាន់បានពិចារណា ខ្លួនឯងមិនគួរឆាន់ផង ទាំងមិនគួរប្រគេនដល់ភិក្ខុដទៃផង ។ ភិក្ខុបានភត្តាហារ ឬរបស់គួរទំពាណាមួយដែលជារបស់កន្ទួលរាត្រីអំពីត្រកូលមិច្ឆាទិដ្ឋិនោះ ភត្តាហារជាដើមនោះមិនគួរឆាន់ ។ ព្រោះថា ត្រកូលទាំងនោះរមែងប្រគេនវត្ថុដែលគេមិនបានយកអ្វីគ្រប ដែលមានពស់ និងខ្ទួយជាដើមដេកសន្កត់ ជារបស់ដែលត្រូវចោលជាធម្មតា ។ ភិក្ខុមិនគួរទទួលបិណ្ឌបាត ដែលប្រឡាក់ដោយវត្ថុ មានគ្រឿងក្រអូប និងរមៀតជាដើមអំពីត្រកូលមិច្ឆាទិដ្ឋិនោះ ។ ពិតហើយ ត្រកូលមិច្ឆាទិដ្ឋិទាំងនោះ រមែងសម្គាល់នូវភត្តាហារដែលខ្លួនដុសជូត មានរោគក្នុងរាងកាយ ហើយរក្សាទុកថា ជារបស់គួរប្រគេន ដូច្នេះ ។

ក្នុងរឿងសាកល្បងថ្នាំពិស មានវិនិច្ឆ័យដូច្នេះថា ភិក្ខុកាលសាកល្បង

ទើបសាកល្បង ២ យ៉ាង ( សាកល្បងថ្នាំពិស និងបុគ្គល ) គឺសាកល្បងថ្នាំពិសដោយគិតថា ថ្នាំពិសមួយនាឡិប៉ុណ្ណោះ អាចសម្លាប់បុគ្គលនេះស្លាប់ឬទេហ្ន៎ ឬសាកល្បងបុគ្គល ដោយគិតថា បុគ្គលនេះ ផឹកថ្នាំពិសប៉ុណ្ណោះហើយ គប្បីស្លាប់ឬទេហ្ន៎ កាលភិក្ខុឲ្យថ្នាំពិស ដោយបំណាងនឹងសាកល្បងទាំងពីរយ៉ាង បុគ្គលនោះស្លាប់ ឬមិនស្លាប់ក៏ដោយ ត្រូវអាបត្តិថុល្លច្ច័យ ។ តែកាលភិក្ខុឲ្យថ្នាំពិស ដោយគិតយ៉ាងនេះថា ថ្នាំពិសប៉ុណ្ណោះ ចូរសម្លាប់បុគ្គលនេះឲ្យស្លាប់ ឬថា បុគ្គលម្នាក់នេះ ផឹកថ្នាំពិសប៉ុណ្ណោះហើយ ចូរស្លាប់ដូច្នេះ បើបុគ្គលនោះស្លាប់ ត្រូវអាបត្តិបារាជិក បើមិនស្លាប់ ត្រូវអាបត្តិថុល្លច្ច័យ ។

[ ២១១ ] រឿងភិក្ខុហុចថ្ម ៣ រឿង បន្ទាប់អំពីរឿងសាកល្បងថ្នាំពិសនេះទៅ និងរឿងកឥដ្ឋ រឿងហុចកាំបិតព្រា និងរឿងហុចបង្គន់ ៣ រឿង មានអត្ថរាក់ទាំងអស់ ។ ឯសេចក្តីវិសេសនៃអាបត្តិ និងអនាបត្តិនេះ មិនមែនមានដោយអំណាចនៃដុំថ្មជាដើមតែម្យ៉ាងប៉ុណ្ណោះឡើយ ។ តែរមែងមានដោយអំណាចនៃវត្ថុ មានដំបង ញញួរ ពន្លាក និងត្រល់ជាដើមក៏ដូចគ្នា ព្រោះដូច្នោះ វត្ថុ មានដំបងជាដើមនោះ សូម្បីមិនមានមកក្នុងព្រះបាលី ក៏គប្បីជ្រាបដោយ ន័យដែលមកហើយនោះឯង ។

ក្នុងរឿងភិក្ខុចងរទ្ទា មានវិនិច្ឆ័យដូច្នេះថា រានលើអាកាស ដែលជារបស់ពួកជនចងទុក ដើម្បីប្រយោជន៍ដល់ការងារ មានសេតកម្ម ( ការលាបពណ៌ស ) មាលាកម្ម ( គំនូរភ្ញីផ្កា ) និងលតាកម្ម ( គំនូរភ្ញីវល្លិ៍ ) ជាដើម

ហៅថា រន្ធ ។ ក្នុងរឿងចងរន្ធនោះ ភិក្ខុមានបំណងឲ្យស្លាប់ ពោលសំដៅយកទីកន្លែងដែលភិក្ខុឈរ ហើយគប្បីដាច់ធ្លាក់ចុះចំជង្គត់ ឬគប្បីស្លាប់ទៅក្នុងអណ្តូង និងជ្រោះជាដើមថា អាវុសោ ចូរលោកឈរត្រង់នេះ ។

បណ្តាទីកន្លែងទាំងនេះ ភិក្ខុអង្គខ្លះរមែងកំណត់ទីខាងលើទុក ដោយគិតថា បុគ្គលនោះនឹងធ្លាក់អំពីទីនេះស្លាប់ អង្គខ្លះរមែងកំណត់ទីខាងក្រោមទុក ដោយគិតថា បុគ្គលនោះ នឹងភ្លាត់ធ្លាក់ក្នុងទីនេះ អង្គខ្លះរមែងកំណត់ទីទាំងពីរកន្លែង ដោយគិតថា បុគ្គលនោះនឹងភ្លាត់ធ្លាក់អំពីទីនេះ ហើយស្លាប់ក្នុងទីនេះ បណ្តាស្ថានទីដែលភិក្ខុកំណត់ទុកនោះ បុគ្គលណាមិនភ្លាត់ធ្លាក់ទៅអំពីទីដែលភិក្ខុកំណត់ទុកខាងលើ ភ្លាត់ធ្លាក់ទៅអំពីទីដទៃក្តី មិនភ្លាត់ធ្លាក់ទៅក្នុងទីដែលភិក្ខុ កំណត់ទុកខាងក្រោម ភ្លាត់ធ្លាក់ទៅក្នុងទីដទៃក្តី ភ្លាត់ធ្លាក់ទៅខុសក្នុងបណ្តាទីកំណត់ទុកទាំងពីរកន្លែង ណាមួយក្តី កាលបុគ្គលនោះស្លាប់ ឈ្មោះថា មិនត្រូវអាបត្តិ ព្រោះមានការខុសសង្កេត ។

[ ២១២ ] សូម្បីក្នុងរឿងប្រក់វិហារ ក៏មានន័យនេះ ។

[ ២១៣ ] ក្នុងរឿងភិក្ខុអផ្សុក មានវិនិច្ឆ័យដូច្នេះ បានឮថា ភិក្ខុនោះឃើញការផ្សាយឡើង នៃអកុសលវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើម កាលមិនអាចហាមឃាត់បាន និងមិនត្រេកអរក្នុងសាសនា ទើបជាបុគ្គលបែរមុខទៅដើម្បីទៅជាគ្រហស្ថ តែក្រោយមក រឭកបានថា អញនឹងស្លាប់ទាំងដែលអញមិនទាន់វិនាសសីល ។ គ្រានោះ ទើបភិក្ខុនោះឡើងភ្នំ ហើយលោតចុះទៅក្នុងជ្រោះ ជាន់ជាងត្បាញផែងម្នាក់ស្លាប់ ។

បទថា **វិលីវការំ** ប្រែថា ជាឥត្បាញផែនឫស្សី ។

ស្រីនបទថា **ន ច ភិក្ខវេ អត្តានំ ចាតេតព្វំ** សេចក្តីថា ខ្លួនដែល ភិក្ខុមិនគប្បីឲ្យធ្លាក់ទៅ ។ បទថា **អត្តានំ** នោះ ព្រះដ៏មានព្រះភាគត្រាស់ ដោយផ្លាស់ប្តូរវិភត្តិ ។ តែក្នុងអធិការពោលដោយការញ៉ាំងខ្លួនឲ្យធ្លាក់ទៅនេះ ភិក្ខុមិនគួរញ៉ាំងខ្លួនឲ្យធ្លាក់ទៅតែម្យ៉ាងក៏ទេ សូម្បីបុគ្គលដទៃក៏មិនគួរសម្លាប់ ដោយសេចក្តីព្យាយាមឯណាមួយ ដោយការអត់អាហារ ។ ពិតហើយ ភិក្ខុ ណា សូម្បីអាពាធ មានបំណងនឹងស្លាប់ កាលភេសជ្ជៈ និងអ្នកឧបដ្ឋាកមាន ក៏លះបង់អាហារចោល ភិក្ខុនោះត្រូវអាបត្តិទុក្កដនោះឯង ។ ឯភិក្ខុណាឈឺ ធ្ងន់ មានគ្រឿងជាប់ជំពាក់នៅយូរ ( ត្រូវរក្សាព្យាបាលយូរ ) ភិក្ខុទាំងឡាយ ដែលឧបដ្ឋាករមែងលំបាក ខ្ពើមរអើម ធុញទ្រាន់ ដោយគិតថា អង្កាល់ណា ហ្ន៎ ពួកយើងនឹងផុតអំពីភិក្ខុអាពាធ ។ បើភិក្ខុនោះគិតថា អត្តភាពនេះ ទោះ ត្រូវទំនុកបម្រុង ក៏មិនតាំងនៅ ឯភិក្ខុទាំងឡាយក៏លំបាក ហើយអត់អាហារ មិនបរិភោគភេសជ្ជៈ ការដែលភិក្ខុអត់អាហារនោះ រមែងគួរ ។ ចំណែកភិក្ខុ ណាគិតថា រោគនេះក្លៀវក្លា អាយុសង្ខារ រមែងមិនតាំងនៅ ហើយការ សម្រេចគុណវិសេសរបស់អញនេះ រមែងប្រាកដ ដូចជានៅក្នុងកណ្តាប់ដៃ ហើយ ទើបផ្តាច់បង់នូវអាហារ ការដែលភិក្ខុផ្តាច់បង់នូវអាហារនោះ រមែងគួរ ដូចគ្នា ។ សូម្បីភិក្ខុមិនមានអាពាធ កើតសេចក្តីសង្វេគឡើងហើយ ផ្តាច់បង់ នូវអាហារ ដោយបរិកម្មកម្មដ្ឋាន ព្រោះរឭកបានថា ឈ្មោះថា ការស្វែងរក អាហារ ជាទីឃឺតយូរ អញនឹងតាមប្រកបកម្មដ្ឋានប៉ុណ្ណោះ ដូច្នេះ ការដែល

ភិក្ខុផ្តាច់បង់នូវអាហារនោះ រមែងគួរ ភិក្ខុព្យាករការសម្រេចគុណវិសេស ហើយផ្តាច់បង់នូវអាហារ សេចក្តីនោះ រមែងមិនគួរ ។ តែបើប្រាប់ដល់លជ្ជីភិក្ខុទាំងឡាយដែលជាសភាគគ្នា គួរ ។

ក្នុងរឿងដុំថ្ម មានវិនិច្ឆ័យដូច្នេះ បទថា **ឧស្សាយ** ប្រែថា ដោយការលេង គឺដោយការសើច អធិប្បាយថា ដោយការលេងផ្តេសផ្តាស ។ ដែលឈ្មោះថា **សិលា** បានដល់ ដុំថ្ម ។ មិនមែនតែដុំថ្មប៉ុណ្ណោះទេ សូម្បីកំណាត់ឈើ ឬដុំឥដ្ឋណាមួយដទៃ ភិក្ខុប្រើដៃ ឬគ្រឿងយន្តប្រមៀល រមែងមិនគួរ ។ ពួកភិក្ខុនាំគ្នាសើច សើចសប្បាយ ប្រមៀលក្តី លើកឡើងក្តី នូវវត្ថុ មានដុំថ្មជាដើម ដើម្បីប្រយោជន៍ដល់ព្រះចេតិយជាដើម ចាត់ជាសម័យធ្វើការងារ ព្រោះហេតុនោះ កិច្ច មានការប្រមៀលជាដើម ទើបគួរ ពួកភិក្ខុកាលធ្វើនវកម្មដទៃ ដូច្នេះ ឬទឹងទាញវត្ថុ លើកដើមឈើ ឬកំណាត់ឈើ សម្រាប់ទាញឡើង ហើយប្រមៀលទៅ សេចក្តីនោះរមែងគួរ ។ ក្នុងវេលាធ្វើភត្តកិច្ចជាដើម ភិក្ខុគ្រវែងកំណាត់ឈើ ឬបំណែកអំបែងទៅ ដើម្បីដេញក្អែកនិងពួកក្អែកឲ្យគេចទៅ សេចក្តីនោះ រមែងគួរ ។

[ ២១៤ ] រឿងទាំងឡាយ មានរឿងត្នងមានអត្ថជាក់ច្បាស់ទាំងអស់ហើយ ។ ម្យ៉ាងទៀត ក្នុងវិស័យនៃរឿងត្នងខ្ទងជាដើមនេះ ភិក្ខុមិនគួរធ្វើគិលានុបដ្ឋាក ដោយគិតថា អញមានសេចក្តីរង្កៀសគ្រប់យ៉ាង គប្បីចូលទៅកំណត់កម្លាំង ឬមិនមានកម្លាំង ការពេញចិត្ត និងការសប្បាយរបស់ភិក្ខុអាពាធ ហើយធ្វើដោយភាពជាអ្នកប្រាថ្នានូវប្រយោជន៍ ។

[ ២១៥ ] ក្នុងរឿងស្រីមានគភ៌នឹងសហាយ មានវិនិច្ឆ័យដូច្នេះ បទថា **បវុត្ថបតិកា** ប្រែថា ស្រីដែលមានប្តីបែកទៅយូរហើយ ។ បទថា **គព្ភធាតនំ** បានដល់ ភេសជ្ជៈ ល្មមដែលស្ត្រីបរិភោគហើយ ជាហេតុឲ្យគភ៌ធ្លាក់ទៅ ។ រឿងស្រីរួមប្តីពីរនាក់ មានអត្ថជាក់ច្បាស់ហើយនោះឯង ។

ក្នុងរឿងស្ត្រីប្របាច់ពោះ មានវិនិច្ឆ័យដូច្នេះថា ស្រីមានគភ៌ កាលភិក្ខុប្រាប់ថា នាងចូរប្របាច់ឲ្យធ្លាក់ទៅឯងចុះ បែរទៅជាឲ្យអ្នកដទៃប្របាច់ធ្វើឲ្យធ្លាក់ទៅ ជាការខុសសង្កេត បើភិក្ខុប្រាប់ថា ចូរពឹងឲ្យអ្នកដទៃប្របាច់ធ្វើឲ្យធ្លាក់ចុះ តែនាងប្របាច់ធ្វើឲ្យធ្លាក់ទៅខ្លួនឯង នេះជាការខុសសង្កេតដូចគ្នា ។ ឈ្មោះថាបរិយាយក្នុងមនុស្សវិគ្គហៈ រមែងមិនមាន ព្រោះហេតុនោះ កាលភិក្ខុពោលថា ឈ្មោះថា គភ៌ ត្រូវប្របាច់ហើយ នឹងធ្លាក់ទៅឯង ស្រីមានគភ៌នោះ ប្របាច់ឯង ឬពឹងឲ្យអ្នកដទៃប្របាច់ ឲ្យធ្លាក់ទៅក៏ដោយ មិនខុសសង្កេត ត្រូវអាបត្តិបារាជិកនោះឯង ។ ក្នុងរឿងកម្តៅគភ៌ឲ្យក្តៅ ក៏មានន័យដូចគ្នា ។

ក្នុងរឿងស្រីអារ មានវិនិច្ឆ័យដូច្នេះ ស្រីដែលមិនមានគភ៌ ឈ្មោះថាស្រីអារ ។ ធម្មតាស្រីមិនតាំងគភ៌ រមែងមិនមាន តែគភ៌ដែលស្រីណាតាំងហើយ មិនតាំងនៅ សេចក្តីនេះ លោកពោលសំដៅយកស្រីនោះ ។ បានឮថា ក្នុងគ្រាមានរដូវ ស្រីគ្រប់ជំពូក រមែងតាំងគភ៌ តែអកុសលវិបាកមកជួបប្រសព្វដល់ពួកសត្វដែលកើតក្នុងផ្ទៃរបស់ស្រី ដែលហៅថា ស្រីអារនេះ ។ សត្វទាំងនោះបដិសន្ធិមកដោយកុសលវិបាកតិចតួច ត្រូវអកុសលវិបាកគ្រប

សន្តតិ ទើបវិនាសទៅ ។ ពិតហើយ ក្នុងខណៈបដិសន្ធិថ្មីៗ នោះឯង គភ៌តាំងនៅមិនបានដោយអាការ ២ យ៉ាង គឺដោយខ្យល់ និងសត្វល្អិតតូចៗ ព្រោះកម្មានុភាពខ្យល់បក់ ( គភ៌ ) ឲ្យស្ងួតហើយ ធ្វើឲ្យអន្តរធានទៅ ។ សត្វតូចៗ ទាំងឡាយបឺតជញ្ជក់ ( គភ៌ ) ឲ្យអន្តរធានទៅ ។ តែគ្រូប្រកបថ្នាំដើម្បីកម្ចាត់ខ្យល់ និងពួកសត្វល្អិតនោះហើយ គភ៌គប្បីតាំងនៅបាន ។ ភិក្ខុនោះមិនបានរៀបចំភេសជ្ជៈឲ្យល្មមប្រមាណនោះ បានឲ្យភេសជ្ជៈដែលខ្លាំងក្លាប្រមាណដទៃ ។ នាងបានស្លាប់ទៅ ព្រោះភេសជ្ជៈប្រមាណនោះ ព្រះមានព្រះភាគទ្រង់បានបញ្ញត្តអាបត្តិទុក្កដ ព្រោះភិក្ខុរៀបចំភេសជ្ជៈ ។ សូម្បីក្នុងរឿងទី ២ ក៏មានន័យនោះដូចគ្នា ។

## ភិក្ខុមិនគួរធ្វើថ្នាំដល់ជនដទៃ គួរធ្វើដល់សហធម្មិកទាំង ៥

ព្រោះដូច្នោះ ភិក្ខុមិនគួរធ្វើភេសជ្ជៈដល់អ្នកដទៃដែលមកហើយ កាលធ្វើត្រូវអាបត្តិទុក្កដ ។ តែគួរធ្វើឲ្យដល់សហធម្មិកទាំង ៥ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ។ ពិតហើយ សហធម្មិកទាំង ៥ នោះជាអ្នកមានសីល មានសទ្ធា និងបញ្ញាស្មើគ្នា ទាំងប្រកបក្នុងត្រៃសិក្ខាផង ភិក្ខុមិនធ្វើភេសជ្ជៈឲ្យមិនបាន កាលនឹងធ្វើ បើរបស់នៃសហធម្មិកទាំងនោះមាន គប្បីកាន់យករបស់នៃសហធម្មិកទាំងនោះផ្សំឲ្យ បើមិនមាន គួរយករបស់ខ្លួនឯងធ្វើឲ្យ បើរបស់ខ្លួនមិនមាន គប្បីស្វែងរកដោយភិក្ខាចារវត្ត ឬអំពីទីនៃញាតិ និងអ្នកបវារណា ( របស់ខ្លួន ) ។ បើមិនបាន គួរនាំរបស់មកធ្វើឲ្យដោយមិនធ្វើវិញ្ញត្តិ ( គឺសូមក្នុងទីដែលគេមិនបានបវារណា ) ។ ដើម្បី

ប្រយោជន៍ដល់អ្នកជំងឺ ។ គួរធ្វើថ្នាំឲ្យដល់បុគ្គល ៥ ពួកដទៃទៀត គឺមាតា ១ បិតា ១ អ្នកទំនុកបម្រុងមាតាបិតា ១ វេយ្យាវច្ចៈរបស់ខ្លួន ១ បណ្ឌុ-បលាសជន ១ ។ បុគ្គលដែលឈ្មោះថា បណ្ឌុបលាស បានដល់ បុគ្គលដែលសម្លឹងបព្វជ្ជា ស្ថិតនៅក្នុងវិហារអស់វេលាដែលនៅត្រៀមបាត្រ និងចីវរ បណ្ដាជន ៥ ពួកនោះ បើមាតា និងបិតាជាធំ មិនសង្ឃឹមការតបស្នងសោត មិនធ្វើឲ្យក៏គួរ ។ តែបើលោកទាំងពីរតាំងនៅក្នុងរាជសម្បត្តិ ទន្ទឹងការតបស្នង មិនធ្វើ មិនគួរ ។ កាលលោកទាំងពីរទន្ទឹងភេសជ្ជៈ គួរឲ្យភេសជ្ជៈ បើលោកទាំងពីរមិនដឹងវិធីផ្សំថ្នាំ គួរផ្សំថ្នាំឲ្យ ។ គួរស្វែងរកភេសជ្ជៈ ដើម្បីប្រយោជន៍ដល់ជន ៥ ពួក មានមាតាបិតាជាដើម ដោយន័យដូចពោលហើយ ក្នុងសហធម្មិកនោះឯង ។ បើភិក្ខុនាំមាតាមកប្រណិប័តន៍ក្នុងវិហារ កុំចាប់ពាល់ គប្បីបរិកម្មគ្រប់យ៉ាង គប្បីឲ្យរបស់ទំពា របស់បរិភោគដោយដៃខ្លួនឯង ចំណែកបិតា គប្បីទំនុកបម្រុងដោយកិច្ចទាំងឡាយ មានការផ្ងូតទឹកឲ្យ និងការគក់ប្រេបាច់ជាដើមដោយដៃខ្លួនឯង ដូចជាសាមណេរដូច្នោះ ។ ជនទាំងឡាយណា រមែងទំនុកបម្រុង ផ្គត់ផ្គង់មាតា និងបិតា ភិក្ខុគួរធ្វើភេសជ្ជៈដល់ជនទាំងឡាយនោះ យ៉ាងនោះដូចគ្នា ។ បុគ្គលដែលឈ្មោះថាវេយ្យាវច្ចៈ បានដល់ អ្នកទទួលតម្លៃហើយ កាប់ឧសក្នុងព្រៃ ឬធ្វើការងារណាមួយដទៃ ។ កាលរោគកើតឡើងដល់បុគ្គលនោះ ភិក្ខុគួរធ្វើភេសជ្ជៈឲ្យ ទម្រាំពួកញាតិប្រទះឃើញ ។ ចំណែកបុគ្គលណា ដោយគ្រាន់តែអាស្រ័យភិក្ខុធ្វើការងារគ្រប់យ៉ាង ភិក្ខុគួរធ្វើភេសជ្ជៈឲ្យដល់ជននោះដូចគ្នា ។ សូម្បីក្នុងបណ្ឌុបលាស

ក៏គួរបដិបត្តិដូចក្នុងសាមណេរ ដូច្នោះ ។

## ភិក្ខុគួរធ្វើថ្នាំឱ្យបុគ្គល ១០ ពួកដទៃទៀត

ភិក្ខុគួរធ្វើថ្នាំឲ្យដល់ជន ១០ ពួកដទៃទៀត គឺបងប្រុស ១ ប្អូនប្រុស ១ បងស្រី ១ ប្អូនស្រី ១ មីង ( ប្អូនស្រីរបស់ម្តាយ ) ១ អ៊ំស្រី ( បងស្រីរបស់ម្តាយ និងឪពុក ) ១ ឪពុកមា ( ប្អូនប្រុសរបស់ឪពុក ) ១ អ៊ំប្រុស ( បងប្រុសរបស់ម្តាយ និងឪពុក ) ១ មីង ( ប្អូនស្រីរបស់ឪពុក ) ១ ឪពុកមា ( ប្អូនប្រុសរបស់ម្តាយ ) ១ ។ កាលនឹងធ្វើឲ្យដល់ជន មានបងប្រុសជាដើមទាំងអស់នោះ គួរយកភេសជ្ជៈដែលជារបស់នៃជនទាំងនោះឯងផ្សំឲ្យតែម្យ៉ាង តែបើរបស់នៃជនទាំងនោះមិនគ្រប់គ្រាន់ ហើយជនទាំងនោះក៏សូមថា បពិត្រលោកម្ចាស់ មេត្តាឲ្យពួកខ្ញុំចុះ ពួកខ្ញុំនឹងសងដល់លោកម្ចាស់ គួរឲ្យជារបស់ខ្ចី សូម្បីពួកជនទាំងនោះមិនសូម ភិក្ខុគួរពោលថា អាត្មាមានភេសជ្ជៈ ពួកអ្នកកាន់យកជារបស់ខ្ចីចុះ ឬគួរធ្វើការចងចិត្តទុកថា របស់នៃជនទាំងនោះនឹងមានក្នុងកាលណា បុគ្គលនោះ នឹងឲ្យក្នុងកាលនោះ ដូច្នេះហើយគប្បីឲ្យទៅ ។ បើបុគ្គលនោះសង គួរទទួលយក បើមិនសង មិនគួរទារ ។ វៀរញាតិទាំង ១០ ពួកនោះចេញ មិនគួរឲ្យភេសជ្ជៈដល់ជនដទៃឡើយ ។ កាលភិក្ខុប្រើឲ្យញាតិនាំចតុប្បច្ច័យមកដរាប រហូតដល់ ៧ ជួរត្រកូល ដោយបន្តៗ គ្នាមក នៃកូនរបស់ញាតិ ១០ ពួក មានបងប្រុសជាដើមនោះ មិនជាការធ្វើវិញ្ញត្តិ កាលធ្វើភេសជ្ជៈ ( ដល់ជនទាំងនោះ ) មិនជាវេជ្ជកម្ម ឬមិនត្រូវអាបត្តិ ព្រោះកុលទូសកៈ ។ បើបងថ្លៃស្រី ប្អូនថ្លៃស្រី ឬ

បងថ្លៃប្រុស ប្អូនថ្លៃប្រុសមានជំងឺ បើបុគ្គលនោះជាញាតិនឹងធ្វើភេសជ្ជៈដល់ញាតិទាំងនោះក៏គួរ បើមិនមែនញាតិ គប្បីធ្វើឲ្យដល់បងប្រុស និងបងស្រីដោយប្រាប់ថា ចូរឲ្យក្នុងទីបដិបត្តិរបស់ពួកអ្នកចុះ ។ម្យ៉ាងទៀត គប្បីធ្វើឲ្យដល់បុត្ររបស់បុគ្គលទាំងនោះ ដោយប្រាប់ថា ចូរឲ្យដល់ម្ដាយ និងឪពុកនៃពួកឯងចុះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងពួងដោយឧបាយនេះ ។ ភិក្ខុកាលនឹងប្រើ សាមណេរទាំងឡាយឲ្យនាំភេសជ្ជៈមកអំពីព្រៃ ដើម្បីប្រយោជន៍ដល់បងថ្លៃស្រី ប្អូនថ្លៃស្រីជាដើមនោះ គួរឲ្យពួកសាមណេរដែលជាញាតិនាំមក ឬគប្បីឲ្យនាំមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយទើបឲ្យទៅ ។ សូម្បីពួកសាមណេរ ដែលមិនមែនញាតិទាំងនោះ ក៏គួរនាំមកដោយមាតិកាវត្តថា ពួកយើងនាំមក ប្រគេនព្រះឧបជ្ឈាយ៍ ។ ញោមស្រី និងញោមប្រុសរបស់ព្រះឧបជ្ឈាយ៍ មានជំងឺ មកកាន់វិហារ តែព្រះឧបជ្ឈាយ៍ចៀសចេញទៅកាន់ទិស ។ សទ្ធិវិហារិកគួរឲ្យភេសជ្ជៈ ដែលជារបស់ព្រះឧបជ្ឈាយ៍ ។ បើមិនមាន គួរបរិច្ចាគភេសជ្ជៈរបស់ខ្លួន ប្រគេនព្រះឧបជ្ឈាយ៍ឲ្យទៅ ។ បើរបស់ខ្លួនមិនមាន គួរស្វែងរក ធ្វើឲ្យជារបស់ព្រះឧបជ្ឈាយ៍ ហើយឲ្យទៅ ដោយន័យដូចពោលហើយ ។ ក្នុងញោមស្រី និងញោមប្រុសរបស់សទ្ធិវិហារិកព្រះឧបជ្ឈាយ៍ក៏គួរបដិបត្តិយ៉ាងនោះដូចគ្នាដែរ ។ ក្នុងអាចារ្យ និងអន្តេវាសិកក៏មានន័យដូច្នេះ ។

## ភិក្ខុគួរធ្វើថ្នាំឲ្យដល់បុគ្គល ៦ ពួក

បុគ្គលដទៃណា គឺភ្ញៀវ ១ ចោរ ១ អ្នកចាញ់ចម្បាំង ១ ឥស្សរជន ១

បុគ្គលដែលពួកញាតិលះបង់ ១ បុគ្គលត្រៀមនឹងទៅ ១ ដែលមានជំងឺចូលទៅកាន់វិហារ ។ ភិក្ខុដែលមិនសង្ឃឹមផលតបស្នង គួរធ្វើភេសជ្ជៈដល់មនុស្សទាំងអស់នោះ ។ ត្រកូលដែលមានសទ្ធា ទំនុកបម្រុងដោយបច្ច័យ ៤ រមែងតាំងនៅក្នុងឋានៈជាមាតា និងបិតារបស់ភិក្ខុសង្ឃ ។ បើក្នុងត្រកូលនោះ មានបុគ្គលខ្លះកើតជំងឺ ជនទាំងឡាយសូមដើម្បីប្រយោជន៍ដល់អ្នកជំងឺនោះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ធ្វើភេសជ្ជៈឲ្យដោយសេចក្ដីស្និទ្ធស្នាលចុះ មិនគួរឲ្យ ទាំងមិនគួរធ្វើឡើយ ។ បើពួកបុគ្គលនោះ ដឹងរបស់ដែលគួរសាកសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ គេដាក់ភេសជ្ជៈអ្វីដល់រោគឈ្មោះនោះ ភិក្ខុទោះឆ្លើយថា គេយករបស់នេះ និងរបស់នេះធ្វើ ( ភេសជ្ជៈ ) ដូច្នេះក៏គួរ ។ ភិក្ខុត្រូវគ្រហស្ថសាកសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ ម្ដាយរបស់ខ្ញុំមានជំងឺ សូមលោកម្ចាស់មេត្តាប្រាប់ថ្នាំផងចុះ ដូច្នេះ មិនគួរប្រាប់ឡើយ ។ តែគួរសន្ទនានូវពាក្យដល់គ្នានិងគ្នាថា អាវុសោ ក្នុងរោគប្រភេទនេះ របស់ភិក្ខុឈ្មោះនោះ គេផ្សំភេសជ្ជៈអ្វីព្យាបាល ភិក្ខុទាំងឡាយប្រាប់ថា គេយករបស់នេះ និងរបស់នេះផ្សំភេសជ្ជៈ លោកម្ចាស់ ចំណែកអ្នកស្រុកស្ដាប់ពាក្យសន្ទនានោះហើយ រមែងផ្សំថ្នាំដល់ម្ដាយក្នុងសេចក្ដីដែលភិក្ខុសន្ទនាគ្នានោះ រមែងគួរ ។

## រឿង ព្រះមហាបទុមត្ថេរ

បានឮថា ព្រះមហាបទុមត្ថេរ កាលព្រះទេវីរបស់ព្រះបាទវសភៈប្រឈួនព្រះរោគាឡើង ក៏ត្រូវនាងស្នំម្នាក់មកសាកសួរ លោកក៏មិនពោលថា មិនដឹង

បានសន្ទនានឹងពួកភិក្ខុ ដូចដែលពោលមកហើយនោះឯង ។ ពួករាជបរិវារស្តាប់ពាក្យសន្ទនានោះហើយ បានផ្សំភេសជ្ជៈថ្វាយដល់ព្រះទេវីអង្គនោះ ។ ហើយកាលព្រះរោគជាសះស្បើយហើយ រាជបរិវារបានដាក់ភេសជ្ជៈឲ្យពេញប្រអប់ មួយអន្ទើដោយត្រៃចីវរ និងកហាបណៈ ៣០០ នាំទៅទុកទៀបបាទារបស់ព្រះថេរៈ ហើយប្រាប់ថា បពិត្រលោកម្ចាស់ មេត្តាធ្វើការបូជាដោយផ្កាចុះ ។ ព្រះថេរៈគិតថា នេះជាចំណែករបស់អាចារ្យ ហើយឲ្យវេយ្យាវច្ចករទទួលទុកដាក់ ដោយអំណាចជារបស់កប្បិយៈ បានធ្វើការបូជាដោយផ្កាហើយ ភិក្ខុគួរបដិបត្តិក្នុងភេសជ្ជៈយ៉ាងនេះជាបឋម ។

## អំពីព្រះបរិត្ត

ក្នុងព្រះបរិត្ត មានវិនិច្ឆ័យដូច្នេះថា ភិក្ខុត្រូវអ្នកស្រុកអារាធនាថា សូមធ្វើព្រះបរិត្តដល់អ្នកជំងឺចុះលោកម្ចាស់ ដូច្នេះ មិនគួរធ្វើឡើយ តែបើគេអារាធនាថា សូមសូធ្យចុះ គួរធ្វើ ។ បើភិក្ខុនោះមានសេចក្តីត្រិះរិះថា ធម្មតាមនុស្សទាំងឡាយ រមែងមិនដឹង កាលអញមិនធ្វើ នឹងជាអ្នកក្តៅក្រហាយដូច្នេះ ក៏គួរធ្វើ ។ ចំណែកភិក្ខុត្រូវអារាធនាថា សូមធ្វើទឹកព្រះបរិត្ត អំបោះព្រះបរិត្តឲ្យចុះ ដូច្នេះ គួរយកដៃ ( របស់ខ្លួន ) កូរទឹក ស្ទាបអង្អែលសរសៃអំបោះរបស់មនុស្សទាំងនោះឯងឲ្យទៅ ។ បើភិក្ខុឲ្យទឹកអំពីវិហារ ឬសរសៃអំបោះ ដែលជារបស់ខ្លួន ត្រូវអាបត្តិទុក្កដ ។ ពួកអ្នកស្រុកអង្គុយកាន់ទឹកនិងសរសៃអំបោះ ពោលថា សូមនិមន្តសូធ្យព្រះបរិត្តដូច្នេះ គួរធ្វើ បើបុគ្គលទាំងនោះមិនដឹង ភិក្ខុគួរប្រាប់ ។ ពួកអ្នកស្រុកប្រួចទឹកទក្ខិណោទកចុះ និងដាក់

សរសេរអំពោះទុកទៀបជើងទាំងឡាយរបស់ពួកភិក្ខុ ដែលអង្គុយហើយ ក៏ទៅដោយប្រាប់ថា សូមនិមន្តធ្វើព្រះបរិត្ត សូត្រព្រះបរិត្តចុះ ដូច្នេះ ភិក្ខុមិនគប្បីដកជើងចេញ ព្រោះថា ពួកអ្នកស្រុកនឹងមានសេចក្តីក្តៅក្រហាយ ពួកអ្នកស្រុកបញ្ជូនមនុស្សទៅកាន់វិហារដើម្បីប្រយោជន៍ដល់អ្នកជំងឺ ខាងក្នុងស្រុកដោយប្រាប់ថា សូមភិក្ខុទាំងឡាយ មេត្តាសូត្រព្រះបរិត្ត ដូច្នេះ ភិក្ខុសូត្រគួរ ។ បើរោគ ឬចង្រៃកើតឡើង ក្នុងព្រះរាជមន្ទីរជាដើម ខាងក្នុងស្រុកឥស្សរជន មានក្សត្រជាដើមប្រាប់ឲ្យអារាធនាភិក្ខុមកហើយ និមន្តឲ្យសូត្រ ( ព្រះបរិត្តជាដើម ) ។ ភិក្ខុគប្បីសូត្រព្រះសូត្រទាំងឡាយ មានអាដានាដិយសូត្រជាដើម ។ កាលពួកអ្នកស្រុកបញ្ជូនមនុស្សទៅនិមន្តថា សូមភិក្ខុទាំងឡាយមកឲ្យសិក្ខាបទ សម្តែងធម៌ដល់អ្នកជំងឺចុះ ឬថា ចូរមកឲ្យសិក្ខាបទ សម្តែងធម៌ឯព្រះរាជវាំង ឬត្រង់លំនៅរបស់អមាត្យចុះ ដូច្នេះ ភិក្ខុគួរទៅឲ្យសិក្ខាបទ គួរពោលធម៌ ។ ពួកអ្នកស្រុកនិមន្តថា សូមភិក្ខុទាំងឡាយ មកដើម្បីជាបរិវារ ( សម្ភាញ់ ) របស់មនុស្សស្លាប់ មិនគួរទៅ ។ ភិក្ខុនឹងទៅដោយឧទ្ទិសកម្មជាគោលថា យើងនឹងបាននូវមរណស្សតិ ព្រោះឃើញឆ្អឹងក្នុងឈាបនដ្ឋាន និងព្រោះឃើញអសុភ ដូច្នេះគួរ ។ ភិក្ខុគួរបដិបត្តិក្នុងព្រះបរិត្តដូចពណ៌នាមក ដូច្នេះ ។

## អនាមដ្ឋបិណ្ឌបាតកថា

ចំណែកក្នុងបិណ្ឌបាត មានវិនិច្ឆ័យដូច្នេះថា សួរថា អនាមដ្ឋបិណ្ឌបាត (អាហារថ្មោង) គួរឲ្យដល់អ្នកណា មិនគួរឲ្យដល់អ្នកណា ឆ្លើយថា គួរឲ្យ

ដល់បិតា និងមាតាមុន ។ បើបិណ្ឌបាតនោះជារបស់មានតម្លៃរាប់កហាបណៈ ក៏មិនរាប់ថា ញ៉ាំងសទ្ធាទេយ្យឲ្យធ្លាក់ចុះទៅឡើយ សូម្បីជនទាំងនេះ គឺពួកជនទំនុកបម្រុងមាតាបិតា វេយ្យាវច្ចៈ បណ្ឌុបលាស ក៏គួរឲ្យ ។ បណ្ដាជនទាំងនោះ សម្រាប់បណ្ឌុបលាសជន នឹងដាក់ក្នុងភាជនៈឲ្យក៏គួរ ។ វៀរបណ្ឌុបលាសជននោះចេញ នឹងដាក់ក្នុងភាជនៈឲ្យដល់គ្រហស្ថដទៃ សូម្បីមាតាបិតា ក៏មិនគួរ ព្រោះថា គ្រឿងបរិភោគរបស់បព្វជិត តាំងនៅក្នុងឋានៈជាចេតិយរបស់ពួកគ្រហស្ថ ។ ម្យ៉ាងទៀត ឈ្មោះថា អនាមដ្ឋបិណ្ឌបាតនេះ គប្បីឲ្យដល់ចោរ ដែលល្បីឈ្មោះខ្លះ និងដល់ឥស្សរជនខ្លះ ដែលមកដល់ ។ ព្រោះហេតុអ្វី ព្រោះថា ជនទាំងនោះ បើមិនឲ្យ ក៏ក្រោធថា មិនឲ្យ កាលចាប់ឲ្យ ក៏ក្រោធថា ឲ្យរបស់សំណល់ ។ ជនទាំងនោះ ក្រោធហើយ រមែងផ្ដាច់បង់ជីវិតខ្លះ រមែងធ្វើអន្តរាយដល់សាសនាខ្លះ ។ ក្នុងសេចក្ដីនេះ គប្បីសម្ដែងរឿងព្រះបាទចោរនាគ ដែលត្រាច់ប្រាថ្នារាជសម្បត្តិ ( ជាឧបមា ) ។ ភិក្ខុគួរបដិបត្តិក្នុងបិណ្ឌបាត ដូចពណ៌នាមកដូច្នេះ ។

## បដិសណ្ឋារកថា

ចំណែកក្នុងបដិសណ្ឋារៈ មានវិនិច្ឆ័យដូច្នេះ សួរថា បដិសណ្ឋារៈ គួរធ្វើដល់នរណា មិនគួរធ្វើដល់នរណា ឆ្លើយថា ឈ្មោះថា បដិសណ្ឋារៈ ភិក្ខុគួរធ្វើដល់បុគ្គលណាមួយ ដែលមកដល់វិហារ ទោះជាអ្នកដំណើរ បុគ្គលអនាថា ចោរ ឬឥស្សរជនក៏ដោយ ។ សួរថា គប្បីធ្វើដូចម្ដេច ឆ្លើយថា ឃើញអាគន្តុកៈអស់ស្បៀងអាហារមកដល់វិហារ គប្បីឲ្យទឹកផឹកមុន ដោយ

ពោលថា អញ្ជើញផឹកទឹកចុះ គប្បីឲ្យប្រេងលាបជើង ។ អាគន្តុកៈមកក្នុងកាល គប្បីឲ្យបបរ និងភត្ត ។ អាគន្តុកៈមកក្នុងវេលាវិកាល បើអង្ករមាន គប្បីឲ្យអង្ករ មិនគួរពោលថា លោកមកដល់ក្នុងវេលាពុំជួកាល ចូរទៅចុះ ។ គប្បីឲ្យទីដេក ។ មិនសង្ឃឹមផលតបស្នងឡើយ គួរធ្វើកិច្ចគ្រប់យ៉ាង ។ មិនគួរឲ្យការគិតកើតឡើងថា ធម្មតាមនុស្សដែលឲ្យបច្ច័យ ៤ កាលអញធ្វើការសង្គ្រោះយ៉ាងនេះ នឹងជ្រះថ្លាធ្វើឧបការៈរឿយៗ ។ សូម្បីវត្ថុរបស់សង្ឃ ក៏គួរឲ្យដល់ពួកចោរបាន ។ ដើម្បីសម្តែងអានិសង្សក្នុងបដិសណ្ឋារៈ ទើបព្រះអដ្ឋកថាចារ្យពោលរឿងច្រើនរឿង ក្នុងមហាអដ្ឋកថាដោយពិស្តារ មានជាដើមយ៉ាងនេះ គឺរឿងព្រះបាទចោរនាគ រឿងព្រះបាទមហានាគ ដែលយាងទៅទូទៅជម្ពូទ្វីប មួយអន្ទើដោយព្រះរាជភាតា រឿងអមាត្យ ៤ នាក់ ក្នុងរជ្ជសម័យនៃព្រះបាទបិតុរាជ រឿងអភយចោរ ។

## រឿង ព្រះអភយត្ថេរ

បណ្តារឿងទាំងនោះ នឹងសម្តែងរឿងមួយដូចតទៅនេះ បានឮមកថា ក្នុងកោះសីហឡ ចោរឈ្មោះអភ័យ មានបរិវារប្រមាណ ៥០០ នាក់ វាយបណ្តាញក្នុងទីកន្លែងមួយ ធ្វើប្រជាជនឲ្យកៀសខ្លួនទៅ រហូត ( ទីមានប្រមាណ ) ៣ យោជន៍ដោយជុំវិញ អ្នកក្រុងអនុរាធបុរី ឆ្លងស្ទឹងកឡម្ពនទីមិនបាន ។ ក្នុងផ្លូវទៅចេតិយគិរីវិហារ ផ្តាច់ការសញ្ចរទៅមករបស់មហាជន ។ ថ្ងៃមួយ ចោរបានទៅដោយគិតថា នឹងប្លន់ចេតិយគិរីវិហារ ។ ពួកញោមវត្តឃើញ ទើបប្រាប់ដល់ព្រះទីឃភាណកអភយត្ថេរ ។

ព្រះថេរៈសួរថា ទឹកដោះថ្លា និងទឹកអំពៅជាដើមមានឬទេ ញោមវត្ត ប្រាប់ថា មាន លោកម្ចាស់ ព្រះថេរៈប្រាប់ថា ពួកអ្នកចូរឲ្យដល់ពួកចោរ ។ ព្រះថេរៈសួរថា អង្ករមានឬទេ ពួកញោមវត្តប្រាប់ថា មានលោកម្ចាស់ អង្ករ ជ្រក់ និងគោរស ដែលគេនាំមកដើម្បីប្រយោជន៍ដល់សង្ឃ ព្រះថេរៈប្រាប់ថា ពួកអ្នកចូររៀបចំភត្តឲ្យដល់ពួកចោរ ។ ពួកញោមវត្តធ្វើតាមព្រះថេរៈបញ្ជា ហើយ ទើបសួរថា នរណាធ្វើការទទួល ពួកញោមវត្តប្រាប់ថា ព្រះអភយត្ថេរ ជាម្ចាស់របស់ពួកយើង ។

ពួកចោរទៅកាន់សម្នាក់របស់ព្រះថេរៈ ថ្វាយបង្គំហើយប្រាប់ថា ពួកខ្ញុំ មកដោយគិតថា នឹងប្លន់យករបស់សង្ឃ និងរបស់ចេតិយ តែត្រឡប់ជាជ្រះ ថ្លា ដោយបដិសណ្ឋារៈនេះរបស់លោកម្ចាស់ទាំងឡាយ តាំងអំពីថ្ងៃនេះទៅ ការរក្សាដែលត្រូវតាមធម៌ ក្នុងព្រះវិហារទុកជានាទីរបស់ពួកខ្ញុំចុះ ពួកអ្នក ស្រុកចូលមកថ្វាយទាន ចូលថ្វាយបង្គំព្រះចេតិយ ។ តាំងអំពីថ្ងៃនោះមក ពួកអ្នកមកថ្វាយទាន ពួកចោរក៏ទៅទទួលដល់មាត់ច្រាំងស្ទឹងនោះឯង ឃ្លាំ រក្សានាំទៅព្រះវិហារ កាលអ្នកស្រុកកំពុងថ្វាយទានក្នុងព្រះវិហារ ក៏នាំគ្នាឈរ ធ្វើការរក្សា ។ អ្នកស្រុកទាំងនោះ ក៏បានឲ្យភត្តដែលសល់អំពីភិក្ខុទាំងឡាយ ឆាន់ហើយដល់ពួកចោរ ។ សូម្បីក្នុងវេលាត្រឡប់ទៅ ពួកចោរទាំងនោះ ក៏ ជួយបញ្ជូនអ្នកស្រុកដល់មាត់ស្ទឹងហើយ ទើបត្រឡប់ ។

## ព្រះថេរៈត្រូវពួកភិក្ខុលើកទោស

ថ្ងៃមួយ កើតពាក្យនិន្ទាឡើងក្នុងពួកភិក្ខុថា ព្រះថេរៈបានឲ្យរបស់សង្ឃ

ដល់ពួកចោរ ព្រោះអាងថា ខ្លួនធំ ។ ព្រះថេរៈប្រាប់ឲ្យធ្វើការប្រជុំ ( សង្ឃ ) ហើយពោលថា ពួកចោរនាំគ្នាមក ដោយតាំងចិត្តថា នឹងប្លន់យកទ្រព្យ តម្លៃអាហារតាមប្រក្រតីរបស់សង្ឃ និងរបស់ចេតិយ កាលបើដូច្នោះ ទើបខ្ញុំបានធ្វើបដិសណ្ឋារៈដល់ពួកចោរទាំងនោះ ដែលមានប្រមាណប៉ុណ្ណេះ ដោយគិតឃើញថា ពួកចោរ នឹងមិនប្លន់ដោយអាការយ៉ាងនេះ ពួកលោកចូរប្រមូលរបស់ទាំងអស់នោះ ដាក់ជុំគ្នាហើយ វាយតម្លៃចុះ ចូរប្រមូលរបស់របរដែលពួកចោរមិនប្លន់ទៅ ដោយហេតុនោះ ដាក់ជុំគ្នាហើយ វាយតម្លៃ ( ប្រៀបធៀបគ្នាមើល ) ទ្រព្យដែលព្រះថេរៈឲ្យទៅទាំងអស់ អំពីទ្រព្យរបស់សង្ឃនោះ មានតម្លៃមិនបានពាក់កណ្ដាលកម្រាល ដែលវិចិត្រដោយរូបភាពដ៏ស្អាតមួយផ្ទាំង ក្នុងខឿនព្រះចេតិយ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលថា បដិសណ្ឋារៈដែលព្រះថេរៈធ្វើហើយ ជាការធ្វើប្រពៃហើយ បុគ្គលណាមួយមិនបានដើម្បីចោទ ឬដើម្បីឲ្យរឭក មិនមានសំណង ឬអវហារ ។ បដិសណ្ឋារៈ មានអានិសង្សច្រើនយ៉ាងនេះ ភិក្ខុដែលជាបណ្ឌិត កំណត់ដូចពោលមកនេះហើយ គួរធ្វើបដិសណ្ឋារៈដូច្នេះឯង ។

[ ២១៦ ] ក្នុងរឿងចាក់ក្រឡេកដោយម្រាមដៃ មានវិនិច្ឆ័យដូច្នេះ បទថា **ឧត្តសន្តោ** បានដល់ បុគ្គលអស់កម្លាំង ។ បទថា **អនស្សាសកោ** បានដល់ ខ្យល់ដង្ហើមចេញមិនទាន់ ។ ឯអាបត្តិដែលគប្បីមានក្នុងរឿងនេះ ទ្រង់សម្ដែងហើយ ក្នុងពួកខុទ្ទកសិក្ខាបទ ព្រោះហេតុនោះ ទើបមិនត្រាស់ក្នុងសិក្ខាបទនេះ ។

[ ២១៧ ] ក្នុងរឿងដែលមានក្នុងលំដាប់នៃរឿងចាក់ក្រឡេក ដោយម្រាមដៃនោះ មានវិនិច្ឆ័យដូច្នេះ បទថា **ឱត្ថរិត្វា** ប្រែថា ជាន់ហើយ ។ បានឮមកថា ភិក្ខុអង្គនោះដួលចុះ ត្រូវពួកសត្តរសវគ្គិយទាំងនោះអូសទាញទៅ ។ ភិក្ខុមួយអង្គឡើងអង្គុយសង្កត់លើពោះរបស់ភិក្ខុនោះ ភិក្ខុ ១៥ អង្គដ៏សេស ក៏ជួយគ្នាសង្កត់ចុះទៅត្រង់ផែនដីរហូតស្លាប់ ដូចជាអង្គប់សង្កត់ម្រឹគស្លាប់ ដូច្នោះ ។ ព្រោះភិក្ខុសត្តរសវគ្គិយទាំងនោះ មានបំណងនឹងធ្វើកម្ម មិនមានបំណង នឹងសម្លាប់ឡើយ ដូច្នោះ ទើបព្រះដ៏មានព្រះភាគ មិនកាត់អាបត្តិបារាជិក ។

[ ២១៨ ] ក្នុងរឿងភិក្ខុជាពេទ្យចាប់ខ្មោច មានវិនិច្ឆ័យដូច្នេះ ពីរបទថា **យក្ខំ មារេសិ**[១] សេចក្តីថា ពួកអាចារ្យវេជ្ជភូតបំណងនឹងដោះបុគ្គលដែលត្រូវយក្ខចូលសណ្ឋិត ទើបហៅយក្ខឲ្យចេញមក ហើយពោលថា ចូរលែង បើយក្ខមិនលែង វេជ្ជភូតក៏យកម្សៅ ឬដីឥដ្ឋ ធ្វើជារូបសត្វខ្ទង់ ហើយកាត់អវយវៈ មានដៃ និងជើងជាដើមចេញ អវយវៈណារបស់រូបសិប្បនិមិត្តនោះដាច់ទៅ អវយវៈនោះៗ របស់យក្ខ ឈ្មោះថា ត្រូវវេជ្ជភូតកាត់ហើយដូចគ្នា ។ កាលក្បាល ( រូបសិប្បនិមិត្ត ) ត្រូវដាច់ សូម្បីយក្ខក៏ស្លាប់ ។ ភិក្ខុចេះវេជ្ជភូតនោះ បានសម្លាប់យក្ខស្លាប់ ដោយវិធីដូចពោលមកនេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ កាត់អាបត្តិថុល្លច្ច័យ ។ អាបត្តិថុល្លច្ច័យ មិនមែនមានដល់ភិក្ខុអ្នកសម្លាប់យក្ខតែម្យ៉ាងប៉ុណ្ណោះទេ ដោយពិត

---

១- បិដកថា យក្ខំ ជីវិតា វោរោបេសិ ។ យកតាមអដ្ឋកថា ។

សូម្បីភិក្ខុណាសម្លាប់សក្កទេវរាជ ភិក្ខុនោះ ក៏ត្រូវអាបត្តិថុល្លច្ច័យដូចគ្នា ។

[ ២១៩ ] ក្នុងរឿងយក្ខកាច មានវិនិច្ឆ័យដូច្នេះ បទថា **វាឡយក្ខវិហារំ** សេចក្តីថា (បញ្ជូនទៅ) កាន់វិហារដែលមានយក្ខកាចនៅ ពិតហើយ ភិក្ខុណា បើមិនជ្រាបវិហារដែលមានសភាពបែបនោះ ទើបបញ្ជូនទៅ ដើម្បីឲ្យស្នាក់នៅតែម្យ៉ាង មិនត្រូវអាបត្តិដល់ភិក្ខុនោះ ភិក្ខុណាមានបំណងនឹងឲ្យស្លាប់ ទើបបញ្ជូនទៅ ភិក្ខុនោះទៅ ព្រោះភិក្ខុនោះស្លាប់ ភិក្ខុអ្នកបញ្ជូន ត្រូវអាបត្តិបារាជិក បើភិក្ខុនោះមិនស្លាប់ ត្រូវអាបត្តិថុល្លច្ច័យ ។ បណ្ឌិតគប្បីជ្រាបសេចក្តីផ្សេងគ្នានៃអាបត្តិ និងអនាបត្តិរបស់ភិក្ខុអ្នកបញ្ជូន ( ភិក្ខុណាមួយ ) ទៅកាន់វិហារដែលមានសត្វកាច មានសីហម្រឹគ និងខ្លាធំដែលកាចជាដើម ឬមានទីឃជាតិទាំងឡាយ មានពស់ថ្លាន់ និងពស់វែកជាដើមនៅអាស្រ័យ ដូចជាភិក្ខុបញ្ជូនភិក្ខុមួយអង្គទៅកាន់វិហារដែលមានយក្ខកាចដូច្នោះ ។

## ចាលីមុត្តកវិនិច្ឆ័យ

ក្នុងបាលីមុត្តកៈ មានន័យដូចតទៅនេះថា បណ្ឌិតគប្បីជ្រាបការផ្សេងគ្នានៃអាបត្តិរបស់ភិក្ខុដែលបញ្ជូនយក្ខកាចទៅកាន់សម្នាក់របស់ភិក្ខុ ដូចដែលភិក្ខុបញ្ជូនភិក្ខុទៅកាន់វិហារដែលមានយក្ខកាច ដូច្នោះ ។ ក្នុងរឿងទាំងឡាយមានវាឡកន្តារ ( ផ្លូវកន្តារដោយសត្វកាច ) ជាដើម ក៏មានន័យនេះដូចគ្នា ។ ពិតហើយ ក្នុងរឿងវាឡកន្តារជាដើមនេះ មានត្រឹមតែអត្ថចំពោះបទតែម្យ៉ាងប៉ុណ្ណោះ ជាឈ្មោះ ( ដែលផ្សេងគ្នា ) យ៉ាងនេះ គឺផ្លូវកន្តារដែលមានពួក

ម្រឹគកាច ឬមានទីយជាតិរស់នៅ ឈ្មោះថា វាឡកន្តារ ផ្លូវកន្តារដែលមានចោរនៅ ឈ្មោះថា ចោរកន្តារ ។ ជាធម្មតាមនុស្សវិគ្គហបារាជិកនេះ ល្អិតល្អន់ រមែងមិនផុតដោយបរិយាយកថា ( ពោលដោយអម ) ។ ព្រោះដូច្នោះ ភិក្ខុណាគប្បីពោលថា បុគ្គលណាកាត់ក្បាលរបស់ចោរដែលអន្ទុយនៅក្នុងឱកាសឈ្មោះនោះ ហើយនាំមក ភិក្ខុនោះរមែងបានសក្ការៈវិសេសអំពីព្រះរាជា ដូច្នេះ ។ បើមានបុគ្គលណាបានស្តាប់ពាក្យរបស់ភិក្ខុនោះហើយទៅសម្លាប់ចោរនោះ ភិក្ខុនេះរមែងត្រូវអាបត្តិបារាជិក ដូច្នេះ ។

## បាលីមុត្តកវិនិច្ឆ័យ ចប់

[ ២២០ ] ក្នុងពាក្យថា **តំ មញ្ញមានោ** ជាដើម មានវិនិច្ឆ័យដូច្នេះបានឮថា ភិក្ខុនោះប្រាថ្នានឹងសម្លាប់ភិក្ខុដែលជាសត្រូវរបស់ខ្លួន ទើបគិតថា ការដែលអញសម្លាប់ភិក្ខុដែលមានពៀរនឹងគ្នានេះក្នុងពេលថ្ងៃ គេចទៅដោយការផុតភ័យ មិនគប្បីជាវត្ថុដែលធ្វើបានងាយឡើយ ណ្ហើយចុះ អញនឹងសម្លាប់ភិក្ខុនោះក្នុងពេលយប់ កាលកំណត់ហើយ មកក្នុងពេលយប់ សម្គាល់ថា ភិក្ខុជាសត្រូវនោះ ក្នុងទីដែលភិក្ខុច្រើនអង្គសិង ទើបសម្លាប់ភិក្ខុអង្គនោះឯងឲ្យដាច់ចាកជីវិត ។ មួយអង្គទៀត សម្គាល់ថា ភិក្ខុជាសត្រូវនោះពិត តែផ្តាច់បង់ជីវិតភិក្ខុអង្គដទៃទៅវិញ ។ មួយអង្គទៀត សម្គាល់ថា ភិក្ខុដទៃពិតដែលជាសម្លាញ់របស់ភិក្ខុសត្រូវនោះឯង តែក៏ផ្តាច់ជីវិតភិក្ខុដែលជាសត្រូវ

នោះទៅវិញ ។ មួយអន្តទៀត សម្គាល់ថា ភិក្ខុដទៃពិត ដែលជាសម្លាញ់របស់ភិក្ខុជាសត្រូវនោះឯង តែក៏សម្លាប់ភិក្ខុដទៃដែលជាសម្លាញ់របស់ភិក្ខុដែលជាសត្រូវនោះឯង ត្រូវអាបត្តិបារាជិកដល់ភិក្ខុទាំងអស់ដូចៗ គ្នា ។

[ ២២១ ] ក្នុងរឿងភិក្ខុខ្មោចចូល មានវិនិច្ឆ័យដូច្នេះថា ភិក្ខុមួយអង្គបានធ្វើការប្រហារ ( ដល់ភិក្ខុខ្មោចចូលនោះ ) ដោយគិតថា នឹងបណ្តេញយក្ខឲ្យគេចទៅ ។ ភិក្ខុក្រៅអំពីនេះគិតថា គ្រានេះ យក្ខនេះមិនអាចនឹងធ្វើពិរុទ្ធ អញនឹងសម្លាប់វាចោល បានធ្វើការប្រហារ ។ ក្នុងរឿងរបស់ភិក្ខុដែលត្រូវខ្មោចចូលទី ១ នេះ ព្រះដ៏មានព្រះភាគត្រាស់ថា មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យស្លាប់ ព្រោះហេតុនោះ ព្រះពុទ្ធតម្រាស់ត្រឹមប៉ុណ្ណេះនោះឯង ទើបភិក្ខុមិនគួរធ្វើការប្រហារដល់ភិក្ខុដែលត្រូវខ្មោចចូល តែគប្បីយកស្លឹកត្នោត ឬអំបោះព្រះបរិត្តចងត្រង់ដៃ ឬជើង គប្បីសូត្រព្រះបរិត្តទាំងឡាយ មានរតនសូត្រជាដើម គប្បីធ្វើធម្មកថាថា អ្នកកុំបៀតបៀនភិក្ខុអ្នកមានសីលឡើយ ដូច្នេះ ។

[ ២២២ ] រឿងពណ៌នាស្ថានសួគ៌ និងនរកជាដើម មានអត្ថជាក់ច្បាស់ ។ ឯពាក្យដែលគប្បីពោលក្នុងរឿងពណ៌នាស្ថានសួគ៌ និងនរកជាដើមនេះ ខ្ញុំបានពោលទុកហើយនោះឯង ។

[ ២២៣ ] រឿងកាប់ដើមឈើ ក៏ដូចគ្នានឹងរឿងចងរន្ទាដែរ ។ តែមានសេចក្តីវិសេសដូចតទៅនេះថា ភិក្ខុណា ត្រូវដើមឈើរលំសង្កត់ហើយ មិនទាន់ស្លាប់ ហើយភិក្ខុអាចនឹងកាប់ដើមឈើ ឬជីកផែនដី ហើយចេញទៅ

ចំហៀងណាមួយបាន និងក្នុងដៃរបស់ភិក្ខុក៏មានកាំបិត និងចប ភិក្ខុនោះគួរលះបង់ជីវិត មិនគួរកាប់ដើមឈើ ឬមិនគួរជីកដី ព្រោះហេតុអ្វី ព្រោះថាភិក្ខុកាលធ្វើយ៉ាងនោះ រមែងត្រូវអាបត្តិបាចិត្តិយ រមែងបំពានទូវពុទ្ធអាណា រមែងមិនធ្វើសីលឲ្យមានជីវិតជាទីបំផុត ព្រោះហេតុនោះ សូម្បីជីវិត ក៏គួរលះបង់ តែមិនគួរលះបង់សីល កាលភិក្ខុគណនាបានល្អិតល្អន់ ដូចពោលមកហើយនេះ មិនគប្បីធ្វើ ( ការកាប់ដើមឈើ និងជីកដី ) ដោយអាការយ៉ាងនេះ ។ ការកាប់ដើមឈើ ឬជីកដី ហើយនាំភិក្ខុនោះចេញ រមែងគួរដល់ភិក្ខុអង្គដទៃ ។ បើភិក្ខុគប្បីត្រូវគេប្រមៀលដើមឈើទៅដោយរ៉កយន្តនាំចេញ គួរកាប់ដើមឈើនោះឯង ប្រើជារ៉កដូច្នេះ។ ព្រះមហាសុមត្ថេរពោលថា នឹងកាត់យកដើមឈើដទៃក៏គួរ ។ ព្រះមហាបទុមត្ថេរពោលថា ក្នុងការចងបង្អោងជួយមនុស្ស ដែលធ្លាក់ចុះទៅក្នុងអណ្តូងជាដើមឲ្យឡើងបាន ក៏មានន័យដូចគ្នា ភិក្ខុមិនគួរកាត់កូតគាម ធ្វើបង្អោងដោយខ្លួនឯង ។ ការធ្វើបង្អោងហើយលើកឡើង រមែងសមគួរដល់ភិក្ខុដទៃ ។

[ ២២៤ ] ក្នុងរឿងដុតព្រៃ មានវិនិច្ឆ័យដូច្នេះ ពីរបទថា **ទាយំ អាលិម្បេសុំ** សេចក្តីថា ពួកឆព្វគ្គិយភិក្ខុបានដុតភ្លើងក្នុងព្រៃ ។ ក្នុងរឿងដុតព្រៃនេះ បណ្ឌិតគប្បីជ្រាបថា ត្រូវអាបត្តិបារាជិកជាដើម ដោយសមគួរដល់វត្ថុនៃបារាជិក អនន្តរិយកម្ម ថុល្លច្ច័យ និងបាចិត្តិយ ដោយអំណាចប្រយោគដែលចំពោះ និងមិនចំពោះ និងភាពជាគំនរអកុសល ដោយន័យដូចពោលហើយខាងដើមនោះឯង អដ្ឋកថាចារ្យបានពោលក្នុងសង្ខេបអដ្ឋកថា កាលភិក្ខុ

ដុតដោយគិតថា ស្មៅស្រស់ និងឈើម្នាស់ព្រៃទាំងឡាយ ចូរឆេះចុះ ត្រូវអាបត្តិបាចិត្តិយ កាលដុតដោយគិតថា គ្រឿងឧបករណ៍ឈើទាំងឡាយ ចូរវិនាសទៅ ត្រូវអាបត្តិទុក្កដ បើដុតដោយបំណងនឹងលេង ក៏ត្រូវអាបត្តិទុក្កដ បើដុតដោយគិតថា ឈើស្រស់ និងឈើស្ងួតប្រភេទណាមួយ ដែលមានឥន្ទ្រិយ និងមិនមានឥន្ទ្រិយក៏ដោយ ចូរឆេះចុះ គប្បីជ្រាបថា ត្រូវអាបត្តិបារាជិក ថុល្លច្ច័យ បាចិត្តិយ ទុក្កដ ដោយអំណាចនៃវត្ថុ ។ ការដុតភ្លើងទទួល ( ដុតកាត់ ) និងដុតការពារ ព្រះមានព្រះភាគទ្រង់អនុញ្ញាតហើយ ។ ព្រោះដូច្នោះ ការដែលភិក្ខុឃើញភ្លើងដែលពួកវនកម្មិកជនដុត ឬភ្លើងដែលកើតឡើងឯងក្នុងព្រៃកំពុងរាលមក ហើយដុតភ្លើងកាត់ ដែលជាហេតុឲ្យភ្លើងឆេះ មកដល់គ្នារលត់ទៅ ដោយតាំងចិត្តថា កុដិស្បូវទាំងឡាយ ចូរកុំវិនាសដូច្នេះ រមែងគួរ ។ ការដែលភិក្ខុធ្វើគ្រឿងការពារ គឺការជីកផែនដី ឬជីកគូទឹកទុកដោយជុំវិញកុដិស្បូវ ដោយប្រការដែលភ្លើងឆេះរាលមកមិនបាន កំញមនឹងរលត់ទៅឯងក៏គួរ ។ កាលភ្លើងឆេះរាលឡើងហើយប៉ុណ្ណោះ ទើបគួរធ្វើកិច្ច មានដុតភ្លើងកាត់ជាដើមនោះ ។ កាលភ្លើងមិនទាន់ឆេះរាលឡើង គប្បីប្រើអនុបសម្បន្នឲ្យធ្វើដោយកប្បិយវោហារ បើនឹងពន្លត់ដោយទឹក គួរប្រើទឹកដែលមិនមានសត្វប៉ុណ្ណោះពន្លត់ ។

[ ២២៥ ] រឿងទីសម្លាប់ចោរ មានវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិបារាជិកព្រោះ ពាក្យប្រាប់ឲ្យប្រហារតែម្តង យ៉ាងណា សូម្បីក្នុងពាក្យប្រាប់ជាដើមថា **ទ្វីហិ បហារេហិ** ក៏គប្បីជ្រាបថា ត្រូវអាបត្តិបារាជិកយ៉ាងនោះ ។ កាលបើ

អ្នកទោសត្រូវនាយពេជ្ឈឃាតសម្លាប់ស្លាប់ ដោយការប្រហារតែម្តង ភិក្ខុប្រាប់ថា **ទ្វីហិ** ដូច្នេះ ឈ្មោះថា បារាជិក ព្រោះឈានចុះកាន់ដែនហើយនោះឯង ។ តែកាលអ្នកទោស ត្រូវពេជ្ឈឃាតសម្លាប់ស្លាប់ ដោយការប្រហារ ៣ ដង ជាការខុសសង្កេត ។ បើសម្លាប់ត្រូវក្នុងខេត្តតាមកំណត់ទុក ឬក្នុងការសង្គ្រោះដែលកំណត់ទុក រមែងមិនខុសសង្កេតឡើយ ដោយប្រការដូច្នេះ ។ តែ ( បើត្រូវសម្លាប់ ) ក្នុងកាលកន្លងហួសកំណត់ រមែងខុសសង្កេតក្នុងទីគ្រប់អន្ទើ ភិក្ខុអ្នកប្រាប់រមែងផុតចាកអាបត្តិ ពេជ្ឈឃាតប៉ុណ្ណោះមានទោស ។ ដូចន័យដែលពោលទុកហើយ ក្នុងការប្រហារម្តង យ៉ាងណា សេចក្តីនេះក៏ដូច្នោះ បណ្ឌិតគប្បីជ្រាបថា បើភិក្ខុប្រាប់ថា បណ្តារាជបុរសទាំងឡាយ រាជបុរសម្នាក់ ចូរសម្លាប់បុគ្គលម្នាក់ឲ្យស្លាប់ ដូច្នេះ កាលបុរសនោះ ត្រូវរាជបុរសម្នាក់នោះឯងសម្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក បើបុគ្គលនោះត្រូវរាជបុរសពីរនាក់សម្លាប់ ជាការខុសសង្កេត កាលភិក្ខុប្រាប់ថា រាជបុរសពីរនាក់ ចូរនាំគ្នាសម្លាប់បុរសម្នាក់ ដូច្នេះ កាលបុគ្គលនោះត្រូវរាជបុរសម្នាក់ ឬពីរនាក់សម្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក បើរាជបុរស ៣ នាក់សម្លាប់ ជាការខុសសង្កេត ។ បើមានបុគ្គលសួរថា ភិក្ខុមួយអង្គយកដាវកាត់ក្បាលរបស់បុរស ដែលរត់ទៅយ៉ាងលឿនក្នុងលានចម្បាំង សរីរៈមិនមានក្បាលរមែងរត់ជ្រុលទៅ ទើបភិក្ខុអង្គដទៃប្រហារសរីរៈ ដែលមិនមានក្បាលនោះឲ្យដួលទៅ ភិក្ខុអង្គណាមួយត្រូវបារាជិក ដូច្នេះ ព្រះថេរៈចំនួនពាក់កណ្តាលពោលឆ្លើយថា ត្រូវអាបត្តិបារាជិកដល់ភិក្ខុដែលប្រហារសរីរៈ

ដែលមិនមានក្បាល ។ ព្រះគោទត្តត្ថេរអ្នកជំនាញក្នុងព្រះអភិធម្មពោលឆ្លើយថា ត្រូវអាបត្តិបារាជិកដល់ភិក្ខុដែលកាត់ក្បាល ។ ក្នុងការសម្តែងអត្ថនៃរឿងនេះ បណ្ឌិតគួរពោលរឿងទាំងឡាយ ដែលមានសភាពបែបនេះដូច្នេះឯង ។

[ ២២៦ ] ក្នុងរឿងខ្ទាញ់ទឹកដោះគោ មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុប្រាប់មិនកំណត់ថា ពួកអ្នកចូរឲ្យបុរសដែលមានដៃ និងជើងកំបុតនោះផឹកខ្ទាញ់ទឹកដោះគោ ដូច្នេះ កាលបុរសនោះត្រូវពួកញាតិឲ្យផឹកខ្ទាញ់ទឹកដោះគោប្រភេទណាមួយស្លាប់ទៅ ភិក្ខុត្រូវអាបត្តិបារាជិក តែបើភិក្ខុប្រាប់កំណត់ថា ចូរឲ្យផឹកខ្ទាញ់គោ ខ្ទាញ់ក្របី ខ្ទាញ់ពពែ ឬប្រាប់ថា ចូរឲ្យផឹកខ្ទាញ់ដែលត្រជាក់ ខ្ទាញ់ដែលក្តៅ ខ្ទាញ់ដែលផ្សែងរំ ខ្ទាញ់ដែលផ្សែងមិនបានរំ កាលបុរសនោះ ត្រូវពួកញាតិឲ្យផឹកខ្ទាញ់ប្រភេទដទៃអំពីខ្ទាញ់ ដែលភិក្ខុប្រាប់នោះស្លាប់ទៅ ជាការខុសសង្កេត ។

ក្នុងរឿងថ្នាំត្រាំ ឈ្មោះលោណសោចិរកៈ គឺថ្នាំត្រាំដោយអំបិល មានវិនិច្ឆ័យដូច្នេះថា ភេសជ្ជៈមួយប្រភេទ ដែលផ្សំដោយស្រូវគ្រប់ប្រភេទ ឈ្មោះថា លោណសោចិរកៈ ។ កាលបុគ្គលធ្វើភេសជ្ជៈប្រភេទនោះ យកទឹកចត់នៃផ្លែសម៉ កន្ទួតព្រៃ និងសម៉ពិភេក ធញ្ញជាតិគ្រប់ប្រភេទ អបរណ្ណជាតិគ្រប់ប្រភេទ បាយនៃធញ្ញជាតិទាំង ៧ ប្រភេទ ផ្លែឈើគ្រប់ប្រភេទ មានផ្លែចេកជាដើម ផ្លែឈើដែលដុះពីមើមគ្រប់ប្រភេទ មានផ្លែផ្តៅ ផ្លែរំចេក និងល្ពៅជាដើម សាច់ត្រី និងសាច់ម្រឹគ និងភេសជ្ជៈច្រើនយ៉ាង មានទឹកឃ្មុំ ទឹកអំពៅ អំបិលសិន្ធវៈ អំបិលធម្មតា និងគ្រឿងក្តៅ ៣ ប្រភេទជាដើម ហើយ

ដាក់រួមគ្នាចូល ( ក្នុងថ្នាំង ) បិទបូកលាបមាត់ថ្នាំងទុកយ៉ាងល្អ ហើយរក្សាទុក ១-២-៣ ឆ្នាំ ថ្នាំលោណសោចិរកៈនោះកាច់ឲ្យមានពណ៌ មានរសដូចទឹកព្រីង ជាគ្រឿងបរិភោគយ៉ាងស្និទ្ធ ជាថ្នាំកែរោគយ៉ាងស័ក្តិសិទ្ធ នៃបុគ្គលដែលកើតរោគខ្យល់ រោគក្អក រោគឃ្លង់ រោគលឿង និងរោគឫសដូងបាតជាដើម និងជាគ្រឿងផឹកខាងក្រោយនៃបុគ្គលដែលបរិភោគអាហារហើយ ។ ភេសជ្ជៈជាគ្រឿងរំលាយអាហារដែលបរិភោគហើយ ដូចថ្នាំប្រភេទនោះរមែងមិនមាន ។ ថ្នាំលោណសោចិរកៈនោះ រមែងសមគួរដល់ភិក្ខុទាំងឡាយសូម្បីក្នុងបច្ឆាភត្ត ។ សម្រាប់ភិក្ខុដែលអាពាធ ចាត់ជាថ្នាំតាមប្រក្រតីនោះ បើបុគ្គលមិនអាពាធ ត្រូវលាយជាមួយទឹក ទើបគួរ ដោយភាពជាគ្រឿងផឹក និងគ្រឿងបរិភោគ ដូច្នេះ ។

តតិយបារាជិកវណ្ណនា ក្នុងអដ្ឋកថាព្រះវិន័យ

ឈ្មោះ សមន្តបាសាទិកា ចប់

# វិនយបិដក

## ទារាជិកកណ្ឌ សិក្ខាបទទី ៤

[ ២២៧ ] សម័យនោះ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់គង់នៅ កូដាគារសាលាព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ មានភិក្ខុច្រើនរូប ជាមិត្របានជួបប្រទះគ្នាថ្មី និងមិត្រស្និទ្ធស្នាលមាំមួន បាននៅចាំវស្សាប្រប ឆ្នេរស្ទឹងវគ្គុមុទា កាលនោះ ស្រុកវជ្ជីកើតទុរ្ភិក្សអត់បាយ មនុស្សទាំងឡាយ ចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្ស ( ដែលក្រលំបាកស្រាប់ ក៏ដល់ នូវសេចក្តីស្លាប់ ) មានឆ្អឹងស ( ដេរដាសលើផែនដី ) មនុស្ស ( ដែល មានទ្រព្យសម្បត្តិល្មមទិញដូវស្រូវអង្ករគេបាន ) ក៏មិនងាយនឹងទិញដូវដែរ លុះតែមានស្លាកកាន់ជាសម្គាល់ ទើបទិញដូវបាន មនុស្សទាំងអស់ក្នុងស្រុក នោះនឹងព្យាយាមស្វែងរកអាហារបានដោយកម្រក្រៃពេក ។ វេលានោះឯង ភិក្ខុទាំងនោះក៏គិតគ្នាថា ឥឡូវនេះ ស្រុកវជ្ជីកើតទុរ្ភិក្សអត់បាយ មនុស្សទាំង-ឡាយចិញ្ចឹមជីវិតបានដោយកម្រក្រៃពេក មនុស្ស ( ដែលក្រលំបាកស្រាប់ ក៏ដល់នូវសេចក្តីស្លាប់ ) មានឆ្អឹងស ( ដេរដាសលើផែនដី ) មនុស្ស ( ដែលមានទ្រព្យសម្បត្តិល្មមទិញដូវស្រូវអង្ករគេបាន ) ក៏មិនងាយនឹង ទិញដូវដែរ លុះតែមានស្លាកកាន់ជាសម្គាល់ទើបទិញដូវបាន មនុស្សទាំង អស់ក្នុងស្រុកនោះនឹងព្យាយាមស្វែករកអាហារបានដោយកម្រក្រៃពេក តើ យើងនឹងគិតធ្វើឧបាយដូចម្តេចឲ្យបានសាមគ្គីស្មោះសរ កុំឲ្យមានវិវាទទាស់ ទែងគ្នា នៅចាំវស្សាឲ្យបានស្រួលផង កុំឲ្យលំបាកដោយអាហារបិណ្ឌបាត

ផង ។ ភិក្ខុខ្លះឆ្លើយថា ម្នាលអាវុសោ បើដូច្នោះ យើងត្រូវទទួលរ៉ាប់រង ការងាររបស់ពួកគ្រហស្ថចុះ កាលបើយើងធ្វើយ៉ាងនេះហើយ ពួកគ្រហស្ថ ទាំងនោះ គង់នឹងនឹកនាំឲ្យអាហារដល់យើងមិនខាន កាលបើបានអាហារយ៉ាង នេះហើយ យើងក៏បានសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ ស្រួលផង ហើយមិនលំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុខ្លះឆ្លើយថា ម្នាលអាវុសោ កុំ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថ (នោះ) ម្នាលអាវុសោ ណ្ហើយចុះ យើងត្រូវធ្វើជាអ្នកបម្រើនាំដំណឹងដល់ពួកគ្រហស្ថ វិញ កាលបើយើងធ្វើយ៉ាងនេះហើយ ពួកជនទាំងនោះគង់នឹងនឹកនាំឲ្យអាហារ បិណ្ឌបាតដល់យើងមិនខាន កាលបើបានអាហារយ៉ាងនេះ យើងនឹងព្រម ព្រៀងស្មោះសរមិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលផង ហើយមិន លំបាកដោយអាហារបិណ្ឌបាតផង ។ ភិក្ខុខ្លះឆ្លើយថា ម្នាលអាវុសោ កុំ ប្រយោជន៍អ្វីនឹងទទួលរ៉ាប់រងការងាររបស់គ្រហស្ថ ប្រយោជន៍អ្វីនឹងធ្វើជាអ្នក បម្រើនាំដំណឹងដល់ពួកគ្រហស្ថ ( នោះ ) ម្នាលអាវុសោ ណ្ហើយចុះ យើង ត្រូវពោលអួតឧត្តរិមនុស្សធម្មគ្នាយើងទៅវិញទៅមក ឲ្យពួកគ្រហស្ថ ( គេ ស្តាប់វិញ ) ថាភិក្ខុឯណោះបានឈានទី ១ ភិក្ខុឯណោះបានឈានទី ២ ភិក្ខុ ឯណោះបានឈានទី ៣ ភិក្ខុឯណោះបានឈានទី ៤ ភិក្ខុឯណោះជាសោតា- បន្ន ភិក្ខុឯណោះជាសកទាគាមី ភិក្ខុឯណោះជាអនាគាមី ភិក្ខុឯណោះជាព្រះ អរហន្ត ភិក្ខុឯណោះបានត្រៃវិជ្ជា ភិក្ខុឯណោះបានអភិញ្ញា ៦ កាលបើយើង ពោលយ៉ាងនេះហើយ ពួកជនទាំងនោះគង់នឹងនឹកនាំឲ្យអាហារបិណ្ឌបាតដល់

យើងមិនខាន កាលបើបានអាហារយ៉ាងនេះហើយ យើងក៏នឹងមានសាមគ្គី ស្មោះសរនឹងគ្នា មិនវិវាទទាស់ទែងគ្នាឡើយ ។ នៅចាំវស្សាក៏ស្រួលហើយ មិនលំបាកដោយបិណ្ឌបាតផង ។ ភិក្ខុទាំងនោះក៏យល់ព្រមថា ម្នាលអាវុសោទាំងឡាយ ការពោលអួតឧត្តរិមនុស្សធម្មរបស់គ្នាយើងទៅវិញទៅមកដល់ពួកគ្រហស្ថ ដែលលោកថាមកនឹងយើង ( អម្បាញ់មិញនេះ ) ស្រួលហើយ ។ ក្នុងកាលជាខាងក្រោយមក ភិក្ខុទាំងនោះក៏បានពោលអួតឧត្តរិ-មនុស្សធម្មទៅវិញទៅមកដល់មនុស្សគ្រហស្ថថា ភិក្ខុឯណោះ បានឈានទី ១ ។បេ។ ភិក្ខុឯណោះបានឈានទី ៤ ភិក្ខុឯណោះជាសោតាបន្ន ។បេ។ ភិក្ខុឯណោះបានអភិញ្ញា ៦ ។ គ្រានោះ មនុស្សទាំងនោះ ក៏និយាយគ្នាថា យើងរាល់គ្នាបានភិក្ខុបែបនេះមកនៅចាំវស្សា អើហ្ន៎ ហៅពេញជាលាភរបស់យើង ឈ្មោះថា យើងបានបុណ្យដោយងាយណាស់ហ្ន៎ ពីដើមយើងរាល់គ្នាមិនដែលបានពួកភិក្ខុមានសីល មានធម៌ជាកុសល ដូចជាពួកភិក្ខុនេះមកនៅចាំវស្សា ( ដល់ម្ដង ) សោះឡើយ ។ មនុស្សទាំងនោះ ( កាលបើបាន ) ភោជនាហារដែលធ្លាញ់ពីសា ក៏បម្រុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានបរិភោគមាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតា កូន ប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្ត អមាត្យ មន្ត្រី និងញាតិសាលោហិតសោះឡើយ ឬបានខាទនីយាហារដែលធ្លាញ់ពីសា ក៏បម្រុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានបរិភោគមាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតាទេ ។បេ។ មិនដែលបានឲ្យទៅញាតិសាលោហិតឡើយ ឬបានគ្រឿងសម្រាប់ជញ្ជក់

ជញ្ជាប់ដែលធ្លាញ់ពីសា ក៏បម្រុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានជញ្ជក់ជញ្ជាប់មាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតាទេ ។បេ។ មិនដែលបានឲ្យទៅញាតិសាលោហិតឡើយ ឬបានទឹកដែលមានរសល្អ ក៏បម្រុងទុកតែនឹងប្រគេនភិក្ខុទាំងនោះ មិនហ៊ានផឹកមាត់ខ្លួនឡើយ ហើយមិនដែលបានជូនទៅមាតាបិតា កូន ប្រពន្ធ ខ្ញុំកំដរ កម្មករបុរស មិត្រ អមាត្យញាតិសាលោហិតឡើយ ។ គ្រានោះ ភិក្ខុទាំងនោះ ( លុះបានអាហារធាន់បរិបូណ៌ ) ក៏មានសម្បុរល្អមានឥន្ទ្រិយពេញលេញ មានទឹកមុខស្រស់បស់សម្បុរស្បែកក៏ជ្រះថ្លា ។ ភិក្ខុទាំងឡាយ កាលបើចេញវស្សារួចហើយ តែងនាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ នេះជាទំនៀមមិនដែលខានឡើយ ។ វេលានោះឯង ភិក្ខុទាំងនោះ លុះបាននៅចាំវស្សាគ្រប់ ៣ ខែហើយ ក៏រៀបចំទុកដាក់គ្រឿងសេនាសនៈរួចហើយ នាំយកបាត្រ និងចីវរចូលទៅក្រុងវេសាលី ដើរទៅកាន់ចារិកតាមលំដាប់ បានចូលទៅគាល់ព្រះដ៏មានព្រះភាគដែល គង់នៅកូដាគារសាលាព្រៃមហាវ័ន ទៀបក្រុងវេសាលី លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[ ២២៨ ] សម័យនោះឯង ពួកភិក្ខុដែលនៅចាំវស្សាក្នុងទិសទាំងឡាយ ( រាល់តំបន់ឯទៀត ) សឹងដ៏មានកាយស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជារោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ។ ឯពួកភិក្ខុដែលនៅទៀបត្រើយស្ទឹងវគ្គមុទា សឹងដ៏មានសម្បុរល្អមានឥន្ទ្រិយពេញលេញ មានមុខមាត់ស្រស់បស់ សម្បុរស្បែកក៏ជ្រះថ្លាទាំងអស់គ្នា ។

មានសេចក្តីថា ការស្មោះសរចំពោះជាមួយនឹងអាគន្តុកភិក្ខុ គឺភិក្ខុដែលទើបនឹងមកដល់ថ្មី នេះជាទំនៀមរបស់ព្រះពុទ្ធដ៏មានព្រះភាគគ្រប់ព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សួរទៅពួកភិក្ខុដែលនៅទៀបឆ្នេរស្ទឹងវគ្គុមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ធន់បានទេឬ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលទេឬ អ្នកទាំងឡាយមានសេចក្តីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទាំងអស់គ្នាល្មមប្រព្រឹត្តទៅបានដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងអស់គ្នា មានសេចក្តីសាមគ្គីស្មោះសរ ឥតមានវិវាទទាស់ទែងគ្នាទេ នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតទេ ។ ( មានសេចក្តីថា ) ព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវហេតុហើយត្រាស់សួរក៏មាន ជ្រាបច្បាស់ហើយមិនត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយត្រាស់សួរក៏មាន ជ្រាបច្បាស់នូវកាលគួរហើយ មិនត្រាស់សួរក៏មាន ព្រះតថាគតទាំងឡាយ ទ្រង់សួរចំពោះតែអំពើដែលមានប្រយោជន៍ អំពើដែលមិនមានប្រយោជន៍ ទ្រង់មិនសួរឡើយ ព្រោះព្រះតថាគតទាំងឡាយ ទ្រង់ផ្តាច់បង់នូវអំពើដែលមិនមានប្រយោជន៍ដោយអរិយមគ្គអស់ហើយ ។ ព្រះសម្ពុទ្ធជាម្ចាស់ទាំងឡាយដ៏មានជោគ ទ្រង់សួរពួកភិក្ខុដោយហេតុពីរប្រការ គឺទ្រង់សួរដើម្បីនឹងសម្តែងធម៌ ១ ដើម្បីនឹងបញ្ញត្តសិក្ខាបទដល់ពួកសាវក ១ ។

កាលនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរពួកភិក្ខុ ដែលនៅទៀបឆ្នេរស្ទឹងវគ្គមុទាថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាបានជាមានសេចក្ដីសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាក៏ស្រួលបួល មិនលំបាកដោយអាហារបិណ្ឌ-បាតនោះ តើដោយហេតុអ្វី ។ គ្រានោះ ភិក្ខុទាំងអម្បាលនោះ ក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ( ដោយសព្វគ្រប់ ) ។ ទើបព្រះអង្គត្រាស់សួរថា នែភិក្ខុទាំងឡាយ គុណវិសេសរបស់ពួកអ្នកនោះ មានឬទេ ។ ភិក្ខុទាំងនោះក្រាបទូលតបវិញថា មិនមានទេ ព្រះអង្គ ។

[ ២២៩ ] ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា នែមោឃ-បុរសទាំងឡាយ អំពើដែលអ្នកទាំងអស់គ្នាធ្វើនេះ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើសោះ នែមោឃ-បុរសទាំងឡាយ គួរបើដែរ អ្នកឯងរាល់គ្នាហ៊ានពោលអួតឧត្តរិមនុស្សធម្មទៅវិញទៅមកចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ចម្អែតផ្ទៃ នែមោឃបុរសទាំងឡាយ បើអ្នករាល់គ្នាយកកាំបិតយ៉ាងមុត ដែលសម្រាប់ពន្វះសាច់គោមកវះពោះ ( របស់ខ្លួន ) វិញប្រសើរជាង ឯការពោលអួតឧត្តរិមនុស្សធម្មរបស់គ្នានឹងគ្នាចំពោះពួកគ្រហស្ថ ព្រោះហេតុតែចង់ចម្អែតផ្ទៃ ដែលអ្នកឯងទាំងអស់គ្នាពោលរួចទៅហើយ ( នោះ ) ពុំប្រសើរសោះឡើយ ហេតុអ្វីបានជាតថាគតពោលយ៉ាងនោះ ម្នាលមោឃបុរសទាំងឡាយ ពីព្រោះបុគ្គលដែលវះពោះខ្លួនឯងនោះ ជាហេតុបានតែត្រឹមសេចក្ដីស្លាប់ ឬលំបាកទៀបស្លាប់ប៉ុណ្ណោះ កាលបើរំលោងខន្ធតអំពីមរណកាលទៅ ក៏មិនទៅកើតជាតិរច្ឆាន

ប្រេត អសុរកាយ នរក ព្រោះហេតុដែលវះពោះនោះឡើយ ម្នាលមោឃ-បុរសទាំងឡាយ ឯចំណែកខាងភិក្ខុដែលពោលអួតឧត្តរិមនុស្សធម្ម ជាហេតុជាទីតាំងនេះ កាលបើរំលោងខន្ធគអំពីមរណកាលទៅហើយ ទៀងតែទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ នរក មិនខានឡើយ ម្នាលមោឃបុរសទាំង-ឡាយ ការដែលពោលអួតឧត្តរិមនុស្សធម្មនេះ នឹងបាននាំមនុស្សដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ឬមនុស្សដែលជ្រះថ្លាហើយឲ្យកាន់តែជ្រះថ្លាឡើងក៏ទេ ។បេ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់តិះដៀលពួកភិក្ខុទាំងនោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំហើយ ទើបទ្រង់សម្តែងធម្មីកថា តទៅថា ។

[ ២៣០ ] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ មានភិក្ខុជាមហាចោរ ៥ ពួក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមហាចោរ ៥ ពួកនោះដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រិះរិះរបស់មហាចោរខ្លះដែលមានក្នុងលោកនេះថា បើដល់វេលាណាអញបានបរិសទ្យ ១ រយ ឬ ១ ពាន់ចោមរោមជាគ្នាហើយ នឹងលើកចូលទៅក្នុងស្រុកនិគមរាជធានី ហើយនឹងវាយសំពងផ្តាច់ជីវិតពួកអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យផ្តាច់ជីវិត ដុតរោលអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតរោល ។ លុះដល់សម័យខាងក្រោយមក មហាចោរនោះបានបរិសទ្យ ១ រយ ឬ ១ ពាន់ ចោមរោមជាគ្នាហើយ ក៏លើកចូលទៅក្នុងស្រុកនិគមរាជធានី វាយសំពងផ្តាច់ជីវិតអ្នកស្រុកទាំងនោះ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យផ្តាច់ជីវិត ដុតរោលអ្នកស្រុកទាំងនោះដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យដុតរោល យ៉ាងណាមិញ ។

ម្នាលភិក្ខុទាំងឡាយ សេចក្ដីត្រិះរិះរបស់ភិក្ខុបាបខ្លះដែលមានក្នុងសាសនានេះ ក៏យ៉ាងនោះដែរ ( ត្រិះរិះ ) ថាបើដល់កាលណា អញបានបរិវារ ១ រយ ឬ ១ ពាន់ ចោមរោមជាគ្នាហើយ នឹងត្រាច់ទៅកាន់ចារិកក្នុងស្រុកនិគមរាជ-ធានី ក៏នឹងបានទូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្តី ពួកបព្វជិតក្តី ធ្វើសក្ការគោរពរាប់អានបូជាកោតក្រែង ។ លុះដល់សម័យខាងក្រោយមក ភិក្ខុបាបនោះ បានបរិវារ ១ រយ ឬ ១ ពាន់ចោមរោមជាគ្នាហើយ ក៏ត្រាច់ទៅកាន់ចារិកក្នុងស្រុកនិគមរាជធានី បាន ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថ ក្តី បព្វជិក្តី ធ្វើសក្ការគោរពរាប់អានបូជាក្រោតក្រែង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មហាចោរទី ១ ដែលមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំង-ឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះរៀនសូត្រ ធម្មវិន័យដែលតថាគតបានសម្ដែងហើយ ដុតកម្ដៅខ្លួនឯងចោល ។ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា មហាចោរទី ២ ដែលមានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះមានភិក្ខុបាបខ្លះ ពោលចោទភិក្ខុដែលប្រព្រឹត្តធម៌ប្រសើរដ៏ស្អាត ដែលកំពុងប្រព្រឹត្តធម៌ប្រសើរ ដ៏បរិសុទ្ធ ចោទដោយការប្រព្រឹត្តមិនប្រសើររកមូលគ្មាន ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនេះហៅថា មហាចោរទី ៣ មានប្រាកដក្នុងលោក ។ ម្នាលភិក្ខុ ទាំងឡាយ ហេតុដទៃមានតទៅទៀត ក្នុងសាសនានេះ មានភិក្ខុបាបខ្លះ សង្គ្រោះផ្គាប់ផ្គុនគ្រហស្ថដោយគ្រឿងគរុភណ្ឌរបស់សង្ឃ ឬគ្រឿងគរុបរិក្ខារ

គ្រឿងគរុភណ្ឌ គឺអ្វីខ្លះ គ្រឿងគរុភណ្ឌនោះ គឺគុម្ពផ្កា និងដើមឈើ ១ ទីដែលសម្រាប់ដាំគុម្ពផ្កា និងដើមឈើ ១ កុដិ ១ ទីដែលសម្រាប់សង់កុដិ ១ គ្រែ ១ តាំង ១ ពូក ១ ខ្នើយ ១ ឆ្នាំងលោហៈ ១ ស្នូកលោហៈ ១ ក្អមលោហៈ ១ ផើងលោហៈ ១ កាំបិត ១ ពូថៅ ១ ដឹង ១ ចប ១ ពន្លាក ១ ( ឬដែកកណ្ដារ ) ១ វល្លិប្រវែងមួយលូកឡើងទៅ ១ ឫស្សីប្រវែង ៨ ធ្នាប់ឡើងទៅ ១ ស្មៅដំណេកទន្សាយ ១ ស្មៅយាប្លង ១ ស្មៅធម្មតា ១ ដីស្អិត ១ គ្រឿងធ្វើនឹងឈើ ១ គ្រឿងធ្វើនឹងដី ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថាមហាចោរទី ៤ មានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាពោលអួតឧត្តរិមនុស្សធម្មដែលមិនមានមិនប្រាកដក្នុងខ្លួន ភិក្ខុនេះជាមហាចោរទី ៥ ជាចោរធំបំផុតក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហេតុអ្វីបានជាតថាគតពោលដូច្នោះ ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺភិក្ខុនោះឯង លួចយកមកបរិភោគ ។ ( ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រាថ្នានឹងធ្វើសេចក្ដីនុ៎ះឲ្យច្បាស់លាស់ឡើង ទើបត្រាស់សម្ដែងសេចក្ដីជាគាថាតទៅទៀតថា )

ភិក្ខុណាមានខ្លួនតាំងនៅ ដោយអាការដទៃ គឺថា ខ្លួនមានកាយ
សមាចារមិនបរិសុទ្ធជាដើម ហើយញុំាងអ្នកដទៃឲ្យដឹងថា ខ្លួនតាំង
នៅដោយអាការដទៃ គឺថា ខ្លួនមានកាយសមាចារជាដើមស្អាតវិញ
ភិក្ខុនោះឯង ហៅថា លួចភោជនគេមកបរិភោគ ដូចជា ព្រានសត្វ

ស្វាប លបលាក់ខ្លួនប្របគុម្ពឈើបម្រុងចាំបាញ់សត្វ ។ ភិក្ខុដែលយកសំពត់កាសាវៈមកព័ទ្ធព័ន្ធក តែប្រព្រឹត្តធម៌អាក្រក់ជាធម្មតា គ្មានសង្រួម ( តាមធម៌វិន័យ ) ឡើយ ជាបុគ្គលលាមកក្រៃលែងសឹងមានច្រើន ភិក្ខុនោះទៀងតែទៅនរក ព្រោះអំពើដែលខ្លួនធ្វើអាក្រក់ ។ បរិភោគដុំដែកដែលកំពុងឆេះក្តៅ ឧបមាដូចជាអណ្តាតភ្លើងវិញប្រសើរជាង ឯភិក្ខុដែលទ្រុស្តសីល មិនសង្រួម ( តាមធម៌វិន័យ ) នឹងបរិភោគនូវដុំអាមិសរបស់ជនអ្នកនៅក្នុងដែន ( នោះ ) ពុំប្រសើរសោះឡើយ ។

[ ២៣១ ] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលពួកភិក្ខុដែលនៅទៀបច្រាំងស្ទឹងវគ្គុមុទា ដោយអនេកបរិយាយ ហើយទ្រង់សម្តែងនូវទោសនៃការដែលគេលំបាកចិញ្ចឹមលំបាកថែទាំ ។ បេ ។ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនដឹងចំពោះ ហើយពោលអួតឧត្តរិមនុស្សធម្ម ជាធម៌គួរឃើញដោយញាណដ៏ប្រសើរ បង្អោនមកដាក់ក្នុងខ្លួនថា ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ លុះដល់សម័យដទៃពីនោះមក ទោះមានគេសាកសួរក្តី ឥតមានគេសាកសួរក្តី ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ ( ទោះបី ) មានប្រាថ្នាចង់ឲ្យបរិសុទ្ធ ហើយត្រឡប់ជានិយាយកែសំនួនយ៉ាងនេះវិញថា នែអាវុសោ ខ្ញុំមិនដឹងយ៉ាងនេះទេ ( ប៉ុន្តែ ) ពោលថា ដឹង ខ្ញុំមិនឃើញយ៉ាងនេះទេ ( ប៉ុន្តែ ) ពោលថា ឃើញ ខ្ញុំពោលកុហកសោះទេ ភិក្ខុនេះឯងក៏នៅតែត្រូវអាបត្តិបារាជិក រក

សំវាសគ្មាន ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តដល់ពួកភិក្ខុរូបស្រេចយ៉ាងនេះ ។

[ ២៣២ ] វេលានោះឯង មានភិក្ខុច្រើនរូបមានសេចក្ដីសម្គាល់ថាឃើញ ក្នុងហេតុដែលខ្លួនមិនឃើញ សម្គាល់ថាដល់ក្នុងហេតុដែលខ្លួនឥតបានដល់ សម្គាល់ថាត្រាស់ដឹងក្នុងហេតុដែលខ្លួនឥតបានត្រាស់ដឹង សម្គាល់ថាធ្វើឲ្យច្បាស់លាស់ ក្នុងហេតុដែលខ្លួនឥតបានធ្វើឲ្យច្បាស់លាស់ ហើយបានពោលអួតអរហត្តផលដោយសម្គាល់ថាខ្លួនបានត្រាស់ដឹង ។ លុះដល់សម័យដទៃមក ចិត្តរបស់ភិក្ខុទាំងនោះ ក៏ឱនទៅរករាគៈខ្លះ ចិត្តឱនទៅរកទោសៈខ្លះ ចិត្តឱនទៅរកមោហៈខ្លះ ។ សេចក្ដីសង្ស័យ ក៏កើតឡើងដល់ភិក្ខុទាំងនោះថា សិក្ខាបទព្រះដ៏មានព្រះភាគ ទ្រង់បានបញ្ញត្តរួចជាស្រេចហើយ ម្ដេចឡើយក៏យើងមកសម្គាល់ថាឃើញក្នុងហេតុដែលយើងឥតបានឃើញ សម្គាល់ថាដល់ក្នុងហេតុដែលយើងឥតបានដល់ សម្គាល់ថា ត្រាស់ដឹងក្នុងហេតុដែលយើងឥតបានត្រាស់ដឹង សម្គាល់ថាធ្វើឲ្យច្បាស់លាស់ក្នុងហេតុដែលយើងឥតបានធ្វើឲ្យច្បាស់លាស់ ហើយបានពោលអួតអរហត្តផល ដោយសម្គាល់ថា ខ្លួនយើងបានត្រាស់ដឹង ( ដូច្នេះ ) យើងប្រហែលជាត្រូវអាបត្តិបារាជិកទេដឹង ។ ភិក្ខុទាំងនោះបានប្រាប់សេចក្ដីនេះ ដល់ព្រះអានន្ទដ៏មានអាយុ ។ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលអានន្ទ ភិក្ខុទាំងឡាយដែលមានសេចក្ដីសម្គាល់ថាឃើញក្នុងហេតុដែលខ្លួនឥតឃើញ សម្គាល់ថាបានដល់ក្នុងហេតុដែលខ្លួនឥត

បានដល់ សម្គាល់ថាបានត្រាស់ដឹងក្នុងហេតុដែលខ្លួនឥតបានត្រាស់ដឹង សម្គាល់ថាធ្វើឲ្យច្បាស់លាស់ក្នុងហេតុដែលខ្លួនឥតបានធ្វើឲ្យច្បាស់លាស់ ហើយពោលអួតអរហត្តផល ដោយសេចក្ដីសម្គាល់ថា ខ្លួនបានត្រាស់ដឹង ក៏អំពើដែលពោលអួតនេះ ជាអព្វោហារិក ( មិនហៅថាជាអង្គនៃអាបត្តិឡើយ ) ។ ព្រោះនិទាននេះ ព្រោះដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយទ្រង់សម្ដែងធម្មីកថាក្នុងគ្រានោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនដឹងច្បាស់ហើយពោលអួតឧត្តរិមនុស្សធម្ម ជាធម៌មានញាណ ( សេចក្ដីដឹង ) និងទស្សនៈ ( កិរិយាឃើញ ) ដ៏ប្រសើរ អាចកម្ចាត់នូវកិលេសគួរបង្អោនមកដាក់ក្នុងខ្លួនដោយពាក្យថា ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ លុះដល់សម័យដទៃអំពីនោះមក ទោះមានគេសាកសួរក្ដី ឥតមានគេសាកសួរក្ដី ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ ( ទោះបី ) មានប្រាថ្នាចង់ឲ្យបរិសុទ្ធហើយត្រឡប់ជានិយាយកែសំនួនយ៉ាងនេះវិញថា នែអាវុសោ ខ្ញុំមិនដឹងយ៉ាងនេះទេ ( ប៉ុន្ដែ ) ពោលថាដឹង ខ្ញុំមិនឃើញយ៉ាងនេះទេ ( ប៉ុន្ដែ ) ពោលថាឃើញ ខ្ញុំពោលកុហកសោះទេ ភិក្ខុនេះក្ដី ក៏ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន វៀរលែងតែសម្គាល់ថា ខ្លួនបានត្រាស់ដឹង ។

[ ២៣៣ ] ត្រង់ពាក្យថា ណាមួយ សេចក្ដីថា ណាក៏ដោយ ។បេ។ ត្រង់ពាក្យថា ភិក្ខុ ។បេ។ ភិក្ខុដែលបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចានេះ សំដៅឲ្យឈ្មោះថា ភិក្ខុ ក្នុងអត្ថនេះ ។ ត្រង់ពាក្យថា មិនដឹងច្បាស់

សេចក្តីថា មិនដឹងមិនឃើញនូវកុសលធម៌ដែលមិនមានមិនពិតមិនប្រាកដក្នុងខ្លួន ( ហើយចូលចិត្តថា ) កុសលធម៌ទាំងឡាយរបស់អញមាន ។ ឈាន ( គុណជាតសម្រាប់ដុតបង់នូវកិលេស ) ១ វិមោក្ខ ( គុណធម៌ដែលផុតស្រឡះចាករាគៈជាដើម ) ១ សមាធិ ( សភាពដែលតម្កល់ចិត្តស្មើមាំល្អក្នុងអារម្មណ៍ ) ១ សមាបត្តិ ( គុណជាតដែលដល់ព្រម ) ១ ញាណ-ទស្សនៈ ( កិរិយាឃើញដោយបញ្ញា ) ១ មគ្គភាវនា ( កិរិយាចម្រើននូវមគ្គ ) ១ ផលសច្ឆិកិរិយា ( ដំណើរធ្វើឲ្យច្បាស់លាស់នូវផល ) ១ កិលេ-សប្បហាន ( កិរិយាលះបង់កិលេស ) ១ និវរណតា ចិត្តស្ស ចិត្តមាននីវរណធម៌ប្រាសហើយ ១ សុញ្ញាគារេ អភិរតិ សេចក្តីត្រេកអរក្នុងផ្ទះដ៏ស្ងាត់ ១ ( ធម៌ទាំង ១០ នេះ ) ហៅថា ឧត្តរិមនុស្សធម្ម ។ ត្រង់ពាក្យថា បង្អោនមកដាក់ក្នុងខ្លួន សេចក្តីថា បង្អោនកងកុសលធម៌ទាំងនោះមកដាក់ក្នុងចិត្ត ឬបង្អោនចិត្តទៅក្នុងកងកុសលធម៌ទាំងនោះ ។ ត្រង់ពាក្យថា ញាណ បានដល់វិជ្ជា គឺសេចក្តីដឹងវិសេស ៣ យ៉ាង ។ ត្រង់ពាក្យថា ទស្សនៈ សេចក្តីថា ធម្មជាតណា ហៅថា ញាណ ធម្មជាតនោះ ហៅថា ទស្សនៈ ធម្មជាតណា ហៅថា ទស្សនៈ ធម្មជាតនោះ ហៅថា ញាណ ។ ត្រង់ពាក្យថា ពោលអួត សេចក្តីថា ប្រាប់ដល់ស្រីក្តី ប្រុសក្តី គ្រហស្ថក្តី បព្វជិតក្តី ។ ត្រង់ពាក្យថា ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ សេចក្តីថា ខ្ញុំដឹងធម៌នេះ ខ្ញុំឃើញធម៌នេះម្យ៉ាងទៀត ធម៌នេះជារបស់ខ្ញុំៗ ក៏យល់ជាក់ច្បាស់ក្នុងធម៌នេះហើយ ។

[ ២៣៤ ] ត្រង់ពាក្យថា លុះដល់សម័យដទៃពីនោះមក សេចក្តីថា

កិរិយាពោលអួតក្នុងខណៈណា លុះដល់សម័យដែលកន្លងនូវខណៈ នូវស្របក់ នូវពេលមួយរំពេចនោះមក ។ ត្រង់ពាក្យថា ទោះមានគេសាកសួរក្តី សេចក្តីថា វត្ថុណាដែលខ្លួនបានប្តេជ្ញាហើយ ក៏មានអ្នកឯទៀតគេសាកសួរចំពោះវត្ថុនោះថា ធម៌អ្វីខ្លះដែលលោកបានត្រាស់ដឹង ព្រោះហេតុដូចម្តេចបានជាលោកបានត្រាស់ដឹង លោកបានត្រាស់ដឹងពីអង្កាល់ លោកបានត្រាស់ដឹងក្នុងទីណា កិលេសណាខ្លះ ដែលលោកបានលះរួចហើយ លោកបានធម៌ដូចម្តេចខ្លះ ។ ត្រង់ពាក្យថា ទោះឥតមានគេសាកសួរក្តី សេចក្តីថា ឥតមានអ្នកណាមួយសួរដណ្តឹងឡើយ ។ ត្រង់ពាក្យថា ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ សេចក្តីថា ( ភិក្ខុ ) មានសេចក្តីប្រាថ្នាអាក្រក់ គឺសេចក្តីប្រាថ្នាគ្របសង្កត់ហើយពោលអួតឧត្តរិមនុស្សធម្មដែលមិនពិតមិនប្រាកដ ក៏ហៅថា ត្រូវអាបត្តិបារាជិកហើយ ។ ត្រង់ពាក្យថា មានប្រាថ្នាចង់ឲ្យបរិសុទ្ធ សេចក្តីថា ( ភិក្ខុនោះ ) ទោះមានប្រាថ្នាចង់ទៅជាគ្រហស្ថក្តី ចង់ទៅជាឧបាសកក្តី ចង់ទៅជាញោមវត្តក្តី ចង់ទៅជាសាមណេរក្តី ។ ត្រង់ពាក្យថា ម្នាលអាវុសោខ្ញុំមិនដឹងយ៉ាងនេះហើយ ពោលថាដឹង ខ្ញុំមិនបានឃើញយ៉ាងនេះហើយពោលថាឃើញ សេចក្តីថា ខ្ញុំមិនបានដឹងធម៌នេះទេ ខ្ញុំមិនបានឃើញធម៌នេះទេ ធម៌នេះខ្ញុំគ្មានទេ ខ្ញុំនឹងបានឃើញច្បាស់ក្នុងធម៌នេះក៏ទេ ។ ត្រង់ពាក្យថា ខ្ញុំពោលកុហកសោះទេ សេចក្តីថា ខ្ញុំពោលសោះទទេ ខ្ញុំពោលកុហកទេ ខ្ញុំពោលមិនពិតទេ ខ្ញុំពោលមិនប្រាកដទេ ខ្ញុំបានជាជ្រុលពោលមកពីហេតុមិនដឹងសោះទេ ។ ត្រង់ពាក្យថា វៀរលែងតែសម្គាល់ថា ខ្លួនបានត្រាស់ដឹង

សេចក្តីថា លើកលែងតែខ្លួនបានត្រាស់ដឹងមែន ។

[ ២៣៥ ] ត្រង់ពាក្យថា ភិក្ខុនេះក្តី ពោលប្រៀបធៀបនឹងភិក្ខុដែលមានក្នុងសិក្ខាបទមុន ។ ត្រង់ពាក្យថា បារាជិក សេចក្តីថា ធម្មតាដើមត្នោតតែមានកកំបុតហើយ មិនអាចនឹងដុះឡើងទៀតបាន មានឧបមាដូចម្តេចមិញ ភិក្ខុដែលមានប្រាថ្នាអាក្រក់ គឺសេចក្តីប្រាថ្នាគ្របសង្កត់ហើយពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន មិនកើតក្នុងខ្លួន មិនមែនជាសមណៈ មិនមែនជាសក្យបុត្រ ក៏មានឧបមេយ្យដូច្នោះឯង ព្រោះហេតុនោះ ទើបតថាគតពោលថា ត្រូវអាបត្តិបារាជិក ។ ត្រង់ពាក្យថា រកសំវាសគ្មាន ដែលហៅថា សំវាសនោះ គឺសង្ឃកម្មជាមួយគ្នា បាតិមោក្ខុទ្ទេសជាមួយគ្នា សេចក្តីសិក្សាស្មើគ្នា នេះហៅថា សំវាស ។ ភិក្ខុនោះគ្មានសំវាសដូច្នោះទេ ព្រោះហេតុនោះ បានជាតថាគតពោលថា រកសំវាសគ្មាន ។

[ ២៣៦ ] ដែលហៅថា ឧត្តរិមនុស្សធម្ម ( នោះសំដៅយក ) ឈាន ១ វិមោក្ខ ១ សមាធិ ១ សមាបត្តិ ១ ញាណទស្សនៈ ១ មគ្គភាវនា ១ ផលសច្ឆិកិរិយា ១ កិលេសប្បហាន ១ វិនីវរណតា ចិត្តស្ស ១ សុញ្ញាគារេ អភិរតិ ១ ។ ត្រង់ពាក្យថា ឈាន បានខាងបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ ត្រង់ពាក្យថា វិមោក្ខ ( នោះ ) បានខាងឯសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ ។ ត្រង់ពាក្យថា សមាធិ ( នោះ ) បានខាងឯសុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ ។ ត្រង់ពាក្យថា សមាបត្តិ ( នោះ ) បានខាងសុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិ-

ហិតសមាបត្តិ ។ ត្រង់ពាក្យថា ញាណ ( នោះ ) បានខាងត្រៃវិជ្ជា ។ ត្រង់ពាក្យថា មគ្គភាវនា ( នោះ ) បានខាងសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិ-បាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ត្រង់ពាក្យថា ផលសច្ឆិកិរិយា ( នោះ ) បានខាងធ្វើឲ្យច្បាស់លាស់នូវសោតាបត្តិផល ធ្វើឲ្យច្បាស់លាស់នូវសកទាគាមិផល ធ្វើឲ្យច្បាស់លាស់នូវអនាគាមិផល ធ្វើឲ្យច្បាស់លាស់នូវអរហត្តផល ។ ត្រង់ពាក្យថា កិលេសប្បហាន ( នោះ ) បានខាងកិរិយាលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ។ ត្រង់ពាក្យថា វិនីវរណតា ចិត្តស្ស ( នោះ ) បានខាងការហាមឃាត់ចិត្តចាករាគៈ ហាមឃាត់ចិត្តចាកទោសៈ ហាមឃាត់ចិត្តចាកមោហៈ ។ ត្រង់ពាក្យថា សុញ្ញាគារេ អភិរតិ ( នោះ ) បានខាងឯសេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយបឋមជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយទុតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយតតិយជ្ឈាន សេចក្តីត្រេកអរក្នុងផ្ទះស្ងាត់ ដោយចតុត្ថជ្ឈាន ។

[ ២៣៧ ] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ ៤ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនិយាយកុហក ១ កំពុង

និយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីយល់ឃើញ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ ៥ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីយល់ឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ ៦ យ៉ាង គឺមុននឹងនិយាយដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីយល់ឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈានហើយ ដោយអាការ ៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីយល់ឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ បិទបាំងសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

[ ២៣៨ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹង

និយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ ៤ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ ៥ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈាន ដោយអាការ ៦ យ៉ាងគឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាកំពុងចូលបឋមជ្ឈានដោយអាការ ៧ យ៉ាងគឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយ

កុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ បិទបាំងសេចក្ដីគាប់ចិត្ត ១ បិទបាំងសេចក្ដីពេញចិត្ត ១ បិទបាំងសេចក្ដីពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

[ ២៣៩ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ ៤ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ ៥ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ បិទបាំងសេចក្ដីគាប់ចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ ៦ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយ កុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ បិទបាំងសេចក្ដីគាប់ចិត្ត ១ បិទបាំងសេចក្ដីពេញចិត្ត ១

ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលបឋមជ្ឈាន ដោយអាការ ៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ បិទបាំងសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

[ ២៤០ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ ៤ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយដោយអាការ ៥ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកបានបឋមជ្ឈានហើយ ដោយអាការ ៦

យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អញជាអ្នកបានបឋមជ្ឈាន ដោយអាការ ៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ បិទបាំងសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

[ ២៤១ ] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ ៤ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ ៥ យ៉ាង គឺមុននឹង

និយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ ៦ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈាន ដោយអាការ ៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ បិទបាំងសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

[ ២៤២ ] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មា

បានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ ៤ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ ៥ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ បិទបាំងសេចក្ដីគាប់ចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ ៦ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ បិទបាំងសេចក្ដីគាប់ចិត្ត ១ បិទបាំងសេចក្ដីពេញចិត្ត ១ ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា បឋមជ្ឈានអាត្មាបានធ្វើឲ្យច្បាស់លាស់រួចហើយ ដោយអាការ ៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ បិទបាំងសេចក្ដីគាប់ចិត្ត ១ បិទបាំងសេចក្ដីពេញចិត្ត ១ បិទបាំងសេចក្ដីពិតត្រង់ ១ ត្រូវអាបត្តិ

បារាជិក ។ ( បឋមជ្ឈានទេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងឲ្យពិស្តារ ហើយយ៉ាងណា ឈានទាំងពួង មានទុតិយជ្ឈានជាដើម បណ្ឌិតត្រូវសម្តែង ឲ្យពិស្តារយ៉ាងនោះផងចុះ ) ។

[ ២៤៣ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន អាត្មា ជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងចតុត្ថជ្ឈាន ចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុង និយាយកុហក ១ និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញ ចិត្ត ១ បិទបាំងសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

[ ២៤៤ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់សុញ្ញតវិមោក្ខ កាន់អនិមិត្តវិមោក្ខ កាន់អប្បណិហិត វិមោក្ខ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងអប្បណិហិត វិមោក្ខ អប្បណិហិតវិមោក្ខ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៤៥ ] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់សុញ្ញតសមាធិ កាន់អនិមិត្តសមាធិ កាន់អប្បណិ- ហិតសមាធិ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងអប្បណិ-

ហិតសមាធិ អប្បណិហិតសមាធិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៨៦ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់សុញ្ញតសមាបត្តិ កាន់អនិមិត្តសមាបត្តិ កាន់អប្បណិហិតសមាបត្តិ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងអប្បណិហិតសមាបត្តិ អប្បណិហិតសមាបត្តិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៨៧ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវត្រៃវិជ្ជា អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងត្រៃវិជ្ជា ត្រៃវិជ្ជាអាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៨៨ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងឥទ្ធិបាទ ៤ ឥទ្ធិបាទ ៤ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៨៩ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវឥន្ទ្រិយ ៥ ពល ៥ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងពល ៥ ពល ៥ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ

ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥០ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានត្រាស់ដឹងហើយ កំពុងត្រាស់ដឹង បានត្រាស់ដឹងនូវពោជ្ឈង្គ ៧ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងពោជ្ឈង្គ ៧ ពោជ្ឈង្គ ៧ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥១ ] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានត្រាស់ដឹងហើយ កំពុងត្រាស់ដឹង បានត្រាស់ដឹងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយក្នុងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥២ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានសម្រេចហើយ កំពុងសម្រេច បានសម្រេចនូវសោតាបត្តិផល សកទាគាមិផល អនាគាមិផល អរហត្តផល អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយក្នុងអារហត្តផល អរហត្តផល អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥៣ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា រាគៈអាត្មាបានកម្ចាត់បង់ហើយ រាគៈអាត្មាបានខ្ជាក់ចោលហើយ រាគៈអាត្មាបាន ( ធ្វើ ) ឲ្យផុតហើយ រាគៈអាត្មាបានបន្សាត់ចេញហើយ រាគៈអាត្មាបានលោះចោលហើយ រាគៈអាត្មាបានរើចោលហើយ រាគៈអាត្មាបានគាស់រំលើងហើយ ដោយអាការ

៣ យ៉ាង ត្រូវអាបត្តិបារាជិក ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ទោសៈ អាត្មាបានកម្ចាត់បង់ហើយ ។បេ។ មោហៈ អាត្មាបានកម្ចាត់បង់ហើយ បាន ខ្ជាក់ចោលហើយ បាន ( ធ្វើ ) ឲ្យផុតហើយ បានបន្សាត់ចេញហើយ បាន រលាស់ចោលហើយ បានរើចោលហើយ បានគាស់រំលើងហើយ ដោយ អាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥៤ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា ចិត្តរបស់អាត្មាមាន សេចក្តីរាំងប្រាស គឺផុតស្រឡះហើយចាករាគៈ ចិត្តរបស់អាត្មាផុតស្រឡះ ហើយចាកទោសៈ ចិត្តរបស់អាត្មាផុតស្រឡះចាកមោហៈ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។ មុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយ កុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយ រួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីយល់ឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ បិទបាំងសេចក្តី ពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

## សុទ្ធិកវារៈ ចប់

[ ២៥៥ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង កាន់ទុតិយជ្ឈានផង អាត្មាជាអ្នកបាន ហើយ ជាអ្នកស្ទាត់ជំនាញហើយ ក្នុងបឋមជ្ឈានផង ទុតិយជ្ឈានផង បឋមជ្ឈាន និងទុតិយជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ

៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង តតិយជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈានផង តតិយជ្ឈានផង បឋមជ្ឈាន និងតតិយជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ បឋមជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈានផង ចតុត្ថជ្ឈាន បឋមជ្ឈាន និងចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥៦ ]ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អត្មាអញបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង សុញ្ញតវិមោក្ខផង បឋមជ្ឈានផង អនិមិត្តវិមោក្ខផង បឋមជ្ឈានផង អប្បណិហិតវិមោក្ខផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ជំនាញហើយក្នុងបឋមជ្ឈានផង អប្បណិហិតវិមោក្ខផង បឋមជ្ឈាន និងអប្បណិហិតវិមោក្ខ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥៧ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង សុញ្ញតសមាធិផង បឋមជ្ឈានផង អនិមិត្តសមាធិផង បឋមជ្ឈានផង អប្បណិហិតសមាធិផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈានផង អប្បណិហិតសមាធិផង

បឋមជ្ឈាន និងអប្បណិហិតសមាធិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥៨ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង សុញ្ញតសមាបត្តិផង បឋមជ្ឈានផង អនិមិត្តសមាបត្តិផង បឋមជ្ឈានផង អប្បណិហិតសមាបត្តិផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈានផង អប្បណិហិតសមាបត្តិផង បឋមជ្ឈាន និងអប្បណិហិតសមាបត្តិ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៥៩ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានចូលកាន់បឋមជ្ឈានផង ត្រៃវិជ្ជាផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈាន ត្រៃវិជ្ជាផង បឋមជ្ឈាន និងត្រៃវិជ្ជា អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៦០ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង សតិប្បដ្ឋាន ៤ ផង បឋមជ្ឈានផង សម្មប្បធាន ៤ ផង បឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈានផង ឥទ្ធិបាទ ៤ ផង បឋមជ្ឈាន និងឥទ្ធិបាទ ៤ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៦១ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ

កំពុងដល់ បានដល់នូវបឋមជ្ឈានផង ឥន្ទ្រិយ ៥ ផង បឋមជ្ឈានផង ពល ៥ ផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈានផង ពល ៥ ផង បឋមជ្ឈាន និងពល ៥ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៦២ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈានផង ពោជ្ឈង្គ ៧ ផង បឋមជ្ឈាន និងពោជ្ឈង្គ ៧ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៦៣ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈានផង ក្នុងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង បឋមជ្ឈាន និងមគ្គប្រកបដោយអង្គ ៨ដ៏ប្រសើរ អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៦៤ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវបឋមជ្ឈានផង សោតាបត្តិផលផង បឋមជ្ឈានផង សកទាគាមិផលផង បឋមជ្ឈានផង អនាគាមិផលផង បឋមជ្ឈានផង អរហត្តផលផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈានផង

អរហត្តផលផង បឋមជ្ឈាន និងអរហត្តផល អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៦៥ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង ទាំងរាគៈអាត្មាក៏បានកម្ចាត់ចេញហើយ ។បេ។ អាត្មាបានចូលហើយ កាន់បឋមជ្ឈាន ។បេ។ ទាំងទោសៈអាត្មាក៏បានកម្ចាត់ចេញហើយ ។បេ។ អាត្មាបានចូលហើយ កាន់បឋមជ្ឈាន ។បេ។ ទាំងមោហៈអាត្មាក៏បានកម្ចាត់ចេញហើយ បានខ្ជាក់ចោលហើយ បានធ្វើឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានលះលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

[ ២៦៦ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក និយាយរួចហើយ ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីយល់ឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ ត្រូវអាបត្តិបារាជិក ។

**ខណ្ឌចក្ក ចប់**

[ ២៦៧ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈានផង តតិយជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងទុតិយជ្ឈានផង តតិយជ្ឈានផង ទុតិយជ្ឈាននិងតតិយជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈានផង ចតុត្ថជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងទុតិយជ្ឈានផង ចតុត្ថជ្ឈានផង ទុតិយជ្ឈាននិងចតុត្ថជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានដល់ហើយ កំពុងដល់ បានដល់នូវទុតិយជ្ឈានផង សុញ្ញតវិមោក្ខផង ទុតិយជ្ឈានផង អនិមិត្តវិមោក្ខផង ទុតិយជ្ឈានផង អប្បណិហិតវិមោក្ខផង ទុតិយជ្ឈានផង សុញ្ញតសមាធិផង ទុតិយជ្ឈានផង អនិមិត្តសមាធិផង ទុតិយជ្ឈានផង អប្បណិហិតសមាធិផង ទុតិយជ្ឈានផង សុញ្ញតសមាបត្តិផង ទុតិយជ្ឈានផង អនិមិត្តសមាបត្តិផង ទុតិយជ្ឈានផង អប្បណិហិតសមាបត្តិផង ទុតិយជ្ឈានផង ត្រៃវិជ្ជាផង ទុតិយជ្ឈានផង សតិប្បដ្ឋាន ៤ ផង ទុតិយជ្ឈានផង សម្មប្បធាន ៤ ផង ទុតិយជ្ឈានផង ឥទ្ធិបាទ ៤ ផង ទុតិយជ្ឈានផង ឥន្ទ្រិយ ៥ ផង ទុតិយជ្ឈានផង ពល ៥ ផង ទុតិយជ្ឈានផង ពោជ្ឈង្គ ៧ ផង ទុតិយជ្ឈានផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង ទុតិយជ្ឈានផង សោតាបត្តិផលផង ទុតិយជ្ឈានផង សកទាគាមិផលផង ទុតិយជ្ឈានផង

អនាគាមិផលផង ទុតិយជ្ឈានផង អរហត្តផលផង ។បេ។ អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន ទាំងរាគៈ អាត្មាក៏បានកម្ចាត់ចេញហើយ ។បេ។ ទាំងទោសៈអាត្មាក៏បានកម្ចាត់ចេញហើយ ។បេ។ ទាំងមោហៈ អាត្មាក៏បានកម្ចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន ( ធ្វើ ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន ទាំងចិត្តរបស់អាត្មាក៏បានផុតស្រឡះហើយចាករាគៈ អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន ទាំងចិត្តរបស់អាត្មា ក៏បានផុតស្រឡះហើយចាកទោសៈ អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន ទាំងចិត្តរបស់អាត្មាក៏ផុតស្រឡះហើយចាកមោហៈ ត្រូវអាបត្តិបារាជិក ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈានផង បឋមជ្ឈានផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងទុតិយជ្ឈានផង បឋមជ្ឈានផង ទុតិយជ្ឈាន និងបឋមជ្ឈាន អាត្មាបានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

## ពទ្ធចក្ក ចប់

បណ្ឌិតត្រូវធ្វើពទ្ធចក្កឲ្យមានបទផ្លាស់ប្តូរគ្នា ធ្វើតាមមូលមួយៗ ដូចន័យដែលព្រះសម្ពុទ្ធទ្រង់សម្តែងហើយនោះផងចុះ ។

# នេះជាសេចក្ដីសង្ខេប

[ ២៦៨ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកមោហៈផង អាត្មាបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈានផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង អាត្មាជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយក្នុងបឋមជ្ឈានផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ទាំងបឋមជ្ឈាន អាត្មាក៏បានធ្វើឲ្យច្បាស់លាស់ហើយ ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង អាត្មាបានចូលហើយកាន់ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង សុញ្ញតសមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង ត្រៃវិជ្ជាផង សតិប្បដ្ឋាន ៤ ផង សម្មប្បធាន ៤ ផង ឥទ្ធិបាទ ៤ ផង ឥន្ទ្រិយ ៥ ផង ពល ៥ ផង ពោជ្ឈង្គ ៧ ផង មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ដោយអាការ ៣ យ៉ាង ។បេ។ រាគៈអាត្មាបានកម្ចាត់ចេញហើយផង ។បេ។ ទោសៈអាត្មាបានកម្ចាត់ចេញហើយផង ។បេ។ ទាំងមោហៈអាត្មាបានកម្ចាត់ចេញហើយ បានខ្ជាក់ចោលហើយបាន ( ធ្វើ ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានលះបង់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ចិត្តរបស់អាត្មាបានផុត

ស្រឡះហើយចាករាគៈផង ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកទោសៈផង ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកមោហៈផង ដោយអាការ ៣ យ៉ាង ត្រូវអាបត្តិបារាជិក ។បេ។

**ចក្កមានមូល ១ ចប់ដោយសង្ខេប**

[ ២៦៩ ] ចក្កមានមូល ១ ដែលព្រះសម្ពុទ្ធទ្រង់សម្តែងដោយពិស្តារហើយយ៉ាងណា ចក្កមានមូល ២ ក្តី មានមូល ៣ ក្តី មានមូល ៤ ក្តី មានមូល ៥ ក្តី មានមូល ៦ ក្តី មានមូល ៧ ក្តី មានមូល ៨ ក្តី មានមូល ៩ ក្តី មានមូល ១០ ក្តី បណ្ឌិតត្រូវសម្តែងឲ្យពិស្តារយ៉ាងនោះផងចុះ ។

**នេះចក្កមានមូលគ្រប់ទាំងអស់ ( ដូចមានសេចក្តីតទៅនេះ )**

[ ២៧០ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា អាត្មាបានចូលហើយកំពុងចូល បានចូលកាន់បឋមជ្ឈានផង ទុតិយជ្ឈានផង តតិយជ្ឈានផង ចតុត្ថជ្ឈានផង សុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង សុញ្ញតសមាធិផង អនិមិត្តសមាធិផង អប្បណិហិតសមាធិផង សុញ្ញត-សមាបត្តិផង អនិមិត្តសមាបត្តិផង អប្បណិហិតសមាបត្តិផង ត្រៃវិជ្ជាផង សតិប្បដ្ឋាន ៤ ផង សម្មប្បធាន ៤ ផង ឥទ្ធិបាទ ៤ ផង ឥន្ទ្រិយ ៥ ផង ពល ៥ ផង ពោជ្ឈង្គ ៧ ផង មគ្គមានអង្គ ៨ ដ៏ប្រសើរផង សោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ។បេ។

រាគៈអាត្មាបានកម្ចាត់ចេញហើយផង ។បេ។ ទោសៈអាត្មាបានកម្ចាត់ចេញហើយផង ។បេ។ ទាំងមោហៈអាត្មាក៏បានកម្ចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន ( ធ្វើ ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានលះចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ចិត្តរបស់អាត្មា ផុតស្រឡះហើយ ចាករាគៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយ ចាកទោសៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយ ចាកមោហៈផង ដោយអាការ ៣ យ៉ាង ។បេ។ ដោយអាការ ៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីយល់ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ បិទបាំងសេចក្តីពិតត្រង់ ១ ត្រូវអាបត្តិបារាជិក ។

## ចក្កមានមូលគ្រប់ទាំងអស់ ចប់

## សុទ្ធិកវារកថា ចប់

[ ២៧១ ] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈាន ដូច្នេះទៅវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជា

និយាយថា អាត្មាបានចូលហើយកាន់តតិយជ្ឈានដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក ។ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយកាន់ចតុត្ថជ្ឈាន ដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយ កាន់សុញ្ញតវិមោក្ខ កាន់អនិមិត្តវិមោក្ខ កាន់អប្បណិហិតវិមោក្ខ កាន់សុញ្ញតសមាធិ កាន់អនិមិត្តសមាធិ កាន់អប្បណិហិតសមាធិ កាន់សុញ្ញតសមាបត្តិ កាន់អនិមិត្តសមាបត្តិ កាន់អប្បណិហិតសមាបត្តិ កាន់ត្រៃវិជ្ជា កាន់សតិប្បដ្ឋាន ៤ កាន់សម្មប្បធាន ៤ កាន់ឥទ្ធិបាទ ៤ កាន់ឥន្ទ្រិយ ៥ កាន់ពល ៥ កាន់ពោជ្ឈង្គ ៧ កាន់មគ្គមានអង្គ ៨ ដ៏ប្រសើរ កាន់សោតាបត្តិផល កាន់សកទាគាមិផល កាន់អនាគាមិផល កាន់អរហត្តផល ដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈាន កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា រាគៈអាត្មាបានកម្ចាត់ចេញហើយ ។បេ។

ទោសៈអាត្មាបានកម្ចាត់ចេញហើយ ។បេ។ ទាំងមោហៈ អាត្មាក៏បានកម្ចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន ( ធ្វើ ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈានកាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈ ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដូច្នេះវិញ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយដឹងខ្លួនថា អញកំពុងនិយាយកុហក លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ ដូច្នេះ បិទបាំងសេចក្តីឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។

## ខណ្ឌចក្ក នៃនិក្ខេបបទ ជាវត្ថុនិស្សារក ចប់

[ ២៧២ ] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយ កាន់ទុតិយជ្ឈានកាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយកាន់តតិយជ្ឈាន ដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នក

ស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈ ដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈានដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។

## ពទ្ធចក្កមានមូលមួយ នៃវត្ថុនិស្សារក
## និយាយពីមូល ដែលព្រះសម្ពុទ្ធសម្តែងហើយដោយសង្ខេប
## ( ដូចមានសេចក្តីតទៅនេះ )

[ ២៧៣ ] ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយ ចាកមោហៈ កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈានដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវត្រឹមអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុត

ស្រឡះហើយចាកមោហៈ កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈ ដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។

### ចក្កមានមូល ១ នៃវត្ថុនិស្សារក
### ដែលព្រះសម្ពុទ្ធសម្តែងដោយសង្ខេបចប់

[ ២៧៤ ] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈានផង ទុតិយជ្ឈានផង កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា អាត្មាបានចូលហើយកាន់តតិយជ្ឈានផង ចតុត្ថជ្ឈានផងដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈានផង ទុតិយជ្ឈានផង កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាបានផុតស្រឡះហើយចាកមោហៈដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។

### ខណ្ឌចក្កមានមូលពីរនៃវត្ថុនិស្សារក ។

[ ២៧៥ ] ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់ទុតិយជ្ឈាន

ផង កាន់តតិយជ្ឈានផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន ហើយនិយាយថា អាត្មាបានចូលហើយកាន់ចតុត្ថជ្ឈានដូច្នេះវិញដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់ទុតិយជ្ឈានផង កាន់តតិយជ្ឈានផង កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន ហើយនិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។ ភិក្ខុចង់និយាយថា អាត្មាបានចូលហើយកាន់ទុតិយជ្ឈានផង កាន់តតិយជ្ឈានផង កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន ហើយនិយាយថា អាត្មាបានចូលហើយ កាន់បឋមជ្ឈានដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។

## ពទ្ធចក្កមានមូលពីរ នៃវត្ថុនិស្សារក ។

[ ២៧៦ ] ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន ហើយនិយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈានដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ

។បេ។ ភិក្ខុចង់និយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយ ចាកទោសៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង កាលដែលនិយាយក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈដូច្នេះវិញ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិថុល្លច្ច័យ ។បេ។

ចក្កមានមូលពីរនៃវត្ថុនិស្សារកដែលព្រះសម្ពុទ្ធសំដែងដោយសង្ខេប ចប់

[ ២៧៧ ] ចក្កមានមូលមួយៗ នៃបទទាំងឡាយដែលព្រះសង្គីតិកាចារ្យបានតម្កល់ទុកហើយ បណ្ឌិតគប្បីសំដែងយ៉ាងណា ចក្កមានមូល ៣ ក្តី មានមូល ៤ ក្តី មានមូល ៥ ក្តី មានមូល ៦ ក្តី មានមូល ៧ ក្តី មានមូល ៨ ក្តី មានមូល ៩ ក្តី មានមូល ១០ ក្តី បណ្ឌិតគប្បីធ្វើយ៉ាងនោះផងចុះ ។ ( ម្យ៉ាងទៀត ) ចក្កមានមូលមួយ ព្រះសម្ពុទ្ធទ្រង់សំដែងហើយដោយពិស្តារយ៉ាងណា ( ចក្កមានមូលបីជាដើម ) បណ្ឌិតគប្បីសំដែងដោយពិស្តារយ៉ាងនោះផងចុះ ។

## នេះចក្កមានមូលគ្រប់ទាំងអស់ ( ដូចមានសេចក្តីតទៅនេះ )

[ ២៧៨ ] ភិក្ខុនិយាយថា អាត្មាបានចូលហើយកាន់បឋមជ្ឈានផង កាន់ទុតិយជ្ឈានផង កាន់តតិយជ្ឈានផង កាន់ចតុត្ថជ្ឈានផង កាន់សុញ្ញតវិមោក្ខផង កាន់អនិមិត្តវិមោក្ខផង កាន់អប្បណិហិតវិមោក្ខផង កាន់សុញ្ញតសមាធិផង កាន់អនិមិត្តសមាធិផង កាន់អប្បណិហិតសមាធិផង កាន់សុញ្ញត-

សមាបត្តិផង កាន់អនិមិត្តសមាបត្តិផង កាន់អប្បណិហិតសមាបត្តិផង កាន់ត្រៃវិជ្ជាផង កាន់សតិប្បដ្ឋាន ៤ ផង កាន់សម្មប្បធាន ៤ ផង កាន់ឥទ្ធិបាទ ៤ ផង កាន់ឥន្ទ្រិយ ៥ ផង កាន់ពល ៥ ផង កាន់ពោជ្ឈង្គ ៧ ផង កាន់មគ្គមានអង្គ ៨ ដ៏ប្រសើរផង កាន់សោតាបត្តិផលផង កាន់សកទាគាមិផលផង កាន់អនាគាមិផលផង កាន់អរហត្តផលផង រាគៈអាត្មាបានកម្ចាត់ចេញហើយផង ។បេ។ ទោសៈអាត្មាបានកម្ចាត់ចេញហើយផង ។បេ។ ទាំងមោហៈអាត្មាក៏បានកម្ចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន ( ធ្វើ ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានលះបង់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ចិត្តរបស់អាត្មាផុតស្រឡះហើយចាករាគៈផង ចិត្តរបស់អាត្មាផុតស្រឡះហើយចាកទោសៈផង កាលដែលនិយាយ ក៏និយាយកុហកដោយដឹងខ្លួន បែរជានិយាយថា ចិត្តរបស់អាត្មាផុតស្រឡះហើយចាកមោហៈផង ដូច្នេះវិញ ដោយអាការ ៣ យ៉ាង ។បេ។ ដោយអាការ ៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ និយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្ដីឃើញ ១ បិទបាំងសេចក្ដីគាប់ចិត្ត បិទបាំងសេចក្ដីពេញចិត្ត ១ បិទបាំងសេចក្ដីពិតត្រង់ ១ បើអ្នកស្ដាប់ដឹងសេចក្ដីច្បាស់ ត្រូវអាបត្តិបារាជិក បើអ្នកស្ដាប់មិនដឹងសេចក្ដីច្បាស់ទេ ត្រូវត្រឹមតែអាបត្តិថុល្លច្ច័យ ។

ចក្កបេយ្យាល នៃវត្ថុនិស្សារក ចប់

វត្ថុកាមវារកថា ចប់

[ ២៧៩ ] ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្តរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន ភិក្ខុនោះជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈាន បឋមជ្ឈាន ភិក្ខុអង្គនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយ ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្តរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន ភិក្ខុនោះជាអ្នកបានហើយ ជាអ្នកស្ទាត់ហើយ ក្នុងបឋមជ្ឈាន បឋមជ្ឈានភិក្ខុអង្គនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ដោយអាការ ៤-៥-៦-៧ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក ១ កំពុងនិយាយក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក ១ លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ ១ បិទបាំងសេចក្តីយល់ឃើញ ១ បិទបាំងសេចក្តីគាប់ចិត្ត ១ បិទបាំងសេចក្តីពេញចិត្ត ១ បិទបាំងសេចក្តីពិតត្រង់ ១ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្តរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន កាន់សុញ្ញតវិមោក្ខ កាន់អនិមិត្តវិមោក្ខ កាន់

អប្បណិហិតវិមោក្ខ កាន់សុញ្ញតសមាធិ កាន់អនិមិត្តសមាធិ កាន់អប្បណិ-ហិតសមាធិ កាន់សុញ្ញតសមាបត្តិ កាន់អនិមិត្តសមាបត្តិ កាន់អប្បណិហិ-តសមាបត្តិ កាន់ត្រៃវិជ្ជា កាន់សតិប្បដ្ឋាន ៤ កាន់សម្មប្បធាន ៤ កាន់ឥទ្ធិបាទ ៤ កាន់ឥន្ទ្រិយ ៥ កាន់ពល ៥ កាន់ពោជ្ឈង្គ ៧ កាន់មគ្គមានអង្គ ៨ ដ៏ប្រសើរ កាន់សោតាបត្តិផល កាន់សកទាគាមិផល កាន់អនាគាមិផល កាន់អរហត្តផល ភិក្ខុនោះជាអ្នកបាន ជាអ្នកស្ទាត់ក្នុងអរហត្តផល អរហត្តផលភិក្ខុអង្គនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្តរបស់អ្នក រាគៈភិក្ខុនោះបានកម្ចាត់ចេញហើយ ។បេ។ ទោសៈភិក្ខុនោះបានកម្ចាត់ចេញហើយ ។បេ។ ទាំងមោហៈក៏ភិក្ខុនោះបានកម្ចាត់ចេញហើយ បានខ្ជាក់ចោលហើយ បាន ( ធ្វើ ) ឲ្យផុតស្រឡះហើយ បានបន្សាត់ចេញហើយ បានរលាស់ចោលហើយ បានគាស់រំលើងហើយ បានរើចោលហើយ ដោយអាការ ៣ យ៉ាង បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ ។បេ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្តរបស់អ្នក ចិត្តរបស់ភិក្ខុនោះផុតស្រឡះហើយចាករាគៈ ចិត្តរបស់ភិក្ខុនោះផុតស្រឡះហើយចាកទោសៈ ចិត្តរបស់ភិក្ខុនោះផុតស្រឡះហើយចាកមោហៈ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយ

កុហក លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនិយាយកុហកដោយដឹងខ្លួនថា ភិក្ខុណានៅក្នុងវត្តរបស់អ្នក ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាន ជាអ្នកស្ទាត់ ក្នុងចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈាន ភិក្ខុអង្គនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ក្នុងផ្ទះដ៏ស្ងាត់ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិបុល្លច្ច័យ បើអ្នកស្តាប់មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ ។

[ ២៨០ ] ភិក្ខុនិយាយកុហក ដោយដឹងខ្លួនថា ភិក្ខុណាបានប្រើប្រាស់ចីវររបស់អ្នក ភិក្ខុណាបានឆាន់បិណ្ឌបាតរបស់អ្នក ភិក្ខុណាបានប្រើប្រាស់ទីសេនាសនៈរបស់អ្នក ភិក្ខុណាបានបរិភោគភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺរបស់អ្នក វត្តរបស់អ្នកដែលភិក្ខុណាបាននៅហើយ ចីវររបស់អ្នកដែលភិក្ខុណាបានប្រើប្រាស់ហើយ បិណ្ឌបាតរបស់អ្នកដែលភិក្ខុណាបានឆាន់

ហើយ ទីសេនាសនៈរបស់អ្នកដែលភិក្ខុណាបានប្រើប្រាស់ហើយ ភេសជ្ជ-បរិក្ខារជាបច្ច័យដល់មនុស្សឈឺដែលភិក្ខុណាបានបរិភោគហើយ អ្នកអាស្រ័យនឹងភិក្ខុណា ហើយបានប្រគេនវត្ថ បានប្រគេនចីវរ បានប្រគេនបិណ្ឌបាត បានប្រគេនទីសេនាសនៈ បានប្រគេនភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ភិក្ខុនោះបានចូលហើយ កំពុងចូល បានចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន កាន់ចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ភិក្ខុនោះជាអ្នកបាន ជាអ្នកស្ងាត់ ក្នុងចតុត្ថជ្ឈាន ក្នុងផ្ទះដ៏ស្ងាត់ ចតុត្ថជ្ឈាន ភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ក្នុងផ្ទះដ៏ស្ងាត់ ដោយអាការ ៣ យ៉ាង គឺមុននឹងនិយាយ ដឹងខ្លួនថា អញនឹងនិយាយកុហក កំពុងនិយាយ ក៏ដឹងខ្លួនថា អញកំពុងនិយាយកុហក លុះនិយាយរួចហើយ ក៏ដឹងខ្លួនថា អញនិយាយកុហករួចហើយ បិទបាំងសេចក្តីឃើញ បិទបាំងសេចក្តីគាប់ចិត្ត បិទបាំងសេចក្តីពេញចិត្ត បិទបាំងសេចក្តីពិតត្រង់ បើអ្នកស្តាប់ដឹងសេចក្តីច្បាស់ ត្រូវអាបត្តិថុល្លច្ច័យ បើអ្នកស្តាប់ មិនដឹងសេចក្តីច្បាស់ទេ ត្រូវអាបត្តិទុក្កដ ។

### បេយ្យាលចំនួន ១៥ ចប់

### បច្ចយប្បដិសំយុត្តវារកថា ចប់

[ ២៨១ ] ភិក្ខុនិយាយស្មានថា ខ្លួនបានមគ្គផល ១ ភិក្ខុនិយាយពីមគ្គផលដោយឥតមានប្រាថ្នានឹងពោលអួតកុហក ១ ភិក្ខុឆ្កួត ១ ភិក្ខុមានចិត្តរវើរវាយ ១ ភិក្ខុមានវេទនាគ្របសង្កត់ ១ ភិក្ខុជាខាងដើមបញ្ញត្តិ ១ ( ភិក្ខុប៉ុណ្ណោះ ) ឥតមានអាបត្តិឡើយ ។

[ ២៨២ ] ( មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសម្តែងតទៅ ដូចមានសេចក្តីខាងក្រោមនេះ )

រឿងអធិមានភិក្ខុ រឿងភិក្ខុនៅក្នុងព្រៃ រឿងភិក្ខុទៅបិណ្ឌបាត រឿងសទ្ធិវិហារិកនៃឧបជ្ឈាយ៍ រឿងពួកភិក្ខុតម្កល់ឥរិយាបថ រឿងភិក្ខុអួតថាលះសញ្ញោជនធម៌បាន រឿងភិក្ខុនៅក្នុងទីស្ងាត់ រឿងភិក្ខុនៅក្នុងវត្ត រឿងភិក្ខុដែលឧបាសកផ្គត់ផ្គង់ រឿងភិក្ខុនិយាយអួតអរហត្តផលថាគ្មានក្រ រឿងភិក្ខុព្យាយាម រឿងពួកភិក្ខុនិយាយថា អាវុសោទាំងឡាយភិក្ខុដែលមានសេចក្តីស្តាយក្រោយទើបត្រូវខ្លាចមច្ចុ រឿងពួកភិក្ខុនិយាយថា ធម៌តែបុគ្គលប្រកបព្យាយាមត្រូវហើយអាចឲ្យប្រោសប្រាណបាន រឿងភិក្ខុ ២ រូបជាអ្នកអត់ធន់វេទនា រឿងភិក្ខុ ៥ រូបដែលព្រាហ្មណ៍និមន្ត រឿងភិក្ខុ ៣ រូបនិយាយអួតអរហត្តផល រឿងភិក្ខុឃាត់បង់នូវផ្ទះ រឿងភិក្ខុឃាត់បង់កាមទាំងឡាយ រឿងភិក្ខុអ្នកត្រេកអរ រឿងភិក្ខុចៀសចេញទៅ រឿងជនពិឃាតគោ ២ នាក់ ម្នាក់កើតជាអដ្ឋិសង្ខលិកប្រេត ម្នាក់កើតជាមំសបេសីប្រេត រឿងព្រានសត្វស្លាបកើតជាមំសបិណ្ឌប្រេត រឿងអ្នកសម្លាប់សត្វចៀមកើតជានិច្ឆវិប្រេត រឿងអ្នកសម្លាប់ជ្រូកកើតជាអសិលោមប្រេត រឿងព្រានម្រឹគកើតជាសត្តិលោមប្រេត រឿងពេជ្ឈឃាតកើតជាឧសុលោមប្រេត រឿងនាយសារថីកើតជាសុចិលោមប្រេត រឿងបុរសដែលនិយាយពាក្យញុះញង់កើតជាសូចកប្រេត រឿងអមាត្យកាត់ក្តី អ្នកស្រុកវៀចកើតជាអណ្ឌភារិប្រេត រឿងអ្នកដែលធ្វើបរទារកម្មកើតជាប្រេត លិចទៅក្នុងរណ្តៅលាមក រឿងព្រាហ្មណ៍កំណាចកើតជាប្រេតស៊ីតែលាមក ជាប្រក្រតី

រឿងស្រីប្រព្រឹត្តកន្ទង់ចិត្តប្តីកើតជានិច្ចវិប្រេត រឿងស្រីមេមត់កើតជាមង្គុលីប្រេត រឿងស្រីមកកើតជាឱកិលិនីប្រេត ព្រោះចាក់ស្រោចរងើកភ្លើង លើស្រីរួមប្តី រឿងអ្នកពិឃាតចោរ កើតជាប្រេតដាច់ក្បាល រឿងភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ដែលបួសក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សប ប្រព្រឹត្តធ្វើតែបាបកម្មជាដរាប រឿងស៊ីងតបោទា រឿងចម្បាំងក្នុងក្រុងរាជគ្រឹះ រឿងដែលចុះឡើងនៃពួកដំរី រឿងសោភិតភិក្ខុជាអរហន្ត រឭកជាតិបាន ៥០០ កប្ប ។

[ ២៨៣ ] សម័យនោះ ភិក្ខុមួយរូប ពោលអួតអរហត្តផល ដោយនឹកស្មានថា ខ្លួនបានសម្រេចពិតហើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា សិក្ខាបទព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តជាស្រេចហើយ អញត្រូវអាបត្តិបារាជិកហើយដឹង ។ ភិក្ខុនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងកាលនោះឯង ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ( ដំណើរនិយាយអួតអរហត្តផល ) ដោយនឹកស្មានថា ខ្លួនបានសម្រេចពិត មិនត្រូវអាបត្តិទេ ។

[ ២៨៤ ] គ្រានោះ មានភិក្ខុមួយរូបនៅក្នុងព្រៃ ដោយតាំងចិត្តថា កាលបើអញនៅក្នុងព្រៃយ៉ាងនេះ អ្នកផងគង់នឹងសរសើរអញ ។ អ្នកផងក៏បានសរសើរភិក្ខុនោះ ( មែន ) ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយមិនត្រូវតាំងចិត្តនឹងនៅក្នុងព្រៃឲ្យគេសរសើរឡើយ ភិក្ខុណានៅ ( ដោយតាំងចិត្តយ៉ាងនោះ ) ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ សម័យនោះ

មានភិក្ខុមួយរូបដើរទៅដើម្បីបិណ្ឌបាត ដោយតាំងចិត្តថា កាលបើអញដើរទៅបិណ្ឌបាតយ៉ាងនេះ អ្នកផងនឹងសរសើរអញ ។ អ្នកផងក៏បានសរសើរភិក្ខុនោះ ( មែន ) ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយមិនត្រូវតាំងចិត្តនឹងដើរទៅបិណ្ឌបាតឲ្យគេសរសើរឡើយ ភិក្ខុណាដើរទៅ ( ដោយគិតយ៉ាងនោះ ) ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

[ ២៨៥ ] សម័យនោះឯង មានភិក្ខុមួយរូប បានពោលពាក្យនឹងភិក្ខុមួយរូបថា ម្នាលអាវុសោ ពួកភិក្ខុណាដែលជាសទ្ធិវិហារិករបស់ឧបជ្ឈាយ៍នៃយើង ភិក្ខុទាំងនោះ សុទ្ធតែជាអរហន្តទាំងអស់ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។ ក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះ ក្រាបទូលថា បពិត្រដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានប្រាថ្នានឹងអួតអាង ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះ ភិក្ខុមួយរូបបានពោលពាក្យនឹងភិក្ខុមួយរូបថា ម្នាលអាវុសោ ពួកភិក្ខុណាដែលជាអន្តេវាសិកនៃឧបជ្ឈាយ៍របស់យើង ភិក្ខុទាំងអស់នោះសុទ្ធតែជាអ្នកមានឫទ្ធិធំ មានអានុភាពច្រើន ។ ភិក្ខុនោះ ក៏មានសេចក្ដីសង្ស័យ ។ ទើបក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានបុណ្យ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត ។ ព្រះអង្គត្រាស់ថា ម្នាល

ភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២៨៦ ] សម័យនោះ មានភិក្ខុមួយរូបដើរចង្ក្រម ដោយតាំងចិត្តថា កាលបើអញចង្ក្រមយ៉ាងនេះ បណ្ដាជននឹងសរសើរអញ ។ បណ្ដាជនក៏បាន សរសើរភិក្ខុនោះ ( មែន ) ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។ ទើបក្រាប ទូលដំណើរទុំះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិន ត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយ មិនត្រូវដើរ ចង្ក្រមដោយតាំងចិត្ត ( នឹងឲ្យគេសរសើរដូច្នោះ ) ឡើយ ភិក្ខុណាដើរចង្ក្រម ( ដោយគិតយ៉ាងនោះ ) ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ សម័យនោះ មានភិក្ខុ មួយរូបឈរដោយតាំងចិត្ត ។បេ។ អង្គុយដោយតាំងចិត្ត ។បេ។ ដេកដោយ តាំងចិត្តថា កាលបើអញប្រព្រឹត្តយ៉ាងនេះ អ្នកផងនឹងសរសើរអញ ។ អ្នក ផងក៏សរសើរភិក្ខុនោះ ( មែន ) ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។ ទើប ក្រាបទូលរឿងទុំះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែអ្នកទាំងឡាយមិនត្រូវ សម្រេចឥរិយាបថដេកដោយតាំងចិត្ត ( នឹងឲ្យគេសរសើរដូច្នោះ ) ឡើយ ភិក្ខុណាសម្រេច ( ឥរិយាបថយ៉ាងនោះ ) ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

[ ២៨៧ ] សម័យនោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្សធម្ម ដល់ភិក្ខុមួយរូប ។ ភិក្ខុដែលអួតនោះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ សញ្ញោជនធម៌ទាំងឡាយ ខ្ញុំលះបង់អស់ហើយ ។ ភិក្ខុអ្នកអួតនោះក៏មានសេចក្ដី សង្ស័យ ។ បានក្រាបទូលរឿងទុំះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់

ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ២៨៨ ] សម័យនោះ មានភិក្ខុមួយរូប ទៅនៅក្នុងទីស្ងាត់ ក៏ពោលអួតឧត្តរិមនុស្សធម្ម ។ មានភិក្ខុអ្នកបានបរចិត្តវិជ្ជា គឺកិរិយាកំណត់ដឹងចិត្តរបស់អ្នកដទៃ លោកបានហាមប្រាមភិក្ខុនោះថា ម្នាលអាវុសោ លោកកុំនិយាយអួតឧត្តរិមនុស្សធម្មយ៉ាងនេះឡើយ ( ព្រោះ ) ឧត្តរិមនុស្សធម្មនុ៎ះមិនមានដល់ខ្លួនលោកទេ ។ ភិក្ខុនោះក៏មានសេចក្ដីសង្ស័យ ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ ក្នុងសម័យនោះ មានភិក្ខុមួយរូបទៅនៅក្នុងទីស្ងាត់ ហើយពោលអួតឧត្តរិមនុស្សធម្ម ។ ទេវតាបានពោលឃាត់ហាមភិក្ខុនោះថា បពិត្រលោកម្ចាស់ លោកកុំពោលអួតឧត្តរិមនុស្សធម្មយ៉ាងនេះ ( ពីព្រោះ ) ឧត្តរិមនុស្សធម្មនុ៎ះមិនទាន់មានដល់លោកទេ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ២៨៩ ] សម័យនោះ មានភិក្ខុមួយរូប បាននិយាយនឹងឧបាសកម្នាក់ថា ម្នាលអ្នកដ៏មានអាយុ ភិក្ខុណាគង់នៅក្នុងវត្តរបស់អ្នក ភិក្ខុនោះជាព្រះអរហន្ត ។ ឯភិក្ខុនោះ តែងនៅក្នុងវត្តរបស់ឧបាសកនោះ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។ ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះ ក្រាបទូល

ថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ គ្រានោះ មានភិក្ខុមួយរូបបានពោលពាក្យនេះ នឹងឧបាសកម្នាក់ថា ម្នាលអ្នកដ៏មានអាយុ អ្នកបានទំនុកបម្រុងភិក្ខុអង្គណាដោយចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សមានជំងឺ ភិក្ខុអង្គនោះជាព្រះអរហន្ត ។ ឯឧបាសកនោះក៏តែងទំនុកបម្រុងភិក្ខុនោះដោយចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សមានជំងឺ ។ ភិក្ខុនោះ ក៏មានសេចក្ដីសង្ស័យ ។ ទើបក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២៩០ ] សម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា លោកដ៏មានអាយុបានសម្រេចដល់ឧត្តរិមនុស្សធម្មហើយឬ ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ កិរិយាដែលនឹងធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល មិនមែនក្រឡើយ ។ ភិក្ខុនោះ ក៏មានសេចក្ដីសង្ស័យថា ភិក្ខុទាំងឡាយឯណា ដែលជាសាវ័ករបស់ព្រះដ៏មានព្រះភាគលោកទាំងអម្បាលនោះ ទើបគួរពោលយ៉ាងនេះ ក៏ខ្ញុំអញមិនទាន់បានជាសាវ័ករបស់ព្រះដ៏មានព្រះភាគនៅឡើយ អញប្រហែលត្រូវអាបត្តិបារាជិក

ហើយដឹង ។ ( លុះគិតដូច្នេះហើយ ) ទើបក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួតទេ ។ ទើបព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។ ក្នុងសម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា លោកដ៏មានអាយុមានឧត្តរិមនុស្សធម្មដែរឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកមានព្យាយាមប្រារព្ធហើយ រមែងញ៉ាំងព្រះធម៌ឲ្យប្រោសប្រាណបាន ។ សេចក្តីសង្ស័យក៏កើតមានដល់ភិក្ខុនោះ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងអួត មិនត្រូវអាបត្តិឡើយ ។ សម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះថា នែអាវុសោ លោកកុំគប្បីខ្លាចឡើយ ។ ភិក្ខុនោះតបថា ម្នាលភិក្ខុអាវុសោទាំងឡាយ ខ្ញុំមិនខ្លាចសេចក្តីស្លាប់ទេ ។ សេចក្តីសង្ស័យក៏កើតមានដល់ភិក្ខុនោះ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ភិក្ខុដែលមិនមានបំណងនឹងអួត មិនត្រូវអាបត្តិឡើយ ។ សម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយ បានពោលពាក្យនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកកុំខ្លាចឡើយ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ភិក្ខុណា នៅមានសេចក្តីក្តៅក្រហាយស្តាយក្រោយដោយពិតនៅឡើយ ភិក្ខុនោះ ទើបត្រូវខ្លាច ។ សេចក្តីសង្ស័យក៏កើតមានដល់ភិក្ខុនោះ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណង

នឹងពោលអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុមានឧត្តរិមនុស្សធម្មដែរឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកដែលប្រកបដោយសេចក្ដីព្យាយាមត្រូវហើយ រមែងញ៉ាំងព្រះធម៌ឲ្យប្រោសប្រាណបាន ។ ភិក្ខុនោះ ក៏មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិឡើយ ។ គ្រានោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយសួរ ភិក្ខុនោះថា លោកដ៏មានអាយុ មានឧត្តរិ-មនុស្សធម្មដែរឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកមានព្យាយាមប្រារព្ធហើយ រមែងញ៉ាំងព្រះធម៌ឲ្យប្រោសប្រាណបាន ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយសួរភិក្ខុនោះថា លោកដ៏មានអាយុ មានឧត្តរិ-មនុស្សធម្មដែរឬ ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ ធម្មតាអ្នកមានព្យាយាមប្រកបត្រូវហើយ រមែងញ៉ាំងព្រះធម៌ឲ្យប្រោសប្រាណបាន ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយ បានសួរភិក្ខុនោះថា ម្នាលអាវុសោ លោកល្មមអត់ធន់បានទេឬ លោកល្មមឲ្យប្រព្រឹត្តទៅបានឬទេ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលក្រៅការមិនអាចនឹងអត់ធន់បាន

ឡើយ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកដែលមិនមានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ មានភិក្ខុមួយរូបមានជំងឺ ។ ភិក្ខុទាំងឡាយបានសួរភិក្ខុនោះថា ម្នាលអាវុសោ លោកល្មមអត់ធន់បានទេឬ លោកល្មមឲ្យប្រព្រឹត្តទៅបានទេឬ ។ ភិក្ខុនោះតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលជាបុថុជ្ជនមិនអាចនឹងអត់ធន់បានឡើយ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ បានក្រាបទូលរឿងនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមានបំណងនឹងពោលអួត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិបារាជិកទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ២៩១ ] សម័យនោះ មានព្រាហ្មណ៍ម្នាក់បាននិមន្តពួកភិក្ខុ ហើយបានពោលពាក្យទូលថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តចូលមក ។ ភិក្ខុទាំងនោះក៏មានសេចក្ដីសង្ស័យថា យើងទាំងឡាយ មិនមែនជាព្រះអរហន្តទេ ប៉ុន្តែព្រាហ្មណ៍នេះនិយាយលើកយើងទាំងឡាយដោយពាក្យថា ព្រះអរហន្ត យើងរាល់គ្នា ត្រូវប្រតិបត្តិដូចម្ដេចហ្ន៎ ។ ទើបភិក្ខុទាំងនោះក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ពោលដោយសេចក្ដីជ្រះថ្លា មិនត្រូវអាបត្តិទេ ។ សម័យនោះ មានព្រាហ្មណ៍ម្នាក់និមន្តភិក្ខុទាំងឡាយហើយបានពោលពាក្យថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំង-

ឡាយនិមន្តគង់ ។បេ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តឆាន់ ។បេ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តឆាន់ឲ្យឆ្អែត ។បេ។ បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកជាអរហន្តទាំងឡាយនិមន្តទៅចុះ ។ ភិក្ខុទាំងនោះ ក៏មានសេចក្តីសង្ស័យថា យើងទាំងឡាយមិនមែនជាអរហន្តទេ ក៏ព្រាហ្មណ៍នេះនិយាយលើកយើងដោយពាក្យថា ព្រះអរហន្ត យើងគួរប្រតិបត្តិដូចម្តេចហ្ន៎ ។ ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ពោលដោយសេចក្តីជ្រះថ្លាមិនត្រូវអាបត្តិទេ ។

[ ២៩២ ] សម័យនោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្សធម្មចំពោះភិក្ខុមួយរូប ។ ភិក្ខុដែលពោលអួតនោះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ អាសវធម៌ទាំងឡាយ ខ្ញុំបានលះបង់អស់ហើយ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ គ្រានោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្ស-ធម្មចំពោះភិក្ខុមួយរូប ។ ភិក្ខុដែលពោលអួតនោះ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោ ក៏ឧត្តរិមនុស្សធម្មទាំងនេះ ខ្ញុំព្រះករុណាមានសព្វគ្រប់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ សម័យនោះ មានភិក្ខុមួយរូប ពោលអួតឧត្តរិមនុស្សធម្មចំពោះភិក្ខុមួយរូប ។ ភិក្ខុ

ដែលពោលអួតនោះបានពោលយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំឃើញចំពោះខ្លួនឯង ក្នុងធម៌ទាំងនោះ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ២៩៣ ] សម័យនោះ ជនទាំងឡាយជាញាតិបាននិមន្តភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន សូមលោកនិមន្តមកនៅគ្រប់គ្រងផ្ទះ ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ បុគ្គលដូចជាអាត្មា មិនគួរដើម្បីនឹងនៅគ្រប់គ្រងផ្ទះទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួតទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលគ្មានបំណងនឹងអួត មិនត្រូវអាបត្តិទេ ។ សម័យនោះ ជនទាំងឡាយជាញាតិ បាននិមន្តភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន សូមលោកនិមន្តមកបរិភោគកាមទាំងឡាយចុះ ។ ភិក្ខុនោះឆ្លើយតបថា ម្នាលអ្នកដ៏មានអាយុទាំង-ឡាយ ឯកាមទាំងឡាយ អាត្មាឃាត់រាំងរាបានហើយ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួតទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលគ្មានបំណងនឹងអួត មិនត្រូវអាបត្តិទេ ។

សម័យនោះ ជនទាំងឡាយជាញាតិ បានសួរភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ត្រេកសប្បាយដែរឬទេ ។ ភិក្ខុនោះនិយាយថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ អាត្មាត្រេកសប្បាយដែរ ( តែត្រេកសប្បាយ ) ដោយសេចក្ដីសប្បាយដ៏ឧត្ដម ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យថា ភិក្ខុទាំងឡាយណាមួយដែលជាសាវ័ករបស់ព្រះដ៏មានព្រះភាគ ភិក្ខុទាំងនោះ ទើបគួរពោលពាក្យយ៉ាងនេះបាន ក៏ខ្លួនអញមិនមែនជាសាវ័ករបស់ព្រះដ៏មានព្រះភាគទេ អញត្រូវអាបត្តិបារាជិកហើយដឹង ។ ភិក្ខុនោះ ក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្ដេច ។ ភិក្ខុនោះក៏ទូលតបថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គគ្មានបំណងនឹងពោលអួតទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកដែលគ្មានបំណងនឹងពោលអួត មិនត្រូវអាបត្តិទេ ។

[ ២៩៤ ] សម័យនោះ មានភិក្ខុច្រើនរូប នៅចាំវស្សាក្នុងអាវាសមួយ បានធ្វើកតិកា ( ណាត់គ្នា ) ថា ភិក្ខុអង្គណានឹងចេញចាកអាវាសនេះជាមុនគេ យើងទាំងឡាយនឹងដឹងថា ភិក្ខុអង្គនោះជាព្រះអរហន្ត ។ មានភិក្ខុមួយរូបចេញចាកអាវាសនោះទៅមុនគេ ដោយគិតថា ភិក្ខុទាំងនោះចូរដឹងនូវអញថាជាព្រះអរហន្តចុះ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា អញត្រូវអាបត្តិបារាជិកហើយដឹង ។ ក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។

[ ២៩៥ ] គ្រានោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់នៅក្នុងវត្តវេឡុវន-

កលន្ទកនិវាបស្ថាន ។ សម័យនោះ ព្រះលក្ខណត្ថេរ និងព្រះមហាមោគ្គល្លានត្ថេរ ដ៏មានអាយុ គង់នៅលើភ្នំគិជ្ឈកូដ ។ គ្រានោះឯង ព្រះមហាមោគ្គល្លានត្ថេរ ដ៏មានអាយុ ស្លៀកស្បង់ ទ្រង់បាត្រ និងចីវរចូលសំដៅទៅឯទីដែលព្រះលក្ខណត្ថេរគង់ ក្នុងវេលាបុព្វណ្ហសម័យ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះលក្ខណត្ថេរដ៏មានអាយុថា ម្នាលអាវុសោលក្ខណៈ មក យើងនឹងចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ។ ព្រះលក្ខណត្ថេរដ៏មានអាយុ ក៏ទទួលពាក្យព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុថា ករុណាអាវុសោ ។ គ្រាដែលព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ កំពុងតែចុះអំពីភ្នំគិជ្ឈកូដ ( ដល់មក ) ត្រង់កន្លែងមួយក៏បានធ្វើនូវញញឹមឲ្យប្រាកដ ។ លំដាប់នោះ ព្រះលក្ខណត្ថេរដ៏មានអាយុ ក៏សួរព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុថា ម្នាលអាវុសោមហាមោគ្គល្លាន អ្វីជាហេតុ អ្វីជាបច្ច័យ ចំពោះកិរិយាធ្វើនូវញញឹមឲ្យប្រាកដ ( នេះ ) ។ ព្រះមហាមោគ្គល្លានត្ថេរឆ្លើយតបថា ម្នាលអាវុសោលក្ខណៈ កាលនេះមិនមែនជាកាលគួរនឹងព្យាករប្រស្នានេះទេ លោកចូរសួរប្រស្នានេះនឹងខ្ញុំក្នុងសំណាក់ព្រះដ៏មានព្រះភាគចុះ ។ លំដាប់នោះ ព្រះលក្ខណត្ថេរដ៏មានអាយុ និងព្រះមហាមោគ្គល្លានត្ថេរដ៏មានអាយុ ក៏និមន្តទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ហើយត្រឡប់អំពីបិណ្ឌបាតក្នុងវេលាក្រោយភត្ត ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ ព្រះលក្ខណត្ថេរដ៏មានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះមហាមោគ្គល្លានដ៏

មានអាយុថា ក្នុងថ្ងៃនេះ មហាមោគ្គល្លានដ៏មានអាយុ កាលដែលចុះអំពីភ្នំគិជ្ឈកូដ បានធ្វើនូវញញឹមឲ្យប្រាកដក្នុងកន្លែងមួយ ម្នាលអាវុសោមោគ្គល្លាន អ្វីជាហេតុ អ្វីជាបច្ច័យ ចំពោះកិរិយាធ្វើនូវញញឹមឲ្យប្រាកដនោះ ។ ព្រះមហាមោគ្គល្លានត្រូវឆ្លើយតបថា ម្នាលអាវុសោ ក្នុងថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញអដ្ឋិសង្ខលិកប្រេត ( ប្រេតឥតមានសាច់ឈាមឡើយ មានតែរាងឆ្អឹង ) កំពុងតែអណ្តែតឯអាកាស ពពួកត្មាត ពពួកក្អែង ពពួករអាត ដេញតាមចោមចាបចឹកចោះ កើចជញ្ជែងអដ្ឋិសង្ខលិកប្រេតនោះ តាមចន្លោះនៃឆ្អឹងជំនីទាំងឡាយ អដ្ឋិសង្ខលិកប្រេតនោះចេះតែស្រែកថ្ងូរ ម្នាលអាវុសោ ទើបខ្ញុំមានបរិវិតក្កៈថា យីអើហ្ន៎ ( នេះហៅពេញ ) ជាអស្ចារ្យ យីអើហ្ន៎ មិនធ្លាប់កើតមានសោះឡើយ សត្វបែបនេះនឹងត្រឡប់ទៅជាមានខ្លះ តើ យក្ខបែបនេះនឹងត្រឡប់ទៅជាមានខ្លះ ប្រេតបែបនេះនឹងត្រឡប់ទៅជាមានខ្លះ កិរិយាត្រឡប់បានរូបរាងបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរតើ ។ ភិក្ខុទាំងឡាយ ទើបពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះមហាមោគ្គល្លានដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម ។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ហៅពួកភិក្ខុមក ហើយត្រាស់ប្រាប់ថា ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយមានញាណកើតពិតហើយ ព្រោះហេតុថា សាវកនឹងដឹង ឬនឹងឃើញប្រេតបែបនេះ ឬថានឹងធ្វើប្រេតបែបនេះឲ្យជាបន្ទាល់ ( របស់តថាគត ) ម្នាលភិក្ខុទាំងឡាយ សត្វនោះ តថាគតបានឃើញពីក្នុងកាលមុនរួចមកហើយ ប៉ុន្តែតថាគតមិនបាន

សម្ដែង ព្រោះថា បើតថាគតសម្ដែងទៅ ពពួកជនដទៃមិនជឿ ( ពាក្យ ) តថាគត ពពួកជនណាដែលមិនជឿតថាគត សេចក្ដីដែលមិនជឿនោះ នឹងនាំឲ្យខានបានប្រយោជន៍ នាំឲ្យបានសេចក្ដីទុក្ខអស់កាលយូរអង្វែងដល់ពពួកជនទាំងនោះ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអ្នកពិឃាតគោក្នុងក្រុងរាជគ្រឹះនេះឯង ដោយកម្មវិបាកនោះ អ្នកពិឃាតគោនោះទៅឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយពាន់សែនឆ្នាំដ៏ច្រើន ដោយសេសសល់នៃកម្មវិបាកនោះក៏ត្រឡប់មកទទួលផល គឺត្រឡប់បាននូវអត្តភាពបែបនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដបានឃើញមំសបេសីប្រេត ( ប្រេតមានរាងកាយដូចជាចម្រៀកសាច់ ) កំពុងតែអណ្ដែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោមចាបចឹកចោះ ជញ្ជែងមំសបេសីប្រេតនោះឯង មំសបេសីប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអ្នកពិឃាតគោ ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញមំសបិណ្ឌប្រេត ( ប្រេតមានរាងកាយដូចជាដុំសាច់ ) កំពុងតែអណ្ដែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោមចាបចឹកចោះ ជញ្ជែងមំសបិណ្ឌប្រេតនោះឯង មំសបិណ្ឌប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាព្រានសត្វស្លាប ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ

ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជានិច្ឆវិប្រេត ( ប្រេតមានរាងកាយរងោលឥតស្បែក ) កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែង រអាត ដេញតាមចោមចាបចឹកចោះជញ្ជែងនិច្ឆវិប្រេតនោះឯង និច្ឆ-វិប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអ្នកសម្លាប់សត្វចៀម ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាអសិលោមប្រេត ( ប្រេតមានដាវដោតជាប់នឹងរាងកាយដូចជារោម ) កំពុងតែអណ្តែតទៅឯអាកាស ដាវទាំងឡាយរបស់ប្រេតនោះ អណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់ចុះមកដោតជាប់ព្ធដ៏កាយនៃប្រេតនោះឯង អសិលោមប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអ្នកពិឃាតជ្រូកចិញ្ចឹមជីវិត ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាសត្តិលោមប្រេត ( ប្រេតមានលំពែងដោតជាប់នឹងរាងកាយដូចជារោម ) កំពុងតែអណ្តែតទៅឯអាកាស លំពែងទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់ព្ធដ៏កាយនៃប្រេតនោះឯង សត្តិលោមប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាព្រានម្រឹគ ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាឧសុលោមប្រេត ( ប្រេតមានព្រួញដោតជាប់នឹងរាងកាយដូចជារោម ) កំពុងតែអណ្តែតទៅឯ

អាកាស ព្រួញទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មក ដោតជាប់ព្ធដ៏កាយនៃប្រេតនោះឯង ឧសុលោមប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាពេជ្ឈឃាត ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាសូចិលោមប្រេត ( ប្រេតមានម្ជុលដោតជាប់នឹងរាងកាយដូចជារោម ) កំពុងតែអណ្តែតទៅឯអាកាស ម្ជុលទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់នឹងកាយរបស់ប្រេតនោះឯង សូចិលោមប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជានាយសារថី ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាសូចិលោមប្រេត ( ប្រេតមានដែកស្រួចចាក់ខ្វាស់ច្រូងច្រាងនារាងកាយដូចជារោម ) កំពុងតែអណ្តែតទៅឯអាកាស ដែកស្រួចទាំងឡាយរបស់ប្រេតនោះដោតចូលទៅតាមក្បាល ហើយធ្លាយចេញមកខាងមាត់ ដោតចូលទៅតាមមាត់ហើយធ្លាយចេញមកខាងទ្រូង ដោតចូលទៅតាមទ្រូងហើយធ្លាយចេញមកខាងពោះ ដោតចូលទៅតាមពោះ ហើយធ្លាយចេញមកតាមភ្លៅ ( ទាំងពីរ ) ដោតចូលទៅតាមភ្លៅ ( ទាំងពីរ ) ហើយធ្លាយចេញ មកខាងស្មង ( ទាំងពីរ ) ដោតចូលទៅតាមស្មង ( ទាំងពីរ ) ហើយធ្លាយចេញមកខាងជើង ( ទាំងពីរ ) សូចិលោមប្រេតនោះ ចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ( កាលពីដើម )ជាអ្នកញុះញង់គេ ក្នុងក្រុង

រាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលកើតជាកុម្ភណ្ឌប្រេត កំពុងតែអណ្តែតទៅឯអាកាស ប្រេតនោះកាលបើដើរលុះតែលើកអណ្ឌៈទាំងនោះលី ទើបដើរទៅបាន កាលបើអង្គុយ ក៏បេះតែអង្គុយសង្កត់លើអណ្ឌៈទាំងនោះឯង ពពួកត្មាតខ្លែង រអាត ដេញតាមចោមចាបចឹកចោះជញ្ជែងកុម្ភណ្ឌប្រេតនោះ បេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអមាត្យអ្នកវិនិច្ឆ័យក្តីនៃអ្នកស្រុកដោយអំពើវៀច ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលលិចចុះទាំងក្បាលទៅក្នុងរណ្តៅលាមក ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអ្នកធ្វើបរទារកម្ម ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញបុរសដែលលិចចុះទាំងក្បាលទៅក្នុងរណ្តៅលាមក ( គូថខាទិប្រេត ) កំពុងតែ ( ចាប់ ) លាមកដោយដៃទាំងពីរស៊ី ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាព្រាហ្មណ៍កំណាចក្នុងក្រុងរាជគ្រឹះនេះឯង ព្រាហ្មណ៍នោះ កាលក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប បាននិមន្តភិក្ខុសង្ឃដោយ ( ពាក្យថា និមន្តឆាន់ ) ភត្តាហារ ក៏ចាក់លាមកពេញក្នុងស្នូក រួចហើយ ប្រើគេឲ្យប្រាប់ភត្តកាលថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកម្ចាស់និមន្តឆាន់ ( ចង្ហាន់ ) ទាល់ឆ្អែតក្នុងទីនេះផង សូមនិមន្តយក ( ចង្ហាន់ ) អំពីទីនេះទៅផង ដោយកម្មវិបាកនោះ ព្រាហ្មណ៍កំណាចនោះក៏ធេះ

នៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយពាន់សែនឆ្នាំដ៏ច្រើន ដោយសំណល់នៃកម្មវិបាកនោះឯង ក៏បានមកសោយនូវផលកម្មដែលត្រឡប់បាននូវអត្តភាពបែបនេះ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញស្រីដែលកើតជានិច្ឆវិប្រេត ( ប្រេតមានរាងកាយរលាលឥតស្បែក ) កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែងរអាត ដេញតាមចោមចាបចឹកចោះជញ្ជែងនិច្ឆវិប្រេតនោះឯង និច្ឆវិប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ ស្រីនោះ ( កាលពីដើម ) ជាស្រីប្រព្រឹត្តកន្លងចិត្តប្តី ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលកំពុងចុះអំពីភ្នំគិជ្ឈកូដ បានឃើញស្រីដែលកើតជាមង្គុលីប្រេត ( ប្រេតមានរាងកាយអាក្រក់គួរខ្ពើមឆ្អើម ) មានក្លិនស្អុយ កំពុងតែអណ្តែតទៅឯអាកាស ពពួកត្មាត ខ្លែងរអាត ដេញតាមចោមចាបចឹកចោះជញ្ជែងមង្គុលីប្រេតនោះឯង មង្គុលីប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ ( កាលពីដើម ) ជាស្រីមេមត់ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញស្រីដែលកើតជាឱកិលិនីប្រេត ( ប្រេតមានរាងកាយស្រោចដោយរងើកភ្លើង ) ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន ( ក្តៅអន្ទះសា ) កំពុងតែអណ្តែតទៅឯ

អាកាស ឱកិលិនីប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ ( កាលពីដើម ) ជាអគ្គមហេសីនៃស្តេចក្នុងដែនកលិង្គ ជាស្រីមានចិត្តឫស្យា បានចាក់រងើកភ្លើងមួយអំបែងលើស្រីជាសត្រូវ ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញអសីសកពន្ធប្រេត ( ប្រេតឥតក្បាលមានរូបសណ្ឋានដូចសាកអសុភដាច់ក្បាល ) កំពុងតែអណ្តែតទៅឯអាកាស ប្រេតនោះមានភ្នែក និងមុខនៅត្រង់ទ្រូង ពពួកត្មាតខ្លែង រអាត ដេញតាមចោមចាបចឹកចោះ ជញ្ជែងនូវអសីសកពន្ធប្រេតនោះឯង ប្រេតនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអ្នកពិឃាតចោរឈ្មោះទាមរិក ក្នុងក្រុងរាជគ្រឹះនេះឯង ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុ ( ភិក្ខុប្រេត គឺប្រេតមានភេទដូចជាភិក្ខុ ) កំពុងតែអណ្តែតទៅឯអាកាស សង្ឃាដិរបស់ភិក្ខុនោះក្តី មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ វត្តពន្ធចង្កេះក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ រាងកាយរបស់ភិក្ខុនោះក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ ភិក្ខុនោះចេះតែស្រែកថ្ងូរ ។បេ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនុ៎ះ ជាភិក្ខុបាបក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ។បេ។ ម្នាលអាវុសោលក្ខណៈ ថ្ងៃនេះ ខ្ញុំកាលដែលចុះអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុនី ( ភិក្ខុនីប្រេត ) ។បេ។ បានឃើញសិក្ខមានា ( សិក្ខមានាប្រេត ) បានឃើញសាមណេរ ( សាមណេរប្រេត ) បានឃើញសាមណេរី ( សាមណេរីប្រេត ) កំពុងតែអណ្តែតទៅឯអាកាស សង្ឃាដិរបស់សាមណេរីនោះក្តី មាន

ភ្លើងឆេះភ្លឺសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ វត្តពន្ធបង្កេះក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះភ្លឺសន្ធោសន្ធៅ សាមណេរីនោះចេះតែស្រែកថ្ងូរ ម្នាលអាវុសោលក្ខណៈ ខ្ញុំក៏មានបរិវិតក្កៈថា យីអើហ្ន៎ ( នេះហៅពេញ ) ជាអស្ចារ្យ យីអើហ្ន៎ មិនដែលកើតមានសោះឡើយ សត្វបែបនេះនឹងត្រឡប់ទៅជាមានខ្វះទេតើ យក្ខបែបនេះនឹងត្រឡប់ទៅជាមានខ្វះ ប្រេតបែបនេះនឹងត្រឡប់ទៅជាមានខ្វះ កិរិយាត្រឡប់បាននូវអត្តភាពបែបនេះ ក៏សឹងមានខ្វះដែរតើ ។ ភិក្ខុទាំងឡាយក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ព្រះមហាមោគ្គល្លានដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះសាវកទាំងឡាយ មានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយមានញាណកើត ពិតហើយ ព្រោះហេតុថា សាវកនឹងដឹង ឬនឹងឃើញសាមណេរីបែបនេះ ឬថា នឹងធ្វើនូវសាមណេរីបែបនេះឲ្យជាបន្ទាល់ ម្នាលភិក្ខុទាំងឡាយ សាមណេរីនោះតថាគតបានឃើញតាំងពីក្នុងកាលមុន រួចមកហើយដែរ តែតថាគតមិនបានសម្តែងប្រាប់ ព្រោះថា បើតថាគតសម្តែងប្រាប់ទៅ ជនទាំងឡាយឯទៀត គេក៏មិនជឿ ពួកជនណាដែលមិនជឿពាក្យតថាគត សេចក្តីដែលមិនជឿនោះ នឹងនាំឲ្យបាននូវកម្មមិនមែនជាប្រយោជន៍ នឹងនាំឲ្យបានសេចក្តីទុក្ខអស់កាលយូរអង្វែងដល់ជនទាំងនោះ ម្នាលភិក្ខុទាំងឡាយ សាមណេរីនុ៎ះជាសាមណេរីបាប ក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប ដោយកម្មវិបាកនោះ សាមណេរីនោះឆេះនៅ

ក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺថា អស់រយ-ពាន់-សែនឆ្នាំដ៏ច្រើន ដោយសំណល់នៃកម្មវិបាកនោះ ទើបបានមកសោយផលកម្មដែលត្រឡប់បាននូវអត្តភាពបែបនេះ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំង-ឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។

[ ២៩៦ ] គ្រានោះ ព្រះមហាមោគ្គលានដ៏មានអាយុ ហៅភិក្ខុទាំង-ឡាយមកហើយនិយាយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ស្ទឹងតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះ មានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ដ៏ល្អ គួរជាទីរីករាយ មានត្រី និងអណ្តើកដ៏ច្រើន មានទាំងផ្កាឈូកប៉ុនៗ កង់ ( នៃរថ ) រីកស្គុះស្គាយ តែថា ស្ទឹងតបោទានេះ មានទឹកក្តៅហូរមក ។ ភិក្ខុទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ហេតុអ្វីព្រះមហាមោគ្គល្លានពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ស្ទឹងតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះ មានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ដ៏ល្អ គួរជាទីរីករាយ មានត្រី និងអណ្តើកដ៏ច្រើន មានទាំងផ្កាឈូកប៉ុនៗ កង់ ( នៃរថ ) រីកស្គុសស្គាយ តែថា ស្ទឹងតបោទានេះមានទឹកក្តៅហូរមក ព្រះមហាមោគ្គល្លានដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម ( ទេតើ ) ។ ទើបក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្ទឹងតបោទានេះហូរមកអំពីអន្លង់ទឹកណា អន្លង់នោះមានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ដ៏ល្អ គួរជាទីរីករាយ មានត្រី និងអណ្តើកដ៏ច្រើន មានទាំងផ្កាឈូកប៉ុនៗ កង់( នៃរថ ) រីកស្គុស-

ស្គាយ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្ទឹងតបោទានេះ មកតាមចន្លោះនៃមហានរក ទាំងពីរ ព្រោះហេតុនោះ បានជាស្ទឹងតបោទានេះ មានទឹកក្តៅហូរមក ម្នាល ភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លាន មិនត្រូវអាបត្តិទេ ។

[ ២៩៧ ] សម័យនោះ ព្រះរាជាទ្រង់ព្រះនាមពិម្ពិសារ ជាឥស្សរៈក្នុង ដែនមគធៈ ជាអធិបតីលើសេនា កំពុងតែ តសង្គ្រាមជាមួយនឹងពពួកស្តេច លិច្ឆវី ក៏ទ្រង់បាក់ទ័ព ( បរាជ័យ ) ។ លុះកាលជាខាងក្រោយមក ព្រះ-រាជាទ្រង់ត្រាស់ឲ្យកេណ្ឌប្រមូលពួកសេនា ហើយទ្រង់ផ្ចាញ់ពពួកស្តេចលិច្ឆវី បានវិញ ។ ស្តេចក៏ទ្រង់ឲ្យទូងវិជយភេរីទៅក្នុងទីសង្គ្រាមដោយប្រកាសសេចក្តី ថា ពពួកស្តេចលិច្ឆវី ព្រះរាជាទ្រង់ឲ្យបាក់ទ័ព ( បរាជ័យ ) បានហើយ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានហៅពួកភិក្ខុមកហើយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ព្រះបាទពិម្ពិសារទ្រង់ផ្ចាញ់ពួកស្តេចលិច្ឆវីបានហើយ ទើបទ្រង់ឲ្យទូងវិជយភេរីទៅក្នុងទីសង្គ្រាម ដោយប្រកាសសេចក្តីថា ពពួក ស្តេចលិច្ឆវីព្រះរាជាទ្រង់ឲ្យបាក់ទ័ព ( បរាជ័យ ) បានហើយ ។ ភិក្ខុទាំង-ឡាយក៏ពោលទោសតិះដៀល បន្ទុះបន្អាប់ថា ហេតុអ្វីក៏ព្រះមហាមោគ្គល្លាន ពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះបាទពិម្ពិសារទ្រង់ផ្ចាញ់ពួក ស្តេចលិច្ឆវីបានហើយ ក៏ទ្រង់ឲ្យទូងវិជយភេរីទៅក្នុងទីសង្គ្រាមដោយប្រកាស សេចក្តីថា ពពួកស្តេចលិច្ឆវីព្រះរាជាទ្រង់ឲ្យបាក់ទ័ព ( បរាជ័យ ) បានហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម ( ទេតើ ) ។ ភិក្ខុ ទាំងនោះក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ព្រះបាទពិម្ពិសារទ្រង់បាក់ទ័ព ( បរាជ័យចាញ់ ) ពួកស្តេចលិច្ឆវីជាន់ដំបូង លុះកាលជាខាងក្រោយ ស្តេចទ្រង់ឲ្យកេណ្ឌប្រមូលពួកសេនាបាន ទើបផ្ចាញ់ពួកស្តេចលិច្ឆវីបានវិញ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។

[ ២៩៨ ] គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកហើយ ប្រាប់ថា ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំបានចូលសមាធិឥតមានកម្រើកប្រែប្រួល ទៀបឆ្នេរស្ទឹងឈ្មោះសប្បិនិកា បានឮសូរសម្រែកដំរីទាំងឡាយដែលកំពុងតែចុះឡើងស្រែកបន្លឺកោញ្ចនាទ ។ ភិក្ខុទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ហេតុអ្វី បានជាព្រះមហាមោគ្គល្លានដ៏មានអាយុពោលយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ថ្ងៃនេះ ខ្ញុំបានចូលសមាធិឥតមានកម្រើកប្រែប្រួល ទៀបឆ្នេរស្ទឹងសប្បិនិកា បានឮសូរសម្រែកដំរីទាំងឡាយ ដែលកំពុងចុះឡើងស្រែកបន្លឺកោញ្ចនាទ ព្រះមហាមោគ្គល្លានដ៏មានអាយុពោលអួតឧត្តរិមនុស្សធម្ម ( ទេតើ ) ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមាធិនុ៎ះមាន ប៉ុន្តែសមាធិនុ៎ះមិនបរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ ។

[ ២៩៩ ] គ្រានោះ ព្រះសោភិតត្ថេរដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកហើយនិយាយប្រាប់ថា ម្នាលអាវុសោទាំងឡាយ ខ្ញុំរឭកជាតិបានប្រមាណ ៥០០ កប្ប ។ ភិក្ខុទាំងឡាយក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ហេតុអ្វី បានជាព្រះសោភិតត្ថេរដ៏មានអាយុពោលយ៉ាងនេះថា ម្នាលអាវុសោទាំង-

ឡាយ ខ្ញុំរឭកជាតិបានប្រមាណ ៥០០ កប្ប ព្រះសោភិតត្រូវដ៏មានអាយុ ពោលអួតឧត្តរិមនុស្សធម្ម ( ទេតើ ) ទើបក្រាបទូលសេចក្ដីនុ៎ះចំពោះ ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុរឭកជាតិបានមែន តែថា រឭកបានត្រឹមតែជាតិ ១ ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុពោលនូវពាក្យពិត ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុមិនត្រូវអាបត្តិទេ ។

## បារាជិកទី ៤ ចប់

[ ៣០០ ] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះបារាជិកទាំង ៤ ដែលខ្ញុំបានសម្ដែងហើយនេះ បណ្ដាអាបត្តិទាំង ៤ នុ៎ះ ភិក្ខុណាត្រូវអាបត្តិណាមួយហើយ ក៏មិនបាននូវកិរិយានៅរួបរួមជាមួយនឹងភិក្ខុទាំងឡាយឡើយ ភិក្ខុនោះ ជាបារាជិករកសំវាសគ្មាន កាលពីមុនយ៉ាងណាមិញ ខាងក្រោយក៏ដូច្នោះដែរ ។ ខ្ញុំព្រះករុណា សូមសួរលោកដ៏មានអាយុទាំងឡាយក្នុងអាបត្តិបារាជិកទាំង ៤ នោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំព្រះករុណាសូមសួរគម្រប់ពីរដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំព្រះករុណាសូមសួរគម្រប់ ៣ ដងទៀត លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងបារាជិកាបត្តិទាំង ៤ នុ៎ះ ព្រោះហេតុដូច្នោះ បានជាស្ងៀម ។ ខ្ញុំព្រះករុណាដឹងថា លោកទាំងឡាយបរិសុទ្ធហើយ ដោយដែលស្ងៀមយ៉ាងនេះ ។

បារាជិកកណ្ឌ ចប់

# អដ្ឋកថា
## ឧត្តរិមនុស្សធម្មសិក្ខាបទវណ្ណនា
## រឿង ពួកភិក្ខុនៅទៀបច្រាំងវគ្គុមុទា

ព្រះសាស្តា ទ្រង់ជ្រាបច្បាស់អរិយសច្ចទាំង ៤ ទ្រង់ប្រកាសចតុត្ថបារាជិកណាទុកហើយ ឥឡូវនេះ មកដល់លំដាប់នៃការពិពណ៌នាចតុត្ថបារាជិកនោះហើយ ព្រោះហេតុនោះ ពាក្យណាដែលគប្បីដឹងបានងាយ និងពាក្យដែលខ្ញុំបានប្រកាសហើយខាងដើម ការពិពណ៌នានៃចតុត្ថបារាជិកនេះ វៀរពាក្យនោះចេញ ។

[ ២២៧ ] ពាក្យថា **តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ ។បេ។ គិហីនំ កម្មន្តំ អធិដ្ឋេម** សេចក្តីថា ពួកយើងចូរទទួលរ៉ាប់រងការងារដែលគួរធ្វើក្នុងស្រែ និងក្នុងចម្ការជាដើមរបស់ពួកគ្រហស្ថចុះ ។ មានពាក្យអធិប្បាយថា ពួកយើងចូរប្រាប់ និងចូរប្រៀនប្រដៅថា ពួកលោកគួរធ្វើយ៉ាងនេះ មិនគួរធ្វើយ៉ាងនេះ ។

បទថា **ទូតេយ្យំ** បានដល់ ការងាររបស់ទូត ។

បទថា **ឧត្តរិមនុស្សធម្មស្ស** បានដល់ ធម៌ដែលកន្លងហួសពួកមនុស្សទៅ អធិប្បាយថា ធម៌ដែលកន្លងហួសពួកមនុស្សទៅ ឲ្យសម្រេចភាពជាព្រហ្ម ឬព្រះនិព្វាន ។ ម្យ៉ាងទៀត បានដល់ ធម៌របស់មនុស្សដ៏កំពូល គឺបុរសដែលប្រសើរបំផុត ដែលជាអ្នកបានឈាន និងជាព្រះអរិយៈ ។

ក្នុងពាក្យថា **អសុកោ ភិក្ខុ** ជាដើម មានវិនិច្ឆ័យដូច្នេះថា ភិក្ខុទាំង-

ឡាយប្រឹក្សាគ្នាយ៉ាងនេះហើយ ក្រោយមក កាលពោលដល់ពួកគ្រហស្ថ គប្បីជ្រាបថា បានពោលសរសើរដោយអំណាចនៃឈ្មោះនោះឯង យ៉ាងនេះថា ភិក្ខុឈ្មោះពុទ្ធរក្ខិត បានបឋមជ្ឈាន ឈ្មោះធម្មរក្ខិតបានទុតិយជ្ឈានជាដើម ។

បណ្តាបទទាំងនោះ បទថា **ឯសោយេវ ខោ អាវុសោ សេយ្យោ** សេចក្តីថា ការជួយទទួលរ៉ាប់រងការងារ និងការនាំដំណឹងទៅ ដោយភាពជាទូត មានសត្រូវច្រើន មានការប្រកួតប្រជែងច្រើន ទាំងជារបស់មិនគួរដល់សមណៈ ចំណែកការដែលពួកយើងនាំគ្នាពោលសរសើរឧត្តរិមនុស្សធម្មនៃគ្នានិងគ្នា ដល់ពួកគ្រហស្ថនេះឯង ជារបស់ដែលគួរសរសើរជាង គឺឧត្តមក្រៃលែងជាង បានដល់ ល្អជាងកិច្ចទាំងពីរនោះ ។ លោកពោលអធិប្បាយទុកដូចម្តេច លោកពោលទុកថា ការដែលពួកយើងនាំគ្នាពោលសរសើរឧត្តរិមនុស្សធម៌នៃគ្នានិងគ្នាដល់ពួកគ្រហស្ថ ដែលសួរក្តី អ្នកមិនបានសួរក្តី ដល់ភិក្ខុដែលអង្គុយស្នាក់នៅក្នុងឥរិយាបថ មានជាដើមយ៉ាងនេះថា ភិក្ខុឈ្មោះនោះបានបឋមជ្ឈាន បឋមជ្ឈាននេះឯងប្រសើរបំផុត ។

កាលការសម្ពន្ធដោយកិរិយាអនាគតមិនមាន ភិក្ខុទាំងនោះនឹងពោលសរសើរគុណនោះ ក្នុងខណៈនោះមិនបានឡើយ ។ ព្រោះហេតុនោះ អត្ថដែលលោកមិនបានរចនា បាឋៈដ៏សេស ពោលទុកថា **ភាសិតោ ភវិស្សតិ** ទើបមិនត្រឹមត្រូវ ព្រោះដូច្នោះ ក្នុងបទថា **ភាសិតោ** នេះ បណ្ឌិតគួរធ្វើឲ្យមានការសម្ពន្ធដោយកិរិយាអនាគត ហើយគប្បីជ្រាបអត្ថយ៉ាងនេះថា គុណឯណាជារបស់ដែលពួកយើងពោលអួតយ៉ាងនោះ គុណយ៉ាងនោះ ត្រូវប្រសើរ

បំផុត ។ អ្នកសិក្សាគួរស្វែងរកលក្ខណៈអំពីគម្ពីរសព្ទសាស្ត្រ ។

ពីរបទថា **វណ្ណវន្តោ អហេសុំ** សេចក្តីថា ពណ៌សម្បុរនៃសរីរៈដែលថ្មីដទៃនោះឯង កើតឡើងដល់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះបានជាបុគ្គលបរិបូណ៌ដោយវណ្ណៈនោះ ។

បទថា **បីណិន្ទ្រិយា** សេចក្តីថា ជាអ្នកមានឥន្ទ្រិយពេញលេញ ដោយភាពដែលឥន្ទ្រិយទាំងឡាយ មានចិត្តជាគម្រប់ ៦ មិនស្វិតស្រពោន ព្រោះឱកាសដែលបសាទទាំង ៥ តាំងមាំ ជារបស់បរិបូណ៌ ។

បទថា **បសន្នមុខវណ្ណា** សេចក្តីថា ជាអ្នកមានពណ៌សម្បុរដោយមិនប្លែកគ្នា សូម្បីដូច្នោះ សម្បុរមុខរបស់ភិក្ខុទាំងនោះ ក៏ផូរផង់ពន់ពេកជាងពណ៌នៃសរីរៈ ។ អធិប្បាយថា ផូរផង់មិនសៅហ្មង គឺបរិសុទ្ធ ។

បទថា **វិប្បសន្នច្ឆវិវណ្ណា** សេចក្តីថា ភិក្ខុទាំងនោះ ជាអ្នកមានពណ៌សម្បុរដោយវណ្ណៈណា ហាក់ដូចជាផ្កាកណិការ ពណ៌សម្បុរដូច្នោះរបស់មនុស្សទាំងឡាយដទៃក៏មាន ដូចជា ( វណ្ណៈដូច្នោះ ) របស់មនុស្សទាំងនេះ យ៉ាងណា របស់ភិក្ខុទាំងនោះ មិនជាយ៉ាងនោះ គឺពណ៌សម្បុររបស់ភិក្ខុទាំងនោះ ផូរផង់ ព្រោះហេតុនោះ ទើបធម្មសង្គាហកាចារ្យទាំងឡាយពោលថា មានពណ៌សម្បុរផូរផង់ ។ ដោយប្រការយ៉ាងនេះឯង ភិក្ខុទាំងនោះមិនព្យាយាមប្រកបឧទ្ទេស និងបរិបុច្ឆាឡើយ ទាំងមិនព្យាយាមប្រកបកម្មដ្ឋានផងដែរ ដោយពិតនោះ កាលឆាន់ភោជនដ៏ប្រណីត ដែលបានមកដោយការពណ៌នាគុណ ដែលមិនពិត ជាការភូតកុហក តាមប្រកបនូវភាពជាបុគ្គល

ត្រេកអរក្នុងការដេកលក់តាមសប្បាយ និងដោយភាពជាអ្នកត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកគណៈ ទើបដល់នូវភាពសោភាតាមសរីរៈនេះ មានចំណែកប្រៀបដូចពាឡម្រឹគយង់ឃ្នង ដូច្នេះឯង ។

[ ២២៨ ] បទថា **វគ្គុមុទាតីរិយា** បានដល់ ពួកភិក្ខុដែលនៅអាស្រ័យត្រង់ច្នេរស្ទឹងវគ្គុមុទា ។

ពាក្យថា **កច្ចិ ភិក្ខវេ ខមនីយំ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ សរីរយន្តនេះរបស់ពួកអ្នក មានចក្រ ៤ មានទ្វារ ៩ ល្មមអត់ធន់បានដែរឬ គឺពួកអ្នកអាចដើម្បីអត់សង្កត់ ដើម្បីបរិហារបានដែរឬ សរីរយន្តរបស់ពួកអ្នក មិនឲ្យទុក្ខណាមួយកើតឡើងខ្លះទេឬ ។

បទថា **កច្ចិ យាបនីយំ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ពួកអ្នកអាចឲ្យសរីរយន្តប្រព្រឹត្តទៅ គឺឲ្យដំណើរទៅក្នុងកិច្ចទាំងពួងបានដែរឬ សរីរយន្តរបស់ពួកអ្នក មិនសម្តែងអន្តរាយណាខ្លះទេឬ ។

[ ២២៩ ] ពីរបទថា **កុច្ឆិ បរិកន្តោ** សេចក្តីថា ពោះដែលអ្នកវះហើយ គប្បីជារបស់ល្អជាង ។ បាឋៈថា **កុច្ឆិ បរិកន្តោ** ដូច្នេះក៏ប្រើបាន ។

## មហាចោរ ៥ ពួក

[ ២៣០ ] គ្រានោះឯង ព្រះមានព្រះភាគ កាលទ្រង់តិះដៀលពួកភិក្ខុដែលនៅត្រង់ច្រាំងស្ទឹងវគ្គុមុទាដោយអនេកបរិយាយយ៉ាងនេះហើយ ឥឡូវនេះ ទើបត្រាស់ហៅភិក្ខុទាំងឡាយមក ។ កាលត្រាស់ហៅមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាចោរ ៥ ពួកនេះជាដើម ដើម្បីមិនឲ្យភិក្ខុ

ដទៃធ្វើកម្មដែលមានសភាពបែបនោះតទៅ ព្រោះកម្មដែលពួកភិក្ខុនៅត្រង់មាត់ស្ទឹងវគ្គុមុទាទាំងនោះធ្វើ ចាត់ជាចោរកម្ម ។

បណ្ដាបទទាំងនោះ ពីរបទថា **សន្តា សំវិជ្ជមានា** មានពាក្យអធិប្បាយថា មាន និងរកបាន ។

បទថា **លោក** គឺ ក្នុងសត្វលោកនេះ ។

ពីរបទថា **ឯវំ ហោតិ** សេចក្ដីថា សេចក្ដីប្រាថ្នាខាងដើម រមែងកើតឡើងយ៉ាងនេះ ។ សព្ទថា **សុ** ក្នុងបទថា **កុទាស្សុ នាមាហំ** នេះ ជានិបាត សេចក្ដីថា កាលណាហ្ន៎ ។

បទថា **សោ អបរេន សមយេន** សេចក្ដីថា មហាចោរនោះ កាលគិតក្នុងចំណែកខាងដើមយ៉ាងនោះហើយ ក៏ប្រមូលបរិស័ទដោយលំដាប់ ធ្វើកម្មជាដើមយ៉ាងនេះ គឺកម្មជាហេតុប្រទូសរ៉ាយអ្នកដំណើរ ប្លន់អ្នកមានក្នុងស្រុក ដែលតាំងនៅក្នុងជាយដែន ជាបុរសដែលដល់នូវការចម្រើនបរិបូណ៌ហើយ ធ្វើស្រុកមិនឲ្យជាស្រុកខ្លះ ធ្វើជនបទមិនឲ្យជាជនបទខ្លះ សម្លាប់ឯងខ្លះ ឲ្យអ្នកដទៃសម្លាប់ខ្លះ កាត់ឯងខ្លះ ឲ្យអ្នកដទៃកាត់ខ្លះ ដុតកម្ទេចឯងខ្លះ ឲ្យអ្នកដទៃដុតខ្លះ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងចោរខាងក្រៅយ៉ាងនេះហើយ ទើបត្រាស់ថា **ឯវមេវ ខោ** ជាដើម ដើម្បីទ្រង់សម្ដែងមហាចោរ ៥ ពួក ក្នុងសាសនា ដែលដូចជាចោរខាងក្រៅនោះ ។

បណ្ដាបទទាំងនោះ បទថា **ឥធេកច្ចស្ស ភិក្ខុនោ** សេចក្ដីថា ក្នុងទីដទៃៗ ភិក្ខុ

ត្រូវអាបត្តិបារាជិក មានឫសគល់ដាច់ហើយ លោកហៅថា បាបភិក្ខុ ។ ឯក្នុងសិក្ខាបទនេះ ភិក្ខុមិនបានត្រូវបារាជិក តែតាំងនៅក្នុងឥច្ឆាចារ ត្រាច់ញាំញីសិក្ខាបទតូចធំ លោកបំណងយកថា ជាបាបភិក្ខុ ។ សេចក្តីប្រាថ្នាក្នុងចំណែកខាងដើមរមែងកើតឡើងដល់បាបភិក្ខុនោះ ដូចកើតឡើងដល់មហាចោរខាងក្រៅ យ៉ាងនេះថា កាលណាហ្ន៎ អញនឹងជាអ្នកដែល ភិក្ខុ ១០០ ឬ ១០០០ ចោមរោមហើយ ត្រាច់ចារិកទៅក្នុងគាមនិគម និងរាជធានី ដែលគ្រហស្ថ និងបព្វជិតធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរបិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។

បណ្តាបទទាំងនោះ បទថា **សក្កតោ** បានដល់ ដែលជួបសក្ការៈ ។

បទថា **គរុកតោ** បានដល់ ដែលបានទទួលសេចក្តីគោរព ។

បទថា **មានិតោ** បានដល់ បុគ្គលដែលគេស្រឡាញ់ដោយទឹកចិត្ត ។

បទថា **បូជិតោ** បានដល់ បុគ្គលដែលគេបូជាហើយ ដោយការបូជាគឺនាំមកចំពោះនូវបច្ច័យទាំង ៤ ។

បទថា **អបចិតោ** បានដល់ ដែលសម្រេចសេចក្តីកោតក្រែង ។ បណ្តាបុគ្គលទាំងនោះ ជនទាំងឡាយធ្វើសក្ការៈដោយបច្ច័យ ៤ គឺធ្វើបច្ច័យ ៤ ដែលរៀបចំទុកយ៉ាងល្អ ឲ្យប្រណីតៗ ហើយទើបប្រគេនដល់ភិក្ខុអង្គណាភិក្ខុអង្គនោះ ឈ្មោះថា ដែលគេធ្វើសក្ការៈហើយ ។ ជនទាំងឡាយឲ្យសេចក្តីគោរព ចូលទៅតាំងនៅចំពោះក្នុងភិក្ខុអង្គណា ហើយទើបប្រគេន ភិក្ខុអង្គនោះ ឈ្មោះថា ដែលគេគោរពហើយ ។ ជនទាំងឡាយ រមែងស្រឡាញ់ភិក្ខុ

អង្គណាដោយចិត្ត ភិក្ខុអង្គនោះ ឈ្មោះថា ដែលគេរាប់អានហើយ ។ ជនទាំងឡាយរមែងធ្វើកិច្ច មានសក្ការៈជាដើមទាំងនោះ ដល់ភិក្ខុអង្គណា ភិក្ខុអង្គនោះ ឈ្មោះថា ដែលគេបូជាហើយ ។ ជនទាំងឡាយ រមែងធ្វើការនមស្ការយ៉ាងក្រៃលែង ដោយអំណាចនៃកិច្ច មានការថ្វាយបង្គំ ក្រោកទទួល និងប្រណម្យអញ្ជលីជាដើមដល់ភិក្ខុអង្គណា ភិក្ខុអង្គនោះ ឈ្មោះថា ដែលគេកោតក្រែងហើយ ។ ឯសេចក្តីប្រាថ្នាយ៉ាងនេះ រមែងមានដល់ភិក្ខុលាមកនេះ ដែលប្រាថ្នានូវលោកាមិសទាំងអស់នេះ ។

បទថា **សោ អបរេន សមយេន** សេចក្តីថា បាបភិក្ខុនោះ កាលគិតក្នុងចំណែកខាងដើមយ៉ាងនោះហើយ សង្គ្រោះបាបភិក្ខុ ដែលមិនមានសេចក្តីគោរពខ្លាំងក្លាក្នុងសិក្ខា រាយមាយ ច្រើនថ្ងៃ ញាប់ញ័រ មាត់រឹង និយាយរាយមាយ គ្មានស្មារតី មិនមានសម្បជញ្ញៈ មានឥន្ទ្រិយបើក ( គឺមិនសង្រួមឥន្ទ្រិយ ) ដែលអាចារ្យ និងឧបជ្ឈាយ៍លះបង់ហើយ ជាអ្នកជូនក្នុងលាភដោយលំដាប់ ហើយឲ្យសិក្សាទំនៀមរបស់បុគ្គលបោកបញ្ឆោតទាំងឡាយ មានការដាក់ចុះនូវអាកប្បកិរិយាជាដើម ជាអ្នកមានគុណដែលពួកបាបភិក្ខុធ្វើការសន្សំក្នុងនិទានជាតកជាដើម បរិបូណ៌ដោយក្រសែសំឡេង អាចបោកបញ្ឆោតពួកអ្នកស្រុក សរសើរដោយឧបាយទាំងឡាយ មានការពណ៌នាដល់សេនាសនៈ ដែលសត្វលោកសន្មតជាដើមយ៉ាងនេះថា ព្រះថេរៈអង្គនេះចាំវស្សាក្នុងសេនាសនៈឈ្មោះនោះ បំពេញវត្តបដិបត្តិ ចេញវស្សាហើយនឹងចេញទៅ ជាបុគ្គលដែលភិក្ខុ ១០០ ឬ ១០០០ ចោមរោម ត្រាច់ចារិកទៅ

ទៅក្នុងគាមនិគម និងរាជធានីដែលគ្រហស្ថ និងបព្វជិតធ្វើសក្ការៈ គោរព រាប់អាន បូជាកោតក្រែង បានចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។

បទថា **អយំ ភិក្ខវេ បឋមោ មហាចោរោ** សេចក្ដីថា បាបភិក្ខុ ដូចជាចោរដែលកាត់ទីតជាដើមនេះ គប្បីជ្រាបថា ជាមហាចោរពួកទី ១ ព្រោះមិនមែនបោកបញ្ឆោត ១ ត្រកូលឬ ២ ត្រកូលប៉ុណ្ណោះឡើយ ដោយពិតបោកបញ្ឆោតមហាជន កាន់យកបច្ច័យ ៤ ផងដែរ ។ ភិក្ខុពួកណាដែលជំនាញក្នុងព្រះសូត្រ ជំនាញក្នុងព្រះអភិធម្ម ឬទ្រទ្រង់ព្រះវិន័យ កាលភិក្ខាមិនសម្បូរ ត្រាច់ចារិកទៅតាមជនបទ ប្រាប់បាលី ពោលអដ្ឋកថា ញុំាងសត្វលោកឲ្យជ្រះថ្លា អនុមោទនាដោយធម្មកថា និងដោយការសង្រួមនៃអាកប្បកិរិយា ភិក្ខុទាំងនោះ មហាជនធ្វើសក្ការៈ គោរព រាប់អាន បូជាកោតក្រែងហើយ គប្បីជ្រាបថា ជាអ្នកញុំាងសាសនាឲ្យរុងរឿង បន្តលំអាននិងបវេណី ។

បទថា **តថាគតប្បវេទិតំ** សេចក្ដីថា ដែលព្រះតថាគតត្រាស់ដឹងហើយ គឺធ្វើឲ្យប្រចក្សហើយផង ញុំាងអ្នកដទៃឲ្យដឹងហើយផង ។

ពីរបទថា **អត្តនោ ឧហាតិ** សេចក្ដីថា បាបភិក្ខុ ប្រៀបធៀបបាលីនិងអដ្ឋកថានៅក្នុងចំណោមបរិស័ទ ពោលព្រះសូត្រដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ដោយសំឡេងដ៏ពីរោះ ត្រូវវិញ្ញូជនដែលកើតមានសេចក្ដីអស្ចារ្យក្នុងចិត្ត សាកសួរក្នុងទីបំផុតនៃធម្មកថាថា ឱ លោកដ៏ចម្រើន បាលី និង

អដ្ឋកថាបរិសុទ្ធ លោកម្ចាស់រៀនយកក្នុងសម្នាក់នៃបុគ្គលណា ដូច្នេះ ពោលថា បុគ្គលណាអាចឲ្យមនុស្សដូចអាត្មារៀន ហើយមិនប្រាប់ឈ្មោះអាចារ្យ ប្រកាសធម្មវិន័យដែលខ្លួនត្រាស់ដឹងឯង គឺដែលខ្លួនបានសម្រេចដោយសយម្ភូញាណ ។ ភិក្ខុលួចធម៌ដែលព្រះតថាគត ទ្រង់បំពេញបារមីអស់ ៤ អសង្ខេយ្យ កម្រៃមួយសែនកប្ប បានត្រាស់ដឹងដោយសែនលំបាកនេះ ចាត់ជាមហាចោរពួកទី ២ ។

បទថា **សុទ្ធំ ព្រហ្មចារឹ** បានដល់ ភិក្ខុដែលអស់អាសវៈហើយ ។

ពាក្យថា **បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តំ** បានដល់ សព្រហ្មចារី ដែលប្រព្រឹត្តចរិយាដ៏ប្រសើរ មិនមានឧបក្កិលេស ។ ម្យ៉ាងទៀត បានដល់ អ្នកប្រព្រឹត្តព្រហ្មចរិយៈដ៏បរិសុទ្ធ ដែលជាទីតាំងនៃការមិនក្តៅក្រហាយជាដើមដទៃទៀត តាំងអំពីព្រះអនាគាមី ដរាបដល់បុថុជ្ជនអ្នកមានសីល ។

បទថា **អមូលកេន ព្រហ្មចរិយេន អនុទ្ធំសេតិ** សេចក្តីថា បាបភិក្ខុរមែងពោលរក គឺចោទដោយអន្តិមវត្ថុ ដែលមិនមាននៅក្នុងបុគ្គលនោះ ។ ភិក្ខុលុបគុណដែលមាន លួចអរិយគុណនេះ ចាត់ជាមហាចោរពួកទី ៣ ។

ក្នុងពីរបទថា **គរុភណ្ឌានិ គរុបរិក្ខារានិ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ក្នុងអទិន្នាទានសិក្ខាបទ កណ្ឌៈមានតម្លៃ ៥ មាសក លោកហៅថា គរុ-ភណ្ឌ ក្នុងពាក្យថា បុគ្គល ៤ នាក់ បបួលគ្នាលួចគរុភណ្ឌ នេះយ៉ាងណា ក្នុងសិក្ខាបទនេះ មិនមែនដូច្នោះឡើយ ដោយពិតនោះ កណ្ឌៈដែលចាត់ជាគរុភណ្ឌ ក៏ព្រោះជារបស់ដែលមិនគួរចំណាយ ដោយព្រះបាលីថា ម្នាលភិក្ខុ

ទាំងឡាយ ភណ្ឌៈ ៥ ពួកនេះ មិនគួរចំណាយ កុំចំណាយឡើយ សង្ឃក្តី គណៈក្តី បុគ្គលក្តី សូម្បីចំណាយទៅ ក៏មិនឈ្មោះថា ចំណាយ ភិក្ខុណា ចែកចាយ កាត់អាបត្តិថុល្លច្ច័យដល់ភិក្ខុនោះ ភណ្ឌៈ ៥ ពួក គឺអ្វីខ្លះ គឺ អារាម អារាមវត្ថុ ។បេ។ ភណ្ឌៈឈើ ភណ្ឌៈដី បរិក្ខារដែលចាត់ជាគរុបរិក្ខារ ដោយភាពជាបរិក្ខារសាធារណៈ ព្រោះជារបស់មិនគួរចែក ដោយព្រះបាលី ថា ម្នាលភិក្ខុទាំងឡាយ បរិក្ខារ ៥ ពួកនេះ ក៏មិនគួរចែក កុំចែកឡើយ សង្ឃក្តី គណៈក្តី បុគ្គលក្តី សូម្បីចែកទៅហើយ ក៏មិនឈ្មោះថា ចែក ភិក្ខុ ណាចែក ត្រូវអាបត្តិថុល្លច្ច័យដល់ភិក្ខុនោះ បរិក្ខារ ៥ ពួក គឺអ្វីខ្លះ គឺអារាម អារាមវត្ថុ ។បេ។ ភណ្ឌៈឈើ ភណ្ឌៈដី ។ ពាក្យណាដែលគួរពោលក្នុងបទថា **អារាមោ អារាមវត្ថុ** ជាដើម ខ្ញុំនឹងពោលពាក្យទាំងអស់នេះ ក្នុងវណ្ណនានៃ ព្រះសូត្រ ដែលមកក្នុងខន្ធកៈថា **បញ្ចិមានិ ភិក្ខវេ អវិស្សជ្ជិយានិ** នោះឯង ។

បទថា **តេហិ គិហី សំគណ្ហាតិ** សេចក្តីថា ឲ្យគរុភណ្ឌ គរុបរិក្ខារ មានអារាមជាដើមនោះ សង្គ្រោះ គឺអនុគ្រោះពួកគ្រហស្ថ ។

បទថា **ឧបលាបេតិ** សេចក្តីថា ធ្វើឲ្យពួកគ្រហស្ថរីករាយ គឺឲ្យជាប់ ចិត្ត បានដល់ មានសេចក្តីស្រឡាញ់យ៉ាងនេះថា ល្អពិត លោកម្ចាស់របស់ ពួកយើង ។ ភិក្ខុដែលលួចគរុបរិក្ខារដែលមិនគួរចំណាយ និងមិនគួរចែក ដោយសភាពយ៉ាងនោះ សង្គ្រោះគ្រហស្ថនេះ ចាត់ជាមហាចោរពួកទី ៤ ។ ឯ ភិក្ខុនេះ កាលចំណាយគរុភណ្ឌនេះ ដើម្បីសង្គ្រោះត្រកូល រមែងត្រូវកុល- ទូសកទុក្កដផង រមែងជាបុគ្គលគួរដល់បព្វាជនីយកម្មផង បើចំណាយដោយ

ភាពជាបុគ្គលជាធំលើភិក្ខុសង្ឃ រមែងត្រូវអាបត្តិថុល្លច្ច័យ បើចំណាយដោយថេយ្យចិត្ត គប្បីវាយតម្លៃកណ្ឌ: កាត់អាបត្តិ ដូច្នេះ ។

បទថា **អយំ អគ្គោ មហាចោរោ** សេចក្តីថា ភិក្ខុលួចលោកុត្តរធម៌ដែលសុខុមល្អិតពន់ពេក ប្រព្រឹត្តទៅកន្លងការកាន់យក ដោយឥន្ទ្រិយ ៥ នេះ ចាត់ជាចោរធំបំផុត របស់មហាចោរទាំងនេះ ឈ្មោះថា ចោរ ដូចភិក្ខុនេះ មិនមាន ។

សួរថា លោកុត្តរធម៌ បុគ្គលអាចបោកបញ្ឆោត គឺលួចយកដូចទ្រព្យមានប្រាក់ និងមាសជាដើមឬ ឆ្លើយថា មិនអាច ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុណា ពោលអួតឧត្តរិមនុស្សធម៌ដែលមិនមាន តាមសេចក្តីពិត ។ ពិតហើយ ភិក្ខុនេះ រមែងពោលអួតធម៌ដែលមិនមានក្នុងខ្លួនតែម្យ៉ាងថា ធម៌នេះរបស់អញមាន ។ តែមិនអាចឲ្យឧត្តរិមនុស្សធម៌នោះរំកិលទៅចាកទីបានផង មិនអាចធ្វើឲ្យមាននៅក្នុងខ្លួនបានផង ។

សួរថា បើដូច្នោះ ព្រោះហេតុអ្វី ទើបពោលថា ជាចោរទៅវិញ ឆ្លើយថា ព្រោះថា ភិក្ខុនេះពោលអួតឧត្តរិមនុស្សធម៌នោះហើយ កាន់យកបច្ច័យដែលកើតឡើង ព្រោះការអួតគុណដែលមិនមាន ព្រោះហេតុនោះ បច្ច័យទាំងនោះ គឺភិក្ខុកាន់យក ( ដោយការអួតធម៌ដែលមិនមាន ) យ៉ាងនោះ បោកបញ្ឆោត គឺលួចយកដោយឧបាយដ៏ល្អិតល្អន់ ។ ដោយហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីនុ៎ះ ព្រោះហេតុអ្វី ព្រោះដុំបាយរបស់អ្នកស្រុក ដែលភិក្ខុនោះឆាន់ហើយ ដោយភាពជាចោរ ។

ឯអត្ថក្នុងពាក្យថា **តំ កិស្ស ហេតុ** នេះ គប្បីជ្រាបដូចតទៅនេះថា តថាគតបានពោលពាក្យណាថា ភិក្ខុណាពោលអួតឧត្តរិមនុស្សធម៌ដែលមិនមាន មិនពិត ភិក្ខុនេះជាកំពូលមហាចោរ បើមានអ្នកចោទសួរថា សេចក្តីនោះព្រោះហេតុអ្វី គឺតថាគតបានពោលពាក្យនោះ ដោយហេតុណា តថាគតគប្បីឆ្លើយថា ម្នាលភិក្ខុទាំងឡាយ ព្រោះដុំបាយរបស់អ្នកស្រុកដែលភិក្ខុនោះឆាន់ហើយ ដោយភាពជាចោរនោះឯង អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រោះដុំបាយរបស់អ្នកស្រុកដែលភិក្ខុនោះឆាន់ហើយដោយថេយ្យចិត្ត ព្រោះហេតុនោះ ទើបតថាគតពោលពាក្យនោះ ។

ពិតហើយ **ហិ** ក្នុងពាក្យថា **ថេយ្យាយ ហិ** នេះ ជានិបាត ចុះក្នុងអត្ថ ត្រឹមតែជាគ្រឿងធ្វើបទឲ្យពេញ ដូច **ហិ** សព្ទ ក្នុងពាក្យថា **យេ ហិ ហិ អរិយា អរញ្ញវនបដ្ឋានិ** ជាដើម ប្រែថា ពិតហើយ ព្រះអរិយៈទាំងឡាយ រមែងសេពជនព្រៃក្នុងព្រៃ ។ ព្រោះហេតុនោះ អ្នកសិក្សាមិនគប្បីឃើញអត្ថនៃ **ហិ** សព្ទនេះ យ៉ាងនេះថា **តុម្ហេហិ ភុត្តោ** ប្រែថា ដែលភិក្ខុទាំងឡាយឆាន់ហើយ ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើអត្ថនោះឯង ឲ្យជាក់ច្បាស់ឡើងដោយគាថា ទើបត្រាស់គាថាថា **អញ្ញថា សន្តំ** ជាដើម ។

បណ្តាបទទាំងនោះ ពីរបទថា **អញ្ញថា សន្តំ** សេចក្តីថា ដែលមាននៅដោយអាការដទៃ ដែលមានកាយសមាចារមិនបរិសុទ្ធជាដើម ។

បាទគាថាថា **អញ្ញថា យោ បវេទយេ** សេចក្តីថា ភិក្ខុអង្គណា គប្បី

ប្រកាសដោយអាការដទៃ ដែលមានកាយសមាចារបរិសុទ្ធជាដើម គឺឲ្យជនដទៃយល់យ៉ាងនេះថា អាត្មាអញជាបុគ្គលបរិសុទ្ធក្រៃលែង លោកុត្តរធម៌មាននៅខាងក្នុងអញ ។ កាលប្រកាសហើយ ( សម្តែងខ្លួន ) ដូចព្រះអរហន្តឆាន់ភោជនដែលកើតឡើង ព្រោះការប្រកាសនោះ ។

បទថា **ឆិកច្ច** ក្នុងពីរបាទគាថាថា **ឆិកច្ច កីតវាស្សេវ ភុត្តំ ថេយ្យេន តស្ស តំ** នេះ ប្រែថា បោកបញ្ឆោត គឺសម្តែងខ្លួនដែលមាននៅដោយអាការដទៃ ដោយអាការបែបដទៃ បានដល់ សម្តែងខ្លួនដែលមិនមែនគុម្ពោតឈើនិងមិនមែនគុម្ពឈើ ឲ្យដូចជាគុម្ពោតឈើ និងឲ្យដូចគុម្ពឈើ ព្រោះយកមែកឈើ ស្លឹកឈើ និងស្លឹកខ្ចីជាដើមបិទបាំង ។

បទថា **កីតវាស្សេវ** សេចក្តីថា ដូចព្រានបក្សីបញ្ឆោត គឺបញ្ឆោតចាប់បក្សីដែលមកហើយក្នុងព្រៃ ដោយមានសេចក្តីសម្គាល់ថា ជាគុម្ពោតឈើនិងគុម្ពឈើ ហើយចិញ្ចឹមជីវិត ដូច្នោះ ។

បាទគាថាថា **ភុត្តំ ថេយ្យេន តស្ស តំ** សេចក្តីថា កាលភិក្ខុនោះដែលមិនមែនជាព្រះអរហន្ត សម្តែងថាជាព្រះអរហន្ត ឆាន់ភោជនដែលខ្លួនបានមកភោជនដែលភិក្ខុឆាន់ ឈ្មោះថា ភិក្ខុឆាន់ហើយ ដោយភាពជាចោរ ព្រោះភិក្ខុឆាន់ភោជនដែលខ្លួនបោកបញ្ឆោតមនុស្សទាំងឡាយ ហើយបានមក ប្រៀបដូចព្រានបក្សី មានគ្រឿងបិទបាំង បញ្ឆោត គឺបញ្ឆោតចាប់បក្សី ដូច្នោះ ។ ភិក្ខុណា កាលមិនដឹងអំណាចនៃប្រយោជន៍នេះ រមែងឆាន់ដោយអាការយ៉ាងនោះ ភិក្ខុជាច្រើនមានសំពត់កាសាវៈរុំក មានធម៌ដ៏លាមក មិនសង្រួម ហើយ

បាបភិក្ខុទាំងនោះ រមែងចូលដល់នូវនរក ព្រោះកម្មទាំងឡាយដ៏លាមក ។

បទថា **កាសាវកណ្ឋា** បានដល់ បុគ្គលមានក ដែលរុំដោយសំពត់កាសាវៈ ។ អធិប្បាយថា គុណជាតិជាសមណៈ គឺអរហត្តផល រមែងមិនមានដល់បុគ្គលទាំងឡាយណា បុគ្គលទាំងឡាយនោះ មានតែការទ្រទ្រង់ទុកនូវទង់ជ័យនៃព្រះអរិយៈត្រឹមនេះប៉ុណ្ណោះ ។ ពាក្យថា អ្នកមានកាសាវៈរុំកនេះ ជាឈ្មោះនៃបព្វជិតទ្រុស្តសីល ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលអានន្ទ ឯគោត្រភូសង្ឃទាំងឡាយ ដែលមានសំពត់កាសាវៈរុំក នឹងមានក្នុងកាលអនាគត ។

បទថា **បាបធម្មា** បានដល់ មានធម៌ដ៏លាមក ។

បទថា **អសញ្ញតា** បានដល់ បុគ្គលមិនសង្រួមផ្លូវកាយជាដើម ។

បទថា **បាបា** បានដល់ បុគ្គលលាមក ។

ពីរបទថា **បាបេហិ កម្មេហិ** សេចក្តីថា ព្រោះកម្មដ៏លាមកទាំងឡាយមានការបោកអ្នកដទៃជាដើមនោះ ដែលខ្លួនធ្វើហើយ ព្រោះមិនឃើញទោសក្នុងវេលាធ្វើ ។

បាទគាថាថា **និរយន្តេ ឧបបជ្ជរេ** សេចក្តីថា ភិក្ខុបាបទាំងនោះ រមែងចូលដល់ទុគ្គតិ ដែលមិនមានសេចក្តីត្រេកអរ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់គាថាថា **សេយ្យោ អយោគុឡោ** ជាដើម ។

គប្បីជ្រាបអត្ថនៃគាថានោះថា បើបុគ្គលទ្រុស្តសីល មិនសង្រួម តាំងនៅក្នុងឥច្ឆាចារ ជាអ្នកបោកបញ្ឆោតលោក ដោយកិរិយាធបោកនេះ គប្បី

បរិភោគ គឺគប្បីលេបដុំដែកឆេះក្រហមដូចអណ្តាតភ្លើង ការដែលបុគ្គលទ្រុស្ត-សីលឆាន់ដុំបាយរបស់អ្នកស្រុកនេះ ១ កាលដែលបុគ្គលបរិភោគដុំដែកឆេះក្រហមនេះ ១ ក្នុង ២ យ៉ាងនោះ ដុំដែកនោះឯង ដែលភិក្ខុនោះបរិភោគហើយ គប្បីជារបស់ប្រសើរជាង គឺល្អជាង និងប្រណីតជាង ព្រោះថា ភិក្ខុនោះ នឹងមិនសោយទុក្ខ ដែលមានការកំណត់ដឹងបានលំបាក សូម្បីដោយសព្វញ្ញុតញ្ញាណ ក្នុងសម្បរាយភព ព្រោះបរិភោគដុំដែកក្រហម តែនឹងបានសោយទុក្ខ មានប្រការដូចពោលហើយក្នុងសម្បរាយភព ព្រោះភិក្ខុបរិភោគដុំបាយរបស់អ្នកស្រុក ដែលខ្លួនបានមកហើយ ដោយអាការយ៉ាងនោះ ។ ការពិត អាជីវៈនេះ ចាត់ជាមិច្ឆាជីវៈដ៏កំពូល ។

[ ២៣១ ] គ្រានោះឯង ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងទោសដល់ពួកភិក្ខុដែលមិនឃើញទោស ក្នុងការធ្វើអំពើអាក្រក់យ៉ាងនោះហើយ ទើបទ្រង់តិះដៀលពួកភិក្ខុដែលនៅត្រង់មាត់ស្ទឹងវគ្គមុទា ដោយអនេកបរិយាយ ហើយទ្រង់ត្រាស់ទោសនៃការចិញ្ចឹមក្រ និងភាពជាអ្នកទំនុកបម្រុងលំបាក ។បេ។ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះ ... ដូច្នេះហើយ កាលទ្រង់បញ្ញត្ត-ចតុត្ថបារាជិក ទើបត្រាស់ថា **យោ បន ភិក្ខុ អនភិជានំ** ជាដើម ប្រែថា ម្យ៉ាងទៀត ភិក្ខុណាមួយមិនដឹងចំពោះ ដូច្នេះជាដើម ។

# អនុប្បញ្ញត្តិចតុត្ថបារាជិក

[ ២៣២ ] កាលព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តចតុត្ថបារាជិក ធ្វើឲ្យធ្ងន់ឡើង ដោយអំណាចការដាច់មូលយ៉ាងនោះហើយ រឿងសម្គាល់ថា បានត្រាស់ដឹងដទៃទៀតក៏កើតឡើង ដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ ដើម្បីសម្តែងការកើតឡើងនៃរឿងសម្គាល់ថាបានសម្រេចនោះ ទើបធម្មសង្គាហកត្ថេរទាំងឡាយពោលយ៉ាងនេះថា សិក្ខាបទនេះ គឺព្រះមានព្រះភាគ ទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយ ដោយប្រការយ៉ាងនេះ ។

បណ្តាបទទាំងនោះ ពីរបទថា **អទិដ្ឋេ ទិដ្ឋសញ្ញិនោ** សេចក្តីថា ( ភិក្ខុទាំងឡាយ ) ជាអ្នកមានសេចក្តីសម្គាល់ក្នុងអរហត្តផល ដែលខ្លួនមិនទាន់បានឃើញដោយញាណចក្ខុ ថាបានឃើញ ដោយពាក្យថា អរហត្តផលយើងទាំងឡាយឃើញហើយ ។ ក្នុងអរហត្តផលដែលខ្លួនមិនទាន់បានដល់ជាដើម ក៏មានន័យដូច្នេះ ។ តែសេចក្តីវិសេស មានដូចតទៅនេះថា

បទថា **អប្បត្តេ** សេចក្តីថា ដែលខ្លួនមិនទាន់បានដល់ ដោយអំណាចការកើតឡើងក្នុងសន្តានរបស់ខ្លួន ។

បទថា **អនធិគតេ** បានដល់ ខ្លួនមិនទាន់បានសម្រេចដោយមគ្គភាវនា សេចក្តីថា ដែលខ្លួនមិនទាន់បាន ។

បទថា **អសច្ឆិកតេ** បានដល់ ដែលខ្លួនមិនទាន់បានចាក់ធ្លុះ ឬមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ដោយអំណាចការពិចារណា ។

បទថា **អធិមានេន** បានដល់ ដោយការសម្គាល់ថា ខ្លួនបានត្រាស់ដឹង អធិប្បាយថា ដោយការសម្គាល់ដែលកើតឡើងយ៉ាងនេះថា អញបានត្រាស់

ដឹងហើយ ម្យ៉ាងទៀត សេចក្ដីថា ដោយការប្រកាន់ខ្លួនក្រៃលែង គឺដោយមានះដ៏ខ្លាំងក្លា ។

ពីរបទថា **អញ្ញំ ព្យាករឹសុ** សេចក្ដីថា បានព្យាករអរហត្តផល គឺបានប្រាប់ដល់ភិក្ខុទាំងឡាយថា អាវុសោ ពួកយើងបានសម្រេចអរហត្តផលហើយ កិច្ចដែលគួរធ្វើ ពួកយើងបានធ្វើស្រេចហើយ ។ ព្រោះមិនទាន់លះកិលេសបានដោយមគ្គ ចិត្តរបស់ភិក្ខុទាំងនោះ សង្កត់កិលេសទុកបាន ដោយអំណាចសមថៈ និងវិបស្សនាតែម្យ៉ាង ដោយសម័យតមក គឺក្នុងវេលាប្រកបព្រមដោយបច្ច័យបែបនោះ រមែងបង្អោនទៅដើម្បីតម្រេកខ្លះ អធិប្បាយថា រមែងបង្អោនទៅដើម្បីតម្រេក ។ ក្នុងបទទាំងឡាយក្រៅអំពីនេះ ក៏មានន័យដូច្នេះ ។

បទថា **តញ្ច ខោ ឯតំ អព្ពោហារិកំ** សេចក្ដីថា ឯការព្យាករអរហត្តនេះរបស់ភិក្ខុទាំងនោះ ជាអព្វោហារិក មិនចូលដល់វោហារ ក្នុងការជាហេតុឲ្យបញ្ញត្តអាបត្តិ អធិប្បាយថា មិនជាអង្គនៃអាបត្តិ ។

សួរថា ឯការសម្គាល់ថា បានសម្រេចនេះ រមែងកើតឡើងដល់បុគ្គលណា មិនកើតឡើងដល់បុគ្គលណា ឆ្លើយថា រមែងមិនកើតឡើងដល់អរិយសាវក ពិតហើយ អរិយសាវកនោះ មានសោមនស្សកើតឡើងហើយដោយញាណជាគ្រឿងពិចារណាមគ្គ ផល និព្វាន កិលេសដែលបានលះហើយ និងកិលេសដែលនៅសល់ ជាបុគ្គលមិនមានសេចក្ដីសង្ស័យ ក្នុងការត្រាស់ដឹងអរិយគុណ ព្រោះហេតុនោះ ទើបមានះមិនកើតឡើងដល់អរិយសាវកទាំងឡាយ មានសោតាបន្នជាដើម ដោយអំណាចការប្រកាន់ថា អញ

ជាសកទាគាមីជាដើម ។ នឹងមិនកើតឡើងដល់បុគ្គលទ្រុស្តសីល ព្រោះថា បុគ្គលទ្រុស្តសីលនោះ ជាបុគ្គលគ្មានសង្ឃឹមក្នុងការត្រាស់ដឹងអរិយគុណនោះឯង និងមិនកើតដល់បុគ្គលដែលមានសីល ដែលលះបង់កម្មដ្ឋានចោល ហើយតាមប្រកបហេតុនៃសេចក្ដីខ្ជិលច្រអូស មានភាពជាអ្នកត្រេកអរក្នុងការដេកជាដើម ។ តែកើតឡើងដល់បុគ្គលអ្នកផ្ដើមចម្រើនវិបស្សនា មានសីលបរិសុទ្ធល្អ មិនប្រមាទក្នុងកម្មដ្ឋាន ឆ្លងផុតសេចក្ដីសង្ស័យហើយ ព្រោះកំណត់នាមរូប កំណត់បច្ច័យបាន លើកត្រៃលក្ខណ៍ឡើង ពិចារណាសង្ខារទាំងឡាយ ។ ហើយការសម្គាល់ថា បានត្រាស់ដឹងកើតឡើងហើយ រមែងបញ្ឈប់បុគ្គលដែលបានសមថៈសុទ្ធៗ ឬដែលបានវិបស្សនាសុទ្ធៗ ត្រង់ពាក់កណ្ដាល ។ ពិតហើយ បុគ្គលនោះ កាលមិនឃើញការផ្សាយឡើងនៃកិលេស រហូត ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ រមែងយល់ថា អញជាព្រះសោតាបន្ន ឬថា អញជាព្រះសកទាគាមី ឬថា អញជាព្រះអនាគាមី ។ ចំណែកការសម្គាល់ថា បានសម្រេចនោះ រមែងតាំងបុគ្គលដែលបានទាំងសមថៈ និងវិបស្សនា ទុកក្នុងអរហត្តផលនោះ ។ ពិតហើយ បុគ្គលនោះ សង្កត់កិលេសទាំងឡាយបានដោយកម្លាំងសមាធិ កំណត់សង្ខារទាំងឡាយបានល្អ ដោយកម្លាំងវិបស្សនា ព្រោះដូច្នោះ ទើបកិលេសទាំងឡាយ មិនផ្សាយឡើងអស់ ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ការត្រាច់ទៅនៃចិត្តដូចចិត្តព្រះខីណាស្រព ដូច្នោះ ។ បុគ្គលនោះ កាលមិនឃើញការផ្សាយឡើងនៃកិលេសអស់រាត្រីដ៏យូរ ដោយអាការយ៉ាងនោះ មិនឈប់ក្នុងចន្លោះ

ឡើយ ទើបសម្គាល់ថា អញជាព្រះអរហន្ត ដូច្នេះឯង ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃចតុត្ថបារាជិក

[ ២៣៣ ] បទថា **អនភិជានំ** បានដល់ មិនដឹងចំពោះ ។ ព្រោះភិក្ខុនេះមិនដឹងពិត ហើយពោលអួតឧត្តរិមនុស្សធម្មនោះ មិនកើតឡើងក្នុងសន្តានរបស់លោក ទាំងខ្លួនលោកក៏មិនបានធ្វើឲ្យជាក់ច្បាស់នៃញាណ ទើបឈ្មោះថា មិនមានពិត ព្រោះដូច្នោះ ក្នុងវារៈចែកបទថា **អនភិជានំ** នោះព្រះឧបាលិត្ថេរពោលថា ( ឧត្តរិមនុស្សធម្ម ) មិនមានពិត មិនកើតពិត មិនបានហើយ ទើបពោលថា ( ភិក្ខុ ) មិនដឹង ដូច្នេះ ។

បទថា **ឧត្តរិមនុស្សធម្មំ** ប្រែថា ធម៌របស់មនុស្សដ៏ប្រសើរ គឺលោកអ្នកបានឈាន និងព្រះអរិយៈទាំងឡាយ ។

បទថា **អត្តុបនាយិកំ** មានអត្ថវិគ្គហៈថា ភិក្ខុរមែងបង្អោនឧត្តរិមនុស្សធម្មនោះចូលមកក្នុងខ្លួន ឬរមែងបង្អោនខ្លួន ចូលទៅក្នុងឧត្តរិមនុស្សធម្មនោះ ព្រោះហេតុនោះ ទើបឧត្តរិមនុស្សធម្មនោះ ឈ្មោះថា **អត្តុបនាយិក** ។ ( ភិក្ខុ ) ពោលអួតឧត្តរិមនុស្សធម្មនោះ ជាទីបង្អោនចូលមកក្នុងខ្លួន ឬជាទីបង្អោនខ្លួនចូលទៅរក ។ ភ្ជាប់សេចក្តីថា ភិក្ខុធ្វើយ៉ាងនេះ ពោលអួត តែក្នុងវារៈចែកបទ ព្រោះហេតុដែលព្រះឧបាលីពោលធម៌ច្រើនប្រការ មានឈានជាដើមយ៉ាងនេះថា ឈាន វិមោក្ខ សមាធិ សមាបត្តិ ញាណទស្សនៈ ។បេ។ ( ការញុំាងមគ្គឲ្យចម្រើន ការធ្វើឲ្យជាក់ច្បាស់នូវផល ការលះកិលេស

ការដែលចិត្តប្រាសចាកនីវរណៈ ) ការត្រេកអរក្រៃលែងក្នុងផ្ទះស្ងាត់ ឈ្មោះថា ឧត្តរិមនុស្សធម្ម ដូច្នេះ ព្រោះដូច្នោះ កាលលោកសម្ដែងភាពដែលឧត្តរិ-មនុស្សធម្មនោះ ជាធម៌បង្អោនចូលមកក្នុងខ្លួន ដោយអំណាចនៃធម៌ទាំងនោះ ទើបបានធ្វើនិទ្ទេសជាពហុវចនៈថា ភិក្ខុរមែងបង្អោនកុសលធម៌ទាំងនោះចូលមកក្នុងខ្លួនផង ។ ក្នុងបណ្ដាការបង្អោនពីរយ៉ាងនោះ កាលភិក្ខុអួតថា ធម៌ទាំងនេះរមែងប្រាកដក្នុងខ្ញុំ គប្បីជ្រាបថា ឈ្មោះថា បង្អោន ( ធម៌ទាំងនោះ ) ចូលមកក្នុងខ្លួន បើអួតថា ខ្ញុំរមែងប្រាកដក្នុងធម៌នេះ គប្បីជ្រាបថា ឈ្មោះថា បង្អោនខ្លួនចូលទៅក្នុងធម៌ទាំងនោះ ។

គប្បីជ្រាបការក្ដាប់អត្ថនៃបទ ក្នុងពាក្យថា **អលមរិយញាណទស្សនំ** នេះ យ៉ាងនេះ គឺបញ្ញាដែលជាលោកិយផង លោកុត្តរផង ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង ឈ្មោះថា ទស្សនៈ ព្រោះអត្ថថា ឃើញ ព្រោះធ្វើនូវធម៌ដែលដូចជាឃើញដោយចក្ខុ ព្រោះដូច្នោះ ទើបឈ្មោះថា ញាណទស្សនៈ ។ ញាណទស្សនៈដ៏ប្រសើរ គឺបរិសុទ្ធឧត្តម ព្រោះដូច្នោះ ទើបឈ្មោះថា អរិយញាណទស្សនៈ ។ ញាណទស្សនៈដ៏ប្រសើរយ៉ាងមានសមត្ថភាព គឺក្លៀវក្លា អាចកម្ចាត់កិលេស មានក្នុងឧត្តរិមនុស្សធម្ម ដោយប្រភេទ មានឈានជាដើមនេះ ឬញាណទស្សនៈដ៏ប្រសើរ យ៉ាងអង់អាច ជារបស់នៃឧត្តរិមនុស្សធម៌ ព្រោះហេតុនោះ ទើបឧត្តរិមនុស្សធម៌នោះ ឈ្មោះថា មានការដឹង ឃើញដ៏ប្រសើរ ដ៏អង់អាច ។ ភិក្ខុមិនដឹងពិត ពោលអួតឧត្តរិមនុស្ស-ធម៌ ដែលមានការដឹង ឃើញដ៏ប្រសើរ ដ៏អង់អាចនោះ ។

ក្នុងបទភាជនីយ៍នោះ ឧត្តរិមនុស្សធម្មនោះ លោកហៅថា អលមរិយ-ញ្ញាណទស្សនា ដោយញាណទស្សនៈណា ដើម្បីសម្តែងញាណទស្សនៈនោះឯង ទើបព្រះឧបាលីពោលបទភាជនៈ ដោយវិជ្ជាជាធំថា **ញាណ** នោះ បានដល់ វិជ្ជា ៣ **ទស្សនៈ** នោះ គឺញាណយ៉ាងណា ទស្សនៈក៏យ៉ាងនោះ ទស្សនៈ យ៉ាងណា ញាណក៏យ៉ាងនោះ ។ តែក្នុងបទថា **ញាណំ** នេះ បញ្ញាទាំងអស់ ដែលជាមហគ្គតៈក្តី លោកុត្តរក្តី គប្បីជ្រាបថា ញាណ ។

បទថា **សមុទាចរេយ្យ** សេចក្តីថា គប្បីអួតឧត្តរិមនុស្សធម្ម មានប្រការដូចពោលហើយ ធ្វើឲ្យបង្អោនចូលមកក្នុងខ្លួន ។ ចំណែកបទថា **ឥត្ថិយា វា** ជាដើម បង្ហាញដល់បុគ្គលដែលភិក្ខុគប្បីអួត ។ ពិតហើយ កាលអួតឧត្តរិ-មនុស្សធម្មដល់បុគ្គលទាំងនេះ រមែងជាការអួត ។ កាលអួតជាមួយទេវតា មារ ព្រហ្ម ឬដល់ប្រេត យក្ខ និងសត្វតិរច្ឆាន មិនជាការអួតឡើយ ។

បទថា **ឥតិ ជានាមិ ឥតិ បស្សាមិ** នេះ សម្តែងអាការអួត ។ តែក្នុងបទភាជនៈនៃបទថា **ឥតិ ជានាមិ ឥតិ បស្សាមិ** នោះ ពាក្យថា ខ្ញុំដឹងធម៌ទាំងនេះ ខ្ញុំឃើញធម៌ទាំងនេះ នេះសម្តែងដល់ការប្រព្រឹត្តទៅនៃបញ្ញា និងទស្សនៈក្នុងធម៌ មានឈានជាដើមទាំងនោះ ។ ពាក្យថា ធម៌ទាំងនេះ មានដល់ខ្ញុំជាដើម សម្តែងការបង្អោនចូលមកក្នុងខ្លួន ។

[ ២៣៤ ] បទថា **តតោ អបរេន សមយេន** នេះ សម្តែងដល់សម័យដែលប្តេជ្ញាថា ជាអាបត្តិ ។ តែភិក្ខុនេះត្រូវអាបត្តិបារាជិកក្នុងខណៈដែលអួតនោះឯង ។ ភិក្ខុត្រូវអាបត្តិហើយ ត្រូវភិក្ខុដទៃចោទក្តី មិនចោទក្តី រមែងប្តេជ្ញា

ព្រោះដូច្នោះ ទើបលោកពោលថា ភិក្ខុដែលបុគ្គលណាមួយជឿក្តី មិនជឿក្តី ។

បណ្តាការជឿ និងមិនជឿនោះ ក្នុងការជឿ គប្បីជ្រាបវិនិច្ឆ័យជាមុន គឺ

ពាក្យថា ធម៌អ្វីដែលលោកបានត្រាស់ដឹង គឺជាពាក្យសួរដល់ធម៌ដែលបានសម្រេច ។ មានពាក្យអធិប្បាយថា បណ្តាគុណធម៌ មានឈាន និងវិមោក្ខជាដើម ឬបណ្តាមគ្គ មានសោតាបត្តិមគ្គជាដើម លោកបានសម្រេចអ្វី ១ ។ ពាក្យថា ហេតុដូចម្តេចបានជាលោកបានត្រាស់ដឹង គឺជាពាក្យសួរដល់ឧបាយ ។ សេចក្តីពិតក្នុងពាក្យនេះ មានអធិប្បាយដូចតទៅនេះ គឺលោកធ្វើអនិច្ចលក្ខណៈឲ្យជាធុរៈ ហើយទើបបានសម្រេច ឬលោកធ្វើបណ្តាទុក្ខ-លក្ខណៈ អនត្តលក្ខណៈឯណានីមួយឲ្យជាធុរៈ ហើយទើបសម្រេច លោកតាំងមាំហើយ ដោយអំណាចសមាធិ ឬតាំងមាំហើយ ដោយអំណាចវិបស្សនា ទើបបានសម្រេច ម្យ៉ាងទៀត លោកតាំងមាំហើយក្នុងរូបធម៌ ឬតាំងមាំហើយក្នុងអរូបធម៌ ទើបសម្រេច លោកតាំងមាំហើយក្នុងកាយជាខាងក្នុង ឬតាំងមាំហើយក្នុង កាយជាខាងក្រៅ ទើបបានសម្រេច ១ ។

ពាក្យថា លោកបានត្រាស់ដឹងពីអង្កាល់ គឺជាពាក្យសួរដល់កាល ។ មានពាក្យអធិប្បាយថា ក្នុងបណ្តាកាល មានពេលព្រឹក និងថ្ងៃត្រង់ជាដើម ក្នុងកាលណាមួយ ១ ។

ពាក្យថា លោកបានត្រាស់ដឹងក្នុងទីណា គឺជាពាក្យសួរដល់ឱកាស ។ អធិប្បាយថា ក្នុងឱកាសណា គឺក្នុងទីសម្រាកពេលយប់ ក្នុងទីសម្រាកពេលថ្ងៃ ត្រង់គល់ឈើ ត្រង់មណ្ឌប ឬក្នុងវិហារមួយណា ១ ។

ពាក្យថា កិលេសណាខ្លះដែលលោកបានលះរួចហើយ គឺជាពាក្យសួរ

ដល់កិលេសដែលលះបានហើយ ។ អធិប្បាយថា កិលេសទាំងឡាយដែលមគ្គពួកណាសម្លាប់ លោកលះបានហើយ ១ ។

ពាក្យថា លោកបានធម៌ដូចម្ដេចខ្លះ គឺជាពាក្យសួរដល់ធម៌ដែលបានហើយ មានពាក្យអធិប្បាយថា បណ្ដាមគ្គ មានបឋមមគ្គជាដើម លោកបានធម៌ពួកណា ១ ។

ព្រោះដូច្នោះ ឥឡូវនេះ បើភិក្ខុអង្គណា គប្បីព្យាករការសម្រេចឧត្តរិ-មនុស្សធម្ម ភិក្ខុដែលបុគ្គលណាមួយ មិនគួរសក្ការៈ ដោយពាក្យព្យាករមានប្រមាណប៉ុណ្ណោះសិន ។ តែភិក្ខុគួរសាកសួរដើម្បីស្ទាបស្ទង់ឲ្យសស្អាត ក្នុងឋានៈទាំង ៦ នេះថា លោកបានសម្រេចអ្វី គឺលោកបានសម្រេចឈាន ឬបានសម្រេចបណ្ដាវិមោក្ខជាដើមឯណាមួយឬ ពិតហើយ ធម៌ដែលបុគ្គលណាបានសម្រេចហើយ រមែងជារបស់ប្រាកដដល់ភិក្ខុនោះ ។ បើលោកពោលថា ខ្ញុំមិនបានសម្រេចធម៌ឈ្មោះនេះ លំដាប់នោះ គួរសាកសួរលោកថា លោកបានសម្រេចដោយវិធីដូចម្ដេច គឺគួរសាកសួរថា លោកធ្វើអ្វីក្នុងបណ្ដាត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើមឲ្យជាធុរៈ ឬតាំងមាំនៅដោយមាតិកាអ្វី ក្នុងបណ្ដាអារម្មណ៍ ៣៨ យ៉ាង ឬក្នុងបណ្ដាធម៌ មានរូបធម៌ អរូបធម៌ កាយជាខាងក្នុង និងកាយជាខាងក្រៅជាដើម ទើបបានសម្រេច ពិតហើយ ការតាំងមាំណារបស់បុគ្គលណាមាន ការតាំងមាំនោះ រមែងប្រាកដដល់បុគ្គលនោះ ។ បើភិក្ខុពោលថា ការតាំងមាំឈ្មោះនេះ របស់ខ្ញុំមាន ខ្ញុំបានសម្រេចដោយវិធីយ៉ាងនេះ ដូច្នេះ លំដាប់នោះ ការសាកសួរថា លោកបាន

សម្រេចក្នុងកាលណា គឺ គួរសាកសួរលោកថា លោកបានសម្រេចក្នុងវេលាព្រឹក ឬក្នុងវេលាថ្ងៃត្រង់ជាដើម ពេលណានីមួយឬ សេចក្ដីពិត កាលដែលខ្លួនបានសម្រេច រមែងជារបស់ប្រាកដដល់ជនគ្រប់ពួក ។ បើភិក្ខុពោលថា ខ្ញុំបានសម្រេចក្នុងកាលឈ្មោះនោះ លំដាប់នោះ គួរសាកសួរលោកថា លោកបានសម្រេចក្នុងទីណា គឺគួរសាកសួរលោកថា លោកបានសម្រេចក្នុងទីសម្រាកពេលថ្ងៃ ឬក្នុងបណ្ដាទីសម្រាកពេលយប់ជាដើម ឱកាសណានីមួយឬ សេចក្ដីពិត ឱកាសដែលបានសម្រេច រមែងប្រាកដដល់ជនគ្រប់ពួក ។ បើភិក្ខុពោលថា ខ្ញុំបានសម្រេចក្នុងឱកាសឈ្មោះនោះ លំដាប់នោះ គួរសាកសួរលោកថា លោកលះកិលេសពួកណាបាន គឺសាកសួរលោកថា កិលេសទាំងឡាយដែលបឋមមគ្គគប្បីសម្លាប់ ឬដែលទុតិយមគ្គជាដើមគប្បីសម្លាប់ លោកលះបានហើយ សេចក្ដីពិត មគ្គដែលខ្លួនបានសម្រេចលះកិលេសបានហើយ រមែងប្រាកដដល់ជនគ្រប់ពួក ។ បើភិក្ខុពោលថា កិលេសឈ្មោះនេះខ្ញុំលះបានហើយ លំដាប់នោះ គួរសាកសួរលោកថា លោកបានធម៌ពួកណា គឺគួរសាកសួរលោកថា លោកបានសោតាបត្តិមគ្គ ឬបានបណ្ដាមគ្គមានសកទាគាមិមគ្គជាដើមណានីមួយឬ សេចក្ដីពិត ធម៌ដែលខ្លួនបានសម្រេចហើយ រមែងប្រាកដដល់ជនគ្រប់ពួក ។ បើភិក្ខុពោលថា ខ្ញុំបានធម៌ឈ្មោះនេះ មិនគួរជឿពាក្យសម្ដីរបស់លោក ដោយពាក្យព្យាករមានប្រមាណត្រឹមប៉ុណ្ណេះ។ ពិតហើយ ភិក្ខុទាំងឡាយ ដែលជាពហូស្សុត ជាអ្នកឈ្លាសក្នុងបរិយត្តិ និងការសាកសួរ រមែងអាចសាកសួរឋានៈទាំង ៦ នេះ ឲ្យសស្អាត ។

ចំណែកអាគមនបដិបទា ( ការបដិបត្តិជាហេតុមកនៃមគ្គ ) របស់ភិក្ខុនេះ គួរពិសោធឲ្យជ្រះស្រឡះ ។ បើអាគមនបដិបទាមិនបរិសុទ្ធ ភិក្ខុទាំងឡាយគួរពោលថា ដែលឈ្មោះថា លោកុត្តរធម៌ លោកមិនបានដោយបដិបទានេះឡើយ ហើយនាំលោកចេញទៅ ។ តែអាគមនបដិបទារបស់ភិក្ខុនោះបរិសុទ្ធ បើភិក្ខុនោះប្រាកដក្នុងបដិបទានោះថា ជាអ្នកមិនប្រមាទក្នុងត្រៃសិក្ខាទាំងព្យាយាមប្រកបធម៌ ជាគ្រឿងភ្ញាក់រឭកអស់រាត្រីយូរ មិនជាប់ជំពាក់ក្នុងបច្ច័យទាំង៤ ដោយចិត្ត ប្រៀបដូចគ្រវីដៃក្នុងអាកាស ពាក្យព្យាកររបស់ភិក្ខុនោះ រមែងប្រៀបធៀបជាមួយបដិបទាបាន គឺដូចគ្នានឹងពុទ្ធវចនៈដែលត្រាស់ថា ទឹកក្នុងទន្លេគង្គា ប្រៀបស្មើនឹងទឹកក្នុងទន្លេយមុនា ដូចម្តេចមិញ បដិបទាជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តល្អហើយដល់សាវកទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា ក៏ប្រៀបធៀបគ្នាបានដូច្នោះដែរ ។ ម្យ៉ាងទៀត សក្ការៈដែលបុគ្គលណាមួយ មិនគួរធ្វើសូម្បីដោយពាក្យព្យាករមានប្រមាណត្រឹមប៉ុណ្ណេះ ។ ព្រោះហេតុអ្វី ព្រោះថា ភិក្ខុដែលជាបុថុជ្ជនអង្គខ្លះ ក៏មានបដិបទាដូចគ្នានឹងព្រះខីណាស្រពដែរ ព្រោះដូច្នោះ ភិក្ខុអង្គនោះ ដែលបុគ្គលណាមួយ គប្បីធ្វើឲ្យតក់ស្លុតបានដោយឧបាយនោះៗ ។ ធម្មតាព្រះខីណាស្រព សូម្បីមានអសនីបាត ( គឺរន្ទះ ) ធ្លាក់ចុះមកចំក្បាល ក៏មិនមានការតក់ស្លុត ភ័យខ្លាច ឬព្រឺរោម ព្រឺស្បែកឡើយ។ បើការខ្លាចក្តី ការភ្ញាក់ផ្អើលតក់ស្លុតក្តី ការព្រឺរោម ព្រឺស្បែកក្តី កើតឡើងដល់ភិក្ខុនោះ ភិក្ខុដែលភិក្ខុទាំងឡាយគប្បីពោលជាស់តឿនថា លោកមិនមែន

ជាព្រះអរហន្ត ហើយគប្បីនាំចេញ ។ តែបើភិក្ខុនោះជាអ្នកមិនខ្វាច ជាអ្នកមិនភ្ញាក់ផ្អើល ជាអ្នកមិនតក់ស្លុត រមែងអង្គុយស្ងៀម ដូចរាជសីហ៍ដូច្នោះ ភិក្ខុនេះឈ្មោះថា ជាអ្នកមានព្យាករដ៏សម្បូរ រមែងគួរទទួលសក្ការៈដែលព្រះរាជានិងរាជមហាមាត្យជាដើមបញ្ជូនទៅប្រគេនដោយជុំវិញ ដូច្នេះឯង ។

បទថា **បាបិច្ឆោ** បានដល់ ភិក្ខុដែលប្រកបដោយភាពជាអ្នកប្រាថ្នាលាមក ដែលព្រះមានព្រះភាគត្រាស់ដោយន័យជាដើមថា បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកទ្រុស្តសីល ប្រាថ្នាថា ជនចូរដឹងនូវអញ ថាជាអ្នកមានសីល ដូច្នេះ ។

បទថា **ឥច្ឆាបកតោ** បានដល់ ភិក្ខុដែលត្រូវអាបត្តិបារាជិក ត្រូវប្រាថ្នាលាមកនោះគ្របសង្កត់ គឺញាំញី ។

បទថា **វិសុទ្ធាបេក្ខោ** បានដល់ បុគ្គលសម្លឹង គឺត្រូវប្រាថ្នាភាពបរិសុទ្ធដើម្បីខ្លួន ។ ពិតហើយ ព្រោះហេតុដែលភិក្ខុនេះ ត្រូវអាបត្តិបារាជិកហើយ ដូច្នោះ លោកនៅតាំងនៅក្នុងភាពជាភិក្ខុជាបុគ្គលមិនគួរសម្រេចគុណធម៌ មានឈានជាដើម ។ ពិតហើយ ភាពជាភិក្ខុរបស់លោក រមែងជាការអន្តរាយចំពោះសួគ៌ផង ជាអន្តរាយចំពោះមគ្គផង ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ភាពជាសមណៈដែលបព្វជិត កាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក យ៉ាងនោះឯង ។ ព្រះតម្រាស់ដទៃទៀតត្រាស់ថា សមណធម៌ ជាគ្រឿងវៀរចាកកិលេសធូរថយ រមែងរោយធូលី គឺរាគាទិក្កិលេសដល់បុគ្គលដោយក្រៃលែង ដូច្នេះ ភាពជាភិក្ខុ

របស់លោក រមែងឈ្មោះថា ជារបស់មិនបរិសុទ្ធ ដូច្នេះឯង ។

មួយទៀត ភិក្ខុត្រូវអាបត្តិបារាជិកនោះ ( លះភិក្ខុភាវៈ ) ជាគ្រហស្ថ ឬជាឧបាសក ជាអារាមិក ឬជាសាមណេរ រមែងជាបុគ្គលគួរញ៉ាំងផ្លូវសួគ៌ឲ្យសម្រេច ដោយគុណធម៌ទាំងឡាយ មានទាន សរណៈ សីល និងសំវរៈជាដើម ឬញ៉ាំងផ្លូវព្រះនិព្វានឲ្យសម្រេចដោយគុណធម៌ទាំងឡាយ មានឈាននិងវិមោក្ខជាដើម ព្រោះហេតុនោះ ទើបភាពជាគ្រហស្ថជាដើមរបស់លោកឈ្មោះថា ជាការបរិសុទ្ធ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅលោកថា បុគ្គលសម្ញឹងភាពបរិសុទ្ធ ព្រោះសម្ញឹងដល់ការបរិសុទ្ធនោះ ។ ដោយហេតុនោះឯង ក្នុងបទភាជនៈនៃបទថា **វិសុទ្ធាបេក្ខោ** នោះ ទើបព្រះឧបាលីពោលពាក្យជាដើមថា បំណងនឹងជាគ្រហស្ថ ។

ពីរបទថា **ឯវំ វទេយ្យ** ប្រែថា គប្បីពោលយ៉ាងនេះ សួរថា គប្បីពោលដូចម្តេច ឆ្លើយថា គប្បីពោលថា នែ លោក ខ្ញុំមិនដឹងយ៉ាងនោះ បានពោលថា ដឹង មិនឃើញយ៉ាងនោះ បានពោលថា ឃើញ ។ ចំណែកក្នុងបទភាជនៈ ព្រះឧបាលីមិនបានលើកបទថា **ឯវំ វទេយ្យ** នេះឡើងឡើយ បានពោលពាក្យជាដើមថា ខ្ញុំមិនដឹងធម៌ទាំងនោះ ដូច្នេះ ដើម្បីសម្តែងអាការដែលភិក្ខុអ្នកពោលជាហេតុឲ្យលោកហៅឈ្មោះថា រមែងពោលថា នែលោក ខ្ញុំមិនដឹងយ៉ាងនោះ បានពោលថា ដឹង មិនឃើញយ៉ាងនោះ បានពោលថា ឃើញ ។

បទថា **តុច្ឆំ មុសា វិលបិន្តិ** អធិប្បាយថា ខ្ញុំបានពោល គឺបានកែ

សំនួន ដោយវៀរចាកប្រយោជន៍នៃពាក្យពោល ជាពាក្យកុហកទទេៗ ដោយការបំណងនឹងបោកបញ្ឆោត ។ ចំណែកក្នុងបទភាជនៈនៃបទនោះ ព្រះឧបាលីពោលពាក្យជាដើមថា ខ្ញុំពោលកែសំនួនដូច្នេះ ក៏ដើម្បីសម្ដែងត្រឹមតែអត្ថដោយបទ និងព្យញ្ជនៈដទៃប៉ុណ្ណោះ ។

[ ២៣៥ ] ពីរបទថា **បុរិមេ ឧបាទាយ** សេចក្ដីថា ប្រៀបធៀបបុគ្គលដែលត្រូវអាបត្តិបារាជិកទាំង ៣ មុនៗ ។ ពាក្យដ៏សេសឈ្មោះថា ប្រាកដជាក់ច្បាស់ហើយ ព្រោះមានន័យដូចពោលហើយខាងដើម និងព្រោះមានអត្ថជាក់ច្បាស់ ដូច្នេះឯង ។

សិក្ខាបទវិភង្គនៃចតុត្ថបារាជិក ចប់

# អធិប្បាយ
# បទភាជនីយ៍នៃចតុត្ថបារាជិក

[ ២៣៦ ] ព្រះមានព្រះភាគ កាលទ្រង់ចែកសិក្ខាបទដែលទ្រង់ឧទ្ទេសទុកតាមលំដាប់បទដូច្នេះហើយ ឥឡូវនេះ ទ្រង់មានបំណងនឹងតាំងបទភាជនៈនោះឯង ក្នុងឋានជាមាតិកាទៀត ហើយសម្ដែងឧត្តរិមនុស្សធម្មដោយពិស្ដារ សម្ដែងប្រភេទអាបត្តិ ដើម្បីកាន់យកអត្ថ ដោយអាការទាំងពួង ទើបត្រាស់ពាក្យថា ឈាននោះ បានដល់ បឋមជ្ឈាន ទុតិយជ្ឈានជាដើម ព្រោះថាក្នុងបទភាជនីយ៍ខាងដើម ទ្រង់បានសម្ដែងឧត្តរិមនុស្សធម្មទុកដោយសង្ខេបយ៉ាងនេះថា ឈាន វិមោក្ខ សមាធិ សមាបត្តិ ញាណទស្សនៈ ។បេ។ សេចក្ដីត្រេកអរចំពោះសុញ្ញាគារ ទ្រង់មិនបានលើកអាបត្តិ តាំងជាបែបផែនដោយពិស្ដារឡើយ កាលសម្ដែងអត្ថដោយសង្ខេបហើយ អ្នកសិក្សាទាំងឡាយ មិនអាចកាន់យកអត្ថបានដោយគ្រប់ចំនួន ។

ក្នុងបទថា **បឋមំ ឈានំ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះថា អប្បមញ្ញាឈាន មានមេត្តាឈានជាដើមក្ដី អសុភជ្ឈានជាដើមក្ដី អានាបានស្សតិសមាធិជ្ឈានក្ដី លោកិយជ្ឈានក្ដី លោកុត្តរជ្ឈានក្ដី សង្គ្រោះចូលដោយបឋមជ្ឈានជាដើមនោះឯង ព្រោះហេតុនោះ កាលភិក្ខុអួតថា ខ្ញុំចូលបឋមជ្ឈានហើយក្ដី ... ខ្ញុំចូលចតុត្ថជ្ឈានហើយក្ដី អួតថា ខ្ញុំចូលមេត្តាឈានក្ដី ... ខ្ញុំចូលឧបេក្ខាឈានក្ដី ខ្ញុំចូលអសុភជ្ឈានហើយក្ដី ខ្ញុំចូលអានាបានស្សតិសមាធិជ្ឈានហើយក្ដី ខ្ញុំចូលលោកិយជ្ឈានហើយក្ដី ខ្ញុំចូលលោកុត្តរជ្ឈានហើយក្ដី គប្បីជ្រាបថា ត្រូវអាបត្តិបារាជិកទាំងអស់ ។

អរិយមគ្គដែលផុតដោយល្អ ឬដែលផុតចាកកិលេស មានសភាពផ្សេងៗ ព្រោះដូច្នោះ ទើបអរិយមគ្គនោះ ឈ្មោះថា វិមោក្ខ ។ ឯវិមោក្ខនេះ លោកហៅថា សុញ្ញតវិមោក្ខ ព្រោះទទេចាករាគៈ ទោសៈ និងមោហៈ លោកហៅថា អនិមិត្តវិមោក្ខ ព្រោះមិនមាននិមិត្តដោយនិមិត្ត គឺរាគៈ ទោសៈ និងមោហៈ លោកហៅថា អប្បណិហិតវិមោក្ខ ព្រោះមិនមានទីតាំង គឺរាគៈ ទោសៈ និងមោហៈ ។ ធម្មជាតដែលឈ្មោះថា សមាធិ ព្រោះអត្ថថា តាំងចិត្តទុកស្មើ គឺតាំងចិត្តទុកក្នុងអារម្មណ៍ ។ ដែលឈ្មោះថា សមាបត្តិ ព្រោះជាធម្មជាតដែលព្រះអរិយៈទាំងឡាយគប្បីចូល ។ បទដ៏សេស ក្នុងពាក្យទាំងនេះមានន័យដូចពោលហើយនោះឯង ។ អរិយមគ្គ ព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងតិកៈទាំងនេះ ដោយពួក ៣ នៃវិមោក្ខ និងដោយពួក ៣ នៃសមាធិ ផលសមាបត្តិ ត្រាស់ទុកដោយពួក ៣ នៃសមាបត្តិ ។ ក្នុងបទទាំងនោះ ភិក្ខុកាន់យកបទឯណានីមួយ ត្រឹមតែមួយបទ ពោលថា ខ្ញុំមានប្រក្រតីបានធម៌នេះ រមែងជាបារាជិកដោយពិត ។

ដែលឈ្មោះថា វិជ្ជា ៣ បានដល់ បុព្វេនិវាសានុស្សតិ ទិព្វចក្ខុ អាសវក្ខយញ្ញាណនោះឯង ។ ក្នុងវិជ្ជា ៣ នោះ កាលភិក្ខុកាន់យកឈ្មោះនៃវិជ្ជាណាមួយ អួតថា ខ្ញុំមានប្រក្រតីបានវិជ្ជានេះ រមែងត្រូវអាបត្តិបារាជិកដោយពិត ។ តែក្នុងសង្ខេបអដ្ឋកថា ពោលថា កាលភិក្ខុពោលថា ខ្ញុំមានប្រក្រតីបានវិជ្ជាទាំងឡាយដូច្នេះក្តី ពោលថា ខ្ញុំមានប្រក្រតីបានវិជ្ជា ៣ ដូច្នេះក្តី រមែងត្រូវអាបត្តិបារាជិកដូចគ្នា ។ មគ្គភាវនាបានពោលហើយក្នុងបទ

ភាជនីយ៍ ។ ពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលសម្បយុត្តដោយមគ្គ ជាលោកុត្តរពិត លោកបំណងយកក្នុងបទថា **មគ្គភាវនា** នេះ ព្រោះហេតុនោះ ទើបក្នុងមហាអដ្ឋកថា ពោលថា ត្រូវអាបត្តិបារាជិកដល់ភិក្ខុ ដែលពោលថា ខ្ញុំមានប្រក្រតីបានសតិប្បដ្ឋានដែលជាលោកុត្តរ ខ្ញុំមានប្រក្រតី បានសម្មប្បធាន ... ឥទ្ធិបាទ ... ឥន្ទ្រិយ ... ពល .... ពោជ្ឈង្គ ... អរិយមគ្គមានអង្គ ៨ ដែលជាលោកុត្តរ ។

ចំណែកក្នុងមហាបច្ចរីជាដើម ពោលថា កាលភិក្ខុពោលដោយអំណាចចំណែកនីមួយៗ យ៉ាងនេះថា ខ្ញុំជាអ្នកមានប្រក្រតី បានសតិប្បដ្ឋានដូច្នេះក្តី ដោយអំណាចធម៌នីមួយៗ ក្នុងចំណែកទាំងនោះ យ៉ាងនេះថា ខ្ញុំជាអ្នកមានប្រក្រតីបានកាយានុបស្សនាសតិប្បដ្ឋានដូច្នេះក្តី ត្រូវអាបត្តិបារាជិកដូចគ្នា ។ ពាក្យដែលលោកពោលក្នុងមហាបច្ចរីជាដើមនោះ រមែងសមគ្នា ព្រោះហេតុអ្វី ព្រោះដែលលោកពោលសំដៅយកសតិប្បដ្ឋាន ដែលកើតឡើងក្នុងខណៈនៃមគ្គដូចគ្នា ។ សូម្បីក្នុងការធ្វើឲ្យជាក់ច្បាស់នូវផល ក៏គប្បីជ្រាបថា ត្រូវអាបត្តិបារាជិក ដោយអំណាចនៃផលនីមួយៗ ។ ចំពោះការលះកិលេស ព្រះដ៏មានព្រះភាគត្រាស់ក្នុងពួក ៣ មានពាក្យថា **រាគស្ស បហានំ** ជាដើម ។ ការលះកិលេសនោះ វៀរមគ្គចេញហើយ រមែងមិនមាន ពិតហើយ ការលះរាគៈ និងទោសៈ រមែងមានដោយមគ្គទី ៣ ការលះមោហៈ រមែងមានដោយមគ្គទី ៤ ព្រោះហេតុនោះ ទើបត្រូវអាបត្តិបារាជិក ដល់ភិក្ខុដែលពោលពាក្យជាដើមថា រាគៈខ្ញុំលះបានហើយ ។ ចំពោះលោកុត្តរចិត្ត និងសមាបត្តិ

ព្រះដ៏មានព្រះភាគត្រាស់ក្នុងពួក ៣ មានពាក្យថា **រាគា ចិត្តំ វិនីវរណាតា** ជាដើម ។ ព្រោះហេតុនោះ កាលភិក្ខុពោលពាក្យជាដើមថា ចិត្តរបស់ខ្ញុំប្រាសចេញអំពីរាគៈ ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។ ចំណែកក្នុង បទភាជនៈនៃបទសុញ្ញាគារ លោកមិនបំណងកាត់បារាជិក ដោយត្រឹមតែពាក្យដែលមិនទាក់ទងដោយឈានថា ខ្ញុំត្រេកអរចំពោះក្នុងសុញ្ញាគារ ព្រោះដូច្នោះ ទើបលោកពោលពាក្យជាដើមថា ខ្ញុំត្រេកអរចំពោះក្នុងសុញ្ញាគារដោយបឋមជ្ឈាន ។ ព្រោះហេតុនោះ ភិក្ខុណាពោលទាក់ទងដោយឈានថា ខ្ញុំត្រេកអរចំពោះក្នុងសុញ្ញាគារ ដោយឈានឈ្មោះនេះ ភិក្ខុនេះឯងគប្បីជ្រាបថា ត្រូវបារាជិក ។

បណ្តាវិជ្ជា ៨ ដែលត្រាស់ក្នុងព្រះសូត្រទាំងឡាយ មានអម្ពដ្ឋសូត្រជាដើម វិជ្ជា ៥ ណា មានវិបស្សនាញាណ មនោមយិទ្ធិ ឥទ្ធិវិធី ទិព្វសោត និងចេតោបរិយញ្ញាណ មិនបានមកហើយក្នុងបទភាជនៈនៃបទថា **ញាណំ** នេះ បណ្តាវិជ្ជា ៥ នោះ ចំពោះវិបស្សនាតែម្យ៉ាង រមែងមិនជាវត្ថុនៃបារាជិក វិជ្ជាដ៏សេសគប្បីជ្រាបថា ជាវត្ថុនៃបារាជិក ។ ព្រោះហេតុនោះ កាលភិក្ខុពោលថា ខ្ញុំជាអ្នកមានប្រក្រតីបានវិបស្សនាក្តី ថា ខ្ញុំជាអ្នកមានប្រក្រតីបានវិបស្សនាញាណក្តី មិនទាន់ត្រូវបារាជិក ។ តែព្រះបុស្សទេវត្ថេរ ពោលថា វិជ្ជា ៤ ក្រៅអំពីនេះ មិនទាក់ទងដោយញាណ រមែងមិនជាវត្ថុនៃបារាជិក ព្រោះហេតុនោះ ទើបមិនត្រូវបារាជិកដល់ភិក្ខុដែលពោលថា ខ្ញុំជាអ្នកមានប្រក្រតីបានមនោមយៈ ខ្ញុំជាអ្នកមានប្រក្រតីបានឥទ្ធិវិធី ខ្ញុំជាអ្នកមានប្រក្រតីបានទិព្វសោតធាតុ ខ្ញុំជាអ្នកមានប្រក្រតីបានចេតោបរិយញ្ញាណ ។ ពាក្យនោះ

ត្រូវពួកអន្តេវាសិករបស់លោកនោះឯងជំទាស់ហើយថា លោកអាចារ្យមិនមែនជាអ្នកជំនាញក្នុងអភិធម្ម រមែងមិនជ្រាបធម៌ដែលជាភូមិដទៃ ដែលឈ្មោះថា អភិញ្ញា មានចតុត្ថជ្ឈានជាបាទផង ជាមហគ្គតធម៌ផង រមែងសម្រេចបានដោយឈានប៉ុណ្ណោះ ព្រោះហេតុនោះ ភិក្ខុទោះពោលថា ខ្ញុំជាអ្នកមានប្រក្រតីបានមនោមយៈ ឬពោលថា ខ្ញុំជាអ្នកមានប្រក្រតីបាន មនោមយញ្ញាណ ឬពោលដោយប្រការតាមដែលខ្លួនបំណងពោលក៏ដោយ ភិក្ខុរមែងត្រូវបារាជិកដូចគ្នា ។ ពិតហើយ ក្នុងចតុត្ថបារាជិកនេះ ព្រះនិព្វាន មិនបានមកក្នុងព្រះបាលីក៏ពិត តែទោះជាយ៉ាងនោះ កាលភិក្ខុពោលថា ព្រះនិព្វានខ្ញុំបានសម្រេចហើយ ឬពោលថា ព្រះនិព្វាន ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ រមែងត្រូវបារាជិកដូចគ្នា ។ ព្រោះហេតុអ្វី ព្រោះថា ព្រះនិព្វានជាលោកុត្តរធម៌ មានវដ្ដៈខ្ចាក់ចោលហើយ ។

ម្យ៉ាងទៀត កាលភិក្ខុពោលថា ខ្ញុំចាក់ធ្លុះអរិយសច្ច ៤ ឬសច្ចៈ ៤ ខ្ញុំបានចាក់ធ្លុះហើយ ត្រូវអាបត្តិបារាជិកដូចគ្នា ព្រោះហេតុអ្វី ព្រោះពាក្យថា ចាក់ធ្លុះអរិយសច្ច ជាពាក្យហៅចំពោះមគ្គ ។ ម្យ៉ាងទៀត លោកពោលទុកក្នុងវិភង្គថា បដិសម្ភិទា ៣ រមែងកើតឡើងក្នុងចិត្តុប្បាទដែលជាកាមាវចរ-កុសលញាណសម្បយុត្ត ៤ ដួង រមែងកើតឡើងក្នុងចិត្តុប្បាទកិរិយាញាណ-សម្បយុត្ត ៤ ដួង អត្ថប្បដិសម្ភិទា រមែងកើតឡើងក្នុងចិត្តុប្បាទទាំងនេះផង រមែងកើតឡើងក្នុងមគ្គ ៤ ផល ៤ ផង ព្រោះហេតុនោះ កាលភិក្ខុពោលពាក្យថា ខ្ញុំជាអ្នកមានប្រក្រតីបានធម្មប្បដិសម្ភិទា ឬពោលថា ខ្ញុំជាអ្នកមាន

ប្រក្រតីបាននិរុត្តិប្បដិសម្ភិទា ឬពោលថា ខ្ញុំជាអ្នកមានប្រក្រតីបានបដិ-ភាណប្បដិសម្ភិទា ឬពោលថា ខ្ញុំជាអ្នកមានប្រក្រតី បានលោកិយអត្ថប្បដិ-សម្ភិទា ដូច្នេះ មិនទាន់ត្រូវអាបត្តិបារាជិក ។ សូម្បីកាលភិក្ខុពោលពាក្យថា ខ្ញុំជាអ្នកមានប្រក្រតីបានបដិសម្ភិទាទាំងឡាយ អាបត្តិមិនទាន់ដល់ទីបំផុតទេ ។ តែកាលលោកពោលថា ខ្ញុំជាអ្នកមានប្រក្រតីបាន លោកុត្តរត្ថប្បដិសម្ភិទា រមែងត្រូវអាបត្តិបារាជិក ។

ចំណែកក្នុងសង្ខេបអដ្ឋកថា ពោលថា កាលភិក្ខុពោលដោយការមិនប្លែកគ្នាថា ខ្ញុំជាអ្នកបានសម្រេចអត្ថប្បដិសម្ភិទា ត្រូវអាបត្តិបារាជិក សូម្បីក្នុងកុរុន្ទី ក៏ពោលថា រមែងមិនរួចផុត តែក្នុងមហាអដ្ឋកថា ពោលថា មិនជាបារាជិកដោយហេតុត្រឹមប៉ុណ្ណេះ អាបត្តិមិនទាន់ដល់ទីបំផុតដោយហេតុត្រឹមប៉ុណ្ណេះ បុគ្គលណាមួយមិនអាចធ្វើអដ្ឋកថាដទៃឲ្យជាប្រមាណបាន ព្រោះលោក បានពិចារណាហើយថា ភិក្ខុមិនទាន់ត្រូវបារាជិក ដោយហេតុមានប្រមាណប៉ុណ្ណេះ ។ សូម្បីភិក្ខុពោលថា ខ្ញុំចូលនិរោធសមាបត្តិ ឬថា ខ្ញុំជាអ្នកមានប្រក្រតីបាននិរោធសមាបត្តិនោះ ក៏មិនត្រូវបារាជិក ព្រោះហេតុអ្វី ព្រោះថា និរោធសមាបត្តិមិនមែនលោកិយ និងមិនមែនលោកុត្តរ ដូច្នេះឯង ។

ក្នុងមហាបច្ចរី និងសង្ខេបអដ្ឋកថា ពោលថា បើបុគ្គលនោះមានការរំពឹងយ៉ាងនេះថា ព្រះអនាគាមី ឬព្រះខីណាស្រព រមែងចូលនិរោធបាន ទើបព្យាករដោយធ្វើទុកក្នុងចិត្តថា ជនទាំងឡាយនឹងដឹងអញថា ជាបុគ្គលណាមួយ ក្នុងបណ្តាព្រះអនាគាមី និងព្រះខីណាស្រពទាំងនោះ ហើយអ្នកដទៃ

ក៏យល់ភិក្ខុនោះយ៉ាងនោះ ត្រូវអាបត្តិបារាជិក ពាក្យនេះ គួរពិចារណាជាមុនសិន សឹមកាន់យក ។ កាលភិក្ខុពោលថា ក្នុងភពដែលកន្លងទៅហើយ គឺក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ខ្ញុំជាព្រះសោតាបន្ន មិនត្រូវបារាជិកឡើយ ពិតហើយ អាបត្តិមិនដល់ទីបំផុត ព្រោះភិក្ខុសំដៅដល់ខន្ធដែលកន្លងទៅហើយ ដូច្នេះ ។

ចំណែកក្នុងសង្ខេបអដ្ឋកថា ពោលថា អាចារ្យខ្លះពោលថា កាលភិក្ខុពោលថា ខ្ញុំជាអ្នកមានប្រក្រតីបានសមាបត្តិ ៨ ក្នុងអតីត មិនត្រូវអាបត្តិបារាជិក ព្រោះសមាបត្តិ ៨ ក្នុងអតីត ជាកុប្បធម៌ ( ធម៌ដែលកម្រើក ) តែបើពោលថា ខ្ញុំជាអ្នកមានប្រក្រតីបានសមាបត្តិ ៨ ក្នុងភពនេះ ដូច្នេះ រមែងត្រូវបារាជិក ព្រោះសមាបត្តិ ៨ ក្នុងភពនេះ ជាអកុប្បធម៌ ។ ពាក្យដែលពោលទុកក្នុងសង្ខេបអដ្ឋកថានោះ លោកពោលជំទាស់ក្នុងសង្ខេបអដ្ឋកថានោះឯងថា កាលភិក្ខុពោលសំដៅយកអត្តភាពក្នុងអតីត មិនត្រូវបារាជិក ទាល់តែពោលសំដៅយកអត្តភាពក្នុងបច្ចុប្បន្ននេះឯង ទើបត្រូវបារាជិក ។

## សុទ្ធិកមហាវារកថា

## ពោលអំពីសុទ្ធិកវារៈ

[ ២៣៧-២៥៤ ] ព្រះមានព្រះភាគ កាលទ្រង់ញ៉ាំងបទមាតិកា ១០ មានឈានជាដើមឲ្យពិស្តារយ៉ាងនេះហើយ ឥឡូវនេះ ភិក្ខុអ្នកពោលអួតឧត្តរិមនុស្សធម្ម រមែងពោលសម្បជានមុសាវាទណា ( កុហកទាំងដឹងខ្លួន )

កាលទ្រង់សម្តែងអង្គនៃសម្បជានមុសាវាទនោះហើយ ធ្វើចក្កបេយ្យាលទុក ដោយអំណាចនៃសេចក្តីពិស្តារនោះឯង ដើម្បីសម្តែងអាការនៃការអួត និង ប្រភេទនៃអាបត្តិ ទើបត្រាស់ថា **តីហាការេហិ** ដូច្នេះជាដើម ។

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូចតទៅនេះថា មហាវារៈ ៣ គឺសុទ្ធិកវារៈ ( វារៈកំណត់ដោយការអួតសុទ្ធ ) ១ វត្ថុកាមវារៈ ( វារៈកំណត់ដោយភិក្ខុ ដែលបំណងនឹងអួត ) ១ បច្ចយបដិសំយុត្តវារៈ ( វារៈកំណត់ដោយការ អួតដែលទាក់ទងដោយបច្ច័យ ) ១ បណ្តាមហាវារៈ ៣ នោះ ក្នុងសុទ្ធិកវារៈ ៦ បទ គឺ **សមាបជ្ជឹ សមាបជ្ជាមិ សមាបន្នោ លាភិម្ហិ វសិម្ហិ សច្ឆិកតំ មយា** ទ្រង់ប្រកបបទនីមួយៗ ៥ ដងយ៉ាងនេះថា ដោយអាការ ៣ ដោយ អាការ ៤ ដោយអាការ ៥ ដោយអាការ ៦ ដោយអាការ ៧ ក្នុងបទមួយៗ ផ្តើមពីបឋមជ្ឈាន រហូតដល់បទថា ដោះចិត្តចាកមោហៈ ត្រាស់ឈ្មោះថា សុទ្ធិកន័យ ។

[ ២៥៥-២៦៦ ] លំដាប់នោះ កាលទ្រង់បន្តបទនីមួយៗ ជាមួយ បឋមជ្ឈានយ៉ាងនេះថា នូវបឋមជ្ឈាន នូវទុតិយជ្ឈាន ដូច្នេះ ទ្រង់តគ្រប់ៗ បទ ត្រាស់ឈ្មោះថា ខណ្ឌចក្ក ដោយអត្ថដែលពិស្តារនោះឯង អធិប្បាយថា ខណ្ឌចក្កនោះ ឈ្មោះថា ខណ្ឌចក្ក ព្រោះទ្រង់មិននាំមកប្រកបជាមួយឈាន មានបឋមជ្ឈានជាដើមទៀត ។

[ ២៦៧ ] លំដាប់នោះ ទ្រង់តបទនីមួយៗ ជាមួយទុតិយជ្ឈានយ៉ាង នេះថា នូវទុតិយជ្ឈាន នូវតតិយជ្ឈាន ដូច្នេះ ហើយទ្រង់នាំមកភ្ជាប់ជាមួយ

បឋមជ្ឈានទៀត ត្រាស់ឈ្មោះថា ពទ្ធចក្ក ដោយអត្ថដែលពិស្តារនោះឯង ។ លំដាប់នោះ ទ្រង់តបទនីមួយៗ ជាមួយឈាន មានតតិយជ្ឈានជាដើម តែម្យ៉ាង និងតបទនីមួយៗ ជាមួយទុតិយជ្ឈាន ហើយទ្រង់នាំមកភ្ជាប់ជាមួយឈាន មានទុតិយជ្ឈានជាដើមទៀត ត្រាស់ពទ្ធចក្ក ២៩ ដងទៀត ដោយអត្ថដែលពិស្តារនោះឯង ឲ្យសម្រេចជាឯកមូលកន័យហើយ ។

[ ២៦៨ ] ម្យ៉ាងទៀត បាឋៈ ព្រះអង្គទ្រង់ក៏សម្តែងទុកដោយសង្ខេប ។ បាឋៈនោះ ដែលអ្នកសិក្សាមិនវង្វេង គួរជ្រាបដោយពិស្តារ ។

[ ២៦៩ ] ក្នុងទុមូលកន័យជាដើម ទ្រង់ក៏ត្រាស់ដូចឯកមូលកន័យ ហើយបានត្រាស់ន័យ ៤៣៥ ន័យ ដែលមានសព្វមូលកន័យជាទីបំផុត ។ មូលនោះដូចម្តេច គឺត្រាស់ទ្វិមូលកន័យ ២៩ ត្រាស់តិមូលកន័យ ២៨ ត្រាស់ចតុមូលកន័យ ២៧ ។ សូម្បីក្នុង បញ្ចមូលកន័យជាដើម អ្នកសិក្សាក៏គួរបន្ថយចុះ ១ ន័យ ហើយជ្រាបរហូតដល់តឹសមូលកន័យយ៉ាងនេះ ។ ក្នុងបាឋៈ លោកសង្ខេបឈ្មោះរបស់ន័យទាំងនោះហើយ សម្តែងចំពោះតឹសមូលកន័យតែម្តងថា នេះជាមូលកន័យទាំងអស់ ។ ក៏ព្រោះភិក្ខុមិនតបទសុញ្ញាគារចូលជាមួយឈាន ( អាបត្តិ ) ទើបមិនទាន់ដល់ទីបំផុត ហេតុនោះ គួរប្រកបសេចក្តីក្នុងបទទាំងពួង មានបទថា ដោះចិត្តចាកមោហៈជាទីបំផុតនោះឯង គប្បីជ្រាបថា លោកសម្តែងហើយ ព្រោះមិនប៉ះពាល់បទសុញ្ញាគារនោះ ។ ឯក្នុងសុទ្ធិកមហាវារៈជុំទី ១ ដែលព្រះឧបាលីពោលដោយអំណាចការសម្តែងអត្ថនោះថា កាលភិក្ខុតក្តី មិនតក្តី នូវបឋមជ្ឈានជាដើមជាមួយទុតិយជ្ឈាន

ជាដើមតាមលំដាប់ក្តី ខុសលំដាប់ក្តី ហើយអួតដោយន័យថា ខ្ញុំចូលហើយ ជាដើមយ៉ាងនេះ ការរួចផុតអាបត្តិរមែងមិនមាន រមែងត្រូវបារាជិកពិតនោះឯង នេះជាការពណ៌នាអត្ថ ដោយសង្ខេប ។

[ ២៧០ ] បទថា **តីហាការេហិ** គឺដោយហេតុ ៣ យ៉ាង ដែលជាអង្គនៃសម្បជានមុសាវាទ ។

បទថា **បុព្វេវស្ស ហោតិ** សេចក្តីថា ក្នុងចំណែកខាងដើមនោះឯង បុគ្គលនោះរមែងមានការគិតយ៉ាងនេះថា អញនឹងពោលកុហក ។

បទថា **ភណន្តស្ស ហោតិ** សេចក្តីថា បុគ្គលនោះកំពុងពោល រមែងមានការដឹងយ៉ាងនេះថា អញកំពុងពោលកុហក ។

បទថា **ភណិតស្ស ហោតិ** សេចក្តីថា កាលពោលកុហកហើយ បុគ្គលនោះ រមែងមានការដឹងយ៉ាងនេះថា អញពោលកុហកហើយ ។ អធិប្បាយថា កាលភិក្ខុពោលពាក្យដែលគប្បីពោលនោះហើយ រមែងមានការដឹងយ៉ាងនេះ ។

ម្យ៉ាងទៀត បទថា **ភណិតស្ស** សេចក្តីថា ការដឹងយ៉ាងនោះ រមែងមានដល់បុគ្គលនោះ ជាអ្នកមានពាក្យដែលពោលហើយ គឺមានពាក្យពោលសម្រេចហើយ ។ ក្នុងអង្គនៃសម្បជានមុសាវាទនេះ លោកសម្តែងអត្ថទុកដូច្នេះថា ភិក្ខុណាខាងដើមក៏ដឹងយ៉ាងនេះ កំពុងពោលក៏ដឹង ខាងក្រោយក៏ដឹងថា អញពោលកុហកហើយ ភិក្ខុនោះ កាលពោលថា ខ្ញុំចូលបឋមជ្ឈានដូច្នេះ រមែងត្រូវបារាជិក ។ ទោះជាលោកសម្តែងអត្ថទុកហើយក៏ពិត សូម្បី

យ៉ាងនោះ ក្នុងអង្គនៃសម្បជានមុសាវាទនេះ គង់មានសេចក្ដីប្លែកគ្នាដូច្នេះថា មានពាក្យសួរដំបូងថា ខាងដើមភិក្ខុគិតថា អញនឹងពោលមុសា មាន ឯខាងក្រោយថា អញនិយាយមុសាហើយ មិនមាន ពិតហើយ បុគ្គលខ្លះ រមែងភ្លេចពាក្យសម្ដី ដោយគ្រាន់តែនិយាយចេញទៅនោះឯង ភិក្ខុនោះត្រូវបារាជិកឬមិនត្រូវ ។

ពាក្យសួរនោះ លោកដោះស្រាយទុកហើយ ក្នុងអដ្ឋកថាទាំងឡាយយ៉ាងនេះថា អញនឹងពោលកុហកក្នុងខាងដើម កាលកំពុងពោលក៏ដឹងថា អញកំពុងពោលកុហក ការមិនដឹងថា អញនិយាយកុហកហើយ ក្នុងខាងក្រោយ មិនអាចមាន ទោះបីមានក៏ត្រូវបារាជិកដូចគ្នា ព្រោះអង្គ ២ ខាងដើមនោះឯង ជាអង្គសំខាន់ ។ សូម្បីភិក្ខុណាដំបូង មិនមានការគិតថា អញនឹងពោលកុហក តែខណៈពោល រមែងដឹងថា អញពោលកុហក កាលពោលហើយ ក៏ដឹងថា អញពោលកុហកហើយ ភិក្ខុនោះ ព្រះវិនយធរ មិនគប្បីកាត់អាបត្តិ ព្រោះចំណែកខាងដើមសំខាន់ជាង បើចំណែកខាងដើមនោះមិនមាន ជាការដែលលោកពោលលេង ឬពោលភ្លាត់ទៅក៏ថាបាន ដូច្នេះឯង ។

ឯក្នុងពាក្យថា **មុសា ភាណិស្សំ** ជាដើមនេះ គួរលះការដឹង និងការប្រជុំព្រមនៃការដឹងចេញ ។

ពាក្យថា គួរលះការដឹងនោះចេញ បានដល់ គប្បីលះការដឹងនោះថា រមែងដឹងបានក្នុង ៣ ខណៈ ដោយចិត្ត ១ ដួងប៉ុណ្ណោះយ៉ាងនេះថា ភិក្ខុកំពុងដឹងថា អញនឹងពោលកុហក ដូច្នេះ ដោយចិត្តដួងណា រមែងដឹងថា

អញកំពុងពោលកុហក និងដឹងថា អញពោលកុហកហើយ ដូច្នេះ ដោយចិត្ត ១ ដួងនោះឯង ។ ពិតហើយ បុគ្គលណាមិនអាចដឹងចិត្តដោយចិត្តដួងនោះឯងបាន ដូចបុគ្គលមិនអាចយកដាវមួយដើមនោះ កាត់ដាវខ្លួនឯងនោះឯងបានឡើយ ដូច្នេះឯង ។ ឯចិត្តដួងដែលកើតឡើងមុនៗ ជាបច្ច័យនៃការកើតឡើងយ៉ាងនោះរបស់ចិត្តដួងក្រោយៗ ហើយរមែងរលត់ទៅ ។ ដោយហេតុនោះ ទើបបណ្ឌិតពោលពាក្យនេះថា

> ចំណែកខាងដើមប៉ុណ្ណោះ ជាប្រមាណ កាលចំណែកខាងដើមនោះមាន ពាក្យថា ពីរបទដ៏សេសនឹងមិនមានដូច្នេះនោះ រមែងមិនមាន ព្រោះដូច្នោះ ទើបវាចា ឈ្មោះថា មានអង្គ ៣ ។

ពាក្យថា គួរលះការប្រជុំព្រមនៃការដឹង សេចក្តីថា ចិត្ត ៣ ដួងនេះ មិនគួរកាន់យកថា កើតឡើងក្នុងខណៈតែមួយ ។ ពិតហើយ ធម្មតាចិត្តនេះ រមែងប្រាកដដូចជាដួងមួយ ព្រោះកើតឡើងជាប់តគ្នា កាលចិត្តដួងដំបូងមិនទាន់រលត់ ចិត្តដួងក្រោយក៏មិនកើតឡើង ដូច្នេះឯង ។

ខ្ញុំនឹងពោលពាក្យបន្ទាប់អំពីពាក្យនេះតទៅថា បុគ្គលណា រមែងពោលសម្បជានមុសាវាទថា ខ្ញុំចូលបឋមជ្ឈាន បុគ្គលនោះ រមែងជាអ្នកមានការឃើញយ៉ាងនេះថា បឋមជ្ឈានរបស់អញ រមែងមិនមាន ពិតហើយ លទ្ធិនេះរបស់បុគ្គលនោះមានពិត ម្យ៉ាងទៀត លទ្ធិយ៉ាងនេះថា បឋមជ្ឈានរបស់អញរមែងមិនមាន ដូច្នេះ រមែងគាប់ចិត្ត និងពេញចិត្តដល់បុគ្គលនោះ ហើយ

បុគ្គលនោះមានចិត្ត មានសភាពយ៉ាងនេះឯងថា បឋមជ្ឈានរបស់អញ រមែង មិនមាន ឯក្នុងកាលណាខ្លួនជាបុគ្គលប្រាថ្នានឹងពោលកុហក ក្នុងកាលនោះ បុគ្គលនោះលះ គឺលះបង់ចោលនូវការបិទបាំងទិដ្ឋិនោះក្តី ការគាប់ចិត្តផង ទិដ្ឋិ និងការគាប់ចិត្តក្តី ទិដ្ឋិផង ការគាប់ចិត្តផង ការពេញចិត្តផងក្តី ទិដ្ឋិផង ការ គាប់ចិត្តផង ការពេញចិត្តផង ការពិតត្រង់ផងក្តី ហើយពោលពាក្យឲ្យជា ពាក្យកុហក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ចតូហិ អាការេហិ** ជាដើម ដើម្បីសម្តែងការផ្សេងគ្នានៃអង្គ ដោយអំណាចការឃើញជាដើមទាំង នោះ ។ ក៏ព្រោះក្នុងគម្ពីរបរិវារពោលថា មុសាវាទមានអង្គ ៨ ក្នុងអធិការ នេះ ទើបគួរប្រកបន័យមួយថា **អដ្ឋហាការេហិ** ជាន័យមួយទៀត ផ្សំនឹង សញ្ញា ដែលលោកបំណងក្នុងគម្ពីរបរិវារនោះ ។

ឯបណ្តាបទទាំងនេះ បទថា **វិនិធាយ ទិដ្ឋឹ** ទ្រង់ត្រាស់ដោយអំណាច ការលះធម៌ដែលមានកម្លាំងចេញ ។

បទថា **វិនិធាយ ខន្តឹ** ជាដើម ទ្រង់ត្រាស់ដោយអំណាចការលះធម៌ ទាំងឡាយដែលខ្សោយកម្លាំង ដែលថយកម្លាំងជាងធម៌ដែលមានកម្លាំងនោះ។

ឯបទថា **វិនិធាយ សញ្ញំ** នេះ ឈ្មោះថា ត្រឹមតែជាសញ្ញាដែល ប្រព្រឹត្តទៅដោយអំណាចការលះធម៌ ដែលទុព្វលកម្លាំងជាងធម៌ទាំងពួនក្នុងទី នេះ ។

បានៈថា មិនលះ នឹងពោលសម្បជានមុសាវាទនេះ នឹងមិនមាន ព្រោះ មិនត្រូវបារាជិក ដោយពាក្យដែលសំដៅដល់អនាគតជាដើមថា ខ្ញុំនឹងចូល

ហេតុដូច្នោះ បទដែលសំដៅដល់អតីត និងបច្ចុប្បន្នថា ខ្ញុំចូលហើយជាដើម ប៉ុណ្ណោះ គប្បីជ្រាបថា ទ្រង់ត្រាស់ទុកក្នុងព្រះបាលី ។

[ ២៧១-២៧៧ ] ខាងមុខអំពីនេះទៅ ពាក្យទាំងអស់ក្នុងសុទ្ធិកមហាវារៈនេះ មានអត្ថរាក់ទាំងអស់ហើយ ។ ពិតហើយ ក្នុងសុទ្ធិកមហាវារៈនេះ មិនមានពាក្យ ដែលមិនអាចដឹងបានដោយវិនិច្ឆ័យនេះ វៀរតែអត្ថនៃបទថា **រាគោ មេ ចត្តោ វន្តោ** ជាដើម ក្នុងបទភាជនីយ៍នៃបទថា ការលះកិលេស ។ អត្ថនេះ ខ្ញុំនឹងពោលតទៅថា បណ្តាបទទាំងនេះ បទថា **ចត្តោ** នេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចការលះភាវៈនៃខ្លួន ។

បទថា **វន្តោ** នេះ ទ្រង់ត្រាស់ដោយអំណាចសម្តែងភាវៈ ដែលរាគៈប្រកាន់មិនបានទៀត ។

បទថា **មុត្តោ** នេះ ត្រាស់ដោយអំណាចការផុតចាកសន្តតិ ។

បទថា **បហីនោ** នេះ ទ្រង់ត្រាស់ដោយអំណាចសម្តែងការតាំងចុះមិនបាន ក្នុងទីណាមួយ នៃរាគៈដែលរួចផុតទៅហើយ ។

បទថា **បដិនិស្សដ្ឋោ** នេះ ត្រាស់ដោយអំណាចសម្តែងការលះបង់រាគៈដែលធ្លាប់ប្រកាន់ទុកក្នុងខាងដើមចេញ ។

បទថា **ឧក្ខេដិតោ** នេះ ត្រាស់ដោយអំណាចសម្តែងភាវៈដែលត្រឡប់កើតមិនបានទៀត ព្រោះត្រូវអរិយមគ្គដកឡើងហើយ ។ អត្ថនេះ អ្នកសិក្សាទាំងឡាយ គប្បីគ្នាន់គ្នេរចាកគម្ពីរសេពួសាស្រ្តចុះ ។

បទថា **សមុក្ខេដិតោ** នេះ ទ្រង់ត្រាស់ទុកដោយអំណាចសម្តែងភាវៈ

ដែលវិលត្រឡប់មិនបានទៀតនៃរាគៈ ដែលសហគតៈត្រឹមបន្តិចបន្តួច ព្រោះដកឡើងជាសមុច្ឆេទ ដោយប្រការដូច្នេះ ។

សុទ្ធិកវារកថា ចប់

## ពោលអំពីវត្ថុកាមវារៈ

[ ២៧៨ ] អត្ថនៃបទថា **តីហាការេហិ** ជាដើម និងប្រភេទនៃវារៈ ៥០ពេយ្យាលទាំងពួងក្នុងវត្ថុកាមវារៈ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងសុទ្ធិកវារៈនេះឯង ។ ឯវត្ថុកាមវារៈនេះ ព្រះដ៏មានព្រះភាគត្រាស់ដើម្បីរាំងឱកាសបាបបុគ្គលទាំងឡាយតែម្យ៉ាង ដែលស្វែងរកឱកាសយ៉ាងនេះថា ពាក្យនេះ អញបំណាងនឹងពោលពាក្យដទៃ ពោលខុសជាពាក្យដទៃ ព្រោះដូច្នោះទើបអាបត្តិមិនមានដល់អញ ។ ដូចភិក្ខុប្រាថ្នានឹងពោលថា **ពុទ្ធំ បច្ចក្ខាមិ** កាលពោលបទណានីមួយ បណ្តាបទសម្រាប់លាសិក្ខា មានបទថា **ធម្មំ បច្ចក្ខាមិ** ជាដើម រមែងជាការពោលលាសិក្ខាហើយពិត ព្រោះបទទាំងនោះឈមចុះក្នុងខេត្ត យ៉ាងណា សេចក្តីនេះក៏ដូច្នោះ ភិក្ខុណាប្រាថ្នានឹងពោលបទណានីមួយ បណ្តាបទឧត្តរិមនុស្សធម្ម មានបឋមជ្ឈានជាដើម កាលពោលបទដទៃណាមួយ ក្រៅអំពីបទនោះ រមែងត្រូវបារាជិកនោះឯង ព្រោះបទនោះឈមចុះក្នុងខេត្ត ។ បើលោកពោលដល់បុគ្គលណា បុគ្គលនោះ រមែងដឹង

សេចក្តីនោះក្នុងខណៈនោះភ្លាម ។ ឯលក្ខណៈនៃការដឹងក្នុងការអួតឧត្តរិ-មនុស្សធម្ម ដែលមិនមានពិតនេះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងការពោលលាសិក្ខានោះឯង ។ តែការប្លែកគ្នាមានដូច្នេះថា ការពោលលាសិក្ខារមែងមិនដល់នូវការសម្រេចដោយហត្ថមុទ្ទា ( ដោយការផ្ចាត់ម្រាមដៃ ) ការអួតឧត្តរិមនុស្សធម្មដែលមិនមានពិតនេះ រមែងឈមចុះ គឺសម្រេចហត្ថ-មុទ្ទា ។ ពិតហើយ ភិក្ខុណាពោលអួតឧត្តរិមនុស្សធម្មដែលមិនមានពិត ដោយការកម្រើកអវយវៈតូចធំ មានហត្ថវិការ ( ការកម្រើកដៃ ) ជាដើមដល់បុគ្គលដែលឈរនៅក្នុងគន្លងនៃវិញ្ញត្តិ ។ ហើយបុគ្គលនោះដឹងអត្ថនោះបាន ភិក្ខុនោះត្រូវអាបត្តិបារាជិកពិត ។ តែបើភិក្ខុប្រាប់ដល់បុគ្គលណា បុគ្គលនោះមិនយល់ ឬដល់នូវការសង្ស័យថា ភិក្ខុនេះនិយាយអ្វី ឬពិចារណាយូរទើបដឹងក្នុងកាលជាក្រោយ រមែងដល់នូវការរាប់ថា បុគ្គលមិនយល់ភ្លាមៗ ដូចគ្នា ។ កាលភិក្ខុប្រាប់ដល់បុគ្គលដែលមិនយល់ភ្លាមយ៉ាងនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ឯបុគ្គលណាមិនស្គាល់ឧត្តរិមនុស្សធម្ម មានឈានជាដើមដោយខ្លួនឯង ដោយអំណាចការបានសម្រេច ឬដោយអំណាចការរៀន និងការសាកសួរជាដើម បានឮតែត្រឹមពាក្យថា ឈាន ឬពាក្យថា វិមោក្ខតែម៉្យាងប៉ុណ្ណោះ បុគ្គលនោះ កាលភិក្ខុនោះប្រាប់ហើយ បើដឹងបានត្រឹមប៉ុណ្ណោះថា បានឮថា ភិក្ខុនេះពោលថា ខ្ញុំចូលឈានហើយ ដូច្នេះ រមែងដល់នូវការរាប់ថា ដឹងដូចគ្នា កាលភិក្ខុនោះប្រាប់ដល់បុគ្គលនោះ ត្រូវអាបត្តិបារាជិកពិត ។ សេចក្តីប្លែកគ្នាដោយអំណាចបុគ្គលម្នាក់ ពីរនាក់ ឬច្រើននាក់ ដែលភិក្ខុ

កំណត់ទុក ឬមិនបានកំណត់ទុកទាំងអស់នោះ គប្បីជ្រាបតាមន័យដែលពោល ហើយ ក្នុងកថាពោលអំពីការពោលលាសិក្ខានោះឯង ដោយប្រការដូច្នេះ ។

វត្ថុកាមវារកថា ចប់

# ពោលអំពី បច្ចយបដិសំយុត្តវារៈ

[ ២៧៩ ] ក្នុងបច្ចយបដិសំយុត្តវារៈ ទាក់ទងដោយបច្ច័យ គប្បីជ្រាបប្រភេទនៃវារៈបេយ្យាលទាំងអស់ និងអត្ថនៃបទដែលមកខាងដើម ដោយន័យដែលពោលហើយនោះឯង ហើយជ្រាបលំដាប់ព្រះបាលីយ៉ាងនេះមុន ។ ក្នុងបច្ចយបដិសំយុត្តវារៈនេះ លោកពោលវារៈកំណត់ដោយបឋមាវិភត្តិទាំង ៥ នេះថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ១ ភិក្ខុណាបរិភោគចីវររបស់អ្នក ១ ភិក្ខុណាឆាន់បិណ្ឌបាតរបស់អ្នក ១ ភិក្ខុណាប្រើប្រាស់សេនាសនៈរបស់អ្នក ១ ភិក្ខុណាបរិភោគគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់អ្នក ១ ដូច្នេះ ពោលវារៈកំណត់ដោយតតិយាវិភត្តិ ៥ មានពាក្យថា វិហាររបស់អ្នកដែលភិក្ខុណាប្រើប្រាស់ហើយជាដើម ពោលវារៈកំណត់ដោយទុតិយាវិភត្តិ ៥ មានពាក្យថា អ្នកអាស្រ័យភិក្ខុណា ទើបបានប្រគេនវិហារដូច្នេះជាដើម គប្បីជ្រាបប្រភេទនៃ វារៈបេយ្យាលគ្រប់ៗ បទ មានបឋមជ្ឈានជាដើម ដែលលោកពោលទុកខាងដើម ព្រមទាំងបទសុញ្ញាគារដែលពោលហើយ ក្នុងបច្ចយ-

បដិសំយុត្តវារៈនេះ ដោយអំណាចនៃវារៈទាំងនោះ ។

[ ២៨០ ] ក្នុងបច្ចយបដិសំយុត្តវារៈនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ព្រោះភិក្ខុពោលដោយអមយ៉ាងនេះថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក វិហាររបស់អ្នកដែលភិក្ខុណានៅហើយ អ្នកអាស្រ័យភិក្ខុណាទើបបានប្រគេនវិហារ និងព្រោះភិក្ខុមិនបានពោលថា ខ្ញុំ ក្នុងបច្ចយបដិសំយុត្តវារៈនេះ កាលពោលអួតឧត្តរិមនុស្សធម្មដល់បុគ្គលដែលយល់បានភ្លាម ទើបត្រូវអាបត្តិថុល្លច្ច័យ ពោលអួតដល់បុគ្គលដែលមិនយល់បានភ្លាម ទើបត្រូវអាបត្តិទុក្កដ ។

[ ២៨១ ] ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃអាបត្តិ ដោយអំណាចសេចក្តីពិស្តារយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សម្តែងអនាបត្តិ ទើបត្រាស់ពាក្យថា **អនាបត្តិ អធិមានេន** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អធិមានេន** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលអួត ដោយសម្គាល់ថា ខ្លួនបានសម្រេច ។

បទថា **អនុល្លបនាធិប្បាយស្ស** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនបានតាំងនៅក្នុងឥច្ឆាចារ ដោយភាពជាអ្នកបោកបញ្ឆោត មិនបំណងនឹងអួត ព្យាករអរហត្តផល ក្នុងសម្នាក់របស់សព្រហ្មចារីទាំងឡាយ ។ ភិក្ខុឆ្កួតជាដើម មានន័យដូចពោលហើយខាងដើមនោះឯង ។ម្យ៉ាងទៀត ភិក្ខុទាំងឡាយ ដែលចាំវស្សាជិតមាត់ស្ទឹងវគ្គុមុទា ជាបុគ្គលដើមបញ្ញត្តិក្នុងសិក្ខាបទនេះ មិនត្រូវអាបត្តិដល់ភិក្ខុទាំងនោះ ដូច្នេះឯង ។

# បកិណ្ណកកថា

ក្នុងសមុដ្ឋានជាដើម មានវិនិច្ឆ័យដូច្នេះថា សិក្ខាបទនេះមានសមុដ្ឋាន ៣ គឺកើតអំពីកាយ និងចិត្តរបស់ភិក្ខុអ្នកអួតដោយមេដៃ ១ កើតអំពីវាចា និងចិត្តរបស់ភិក្ខុដែលអួតដោយការបន្ទឺវាចា ១ កើតអំពីកាយ វាចា និងចិត្ត របស់ភិក្ខុដែលធ្វើទាំងពីរយ៉ាង ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម វចីកម្ម ជាអកុសលចិត្ត មានវេទនា ៣ ។ ពិតហើយ ភិក្ខុរមែងពោលអួតទាំងដែលមានសោមនស្ស សប្បាយចិត្តក៏មាន ខ្លាចហើយអួតក៏មាន មានខ្លួនជាកណ្តាលអួតក៏មាន ។

បច្ចយបដិសំយុត្តវារកថា ចប់

បទភាជនីយ៍នៃចតុត្ថបារាជិក ចប់

# អធិប្បាយ
# វិធីតវត្តក្នុងចតុត្ថបារាជិក

[ ២៨៣ ] ក្នុងរឿងសម្គាល់ថា បានសម្រេច ក្នុងវិនីតវត្ថុទាំងឡាយ មានន័យដូចពោលហើយក្នុងអនុប្បញ្ញត្តិនោះឯង ។

[ ២៨៤ ] ក្នុងរឿងទី ២ មានវិនិច្ឆ័យដូច្នេះ បទថា **បណិធាយ** បាន ដល់ ធ្វើសេចក្តីប្រាថ្នា ។

បទថា **ឯវំ មំ ជនោ សម្ភាវេស្សតិ** សេចក្តីថា ( ភិក្ខុអង្គណាមួយនៅក្នុងព្រៃដោយតាំងចិត្តថា ) ជននឹងសរសើរអញដែលនៅក្នុងព្រៃ ក្នុងភាពជាព្រះអរហន្ត ឬក្នុងសេក្ខភូមិ ដោយវិធីយ៉ាងនេះ បន្ទាប់អំពីកាលនោះទៅ អញនឹងជាអ្នកដែលអ្នកស្រុកធ្វើសក្ការៈ គោរពរាប់អាន បូជា ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** សេចក្តីថា កាលភិក្ខុដើរទៅ ដោយតាំងចិត្តយ៉ាងនេះថា អញនឹងនៅក្នុងព្រៃ ត្រូវអាបត្តិទុក្កដគ្រប់ជំហាន ក្នុងកិច្ចទាំងពួង មានការធ្វើកុដិ ដើរចង្ក្រម អង្គុយ និងស្លៀកដណ្តប់ជាដើមក្នុងព្រៃ ត្រូវទុក្កដគ្រប់ប្រយោគយ៉ាងនោះ ។ ព្រោះហេតុនោះ ភិក្ខុមិនគួរនៅក្នុងព្រៃដោយការតាំងចិត្តយ៉ាងនោះ ។ ពិតហើយ កាលនៅដោយការតាំងចិត្តយ៉ាងនោះ ទោះបានការសរសើរ ឬមិនបានក៏ដោយ រមែងត្រូវអាបត្តិទុក្កដ ។ ចំណែកភិក្ខុណាសមាទានធុតង្គហើយ គិតថា អញនឹងរក្សាធុតង្គ ឬថា កាលអញស្នាក់នៅក្នុងស្រុកភូមិ ចិត្តរមែងរាយមាយ ព្រៃជាទីសប្បាយ ដូច្នេះ ទើបជាអ្នកមានបំណងនឹងនៅព្រៃដែលមិនមានទោស ដោយធ្វើការប្រាថ្នាយ៉ាងនេះថា អញនឹងបានបណ្តាវិវេកទាំង ៣ ណាមួយ ក្នុងព្រៃដោយពិត ដូច្នេះក្តី ឬថា

អញចូលទៅកាន់ព្រៃ បើមិនទាន់សម្រេចជាព្រះអរហន្តហើយ នឹងមិនចេញមក ដូច្នេះក្តី ឬថា ឈ្មោះថា ការនៅព្រៃព្រះដ៏មានព្រះភាគ ទ្រង់សរសើរ ហើយអញកាលស្នាក់នៅក្នុងព្រៃ សព្រហ្មចារីជាច្រើននឹងលះស្រុក ហើយនៅព្រៃជាវត្ត ដូច្នេះក្តី ភិក្ខុនោះគួរនៅក្នុងព្រៃ ។

ក្នុងរឿងទី ៣ មានវិនិច្ឆ័យដូច្នេះថា ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ផ្តើមពីកិច្ច គឺការស្លៀកដណ្តប់ ដោយតាំងចិត្តថា អញនឹងដាក់ឥរិយាបថ មានការឈានទៅជាដើម ត្រាច់បិណ្ឌបាត រហូតដល់ការទំពាធាន់ជាទីបំផុត ភិក្ខុទោះបានការសរសើរ ឬមិនបានក៏ដោយ ត្រូវអាបត្តិទុក្កដទាំងអស់ តែបើភិក្ខុចូលទៅបិណ្ឌបាតដោយឥរិយាបថដែលគួរជ្រះថ្លា មានការឈានទៅមុខ និងឈានថយក្រោយជាដើម ដើម្បីបំពេញខន្ធកវត្ត និងសេក្ខិយវត្តឲ្យបរិបូណ៌ ឬដើម្បីដល់នូវទិដ្ឋានុគតិ ដល់សព្រហ្មចារីទាំងឡាយ ជាបុគ្គលដែលវិញ្ញូជនទាំងឡាយ មិនគប្បីតិះដៀលដូច្នេះ ។

[ ២៨៥ ] ក្នុងរឿងទី ៤-៥ ព្រោះភិក្ខុមិនបានពោលថា ខ្ញុំ ដោយន័យដូចពោលទុកហើយ ក្នុងពាក្យនេះថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ទើបមិនត្រូវបារាជិក ពិតហើយ កាលភិក្ខុអួតឧត្តរិមនុស្សធម្ម ជាទីបង្អោនមកក្នុងខ្លួនប៉ុណ្ណោះ ទើបលោកកាត់អាបត្តិបារាជិក ។

[ ២៨៦ ] ពាក្យជាដើមថា ( ភិក្ខុអង្គណាមួយ ) ដើរចង្ក្រមដោយតាំងចិត្តថា ... ដូច្នេះ មានន័យដូចពោលហើយខាងដើមនោះឯង ។

[ ២៨៧ ] រឿងភិក្ខុអួតថាលះសំយោជនធម៌បាន មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុពោលថា សំយោជនៈទាំងឡាយ ខ្ញុំលះបានហើយក្តី សំយោជនៈ

ទាំង ១០ ខ្ញុំលះបានហើយក្តី សំយោជនៈ ១ ខ្ញុំលះបានហើយក្តី ការលះកិលេសនោះឯង ឈ្មោះថា លោកប្រាប់ហើយ ព្រោះហេតុនោះ ទើបត្រូវអាបត្តិបារាជិក ។

[ ២៨៨ ] ក្នុងរឿងភិក្ខុនៅក្នុងទីស្ងាត់ មានវិនិច្ឆ័យដូច្នេះថា ពាក្យថា **រហោគតោ ឧត្តរិមនុស្សធម្មំ ឧល្លបតិ** សេចក្តីថា ភិក្ខុនៅក្នុងទីស្ងាត់ពោលថា ខ្ញុំជាព្រះអរហន្ត ដូច្នេះ តែមិនបានធ្វើការគិតដោយចិត្តឡើយ ព្រោះហេតុនោះ ទើបក្នុងរឿងនេះលោកកាត់អាបត្តិទុក្កដ ។

[ ២៨៩ ] រឿងភិក្ខុនៅក្នុងវិហារ និងរឿងភិក្ខុដែលឧបាសកផ្គត់ផ្គង់ មានវិនិច្ឆ័យដូចពោលហើយ ( ក្នុងពុទ្ធដីកានោះឯង ) ។

[ ២៩០ ] ក្នុងរឿងភិក្ខុនិយាយអួតអរហត្តផល មិនមែនក្រឡើយ មានវិនិច្ឆ័យដូច្នេះថា លទ្ធិរបស់ភិក្ខុនោះមានដូច្នេះថា ព្រះអរិយបុគ្គលទាំងឡាយដែលជាសាវ័ក របស់ព្រះដ៏មានព្រះភាគ ( គប្បីពោលយ៉ាងនោះ ) ។ ព្រោះហេតុនោះ ទើបភិក្ខុនោះពោលថា ព្រោះលោកដែលជាសាវ័ករបស់ព្រះដ៏មានព្រះភាគប៉ុណ្ណោះគប្បីពោលយ៉ាងនោះ ។ ឯបំណងរបស់ភិក្ខុនោះ មានដូច្នេះថា កាលដែលភិក្ខុអ្នកមានសីលចម្រើនវិបស្សនា ព្យាករព្រះអរហត្តផល ធ្វើបានមិនក្រឡើយ លោកអាចសម្រេចអរហត្តបាន ព្រោះហេតុនោះ ទើបភិក្ខុអង្គនោះ ក្រាបទូលថា ខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួត ។

ក្នុងរឿងភិក្ខុព្យាយាម មានវិនិច្ឆ័យដូច្នេះថា បទថា **អារាធនីយោ** សេចក្តីថា អាចញុំាងធម៌ឲ្យប្រោសប្រាណបាន គឺញុំាងខ្លួនឲ្យសម្រេចបាន

សេចក្ដីថា ដើម្បីឲ្យកើតបាន ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

ក្នុងរឿងភិក្ខុមិនខ្លាចសេចក្ដីស្លាប់ មានវិនិច្ឆ័យដូច្នេះ ភិក្ខុនោះអាស្រ័យអំណាចនៃប្រយោជន៍នេះថា បុគ្គលដែលមានសេចក្ដីក្ដៅក្រហាយចិត្តកើតឡើង ទើបខ្លាចពិត តែសីលរបស់អញបរិសុទ្ធ មិនជាទីតាំងនៃសេចក្ដីក្ដៅក្រហាយចិត្តឡើយ ។ អាត្មាអញនឹងត្រូវខ្លាចចំពោះសេចក្ដីស្លាប់ធ្វើអ្វី ដូច្នេះ ទើបឆ្លើយថា អាវុសោទាំងឡាយ ខ្ញុំរមែងមិនខ្លាចចំពោះសេចក្ដីស្លាប់ ព្រោះហេតុនោះ ទើបអាបត្តិមិនមានដល់ភិក្ខុនោះ ។ សូម្បីក្នុងរឿងក្ដៅក្រហាយស្ដាយក្រោយ ក៏មានន័យដូចគ្នានេះ ។ ៣ រឿង បន្ទាប់ពីរឿងក្ដៅក្រហាយស្ដាយក្រោយនោះទៅ ដូចរឿងភិក្ខុមានសេចក្ដីព្យាយាមនោះឯង ។

រឿងភិក្ខុអត់ធន់វេទនាទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងទី ១ សិនភិក្ខុនោះតាំងនៅក្នុងអធិវាសនខន្តិ ដោយកម្លាំងនៃការពិចារណា ទើបឆ្លើយថា នែអាវុសោទាំងឡាយ បុគ្គលក្រៅការមិនអាចនឹងអត់ធន់បានឡើយ ។ ព្រោះហេតុនោះ ទើបអាបត្តិមិនមានដល់លោក ។ ចំណែកក្នុងរឿងទី ២ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះភិក្ខុនោះមិនបានធ្វើការអួតឧត្តរិមនុស្សធម្មជាទីបង្អោនចូលមកក្នុងខ្លួន ពោលដោយអមថា នែអាវុសោទាំងឡាយ បុថុជ្ជនមិនអាចនឹងអត់ធន់បានឡើយ ។

[ ២៩១ ] រឿងភិក្ខុ ៥ រូបដែលព្រាហ្មណ៍និមន្ត មានវិនិច្ឆ័យដូច្នេះថា បានឮថា ព្រាហ្មណ៍ម្នាក់នោះបានពោលថា និមន្តព្រះអរហន្តទាំងឡាយចូលមក

ដូច្នេះតែម្យ៉ាងក៏ទេ ( ដោយពិត ) ពាក្យពោលទាំងអស់ដែលបន្ទឺចេញអំពីមាត់របស់ព្រាហ្មណ៍នោះ ប្រកបដោយវាទៈថា អរហន្តទាំងអស់ ដូច្នេះថា អ្នកទាំងឡាយ ចូរក្រាលអាសនៈ ចូរប្រគេនទឹកលាងជើងដល់ព្រះអរហន្តទាំងឡាយ សូមព្រះអរហន្តទាំងឡាយលាងជើងចុះ ឯពាក្យពោលរបស់ព្រាហ្មណ៍នោះ ជាការពោលដោយសេចក្ដីជ្រះថ្លា គឺជាពាក្យពោលរបស់ព្រាហ្មណ៍ដែលត្រូវកម្លាំងសទ្ធារបស់ខ្លួនឲ្យមាំទាំហើយ ព្រោះជាអ្នកមានសទ្ធាចរិត ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនត្រូវអាបត្តិ ព្រោះការពោលដោយសេចក្ដីជ្រះថ្លា ។ ឯភិក្ខុដែលត្រូវគេពោលយ៉ាងនោះ មិនគួរជាអ្នកត្រេកអរ ហើយបរិភោគបច្ច័យទាំងឡាយឡើយ គួរធ្វើសេចក្ដីព្យាយាម ដោយគិតយ៉ាងនេះថា អាត្មាអញនឹងបំពេញបដិបទាដែលនឹងញុំាងខ្លួនឲ្យដល់អរហត្ត ដូច្នេះឯង ។

[ ២៩២ ] រឿងភិក្ខុ ៣ រូប និយាយអួតអរហត្តផល ដូចគ្នានឹងរឿងភិក្ខុអួតថា លះសំយោជនធម៌បាននោះឯង ។

[ ២៩៣ ] ក្នុងរឿងភិក្ខុឃាត់បង់នូវផ្ទះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុនោះបានពោលថា នែអាវុសោ បុគ្គលដូចខ្ញុំមិនគួរឡើយ ដូច្នេះ ព្រោះលោកមិនមានសេចក្ដីត្រូវការ មិនមានការជាប់ជំពាក់ក្នុងភាពជាគ្រហស្ថ មិនបានពោលដោយបំណងនឹងអួតឡើយ ព្រោះហេតុនោះ ទើបអាបត្តិមិនមានដល់លោក ។

ក្នុងរឿងភិក្ខុឃាត់បង់កាមទាំងឡាយ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុនោះជាអ្នកអស់ការជាប់ជំពាក់ក្នុងវត្ថុកាម និងកិលេសកាម ព្រោះសម្លឹងឃើញទោស

ដែលជាលោកិយនោះឯង ព្រោះដូច្នោះ ទើបភិក្ខុនោះពោលថា នែអាវុសោកាមទាំងឡាយ ខ្ញុំឃាត់បង់បានហើយ ដូច្នេះ ព្រោះហេតុនោះ ទើបអាបត្តិមិនមានដល់ភិក្ខុនោះ ។

ឯពាក្យថា **អាវដា** ក្នុងពាក្យថា **អាវដា មេ** នេះ មានអត្ថថា ខ្ញុំរារាំងបានហើយ គឺឃាត់បង់ហើយ បដិសេធហើយ ។

រឿងភិក្ខុអ្នកត្រេកអរ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុនោះ ពោលថា នែអាវុសោ ខ្ញុំនៅត្រេកអរក្រៃលែង ដោយការត្រេកអរដ៏កំពូល ដូច្នេះ ព្រោះភិក្ខុនោះជាអ្នកមិនអផ្សុក និងព្រោះនៅមានសេចក្តីត្រេកអរក្នុងឧទ្ទេស និងបុច្ឆាជាដើមក្នុងសាសនា មិនបានពោលដោយបំណងនឹងអួតឡើយ ព្រោះហេតុនោះ ទើបអាបត្តិមិនមានដល់លោក ។

[ ២៩៤ ] ក្នុងរឿងចៀសចេញទៅ មានវិនិច្ឆ័យដូច្នេះថា ពាក្យថា ភិក្ខុណាចៀសចេញទៅអំពីអាវាសនេះមុនគេ អធិប្បាយថា សង្ឃកំណត់អាវាសមណ្ឌលសីមា ឬទីកន្លែងណាមួយ ហើយតាំងកតិកាទុក ភិក្ខុណាចៀសចេញទៅអំពីទីកន្លែងនោះមុន ដោយគិតថា ភិក្ខុទាំងឡាយចូរដឹងអញថា អញជាព្រះអរហន្ត ភិក្ខុនោះត្រូវអាបត្តិបារាជិក ។ ចំណែកភិក្ខុណាដើរហួសស្ថានទីនោះទៅ ដោយកិច្ចធុរៈរបស់អាចារ្យ និងឧបជ្ឈាយ៍ក្តី ដោយករណីជទៃក្តី ដើម្បីភិក្ខាចារក្តី ឬដើម្បីប្រយោជន៍ដល់ឧទ្ទេស និងបរិបុច្ឆាក្តី មិនត្រូវអាបត្តិដល់ភិក្ខុនោះ ។ បើភិក្ខុនោះដើរទៅដោយកិច្ចយ៉ាងនោះ ក្រោយមក ឥច្ចាចារ (ការប្រាថ្នាលាមក ) កើតឡើងថា ឥឡូវនេះ អញនឹងមិនទៅក្នុងស្ថានទី

*នោះ ។ ព្រោះថា ជនទាំងឡាយនឹងសរសើរអញថា ជាព្រះអរហន្តដោយអាការយ៉ាងនេះ មិនត្រូវអាបត្តិដូចគ្នា ។ ចំណែកភិក្ខុណា លុះដល់ទីកន្លែងនោះ ដោយករណីណាមួយហើយ ជាអ្នកបញ្ជូនចិត្តទៅក្នុងទីដទៃ ដោយអំណាចការដាក់ ចិត្តក្នុងការស្វាធ្យាយជាដើម ឬត្រូវចោរជាដើមដេញតាម ឬឃើញភ្លៀងតាំងឡើងហើយ មានបំណងនឹងចូលទៅជ្រកភ្លៀង ទើបកន្លងស្ថានទីនោះទៅ មិនត្រូវអាបត្តិដល់ភិក្ខុនោះ ។ សូម្បីភិក្ខុដែលទៅដោយយាន ឬដោយឫទ្ធិក៏មិនត្រូវអាបត្តិ តែរមែងត្រូវអាបត្តិដោយការដើរទៅដោយជើងប៉ុណ្ណោះ ។ ភិក្ខុដើរទៅដល់ទីកន្លែងនោះ មិនមុនមិនក្រោយ មួយអន្លើដោយពួកភិក្ខុដែលរួមគ្នាតាំងកតិកាទុក មិនត្រូវអាបត្តិ ។ ព្រោះថា ភិក្ខុទាំងឡាយកាលដើរទៅយ៉ាងនោះ នៅរក្សាគ្នានិងគ្នាបានទាំងអស់ ។ សូម្បីភិក្ខុទាំងឡាយកំណត់ស្ថានទីកន្លែងខ្លះ បណ្តាមណ្ឌប និងគល់ឈើជាដើម ហើយតាំងកតិកាទុក ដោយន័យជាដើមថា ពួកយើងនឹងដឹងភិក្ខុដែលអង្គុយ ឬដើរចង្ក្រមនៅក្នុងទីនេះថា ជាព្រះអរហន្ត ឬយកផ្កាដាក់ដោយន័យជាដើមថា ពួកយើងនឹងជ្រាបភិក្ខុដែលកាន់យកផ្កាទាំងនេះ ហើយធ្វើការបូជា ថាជាព្រះអរហន្ត ។ សូម្បីក្នុងកតិកាវត្តនោះ កាលភិក្ខុធ្វើយ៉ាងនោះ ដោយអំណាចឥច្ឆាចារ ត្រូវបារាជិកដូចគ្នា ។ បើឧបាសកធ្វើវិហារទុកក្នុងចន្លោះផ្លូវក្តី រៀបចំបច្ច័យ មានចីវរជាដើមទុកក្តី ដោយពោលថា សូមភិក្ខុដែលជាព្រះអរហន្តទាំងឡាយស្នាក់នៅក្នុងវិហារនេះ និងសូមកាន់យកបច្ច័យ មានចីវរជាដើម ក្នុងកតិកាវត្តដែលឧបាសកតាំងទុកនោះ កាលភិក្ខុស្នាក់នៅ ឬកាន់យកបច្ច័យ*

មានចីវរជាដើមនោះ ដោយអំណាចឥច្ឆាចារ ត្រូវបារាជិកដូចគ្នា ។ តែកតិកា នោះជាកតិកាវត្តដែលមិនប្រពៃ ព្រោះហេតុនោះ ទើបមិនគួរ ( នាំគ្នា ) ធ្វើ ។

ម្យ៉ាងទៀត វត្តដទៃបែបនេះ មានកតិកាថា ខាងក្នុង ៣ ខែនេះ ភិក្ខុទាំងអស់ ចូរកាន់ការនៅព្រៃជាវត្ត ឬថា ទ្រទ្រង់ទុកនូវធុតង្គដ៏សេស មានអង្គនៃភិក្ខុដែលត្រាច់បិណ្ឌបាតជាវត្តជាដើម ឬថា ចូរជាអ្នកអស់អាសវៈទាំងអស់គ្រប់អង្គគី ដូច្នេះ ( ឈ្មោះថា វត្តដែលមិនប្រពៃ ) ដោយពិត ភិក្ខុទាំងឡាយដែលនៅក្នុងជនបទផ្សេងៗ រមែងប្រជុំគ្នា ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ ទុព្វលភាព មានកម្លាំងតិច រមែងមិនអាចនឹងតាមរក្សាវត្តបែបនោះបាន ព្រោះហេតុនោះ ទើបវត្តបែបនោះមិនគួរធ្វើ ។ ហើយវត្តយ៉ាងនេះថា ៣ ខែនេះ ភិក្ខុទាំងអស់មិនគប្បីសម្ដែងធម៌ មិនគប្បីរៀនធម៌ មិនគប្បីឲ្យបព្វជ្ជា តែគួររៀនយកមូគវត្ត ( វត្តមនុស្សគ ) គួរឲ្យលាភសង្ឃដល់ភិក្ខុដែលនៅខាងក្រៅសីមាផង ដូច្នេះ ក៏មិនគួរធ្វើដូចគ្នា ។

[ ២៩៥ ] ព្រះលក្ខណត្ថេរ ដែលព្រះធម្មសង្គាហកាចារ្យពោលទុកក្នុងលក្ខណសំយុត្តថា **អាយស្មា ច លក្ខណោ** ជាដើមនេះ បណ្ឌិតគប្បីជ្រាបថា មានខាងក្នុងនៃភិក្ខុជដិលមួយពាន់អង្គ ឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា បានសម្រេចជាព្រះអរហន្តក្នុងខណៈចប់អាទិត្តបរិយាយសូត្រ ជាព្រះមហាសាវកមួយអង្គ ព្រោះព្រះថេរៈអង្គនេះ ប្រកបដោយអត្តភាពដូចព្រហ្ម សម្បូរដោយលក្ខណៈ ពេញលេញដោយអាការគ្រប់យ៉ាង ដូច្នោះ ទើបលោកដល់នូវការរាប់ថា លក្ខណៈ ចំណែកព្រះមហាមោគ្គល្លានត្ថេរ ជា

អគ្គទុតិយសាវកបានសម្រេចជាព្រះអរហន្តក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃដែលលោកបួសហើយ ។

ពីរបទថា **សិតំ បាត្វាកាសិ** សេចក្តីថា ព្រះមហាមោគ្គល្លានត្ថេរបានធ្វើការញញឹមតិចៗ ឲ្យប្រាកដ អធិប្បាយថា ប្រកាស គឺបង្ហាញ ។

សួរថា ព្រះថេរៈឃើញអ្វី ទើបបានធ្វើញញឹមឲ្យប្រាកដ ឆ្លើយថា ព្រះថេរៈឃើញសត្វដែលកើតក្នុងបេតលោកម្នាក់ មានតែរាងឆ្អឹង ដែលមកហើយក្នុងបាលីខាងដើម ឯការឃើញសត្វនោះ ឃើញបានដោយទិព្វចក្ខុ មិនមែនឃើញដោយចក្ខុបសាទទេ ។ ពិតហើយ អត្តភាពទាំងនោះ មិនបានមកកាន់គន្លងនៃចក្ខុបសាទឡើយ ។

សួរថា ព្រះថេរៈឃើញអត្តភាពមានសភាពយ៉ាងនោះហើយ ព្រោះហេតុអ្វី ទើបធ្វើការញញឹមឲ្យប្រាកដ ក្នុងកាលគួរធ្វើសេចក្តីករុណាទៅវិញ ឆ្លើយថា ព្រោះលោករឭកដល់សម្បត្តិរបស់ខ្លួន និងព្រះញាណរបស់ព្រះសម្ពុទ្ធផងដែរ ។ ពិតហើយ ព្រះថេរៈឃើញប្រេតនោះហើយ បានរឭកដល់សម្បត្តិរបស់ខ្លួនថា អត្តភាពដែលមានសភាពបែបនេះ ដែលបុគ្គលឈ្មោះថាមិនទាន់ឃើញសច្ចៈគប្បីបាន អញផុតហើយចាកអត្តភាពដូច្នោះ ជាលាភរបស់អញហ្ន៎ អញបានល្អហើយហ្ន៎ ហើយបានរឭកដល់សម្បត្តិនៃព្រះពុទ្ធញាណយ៉ាងនេះថា ញាណសម្បត្តិរបស់ព្រះមានព្រះភាគសម្មាសម្ពុទ្ធ ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ កម្មវិបាកជាអចិន្តេយ្យ ដែលបុគ្គលមិនគប្បីគិត គួរអស្ចារ្យ ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងសម្តែងធ្វើឲ្យប្រចក្សហ្ន៎ ធម្ម-

ធាតុដែលព្រះពុទ្ធទាំងឡាយ ទ្រង់ចាក់ចុះល្អហើយ ដូច្នេះ ទើបបានធ្វើការញញឹមឲ្យប្រាកដ ។

ធម្មតាព្រះខីណាស្រពទាំងឡាយ មិនធ្វើការញញឹមឲ្យប្រាកដ ព្រោះមិនមានហេតុ ព្រោះដូច្នោះ ទើបព្រះលក្ខណត្ថេរសួរព្រះមហាមោគ្គល្លានត្ថេរនោះថា នែអាវុសោ មោគ្គល្លាន អ្វីជាហេតុ អ្វីជាបច្ច័យ នៃការធ្វើការញញឹមឲ្យប្រាកដ តែព្រះថេរៈឆ្លើយថា អាវុសោ លក្ខណៈ កាលនេះជាកាលមិនសមគួរជាដើម ដោយហេតុដែលលោកមានបំណងនឹងឲ្យព្រះមានព្រះភាគជាបន្ទាល់ជាមុន ទើបព្យាករ ព្រោះថា ភិក្ខុទាំងឡាយដែលមិនបានឃើញការឧប្បត្តិកឡើងនេះ ដោយខ្លួនឯងហើយ នឹងប្រាប់ឲ្យជឿបានដោយលំបាក ។ ខាងក្រោយអំពីនោះមក ព្រះមហាមោគ្គល្លានត្ថេរត្រូវព្រះលក្ខណត្ថេរសួរក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ទើបបានព្យាករដោយន័យជាដើមថា **ឥធាហំ អាវុសោ ។**

បណ្តាបទទាំងនោះ បទថា **អដ្ឋិសង្ខលិកំ** បានដល់ មានតែរាងឆ្អឹងដែលមានពណ៌ស មិនមានសាច់ និងឈាម ។

ត្បាតយក្ខ ខ្លែងយក្ខ និងរអាតយក្ខ ទាំងនេះ គប្បីជ្រាបថា ត្បាតខ្លះ ខ្លែងខ្លះ រអាតខ្លះ ។ ឯរូបនោះមិនមកកាន់គន្លង ( នៃចក្ខុ ) របស់ហ្វូងត្បាតប្រក្រតីជាដើម ។

ពីរបទថា **អនុបតិត្វា អនុបតិត្វា** បានដល់ នាំគ្នាដេញតាមទៅហើយ ។

បទថា **វិតុទេន្តិ** បានដល់ ចឹកហើយ ហើរទៅ ។ម្យ៉ាងទៀត បាឋៈថា **វិតុឧន្តិ** ក៏មាន អធិប្បាយថា រមែងចឹកយ៉ាងញាប់ ដោយចំពុះលោហៈដ៏មុតស្រួច ប្រៀបដូចចុងដាវ ។ ថា **សុទំ** ក្នុងពាក្យថា **ស្វាស្សុទំ អដ្ដស្សរំ** នេះ ជានិបាត អធិប្បាយថា អដ្ឋិសង្ខលិកប្រេតនោះ រមែងធ្វើសំឡេងស្រែកដ៏ខ្លាំង គឺសំឡេងគ្រលួច ។ បានឮថា អត្តភាពដូច្នោះ មានប្រមាណមួយយោជន៍ រមែងកើតឡើង មានបសាទដែលប៉ុនឡើង ដូចគ្នានឹងបូសដែលទុំហើយ ដើម្បីតាមសោយផលនៃអកុសល ព្រោះដូច្នោះ អដ្ឋិសង្ខលិកប្រេតនោះ ក្តៅក្រហាយព្រោះវេទនាដ៏ខ្លាំងក្លា ទើបបានធ្វើសំឡេងដូច្នោះ ។

ព្រះមហាមោគ្គល្លានកាលពោលយ៉ាងនេះហើយ កាលនឹងសម្តែងដដែលនូវធម្មសង្វេគដែលកើតឡើង ព្រោះអាស្រ័យសេចក្តីករុណាក្នុងសត្វទាំងឡាយថា ឈ្មោះថា សត្វទាំងឡាយដែលទៅក្នុងវដ្ដៈ រមែងមិនផុតចាកអត្តភាពបែបនេះទៅបានឡើយ ទើបពោលពាក្យជាដើមថា អ្នកដ៏មានអាយុ ខ្ញុំនោះមានការគិតយ៉ាងនេះថា លោកដ៏ចម្រើន គួរអស្ចារ្យពិតហ្ន៎ ដូច្នេះ ។

ពីរបទថា **ភិក្ខូ ឧជ្ឈាយន្តិ** សេចក្តីថា ការឧប្បត្តិកឡើងនៃប្រេតនោះ មិនឃើញប្រចក្សដល់ភិក្ខុពួកណា ភិក្ខុទាំងនោះ នាំគ្នាចោទ ។ ចំណែកព្រះមានព្រះភាគ កាលទ្រង់ប្រកាសអានុភាពរបស់ព្រះថេរៈ ទើបមានព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយ ជាអ្នកមានចក្ខុហ្ន៎ជាដើម ។

ក្នុងបទទាំងនោះ សាវកទាំងឡាយ ឈ្មោះថា ជាអ្នកមានចក្ខុ ព្រោះអត្ថថា សាវកទាំងនោះ មានចក្ខុកើតហើយ ប្រាកដហើយ ឧប្បត្តិកហើយ ។

សេចក្តីថា បុគ្គលមានចក្ខុកើតហើយ គឺមានចក្ខុប្រាកដហើយ ញុំាងចក្ខុឲ្យកើតឡើងហើយ ។ ក្នុងបទទី ២ ក៏មានន័យដូចគ្នា ។ ពាក្យថា **យត្រ** ដែលមាននៅក្នុងបទថា **យត្រ ហិ ណាម** នេះ ជាពាក្យប្រាវព្ធដល់ហេតុ ។ ក្នុងពាក្យថា **ចក្ខុភូតា** ជាដើមនោះ មានការប្រកបអត្ថដូចតទៅនេះថា ព្រោះថាសូម្បីសាវកនឹងដឹង ឬនឹងឃើញ ឬនឹងធ្វើអត្តភាពដែលមានសភាពបែបនេះឲ្យជាបន្ទាល់បាន ដូច្នោះ ទើបតថាគតពោលថា ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយជាអ្នកមានចក្ខុហ្ន៎ ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយជាអ្នកមានញាណហ្ន៎ ដូច្នេះ ។

ពាក្យថា **បុព្វេវ មេ សោ ភិក្ខវេ សត្តោ ទិដ្ឋោ** សេចក្តីថា ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ នាមណ្ឌលពោធិព្រឹក្ស ធ្វើពួកសត្វ និងភព គតិ ឋិតិ និងនិវាស មិនមានប្រមាណក្នុងចក្រវាលទាំងឡាយមិនមានប្រមាណឲ្យប្រចក្ស បានឃើញសត្វនោះហើយក្នុងបឋមពោធិកាលនោះឯង ។

បទថា **គោឃាតកោ** សេចក្តីថា ជាអ្នកសម្លាប់គោទាំងឡាយហើយពន្លះសាច់ចេញអំពីឆ្អឹង លក់ដូរចិញ្ចឹមជីវិត ។

ច្រើនបទថា **តស្សេវ កម្មស្ស វិបាកាវសេសេន** សេចក្តីថា នៃអបរាបរវេទនីយកម្ម ដែលចេតនាផ្សេងៗ ប្រមូលមកហើយនោះឯង ។ ពិតហើយ បណ្តាចេតនាទាំងនោះ បដិសន្ធិក្នុងនរក ដែលចេតនាណាឲ្យកើតឡើងហើយ កាលវិបាកនៃចេតនាដួងនោះអស់ទៅហើយ បដិសន្ធិក្នុងប្រេត

ជាដើម រមែងកើតឡើងទៀត ព្រោះធ្វើកម្មដ៏សេស ឬកម្មនិមិត្តឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបបដិសន្ធិនោះ លោកហៅថា វិបាកដ៏សេសនៃកម្មនោះឯង ព្រោះមានចំណែកស្មើដោយកម្ម ឬព្រោះមានចំណែកស្មើដោយអារម្មណ៍ ។ ឯសត្វនេះកើតឡើងហើយយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ដោយវិបាកដែលនៅសេសសល់នៃកម្មនោះឯង បានឮថា ក្នុងវេលាឃ្លាតចាកនរក សត្វនោះមាននិមិត្ត គឺគំនរនៃឆ្អឹងគោទាំងឡាយ ដែលត្រូវធ្វើមិនឲ្យមានសាច់ សត្វនោះ កាលធ្វើកម្មនោះ ដែលបិទបាំងឲ្យកើតដូចប្រាកដដល់វិញ្ញូជនទាំងឡាយ ទើបកើតជាអដ្ឋិសង្ខលិកប្រេត ។

ក្នុងរឿងមំសបេសីប្រេត មានវិនិច្ឆ័យដូច្នេះថា មំសបេសីប្រេតនោះ ជាអ្នកសម្លាប់គោ ធ្វើចម្រៀកសាច់ហាលឲ្យស្ងួតហើយ ចិញ្ចឹមជីវិត ដោយការលក់សាច់ងៀតច្រើនឆ្នាំ ដោយហេតុនោះ វេលាឃ្លាតចាកនរក ទើបបុរសនោះមាននិមិត្ត គឺចម្រៀកសាច់នោះឯង ទើបបុរសនោះកើតជាមំសបេសីប្រេត ។

ក្នុងរឿងមំសបិណ្ឌប្រេត មានវិនិច្ឆ័យដូច្នេះថា មំសបិណ្ឌប្រេតនោះ ជានាយព្រានបក្សី ចាប់បក្សីបានហើយ វេលាលក់ បានធ្វើការដកស្លាប និងស្បែកចេញអស់ ឲ្យនៅត្រឹមតែដុំសាច់ ហើយលក់ចិញ្ចឹមជីវិត ដោយហេតុនោះ វេលាឃ្លាតចាកនរក ទើបបុរសនោះមាននិមិត្ត គឺដុំសាច់ប៉ុណ្ណោះ ទើបបុរសនោះកើតជាមំសបិណ្ឌប្រេត ។

ក្នុងរឿងនិច្ឆវិប្រេត មានវិនិច្ឆ័យដូច្នេះថា និច្ឆវិប្រេតនោះ ជាអ្នកសម្លាប់ពពែ ហើយពន្លាត់ស្បែកចិញ្ចឹមជីវិត ទើបមាននិមិត្ត គឺសរីរៈពពែប្រាសចាក

ស្បែក តាមន័យមុននោះឯង ទើបបុរសនោះកើតជានិច្ឆវិប្រេត ។

ក្នុងរឿងអសិលោមប្រេត មានវិនិច្ឆ័យដូច្នេះថា អសិលោមប្រេតនោះ ជាអ្នកសម្លាប់ជ្រូក ប្រើដាវសម្លាប់ជ្រូកទាំងឡាយ ដែលខ្លួនបំប៉នដោយចំណី អស់កាលយូរ ហើយចិញ្ចឹមជីវិត មកអស់រាត្រីដ៏យូរ ទើបបុរសនោះមាន និមិត្ត គឺការៈរបស់ខ្លួនដែលងាដាវឡើង ដូច្នោះ ទើបបុរសកើតជាអសិលោម-ប្រេត ។

ក្នុងរឿងសត្តិលោមប្រេត គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា សត្តិលោមប្រេត នោះ ជាព្រានម្រឹគ នាំយកម្រឹគធ្លាក់មួយក្បាល និងកាន់លំពែងមួយដើមទៅ ព្រៃ ហើយប្រើលំពែងចាក់ម្រឹគដែលនាំគ្នាមកកាន់ទីជិតម្រឹគនោះឲ្យស្លាប់ ។ ទើបបុរសនោះបាននិមិត្ត គឺការៈដែលប្រើលំពែងចាក់ ដូច្នោះ ទើបបុរស នោះកើតជាសត្តិលោមប្រេត ។

ក្នុងរឿងឧសុលោមប្រេត គប្បីជ្រាបវិនិច្ឆ័យតទៅ បទថា **ការណិកោ** សេចក្ដីថា ជាបុរសដែលបៀតបៀនពួកបុគ្គលដែលខុសចំពោះព្រះរាជា ដោយ ហេតុទាំងឡាយដ៏ច្រើន ចុងក្រោយក៏ប្រើព្រួញបាញ់ឲ្យស្លាប់ បានឮថា បុរស នោះជ្រាបមុនថា អ្នកត្រូវចំណែកឯណោះ ទើបនឹងស្លាប់ ដូច្នេះ ទើបបាញ់ ។ បុរសនោះឯងចិញ្ចឹមជីវិត ហើយកើតឡើងក្នុងនរក វេលាកើតក្នុងបេតវិស័យ នេះ មាននិមិត្ត គឺការៈដែលប្រើព្រួញបាញ់ ដោយវិបាកដ៏សេសអំពីនរកនោះ ដូច្នោះ ទើបបុរសនោះកើតជាឧសុលោមប្រេត ។

ក្នុងរឿងសូចិលោមប្រេត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **សារថិ** គឺ

ជាអ្នកបង្ហឹកសេះ ។ ក្នុងអដ្ឋកថាកុរុន្ទីពោលថា ជាអ្នកបង្ហឹកគោ ដូច្នេះក៏មាន បុរសនោះបាននិមិត្ត គឺការៈដែលចាក់ដោយជន្លួញ ទើបកើតជាសូចិលោមប្រេត ។

ក្នុងរឿងសូចិលោមប្រេតទី ២ គប្បីជ្រាបវិនិច្ឆ័យតទៅ បទថា **សូចកោ** គឺជាបុគ្គលធ្វើការញុះញង់ បានឮថា បុរសនោះបំបែកមនុស្សទាំងឡាយពួកតែមួយ និងញុះញង់រាជត្រកូលថា បុគ្គលនេះខុសនេះ បុគ្គលនេះធ្វើខុសនេះ ដូច្នេះ កាលញុះញង់ហើយ ធ្វើឲ្យដល់ការវិនាសវឹកវរ ។ ដូច្នោះ ទើបបុរសនោះកើតជាសូចិលោមប្រេត ព្រោះធ្វើនិមិត្ត គឺកម្ម ដើម្បីការសោយទុក្ខ អំពីការទម្លុះដោយម្ជុលទាំងឡាយ ដូចដែលបុរសនោះស៊កសៀតបំបែកពួកមនុស្សដូច្នោះ ។

ក្នុងរឿងប្រេតលីអណ្ឌៈ មានវិនិច្ឆ័យតទៅ បទថា **គាមកូដោ** គឺជាអមាត្យដែលកាត់ក្តី ។ សត្វនោះមានអណ្ឌៈ គឺពងប៉ុនក្អម មានទំហំប៉ុនក្អមធំ ព្រោះមានចំណែកស្មើដោយកម្ម ។ ព្រោះថា សត្វនោះទទួលសំណូកក្នុងស្ថានទីដែលបិទបាំង កាលធ្វើទោសឲ្យប្រាកដ ដោយការកាត់ក្តីកោង បានធ្វើពួកម្ចាស់ទ្រព្យ មិនឲ្យជាម្ចាស់ទ្រព្យ ព្រោះដូច្នោះ ទើបអវយវៈកំបាំងរបស់សត្វនោះ កើតឡើងប្រាកដ ។ ព្រោះហេតុដែលសត្វនោះ កាលផ្តើមតាំងអាជ្ញា បានលើករបស់ធ្ងន់ ដែលមិនគួរនឹងអត់ធន់បាន ឲ្យដល់ជនដទៃ ព្រោះដូច្នោះ ទើបអវយវៈកំបាំងរបស់សត្វនោះ កើតជារបស់ធ្ងន់ ដែលមិនគួរអត់ធន់បាន ។ ព្រោះហេតុដែលសត្វនោះ តាំងនៅក្នុងតំណែងណា គួរនឹងជា

បុគ្គលស្មើ តែតាំងនៅក្នុងតំណែងនោះហើយ មិនបានជាអ្នកយុត្តិធម៌ឡើយ ដូច្នោះ ទើបសត្វនោះមានការអន្ទយមិនស្មើលើអវយវៈកំបាំង ។

ក្នុងរឿងប្រេតប្រព្រឹត្តខុសក្នុងប្រពន្ធគេ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា សត្វនោះ កាលលួចនូវផោដ្ឋព្វៈដែលមានម្ចាស់គេគ្រប់គ្រងរក្សាហើយ ញុំាងចិត្តឲ្យត្រេកអរ ដោយសេចក្ដីសុខក្នុងកាម ដែលជាសេចក្ដីសុខក្នុងឧច្ចារៈ ទើបកើតក្នុងបេតវិស័យនោះ ដើម្បីប៉ះពាល់ផោដ្ឋព្វៈដែលជាលាមក សោយទុក្ខ ព្រោះមានចំណែកស្មើដោយកម្ម ។

ក្នុងរឿងព្រាហ្មណ៍កំណាច ( ព្រះអដ្ឋកថាមិនមានអធិប្បាយ ) ។

ក្នុងរឿងនិច្ឆវិប្រេត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ឈ្មោះថា មាតុគ្រាម មិនជាឥស្សរៈក្នុងសម្ផស្សរបស់ខ្លួន តែស្រីនោះលួចសម្ផស្សរបស់ប្ដីនោះ ញុំាងការត្រេកអរឲ្យកើតដល់បុរសដទៃ ដូច្នោះ ទើបកើតជាស្រីប្រេត ប្រាសចាកស្បែក ដើម្បីកម្ចាត់សម្ផស្សជាសុខនោះចេញ ហើយសោយសម្ផស្សជាទុក្ខ ព្រោះមានចំណែកស្មើដោយកម្ម ។

ក្នុងរឿងមង្គុលីប្រេត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **មង្គុលី** បានដល់មានរូបខុសប្រក្រតី គឺមើលទៅគួរស្អប់ គួរខ្ពើម បានឮថា ស្រីនោះ ធ្វើកិច្ចជាមេមត់ គឺធ្វើកិច្ចជាទាសីរបស់យក្ខ ពោលថា កាលធ្វើពលីកម្មយ៉ាងនេះ ដោយរបស់នេះ និងវត្ថុនេះ សេចក្ដីចម្រើនរបស់អ្នកឈ្មោះនេះនឹងមាន ដូច្នេះ ហើយកាន់យកគ្រឿងក្រអូប និងផ្កាជាដើមរបស់មហាជន ដោយការបោកបញ្ឆោត ញុំាងមហាជនឲ្យប្រកាន់មិច្ឆាទិដ្ឋិ ដែលជាទិដ្ឋិអាក្រក់ ។ ព្រោះដូច្នោះ

ទើបនាងកើតជាស្រីប្រេត មានក្លិនស្អុយ ព្រោះលួចគ្រឿងក្រអូប និងផ្កាជាដើម ជាស្រីប្រេត មើលគួរស្អប់ មានរូបខុសប្រក្រតី គួរខ្ពើម ព្រោះហេតុឲ្យមហាជនយល់ខុស ព្រោះមានចំណែកស្មើដោយកម្មនោះ ។

ក្នុងរឿងឧក្កិលិនីប្រេត គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះថា ពាក្យថា **ឧប្បក្កំ ឱកិលិនី ឱកីរណី** សេចក្តីថា បានឮថា ស្រីប្រេតនោះដេកនៅលើដើងថ្ករងើកភ្លើង បម្រះទៅមក ត្រូវភ្លើងឆេះ ព្រោះដូច្នោះ ទើបនាងជាអ្នកត្រូវភ្លើងឆេះរោលរាល មានសរីរៈឆ្អិនដោយភ្លើងក្រុត មានញើសស្រក់មានសរីរៈសើម គឺញើសទាំងឡាយរមែងហូរចេញអំពីសរីរៈរបស់ប្រេតនោះ ហើយមានរងើកភ្លើងដេរដាស គឺដេរដាសដោយរងើកភ្លើង ។ ព្រោះថា រងើកភ្លើងទាំងឡាយ មានពណ៌ដូចផ្កាចារ រមែងធ្លាក់អំពីខាងក្រោមរបស់ស្រីប្រេតនោះ រងើកភ្លើងទាំងឡាយ រមែងធ្លាក់សូម្បីទាំងសងខាងអំពីអាកាស ក្នុងខាងលើស្រីប្រេតនោះ ។ ដោយហេតុនោះ ទើបលោកពោលថា ត្រូវភ្លើងដុតរោល តំណក់ញើសស្រក់ មានរងើកភ្លើងដេរដាស ស្រីប្រេតនោះជាអ្នកប្រចណ្ឌ យកខ្ទះរងើកភ្លើង ស្រោចស្រីរួមប្តី ។ បានឮថា ស្រីរបាំម្នាក់របស់ព្រះរាជាអង្គនោះ ដាក់ខ្ទះរងើកភ្លើងទុកក្នុងទីជិត ជូតទឹកអំពីខ្លួន និងអប់ដោយបាតដៃ ។ ព្រះរាជាទ្រង់សន្ទនាជាមួយស្រីរបាំនោះ ហើយទ្រង់សម្តែងអាការប្រោសប្រាណពន់ពេក ។ ព្រះអគ្គមហេសី អត់ធន់មើលហេតុការណ៍នោះមិនបាន ព្រះនាងប្រចណ្ឌ កាលព្រះរាជាយាងចេញទៅមិនយូរប៉ុន្មាន ក៏យកខ្ទះរងើកភ្លើងនោះ ស្រោចចុះខាងលើនាងរបាំនោះ ព្រះនាងធ្វើកម្មនោះហើយ

កើតក្នុងបេតលោក ដើម្បីសោយវិបាកនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ពេជ្ឈឃាតអ្នកសម្លាប់ចោរនោះ កាត់ក្បាលពួកចោរមកអស់កាលដ៏យូរ តាមពាក្យប្រើរបស់ព្រះរាជា កាលកើតឡើងក្នុងបេតលោក ទើបកើតជាសរីរៈមិនមានក្បាល ។

ក្នុងរឿងភិក្ខុ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **ចាបភិក្ខុ** ជាភិក្ខុលាមក បានឮថា ភិក្ខុនោះបរិភោគបច្ច័យ ៤ ដែលគេប្រគេនដោយសទ្ធា របស់អ្នកស្រុក ជាអ្នកមិនសង្រួមតាមកាយ និងវាចា មានអាជីវៈទម្លាយហើយ ត្រាច់លេងដោយសប្បាយតាមការពេញចិត្ត ។ ក្រោយមក ត្រូវឆេះក្នុងនរកអស់មួយពុទ្ធន្តរ កាលកើតក្នុងបេតលោក ក៏កើតឡើងដោយអត្តភាពដូចគ្នានឹងភិក្ខុនោះឯង ។ សូម្បីក្នុងរឿងភិក្ខុនី រឿងសិក្ខមានា រឿងសាមណេរប្រេត សាមណេរីប្រេត ក៏មានវិនិច្ឆ័យយ៉ាងនេះដូចគ្នា ។

[ ២៩៦ ] ក្នុងរឿងស្ទឹងតបោទា គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **អច្ឆោទកោ** ប្រែថា មានទឹកថ្លា ។

បទថា **សីតោទកោ** ប្រែថា មានទឹកត្រជាក់ ។ បទថា **សាតោទកោ** ប្រែថា មានទឹកមានរសឆ្ងាញ់ ។ បទថា **សេតោទកោ** ប្រែថា មានទឹកបរិសុទ្ធ គឺមិនមានសារាយ ចក និងភក់ ។ បទថា **សុប្បតិត្ថោ** គឺចូលដល់ហើយ ដោយកំពង់ទាំងឡាយដ៏ល្អ ។ បទថា **រមណីយោ** ប្រែថា គួរឲ្យកើតសេចក្តីត្រេកអរ ។ បទថា **ចក្កមត្តានិ** ប្រែថា មានប្រមាណប៉ុនកង់រថ ។ បទថា **កុថិតា សន្ទតិ** សេចក្តីថា ជាស្ទឹងក្តៅ ហូរទៅជានិច្ច ។

បទថា **យតាយំ ភិក្ខវេ** កាត់បទជា **យតោ អយំ ភិក្ខវេ** ប្រែថា ម្នាលភិក្ខុទាំងឡាយ ស្ទឹងតបោទានេះ ហូរមកអំពីទីណា ... ។

បទថា **សោ ទហោ** ប្រែថា អន្លង់ទឹកនោះ ។

សួរថា ស្ទឹងតបោទានេះ ហូរមកអំពីទីណា ឆ្លើយថា បានឮថា ខាងក្រោមភ្នំវេភារបព៌ត មានភពនាគប្រមាណ ៥០០ យោជន៍ របស់ពួកនាគដែលនៅលើផែនដី ដូចជាទេវលោក ប្រកបដោយផែនដី សម្រេចដោយកែវមណី និងដោយអារាម និងឧទ្យាន ។ អន្លង់ទឹកនោះ ជាទីកំសាន្តរបស់ពួកនាគ ក្នុងភពនាគនោះ ។ ស្ទឹងតបោទានេះ ហូរមកអំពីអន្លង់ទឹកនោះ ។

ពាក្យថា **ទ្វិន្នំ មហានិរយានំ អន្តរិកាយ អាគច្ឆតិ** សេចក្តីថា បានឮថា មហាបេតលោកលាតសន្ធឹងមកដល់ក្រុងរាជគ្រឹះ ស្ទឹងតបោទានេះមកអំពីចន្លោះមហាលោហកុម្ភីនរក ២ រណ្តៅ ក្នុងមហាបេតលោកនោះ ដូច្នោះ ទើបទឹកក្តៅហូរមក ។

[ ២៩៧ ] ក្នុងរឿងចម្បាំង គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ពាក្យថា **ឆដ្ឋិចរតិ** បានដល់ វាយស្គរពិជ័យភេរី ត្រាច់ប្រកាសទៅ ។

ពាក្យថា **រាជា អាវុសោ លិច្ឆវីហិ** សេចក្តីថា បានឮថា ព្រះថេរៈអង្គុយសម្រាកក្នុងពេលថ្ងៃ និងទីសម្រាកពេលយប់របស់ខ្លួន ឃើញពួកស្តេចលិច្ឆវីដែលមានថ្វីដៃបាញ់បានល្អ កាលត្រិះរិះថា ព្រះរាជាទ្រង់ធ្វើសង្គ្រាមជាមួយស្តេចលិច្ឆវីទាំងនោះ បានឃើញព្រះរាជាទ្រង់បរាជ័យ គេចទៅដោយទិព្វចក្ខុ ។ លំដាប់នោះ ទើបព្រះថេរៈហៅភិក្ខុទាំងឡាយមកពោលថា អ្នក

មានអាយុទាំងឡាយ ព្រះរាជាជាអ្នកឧបដ្ឋាករបស់ពួកលោក ទ្រង់ចាញ់ស្តេចលិច្ឆវីហើយ ។

ពាក្យថា **សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ** សេចក្តីថា មោគ្គល្លានកាលពិចារណាក្នុងវេលាដែលព្រះរាជាទ្រង់បរាជ័យ ពោលវត្ថុដែលខ្លួនឃើញឈ្មោះថា ពោលពិត ។

[ ២៩៨ ] រឿងការចុះឡើងនៃពួកដំរី មានវិនិច្ឆ័យដូច្នេះ បទថា **សប្បិនិកាយ** គឺស្ទឹងដែលមានឈ្មោះយ៉ាងនេះ ។

បទថា **អនេញ្ជំ សមាធឹ** បានដល់ ចតុត្ថជ្ឈានសមាធិដែលជាអនេញ្ជៈ គឺមិនកម្រើក វៀរចាកការកម្រើកតាមកាយ និងវាចា ។

បទថា **នាគានំ** ប្រែថា នៃដំរីទាំងឡាយ ។

ពាក្យថា **ឱគាហំ ឧត្តរន្តានំ** សេចក្តីថា ចុះទឹកហើយ ឡើងវិញ ។ បានឮថា ដំរីទាំងនោះចុះទឹកជ្រៅហើយ ងូត និងផឹកក្នុងទឹកនោះ យកប្រមោយបឺតទឹក ហើយបាញ់ដាក់គ្នានឹងគ្នា ទើបឡើងទៅ ។ មានពាក្យអធិប្បាយថា ដំរីទាំងនោះចុះទឹកហើយឡើងយ៉ាងនេះ ។

ពាក្យថា **កោញ្ចំ ករោន្តានំ** សេចក្តីថា ឈរនៅត្រង់ច្រាំងស្ទឹង លូកប្រមោយចូលក្នុងមាត់ហើយ ធ្វើសំឡេងដូចសត្វក្រៀល ។

ពាក្យថា **សទ្ទំ អស្សោសឹ** សេចក្តីថា ខ្ញុំបានឮសំឡេងកោញ្ចនាទនោះ ។

ពាក្យថា **អត្ថេសោ ភិក្ខវេ សមាធិ សោ ច ខោ អបរិសុទ្ធោ** សេចក្តីថា សមាធិនោះរបស់ព្រះមហាមោគ្គល្លានមាន ។ តែសមាធិនោះឯង

ជារបស់មិនបរិសុទ្ធ ។ បានឮថា ព្រះថេរៈក្នុងថ្ងៃទី ៧ បន្ទាប់អំពីបួស បានសម្រេចអរហត្តផលក្នុងថ្ងៃនោះ មិនទាន់មានវសីដែលប្រព្រឹត្តហើយ ដោយអាការ ៥ យ៉ាងក្នុងសមាបត្តិ ៨ មិនទាន់បានញ៉ាំងធម៌ដែលជាសត្រូវចំពោះសមាធិឲ្យបរិសុទ្ធដោយល្អ អង្គុយចូលចតុត្ថជ្ឈាន ធ្វើឲ្យមានត្រឹមតែសញ្ញានៃការនឹក ការចូល ការតាំងចិត្ត ការចេញ និងការពិចារណាប៉ុណ្ណោះ ចេញអំពីអង្គឈានហើយ បានឮសំឡេងដំរីទាំងឡាយ មានសេចក្ដីសម្គាល់យ៉ាងនេះថា អញបានឮសំឡេងខាងក្នុងសមាបត្តិ ដូច្នេះ ដោយហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមាធិនោះមាន តែសមាធិនោះឯងមិនបរិសុទ្ធ ។

[ ២៩៩ ] ក្នុងរឿងសោភិតភិក្ខុ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អហំ អាវុសោ បញ្ចកប្បសតានិ អនុស្សរាមិ** សេចក្ដីថា ព្រះថេរៈពោលថា ខ្ញុំរឭកជាតិបានដោយអាវជ្ជនចិត្ត ១ ។ កាលកាន់យកសេចក្ដីដទៃម្យ៉ាងទៀត ការរឭកដល់ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងអតីតនោះ ដោយអាវជ្ជនចិត្តផ្សេងៗ គ្នាដោយលំដាប់របស់ព្រះសាវកទាំងឡាយ មិនគួរអស្ចារ្យ ព្រោះដូច្នោះ ទើបភិក្ខុទាំងឡាយមិនលើកទោស តែព្រោះសោភិតភិក្ខុនោះពោលថា ខ្ញុំរឭកជាតិបានដោយអាវជ្ជនចិត្ត ១ ដូច្នេះ ព្រោះដូច្នោះ ទើបភិក្ខុទាំងឡាយលើកទោស ។

ពាក្យថា **ឯកាវេសា ភិក្ខវេ សោភិតស្ស សា ច ខោ ឯកាយេវ ជាតិ** សេចក្ដីថា ជាតិដែលសោភិតភិក្ខុពោលថា ខ្ញុំរឭកជាតិបានដូច្នេះរបស់

សោភិតភិក្ខុមាន ឯជាតិនោះ មានត្រឹមតែមួយជាតិប៉ុណ្ណោះ អធិប្បាយថា សោភិតភិក្ខុមិនបានរឭកដោយខុសលំដាប់ មិនជាប់តគ្នា ។

សួរថា សោភិតភិក្ខុនេះ រឭកជាតិបានដូចម្ដេច ឆ្លើយថា បានឮថា សោភិតភិក្ខុនេះ បួសក្នុងលទ្ធិតិរ្ថិយ ញ៉ាំងសញ្ញីសមាបត្តិឲ្យកើតឡើង ជាអ្នកមានឈានមិនវិនាស ស្លាប់ហើយ កើតក្នុងអសញ្ញីភពប្រមាណ ៥០០ កប្ប លោកនៅក្នុងអសញ្ញីភពនោះដរាបដល់ជន្មាយុក្នុងទីបំផុត កើតក្នុងមនុស្សលោក ហើយបួសក្នុងសាសនា បានធ្វើវិជ្ជា ៣ ឲ្យជាក់ច្បាស់ កាលលោករឭកដល់ខន្ធដែលធ្លាប់នៅអាស្រ័យក្នុងកាលមុន ឃើញបដិសន្ធិក្នុងអត្តភាពនេះ បន្ទាប់អំពីនោះ បានឃើញចំពោះចុតិក្នុងអត្តភាពទី ៣ ។ លំដាប់នោះ លោកមិនអាចរឭកដល់អត្តភាពដែលមិនមានចិត្ត ក្នុងចន្លោះចុតិ និងបដិសន្ធិទាំង ២ បាន ទើបកំណត់បានដោយន័យថា អាត្មាអញកើតក្នុងអសញ្ញីភពពិតប្រាកដ ព្រះសោភិតៈនោះកំណត់បានយ៉ាងនេះ បានធ្វើវត្ថុដែលធ្វើបានលំបាក ដូចជាការយកចុងរោមទ្រាយដែលគេច្រៀកជា ៧ ចម្រៀក ចាក់ឲ្យចំចុងរោមទ្រាយ ដូច្នោះ និងដូចសម្ដែងស្នាមជើងក្នុងអាកាស ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគ ទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈ ព្រោះរឿងនេះឯងថា ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុទាំងឡាយដែលជាសាវ័ករបស់តថាគត សោភិតៈនេះ ជាកំពូលនៃភិក្ខុទាំងឡាយ អ្នករឭកដល់ខន្ធដែលធ្លាប់អាស្រ័យក្នុងកាលមុន ដូច្នេះ ។

# គាថាសរុប ធារាជិក
# ធារាជិក ២៤

[ ៣០០ ] ពាក្យថា លោកដ៏មានអាយុទាំងឡាយ ធម៌ គឺបារាជិក ៤ ខ្ញុំលើកឡើង សូត្របើយ ដូច្នេះនេះ ជាពាក្យសម្តែងដល់បារាជិក ដែលលើកឡើងសម្តែង ក្នុងបារាជិកុទ្ទេសនោះឯង ។ តែប្រមូលគ្នាហើយ គប្បីជ្រាបបារាជិកទាំងអស់នោះឯងថា មាន ២៤ យ៉ាង បារាជិក ២៤ យ៉ាង គឺអ្វីខ្លះ គឺដែលមកក្នុងព្រះបាលី ៨ យ៉ាងមុន គឺរបស់ពួកភិក្ខុ ៤ ចំពោះរបស់ពួកភិក្ខុនី ៤ អភព្វបុគ្គល ១១ ពួក ។ បណ្តាអភព្វបុគ្គល ១១ ពួកនោះខ្ទើយ សត្វតិរច្ឆាន និងឧភតោព្យញ្ជនកៈ ៣ ពួក ជាពួកអហេតុកបដិសន្ធិ ចាត់ជាពួកវត្ថុវិបត្តិ ពួកវត្ថុវិបត្តិទាំងនោះ មិនបានហាមស្ថានសួគ៌ តែហាមមគ្គ ។ ពិតហើយ ខ្ទើយជាដើមនោះ ចាត់ជាអភព្វបុគ្គលសម្រាប់ការបានមគ្គ ព្រោះជាពួកវត្ថុវិបត្តិ ។ សូម្បីបព្វជ្ជាសម្រាប់ពួកបុគ្គលនោះ ទ្រង់ក៏ហាម ។ ព្រោះដូច្នោះ ទើបខ្ទើយជាដើមនោះ ចាត់ជាអ្នកចាលចាញ់ ( បារាជិក ) ។ បុគ្គល ៨ ពួកនេះ គឺ បុគ្គលលួចភេទ ភិក្ខុចូលតិរ្ថិយ អ្នកសម្លាប់មាតា អ្នកសម្លាប់បិតា អ្នកសម្លាប់ព្រះអរហន្ត សាមណេរដែលប្រទូស្តភិក្ខុនី អ្នកធ្វើលោហិតុប្បាទ ភិក្ខុដែលធ្វើសង្ឃភេទ ឈ្មោះថា ដល់ឋានៈជាអភព្វបុគ្គល ព្រោះជាបុគ្គលវិបត្តិ ដោយការធ្វើរបស់ខ្លួន ព្រោះដូច្នោះ ទើបចាត់ជាអ្នកចាលចាញ់ផងដែរ ។ បណ្តាបុគ្គល ៨ ពួកនោះ សម្រាប់បុគ្គល ៣ ពួកនេះ គឺបុគ្គលលួចភេទ ភិក្ខុចូលតិរ្ថិយ សាមណេរប្រទូស្តភិក្ខុនី មិនបានហាមសួគ៌ឡើយ តែហាមមគ្គដោយពិត ។ បុគ្គល ៥ ពួកទៀត ហាមទាំង ២ យ៉ាង

ព្រោះថា បុគ្គលទាំងនោះ ជាប្រភេទសត្វដែលត្រូវកើតក្នុងនរក មិនមានចន្លោះ ។ អភព្វបុគ្គល ១១ ពួកនេះ និងបុគ្គលដែលជាបារាជិក ៨ ខាងដើម ទើបរួមជា ១៩ ដោយប្រការដូច្នេះ ។ សូម្បីបុគ្គលទាំងនោះ រួមជាមួយភិក្ខុនីដែលញ៉ាំងការពេញចិត្តឲ្យកើតក្នុងភេទគ្រហស្ថ ហើយស្លៀកដណ្ដប់ដូចគ្រហស្ថ ទើបរួមជា ២០ ។ ពិតហើយ ភិក្ខុនីនោះ សូម្បីមិនបានធ្វើការកន្លងល្មើសដោយអជ្ឈាចារ ក៏រាប់ថា មិនមែនជាសមណីបាន ដោយហេតុមានប្រមាណប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបារាជិកទាំងនេះ មាន ២០ ជាបឋម ។ អាចារ្យពួកខ្លះពោលថា អនុលោមបារាជិកដទៃទៀតមាន ៤ ទៀត ដោយអំណាចភិក្ខុ ៤ ពួកនេះ គឺភិក្ខុមានអង្គជាតវែង ( ប្រាថ្នានឹងសេពមេថុនធម្ម ទើបញាត់អង្គកំណើតចូលទៅក្នុងទ្វារវច្ចមគ្គរបស់ខ្លួន ) ១ ភិក្ខុមានខ្នងទន់ ( ប្រាថ្នានឹងសេពមេថុនធម្ម បៀមអង្គកំណើតរបស់ខ្លួន ) ១ ភិក្ខុយកមាត់បៀមអង្គកំណើតអ្នកដទៃ ១ ភិក្ខុអង្គុយសង្កត់អង្គកំណើតរបស់អ្នកដទៃ ១ ក៏ព្រោះហេតុដែលធម៌របស់បុគ្គលពីរនាក់ ដែលចូលដល់ភាពតែមួយ ដោយអំណាចរាគៈ ត្រាស់ហៅថា មេថុនធម្ម ដូច្នោះ បារាជិក ៤ នេះ ឈ្មោះថា រមែងអនុលោមដល់មេថុនធម្មបារាជិក ដោយបរិយាយនេះ ព្រោះភិក្ខុ ៤ ពួកនោះ សូម្បីមិនបានសេពមេថុនធម្ម ក៏គប្បីត្រូវអាបត្តិបាន ដោយអំណាចការញ៉ាំងមគ្គ ឲ្យចូលទៅក្នុងមគ្គតែម្យ៉ាង ។ ព្រោះហេតុនោះ ទើបលោកហៅថា អនុលោមបារាជិក ដូច្នេះឯង ។ គប្បីសរុបអនុលោមបារាជិក ៤ នេះ និងបារាជិក ២០ ប្រការខាងដើមចូលគ្នាហើយ ជ្រាបបារាជិកទាំងអស់នោះឯង ថាមាន ២៤ ដោយប្រការដូច្នេះ ។

ពាក្យថា **ន លភតិ ភិក្ខូហិ សទ្ធឹ សំវាសំ** សេចក្តីថា រមែងមិនបាន សង្វាសដោយប្រភេទ មានឧបោសថ បវារណា បាតិមោក្ខុទ្ទេស និងសង្ឃ-កម្មជាមួយភិក្ខុទាំងឡាយ ។

ពាក្យថា **យថា បុរេ តថា បច្ឆា** សេចក្តីថា ក្នុងកាលមុន គឺក្នុងវេលាជាគ្រហស្ថ និងវេលាដែលមិនទាន់បានឧបសម្បទា ( រមែងជាអ្នកមិនមានសង្វាស ) យ៉ាងណា ក្រោយមក កាលត្រូវបារាជិកហើយ ក៏ជាអ្នកមិនមានសង្វាសដូច្នោះដូចគ្នា ។ សង្វាសដោយប្រភេទ មានឧបោសថ បវារណា បាតិមោក្ខុទ្ទេស និងសង្ឃកម្មជាមួយភិក្ខុទាំងឡាយ របស់ភិក្ខុនោះ មិនមាន ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា រមែងមិនបានសង្វាសជាមួយភិក្ខុទាំង-ឡាយ ។

ពាក្យថា **តត្ថាយស្មន្តេ បុច្ឆាមិ** សេចក្តីថា ខ្ញុំសូមសួរលោកទាំងឡាយ ក្នុងបារាជិក ៤ នេះថា លោកជាអ្នកបរិសុទ្ធហើយឬ ។

បទថា **កច្ចិត្ថ** កាត់បទថា **កច្ចិ ឯត្ថ** សេចក្តីថា ក្នុងបារាជិក ៤ នេះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ។

ម្យ៉ាងទៀត ពីរបទថា **កច្ចិត្ថ បរិសុទ្ធា** សេចក្តីថា លោកទាំងឡាយ រមែងជាអ្នកបរិសុទ្ធហើយឬ ។ បទដ៏សេសគ្រប់ៗ អន្ទើ មានអត្ថពាក់ទាំងអស់ហើយ ដូច្នេះឯង ។

ចតុត្ថបារាជិកវណ្ណនា ក្នុងអដ្ឋកថាព្រះវិន័យ

ឈ្មោះ សមន្តបាសាទិកា ចប់

# អធិដ្ឋានគាថា

**ចិរំ តិដ្ឋតុ សទ្ធម្មោ  កាលេ វស្សំ ចិរំ បជំ**

**តព្វេតុ ទេវោ ធម្មេន  រាជា រក្ខតុ មេទនិត្តិ។**

*សូមព្រះសទ្ធម្មតាំងនៅអស់កាលដ៏យូរ  សូមភ្លៀងធ្លាក់ចុះត្រូវតាមរដូវកាល  ញុំាងពួកសត្វឲ្យឆ្អែត  អស់កាលដ៏យូរ  សូមព្រះរាជាគ្រប់គ្រងផែនដីដោយធម៌ហោង ។*

# វិនយបិដក បាលីប្រែ ២

## តេរសកណ្ឌ

បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះ
សង្ឃាទិសេសទាំង ១៣ សិក្ខាបទនេះ មកកាន់ឧទ្ទេស ។

## សង្ឃាទិសេសទី ១

[ ១ ] សម័យនោះ ព្រះពុទ្ធដ៏មានជោគ ទ្រង់គង់នៅក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ សេយ្យសកភិក្ខុដ៏មានអាយុ មិនត្រេកអរនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ( ចង់សឹក ) ។ ដោយហេតុនោះ សេយ្យសកភិក្ខុក៏ទៅជាស្គាំងស្គមមានសម្បុរអាប់អន់ កើតមានរោគស្គមលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ។ ឧទាយិត្ថេរដ៏មានអាយុ ឃើញសេយ្យសកភិក្ខុដ៏មានអាយុស្គាំងស្គម មានសម្បុរអាប់អន់កើតមានរោគស្គមលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះឃើញហើយ ទើបសួរសេយ្យសកភិក្ខុថា ម្នាលអាវុសោសេយ្យសក ហេតុអ្វី បានជាលោកស្គាំងស្គម មានសម្បុរអាប់អន់ កើតមានរោគស្គមលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ( ដូច្នេះ ) ម្នាលអាវុសោសេយ្យសក លោកមិនត្រេកអរនឹងព្រហ្មចរិយធម៌ឬអ្វី ។ សេយ្យសកភិក្ខុឆ្លើយថា ករុណាអាវុសោ ។ ឧទាយិក៏បង្គាប់ថា ម្នាលអាវុសោសេយ្យសក បើដូច្នោះ លោកចូរឆាន់ឲ្យឆ្អែត សិងឲ្យស្កប់ ស្រង់ឲ្យពេញចំណង់ទៅ លុះដល់ឆាន់ឆ្អែត ឆាន់ពេញចំណង់ហើយ កាលណាបើសេចក្ដីអផ្សុកកើតមានដល់លោក រាគៈគ្របសង្កត់ចិត្ត

លោក លោកចូរព្យាយាមដោយដៃ ញុំាងទឹកអសុចិឲ្យឃ្លាតចេញក្នុងកាល នោះចុះ ។ ទើបសេយ្យសកភិក្ខុសួរថា ម្នាលអាវុសោ កិរិយាដែលសមណៈធ្វើយ៉ាងហ្នឹងគួរដែរឬ ។ ឧទាយិឆ្លើយថា ករុណាអាវុសោ ទុកជាខ្ញុំក៏ធ្វើយ៉ាងហ្នឹងដែរ ។ លំដាប់តពីនោះមក សេយ្យសកដ៏មានអាយុ ក៏ឆាន់ទាល់តែឆ្អែត សិងទាល់តែស្កប់ ស្រង់ទាល់តែពេញចំណង់ លុះដល់ឆាន់ឆ្អែត សិងស្កប់ ស្រង់ពេញចំណង់ហើយ កាលណាសេចក្តីអផ្សុកកើតឡើង រាគគ្របសង្កត់ចិត្ត ក៏ព្យាយាមដោយដៃ ញុំាងទឹកអសុចិឲ្យឃ្លាតចេញក្នុងកាលនោះ ។ គ្រាតមក សេយ្យសកភិក្ខុក៏ត្រឡប់ជាមានសម្បុរ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់បស់ មានសម្បុរស្បែកដ៏ផូរផង់ឡើងវិញ ។ គ្រានោះ ពួកភិក្ខុដែលជាសម្លាញ់សេយ្យសកដ៏មានអាយុ ក៏សួរសេយ្យសកដ៏មានអាយុថា ម្នាលអាវុសោសេយ្យសក កាលពីដើម លោកស្គាំងស្គម មានសម្បុរអាប់អន់ កើតទៅជាពកស្គមលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ឥឡូវនេះ លោកមានសម្បុរ មានឥន្ទ្រិយពេញលេញ មានសម្បុរមុខស្រស់-បស់ មានសម្បុរស្បែកផូរផង់ឡើងវិញ លោកបានធ្វើថ្នាំអ្វី ( ឆាន់ ) អាវុសោសេយ្យសក ។ សេយ្យសកភិក្ខុឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ ខ្ញុំគ្មានធ្វើថ្នាំអ្វី ( ឆាន់ ) ទេ តែខ្ញុំបានឆាន់ឆ្អែតសិងស្កប់ ស្រង់ទឹកពេញចំណង់ លុះបានឆាន់ឆ្អែតសិងស្កប់ ស្រង់ទឹកពេញចំណង់ហើយ កាលណាសេចក្តីអផ្សុកកើតឡើង រាគៈគ្របសង្កត់ចិត្តខ្ញុំ ខ្ញុំព្យាយាមបញ្ចេញទឹកអសុចិដោយដៃក្នុងកាលនោះ ។ ទើបពួកភិក្ខុជាសម្លាញ់សួរថា ម្នាលអាវុសោសេយ្យសក

លោកទទួលបរិភោគនូវរបស់ដែលគេឲ្យដោយសទ្ធា ដោយដៃណា លោកព្យាយាមបញ្ចេញទឹកអសុចិដោយដៃនោះឯង ឬអ្វី ។ សេយ្យសកភិក្ខុឆ្លើយថា ម្នាលអាវុសោទាំងឡាយ ពិតដូច្នោះឯង ។ ភិក្ខុទាំងឡាយណា ដែលជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោសត្មះតិះដៀលថា ហេតុអ្វីបានជាសេយ្យសកដ៏មានអាយុ ព្យាយាមបញ្ចេញទឹកអសុចិដោយដៃ ( ដូច្នោះ ) ។ គ្រានោះ ពួកភិក្ខុទាំងនោះ ក៏តិះដៀលសេយ្យសកដ៏មានអាយុដោយអនេកបរិយាយហើយ បានក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ទើបព្រះដ៏មានព្រះភាគ អាស្រ័យហេតុនេះ អាស្រ័យដំណើរនេះ ទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះទៅ សេយ្យសកដ៏មានអាយុថា ម្នាលសេយ្យសក បានឮថា អ្នកឯងព្យាយាមញ៉ាំងទឹកអសុចិឲ្យឃ្លាតចេញដោយដៃមែនឬ ។ សេយ្យសកទទួលតបថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់តិះដៀលថា ម្នាលបុរសឥតអំពើ កម្មនុ៎ះមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាលមោឃបុរស ហេតុអ្វីបានជាអ្នកឯងព្យាយាមបញ្ចេញទឹកអសុចិដោយដៃ ( ដូច្នោះ ) ម្នាលមោឃបុរស ធម៌ដែលតថាគតសម្តែងហើយដោយអនេកបរិយាយដ៏ច្រើន ( សុទ្ធតែ ) ដើម្បីឲ្យប្រាសចាករាគៈ មិនមែនដើម្បីប្រកបដោយរាគៈទេ ធម៌ដែលតថាគតសម្តែងហើយ ដើម្បីឲ្យប្រាសចាកគ្រឿងប្រកប មិនមែនដើម្បីគ្រឿងប្រកបទេ ធម៌ដែលតថាគតសម្តែងហើយដើម្បីឲ្យប្រាសចាកសេចក្តីប្រកាន់មាំ មិនមែនដើម្បីសេចក្តីប្រកាន់មាំទេ

( ដូច្នេះ ) មិនមែនឬ ម្នាលមោឃបុរស កាលបើធម៌ដែលតថាគតសំដែង ហើយ ( សុទ្ធតែ ) ដើម្បីឲ្យប្រាសចាករាគៈ អ្នកឯងបែរជារិះគិតត្រង់ធម៌នោះ ដើម្បីប្រកបដោយរាគៈទៅវិញ កាលបើធម៌ដែលតថាគតសំដែងហើយ ដើម្បីឲ្យប្រាសចាកគ្រឿងប្រកប អ្នកឯងបែរជារិះគិតដើម្បីគ្រឿងប្រកបវិញ កាលបើធម៌ដែលតថាគតសំដែងហើយដើម្បីឲ្យប្រាសចាកសេចក្តីប្រកាន់មាំ អ្នកឯងបែរជារិះគិតដើម្បីប្រកបដោយសេចក្តីប្រកាន់មាំវិញ ម្នាលមោឃបុរស ធម៌ដែលតថាគតសំដែងហើយ ដោយបរិយាយដ៏ច្រើន ( សុទ្ធតែ ) ដើម្បីនឿយណាយចាករាគ ដើម្បីញាំញីនូវសេចក្តីស្រវឹង ដើម្បីបន្ទោបង់នូវសេចក្តីស្រេក ដើម្បីដករំលើងនូវសេចក្តីអាល័យ ដើម្បីកាត់ផ្តាច់នូវវដ្ត ដើម្បីអស់ទៅនៃតណ្ហា ដើម្បីឲ្យប្រាសចាករាគៈ ដើម្បីកិរិយារលត់ ដើម្បីនិព្វាន ( ដូច្នេះ ) មិនមែនឬ ម្នាលមោឃបុរស កិរិយាលះបង់នូវកាមទាំងឡាយ តថាគតបានសំដែងហើយ ដោយអនេកបរិយាយ កិរិយាកំណត់ដឹងនូវសេចក្តីសម្គាល់ក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាបន្ទោបង់នូវសេចក្តីស្រេកក្នុងកាមទាំងឡាយ តថាគតបានសំដែងហើយ កិរិយាដករំលើងនូវកាមវិតក្កទាំងឡាយ តថាគតបានសំដែងហើយកិរិយារម្ងាប់បង់នូវសេចក្តីក្តៅក្រហាយព្រោះកាមទាំងឡាយ តថាគតបានសំដែងហើយ មិនមែនឬ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនុ៎ះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ( នោះ ) ទេ មិនមែននាំឲ្យរឹងរឹតតែជ្រះថ្លាឡើងដល់ជនទាំងឡាយ ដែលមានសេចក្តីជ្រះថ្លាហើយ ( នោះ ) ទេ ម្នាលមោឃបុរស អំពើរបស់អ្នកឯងនុ៎ះ បានតែខាងនាំមិនឲ្យ

ជ្រះថ្លាដល់ពួកជនខ្លះ ដែលមិនទាន់មានសេចក្តីជ្រះថ្លា នាំឲ្យរាយមាយសោយចិត្តបាត់សេចក្តីជ្រះថ្លាដល់ជនពួកខ្លះ ដែលមានសេចក្តីជ្រះថ្លាហើយ ( នោះ ) ប៉ុណ្ណោះឯង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលសេយ្យសកភិក្ខុដ៏មានអាយុដោយអនេកបរិយាយ ហើយទ្រង់សំដែងទោសនៃកោសជ្ជ ដែលជាហេតុនាំឲ្យគេចិញ្ចឹមបីបាច់រក្សាបានដោយកម្រ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុមានចិត្តក្លែង ញុំាងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះឯង ។

[ ២ ] សម័យនោះ ភិក្ខុទាំងឡាយបានឆាន់បណីតភោជនទាំងឡាយ ហើយភ្លេចស្មារតីមិនដឹងខ្លួនសិងលក់ទៅ ។ កាលបើភិក្ខុទាំងនោះ កំពុងតែភ្លេចស្មារតី មិនដឹងខ្លួនសិងលក់ ទឹកអសុចិក៏ឃ្លាតចេញដោយយល់សប្តិ ។ ភិក្ខុទាំងនោះ ក៏មានសេចក្តីសង្ស័យដូច្នេះថា សិក្ខាបទព្រះដ៏មានព្រះភាគបានទ្រង់បញ្ញត្តហើយថា ភិក្ខុក្លែងញុំាងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស ក៏ទឹកអសុចិរបស់យើងទាំងឡាយឃ្លាតចេញដោយយល់សប្តិ ឯចេតនាក៏មានក្នុងកាលដែលយល់សប្តិនោះដែរ យើងត្រូវអាបត្តិសង្ឃាទិសេសហើយដឹង ។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចេតនានោះមានមែន ប៉ុន្តែចេតនានោះជាអព្វោហារិកា[១] ។

---

១- អព្វោហារិកា ប្រែថា មិនប្រកបដោយវោហារ គឺថា មិនប្រកបដោយហេតុដែលគួរនិយាយបានឡើយ មិនមែនជាហេតុឲ្យទាស់ខុសនឹងបញ្ញត្តណាមួយឡើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់អាស្រ័យដំណើរនេះជាហេតុ អាស្រ័យដំណើរនេះជាទីតាំង ទើបទ្រង់សម្តែងធម្មកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុក្លែងញ៉ាំងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស លើកលែងតែយល់សប្តិ ។

[ ៣ ] ត្រង់ពាក្យថា ភិក្ខុក្លែង សេចក្តីថា ភិក្ខុកំពុងដឹង កំពុងចាំច្បាស់ ហើយក្លែងបំពានធ្វើឲ្យកន្លង ។ ត្រង់ពាក្យថា ទឹកសុក្ក សេចក្តីថា ទឹកសុក្កមាន ១០ យ៉ាង គឺទឹកសុក្កពណ៌ខៀវ ១ ទឹកសុក្កពណ៌លឿង ១ ទឹកសុក្កពណ៌ក្រហម ១ ទឹកសុក្កពណ៌ស ១ ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ១ ទឹកសុក្កពណ៌ដូចទឹក ១ ទឹកសុក្កពណ៌ដូចប្រេង ១ ទឹកសុក្ក ពណ៌ដូចទឹកដោះស្រស់ ១ ទឹកសុក្កពណ៌ដូចទឹកដោះជូរ ១ ទឹកសុក្កពណ៌ដូចទឹកដោះថ្លា ១ ។ ត្រង់ពាក្យថា ឲ្យឃ្លាតចេញ សេចក្តីថា ឲ្យកក្រើកឃ្លាត ចេញចាកទីកន្លែង ( ដើម ) តថាគតហៅថា ឲ្យឃ្លាតចេញ ។ ត្រង់ពាក្យថា លើកលែងតែយល់សប្តិ ( នោះ ) សេចក្តីថា វៀរលែងតែយល់សប្តិ ។ ត្រង់ពាក្យថា សង្ឃាទិសេស ( នោះ ) សេចក្តីថា សង្ឃតែម្យ៉ាងដែលឲ្យនូវបរិវាស ព្រោះអាបត្តិនោះ ត្រឡប់ស៊េរើចាកមូលាបត្តិ ឲ្យនូវមានត្ត ឲ្យនូវអព្ភាន មិនមែនភិក្ខុច្រើនរូប មិនមែនបុគ្គលតែមួយរូប ព្រោះហេតុនោះ បានជាតថាគតហៅថា សង្ឃាទិសេស ។ម្យ៉ាងទៀតថា ជានាមកម្ម គឺថាជាឈ្មោះរបស់កងអាបត្តិនោះឯង ព្រោះហេតុនោះ បានជាហៅថា សង្ឃាទិសេស ។

[ ៤ ] ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្នុង ( អវយវខ្លួនឯង ) ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្រៅ ( អវយវអ្នកដទៃ ) ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញក្នុងរូបខាងក្នុង និងរូបខាងក្រៅ ភិក្ខុធ្វើចង្កេះឲ្យញ័រក្នុងអាកាសញុំាងទឹកសុក្កឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយរាគៈ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញព្រោះសេចក្តីឧបត្ថម្ភដោយលាមក ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយមូត្រ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយខ្យល់ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ព្រោះសេចក្តីឧបត្ថម្ភដោយដង្កូវមាស់រោល ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍មិនឲ្យមានរោគ ភិក្ខុញុំាងទឹកសុក្ក ឲ្យឃ្លាតចេញដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីត្រូវការដោយភេសជ្ជ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ទាន ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់បុណ្យ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការបូជា ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញ ដើម្បីប្រយោជន៍ដល់ពូជ ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការល្បងមើល ភិក្ខុញុំាងទឹកសុក្កឲ្យឃ្លាតចេញដើម្បីប្រយោជន៍ដល់ការលេង ភិក្ខុញុំាងទឹកសុក្កពណ៌ខៀវឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌លឿងឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ក្រហមឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌សឲ្យឃ្លាតចេញ ភិក្ខុញុំាងទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឲ្យឃ្លាតចេញ ភិក្ខុញុំាង

ទឹកសុក្កពណ៌ដូចទឹកឲ្យឃ្លាតចេញ ភិក្ខុញ៉ាំងទឹកសុក្កពណ៌ដូចប្រេងឲ្យឃ្លាតចេញ ភិក្ខុញ៉ាំងទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឲ្យឃ្លាតចេញ ភិក្ខុញ៉ាំងទឹកសុក្កពណ៌ដូចទឹកដោះជូរឲ្យឃ្លាតចេញ ភិក្ខុញ៉ាំងទឹកសុក្កពណ៌ដូចទឹកដោះថ្លាឲ្យឃ្លាតចេញ ។

[ ៥ ] ត្រង់ពាក្យថា ក្នុងរូបខាងក្នុង សេចក្តីថា ក្នុងរូបដែលមានវិញ្ញាណ ចូលទៅអាស្រ័យនៅជាខាងក្នុង ។ ត្រង់ពាក្យថា ក្នុងរូបខាងក្រៅ សេចក្តីថា ក្នុងរូបដែលមានវិញ្ញាណក្តី ក្នុងរូបដែលឥតវិញ្ញាណក្តី ជាខាងក្រៅ ។ ត្រង់ពាក្យថា ក្នុងរូបខាងក្នុង និងរូបខាងក្រៅ សេចក្តីថា ក្នុងរូបទាំងពីរនោះ ។ ត្រង់ពាក្យថា ធ្វើចង្កេះឲ្យញ័រក្នុងអាកាស សេចក្តីថា អង្គជាតរបស់ភិក្ខុដែលកំពុងព្យាយាមទៅក្នុងអាកាស ក៏ជាអវយវៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយរាគៈ សេចក្តីថា អង្គជាតរបស់ភិក្ខុដែលរាគៈបៀតបៀនហើយ ជាអវយវៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយលាមក សេចក្តីថា អង្គជាតរបស់ភិក្ខុដែលលាមកបៀតបៀនហើយ ជាអវយវៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយមូត្រ សេចក្តីថា អង្គជាតរបស់ភិក្ខុដែលមូត្របៀតបៀនហើយ ជាអវយវៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយខ្យល់ សេចក្តីថា អង្គជាតរបស់ភិក្ខុដែលខ្យល់បក់ត្រូវហើយ ជាអវយវៈគួរដល់កម្ម ។ ត្រង់ពាក្យថា ព្រោះសេចក្តីឧបត្ថម្ភដោយដង្កូវមាស់ពេល សេចក្តីថា អង្គជាតរបស់ភិក្ខុដែលដង្កូវមាស់ពេលបៀតបៀនហើយ ជាអវយវៈគួរដល់កម្ម ។

ត្រង់ពាក្យថា ដើម្បីប្រយោជន៍មិនឲ្យមានរោគ សេចក្តីថា ភិក្ខុគិតថា អញនឹងជាអ្នកមិនមានរោគ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ឲ្យបានសេចក្តីសុខ សេចក្តីថា ភិក្ខុគិតថា អញនឹងញុំាងសុខវេទនាឲ្យកើតឡើង ។ ត្រង់ពាក្យថា ដើម្បីត្រូវការដោយភេសជ្ជៈ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះ នឹងបានជាថ្នាំ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ទាន សេចក្តីថា ភិក្ខុគិតថា អញនឹងឲ្យទឹកសុក្កជាទាន ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់បុណ្យ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះនឹងជាបុណ្យ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការបូជា សេចក្តីថា ភិក្ខុតាំងចិត្តថា អញនឹងបូជាទឹកសុក្កជាគ្រឿងយញ្ញ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ សេចក្តីថា ភិក្ខុគិតថា អញនឹងទៅកាន់ស្ថានសួគ៌ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ពូជ សេចក្តីថា ភិក្ខុគិតថា ទឹកសុក្កនេះនឹងជាពូជ ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការល្បងមើល សេចក្តីថា ភិក្ខុគិតថា អញនឹងល្បងមើល ទឹកសុក្កនេះនឹងជាពណ៌ខៀវ នឹងជាពណ៌លឿង នឹងជាពណ៌ក្រហម នឹងជាពណ៌ស ។បេ។ ទឹកសុក្កនេះនឹងជាពណ៌ដូចទឹកដោះថ្លា ។ ត្រង់ពាក្យថា ដើម្បីប្រយោជន៍ដល់ការលេង សេចក្តីថា ភិក្ខុមានបំណងក្នុងការលេង ។

[ ៦ ] ភិក្ខុគិតចំពោះរូបខាងក្នុង ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតចំពោះរូបខាងក្រៅ ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតចំពោះរូប ខាងក្នុងនិងរូបខាងក្រៅ ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិ-

សេស ។ ភិក្ខុគិតនឹងធ្វើចង្កេះឲ្យញ័រទៅក្នុងអាកាស ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយរាគៈ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយលាមក ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយមូត្រ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយខ្យល់ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតក្នុងសេចក្តីឧបត្ថម្ភដោយសត្វដង្កូវមោស់រោល ក៏ព្យា-យាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីប្រ-យោជន៍ មិនឲ្យមានរោគ ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីប្រយោជន៍ ឲ្យបានសេចក្តីសុខ ។បេ។ ដើម្បីត្រូវការដោយភេសជ្ជៈ ដើម្បីប្រយោជន៍ដល់ទាន ដើម្បីប្រយោជន៍ដល់បុណ្យ ដើម្បីប្រយោជន៍ដល់ការបូជា ដើម្បីប្រយោជន៍ដល់ស្ថានសួគ៌ ដើម្បីប្រយោជន៍ដល់ពូជ ដើម្បីប្រយោជន៍ដល់ការល្បងមើល ដើម្បីប្រយោជន៍ដល់ការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតចំពោះទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតចំពោះទឹកសុក្កពណ៌លឿង ចំពោះទឹកសុក្កពណ៌ក្រហម ចំពោះទឹកសុក្កពណ៌ស ចំពោះទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ចំពោះទឹកសុក្កពណ៌ដូចទឹក ចំពោះទឹកសុក្កពណ៌ដូចប្រេង ចំពោះទឹកសុក្កពណ៌

ដូចទឹកដោះស្រស់ ចំពោះទឹកសុក្កពណ៌ដូចទឹកដោះជូរ ចំពោះទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

## បទភាជនីយ៍សុទ្ធិក ចប់

[ ៧ ] ភិក្ខុគិតដើម្បីមិនឲ្យមានរោគ និងដើម្បីសេចក្តីសុខ ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីមិនឲ្យមានរោគ និងដើម្បីជាភេសជ្ជ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាទាន ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាបុណ្យ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីស្ថានសួគ៌ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីជាពូជ ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីល្បងមើល ។ ដើម្បីមិនឲ្យមានរោគ និងដើម្បីការលេង ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ខណ្ឌចក្កមានមូល ១ ចប់

[ ៨ ] ភិក្ខុគិតដើម្បីសេចក្តីសុខ និងដើម្បីជាភេសជ្ជ ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីសេចក្តីសុខ និងដើម្បីជាទាន ។ ដើម្បីសេចក្តីសុខ និងដើម្បីជាបុណ្យ ។ ដើម្បីសេចក្តីសុខ និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីសេចក្តីសុខ និងដើម្បីស្ថានសួគ៌ ។ ដើម្បីសេចក្តីសុខ និងដើម្បីជាពូជ ។ ដើម្បីសេចក្តីសុខ និងដើម្បីល្បងមើល ។ ដើម្បីសេចក្តីសុខ និងដើម្បីការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវ

អាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីសេចក្តីសុខ និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ៩ ] ភិក្ខុគិតដើម្បីជាភេសជ្ជ និងដើម្បីជាទាន ក៏ព្យាយាមទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីជាភេសជ្ជ និងដើម្បីជាបុណ្យ ។ ដើម្បីជាភេសជ្ជ និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីជាភេសជ្ជ និងដើម្បីស្ថានសួគ៌ ។ ដើម្បីជាភេសជ្ជ និងដើម្បីជាពូជ ។ ដើម្បីជាភេសជ្ជ និងដើម្បីល្បងមើល ។ ដើម្បីជាភេសជ្ជ និងដើម្បីការលេង ។ ដើម្បីជាភេសជ្ជ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាភេសជ្ជ និងដើម្បីសេចក្តីសុខ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១០ ] ភិក្ខុគិតដើម្បីជាទាន និងដើម្បីជាបុណ្យ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ដើម្បីជាទាន និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីជាទាន និងដើម្បីស្ថានសួគ៌ ។ ដើម្បីជាទាន និងដើម្បីស្ថានសួគ៌ ។ ដើម្បីជាទាន និងដើម្បីជាពូជ ។ ដើម្បីជាទាន និងដើម្បីល្បងមើល ។ ដើម្បីជាទាន និងដើម្បីការលេង ។ ដើម្បីជាទាន និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាទាន និងដើម្បីសេចក្តីសុខ ។ ដើម្បីជាទាន និងដើម្បីជាភេសជ្ជ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១១ ] ភិក្ខុគិត ដើម្បីជាបុណ្យ និងដើម្បីជាគ្រឿងយញ្ញ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីជាបុណ្យ

និងដើម្បីស្ថានសួគ៌ ។ ដើម្បីជាបុណ្យ និងដើម្បីជាពូជ ។ ដើម្បីជាបុណ្យ និងដើម្បីល្បងមើល ។ ដើម្បីជាបុណ្យ និងដើម្បីការលេង ។ ដើម្បីជាបុណ្យ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាបុណ្យ និងដើម្បីសេចក្តីសុខ ។ ដើម្បីជាបុណ្យ និងដើម្បីជាភេសជ្ជ ។ ដើម្បីជាបុណ្យ និងដើម្បីជាទាន ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១២ ] ភិក្ខុគិត ដើម្បីជាគ្រឿងយញ្ញ និងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាពូជ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីល្បងមើល ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីការលេង ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីសេចក្តីសុខ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាភេសជ្ជ ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាទាន ។ ដើម្បីជាគ្រឿងយញ្ញ និងដើម្បីជាបុណ្យ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៣ ] ភិក្ខុគិត ដើម្បីស្ថានសួគ៌ និងដើម្បីជាពូជ ។ ដើម្បីស្ថានសួគ៌ និងដើម្បីល្បងមើល ។ ដើម្បីស្ថានសួគ៌ និងដើម្បីការលេង ។ ដើម្បីស្ថានសួគ៌ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីស្ថានសួគ៌ និងដើម្បីសេចក្តីសុខ ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាភេសជ្ជ ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាទាន ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាបុណ្យ ។ ដើម្បីស្ថានសួគ៌ និងដើម្បីជាគ្រឿងយញ្ញ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៤ ] ភិក្ខុគិត ដើម្បីជាពូជ និងដើម្បីល្បងមើល ។ ដើម្បីជាពូជ និងដើម្បីការលេង ។ ដើម្បីជាពូជ និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីជាពូជ និងដើម្បីសេចក្តីសុខ ។ ដើម្បីជាពូជ និងដើម្បីជាភេសជ្ជ ។ ដើម្បីជាពូជ និងដើម្បីជាទាន ។ ដើម្បីជាពូជ និងដើម្បីជាបុណ្យ ។ ដើម្បីជាពូជ និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីជាពូជ និងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៥ ] ភិក្ខុគិតដើម្បីល្បងមើល និងដើម្បីការលេង ។ ដើម្បីល្បងមើល និងដើម្បីមិនឲ្យមានរោគ ។ ដើម្បីល្បងមើល និងដើម្បីសេចក្តីសុខ ។ ដើម្បីល្បងមើល និងដើម្បីជាភេសជ្ជ ។ ដើម្បីល្បងមើល និងដើម្បីជាទាន ។ ដើម្បីល្បងមើល និងដើម្បីជាបុណ្យ ។ ដើម្បីល្បងមើល និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីល្បងមើល និងដើម្បីស្ថានសួគ៌ ។ ដើម្បីល្បងមើល និងដើម្បីជាពូជ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៦ ] ភិក្ខុគិត ដើម្បីការលេង និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតដើម្បីការលេង និងដើម្បីសេចក្តីសុខ ។ ដើម្បីការលេង និងដើម្បីជាភេសជ្ជ ។ ដើម្បីការលេង និងដើម្បីជាទាន ។ ដើម្បីការលេង និងដើម្បីជាបុណ្យ ។ ដើម្បីការលេង និងដើម្បីជាគ្រឿងយញ្ញ ។ ដើម្បីការលេង និងដើម្បីស្ថានសួគ៌ ។ ដើម្បីការលេង និងដើម្បីជាពូជ ។ ដើម្បីការលេង និងដើម្បីល្បងមើល ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពន្ធចក្កមានមូល ១ ចប់**

ឯចក្កមានមូលពីរជាដើម បណ្ឌិតគប្បីនាំមក ( សម្តែង ) ដូចគ្នាផងចុះ ។

[ ១៧ ] ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីសេចក្តីសុខ និងដើម្បីជាភេសជ្ជៈ ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីសេចក្តីសុខ និងដើម្បីការលេង ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្ក មានមូល ២

[ ១៨ ] ភិក្ខុគិត ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីជាទាន ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីការលេង ។បេ។ ភិក្ខុគិត ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ភិក្ខុគិតដើម្បីល្បងមើល ដើម្បីការលេង និងដើម្បីមិនឲ្យមានរោគ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ភិក្ខុគិត ដើម្បីល្បងមើល ដើម្បីការលេង និងដើម្បីជាពូជ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ពទ្ធចក្កមានមូល ២ ចប់

[ ១៩ ] ពទ្ធចក្កមានមូល ៣ មូល ៤ មូល ៥ មូល ៦ មូល ៧ មូល ៨ មូល ៩ បណ្ឌិតគប្បីធ្វើយ៉ាងនេះឯង ។

នេះជាចក្កមានមូលគ្រប់ទាំងអស់ ( ដូចមានសេចក្តីខាងក្រោយនេះ ) ។

[ ២០ ] ភិក្ខុគិត ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្អានសួគ៌ ដើម្បីជាពូជ ដើម្បីល្បងមើល និងដើម្បីការលេង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូលគ្រប់ទាំងអស់ ចប់**

[ ២១ ] ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌លឿង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌ក្រហម ។បេ។ ពណ៌ខៀវ និងពណ៌ស ។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ខៀវ និងពណ៌ដូចទឹក ។ ពណ៌ខៀវ និងពណ៌ដូចប្រេង ។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះជូរ ។ ពណ៌ខៀវ និងពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ខណ្ឌចក្កមានមូល ១ ចប់**

[ ២២ ] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌លឿង និងពណ៌ក្រហម ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌លឿង និងពណ៌ស ។បេ។ ពណ៌លឿង និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌លឿង និងពណ៌ដូចទឹក ។ ពណ៌លឿង និងពណ៌ដូចប្រេង ។ ពណ៌លឿង និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌លឿង និង

ពណ៌ដូចទឹកដោះជូរ ។ ពណ៌លឿង និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌លឿង និង ពណ៌ខៀវ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ក្រហម និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ក្រហម និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ក្រហម និងពណ៌ដូចទឹក ។ ពណ៌ក្រហម និងពណ៌ដូចប្រេង ។ ពណ៌ក្រហម និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ក្រហម និងពណ៌ដូចទឹកដោះជូរ ។ ពណ៌ក្រហម និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ក្រហម និងពណ៌ខៀវ ។ ពណ៌ក្រហម និងពណ៌លឿង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ស និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ស និងពណ៌ដូចទឹក ។ ពណ៌ស និងពណ៌ដូចប្រេង ។ ពណ៌ស និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ស និងពណ៌ដូចទឹកដោះជូរ ។ ពណ៌ស និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ស និងពណ៌ខៀវ ។ ពណ៌ស និងពណ៌លឿង ។ ពណ៌ស និងពណ៌ក្រហម ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចប្រេង ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹកដោះជូរឡើងពពុះនិងពណ៌ខៀវ ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ

និងពណ៌លឿង ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ក្រហម ។ ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹក និងពណ៌ដូចប្រេង ។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹក និងពណ៌ខៀវ ។ ពណ៌ដូចទឹក និងពណ៌លឿង ។ ពណ៌ដូចទឹកនិងពណ៌ក្រហម ។ ពណ៌ដូចទឹក និងពណ៌ស ។ ពណ៌ដូចទឹក និងពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចប្រេង និងពណ៌ខៀវ ។ ពណ៌ដូចប្រេង និងពណ៌លឿង ។ ពណ៌ដូចប្រេង និងពណ៌ក្រហម ។ ពណ៌ដូចប្រេង និងពណ៌ស ។ ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ដូចប្រេង និងពណ៌ដូចទឹក ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះជូរ ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ខៀវ ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌លឿង ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ក្រហម ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ស ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។

ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចប្រេង ក៏ព្យាយាមត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះថ្លា ។ ពណ៌ដូចទឹកដោះជូរ និងពណ៌ខៀវ ។ ពណ៌ដូចទឹកដោះជូរ និងពណ៌លឿង ។ ពណ៌ដូចទឹកដោះជូរ និងពណ៌ក្រហម ។ ពណ៌ ដូចទឹកដោះជូរ និងពណ៌ស ។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចប្រេង ។ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា និងពណ៌ខៀវ ក៏ព្យាយាមត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា និងពណ៌លឿង ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ក្រហម ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ស ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹក ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចប្រេង ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹកដោះស្រស់ ។ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពទ្ធចក្កមានមូល ១ ចប់**

**៦ចក្កមានមូលពីរជាដើម បណ្ឌិតគប្បីនាំមក ( សម្តែង ) ដូចគ្នាផងចុះ ។**

[ ២៣ ] ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌

ក្រហម ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ខណ្ឌចក្កមានមូលពីរ ចប់**

[ ២៤ ] ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌លឿង ពណ៌ក្រហម និងពណ៌ស ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌លឿង ពណ៌ក្រហម និងពណ៌ខៀវ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា និងពណ៌ខៀវ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។បេ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា និងពណ៌ដូចទឹកដោះស្រស់ ក៏ព្យា-យាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពទ្ធចក្កមានមូលពីរ ចប់**

[ ២៥ ] ចក្កមានមូល ៣ មូល ៤ មូល ៥ មូល ៦ មូល ៧ មូល ៨ មូល ៩ បណ្ឌិតគប្បីធ្វើយ៉ាងនោះផងចុះ ។

នេះចក្កមានមូលគ្រប់ទាំងអស់ ( ដូចមានសេចក្តីខាងក្រោយនេះ ) ។

[ ២៦ ] ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម

ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាមត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូលគ្រប់ទាំងអស់ ចប់**

[ ២៧ ] ភិក្ខុគិត បញ្ចេញទឹកសុក្កពណ៌ខៀវតែម៉្យាង ដើម្បីមិនឲ្យមានរោគតែម៉្យាង ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ និងពណ៌លឿង ដើម្បីមិនឲ្យមានរោគ និងដើម្បីឲ្យស្រួលខ្លួន ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង និងពណ៌ក្រហម ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន និងដើម្បីជាភេសជ្ជៈ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម និងពណ៌ស ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ និងដើម្បីជាទាន ក៏ព្យាយាមត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស និងពណ៌ដូចទឹកដោះជូរឡើងពពុះ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន និងដើម្បីជាបុណ្យ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ និងពណ៌ដូចទឹក ដើម្បីមិន

ឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ និងដើម្បីជាគ្រឿងបូជា ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក និងពណ៌ដូចប្រេង ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា និងដើម្បីស្ថានសួគ៌ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង និងពណ៌ដូចទឹកដោះស្រស់ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ និងដើម្បីជាពូជ ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ និងពណ៌ដូចទឹកដោះជូរ ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ និងដើម្បីល្បងមើល ក៏ព្យាយាម ត្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតបញ្ចេញទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់

ពណ៌ដូចទឹកដោះជូរ និងពណ៌ដូចទឹកដោះថ្លា ដើម្បីមិនឲ្យមានរោគ ដើម្បីឲ្យស្រួលខ្លួន ដើម្បីជាភេសជ្ជៈ ដើម្បីជាទាន ដើម្បីជាបុណ្យ ដើម្បីជាគ្រឿងបូជា ដើម្បីស្ថានសួគ៌ ដើម្បីជាពូជ ដើម្បីល្បងមើល និងដើម្បីការលេង ក៏ព្យាយាមគ្រាតែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ឧភតោពទ្ធមិស្សកចក្ក ចប់**

[ ២៨ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថាអញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចប្រេងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូច

ទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ខណ្ឌចក្ក ចប់

[ ២៩ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ។បេ។ ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ។ ពណ៌ដូចទឹកឃ្លាតចេញវិញ ។ ពណ៌ដូចប្រេងឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ។ ពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

ពទ្ធចក្ក ចប់

[ ៣០ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ។បេ។ ( បែរជា) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ ។ ពណ៌ដូចប្រេងឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ។ ពណ៌ដូចទឹក

ដោះថ្នាឃ្លាតចេញវិញ ។ ពណ៌ខៀវឃ្លាតចេញវិញ ។ ពណ៌លឿងឃ្លាតចេញ វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ។បេ។ ( បែរជា ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃា-ទិសេស ។( ចក្កទាំងឡាយបណ្ឌិតគប្បីដឹងដោយអាការយ៉ាងនេះ ) ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ។បេ។ ( បែរជា ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ។ ពណ៌សឃ្លាតចេញវិញ ។ពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ។ពណ៌ដូចទឹកឃ្លាតចេញវិញ ។ ពណ៌ដូចប្រេងឃ្លាតចេញវិញ ។ ពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ។ពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃា-ទិសេស ។

## កុច្ឆិចក្ក ចប់

[ ៣១ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញ

នឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹក ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចប្រេង ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌ខៀវឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ១ ចប់**

[ ៣២ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម (បែរជា) ទឹកសុក្កពណ៌លឿងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ២ ចប់**

[ ៣៣ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម

( បែរជា ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌លឿង ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ក្រហមឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ៣ ចប់**

[ ៣៤ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ក្រហម ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌សឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ៤ ចប់**

[ ៣៥ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹក ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ស ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ៥ ចប់**

[ ៣៦ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចប្រេង ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរឡើងពពុះ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ៦ ចប់**

[ ៣៧ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចប្រេងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចទឹកដោះជូរ ពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹក ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចប្រេងឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ៧ ចប់**

[ ៣៨ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ដូចទឹកដោះថ្លា ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចប្រេង ក៏ព្យាយាម ( បែរជា ) ទឹក

សុក្កពណ៌ដូចទឹកដោះស្រស់ឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ៨ ចប់**

[ ៣៩ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះថ្លា ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះស្រស់ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះជូរឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ៩ ចប់**

[ ៤០ ] ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ខៀវ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ទឹកសុក្កពណ៌លឿង ពណ៌ក្រហម ពណ៌ស ពណ៌ដូចទឹកដោះជូរឡើងពពុះ ពណ៌ដូចទឹក ពណ៌ដូចប្រេង ពណ៌ដូចទឹកដោះស្រស់ ។ ភិក្ខុគិតថា អញនឹងបញ្ចេញទឹកសុក្កពណ៌ដូចទឹកដោះជូរ ក៏ព្យាយាម ( បែរជា ) ទឹកសុក្កពណ៌ដូចទឹកដោះថ្លាឃ្លាតចេញវិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ដំណើរនៃបិដ្ឋិចក្កទី ១០ ចប់**

**បិដ្ឋិចក្កចប់ហើយ**

[ ៤១ ] ភិក្ខុគិត ក៏ព្យាយាម ទាល់តែទឹកសុក្កឃ្លាតចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុគិត ក៏ព្យាយាម ( ប៉ុន្តែ ) ទឹកសុក្កមិនឃ្លាតចេញ ត្រូវ

អាបត្តិថុល្លច្ច័យ។ ភិក្ខុគិត (តែ) មិនព្យាយាម (ក៏ស្រាប់តែ) ទឹកសុក្កឃ្លាតចេញឯង មិនត្រូវអាបត្តិឡើយ។ ភិក្ខុគិត (តែ) មិនព្យាយាម ទឹកសុក្កក៏មិនឃ្លាតចេញ មិនត្រូវអាបត្តិឡើយ។ ភិក្ខុមិនគិតទេ (តែ) ព្យាយាម ទឹកសុក្កឃ្លាតចេញ មិនត្រូវអាបត្តិឡើយ។ ភិក្ខុមិនគិតទេ (តែ) ព្យាយាម ទឹកសុក្កមិនឃ្លាតចេញ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុមិនគិត មិនព្យាយាមទេ ( តែ ) ទឹកសុក្កឃ្លាតចេញ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុមិនគិត មិនព្យាយាមទេ ទឹកសុក្កក៏មិនឃ្លាតចេញ មិនត្រូវអាបត្តិឡើយ ។

[ ៤២ ] ( ភិក្ខុ ៦ ពួក ) គឺភិក្ខុយល់សប្តិ ១ ភិក្ខុមិនមានបំណងឲ្យទឹកសុក្កឃ្លាតចេញ ១ ភិក្ខុឆ្កួត ១ ភិក្ខុមានចិត្តរវើរវាយ ១ ភិក្ខុដែលទុក្ខវេទនាគ្របសង្កត់ ១ ភិក្ខុជាអាទិកម្មិក ( អ្នកធ្វើខុសមុនបញ្ញត្តិ ) ១ មិនត្រូវអាបត្តិឡើយ ។

( មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសម្តែងតទៅដូចមានខាងក្រោយនេះ )

[ ៤៣ ] រឿងភិក្ខុយល់សប្តិ ១ ភិក្ខុបន្ទោបង់ឧច្ចារៈ ១ ភិក្ខុបន្ទោបង់បស្សាវៈ ១ ភិក្ខុត្រិះរិះចំពោះកាមវិតក្ក ១ ភិក្ខុងូតទឹកក្តៅ ១ ភិក្ខុលាបថ្នាំ ១ ភិក្ខុអេះរមាស់ត្រង់អណ្ឌ ១ ភិក្ខុដើរតាមផ្លូវ ១ ភិក្ខុកាន់ស្បែកចុងអង្គជាត ១ ភិក្ខុកំដៅជំបារពោះក្នុងរោងភ្លើង ១ ភិក្ខុជជុសអង្គជាតនឹងភ្លៅ ១ ភិក្ខុឲ្យសាមណេរកាន់អង្គជាត ១ ភិក្ខុចាប់អង្គជាតសាមណេរកំពុងដេកលក់ ១ ភិក្ខុតៀ្បតអង្គជាតនឹងភ្លៅទាំងពីរ ១ ភិក្ខុក្តាប់អង្គជាតនឹងដៃ ១ ភិក្ខុពើងចង្កេះ

ពួដ៏អាកាស ១ ភិក្ខុមីតពត់កាយ ១ ភិក្ខុសម្លឹងមើលអង្គជាតមាតុគ្រាម ១ ភិក្ខុបញ្ចូលអង្គជាតក្នុងប្រហោងដាន ( ប្រហោង ឬរន្ធអ្វីៗ ហៅថា ប្រហោងដាន ) ១ ភិក្ខុជដុសអង្គជាតនឹងកំណាត់ឈើ ១ ភិក្ខុងូតទឹកក្នុងទីច្រាសខ្សែទឹក ១ ភិក្ខុលេងទឹកដែលមានល្បាប់ ១ ភិក្ខុស្ទុះចុះទៅក្នុងទឹក ១ ភិក្ខុលេងកងធ្វើដោយផ្កា ១ ភិក្ខុស្ទុះចូលទៅក្នុងព្រៃឈូក ១ ភិក្ខុបញ្ចូលអង្គជាតក្នុងដីខ្សាច់ ១ ភិក្ខុបញ្ចូលអង្គជាតក្នុងភក់ ១ ភិក្ខុស្រោចអង្គជាតនឹងទឹក ១ ភិក្ខុផ្ទាប់អង្គជាតនឹងកន្ទេលដេក ១ ភិក្ខុជដុសអង្គជាតនឹងមេជើង ១ ។

[ ៤៤ ] សម័យនោះឯង ភិក្ខុ ១ រូប កំពុងយល់សប្តិ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយដឹង ។ ទើបភិក្ខុនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិព្រោះយល់សប្តិទេ ។

[ ៤៥ ] សម័យនោះឯង ភិក្ខុ ១ រូប កំពុងបន្ទោបង់ឧច្ចារៈ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង ។ ភិក្ខុនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានប្រាថ្នាឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។

[ ៤៦ ] សម័យនោះឯង ភិក្ខុមួយរូប កំពុងបន្ទោបង់បស្សាវៈ អសុចិ

ក៏ឃ្លាតចេញ ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលមិនមានប្រាថ្នាឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។

[ ៤៧ ] សម័យនោះឯង ភិក្ខុមួយរូប កំពុងត្រិះរិះចំពោះកាមវិតក្ក អសុចិក៏ឃ្លាតចេញ ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិដល់ភិក្ខុដែលត្រិះរិះចំពោះកាមវិតក្កទេ ។

[ ៤៨ ] សម័យនោះឯង ភិក្ខុមួយរូប កំពុងងូតទឹកក្តៅ អសុចិក៏ឃ្លាតចេញ ។ សេចក្តីសង្ស័យមានដល់ភិក្ខុនោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងឲ្យអសុចិឃ្លាតចេញទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងនឹងឲ្យអសុចិឃ្លាតចេញ កំពុងតែងូតទឹកក្តៅអសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងនឹងឲ្យអសុចិឃ្លាតចេញ កំពុងងូតទឹកក្តៅដែរ ( តែ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៤៩ ] សម័យនោះឯង ភិក្ខុមួយរូប កើតដំបៅត្រង់អង្គជាត ។ កាល

ដែលភិក្ខុនោះលាបថ្នាំដំបៅ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង ។ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ អ្នកឯងមានចិត្តគិតដូចម្តេច ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គនឹងមានបំណងចង់ឲ្យអសុចិឃ្លាតចេញក៏ទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណង ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប កើតដំបៅត្រង់អង្គជាត ។ ភិក្ខុនោះមានបំណងនឹងឲ្យអសុចិឃ្លាតចេញ កាលដែលលាបថ្នាំដំបៅ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥០ ] សម័យនោះឯង ភិក្ខុមួយរូបអេះត្រង់អណ្ឌ ( ពងល្វា ) អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញហើយអេះអណ្ឌ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥១ ] សម័យនោះឯង ភិក្ខុមួយរូប កំពុងដើរទៅតាមផ្លូវ អសុចិក៏

ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ កំពុងដើរទៅតាមផ្លូវ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥២ ] សម័យនោះឯង ភិក្ខុមួយរូប កំពុងកាន់ស្បែកខាងចុងនៃអង្គជាតធ្វើបស្សាវៈ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងនឹងឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ កំពុងចាប់ស្បែកខាងចុងនៃអង្គជាតធ្វើបស្សាវៈ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥៣ ] សម័យនោះឯង ភិក្ខុមួយរូប កំពុងកំដៅជំបារពោះក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុ ដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ កំពុងកំដៅជំបារពោះក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ ។បេ។ ( មាន

ភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥៤ ] សម័យនោះឯង ភិក្ខុមួយរូប កំពុងគក់ប្រឋាប់ខ្នងឲ្យឧបជ្ឈាយ៍ក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ កំពុងគក់ប្រឋាប់ខ្នងឲ្យឧបជ្ឈាយ៍ក្នុងរោងភ្លើង អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥៥ ] សម័យនោះឯង ភិក្ខុមួយរូប យកអង្គជាតជជុសទឹងភ្លៅ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ (នោះ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ក៏យកអង្គជាតជជុសទឹងភ្លៅ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥៦ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ បានពោលពាក្យនេះនឹងសាមណេរមួយរូបថា នែអាវុសោសាមណេរ

អ្នកចូរមកនេះ ចូរកាន់អង្គជាតអញចុះ ។ សាមណេរនោះបានកាន់អង្គជាតភិក្ខុនោះ ។ អសុចិរបស់ភិក្ខុនោះ ក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។

[ ៥៧ ] សម័យនោះឯង ភិក្ខុមួយរូប បានចាប់អង្គជាតសាមណេរដែលកំពុងដេកលក់ ។ អសុចិភិក្ខុនោះ ក៏ឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៥៨ ] សម័យនោះឯង ភិក្ខុមួយរូប ច្បៀតនូវអង្គជាតដោយភ្លៅទាំងពីរ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ច្បៀតនូវអង្គជាតដោយភ្លៅទាំងពីរ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៥៩ ] សម័យនោះឯង ភិក្ខុមួយរូប ក្តាប់អង្គជាតដោយកណ្តាប់ដៃ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ក្តាប់អង្គជាតដោយកណ្តាប់ដៃ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិ

មិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦០ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ប្រឹងបំពើងចង្កេះឰដ៏អាកាស អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦១ ] សម័យនោះឯង ភិក្ខុមួយរូប ប្រឹងមឹតពត់កាយ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ប្រឹងមឹតពត់កាយ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦២ ] សម័យនោះឯង ភិក្ខុមួយរូប ត្រេកអរសម្លឹងមើលអង្គជាតមាតុគ្រាម ។ អសុចិនោះក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ម្នាលភិក្ខុទាំងឡាយ តែថាភិក្ខុមិនគួរត្រេកអរ សម្លឹងមើលអង្គជាតមាតុគ្រាមឡើយ ភិក្ខុណាសម្លឹងមើល ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

[ ៦៣ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាត

ចេញ ក៏បញ្ចូលអង្គជាតទៅទីងប្រហោងដាន អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦៤ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដដុសអង្គជាតនឹងកំណាត់ឈើ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦៥ ] សម័យនោះឯង ភិក្ខុមួយរូប ងូតទឹកក្នុងទីប្រាសខ្សែទឹក អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុ ដែលមិនមានបំណងនឹងឲ្យអសុចិឃ្លាតចេញនោះទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ងូតទឹកក្នុងទីប្រាសខ្សែទឹក អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦៦ ] សម័យនោះឯង ភិក្ខុមួយរូប លេងទឹកដែលមានល្បាប់ អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ លេងទឹកដែលមានល្បាប់ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិន

ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦៧ ] សម័យនោះឯង ភិក្ខុមួយរូប ស្ទុះចុះទៅក្នុងទឹក អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ស្ទុះចុះទៅក្នុងទឹក អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦៨ ] សម័យនោះឯង ភិក្ខុមួយរូប លេងកងផ្កា អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ លេងកងធ្វើដោយផ្កា អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៦៩ ] សម័យនោះឯង ភិក្ខុមួយរូប ស្ទុះចូលទៅក្នុងព្រៃឈូក អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ។

សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ស៊ុះចូលទៅក្នុងព្រៃឈូក អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៧០ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដាក់បញ្ចូលអង្គជាតទៅក្នុងដីខ្សាច់ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៧១ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដាក់បញ្ចូលអង្គជាតទៅក្នុងភក់ អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៧២ ] សម័យនោះឯង ភិក្ខុមួយរូប ស្រោចអង្គជាតដោយទឹក អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងចង់ឲ្យអសុចិឃ្លាតចេញ ( នោះ ) ទេ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ស្រោចអង្គជាតដោយទឹក អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៧៣ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ផ្ទាប់អង្គជាតលើទីជេក អសុចិក៏ឃ្លាតចេញ ។បេ។ ( មានភិក្ខុខ្លះ ) អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៧៤ ] សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដដុសអង្គជាតនឹងមេជើង អសុចិក៏ឃ្លាតចេញ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង ។ ក៏ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង ភិក្ខុមួយរូប មានបំណងចង់ឲ្យអសុចិឃ្លាតចេញ ដដុសអង្គជាតនឹងមេជើង អសុចិមិនឃ្លាតចេញ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង ។ ក៏ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

សង្ឃាទិសេសទី ១ ចប់

# អដ្ឋកថា

# សមន្តបាសាទិកា អដ្ឋកថា ព្រះវិន័យ

## មហាវិភង្គវណ្ណនា

## តេរសកណ្ឌវណ្ណនា

*តេរសក (ពួក ១៣) ដែលព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានចងក្រងទុកក្នុងលំដាប់នៃបារាជិកកណ្ឌ មានការពណ៌នាបទ ដែលមិនទាន់មានអំពីមុនដូចតទៅនេះ ។*

## សុក្កវិសដ្ឋិសិក្ខាបទវណ្ណនា

[ ១ ] *បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សម័យនោះឯង ព្រះមានព្រះភាគ ប្រថាប់នៅនាវត្តជេតវន អារាមរបស់អនាថបិណ្ឌិកគហបតី ក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង សេយ្យសកភិក្ខុមិនត្រេកអរប្រព្រឹត្តព្រហ្មចរិយៈនេះ ដូចតទៅនេះថា បទថា* **អាយស្មា** *ជាពាក្យពីរោះពិសា ។*

*បទថា* **សេយ្យសកោ** *ជាឈ្មោះរបស់ភិក្ខុអង្គនោះ ។*

*បទថា* **អនភិរតោ** *សេចក្តីថា ជាអ្នកមានចិត្តរាយមាយ គឺត្រូវសេចក្តីក្តៅក្រហាយ ព្រោះតម្រេកក្នុងកាមដុតរោល តែមិនប្រាថ្នាភាពជាគ្រហស្ថ ។*

*បទថា* **សោ តេន កិសោ ហោតិ** *សេចក្តីថា សេយ្យសកភិក្ខុនោះស្គមស្គាំង ព្រោះជាអ្នកមិនត្រេកអរនោះ ។*

*ក្នុងបទថា* **អទ្ទសា ខោ អាយស្មា ឧទាយិ** *នេះ មានវិនិច្ឆ័យដូច្នេះ*

ថា បទថា **ឧបាយិ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ពិតហើយ ព្រះថេរៈឈ្មោះលោលុទាយីនេះ ជាឧបជ្ឈាយ៍របស់សេយ្យសកភិក្ខុ ដែលជាអ្នកមានចំណែកប្រៀបដោយម្រឹគផ្អើល គឺជាភិក្ខុឡេះឡោះមួយអង្គ បណ្ដាភិក្ខុតាមប្រកបហេតុនៃសេចក្ដីខិលប្រអូស មានភាពជាអ្នកមានការត្រេកអរក្នុងការដេកលក់ជាដើម ។

បទថា **កច្ចិ នោ ត្វំ** ខែសេចក្ដីថា **កច្ចិ នុ ត្វំ** ប្រែថា លោក ... លះបង់ ( ការប្រព្រឹត្តព្រហ្មចរិយធម៌ ) ឬហ្ន៎ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **យាវទត្ថំ ភុញ្ជ** ដូចតទៅនេះថា សេចក្ដីត្រូវការមានប្រមាណត្រឹមណា ឈ្មោះថា **យាវទត្ថ** ( តាមដែលត្រូវការ ) អធិប្បាយថា លោកមានបំណងដោយភោជនប្រមាណប៉ុនណា គឺលោកត្រូវការប្រមាណប៉ុនណា ចូរបរិភោគប្រមាណប៉ុណ្ណោះ ឬលោកប្រាថ្នាដើម្បីដេកក្នុងពេលយប់ ឬពេលថ្ងៃអស់កាលប្រមាណប៉ុនណា ចូរដេកអស់កាលប្រមាណប៉ុណ្ណោះ លោកប្រាថ្នាការជម្រះកាយដោយជីឥដ្ឋជាដើម ខាត់ស្បែកដោយលម្អិតជាដើម ហើយងូតទឹកប្រមាណប៉ុនណា ចូរងូតទឹកប្រមាណប៉ុណ្ណោះ មិនមានប្រយោជន៍ដោយបាលី អដ្ឋកថា វត្តបដិបត្តិ ឬដោយកម្មដ្ឋាន ។

បទថា **យទា តេ អនភិរតិ ឧប្បជ្ជតិ** សេចក្ដីថា ក្នុងកាលណា ការអផ្សុក គឺភាពជាអ្នកមានចិត្តរាយមាយ ដោយអំណាចនៃតម្រេកក្នុងកាមកើតឡើងដល់លោក ។

បទថា **រាគោ ចិត្តំ អនុទ្ធំសេតិ** សេចក្ដីថា កាមរាគៈ រមែងកម្ចាត់

*ទម្លាយ គឺបន្សាត់ចិត្តទៅមក និងធ្វើចិត្តឲ្យស្ងិតស្រពោន ។*

*បទថា* **តទា ហត្ថេន ឧបក្កមិត្វា អសុចឹ មោចេហិ** *សេចក្ដីថា ក្នុងកាលនោះ លោកចូរយកដៃព្យាយាមធ្វើការបញ្ចេញអសុចិ ពិតហើយ ដោយការធ្វើយ៉ាងនេះ ឯកគ្គតាចិត្តនឹងមានដល់លោក ឧបជ្ឈាយ៍ប្រៀនប្រដៅយ៉ាងនេះ ដូចគ្នានឹងមនុស្សល្ងង់ប្រៀនប្រដៅមនុស្សល្ងង់ មនុស្សឆ្កួតប្រៀនប្រដៅមនុស្សឆ្កួត ដូច្នោះ ។*

# អធិប្បាយ អនុប្បញ្ញត្តិ រឿង ភិក្ខុច្រើនរូប

*[ ២ ] បទថា* **តេសំ ។បេ។ ឱក្កមន្តានំ** *សេចក្ដីថា កាលភិក្ខុទាំងនោះលះសតិសម្បជញ្ញៈ សិង ។ ក្នុងពាក្យនោះ មានវិនិច្ឆ័យដូច្នេះថា កាលភិក្ខុទាំងឡាយកំពុងសិង ភវង្គវារៈដែលជាអព្យាកតៈប្រព្រឹត្តទៅ សតិសម្បជញ្ញវារៈនឹងឃ្លៀងឃ្លាតទៅក៏ពិត សូម្បីដូច្នោះ ក្នុងការដេក ភិក្ខុគួរធ្វើមនសិការ ។ ភិក្ខុកាលសិងក្នុងវេលាថ្ងៃ គប្បីសិងព្រមដោយសេចក្ដីឧស្សាហ៍ថា អញនឹងសិងក្នុងវេលា ដែលសក់របស់ភិក្ខុផូតទឹកមិនទាន់ស្ងួត ហើយនឹងក្រោកឡើង ដូច្នេះ បើសិងក្នុងពេលយប់ គប្បីជាអ្នកមានសេចក្ដីឧស្សាហ៍ថា អញនឹងសិងអស់ចំណែកនៃរាត្រីមានប្រមាណប៉ុណ្ណេះ ហើយក្រោកឡើងក្នុងវេលាដែលព្រះចន្ទ ឬផ្កាយគោចរមកដល់ត្រង់ទីឈ្មោះនេះ ។*

*ម្យ៉ាងទៀត គប្បីកំណត់កម្មដ្ឋានឯណាមួយ ក្នុងបណ្ដាកម្មដ្ឋានទាំង ១០ មានពុទ្ធានុស្សតិជាដើម ឬកម្មដ្ឋានដែលពេញចិត្តដទៃ ហើយសឹមសិង ។ កាលភិក្ខុធ្វើដូច្នោះ លោកហៅថា មានសតិសម្បជញ្ញៈ គឺមិនលះសតិ និង*

សម្បជញ្ញៈ សិន ឯភិក្ខុនោះ ជាបុគ្គលល្ងង់ ឡេះឡោះ មានចំណែកប្រៀបដោយម្រឹគផ្អើល មិនបានយ៉ាងនោះ ។ ដោយហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលថា **តេសំ ។បេ។ ឱក្កមន្តានំ** ដូច្នេះ ។

បទថា **អត្ថិ ចេត្ថ ចេតនា ឧបលព្ភតិ** សេចក្តីថា ការពេញចិត្តត្រេកអរក្នុងការយល់សប្តិនេះ មាន គឺរកបាន ។

បទថា **អត្ថេសា ភិក្ខវេ ចេតនា សា ច ខោ អព្វោហារិកា** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ចេតនាជាហេតុត្រេកអរនេះមាន តែចេតនានោះឯងឈ្មោះថា ជាអព្វោហារិក គឺមិនជាអង្គនៃអាបត្តិ ព្រោះកើតឡើងក្នុងឋានៈដែលមិនមែនជាវិស័យ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងភាពដែលចេតនាក្នុងការយល់សប្តិ ជាអព្វោហារិកដោយអាការយ៉ាងនេះហើយ ទើបទ្រង់បញ្ញត្តសិក្ខាបទព្រមទាំងអនុប្បញ្ញត្តិថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុក្លែងញុំាងទឹកសុក្កឲ្យឃ្លាតចេញ ត្រូវសង្ឃាទិសេស លើកលែងតែយល់សប្តិ ដូច្នេះ ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃសុក្កវិសដ្ឋិសិក្ខាបទ

[ ៣ ] ក្នុងសិក្ខាបទនោះ មានវិនិច្ឆ័យដូចតទៅនេះថា ចេតនានៃការបញ្ចេញសុក្កនោះមាន ហេតុនោះ ទើបការបញ្ចេញសុក្កនោះ ឈ្មោះថា សញ្ចេតនា ( មានចេតនា ) សញ្ចេតនានោះឯង ឈ្មោះសញ្ចេតនិកា ។ ម្យ៉ាងទៀត ការក្លែងរបស់ការបញ្ចេញសុក្កនោះមាន ហេតុនោះ ទើបការបញ្ចេញ

សុក្កនោះ ឈ្មោះថា សញ្ចេតនិកា ( មានចិត្តក្លែង )។ ការបញ្ចេញសុក្ក មានចិត្តក្លែង ជារបស់ភិក្ខុណា ភិក្ខុនោះជាអ្នកដឹង គឺដឹងខ្លួន ហើយបញ្ចេញសុក្កនោះរបស់ភិក្ខុនោះ មានការក្លែង គឺបំពានល្មើស ព្រោះហេតុនោះ ដើម្បីសម្តែងតែអត្ថប៉ុណ្ណោះ មិនធ្វើការអើពើក្នុងព្យញ្ជនៈ ទើបព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា **សញ្ចេតនិកា** នោះ យ៉ាងនេះថា អាការដែលដឹង គឺដឹង ក្លែង គឺបំពាន កន្លងល្មើស ឈ្មោះថា មានចិត្តក្លែង ។

បណ្តាបទទាំងនោះ បទថា **ជានន្តោ** បានដល់ ដឹងថា អញកំពុងព្យាយាម ។

បទថា **សញ្ជានន្តោ** បានដល់ ដឹងខ្លួនថា អញកំពុងបញ្ចេញសុក្ក អធិប្បាយថា ដឹងព្រមនឹងអាការដែលព្យាយាម និងការដឹងនោះឯង ។

បទថា **ចេច្ច** បានដល់ ក្លែង គឺ តាំងចិត្ត ដោយអំណាចចេតនា គឺការត្រេកអរក្នុងការបញ្ចេញ ។

បទថា **អភិវិតរិត្វា** បានដល់ កាលបំពានដោយអំណាចសេចក្តីព្យាយាម បញ្ជូនចិត្តដែលប្រាសចាកសេចក្តីរង្កៀសទៅ ។

បទថា **វីតិក្កមោ** មានពាក្យអធិប្បាយថា ការកន្លងល្មើសណារបស់ភិក្ខុដែលប្រព្រឹត្តយ៉ាងនោះ ការកន្លងល្មើសនោះ ជាអត្ថកំពូលនៃ **សញ្ចេតនិកា** សព្ទ ។

ឥឡូវនេះ ព្រះមានព្រះភាគ ត្រាស់ពាក្យថា **សុក្កន្តិ ទស សុក្កានិ** ជាដើម ក៏ដើម្បីសម្តែងសុក្ក និងការបញ្ចេញ ក្នុងបទថា **សុក្កវិសដ្ឋិ** នេះ

ដោយចំនួន និងដោយការផ្សេងនៃពណ៌ជាមុន ។ ក្នុងចំនួន និងការផ្សេងនៃពណ៌នោះ គប្បីជ្រាបការផ្សេងនៃពណ៌ទៀវជាដើម ដោយការផ្សេងគ្នានៃទីអាស្រ័យរបស់សុក្កទាំងឡាយ និងដោយការផ្សេងគ្នានៃធាតុ ។ ការលះឈ្មោះថា ការបញ្ចេញ ។ ពាក្យថា បញ្ចេញនេះ ដោយអត្ថ ជាការធ្វើឲ្យឃ្លាតចាកទី ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា កិរិយាដែលធ្វើឲ្យឃ្លាតចាកទី ហៅថា បញ្ចេញ ។ ក្នុងពាក្យនោះ អាចារ្យទាំងឡាយកំណត់ទីនៃសុក្កទុក ៣ ចំណែក គឺថ្លោកនោម ១ ចង្កេះ ១ កាយ ១ ។ បានឮថា អាចារ្យមួយរូបពោលថា ថ្លោកនោមជាស្ថានរបស់សុក្ក ។ មួយរូបពោលថា ចង្កេះជាស្ថានរបស់សុក្ក ។ មួយរូបពោលថា កាយទាំងមូល ។

ក្នុងអាចារ្យ ៣ រូបនោះ ភាសិតរបស់អាចារ្យទី ៣ ពោលត្រឹមត្រូវ ។ ព្រោះថា វៀរសក់ រោម ក្រចក និងធ្មេញ ផុតអំពីសាច់ និងឧច្ចារៈបស្សាវៈ ទឹកមាត់ ទឹកសម្បោរ និងស្បែកដែលក្រិនចេញហើយ កាយទាំងអស់ដ៏សេស ដែលមានស្បែក និងសាច់ ដែលឈាមរត់ទៅមកបាន ជាស្ថានរបស់កាយបសាទ ភាវរូប ជីវិតិន្ទ្រិយ និងប្រមាត់មិនមានស្រោម និងជាស្ថានរបស់ទឹកសម្ភវៈដូចគ្នា ។ ពិតហើយ ទឹកសម្ភវៈ រមែងហូរអំពីគុម្ពត្រចៀកទាំងពីររបស់ដំរីទាំងឡាយ ដែលត្រូវរាគៈគ្របសង្កត់ហើយ ។ ឯព្រះបាទមហាសេន ដែលត្រូវរាគៈគ្របសង្កត់ ទ្រង់មិនអាចអត់ធន់នឹងកម្លាំងទឹកសម្ភវៈបាន ទើបប្រើឲ្យវះដើមដៃដោយកាំបិត ទ្រង់បង្ហាញទឹកសម្ភវៈដែលហូរចេញតាមមុខដំបៅ ដូច្នេះឯង ។

បណ្ដាវាទៈទាំងនេះ ក្នុងវាទៈរបស់អាចារ្យទី ១ កាលភិក្ខុព្យាយាម ត្រង់និមិត្ត ដោយការត្រេកអរទើងឲ្យឃ្លាត រុយតូចៗ មួយក្បាលគប្បីផឹកទឹក អសុចិមានប្រមាណប៉ុនណាបាន កាលអសុចិមានប្រមាណប៉ុណ្ណោះ គ្រាន់តែ ឃ្លាតចាកថ្លោកនោម ហូរចុះកាន់ដងបដ្ឋរបស់វា: ទោះចេញខាងក្រៅក្ដី មិន ចេញក្ដី ត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងវាទៈរបស់អាចារ្យទី ២ ក៏ដូចគ្នា កាលអសុចិគ្រាន់តែឃ្លាតចាកចង្កេះ ហូរកាន់ដងបដ្ឋរ ត្រូវអាបត្តិសង្ឃា- ទិសេស ។ ក្នុងវាទៈរបស់អាចារ្យទី ៣ ក៏ដូចគ្នា ព្រោះញ៉ាំងកាយទាំងមូល ឲ្យកម្រើក កាលអសុចិគ្រាន់តែឃ្លាតចាកកាយនោះរហូតចុះកាន់ដងបដ្ឋរ ទោះ ចេញខាងក្រៅក្ដី មិនចេញក្ដី ត្រូវអាបត្តិសង្ឃាទិសេស ។ ឯការហូរចុះកាន់ ដងបដ្ឋរ លោកពោលទុកក្នុងការបញ្ចេញសុក្កនេះ ក៏ព្រោះជារបស់ដែល បុគ្គលណា មិនគប្បីអាចនឹងអត់សង្កត់ ហាមឃាត់ក្នុងចន្លោះបាន ។

ពិតហើយ អសុចិឃ្លាតចាកស្ថានហើយ រមែងចុះកាន់ដងបដ្ឋរដោយ ពិត ព្រោះដូច្នោះ ក្នុងការបញ្ចេញសុក្កនេះ គប្បីជ្រាបអាបត្តិ ដោយហេតុ ត្រឹមតែឲ្យឃ្លាតចាកស្ថានប៉ុណ្ណោះ ។ ហើយអាបត្តិនោះឯង រមែងមានដល់ ភិក្ខុដែលព្យាយាមត្រង់និមិត្តប៉ុណ្ណោះ ។ ចំណែកក្នុងការធ្វើហត្ថបរិកម្ម បាទ- បរិកម្ម និងគត្តបរិកម្ម សូម្បីអសុចិឃ្លាតក៏មិនត្រូវអាបត្តិ ។ នេះជាវិនិច្ឆ័យ ទូទៅនៃអាចារ្យទាំងពួង ។

## អធិប្បាយ ហេតុឱ្យយល់សប្តិ ៤ យ៉ាង

ក្នុងពាក្យថា **អញ្ញត្រ សុបិនន្តា** មានវិនិច្ឆ័យដូច្នេះថា សុបិននោះឯង

ឈ្មោះថា **សុបិនន្ត** មានពាក្យអធិប្បាយថា វៀរ គឺនាំការយល់សប្តិនោះចេញទៅ ។ ឯបុគ្គលកាលយល់សប្តិនោះ រមែងយល់សប្តិព្រោះហេតុ ៤ ប្រការ គឺព្រោះធាតុកម្រើក ១ ព្រោះធ្លាប់ដឹងមកមុន ១ ព្រោះទេវតាបណ្តាល ១ ព្រោះបុព្វនិមិត្ត ១ ។

បណ្តាហេតុ ៤ យ៉ាងនោះ បុគ្គលមានធាតុកម្រើក ព្រោះប្រកបដោយបច្ច័យដែលធ្វើឲ្យប្រមាត់ជាដើមកម្រើក ឈ្មោះថា រមែងយល់សប្តិ ព្រោះធាតុកម្រើក ។ ហើយកាលយល់សប្តិ រមែងយល់សប្តិផ្សេងៗ ដូចជាធ្លាក់អំពីភ្នំ ដូចហោះទៅតាមអាកាស ដូចត្រូវម្រឹគកាច ដំរីកាច និងចោរជាដើមដេញជាប់តាម ។ កាលយល់សប្តិ ព្រោះធ្លាប់ដឹងមកអំពីមុន ឈ្មោះថា រមែងយល់សប្តិដល់អារម្មណ៍ដែលខ្លួនធ្លាប់សោយមកហើយ ក្នុងកាលមុន ។ ពួកទេវតារមែងនាំអារម្មណ៍ មានសភាពផ្សេងៗ ចូលទៅ ដើម្បីសេចក្តីចម្រើនខ្លះ ដើម្បីសេចក្តីវិនាសខ្លះ ព្រោះជាអ្នកចង់ឲ្យចម្រើនខ្លះ ព្រោះជាអ្នកចង់ឲ្យវិនាសខ្លះ ដល់បុគ្គលអ្នកយល់សប្តិនោះ ព្រោះទេវតាបណ្តាល បុគ្គលនោះរមែងយល់សប្តិឃើញអារម្មណ៍ទាំងនោះ ដោយអានុភាពរបស់ទេវតានោះ ។ កាលបុគ្គលយល់សប្តិព្រោះបុព្វនិមិត្ត ឈ្មោះថា រមែងយល់សប្តិដែលជាបុព្វនិមិត្តនៃសេចក្តីចម្រើនខ្លះ វិនាសខ្លះ ដែលឲ្យកើតឡើងដោយអំណាចនៃបុណ្យ និងបាប ដូចព្រះមាតារបស់ព្រះពោធិសត្វ ទ្រង់សុបិននិមិត្តក្នុងការដែលនឹងបានព្រះឱរសដូច្នោះ ដូចព្រះពោធិសត្វទ្រង់មហាសុបិន ៥ និងដូចព្រះបាទកោសលទ្រង់ព្រះសុបិន ១៦ ប្រការដូច្នោះឯង ។

បណ្តាការយល់សប្តិ ៤ ប្រការនោះ ការយល់សប្តិដែលអ្នកយល់សប្តិ ព្រោះធាតុកម្រើក និងព្រោះធ្លាប់ដឹងមកអំពីមុន មិនពិតប្រាកដឡើយ ការយល់សប្តិ ដែលអ្នកយល់សប្តិ ព្រោះទេវតាបណ្តាល ពិតក៏មាន មិនពិតក៏មាន ព្រោះថា ទេវតាក្រោធហើយ បំណងនឹងឲ្យវិនាសដោយឧបាយ ទើបសម្តែងឲ្យឃើញវិបរិតទៅខ្លះ ។ ចំណែកការយល់សប្តិ ដែលបុគ្គលយល់សប្តិ ព្រោះបុព្វនិមិត្ត ជាសេចក្តីពិតតែម្យ៉ាង ដូច្នេះ ។ ការប្លែកផ្សេងគ្នានៃយល់សប្តិ ព្រោះការផ្សេងគ្នានៃហេតុទាំង ៤ យ៉ាងនេះ លាយចូលគ្នាក៏មាន បានដូចគ្នា ។ ឯការយល់សប្តិទាំង ៤ យ៉ាងនោះ ព្រះសេក្ខៈ និងបុថុជ្ជនប៉ុណ្ណោះ រមែងយល់សប្តិ ព្រោះមិនទាន់លះវិបល្លាសបាន ។ អសេក្ខៈទាំងឡាយ រមែងមិនយល់សប្តិ ព្រោះលោកលះវិបល្លាសបានហើយ ។

សួរថា បុគ្គលកាលយល់សប្តិនោះ លក់យល់សប្តិ ឬភ្ញាក់យល់សប្តិ ឬមិនលក់ មិនភ្ញាក់ យល់សប្តិ ឆ្លើយថា ក្នុងរឿងយល់សប្តិនេះ លោកគួរពោលបន្ថែមទៀតត្រឹមតែបន្តិចបន្តួច ។ ដំបូងបើបុគ្គលលក់យល់សប្តិ ក៏នឹងត្រូវជំទាស់នឹងព្រះអភិធម្ម ព្រោះថា បុគ្គលដេកលក់ដោយភវង្គចិត្ត ។ ភវង្គចិត្តនោះ មិនមានរូបនិមិត្តជាដើមជាអារម្មណ៍ ឬសម្បយុត្តដោយរាគៈជាដើមឡើយ ។ កាលបុគ្គលយល់សប្តិ ចិត្តទាំងឡាយដូច្នេះ រមែងកើតឡើងបាន ។ បើបុគ្គលភ្ញាក់យល់សប្តិ ក៏ត្រូវជំទាស់នឹងព្រះវិន័យ ព្រោះថា បុគ្គលភ្ញាក់យល់សប្តិឃើញវត្ថុណា បុគ្គលឃើញវត្ថុនោះដោយសព្វោហារិកចិត្ត ( ចិត្តតាមប្រក្រតី ) ។ ឈ្មោះថា អនាបត្តិរមែងមិនមាន ព្រោះការកន្លងល្មើស

ដែលភិក្ខុធ្វើដោយសព្វោហារិកចិត្ត តែកាលបុគ្គលកំពុងយល់សប្តិ ធ្វើការកន្ទងល្មើស ជាអនាបត្តិតែម្យ៉ាង ។ បើបុគ្គលមិនលក់ មិនភ្ញាក់យល់សប្តិ ឈ្មោះថា នរណាក៏យល់សប្តិមិនបាន ហើយកាលបើដូច្នោះ ការយល់សប្តិក៏ត្រូវមិនមានពិត គឺមានមិនបាន ។ ព្រោះហេតុអ្វី ព្រោះបុគ្គលដែលដេកលក់ដូចដំណេកស្វា ទើបយល់សប្តិ ។ សមដូចពាក្យដែលព្រះនាគសេនត្ថេរពោលថា បពិត្រមហារាជ បុគ្គលដេកលក់ដូចដំណេកស្វា ទើបយល់សប្តិនោះឯង ។

បទថា **កបិមិទ្ធបរេតោ** ប្រែថា ប្រកបដោយការដេកលក់ដូចស្វាដេកលក់ ។ ព្រោះថា ការដេកលក់របស់ស្វាប្រែប្រួលរហ័ស យ៉ាងណា ការដេកលក់ណាប្រែប្រួលរហ័ស ព្រោះច្រើនដោយចិត្តជាកុសលជាដើមរឿយៗ ក៏ដូច្នោះ គឺមានការភ្ញាក់ឡើងអំពីភវង្គរឿយៗ ក្នុងវេលាការលក់ណាប្រព្រឹត្តទៅ បុគ្គលនោះ ប្រកបដោយការលក់នោះ រមែងយល់សប្តិបាន ព្រោះហេតុនោះ ទើបការយល់សប្តិនេះ ជាកុសលខ្លះ ជាអកុសលខ្លះ ជាអព្យាកតៈខ្លះ ។ បណ្តាការយល់ ៣ យ៉ាងនោះ ការយល់សប្តិរបស់បុគ្គលដែលយល់សប្តិថា កំពុងធ្វើការថ្វាយបង្គំព្រះចេតិយ ស្តាប់ធម៌ និងសម្តែងធម៌ជាដើម គប្បីជ្រាបថាជាកុសល របស់បុគ្គលដែលយល់សប្តិថា កំពុងធ្វើបាប មានការសម្លាប់សត្វជាដើម គប្បីជ្រាបថា ជាអកុសល ការយល់សប្តិដែលផុតទៅអំពីអន្តទាំងពីរ គប្បីជ្រាបថា ជាអព្យាកតៈក្នុងខណៈនៃអាវជ្ជនចិត្ត និងតទាលម្ពណ-ចិត្ត ។ ការយល់សប្តិនេះ មិនអាចដើម្បីនឹងនាំបដិសន្ធិមកបានទេ ព្រោះ

ចេតនាជាវត្ថុមានកម្លាំងខ្សោយ តែក្នុងបវត្តិកាលដែលកុសល និងអកុសលដទៃឧបត្ថម្ភហើយ រមែងឲ្យវិបាកបាន ទោះបីឲ្យវិបាកបានក៏ពិត សូម្បីដូច្នោះ ចេតនាក្នុងការយល់សប្តិ ក៏រាប់ថាជាអព្វោហារិកនោះឯង ព្រោះកើតក្នុងឋានៈដែលមិនមែនជាវិស័យ ។ ព្រោះហេតុនោះ ទើបព្រះឧបាលីពោលថា វៀរលែងតែយល់សប្តិ ។

## អធិប្បាយ ពាក្យថា សង្ឃាទិសេស

ពាក្យថា **សង្ឃាទិសេស** សេចក្តីថា ជាឈ្មោះរបស់កងអាបត្តិនេះ ។ ព្រោះហេតុនោះ អ្នកសិក្សាគប្បីជ្រាបសម្ពន្ធ ក្នុងសិក្ខាបទនេះ យ៉ាងនេះថា ការបញ្ចេញសុក្ក មានចិត្តក្រែង វៀរការយល់សប្តិឯណា នេះជាកងនៃអាបត្តិឈ្មោះសង្ឃាទិសេស ឯអត្ថចំពោះពាក្យក្នុងបទថា **សង្ឃាទិសេស** នេះថា សង្ឃដែលភិក្ខុគប្បីប្រាថ្នាក្នុងកម្មជាខាងដើម និងក្នុងកម្មដ៏សេសនៃកងអាបត្តិនោះ ព្រោះដូច្នោះ ទើបកងអាបត្តិនោះ ឈ្មោះថា សង្ឃាទិសេស ។ មានពាក្យអធិប្បាយដូចម្តេច មានពាក្យអធិប្បាយថា ភិក្ខុត្រូវអាបត្តិនេះហើយ គប្បីត្រូវការសង្ឃ ដើម្បីប្រយោជន៍ដល់បរិវាស ក្នុងកម្មជាខាងដើម នៃការចេញចាកអាបត្តិ របស់បុគ្គលដែលប្រាថ្នានឹងចេញ និងដើម្បីប្រយោជន៍ដល់ការឲ្យមានត្ត ឬដើម្បីប្រយោជន៍ដល់ការឲ្យមានត្ត រួមទឹងមូលាយបដិកស្សនា ក្នុងកម្មដែលជាកណ្តាល ដើម្បីប្រយោជន៍ដល់អព្ភានកម្ម ក្នុងកម្មជាទីបំផុតដ៏សេសអំពីដែលជាខាងដើម ព្រោះថា បណ្តាកម្មទាំងនេះ កម្មឯណានីមួយ វៀរសង្ឃចេញហើយ បុគ្គលណាមួយមិនអាចនឹងធ្វើបាន ភិក្ខុសង្ឃគប្បីប្រាថ្នា

ក្នុងកម្មខាងដើម និងកម្មដ៏សេសនៃកងអាបត្តិនោះ ព្រោះដូច្នោះ ទើបកង អាបត្តិនោះ ឈ្មោះថា សង្ឃាទិសេស ។

ដើម្បីមិនអើពើនឹងព្យញ្ជនៈ សម្តែងតែអត្ថប៉ុណ្ណោះ ទើបព្រះមានព្រះ ភាគត្រាស់បទភាជនីយ៍នៃបទថា **សង្ឃាទិសេស** នោះ ដូច្នេះថា សង្ឃរមែង ឲ្យបរិវាសដើម្បីអាបត្តិនោះ រមែងសើរើចាកមូលាបត្តិ រមែងឲ្យមានត្ត ឲ្យ អព្ភាន មិនមែនភិក្ខុច្រើនរូប មិនមែនបុគ្គលតែមួយ ព្រោះហេតុនោះ ទើប អាបត្តិនោះ លោកពោលថា **សង្ឃាទិសេស** ។ ហើយត្រាស់ហេតុនៃពាក្យ ទុកក្នុងគម្ពីរបរិវារថា

> សិក្ខាបទណាដែលតថាគតហៅថា សង្ឃាទិសេស ចូរអ្នកប្រុង ស្តាប់សិក្ខាបទនោះ ដូចសម្តែងតទៅនេះ ។ សង្ឃឲ្យបរិវាស ទាញមកដាក់ក្នុងមូលាបត្តិ ឲ្យមានត្ត ឲ្យអព្ភាន ព្រោះហេតុ នោះ សិក្ខាបទនុ៎ះ តថាគតហៅថា សង្ឃាទិសេស ។

ពីរបទថា **តស្សេវ វា អាបត្តិនិកាយស្ស** សេចក្តីថា ( ម្យ៉ាងទៀត កម្មជាឈ្មោះសម្រាប់ហៅ ) ប្រជុំនៃអាបត្តិនោះឯង ។ ក្នុងព្រះបាលីនោះ អាបត្តិនេះ មានត្រឹមតែម្យ៉ាងក៏ពិត ហេតុនោះ **និកាយ** សព្ទ លោកពោល ដោយ **រុឡ្ហិ** សព្ទ ឬដោយវោហារដែលហៅចំណែកទាំងឡាយរួមគ្នា ដូច **ខន្ធ** សព្ទ ក្នុងពាក្យថា វេទនាខន្ធ ១ វិញ្ញាណក្ខន្ធ ១ ដូច្នេះជាដើម ។

សិក្ខាបទវិភង្គនៃសុក្កវិសដ្ឋិសិក្ខាបទ ចប់

# អធិប្បាយ
# បទភាជនីយ៍នៃសុក្កវិសដ្ឋិសិក្ខាបទ

[ ៤ ] ព្រះដ៏មានព្រះភាគ កាលទ្រង់ចែកសិក្ខាបទ ដែលទ្រង់ឧទ្ទេសទុកតាមលំដាប់យ៉ាងនោះហើយ ឥឡូវនេះ ទើបត្រាស់ថា **អជ្ឈត្តរូបេ មោចេតិ** ជាដើម ដើម្បីសម្តែងឧបាយ កាលបំណង និងវត្ថុនៃសេចក្តីបំណងរបស់ភិក្ខុដែលដល់នូវការបញ្ចេញសុក្កនេះ ។

ពិតហើយ ក្នុងចំណែកទាំង ៤ មានឧបាយជាដើមនេះ ឧបាយទ្រង់សម្តែងហើយដោយបទទាំង ៤ មានអជ្ឈត្តរូបជាដើម ព្រោះថា ភិក្ខុគប្បីបញ្ចេញក្នុងរូបខាងក្នុងខ្លះ ក្នុងរូបខាងក្រៅខ្លះ ក្នុងរូបទាំងពីរខ្លះ គប្បីពើងចង្កេះក្នុងអាកាសបញ្ចេញខ្លះ ។ ឧបាយដទៃក្រៅអំពីនេះរមែងមិនមាន ។ ក្នុងឧបាយនោះ ភិក្ខុព្យាយាមបញ្ចេញក្នុងរូបក្តី ព្យាយាមបញ្ចេញដោយរូបក្តី គប្បីជ្រាបថា បញ្ចេញក្នុងរូបទាំងអស់ ព្រោះថា កាលមានរូប ទើបបញ្ចេញបាន មិនមានរូប បញ្ចេញមិនបាន ដូច្នេះឯង ។

ចំណែកកាលទ្រង់សម្តែងដោយ ៥ បទមានរាគៈឧបត្ថម្ភជាដើម ។ ពិតហើយ កាលអង្គជាតណា ជារបស់គួរដល់ការងាររមាន ទើបភិក្ខុបញ្ចេញបានអង្គជាតនោះ រមែងជារបស់គួរដល់ការងារក្នុងកាលដែលរាគៈឧបត្ថម្ភជាដើម ( ក្នុងវេលាមានតម្រេកឧបត្ថម្ភជាដើម ) កាលដទៃក្រៅអំពីនេះ រមែងមិនមាន ព្រោះថា វៀរចាកកាលដែលរាគៈឧបត្ថម្ភជាដើមនោះចេញហើយ កាលដទៃ មានពេលព្រឹកជាដើម ជាទីកំណត់ក្នុងការឲ្យឃាតមិនបាន ។ បំណងទ្រង់សម្តែងដោយ ១០ បទ មានបទថា **អារោគ្យត្ថាយ** ( ជាដើម ) ។

ពិតហើយ ភិក្ខុរមែងឲ្យឃ្លាតតាមប្រភេទនៃបំណាងបែបនេះ មិនមែនដោយប្រការដទៃឡើយ ចំណែកវត្ថុបំណាងទី ៩ ទ្រង់សម្ដែងដោយ ១០ បទ មាន **ធីល** បទជាដើម ។ ពិតហើយ ភិក្ខុកាលសាកល្បង រមែងសាកល្បងដោយអំណាចនៃពណ៌ខៀវជាដើមឯណាមួយ ពណ៌ដទៃផុតចាកពណ៌ទាំងនោះរមែងមិនមាន ដូច្នេះឯង ។

[ ៥ ] តអំពីនេះទៅ ព្រះមានព្រះភាគត្រាស់ពាក្យថា **អជ្ឈត្តរូបេតិ អជ្ឈត្តំ ឧចាធិន្នរូបេ** ជាដើម ដើម្បីប្រកាសបទទាំងឡាយ មាន **អជ្ឈត្តរូប** បទជាដើម ទាំងនោះឯង ។ បណ្ដាបទទាំងនោះ បទថា **អជ្ឈត្តំ ឧចាធិន្នរូបេ** គឺក្នុងរូបប្រភេទផ្សេងៗ មានដៃជាដើមរបស់ខ្លួន ។

បទថា **ពហិទ្ធា ឧចាធិន្នេ** គឺក្នុងរូបដូច្នោះដូចគ្នារបស់អ្នកដទៃ ។

បទថា **ឧចាធិន្នេ** គឺក្នុងរូបប្រភេទផ្សេង មានរន្ធនុកទ្វារជាដើម ។

បទថា **តទុភយេ** គឺក្នុងរូបរបស់ខ្លួនផង របស់អ្នកដទៃផង ។ ការឲ្យសុក្កឃ្លាតយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ដោយអំណាចសេចក្ដីព្យាយាមក្នុងរូបទាំងពីរ ។ ការឲ្យសុក្កឃ្លាតចេញ រមែងមានសូម្បីក្នុងការព្យាយាមរួមគ្នាដោយរូបរបស់ខ្លួន និងដោយអនុបាទិន្នរូប ។

ពីរបទថា **អាកាសេ វាយមន្តស្ស** សេចក្ដីថា មិនព្យាយាមដោយរូបណាមួយឡើយ គ្រវីអង្គជាតដោយប្រយោគ គឺការពើងចង្កេះក្នុងអាកាសតែម្យ៉ាង ។

បទថា **វាតូបត្ថម្ភេ** សេចក្ដីថា ក្នុងវេលាអង្គជាតកើតតម្រេក ព្រោះ

រោគៈដ៏មានកម្លាំង ឬព្រោះតម្រេក ។ អធិប្បាយថា កាលអណ្ឌជាតកើតការរឹង ឡើងហើយ ។

ពីរបទថា **កម្មនិយំ ហោតិ** សេចក្ដីថា អណ្ឌជាតដែលអវយវៈគួរដល់ កម្មក្នុងការឲ្យឃ្លាតចាកទី គឺសមគួរដល់ការព្យាយាម ក្នុងអណ្ឌត្តរូបជាដើម ។

បទថា **ឧច្ចាលិង្គបាណកទដ្ឋបត្តម្ភេ** សេចក្ដីថា កាលអណ្ឌជាតត្រូវ ឧបត្ថម្ភឲ្យកើតតម្រេក ព្រោះដង្កូវមាសរោល ។ ដែលឈ្មោះថា ដង្កូវ មាស ជាសត្វល្អិតមានរោម អណ្ឌជាតដែលរោមរបស់សត្វល្អិតតូចៗ ទាំង នោះពាល់ត្រូវក៏កម្រើកដងបង្អួរ ហើយរឹង ក្នុងបាលីនោះ ព្រះមានព្រះភាគ ត្រាស់ថា ព្រោះត្រូវដង្កូវមាសរោល ព្រោះរោមទាំងនោះរមែងសម្រេចដូច រោលអណ្ឌជាត ។ តែដោយអត្ថ មានអធិប្បាយថា ព្រោះត្រូវរោមរបស់ដង្កូវ មាសរោល ។ បទថា **អរោគោ ភវិស្សាមិ** សេចក្ដីថា អាត្មាអញឲ្យសុក្ក ឃ្លាតចេញហើយ នឹងជាអ្នកមិនមានរោគ ។

បទថា **សុខំ វេទនំ ឧប្បាទេស្សាមិ** សេចក្ដីថា សុខវេទនាឯណា រមែងមានព្រោះការឲ្យឃ្លាត គឺព្រោះបញ្ចេញ និងព្រោះសុក្កឃ្លាតចាកទីហើយ ជាបច្ច័យ អញនឹងញុំាងសុខវេទនានោះឲ្យកើតឡើង ។

បទថា **ភេសជ្ជំ ភវិស្សតិ** សេចក្ដីថា សុក្កដែលអញឲ្យឃ្លាតចាកទី ហើយនេះ នឹងជាថ្នាំប្រភេទខ្លះនោះឯង ។

បទថា **ទានំ ទស្សាមិ** សេចក្ដីថា អញធ្វើឲ្យឃ្លាតចាកទីហើយ នឹង ឲ្យទានដល់សត្វតូចៗ មានរុយ និងស្រមោចជាដើម ។

បទថា **បុញ្ញំ ភវិស្សតិ** សេចក្ដីថា កាលអញបញ្ចេញឲ្យទានដល់សត្វល្អិតជាដើម នឹងជាបុណ្យ ។

បទថា **យញ្ញំ យជិស្សាមិ** សេចក្ដីថា អញធ្វើឲ្យឃាតចាកទីហើយនឹងបូជាយញ្ញដល់ពួកសត្វល្អិតជាដើម អធិប្បាយថា អញនឹងពោលបទមន្តណាមួយ ហើយឲ្យ ។

បទថា **សគ្គំ គមិស្សាមិ** សេចក្ដីថា អញនឹងទៅស្ថានសួគ៌ ដោយការដែលបញ្ចេញឲ្យទានដល់ពួកសត្វល្អិតជាដើម ដោយបុណ្យ ឬដោយយញ្ញពិធី ។

បទថា **វីជំ ភវិស្សតិ** សេចក្ដីថា នឹងជាពូជដើម្បីទារកដែលជាពន្លកនៃវង្សត្រកូល អធិប្បាយថា រមែងបញ្ចេញដោយបំណងនេះថា កូននឹងកើតដោយពូជរបស់អញនេះ ។

បទថា **វីមំសត្ថាយ** គឺដើម្បីដឹង ។

ក្នុងបទថា **នីលំ ភវិស្សតិ** ជាដើម បណ្ឌិតគប្បីជ្រាបអត្ថយ៉ាងនេះថា អញនឹងដឹងមុនថា សុក្កដែលអញបញ្ចេញហើយ នឹងជាពណ៌ខៀវ ឬពណ៌ឯណាមួយ មានពណ៌លឿងជាដើម ។

បទថា **ឆិន្ទាធិប្បាយោ** គឺខ្វល់ខ្វាយក្នុងការលេង មានពាក្យអធិប្បាយថា ភិក្ខុរមែងបញ្ចេញលេងដោយបំណងនោះៗ ។

## អធិប្បាយ សុទ្ធិកសង្ឃាទិសេស

[ ៦ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងអាការដែលភិក្ខុឲ្យសុក្កឃ្លាតចាកទី ត្រូវអាបត្តិ និងចំនួនប្រភេទអាបត្តិ ដោយអំណាចនៃបទ

ទាំងនោះ ក្នុងព្រះតម្រាស់ដែលត្រាស់ថា **អជ្ឈត្តរូបេ មោចេតិ** ជាដើម ទើបត្រាស់ព្រះតម្រាស់ជាដើមថា ភិក្ខុក្លែង គឺព្យាយាមក្នុងរូបខាងក្នុង សុក្ក ឃ្លាតចាកទី ត្រូវអាបត្តិសង្ឃាទិសេស ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ចេតេតិ** សេចក្ដីថា រមែងតាំងចិត្តថា សុក្កចូរឃ្លាតដោយចេតនាដែលដល់នូវការត្រេកអរ ក្នុងការឲ្យឃ្លាតចាកទី ។

បទថា **ឧបក្កមតិ** សេចក្ដីថា រមែងធ្វើសេចក្ដីព្យាយាមដែលសមគួរដល់ការតាំងចិត្តនោះ ។

បទថា **មុច្ចតិ** សេចក្ដីថា ភិក្ខុក្លែងយ៉ាងនោះ ព្យាយាមដោយសេចក្ដីព្យាយាមដែលសមគួរដល់ការតាំងចិត្តនោះ សុក្ករមែងឃ្លាតចាកឋាន ។

បទថា **អាបត្តិ សង្ឃាទិសេសស្ស** សេចក្ដីថា រមែងត្រូវអាបត្តិឈ្មោះសង្ឃាទិសេសដល់ភិក្ខុនោះ ដោយអង្គ ៣ នេះ ។ សូម្បីក្នុង ២៨ បទដ៏សេស មានបទថា **ពហិទ្ធារូបេ** ជាដើមក៏មានន័យដូច្នេះ ។

ក្នុងបញ្ចកៈទាំង ៤ នេះ បណ្ឌិតគប្បីនាំអាបត្តិ ២០០០ មកសម្ដែង ។ សួរថា សម្ដែងដូចម្ដេច ឆ្លើយថា កាលភិក្ខុបញ្ចេញសុក្កពណ៌ខៀវ ដើម្បីបំណងការមិនមានរោគ ក្នុងវេលាកើតតម្រេកក្នុងរូបខាងក្នុងមុន រមែងត្រូវអាបត្តិ ១ ត្រូវអាបត្តិ ៩ ទៀត ដោយអំណាចបញ្ចេញសុក្កពណ៌លឿងជាដើម ក្នុងរូបខាងក្នុងនោះឯង ដើម្បីបំណងការមិនមានរោគ ក្នុងវេលាមានតម្រេក ដូច្នោះ ទើបសរុប ជាអាបត្តិ ១០ ។ ដើម្បីបំណងការមិនមានរោគមានអាបត្តិ ១០ យ៉ាងណា ដើម្បីបំណង ៩ បទ មាន **សុខ** បទជាដើម

ក៏មានអាបត្តិ ១០ ព្រោះចែកចេញទៅមួយបទៗ ១០ ដូច្នោះ អាបត្តិ ៩០ នេះ និងអាបត្តិ ១០ មុន ដោយប្រការយ៉ាងនេះ ដូច្នោះ ទើបជាអាបត្តិ ១០០ ក្នុងវេលាកើតតម្រេកជាបឋម ។ ក្នុងវេលាកើតតម្រេក មានអាបត្តិ ១០០ យ៉ាងណា សូម្បីក្នុងហេតុឧបត្ថម្ភ ៤ យ៉ាង មានឈើឧច្ចារៈជាដើម ក៏មានអាបត្តិ ៤០០ ព្រោះ ចែកហេតុឧបត្ថម្ភមួយៗ ចេញទៅជា ១០០ៗ ដូច្នោះ ។ អាបត្តិ ៤០០ នេះ និងអាបត្តិ ១០០ ពីមុន ដូចពោលមកនេះ ទើបត្រូវជាអាបត្តិ ៥០០ ដោយ អំណាចនៃហេតុឧបត្ថម្ភ ៥ យ៉ាង ក្នុងរូបខាងក្នុង ។ ក្នុងរូបខាងក្នុង មានអាបត្តិ ៥០០ យ៉ាងណា ក្នុងរូបខាងក្រៅ មានអាបត្តិ ៥០០ ដូចគ្នា ក្នុងរូបទាំងខាងក្នុង និងខាងក្រៅ មានអាបត្តិ ៥០០ កាលភិក្ខុពើងចង្កេះក្នុងអាកាស មានអាបត្តិ ៥០០ ដូច្នោះ បណ្ឌិតគប្បីជ្រាបអាបត្តិទាំងអស់ ២០០០ ដោយអំណាចបញ្ចកៈ ៤ ដោយប្រការដូច្នេះ ។

## អធិប្បាយ ខណ្ឌចក្កា និងពទ្ធចក្កជាដើម

[ ៧-២០ ] ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ព្រះបាលី មានសេចក្តីវិចិត្រទៅដោយប្រភេទនៃខណ្ឌចក្ក និងពទ្ធចក្កជាដើមថា ដើម្បីមិនឲ្យមានរោគ និងដើម្បីសេចក្តីសុខ ដូច្នេះ ដើម្បីសម្តែងថា កាលមានការបញ្ចេញសុក្កឲ្យឃ្លាតចាកទីដោយសេចក្តីព្យាយាម ដោយចិត្តក្លែងរបស់ភិក្ខុដែលចាប់ ( អង្គជាត ) តាមលំដាប់ ឬខុសលំដាប់ ឬខាងក្រោម ក្នុង ១០ បទ មានបទថា **អារោគ្យត្ថាយ** ជាដើម ហើយចាប់ខាងលើក្តី ចាប់ខាងលើ ហើយចាប់ខាងក្រោមក្តី ចាប់ទាំងពីរខាង ហើយឈប់នៅត្រង់កណ្តាលក្តី

ចាប់ត្រង់កណ្តាល ហើយក្តោបទាំងពីរខាងក្តី ចាប់ឲ្យមានមូលរួមគ្នាទាំងអស់ក្តី ឈ្មោះថា ខុសសង្កេត មិនមាន ។

[ ២១ ] ក្នុងព្រះបាលីនោះ ព្រះមានព្រះភាគត្រាស់ខណ្ឌចក្ក ១ ប្រកបដោយ **អារោគ្យ** បទ ដោយគ្រប់ៗ បទ យ៉ាងនេះថា ដើម្បីមិនឲ្យមានរោគ និងដើម្បីសេចក្តីសុខ ដើម្បីមិនឲ្យមានរោគ និងដើម្បីភេសជ្ជៈ ដូច្នេះជាដើម ទ្រង់ប្រកប **សុខ** បទជាដើម ដោយអំណាចគ្រប់ៗបទ រហូតដល់បទដែលជាលំដាប់ដែលកន្លងទៅរៀងៗ ខ្លួន ហើយត្រាស់ ៩ ពទ្ធចក្ក ដោយប្រការដូចពោលមកនេះ ទើបជាចក្កមានមូល ១ ជា ១០ ចក្ក ។ ចក្កទាំងនោះ និងដោយចក្កមានមូល ២ ជាដើម អ្នកសិក្សាគប្បីជ្រាបឲ្យពិស្តារ ដោយការមិនវង្វេង ។ ចំណែកអត្ថក្នុងឯកមូលចក្កនេះ ប្រាកដច្បាស់ហើយនោះឯង ។ ហើយត្រាស់ចក្កទាំងឡាយ ក្នុងសុក្កពណ៌ខៀវជាដើម ដោយន័យជាដើមថា កិក្ខុក្លែងព្យាយាមបញ្ចេញសុក្ក មានពណ៌ខៀវ និងពណ៌លឿង ដូច្នេះ ដូចក្នុង ១០ បទ មានបទថា ដើម្បីជាសះស្បើយរោគជាដើមដូច្នោះ ។ សូម្បីចក្កទាំងនោះ ក៏គួរជ្រាបឲ្យពិស្តារដោយការមិនវង្វេង ។ ចំណែកអត្ថក្នុងចក្កទាំងឡាយនេះ ក៏ប្រាកដច្បាស់ហើយដូចគ្នា ។ ទ្រង់ត្រាស់មិស្សកចក្កម្យ៉ាងទៀត ប្រកបដោយបទក្រោយ និងបទមុខយ៉ាងនេះ គឺបទមួយ និងបទមួយ ២ បទ ជាមួយ ២ បទ ។បេ។ ១០ បទជាមួយ ១០ បទថា **អារោគ្យត្ថញ្ច នីលញ្ច អារោគ្យត្ថញ្ច សុខត្ថញ្ច នីលញ្ច បីតញ្ច** ដូច្នេះជាដើម ។

[ ២៨-៤០ ] ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ចក្កដោយន័យជាដើម ថា ភិក្ខុក្លែងព្យាយាមថា អញនឹងបញ្ចេញសុក្កពណ៌ខៀវ តែសុក្កពណ៌លឿង ឃ្លាតចាកទី ដូច្នេះ ដើម្បីសម្តែងន័យនេះ ព្រោះកាលភិក្ខុក្លែងព្យាយាមថា នឹងបញ្ចេញសុក្កពណ៌ខៀវ កាលសុក្កពណ៌ខៀវជាដើមឃ្លាតចាកទីក្តី ក្លែង ព្យាយាមដោយអំណាចនៃសុក្កពណ៌លឿងជាដើម កាលសុក្កពណ៌លឿង ជាដើម ក្រៅអំពីនេះ ឃ្លាតចាកទីក្តី មិនមានការខុសសង្កេតឡើយ ។ បន្ទាប់ អំពីនោះ ទ្រង់ប្រកបបទក្រោយទាំងអស់ ដោយ ៩ បទមាន **នីល** បទជា ដើម ហើយត្រាស់ឲ្យឈ្មោះថា **កុច្ឆិចក្ក**។ បន្ទាប់អំពីនោះ ទ្រង់ប្រកប ៩ បទ មាន **បីតក** បទជាដើម ចូលដោយនីលបទត្រឹមតែបទមួយ ហើយត្រាស់ ឲ្យឈ្មោះថា **បិដ្ឋិចក្ក**។ បន្ទាប់អំពីនោះ ទ្រង់ប្រកប ៩ បទ មានលោហិតក ជាដើមចូលមួយអន្លើដោយបីតកបទមួយប៉ុណ្ណោះ ហើយត្រាស់ទុតិយបិដ្ឋិចក្ក ។ ទ្រង់ប្រកប ៩ បទៗ ក្រៅអំពីនេះ ជាមួយលោហិតកបទជាដើមយ៉ាងនោះ ហើយត្រាស់ ៨ ចក្កដទៃ ព្រោះដូច្នោះ គប្បីជ្រាបបិដ្ឋិចក្កមានគតិ ១០ យ៉ាង ដោយប្រការដូច្នេះ ។

[ ៤១ ] ព្រះមានព្រះភាគ ទ្រង់សម្តែងគរុកាបត្តិតែម្យ៉ាងដោយពិស្តារ ដោយអំណាចនៃចក្កដ៏ច្រើន មានខណ្ឌចក្កជាដើមយ៉ាងនេះហើយ ដើម្បីទ្រង់ សម្តែងគរុកាបត្តិ លហុកាបត្តិ និងអនាបត្តិ ដោយអំណាចនៃអង្គប៉ុណ្ណោះ ទើបត្រាស់ពាក្យជាដើមថា រមែងក្លែង រមែងព្យាយាម សុក្កឃ្លាតចាកទី ដូច្នេះ ។

បណ្ដាន័យទាំងនោះ ព្រះមានព្រះភាគ ត្រាស់គរុកាបត្តិដល់ព្រមដោយអង្គ ៣ ព្រោះសេចក្ដីព្យាយាមបញ្ចេញអសុចិនៃភិក្ខុអ្នកក្មេង ដើម្បីត្រូវការមិនមានរោគជាដើម ។ ក្នុងវេលាកើតមានតម្រេកជាដើម ក្នុងអជ្ឈត្តរូបជាដើមដោយន័យមុននោះឯង ។ ត្រាស់លហុកាបត្តិ គឺអាបត្តិថុល្លច្ច័យ សម្រេចដោយអង្គ ២ ក្នុងកាលមិនមានការបញ្ចេញនៃភិក្ខុអ្នកក្មេង និងព្យាយាមដោយន័យទី ២ ។ ត្រាស់អនាបត្តិដោយ ៦ ន័យ មានន័យថា មានបំណងមិនព្យាយាម អសុចិឃ្លាតចាកទីដូច្នេះជាដើម ។ ការផ្សេងគ្នានៃអាបត្តិ និងអនាបត្តិនេះ ល្អិតសុខុមពេកណាស់ ព្រោះដូច្នោះ វិនយធរគួរកំណត់ឲ្យល្អ កាលកំណត់បានល្អហើយ ត្រូវសាកសួរដល់សេចក្ដីវង្វៀស គប្បីប្រាប់អាបត្តិ ឬអនាបត្តិ ឬគប្បីធ្វើវិនយកម្ម ។ ពិតហើយ វិនយធរកាលកំណត់មិនបាន ហើយធ្វើ រមែងដល់នូវសេចក្ដីលំបាក និងមិនអាចដោះស្រាយដល់បុគ្គលដូច្នោះបាន ដូចគ្រូពេទ្យមិនដឹងសមុដ្ឋាននៃរោគ ហើយដាក់ថ្នាំ ដូច្នោះ ។

វិធីកំណត់ក្នុងអធិការពោលដោយការផ្សេងគ្នានៃអាបត្តិ និងអនាបត្តិនោះ មានដូចតទៅនេះ ភិក្ខុមកព្រោះសេចក្ដីវង្វៀស ព្រះវិនយធរគប្បីសួរវត្ថុ ៣ ដងថា លោកត្រូវដោយប្រយោគណា ដោយតម្រេកណា ។ បើគ្រាដំបូងលោកពោលតែម្យ៉ាង ហើយគ្រាក្រោយ លោកពោលម្យ៉ាងទៀត មិនពោលដោយគន្លងមួយ គប្បីពោលជាស់តឿនលោកថា លោកមិនពោលតែមួយផ្លូវ ពោលឃ្វៀងឃ្លាតទៅ ខ្ញុំមិនអាចធ្វើវិនយកម្មដល់លោកបានឡើយ ចូរលោកទៅ ស្វែងរកសេចក្ដីសួស្ដីចុះ ។ បើលោកពោលបញ្ជាក់

ដោយគន្ធដមួយប៉ុណ្ណោះ អស់ទៅ ៣ ដង ធ្វើខ្លួនឲ្យជាក់ច្បាស់តាមសេចក្តីពិត លំដាប់នោះ ព្រះវិនយធរគប្បីពិចារណាបយោគ ១១ ដោយអំណាចនៃភាគៈ ១១ យ៉ាង ដើម្បីវិនិច្ឆ័យអាបត្តិ អនាបត្តិ គរុកាបត្តិ និងលហុកាបត្តិរបស់ភិក្ខុនោះ ។

## អធិប្បាយ ភាគៈ និងបយោគ ១១ យ៉ាង

បណ្តាភាគៈ និងបយោគ ១១ នោះ ភាគៈ ១១ គឺការត្រេកអរ ដើម្បីឲ្យឃ្លាតចាកទី ១ ការត្រេកអរក្នុងខណៈឃ្លាតចាកទី ១ ការត្រេកអរក្នុងកាលអសុចិឃ្លាតចាកទីហើយ ១ ការត្រេកអរក្នុងមេថុន ១ ការត្រេកអរក្នុងផស្សៈ ១ ការត្រេកអរក្នុងរមាស់ ១ ការត្រេកអរក្នុងការមើល ១ ការត្រេកអរក្នុងកិរិយាអង្គុយ ១ ត្រេកអរក្នុងវាចា ១ សេចក្តីស្រឡាញ់អាស្រ័យផ្ទះ ១ ការត្រេកអរដោយមែកឈើដែលគប្បីកាច់បាន ១ ។

ក្នុងភាគៈ ១១ យ៉ាងនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា សេចក្តីត្រេកអរដើម្បីឲ្យសុក្កឃ្លាតចាកទី ឈ្មោះថា **មោចនស្សាទ** ។ សេចក្តីត្រេកអរក្នុងខណៈអសុចិឃ្លាតចាកទី ឈ្មោះថា **មុច្ចនស្សាទ** ។ សេចក្តីត្រេកអរក្នុងកាលអសុចិឃ្លាតចាកទីហើយ ឈ្មោះថា **មុត្តស្សាទ**។ សេចក្តីត្រេកអរក្នុងមេថុន ឈ្មោះថា **មេថុនស្សាទ** ។ សេចក្តីត្រេកអរក្នុងផស្សៈ ឈ្មោះថា **ផស្សស្សាទ** ។ សេចក្តីត្រេកអរក្នុងរមាស់ ឈ្មោះថា **កណ្ឌុវនស្សាទ** ។ សេចក្តីត្រេកអរក្នុងមើល ឈ្មោះថា **ទស្សនស្សាទ** ។ សេចក្តីត្រេកអរក្នុងការអង្គុយ ឈ្មោះថា **និសជ្ជស្សាទ**។ សេចក្តីត្រេកអរក្នុងពាក្យសម្តី ឈ្មោះ

ថា **វាចស្សាន** ។ ការស្រឡាញ់អាស្រ័យផ្ទះ ឈ្មោះថា **គេហសិតបេម** ។ វត្ថុវៈឯណាមួយ មានផ្កា និងផ្លែជាដើម ដែលគេកាច់យកមកអំពីព្រៃ ឈ្មោះថា **វនភង្គិយ** ( របស់គាប់ចិត្ត ) ។

បណ្តាបទទាំង ១១ នេះ ព្រះមានព្រះភាគត្រាស់រាគៈ ដោយលើកការត្រេកអរដែលសម្បយុត្តជាប្រធាន ដោយ ៩ បទ ត្រាស់ដោយសរុបតែ ១ បទ ត្រាស់ដោយវត្ថុតែ ១ បទ ។ ពិតហើយ វនភង្គៈ ជាទីតាំងនៃរាគៈ មិនមែនជាតួរាគៈ ។ តែបយោគ ( ក្នុងការបញ្ចេញ ) ព្រះវិនយធរគប្បីជ្រាបដោយអំណាចនៃរាគៈទាំងនេះ ដោយន័យដូចពោលតទៅនេះថា ក្នុងការត្រេកអរដើម្បីឲ្យសុក្កឃ្លាតចាកទី គប្បីជ្រាបវិនិច្ឆ័យថា កាលភិក្ខុមានបំណងនឹងត្រេកអរដោយមោចនស្សាទចេតនា ព្យាយាម អសុចិឃ្លាតចាកទី ត្រូវអាបត្តិសង្ឃាទិសេស កាលភិក្ខុមានបំណង និងត្រេកអរ ដោយចេតនាយ៉ាងនោះដូចគ្នា ព្យាយាម តែអសុចិមិនឃ្លាតចាកទី ត្រូវអាបត្តិថុល្លច្ច័យ តែក្នុងវេលាដេក ភិក្ខុត្រូវរាគៈគ្របសង្កត់ យកភ្លៅឬក្តៀតក្តី ដៃប្រចាប់អង្គជាតឲ្យណែនក្តី ហើយដេកលក់ទៅ ទាំងដែលនៅមានសេចក្តីឧស្សាហ៍ត្រូវការនឹងឲ្យចេញ កាលភិក្ខុនោះដេកលក់ អសុចិឃ្លាតចាកទី ត្រូវអាបត្តិសង្ឃាទិសេស បើលោកញ៉ាំងការគ្របសង្កត់ដោយរាគៈឲ្យស្ងប់ ដោយមនសិការអសុភ មានចិត្តបរិសុទ្ធ ដេកលក់ទៅ សូម្បីអសុចិឃ្លាតចាកទី ខណៈលោកដេកលក់ ក៏ជាអនាបត្តិ ។

ក្នុងការត្រេកអរ ខណៈឃ្លាតចាកទី គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ភិក្ខុ

ត្រេកអរក្នុងអសុចិដែលកំពុងឃ្លាតចាកទី ដោយធម្មតារបស់វា មិនព្យាយាម អសុចិឃ្លាតចាកទី ជាអនាបត្តិ ។ តែកាលភិក្ខុត្រេកអរក្នុងអសុចិដែលកំពុងឃ្លាតចាកទី ព្យាយាម កាលអសុចិឃ្លាតចាកទីហើយ ដោយសេចក្តីព្យាយាមនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងមហាបច្ចរីពោលថា កាលអសុចិឃ្លាតចាកទីដោយធម្មតារបស់វា លោកចាប់អង្គជាតទុក ដោយគិតថា កុំឲ្យប្រឡាក់សំពត់កាសាវៈក្តី សេនាសនៈក្តី ទៅកាន់ទីដែលមានទឹក ដើម្បីជម្រះរមែងគួរ ។

ក្នុងការត្រេកអរ ក្នុងកាលអសុចិឃ្លាតចាកទីហើយ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា កាលអសុចិឃ្លាតចាកទី គឺឃ្លាតចាកឋានដោយធម្មតារបស់វាហើយ កាលភិក្ខុត្រេកអរខាងក្រោយ អសុចិឃ្លាតចាកទីនោះ វៀរចាកការព្យាយាម ជាអនាបត្តិ ។ បើលោកត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការឲ្យឃ្លាតចាកទីទៀត ហើយឲ្យឃ្លាតចាកទី ត្រូវអាបត្តិសង្ឃាទិសេស ។

ការត្រេកអរក្នុងមេថុន គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ភិក្ខុចាប់មាតុគ្រាមដោយតម្រេកក្នុងមេថុន អសុចិឃ្លាតចាកទី ព្រោះប្រយោគនោះ ជាអនាបត្តិ តែការចាប់ពាល់ ( មាតុគ្រាម ) ដូច្នោះ ត្រូវអាបត្តិទុក្កដ ព្រោះជាប្រយោគនៃមេថុនធម្ម កាលដល់ទីបំផុត ត្រូវអាបត្តិបារាជិក ។ បើភិក្ខុត្រេកអរដោយតម្រេកក្នុងមេថុន ត្រឡប់ត្រេកអរ ព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការនឹងបញ្ចេញ ហើយបញ្ចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ គប្បីជ្រាបវិនិច្ឆ័យក្នុងការត្រេកអរក្នុងផស្សៈដូចតទៅនេះថា ផស្សៈមាន ២ យ៉ាង ផស្សៈដែលជា

ខាងក្នុង ១ ផស្សៈដែលជាខាងក្រៅ ១ គប្បីជ្រាបវិនិច្ឆ័យផស្សៈ ដែលជាខាងក្នុងមុន កាលភិក្ខុលេងនិមិត្តរបស់ខ្លួន ដោយគិតថា អញនឹងដឹងថា រឹង ឬទន់ក្តី ដោយការពិសក្តី អសុចិឃាតចាកទី ជាអនាបត្តិ ។ បើលោកលេងដោយត្រេកអរ ព្យាយាមត្រង់និមិត្ត បំណងនឹងឲ្យចេញ ហើយបញ្ចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

ចំណែកក្នុងផស្សៈខាងក្រៅ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា កាលភិក្ខុស្ទាបអង្អែលអវយវៈតូចធំរបស់មាតុគ្រាមក្តី ឱបដោយតម្រេក ក្នុងការប៉ះពាល់កាយ អសុចិឃាតចាកទី ជាអនាបត្តិ ។ តែភិក្ខុត្រូវកាយសំសគ្គសង្ឃាទិសេសឯណោះ ។ បើភិក្ខុត្រេកអរដោយតម្រេកក្នុងការឱបរឹតកាយ ត្រឡប់ជាត្រេកអរ ព្យាយាមក្នុងនិមិត្ត ដើម្បីត្រូវការបញ្ចេញ ហើយបញ្ចេញ ត្រូវអាបត្តិសង្ឃាទិសេស ព្រោះការបញ្ចេញសុក្កជាបច្ច័យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការត្រេកអរ ដោយរមាស់ដូច្នេះថា កាលភិក្ខុអេះនិមិត្តដែលកំពុងរមាស់ ដោយអំណាចនៃរោគស្រែង និងរមាស់ ពងបែក និងសត្វល្អិតរោលជាដើមឯណាមួយ ដោយសេចក្តីត្រេកអរក្នុងរមាស់ប៉ុណ្ណោះ អសុចិឃាតចាកទី ជាអនាបត្តិ ។ ភិក្ខុពេញចិត្តដោយការត្រេកអរក្នុងការរមាស់ ត្រឡប់ជាត្រេកអរ ព្យាយាមក្នុងនិមិត្ត ដើម្បីត្រូវការបញ្ចេញ ហើយបញ្ចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យសេចក្តីត្រេកអរក្នុងការមើល ដូច្នេះថា ភិក្ខុសម្លឹងមើលឱកាសដែលមិនសមគួរ ( អង្គកំណើត ) របស់មាតុគ្រាមរឿយៗ ដោយ

អំណាចការត្រេកអរក្នុងការមើល អសុចិឃ្លាតចាកទី ជាអនាបត្តិ តែត្រូវអាបត្តិទុក្កដ ព្រោះសម្លឹងមើលទីដែលមិនមែនឱកាសសមគួរនៃមាតុគ្រាម ។ បើភិក្ខុពេញចិត្តដោយសេចក្តីត្រេកអរក្នុងការមើល ត្រឡប់ជាត្រេកអរព្យាយាមក្នុងនិមិត្ត ដើម្បីត្រូវការនឹងបញ្ចេញ ហើយញ៉ាំងឲ្យចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យដោយការត្រេកអរ ក្នុងការអង្គុយដូច្នេះថា កាលភិក្ខុអង្គុយដោយតម្រេកក្នុងការអង្គុយ ក្នុងទីស្ងាត់ជាមួយមាតុគ្រាម អសុចិឃ្លាតចាកទី ជាអនាបត្តិ តែវិនយធរគប្បីកាត់អាបត្តិលោក ដោយអាបត្តិដែលត្រូវព្រោះការអង្គុយក្នុងទីកំបាំងជាបច្ច័យ ។ បើភិក្ខុមានតម្រេកដោយការត្រេកអរក្នុងការអង្គុយ ហើយត្រឡប់ត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការបញ្ចេញ ហើយចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការត្រេកអរ ដោយពាក្យសម្តីដូច្នេះថា ភិក្ខុនិយាយទាក់ទងជាមួយមាតុគ្រាមដោយពាក្យសម្តី អាស្រ័យមេថុន ដោយតម្រេកក្នុងពាក្យសម្តី អសុចិឃ្លាតចាកទី ជាអនាបត្តិ តែភិក្ខុនោះ ត្រូវសង្ឃាទិសេស ព្រោះទុដ្ឋុល្លវាចា ។ បើភិក្ខុមានតម្រេកដោយសេចក្តីត្រេកអរ ក្នុងពាក្យសម្តីហើយ ត្រឡប់ត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការឲ្យចេញ ហើយចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការស្រឡាញ់អាស្រ័យផ្ទះ ដូច្នេះថា កាលភិក្ខុស្ទាបអង្អែល និងឱបរឹតរឿយៗ នូវមាតា ដោយសេចក្តីស្រឡាញ់ ថាជា

មាតាក្តី នូវបងស្រី ប្អូនស្រី ដោយសេចក្តីស្រឡាញ់ ថាជាបងស្រី ប្អូនស្រីក្តី អសុចិឃ្លាតចាកទី ជាអនាបត្តិ តែត្រូវអាបត្តិទុក្កដ ព្រោះពាល់ត្រូវដោយសេចក្តីស្រឡាញ់អាស្រ័យផ្ទះជាបច្ច័យ ។ បើភិក្ខុមានតម្រេកដោយសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ហើយត្រឡប់ត្រេកអរ ព្យាយាមត្រង់និមិត្ត ដើម្បីត្រូវការឲ្យចេញ ហើយចេញ ត្រូវអាបត្តិសង្ឃាទិសេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវនភង្គៈ ( របស់កំណាន់ ) ដូច្នេះថា ស្រី និងប្រុស រមែងបញ្ជូនបណ្ណាការ ( របស់កំណាន់ ) មានប្រភេទ គឺស្លា ម្លូ ផ្កា និងគ្រឿងអប់ក្លិនជាដើមណាមួយ ទៅឲ្យគ្នានិងគ្នា ដើម្បីត្រូវការសន្ធវមេត្រីដែលមាំទាំ នេះឈ្មោះថា **វនភង្គៈ** ។ បើមាតុគ្រាមបញ្ជូនរបស់កំណាន់ដូច្នោះទៅឲ្យដល់ភិក្ខុដែលចូលកាន់ត្រកូល ដែលជិតស្និទ្ធស្នាលរូបខ្លះ កាលភិក្ខុមានតម្រេកខ្លាំង គិតថា របស់នេះ ស្ត្រីឈ្មោះនោះបញ្ជូនមកឲ្យ ដូច្នេះហើយ យកដៃស្ទាបអង្អែលរបស់កំណាន់លេងរឿយៗ អសុចិឃ្លាតចាកទី ជាអនាបត្តិ ។ បើភិក្ខុមានតម្រេកខ្លាំងក្នុងវនភង្គៈ ហើយត្រឡប់ត្រេកអរព្យាយាមត្រង់និមិត្ត ដើម្បីបំណងឲ្យចេញ ហើយចេញ ត្រូវអាបត្តិសង្ឃាទិសេស ។ សូម្បីកាលភិក្ខុព្យាយាម តែអសុចិមិនឃ្លាតចាកទី ត្រូវអាបត្តិថុល្លច្ច័យ ។

ព្រះវិនយធរគប្បីពិចារណាប្រយោគ ១១ នេះ ដោយអំណាចនៃវគ្គៈ ១១ នេះហើយ កំណត់អាបត្តិក្តី អនាបត្តិក្តី ដោយប្រការយ៉ាងនេះ កាលកំណត់ល្អហើយ បើជាគរុកាបត្តិ គប្បីប្រាប់ថា ជាគរុកាបត្តិ បើជាលហុកាបត្តិ គប្បីប្រាប់ថា ជាលហុកាបត្តិ ហើយគប្បីធ្វើវិនយកម្មឲ្យសមគួរដល់

អាបត្តិនោះ ។ ពិតហើយ វិនយកម្មដែលធ្វើហើយយ៉ាងនេះ ឈ្មោះថា ជាកម្មដែលធ្វើល្អហើយ ដូចគ្រូពេទ្យដឹងសមុដ្ឋាននៃរោគ ហើយដាក់ថ្នាំ ដូច្នេះ និងរមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសុខដល់បុគ្គលរូបនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ចេតេតិ ន ឧបក្កមតិ** ជាដើមដូច្នេះថា ភិក្ខុបំណងដោយចេតនាត្រេកអរនឹងបញ្ចេញ តែមិនព្យាយាម អសុចិឃ្លាតចាកទី មិនត្រូវអាបត្តិ ។ ភិក្ខុត្រូវសេចក្ដីត្រេកអរក្នុងការបញ្ចេញគ្របសង្កត់ ហើយ បំណងថា ធ្វើដូចម្ដេចហ្ន៎ អសុចិគប្បីឃ្លាតចាកទី តែមិនព្យាយាម អសុចិមិនឃ្លាតចាកទី មិនត្រូវអាបត្តិ ។ ភិក្ខុមិនបំណងដោយសេចក្ដីត្រេកអរក្នុងការបញ្ចេញ ព្យាយាមដោយសេចក្ដីត្រេកអរក្នុងផស្សៈក្ដី ដោយការត្រេកអរក្នុងការរមាស់ក្ដី អសុចិឃ្លាតចាកទី មិនត្រូវអាបត្តិ ។ ភិក្ខុមិនបំណងយ៉ាងនោះដូចគ្នា តែព្យាយាម អសុចិមិនឃ្លាត មិនត្រូវអាបត្តិ ។ ភិក្ខុកាលត្រិះរិះដល់កាមវិតក្ក មិនមានបំណង មិនព្យាយាមដើម្បីត្រូវការបញ្ចេញ តែអសុចិឃ្លាតចាកទី មិនត្រូវអាបត្តិ ។ បើភិក្ខុនោះ ត្រិះរិះដល់កាមវិតក្ក អសុចិមិនឃ្លាតចាកទី ពាក្យនេះ ជាពាក្យដែលនាំមកអាងក្នុងអដ្ឋកថា បុរាណថា ភិក្ខុមិនបំណង មិនព្យាយាម អសុចិមិនឃ្លាតចាកទី មិនត្រូវអាបត្តិដូច្នេះ ។

[ ៤២ ] បទថា **អនាបត្តិ សុបិនន្តេន** សេចក្ដីថា កាលភិក្ខុដេកលក់ ហើយយល់សប្តិសេពមេថុនធម្មក្ដី យល់សប្តិស្ទាបអង្អែលកាយ ( មាតុគ្រាម ) ជាដើមក្ដី មិនជាអាបត្តិដល់ភិក្ខុដែលមានអសុចិឃ្លាតចាកទី ព្រោះ

ហេតុក្នុងការយល់សប្តិនោះឡើយ ។ តែកាលចេតនាត្រេកអរកើតឡើងក្នុងការយល់សប្តិ បើជាវិស័យរបស់លោក កុំគប្បីកម្រើក មិនគប្បីយកដៃចាប់និមិត្តលេង តែដើម្បីនឹងរក្សាសំពត់កាសាវៈ និងសំពត់ដែលក្រាលដេក ទោះយកដៃចាប់ទៅកាន់ទីមានទឹក ដើម្បីសម្អាត គួរ ។

បទថា **ឆមោចនាធិប្បាយស្ស** សេចក្តីថា កាលភិក្ខុណាលាបនិមិត្តដោយកេសជ្ជៈក្តី ធ្វើការបន្ទោបង់ឧច្ចារៈជាដើមក្តី មិនមានបំណងក្នុងការឲ្យឃ្លាតចាកទី អសុចិឃ្លាតចាកទី មិនជាអាបត្តិដល់ភិក្ខុនោះ ។ មិនជាអាបត្តិសូម្បីដល់ភិក្ខុឆ្កួតទាំងពីរពួក ។ ក្នុងសិក្ខាបទនេះ សេយ្យសកភិក្ខុជាខាងដើមបញ្ញត្តិ មិនត្រូវអាបត្តិដល់សេយ្យសកភិក្ខុ ដែលជាខាងដើមបញ្ញត្តិនោះដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសមុដ្ឋានជាដើម ដូច្នេះថា សិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ រមែងតាំងឡើងតាមកាយ និងចិត្ត ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាអកុសលចិត្ត មានវេទនា ២ ដោយជាសុខវេទនា និងឧបេក្ខាវេទនាទាំងពីរនោះឯង ។

បទភាជនីយ៍នៃសុក្កវិសដ្ឋិសិក្ខាបទ ចប់

# អធិប្បាយ
## វិធីតវត្ថុក្នុងសុក្កវិសដ្ឋិសិក្ខាបទ

[ ៤៤-៤៦ ] បណ្តាវិនីតវត្ថុទាំងឡាយ រឿងភិក្ខុយល់សប្តិ មានន័យដូចព្រះដ៏មានព្រះភាគត្រាស់ហើយ ក្នុងអនុប្បញ្ញត្តិនោះឯង ។ រឿងបន្ទោបង់ឧច្ចារៈ បស្សាវៈច្រើនរឿង មានអត្ថជាក់ច្បាស់ទាំងអស់ហើយ ។

[ ៤៧ ] ក្នុងរឿងភិក្ខុត្រិះរិះចំពោះកាមវិតក្ក បទថា **កាមវិតក្កំ** បានដល់ការត្រិះរិះដល់កាមដែលអាស្រ័យផ្ទះ ។ ក្នុងរឿងកាមវិតក្កនោះ ទ្រង់ត្រាស់អនាបត្តិទុកដោយពិត សូម្បីដូច្នោះ ភិក្ខុមិនគួរធ្លាក់នៅក្នុងអំណាចនៃវិតក្ក ។

[ ៤៨ ] រឿងភិក្ខុងូតទឹកក្តៅទី ១ ងាយហើយនោះឯង ។ ក្នុងរឿងភិក្ខុងូតទឹកក្តៅទី ២ ភិក្ខុនោះប្រាថ្នាដើម្បីនឹងបញ្ចេញ យកទឹកក្តៅស្រោចហើយស្រោចទៀតត្រង់និមិត្ត ហើយងូតទឹក ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគកាត់អាបត្តិដល់ភិក្ខុនោះ ។ ក្នុងរឿងភិក្ខុងូតទឹកក្តៅទី ៣ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះមានការព្យាយាម ។

[ ៤៩-៥០ ] រឿងភិក្ខុលាបថ្នាំ និងរឿងភិក្ខុអេះរមាស់ត្រង់ពងល្វាមានអត្ថជាក់ច្បាស់ទាំងអស់ហើយ ។

[ ៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គវត្ថុច្រើនរឿង ដូច្នេះថា កាលភិក្ខុទី ១ មានក្ដៅជំកំពុងដើរផ្លូវ អសុចិបានឃ្លាតចាកទី ព្រោះការប៉ះពាល់ក្នុងទីចន្លោះ មិនត្រូវអាបត្តិដល់ភិក្ខុនោះ ព្រោះមិនមានបំណងក្នុងការឲ្យឃ្លាតចាកទី ។ សម្រាប់ភិក្ខុអង្គទី ២ អសុចិបានឃ្លាតចាកទីដូច្នោះដូចគ្នា តែត្រូវអាបត្តិសង្ឃាទិសេស ព្រោះមានបំណងក្នុងការឲ្យឃ្លាតចាកទី ។ ភិក្ខុអង្គទី

៣ អសុចិមិនឃ្លាតចាកទី តែត្រូវអាបត្តិថុល្លច្ច័យ ព្រោះមានសេចក្តីព្យាយាម ។ ព្រោះហេតុនោះ ភិក្ខុកំពុងដើរផ្លូវ កាលរាគៈកើតឡើង មិនគួរធ្វើដំណើរ គប្បីឈប់ដើរ ញុំាងចិត្តឲ្យស្ងប់ដោយមនសិការក្នុងអសុភជាដើម កំណត់កម្មដ្ឋានដោយចិត្តបរិសុទ្ធ ហើយសឹមដើរតទៅ បើឈប់ឈរហើយ មិនអាចបន្ទោបង់បាន គប្បីចៀសចេញអំពីផ្លូវ អង្គុយបន្ទោបង់ហើយ ដើរកំណត់កម្មដ្ឋានដោយចិត្តបរិសុទ្ធនោះឯង ។

[ ៥២ ] ក្នុងរឿងស្បែកជងបង្ហូរច្រើនរឿង ពួកភិក្ខុទាំងនោះ ចាប់ចុងអង្គជាតឲ្យណែន បញ្ចេញទឹកនោមឲ្យពេញ ហើយទើបលែង ដូចពួកក្មេងអ្នកស្រុក ។

[ ៥៣ ] ក្នុងរឿងភិក្ខុកម្តៅជំបារពោះ មានបំណងនឹងឲ្យឃ្លាតចាកទីក្តី មិនមានបំណងឲ្យឃ្លាតចាកទីក្តី កាលអសុចិឃ្លាតចាកទីហើយ ជាអនាបត្តិដូចគ្នា ។

[ ៥៤ ] រឿងភិក្ខុប្រាប់ខ្នងឲ្យឧបជ្ឈាយ៍ អសុចិឃ្លាតចាកទីដោយអំណាចនៃការញុំាងនិមិត្តឲ្យកម្រើក ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគកាត់អាបត្តិក្នុងឋានៈនៃអាបត្តិ ។

[ ៥៥ ] ក្នុងរឿងបៀតបៀនដោយភ្លៅច្រើនរឿង លោកពោលទុកក្នុងកុរុន្ទីអដ្ឋកថាយ៉ាងនេះថា ព្រះដ៏មានព្រះភាគកាត់អាបត្តិដល់ភិក្ខុពួកណា ភិក្ខុទាំងនោះ បណ្ឌិតគប្បីជ្រាបថា ច្រៀតបៀតដោយជុំវិញអង្គជាត ឲ្យពាល់ត្រូវអង្គជាតនោះហើយ ។

[ ៥៦-៦០ ] រឿងភិក្ខុឲ្យសាមណេរកាន់អង្គជាតជាដើម មានអត្ថជាក់ច្បាស់ទាំងអស់ហើយ ។

[ ៦១ ] ក្នុងរឿងមីតពត់កាយ ពាក្យថា **កាយំ ថម្ភេន្តស្ស** សេចក្តីថា កាលភិក្ខុអង្គុយយូរ ឬដេកយូរក្តី ធ្វើនវកម្មក្តី ហើយពត់កាយ ដើម្បីបន្ទូរការចុករួយ ។

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងរឿងភិក្ខុសម្លឹងមើលអង្គជាតមាតុគ្រាម ដូច្នេះថា សូម្បីស្រីនោះស្លៀកសំពត់រាប់រយជាន់ ភិក្ខុឈរខាងមុខក្តី ឈរខាងក្រោយក្តី សម្លឹងមើលថា និមិត្តនៅក្នុងឱកាសឈ្មោះនេះ ត្រូវអាបត្តិទុក្កដ ។ កាលសម្លឹងមើលនិមិត្តនៃពួកក្មេងស្រីអ្នកស្រុក ដែលមិនស្លៀកសំពត់ នឹងចាំបាច់ពោលទៅថ្វី សូម្បីក្នុងនិមិត្តនៃសត្វតិរច្ឆាន ក៏មានន័យដូចគ្នានេះ ។ តែកាលភិក្ខុមិនក្រឡេកទៅខាងនោះ ទៅខាងនេះ សម្លឹងមើលដោយប្រយោគមួយ សូម្បីអស់មួយថ្ងៃ ក៏ត្រូវអាបត្តិទុក្កដមួយប៉ុណ្ណោះ ។ កាលក្រឡេកមើលខាងនោះ និងខាងនេះ សម្លឹងមើលម្តងហើយម្តងទៀត ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ។ ព្រះវិនយធរមិនគប្បីកាត់អាបត្តិ ដោយអំណាចការបើកភ្នែក និងការបិទភ្នែក ( ប៉ប្រិចភ្នែក ) ។ កាលសម្លឹងមើលដោយចៃដន្យ ត្រឡប់ពិចារណាហើយ តាំងនៅក្នុងសំវរៈវិញ ជាអនាបត្តិ កាលលះសំវរៈនោះហើយ សម្លឹងមើលទៀត ត្រូវអាបត្តិទុក្កដនោះឯង ។

[ ៦៣-៦៤ ] រឿងភិក្ខុបញ្ចូលអង្គជាតក្នុងប្រហោងដានជាដើម មានអត្ថជាក់ច្បាស់ទាំងអស់ហើយ ។

[ ៦៥-៦៧ ] ក្នុងរឿងភិក្ខុដូតទឹកច្រើនរឿង ព្រះដ៏មានព្រះភាគ កាត់អាបត្តិដល់ពួកភិក្ខុដែលយកនិមិត្តរុញក្រសែទឹក ។ សូម្បីរឿងកក់ល្បាប់ច្រើន ក៏មានន័យដូចគ្នា ។ ក្នុងរឿងកក់ល្បាប់នេះ កក់ល្បាប់ លោកហៅថា **ឧទញ្ជល** ។ រឿងដទៃក្រៅអំពីនេះទាំងអស់ មានរឿងភិក្ខុស្ទុះទៅក្នុងទឹកជាដើម បណ្ឌិតគប្បីជ្រាបដោយឧបាយនេះដូចគ្នា ។

[ ៦៨ ] ចំណែកសេចក្ដីប្លែកគ្នាក្នុងរឿងភិក្ខុលេងកងផ្ញើអំពីផ្កា ដូចតទៅនេះថា សូម្បីមិនត្រូវអាបត្តិដល់ភិក្ខុដែលមិនមានបំណងក្នុងការឲ្យឃ្លាតចាកទី ។ តែសូម្បីដូច្នោះ ក៏ត្រូវអាបត្តិទុក្កដ ព្រោះការលេងជាបច្ច័យដូច្នេះឯង ។

សុក្កវិសដ្ឋិសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ២

[ ៧៥ ] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុ សម្រេចឥរិយាបថនៅក្នុងព្រៃ ។ លំនៅឧទាយិភិក្ខុដ៏មានអាយុនោះ ល្អគួរឲ្យចង់មើល គួរឲ្យជ្រះថ្លា មានបន្ទប់ខាងក្នុង មានរបៀងជុំវិញ គ្រែ តាំង ពូក ខ្នើយក៏រៀបចំល្អ ទឹកសម្រាប់ឆាន់និងទឹកសម្រាប់ប្រើប្រាស់ ក៏តម្កល់ទុកស្រួល ទាំងទីបរិវេណសោត ក៏បោសរលីងស្អាត ។ មានមនុស្សជាច្រើននាក់ ដែលត្រូវការមើលលំនៅរបស់ឧទាយិភិក្ខុដ៏មានអាយុ ក៏តែងតែមកមើល ។ ( កាលនោះ ) មានព្រាហ្មណ៍ម្នាក់ នាំប្រពន្ធចូលទៅរកឧទាយិភិក្ខុដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងឧទាយិភិក្ខុដ៏មានអាយុថា យើងខ្ញុំចង់មើលលំនៅរបស់លោកម្ចាស់ឧទាយិ ។ ឧទាយិក៏និយាយតបថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរមើលចុះ ( ថាហើយ ) ក៏កាន់កូនសោដកគន្លឹះហើយប្រានសន្ទះទ្វារ ចូលទៅកាន់កុដិលំនៅ ។ ឯព្រាហ្មណ៍នោះឯងក៏ដើរចូលទៅតាមក្រោយឧទាយិដ៏មានអាយុទៅ ។ ចំណែកខាងនាងព្រាហ្មណីនោះឯង ក៏ដើរចូលតាមក្រោយព្រាហ្មណ៍នោះទៅ ។ គ្រានោះឯង ឧទាយិដ៏មានអាយុ ក៏បើកបង្អួចកន្លែងខ្លះ បិទបង្អួចកន្លែងខ្លះ ដើរក្រឡឹងតាមបន្ទប់ហើយមកពីក្រោយខ្នងហើយ ក៏ស្ទាបអង្អែលអវយវៈតូចធំនៃនាងព្រាហ្មណីនោះ ។ គ្រានោះឯង ព្រាហ្មណ៍នោះនិយាយរួសរាយជាមួយនឹងឧទាយិដ៏មាន

អាយុហើយក៏លាទៅ ។ លំដាប់តមក ព្រាហ្មណ៍នោះពេញចិត្ត ក៏បញ្ចេញវាចាតាមសេចក្តីពេញចិត្តថា ពួកសមណៈដែលនៅក្នុងព្រៃមានសភាពយ៉ាងនេះសុទ្ធសឹងតែពួកសមណៈ ជាកូនចៅព្រះពុទ្ធ ជាសក្យបុត្ត ថ្កុំថ្កើងណាស់ លោកឧទាយិដែលនៅក្នុងព្រៃមានសភាពយ៉ាងនេះ លោកឧទាយិដ៏ចម្រើននុ៎ះ ក៏ថ្កុំថ្កើងដែរ ។ កាលបើព្រាហ្មណ៍ពោលពាក្យសរសើរយ៉ាងនេះហើយ នាងព្រាហ្មណីនោះបានពោលពាក្យនេះនឹងព្រាហ្មណ៍នោះថា សេចក្តីថ្កុំថ្កើងរបស់លោកឧទាយិនោះមានពីណា ( ឥតមានថ្កុំថ្កើងអ្វីទេ ) ខ្ញុំនអ្នកស្ទាបអង្អែលអវយវៈតូចធំរបស់ខ្ញុំយ៉ាងណា សមណៈឈ្មោះឧទាយិ ក៏ស្ទាបអង្អែលអវយវៈតូចធំរបស់ខ្ញុំយ៉ាងនោះដែរ ។ គ្រានោះឯង ព្រាហ្មណ៍នោះក៏និយាយពោលទោសជៀលត្មះថា សមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្តពួកនេះ មិនមានខ្មាស ជាមនុស្សទ្រុស្តសីល តែងពោលពាក្យមុសា ព្រោះសមណៈអម្បាលនេះ ប្តេជ្ញាខ្លួនថា យើងសុទ្ធតែជាអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ប្រព្រឹត្តព្រហ្មចារ្យ ពោលតែពាក្យសត្យ ជាអ្នកមានសីល មានធម៌ល្អ ( ឥឡូវនេះ ) សាមញ្ញគុណរបស់សមណៈពួកនេះមិនមានទេ ព្រហ្មញ្ញគុណរបស់សមណៈពួកនេះមិនមានទេ សាមញ្ញគុណរបស់សមណៈពួកនេះវិនាសហើយ ព្រហ្មញ្ញគុណរបស់សមណៈពួកនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណៈពួកនេះមានពីណា ព្រហ្មញ្ញគុណរបស់សមណៈពួកនេះមានពីណា សមណៈពួកនេះឃ្លាតផុតចាកសាមញ្ញគុណអស់ហើយ សមណៈពួកនេះឃ្លាតផុតចាកព្រហ្មញ្ញគុណអស់ហើយ ដូចយ៉ាងសមណៈឈ្មោះឧទាយិ ហ៊ានស្ទាបអង្អែល

អវយវៈតូចធំរបស់កិរិយាអញទៅហើយ ពួកស្ត្រីក្នុងត្រកូល ធីតារបស់ត្រកូល កុមារីរបស់ត្រកូល ស្ត្រីជាកូនប្រសារបស់ត្រកូល ទាសីរបស់ត្រកូលទាំង-ឡាយ ម្តេចនឹងហ៊ានទៅកាន់អារាម ឬវិហារបាន ព្រោះថា បើពួកស្ត្រីក្នុងត្រកូល ធីតារបស់ត្រកូល កុមារីរបស់ត្រកូល ស្ត្រីជាកូនប្រសារបស់ត្រកូល ទាសីរបស់ត្រកូលទាំងឡាយ ខំទៅកាន់អារាម ឬវិហារ មុខជាសមណៈទាំងឡាយជាកូនចៅព្រះពុទ្ធ ជាសក្យបុត្ត នឹងប្រទូស្តចំពោះស្ត្រីទាំងអម្បាលនោះមិនខាន ។ ភិក្ខុទាំងឡាយ ក៏បានឮពាក្យដែលព្រាហ្មណ៍ពោលទោសដៀលត្មះ និយាយដើម ( នោះ ) ។ ភិក្ខុទាំងឡាយឯណា ដែលមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីអៀនខ្មាសក្រែងរអែងបាបពេញចិត្តនឹងការសិក្សា ភិក្ខុអម្បាលនោះ ក៏ពោលទោសត្មះតិះដៀលថា ភិក្ខុឈ្មោះឧទាយិដ៏មានអាយុ មិនសមបីបើនឹងហ៊ានដល់ស្ទាបអង្អែលកាយមាតុគ្រាមសោះ ។ ទើបភិក្ខុអម្បាលនោះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះហេតុដំណើរនេះ ទើបព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃហើយ ត្រាស់សួរចំពោះឧទាយិដ៏មានអាយុថា ម្នាលឧទាយិ ឮថា អ្នកឯងស្ទាបអង្អែលកាយមាតុគ្រាមមែនឬ ។ ឧទាយិក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ( ដំណើរនុ៎ះ ) ពិតមែន ។ ព្រះពុទ្ធដ៏មានជោគទ្រង់ត្មះតិះដៀលថា ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើ មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនជារបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ នៃមោឃបុរស មិនគួរបើអ្នកឯងនឹងហ៊ានដល់ស្ទាបអង្អែលកាយមាតុគ្រាមសោះ នៃមោឃ-

បុរស ធម៌ដែលតថាគតសម្ដែងហើយដោយបរិយាយដ៏ច្រើន ( សុទ្ធតែ ) ដើម្បីប្រាសចាកតម្រេក មិនមែនដើម្បីប្រកបដោយតម្រេកឡើយ មិនមែនឬ ។បេ។ ដំណើរស្ងប់រម្ងាប់នៃសេចក្ដីក្ដៅក្រហាយព្រោះកាមទាំងឡាយ តថាគតក៏បានសម្ដែងហើយ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ក៏អ្នកទាំងឡាយត្រូវសម្ដែងសិក្ខាបទនេះឡើងយ៉ាងនេះថា ភិក្ខុណាមួយ គឺកាមរាគៈគ្របសង្កត់ហើយ មានចិត្តប្រែប្រួលហើយ ដល់ព្រមនូវកាយ-សំសគ្គ មួយអន្លើដោយមាតុគ្រាម ទោះចាប់ដៃក្ដី ចាប់ផ្នួងសក់ក្ដី ឬស្ទាបអង្អែលអវយវៈត្រង់ណាៗ ក្ដី ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ៧៦ ] ត្រង់ពាក្យថា ណាមួយ សេចក្ដីថា ឯណា គឺថា ដូចជាឯណា ។បេ។ ត្រង់ពាក្យថា ភិក្ខុ ។បេ។ ភិក្ខុដែលបានសម្រេចឧបសម្បទា ដោយញត្តិចតុត្ថកម្មវាចាដ៏ត្រឹមត្រូវ តថាគតសំដៅយកឲ្យឈ្មោះថា ភិក្ខុក្នុងអត្ថនេះ ។ ភិក្ខុដែលត្រេកអរ មានសេចក្ដីអាឡោះអាល័យ មានចិត្តប្រតិព័ទ្ធ ហៅថា ( ភិក្ខុ ) គឺកាមរាគៈគ្របសង្កត់ហើយ ។ ត្រង់ពាក្យថា ប្រែប្រួលហើយ សេចក្ដីថា ចិត្តដែលត្រេកអរក៏ហៅថា ប្រែប្រួលហើយ ចិត្តដែលខឹងក៏ហៅថា ប្រែប្រួលហើយ ចិត្តដែលវង្វេង ក៏ហៅថា ប្រែប្រួលហើយ ប៉ុន្តែក្នុងអត្ថនេះ តថាគតសំដៅយកចិត្តដែលត្រេកអរ ឲ្យឈ្មោះថា ចិត្តប្រែប្រួលហើយ ។ មនុស្សស្រី ហៅថា មាតុគ្រាម ឯយក្សស្រី ប្រេតស្រី សត្វតិរច្ឆានញី មិនហៅថា មាតុគ្រាមទេ ( ក្នុងសិក្ខាបទនេះ ) ដោយហោចទៅ

ទោះក្មេងស្រីសូម្បីកើតក្នុងថ្ងៃនោះ ក៏ហៅថា មាតុគ្រាមដែរ មិនចាំបាច់ពោលដល់ស្ត្រីដែលធំ ជាងនោះទេ ។ ត្រង់ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ សេចក្តីប្រព្រឹត្តល្មើស តថាគតហៅថា គប្បីដល់ព្រមដោយកាយសំសគ្គ ។ សរីរប្រទេស រាប់តាំងពីត្រឹមជុំដៃរហូតដល់ចុងក្រចក ហៅថា ដៃ ។ សក់សុទ្ធក្តី សក់លាយដោយអំបោះក្តី លាយដោយផ្កាកម្រងក្តី លាយដោយប្រាក់ក្តី លាយដោយមាសក្តី លាយដោយកែវមុក្តាក្តី លាយដោយកែវមណីក្តី ហៅថា ផ្នួងសក់ ។ ត្រង់ពាក្យថា អវយវៈ ( នោះ ) គឺសរីរៈដ៏សេស លើកលែងតែដៃ និងផ្នួងសក់ចេញ ហៅថា អវយវៈ ។

[ ៧៧ ] ( ប្រភេទ ១២ យ៉ាង ) គឺកិរិយាស្ទាប អង្អែល ស្ទាបចុះ ស្ទាបឡើង ផ្ទុបចុះ ផ្ងើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្ងេច កាន់ ពាល់ ។

[ ៧៨ ] កិរិយាគ្រាន់តែលូកពាល់ ហៅថា ស្ទាប ។ កិរិយាស្ទាបបន្តិរពីខាងនេះខាងនោះ ហៅថា អង្អែល ។ កិរិយាពាល់ចុះក្រោម ហៅថា ស្ទាបចុះ ។ កិរិយាពាល់ខាងលើ ហៅថា ស្ទាបឡើង ។ កិរិយាចាប់បន្ទន់ទៅក្រោម ហៅថា ផ្ទុបចុះ ។ កិរិយាចាប់ផ្ងារទៅខាងលើ ហៅថា ផ្ងើយឡើង ។ កិរិយាទាញចូលមក ហៅថា ទាញមក ។ កិរិយាបង្អែនត្រឡប់ ( ទាញពីក្រោយ ) ហៅថា ទាញត្រឡប់ ។ កិរិយាចាប់អវយវៈហើយច្របាច់ឈ្ងេច ហៅថា ចាប់សង្កត់ ។ កិរិយាត្បៀត គាប ដោយអវយវៈណាទីមួយ ហៅថា ចាប់ឈ្ងេច ។ កិរិយាគ្រាន់តែចាប់ ហៅថា កាន់ ។ កិរិយាប៉ះត្រូវ

ហៅថា ពាល់ ។

[ ៧៩ ] ត្រង់ពាក្យថា សង្ឃាទិសេស ( សេចក្តីក្នុងបេយ្យាលមានអធិប្បាយក្នុងសង្ឃាទិសេសទី ១ រួចហើយ ) ។

[ ៨០ ] មនុស្សស្រីពិត ភិក្ខុសម្គាល់ថាជាស្រី មានសេចក្តីត្រេកអរ ក៏យកកាយ ( ខ្លួន ) ស្ទាប អង្អែល ស្ទាបចុះ ស្ទាបឡើង ផ្ទុបចុះ ផ្ងើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្ងោច កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ មនុស្សស្រីពិត តែភិក្ខុមានសេចក្តីសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ មនុស្សស្រីពិត ភិក្ខុសម្គាល់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ មនុស្សស្រីពិត តែភិក្ខុសម្គាល់ថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ មនុស្សស្រីពិត តែភិក្ខុសម្គាល់ថាជាសត្វតិរច្ឆាន ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ មនុស្សខ្ទើយពិត ភិក្ខុក៏សម្គាល់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយមនុស្សខ្ទើយនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ មនុស្សខ្ទើយពិត តែភិក្ខុសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយមនុស្សខ្ទើយនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សខ្ទើយពិត តែភិក្ខុសម្គាល់ថា ប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយ

មនុស្សស្រីឃើញនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សស្រីឃើញពិត តែភិក្ខុសម្គាល់ថា សត្វតិរច្ឆាន ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយមនុស្សស្រីឃើញនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សស្រីឃើញពិត តែភិក្ខុសម្គាល់ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយមនុស្សឃើញនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សប្រុសពិត ភិក្ខុសម្គាល់ថា ប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សប្រុសពិត តែភិក្ខុសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សប្រុសពិត តែភិក្ខុសម្គាល់ថាសត្វតិរច្ឆាន ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សប្រុសពិត តែភិក្ខុសម្គាល់ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ ។ មនុស្សប្រុសពិត តែភិក្ខុសម្គាល់ថា ខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយប្រុសនោះ ត្រូវអាបត្តិទុក្កដ ។ សត្វតិរច្ឆានឈ្មោលពិត ភិក្ខុសម្គាល់ថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ ។ សត្វតិរច្ឆានឈ្មោលពិត តែភិក្ខុសង្ស័យ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយសត្វតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ ។ សត្វតិរច្ឆានឈ្មោលពិត តែភិក្ខុសម្គាល់ថាមនុស្សស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់

កាយសត្វតិរច្ឆានឈ្មោលនោះ ត្រូវអាបត្តិទុក្កដ ។ សត្វតិរច្ឆានឈ្មោលពិត តែភិក្ខុសម្គាល់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយសត្វតិរច្ឆានឈ្មោលនោះ ត្រូវអាបត្តិទុក្កដ ។ សត្វតិរច្ឆានឈ្មោល ពិត តែភិក្ខុសម្គាល់ថា មនុស្សប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយសត្វតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ ។

[ ៨១ ] ស្រីពីរនាក់ ភិក្ខុសម្គាល់ថាស្រីទាំងពីរនាក់ ត្រេកអរ ក៏យក កាយស្ទាបអង្អែល ។បេ។ កាន់ ពាល់កាយស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិ សង្ឃាទិសេសពីរ ។ ស្រីពីរនាក់ ភិក្ខុសង្ស័យនឹងស្រីពីរនាក់ ត្រេកអរ ក៏ យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយស្រីទាំងពីរនាក់នោះ ត្រូវ អាបត្តិថុល្លច្ច័យពីរ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាខ្ទើយ ។បេ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាប្រុស ។បេ។ ស្រីពីរ នាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យក កាយ ស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយស្រីទាំងពីរនាក់នោះ ត្រូវ អាបត្តិថុល្លច្ច័យពីរ ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសម្គាល់មនុស្សខ្ទើយទាំងពីរ នាក់ថាជាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយខ្ទើយទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសង្ស័យមនុស្សខ្ទើយទាំងពីរនាក់ ។បេ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសម្គាល់ មនុស្សខ្ទើយទាំងពីរនាក់ថាប្រុស ។បេ។ មនុស្សខ្ទើយពីរនាក់ ភិក្ខុសម្គាល់ មនុស្សខ្ទើយទាំងពីរនាក់ថា សត្វតិរច្ឆានឈ្មោល ។បេ។ មនុស្សខ្ទើយពីរនាក់

ភិក្ខុសម្គាល់មនុស្សខ្ទើយទាំងពីរនាក់ ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយខ្ទើយពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ មនុស្សប្រុសពីរនាក់ ភិក្ខុសម្គាល់ប្រុសទាំងពីរនាក់ថាជាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយប្រុសទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុសពីរនាក់ ភិក្ខុសង្ស័យប្រុសទាំងពីរនាក់ ។បេ។ ប្រុសពីរនាក់ ភិក្ខុសម្គាល់ប្រុសទាំងពីរនាក់ថាសត្វតិរច្ឆានឈ្មោល ។បេ។ ប្រុសពីរនាក់ ភិក្ខុសម្គាល់ប្រុសទាំងពីរនាក់ថាស្រី ។បេ។ ប្រុសពីរនាក់ ភិក្ខុសម្គាល់ប្រុសទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយប្រុសពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសម្គាល់សត្វតិរច្ឆានឈ្មោលទាំងពីរ ថាជាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយសត្វតិរច្ឆានឈ្មោលទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសង្ស័យនឹងសត្វតិរច្ឆានទាំងពីរ ។បេ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសម្គាល់សត្វតិរច្ឆានឈ្មោលទាំងពីរថាមនុស្សស្រី ។បេ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសម្គាល់សត្វតិរច្ឆានឈ្មោលទាំងពីរថាខ្ទើយ ។បេ។ សត្វតិរច្ឆានឈ្មោលពីរ ភិក្ខុសម្គាល់សត្វតិរច្ឆានឈ្មោលទាំងពីរថាមនុស្សប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយសត្វតិរច្ឆានឈ្មោលទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។

[ ៨២ ] ស្រី និងខ្ទើយ ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយជនទាំងពីរនោះ ត្រូវ

អាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រីនិងខ្ទើយ ភិក្ខុសង្ស័យនឹងមនុស្សទាំងពីរនាក់ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាប្រុស ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ ថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រី និងប្រុស ភិក្ខុសង្ស័យនឹងមនុស្សទាំងពីរនាក់ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ។ ស្រី និងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាប្រុស ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល ។បេ។ កាន់ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី

និងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ ថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់មនុស្សស្រីនិងសត្វតិរច្ឆានទាំងពីរថា មនុស្សស្រី ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយស្រី និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រី និងតិរច្ឆានឈ្មោល ភិក្ខុសង្ស័យស្រី និងតិរច្ឆានទាំងពីរ ត្រេកអរ ក៏យកកាយ ស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយស្រី និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ស្រី និងសត្វតិរច្ឆានទាំងពីរថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយស្រីនិងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ស្រី និងសត្វតិរច្ឆានទាំងពីរថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយស្រី និងសត្វ តិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រី និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ស្រី និងសត្វតិរច្ឆានទាំងពីរថាសត្វតិរច្ឆានឈ្មោល ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយស្រីនិងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ មនុស្សខ្ទើយនិងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ មនុស្សខ្ទើយនិងប្រុស ភិក្ខុសង្ស័យនឹង

មនុស្សទាំងពីរនាក់ ។បេ។ ត្រូវអាបត្តិទុក្កដពីរ ។ មនុស្សខ្ទើយនិងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរ នាក់ថាប្រុស ។បេ។ មនុស្សខ្ទើយ និងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថា សត្វតិរច្ឆានឈ្មោល ។បេ។ មនុស្សខ្ទើយ និងប្រុស ភិក្ខុសម្គាល់មនុស្សទាំងពីរនាក់ថាស្រី ត្រេកអរ ក៏យកកាយស្ទាបអង្អែល ។បេ។ កាន់ ពាល់កាយមនុស្សទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ខ្ទើយ និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ខ្ទើយ និងសត្វតិរច្ឆានទាំងពីរថាខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយខ្ទើយ និងតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ខ្ទើយ និងសត្វតិរច្ឆានឈ្មោល ភិក្ខុសង្ស័យខ្ទើយ និងសត្វតិរច្ឆានឈ្មោលទាំងពីរ ។បេ។ ខ្ទើយនិងសត្វ តិរច្ឆានឈ្មោល ភិក្ខុសម្គាល់ខ្ទើយ និងសត្វតិរច្ឆានទាំងពីរថាប្រុស ។បេ។ ខ្ទើយ និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ខ្ទើយ និងសត្វតិរច្ឆានទាំងពីរថា សត្វតិរច្ឆានឈ្មោល ។បេ។ ខ្ទើយនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ខ្ទើយ និងសត្វតិរច្ឆានទាំងពីរថាស្រី ត្រេកអរ ក៏យកកាយស្ទាបអង្អែល ។បេ។ កាន់ ពាល់កាយខ្ទើយនិងសត្វតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុស និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ប្រុស និងតិរច្ឆានទាំងពីរថាប្រុស ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយប្រុស និងសត្វតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុស និងសត្វតិរច្ឆានឈ្មោល ភិក្ខុសង្ស័យ ប្រុសនិងសត្វតិរច្ឆានទាំងពីរ ។បេ។ ប្រុសនិងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ប្រុស និងសត្វតិរច្ឆានទាំងពីរថា សត្វ

តិរច្ឆានឈ្មោល ។បេ។ ប្រុស និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ប្រុស និងសត្វតិរច្ឆានទាំងពីរជាស្រី ។បេ។ ប្រុស និងសត្វតិរច្ឆានឈ្មោល ភិក្ខុសម្គាល់ប្រុស និងសត្វតិរច្ឆានឈ្មោលទាំងពីរជា ខ្ទើយ ត្រេកអរ ក៏យកកាយស្ទាប អង្អែល ។បេ។ កាន់ ពាល់កាយមនុស្សប្រុស និងសត្វតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។

[ ៨៣ ] ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីនោះដោយកាយ ( របស់ខ្លួន ) ត្រូវអាបត្តិថុល្លច្ច័យ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីទាំងពីរនាក់នោះ ដោយកាយ ( របស់ខ្លួន ) ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់ជនទាំងពីរនាក់ ថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយជនទាំងពីរនាក់នោះ ដោយកាយ ( របស់ខ្លួន ) ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយស្រីនោះ ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិថុល្លច្ច័យ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរ ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយស្រីទាំងនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ស្រី និងខ្ទើយ ភិក្ខុ

សម្គាល់ជនទាំងពីរនាក់នោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយជនទាំងពីរនាក់នោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយស្រីទាំងពីរនាក់នោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់ជនទាំងពីរនាក់នោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយជនទាំងពីរនាក់នោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល កាយស្រីនោះ ដោយនិស្សគ្គិយវត្ថុ[១] ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល កាយស្រីទាំងពីរនោះដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់ជនទាំងពីរនោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល កាយជនទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។ ស្រីជា

---

១- របស់ដែលសម្រាប់ចោល ឬបោះ ។

ប្រាកដ ភិក្ខុសម្គាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល នូវវត្ថុដែលជាប់នឹងកាយស្រីនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល នូវវត្ថុដែលជាប់នឹងកាយស្រីទាំងពីរនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់នោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល នូវវត្ថុដែលជាប់នឹងកាយជនទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល នូវនិស្សគ្គិយវត្ថុរបស់ស្រីនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល នូវនិស្សគ្គិយវត្ថុរបស់ស្រីទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់នោះថាជាស្រី ក៏មានសេចក្តីត្រេកអរ ស្ទាប អង្អែល នូវនិស្សគ្គិយវត្ថុរបស់ជនទាំងពីរនាក់នោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ត្រូវអាបត្តិទុក្កដពីរ ។

### ភិក្ខុបេយ្យាល ចប់

[ ៨៤ ] ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីនោះសោតក៏ស្ទាប អង្អែល ស្ទាបចុះ ស្ទាបឡើង ផ្ទបចុះ ផ្ទើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្ងេច កាន់ ពាល់ នូវកាយ

របស់ភិក្ខុនោះ ដោយកាយ ( របស់ខ្លួន ) ភិក្ខុមានសេចក្តីប្រាថ្នានឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងនោះសោតក៏ស្ទាប អង្អែល ស្ទាបចុះ ស្ទាបឡើង ផ្ទុបចុះ ផ្ងើយឡើង ទាញមក ទាញត្រឡប់ ចាប់សង្កត់ ចាប់ឈ្ងោច កាន់ ពាល់ នូវកាយរបស់ភិក្ខុនោះ ដោយកាយ ( របស់ខ្លួន ) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិសង្ឃាទិសេសពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ជនទាំងពីរនាក់សោតក៏ស្ទាប អង្អែល ។បេ។ កាន់ ពាល់ កាយរបស់ភិក្ខុនោះ ដោយកាយ ( របស់ខ្លួន ) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីសោតក៏ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយកាយ ( របស់ខ្លួន ) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិថុល្លច្ច័យ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងនោះសោតក៏ស្ទាប អង្អែល ។បេ។ កាន់ ពាល់ នូវវត្ថុដែលជាប់នឹងកាយរបស់ភិក្ខុនោះ ដោយកាយ ( របស់ខ្លួន ) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិ

ថុល្លច្ច័យពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្ដីត្រេកអរ ជនទាំងពីរនាក់សោតក៏ស្ទាប អង្អែល ។បេ។ កាន់ ពាល់នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយកាយ ( របស់ខ្លួន ) ភិក្ខុមាន សេចក្ដីប្រាថ្នានឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវ អាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាស្រីពិតមែន ក៏ មានសេចក្ដីត្រេកអរ ស្រីសោតក៏ស្ទាប អង្អែល ។បេ។ ចាប់ ពាល់ នូវកាយ របស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ភិក្ខុមានសេចក្ដី ប្រាថ្នានឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិ ថុល្លច្ច័យ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាស្រីពិតមែន ក៏មាន សេចក្ដីត្រេកអរ ស្រីទាំងនោះសោតក៏ស្ទាប អង្អែល ។បេ។ ចាប់ ពាល់នូវ កាយរបស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ភិក្ខុមានសេចក្ដី ប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិ ថុល្លច្ច័យពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាជាស្រី ក៏មាន សេចក្ដីត្រេកអរ ជនទាំងពីរនាក់សោតក៏ស្ទាប អង្អែល ។បេ។ ចាប់ ពាល់ កាយរបស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ភិក្ខុមាន សេចក្ដីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាស្រីពិតមែន ក៏មានសេចក្ដីត្រេកអរ ស្រីសោតក៏ស្ទាប អង្អែល ។បេ។ ចាប់ ពាល់ នូវ វត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន )

ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ស្រីទាំងពីរនាក់នោះ ស្ទាប អង្អែល ។បេ។ ចាប់ ពាល់ នូវវត្ថុដែលជាប់នឹងកាយរបស់ភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់ជនទាំងពីរនោះថាជាស្រីពិតមែន ហើយមានសេចក្តីត្រេកអរ ជនទាំងពីរនោះ ស្ទាប អង្អែល ។បេ។ ចាប់ ពាល់នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយវត្ថុដែលជាប់នឹងកាយ ( របស់ខ្លួន ) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីជាប្រាកដ ភិក្ខុក៏សម្គាល់ថាស្រីពិតមែន ហើយមានសេចក្តីត្រេកអរ ស្រីនោះស្ទាប អង្អែល នូវកាយរបស់ភិក្ខុនោះ ដោយនិស្សគ្គិយ-វត្ថុ ( របស់ខ្លួន ) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុក៏សម្គាល់ស្រីទាំងពីរនាក់នោះថាជាស្រីពិតមែន ហើយមានសេចក្តីត្រេកអរ ស្រី ( ទាំងពីរនាក់នោះ ) ស្ទាប អង្អែលនូវកាយរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។ ស្រី និងខ្ទើយ ភិក្ខុក៏សម្គាល់ជនទាំងពីរនោះថាជាស្រី មានសេចក្តីត្រេកអរ ជនទាំង

ពីរនោះ ស្ទាប អង្អែល កាយរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុក៏មានសេចក្ដីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីជាប្រាកដ ភិក្ខុក៏សម្គាល់ថាស្រីពិតមែន ក៏មានសេចក្ដីត្រេកអរ ស្រីនោះសោតក៏ស្ទាប អង្អែលនូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុមានសេចក្ដីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាស្រីពិតមែន ក៏មានសេចក្ដីត្រេកអរ ស្រីទាំងនោះសោត ក៏ស្ទាប អង្អែល នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុមានសេចក្ដីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់ជនទាំងពីរនោះថាជាស្រី ក៏មានសេចក្ដីត្រេកអរ ជនទាំងពីរនោះសោតក៏ស្ទាប អង្អែល នូវវត្ថុដែលជាប់នឹងកាយភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុមានសេចក្ដីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាជាស្រីពិតមែន ក៏មានសេចក្ដីត្រេកអរ ស្រីនោះសោតក៏ស្ទាប អង្អែល នូវនិស្សគ្គិយវត្ថុរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុមានសេចក្ដីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់នោះថាជាស្រីពិតមែន ក៏មានសេចក្ដីត្រេកអរ ស្រីទាំងនោះសោតក៏ស្ទាប

អង្អែល នូវនិស្សគ្គិយវត្ថុរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។ ស្រី និងខ្ទើយ ភិក្ខុសម្គាល់ជនទាំងពីរនោះថាជាស្រី ហើយមានសេចក្តីត្រេកអរ ជនទាំងពីរនោះ ស្ទាប អង្អែល នូវនិស្សគ្គិយវត្ថុរបស់ភិក្ខុនោះ ដោយនិស្សគ្គិយវត្ថុ ( របស់ខ្លួន ) ភិក្ខុក៏មានសេចក្តីប្រាថ្នាដើម្បីនឹងសេព ហើយព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដពីរ ។

[ ៨៥ ] ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព ក៏ព្យាយាមដោយកាយ តែមិនដឹងច្បាស់នូវផស្សៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព តែមិនព្យាយាមដោយកាយ គ្រាន់តែដឹងច្បាស់នូវផស្សៈ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងសេព តែមិនព្យាយាមដោយកាយ មិនដឹងច្បាស់នូវផស្សៈ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច ក៏ព្យាយាមដោយកាយ ដឹងច្បាស់នូវផស្សៈ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច ក៏ព្យាយាមដោយកាយ តែមិនដឹងច្បាស់នូវផស្សៈ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច តែមិនព្យាយាមដោយកាយ គ្រាន់តែដឹងច្បាស់នូវផស្សៈ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុមានសេចក្តីប្រាថ្នាដើម្បីនឹងដោះខ្លួនឲ្យរួច តែមិនព្យាយាម

ដោយកាយ មិនដឹងច្បាស់នូវផស្សៈ មិនត្រូវអាបត្តិឡើយ ។

[ ៨៦ ] អាបត្តិមិនមាន ( ដល់ភិក្ខុ ៨ ពួក ) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹង ១ ភិក្ខុមិនត្រេកអរ ១ ភិក្ខុឆ្កួត ១ ភិក្ខុមានចិត្តរវើរវាយ ១ ភិក្ខុដែលវេទនាគ្របសង្កត់ ១ ភិក្ខុជាខាងដើមបញ្ញត្តិ ១ ។

[ ៨៧ ] ( មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀប ដូចមានសេចក្តីខាងក្រោយនេះ )

រឿងមាតា រឿងធីតា រឿងបងប្អូនស្រី រឿងប្រពន្ធ រឿងយក្សស្រី រឿងខ្ទើយ រឿងស្រីដេកលក់ រឿងស្រីស្លាប់ រឿងតិរច្ឆានញី រឿងរូបចម្លាក់ឈើ ( រូបតុក្កតា ) រឿងស្រីចាប់កៀកភិក្ខុ រឿងស្រីឡើងលើស្ពាន រឿងផ្លូវ រឿងដើមឈើ រឿងទូក រឿងខ្សែ រឿងដំបង រឿងភិក្ខុប្រានស្រីដោយបាត្រ រឿងស្រីថ្វាយបង្គំភិក្ខុ រឿងភិក្ខុព្យាយាមចាប់ស្រីតែចាប់មិនត្រូវ ។

[ ៨៨ ] សម័យនោះឯង ភិក្ខុមួយរូប ចាប់ពាល់មាតាដោយសេចក្តីស្រឡាញ់មាតា ។ ភិក្ខុនោះ មានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសទេដឹង ។ ទើបក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ពាល់កូនស្រី ដោយសេចក្តីស្រឡាញ់កូនស្រី ។បេ។ ចាប់ពាល់បងប្អូនស្រី ដោយសេចក្តីស្រឡាញ់បងប្អូនស្រី ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។ ទើបក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃា-

ទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៨៩ ] សម័យនោះឯង ភិក្ខុមួយរូប ចាប់កាយស្រីជាប្រពន្ធពីដើម ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយយក្សស្រី ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយមនុស្សខ្ទើយ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ភិក្ខុមួយរូបចាប់ត្រូវកាយស្រីដែលកំពុងដេកលក់ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវកាយស្រីដែលស្លាប់ហើយ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ភិក្ខុចាប់ត្រូវកាយសត្វតិរច្ឆានញី ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង ភិក្ខុមួយរូប ចាប់ត្រូវរូបឈើធ្វើជារូបស្រី ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ទ្រង់ត្រាស់ថា មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៩០ ] សម័យមួយនោះ មានស្រីច្រើននាក់ចាប់កៀកភិក្ខុ ១ រូប នាំទៅដោយដើមដៃគ្នា ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គមានព្រះបន្ទូលសួរថា ម្នាលភិក្ខុ អ្នកឯងត្រេកអរដែរឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ( បើ ) មិនត្រេកអរ មិនត្រូវអាបត្តិទេ ។

[ ៩១ ] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏ចាប់អង្រួនស្ពានដែលស្រីកំពុងឡើង ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៩២ ] សម័យនោះឯង ភិក្ខុមួយរូប ប្រទះស្រីក្នុងផ្លូវជួបគ្នា មានសេចក្តីត្រេកអរ ក៏ទន្គិចស្រីនោះដោយចង្កូយស្មា ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃា-ទិសេសហើយ ។

[ ៩៣ ] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏អង្រួនដើមឈើដែលស្រីឡើង ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៩៤ ] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏អង្រួនទូកដែលស្រីឡើងជិះ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់

ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ៩៥ ] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏ចាប់ទាញខ្សែដែលស្រីកំពុងកាន់ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏ចាប់ទាញដំបងដែលស្រីកំពុងកាន់ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ៩៦ ] សម័យនោះឯង ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏ច្រានស្រីដោយបាត្រ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។ សម័យនោះឯង ភិក្ខុមួយរូប កាលស្រីកំពុងថ្វាយបង្គំ មានសេចក្តីត្រេកអរ ក៏លើកជើងឡើងវេងឲ្យចំពប់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង ភិក្ខុមួយរូប គិតថាអញនឹងចាប់ស្រី ក៏ព្យាយាមតែចាប់មិនត្រូវ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយដឹង ។ ទើបក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

សង្ឃាទិសេសទី ២ ចប់

# អដ្ឋកថា

# កាយសំសគ្គសិក្ខាបទវណ្ណនា

[ ៧៥ ] កាយសំសគ្គសិក្ខាបទ ត្រង់ពាក្យថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅថា ក្នុងកាយសំសគ្គសិក្ខាបទនោះ មានការពណ៌នាបទដែលមិនជាក់ច្បាស់ ដូចតទៅនេះថា

ពីរបទថា **អរញ្ញេ វិហរតិ** សេចក្តីថា មិនមែននៅក្នុងព្រៃមួយផ្នែកឯណោះទេ គឺនៅក្នុងទីបំផុតដែនមួយនៃព្រះវិហារជេតពននោះឯង ។

ពីរបទថា **មជ្ឈេ គព្ភោ** សេចក្តីថា ឯទីត្រង់កណ្តាលវិហាររបស់ឧទាយិ-ភិក្ខុនោះ មានបន្ទប់ ។

បទថា **សមន្តាបរិយាគារោ** សេចក្តីថា ដោយជុំវិញបន្ទប់នោះ មានរបៀងរោងមូលជាគ្រឿងព័ទ្ធជុំវិញ បានឮថា បន្ទប់នោះ ឧទាយិភិក្ខុធ្វើឲ្យជាបន្ទប់ ៤ ជ្រុងត្រង់កណ្តាល ដោយមានរោងមូលជារបៀងព័ទ្ធខាងក្រៅដែលមនុស្សទាំងឡាយអាចដើរវិលជុំវិញខាងក្នុងបាននោះឯង ។

បទថា **សុបញ្ញត្តំ** ប្រែថា រៀបចំទុករៀបរយ អធិប្បាយថា គ្រែតាំងនោះ ទុកដាក់ដោយប្រការណាមួយ និងក្នុងឱកាសណាមួយ ទើបនឹងញ៉ាំងឲ្យកើតសេចក្តីជ្រះថ្លា ឲ្យអ្នកស្រុកត្រេកអរ លោកបានរៀបចំដោយប្រការនោះៗ ក្នុងឱកាសនោះៗ ។ ពិតហើយ ឧទាយិភិក្ខុនោះនឹងធ្វើកិច្ចឯណាមួយដោយលើកវត្តឡើងជាប្រធានក៏ទេ ។

បទថា **ឯកច្ចេ វាតបានេ** សេចក្តីថា បើកបង្អួចទាំងឡាយដែលកាលបិទហើយ មានសភាពងងឹត បិទបង្អួចទាំងឡាយដែលបើកហើយមានពន្លឺ ។

បទថា **ឯវំ វុត្តេ សា ព្រាហ្មណី តំ ព្រាហ្មណំ ឯតទវោច** សេចក្តីថា កាលព្រាហ្មណ៍នោះពោលសរសើរយ៉ាងនេះ ព្រាហ្មណីនោះយល់ថា ព្រាហ្មណ៍នេះជ្រះថ្លាហើយ ប្រហែលជាចង់បួស កាលនឹងបើកបង្ហាញអាការដែលគួរលាក់បាំងនោះរបស់ខ្លួន សូម្បីគួរបិទបាំង មានបំណងនឹងកាត់ផ្តាច់សទ្ធារបស់ព្រាហ្មណ៍នោះតែម្យ៉ាង ទើបពោលពាក្យជាដើមថា **កុតោ តស្ស ឧឡារតា** នេះ ។

ក្នុងបទថា **ឧឡារតា** នោះ មានវិគ្គហៈថា ខ្លួន ( អធ្យាស្រ័យ ) របស់បុគ្គលនោះ ឧឡារ ( ល្អ ) ព្រោះហេតុនោះ ទើបឈ្មោះថា មានខ្លួនដ៏ឧឡារ ។ ភាវៈនៃបុគ្គលអ្នកមានខ្លួនដ៏ឧឡារនោះ ឈ្មោះថា **ឧឡារតា**។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **កុលិត្ថីហិ** ជាដើមតទៅនេះថា ស្រីមេផ្ទះទាំងឡាយ ឈ្មោះថា **កុលិត្ថី** ។ ពួកកូនក្រមុំរបស់ត្រកូលដែលទៅជាមួយបុរសដទៃបាន ឈ្មោះថា **កុលធីតា** ។ ពួកស្រីជំទង់ មានចិត្តមិនទាន់ពិតប្រាកដ ហៅថា **កុលកុមារី** ។ ស្រីដែលគេនាំមកអំពីត្រកូលដទៃ ដើម្បីកំលោះក្នុងត្រកូល ហៅថា **កុលសុណ្ហា**។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃកាយសំសគ្គសិក្ខាបទ

[ ៧៦ ] បទថា **ឱតិណ្ណោ** នោះ បានដល់ បុគ្គលដែលរាគៈកើតខាងក្នុងគ្របសង្កត់ហើយ ប្រៀបដូចសត្វទាំងឡាយ ដែលត្រូវយក្ខជាដើម ញាំងឲ្យនៅក្នុងអំណាច ដូច្នោះ ។ ម្យ៉ាងទៀត កាលមិនពិចារណាតម្រេកក្នុងឋានៈ

ដែលគួរមានតម្រេក ឈ្មោះថា ធ្លាក់ចុះកាន់តម្រេកខ្លួនឯង ដូចសត្វដែលមិនពិចារណាធ្លាក់រណ្ដៅជាដើម ដូច្នោះ ។ ឯបទថា **ឱតិណ្ណោ** នេះ ជាឈ្មោះរបស់ភិក្ខុដែលច្រើនដោយរាគៈប៉ុណ្ណោះ សូម្បីដោយប្រការទាំងពីរ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់បទភាជនីយ៍នៃបទថា **ឱតិណ្ណោ** នោះយ៉ាងនេះថា បុគ្គលតម្រេកខ្លាំង បុគ្គលមានសេចក្ដីសម្ងំ បុគ្គលមានចិត្តប្រតិព័ទ្ធ ។

បណ្ដាបទទាំងនោះ បទថា **សារត្តោ** បានដល់ បុគ្គលត្រេកត្រអាលខ្លាំង ដោយកាយសំសគ្គរាគៈ ។

បទថា **អបេក្ខវា** បានដល់ បុគ្គលមានការសម្ងំដល់បំណងក្នុងកាយសំសគ្គៈ ។

បទថា **បដិពទ្ធចិត្តោ** បានដល់ បុគ្គលមានចិត្តជាប់ជំពាក់ក្នុងវត្ថុនោះដោយកាយសំសគ្គរាគៈនោះឯង ។

បទថា **វិបរិណតេន** សេចក្ដីថា មានចិត្តលះប្រក្រតីចោល ពោលគឺភវង្គសន្តតិដែលបរិសុទ្ធ ប្រព្រឹត្តទៅដោយប្រការដទៃ រាប់ថា ប្រែប្រួលទៅខុសប្រក្រតី ឬផ្លាស់ប្ដូរទៅខុសប្រក្រតី ។ អធិប្បាយថា ចិត្តផ្លាស់ប្ដូរយ៉ាងណា ឈ្មោះថា ខុសប្រក្រតី មានចិត្តផ្លាស់ប្ដូរទៅយ៉ាងនោះ ។ ព្រោះហេតុដែលចិត្តនោះមិនកន្លងការប្រកបព្រមដោយកិលេស មានរាគៈជាដើមទៅបាន ដូច្នោះ កាលព្រះដ៏មានព្រះភាគត្រាស់បទភាជនីយ៍នៃបទថា **វិបរិណតំ** នោះដោយន័យជាដើមថា **វិបរិណតន្តិ រត្តម្បិ ចិត្តំ** ហើយទ្រង់សម្ដែងអត្ថដែល

បំណងក្នុងសិក្ខាបទក្នុងទីបំផុត ទើបត្រាស់ថា តែចិត្តដែលត្រេកត្រអាល ហើយ ឈ្មោះថា ចិត្តប្រែប្រួលដែលបំណងក្នុងអត្ថនេះ ។

បទថា **តទហុជាតា** បានដល់ ក្មេងស្រីដែលកើតក្នុងថ្ងៃនោះ គឺគ្រាន់តែកើតនៅមានពណ៌ជាដុំសាច់ស្រស់ ។ ពិតហើយ ព្រោះស្ទាបអង្អែលកាយទារិកាសូម្បីមានសភាពបែបនេះ ក៏រមែងត្រូវអាបត្តិសង្ឃាទិសេស ព្រោះឈានកន្លងដោយមេថុន រមែងត្រូវអាបត្តិបារាជិក ព្រោះត្រេកអរដោយរហោនិសជ្ជៈ ( ការអង្គុយក្នុងទីកំបាំង ) រមែងត្រូវអាបត្តិបាចិត្តិយ ។

បទថា **បគេវ** បានដល់ ស្រីដែលពោលមុននោះឯង ។

ពីរបទថា **កាយសំសគ្គំ សមាបជ្ជេយ្យ** សេចក្តីថា គប្បីដល់នូវការកៀកកិតកាយ មានចាប់ដៃជាដើម គឺភាពជាបុគ្គលស្ទាបអង្អែលដោយកាយ។ ឯកាយសំសគ្គៈរបស់ភិក្ខុ ដែលចូលដល់ការស្ទាបអង្អែលដោយកាយនោះឯងដោយអត្ថ រមែងជាអជ្ឈាចារ គឺការប្រព្រឹត្តកន្លងដែននៃសំវរៈ ដោយអំណាចរាគៈ ព្រោះហេតុនោះ កាលព្រះដ៏មានព្រះភាគទ្រង់សម្តែងអត្ថដោយសង្ខេបនៃបទនោះ ទើបត្រាស់បទភាជនីយ៍ថា តថាគតហៅថា អជ្ឈាចារ ។

បទថា **ហត្ថគ្គាហំ វា** ជាដើម ជាបទចែករបស់ពីរបទនោះ លោកសម្តែងដោយពិស្តារក្នុងសិក្ខាបទនេះ ។ ព្រះដ៏មានព្រះភាគត្រាស់ពាក្យជាដើមថា **ហត្ថោ នាម កប្បរំ ឧបាទាយ** ដើម្បីសម្តែងវិភាគនៃអវយវៈ មានដៃជាដើមក្នុងបទភាជនីយ៍នោះ ។

បណ្តាបទទាំងនោះ ពីរបទថា **កប្បរំ ឧបាទាយ** សេចក្តីថា សំដៅ

ដល់ទីតជំទី ២ ( តាំងអំពីកែងដៃចុះទៅ ) ។ តែក្នុងទីដទៃ តាំងពីដើមដៃដល់ចុងក្រចក រាប់ថា ដៃ ។ ក្នុងទីនេះ បំណងយកពីកែងដៃរហូតដល់ចុងក្រចក ។

បទថា **សុទ្ធកេសានំ វា** បានដល់ សក់ដែលមិនលាយដោយអំបោះជាដើម គឺសក់សុទ្ធៗ នោះឯង ។ ពាក្យថា ផ្នួងនេះ ជាឈ្មោះរបស់បាច់សក់ដែលក្រងដោយសក់ ៣ ជួង ។

បទថា **សុត្តមិស្សា** បានដល់ ផ្នួងដែលគេយកអំបោះ ៥ ពណ៌សៀតក្នុងសក់ ។ បទថា **មាលាមិស្សា** បានដល់ ផ្នួងដែលគេសៀតដោយផ្កាម្លិះជាដើម ឬក្រងដោយសក់ ៣ ជួង ។ ម្យ៉ាងទៀត បាច់សក់ដែលសៀតដោយផ្កាតែម្យ៉ាង សូម្បីមិនបានក្រង ក៏គប្បីជ្រាបថា ផ្នួងក្នុងទីនេះ ។

បទថា **ហិរញ្ញមិស្សា** បានដល់ ផ្នួងដែលសៀតដោយកម្រងកហាបណៈ ។ បទថា **សុវណ្ណមិស្សា** បានដល់ ផ្នួងដែលប្រដាប់ដោយកម្រងមាស ឬដោយសង្វារជាដើម ។ បទថា **មុត្តាមិស្សា** បានដល់ ផ្នួងដែលប្រដាប់ដោយកែវមុក្តា ។ បទថា **មណិមិស្សា** បានដល់ ផ្នួងដែលប្រដាប់ដោយកែវមណីជោតអំបោះ ។ ពិតហើយ កាលភិក្ខុចាប់ផ្នួងសក់ប្រភេទណាទីមួយ ក្នុងប្រភេទទាំងនេះ ជាសង្ឃាទិសេសទាំងអស់ ។ ការរួចផុតមិនមានដល់ភិក្ខុដែលកែខ្លួនថា ខ្ញុំបានចាប់ផ្នួងសក់ដែលលាយ ។

ចំណែកសក់ដែលព្រះដ៏មានព្រះភាគ ទ្រង់កាន់យកដោយ **វេណិ** សព្ទក្នុងបទថា **វេណិគ្គាហំ** នេះ ។ ព្រោះហេតុនោះ កាលភិក្ខុណាចាប់សូម្បីសក់មួយសរសៃ ភិក្ខុនោះ ក៏ត្រូវអាបត្តិដូចគ្នា ។

រាងកាយដ៏សេស រៀវដៃ និងផ្នួងសក់ មានប្រការគ្រប់យ៉ាង ដែលមានលក្ខណៈដូចពោលហើយក្នុងពាក្យថា **ហត្ថញ្ច វេណិញ្ច ឋបេត្វា** នេះ គប្បីជ្រាបថាជា អវយវៈ ។ បណ្តាអវយវៈ មានដៃជាដើមដែលកំណត់ហើយយ៉ាងនេះ ការចាប់ដៃ ឈ្មោះថា **ហត្ថគ្គាហោ** ។ ការចាប់ផ្នួងសក់ ឈ្មោះថា **វេណិគ្គាហោ** ។ ការស្ទាបអង្អែលសរីរៈដ៏សេស ឈ្មោះថា **អង្គស្ស បរាមសនំ** ។ សេចក្តីថា ភិក្ខុណា ទោះបីចាប់ដៃក្តី ចាប់ផ្នួងសក់ក្តី ស្ទាបអវយវៈឯណាមួយក្តី ជាកងអាបត្តិសង្ឃាទិសេសដល់ភិក្ខុនោះ ដូច្នេះជាអត្ថនៃសិក្ខាបទ ។

[ ៧៧ ]ម្យ៉ាងទៀត ការចាប់ដៃក្តី ការចាប់ផ្នួងសក់ក្តី ការស្ទាបអវយវៈដ៏សេសទាំងអស់ក្តី ដោយការផ្សេងគ្នាមាន ១២ យ៉ាង ព្រោះដូច្នោះ ដើម្បីសម្តែងការផ្សេងគ្នានោះ ទើបព្រះដ៏មានព្រះភាគ ត្រាស់បទភាជនីយ៍នៃបទថា **ហត្ថគាហោ** ជាដើមនោះ ដោយន័យជាដើមថា **អាមសនា បរាមសនា** ដូច្នេះ ។

[ ៧៨ ] បទថា **អាមសនា** ជាដើមនោះ ពីរបទដែលព្រះដ៏មានព្រះភាគត្រាស់ថា **អាមសនា នាម អាមដ្ឋមត្តា** និងពាក្យថា **ឆុបនំ នាម ផុដ្ឋមត្តំ** នេះ មានការប្លែកគ្នាដូចតទៅនេះថា ការប៉ះពាល់ គឺការស្ទាបក្នុងឱកាសដែលពាល់ត្រូវប៉ុណ្ណោះ មិនកន្លងឱកាសដែលពាល់ត្រូវទៅ ឈ្មោះថា **អាមសនា** ។ ពិតហើយ ការស្ទាបនេះ ព្រះដ៏មានព្រះភាគត្រាស់ហៅថា **អាមដ្ឋមត្តា** ។ កិរិយាដោយគ្រាន់តែពាល់ត្រូវ មិនស្ទាប ឈ្មោះថា **ឆុបនំ** ។

សូម្បីក្នុងបទដូចគ្នានោះឯង ដែលព្រះមានព្រះភាគត្រាស់ក្នុងនិទ្ទេសនៃ **ឧម្ម-សនា** និង **ឧល្លង្ឃនា** ថា **ឧទ្ធំ** **ឧច្ចារណា** ដូច្នេះ មានសេចក្តីប្លែកគ្នាដូចតទៅនេះថា បទទី ១ ត្រាស់ដោយអំណាចនៃកាយរបស់ខ្លួនពាល់ត្រូវខាងលើកាយរបស់ស្រី បទទី ២ ត្រាស់ដោយអំណាចលើកកាយរបស់ស្រីឡើង ។ បទដ៏សេសប្រាកដច្បាស់ហើយ ។

សិក្ខាបទវិភង្គនៃកាយសំសគ្គសិក្ខាបទ ចប់

# អធិប្បាយ

# បទភាជនីយ៍នៃកាយសំសគ្គសិក្ខាបទ

[ ៨០ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃអាបត្តិដោយពិស្តារ ដោយអំណាចនៃបទទាំងនេះ របស់ភិក្ខុដែលត្រូវរាគៈគ្របសង្កត់ហើយ មានចិត្តប្រែប្រួល ដល់នូវការស្ទាបអង្អែលកាយ ទើបត្រាស់ពាក្យជាដើមថា ស្រី ១ ភិក្ខុមានការសម្គាល់ថាជាស្រី ១ មានសេចក្តីត្រេកអរ ១ ស្ទាបអង្អែលកាយដោយកាយរបស់ស្រី ១ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះ ដូច្នេះថា ពាក្យថា **ភិក្ខុ ច នំ ឥត្ថិយា កាយេន កាយំ** សេចក្តីថា ភិក្ខុនោះមានសេចក្តីត្រេកអរ ១ មានការសម្គាល់ជាស្រី ១ ( ស្ទាបអង្អែលកាយរបស់ស្រី ) ដោយកាយរបស់ខ្លួន ១ ។

បទថា **នំ** ត្រឹមតែជានិបាត ។ ម្យ៉ាងទៀត សេចក្តីថា ( ស្ទាបអង្អែល ) កាយនោះ គឺកាយមានដៃជាដើមរបស់ស្រី ។

បទថា **អាមសតិ បរាមសតិ** សេចក្តីថា ភិក្ខុប្រព្រឹត្តកន្លងដោយអាការឯណាមួយ បណ្តាការចាប់ពាល់ជាដើមនោះឯង ត្រូវសង្ឃាទិសេសក្នុងការចាប់ពាល់ជាដើមនោះ ភិក្ខុចាប់ពាល់ម្តងជាអាបត្តិ ១ កាលចាប់ពាល់ញយៗ ក៏ជាសង្ឃាទិសេសគ្រប់ៗ ប្រយោគ ។ សូម្បីកាលស្ទាបអង្អែលបើមិនស្ទាបអង្អែលឲ្យផុតចាកកាយឡើយ បពោស ផ្ទាស់ សម្រូតក្តី ដៃ ឬកាយរបស់ខ្លួនទៅខាងនោះខាងនេះ ( មិនដកដៃឲ្យផុតពីកាយ ) កាលស្ទាបអង្អែលយ៉ាងនេះ សូម្បីអស់មួយថ្ងៃក៏ត្រូវអាបត្តិ ១ ប៉ុណ្ណោះ ។ បើដកដៃឲ្យ

ផុតចាកកាយហើយ ស្ទាបអង្អែលវិញរឿយៗ ត្រូវអាបត្តិគ្រប់ៗ ប្រយោគ ។ កាលអង្អែលចុះក្រោម បើមិនឲ្យផុតចាកកាយ អង្អែលតាំងអំពីក្បាលរបស់ស្រី ចុះទៅរហូតដល់ខ្នងជើង ក៏ត្រូវត្រឹមអាបត្តិ ១ ប៉ុណ្ណោះ បើដល់ទីនោះៗ បណ្តាទី មានពោះជាដើម ដក ( ដៃ ) ហើយស្ទាបចុះទៅ ត្រូវអាបត្តិគ្រប់ៗ ប្រយោគ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការស្ទាបអង្អែលឡើង ដូច្នេះថា កាលភិក្ខុស្ទាបអង្អែលឡើងតាំងពីជើងរហូតដល់ក្បាល ក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការសង្កត់ចុះ ដូច្នេះថា កាលភិក្ខុចាប់មាតុគ្រាមត្រង់សក់ ហើយសង្កត់ចុះ ធ្វើអជ្ឈាចារតាមប្រាថ្នា មានការថើបជាដើម ហើយលែងទៅ ជាអាបត្តិ ១ ប៉ុណ្ណោះ កាលភិក្ខុសង្កត់ស្រីដែលងើបឡើងហើយ ឲ្យឱនចុះរឿយៗ ត្រូវអាបត្តិគ្រប់ៗ ប្រយោគ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការលើកឡើង ដូច្នេះថា កាលភិក្ខុចាប់មាតុគ្រាមត្រង់សក់ក្តី ត្រង់ដៃទាំងពីរក្តីឲ្យក្រោកឡើង ក៏មានន័យយ៉ាងនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការទាញមក ដូច្នេះថា ភិក្ខុទាញមាតុគ្រាមឲ្យបែរមុខមករកខ្លួន មិនទាន់លែង ( ដៃ ) ដរាបណា ត្រូវអាបត្តិ ១ ដរាបនោះឯង ។ កាលលែង ( ដៃ ) ហើយចាប់ទាញមកទៀត ត្រូវអាបត្តិ គ្រប់ៗ ប្រយោគ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការច្រានចេញ ដូច្នេះថា កាលភិក្ខុចាប់ត្រង់ខ្នងមាតុគ្រាមពីក្រោយ ហើយច្រានទៅ មានន័យដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការអូសទៅ ដូច្នេះថា កាលភិក្ខុចាប់ត្រង់ដៃ ឬត្រង់ដើមដៃមាតុគ្រាមឲ្យណែន ហើយដើរទៅ សូម្បីអស់រយៈមួយយោជន៍ ជាអាបត្តិ ១ ប៉ុណ្ណោះ កាលលែងហើយចាប់ៗ ជាអាបត្តិគ្រប់ៗ ប្រយោគ ព្រះមហាសុមត្ថេរពោលថា បើមិនលែង ចាប់ពាល់ក្តី ឱបក្តី រឿយៗ ត្រូវអាបត្តិគ្រប់ៗ ប្រយោគ ចំណែកព្រះបទុមត្ថេរពោលថា ការចាប់ផ្តើមនោះឯងជាប្រមាណ ព្រោះហេតុនោះ ភិក្ខុនៅមិនទាន់លែង ( ដៃ ) ដរាបណា ត្រូវអាបត្តិត្រឹមតែ ១ ដរាបនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងការប្រហារ ដូច្នេះថា កាលភិក្ខុប្រហារដោយសំពត់ក្តី គ្រឿងប្រដាប់ក្តី មិនប៉ះត្រូវខ្លួន ត្រូវអាបត្តិថុល្លច្ច័យ កាលប៉ះត្រូវខ្លួន ត្រូវអាបត្តិសង្ឃាទិសេស ។ ត្រូវអាបត្តិ ១ ដោយប្រយោគ ១ ត្រូវអាបត្តិផ្សេងៗ ដោយប្រយោគផ្សេងៗ ។ ក្នុងការចាប់ និងការប៉ះពាល់ បើមិនធ្វើកាយវិការណាមួយដទៃ រមែងត្រូវអាបត្តិដោយអាការត្រឹមតែចាប់ ត្រឹមតែប៉ះ ។

បណ្តាអាការ មានការចាប់ពាល់ជាដើមនេះ ដូចពោលមកនេះ កាលភិក្ខុមានការសម្គាល់ក្នុងស្រី ថាជាមនុស្សស្រី ប្រព្រឹត្តកន្លងដោយអាការណាមួយ ត្រូវអាបត្តិសង្ឃាទិសេស ។ បើភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិថុល្លច្ច័យ សូម្បីភិក្ខុសម្គាល់ក្នុងស្រី ថាជាខ្ទើយ ជាប្រុស ជាតិរច្ឆាន ក៏ត្រូវអាបត្តិថុល្លច្ច័យដូចគ្នា ។ ត្រូវអាបត្តិថុល្លច្ច័យដល់ភិក្ខុ ដែលមានសេចក្តីសម្គាល់ក្នុងខ្ទើយ ថាជាខ្ទើយ បើភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សម្រាប់ភិក្ខុដែលសម្គាល់ ( ក្នុងខ្ទើយ ) ថាជាបុរស ជាតិរច្ឆាន និងជាស្រី

ត្រូវអាបត្តិទុក្កដដូចគ្នា ។ បើភិក្ខុមានការសម្គាល់ក្នុងបុរស ថាជាបុរសក្តី មានសេចក្តីសង្ស័យក្តី មានសេចក្តីសម្គាល់ថាជាស្រីក្តី ជាខ្ទើយក្តី ជាសត្វតិរច្ឆានក្តី ត្រូវអាបត្តិទុក្កដទាំងអស់ ។ សូម្បីក្នុងសត្វតិរច្ឆាន ក៏ត្រូវអាបត្តិទុក្កដ ដោយអាការគ្រប់យ៉ាងដូចគ្នានោះឯង ។

[ ៨១ ] បណ្ឌិតគប្បីកំណត់អាបត្តិទាំងនេះ ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងឯកមូលកន័យ ហើយជ្រាបអាបត្តិទ្វេគុណ ក្នុងទ្វិមូលកន័យ ដែលត្រាស់ដោយឧបាយនេះ និងដោយអំណាចនៃពាក្យថា **ទ្វេ ឥត្ថិយោ ទ្វិន្នំ ឥត្ថីនំ** ជាដើម ។

ក្នុងស្រី ២ នាក់ គប្បីជ្រាបសង្ឃាទិសេស ២ យ៉ាងណា ក្នុងស្រីច្រើននាក់ គប្បីជ្រាបសង្ឃាទិសេសច្រើនយ៉ាងនោះ ។ ពិតហើយ ភិក្ខុណាយកដៃទាំងពីររួមចាប់ស្រីមានចំនួនច្រើននាក់ ដែលឈររួមគ្នា ភិក្ខុនោះ ត្រូវសង្ឃាទិសេសច្រើន ដោយការរាប់ចំនួនស្រី ដែលខ្លួនពាល់ត្រូវ ត្រូវអាបត្តិថុល្លច្ច័យ ដោយការរាប់ស្រីដែលនៅត្រង់កណ្តាល ។ ពិតហើយ ស្រីទាំងនោះឈ្មោះថា ភិក្ខុនោះចាប់ពាល់ដោយរបស់ដែលជាប់ទាក់ទងដោយកាយ ។

ម្យ៉ាងទៀត ភិក្ខុណា ចាប់ម្រាមដៃ ឬសក់របស់ស្រីចំនួនច្រើនរួមគ្នា ព្រះវិនយធរកុំរាប់ម្រាមដៃ ឬសរសៃសក់ កាត់អាបត្តិឡើយ គប្បីរាប់ចំនួនស្រី កាត់អាបត្តិដោយសង្ឃាទិសេស និងភិក្ខុរមែងត្រូវអាបត្តិថុល្លច្ច័យដោយការរាប់ស្រីទាំងឡាយ ដែលមានដៃ និងសក់នៅត្រង់កណ្តាល ។ ពិតហើយ ស្រីទាំងនោះ រមែងឈ្មោះថា ភិក្ខុនោះចាប់ពាល់ហើយដោយរបស់ដែលជាប់

ទាក់ទងដោយកាយ តែបើភិក្ខុសរុបចាប់ស្រីជាច្រើនដោយរបស់ដែលទាក់ទង ដោយកាយ មានខ្សែ និងសំពត់ជាដើម រមែងត្រូវអាបត្តិថុល្លច្ច័យ ដោយការរាប់ស្រីទាំងអស់ដែលនៅខាងក្នុងរង្វង់ ( ខ្សែ ) នោះឯង ។ ក្នុងមហាបច្ចរី ដាក់អាបត្តិទុក្កដក្នុងពួកស្រី ដែលមិនបានពាល់ត្រូវ ។ បណ្ដាន័យមុន និងន័យដែលលោកពោលក្នុងមហាបច្ចរីនោះ ព្រោះដែលបាន ឈ្មោះថា ការចាប់ពាល់ត្រូវរបស់ដែលទាក់ទងដោយកាយ និងរបស់ទាក់ទងដោយកាយ មិនមានក្នុងព្រះបាលី ព្រោះដូច្នោះឯង ន័យមុនដែលលោក សរុបរួមរបស់ដែលទាក់ទងដោយកាយចូលគ្នា ហើយពោលទុកក្នុងមហាអដ្ឋកថា និងកុរុន្ទីប្រាកដថា ត្រឹមត្រូវជាងក្នុងអធិការនេះ ។

ភិក្ខុណា មានតម្រេកខ្លាំងប៉ុនគ្នាក្នុងស្រីទាំងឡាយ ដែលឈរយកដៃចាប់ដៃគ្នាតាមលំដាប់ ចាប់ស្រីម្នាក់ត្រង់ដៃ ភិក្ខុនោះរមែងត្រូវអាបត្តិសង្ឃាទិសេស ១ ដោយអំណាចនៃស្រីដែលខ្លួនចាប់ ត្រូវអាបត្តិថុល្លច្ច័យច្រើននាក់តាមចំនួននៃស្រីក្រៅអំពីនេះ ដោយន័យមុននោះឯង ។ បើភិក្ខុនោះចាប់ស្រីនោះត្រង់សំពត់ ឬផ្កាដែលជារបស់ទាក់ទងដោយកាយ រមែងត្រូវអាបត្តិថុល្លច្ច័យច្រើន តាមចំនួននៃស្រីទាំងអស់ ដូចភិក្ខុសរុបចាប់ស្រីទាំងឡាយដោយខ្សែ និងសំពត់ជាដើម រមែងឈ្មោះថា ចាប់ស្រីទាំងអស់ដោយរបស់ដែលជាប់នឹងកាយ យ៉ាងណា សូម្បីក្នុងអធិការនេះ ស្រីទាំងអស់ ឈ្មោះថា ភិក្ខុចាប់ពាល់ហើយដោយរបស់ ដែលជាប់ដោយកាយដូច្នោះដូចគ្នា ។

បើស្រីទាំងនោះ ឈរចាប់គ្នានឹងគ្នាត្រង់ជាយសំពត់ ភិក្ខុចាប់ស្រីដំបូង

ក្នុងបណ្តាស្រីទាំងនោះត្រង់ដៃ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ដោយអំណាចស្រីម្នាក់ដែលខ្លួនចាប់ ត្រូវអាបត្តិទុក្កដច្រើន តាមចំនួននៃស្រីក្រៅអំពីនេះ ដោយន័យមុននោះឯង ។ ព្រោះថា របស់ដែលជាប់នឹងកាយ និងរបស់ដែលជាប់នឹងកាយរបស់ស្រីទាំងអស់នោះ ឈ្មោះថា ភិក្ខុនោះ ចាប់ពាល់ហើយ ដោយន័យមុននោះឯងដូចគ្នា ។ បើភិក្ខុនោះ ចាប់ស្រីនោះចំពោះរបស់ដែលជាប់ដោយកាយប៉ុណ្ណោះ ត្រូវទុក្កដជាច្រើន តាមចំនួននៃស្រីក្រៅអំពីនេះ ដោយន័យបន្ទាប់មកនោះឯង ។

បើភិក្ខុណា ប៉ះត្រូវសំពត់មនុស្សស្រីដែលស្លៀកសំពត់ក្រាស់ ដោយកាយសំសគ្គរាគៈ ភិក្ខុនោះត្រូវអាបត្តិថុល្លច្ច័យ ប៉ះត្រូវសំពត់មនុស្សស្រីដែលស្លៀកសំពត់ស្តើង បើក្នុងទីដែលប៉ះនោះ រោមរបស់ស្រីដែលធ្លុះចេញអំពីសំពត់ប៉ះភិក្ខុ ឬរោមរបស់ភិក្ខុធ្លុះចូលទៅប៉ះស្រី ឬរោមទាំងពីរចំណែកប៉ះគ្នាប៉ុណ្ណោះ ត្រូវអាបត្តិសង្ឃាទិសេស ព្រោះថា សូម្បីត្រូវរូបដែលមានវិញ្ញាណគ្រប់គ្រង ឬមិនមានវិញ្ញាណគ្រប់គ្រង ( របស់ស្រី ) ដោយកម្មជរូបដែលមានវិញ្ញាណ ( របស់ខ្លួន ) ក្តី ត្រូវរូបដែលមានវិញ្ញាណគ្រប់គ្រង ឬមិនមានវិញ្ញាណគ្រប់គ្រង ( របស់ស្រី ) ដោយសក់របស់ខ្លួន សូម្បីមិនមានវិញ្ញាណគ្រប់គ្រងក្តី រមែងត្រូវអាបត្តិសង្ឃាទិសេសដូចគ្នា ។ ក្នុងការដែលរោម និងរោមប៉ះគ្នានោះ ក្នុងកុរុន្ទីពោលថា គប្បីរាប់ចំនួនរោម កាត់អាបត្តិសង្ឃាទិសេស ។ តែក្នុងមហាអដ្ឋកថាពោលថា មិនគួររាប់រោមកាត់អាបត្តិ ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ១ ប៉ុណ្ណោះ ចំណែកភិក្ខុមិនក្រាលកម្រាល

ដេកលើគ្រែរបស់សង្ឃ ទើបគួរពាប់រោមកាត់អាបត្តិ ។ ពាក្យរបស់អដ្ឋកថានោះឯងប្រពៃ ព្រោះថា អាបត្តិនេះ កាត់ដោយអំណាចនៃស្រី មិនមែនកាត់ដោយអំណាចនៃចំណែក ដូច្នេះឯង ។

ក្នុងអធិការនេះ លោកតាំងសំណួរថា ភិក្ខុណាគិតថា នឹងចាប់របស់ដែលជាប់ដោយកាយ ហើយចាប់កាយក្តី គិតថា នឹងចាប់កាយ ហើយចាប់របស់ដែលជាប់កាយក្តី ភិក្ខុនោះត្រូវអាបត្តិអ្វី ព្រះសុមត្ថេរឆ្លើយមុនថា ត្រូវអាបត្តិតាមវត្ថុប៉ុណ្ណោះ ។ បានឮថា លទ្ធិរបស់លោកមានដូច្នេះថា វត្ថុ ១ សញ្ញា ១ រាគៈ ១ ការដឹងផស្សៈ ១ ព្រោះដូច្នោះ គួរកាត់គរុកាបត្តិដែលពោលហើយក្នុងនិទ្ទេស តាមដែលទ្រង់អធិប្បាយទុក ។

ក្នុងគាថានេះ វត្ថុនោះ បានដល់ ស្រី សញ្ញានោះ បានដល់ ការសម្គាល់ថាជាស្រី រាគៈនោះ បានដល់ តម្រេកក្នុងការស្ទាបអង្អែលដោយកាយ ការដឹងផស្សៈនោះ បានដល់ ការដឹងផស្សៈក្នុងការស្ទាបអង្អែលដោយកាយ ។ ព្រោះដូច្នោះ ភិក្ខុណា មានសេចក្តីសម្គាល់ថាជាស្រីដោយតម្រេកក្នុងការស្ទាបអង្អែលដោយកាយ គិតថា នឹងចាប់វត្ថុដែលជាប់ដោយកាយសូម្បីភ្លាត់ទៅចាប់កាយ ភិក្ខុនោះត្រូវសង្ឃាទិសេស ជាទោសធ្ងន់ពិត ឯភិក្ខុក្រៅអំពីនេះ ត្រូវអាបត្តិថុល្លច្ច័យដូច្នេះឯង ។

ចំណែកព្រះមហាបទុមត្ថេរពោលថា កាលការសម្គាល់ខុសទៅ និងការចាប់ក៏ភ្លាត់ទៅ អាបត្តិធ្ងន់ក្នុងនិទ្ទេសតាមដែលទ្រង់អធិប្បាយទុក រមែងមិនប្រាកដក្នុងការចាប់នោះ ។

លទ្ធិរបស់លោកមានដូច្នេះថា ពិតហើយ លោកកាត់អាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលមានសេចក្តីសម្គាល់ក្នុងមនុស្សស្រី ថាជាស្រី តែសេចក្តីសម្គាល់ថាជាស្រី ភិក្ខុនេះឲ្យឃ្លាតបង់ ការសម្គាល់ក្នុងវត្ថុជាប់កាយ ថាជាវត្ថុជាប់កាយ ដែលភិក្ខុឲ្យកើតឡើងហើយ កាលលោកចាប់វត្ថុជាប់កាយនោះ លោកកាត់អាបត្តិថុល្លច្ច័យ ។

ម្យ៉ាងទៀត ការចាប់នោះ ភិក្ខុនេះក៏ឲ្យឃ្លាតបង់ លោកមិនបានចាប់របស់ទាក់ទងដោយកាយនោះ តែបានចាប់មនុស្សស្រី ព្រោះដូច្នោះ សង្ឃាទិសេស ឈ្មោះថា មិនប្រាកដក្នុងការចាប់នេះ ព្រោះមិនមានសេចក្តីសម្គាល់ថាជាស្រី អាបត្តិថុល្លច្ច័យក៏មិនប្រាកដ ព្រោះរបស់ដែលជាប់កាយ ភិក្ខុក៏មិនបានចាប់ តែកាត់អាបត្តិទុក្កដ ព្រោះភិក្ខុពាល់ត្រូវដោយកាយសំសគ្គរាគៈ ពិតហើយ កាលពាល់ត្រូវវត្ថុដូច្នេះ ដោយកាយសំសគ្គរាគៈ ពាក្យថា អនាបត្តិ មិនមាន ព្រោះដូច្នោះ ទើបត្រូវអាបត្តិទុក្កដពិត ។

ឯព្រះមហាបទុមត្ថេរ កាលពោលពាក្យនេះហើយ ទើបពោលចតុក្កៈនេះថា ភិក្ខុគិតថា នឹងចាប់រូបដោយមានតម្រេក ហើយចាប់រូបដោយមានតម្រេក ត្រូវអាបត្តិសង្ឃាទិសេស គិតថា នឹងចាប់រូបដោយប្រាសចាកតម្រេក ហើយចាប់រូបដោយប្រាសចាកតម្រេក ត្រូវអាបត្តិទុក្កដ ។ គិតថា នឹងចាប់រូបដោយមានតម្រេក បែរជាទៅចាប់រូបដោយប្រាសចាកតម្រេក ត្រូវអាបត្តិទុក្កដ ។ គិតថា ចាប់រូបដោយប្រាសចាកតម្រេក បែរជាទៅចាប់រូបដោយមានតម្រេក ត្រូវអាបត្តិទុក្កដដូចគ្នា ។

ព្រះមហាបទុមត្ថេរពោលយ៉ាងនេះក៏ពិត សូម្បីយ៉ាងនោះ ក្នុងវាទៈនៃព្រះថេរៈទាំងពីរនេះ វាទៈរបស់ព្រះមហាសុមត្ថេរប៉ុណ្ណោះ រមែងសមនឹងព្រះបាលីថា មនុស្សស្រី ១ ភិក្ខុមានសេចក្ដីសម្គាល់ថាជាស្រី ១ មានសេចក្ដីត្រេកអរ ១ ស្ទាប អង្អែល ចាប់ ពាល់ត្រូវនូវរបស់ដែលជាប់នឹងកាយរបស់ស្រីដោយកាយ ត្រូវអាបត្តិថុល្លច្ច័យ និងដោយវិនិច្ឆ័យក្នុងអដ្ឋកថាជាដើមថា ភិក្ខុណា យកដៃទាំងពីររួមចាប់ស្រីច្រើននាក់ដែលឈររួមគ្នា ភិក្ខុនោះត្រូវសង្ឃាទិសេស ស្មើនឹងចំនួនស្រីដែលខ្លួនពាល់ត្រូវ ដូច្នោះ ។

បើការចាប់ ឈ្មោះថា ឃៀងឃាតទៅ ដោយការឃៀងឃាតនៃសញ្ញាជាដើមគប្បីមានសោត ព្រះដ៏មានព្រះភាគ គប្បីត្រាស់ការប្ដូកគ្នានៃបាលីដោយន័យជាដើមថា **កាយបដិពទ្ធញ្ច ហោតិ កាយសញ្ញី ច** ដូច្នេះខ្លះ ដូចត្រាស់ក្នុងបាលីជាដើមថា **បណ្ឌកោ ច ហោតិ ឥត្ថីសញ្ញី** ដូច្នេះ ។ ព្រោះការប្ដូកគ្នានោះ ព្រះមានព្រះភាគមិនត្រាស់ឡើយ ដូច្នោះ ការកើតតាមវត្ថុថា កាលមានសេចក្ដីសម្គាល់ក្នុងមនុស្សស្រី ថាជាមនុស្សស្រី ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលពាល់ត្រូវមនុស្សស្រី ត្រូវអាបត្តិថុល្លច្ច័យដល់ភិក្ខុដែលពាល់ត្រូវរបស់ដែលជាប់កាយ ដូច្នេះប៉ុណ្ណោះ រមែងត្រឹមត្រូវ ។

ពិតហើយ ក្នុងមហាបច្ចរីពោលថា កាលស្រីខ្មៅដណ្ដប់សំពត់ពណ៌ខៀវដេក ភិក្ខុគិតថា នឹងស្ទាបកាយ ហើយស្ទាបកាយ ត្រូវសង្ឃាទិសេស គិតថា នឹងស្ទាបកាយ ហើយស្ទាបសំពត់ពណ៌ខៀវ ត្រូវថុល្លច្ច័យ គិតថា នឹងស្ទាប់សំពត់ពណ៌ខៀវ ហើយស្ទាបសំពត់ពណ៌ខៀវ ត្រូវថុល្លច្ច័យ ។

[ ៨២ ] ឯវត្ថុមិស្សកន័យ ដែលព្រះមានព្រះភាគត្រាស់ដោយន័យមានពាក្យថា **ឥត្ថី ច បណ្ឌកោ ច** ជាដើម ក្នុងមិស្សកវត្ថុនោះ អាបត្តិទាំង-ឡាយដែលព្រះអង្គត្រាស់ដោយអំណាចការសម្គាល់ និងការសម្គាល់ខុសក្នុងវត្ថុដែលបុគ្គលមិនវង្វេងក្នុងព្រះបាលីគប្បីជ្រាប ។

[ ៨៣ ] ឯក្នុងវារៈពោលដោយវត្ថុជាប់កាយនិងកាយ កាលភិក្ខុមានការសម្គាល់ក្នុងមនុស្សស្រី ថាមនុស្សស្រី ហើយចាប់របស់ជាប់កាយ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងវត្ថុដ៏សេស ត្រូវអាបត្តិទុក្កដគ្រប់ៗ បទ សូម្បីក្នុងវារៈពោលដោយកាយ និងរបស់ជាប់កាយ ក៏មានន័យដូចគ្នានេះ ។ ក្នុងវារៈពោលដោយរបស់ជាប់កាយ និងរបស់ជាប់កាយ និងក្នុងវារៈទាំងឡាយ មានវារៈពោលដោយកាយ និងនិស្សគ្គិយវត្ថុជាដើម គង់ជាអាបត្តិទុក្កដដល់ភិក្ខុនោះ ដូចគ្នាគ្រប់ៗ បទ ។

[ ៨៤ ] វារៈជាដើមថា **ឥត្ថី ច ហោតិ ឥត្ថីសញ្ញី សារត្តោ ច ឥត្ថី ច នំ ភិក្ខុស្ស កាយេន កាយំ** ព្រះដ៏មានព្រះភាគត្រាស់ដោយអំណាចនៃតម្រេកខ្លាំងរបស់មាតុគ្រាមក្នុងភិក្ខុ ។

បណ្តាបទទាំងនោះ ប្រើនបទថា **ឥត្ថី ច នំ ភិក្ខុស្ស កាយេន កាយំ** សេចក្តីថា ស្រីជាអ្នកមានតម្រេកខ្លាំងក្នុងភិក្ខុ ទើបទៅកាន់ឱកាស ដែលភិក្ខុអង្គុយ ឬដេក ហើយចាប់កាយរបស់ភិក្ខុនោះ ដោយកាយរបស់ខ្លួន ។

ពាក្យថា **សេវនាធិប្បាយោ កាយេន វាយមតិ ផស្សំ បដិវិជានាតិ** សេចក្តីថា ភិក្ខុដែលស្រីនោះចាប់ពាល់ហើយ ឬពាល់ត្រូវយ៉ាងនោះហើយ

ជាអ្នកមានបំណងក្នុងការសេព បើអង្រួន ឬករម្រើកកាយស្ទាបអង្អែល ដើម្បីដឹងផស្សៈ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ។

ត្រូវអាបត្តិសង្ឃាទិសេស ២ ក្នុងបទថា ស្រី ២ នាក់ ។ ក្នុងស្រី និងខ្ទើយ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។ ដោយឧបាយនេះ ពាក្យថា មនុស្សស្រីប៉ះពាល់និស្សគ្គិយវត្ថុ ភិក្ខុមានបំណងក្នុងការសេព ព្យាយាមដោយកាយ តែមិនដឹងផស្សៈ ត្រូវអាបត្តិទុក្កដ ដូច្នេះ នៅមានជាបណាប្រភេទរបស់អាបត្តិ គប្បីជ្រាបតាមន័យមុននោះឯងជាបនោះ ។

ឯក្នុងពាក្យថា **កាយេន វាយមតិ ន ច ផស្សំ បដិវិជានាតិ** សេចក្តីថា ភិក្ខុឃើញស្រីគ្រវែងផ្កា ឬផ្លែឈើដែលខ្លួនគ្រវែងទៅ ដោយផ្កា ឬផ្លែឈើសម្រាប់គ្រវែងរបស់នាង ទើបធ្វើកាយវិការ ឬផ្ទាត់ម្រាមដៃ ឬញាក់ចិញ្ចើម ឬប៉ប្រិចភ្នែក ឬធ្វើកាយវិការបែបនោះដទៃទៀត ភិក្ខុនេះ ហៅថា ព្យាយាមដោយកាយ តែមិនដឹងផស្សៈ ។ ភិក្ខុនេះឈ្មោះថា ត្រូវអាបត្តិទុក្កដ ព្រោះមានសេចក្តីព្យាយាមដោយកាយ ស្រី ២ នាក់ ត្រូវអាបត្តិទុក្កដ ២ ខ្ទើយ និងស្រី ត្រូវអាបត្តិទុក្កដ ២ ដូចគ្នា ។

[ ៨៥ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃអាបត្តិដោយពិស្តារដោយអំណាចនៃវត្ថុយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សម្តែងអាបត្តិ និងអនាបត្តិដោយសង្ខេប ដោយអំណាចលក្ខណៈ ទើបត្រាស់ពាក្យថា **សេវនាធិប្បាយោ** ជាដើម ។

បណ្តាន័យទាំងនោះ ន័យទី ១ ជាសង្ឃាទិសេស ព្រោះគ្រប់អង្គ ៣

គឺភិក្ខុអ្នកដែលស្រីប៉ះពាល់មាន ១ មានបំណងក្នុងការសេព ព្យាយាមដោយកាយ ១ ដឹងផស្សៈ ១ ។ ន័យទី ២ ត្រូវអាបត្តិទុក្កដ ដោយគ្រប់អង្គ ២ គឺព្រោះព្យាយាមក្នុងការប៉ះពាល់និស្សគ្គិយវត្ថុ ដោយនិស្សគ្គិយវត្ថុ ១ ព្រោះមិនដឹងផស្សៈដូចក្នុងការមិនពាល់ត្រូវ ១ ។ ន័យទី ៣ មិនត្រូវអាបត្តិដល់ភិក្ខុដែលមិនព្យាយាមដោយកាយ ។

ពិតហើយ ភិក្ខុណា មានបំណងនឹងសេព តែមានការអង្គុយស្ងៀមដឹង គឺត្រេកអរ សោយផស្សៈតែម្យ៉ាង មិនត្រូវអាបត្តិដល់ភិក្ខុនោះ ព្រោះអាបត្តិមិនមានដោយគ្រាន់តែការកើតឡើងនៃចិត្ត ។

ចំណែកន័យទី ៤ ការដឹងផស្សៈមិនមាន ដូចក្នុងការប៉ះពាល់និស្សគ្គិយ-វត្ថុដោយនិស្សគ្គិយវត្ថុ មានត្រឹមតែចិត្តុប្បាទតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះទើបមិនត្រូវអាបត្តិ ។ អាបត្តិមិនមាន ដោយអាការទាំងពួងរបស់ភិក្ខុ ដែលបំណងដោះខ្លួនឲ្យរួច ។

ឯក្នុងឋានៈនេះ គប្បីជ្រាបអធិប្បាយថា ភិក្ខុណាត្រូវស្រីចាប់ ប្រាថ្នានឹងឲ្យស្រីនោះផុតអំពីសរីរៈរបស់ខ្លួន ទើបច្រានក្តី វាយក្តី ភិក្ខុនេះ ឈ្មោះថាព្យាយាមដោយកាយ ដឹងផស្សៈ ។ ភិក្ខុណាឃើញស្រីកំពុងមក ប្រាថ្នានឹងរួចខ្លួនអំពីស្រីនោះ ទើបសម្គុតឲ្យគេចទៅ ភិក្ខុនេះឈ្មោះថា ព្យាយាមដោយកាយ តែមិនដឹងផស្សៈ ។ ភិក្ខុណាឃើញពស់លូនឡើងលើកាយ តែមិនរលាស់ ដោយគិតថា ឯងចូរទៅចុះ ពស់ត្រូវអាត្មាអញរលាស់ គប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ឬថា ស្រីនោះឯងត្រូវខ្លួនព្រងើយកន្តើយ ធ្វើមិនដឹង

ដោយគិតថា ស្រីនេះដឹងថា ភិក្ខុនេះមិនត្រូវការអញ នឹងចៀសចេញទៅឯង ឬ ភិក្ខុកំលោះត្រូវស្រីមានកម្លាំងឱបទុកយ៉ាងណែន សូម្បីចង់គេច តែត្រូវស្នៀម ព្រោះត្រូវទាញទុកយ៉ាងមាំ ភិក្ខុនេះឈ្មោះថា មិនបានព្យាយាមដោយកាយ តែដឹងផស្សៈ ។ ចំណែកភិក្ខុណា ឃើញស្រីដើរមក ហើយជាអ្នកព្រងើយ កន្តើយ ដោយគិតថា នាងចូរមកសិនចុះ អញនឹងវាយ ប្រានស្រីនោះ ហើយ ចៀសចេញទៅអំពីនោះ ភិក្ខុនេះ គប្បីជ្រាបថា មានបំណងនឹង រួចផុត មិន ព្យាយាមដោយកាយ មិនដឹងផស្សៈ ។

[ ៨៦ ] បទថា **អសញ្ចិច្ច** សេចក្តីថា មិនក្លែងថា អញនឹងប៉ះពាល់ ស្រីម្នាក់នេះ ដោយឧបាយនេះ ។ ពិតហើយ ព្រោះមិនក្លែងយ៉ាងនោះ កាលភិក្ខុមិនប៉ះពាល់ខ្លួនមាតុគ្រាមក្នុងគ្រាដែលទទួលបាត្រជាដើម រមែងមិន ត្រូវអាបត្តិ ។

បទថា **អសតិយា** សេចក្តីថា ភិក្ខុជាអ្នកបញ្ជូនចិត្តទៅក្នុងទីដទៃ គឺ មិនមានការគិតថា អញនឹងប៉ះពាល់មាតុគ្រាម ព្រោះមិនមានសតិយ៉ាងនេះ មិនត្រូវអាបត្តិដល់ភិក្ខុ ដែលប៉ះពាល់ក្នុងវេលាលាតដៃ និងជើងជាដើម ។

បទថា **អជានន្តស្ស** សេចក្តីថា ភិក្ខុឃើញកុមារី មានភេទដូចកុមារ មិនដឹងថា ជាក្មេងស្រី ប៉ះពាល់ដោយករណីយកិច្ចឯណាមួយប៉ុណ្ណោះ មិនត្រូវ អាបត្តិដល់ភិក្ខុដែលមិនដឹងថាជាស្រី ហើយប៉ះពាល់ដោយអាការយ៉ាងនេះ ។

បទថា **អសាទិយន្តស្ស** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលមិន ត្រេកអរក្នុងការស្ទាបអង្អែលដោយកាយ ដូចអាបត្តិមិនត្រូវដល់ភិក្ខុដែលត្រូវ

ស្រីចាប់ដើមដៃគ្នានិងគ្នា ហ៊ុមព័ទ្ធនាំយកទៅដូច្នោះ កិក្ខុច្ចតជាដើម មានន័យដូចពោលហើយនោះឯង ។ ហើយព្រះឧទាយិត្ថេរ ជាអាទិកម្មិកក្នុងសិក្ខាបទនេះ មិនត្រូវអាបត្តិដល់លោក ដែលជាអាទិកម្មិកនោះដូច្នេះឯង ។

បណ្តាសមុដ្ឋានជាដើមក្នុងសិក្ខាបទនេះ មានសមុដ្ឋានដូចបឋមបារាជិកសិក្ខាបទ រមែងកើតតាមផ្លូវកាយ និងចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម អកុសលចិត្ត មានវេទនា ២ ដោយជាសុខវេទនា និងឧបេក្ខាវេទនាទាំង ២ ដូច្នេះ ។

បទភាជនីយ៍នៃកាយសំសគ្គសិក្ខាបទ ចប់

# អធិប្បាយ
# វិធីតវត្តក្នុងកាយសំសគ្គសិក្ខាបទ

[ ៨៨ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិធីតវត្តដូចតទៅនេះ ពីរបទថា **មាតុយា មាតុបេម្មេន** សេចក្តីថា រមែងប៉ះពាល់កាយរបស់មាតា ដោយសេចក្តីស្រឡាញ់ថាមាតា ។ ក្នុងរឿងកូនស្រី និងបងប្អូនស្រី ក៏មានន័យនេះដូចគ្នា ក្នុងព្រះបាលីនោះ ព្រះដ៏មានព្រះភាគកាត់អាបត្តិទុក្កដដូចគ្នាទាំងអស់ ដល់ភិក្ខុដែលចាប់ពាល់ ដោយការស្រឡាញ់អាស្រ័យផ្ទះថា បុគ្គលនេះជាម្តាយរបស់អញ នេះជាកូនស្រីរបស់អញ នេះជាបងប្អូនស្រីរបស់អញ ព្រោះដែលឈ្មោះថា មនុស្សស្រីសូម្បីទាំងអស់ ទោះជាមាតាក្តី ធីតាក្តី ជាសត្រូវដល់ព្រហ្មចរិយៈទាំងអស់ ។ កាលភិក្ខុរឭកដល់អាជ្ញានេះរបស់ព្រះដ៏មានព្រះភាគ សូម្បីឃើញមាតា ត្រូវខ្សែទឹកកួចទៅ មិនគួរចាប់ពាល់ដោយដៃឡើយ ។ តែភិក្ខុអ្នកឈ្លាសវៃ គប្បីនាំទូក ឬបន្ទះក្តារ ឬដើមចេក ឬកំណាត់ឈើចូលទៅឲ្យ បើទូកជាដើមមិនមាន សូម្បីសំពត់កាសាវៈនាំទៅដាក់ខាងមុខ តែមិនគួរពោលថា ចូរចាប់ទីនេះ ។ កាលលោកចាប់ហើយ គប្បីស្រាវមក ដោយធ្វើក្នុងចិត្តថា អញទាញបរិក្ខារមក ។ បើម្តាយភ័យ គប្បីហែលទៅខាងមុខហើយលួងលោមថា កុំភ័យ បើមាតាត្រូវទឹកកួចទៅ ប្រញាប់ប្រញាល់ឱបក ឬចាប់ត្រង់ដៃរបស់ភិក្ខុជាកូន ភិក្ខុកុំគប្បីរលាស់ ដោយពោលថា ចៀសចេញទៅ ស្រីចាស់ គប្បីបញ្ជូនទៅឲ្យដល់គោក ។ កាលមាតាជាប់ក្នុងរណ្តៅក្តី ធ្លាក់ក្នុងអណ្តូងក្តី មានន័យនេះដូចគ្នា អធិប្បាយថា ភិក្ខុគប្បីទាញឡើង តែកុំគប្បីចាប់ពាល់ឡើយ ។

# អធិប្បាយ អនាមាសវត្ថុ

មិនមែនតែរាងកាយរបស់មាតុគ្រាម តែម្យ៉ាងប៉ុណ្ណោះទេ ជាអនាមាសនោះ សូម្បីសំពត់ស្លៀក និងសំពត់ដណ្តប់ក្តី របស់របរគ្រឿងប្រដាប់ក្តី រហូតដល់កម្រងស្មៅក្តី ចិញ្ចៀនស្លឹកត្នោតក្តី ជាអនាមាសវត្ថុទាំងអស់ ។ ឯសំពត់ស្លៀក និងសំពត់ដណ្តប់នោះ តាំងទុកដើម្បីប្រើជាគ្រឿងប្រដាប់ប៉ុណ្ណោះ ។ បើមាតុគ្រាមដាក់សំពត់ស្លៀក ឬសំពត់ដណ្តប់ទុកក្នុងទីជិតជើងដើម្បីឲ្យប្តូរជាចីវរ សំពត់នោះ រមែងគួរ ។ បណ្តាគ្រឿងប្រដាប់ ភណ្ឌៈដែលជាកប្បិយៈ មានគ្រឿងប្រដាប់ក្បាលជាដើម ដែលមាតុគ្រាមប្រគេនថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់មេត្តាទទួលរបស់នេះចុះ ភិក្ខុគួរទទួលដើម្បីជាគ្រឿងប្រើប្រាស់ មានស្រោមកំបិតកោរ និងបំពង់ម្ជុលជាដើម ឯភណ្ឌៈដែលធ្វើដោយមាស ប្រាក់ និងកែវមុក្តាជាដើម ជាអនាមាសពិត សូម្បីគេប្រគេន ក៏មិនគួរទទួល ។

ម្យ៉ាងទៀត មិនមែនតែគ្រឿងតាក់តែងកាយ ដែលស្លៀកដណ្តប់រាងកាយរបស់ស្រីតែម្យ៉ាងប៉ុណ្ណោះទេ ដែលជាអនាមាសនោះ សូម្បីរូបធ្វើអំពីឈើក្តី ភ្លុកក្តី ដែកក្តី គជ់ក្តី រូបគំនូរក្តី រូបដែលសម្រេចដោយរតនៈគ្រប់យ៉ាងក្តី ដែលគេធ្វើរូបរាងសណ្ឋាននៃមនុស្សស្រី ដោយហោច សូម្បីរូបដែលសូនដោយម្សៅ ក៏ជាអនាមាសទាំងអស់ ។ បើបានរបស់ដែលគេប្រគេនថា របស់នេះសូមជារបស់លោកម្ចាស់ចុះ វៀររបស់ដែលសម្រេចដោយរតនៈគ្រប់យ៉ាង ទម្លាយរូបដ៏សេស បង្អោនយកវត្ថុដែលគួរ ជាគ្រឿងឧបករណ៍ចូលក្នុងគ្រឿងឧបករណ៍ និងវត្ថុដែលគួរប្រើប្រាស់ចូលក្នុងវត្ថុសម្រាប់ប្រើ

ប្រាស់ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ គួរ ។

ម្យ៉ាងទៀត សូម្បីធញ្ញជាតិ ៧ ប្រការ ក៏ជាអនាមាសដូចគ្នានឹងរូបស្រ្តី ដូច្នោះ ។ ព្រោះដូច្នោះ កាលដើរទៅកណ្តាលវាលស្រែ កុំដើរចាប់ពាល់គ្រាប់ធញ្ញជាតិដែលកើតនៅក្នុងស្រែនោះបណ្តើរៗ ទៅឡើយ ។ បើមានធញ្ញជាតិដែលគេហាលត្រង់ទ្វារផ្ទះ ឬត្រង់ផ្លូវដើរ បើខាងៗ មានផ្លូវដើរ កុំដើរជាន់ទៅឡើយ ។ បើមិនមានផ្លូវដើរ គប្បីអធិដ្ឋានឲ្យជាផ្លូវ ហើយដើរទៅចុះ ។ មនុស្សទាំងឡាយក្រាលអាសនៈលើគំនរធញ្ញជាតិក្នុងចន្លោះស្រុក ទោះអង្គុយក៏គួរ ។ ជនពួកខ្លះចាក់ធញ្ញជាតិគរទុកក្នុងរោងឆាន់ បើអាចឲ្យនាំចេញបានក៏គប្បីឲ្យនាំចេញ បើមិនអាច កុំជាន់ធញ្ញជាតិ គប្បីតាំងនៅក្នុងចំណែកម្ខាង ហើយអង្គុយចុះ ។ បើមិនមានឱកាស ពួកអ្នកស្រុកក្រាលអាសនៈប្រគេនត្រង់កណ្តាលធញ្ញជាតិនោះឯង គប្បីអង្គុយចុះ ។ សូម្បីក្នុងធញ្ញជាតិដែលមាននៅលើទូក ក៏មានន័យយ៉ាងនេះដូចគ្នា ។ សូម្បីអបរណ្ណជាតិ មានសណ្តែកបាយ និងសណ្តែករាជមាសជាដើមក្តី ផ្លែឈើ មានត្នោត និងខ្នុរជាដើមក្តី ដែលកើតក្នុងទីនោះ ភិក្ខុមិនគួរចាប់លេង ។ សូម្បីក្នុងអបរណ្ណជាតិនិងផ្លែឈើ ដែលអ្នកស្រុកគរជាគំនរទុក ក៏មានន័យនេះដូចគ្នា ។ តែការដែលភិក្ខុកាន់យកផ្លែឈើដែលជ្រុះអំពីដើមក្នុងព្រៃ ដោយតាំងចិត្តថា នឹងឲ្យដល់ពួកអនុបសម្បន្ន គួរ ។

បណ្តារតនៈ ១០ ប្រការទាំងនេះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ សង្ខ សិលា កែវពពាល ប្រាក់ មាស កន្ទឹម កែវមកិត កែវមុក្តាធម្មជាតិ

ដែលមិនបានច្នៃ និងចោះ ភិក្ខុចាប់ពាល់ក៏បាន ។ អាចារ្យពួកខ្លះពោលថា រតនៈដ៏សេសជាអនាមាស ។ តែក្នុងមហាបច្ចរីពោលថា កែវមុក្តាដែលច្នៃហើយក្តី ដែលមិនទាន់ច្នៃក្តី ជាអនាមាស ភិក្ខុទទួលដើម្បីប្រយោជន៍ ដើម្បីជាមូលតម្លៃនៃទ្រព្យ រមែងមិនគួរ តែនឹងទទួលដើម្បីជាថ្នាំដល់បុគ្គលមានរោគឃ្លង់ គួរ ។ កែវមណីប្រភេទពណ៌ខៀវ និងលឿងជាដើមទាំងអស់ដោយហោច សូម្បីកែវផលិកធម្មជាតិដែលគេខាត់ច្នៃ និងក្រឡឹងហើយ ជាអនាមាស តែកែវមណីតាមធម្មជាតិ ដែលផុតចាកអណ្តូងកើត លោកពោលថា ភិក្ខុនឹងទទួលយកទុកដើម្បីជាមូលតម្លៃនៃទ្រព្យ មានបាត្រជាដើម ក៏គួរសូម្បីកែវមណីនោះ លោកហាមទុកក្នុងមហាបច្ចរី កញ្ចក់កែវដែលគេរចនាធ្វើទុកតែម្យ៉ាងប៉ុណ្ណោះ លោកពោលថា គួរ ។ សូម្បីក្នុងកែវពិទូរ្យក៏មានវិនិច្ឆ័យដូចគ្នានឹងកែវមណីដែរ ។

ស័ង្ខ ទោះជាស័ង្ខសម្រាប់ផ្លុំក្តី ស័ង្ខដែលគេខាត់ និងច្នៃហើយក្តីប្រដាប់ដោយរតនៈក្តី ជាអនាមាស ។ ស័ង្ខសម្រាប់ដងទឹកផឹក ដែលគេខាត់ហើយក្តី មិនទាន់ខាត់ក្តី ជារបស់គួរចាប់ពាល់បានពិត ។ ម្យ៉ាងទៀត រតនៈដ៏សេស ភិក្ខុទទួលដើម្បីប្រើជាថ្នាំបន្តក់ភ្នែកជាដើមក្តី ដើម្បីជាមូលតម្លៃនៃរបស់ក្តី គួរ ។

សិលា ដែលខាត់ និងច្នៃហើយ ប្រដាប់ដោយរតនៈ មានពណ៌ដូចសណ្តែកបាយប៉ុណ្ណោះ ជាអនាមាស ។ សិលាដ៏សេស ភិក្ខុកាន់យកមកដើម្បីប្រើជាថ្មសំលៀងកាំបិតក៏បាន ។ ក្នុងពាក្យនេះ អាចារ្យពួកខ្លះពោលថា

បទថា **រតនសំយុត្តា** បានដល់ សិលាដែលរំលាយផ្សំគ្នាជាមួយមាស ។

កែវពពាល ដែលខាត់ និងច្នៃហើយ ជាអនាមាស ។ កែវពពាលដ៏សេស ជាអាមាស ( គួរចាប់ពាល់បាន ) ហើយភិក្ខុគួរទទួលដើម្បីចាយជាមូលតម្លៃនៃទ្រព្យ គួរ ។ តែក្នុងមហាបច្ចរីពោលថា កែវពពាលដែលខាត់ហើយក្តី មិនទាន់ខាត់ក្តី ជាអនាមាសទាំងអស់ នឹងទទួល មិនគួរ ។

មាស និងប្រាក់ សូម្បីគេធ្វើជារូបរាងគ្រប់យ៉ាង ជាអនាមាស ជាវត្ថុមិនគួរទទួល ចាប់តាំងអំពីនៅជារ៉ែ ។ បានឮថា ឧត្តរាជឱរសឲ្យសាងព្រះចេតិយមាស បញ្ជូនទៅប្រគេនព្រះមហាបទុមត្ថេរ ។ ព្រះថេរៈឃាត់ថា មិនគួរ ។ ផ្កាឈូកមាស និងផ្កាយមាសជាដើមមាននៅក្នុងខឿនព្រះចេតិយ សូម្បីវត្ថុនោះ ក៏ជាអនាមាស តែភិក្ខុដែលថែរក្សាខឿនចេតិយ តាំងនៅក្នុងឋានៈជាអ្នកចោលរូបិយៈ ព្រោះហេតុនោះ ទើបលោកពោលថា ភិក្ខុទាំងនោះនឹងស្ទាបអង្អែលមើល ក៏គួរ ។ តែពាក្យនោះលោកហាមទុកក្នុងកុរុន្ទី លោកអនុញ្ញាតត្រឹមតែប៉ុណ្ណេះថា នឹងជម្រះស្មឹមត្រង់ព្រះចេតិយមាស គួរ ។ លោកពោលក្នុងអដ្ឋកថាទាំងពួងថា សូម្បីលោហៈដែលកាឡៃជាមាស ក៏មានគតិដូចមាសដូចគ្នា ចាត់ជាអនាមាស ។ ចំណែកគ្រឿងប្រើប្រាស់ក្នុងសេនាសនៈជាកប្បិយៈទាំងអស់ ព្រោះដូច្នោះ គ្រឿងបរិក្ខារប្រចាំសេនាសនៈគ្រប់យ៉ាងដែលធ្វើដោយមាស និងប្រាក់ ជាអាមាស ។ ពួកអ្នកសាងមណ្ឌបកែវ ជាស្ថានទីសម្តែងធម្មវិន័យដល់ភិក្ខុទាំងឡាយ មានសសរកែវផលិក ប្រដាប់តាក់តែង ដោយកម្រងកែវ ។ ភិក្ខុទាំងឡាយ ថែរក្សាគ្រឿងឧបករណ៍ទាំង

អស់ ក្នុងរតនមណ្ឌបនោះ គួរ ។

ទទឹម និងមក៌ត ដែលខាត់ និងច្នៃហើយ ជាអនាមាស ដែលមិនទាន់បានខាត់ និងច្នៃក្រៅអំពីនេះ លោកពោលថា ជាអាមាស ភិក្ខុទោះទទួលទុកដើម្បីប្រើជាមូលតម្លៃនៃរបស់ គួរ ។ តែក្នុងមហាបច្ចរីពោលថា ទទឹម និងមក៌ត ដែលខាត់ហើយក្តី មិនទាន់ខាត់ក្តី ជាអនាមាសដោយប្រការគ្រប់យ៉ាង ភិក្ខុទទួលទុក មិនគួរ ។

គ្រឿងអាវុធគ្រប់ប្រភេទ ជាអនាមាស សូម្បីគេប្រគេនដើម្បីប្រយោជន៍ចំណាយជាមូលតម្លៃនៃទ្រព្យ ក៏មិនគួរទទួលទុក ឈ្មោះថា ការលក់សស្ត្រាវមែងមិនគួរ ។ សូម្បីដងផ្កាស្ទូក្តី ខ្សែធ្នូក្តី ជន្ទញក្តី កន្ត្រៃដីរក្តី ដោយហោចសូម្បីកាំបិត និងពូថៅជាដើម ដែលគេធ្វើដោយសន្ទេប ជាអាវុធ ក៏ជាអនាមាស ។ បើមានបុគ្គលណាមួយយកលំពែង ឬស្នមកទុកក្នុងវិហារ កាលនឹងបោសប្រាសវិហារ គប្បីឲ្យដំណឹងដល់ពួកម្ចាស់របស់ថា ចូរនាំយកទៅចុះ បើម្ចាស់របស់មិននាំយកទៅ កុំឲ្យរបស់នោះកម្រើក គប្បីជម្រះវិហារចុះ ភិក្ខុឃើញដាវ លំពែងក្តី ស្នក្តី ធ្លាក់នៅក្នុងលានចម្បាំង គប្បីយកថ្ម ឬវត្ថុណាមួយដំចេញហើយ កាន់យកទៅដើម្បីធ្វើជាកាំបិត គួរ ។ ភិក្ខុទោះបំបែកសូម្បីរបស់ក្រៅអំពីនេះហើយ កាន់យករបស់ឯណាមួយ ដើម្បីធ្វើជាកាំបិតរបស់ខ្លះទៀតដើម្បីប្រើជាឈើច្រត់ជាដើម គួរ ។ ចំណែកគ្រឿងអាវុធដែលគេប្រគេនថា សូមលោកម្ចាស់ទទួលអាវុធនេះចុះ ភិក្ខុទោះទទួលទាំងអស់ដោយតាំងចិត្តថា អញនឹងកម្ទេច ហើយធ្វើឲ្យជាកប្បិយភណ្ឌ ដូច្នេះ គួរ ។

គ្រឿងចាប់សត្វ មានសំណាញ់បង់ត្រី និងសំណាញ់ដាក់បក្សីជាដើមក្តី គ្រឿងការពារព្រួញ មានខែល និងសំណាញ់ជាដើមក្តី ជាអានាមាសគ្រប់យ៉ាង ។ បណ្តាគ្រឿងដាក់សត្វ និងគ្រឿងការពារព្រួញ ដែលបានមកដើម្បីជាគ្រឿងប្រើប្រាស់ ដំបូងសំណាញ់ ភិក្ខុនឹងកាន់យកដោយតាំងចិត្តថា អញនឹងចងសន្ទឹងទុក ឬរុំជាឆត្រទុកខាងលើនៃអាសនៈ ឬព្រះចេតិយ គួរ ។ គ្រឿងការពារព្រួញទាំងអស់ ភិក្ខុទទួលទុកដើម្បីប្រើជាមូលតម្លៃនៃទ្រព្យ ក៏សមគួរ ។ ព្រោះថា គ្រឿងការពារព្រួញនោះ ជាគ្រឿងការពារការបៀតបៀតអំពីអ្នកដទៃ មិនមែនជាគ្រឿងធ្វើការបៀតបៀនឡើយ ដូច្នេះឯង ។ ទោះបីទទួលខែល ដោយតាំងចិត្តថា អញនឹងធ្វើជាភាជនៈដាក់ឈើស្ទន់ដូច្នេះ ក៏គួរ ។

គ្រឿងតន្ត្រី មានពិណ និងស្គរជាដើម ដែលពាសដោយស្បែក ជាអនាមាស ។ តែក្នុងកុរុន្ទីពោលថា តួស្គរក្តី តួពិណក្តី ស្នូកទទេក្តី ស្បែកដែលគេបិទទុកត្រង់កណ្តាប់មាត់ក្តី ដងពិណក្តី ជាអនាមាសទាំងអស់ ។ ទោះភិក្ខុសន្ទឹងខ្លួនឯងក្តី ឲ្យអ្នកដទៃសន្ទឹងក្តី ប្រគំខ្លួនឯងក្តី ឲ្យគេប្រគំក្តី មិនបានទាំងអស់ ។ សូម្បីឃើញគ្រឿងតន្ត្រី ដែលពួកមនុស្សធ្វើការបូជា ហើយទុកចោលត្រង់លានព្រះចេតិយ កុំធ្វើឲ្យឃ្លាតចាកទីឡើយ គប្បីបោសទៅក្នុងចន្លោះៗ ។ តែក្នុងមហាបច្ចរីពោលថា ក្នុងវេលាចាក់សំរាម គប្បីនាំទៅដោយកំណត់ថាជាសំរាម ហើយទុកក្នុងចំណែកម្ខាង គួរ ។ ទោះជាទទួលទុកដើម្បីប្រើជាមូលតម្លៃនៃទ្រព្យ ក៏គួរ។ បើបានមកដើម្បីប្រើប្រាស់ ទោះកាន់

យកដើម្បីធ្វើឲ្យជាបរិក្ខារនោះៗ ដោយតាំងចិត្តយ៉ាងនេះថា អញនឹងធ្វើស្នូកពិណ និងត្រួស្គរ ឲ្យជាកាជនៈដាក់ឈើជម្រះធ្មេញ ស្បែកនឹងធ្វើជាស្រោមកាំបិត ហើយធ្វើតាមដែលតាំងចិត្តនោះៗ គួរ ។

[ ៨៩ ] រឿងកិរិយាចាស់ មានអត្ថជាក់ច្បាស់ហើយនោះឯង ។ គប្បីវិនិច្ឆ័យក្នុងរឿងយក្ខិនី ដូច្នេះ បើភិក្ខុដល់នូវការស្ទាបអង្អែលកាយជាមួយទេពីរបស់ស្តេចបរនិម្មិតវសវត្តី ក៏ត្រូវអាបត្តិថុល្លច្ច័យតែម្យ៉ាងប៉ុណ្ណោះ ។

រឿងខ្ទើយ និងរឿងស្រីដេកលក់ប្រាកដច្បាស់ហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងស្រីស្លាប់ ដូច្នេះថា ភិក្ខុនោះ ត្រូវអាបត្តិថុល្លច្ច័យ ក្នុងឋានៈដែលជាបារាជិកត្រូវអាបត្តិបារាជិក ក្រៅអំពីនោះទុក្កដ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសត្វតិរច្ឆាន ដូច្នេះថា ភិក្ខុស្ទាបអង្អែលកាយនាគមាណវិកាក្តី សុបណ្ណមាណវិកាក្តី កិន្នរីក្តី មេគោក្តី ត្រូវអាបត្តិទុក្កដទាំងអស់ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងរឿងរូបចម្លាក់ឈើ ដូច្នេះថា មិនមែនត្រឹមតែឈើតែម្យ៉ាងប៉ុណ្ណោះ ដោយហោចសូម្បីរូបស្រីដែលគេគូរ ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។

[ ៩០ ] ក្នុងរឿងស្រីចាប់កៀកភិក្ខុ មានអត្ថជាក់ច្បាស់ហើយ ។

[ ៩១ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងរឿងស្រីឡើងលើស្ពាន ដូច្នេះថា ស្ពានដែលមនុស្សដើរបានតែម្នាក់ក្តី ស្ពានដែលជាផ្លូវរទេះធំក្តី គ្រាន់តែភិក្ខុធ្វើប្រយោគដោយតាំងចិត្តថា អញនឹងអង្រួនស្ពាន ដូច្នេះ ទោះអង្រួនក្តី មិន

អង្រួនក្តី ត្រូវអាបត្តិទុក្កដ ។

[ ៩២ ] រឿងផ្លូវ ប្រាកដច្បាស់ហើយ ។

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងរឿងដើមឈើ ដូច្នេះថា ដើមឈើជាឈើធំ ទំហំប៉ុនដើមព្រីងធំក្តី ( ព្រីងប្រចាំទ្វីប ) ជាដើមឈើតូចក្តី ភិក្ខុអាចអង្រួនក្តី មិនអាចអង្រួនក្តី ត្រូវអាបត្តិទុក្កដ ព្រោះហេតុត្រឹមតែមានសេចក្តីព្យាយាម ។

[ ៩៤ ] ក្នុងរឿងទូក ក៏មានន័យដូច្នេះដូចគ្នា ។

[ ៩៥ ] ក្នុងរឿងខ្សែ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុអាចនឹងទាញខ្សែឲ្យឃ្លាតចាកឋានបាន ត្រូវអាបត្តិថុល្លច្ច័យ ព្រោះខ្សែនោះ ។ ខ្សែប្រភេទណាមួយ ជាខ្សែធំ រមែងមិនកម្រើកឃ្លាតចាកឋាន សូម្បីបន្តិចបន្តួច ត្រូវអាបត្តិទុក្កដ ព្រោះខ្សែនោះ ។ សូម្បីរឿងជំបង ក៏មានន័យដូចគ្នា ។ ពិតហើយ សូម្បីដើមឈើធំដែលរលំលើផែនដី ក៏ទ្រទ់កាន់យកហើយ ដោយ **ឧណ្ណា** សព្វដូចគ្នា ក្នុងរឿងជំបងនេះ ។

[ ៩៦ ] ក្នុងរឿងភិក្ខុប្រានស្រីដោយបាត្រ ប្រាកដច្បាស់ហើយ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងរឿងស្រីថ្វាយបន្ទំភិក្ខុ ដូច្នោះថា ស្រីថ្វាយបន្ទំបំណងនឹងប្របាច់ជើងទាំងពីរ ភិក្ខុគប្បីឃាត់ គប្បីបិទបាំងជើងទុក ឬគប្បីនៅស្ងៀម ។ ព្រោះថា ភិក្ខុកាលនៅស្ងៀម សូម្បីចិត្តត្រេកអរ ក៏មិនត្រូវអាបត្តិ ។ រឿងចុងក្រោយ ប្រាកដច្បាស់ហើយ ដូច្នេះ ។

កាយសំសគ្គវណ្ណនា ចប់ ដោយប្រការដូច្នេះ

# វិនយបិដក

## សង្ឃាទិសេសទី ៣

[ ៩៧ ] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតវនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯងឧទាយិភិក្ខុដ៏មានអាយុសម្រេចឥរិយាបថនៅក្នុងព្រៃ ។ គ្រានោះ មានស្រីច្រើននាក់ជាពួកអ្នកត្រូវការមើលវិហារ ហើយក៏នាំគ្នាមកកាន់អារាម ។ ស្រីទាំងនោះក៏ចូលទៅរកឧទាយិភិក្ខុដ៏មានអាយុក្នុងពេលនោះ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចម្រើនយើងទាំងឡាយចង់មើលវិហាររបស់លោកម្ចាស់ ។ លំដាប់នោះ ឧទាយិភិក្ខុដ៏មានអាយុ ក៏នាំស្រីទាំងនោះមើលវិហាររួចហើយ ពោលសរសើរខ្លះ ពោលបន្អាប់ខ្លះ សូមខ្លះ អង្វរខ្លះ សួរខ្លះ សួរតបខ្លះ ប្រាប់ខ្លះ ប្រៀនប្រដៅខ្លះ ជេរខ្លះ ចំពោះវច្ចមគ្គ និងបស្សាវមគ្គនៃស្រីទាំងនោះ ។ ស្រីណាដែលគ្មានសេចក្តីខ្មាស ជាស្រីអ្នកលេងឥតមានអៀនខ្មាស ស្រីនោះក៏ញញឹមញញែមនិយាយបញ្ចោរ សើចក្អាកក្អាយ ចំអន់ជាមួយនឹងឧទាយិភិក្ខុដ៏មានអាយុចំណែកខាងស្រីណា ដែលមានសេចក្តីអៀនខ្មាស ស្រីនោះចេញមកក៏ពោលទោសឧទាយិប្រាប់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ការនេះគ្មានលាក់បាំង គ្មានគួរសមសោះ ចុះហេតុអ្វីក៏លោកម្ចាស់ឧទាយិនិយាយយ៉ាងនេះសូម្បីដល់ទៅប្តី បើនិយាយយ៉ាងនេះ ក៏យើងទាំងឡាយមិនប្រាថ្នាដែរ ។ ភិក្ខុទាំងឡាយឯណា ដែលមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មាន

សេចក្តីអៀនខ្មាស ជាអ្នករង្កៀស ប្រាថ្នាតែខាងការរៀនសូត្រ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុអ្វី បានជាឧទាយិភិក្ខុដ៏មានអាយុពោលចង់មាតុគ្រាម ដោយសំដីអាក្រក់ ( ដូច្នោះ ) ។ កាលនោះ ភិក្ខុទាំងនោះ យកសេចក្តីនោះក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរឧទាយិភិក្ខុដ៏មានអាយុក្នុងកាលនោះថា ម្នាលឧទាយិ បានឮថា អ្នកឯងពោលចង់មាតុគ្រាម ដោយសំដីអាក្រក់មែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ( សេចក្តីនុ៎ះ ) ពិតមែន ។ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលបុរសសោះសូន្យ ដំណើរនេះមិនទំនង មិនសមគួរ មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ នែមោឃបុរស ចុះហេតុអ្វី បានជាអ្នកឯងពោលចង់មាតុគ្រាមដោយសំដីអាក្រក់ ( ដូច្នោះ ) ម្នាលមោឃបុរស ធម៌ដែលតថាគតសំដែងហើយដោយអនេកបរិយាយ ( សុទ្ធតែ ) ដើម្បីប្រាសចាកតម្រេក មិនមែនសំដែងឲ្យប្រកបដោយតម្រេកឡើយ ។ បេ។ ការរម្ងាប់សេចក្តីក្តៅក្រហាយព្រោះកាមទាំងឡាយ ក៏តថាគតសំដែងរួចអស់ហើយតើ មិនមែនឬ នែមោឃបុរស ដំណើរនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា ( នោះ ) ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះដូច្នេះថា ភិក្ខុណាមួយ គឺរាគៈគ្របសង្កត់ហើយ មានចិត្តប្រែប្រួល និយាយចង់មាតុគ្រាមដោយសំដីអាក្រក់ ដូចប្រុសកម្លោះនិយាយចង់ស្រីក្រមុំ

ដោយសំដីដែលប្រកបដោយមេថុន ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ៩៨ ] ត្រង់ពាក្យថា ណាមួយ អធិប្បាយថា ឯណាក៏ដោយ ។បេ។ ត្រង់ពាក្យថា ភិក្ខុ ។បេ។ ( ភិក្ខុដែលបានសម្រេចឧបសម្បទាដោយញត្តិ-ចតុត្ថកម្មវាចាដ៏ត្រឹមត្រូវ ) តថាគតសំដៅឲ្យឈ្មោះថា ភិក្ខុក្នុងអត្ថនេះ ។ ត្រង់ពាក្យថា គឺរាគៈគ្របសង្កត់ហើយ សេចក្តីថា ភិក្ខុដែលត្រេកអរ មានសេចក្តីអាឡោះអាល័យ មានចិត្តប្រតិព័ទ្ធ ។ ត្រង់ពាក្យថា មានចិត្តប្រែប្រួល សេចក្តីថា ចិត្តដែលត្រេកអរ ក៏ហៅថា ប្រែប្រួល ចិត្តដែលខឹង ក៏ហៅថា ប្រែប្រួល ចិត្តដែលវង្វេង ក៏ហៅថាប្រែប្រួល ប៉ុន្តែក្នុងអត្ថនេះ តថាគតសំដៅយកចិត្តដែលត្រេកអរ ឲ្យឈ្មោះថា ចិត្តប្រែប្រួល ។ មនុស្សស្រីដែលដឹងសេចក្តី ឆ្លៀវឆ្លាស អាចដឹងច្បាស់នូវពាក្យដែលគេនិយាយល្អ និងអាក្រក់ សំដីគួរ និងមិនគួរ ហៅថា មាតុគ្រាម ( ក្នុងសិក្ខាបទនេះ ) ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថា មាតុគ្រាមទេ ។ ឯសំដីដែលហៅថា អាក្រក់នោះ បានដល់សំដីដែលប្រកបដោយមេថុនធម្មចំពោះវច្ចមគ្គនិងបស្សាវមគ្គ ។ សេចក្តីប្រព្រឹត្តល្មើស តថាគតត្រាស់ហៅថា និយាយចង់ ។ ត្រង់ពាក្យថា ដូចប្រុសកម្លោះនិយាយចង់ស្រីក្រមុំ សេចក្តីថា ប្រុសកម្លោះនិយាយចង់ស្រីក្រមុំ ប្រុសជំទង់និយាយចង់ស្រីជំទង់ ប្រុសអ្នកបរិភោគកាមនិយាយចង់ស្រីអ្នកបរិភោគកាម ។ ត្រង់ពាក្យថា ដោយសំដីដែលប្រកបដោយមេថុន គឺសំដីដែលប្រកបព្រមចំពោះដោយមេថុនធម្ម ។ ត្រង់ពាក្យថា ត្រូវអាបត្តិសង្ឃាទិសេស មានអធិប្បាយពិស្តារក្នុងសង្ឃាទិសេសទី ១ រួច

ហើយ ។

[ ៩៩ ] ពោលសរសើរក្តី ពោលបង្អាប់ក្តី សូមក្តី អង្វរក្តី សួរក្តី សួរបញ្ជាក់ក្តី ប្រាប់ក្តី ប្រៀនប្រដៅក្តី ជេរក្តី ចំពោះទ្វារមគ្គទាំងពីរ ។

[ ១០០ ] ភិក្ខុនិយាយស្ញើចពណ៌នាសរសើរទ្វារមគ្គទាំងពីរ ហៅថា ពោលសរសើរ ។ ភិក្ខុជេរតិះដៀលនិន្ទាទ្វារមគ្គទាំងពីរ ហៅថា ពោលបង្អាប់ ។ ភិក្ខុនិយាយថា នាងចូរឲ្យ ( មេថុនធម្ម ) ដល់អាត្មា នាងចូរដាក់ទាន ( មេថុនធម្ម ) ដល់អាត្មា នាងគួរឲ្យ ( មេថុនធម្ម ) ដល់អាត្មា ហៅថា សូម ។ ភិក្ខុនិយាយថា មាតារបស់នាងនឹងជ្រះថ្លាក្នុងកាលណា បិតារបស់នាងនឹងជ្រះថ្លាក្នុងកាលណា ទេវតាទាំងឡាយរបស់នាងនឹងជ្រះថ្លាក្នុងកាលណា ពេលល្អ ស្របក់ល្អ យាមល្អ របស់នាងនឹងមានក្នុងកាលណា អាត្មានឹងបានននូវមេថុនធម្មរបស់នាងក្នុងកាលណា ( និយាយយ៉ាងនេះ ) ហៅថា អង្វរ ។ ភិក្ខុនិយាយថា នាងឲ្យ ( មេថុនធម្ម ) ដល់ប្តីដូចម្តេច នាងឲ្យ ( មេថុនធម្ម ) ដល់សហាយដូចម្តេច ( យ៉ាងនេះ ) ហៅថា សួរ ។ ភិក្ខុនិយាយថា បានឮថា នាងឲ្យ ( មេថុនធម្ម ) ដល់ប្តីយ៉ាងនេះ នាងឲ្យ ( មេថុនធម្ម ) ដល់សហាយយ៉ាងនេះ ដូច្នេះ ហៅថា សួរបញ្ជាក់ ។ ភិក្ខុដែលស្រីសួរហើយនិយាយថា នាងចូរឲ្យ ( មេថុនធម្ម ) យ៉ាងនេះ កាលបើឲ្យ ( មេថុនធម្ម ) យ៉ាងនេះ នាងឯងនឹងជាទីស្រឡាញ់ផង ជាទីគាប់ចិត្តផង របស់ប្តី ដូច្នេះ ហៅថា ប្រាប់ ។ ភិក្ខុដែលស្រីមិនសួរសោះទេ ស្រាប់តែនិយាយថា នាងចូរឲ្យ ( មេថុនធម្ម ) យ៉ាងនេះ កាលបើឲ្យ ( មេថុន-

ធម្ម ) យ៉ាងនេះ នាងឯងនឹងជាទីស្រឡាញ់ផង ជាទីគាប់ចិត្តផងរបស់ប្តី ដូច្នេះ ហៅថា ប្រៀនប្រដៅ ។ ភិក្ខុពោលពាក្យថា មេគ្មាននិមិត្ត មេមានហេតុគ្រាន់តែជានិមិត្ត មេគ្មានឈាម មេមានឈាមជានិច្ច មេមានកំណាត់សំពត់ជានិច្ច មេហូរឈាមជានិច្ច មេសិខិរណី ( ពាក្យជេរលើកអាស ) មេស្រីខ្ទើយ មេស្រីមានរូបដូចប្រុស មេមានទ្វារមគ្គរលាយចូលគ្នា មេឧកតោព្យញ្ជនក ដូច្នេះ ហៅថា ជេរ ។

[ ១០១ ] ស្រីជាប្រាកដ ភិក្ខុសម្គាល់ថាស្រីពិតមែន ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្អាប់ក្តី សូមក្តី អង្វរក្តី សួរក្តី សួរបញ្ជាក់ក្តី ប្រាប់ក្តី ប្រៀនប្រដៅក្តី ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គរបស់ស្រីនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ស្រីជាប្រាកដ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គរបស់ស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ខ្ទើយជាប្រាកដ ភិក្ខុសម្គាល់ថាខ្ទើយពិតមែន ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គរបស់ខ្ទើយនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ខ្ទើយជាប្រាកដ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវ-

មគ្គរបស់ខ្ទើយនោះ ត្រូវអាបត្តិទុក្កដ ។ បុរសជាប្រាកដ ភិក្ខុសម្គាល់ថាបុរសពិតមែន មានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ឬបស្សាវមគ្គនៃបុរសនោះ ត្រូវអាបត្តិទុក្កដ ។ សត្វតិរច្ឆានឈ្មោលជាប្រាកដ ភិក្ខុសម្គាល់ថាសត្វតិរច្ឆានឈ្មោលពិតមែន មានសេចក្តីសង្ស័យក្តី សម្គាល់ថា ស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាបុរស ( ក្តី ) ក៏មាន សេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។ បេ ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃសត្វតិរច្ឆានឈ្មោលនោះ ត្រូវអាបត្តិទុក្កដ ។

[ ១០២ ] ស្រីពីរនាក់ពិតមែន ភិក្ខុក៏សម្គាល់ស្រីទាំងពីរនាក់ថាស្រី មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តីចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេសពីរ ។ ស្រីពីរនាក់ ភិក្ខុមានសេចក្តីសង្ស័យក្តី សម្គាល់ថា ខ្ទើយ ( ក្តី ) សម្គាល់ថាបុរសក្តី សម្គាល់ថាតិរច្ឆានក្តី ចំពោះស្រីទាំងពីរនាក់ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។ បេ ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ខ្ទើយពីរនាក់ ភិក្ខុសម្គាល់ខ្ទើយទាំងពីរនាក់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវ-មគ្គនៃខ្ទើយទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ខ្ទើយពីរនាក់ ភិក្ខុមាន

សេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) ចំពោះខ្ទើយទាំងពីរនាក់ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។ បេ ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃខ្ទើយទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុសពីរនាក់ ភិក្ខុសម្គាល់ថាប្រុសក្តី មានសេចក្តីសង្ស័យក្តី សម្គាល់ថាតិរច្ឆានក្តី សម្គាល់ថាស្រីក្តី សម្គាល់ថាខ្ទើយក្តី ចំពោះប្រុសទាំងពីរនាក់ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃប្រុសទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ តិរច្ឆានពីរ ភិក្ខុសម្គាល់ថាតិរច្ឆានក្តី មានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) ចំពោះតិរច្ឆានទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃតិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។

[ ១០៣ ] ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ ចំពោះជនទាំងពីរនាក់ ។បេ។ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។បេ។ ភិក្ខុសម្គាល់ថាខ្ទើយ ។បេ។ ត្រូវអាបត្តិថុល្លច្ច័យពីរ ។បេ។ ភិក្ខុសម្គាល់ថាប្រុស ។បេ។ សម្គាល់ថាតិរច្ឆាន ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។

ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) ចំពោះជនទាំងពីរនាក់ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុសម្គាល់ជនទាំងពីរថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តី

សង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) ចំពោះជនទាំងពីរនាក់ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុសម្គាល់នូវជនទាំងពីរថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ឬបស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) ចំពោះជនទាំងពីរក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ឬបស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុសម្នាក់ តិរច្ឆានមួយ ភិក្ខុសម្គាល់ថាប្រុស ( ក្តី ) មានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។បេ។ ជេរក្តី ចំពោះវច្ចមគ្គ ( ឬ ) បស្សាវមគ្គនៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។

[ ១០៤ ] ស្រីពិតមែន ភិក្ខុសម្គាល់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបន្ទាប់ក្តី ។បេ។ ជេរក្តី ( ចំពោះកាយ ) ខាងក្រោមពីត្រឹមដងកាំបិតចុះមក ខាងលើពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែវច្ចមគ្គ ឬបស្សាវមគ្គនៃស្រីនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ខ្ទើយពិតមែន

ភិក្ខុសម្គាល់ថាជាស្រី ។បេ។ ប្រុសពិតមែន ភិក្ខុសម្គាល់ថាជាស្រី ។បេ។ តិរច្ឆានពិតមែន ភិក្ខុសម្គាល់ថាស្រី ។បេ។ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរ ក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ( ចំពោះកាយ ) ខាងក្រោម ពីត្រឹមដង កាំបិតចុះមក ខាងលើពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែវច្ចមគ្គ និង បស្សាវមគ្គនៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ( ចំពោះកាយ ) ខាងក្រោម ពីត្រឹមដង កាំបិតចុះមក ខាងលើ ពីត្រឹមមណ្ឌលជង្គង់ឡើងទៅ វៀរលែងតែវច្ចមគ្គ ឬ បស្សាវមគ្គនៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។

[ ១០៥ ] ស្រីពិតមែន ភិក្ខុសម្គាល់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ( ចំពោះកាយ ) ខាងលើ ពីត្រឹមដងកាំបិតឡើងទៅ ខាងក្រោម ពីត្រឹមមណ្ឌលជង្គង់ចុះមកនៃស្រីនោះ ត្រូវអាបត្តិទុក្កដ ។ ខ្ទើយពិតមែន ភិក្ខុសម្គាល់ថាជាស្រី ។បេ។ ប្រុសពិត មែន ភិក្ខុសម្គាល់ថាជាស្រី ។បេ។ តិរច្ឆានឈ្មោលពិតមែន ភិក្ខុសម្គាល់ថា ស្រី ។បេ។ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ ថា ជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរ ក្តី ( ចំពោះកាយ ) ខាងលើ ពីត្រឹមដងកាំបិតឡើងទៅ ខាងក្រោមពីត្រឹម មណ្ឌលជង្គង់ចុះមក នៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់

ហើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ( ចំពោះកាយ ) ខាងលើ ពីត្រឹមដងកាំបិតឡើងទៅ ខាងក្រោមពីត្រឹមមណ្ឌលជង្គង់ចុះមក នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ស្រីពិតមែន ភិក្ខុសម្គាល់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយស្រីនោះ ត្រូវអាបត្តិទុក្កដ ។ ហើយពិតមែន ។បេ។ ប្រុសពិតមែន ។បេ។ តិរច្ឆានឈ្មោលពិតមែន ។បេ។ ត្រូវអាបត្តិទុក្កដ ។ ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយនៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់ ហើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរក្តី ពោលបង្អាប់ក្តី ។បេ។ ជេរក្តី ចំពោះវត្ថុដែលជាប់នឹងកាយ នៃស្រីទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដទាំងពីរ ។

[ ១០៦ ] អាបត្តិមិនមាន ( ដល់ភិក្ខុ ៥ ពួក ) គឺភិក្ខុដែលកំពុងអធិប្បាយសេចក្តី ១ ភិក្ខុដែលកំពុងបង្រៀនធម៌ ១ ភិក្ខុដែលកំពុងប្រៀនប្រដៅ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាខាងដើមបញ្ញត្តិ ១ ។

( មាតិកានុក្រម គឺបញ្ជីរឿងតាមរបៀបហូរហែ ដែលនឹងសំដែងតទៅដូចមានខាងក្រោយនេះ )

[ ១០៧ ] សំពត់កម្ពលក្រហម ១ សំពត់កម្ពលមានរោមខ្លី ១ សំពត់

កម្ពលមានរោមក្រញាញ់ ១ សំពត់កម្ពលមានរោមវែង ១ សំពត់កម្ពលមានរោមវែង ១ ស្រីព្រោះស្រូវ ១ ភិក្ខុសួរថាផ្លូវប្រព្រឹត្តទៅស្រួលទេឬ ១ សទ្ធា ១ ទានដ៏ប្រសើរ ១ ស្រីកំពុងធ្វើការងារ ១ ។

[ ១០៨ ] សម័យនោះឯង មានស្រីម្នាក់ ដណ្តប់សំពត់កម្ពលជ្រលក់ថ្មី ៗ ភិក្ខុ ១ រូប មានសេចក្តីត្រេកអរ ក៏និយាយនូវពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងក្រហមឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សំពត់កម្ពលខ្ញុំជ្រលក់ថ្មី ៗ ភិក្ខុនោះមានសេចក្តីសង្ស័យថាអញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង ។ ទើបក្រាបទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ដណ្តប់សំពត់កម្ពលមានរោមខ្ចី ។ ភិក្ខុមួយរូប មានសេចក្តីត្រេកអរ ក៏និយាយនូវពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមខ្ចីឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សំពត់កម្ពលខ្ញុំមានរោមខ្ចី ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ដណ្តប់សំពត់កម្ពលទើបតែនឹងលាងថ្មី ។ មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមក្រញាញ់ឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ សំពត់កម្ពលខ្ញុំ ទើបតែនឹងលាងថ្មី ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ជណ្តប់សំពត់កម្ពលមានរោមវែង ។ មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមវែងឬ ។ ស្រីនោះមិនដឹងច្បាស់ក៏ឆ្លើយថា ករុណា លោកម្ចាស់ សំពត់កម្ពលខ្ញុំមានរោមវែង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ១០៩ ] សម័យនោះឯង មានស្រីម្នាក់ជណ្តប់សំពត់បាវារមានរោមវែង ។ មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងមានរោមវែងឬ ។ ស្រីនោះមិនដឹងច្បាស់ក៏ឆ្លើយថា ករុណាលោកម្ចាស់ សំពត់បាវារខ្ញុំមានរោមវែង ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ១១០ ] សម័យនោះឯង មានស្រីម្នាក់ ប្រើគេឲ្យព្រោះស្រូវស្រែរួចហើយត្រឡប់មកវិញ ។ មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី វត្ថុរបស់នាងឲ្យគេព្រោះហើយឬ ។ ស្រីនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ ស្រែខ្ញុំគេមិនទាន់ព្រោះទេ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ១១១ ] សម័យនោះឯង មានភិក្ខុ ១ រូប ប្រទះនឹងនាងបរិញ្វាជិកា ត្រង់ផ្លូវជួបគ្នា មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងបរិញ្វាជិកានោះថា ម្នាលប្អូនស្រី ផ្លូវរបស់នាងប្រព្រឹត្តទៅស្រួលទេឬ ។ នាងនោះមិនដឹងច្បាស់ ក៏ឆ្លើយថា ករុណាលោកម្ចាស់ លោកនឹងដើរទៅបាន ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

[ ១១២ ] សម័យនោះឯង មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ និយាយពាក្យនេះនឹងស្រីម្នាក់ថា ម្នាលប្អូនស្រី នាងជាស្រីមានសទ្ធា ប៉ុន្តែនាងឲ្យវត្ថុណាដល់ស្វាមី នាងមិនឲ្យវត្ថុនោះដល់អាត្មាផងសោះ ។ ស្រីនោះសួរថា អ្វីលោកម្ចាស់ ។ ភិក្ខុនោះឆ្លើយថា មេថុនធម្ម ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃា-ទិសេសហើយ ។ សម័យនោះឯង មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីម្នាក់ថា ម្នាលប្អូនស្រី នាងជាស្រីមានសទ្ធា ប៉ុន្តែទានណាដ៏ប្រសើរ នាងមិនឲ្យទាននោះដល់អាត្មាផងសោះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះ ឆ្លើយថា ទានដ៏ប្រសើរនោះ គឺមេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។

[ ១១៣ ] សម័យនោះឯង មានស្រីម្នាក់កំពុងធ្វើការងារ ។ មានភិក្ខុ ១ រូប មានសេចក្តីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី

នាងឈប់ចុះចាំអាត្មាធ្វើឲ្យ ។ ស្រីនោះមិនដឹងច្បាស់ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់ កំពុងធ្វើការងារ ។ មានភិក្ខុ ១ រូប មានសេចក្ដីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី ចូរនាងអង្គុយទៅ អាត្មានឹងធ្វើឲ្យ ។ ស្រីនោះមិនដឹងច្បាស់ ។ ភិក្ខុនោះមានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង មានស្រីម្នាក់កំពុងធ្វើការងារ ។ មានភិក្ខុ ១ រូប មានសេចក្ដីត្រេកអរ ក៏និយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី នាងចូរដេកទៅ អាត្មានឹងធ្វើឲ្យ ។ ស្រីនោះមិនដឹងច្បាស់ ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

សង្ឃាទិសេសទី ៣ ចប់

## អដ្ឋកថា

## ទុដ្ឋុល្លវាចាសិក្ខាបទវណ្ណនា

[ ៩៧ ] ទុដ្ឋុល្លវាចាសិក្ខាបទ ពាក្យថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅថា គប្បីជ្រាបវិនិច្ឆ័យក្នុងទុដ្ឋុល្លវាចាសិក្ខាបទនោះ ដូច្នេះ ។ បទថា **អាធិស្ស** ប្រែថា សំដៅដល់ ។

ច្រើនបទថា **វណ្ណម្បិ ភណតិ** ជាដើម នឹងមានច្បាស់ទៅខាងមុខ ។

បទថា **ជិន្នកា** ប្រែថា មិនមានការខ្មាចបាប ។

បទថា **ធុត្តិកា** ប្រែថា អ្នកមានមាយា ។

បទថា **អហិរិកាយោ** ប្រែថា បុគ្គលមិនមានការខ្មាស ។

បទថា **ឧហសន្តិ** ប្រែថា ញញឹមពព្រាយ ហើយសើចតិចៗ ។

បទថា **ឧល្លបន្តិ** សេចក្តីថា រមែងពោលពាក្យបញ្ឆោរមានប្រការផ្សេងៗ លើកដើងដោយន័យជាដើមថា ឱ លោកម្ចាស់ ។

បទថា **ឧជ្ជគ្ឃន្តិ** ប្រែថា រមែងសើចមានសំឡេងខ្លាំង ។

បទថា **ឧប្បណ្ឌេន្តិ** សេចក្តីថា ធ្វើការចំអកចំអន់ដោយន័យជាដើមថា នេះជាខ្ទើយ នេះមិនមែនមនុស្សប្រុស ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃទុដ្ឋុល្លវាចាសិក្ខាបទ

[ ៩៨ ] បទថា **សារត្តោ** ប្រែថា ត្រេកត្រអាលហើយដោយតម្រេកដោយអំណាចនៃការពេញចិត្តក្នុងទុដ្ឋុល្លវាចា ។

បទថា **អបេក្ខវា បដិពទ្ធចិត្តោ** មានន័យដូចពោលហើយនោះឯង ។ ក្នុងសិក្ខាបទនេះ គប្បីប្រកបភាគៈ ដោយអំណាចនៃការត្រេកអរក្នុងវាចាតែម្យ៉ាង ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងមាតុគ្រាម ដែលទ្រង់បំណងក្នុងពាក្យថា **មាតុគាមំ ទុដ្ឋុល្លាហិ វាចាហិ** នេះ ទើបត្រាស់ពាក្យថា **មាតុគាមោ** ជាដើម ។ បណ្តាបទទាំងនោះ ពាក្យថា ជាស្រីដែលដឹងក្តី អាចជ្រាបពាក្យដែលជាសុភាសិត ទុព្ភាសិត វាចាអាក្រក់ និងវាចាសុភាពបាន ដែលព្រះឧបាលីសម្តែងថា ស្រីដែលជាអ្នកឈ្លាសវាងវៃ អាចដើម្បីជ្រាបពាក្យសម្តីដែលជាប្រយោជន៍ និងឥតប្រយោជន៍ ពាក្យសម្តីដែលអាស្រ័យអសទ្ធម្ម និងសទ្ធម្ម ទ្រង់បំណងយកក្នុងសិក្ខាបទនេះ ចំណែកស្រីដែលល្ងង់ខ្លៅ ឥតបញ្ញា ទោះជាមនុស្សធំ ក៏ទ្រង់មិនបំណងយកក្នុងសិក្ខាបទនេះ ។

បទថា **ឱភាសេយ្យ** សេចក្តីថា គប្បីពោលចៃចង់ គឺពោលអាស្រ័យអសទ្ធម្ម មានប្រការផ្សេងៗ ។ ដែលឈ្មោះថា ការពោលចៃចង់របស់ភិក្ខុដែលពោលយ៉ាងនេះ ដោយអត្ថ ជាអជ្ឈាចារ គឺការប្រព្រឹត្តកន្លងព្រំដែននៃការសង្រួម ដោយអំណាចនៃរាគៈ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអត្ថនោះទើបត្រាស់ថា បទថា **ឱភាសេយ្យ** គឺដែលហៅថា អជ្ឈាចារ។

ពាក្យថា **តំ** ក្នុងពាក្យថា **យថាតំ** នេះ ជានិបាត ។ សេចក្តីថា ដូចបុរសកំលោះពោលចង់ស្រីក្រមុំ ដូច្នោះ ។

សិក្ខាបទវិភង្គនៃទុដ្ឋុល្លវាចាសិក្ខាបទ ចប់

# អធិប្បាយ
# បឋមភាណវារៈនៃឧជ្ឈាយវត្តសិក្ខាបទ

[ ៩៩ ] ពាក្យជាដើមថា **ទេ្វ មគ្គេ អាទិស្ស** ដូច្នេះ ព្រះមានព្រះភាគ ត្រាស់ហើយ ដើម្បីទ្រង់សម្តែងអាការដែលជាហេតុឲ្យសង្ឃាទិសេសដល់ភិក្ខុ ដែលពោលចំចង់ ( ស្រ្តី ) ។

បណ្តាបទទាំងពីរបទថា **ទេ្វ មគ្គេ** បានដល់ វច្ចមគ្គ និងបស្សាវមគ្គ ពាក្យដ៏សេស ប្រាកដហើយអំពីដំបូង ក្នុងឧទ្ទេសនោះឯង ។ ឯក្នុងឧទ្ទេស ពាក្យថា និយាយសរសើរ គឺនិយាយថា នាងជាអ្នកដល់ព្រមដោយលក្ខណៈ របស់ស្រី គឺដោយសុភលក្ខណៈ អាបត្តិមិនទាន់ដល់ទីបំផុត ។ ពោលថា វច្ចមគ្គ និងបស្សាវមគ្គរបស់នាង ដូច្នេះ នាងជាអ្នកដល់ព្រមដោយលក្ខណៈ របស់ស្រី គឺដោយសុភលក្ខណៈ ដូច្នេះ ដោយហេតុដូច្នោះ អាបត្តិរមែងដល់ ទីបំផុត គឺជាសង្ឃាទិសេស ។

[ ១០០ ] ពីរបទថា **វណ្ណេតិ បសំសតិ** នេះ ជាវេវចនៈនៃបទថា ពោលសរសើរ ។

បទថា **ខុំសេតិ** សេចក្តីថា រមែងពោលជេរ ប្រៀបដូចជន្ទញ គឺវាចា ។

បទថា **វម្ភេតិ** ប្រែថា ពោលតិះដៀល ។

បទថា **គរហតិ** ប្រែថា រមែងពោលទោស ។

តែកាលមិនទាន់ពោលភ្ជាប់ជាមួយ ១១ បទ មានបទថា **អនិមិត្តាសិ** ជាដើម ដែលមកក្នុងបាលីខាងដើម អាបត្តិមិនទាន់ដល់ទីបំផុតឡើយ សូម្បី ភ្ជាប់ហើយ កាលពោលភ្ជាប់ដោយបទ ៣ ទាំងនេះថា មេសិខិរណី មេមាន

ទ្វារមគ្គរលាយចូលគ្នា មេឧកតោព្យញ្ជនកៈ ដូច្នេះប៉ុណ្ណោះ ក្នុងបណ្ដា ១១ បទ នោះ ទើបត្រូវអាបត្តិសង្ឃាទិសេស ។ សូម្បីក្នុងការពោលសូមថា នាងចូរឲ្យដល់ខ្ញុំ អាបត្តិនៅមិនទាន់ដល់ទីបំផុត ដោយពាក្យមានប្រមាណប៉ុណ្ណោះ លុះពោលភ្ជាប់ដោយមេថុនធម្មយ៉ាងនេះថា នាងចូរឲ្យមេថុនធម្ម ត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងពាក្យពោលអង្វរថា កាលណាម្ដាយរបស់នាងនឹងជ្រះថ្លាជាដើម អាបត្តិមិនទាន់ដល់ទីបំផុតដោយពាក្យពោលមានប្រមាណប៉ុណ្ណោះ តែបើពោលភ្ជាប់ដោយមេថុនធម្ម ដោយន័យជាដើមថា កាលណាមាតារបស់នាងនឹងជ្រះថ្លា កាលណាខ្ញុំនឹងបានមេថុនធម្មរបស់នាង ឬថា កាលមាតានាងជ្រះថ្លាហើយ ខ្ញុំនឹងបានមេថុនធម្ម ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេស ។ ក្នុងពាក្យសួរជាដើមថា នាងឲ្យដល់ប្ដីដូចម្ដេច កាលពោលថា មេថុនធម្មប៉ុណ្ណោះ ទើបត្រូវអាបត្តិសង្ឃាទិសេស មិនមែនដោយប្រការដទៃឡើយ ។ សូម្បីក្នុងពាក្យសាកសួរថា បានឮថា នាងឲ្យដល់ប្ដីយ៉ាងនេះឬ ក៏មានន័យដូចគ្នាយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងការប្រាប់ដូច្នេះ ពីរបទថា **បុដ្ឋោ ភណតិ** សេចក្ដីថា ភិក្ខុកាលស្រីសួរថា កាលឲ្យដូចម្ដេច ទើបជាទីស្រឡាញ់របស់ប្ដីហើយប្រាប់ ។ ក្នុងកាលប្រាប់នោះ សូម្បីពោលថា ចូរឲ្យយ៉ាងនេះ កាលឲ្យយ៉ាងនេះ អាបត្តិមិនទាន់ដល់ទីបំផុត តែកាលភ្ជាប់ដោយមេថុនធម្មប៉ុណ្ណោះ ដោយន័យជាដើមថា នាងចូរឲ្យ ចូរបង្អោនចូលទៅនូវមេថុនធម្មយ៉ាងនេះ កាលឲ្យ កាលបង្អោនចូលទៅនូវមេថុនធម្មយ៉ាងនេះ នឹងជាទីស្រឡាញ់ ត្រូវ

អាបត្តិសង្ឃាទិសេស ។ ក្នុងការប្រៀនប្រដៅ ក៏មានន័យដូចគ្នានេះ ។

វិនិច្ឆ័យក្នុងអក្កោសនិទ្ទេស គប្បីជ្រាបដូច្នេះ បទថា **អនិមិត្តាសិ** ប្រែថា នាងជាបុគ្គលប្រាសចាកនិមិត្ត អធិប្បាយថា ប្រហោងបស្សាវៈរបស់នាង មានប្រមាណប៉ុនរន្ធសោប៉ុណ្ណោះ ។

បទថា **និមិត្តមត្តាសិ** ប្រែថា ឥត្ថីនិមិត្តរបស់នាងមិនពេញបរិបូណ៌ អធិប្បាយថា គ្រាន់តែជាទីចំណាំប៉ុណ្ណោះ ។

បទថា **អលោហិតា** ប្រែថា មានទ្វារកំណើតស្ងួត ។

បទថា **ធុវលោហិតា** ប្រែថា មានទ្វារកំណើតសើមទៅដោយលោហិតជានិច្ច ។

បទថា **ធុវចោឡា** ប្រែថា មានសំពត់ចុកជានិច្ច អធិប្បាយថា នាងប្រើសំពត់ចុកជានិច្ច ។

បទថា **បគ្ឃរន្តិ** ប្រែថា រមែងហូរចេញ អធិប្បាយថា ទឹកមូត្ររបស់នាងហូរចេញជានិច្ច ។

បទថា **សិខរណី** ប្រែថា មានសាច់ដុះចេញមកខាងក្រៅ ។ ស្រីដែលមិនមាននិមិត្ត លោកហៅថា ស្រីខ្ទើយ ស្រីដែលមានពុកមាត់ ពុកចង្កា រូបរាងដូចបុរស លោកហៅថា ស្រីដូចប្រុស ។

បទថា **សម្ភិន្នា** សេចក្តីថា មានវច្ចមគ្គ និងបស្សាវមគ្គចូលគ្នា ។

បទថា **ឧភតោព្យញ្ជនា** សេចក្តីថា ជាអ្នកប្រកបដោយភេទទាំងពីរ គឺនិមិត្តស្ត្រី ១ និមិត្តបុរស ១ ។

បណ្ដាបទទាំង ១១ នេះ ៣ បទសុទ្ធៗ នេះ គឺស្ត្រីមានសាច់ដុះ ស្ត្រីមានទ្វារមគ្គលាយចូលគ្នា ស្ត្រីកេទពីរប៉ុណ្ណោះ រមែងដល់ទីបំផុត ។ ៣ បទនេះ និង ៣ បទមុនៗ គឺបទពោលដោយវច្ចមគ្គ បស្សាវមគ្គ និងមេថុនធម្ម រួមជា ៦ បទសុទ្ធៗ ធ្វើឲ្យជាអាបត្តិបាន ដោយប្រការដូច្នេះ ។

បទដ៏សេសជាដើមថា នាងជាបុគ្គលមិនមាននិមិត្ត ដែលភ្ជាប់ក្នុងបទថា មិនមាននិមិត្ត ដោយមេថុនធម្មហើយនោះឯង ដោយន័យជាដើមថា នាងចូរឲ្យមេថុនធម្មដល់ខ្ញុំក្តី ឬថា នាងជាបុគ្គលមិនមាននិមិត្ត ចូរឲ្យមេថុនធម្មដល់ខ្ញុំក្តី គប្បីជ្រាបថា ជាបទធ្វើឲ្យកើតអាបត្តិបាន ។

[ ១០១ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងប្រភេទនៃអាបត្តិដោយពិស្តារ ដោយអំណាចនៃអាការ មានការពោលសរសើរទាំងនេះជាដើម អាស្រ័យដល់វច្ចមគ្គ និងបស្សាវមគ្គ របស់ភិក្ខុដែលតម្រេក មានចិត្តប្រែប្រួល ពោលចង់មាតុគ្រាម ទើបត្រាស់ពាក្យថា **ឥត្ថី ច ហោតិ ឥត្ថីសញ្ញី** ជាដើម ។ អត្ថនៃបទទាំងនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងកាយសំសគ្គៈនោះឯង ។ ចំណែកការប្លែកគ្នា មានដូចតទៅនេះថា

[ ១០៤ ] បទថា **អធក្ខកំ** គឺខាងក្រោម ចាប់ពីឆ្អឹងដងកាំបិតចុះមក ។ បទថា **ឧព្ភជានុមណ្ឌលំ** គឺខាងលើ តាំងអំពីមណ្ឌលជង្គង់ឡើងទៅ ។

[ ១០៥ ] បទថា **ឧព្ភក្ខកំ** គឺខាងលើ តាំងអំពីឆ្អឹងដងកាំបិតឡើងទៅ ។ បទថា **អធោជានុមណ្ឌលំ** គឺខាងក្រោម តាំងអំពីមណ្ឌលជង្គង់ចុះទៅ ។ ឆ្អឹងដងកាំបិត និងមណ្ឌលជង្គង់ សង្គ្រោះចូលក្នុងខេត្តនៃទុក្កដ ចំពោះ

ក្នុងសិក្ខាបទនេះ ដូចក្នុងកាយសំសគ្គៈរបស់ភិក្ខុនី ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនបញ្ញត្តគរុការបត្តិឲ្យមានចំណែកសេសសល់ឡើយ ។

បទថា **កាយប្បដិពទ្ធំ** បានដល់ សំពត់ក្តី ផ្កាក្តី គ្រឿងប្រដាប់ក្តី ។

## អនាបត្តិវារៈ

[ ១០៦ ] បទថា **អត្ថបុរេក្ខារស្ស** សេចក្តីថា អ្នកពោលអត្ថនៃបទជាដើមថា **អនិមិត្តាសិ** ឬអ្នកធ្វើការស្វាធ្យាយអដ្ឋកថា ។

បទថា **ធម្មបុរេក្ខារស្ស** សេចក្តីថា អ្នកប្រាប់ ឬស្វាធ្យាយព្រះបាលីកាលភិក្ខុសំដៅយកអត្ថ សំដៅយកធម៌ ពោលយ៉ាងនេះ ឈ្មោះថា មិនត្រូវអាបត្តិដល់បុគ្គលសំដៅយកអត្ថ និងសំដៅយកធម៌ ។

បទថា **អនុសាសនីបុរេក្ខារស្ស** សេចក្តីថា កាលភិក្ខុប្រៀនប្រដៅសូម្បីពោលយ៉ាងនេះថា ឥឡូវនេះ នាងក៏ជាបុគ្គលមិនមាននិមិត្ត ជាបុគ្គលភេទពីរ នាងគប្បីធ្វើការមិនប្រមាទពីឥឡូវនេះទៅ នាងកុំធ្វើយ៉ាងនេះតទៅឡើយ ឈ្មោះថា មិនត្រូវអាបត្តិដល់អ្នកបំណងប្រៀនប្រដៅ ។ ចំណែកភិក្ខុណា កាលប្រាប់បាលីដល់ពួកភិក្ខុនី លះទំនងវាចាតាមប្រក្រតី សើចចំអកនិយាយដដែលៗ ថា នាងជាអ្នកដុះសាច់ ជាអ្នកមានទ្វារមគ្គរលាយចូលគ្នា ជាអ្នកមានភេទពីរ ភិក្ខុនោះ ប្រព្រឹត្តជាអាបត្តិពិត ។ អាបត្តិមិនមានដល់មនុស្សឆ្កួត ព្រះឧទាយិត្ថេរជាដើមបញ្ញត្តិ ក្នុងសិក្ខាបទនេះ អាបត្តិមិនមានដល់លោកដែលជាដើមបញ្ញត្តិ ដូច្នេះឯង ។

បណ្ណាបកិណ្ណកៈ មានសមុដ្ឋានជាដើម សិក្ខាបទនេះមានសមុដ្ឋាន ៣

រមែងកើតឡើងតាមកាយ និងចិត្ត ១ តាមវាចា និងចិត្ត ១ តាមកាយវាចា និងចិត្ត ១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ២ ដូច្នេះឯង ។

បទភាជនីយ៍នៃទុដ្ឋុល្លវាចាសិក្ខាបទ ចប់

# អធិប្បាយ
# វិនីតវត្ថុក្នុងទុដ្ឋុល្លវាចាសិក្ខាបទ

[ ១០៨ ] បណ្ដាវិនីតវត្ថុ គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងសំពត់កម្ពលក្រហម ដូច្នេះថា ភិក្ខុនោះ ពោលសំដៅដល់និមិត្តដែលមានលោហិតរបស់ស្រី ស្រីនោះមិនដឹង ព្រោះដូច្នោះ ទើបត្រូវអាបត្តិទុក្កដ ។ បទថា **កក្កសលោមំ** ប្រែថា មានរោមច្រើន ដោយរោមខ្លីៗ ។ បទថា **អាកិណ្ណលោមំ** ប្រែថា មានរោមក្រញាញ់ ។

បទថា **ខរលោមំ** ប្រែថា មានរោមរឹង ។

[ ១០៩ ] បទថា **ទីឃលោមំ** ប្រែថា មានសរសៃរោមមិនខ្លី ។ ពាក្យទាំងអស់ ភិក្ខុទាំងនោះពោលដល់និមិត្តរបស់ស្រីទាំងនោះ ។

[ ១១០ ] ភិក្ខុនោះពោលសំដៅដល់អសទ្ធម្មថា នាងឲ្យគេព្រោះស្រូវហើយឬ ស្រីនោះមិនយល់ ទើបពោលថា ( ព្រោះហើយ ) តែមិនទាន់បានរាស់លុប ។

ពូជដែលឈ្មោះថា លុបហើយ បានដល់ ពូជដែលគេឲ្យតាំងឡើងជាថ្មី ( ឲ្យសាបព្រោះ ) ក្នុងឱកាសដែលពូជទាំងឡាយមិនទាន់ដុះ ឬក្នុងឱកាសដែលមានពូជ ត្រូវពួកសត្វល្អិតធ្វើឲ្យវិនាស ហើយបញ្ចូលទឹកឲ្យស្មើក្នុងស្រែព្រោះមានទឹក និងពូជដែលគេកៀរឲ្យស្មើដោយនោសមានធ្មេញ ៨ ដដែលទៀត ដើម្បីធ្វើពូជទាំងឡាយ ដែលធ្លាក់ចុះទៅឲ្យស្មើគ្នាក្នុងស្រែទួល ។ បណ្ដាពូជទាំងនោះ ស្រីនេះពោល សំដៅយកពូជឯណាមួយ ។

[ ១១១ ] ក្នុងរឿងផ្លូវ ពាក្យថា ផ្លូវរបស់នាងប្រព្រឹត្តទៅស្រួលទេឬ ភិក្ខុនោះពោលសំដៅដល់ផ្លូវអង្គជាត ។ ពាក្យដ៏សេសមានអត្ថជាក់ច្បាស់ហើយនោះឯង ។

ទុដ្ឋុល្លវាចាសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ៤

[ ១១៤ ] សម័យនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុ ជាអ្នកចូលទៅកាន់ត្រកូល[១] ក៏ចូលទៅរកត្រកូលមានប្រមាណច្រើន ក្នុងក្រុងសាវត្ថី ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមេម៉ាយស្លាប់ប្ដី មានរូបល្អគួរពិតពិលរមិលមើល ជាទីនាំមកនូវសេចក្ដីជ្រះថ្លា ។ គ្រានោះ ឧទាយិភិក្ខុដ៏មានអាយុស្លៀកស្បង់ ទ្រង់បាត្រ ចីវរ ហើយចូលទៅកាន់លំនៅរបស់ស្រីនោះ ក្នុងពេលព្រឹកព្រហាម លុះចូលទៅដល់ហើយក៏អង្គុយលើអាសនៈដែលគេក្រាលប្រគេន ។ ស្រីនោះក៏ចូលមករកឧទាយិភិក្ខុដ៏មានអាយុក្នុងពេលនោះ លុះចូលមកជិតហើយ ក៏ឱនកាយថ្វាយបង្គំឧទាយិភិក្ខុដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ឧទាយិភិក្ខុដ៏មានអាយុក៏ញុំាងស្រីនោះ ដែលអង្គុយនៅក្នុងទីសមគួរ ឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយវាចាដ៏ប្រកបដោយធម៌ ។ ឯស្រីនោះ លុះឧទាយិភិក្ខុដ៏មានអាយុ ឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយវាចាដ៏ប្រកបដោយធម៌ដូច្នោះហើយ ក៏បាននិយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការដោយវត្ថុណា ដែលខ្ញុំព្រះករុណា ល្មមនឹងប្រគេនលោកម្ចាស់

---

១- កុលុបក ប្រែថា ជីតុនក៏បាន គឺភិក្ខុដែលជិតជិតស្និទ្ធស្នាលនឹងត្រកូល ។

បាន ដូចជាចីវរ បិណ្ឌបាត គ្រឿងសេនាសនៈ គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សឈឺនោះ លោកម្ចាស់និមន្តប្រាប់មកចុះ ។ ឧទាយិភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ចីវរ បិណ្ឌបាត គ្រឿងសេនាសនៈ គ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់មនុស្សមានជំងឺដែលជារបស់នាង យើងមិនមែនបានដោយកម្រទេ តែថា របស់ណា ដែលយើងបានដោយកម្រ នាងចូរឲ្យរបស់នោះដល់យើងវិញចុះ ។ ស្រីនោះសួរថា ឲ្យអ្វីលោកម្ចាស់ ។ ឧទាយិភិក្ខុឆ្លើយថា ឲ្យមេថុនធម្ម ។ ស្រីនោះសួរថា លោកម្ចាស់ត្រូវការឬ ។ ឧទាយិភិក្ខុឆ្លើយថា ម្នាលប្អូនស្រី អាត្មាត្រូវការដែរ ។ ស្រីនោះឆ្លើយថា លោកម្ចាស់និមន្តមកចុះ ថាហើយ ក៏ចូលទៅក្នុងបន្ទប់តូចដោះសំពត់សាដកចេញហើយដេកផ្ងារលើគ្រែ ។ ឧទាយិភិក្ខុដ៏មានអាយុ ក៏ចូលទៅជិតស្រីនោះក្នុងពេលនោះឯង លុះចូលទៅដល់ហើយ ក៏ស្តីឲ្យថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ថាហើយ ក៏ខាកស្តោះដើរចេញទៅ ។ គ្រានោះឯង ស្រីនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងនេះជាកូនចៅព្រះពុទ្ធ ជាសក្យបុត្ត គ្មានសេចក្តីអៀនខ្មាស ទ្រុស្តសីល និយាយពាក្យកុហក ព្រោះថា សមណៈទាំងនេះប្តេជ្ញាខ្លួនថា ជាអ្នកប្រព្រឹត្តត្រឹមត្រូវ ប្រព្រឹត្តធម៌ ប្រព្រឹត្តដ៏ប្រសើរ និយាយពាក្យពិត មានសីល មានធម៌ជាកុសល សាមញ្ញគុណរបស់សមណៈទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះគ្មានទេ សាមញ្ញគុណរបស់សមណៈទាំងនេះ វិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះ វិនាសអស់ហើយ សាមញ្ញគុណរបស់

សមណៈទាំងនេះមានពីណា ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះមានពីណា សមណៈទាំងនេះ ប្រាសចាកសាមញ្ញគុណហើយ សមណៈទាំងនេះប្រាសចាកព្រហ្មញ្ញគុណហើយ មិនសមបីបើសមណៈឈ្មោះឧទាយិ សុំមេថុនធម្មនឹងអញដោយខ្លួនឯង ហើយស្តីថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ថាហើយខាកស្តោះ ចៀសចេញទៅ ( ដូច្នេះសោះ ) ការលាមករបស់អញដូចម្តេច ក្លិនអញអាក្រក់ដូចម្តេច អញដូចម្តេច អញអន់ ( ជាងស្រីឯទៀត ) ដោយអ្វី ។ ស្រីទាំងឡាយឯទៀតក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា សមណៈទាំងនេះជាកូនចៅព្រះពុទ្ធជាសក្យបុត្ត គ្មានសេចក្តីអៀនខ្មាស ទ្រុស្តសីល និយាយកុហក ព្រោះថា សមណៈទាំងនេះប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តត្រឹមត្រូវ ប្រព្រឹត្តធម៌ ប្រព្រឹត្តដ៏ប្រសើរ និយាយពាក្យពិត មានសីល មានធម៌ជាកុសល សាមញ្ញគុណរបស់សមណៈទាំងនេះគ្មានទេ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះគ្មានទេ សាមញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ ព្រហ្មញ្ញគុណរបស់សមណៈទាំងនេះវិនាសអស់ហើយ សាមញ្ញគុណរបស់សមណៈទាំងនេះមានពីណា ព្រហ្មញ្ញ-គុណរបស់សមណៈទាំងនេះមានពីណា សមណៈទាំងនេះប្រាសចាកសាមញ្ញ-គុណហើយ សមណៈទាំងនេះប្រាសចាកព្រហ្មញ្ញគុណហើយ មិនសមបីបើសមណៈឈ្មោះឧទាយិសុំមេថុនធម្មនឹងស្រីនេះដោយខ្លួនឯងហើយ បែរជាស្តីថា អ្នកណានឹងហ៊ានស្ទាបអង្អែលស្រីអាក្រក់មានក្លិនស្អុយយ៉ាងនេះ ហើយខាកស្តោះចៀសចេញទៅ ( ដូច្នេះសោះ ) ការលាមករបស់ស្រីនេះដូចម្តេច

ភិក្ខុនីរបស់ស្រីនេះអាក្រក់ដូចម្តេច ស្រីនេះដូចម្តេច ស្រីនេះថោកថយ ( ជាង ស្រីឯទៀត ) ដោយអ្វី ។ ភិក្ខុទាំងឡាយបានឮស្រី ទាំងឡាយនោះពោល ទោស តិះដៀល បន្តុះបង្អាប់ ( ដូច្នោះហើយ ) ។ ភិក្ខុទាំងឡាយណាដែល មានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីខ្មាស មានសេចក្តីរង្កៀស ប្រាថ្នាតែការសិក្សា ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបីបើឧទាយិភិក្ខុដ៏មានអាយុពោលសរសើរ ការបម្រើខ្លួនដោយកាម ក្នុងសំណាក់មាតុគ្រាមសោះ ។ ភិក្ខុទាំងនោះក៏ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏ មានព្រះភាគក្នុងពេលនោះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះ ភាគជាម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ឧទាយិភិក្ខុដ៏មាន អាយុក្នុងពេលនោះថា ម្នាលឧទាយិ បានឮថា អ្នកឯង ពោលសរសើរការ បម្រើខ្លួនដោយកាម ក្នុងសំណាក់មាតុគ្រាមមែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះ ភាគទ្រង់តិះដៀលថា ម្នាលបុរសសាបសូន្យ ដំណើរនេះមិនទំនង មិនសមគួរ មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគប្បីសោះ មិនគួរធ្វើសោះ ម្នាល មោឃបុរស មិនសមបីបើអ្នកឯងពោលសរសើរ ការបម្រើខ្លួនដោយកាមក្នុង សំណាក់មាតុគ្រាម ( ដូច្នោះទេ ) ម្នាលមោឃបុរស ធម៌ដែលតថាគត សម្តែងហើយដោយអនេកបរិយាយ ( សុទ្ធតែ ) ដើម្បីឲ្យប្រាសចាករាគៈ មិនមែនសម្តែងឲ្យប្រកបដោយរាគៈទេ ។បេ។ ការរម្ងាប់សេចក្តីក្តៅក្រហាយ ព្រោះកាម តថាគតក៏បានសម្តែងហើយ ម្នាលមោឃបុរស អំពើលាមករបស់

អ្នកឯងនុ៎ះ មិនមែននាំឲ្យកើតសេចក្ដីជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លានោះទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្ដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ គឺរាគៈគ្របសង្កត់ហើយ មានចិត្តប្រែប្រួល ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃមាតុគ្រាម ដោយសម្ដីប្រកបដោយមេថុនធម្មថា ស្រីណាគប្បីបម្រើនូវភិក្ខុមានសីល មានធម៌ជាកុសល ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរប្រហែលដូចអាត្មាដោយធម៌នេះ ម្នាលប្អូនស្រី ការបម្រើនេះរបស់ស្រីនោះជាការប្រសើរ ជាងការបម្រើទាំងអស់ ( ពោលពាក្យដូច្នោះ ) ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១១៥ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីអធិប្បាយក្នុងបារាជិកកណ្ឌសិក្ខាបទទី ១ រួចហើយ ។ ភិក្ខុមានសេចក្ដីត្រេកអរ ក្រឡេកមៀងមើល មានចិត្តប្រតិព័ទ្ធ ហៅថា មានចិត្ត គឺរាគៈគ្របសង្កត់ហើយ ។ ត្រង់ពាក្យថា ប្រែប្រួល សេចក្ដីថា ចិត្តត្រេកអរ ក៏ហៅថាប្រែប្រួល ចិត្តគឺទោសប្រទូស្ដ ក៏ហៅថាប្រែប្រួល ចិត្តវង្វេង ក៏ហៅថាប្រែប្រួល តែថាព្រះដ៏មានព្រះភាគសំដៅយកចិត្ត ដែលត្រេកអរថាជាចិត្តប្រែប្រួល ក្នុងអត្ថនេះ ។ មនុស្សស្រីដែលដឹងសេចក្ដី ឆ្លៀវឆ្លាស អាចដឹងច្បាស់នូវពាក្យដែលគេនិយាយល្អ និងអាក្រក់ សំដីគួរ និងមិនគួរ ហៅថាមាតុគ្រាម ( ក្នុងសិក្ខាបទនេះ ) ឯយក្សស្រី ប្រេតស្រី តិរច្ឆានញី មិនហៅថា មាតុគ្រាមទេ ។ ត្រង់ពាក្យថា ក្នុងសំណាក់នៃមាតុគ្រាម សេចក្ដីថា ជិតខាងមាតុគ្រាម គឺមិនឆ្ងាយអំពីមាតុគ្រាម ។ ត្រង់ពាក្យថា កាមដើម្បីខ្លួន សេចក្ដីថា ចំណង់ដើម្បី

ខ្លួន ហេតុដើម្បីខ្លួន សេចក្តីប្រាថ្នាដើម្បីខ្លួន ការបម្រើដើម្បីខ្លួន ។ ត្រង់ពាក្យថា ការបម្រើនេះប្រសើរ សេចក្តីថា ការបម្រើនេះប្រសើរ ការបម្រើនេះប្រសើរបំផុត ការបម្រើនេះជាគ្រឿងដោះខ្លួនឲ្យរួចចាកទុក្ខ ការបម្រើនេះខ្ពង់ខ្ពស់ ការបម្រើនេះគួរប្រាថ្នាណាស់ ។ ត្រង់ពាក្យថា ស្រីណា សេចក្តីថា ស្រីក្សត្រិយ៍ក្តី ស្រីព្រាហ្មណ៍ក្តី ស្រីអ្នកឈ្មួញក្តី ស្រីអ្នកគ្រួក្តី ។ ត្រង់ពាក្យថា ប្រហែលដូចអាត្មា សេចក្តីថា ក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី អ្នកឈ្មួញក្តី អ្នកគ្រួក្តី ។ ត្រង់ពាក្យថា មានសីល សេចក្តីថា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកមុសាវាទ ។ ត្រង់ពាក្យថា ប្រព្រឹត្តធម៌ដ៏ប្រសើរ គឺវៀរចាកមេថុនធម្ម ។ មានធម៌ជាកុសល ដោយសីលនោះផង ដោយព្រហ្មចរិយៈនោះផង ហៅថា មានធម៌ជាកុសល ។ ត្រង់ពាក្យថា ដោយធម៌នេះ គឺដោយមេថុនធម្ម ។ ត្រង់ពាក្យថា គប្បីបម្រើ គឺគប្បីត្រេកអរចំពោះ ។ ត្រង់ពាក្យថា ប្រកបដោយមេថុន គឺប្រកបព្រមចំពោះដោយមេថុនធម្ម ។ ត្រង់ពាក្យថា ត្រូវអាបត្តិសង្ឃាទិសេសនោះ មានអធិប្បាយពិស្តារ ក្នុងសង្ឃាទិសេសសិក្ខាបទទី ១ រួចហើយ ។

[ ១១៦ ] ស្រីពិតមែន ភិក្ខុសម្គាល់ថាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ស្រីពិតមែន ភិក្ខុមានសេចក្តីសង្ស័យក្តី សម្គាល់ថាខ្ទើយក្តី សម្គាល់ថាប្រុសក្តី សម្គាល់ថាតិរច្ឆានក្តី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីនោះ ត្រូវអាបត្តិ

ថុល្លច្ច័យ ។ ខ្ទើយពិតមែន ភិក្ខុសម្គាល់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយនោះ ត្រូវអាបត្តិថុល្លច្ច័យ ។ ខ្ទើយពិតមែន ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយនោះ ត្រូវអាបត្តិទុក្កដ ។ ប្រុសពិតមែន ភិក្ខុសម្គាល់ថាប្រុស ( ក្តី ) មានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃប្រុសនោះ ត្រូវអាបត្តិទុក្កដ ។ តិរច្ឆានពិតមែន ភិក្ខុសម្គាល់ថាតិរច្ឆាន ( ក្តី ) មានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃតិរច្ឆាននោះ ត្រូវអាបត្តិទុក្កដ ។

[ ១១៧ ] ស្រីពីរនាក់ ភិក្ខុសម្គាល់ស្រីទាំងពីរថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេសពីរ ។ ស្រីពីរនាក់ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) ចំពោះស្រីទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃស្រីទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។

ខ្ទើយពីរនាក់ ភិក្ខុសម្គាល់ខ្ទើយទាំងពីរថាជាខ្ទើយ ក៏មាន សេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃ ខ្ទើយទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យពីរ ។ ខ្ទើយពីរនាក់ ភិក្ខុមានសេចក្តី សង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) ចំពោះខ្ទើយទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាម ដើម្បីខ្លួន ក្នុងសំណាក់នៃខ្ទើយទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុសពីរនាក់ ភិក្ខុសម្គាល់ប្រុសទាំងពីរ ។បេ។ តិរច្ឆានពីរ ភិក្ខុសម្គាល់ថាតិរច្ឆាន ( ក្តី ) មានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) ចំពោះតិរច្ឆានទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់តិរច្ឆានទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងអាបត្តិទុក្កដ ។ ស្រីម្នាក់ ខ្ទើយម្នាក់ ភិក្ខុមានសេចក្តីសង្ស័យចំពោះជនទាំងពីរនាក់ ។បេ។ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ភិក្ខុសម្គាល់ថាខ្ទើយ ។បេ។ ត្រូវអាបត្តិថុល្លច្ច័យពីរ ។បេ។ ភិក្ខុសម្គាល់ថាប្រុស ។បេ។ ភិក្ខុសម្គាល់ថាតិរច្ឆាន ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងអាបត្តិទុក្កដ ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាស្រី ក៏មានសេចក្តីត្រេកអរ

ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រីម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) ចំពោះជនទាំងពីរនាក់ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុសម្គាល់ជនទាំងពីរជាស្រី ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិសង្ឃាទិសេស និងទុក្កដ ។ ស្រីម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្តី សង្ស័យ ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុសម្គាល់ជនទាំងពីរនាក់ថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ខ្ទើយម្នាក់ ប្រុសម្នាក់ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិទុក្កដពីរ ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុសម្គាល់ជនទាំងពីរនោះថាខ្ទើយ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការ

បម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនាក់នោះ ត្រូវអាបត្តិថុល្លច្ច័យ និងទុក្កដ ។ ខ្ទើយម្នាក់ តិរច្ឆានមួយ ភិក្ខុមានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាប្រុស ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។ ប្រុសម្នាក់ តិរច្ឆានមួយ ភិក្ខុសម្គាល់ថាប្រុស ( ក្តី ) មានសេចក្តីសង្ស័យ ( ក្តី ) សម្គាល់ថាតិរច្ឆាន ( ក្តី ) សម្គាល់ថាស្រី ( ក្តី ) សម្គាល់ថាខ្ទើយ ( ក្តី ) ចំពោះជនទាំងពីរ ក៏មានសេចក្តីត្រេកអរ ពោលសរសើរការបម្រើជាកាមដើម្បីខ្លួន ក្នុងសំណាក់នៃជនទាំងពីរនោះ ត្រូវអាបត្តិទុក្កដពីរ ។

[ ១១៨ ] អាបត្តិមិនមាន ( ដល់ភិក្ខុ ៣ ពួក ) គឺភិក្ខុពោលថា នាងចូរបម្រើអាត្មាដោយចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជា បច្ច័យដល់អ្នកមានជំងឺ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាខាងដើមបញ្ញត្តិ ១ ។

( មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសម្តែងតទៅដូចមានខាងក្រោយនេះ គឺ )

[ ១១៩ ] ស្រីអារ ស្រីបានកូន ស្រីចង់ឲ្យប្តីស្រឡាញ់ ស្រីចង់បានរូបល្អ សួរភិក្ខុថាធ្វើដូចម្តេច ស្រីចង់ឲ្យទាន ស្រីចង់បម្រើ សួរភិក្ខុថាធ្វើដូចម្តេច ស្រីចង់ទៅសុគតិ សួរភិក្ខុថាធ្វើដូចម្តេច ។

[ ១២០ ] សម័យនោះឯង មានស្រីម្នាក់ជាស្រីអារ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណា

នឹងគិតធ្វើដូចម្តេចឲ្យមានកូន ។ ភិក្ខុនោះឆ្លើយថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីអារនោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ទើបយកសេចក្តីនោះក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់ជាស្រីមានកូន បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណា ត្រូវធ្វើដូចម្តេចកុំឲ្យបានកូន ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះ តើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់បាននិយាយពាក្យនេះ នឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណា ត្រូវធ្វើដូចម្តេចឲ្យជាទីស្រឡាញ់នៃប្តី ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់ បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណាត្រូវធ្វើដូចម្តេចឲ្យជាស្រីមាន

រូបល្អ ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះតើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់បាននិយាយពាក្យនេះ នឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណានឹងឲ្យទានដូចម្តេចដល់លោកម្ចាស់ ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះ តើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណាផ្គត់ផ្គង់លោកម្ចាស់ ដោយទានដូចម្តេច ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី ចូរនាងផ្គត់ផ្គង់ដោយទានដ៏ប្រសើរចុះ ។ ស្រីនោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះ តើដូចម្តេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។ សម័យនោះឯង មានស្រីម្នាក់បាននិយាយពាក្យនេះនឹងភិក្ខុដែលតែងទៅមកកាន់ត្រកូលថា បពិត្រលោកដ៏ចម្រើន ខ្ញុំករុណាគប្បីទៅកាន់សុគតិ ដោយកុសលដូចម្តេច ។ ភិក្ខុនោះប្រាប់ថា ម្នាលប្អូនស្រី បើដូច្នោះ នាងចូរឲ្យទានដ៏ប្រសើរចុះ ។ ស្រី

នោះសួរថា បពិត្រលោកដ៏ចម្រើន ទានដ៏ប្រសើរនោះ តើដូចម្ដេច ។ ភិក្ខុនោះប្រាប់ថា មេថុនធម្ម ។ ភិក្ខុនោះមានសេចក្ដីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយទេដឹង ។ ទើបយកសេចក្ដីនោះក្រាបទូលដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិសង្ឃាទិសេសហើយ ។

សង្ឃាទិសេសទី ៤ ចប់

# អដ្ឋកថា

## អត្តកាមបារិចរិយសិក្ខាបទវណ្ណនា

[ ១១៤ ] ត្រង់បទថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅថា វិនិច្ឆ័យក្នុងអត្តកាមបារិចរិយសិក្ខាបទនោះ គប្បីជ្រាបដូច្នេះថា

បទថា **កុលុបកោ** សេចក្តីថា ជាអ្នកចូលជិតត្រកូល គឺជាអ្នកខ្វល់ខ្វាយជានិច្ចក្នុងការចូលរកត្រកូល ដើម្បីបច្ច័យ ៤ ។

បទថា **ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ** បានដល់ ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ ក្នុងបណ្តាបទថា **គិលានប្បច្ចយភេសជ្ជបរិក្ខារំ** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ដែលឈ្មោះថា បច្ច័យ ព្រោះអត្ថថា ធ្វើការបំបាត់ ។ ពាក្យថា បច្ច័យ ជាឈ្មោះនៃភេសជ្ជៈដែលសប្បាយប្រភេទណាមួយ ។ ឈ្មោះថា កម្មរបស់ពេទ្យ ព្រោះពេទ្យទាំងនោះអនុញ្ញាត ដូច្នោះ ទើបឈ្មោះថា ភេសជ្ជៈ ។ គិលានប្បច្ច័យផង ភេសជ្ជៈផង ឈ្មោះថា គិលានប្បច្ចយភេសជ្ជៈ ។ មានពាក្យអធិប្បាយថា ការងាររបស់ពេទ្យ មានប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ប្រភេទណាមួយ ជាទីសប្បាយដល់អ្នកជំងឺ ។ គ្រឿងរក្សា លោកហៅថា បរិក្ខារ ក្នុងពាក្យជាដើមថា **សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ ហោតិ** នគរដែលរៀបចំល្អហើយ ដោយនគរបរិក្ខារ ៧ យ៉ាង ដូច្នេះ ។

គ្រឿងប្រដាប់ លោកហៅថា បរិក្ខារ ក្នុងពាក្យជាដើមថា **រថោ សីលបរិក្ខារោ ឈានក្ខោ ចក្កវីរិយោ** រថ គឺអរិយមគ្គ ( នោះ ) មានសីលជាគ្រឿងប្រដាប់ មានឈានជាភ្លៅ មានវីរិយៈជាកង់ ដូច្នេះ ។ គ្រឿងបម្រុង

លោកហៅថា បរិក្ខារ ក្នុងប្រយោគជាដើមថា **យេ ចិមេ បព្វជិតេន ជីវិត-បរិក្ខារា សមុទានេតព្វា** គ្រឿងបម្រុងជីវិតទាំងឡាយ ដែលបព្វជិតគប្បីស្វែងរក ដូច្នេះ ។ ក្នុងបទថា **គិលានប្បច្ចយភេសជ្ជបរិក្ខារំ** នេះ រមែងគួរទាំងគ្រឿងបម្រុង ទាំងគ្រឿងរក្សា ។

ពិតហើយ គិលានប្បច្ចយភេសជ្ជៈនោះ ជាគ្រឿងរក្សាជីវិតខ្លះ ព្រោះមិនឲ្យឱកាសដល់ការកើតឡើងនៃអាពាធ ដែលនឹងញុំាងជីវិតឲ្យវិនាស ជាគ្រឿងបម្រុងខ្លះ ព្រោះជាហេតុឲ្យជីវិតនោះប្រព្រឹត្តទៅបានយូរ ព្រោះដូច្នោះទើបហៅថា បរិក្ខារ គប្បីជ្រាបអត្ថយ៉ាងនេះថា គិលានប្បច្ចយភេសជ្ជៈនោះផង ជាបរិក្ខារផង ដោយន័យដូចពោលមកនេះ ព្រោះដូច្នោះ ទើបឈ្មោះថា គិលានប្បច្ចយភេសជ្ជបរិក្ខារ ។ នូវគិលានប្បច្ចយភេសជ្ជបរិក្ខារនោះ ។

បទថា **វិសលំ** ប្រែថា ថោកទាប គឺអាក្រក់ ។ ម្យ៉ាងទៀត បុគ្គលដែលឈ្មោះថា **វិសល** ព្រោះអត្ថថា ហូរចេញមក អធិប្បាយថា រមែងខ្ពុរចេញនូវគ្រឿងមិនស្អាត ។

បទថា **ឧដ្ឋុហិត្វា** ប្រែថា ស្តោះទឹកមាត់ឲ្យធ្លាក់ទៅ ។

ដោយពាក្យថា **កិស្សាហំ កេន ហាយាមិ** ដូច្នេះ ស្រីនោះសម្តែងថា អញនឹងអន់ជាងស្រីដទៃមួយណា ពោលដោយអ្វី ពោលដោយភោគៈក្តី ដោយគ្រឿងអលង្ការក្តី ដោយរូបរាងក្តី ស្រីឈ្មោះដូចម្តេចទៅ ដែលជាអ្នកល្អក្រៃលែងជាងអញនោះ ។

បទថា **សន្តិកេ** ប្រែថា ឈរក្នុងទីជិតបង្កើយ គឺក្នុងទីមិនឆ្ងាយដោយ

*ជុំវិញ ។ សូម្បីដោយបទភាជនីយ៍ លោកក៏សម្តែងអត្ថយ៉ាងនេះដូចគ្នា ។*

*បទថា* **អត្តកាមចារិចរិយាយ** *សេចក្តីថា ការបម្រើដោយកាម ពោល គឺមេថុនធម្ម ឈ្មោះថា* **កាមចារិចរិយាយ** ។ *ការបម្រើដោយកាម ដើម្បីប្រយោជន៍ដល់ខ្លួន ឈ្មោះថា* **អត្តកាមចារិចរិយាយ** ។ *ម្យ៉ាងទៀត ការបម្រើដែលខ្លួនស្រឡាញ់ គឺប្រាថ្នា ព្រោះដូច្នោះ ទើបឈ្មោះថា* **អត្តកាម** *អធិប្បាយថា ភិក្ខុឯងប្រាថ្នាហើយ ដោយអំណាចនៃតម្រេកក្នុងមេថុន ការបម្រើនោះផង ដែលខ្លួនឲ្យប្រាថ្នាផង ព្រោះដូច្នោះ ទើបឈ្មោះថា* **អត្តកាម-ចារិចរិយាយ** ។ *នៃការបម្រើដោយកាម ដើម្បីប្រយោជន៍ដល់ខ្លួន ( ឬនៃការបម្រើដែលខ្លួនប្រាថ្នា ) នោះ ។*

*ពីរបទថា* **វណ្ណំ ភាសេយ្យ** *សេចក្តីថា គប្បីប្រកាសគុណ គឺអានិសង្ស ។ ក្នុងអត្ថវិកប្បទាំងពីរនោះ ក្នុងអត្ថវិកប្បថា ការបម្រើកាមដើម្បីប្រយោជន៍ខ្លួន បានអត្ថ គឺកាម ១ ហេតុ ១ ការបម្រើ ១ ព្យញ្ជនៈដ៏សេស ក្នុងអត្ថវិកប្បថា ការបម្រើនោះផង ដែលខ្លួនប្រាថ្នាផង ឈ្មោះថា* **អត្តកាម-ចារិចរិយា** *បានអត្ថ គឺការបំណង ១ ការបម្រើ ១ ព្យញ្ជនៈដ៏សេស ព្រោះហេតុនោះ ដើម្បីមិនធ្វើការអើពើក្នុងព្យញ្ជនៈ សម្តែងអត្ថប៉ុណ្ណោះ ទើបព្រះដ៏មានព្រះភាគត្រាស់បទភាជនីយ៍ថា គឺជាហេតុនៃខ្លួន ជាទីបំណងនៃខ្លួន ។ ពិតហើយ កាលទ្រង់ត្រាស់ពាក្យថា ការបម្រើខ្លួន បណ្ឌិតទាំងឡាយនឹងជ្រាបថា ការបម្រើដោយកាមដើម្បីប្រយោជន៍ដល់ខ្លួន លោកពោលហើយដោយពាក្យមាន ប្រមាណប៉ុណ្ណោះ កាលលោកពោលពាក្យថា ការបម្រើខ្លួន*

ជាទីបំណាន់នៃខ្លួន បណ្ឌិតទាំងឡាយក៏ជ្រាបថា ការបម្រើដែលខ្លួនប្រាថ្នា ដោយអត្ថថា ដែលខ្លួនបំណាង លោកពោលដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់សម្តែងអាការក្នុងការសរសើរគុណនៃការបម្រើខ្លួនដោយកាមនោះ ទើបទ្រង់ត្រាស់ពាក្យថា **ឯតទគ្គំ** ជាដើម ។ ពាក្យនោះ មានអត្ថជាក់ច្បាស់ហើយ ទាំងដោយឧទ្ទេស និងដោយនិទ្ទេស ។

ចំណែកបទសម្ពន្ធ និងវិនិច្ឆ័យអាបត្តិក្នុងសិក្ខាបទនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ពាក្យថា **ឯតទគ្គំ ។បេ។ បរិចរេយ្យ** សេចក្តីថា ស្រីណាគប្បីបម្រើអ្នកប្រព្រឹត្តព្រហ្មចរិយៈ មានសីល មានកល្យាណធម៌ដូចអាត្មា ដោយធម៌នោះ ដែលឈ្មោះថា ការបម្រើនេះរបស់ស្រីនោះ ដែលបម្រើអ្នកប្រព្រឹត្តព្រហ្មចរិយៈដូចអាត្មាយ៉ាងនោះ ការបម្រើនេះ ជាកំពូលនៃការបម្រើទាំងឡាយ ។

ពីរបទថា **មេថុនូបសញ្ហិតេន សង្ឃាទិសេសោ** សេចក្តីថា ភិក្ខុណាកាលពោលគុណនៃការបម្រើខ្លួន ដោយកាមយ៉ាងនោះ គប្បីពោលដោយអាស្រ័យមេថុនពិតៗ គឺសំដៅចំពោះមេថុនពិតៗ ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុនោះ ។

# អធិប្បាយ
# សិក្ខាបទវិភង្គនៃអត្តកាមចារិចរិយសិក្ខាបទ

[ ១១៥ ] ឥឡូវនេះ ព្រះមានព្រះភាគ កាត់អាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលពោលពាក្យសម្តី បដិសំយុត្តដោយមេថុនប៉ុណ្ណោះ ព្រោះហេតុនោះ

ទើបមិនត្រូវអាបត្តិសង្ឃាទិសេស ដល់ភិក្ខុដែលពោលគុណនៃការបម្រើ ដោយពាក្យជាដើមយ៉ាងនេះថា អាត្មាជាក្សត្រ នាងជាក្សត្រ នាងជាក្សត្រ សមគួរឲ្យដល់ក្សត្រ ព្រោះមានជាតិស្មើគ្នា ។ តែត្រូវអាបត្តិសង្ឃាទិសេស ដល់ភិក្ខុដែលពោលបរិយាយច្រើន មានពាក្យថា អាត្មាជាក្សត្រ នាងក៏ជាក្សត្រជាដើម ហើយពោលពាក្យបដិសំយុត្តដោយមេថុនចំៗ យ៉ាងនេះថា នាងគួរឲ្យមេថុនដល់អាត្មា ។

[ ១១៦ ] បទថា **ឥត្ថី ច ហោតិ** ជាដើម មានន័យដូចពោលហើយខាងដើមនោះឯង ។ ព្រះឧទាយិត្ថេរជាអាទិកម្មិកក្នុងសិក្ខាបទនេះ មិនត្រូវអាបត្តិដល់លោកដែលជាអាទិកម្មិក ដូច្នេះឯង ។

បកិណ្ណកៈទាំងពួង មានសមុដ្ឋានជាដើម ដូចទុដ្ឋុលវាចាសិក្ខាបទ ។ សូម្បីវិនីតវត្ថុទាំងឡាយ ក៏មានអត្ថជាក់ច្បាស់ទាំងអស់ដោយប្រការដូច្នេះ ។

អត្តកាមបារិចរិយសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ៥

[ ១២១ ] សម័យនោះឯង ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ឧទាយិភិក្ខុដ៏មានអាយុជាអ្នកចូលទៅកាន់ត្រកូលក្នុងក្រុងសាវត្ថី តែងចូលទៅកាន់ត្រកូលទាំងឡាយមានប្រមាណច្រើន ឃើញកុមារដែលគ្មានប្រពន្ធក្តី ឃើញនាងកុមារីដែលគ្មានប្តីក្តីក្នុងទីណា ក៏និយាយសរសើរនាងកុមារីក្នុងសំណាក់នៃមាតាបិតារបស់កុមារ ( ក្នុងទីនោះ ) ថា នាងកុមារីរបស់ត្រកូលឯណោះមាន រូបល្អគួរគយគន់មើល ល្មមជ្រះថ្លា ជាស្រីមានប្រាជ្ញាអង់អាច ឆ្លៀវឆ្លាសវាងវៃ មិនខ្ជិលច្រអូស នាងកុមារីនោះ សមគ្នានឹងកុមារនេះណាស់ ។ មាតាបិតារបស់កុមារនោះ ក៏និយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ អ្នកអស់នោះគេមិនធ្លាប់ស្គាល់យើងខ្ញុំថា អ្នកអស់ទាំងនុ៎ះ ជាអ្វីក្តី ជាកូនចៅអ្នកណាក្តីដូច្នេះឡើយ បពិត្រលោកដ៏ចម្រើន ប្រសិនបើលោកម្ចាស់ឲ្យគេឲ្យ យើងខ្ញុំគួរនាំនាងកុមារីនោះមកផ្សំឲ្យកុមារនេះដែរ ។ ឧទាយិភិក្ខុដ៏មានអាយុ ពោលសរសើរកុមារក្នុងសំណាក់មាតាបិតារបស់នាងកុមារីថា កុមាររបស់ត្រកូលឯណោះ មានរូបល្អគួរគយគន់មើល ល្មមជ្រះថ្លា ជាប្រុសមានប្រាជ្ញាអង់អាចឆ្លៀវឆ្លាស វៀងវៃ មិនខ្ជិលច្រអូស កុមារនោះ សមគ្នានឹងនាងកុមារីនេះណាស់ ។ ម្តាយឪពុកនាងកុមារីនោះឆ្លើយថា បពិត្រលោកម្ចាស់ អ្នកអស់នុ៎ះមិនធ្លាប់ស្គាល់យើងថា អ្នកអស់នោះជាអ្វីក្តី ជាកូនចៅអ្នកណាក្តី ការ

ដែលយើងនិយាយព្រោះនាងកុមារីដូចជាអៀនមាត់ពេកណាស់ បពិត្រលោកដ៏ចម្រើន បើលោកម្ចាស់ឲ្យគេមកដណ្តឹងយើងៗគួរឲ្យនាងកុមារីនេះដល់កុមារនោះដែរ ។ ឧទាយិភិក្ខុតែងឲ្យត្រកូលរៀបចំអាវាហមង្គលផង វិវាហមង្គលផង ឲ្យស្តីដណ្តឹងគ្នានឹងគ្នាផង សុទ្ធតែដោយឧបាយនេះឯង ។

[ ១២២ ] សម័យនោះឯង មានកូនក្រមុំ នៃស្រីមេម៉ាយម្នាក់ជាប្រពន្ធហោរាចាស់ មានរូបឆោមស្រស់បស់ គួរគយគន់មើល នាំឲ្យជ្រះថ្លា ។ ពួកសាវ័ករបស់អាជីវកនៅស្រុកក្រៅបានចូលមកនិយាយនឹងប្រពន្ធហោរានោះថា ម្នាលអ្នកស្រី អ្នកចូរឲ្យនាងកុមារីនេះ មកកុមាររបស់យើងទៅ ។ ប្រពន្ធហោរា ក៏និយាយយ៉ាងនេះថា បពិត្រអ្នកម្ចាស់ទាំងឡាយ ខ្ញុំឯងមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀតធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយថា ត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ ។ មនុស្សទាំងឡាយសួរទៅពួកសាវ័ករបស់អាជីវកនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ អស់អ្នកមកនេះមានការអ្វី ។ ពួកសាវ័ករបស់អាជីវកនោះប្រាប់ថា យើងមកដណ្តឹងធីតារបស់អ្នកស្រីប្រពន្ធហោរាឈ្មោះឯណោះក្នុងស្រុកនេះ ឲ្យកុមាររបស់យើង តែនាងនោះនិយាយថា បពិត្រអ្នកម្ចាស់ទាំងឡាយ ខ្ញុំឯងមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀតធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយថាត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ ។ មនុស្សទាំងឡាយនោះ ប្រាប់ទៅពួកសាវ័ករបស់អាជីវកវិញថា បពិត្រអ្នកម្ចាស់ទាំងឡាយ ថ្វីបានជាអ្នកទៅដណ្តឹងធីតា

របស់ប្រពន្ធហោភនោះ ក្រែងត្រូវអ្នកទាំងឡាយពិតលោកម្ចាស់ឧទាយិ លោកម្ចាស់ឧទាយិនឹងបង្គាប់ឲ្យគេឲ្យទេឬ ។ គ្រានោះឯង ពួកសាវ័ករបស់អាជីវកក៏ចូលទៅឯទីដែលឧទាយិភិក្ខុនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន យើងមកដណ្តឹងធីតារបស់ប្រពន្ធហោភឈ្មោះឯណោះក្នុងស្រុកនេះ ឲ្យកុមាររបស់យើង តែនាងនោះនិយាយយ៉ាងនេះថា ខ្ញុំឯងមិនធ្លាប់ស្គាល់អស់អ្នកថា អ្នកទាំងឡាយជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀតធីតានេះ ជាធីតាតែមួយរបស់ខ្ញុំ ហើយថាត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ បពិត្រលោកដ៏ចម្រើន យើងសូមពឹងលោកម្ចាស់ សូមលោកម្ចាស់និយាយនឹងប្រពន្ធហោភ ឲ្យៗកូនស្រីមកកុមាររបស់យើងទៅ ។ គ្រានោះឯង ឧទាយិភិក្ខុដ៏មានអាយុ ក៏ចូលទៅត្រង់ទីដែលប្រពន្ធហោភនៅ លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងប្រពន្ធហោភនោះថា ហេតុអ្វីបានជានាងមិនឲ្យធីតាដល់អ្នកអស់នេះ ។ ប្រពន្ធហោភក៏ឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាមិនធ្លាប់ស្គាល់អ្នកអស់នេះថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ធីតានេះជាធីតាតែមួយរបស់ខ្ញុំ ហើយថាត្រូវទៅស្រុកក្រៅផងទៀត ខ្ញុំមិនឲ្យទេ ។ ឧទាយិភិក្ខុក៏និយាយថា នាងចូរឲ្យទៅអ្នកទាំងនេះចុះ អាត្មាធ្លាប់ស្គាល់គេដែរ ។ ប្រពន្ធហោភនិយាយថា បពិត្រលោកដ៏ចម្រើន បើលោកម្ចាស់ស្គាល់ ខ្ញុំព្រះករុណានឹងឲ្យ ។ គ្រានោះឯង ប្រពន្ធហោភនោះ ក៏បានឲ្យធីតាទៅពួកសាវ័ករបស់អាជីវកនោះ ។ លំដាប់នោះ ពួកសាវ័ករបស់អាជីវកនោះឯង ក៏បាន

នាំនាងកុមារីនោះទៅ ហើយប្រើប្រាស់នាងដោយការបម្រើជាកូនប្រសាបាន តែត្រឹម ១ ខែ តពីនោះមក ប្រើប្រាស់នាងដោយការបម្រើជាទាសីទៅវិញ ។

[ ១២៣ ] គ្រានោះឯង នាងកុមារីនោះក៏ប្រើបម្រើទៅឯសំណាក់ម្ដាយ ដោយពាក្យថា ខ្ញុំដល់នូវសេចក្ដីក្រីក្រលំបាក មិនបានសេចក្ដីសុខទេ ព្រោះពួកសាវ័ករបស់អាជីវក ប្រើប្រាស់ខ្ញុំដោយការបម្រើជាកូនប្រសា បាន តែត្រឹម ១ ខែទេ តពីនោះមកក៏ប្រើប្រាស់ខ្ញុំដោយការបម្រើជាទាសីទៅវិញ សូមឲ្យអ្នកម្ដាយខ្ញុំ មកនាំយកខ្ញុំទៅផង ។ គ្រានោះឯង ប្រពន្ធហោរានោះ ក៏ចូលទៅត្រង់ទីដែលពួកសាវ័ករបស់អាជីវកនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងពួកសាវ័ករបស់អាជីវកនោះថា បពិត្រលោកម្ចាស់ទាំងឡាយ អ្នកទាំងឡាយកុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាទាសីឡើយ ត្រូវប្រើប្រាស់នាងកុមារីនោះ ដោយការបម្រើជាកូនប្រសាវិញ ។ ពួកសាវ័ករបស់អាជីវកក៏និយាយថា យើងគ្មានទាក់ទងជាមួយនឹងនាងឯងទេ យើងមានទាក់ទងតែនឹងសមណៈរបស់យើងទេតើ នាងឯងទៅៗ យើងមិនស្គាល់នាងឯងទេ ។ ឯប្រពន្ធហោរានោះ កាលបើពួកសាវ័ករបស់អាជីវកទាំងនោះធ្វើមិនឲ្យជ្រះថ្លាហើយ ក៏ត្រឡប់មកក្រុងសាវត្ថីវិញ ។ នាងកុមារីក៏ប្រើបម្រើទៅឯសំណាក់ម្ដាយ ក្នុងលើកទី ២ ទៀតថា ខ្ញុំដល់នូវសេចក្ដីក្រីក្រលំបាកមិនបានសេចក្ដីសុខទេ ព្រោះពួកសាវ័ករបស់អាជីវកប្រើប្រាស់ខ្ញុំដោយការបម្រើជាកូនប្រសាបានតែត្រឹម ១ ខែទេ តពីនោះមកក៏ប្រើប្រាស់ខ្ញុំដោយការបម្រើជាទាសីទៅវិញ សូមអ្នកម្ដាយខ្ញុំ មកនាំយកខ្ញុំទៅផង ។ ឯ

ប្រពន្ធហោរាក៏ចូលទៅត្រង់ទីដែលឧទាយិភិក្ខុដ៏មានអាយុនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន ឮដំណឹងថា នាងកុមារីនោះ ដល់នូវសេចក្ដីក្រីក្រលំបាក មិនបានសេចក្ដីសុខសោះ ព្រោះពួកសាវ័ករបស់អាជីវកប្រើប្រាស់វា ដោយការបម្រើជាកូនប្រសាបានតែត្រឹម ១ ខែទេ តពីនោះមក ក៏ប្រើប្រាស់ដោយការបម្រើជាទាសីទៅវិញ បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់និយាយនឹងគេដូច្នេះថា ម្នាលអ្នកទាំងឡាយ អ្នកទាំងអស់គ្នា កុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាទាសីឡើយ ចូរប្រើប្រាស់នាងកុមារីនេះដោយការបម្រើជាកូនប្រសាវិញ ។ គ្រានោះឯង ឧទាយិដ៏មានអាយុ ចូលទៅត្រង់ទីដែលពួកសាវ័ករបស់អាជីវកនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងពួកសាវ័ករបស់អាជីវកនោះថា ម្នាលអ្នកទាំងឡាយ អ្នកទាំងអស់គ្នា កុំប្រើប្រាស់នាងកុមារីនោះ ដោយការបម្រើជាទាសីឡើយ ចូរប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាកូនប្រសាវិញ ។ ពួកសាវ័ករបស់អាជីវកនោះឆ្លើយថា យើងគ្មានទាក់ទងជាមួយនឹងលោកទេ យើងមានទាក់ទងតែនឹងប្រពន្ធហោរាទេតើ សមណៈមិនត្រូវខ្វល់ខ្វាយទេ សមណៈត្រូវតែជាសមណៈល្អ លោកចូរទៅវិញទៅ យើងមិនស្គាល់លោកទេ ។ ឯឧទាយិភិក្ខុដ៏មានអាយុ កាលដែលពួកសាវ័ករបស់អាជីវកមិនឲ្យជ្រះថ្លាហើយ ក៏ត្រឡប់មកកាន់ក្រុងសាវត្ថីវិញ ។ នាងកុមារីនោះក៏ប្រើបម្រើទៅឯសំណាក់ម្ដាយក្មេកលើកទី ៣ ទៀតថា ខ្ញុំម្ចាស់ដល់នូវសេចក្ដីក្រីក្រលំបាកណាស់ មិនបានសេចក្ដីសុខទេ ព្រោះពួក

សាវ័ករបស់អាជីវកប្រើប្រាស់ខ្ញុំ ដោយការបម្រើជាកូនប្រសាបានតែត្រឹម ១ ខែទេ តពីនោះមកក៏ប្រើប្រាស់ ដោយការបម្រើជាទាសីវិញ សូមឲ្យអ្នកម្ដាយខ្ញុំអញ្ជើញមកនាំយកខ្ញុំទៅផង ។ ប្រពន្ធហោរានោះចូលទៅឯទីដែលឧទាយិភិក្ខុនៅ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏មានអាយុក្នុងលើកទី ២ ថា បពិត្រលោកម្ចាស់ ឮដំណឹងថានាងកុមារីនោះជាស្រីដល់នូវសេចក្ដីក្រីក្រលំបាកណាស់ មិនបានសេចក្ដីសុខទេ ព្រោះពួកសាវ័ករបស់អាជីវកប្រើប្រាស់វា ដោយការបម្រើជាកូនប្រសាបានតែត្រឹម ១ ខែទេ តពីនោះមក ក៏ប្រើប្រាស់ដោយការបម្រើជាទាសីវិញ បពិត្រលោកដ៏ចម្រើន គួរលោកម្ចាស់ ទៅនិយាយនឹងគេថា ម្នាលអ្នកទាំងឡាយ អ្នកទាំង-ឡាយទាំងអស់គ្នាកុំប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាខ្ញុំស្រី ចូរប្រើប្រាស់នាងកុមារីនេះ ដោយការបម្រើជាកូនប្រសាវិញ ។ ឧទាយិភិក្ខុឆ្លើយថា កាលពីមុន ពួកសាវ័ករបស់អាជីវក ធ្វើអាត្មាមិនឲ្យជ្រះថ្លាម្ដងទៅហើយ ឥឡូវនេះនាងចូរទៅចុះ អាត្មាមិនទៅទៀតទេ ។

[ ១២៤ ] គ្រានោះឯង ប្រពន្ធហោរានោះ ក៏ពោលទោសតិះដៀលបន្តុះបង្អាប់ឧទាយិភិក្ខុថា នាងកុមារីកូនអញ ដល់នូវសេចក្ដីក្រីក្រលំបាកមិនបានសេចក្ដីសុខយ៉ាងណាៗ ក៏ព្រោះតែម្ដាយក្មេកអាក្រក់ ព្រោះតែឪពុកក្មេកអាក្រក់ ព្រោះតែប្ដីអាក្រក់ ចូរឲ្យលោកម្ចាស់ឧទាយិក្រីក្រដូចយ៉ាងកូនអញ ចូរឲ្យលោកម្ចាស់ឧទាយិលំបាកដូចយ៉ាងកូនអញ ចូរឲ្យលោកម្ចាស់ឧទាយិ កុំបានសេចក្ដីសុខ ដូចយ៉ាងកូនអញទៅចុះ ទាំងនាងកុមារីសោត ក៏

ពោលទោស តិះដៀល បន្តុះបង្អាប់ឧទាយិភិក្ខុថា អញដល់នូវសេចក្តីក្រីក្រលំបាក មិនបានសេចក្តីសុខយ៉ាងណាៗ ក៏ព្រោះតែម្តាយក្មេកអាក្រក់ ព្រោះតែឪពុកក្មេកអាក្រក់ ព្រោះតែប្តីអាក្រក់ ឲ្យលោកម្ចាស់ឧទាយិក្រីក្រដូចយ៉ាងអញ ឲ្យលោកម្ចាស់ឧទាយិលំបាកដូចយ៉ាងអញ ឲ្យលោកម្ចាស់ឧទាយិកុំបានសេចក្តីសុខដូចយ៉ាងអញទៅចុះ ។ ទាំងពួកស្រីដទៃ ដែលម្តាយក្មេកក្តី ឪពុកក្មេកក្តី ប្តីក្តី មិនត្រេកអរ ស្រីទាំងនោះ ក៏ផ្តន្ទាថា យើងដល់នូវសេចក្តីក្រីក្រលំបាកមិនបានសេចក្តីសុខយ៉ាងណាៗ ក៏ព្រោះតែម្តាយក្មេកអាក្រក់ ព្រោះតែឪពុកក្មេកអាក្រក់ ព្រោះតែប្តីអាក្រក់ ឲ្យលោកម្ចាស់ឧទាយិក្រីក្រដូចយ៉ាងយើង ឲ្យលោកម្ចាស់ឧទាយិលំបាកដូចយ៉ាងយើង ឲ្យលោកម្ចាស់ឧទាយិ កុំបានសេចក្តីសុខដូចយ៉ាងយើងទៅចុះ ។ ឯពួកស្រីណា ដែលម្តាយក្មេកក្តី ឪពុកក្មេកក្តី ប្តីក្តី ត្រេកអរហើយ ពួកស្រីទាំងនោះ ក៏បន់ស្រន់យ៉ាងនេះថា យើងដល់នូវសេចក្តីសុខបរិបូណ៌ដោយគ្រឿងស្អិតស្អាង ដល់នូវសេចក្តីសប្បាយយ៉ាងណាៗ ក៏ព្រោះតែម្តាយក្មេកល្អ ព្រោះតែឪពុកក្មេកល្អ ព្រោះតែប្តីល្អ សូមឲ្យលោកម្ចាស់ឧទាយិដល់នូវសេចក្តីសុខដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ឧទាយិ បរិបូណ៌ដោយគ្រឿងស្អិតស្អាងដូចយ៉ាងយើង សូមឲ្យលោកម្ចាស់ឧទាយិដល់នូវសេចក្តីសប្បាយដូចយ៉ាងយើងចុះ ។

[ ១២៥ ] ភិក្ខុទាំងឡាយឮស្រីខ្លះ កាលផ្តន្ទាឲ្យវិនាស ស្រីខ្លះកាលបន់ស្រន់ឲ្យចម្រើន ( ដល់ឧទាយិភិក្ខុនោះ ) ។ ពួកភិក្ខុណា ដែលមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស ។បេ។ ពួកភិក្ខុនោះ ក៏ពោលទោស

តិះដៀល បន្តុះបង្អាប់ថា មិនសមបើឧទាយិភិក្ខុដ៏មានអាយុ ប្រព្រឹត្តនិយាយ ដឹកនាំស្រីឲ្យប្រុស ដឹកនាំប្រុសឲ្យស្រីសោះ ។ គ្រានោះឯង ភិក្ខុទាំងឡាយ នោះក៏ក្រាបទូលរឿងនុ៎ះ ដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃមកក្នុងពេលនោះ ហើយទ្រង់ សួរបញ្ជាក់ឧទាយិភិក្ខុដ៏មានអាយុដូច្នេះថា ម្នាលឧទាយិ ឮថាអ្នកឯងប្រព្រឹត្ត និយាយដឹកនាំស្រីប្រុស ពិតមែនឬ ។ ឧទាយិភិក្ខុក្រាបទូលថា សូមទ្រង់ ព្រះមេត្តាប្រោស ពិតមែន ។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះ ដៀលថា ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនុ៎ះមិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ មិនគួរសោះ មិនគប្បីធ្វើសោះឡើយ ម្នាលមោឃបុរស គួរបើដែរ អ្នកឯងហ៊ានប្រព្រឹត្តនិយាយដឹកនាំស្រីប្រុស ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យកើតសេចក្តីជ្រះថ្លាដល់ពួកជនដែល មិនទាន់ជ្រះថ្លានោះទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី សំដែងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ប្រព្រឹត្តនិយាយដឹកនាំ គឺប្រាប់សេចក្តីប្រាថ្នាប្រុសដល់ស្រីក្តី ប្រាប់សេចក្តីប្រាថ្នាស្រីដល់ប្រុសក្តី ឲ្យ បានគ្នាជាប្រពន្ធក្តី ជាប្តី ឬជាសហាយក្តី ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយដោយ ប្រការដូច្នេះឯង ។

[ ១២៦ ] សម័យនោះឯង មានពួកអ្នកលេងច្រើននាក់ ជាអ្នកញ៉ាំង ស្រីឲ្យបម្រើក្នុងឧទ្យាន បានប្រើបម្រើទៅឯសំណាក់ស្រីផ្កាមាសម្នាក់ថា ឲ្យ

នាងមក យើងទាំងឡាយ នឹងឲ្យនាងបម្រើយើងក្នុងឧទ្យាន ។ ស្រីផ្កាមាស នោះបាននិយាយតបយ៉ាងនេះថា ម្នាលអ្នកទាំងឡាយ ខ្ញុំឯងឥតស្គាល់អស់ អ្នករាល់គ្នាថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ខ្ញុំជា អ្នកមានទ្រព្យច្រើន មានបរិក្ខារច្រើន ទាំងមានកិច្ចត្រូវទៅខាងក្រៅក្រុងផង ខ្ញុំនឹងទៅមិនបានទេ ។ លំដាប់នោះឯង អ្នកបម្រើនោះបានប្រាប់សេចក្ដីនុ៎ះ ដល់ពួកអ្នកលេងវិញ ។ កាលបើអ្នកបម្រើប្រាប់យ៉ាងនេះហើយ មានបុរស ម្នាក់និយាយពាក្យនេះ នឹងពួកអ្នកលេងនោះថា នែអ្នកទាំងឡាយ ចុះអ្នក ទាំងអស់គ្នាអង្វរស្រីផ្កាមាសនោះធ្វើអ្វី គួរតែអ្នកទាំងឡាយនិយាយនឹងលោក ម្ចាស់ឧទាយិទេតើ លោកម្ចាស់ឧទាយិនឹងបញ្ជូន ( ស្រីផ្កាមាសនោះ ) មក ឲ្យ ។ កាលបើបុរសនោះ និយាយយ៉ាងនេះហើយ មានឧបាសកម្នាក់ពោល ពាក្យនេះនឹងបុរសនោះថា អ្នកកុំនិយាយយ៉ាងនេះ កិរិយាធ្វើនូវអំពើមាន សភាពយ៉ាងនេះ មិនគួរដល់ពួកសមណៈជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តទេ លោកម្ចាស់ឧទាយិក៏មិនធ្វើអំពើយ៉ាងនេះដែរ ។ កាលបើឧបាសកនោះពោល ដូច្នេះហើយ ជនទាំងឡាយក៏តាំងភ្នាល់គ្នាថា លោកម្ចាស់ឧទាយិនឹងធ្វើអំពើ នេះ នឹងមិនធ្វើអំពើនេះ ។ គ្រានោះឯង ពួកអ្នកលេងក៏ចូលទៅត្រង់ទីដែល ឧទាយិភិក្ខុនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងឧទាយិភិក្ខុដ៏ មានអាយុថា បពិត្រលោកដ៏ចម្រើន ពួកយើងកាលឲ្យស្រីបម្រើក្នុងឱទ្យាន នេះ បានប្រើបម្រើទៅឯសំណាក់ស្រីផ្កាមាសឈ្មោះឯណោះថា ឲ្យស្រីផ្កាមាស មក យើងនឹងឲ្យនាងបម្រើក្នុងឧទ្យាន តែស្រីផ្កាមាសនោះឆ្លើយតបយ៉ាងនេះ

ថា ម្នាលអ្នកទាំងឡាយ ខ្ញុំមិនធ្លាប់ស្គាល់អ្នកទាំងឡាយថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ខ្ញុំជាអ្នកមានទ្រព្យច្រើន មានគ្រឿងបរិក្ខារច្រើន ទាំងមានកិច្ចត្រូវទៅខាងក្រៅក្រុងផង ខ្ញុំនឹងមិនទៅទេ បពិត្រ លោកដ៏ចម្រើន យើងសូមពឹងលោកម្ចាស់ សូមលោកម្ចាស់បញ្ជូនស្រីផ្កាមាសនោះមកឲ្យយើង ។ គ្រានោះឯង ឧទាយិភិក្ខុដ៏មានអាយុក៏ចូលទៅត្រង់ទីដែលស្រីផ្កាមាសនោះនៅ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងស្រីផ្កាមាសនោះថា ហេតុដូចម្តេច បានជានាងឯងមិនទៅរកអ្នកលេងទាំងនេះ ។ ស្រីផ្កាមាសនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាមិនស្គាល់អ្នកអស់នេះថា អ្នកទាំងនេះជាអ្វីទេ ឬជាកូនចៅអ្នកណាទេ ម្យ៉ាងទៀត ខ្ញុំព្រះករុណាជាអ្នកមានទ្រព្យច្រើន មានគ្រឿងបរិក្ខារច្រើន ទាំងមានកិច្ចត្រូវទៅខាងក្រៅក្រុងផង ខ្ញុំនឹងមិនទៅទេ ។ ឧទាយិភិក្ខុឆ្លើយថា នាងចូរទៅរកអ្នកទាំងនេះចុះ អាត្មាធ្លាប់ស្គាល់អ្នកទាំងនេះដែរ ។ ស្រីផ្កាមាសឆ្លើយថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ស្គាល់គេ ខ្ញុំព្រះករុណានឹងទៅ ។ គ្រានោះឯង ពួកអ្នកលេងនោះ ក៏នាំស្រីផ្កាមាសនោះទៅឯឧទ្យាន ។ វេលានោះឧបាសកនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើលោកម្ចាស់ឧទាយិ ប្រព្រឹត្តនិយាយដឹកនាំស្រី ដែលបុរសគប្បីសេពមួយរំពេចនោះសោះ ។ ភិក្ខុទាំងឡាយ បានឮពាក្យឧបាសកនោះពោលទោស តិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ពួកភិក្ខុនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើឧទាយិ

ដ៏មានអាយុប្រព្រឹត្តនិយាយជីកនាំស្រី ដែលបុរសគប្បីសេពមួយរំពេចនោះ សោះ ។ គ្រានោះឯង ពួកភិក្ខុនោះ ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មាន ព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ឲ្យប្រជុំ ភិក្ខុសង្ឃក្នុងពេលនោះ ហើយទ្រង់សួរបញ្ជាក់ឧទាយិភិក្ខុដ៏មានអាយុទៀតថា ម្នាលឧទាយិ ឮថាអ្នកឯង ប្រព្រឹត្តនិយាយជីកនាំស្រីដែលបុរសគប្បីសេព មួយរំពេចនោះមែនឬ ។ ឧទាយិភិក្ខុ នោះក្រាបទូលថា សូមទ្រង់ព្រះមេត្តា ប្រោស ពិតមែន ។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគទ្រង់តិះដៀលថា ម្នាល មោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនសមគួរទេ មិនត្រូវទំនងទេ ។បេ។ ម្នាលមោឃបុរស គួរបើដែរ អ្នកឯងប្រព្រឹត្តនិយាយជីកនាំស្រីដែលបុរស គប្បីសេពមួយរំពេចនោះ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិន មែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ប្រព្រឹត្ត និយាយជីកនាំ គឺប្រាប់សេចក្តីប្រាថ្នាប្រុសដល់ស្រីក្តី ប្រាប់សេចក្តីប្រាថ្នាស្រី ដល់ប្រុសក្តី ឲ្យបានគ្នាជាប្រពន្ធក្តី ជាប្តី ឬជាសហាយក្តី ដោយហោចទៅ សូម្បីតែស្រីដែលបុរសគប្បីនៅរួមអស់ទូមមួយរំពេច[១] នោះ ត្រូវអាបត្តិ សង្ឃាទិសេស ។

[ ១២៧ ] ត្រង់ពាក្យថា ភិក្ខុណាមួយ បានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបឋមបារាជិករួចហើយ ។ ត្រង់ពាក្យថា ប្រព្រឹត្តនិយាយជីកនាំ សេចក្តី

១- បានដល់ ស្រីអ្នកលេង គឺស្រីឈ្នួល ស្រីផ្កាមាស ។

ថា ភិក្ខុដែលស្រីបង្គាប់ឲ្យទៅកាន់សំណាក់បុរសក្តី ភិក្ខុដែលបុរសបង្គាប់ឲ្យទៅកាន់សំណាក់ស្រីក្តី ។ ត្រង់ពាក្យថា ប្រាប់សេចក្តីប្រាថ្នាបុរសដល់ស្រីក្តី គឺប្រាប់បំណងរបស់បុរសដល់ស្រីក្តី ។ ត្រង់ពាក្យថា ប្រាប់សេចក្តីប្រាថ្នាស្រីដល់បុរសក្តី គឺប្រាប់គំនិតរបស់ស្រីដល់បុរសក្តី ។ ត្រង់ពាក្យថា ឲ្យបានគ្នាជាប្រពន្ធក្តី គឺប្រាប់ថា នាងឯងនឹងជាប្រពន្ធគេ ។ ត្រង់ពាក្យថា ជាប្តី ឬជាសហាយក្តី គឺប្រាប់ថា អ្នកឯងនឹងជាសហាយគេ ។ ត្រង់ពាក្យថា ដោយហោចទៅ សូម្បីតែស្រីដែលបុរសគប្បីសេពមួយរំពេចនោះ គឺប្រាប់ថា នាងឯងនឹងជាស្រីដែលបុរសគប្បីសេពមួយស្របក់ ។ ត្រង់ពាក្យថា សង្ឃាទិសេស បានអធិប្បាយក្នុងសង្ឃាទិសេសទី ១ រួចហើយ ។

[ ១២៨ ] ស្រីមាន ១០ ពួក គឺមាតុរក្ខិតា ១ បិតុរក្ខិតា ១ មាតាបិតុរក្ខិតា ១ ភាតុរក្ខិតា ១ ភគិនីរក្ខិតា ១ ញាតិរក្ខិតា ១ គោត្តរក្ខិតា ១ ធម្មរក្ខិតា ១ សារក្ខា ១ សបរិទណ្ឌា ១ ។

[ ១២៩ ] ភរិយាមាន ១០ ពួក គឺធនក្កីតា ១ ឆន្ទវាសិនី ១ ភោគវាសិនី ១ បដវាសិនី ១ ឱទបត្តកិនី ១ ឱភតចុម្ពដា ១ ទាសីភរិយា ១ កម្មការីភរិយា ១ ធជាហដា ១ មុហុត្តិកា ១ ។

[ ១៣០ ] ស្រីដែលម្តាយថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា មាតុរក្ខិតា ។ ស្រីដែលឪពុកថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា បិតុរក្ខិតា ។ ស្រីដែលម្តាយឪពុកថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា មាតាបិតុរក្ខិតា ។ ស្រីដែលបងប្អូនប្រុសថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ

ហៅថា ភាតុរក្ខិតា ។ ស្រីដែលបងប្អូនស្រីថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា ភគិនីរក្ខិតា ។ ស្រីដែលពួកញាតិថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា ញាតិរក្ខិតា ។ ស្រីដែលជនមានគោត្រវង្សស្មើគ្នាថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា គោត្តរក្ខិតា ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នាថែរក្សាគ្រប់គ្រងជាធំត្រួតត្រាលើ ហៅថា ធម្មរក្ខិតា ។ ស្រីដែលប្រុសថែរក្សាទុកតាំងពីក្នុងផ្ទៃដោយតាំងចិត្តថានាងនេះជារបស់អញ ដោយហោចទៅសូម្បីតែស្រីដែលប្រុសបំពាក់ផ្កាកម្រងឲ្យ ( ស្រីនេះឯង ) ហៅថា សារក្ខា ។ អាជ្ញាដែលស្តេចអង្គណា ១ ទ្រង់តាំងទុកដូច្នេះថា បើបុរសណា មករួមនឹងស្រីឈ្មោះនេះ នឹងត្រូវពិន័យប៉ុណ្ណេះដល់បុរសនោះ ( ស្រីនេះ ) ហៅថា សបរិទណ្ឌា ។

[ ១៣១ ] កិរិយាដែលបុរសលោះនឹងទ្រព្យហើយឲ្យនៅរួមជាមួយ ហៅថា ធនក្កីតា ។ ប្រុសជាទីស្រឡាញ់របស់ស្រីឲ្យស្រីជាទីស្រឡាញ់នៅរួមជាមួយ ហៅថា ឆន្ទវាសិនី ។ កិរិយាដែលប្រុសឲ្យភោគៈ[១] ហើយឲ្យនៅរួមជាមួយ ហៅថា ភោគវាសិនី ។ កិរិយាដែលប្រុសឲ្យសំពត់ស្លៀកដណ្តប់ហើយឲ្យនៅរួមជាមួយ ហៅថា បដវាសិនី ។ កិរិយាដែលញាតិចាប់ដៃផ្គុំជាមួយនឹងបុរស ជ្រលក់ក្នុងភាជនទឹក ហើយគេផ្សំឲ្យនៅរួមជាមួយ ហៅថា ឱទបត្តកិនី ។ កិរិយាដែលប្រុសដាក់ទ្រនូលឲ្យ ហើយឲ្យនៅរួមជាមួយគ្នា ហៅថា ឱភតចុម្ពដា ។ ស្រីដែលប្រើប្រាស់ជាខ្ញុំផង ជាកិរិយាផង

---

១- គ្រឿងឧបករណ៍សម្រាប់ផ្ទះ មានត្បាល់ អង្រែជាដើម ។

ហៅថា ទាសីភរិយា ។ ស្រីដែលធ្វើការឈ្នួលផង ជាភរិយាផង ហៅថា កម្មការីភរិយា ។ ស្រីដែល គេចាប់ពីកងទ័ពយកមកធ្វើជាភរិយា ហៅថា ធជាហដា ។ ស្រីដែលប្រុសបានទៅរួមគ្នាមួយរំពេចនោះ ហៅថា មុហុត្តិកា ។

[ ១៣២ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលមាតារក្សាដូច្នេះថា គេថា នាងឯងចូរជាធនក្កីតាភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើលហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីដែលបិតារក្សា ។បេ។ សូមលោកទៅនិយាយនឹងស្រីដែលមាតា និងបិតារក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលបងប្អូនប្រុសរក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលបងប្អូនស្រីរក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលញាតិរក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលជនមានគោត្រវង្សស្មើគ្នារក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលប្រុសប្រកាន់ទុក ។ សូមលោកទៅនិយាយនឹងស្រីដែលមានអាជ្ញាស្តេចតាំងទុកដូច្នេះថា គេថា នាងឯងចូរជាធនក្កីតា-ភរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើលហើយវិលមក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**និក្ខេបបទទាំងឡាយ ចប់**

[ ១៣៣ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅ

និយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលបិតារក្សាផងថា គេថានាងទាំងពីរនាក់ ចូរជាធនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង ។បេ។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលប្រុសហួងហែងផង ។ សូមលោកទៅនិយាយនឹងស្រីដែលមាតារក្សាផង នឹងស្រីដែលស្តេចដាក់អាជ្ញាផងដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាធនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ខណ្ឌចក្ក ចប់

[ ១៣៤ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលបិតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាធនក្តីតាកិរិយារបស់បុរស

ឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបិតារក្សាផង និងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលប្រុសហួងហែងផង ។ ស្រីដែលបិតារក្សាផង ស្រីដែលស្ដេចដាក់អាជ្ញាផង ដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាធនក្កីតាករិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលបិតារក្សាផង និងស្រីឈ្មោះនេះដែលមាតារក្សាផង ដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាធនក្កីតាករិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ពទ្ធចក្ក ចប់

[ ១៣៥ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង នឹងស្រីឈ្មោះនេះដែលបង

ប្អូនប្រុសរក្សាផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលប្រុសហួងហែងផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលមាតារក្សាផង ។ ស្រីដែលមាតាបិតារក្សាផង ស្រីដែលបិតារក្សាផង ដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាជនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ដល់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ពន្ធចក្កទី ២ ចប់

[ ១៣៦ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបងប្អូនប្រុសរក្សាផង និងស្រីឈ្មោះនេះដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលប្រុសហួងហែងផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលស្តេចដាក់អាជ្ញាផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលមាតារក្សាផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង

ស្រីដែលបិតារក្សាផង ។ ស្រីដែលបងប្អូនប្រុសរក្សាផង ស្រីដែលមាតាបិតារក្សាផង ដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាជនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពន្ធចក្កទី ៣ ចប់**

[ ១៣៧ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបងប្អូនស្រីរក្សាផង នឹងស្រីឈ្មោះនេះដែលញាតិរក្សាផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលប្រុសហួងហែងផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលមាតារក្សាផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលបិតារក្សាផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលមាតាបិតារក្សាផង ។ ស្រីដែលបងប្អូនស្រីរក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ដូច្នេះថា គេថា នាងទាំងពីរនាក់ ចូរជាជនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពន្ធចក្កទី ៤ ចប់**

[ ១៣៨ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោក

ម្ចាស់ទៅនិយាយនឹងស្រីឈ្មោះនេះ ដែលញាតិរក្សាផង នឹងស្រីឈ្មោះនេះ ដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលប្រុសហួងហែងផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលមាតារក្សាផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលបិតារក្សាផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលមាតាបិតារក្សាផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលញាតិរក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ដូច្នេះថា គេថានាងទាំងពីរនាក់ចូរជាធនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ពន្ធចក្កទី ៥ ចប់

[ ១៣៩ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលជនមានគោត្រស្មើគ្នារក្សាផង នឹងស្រីឈ្មោះនេះដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលប្រុសហួងហែងផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សា ផង ស្រីដែលមាតារក្សាផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលបិតារក្សាផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលមាតាបិតា

រក្សាផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ស្រីដែលញាតិរក្សាផង ដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាធនក្តីតាកិរិយារបស់បុរសឈ្មោះនេះ ទៅ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ពន្ធចក្កទី ៦ ចប់

[ ១៤០ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង និងស្រីឈ្មោះនេះដែលប្រុសហួងហែងផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលមាតារក្សាផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលបិតារក្សាផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលមាតាបិតារក្សាផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាធនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់

បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ពន្ធចក្កទី ៧ ចប់

[ ១៤១ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលប្រុសហួងហែងផង នឹងស្រីដែលស្តេចដាក់អាជ្ញាទុកផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលមាតារក្សាផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលបិតារក្សាផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលមាតាបិតារក្សាផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលប្រុសហួងហែងផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ដូច្នេះថា គេថានាងទាំងពីរនាក់ ចូរជាជនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ពន្ធចក្កទី ៨ ចប់

[ ១៤២ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលស្តេចដាក់អាជ្ញាទុកផង នឹងស្រីឈ្មោះនេះដែលមាតារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបិតារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលមាតាបិតារក្សាផង ។ ស្រី

ដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលប្រុសហ្មងហែងផង ដូច្នេះថា គេថានាងទាំងពីរ ចូរជាធនក្តីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពទ្ធចក្កមានមូល ៩ ចប់**

**ចក្កមានមូល ១ ចប់**

[ ១៤៣ ] ចក្កមានមូល ២ មូល ៣ មូល ៤ មូល ៥ មូល ៦ មូល ៧ មូល ៨ មូល ៩ ត្រូវធ្វើដូចចក្កមានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្តីតទៅនេះ ) ។

[ ១៤៤ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកម្ចាស់ សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលបិតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនស្រីរក្សាផង នឹងស្រីឈ្មោះនេះដែលញាតិរក្សាផង នឹងស្រីឈ្មោះនេះដែលជនមានគោត្រស្មើគ្នារក្សាផង នឹងស្រីឈ្មោះនេះដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង នឹងស្រីឈ្មោះ

នេះដែលប្រុសហួងហែងផង នឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង ដូច្នេះថា គេថានាងទាំងអស់គ្នា ចូរជាធនក្កីតាកិរិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ធនក្កីតាចក្ក ចប់**

[ ១៤៥ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ដូច្នេះថា គេថានាងចូរជាធនូ-វាសិនីករិយា ជាភោគវាសិនីករិយា ជាបដវាសិនីករិយា ជាឱទបត្តកិនីករិយា ជាឱភតចុម្ពដាករិយា ជាទាសីផង ជាករិយាផង ជាកម្មការីផង ជាករិយាផង ជាធជាហដាករិយា ជាមុហុត្តិកាករិយារបស់បុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បេ ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបិតារក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលមាតាបិតារក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលបងប្អូនប្រុសរក្សា ។ សូមលោកទៅនិយាយនឹងស្រី ដែលញាតិរក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលជនមានគោត្រស្មើគ្នារក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សា ។ សូមលោកទៅនិយាយនឹងស្រីដែលប្រុសហួងហែង ។ សូមលោកទៅនិយាយនឹងស្រីដែលស្តេចដាក់អាជ្ញាទុកថាដូច្នេះ គេថា នាងចូរជាមុហុត្តិកាករិយានៃបុរស

ឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**និក្ខេបបទទាំងឡាយ ចប់**

[ ១៤៦ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលបិតារក្សាផងថាដូច្នេះ គេថានាងទាំងពីរនាក់ ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលមាតារក្សាផង ស្រីដែលប្រុសហួងហែងផង ។ ស្រីដែលមាតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផងថាដូច្នេះ គេថា នាងរាល់គ្នា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ខណ្ឌចក្ក ចប់**

[ ១៤៧ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលបិតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផងថាដូច្នេះ គេថានាងរាល់គ្នា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះ ដែលបិតារក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលបិតារក្សាផង ស្រីដែលបុរសហួងហែងផង ។ ស្រីដែលបិតារក្សាផង ស្រីដែលស្តេចដាក់អាជ្ញាទុកផង ។ ស្រីដែលបិតារក្សាផង ស្រីដែលមាតារក្សាផង ថាដូច្នេះ គេថានាងរាល់គ្នា ចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

### ពន្ធចក្ក ចប់

នេះជាមូលដែលព្រះដ៏មានព្រះភាគសម្តែងដោយសង្ខេប ។

[ ១៤៨ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង នឹងស្រីឈ្មោះនេះ

ដែលមាតារក្សាផង ថាដូច្នេះ គេថានាងទាំងពីរនាក់ ចូរជាមុហុត្តិកាកិរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង នឹងស្រីឈ្មោះនេះដែលបិតារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលមាតាបិតារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនប្រុសរក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលបងប្អូនស្រីរក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលញាតិរក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនមានគោត្រស្មើគ្នារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលជនប្រព្រឹត្តធម៌ត្រូវគ្នារក្សាផង ។ ស្រីដែលស្តេចដាក់អាជ្ញាទុកផង ស្រីដែលប្រុសហួងហែងផង ថាដូច្នេះ គេថានាងរាល់គ្នា ចូរជាមុហុត្តិកាកិរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូល ១ ចប់**

[ ១៤៩ ] ចក្កមានមូល ២ មានមូល ៣ មានមូល ៤ មានមូល ៥ មានមូល ៦ មានមូល ៧ មានមូល ៨ មានមូល ៩ បណ្ឌិតគប្បីធ្វើដូចចក្កដែលមានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្តីតទៅនេះ ) ។

[ ១៥០ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាផង នឹងស្រីឈ្មោះនេះដែលបិតារក្សាផង នឹងស្រីឈ្មោះនេះដែលមាតាបិតារក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនប្រុសរក្សាផង នឹងស្រីឈ្មោះនេះដែលបងប្អូនស្រីរក្សាផង នឹងស្រីឈ្មោះនេះដែលញាតិរក្សាផង នឹងស្រីឈ្មោះនេះដែលជនមានគោត្រស្មើគ្នារក្សាផង នឹងស្រីឈ្មោះនេះដែលជនប្រព្រឹត្តធម៌ស្មើគ្នារក្សាផង នឹងស្រីឈ្មោះនេះដែលប្រុសហួងហែងផង នឹងស្រីឈ្មោះនេះដែលស្តេចដាក់អាជ្ញាទុកផង ជាដូច្នេះ គេថា នាងរាល់គ្នាចូរជាមុហុត្តិកាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## មុហុត្តិកាចក្ក ចប់

[ ១៥១ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ជាដូច្នេះ គេថា នាងចូរជាធនក្កីតាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សា ជាដូច្នេះ គេថា នាងចូរជាឆន្ទវាសិនីភរិយា ចូរជាភោគវាសិនីភរិយា ចូរជាបដវាសិនីភរិយា ចូរជាឱទបត្តកិនីភរិយា ចូរជាឱភតចុម្ពដាភរិយា ចូរជាទាសីផង ភរិយាផង ចូរជាកម្មការី

ផង ជាករិយាផង ចូរជាធជាហដាករិយា ចូរជាមុហុត្តិកាករិយានៃបុរស ឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**និក្ខេបបទទាំងឡាយ ចប់**

[ ១៥២ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាថាដូច្នេះ គេថានាងចូរជាធនក្កីតាករិយាផង ជាឆន្ទវាសិនីករិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាថាដូច្នេះ គេថានាងចូរជាធនក្កីតាករិយាផង ជាភោគវាសិនីករិយាផង ។ ជាធនក្កីតាករិយាផង ជាបដវាសិនីករិយាផង ។ ជាធនក្កីតាករិយាផង ជាឱទបត្តកិនីករិយាផង ។ ជាធនក្កីតាករិយាផង ជាឱភតចុម្ពដាករិយាផង ។ ជាធនក្កីតាករិយាផង នឹងជាទាសីផង ករិយាផង ។ ជាធនក្កីតាករិយាផង នឹងជាកម្មការីផង ករិយាផង ។ ជាធនក្កីតាករិយាផង ជាធជាហដាករិយាផង ។ ជាធនក្កីតាករិយាផង ជាមុហុត្តិកាករិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ខណ្ឌចក្ក ចប់**

[ ១៥៣ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាថាដូច្នេះ គេថានាង ចូរជាធនក្កីតាកិរិយាផង ជាភោគវាសិនីកិរិយាផង នៃបុរសឈ្មោះនេះទៅ ។បេ។ ជាធនក្កីតាកិរិយាផង ជាមុហុត្តិកាកិរិយាផង ។ ជាធនក្កីតាកិរិយាផង ជាធនក្កីតាកិរិយាផង នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពន្ធចក្ក ចប់**

នេះជាមូលដែលព្រះដ៏មានព្រះភាគសម្តែងដោយសង្ខេប ។

[ ១៥៤ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលមាតារក្សាថាដូច្នេះ គេថានាងចូរជាមុហុត្តិកាកិរិយាផង ជាធនក្កីតាកិរិយាផង នៃបុរសឈ្មោះនេះទៅ ។ ជាមុហុត្តិកាកិរិយាផង ជាធនក្កីតាកិរិយាផង ។បេ។ ជាមុហុត្តិកាកិរិយាផង ជាធជាហដាកិរិយាផង នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូល ១ ចប់**

[ ១៥៥ ] ចក្កមានមូល ២ មានមូល ៣ មានមូល ៤ មានមូល ៥ មានមូល ៦ មានមូល ៧ មានមូល ៨ មានមូល ៩ បណ្ឌិតគប្បីធ្វើដូចចក្កមានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្តីតទៅនេះ ) ។

[ ១៥៦ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះដែលម្តាយរក្សាថាដូច្នេះ គេថានាងចូរជាធនក្កីតាកិរិយាផង ជាឆន្ទវាសិនីកិរិយាផង ជាភោគវាសិនីកិរិយាផង ជាបដវាសិនីកិរិយាផង ជាឱទបត្តកិនីកិរិយាផង ជាឱភតចុម្ពដាកិរិយាផង នឹងជាទាសីផងកិរិយាផង នឹងជាកម្មការីផង កិរិយាផង ជាធជាហដាកិរិយាផង ជាមុហុត្តិកាកិរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៥៧ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅ និយាយនឹងស្រីបិតុរក្ខិតា[1] ឈ្មោះនេះ ។ សូមលោកទៅនិយាយនឹងស្រីមាតាបិតុរក្ខិតា ។ សូមលោកទៅនិយាយនឹងស្រីភាតុរក្ខិតា ។ សូមលោកទៅនិយាយនឹងស្រីភគិនីរក្ខិតា ។ សូមលោកទៅនិយាយនឹងស្រីញាតិរក្ខិតា ។ សូមលោកទៅនិយាយនឹងស្រីគោត្តរក្ខិតា ។ សូមលោកទៅនិយាយនឹងស្រីធម្មរក្ខិតា ។ សូមលោកទៅនិយាយនឹងស្រីសារក្ខា ។ សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះថាដូច្នេះ គេថានាងចូរជាធនក្កីតាកិរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅ

---

១- ស្រីទាំង ១០ ជំពូក យើងបានប្រែជាសេចក្តីពីខាងដើមរៀងមកហើយ តពីត្រឹមនេះទៅមិនបាច់ប្រែទៀតទេ ត្រូវហៅជាបាលីវិញ ដើម្បីឲ្យសាធុជនហៅជាបាលីផងក៏បាន ។

ថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះថាដូច្នេះ គេថានាងចូរជាធនូវាសិនីករិយា ជាគោគវាសិនីករិយា ជាបជ-វាសិនីករិយា ជាឱទបត្តកិនីករិយា ជាឱភតចុម្ពដាករិយា នឹងជាទាសីផង ករិយាផង នឹងជាកម្មការីផង ករិយាផង ជាធជាហដាករិយា ជាមុហុត្តិកាករិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**និក្ខេបបទទាំងឡាយ ចប់**

[ ១៥៨ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះថាដូច្នេះ គេថា នាងចូរជាធនក្កីតាករិយាផង ជាធនូវាសិនីករិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះថាដូច្នេះ គេថា នាងចូរជាធនក្កីតាករិយាផង ជាគោគវាសិនីករិយាផង នៃបុរសឈ្មោះនេះទៅ ។ ជាធនក្កីតាករិយាផង ជាបជវាសិនីករិយាផង ។ ជាធនក្កីតាករិយាផង ជាឱទបត្តកិនីករិយាផង ។ ជាធនក្កីតាករិយាផង ជាឱភតចុម្ពដាករិយាផង ។ ជាធនក្កីតាករិយាផង នឹងជាទាសីផង ករិយាផង ។ ជាធនក្កីតាករិយាផង នឹងជាកម្មការីផង ករិយាផង ។ ជាធនក្កីតាករិយាផង ជាធជាហដាករិយាផង ។ ជាធនក្កីតាករិយាផង ជាមុហុត្តិកាករិយាផង នៃបុរសឈ្មោះនេះទៅ

ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ខណ្ឌចក្ក ចប់**

[ ១៥៩ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយទឹងស្រីសបរិទណ្ឌាឈ្មោះនេះថាដូច្នេះ គេថានាងចូរជាធនូវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាធនូវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ។បេ។ ជាធនូវាសិនីភរិយាផង ជាមុហុត្តិកាភរិយាផង ជាធនូវាសិនីភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពទ្ធចក្ក ចប់**

នេះជាមូលដែលព្រះដ៏មានព្រះភាគសម្តែងដោយសង្ខេប ។

[ ១៦០ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយទឹងស្រីសបរិទណ្ឌាឈ្មោះនេះថាដូច្នេះ គេថា នាងចូរជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង ។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូល ១ ចប់**

[ ១៦១ ] ចក្កមានមូល ២ មានមូល ៣ មានមូល ៤ មានមូល ៥

មានមូល ៦ មានមូល ៧ មានមូល ៨ មានមូល ៩ បណ្ឌិតគប្បីធ្វើដូចចក្ក មានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្ដីតទៅនេះ ) ។

[ ១៦២ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីសបរិទណ្ឌាឈ្មោះនេះថាដូច្នេះ គេនាងចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង នឹងជាទាសីផង ភរិយាផង នឹងជាកម្មការីផង ភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៦៣ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីមាតុរក្ខិតាឈ្មោះនេះថាដូច្នេះ គេថានាងចូរជាធនក្កីតាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីមាតុ-រក្ខិតាឈ្មោះនេះផង បិតុរក្ខិតាឈ្មោះនេះផងថាដូច្នេះ គេថា នាងរាល់គ្នាចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏

ចម្រើន សូមលោកទៅនិយាយនឹងស្រីមាតុរក្ខិតាឈ្មោះនេះផង បិតុរក្ខិតាឈ្មោះនេះផង ស្រីមាតាបិតុរក្ខិតាឈ្មោះនេះផង ថាដូច្នេះ គេថា នាងរាល់គ្នាចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ឧភតោពទ្ធក បណ្ឌិតគប្បីធ្វើយ៉ាងនេះ**

នេះចក្កមានមូលគ្រប់ទាំងអស់[១] ( ដូចមានសេចក្តីទៅនេះ )

[ ១៦៤ ] បុរសបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីមាតុរក្ខិតាឈ្មោះនេះផង បិតុរក្ខិតាឈ្មោះនេះផង មាតា-បិតុរក្ខិតាឈ្មោះនេះផង ភាតុរក្ខិតាឈ្មោះនេះផង ភគិនីរក្ខិតាឈ្មោះនេះផង ញាតិរក្ខិតាឈ្មោះនេះផង គោត្តរក្ខិតាឈ្មោះនេះផង ធម្មរក្ខិតាឈ្មោះនេះផង សារក្ខាឈ្មោះនេះផង សបរិទណ្ឌាឈ្មោះនេះផង ថាដូច្នេះ គេថានាងរាល់គ្នាចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង នឹងជាទាសីផង ភរិយាផង នឹងជាកម្មការីផង ភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់បុរសនោះ ) វិញ ត្រូវអាបត្តិសង្ឃា-

---

១- ស្រី ១០ ជំពូក ហៅថា មានមូល ១០ ភរិយា ១០ ជំពូក ហៅថា មានមូល ១០ រួមមូលទាំង ២ ពួក ហៅថា មានមូលគ្រប់ទាំងអស់ ។

ទិសេស ។

## ឧភតោពទ្ធក ចប់

[ ១៦៥ ] ម្តាយបុរសបញ្ជូនភិក្ខុទៅ ។បេ។ ឪពុកបុរសបញ្ជូនភិក្ខុទៅ ។បេ។ ម្តាយឪពុកបុរសបញ្ជូនភិក្ខុទៅ ។បេ។ បងប្អូនប្រុសរបស់បុរសបញ្ជូនភិក្ខុទៅ ។បេ។ បងប្អូនស្រីរបស់បុរសបញ្ជូនភិក្ខុទៅ ។បេ។ ពួកញាតិរបស់បុរសបញ្ជូនភិក្ខុទៅ ។បេ។ ពួកគោត្ររបស់បុរសបញ្ជូនភិក្ខុទៅ ។បេ។ ពួកជនប្រព្រឹត្តធម៌ត្រូវគ្នារបស់បុរសបញ្ជូនភិក្ខុទៅ ។ ( សេចក្តីបំព្រួមអំពីរឿង បណ្ឌិតគប្បីឲ្យពិស្តារចុះ ។ ឧភតោពទ្ធក[១] ដែលព្រះសង្គីតិកាចារ្យឲ្យពិស្តារហើយយ៉ាងណា បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះផងចុះ ) ។

[ ១៦៦ ] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាធនក្កីតាភរិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាឆន្ទវាសិនីភរិយា ជាភោគវាសិនីភរិយា ជាបដវាសិនីភរិយា ជាឱទបត្តកិនីភរិយា ជាឱភតចុម្ពដាភរិយា នឹងជាទាសីផង ភរិយាផង ជាកម្មការីផង ភរិយាផង ជាធជាហដា

---

១- ប្រែថា បទជាប់គ្នាដោយមូលទាំងពីរ ឯមូលទាំងពីរនោះ គឺស្រី ១០ ជំពូក មានមាតុរក្ខិតាជាដើម ហៅថា មានមូល ១ ភរិយា ១០ ជំពូក មានធនក្កីតាជាដើម ហៅថា មូល ១ រួមមូលទាំងពីរនេះចូលគ្នាជាន័យ ១ ហៅថា ឧភតោពទ្ធក ។

ករិយា ជាមុហុត្តិកាករិយានៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**និក្ខេបបទទាំងឡាយ ចប់**

[ ១៦៧ ] ម្ដាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាធនក្កីតាករិយាផង ជាឆន្ទវាសិនីករិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ម្ដាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាធនក្កីតាករិយាផង ជាភោគវាសិនីករិយាផង នៃបុរសឈ្មោះនេះទៅ ។ ជាធនក្កីតាករិយាផង ជាបដវាសិនីករិយាផង ។ ជាធនក្កីតាករិយាផង ជាឱទបត្តកិនីករិយាផង ។ ជាធនក្កីតាករិយាផង ជាឱភតចុម្ពដាករិយាផង ។ ជាធនក្កីតាករិយាផង នឹងជាទាសីផង ករិយាផង ។ ជាធនក្កីតាករិយាផង នឹងជាកម្មការីផង ករិយាផង ។ ជាធនក្កីតាករិយាផង ជាធជាហដាករិយាផង ។ ជាធនក្កីតាករិយាផង ជាមុហុត្តិកាករិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ខណ្ឌចក្ក ចប់**

[ ១៦៨ ] ម្ដាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាឆន្ទ-

វាសិនីកិរិយាផង ជាភោគវាសិនីកិរិយាផង នៃបុរសឈ្មោះនេះទៅ ។ បេ ។ ជាធនូវាសិនីកិរិយាផង ជាមុហុត្តិកាកិរិយាផង ។ ជាធនូវាសិនីកិរិយាផង ជាធនក្កីតាកិរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពន្ធចក្ក ចប់**

នេះជាមូលដែលព្រះដ៏មានព្រះភាគសម្តែងដោយសង្ខេប ។

[ ១៦៩ ] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រី[១]ឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាមុហុត្តិកាកិរិយាផង ជាធនក្កីតាកិរិយាផង នៃបុរសឈ្មោះនេះទៅ ។បេ។ ជាមុហុត្តិកាកិរិយាផង ជាធជាហដាកិរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូល ១ ចប់**

តាំងពីចក្កមានមូល ២ ដរាបដល់ចក្កមានមូល ៩

បណ្ឌិតគប្បីធ្វើដូចចក្កមានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្តីតទៅនេះ )

[ ១៧០ ] ម្តាយរបស់ស្រីមាតុរក្ខិតា បញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជា

---

១- បិដកថៃថា សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ស្រីនោះ ចូរជា ... ។

ធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង នឹងជាទាសីផង ភរិយាផង នឹងជាកម្មការីផង ភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកា ភរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៧១ ] បិតារបស់ស្រីបិតុរក្ខិតា បញ្ជូនភិក្ខុទៅ ។ មាតាបិតារបស់ស្រីមាតាបិតុរក្ខិតា បញ្ជូនភិក្ខុទៅ ។ បងប្អូនប្រុសរបស់ស្រីភាតុរក្ខិតា បញ្ជូនភិក្ខុទៅ ។ បងប្អូនស្រីរបស់ស្រីភគិនីរក្ខិតា បញ្ជូនភិក្ខុទៅ ។ ពួកញាតិរបស់ស្រីញាតិរក្ខិតា បញ្ជូនភិក្ខុទៅ ។ ពួកគោត្ររបស់ស្រីគោត្តរក្ខិតា បញ្ជូនភិក្ខុទៅ ។ ពួកជនប្រព្រឹត្តធម៌ត្រូវគ្នារបស់ស្រីធម្មរក្ខិតា បញ្ជូនភិក្ខុទៅ ។ ស្រីដែលអ្នកណាបានប្រកាន់ទុកហើយ អ្នកនោះបញ្ជូនភិក្ខុទៅដើម្បីស្រីដែលខ្លួនប្រកាន់ទុក ( នោះ ) ។ អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅដើម្បីស្រីដែលព្រះអង្គដាក់កំហិតហើយ ( នោះ ) ថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាធនក្កីតាភរិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅ ដើម្បីស្រីដែលទ្រង់បានដាក់កំហិតហើយ ( នោះ ) ថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន

ចូរជាធន្ទវាសិនីករិយា ជាភោគវាសិនីករិយា ជាបដវាសិនីករិយា ជាឱទបត្ត-កិនីករិយា ជាឱភតចុម្ពដាករិយាផង នឹងជាទាសីផង ករិយាផង នឹងជាកម្មការីផង ករិយាផង ជាធជាហដាករិយា ជាមុហុត្តិកាករិយា នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## និក្ខេបបទទាំងឡាយ ចប់

[ ១៧២ ] អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅដើម្បីស្រីដែលទ្រង់ដាក់កំហិតហើយ ( នោះ ) ថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើនចូរជា ធនក្កីតាករិយាផង ជាធន្ទវាសិនីករិយាផង នៃបុរសឈ្មោះនេះទៅ ។បេ។ ជាធនក្កីតាករិយាផង ជាមុហុត្តិកាករិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃា-ទិសេស ។

## ខណ្ឌចក្ក ចប់

[ ១៧៣ ] អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅដើម្បីស្រីដែលទ្រង់ដាក់កំហិតហើយ ( នោះ ) ថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើនចូរជា ធន្ទវាសិនីករិយាផង ជាភោគវាសិនីករិយាផង នៃបុរសឈ្មោះនេះទៅ ។បេ។ ជាធន្ទវាសិនីករិយាផង ជាមុហុត្តិកាករិយាផង ។បេ។ ជាធន្ទវាសិនី

កិរិយាផង ជាធនក្កីតាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយ ត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពទ្ធចក្ក ចប់**

នេះជាមូលដែលព្រះដ៏មានព្រះភាគសម្តែងដោយសង្ខេប ។

[ ១៧៤ ] អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅដើម្បីស្រីដែលទ្រង់ដាក់កំហិតហើយ ( នោះ ) ថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាមុហុត្តិកាភរិយាផង ជាធនក្កីតាភរិយាផង នៃបុរសឈ្មោះនេះ ។បេ។ ជាមុហុត្តិកាភរិយាផង ជាធជាហដាភរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូល ១ ចប់**

តាំងពីចក្កមានមូល ២ ដរាប់ដល់ចក្កមានមូល ៩
បណ្ឌិតគប្បីធ្វើដូចចក្កមានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្តីទៅនេះ ) ។

[ ១៧៥ ] អាជ្ញាដែលស្តេចអង្គណាបានដាក់កំហិតហើយ ស្តេចអង្គនោះបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងស្រីឈ្មោះនេះថា នាងដ៏ចម្រើន ចូរជាធនក្កីតាភរិយាផង ជាឆន្ទវាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង និងជាទាសីផង ភរិយាផង និងជាកម្មការីផង ភរិយា

ផង ជាធជាហដាកិរិយាផង ជាមុហុត្តិកាកិរិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៧៦ ] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាធនក្កីតាកិរិយានៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាឆន្ទវាសិនីកិរិយា ជាភោគវាសិនីកិរិយា ជាបដវាសិនីកិរិយា ជាឱទបត្តកិនីកិរិយា ជាឱភតចុម្ពដាកិរិយា នឹងជាទាសីផង កិរិយាផង នឹងជាកម្មការីផង កិរិយាផង ជាធជាហដាកិរិយា ជាមុហុត្តិកាកិរិយា នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## និក្ខេបបទទាំងឡាយ ចប់

[ ១៧៧ ] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាកិរិយាផង ជាឆន្ទវាសិនីកិរិយាផង នៃបុរសឈ្មោះនេះ ។ បេ ។ ជាធនក្កីតាកិរិយាផង ជាមុហុត្តិកាកិរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

## ខណ្ឌចក្ក ចប់

[ ១៧៨ ] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាធនក្កីតាវាសិនីកិរិយាផង ជាគោគ-វាសិនីកិរិយាផង នៃបុរសឈ្មោះនេះ ។បេ។ ជាធនក្កីតាវាសិនីកិរិយាផង ជាមុហុត្តិកាកិរិយាផង ។ ជាធនក្កីតាវាសិនីកិរិយាផង ជាធនក្កីតាកិរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ពទ្ធចក្ក ចប់**

នេះជាមូលដែលព្រះដ៏មានព្រះភាគសម្តែងដោយសង្ខេប ។

[ ១៧៩ ] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាមុហុត្តិកាកិរិយាផង ជាធនក្កីតាកិរិយាផង នៃបុរសឈ្មោះនេះ ។បេ។ ជាមុហុត្តិកាកិរិយាផង ជាធជាហដាកិរិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូល ១ ចប់**

ចក្កដ៏សេសមានចក្កមានមូល ២ ជាដើម បណ្ឌិត

គប្បីធ្វើដូចចក្កមានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្តីតទៅនេះ ) ។

[ ១៨០ ] ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាកិរិយាផង ជាធនក្កីតាវាសិនីកិរិយាផង ជាគោគវាសិនីកិរិយាផង ជាបដវាសិនីកិរិយាផង ជាឱទបត្តកិនី

ករិយាផង ជាឱកតបុម្ពជាករិយាផង នឹងជាទាសីផង ករិយាផង នឹងជាកម្មការីផង ករិយាផង ជាធជាហដាករិយាផង ជាមុហុត្តិកាករិយាផង នៃបុរសឈ្មោះនេះទៅ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ១៨១ ] ស្រីបិតុរក្ខិតាបញ្ជូនភិក្ខុទៅ ។ ស្រីមាតាបិតុរក្ខិតាបញ្ជូនភិក្ខុទៅ ។ ស្រីមាតុរក្ខិតាបញ្ជូនភិក្ខុទៅ ។ ស្រីភគិនីរក្ខិតាបញ្ជូនភិក្ខុទៅ ។ ស្រីញាតិរក្ខិតាបញ្ជូនភិក្ខុទៅ ។ ស្រីគោត្តរក្ខិតាបញ្ជូនភិក្ខុទៅ ។ ស្រីធម្មរក្ខិតាបញ្ជូនភិក្ខុទៅ ។ ស្រីសារក្ខាបញ្ជូនភិក្ខុទៅ ។ ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាករិយា របស់បុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាឆន្ទវាសិនីករិយាផង ជាភោគវាសិនីករិយា ជាបដវាសិនីករិយា ជាឱទបត្តកិនីករិយា ជាឱភតបុម្ពជាករិយា នឹងជាទាសីផង ករិយាផង នឹងជាកម្មការីផង ករិយាផង ជាធជាហដាករិយា ជាមុហុត្តិកាករិយា នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**និក្ខេបបទទាំងឡាយ ចប់**

[ ១៨២ ] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនក្កីតាករិយាផង ជាឆន្ទ-

វាសិនីករិយាផង នៃបុរសឈ្មោះនេះ ។បេ។ ជាធនក្កីតាករិយាផង ជាមុហុត្តិកាករិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ខណ្ឌចក្ក ចប់**

[ ១៨៣ ] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូម លោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាធនូវាសិនីករិយាផង ជាភោគវាសិនីករិយាផង នៃបុរសឈ្មោះនេះ ។បេ។ ជាធនូវាសិនីករិយាផង ជាមុហុត្តិកាករិយាផង ។ ជាធនូវាសិនីករិយាផង ជាធនក្កីតាករិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវ អាបត្តិសង្ឃាទិសេស ។

**ពទ្ធចក្ក ចប់**

នេះជាមូលដែលព្រះដ៏មានព្រះភាគសម្តែងដោយសង្ខេប ។

[ ១៨៤ ] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូម លោកទៅនិយាយនឹងប្រុសឈ្មោះនេះថា ខ្ញុំជាមុហុត្តិកាករិយាផង ជាធនក្កីតាករិយាផង នៃបុរសឈ្មោះនេះ ។បេ។ ជាមុហុត្តិកាករិយាផង ជាធជាហដាករិយាផង ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កមានមូល ១ ចប់**

ចក្កមានមូល ២ ជាដើម បណ្ឌិតគប្បីធ្វើដូច

ចក្កមានមូល ១ ផងចុះ ។

នេះចក្កមានមូល ១០ ( ដូចមានសេចក្តីតទៅនេះ ) ។

[ ១៨៥ ] ស្រីសបរិទណ្ឌាបញ្ជូនភិក្ខុទៅថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយនឹងបុរសឈ្មោះនេះថា ខ្ញុំជាធនក្កីតាភរិយាផង ជាឆន្ទ-វាសិនីភរិយាផង ជាភោគវាសិនីភរិយាផង ជាបដវាសិនីភរិយាផង ជាឱទបត្តកិនីភរិយាផង ជាឱភតចុម្ពដាភរិយាផង នឹងជាទាសីផង ភរិយាផង នឹងជាកម្មការីផង ភរិយាផង ជាធជាហដាភរិយាផង ជាមុហុត្តិកាភរិយាផង នៃបុរសឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។

**ចក្កបេយ្យាលគ្រប់ទាំងអស់ ចប់**

[ ១៨៦ ] ភិក្ខុទទួលពាក្យ ទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុទទួលពាក្យ ទៅនិយាយល្បងមើល តែមិនបានវិលមក ( ប្រាប់ ) វិញ ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុទទួលពាក្យ រួចមិនបាននិយាយល្បងមើលឡើយ គ្រាន់តែត្រឡប់មក(ប្រាប់) វិញ ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុទទួលពាក្យ តែមិនបាននិយាយល្បងមើល មិនបានត្រឡប់មក ( ប្រាប់ ) វិញឡើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទទួលពាក្យ តែបាននិយាយល្បងមើល ហើយនាំសេចក្តីមក ( ប្រាប់ ) វិញ ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុមិនបានទទួលពាក្យ តែបាននិយាយល្បងមើល ហើយមិនបានត្រឡប់មក ( ប្រាប់ ) វិញឡើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនបានទទួលពាក្យ មិនបាននិយាយល្បងមើល តែបាននាំសេចក្តីមក ( ប្រាប់ )

ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទទួលពាក្យ មិនបាននិយាយល្បងមើល មិនបាន ត្រឡប់មក ( ប្រាប់ ) វិញទេ មិនត្រូវអាបត្តិឡើយ ។

[ ១៨៧ ] បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចម្រើនទាំង-ឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ក៏ទទួលពាក្យ ភិក្ខុទាំងអស់និយាយល្បងមើល ភិក្ខុទាំងអស់នាំសេចក្តីមក ( ប្រាប់ ) វិញ ភិក្ខុទាំងអស់ ( នោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ក៏ទទួលពាក្យ ភិក្ខុទាំងអស់ទៅនិយាយល្បងមើល ហើយបានឲ្យភិក្ខុមួយរូបវិលមក ( ប្រាប់ ) វិញ ភិក្ខុទាំងអស់ ( នោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ក៏ទទួលពាក្យ បានឲ្យភិក្ខុមួយរូបទៅនិយាយល្បងមើល ហើយភិក្ខុទាំងអស់ក៏វិលមក ( ប្រាប់ ) វិញ ភិក្ខុទាំងអស់ ( នោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបង្គាប់ភិក្ខុច្រើនរូបថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកគ្រប់អង្គទៅនិយាយល្បងនឹងស្រីឈ្មោះនេះ ភិក្ខុទាំងអស់ក៏ទទួលពាក្យ បានចាត់ភិក្ខុមួយរូបឲ្យទៅនិយាយល្បងមើល ហើយឲ្យភិក្ខុមួយរូបនាំដំណឹងមក ( ប្រាប់ ) វិញ ភិក្ខុទាំងអស់ ( នោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួល

ពាក្យ ទៅនិយាយល្បងមើល ហើយវិលមក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យទៅនិយាយល្បងមើល ហើយប្រើកូនសិស្សឲ្យវិលមក ( ប្រាប់ ) វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ រួចប្រើកូនសិស្សឲ្យទៅនិយាយល្បងមើល ហើយវិលមក ( ប្រាប់ ) ដោយខ្លួនឯងវិញ ត្រូវអាបត្តិសង្ឃា-ទិសេស ។ បុរសបង្គាប់ភិក្ខុថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយ ល្បងមើលនឹងស្រីឈ្មោះនេះ ភិក្ខុក៏ទទួលពាក្យ បានប្រើកូនសិស្សឲ្យទៅនិយាយល្បងមើល ឯកូនសិស្សនោះបាននិយាយល្បងមើល ហើយក៏ត្រឡប់មក ទៅប្រាប់បុរសដើមក្រៅពីអាចារ្យដែលប្រើនោះ ត្រូវអាបត្តិថុល្លច្ច័យទាំងពីររូប ។

[ ១៨៨ ] ភិក្ខុទទួលពាក្យទៅនិយាយល្បងមើល ហើយត្រឡប់មក ( ប្រាប់ ) វិញ ដោយពាក្យកុហក ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុកាលទៅមិនទទួលបង្គាប់ តែបាននិយាយល្បងផង វិលមកប្រាប់វិញផង ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុកាលទៅ ក៏បានទទួលពាក្យបង្គាប់ និយាយល្បងមើល ហើយវិលមកប្រាប់វិញ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុកាលទៅក៏មិនបានទទួលបង្គាប់ កាលមកមិននាំដំណឹងមកប្រាប់វិញ មិនត្រូវអាបត្តិឡើយ ។

[ ១៨៩ ] ភិក្ខុដែលទៅ ( កាន់សំណាក់ស្រី និងប្រុស ) ដោយកិច្ច

ដែលត្រូវធ្វើចំពោះសង្ឃក្តី ចំពោះចេតិយក្តី ចំពោះបុគ្គលឈឺក្តី ភិក្ខុឆ្កួត ភិក្ខុដើមបញ្ញត្តិ មិនត្រូវអាបត្តិឡើយ ។

[ ១៩០ ] ( មាតិកានុក្រម គឺបញ្ជីរឿងតាមលំដាប់ហូរហែដែលនឹងសម្តែងតទៅ ដូចមានខាងក្រោមនេះ គឺ )

រឿងស្រីដេកលក់ រឿងស្រីស្លាប់ រឿងស្រីចេញពីលំនៅទៅ រឿងប្រុសប្រឡំជាស្រី រឿងស្រីខ្ទើយ រឿងឈ្លោះគ្នា ភិក្ខុបាននិយាយផ្សះផ្សា រឿងភិក្ខុនាំការឲ្យមនុស្សខ្ទើយ ។

[ ១៩១ ] សម័យនោះឯង បុរសម្នាក់បង្គាប់ភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ។ ភិក្ខុនោះក៏ទៅហើយសួរមនុស្សទាំងឡាយថា ស្រីឈ្មោះនេះនៅឯណា ។ មនុស្សទាំងឡាយឆ្លើយថា នាងនោះដេកលក់ទៅហើយ លោកម្ចាស់ ។ ភិក្ខុនោះមានសេចក្តីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសហើយដឹង ។ ភិក្ខុនោះក៏ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។ សម័យនោះឯង បុរសម្នាក់បង្គាប់ភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ។ ភិក្ខុនោះក៏ទៅហើយសួរមនុស្សទាំងឡាយថា ស្រីឈ្មោះនេះនៅឯណា ។ មនុស្សទាំងឡាយឆ្លើយថា បពិត្រលោកម្ចាស់ ស្រីនោះស្លាប់ហើយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិ

ទុក្កដ ។ សម័យនោះឯង មានបុរសម្នាក់បង្គាប់ភិក្ខុមួយរូបថា បពិត្រលោកដ៏ចម្រើន សូមលោកទៅនិយាយល្បងមើលនឹងស្រីឈ្មោះនេះ ។ ភិក្ខុនោះក៏ទៅ ហើយសួរមនុស្សទាំងឡាយថា ស្រីឈ្មោះនេះនៅឯណា ។ មនុស្សទាំង-ឡាយឆ្លើយថា នាងនោះចេញពីទីនេះទៅហើយ លោកម្ចាស់ ។បេ។ មនុស្សនោះមិនមែនជាស្រីទេ លោកម្ចាស់ ។បេ ។ មនុស្សនោះជា ស្រីខ្ទើយទេ លោកម្ចាស់ ។ ភិក្ខុនោះ មានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិទុក្កដ ។

[ ១៩២ ] សម័យនោះឯង ស្រីម្នាក់ឈ្លោះគ្នានឹងប្តី ហើយរត់ទៅផ្ទះម្តាយ ។ ភិក្ខុជាអ្នកចូលទៅកាន់ត្រកូលបាននិយាយផ្សះផ្សា ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ស្រីនោះប្តីបានលែងលះគ្នាដាច់ខាតហើយឬ ។ ភិក្ខុនោះឆ្លើយថា សូមទ្រង់ព្រះមេត្តាប្រោស មិនទាន់លែងដាច់ទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនមានអាបត្តិទេ ព្រោះគេមិនទាន់លែងគ្នាដាច់ខាត ។

[ ១៩៣ ] សម័យនោះឯង ភិក្ខុមួយរូបប្រព្រឹត្តនិយាយដឹកនាំការឲ្យមនុស្សខ្ទើយទាំងឡាយ ។ ភិក្ខុនោះមានសេចក្តីសង្ស័យ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ មិនត្រូវអាបត្តិសង្ឃាទិសេសទេ ត្រូវតែត្រឹមអាបត្តិថុល្លច្ច័យ ។

សង្ឃាទិសេសទី ៥ ចប់

# អដ្ឋកថា
# សញ្ចរិត្តសិក្ខាបទវណ្ណនា

[ ១២១ ] សញ្ចរិត្តសិក្ខាបទ បទថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅថា ក្នុងសញ្ចរិត្តសិក្ខាបទនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា

បទថា **បណ្ឌិតោ** បានដល់ បុគ្គលប្រកបដោយភាពជាអ្នកឈ្លាស គឺបុគ្គលមានបញ្ញាជាគតិ ។

បទថា **ព្យត្តោ** បានដល់ បុគ្គលប្រកបដោយភាពជាអ្នកអាច គឺជាអ្នកស្គាល់ឧបាយ អ្នកក្លាហាន ។

បទថា **មេធាវី** សេចក្តីថា ជាអ្នកប្រកបដោយបញ្ញា ធ្វើឲ្យអ្នកដទៃឃើញហើយឃើញទៀត ។ បទថា **ទក្ខោ** គឺជាអ្នកមុតស្រួច ។

បទថា **អនលសោ** គឺជាអ្នកដល់ព្រមដោយឧស្សាហ៍ព្យាយាម ។

បទថា **ឆន្នោ** ប្រែថា សមគួរ ។ បទថា **កិស្មឹ វិយ** មានអធិប្បាយថា មើលទៅដូចជាការលំបាក គឺហាក់ដូចជាវិនាស ហាក់ដូចជាការដែលគួរខ្មាសដល់ពួកខ្ញុំ ។ ពីរបទថា **កុមារិកាយ វត្តុំ** សេចក្តីថា ការដែលនឹងពោលព្រោះហេតុនៃក្មេងស្រីថា ពួកលោកចូរទទួលក្មេងស្រីនេះទៅ ( មើលទៅជាការលំបាក ) ។

បណ្តាអាវាហៈជាដើម ដែលឈ្មោះថា **អាវាហា** បានដល់ ការនាំក្មេងស្រីមកអំពីត្រកូលដទៃ ដើម្បីក្មេងប្រុស ។ ដែលឈ្មោះថា **វិវាហា** បានដល់

ការបញ្ជូនក្មេងស្រីរបស់ខ្លួនទៅកាន់ត្រកូលដទៃ ។

បទថា **វារេយ្យានិ** សេចក្ដីថា ការស្ដីដណ្ដឹងថា ពួកអ្នកចូរឲ្យក្មេងស្រីដល់ក្មេងប្រុសរបស់ពួកយើង ឬធ្វើការកំណត់ថ្ងៃ ឫក្ស និងយាម ។

[ ១២២ ] បទថា **បុរាណគណកិយា** សេចក្ដីថា ភរិយារបស់ហោរាម្នាក់ ស្រីនោះ កាលហោរានោះនៅមានជីវិត ប្រាកដឈ្មោះថា **គណកី** ។ កាលហោរាស្លាប់ហើយ ហៅថា **បុរាណគណកី** ។

បទថា **តិរោគាមោ** បានដល់ ក្រៅស្រុក អធិប្បាយថា ស្រុកដទៃ ។

បទថា **មនុស្សា** បានដល់ ពួកអ្នកស្រុកដឹងភាពដែលឧទាយិភិក្ខុ ជាអ្នកចូលចិត្តខ្វល់ខ្វាយក្នុងការនាំពាក្យថែចូវនេះ ។

[ ១២៣ ] បទថា **សុណិសាភោគេន** សេចក្ដីថា ពួកសាវ័ករបស់អាជីវកទាំងនោះ ប្រើស្រីនោះដូចដែលមនុស្សទាំងឡាយ គប្បីប្រើស្រីកូនប្រសា មានការឲ្យបម្រើនកត្ត ឲ្យស្ល និងការអង្គាសជាដើម ។

ប្រើនបទថា **តតោ អបរេន ទាសីភោគេន** សេចក្ដីថា កន្លងទៅបានមួយខែ ពួកសាវ័ករបស់អាជីវកទាំងនោះ ប្រើនាងនោះ ដោយការប្រើដូចមនុស្សទាំងឡាយ នឹងគប្បីប្រើទាសី មានការធ្វើស្រែ ចាក់សំរាម និងដងទឹកជាដើម ។

បទថា **ទុគ្គតា** គឺជាអ្នកក្រីក្រ មា៉ងទៀត សេចក្ដីថា ទៅកាន់ត្រកូលដែលខ្លួនទៅហើយ ជាអ្នកធ្លាក់ខ្លួនទុគ៌ត ។

ប្រែនបទថា **មាយ្យោ ឥមំ កុមារិកំ** សេចក្តីថា លោកកុំប្រើក្មេងស្រីនេះ ដូចប្រើទាសីឡើយ ។

ដោយបទថា **អាហារូបហារោ** ពួកសាវ័ករបស់អាជីវកសម្តែងថា ការជានា និងការយល់ព្រម គឺការទទួល និងការឲ្យ ពួកយើងមិនបានទទួលមក មិនបានប្រគល់ឲ្យអ្វីៗ គឺថា ពួកយើងមិនមានការទិញដូរ គឺការជួញដូរជាមួយលោក ។

បទថា **សមណេន ភវិតព្វំ អព្យាវដេន សមណោ អស្ស សុស្សមណោ** សេចក្តីថា ពួកសាវ័ករបស់អាជីវក រុកកួនព្រះឧទាយិត្ថេរនោះ យ៉ាងនេះថា ធម្មតាសមណៈ ត្រូវជាអ្នកមិនខ្វល់ខ្វាយ គឺត្រូវជាអ្នកមិនព្យាយាមក្នុងការងារបែបនេះ ព្រោះថា សមណៈដែលមានសភាពយ៉ាងនេះ គប្បីជាសមណៈល្អ ហើយពោលថា ទៅចុះលោក ពួកយើងមិនស្គាល់លោកទេ ។

[ ១២៤ ] បទថា **សង្ឃិតោ** សេចក្តីថា ជាអ្នកដល់ព្រមដោយគ្រឿងឧបករណ៍គ្រប់យ៉ាង ឬជាអ្នកដល់ព្រមដោយអាករណៈ ។

[ ១២៦ ] បទថា **ធុត្តា** បានដល់ ពួកអ្នកលេងស្រី ។

បទថា **បរិចារេន្តា** សេចក្តីថា ញ៉ាំងឥន្ទ្រិយទាំងឡាយឲ្យរីករាយ ក្នុងអារម្មណ៍ មានរូបជាដើម ដែលកើតកើនដោយជុំវិញយ៉ាងនោះផង យ៉ាងនេះផង អធិប្បាយថា កំពុងលេង គឺកំពុងត្រេកអរ ។

បទថា **អត្តុតមកំសុ** សេចក្តីថា ពួកអ្នកលេងធ្វើការភ្នាល់គ្នាថា បើឧទាយិភិក្ខុនឹងធ្វើ លោកឈ្នះភ្នាល់ប៉ុណ្ណេះ បើមិនធ្វើ ខ្ញុំឈ្នះភ្នាល់ប៉ុណ្ណេះ

លោកពោលទុកក្នុងមហាបច្ចរីថា ឯការភ្ញាល់គ្នាមិនគួរដល់ភិក្ខុទាំងឡាយ បើភិក្ខុណាធ្វើ អ្នកចាញ់នឹងត្រូវធ្វើសេចក្ដីវិនាសឲ្យដល់ភិក្ខុនោះ ។

វេលាមិនយូរ ហៅថា **តង្ខណា** ( ខណៈនោះ ) ក្នុងពាក្យថា **កថំ ហិ ឆាម អយ្យោ ឧទាយិ តង្ខណិកំ** នេះ ។ បទថា **តង្ខណកំ** បានដល់ការចែចូវ មានការធ្វើកិច្ចមួយរំពេច មិនយូរ ។

# អធិប្បាយ

## សិក្ខាបទវិភង្គនៃសញ្ចរិត្តសិក្ខាបទ

[ ១២៧ ] ពាក្យថា **សញ្ចរិត្តំ សមាបជ្ជេយ្យ** សេចក្ដីថា គប្បីដល់ការៈនិយាយដឹកនាំ ។ ក៏ព្រោះភិក្ខុដែលដល់ការៈនិយាយដឹកនាំនោះ ត្រូវបុគ្គលណាមួយបញ្ជូនទៅហើយ ចាំបាច់ត្រូវទៅក្នុងទីកន្លែងខ្លះ ស្ត្រី និងបុរសដែលលោកបំណងយកក្នុងសិក្ខាបទនេះ ដោយព្រះបាលីជាដើមថា **ឥត្ថិយា វា បុរិសមតឹ** ខាងមុខនោះឯង ដូច្នោះ ដើម្បីទ្រង់សម្ដែងអត្ថនោះ ទើបព្រះមានព្រះភាគត្រាស់បទភាជនីយ៍នៃបទថា **ឥត្ថិយា វា បុរិសមតឹ** នោះ យ៉ាងនេះថា ភិក្ខុដែលត្រូវស្រីពីងពាក់ឲ្យទៅក្នុងសម្នាក់បុរសក្ដី ត្រូវបុរសពឹងពាក់ឲ្យទៅក្នុងសម្នាក់នៃស្រីក្ដី ដូច្នេះ ។

ក្នុងពាក្យថា **ឥត្ថិយា វា បុរិសមតឹ បុរិសស្ស វា ឥត្ថីមតឹ** នេះ បណ្ឌិតគប្បីជ្រាបបាលីដ៏សេសថា **អារោចេយ្យ** ប្រែថា គប្បីប្រាប់ ។ ដោយហេតុនោះឯង ក្នុងបទភាជនីយ៍នៃបទថា **បុរិសស្ស វា ឥត្ថីមតឹ** នោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា រមែងប្រាប់បំណងរបស់បុរសដល់ស្រី ឬ

ប្រាប់បំណាងរបស់ស្ត្រីដល់បុរស ដូច្នេះ ។

ឥឡូវនេះ កាលទ្រង់សម្តែងប្រយោជន៍ គឺបំណង ត្រូវការ អធ្យាស្រ័យ ការគាប់ចិត្ត ការពេញចិត្ត របស់ប្រុស និងស្រីទាំងនោះ ដែលភិក្ខុប្រាប់ ទើបត្រាស់ថា ក្នុងភាពជាប្រពន្ធក្តី ក្នុងភាពជាសហាយស្មន់ក្តី ។

បណ្តាបទទាំងពីរនោះ បទថា **ជាយត្តនេ** គឺក្នុងភាពជាប្រពន្ធ ។

បទថា **ជារត្តនេ** គឺក្នុងភាពជាសហាយ ។ អធិប្បាយថា កាលភិក្ខុប្រាប់បំណាងរបស់បុរសដល់ស្ត្រី ឈ្មោះថា រមែងប្រាប់ក្នុងភាពជាប្រពន្ធ កាលប្រាប់បំណាងស្ត្រីដល់បុរស ឈ្មោះថា រមែងប្រាប់ក្នុងភាពជាសហាយស្មន់ ។ ន័យម្យ៉ាងទៀត កាលប្រាប់សេចក្តីបំណាងរបស់បុរសនោះឯងដល់ស្ត្រី ឈ្មោះថា ប្រាប់ក្នុងភាពជាប្រពន្ធ គឺក្នុងភាពជាប្រពន្ធ ត្រូវតាមច្បាប់ខ្លះ ក្នុងភាពជាសហាយ គឺក្នុងភាពជាមិច្ឆាចារខ្លះ ។ ព្រោះភិក្ខុកាលប្រាប់ភាពជាប្រពន្ធ និងជាសហាយនេះ ចាំបាច់ត្រូវពោលពាក្យជាដើមថា នាងនឹងត្រូវជាភរិយារបស់បុរសនោះ ដូច្នោះ ដើម្បីសម្តែងអាការនៃភាពជាពាក្យសម្តី ចាំបាច់ត្រូវពោលនោះ ទើបទ្រង់ត្រាស់ប្រាប់បទភាជនីយ៍នៃបទទាំងពីរនោះថា ពាក្យថា ក្នុងភាពជាប្រពន្ធ គឺនាងនឹងជាភរិយា ពាក្យថា ក្នុងភាពជាសហាយ គឺនាងនឹងជាសហាយ ដូច្នេះ ។

ដោយឧបាយនោះឯង ក្នុងការប្រាប់បំណាងរបស់ស្ត្រីដល់បុរស បណ្ឌិតគប្បីជ្រាបអាការដែលភិក្ខុចាំបាច់ត្រូវពោលថា អ្នកនឹងជាប្តី អ្នកនឹងជាស្វាមី អ្នកនឹងជាសហាយ ។

ពីរបទថា **អន្តមសោ តំខណិកាយបិ** សេចក្តីថា ស្រីដែលព្រះមាន

ព្រះភាគត្រាស់ហៅថា **តំខណិកា** ព្រោះជាអ្នកដែលបុរសគប្បីនៅរួមចំពោះក្នុងខណៈនោះ គឺត្រឹមមួយរយៈ សេចក្តីថា ជាប្រពន្ធត្រឹមមួយជួរខណៈ ដោយកំណត់យ៉ាងទាបបំផុតជាងគេ ។ កាលភិក្ខុប្រាប់បំណាំងរបស់បុរសដល់ស្រីនោះយ៉ាងនេះថា នាងនឹងជាប្រពន្ធមួយរយៈ ក៏ត្រូវអាបត្តិសង្ឃាទិសេស ។ ដោយឧបាយនោះឯង ភិក្ខុកាលប្រាប់បំណាំង របស់ស្រីដល់ប្រុសយ៉ាងនេះថា អ្នកនឹងជាប្តីមួយរយៈ បណ្ឌិតគប្បីជ្រាបថា ត្រូវអាបត្តិសង្ឃាទិសេស ។

សិក្ខាបទវិភង្គនៃសញ្ចរិត្តសិក្ខាបទ

# អធិប្បាយ
# បទភាជនីយ៍នៃសញ្ចរិត្តសិក្ខាបទ
# ស្រី ២០ ពួក

[ ១២៨ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងស្រីប្រភេទដែលទ្រង់បំណានក្នុងពាក្យថា **ឥត្ថិយា វា បុរិសមតឹ** នេះ ដោយប្រភេទហើយ ទ្រង់សម្តែងប្រភេទនៃអាបត្តិដោយអំណាចភាពជាអ្នកដឹកនាំក្នុងស្រីទាំងនោះ ទើបត្រាស់ពាក្យថា **ទស ឥត្ថិយោ** ជាដើម ។

[ ១៣០ ] បណ្តាបទទាំងនោះ បទថា **មាតុរក្ខិតា** បានដល់ ស្រីដែលម្តាយរក្សា គឺមាតារក្សា ដោយប្រការដែលនឹងសម្រេចការនៅរួមជាមួយបុរសមិនបាន ព្រោះហេតុនោះ ទើបព្រះឧបាលីពោលបទភាជនីយ៍នៃបទ **មាតុរក្ខិតា** នោះថា ម្តាយរមែងរក្សាឃុំគ្រង ញុំាងខ្លួនឲ្យធ្វើភាពជាធំ ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ។

បណ្តាបទទាំងនោះ បទថា **រក្ខតិ** សេចក្តីថា មិនឲ្យទៅក្នុងទីណាមួយ។ បទថា **គោបេតិ** សេចក្តីថា រមែងរាំងទុកក្នុងទីឃុំគ្រងដោយប្រការដែលបុរសដទៃមិនឃើញ ។

ពីរបទថា **ឥស្សរិយំ ការេតិ** សេចក្តីថា ប្រព្រឹត្តសង្កត់សង្កិន គឺហាមការនៅតាមទំនើងចិត្តនៃស្រីនោះ ។

ពីរបទថា **វសំ វត្តេតិ** សេចក្តីថា ញុំាងអំណាចរបស់ខ្លួនឲ្យប្រព្រឹត្តទៅខាងលើនៃស្រីនោះយ៉ាងនេះថា ហងចូរធ្វើវត្ថុនេះ កុំធ្វើយ៉ាងនេះ ។ ស្រីទាំងឡាយ មានស្រីដែលឪពុករក្សាជាដើម គប្បីជ្រាបដោយឧបាយនេះ ។

គោត្រ ឬធម៌ រមែងរក្សាមិនបាន តែថា ស្រីដែលជនមានគោត្រស្មើគ្នា និងដែលជនប្រព្រឹត្តធម៌រួមគ្នា គឺជនអ្នកបួសឧទ្ទិសព្រះសាស្តាអង្គតែមួយ និងជនដែលទាក់ទងក្នុងគណៈតែមួយរក្សាហើយ លោកហៅថា ស្រីដែលគោត្ររក្សា ស្រីដែលធម៌រក្សា ព្រោះដូច្នោះ ទើបលោកពោលបទភាជនីយ៍នៃបទទាំងនោះ ដោយន័យជាដើមថា **សគោត្តា រក្ខន្តិ** ។ ស្រីដែលប្រព្រឹត្តទៅព្រមដោយការរក្សា ឈ្មោះថា **សារក្ខា** ។ ស្រីប្រព្រឹត្តទៅក្នុងអាជ្ញាដោយជុំវិញ ឈ្មោះថា **សបរិទណ្ឌា** ។ និទ្ទេសនៃស្រីទាំងនោះប្រាកដច្បាស់ហើយ ។ បណ្តាស្រី ១០ ពួកនេះ ២ ពួកខាងក្រោយប៉ុណ្ណោះ កាលគប់រកបុរសដទៃ រមែងជាមិច្ឆាចារ ពួកក្រៅអំពីនេះ មិនជាមិច្ឆាចារឡើយ ។

[ ១៣១ ] បណ្តាស្រីដែលគេទិញដោយទ្រព្យជាដើម ស្រីដែលគេទិញមកដោយទ្រព្យតិចក្តី ច្រើនក្តី ឈ្មោះថា **ធនក្កីតា** ។ ព្រោះស្រីនោះ ត្រឹមតែគេទិញមកដោយទ្រព្យប៉ុណ្ណោះ មិនទាន់ឈ្មោះថាជាភរិយា តែដែលឈ្មោះថាភរិយា ក៏ព្រោះគេទិញមកដើម្បីប្រយោជន៍ដល់ការនៅរួម ដូច្នោះ ក្នុងនិទ្ទេសនៃបទថា **ធនក្កីតា** នោះ ទើបព្រះឧបាលីពោលថា បុរសទិញមកដោយទ្រព្យហើយឲ្យនៅ ។

ស្រីណា រមែងនៅដោយការពេញចិត្ត គឺ តម្រេករបស់ខ្លួន ហេតុនោះស្រីនោះ ឈ្មោះថា **ឆន្ទវាសិនី** ។ ព្រោះស្រីនោះរមែងជាភរិយាដោយហេតុត្រឹមតែការពេញចិត្តរបស់ខ្លួន ដោយចំណែកមួយក៏ទេ តែឈ្មោះថា ជាភរិយាព្រោះជាស្ត្រីដែលបុរសទទួលយល់ព្រមហើយ ។ ដូច្នោះ ក្នុងនិទ្ទេសនៃបទថា

**ឆន្ទវាសិនី** នោះ ទើបលោកពោលថា ប្រុសដែលស្រឡាញ់រមែងញ៉ាំងស្រីដែលស្រឡាញ់ឲ្យនៅ ។ ស្រីណា រមែងនៅដោយភោគៈ ហេតុនោះ ស្រីនោះឈ្មោះថា **ភោគវាសិនី** ។ ពាក្យថា **ភោគវាសិនី** នោះ ជាឈ្មោះនៃស្រីក្នុងជនបទ ដែលបានឧបករណ៍នៃផ្ទះ មានត្បាល់ អង្រែជាដើម ហើយចូលដល់ភាពជាភរិយា ។ ស្រីណា រមែងនៅដោយផ្ទាំងសំពត់ ហេតុនោះស្រីនោះ ឈ្មោះថា **បដវាសិនី** ។ ពាក្យថា **បដវាសិនី** នោះ ជាឈ្មោះនៃស្រីក្រីក្រ ដែលបានត្រឹមតែសំពត់ស្លៀកខ្លះ សំពត់ដណ្តប់ខ្លះ ហើយចូលដល់ភាពជាភរិយា ។

ពាក្យថា **ឱទបត្តកិនី** នោះ ជាឈ្មោះនៃស្រីដែលពួកញាតិញ៉ាំងដៃរបស់កូនស្រីកូនប្រុស ឲ្យជ្រមុជចុះក្នុងភាជនៈទឹកជាមួយគ្នា ហើយពោលថា អ្នកទាំងពីរ ចូរត្រូវគ្នា កុំបែកគ្នា ដូចទឹកនេះចុះ ដូច្នេះហើយ កំណាត់កាន់យក សូម្បីក្នុងនិទ្ទេសនៃបទថា **ឱទបត្តកិនី** នោះ គប្បីជ្រាបអត្ថយ៉ាងនេះថា ញាតិឲ្យបុរសនោះចាប់ភាជនៈទឹករួមជាមួយស្រីនោះ ហើយឲ្យនៅ ។

ទ្រនូលរបស់ស្រីនោះ ដែលបុរសនាំចុះ គឺដាក់ចុះហើយ ហេតុនោះស្ត្រីនោះ ឈ្មោះថា **ឱភដចុម្ពដា** គឺបណ្តាស្ត្រីទាំងឡាយ មានស្ត្រីលក់ឧសជាដើមណាមួយ ។ ពាក្យថា **ឱភដចុម្ពដា** នោះ ជាឈ្មោះនៃស្ត្រីដែលបុរសលើកទ្រនូលចុះអំពីក្បាល ហើយឲ្យនៅក្នុងផ្ទះ ។

បទថា **ទាសី ច** បានដល់ ស្ត្រីជាទាសីផង ជាភរិយារបស់ខ្លួនផង ។ ស្ត្រីដែលធ្វើការក្នុងផ្ទះដើម្បីតម្លៃឈ្នួល ឈ្មោះថា **កម្មការី** បុរសខ្លះមិនត្រូវ

ការដោយកិរិយារបស់ខ្លួន ទើបសម្រេចការគ្រប់គ្រងផ្ទះជាមួយស្ត្រីនោះ ទើបស្ត្រីនេះ ហៅថា ស្ត្រីធ្វើការផង ជាកិរិយាផង ។

ស្ត្រីដែលទង់នាំមកហើយ ឈ្មោះថា **ធជាហដា។** អធិប្បាយថា ស្ត្រីដែលកងទ័ពលើកទង់ឡើងហើយ ទៅវាយដណ្តើមដែនរបស់បរបក្ខ ហើយនាំមក ។ បុរសពួកខ្លះធ្វើស្ត្រីនោះឲ្យជាកិរិយា ស្ត្រីនោះ ឈ្មោះថា **ធជាហដា។** ស្រីដែលប្រុសគប្បីនៅរួមត្រឹមមួយរយៈ មានន័យដូចពោលហើយនោះឯង ។ ជាមិច្ឆាចារដល់ស្ត្រីទាំង ១០ ពួក ព្រោះគប់រកបុរសដទៃ ។ ក្នុងស្រី ២០ ពួក ជាមិច្ឆាចារដល់បុរស និងឈ្មោះថា ត្រូវទោសក្នុងការដឹកនាំដល់ភិក្ខុផងដែរ ។

## អធិប្បាយ និក្ខេបបទ រឿង បុរសបញ្ជូនភិក្ខុ

[ ១៣២-១៨៥ ] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បុរិសោ ភិក្ខុំ បហិណាតិ** ជាដើម ដូចតទៅនេះថា ភិក្ខុនោះទទួលពាក្យដែលបុរសនោះពោលយ៉ាងនេះថា លោកម្ចាស់មេត្តាទៅនិយាយនឹងស្រីដែលមាតាគ្រប់គ្រងឈ្មោះនេះថា បានឮថា ចូរនាងជាកិរិយាទិញដោយទ្រព្យរបស់បុរសឈ្មោះនេះ ដូច្នេះ ដោយបទ្វីវាចា ឬអាការឯណាមួយថា ល្អណាស់ ឧបាសកក្តី ឬថា ចូរសម្រេចចុះក្តី យើងនឹងប្រាប់ក្តី ដោយកាយវិការ មានងក់ក្បាលជាដើមក្តី ឈ្មោះថា ទទួល ។

កាលទទួលយ៉ាងនោះហើយ ទៅកាន់សម្នាក់ស្រីនោះ ប្រាប់ពាក្យបញ្ជូននោះ ឈ្មោះថា ប្រាប់ ។

កាលពាក្យបញ្ជូននោះ ដែលភិក្ខុនោះប្រាប់ហើយ ស្រីនោះទទួលថា

សាធុក្តី ឬ យាត់ក្តី នៅស្មៀមព្រោះខ្មាសក្តី ភិក្ខុត្រឡប់មកប្រាប់ដំណឹង នោះដល់បុរសនោះ ឈ្មោះថា ត្រឡប់មកប្រាប់ ។ ដោយអាការត្រឹមប៉ុណ្ណោះ ត្រូវអាបត្តិសង្ឃាទិសេស ព្រោះគ្រប់អង្គ ៣ ពោលគឺ **ទទួលពាក្យ ប្រាប់ ត្រឡប់មកប្រាប់** ។ តែស្រីនោះ ទោះបានជាកិរិយារបស់បុរសនោះក្តី មិនបានក្តី មិនជាហេតុឡើយ ។ ព្រះមហាបទុមត្ថេរពោលថា បើភិក្ខុនោះ ដែលបុរសពឹងពាក់ទៅកាន់សម្នាក់របស់ស្រីដែលម្តាយគ្រប់គ្រង មិនជួបស្រីនោះ ទើបប្រាប់ពាក្យនោះដល់ម្តាយរបស់ស្រីនោះ ឈ្មោះថា ប្រាប់ក្រៅពាក្យបញ្ជូន ព្រោះហេតុនោះ ទើបខុសសង្កេត ។ ចំណែកព្រះមហាសុមត្ថេរពោលថា ទោះជាម្តាយ ឬឪពុកក្តី ដោយហោចសូម្បីទាសីក្នុងផ្ទះ ឬអ្នកដទៃណាមួយ នឹងញុំាងកិរិយានោះឲ្យសម្រេចបាន កាលពាក្យនោះដែលភិក្ខុនោះប្រាប់ហើយ ដល់បុគ្គលនោះ ឈ្មោះថា ប្រាប់ហើយនោះឯង ព្រោះដូច្នោះ គង់ត្រូវអាបត្តិដូចគ្នា ក្នុងវេលាគ្រប់អង្គ ៣ ។ ភិក្ខុណាប្រាថ្នាពោលថា **ពុទ្ធំ បច្ចក្ខាមិ** តែពោលខុសថា **ធម្មំ បច្ចក្ខាមិ** សិក្ខាឈ្មោះថា លោកពោលហើយមិនមែន ឬ សេចក្តីនេះ យ៉ាងណា ម្យ៉ាងទៀត ភិក្ខុប្រាថ្នានឹងពោលថា **បឋមំ ឈានំ សមាបជ្ជាមិ** តែពោលខុសថា **ទុតិយំ ឈានំ សមាបជ្ជាមិ** ភិក្ខុត្រូវអាបត្តិបារាជិកដោយពិតមិនមែនឬ សេចក្តីនេះ យ៉ាងណា ពាក្យជាគ្រឿងឧបមេយ្យឲ្យដល់ព្រមនេះ ក៏ដូច្នោះដូចគ្នា ។

ឯពាក្យរបស់សុមត្ថេរនោះឯង សមដោយបទនេះថា ភិក្ខុទទួល តែឲ្យអន្តេវាសិកប្រាប់ ហើយត្រឡប់មកប្រាប់ដោយខ្លួនឯង ត្រូវសង្ឃាទិសេស ព្រោះដូច្នោះ ពាក្យរបស់លោក ឈ្មោះថា ពោលប្រពៃហើយ ។

កាលភិក្ខុត្រូវបុរសប្រាប់ថា លោកម្ចាស់ សូមប្រាប់ស្រីដែលម្ដាយគ្រប់គ្រង ហើយទៅប្រាប់ដល់ជនដទៃមានម្ដាយជាដើម ដែលអាចនឹងប្រាប់ដល់ស្រីនោះបាន ការខុសសង្កេតរមែងមិនមាន យ៉ាងណា ក្នុងកាលគួរនឹងប្រាប់ថា បានឮថា ចូរនាងជាភរិយាទិញដោយទ្រព្យរបស់បុរសឈ្មោះនេះ សូម្បីកាលភិក្ខុប្រាប់ដោយអំណាចពាក្យថា ចូរនាងជាភរិយាធនូវាសិនីជាដើម ពាក្យណាមួយ ដែលត្រាស់ទុកក្នុងបាលីយ៉ាងនេះថា បានឮថា ចូរនាងជាធនូ-វាសិនីភរិយារបស់បុរសឈ្មោះនេះ ឬដោយអំណាចពាក្យទាំងឡាយ ដែលមិនបានត្រាស់ទុក តែសម្ដែងអត្ថរួមគ្នា មានពាក្យជាដើមថា បានឮថា ចូរនាងជាភរិយា ជាយា បជាបតី ម្ដាយរបស់កូន មេផ្ទះ ម្ចាស់ផ្ទះ អ្នកគ្រួស្រីបម្រើ ស្រីបម្រើកាមរបស់បុរសឈ្មោះនេះ ដូច្នេះ ពាក្យណាមួយ ការខុសសង្កេត រមែងមិនមានដូច្នោះឯង គង់ត្រូវអាបត្តិពិត ព្រោះគ្រប់អង្គ ៣ ។

តែកាលភិក្ខុដែលបុរសពឹងថា សូមប្រាប់ស្រីដែលម្ដាយរក្សា ហើយទៅប្រាប់ស្រីដទៃ មានស្រីដែលឪពុករក្សាជាដើមណាមួយ នេះជាការខុសសង្កេត ។ សូម្បីក្នុងបទថា **បិតុរក្ខិតំ ព្រូហិ** ជាដើមក៏មានន័យនេះឯង ។ សេចក្ដីពិត ការប្លែកគ្នាក្នុងបទថា **បិតុរក្ខិតំ ព្រូហិ** ជាដើមនេះ ក៏ត្រឹមតែជាការផ្សេងគ្នានៃបេយ្យាល ដោយអំណាចនៃចក្ក មានឯកមូលកចក្ក និងទុមូលកចក្កជាដើម និងដោយអំណាចនៃបុគ្គលជាដើម មានជាដើមយ៉ាងនេះ គឺមាតារបស់បុរសដែលពឹងភិក្ខុ មាតារបស់ស្រីដែលមាតាគ្រប់គ្រងពឹងភិក្ខុ ស្រីដែលមាតាគ្រប់គ្រងពឹងភិក្ខុប៉ុណ្ណោះ ។ តែសេចក្ដីប្លែកគ្នានោះ អ្នកសិក្សា

អាចជ្រាបបានតាមគន្លងនៃព្រះបាលីនោះឯង ព្រោះមានវិនិច្ឆ័យដូចបានពោលមកហើយពីមុន ព្រោះហេតុនោះ ទើបខ្ញុំបានធ្វើសេចក្ដីអធិប្បាយ សម្ដែងវិភាគនៃការប្លែកគ្នានោះ ។

[ ១៨៦ ] ឯក្នុង ២ ចតុក្កៈ មានពាក្យថា **បដិគ្គណ្ហាតិ** ជាដើម ក្នុងចតុក្កៈទី ១ ត្រូវអាបត្តិសង្ឃាទិសេស ព្រោះគ្រប់អង្គ ៣ ដោយបទដើម ត្រូវអាបត្តិថុល្លច្ច័យ ព្រោះគ្រប់អង្គ ២ ដោយបទកណ្ដាល ត្រូវអាបត្តិទុក្កដ ព្រោះគ្រប់អង្គ ១ ដោយបទចុង ។ ក្នុងចតុក្កៈទី ២ ត្រូវអាបត្តិថុល្លច្ច័យ ព្រោះគ្រប់អង្គ ២ ដោយបទដើម ត្រូវអាបត្តិទុក្កដ ព្រោះគ្រប់អង្គ ១ ដោយបទកណ្ដាល មិនត្រូវអាបត្តិ ព្រោះមិនមានអង្គ ដោយបទចុង ។

បណ្ដាបទទាំងនោះ បទថា **បដិគ្គណ្ហាតិ** បានដល់ ទទួលពាក្យរបស់អ្នកពឹងពាក់ ។

បទថា **វីមំសតិ** បានដល់ ទៅកាន់ទីដែលគេពឹងពាក់ហើយ និយាយប្រាប់ពាក្យនោះ ។

បទថា **បច្ចាហរតិ** បានដល់ ត្រឡប់មកប្រាប់ដល់អ្នកពឹងពាក់ដែលជាម្ចាស់ដើម ។

បទថា **ន បច្ចាហរតិ** បានដល់ ប្រាប់ហើយ ចៀសចេញទៅអំពីទីនោះ ( មិនវិលមកប្រាប់ ) ។

បទថា **បដិគ្គណ្ហាតិ ន វីមំសតិ** បានដល់ ភិក្ខុដែលបុរសពឹងថា សូមលោកម្ចាស់ទៅនិយាយប្រាប់ស្រីឈ្មោះនេះ ភិក្ខុទទួលពាក្យរបស់បុរស

នោះថា អើ បាន ហើយភ្លេចក្តី មិនភ្លេចពាក្យនោះក្តី ទៅកាន់សម្នាក់របស់ស្រីនោះ ដោយករណីយកិច្ចដទៃ អន្តរាយនិយាយពាក្យបន្តិចបន្តួច ដោយអាការប្រមាណប៉ុណ្ណោះ លោកហៅថា ទទួល តែមិនប្រាប់ ។

លំដាប់នោះ ស្រីនោះនិយាយឯង នឹងភិក្ខុនោះថា បានឮថា ឧបដ្ឋាករបស់លោកម្ចាស់ចង់បានខ្ញុំ ដូច្នេះ កាលនិយាយយ៉ាងនេះហើយ ទើបពោលថា ខ្ញុំនឹងជាភរិយារបស់បុរសនោះក្តី មិនជាភរិយាក្តី ភិក្ខុនោះមិនទទួល មិនជំទាស់ពាក្យរបស់ស្រីនោះ នៅព្រងើយ ក្រោកចាកទីអន្តរាយ មកកាន់សម្នាក់របស់បុរសនោះ ហើយប្រាប់ដំណឹងនោះ ដោយអាការមានប្រមាណប៉ុណ្ណោះ លោកហៅថា ឈ្មោះថា មិនប្រាប់ តែត្រឡប់មកប្រាប់ ។

បទថា **ន វីមំសតិ ន បច្ចាហរតិ** បានដល់ ទទួលពាក្យរបស់អ្នកពឹងពាក់តែម្យ៉ាងប៉ុណ្ណោះ តែមិនធ្វើកិច្ចដទៃក្រៅអំពីនេះ ។

បទថា **ន បដិគ្គណ្ហាតិ វីមំសតិ បច្ចាហរតិ** បានដល់ បុរសខ្លះពោលពាក្យបែបនោះក្នុងទីដែលភិក្ខុឈរក្តី អង្គុយក្តី ។ ភិក្ខុដែលគេមិនបានពឹងពាក់ឡើយ តែធ្វើដូចជាគេពឹងពាក់ ទើបទៅកាន់សម្នាក់របស់ស្រី ហើយនិយាយសាកល្បង ដោយន័យជាដើមថា បានឮថា នាងចូរជាភរិយារបស់បុរសឈ្មោះនេះ ហើយត្រឡប់មកប្រាប់តាមការពេញចិត្ត ឬមិនពេញចិត្តរបស់ស្រីនោះដល់បុរសនេះ ។ ភិក្ខុនិយាយប្រាប់ ហើយត្រឡប់មកប្រាប់ដោយន័យនោះឯង លោកហៅថា មិនទទួលពាក្យ តែនិយាយប្រាប់ ហើយត្រឡប់មកប្រាប់ ។ ភិក្ខុទៅហើយដោយន័យនោះឯង តែមិននិយាយប្រាប់

ស្តាប់ពាក្យសម្តីរបស់ស្រីនោះពោលហើយ មកប្រាប់ដល់បុរសនេះ តាមន័យដូចពោលហើយក្នុងបទទី ៣ នៃបឋមចតុក្កៈ លោកហៅថា មិនទទួល មិនប្រាប់ តែត្រឡប់មកប្រាប់ ។ បទទី ៤ ជាក់ច្បាស់ហើយនោះឯង ។

[ ១៨៧ ] ន័យទាំងឡាយជាដើមថា បញ្ចូនភិក្ខុជាច្រើន ជាក់ច្បាស់ហើយដូចគ្នា ។ ភិក្ខុសូម្បីច្រើនរូប រមែងត្រូវអាបត្តិក្នុងវត្ថុមួយ យ៉ាងណា គប្បីជ្រាបអាបត្តិជាច្រើន ព្រោះវត្ថុច្រើននៃភិក្ខុមួយរូប ដូច្នោះ ។

សេចក្តីនេះដូចម្តេច បុរសបញ្ចូនភិក្ខុថា លោកម្ចាស់ សូមលោកម្ចាស់ទៅត្រង់ប្រាសាទឈ្មោះនោះ មានស្រីប្រមាណ ៦០ នាក់ក្តី ៧០ នាក់ក្តី សូមលោកម្ចាស់ប្រាប់ស្រីទាំងនោះថា បានឮថា ពួកនាងចូរជាភរិយារបស់បុរសឈ្មោះនេះ ។ ភិក្ខុនោះទទួលហើយ ទៅឯប្រាសាទនោះឯង និយាយប្រាប់ ហើយនាំដំណឹងនោះត្រឡប់មកវិញ ។ ភិក្ខុត្រូវអាបត្តិស្មើចំនួនស្រី ។ ពិតហើយ ក្នុងគម្ពីរបរិវារ ព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះថា

> ភិក្ខុត្រូវគរុកាបត្តិទាំងអស់ ៦៤ ជាអាបត្តិដែលខ្លួនកែបាន
> ក្នុងខណៈជាមួយគ្នា ដោយគ្រាន់តែឈានជំហានទៅ និង
> ពោលដោយវាចា ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បាន
> គិតមកហើយ ។

បានឮថា បញ្ហានេះ លោកអាស្រ័យអំណាចនៃអត្ថនេះពោលហើយ ។ ចំណែកពាក្យថា អាបត្តិ ៦៤ ក្នុងគាថានេះ ព្រះមានព្រះភាគត្រាស់ដើម្បីការពីរោះរណ្តំនៃពាក្យ ។ តែកាលភិក្ខុធ្វើយ៉ាងនោះ រមែងត្រូវអាបត្តិរាប់រយក៏បាន រាប់ពាន់នាក់ក៏បានដូច្នេះឯង ។

ចំណែកអាបត្តិជាច្រើន ព្រោះស្រីច្រើនដល់ភិក្ខុមួយរូប ដែលបុរសម្នាក់បញ្ជូនទៅ យ៉ាងណា បុរសម្នាក់បញ្ជូនភិក្ខុច្រើនទៅកាន់សម្នាក់របស់ស្រីម្នាក់ ភិក្ខុទាំងអស់គ្រប់រូប ត្រូវអាបត្តិសង្ឃាទិសេស ដូច្នោះ ។

បុរសម្នាក់ បញ្ជូនភិក្ខុច្រើនរូប ទៅកាន់សម្នាក់របស់ស្រីជាច្រើន ត្រូវអាបត្តិសង្ឃាទិសេសតាមចំនួនស្រី ។ បុរសច្រើននាក់បញ្ជូនភិក្ខុមួយរូបទៅកាន់សម្នាក់របស់ស្រីម្នាក់ ត្រូវអាបត្តិសង្ឃាទិសេសតាមចំនួននៃបុរស ។ បុរសច្រើននាក់ បញ្ជូនភិក្ខុមួយអង្គទៅកាន់សម្នាក់របស់ស្រី ច្រើននាក់ ត្រូវអាបត្តិសង្ឃាទិសេសតាមចំនួនវត្ថុ ។ បុរសច្រើននាក់ បញ្ជូនភិក្ខុច្រើនរូបទៅកាន់សម្នាក់ស្រីម្នាក់ ត្រូវអាបត្តិសង្ឃាទិសេសតាមចំនួនវត្ថុ ។ បុរសច្រើននាក់បញ្ជូនភិក្ខុច្រើនរូបទៅកាន់សម្នាក់នៃស្រីច្រើននាក់ ត្រូវអាបត្តិសង្ឃាទិសេសតាមចំនួនវត្ថុ ។ សូម្បីក្នុងពាក្យថា ស្រីម្នាក់ បញ្ជូនភិក្ខុមួយអង្គជាដើមក៏មានន័យនេះដូចគ្នា ។ ក្នុងសញ្ចរិត្តសិក្ខាបទនេះ ឈ្មោះថា ភាពជាអ្នកត្រូវចំណែក និងមិនត្រូវចំណែកគ្នា មិនជាប្រមាណ កាលភិក្ខុធ្វើការទៅនិយាយចែចូវដល់ឪពុកម្ដាយក្ដី ដល់សហធម្មិកទាំង ៥ ក្ដី ត្រូវអាបត្តិទាំងអស់ ។ ចតុក្កៈថា បុរសពឹងពាក់ភិក្ខុថា និមន្តទៅចុះលោកម្ចាស់ លោកពោលទុកដើម្បីសម្ដែងប្រភេទនៃអាបត្តិ ដោយអំណាចនៃអង្គ ។

ក្នុងបទចុងក្រោយនៃចតុក្កៈនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ច្រើនបទថា **អន្តេវាសី វីមំសិត្វា ពហិទ្ធា បច្ចាហរតិ** សេចក្ដីថា អន្តេវាសិកមក ហើយមិនប្រាប់ដល់អាចារ្យ ទៅកាន់ផ្ទះដទៃប្រាប់ដល់បុរសនោះ ។

ប្រើនបទថា **អាបត្តិ ឧភិន្នំ ថុល្លច្ចយស្ស** សេចក្តីថា ត្រូវអាបត្តិថុល្លច្ច័យដល់អាចារ្យដោយអង្គ ២ គឺព្រោះទទួលពាក្យ ១ ព្រោះប្រើឲ្យទៅនិយាយប្រាប់ ១ ។ ត្រូវអាបត្តិថុល្លច្ច័យដល់អន្តេវាសិកដោយអង្គ ២ គឺព្រោះទៅនិយាយប្រាប់ ១ ព្រោះត្រឡប់មកប្រាប់ ១ ពាក្យដ៏សេស ប្រាកដច្បាស់ហើយ ដូច្នេះ ។

[ ១៨៨ ] ពីរបទថា **គច្ឆន្តោ សម្បាទេតិ** បានដល់ ទទួល និងទៅនិយាយប្រាប់ ។ ពីរបទថា **អាគច្ឆន្តោ វិសំវាទេតិ** បានដល់ មិនត្រឡប់មកប្រាប់ ។ ពីរបទថា **គច្ឆន្តោ វិសំវាទេតិ** បានដល់ មិនទទួលពាក្យ ។ ពីរបទថា **អាគច្ឆន្តោ សម្បាទេតិ** បានដល់ ទៅនិយាយប្រាប់ និងត្រឡប់មកប្រាប់ ។

ក្នុងបទទាំងពីរយ៉ាងនេះ ត្រូវអាបត្តិថុល្លច្ច័យដោយអង្គ ២ ។ ក្នុងបទទី ៣ ជាអាបត្តិ ក្នុងបទទី ៤ មិនជាអាបត្តិ ។

[ ១៨៩ ] ក្នុងពាក្យថា **អនាបត្តិ សង្ឃស្ស វា ចេតិយស្ស វា គិលានស្ស វា ករណីយេន គច្ឆតិ ឧម្មត្តកស្ស អាទិកម្មិកស្ស** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ឧបោសថាគារ ឬការងារណាមួយ របស់ភិក្ខុសង្ឃដែលធ្វើមិនទាន់រួចមាន ឧបាសកពឹងភិក្ខុទៅកាន់សម្នាក់របស់ឧបាសិកា ឬឧបាសិកាពឹងភិក្ខុទៅកាន់សម្នាក់របស់ឧបាសក ដើម្បីអាហារ និងតម្លៃការងារសម្រាប់ពួកជាង ក្នុងការសាងឧបោសថគារជាដើមនោះ កាលភិក្ខុទៅដោយករណីយរបស់សង្ឃដូច្នេះ មិនត្រូវអាបត្តិ ។ សូម្បីក្នុងចេតិយកម្មដែលកំពុងធ្វើ

ក៏មានន័យដូចគ្នា ។ អាបត្តិមិនមានដល់ភិក្ខុដែលឧបាសកបញ្ជូន ហើយទៅកាន់សម្នាក់របស់ឧបាសិកា ឬដែលឧបាសិកាពឹង ហើយទៅកាន់សម្នាក់របស់ឧបាសក ដើម្បីថ្នាំសម្រាប់ភិក្ខុអាពាធ ។ ភិក្ខុឆ្កួត និងភិក្ខុដែលជាអាទិកម្មិក មានន័យដូចពោលហើយនោះឯង ។

បណ្ណាបកិណ្ណកៈ មានសមុដ្ឋានជាដើម សិក្ខាបទនេះ មានសមុដ្ឋាន ៦ កាលភិក្ខុទទួលដំណឹងដោយកាយវិការ មានងក់ក្បាលជាដើម ទៅនិយាយប្រាប់ដោយមេដៃ ហើយត្រឡប់មកប្រាប់ដោយមេដៃ អាបត្តិកើតដោយកាយ ។ កាលបុគ្គលណាម្នាក់ ពោលដល់ភិក្ខុដែលអង្គុយ ត្រង់រោងឆាន់ថាស្រីឈ្មោះនេះនឹងមក លោកម្ចាស់គប្បីដឹងចិត្តរបស់នាង ហើយភិក្ខុទទួលថាសាធុ ហើយប្រាប់ស្រីដែលមករកនោះ កាលស្រីនោះត្រឡប់ទៅហើយ ភិក្ខុប្រាប់បុរសនោះ ក្នុងកាលបុរសនោះត្រឡប់មករក អាបត្តិកើតដោយកម្លាំងវាចាប៉ុណ្ណោះ ។ កាលភិក្ខុទទួលពាក្យ ដោយវាចាថា អើ បាន ហើយទៅកាន់ផ្ទះរបស់ស្រីនោះ ដោយករណីយកិច្ចដទៃក្តី ជួបស្រីនោះក្នុងវេលាទៅទីដទៃក្តី ហើយប្រាប់ដោយបទ្ទីវាចានោះឯង មិនទាន់ចៀសទៅអំពីទីនោះដោយហេតុដទៃនោះឯង ចែជនឡជួបបុរសនោះម្តងទៀត ហើយប្រាប់ អាបត្តិរមែងកើតដោយអំណាចវាចាតែម្យ៉ាង ។ អាបត្តិរមែងកើតតាមផ្លូវកាយ និងវាចាសូម្បីដល់ព្រះទីណាស្រេចដែលមិនដឹងសិក្ខាបទបញ្ញត្តិ ។

សេចក្តីនោះដូចម្តេច បើមាតា និងបិតារបស់ភិក្ខុនោះខឹងក្រោធគ្នា លែងលះគ្នាដាច់ហើយ ។ បិតារបស់ព្រះថេរៈនោះនិយាយនឹងភិក្ខុនោះ ដែលមក

កាន់ផ្ទះថា បពិត្រលោកកូន ញោមស្រីរបស់កូន ចោលញោមដែលចាស់ជរា ទៅកាន់ត្រកូលញាតិហើយ សូមកូនទៅប្រាប់ឲ្យញោមស្រីនោះ ( ត្រឡប់មក ) ដើម្បីប្រណិប័តន៍ញោមចុះ បើភិក្ខុនោះទៅនិយាយនឹងញោមស្រីនោះ ហើយត្រឡប់មកប្រាប់ដំណឹងនៃការមក ឬមិនមកនៃញោមស្រីនោះដល់ញោមប្រុស ត្រូវអាបត្តិសង្ឃាទិសេស ។

សមុដ្ឋាន ៣ នេះ ជាអចិត្តកសមុដ្ឋាន ។ តែកាលភិក្ខុជ្រាបសិក្ខាបទបញ្ញត្តិហើយ ដល់នូវការចែចូវដោយន័យទាំង ៣ នេះឯង អាបត្តិរមែងកើតតាមកាយ និងចិត្ត ១ វាចា និងចិត្ត ១ តាមកាយ វាចា និងចិត្ត ១ ។ សមុដ្ឋាន ៣ នេះ ជាសចិត្តកសមុដ្ឋាន ព្រោះបានដឹងសិក្ខាបទបញ្ញត្តិ ជាកិរិយា នោសញ្ញាវិមោក្ខ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម ហើយក្នុងសិក្ខាបទនេះ មានចិត្ត ៣ ដួង ដោយអំណាចកុសលចិត្តជាដើម មានវេទនា ៣ ដោយអំណាចនៃសុខវេទនាជាដើម ដូច្នេះឯង ។

បទភាជនីយ៍នៃសញ្ចរិត្តសិក្ខាបទ ចប់

# អធិប្បាយ

## វិធីតវត្ថុក្នុងសញ្ចរិត្តសិក្ខាបទ

[ ១៩១ ] បណ្តាវិធីតវត្ថុទាំងឡាយ ក្នុង ៥ រឿងខាងដើម ត្រូវអាបត្តិទុក្កដ ព្រោះត្រឹមតែទទួល ។

[ ១៩២ ] ក្នុងរឿងឈ្មោះគ្នា មានវិនិច្ឆ័យដូច្នេះ បទថា **សម្មោទនីយំ អកាសិ** សេចក្តីថា ឲ្យស្រីនោះយល់ព្រមហើយ បានធ្វើផ្ទះឲ្យជាទីកន្លែងគួរត្រឡប់ទៅវិញ ។

បទថា **នាលំវចនីយា** មានអត្ថថា មិនទាន់លែងគ្នាដាច់ ។ ពិតហើយ ស្រីណាដែលប្តីបោះបង់ចោលហើយ ក្នុងជនបទណាមួយ ដោយប្រការណាមួយ រមែងផុតភារៈជាកិរិយា ស្រីនេះ លោកហៅថា អ្នកលែងលះគ្នាដាច់ តែស្រីនេះ មិនមែនជាអ្នកលែងលះគ្នាដាច់ទេ ។ នាងឈ្មោះគ្នាដោយហេតុប្រការខ្លះ ហើយទៅ ដោយហេតុនោះឯង ក្នុងរឿងឈ្មោះគ្នានេះ ទើបព្រះមានព្រះភាគត្រាស់ថា មិនត្រូវអាបត្តិ ។ ព្រោះព្រះមានព្រះភាគកាត់អាបត្តិថុល្លច្ច័យក្នុងយក្ខិនី ព្រោះកាយសំសគ្គៈ ដូច្នោះ សូម្បីក្នុងទុដ្ឋុល្លសិក្ខាបទជាដើមនេះ យក្ខិនី និងស្រីប្រេត បណ្ឌិតគប្បីជ្រាបថា ជាវត្ថុនៃថុល្លច្ច័យដូចគ្នា តែក្នុងអដ្ឋកថាទាំងឡាយ លោកមិនពិចារណាពាក្យនេះទុក ។ ពាក្យដ៏សេសគ្រប់ៗ រឿង មានអត្ថក្លីច្បាស់ទាំងអស់ហើយ ។

សញ្ចរិតសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ៦

[ ១៩៤ ] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ( កន្លែងដែលស្តេចប្រទានអភ័យ និងចំណីដល់សត្វកង្ហែន ) ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ពួកភិក្ខុនៅក្នុងដែនអាឡវីប្រើគេឲ្យសាងនូវកុដិទាំងឡាយ ដែលមានគ្រឿងឧបករណ៍ ( គ្រឿងប្រដាប់សង់ផ្ទះ ) សូមពីគេមកខ្លួនឯង ឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ ។ កុដិទាំងនោះមិនទាន់សម្រេច ។ ភិក្ខុទាំងនោះក៏ចេះតែសូមញឹកៗ ញយៗ ដោយពាក្យសូមថា អ្នកទាំងឡាយចូរឲ្យនូវបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ៍ ឲ្យឫស្សី ឲ្យស្មៅយាប្លង ឲ្យស្មៅជំណោកទន្សាយ ឲ្យស្មៅ ឲ្យដីស្អិត ( ដល់យើងទាំងឡាយ ) ។ ពួកមនុស្សដែលភិក្ខុទាំងនោះចេះតែបៀតបៀនដោយការសូមញឹកញយហួសពេក លុះដល់ឃើញពួកភិក្ខុហើយ ក៏ភ្ញាក់ផ្អើលខ្លះ តក់ស្លុតខ្លះ លបរត់ទៅខ្លះ គេចទៅទីដទៃខ្លះ បែរមុខទៅទីដទៃខ្លះ បិទទ្វារផ្ទះខ្លះ សូម្បីគ្រាន់តែឃើញនូវគោញីទាំងឡាយ ក៏គេចរត់ដោយស្មានថាជាពួកភិក្ខុ ។

[ ១៩៥ ] ខណៈនោះ ព្រះមហាកស្សបដ៏មានអាយុ គង់ចាំវស្សាក្នុងក្រុងរាជគ្រឹះ ( គ្រប់ត្រៃមាស ) ហើយ ក៏និមន្តចេញទៅឯដែនអាឡវី ត្រាច់ទៅកាន់ចារិកតាមលំដាប់ សំដៅទៅកាន់ដែនអាឡវីនោះ ។ មានសេចក្តី

តំណាលថា ព្រះមហាកស្សបដ៏មានអាយុ សម្រេចឥរិយាបថនៅនាអគ្គាឡវ-ចេតិយ ក្នុងដែនអាឡវីនោះ ។ គ្រានោះ ជាវេលាព្រឹក ព្រះមហាកស្សបដ៏មានអាយុ ស្លៀកស្បង់ទ្រង់បាត្រ និងចីវរចូលទៅកាន់ដែនអាឡវី ដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយបានឃើញព្រះមហាកស្សបដ៏មានអាយុ ក៏ក្រាក់ផ្អើលខ្លះ តក់ស្លុតខ្លះ លបរត់ទៅខ្លះ គេចទៅទីដទៃខ្លះ បែរមុខទៅទីដទៃខ្លះ បិទទ្វារផ្ទះខ្លះ ។ គ្រានោះ ព្រះមហាកស្សបដ៏មានអាយុត្រាច់ទៅបិណ្ឌបាតក្នុងដែនអាឡវីធ្វើភត្តកិច្ចស្រេចហើយ ដល់កាលជាខាងក្រោយអំពីភត្តកិច្ចក៏ហៅពួកភិក្ខុមកហើយសួរថា ម្នាលលោកដ៏មានអាយុទាំងឡាយ កាលពីដើមដែនអាឡវីនេះសម្បូរចង្ហាន់ បិណ្ឌបាតបានងាយ ងាយនឹងព្យាយាមស្វែងរកការចិញ្ចឹមជីវិត ប៉ុន្តែឥឡូវនេះ ដែនអាឡវីនេះប្រែជាកើតទុរ្ភិក្ស បិណ្ឌបាតបានដោយកម្រ លំបាកនឹងព្យាយាមស្វែងរកការចិញ្ចឹមជីវិតទៅវិញ ម្នាលលោកដ៏មានអាយុទាំងឡាយ អ្វីហ្ន៎ជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យដែនអាឡវីនេះប្រែជាកើតទុរ្ភិក្ស បិណ្ឌបាតបានដោយកម្រ លំបាកនឹងព្យាយាមស្វែងរកការចិញ្ចឹមជីវិតទៅវិញ ។ ទើបភិក្ខុទាំងនោះពិតរៀងនុ៎ះដល់ព្រះមហាកស្សបដ៏មានអាយុ ។

[ ១៩៦ ] គ្រានោះ ព្រះដ៏មានព្រះភាគគង់នៅក្នុងក្រុងរាជគ្រឹះគួរដល់ពុទ្ធអធ្យាស្រ័យ ហើយក៏យាងចេញទៅឯដែនអាឡវី យាងទៅកាន់ចារិកតាមលំដាប់ សំដៅទៅកាន់ដែនអាឡវីនោះ ។ មានសេចក្តីតំណាលថា ព្រះដ៏មានព្រះភាគ ទ្រង់សម្រេចឥរិយាបថនៅនាអគ្គាឡវចេតិយ ក្នុងដែនអាឡវី

នោះ ។ ខណៈនោះ ព្រះមហាកស្សបដ៏មានអាយុ ចូលទៅគាល់ព្រះអង្គ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយខាងទីដ៏សមគួរ ។ លុះអង្គុយក្នុងទីដ៏សមគួររួចហើយ ព្រះមហាកស្សបដ៏មានអាយុ បានក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរបញ្ជាក់ពួកភិក្ខុដែនអាឡវីថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នករាល់គ្នាឲ្យគេធ្វើនូវកុដិទាំង-ឡាយដែលមានគ្រឿងឧបករណ៍សូមអំពីគេមកដោយខ្លួនឯង មិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ កុដិទាំងនោះមិនទាន់សម្រេច អ្នករាល់គ្នាចេះតែសូមគេញយៗ ថា អ្នកទាំងឡាយចូរឲ្យនូវបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹងឲ្យចប ឲ្យពន្លាក ឲ្យវល្លិ៍ ឲ្យឫស្សី ឲ្យស្មៅយាប្លង ឲ្យស្មៅដំណេកទន្សាយ ឲ្យស្មៅ ឲ្យដីស្អិត ពួកមនុស្សដែលអ្នកទាំងឡាយចេះតែបៀតបៀនដោយការសូមញឹកញយហួសពេក លុះដល់ឃើញភិក្ខុទាំងឡាយហើយ ក៏ភ្ញាក់ផ្អើលខ្លះ តក់ស្លុតខ្លះ លបរត់ទៅខ្លះ គេចទៅទីដទៃខ្លះ បែរមុខទៅទីដទៃខ្លះ បិទទ្វារផ្ទះខ្លះ សូម្បីគ្រាន់តែឃើញនូវគោញីទាំងឡាយហើយសម្គាល់ថាភិក្ខុ ក៏គេចរត់ទៅ សេចក្តីនេះ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានជោគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ដំណើរនេះ មិនសមគួរទេ ។បេ។ មិនមែនជាកិច្ចដែលត្រូវធ្វើទេ ម្នាលមោឃបុរសទាំងឡាយ មិនសមបីបើអ្នកឯងរាល់គ្នាប្រើគេឲ្យ

សាងកុដិទាំងឡាយ ដែលមានគ្រឿងឧបករណ៍សូមពីគេមកខ្លួនឯង ឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅរបស់ខ្លួន ធំហួសប្រមាណ កុដិទាំងនោះមិនទាន់សម្រេច អ្នកទាំងឡាយចេះតែសូមញយៗ ដោយពាក្យសូមថា អ្នកទាំងឡាយចូរឲ្យនូវបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោ ឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ៍ ឲ្យឫស្សី ឲ្យស្មៅយាប្លង ឲ្យស្មៅជំណោកទន្សាយ ឲ្យស្មៅ ឲ្យដីស្អិត ( ដល់យើងទាំងឡាយ ) ម្នាលមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំង-ឡាយដែលមិនទាន់ជ្រះថ្លា ( នោះ ) ទេ ។ បេ ។ មានតែនាំឲ្យខូចចិត្តដល់ជនទាំងឡាយដែលមានសេចក្តីជ្រះថ្លាហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលពួកភិក្ខុដែនអាឡវីដោយអនេកបរិយាយ ។បេ។ ហើយទ្រង់សំដែងធម្មីកថាតាមសមគួរដល់ហេតុនោះៗ ដល់ភិក្ខុទាំងឡាយ ហើយទ្រង់ហៅពួកភិក្ខុមកហើយ ( ត្រាស់ថា ) ។

[ ១៩៧ ] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម មានឥសីពីរនាក់ ជាបងប្អូននឹងគ្នាសម្នាក់នៅអាស្រ័យនឹងស្ទឹងគង្គា ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ មានស្តេចនាគមួយឈ្មោះមណិកណ្ឋ ឡើងមកអំពីស្ទឹងគង្គាហើយចូលមករកឥសីជាប្អូន លុះចូលមកដល់ហើយក៏ព័ទ្ធព័ន្ធឥសីប្អូនដោយភ្លួន ៧ ជុំ ហើយបើកពពារដ៏ធំបាំងអំពីខាងលើសិរ្សនៃឥសីប្អូននោះ ។ ម្នាលភិក្ខុទាំង-ឡាយ គ្រានោះ ឥសីប្អូនហេតុតែមានសេចក្តីខ្លាចអំពីនាគនោះ ក៏ចេះតែស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតទៅជារោគលឿងស្លេកស្លាំង មានខ្លួន

វាមដោយសរសៃ ។ ម្នាលភិក្ខុទាំងឡាយ ឥសីជាបងបានឃើញឥសីប្អូន ស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះឃើញហើយ ក៏សួរទៅឥសីប្អូនថា ម្នាលអ្នកដ៏ចម្រើន ហេតុអ្វីក៏អ្នកស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ( ដូច្នេះ ) ។ ឥសីជាប្អូនប្រាប់ថា បពិត្រលោកបងដ៏ចម្រើន នាគរាជឈ្មោះមណិកណ្ឋ ឡើងមកអំពីស្ទឹងគង្គា ហើយចូលមករកខ្ញុំក្នុងទីនេះ លុះចូលមកដល់ហើយ ក៏ព័ទ្ធព័ន្ធខ្ញុំដោយភ្នែន ៧ ជុំ ហើយបើកពពារដ៏ធំបាំងពីខាងលើក្បាលខ្ញុំ ព្រោះសេចក្តីខ្លាចនាគរាជនោះ បានជាខ្ញុំស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ។ ឥសីបងសួរថា ម្នាលអ្នកដ៏ចម្រើន អ្នកចង់មិនឲ្យនាគរាជនោះមកដែរឬ ។ ឥសីប្អូនតបថា បពិត្រលោកបងដ៏ចម្រើន ខ្ញុំចង់មិនឲ្យនាគរាជនោះមកទេ ។ ឥសីបងសួរថា ម្នាលអ្នកដ៏ចម្រើន ចុះអ្នកឯងបានឃើញវត្ថុអ្វីជារបស់នាគរាជនោះខ្លះ ។ ឥសីប្អូនតបថា បពិត្រលោកបងដ៏ចម្រើន ខ្ញុំបានឃើញកែវមណីជាគ្រឿងប្រដាប់ពួងកនៃនាគរាជនោះ ។ ឥសីបងក៏បង្គាប់ថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះអ្នកចូរសូមកែវមណីចំពោះនាគរាជនោះថា អ្នកដ៏ចម្រើន សូមអ្នកឲ្យកែវមណីដល់អាត្មាៗ ត្រូវការដោយកែវមណី ។ ម្នាលភិក្ខុទាំងឡាយ ខណៈនោះមណិកណ្ឋនាគរាជក៏ឡើងមកអំពីស្ទឹងគង្គា ហើយចូលមករកឥសីប្អូន លុះចូលមកដល់ហើយ ក៏ស្ថិតនៅក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ ឥសីប្អូន

ក៏បានពោលពាក្យនេះនឹងមណិកណ្ឋនាគរាជ ដែលស្ថិតនៅក្នុងទីដ៏សមគួរ ហើយថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកឲ្យកែវមណីដល់អាត្មាៗ ត្រូវការដោយកែវមណី ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មណិកណ្ឋនាគរាជគិតថា ភិក្ខុនេះតែសូមកែវមណី ភិក្ខុត្រូវការដោយកែវមណី គិតដូច្នេះហើយក៏វិលទៅវិញយ៉ាងឆាប់ ។ ម្នាលភិក្ខុទាំងឡាយ គ្រាទី ២ មណិកណ្ឋនាគរាជឡើងមកអំពីស្ទឹងគង្គា ហើយចូលមករកឥសីប្អូន ។ ម្នាលភិក្ខុទាំងឡាយ ឥសីប្អូនបានឃើញមណិកណ្ឋនាគរាជមកអំពីចម្ងាយ លុះឃើញហើយក៏ពោលពាក្យសូមកែវមណីនឹងមណិកណ្ឋនាគរាជថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកឲ្យកែវមណីដល់អាត្មាៗ ត្រូវការដោយកែវមណី ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មណិកណ្ឋនាគរាជក៏រំពឹងថា ភិក្ខុនេះតែសូមកែវមណី ភិក្ខុត្រូវការដោយកែវមណី ហើយត្រឡប់អំពីទីនោះបាត់ទៅ ។ ម្នាលភិក្ខុទាំងឡាយ គ្រាទី ៣ មណិកណ្ឋនាគរាជក៏ឡើងមកអំពីស្ទឹងគង្គា ។ ម្នាលភិក្ខុទាំងឡាយ ឥសីប្អូនបានឃើញមណិកណ្ឋនាគរាជឡើងមកអំពីស្ទឹងគង្គា លុះឃើញហើយក៏ពោលពាក្យសូមកែវមណីនឹងមណិកណ្ឋនាគរាជថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកឲ្យកែវមណីដល់អាត្មាៗ ត្រូវការដោយកែវមណី ។ ម្នាលភិក្ខុទាំង-ឡាយ គ្រានោះឯង មណិកណ្ឋនាគរាជពោលនឹងឥសីប្អូនដោយគាថាទាំង-ឡាយថា

បាយ និងទឹកដ៏ផ្អិតផ្អង់ជាច្រើន តែងកើតឡើងដល់ខ្ញុំ ព្រោះ
អាស្រ័យកែវមណីនេះ ខ្ញុំនឹងឲ្យកែវមណីនេះ ដល់លោកមិន

បានទេ លោកជាអ្នកសូរសូមហួសពេក ខ្ញុំនឹងលែងមកកាន់ អាស្រមរបស់លោកទៀតហើយ ។ មនុស្សកំលោះដែលមាន ដាវសំលៀងដោយថ្មខ្មៅយ៉ាងមុតក្នុងដៃ នឹងគប្បីធ្វើនរណាៗ ឲ្យស្ញុតខ្លាចបាន ដូចម្តេចមិញ លោកសូមកែវមណីនឹងខ្ញុំ ធ្វើ ខ្ញុំឲ្យស្ញុតខ្លាចក៏ដូច្នោះដែរ ខ្ញុំនឹងឲ្យកែវមណីនោះ ដល់លោក មិនបានទេ លោកជាអ្នកសូរសូមហួសពេក ខ្ញុំនឹងលែងមក កាន់អាស្រមរបស់លោកទៀតហើយ ។

ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មណិកណ្ឋនាគរាជក៏រំពឹងថា ភិក្ខុចេះ តែសូមកែវមណី ភិក្ខុត្រូវការដោយកែវមណី ហើយចៀសចេញទៅ ។ មណិកណ្ឋនាគរាជកាលដែលចៀសចេញទៅដូច្នោះហើយ ក៏លែងត្រឡប់មក វិញទៀត ម្នាលភិក្ខុទាំងឡាយ លុះកាលតមក ឥសីប្អូនព្រោះមិនបានឃើញ នាគដែលគួរឃើញនោះ ក៏រីងរៃតែស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពេគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ។ ម្នាលភិក្ខុទាំង-ឡាយ ឥសីបងបានឃើញឥសីប្អូនរីងរៃតែស្គាំងស្គមសៅហ្មង មានសម្បុរ អាក្រក់ កើតជាពេគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ លុះឃើញ ហើយ បានសួរឥសីប្អូនថា ម្នាលអ្នកដ៏ចម្រើន ហេតុអ្វីបានជាអ្នករីងរៃតែ ស្គាំងស្គមសៅហ្មង មានសម្បុរអាក្រក់ កើតជាពេគលឿងស្លេកស្លាំង មាន ខ្លួនរវាមដោយសរសៃ ។ ឥសីប្អូនឆ្លើយថា បពិត្រលោកបងដ៏ចម្រើន ព្រោះ មិនបានឃើញនាគនោះដែលគួរឃើញ បានជាខ្ញុំរីងរៃតែស្គាំងស្គមសៅហ្មង

មានសម្បុរអាក្រក់ កើតជារោគល្មើងស្មុកស្មាំង មានខ្លួនរវាមដោយសរសៃ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ឥសីបង់បានពោលគាថានឹងឥសីប្អូនថា

បុគ្គលដឹងថា របស់ណាជាទីស្រឡាញ់របស់គេ មិនគួរសូម
របស់នោះអំពីគេ បុគ្គលជាទីស្អប់ខ្ពើមរបស់គេ ក៏ព្រោះសូម
ហួសពេក នាគដែលព្រាហ្មណ៍សូមកែវមណីហើយ លែង
ត្រឡប់មកកាន់ទីនោះឲ្យឃើញទៀត ។

ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាងពួកសត្វតិរច្ឆានទាំងនោះ ក៏មិនពេញចិត្តនឹងការសូម មិនពេញចិត្តនឹងការរែអង្គាស នឹងបាច់ពោលថ្វីដល់មនុស្ស ។

[ ១៩៨ ] ( រឿងទី ២ ថា ) ម្នាលភិក្ខុទាំងឡាយ រឿងដែលមានអំពីអតីតកាលថា មានភិក្ខុមួយរូប សម្រេចឥរិយាបថនៅក្នុងដងព្រៃមួយ នាខាងភ្នំហិមវន្ត ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទីជិតដងព្រៃនោះឯង មានបឹងមួយជាទំនាបធំ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង មានហ្វូងសត្វស្លាបជាច្រើន វេលាថ្ងៃត្រាច់រកអាហារក្នុងបឹងដែលនៅជិតដងព្រៃនោះ ដល់វេលាល្ងាច នាំគ្នាមកអាស្រ័យនៅនាដងព្រៃនោះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ភិក្ខុនោះធុញទ្រាន់អផ្សុកដោយសំឡេងនៃហ្វូងសត្វស្លាបនោះ ក៏ចូលមករកតថាគត លុះចូលមកដល់ហើយថ្វាយបង្គំតថាគតហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះដល់ភិក្ខុនោះអង្គុយស្ងប់ហើយ តថាគតបានពោលពាក្យនេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ ខ្លួនបញ្ចកដែលមានចក្ក ៤ មានទ្វារ ៩ អ្នកល្មមអត់ធន់បានទេឬ ខ្លួនបញ្ចកដែលមានចក្ក ៤ មានទ្វារ ៩

អ្នកល្មមឲ្យប្រព្រឹត្តទៅបានទេឬ អ្នកជាបុគ្គលមកកាន់ផ្លូវឆ្ងាយ ដោយឥតមានលំបាកទេឬ ម្នាលភិក្ខុ ចុះអ្នកមកអំពីទីណា ។ ភិក្ខុនោះពោលថា បពិត្រព្រះដ៏មានព្រះភាគ ខន្ធបញ្ចកដែលមានចក្ក ៤ មានទ្វារ ៩ ខ្ញុំព្រះអង្គល្មមអត់ធន់បាន បពិត្រព្រះដ៏មានព្រះភាគ ខន្ធបញ្ចកដែលមានចក្ក ៤ មានទ្វារ ៩ ខ្ញុំព្រះអង្គល្មមឲ្យប្រព្រឹត្តទៅបាន បពិត្រព្រះអង្គដ៏ចម្រើន មួយសោត ខ្ញុំព្រះអង្គជាបុគ្គលមកកាន់ផ្លូវឆ្ងាយ ដោយឥតមានលំបាកឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខាងក្នុំហិមវន្តមានជង្ហព្រៃមួយធំ បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងទីជិតនៃជង្ហព្រៃនោះ មានបឹងជាទំនាបធំ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ មានហ្វូងសត្វស្លាបច្រើន វេលាថ្ងៃត្រាច់រកអាហារនៅបឹងនោះ លុះដល់វេលាល្ងាច នាំគ្នាមកអាស្រ័យនៅនាជង្ហព្រៃនោះ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានជាមកអំពីទីនោះ ព្រោះអផ្សុកនឹងសំឡេងនៃហ្វូងសត្វស្លាបនោះ ។ តថាគតបានសួរថា ម្នាលភិក្ខុ ចុះអ្នកចង់មិនឲ្យហ្វូងសត្វស្លាបនោះមកទេឬ ។ ភិក្ខុនោះពោលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនចង់ឲ្យហ្វូងសត្វស្លាបនោះមកទេ ។ ទើបតថាគតពោលថា ម្នាលភិក្ខុ បើដូច្នោះ អ្នកឯងទៅដល់ទីនោះហើយៗ ចូលទៅកាន់ជង្ហព្រៃនោះ ហើយប្រកាសនូវសំឡេង ៣ ដង អស់បឋមយាមនៃរាត្រីថា នៃសត្វស្លាបដ៏ចម្រើនទាំងឡាយ បណ្ដាសត្វស្លាបដែលអាស្រ័យនៅក្នុងជង្ហព្រៃនេះទាំងអម្បាលម៉ាន ចូរស្ដាប់យើងៗ ត្រូវការដោយស្លាបរបស់សត្វស្លាបទាំងឡាយ អ្នករាល់គ្នាចូរឲ្យស្លាបមួយៗ ម្នាក់ដល់យើង ( តពីនោះមក ) ចូរប្រកាសនូវសំឡេង ៣ ដង អស់មជ្ឈិមយាម

នៃរាត្រីថា ។បេ។ រួចចូរប្រកាសនូវសំឡេង ៣ ដង អស់បច្ឆិមយាមនៃរាត្រីថា នែសត្វស្វាបដ៏ចម្រើនទាំងឡាយ បណ្តាសត្វស្វាបដែលអាស្រ័យនៅក្នុងជង់ព្រៃនេះទាំងអម្បាលម៉ាន ចូរស្តាប់យើងៗ ត្រូវការដោយស្វាបរបស់សត្វបក្សីទាំងឡាយ ម្នាលសត្វបក្សីដ៏ចម្រើនទាំងឡាយ អ្នករាល់គ្នាចូរឲ្យស្វាបមួយម្នាក់ៗ ដល់យើង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ភិក្ខុនោះក៏ទៅក្នុងទីនោះ ហើយទើបចូលទៅកាន់ជង់ព្រៃនោះ ហើយប្រកាសនូវសំឡេងបីដង អស់បឋមយាមនៃរាត្រីថា នែសត្វបក្សីដ៏ចម្រើនទាំងឡាយ បណ្តាសត្វបក្សីដែលអាស្រ័យនៅក្នុងជង់ព្រៃនេះទាំងអម្បាលម៉ាន ចូរស្តាប់យើងៗ ត្រូវការដោយស្វាបរបស់សត្វបក្សីទាំងឡាយ ម្នាលសត្វបក្សីដ៏ចម្រើនទាំង-ឡាយ អ្នករាល់គ្នាចូរឲ្យស្វាបមួយៗ ម្នាក់ដល់យើង ( តពីនោះមក ) ក៏ប្រកាសនូវសំឡេង ៣ ដង អស់មជ្ឈិមយាមនៃរាត្រី ។បេ។ រួចបានប្រកាសនូវសំឡេង ៣ ដង អស់បច្ឆិមយាមនៃរាត្រីថា នែសត្វបក្សីដ៏ចម្រើនទាំង-ឡាយ បណ្តាសត្វបក្សីដែលអាស្រ័យនៅ ក្នុងជង់ព្រៃនេះទាំងអម្បាលម៉ាន ចូរស្តាប់យើងៗ ត្រូវការដោយស្វាបរបស់សត្វបក្សីទាំងឡាយ ម្នាលសត្វបក្សីដ៏ចម្រើនទាំងឡាយ អ្នករាល់គ្នាចូរឲ្យស្វាបមួយៗ ម្នាក់ដល់យើង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ហ្វូងសត្វបក្សីក៏គិតគ្នាថា ភិក្ខុបេះតែសូមស្វាប ភិក្ខុត្រូវការដោយស្វាប ( លុះគិតហើយ ) ក៏ចៀសចេញទៅចាកជង់ព្រៃនោះ កាលដែលហ្វូងសត្វបក្សីចៀសចេញទៅ ដូច្នេះហើយ ក៏លែងត្រឡប់មកទៀត ។ ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាងសត្វតិរច្ឆានទាំងឡាយនោះ

ម្តេចគង់មិនពេញចិត្តនឹងការសូម មិនពេញចិត្តនឹងការរែអង្គាស ចំណង់បើមនុស្សទាំងឡាយនឹងបាច់និយាយទៅថ្វី ។

[ ១៩៩ ] ម្នាលភិក្ខុទាំងឡាយ មានរឿងពីដើមមកថា បិតារបស់កុលបុត្រឈ្មោះរដ្ឋបាល បានពោលគាថានឹងរដ្ឋបាលកុលបុត្រថា

ម្នាលរដ្ឋបាល ជនទាំងឡាយណាច្រើននាក់ រមែងមកបោម
សូមអ្វីៗ នឹងញោម តែញោមមិនស្គាល់ជនទាំងនោះឡើយ
ហេតុអ្វី បានជាអ្នកមិនសូមអ្វីនឹងញោមខ្លះ ។

រដ្ឋបាលកុលបុត្រក៏និយាយថា

អ្នកសូរសូម រមែងមិនជាទីស្រឡាញ់របស់អ្នកឲ្យ អ្នកមិនឲ្យ
របស់ដែលគេសូម ក៏មិនជាទីស្រឡាញ់របស់អ្នកសូម ព្រោះ
ហេតុនោះ ទើបខ្ញុំមិនសូមអ្វីៗ នឹងអ្នក ដោយគិតថា មិនឲ្យ
ជាទីស្អប់ខ្ពើមដល់ខ្ញុំ ។

ម្នាលភិក្ខុទាំងឡាយ អម្បាលយ៉ាងរដ្ឋបាលកុលបុត្រនោះ ម្តេចគង់បានពោលយ៉ាងនេះនឹងបិតារបស់ខ្លួន នឹងបាច់ពោលទៅថ្វីដល់ជននិងជន ( នឹងខានស្តីថាឲ្យគ្នាឯណាបាន ) ។

[ ២០០ ] ម្នាលភិក្ខុទាំងឡាយ ក៏ភោគៈទាំងឡាយ ដែលពួកគ្រហស្ថសន្សំរកបានដោយកម្រ សូម្បីរកបានមកហើយ ក៏កម្រនឹងថែរក្សាទុកឲ្យគង់បាន ម្នាលមោឃបុរសទាំងឡាយ កាលបើភោគៈទាំងឡាយ ដែលពួកគ្រហស្ថសន្សំរកបានដោយកម្រ សូម្បីរកបានមកហើយក៏កម្រនឹងថែរក្សាយ៉ាងនេះ

អ្នកទាំងឡាយប្រព្រឹត្តតែសូមហួសពេក រែអង្គាសហួសពេក ចំពោះភោគៈទាំងនោះថា អ្នកទាំងឡាយសូមឲ្យបុរស ឲ្យគ្រឿងហត្ថកម្មនៃបុរស ឲ្យគោឲ្យរទេះ ឲ្យកាំបិត ឲ្យពូថៅ ឲ្យដឹង ឲ្យចប ឲ្យពន្លាក ឲ្យវល្លិ៍ ឲ្យឫស្សី ឲ្យស្មៅយាប្លង ឲ្យស្មៅជំណោកទន្សាយ ឲ្យស្មៅ ( ធម្មតា ) ឲ្យដីស្អិត ។ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងអស់គ្នាធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយ ដែលមិនទាន់បានជ្រះថ្លា ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កាលភិក្ខុឲ្យគេធ្វើកុដិដែលមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណកុដិនោះ គឺបណ្តោយ ១២ ចំអាម ទទឹង ៧ ចំអាម ដោយចំអាមព្រះសុគតវាស់ខាងក្នុង ត្រូវនាំពួកភិក្ខុមកដើម្បីសម្តែងទីឲ្យ ភិក្ខុទាំងនោះគប្បីសម្តែងទីដែលមិនមានអន្តរាយ និងមានឧបចារៈ បើភិក្ខុឲ្យគេធ្វើកុដិដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ក្នុងទីដែលមានអន្តរាយ និងមិនមានឧបចារៈក្តី មិនបាននាំពួកភិក្ខុមកដើម្បីសម្តែងទីឲ្យក្តី ធ្វើឲ្យកន្លងហួសប្រមាណក្តី ត្រូវអាបត្តិសង្ឃាទិសេស ។

[ ២០១ ] ភិក្ខុបានសូមបុរសក្តី គ្រឿងហត្ថកម្មនៃបុរសក្តី គោក្តី រទេះក្តី កាំបិតក្តី ពូថៅក្តី ដឹងក្តី ចបក្តី ពន្លាកក្តី ។បេ។ ស្មៅក្តី ដីស្អិតក្តី ដោយខ្លួនឯង ឈ្មោះថា សូមគ្រឿងឧបករណ៍គេមកខ្លួនឯង ។ ដែលឈ្មោះថា កុដិនោះ គឺកុដិដែលលាបខាងក្នុង ឬកុដិដែលលាបខាងក្រៅ ឬកុដិដែល

លាបទាំងខាងក្នុង ទាំងខាងក្រៅ ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ។ ត្រង់ពាក្យថា មិនមានទាយកជាម្ចាស់របស់ សេចក្តីថា មិនមានអ្នកដទៃណាមួយ ទោះស្រីក្តី ប្រុសក្តី គ្រហស្ថក្តី បព្វជិតក្តីជាម្ចាស់របស់ ។ ត្រង់ពាក្យថា ចំពោះជាទីនៅនៃខ្លួន គឺដើម្បីជាប្រយោជន៍ដល់ខ្លួន ។ ត្រង់ពាក្យថា គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណកុដិនោះ គឺបណ្តោយ ១២ ចំអាមដោយចំអាមព្រះសុគត គឺវាស់តាមទីដែលជាខាងក្រៅកុដិ ។ ត្រង់ពាក្យថា ទទឹង ៧ ចំអាមវាស់ខាងក្នុង គឺវាស់តាមទីដែលជាខាងក្នុងកុដិ ។

[ ២០២ ] ត្រង់ពាក្យថា ត្រូវនាំពួកភិក្ខុមកដើម្បីសម្តែងទីឲ្យ សេចក្តីថា រូបភិក្ខុអ្នកធ្វើកុដិនោះ ត្រូវជម្រះទីកុដិ រួចចូលទៅរកសង្ឃ ហើយធ្វើចីវរឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោងប្រណម្យអញ្ជលី ពោលពាក្យយ៉ាងនេះថា បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំករុណាចង់ធ្វើកុដិមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង បពិត្រលោកដ៏ចម្រើនទាំងឡាយ ខ្ញុំករុណាឯងសូមឲ្យសង្ឃពិនិត្យមើលទីធ្វើកុដិឲ្យទាន ។ ភិក្ខុអ្នកធ្វើកុដិនោះ គប្បីសូមជាគម្រប់ពីរដងផង គប្បីសូមជាគម្រប់បីដងផង ។ បើសង្ឃទាំងអស់អាចដើម្បីពិនិត្យមើលទីធ្វើកុដិបាន សង្ឃទាំងអស់គប្បីពិនិត្យមើល ។ បើសង្ឃទាំងអស់មិនអាចពិនិត្យមើលទីធ្វើកុដិបានទេ ភិក្ខុទាំងឡាយឯណាមាន នៅក្នុងទីនោះ ជាអ្នកឆ្លាសអាចនឹងដឹងនូវទីដែលមានហេតុទាស់ និងទី

ដែលមិនមានហេតុទាស់ និងទីដែលមានឧបចារៈ និងមិនមានឧបចារៈ សង្ឃគប្បីអាពាធនា ហើយសម្មតិភិក្ខុទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសម្មតិភិក្ខុទាំងនោះយ៉ាងនេះ គឺភិក្ខុដែលឆ្លាសប្រតិពល ត្រូវញ៉ាំងសង្ឃឲ្យដឹង ( ដោយញត្តិទុតិយកម្មវាចា ) ថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃ ស្តាប់ខ្ញុំភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិដែលឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុនោះសូមការពិនិត្យមើលទីធ្វើកុដិនឹងសង្ឃ ។ បើការពិនិត្យមើលទីធ្វើកុដិមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសម្មតិភិក្ខុទាំងឡាយឈ្មោះនេះផងៗ ដើម្បីឲ្យពិនិត្យមើលនូវទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ ។ នេះជាវាចាសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិដែលឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុនេះសូមការពិនិត្យមើលទីធ្វើកុដិនឹងសង្ឃ ។ សង្ឃសម្មតិភិក្ខុទាំងឡាយ មានឈ្មោះនេះផងៗ ដើម្បីឲ្យពិនិត្យមើលទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ ។ ការសម្មតិភិក្ខុទាំង-ឡាយឈ្មោះនេះផងៗ ដើម្បីឲ្យពិនិត្យមើលទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម ( បើ ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោល ។ ភិក្ខុទាំងឡាយឈ្មោះនេះផងៗ សង្ឃបានសម្មតិដើម្បីឲ្យពិនិត្យ មើលទីធ្វើកុដិរបស់ភិក្ខុឈ្មោះនេះ ។ កិរិយាសម្មតិនេះសមគួរដល់សង្ឃ ព្រោះហេតុនោះ

សង្ឃទើបស្មៀម ។ ខ្ញុំករុណាសូមចាំទុកនូវសេចក្តីនេះដោយ កិរិយាស្មៀម យ៉ាងនេះ ។

[ ២០៣ ] ពួកភិក្ខុដែលសង្ឃបានសម្មតិហើយទាំងនោះ ត្រូវទៅក្នុងទីនោះហើយ ពិនិត្យមើលទីធ្វើកុដិ រូបត្រូវដឹងថាជាទីមានហេតុទាស់ ទីឥតមានហេតុទាស់ ទីមានឧបចារៈ ទីឥតមានឧបចារៈ ។ បើទីមានហេតុទាស់ ទីមិនមានឧបចារៈ គប្បីប្រាប់ថា លោកកុំធ្វើក្នុងទីនេះឡើយ ។ បើទីឥតមានហេតុទាស់ ទីមានឧបចារៈ គប្បីប្រាប់សង្ឃថា ទីនេះ ឥតមានហេតុទាស់ មានឧបចារៈ ។ ភិក្ខុអ្នកធ្វើកុដិនោះ ត្រូវចូលទៅរកសង្ឃ ហើយធ្វើចីវរឆៀងស្មាម្ខាង ថ្វាយបង្គំបាទាភិក្ខុចាស់ទាំងឡាយ ហើយអង្គុយច្រហោង ប្រណម្យអញ្ជលីពោលពាក្យយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំករុណាចង់ធ្វើកុដិមិនមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំករុណាសូមសម្តែងទីធ្វើកុដិនឹងសង្ឃ ។ ភិក្ខុអ្នកធ្វើកុដិនោះ គប្បីសូមជាគម្រប់ពីរដងផង គប្បីសូមជាគម្រប់បីដងផង ។ ភិក្ខុអ្នកឆ្លាសប្រតិពល គប្បីញ៉ាំងសង្ឃឲ្យដឹង ( ដោយញត្តិទុតិយកម្មវាចា ) ថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុនោះសូមការសម្តែងទីធ្វើកុដិនឹងសង្ឃ ។ បើការសម្តែងទីធ្វើកុដិ មានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសម្តែងទីធ្វើកុដិដើម្បីភិក្ខុឈ្មោះនេះ។

នេះជាញត្តិ ( វាចាប្រកាសឲ្យសង្ឃដឹង ) ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុរូបនេះ ឈ្មោះនេះ ចង់ធ្វើកុដិឥតមានទាយកជាម្ចាស់របស់ ចំពោះជាទីនៅនៃខ្លួន ដោយការសូមគ្រឿងឧបករណ៍គេមកខ្លួនឯង ភិក្ខុរូបនោះ សូមការសម្តែងទីធ្វើកុដិនឹងសង្ឃ សង្ឃសម្តែងទីធ្វើកុដិដើម្បីភិក្ខុឈ្មោះនេះ ។ ការសម្តែងទីធ្វើកុដិដើម្បីភិក្ខុឈ្មោះនេះ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម ( បើ ) មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោល ។ សង្ឃបានសម្តែងទីធ្វើកុដិដើម្បីភិក្ខុឈ្មោះនេះហើយ ការនេះសមគួរដល់សង្ឃ ព្រោះហេតុនោះ សង្ឃទើបស្ងៀម ខ្ញុំករុណា សូមចាំទុកសេចក្តីនេះ ដោយកិរិយាស្ងៀមយ៉ាងនេះ ។

[ ២០៤ ] ដែលហៅថា ទីមានហេតុទាស់នោះ គឺបានដឹងកន្លែងជាទីអាស្រ័យនៅនៃពួកសត្វស្រមោចក្រហមក្តី ជាទីអាស្រ័យនៅនៃពួកសត្វកណ្តៀរក្តី ជាទីអាស្រ័យនៅពួកសត្វកណ្តុរក្តី ជាទីអាស្រ័យនៅនៃសត្វពស់ក្តី ជាទីអាស្រ័យនៅនៃពួកសត្វខ្ទួយក្តី ជាទីអាស្រ័យនៅនៃពួកសត្វខ្លែបក្តី ជាទីអាស្រ័យនៅនៃពួកដំរីក្តី ជាទីអាស្រ័យនៅនៃពួកសេះក្តី ជាទីអាស្រ័យនៅនៃពួកសីហៈក្តី ជាទីអាស្រ័យនៅនៃពួកខ្លាធំក្តី ជាទីអាស្រ័យនៅនៃពួកខ្លាដំបងក្តី ជាទីអាស្រ័យនៅនៃពួកខ្លាឃ្មុំក្តី ជាទីអាស្រ័យនៅនៃពួកខ្លារខិនក្តី ជាទីអាស្រ័យនៅនៃពួកសត្វតិរច្ឆានណាមួយក្តី ជាទីតាំងនៅនៃបុព្វណ្ណ[១]ជាតិ

---

១- វត្ថុសម្រាប់បរិភោគមុន បានដល់ ស្រូវ ៧ យ៉ាង មានស្រូវ-ស ស្រូវក្រហមជាដើម ។

ក្តី ជាទីតាំងនៅនៃអបរណ្ណ[១]ជាតិក្តី ជាទីដែលគេសម្ងាប់ចោរក្តី ជាទីសម្រាប់ផ្ចាលទោស[២]ក្តី ជាទីព្រៃស្មសានក្តី ជាទីឱទ្យានក្តី ជាទីស្រែចម្ការស្តេចក្តី ជាទីដែលគេសង់រោងដំរីក្តី ជាទីដែលគេសង់រោងសេះក្តី ជាទីដែលគេធ្វើគុកក្តី ជាទីដែលគេធ្វើរោងសុរាក្តី ជាទីអាស្រ័យនៅនៃផ្ទះលក់សាច់ក្តី ជាទីច្រកក្តី ជាទីវាលសម្រាប់លេងក្តី ជាទីរោងប្រជុំក្តី ជាកន្ទ្រែងផ្លូវទៅមកក្តី ទីប៉ុណ្ណោះហៅថា ទីមានហេតុទាស់ គឺទីមានសេចក្តីអន្តរាយ ។

[ ២០៥ ] ដែលហៅថាទីមានឧបចារៈនោះ គឺបានដឹងទីដែលមិនអាចបង្វិលរទេះ បង្វិលបង្អោនជុំវិញដោយស្រួលបាន ទីប៉ុណ្ណោះហៅថា ទីមិនមានឧបចារៈ ។

[ ២០៦ ] ដែលហៅថា ទីមិនមានអន្តរាយនោះ គឺបានដឹងទីដែលមិនមែនជាទីអាស្រ័យនៅនៃពួកសត្វស្រមោចក្រហមក្តី មិនមែនជាទីអាស្រ័យនៅនៃពួកសត្វកណ្តៀរក្តី មិនមែនជាទីអាស្រ័យនៅនៃពួកសត្វកណ្តុរក្តី មិនមែនជាទីអាស្រ័យនៅនៃពួកពស់ក្តី មិនមែនជាទីអាស្រ័យនៅនៃពួកខ្ទួយក្តី មិនមែនជាទីអាស្រ័យនៅនៃពួកក្អែបក្តី ។បេ។ មិនមែនជាកន្ទ្រែងផ្លូវទៅមកក្តី ទីប៉ុណ្ណោះ ហៅថា ទីមិនមានអន្តរាយ ។

[ ២០៧ ] ដែលហៅថា ទីមានឧបចារៈនោះ គឺបានដឹងទីដែលអាចបង្វិលរទេះ បង្វិលបង្អោនដោយជុំវិញតាមស្រួលបាន ទីប៉ុណ្ណោះ ហៅថា ទីមាន

---

១- វត្ថុសម្រាប់បរិភោគខាងក្រោយ បានដល់ ល្ង សណ្តែក ចេក អំពៅជាដើម ។

២- ទីសម្រាប់ផ្ចាលទោស គឺទីដែលគេសម្រាប់វាយមនុស្សផ្ចាល ។

ឧបចារៈ ។

[ ២០៨ ] ភិក្ខុសូមបុរសក្តី គ្រឿងហត្ថកម្មនៃបុរសក្តី ។បេ។ ពន្ទាកក្តី ដោយខ្លួនឯង ហៅថា សូមគ្រឿងឧបករណ៍គេមកខ្លួនឯង ។ លំនៅរបស់ភិក្ខុដែលលាបខាងក្នុង ឬលាបខាងក្រៅ ឬដែលលាបទាំងខាងក្នុង ទាំងខាងក្រៅ ហៅថា កុដិ ។ ត្រង់ពាក្យថា ឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ។ ត្រង់ពាក្យថា មិនបាននាំពួកភិក្ខុមក ដើម្បីសម្តែងទីឲ្យក្តី ធ្វើឲ្យកន្លងហួសប្រមាណក្តី សេចក្តីថា មិនបានឲ្យសង្ឃសម្តែងទីធ្វើកុដិដោយបណ្តោយក្តី ដោយទទឹងក្តី ដោយញត្តិទុតិយកម្ម ហើយធ្វើខ្លួនឯងក្តី ប្រើគេឲ្យធ្វើក្តី ឲ្យកន្លងហួសប្រមាណ សូម្បីប្រមាណប៉ុនចុងសក់ ត្រូវអាបត្តិទុក្កដរាល់ប្រយោគ កាលនៅតែបូក ១ ដុំទឹងហើយ ត្រូវអាបត្តិថុល្លច្ច័យ កាលបើបូក ១ ដុំនោះហើយស្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ត្រង់ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយពិស្តារក្នុងសង្ឃាទិសេសសិក្ខាបទទី ១ រួចហើយ ។

[ ២០៩ ] ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ គឺទីមានអន្តរាយ មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ តែមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មិនមានហេតុទាស់ មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មិនមានហេតុទាស់ តែមានឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិ

ដែលមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ តែមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ មិនមានហេតុទាស់ មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ មិនមានហេតុទាស់ តែមានឧបចារៈ ជាអនាបត្តិ ( មិនត្រូវអាបត្តិឡើយ ) ។

[ ២១០ ] ភិក្ខុធ្វើកុដិហួសប្រមាណ មានហេតុទាស់ មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិហួសប្រមាណ មានហេតុទាស់ តែមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិហួសប្រមាណ មិនមានហេតុទាស់ និងមិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិហួសប្រមាណ តែមិនមានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិត្រូវប្រមាណ តែមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។ ភិក្ខុធ្វើកុដិត្រូវប្រមាណ តែមានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើកុដិប្រកបដោយប្រមាណ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើកុដិប្រកបដោយប្រមាណ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។

[ ២១១ ] ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិ-

សេសពីរ ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ ឥតមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ ។ ភិក្ខុធ្វើកុដិដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ តែឥតមានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេសពីរ ។

[ ២១២ ] ភិក្ខុធ្វើកុដិ ដែលមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ ឥតមានហេតុទាស់ តែមិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។

[ ២១៣ ] ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។បេ។ មានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។ បេ ។ ឥតមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ ឥតមានហេតុ

ទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ ឥតមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយ ក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ មិនមានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលប្រកបដោយប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមិនមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ មិន

មានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដមួយ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ មិនមានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេសពីរ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។

[ ២១៤ ] ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានបង្គាប់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង មិនមានហេតុទាស់ផង មានទីឧបចារៈផងដូច្នេះឡើយ ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារៈ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ មិនមានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ ( ពួក

ភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផងដូច្នេះឡើយ ។ ភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារៈ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះត្រូវប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផងដូច្នេះឡើយ ។ ភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ ឥតមានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផងដូច្នេះឡើយ ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលប្រកបដោយប្រមាណ មាន

ហេតុទាស់ មិនមានទីឧបចារៈ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរ ធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផងដូច្នេះឡើយ ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលមិនមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ មិនមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ មិនមានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេសពីរ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែមិនបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង មិនមានហេតុទាស់ផង មានទីឧបចារៈផងដូច្នេះឡើយ ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ មិនមានទីឧបចារៈ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។

មិនមានហេតុទាស់ មិនមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានហេតុទាស់ មានទីឧបចារៈ មិនត្រូវអាបត្តិឡើយ ។

[ ២១៥ ] ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដែលមិនមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ មិនមានទីឧបចារៈដើម្បីអាត្មាអញ ។ ភិក្ខុនោះគប្បីទៅខ្លួនឯងក្តី ប្រើបម្រើទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ តែមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ តែមានទីឧបចារៈ ។ ភិក្ខុនោះគប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង ។ បើភិក្ខុនោះមិនទៅខ្លួនឯង

ក្តី មិនប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញដែលឥតមានពួកភិក្ខុសម្តែងទីឲ្យ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះគប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះ គួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង មានទីឧបចារៈផង ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះ គួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះដែលមិនមានពួកភិក្ខុសម្តែងទីឲ្យ ឥតមានហេតុទាស់ មានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញដែលមិនមានពួកភិក្ខុសម្តែងទីឲ្យ ឥតមានហេតុទាស់ មានទីឧបចារៈ ។ ភិក្ខុនោះគប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តីដោយពាក្យថា កុដិនោះ គួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបាន

ពន្យល់ដោយ ពាក្យថា កុដិនោះ គួរជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសម្តែងទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ដែលមានពួកភិក្ខុសម្តែងទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះគប្បីទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសម្តែងទីឲ្យ តែមានហេតុទាស់ មានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្លួនអញ ដែលមានពួកភិក្ខុសម្តែងទីឲ្យ តែមានហេតុទាស់ មានទីឧបចារៈ ។ ភិក្ខុនោះត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិឥតមានហេតុទាស់ ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះ គួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះ ដែលមានពួកភិក្ខុសម្តែងទីឲ្យ ឥតមានហេតុ

ទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្ញុំអញ មានពួកភិក្ខុសម្តែងទីឲ្យ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ។ ភិក្ខុនោះត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិមានទីឧបចារៈ ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិ ដើម្បីភិក្ខុនោះដែលមានពួកភិក្ខុសម្តែងទីឲ្យ ឥតមានហេតុទាស់ មានទីឧបចារៈ មិនត្រូវអាបត្តិឡើយ ។

[ ២១៦ ] ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះ គួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង។ ពួកភិក្ខុក៏ធ្វើកុដិដើម្បីភិក្ខុនោះធំហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិដើម្បីខ្ញុំអញ ធំហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ ។ ភិក្ខុនោះត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។បេ។ គួរប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង ។បេ។ គួរប្រកបដោយប្រមាណផង គួរមានទីឧបចារៈផង ។បេ។ គួរប្រកបដោយប្រមាណ ។ បើភិក្ខុនោះមិនបានទៅខ្លួនឯងក្តី មិនបានប្រើបម្រើ

ឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំង-ឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិឲ្យអាត្មាអញ ប្រកបដោយប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះ ត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះ គួរជាកុដិឥតមានហេតុទាស់ផង មានទីឧបចារៈផង ។បេ។ គួរជាកុដិឥតមានហេតុទាស់ ។បេ។ មានទីឧបចារៈ ។បេ។ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ប៉ុន្តែបានពន្យល់ដោយពាក្យថា កុដិនោះគួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិឥតមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិឲ្យអាត្មាអញ ជាកុដិឥតមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះត្រូវទៅខ្លួនឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះ គួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។បេ។ គួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង ។បេ។ គួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង

ប្រកបដោយប្រមាណផង មានទីឧបចារៈផង ។បេ។ គួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ។ បើភិក្ខុនោះមិនបានទៅខ្ទង់ឯងក្តី មិនបានប្រើបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រូបចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះ គួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា ពួកភិក្ខុធ្វើកុដិឲ្យអាត្មាអញ ជាកុដិដែលមានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារៈ ។ ភិក្ខុនោះត្រូវទៅខ្ទង់ឯងក្តី ប្រើបម្រើឲ្យទៅក្តី ដោយពាក្យថា កុដិនោះគួរជាកុដិឥតមានហេតុទាស់ផង មានទីឧបចារៈផង ។បេ។ ឥតមានហេតុទាស់ ។បេ។ មានទីឧបចារៈ ។បេ។ ជាអនាបត្តិ ។

[ ២១៧ ] ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ រូបចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដបី ។បេ។ មានហេតុទាស់ មានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ឥតមានហេតុទាស់

មានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផង គ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ ថា កុដិនោះ គួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ជាកុដិមានពួកភិក្ខុសម្តែង ទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារៈ ភិក្ខុអ្នកធ្វើត្រូវ អាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ មានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផង គ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ ថា កុដិនោះគួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មាន ទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដបី ។បេ។ មានហេតុទាស់ មានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ឥតមានហេតុ ទាស់ មានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ ( ពួក ភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបាន ពន្យល់ថា កុដិនោះគួរជាកុដិប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ប្រកបដោយប្រមាណ តែ មានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។បេ។

មានហេតុទាស់ តែមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ឥតមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដបួន ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដបី ។បេ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដបី ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ប៉ុន្តែបានពន្យល់ថា កុដិនោះគួរជាកុដិមានពួកភិក្ខុសម្តែងទីឲ្យផង ប្រកបដោយប្រមាណផង ឥតមានហេតុទាស់ផង មានទីឧបចារៈផង ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។

[ ២១៨ ] ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថាអ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ រូបចៀសចេញទៅ ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ ឥតមានទីឧបចារៈ ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះ ត្រូវឲ្យកុដិនោះដល់ភិក្ខុដទៃ ឬត្រូវទម្លាយបង់ហើយឲ្យធ្វើជាថ្មីទៀត ។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទម្លាយបង់ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រូបចៀសចេញទៅ ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ឥតមានពួកភិក្ខុសម្តែងទីឲ្យ មានហេតុទាស់ តែមានទីឧបចារៈ ។ កាលបើការដែលធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះត្រូវឲ្យកុដិនោះដល់ភិក្ខុដទៃ ឬត្រូវទម្លាយបង់ហើយឲ្យធ្វើជាថ្មីទៀត ។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទម្លាយបង់ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រូបចៀសចេញទៅ ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មានពួកភិក្ខុសម្តែងទីឲ្យ តែមានហេតុទាស់ ឥតមានទីឧបចារៈ ។ កាលបើការធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះគប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីទម្លាយបង់

ហើយឲ្យធ្វើជាថ្មីទៀត ។ បើភិក្ខុនោះមិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទម្លាយបង់ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ។ កាលបើការធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះ គប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីទម្លាយបង់ហើយឲ្យធ្វើជាថ្មីទៀត ។ បើភិក្ខុនោះ មិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទម្លាយបង់ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេស ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេស ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ... ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ ប្រកបដោយប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ។ កាលបើការធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះ គប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីទម្លាយបង់ ហើយឲ្យធ្វើជាថ្មីទៀត ។ បើភិក្ខុនោះ មិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានទម្លាយបង់

ហើយឲ្យធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ ។បេ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ ហើយចៀសចេញទៅ ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មិនមានពួកភិក្ខុសម្តែងទីឲ្យ ហួសប្រមាណ មានហេតុទាស់ ឥតមានទីឧបចារៈ ។ កាលបើការធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះគប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីឲ្យរុះរើធ្វើជាថ្មីទៀត ។ បើភិក្ខុនោះមិនបានឲ្យ កុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានឲ្យរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ មានហេតុទាស់ តែមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ ។បេ។ ឥតមានហេតុទាស់ តែឥតមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសពីរ ។ ឥតមានហេតុទាស់ មានទីឧបចារៈ ... ត្រូវអាបត្តិសង្ឃាទិសេសពីរ ។ ភិក្ខុបង្គាប់ ( ពួកភិក្ខុផងគ្នា ) ថា អ្នកទាំងឡាយ ចូរធ្វើកុដិឲ្យខ្ញុំ រួចចៀសចេញទៅ ។ ពួកភិក្ខុក៏ធ្វើកុដិឲ្យភិក្ខុនោះ មានពួកភិក្ខុសម្តែងទីឲ្យ ប្រកបដោយប្រមាណ តែមានហេតុទាស់ ឥតមានទីឧបចារៈ ។ កាលបើការធ្វើកុដិមិនទាន់ស្រេច ក៏ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះគប្បីឲ្យកុដិនោះដល់ភិក្ខុដទៃ ឬគប្បីឲ្យរុះរើធ្វើជាថ្មីទៀត ។ បើភិក្ខុនោះ មិនបានឲ្យកុដិនោះដល់ភិក្ខុដទៃទេ ឬមិនបានឲ្យរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ ។បេ។ មានហេតុទាស់ តែ

មានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ ។ ឥតមានហេតុទាស់ ឥតមានទីឧបចារៈ ... ត្រូវអាបត្តិទុក្កដ ។ ឥតមានហេតុទាស់ មានទីឧបចារៈ ជាអនាបត្តិ ។

[ ២១៩ ] ភិក្ខុធ្វើកុដិមិនទាន់ស្រេចដោយខ្លួនឯង ហើយធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើកុដិមិនទាន់ស្រេចដោយខ្លួនឯង ហើយឲ្យភិក្ខុដទៃធ្វើបង្ហើយ ( ភិក្ខុអ្នកប្រើ ) ត្រូវអាបត្តិសង្ឃាទិ-សេស ។ ពួកភិក្ខុដទៃធ្វើកុដិ ( ឲ្យភិក្ខុរូបណា ) មិនទាន់ស្រេច ហើយភិក្ខុ ( រូបនោះ ) ធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស ។ ពួកភិក្ខុដទៃធ្វើកុដិ ( ឲ្យភិក្ខុរូបណា ) មិនទាន់ស្រេច ហើយភិក្ខុ ( រូបនោះ ) ឲ្យពួកភិក្ខុដទៃទៀតធ្វើបង្ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ២២០ ] ដំណើរដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើលេណ ( ទីសម្រាប់ជ្រកល្ហមនៅបាន ) គុហា ( ទីបិទបាំងល្ហមនៅបាន ) កុដិស្មៅ និងកុដិសម្រាប់ភិក្ខុដទៃ ( មានឧបជ្ឈាយ៍ជាដើម ) និងទីសេនាសនៈទាំងពួង ( មានរោងឧបោសថជាដើម ) វៀរលែងតែធ្វើកុដិសម្រាប់នៅរបស់ខ្លួន ( ម្យ៉ាងទៀត ) ដំណើរដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុឆ្កួត និងភិក្ខុដើមបញ្ញត្តិ ។

សង្ឃាទិសេសទី ៦ ចប់

# អដ្ឋកថា
# កុដិការសិក្ខាបទវណ្ណនា

[ ១៩៤ ] កុដិការសិក្ខាបទ ត្រង់បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងកុដិការសិក្ខាបទនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា

បទថា **អាឡវកា** សេចក្តីថា ទារកកើតក្នុងដែនអាឡវី ឈ្មោះ **អាឡវកា** ។ ទារកទាំងនោះ សូម្បីក្នុងវេលាបួសហើយ ក៏ប្រាកដឈ្មោះថា **អាឡវកា** ដូចគ្នា ។ លោកពោលពាក្យថា **អាឡវកា ភិក្ខូ** សំដៅយក ភិក្ខុ អ្នកដែនអាឡវីទាំងនោះ ។

បទថា **សញ្ញាចិកាយោ** បានដល់ មានគ្រឿងឧបករណ៍ដែលខ្លួនសូម គេមកខ្លួនឯង ។ បទថា **ការាបេន្តិ** បានដល់ ធ្វើខ្លួនឯងខ្លះ ឲ្យអ្នកដទៃធ្វើខ្លះ ។ បានឮថា ភិក្ខុទាំងនោះ ដាក់ចោលធុរៈទាំងពីរ គឺវិបស្សនាធុរៈ និង គន្ថធុរៈ លើកនវកម្មប៉ុណ្ណោះឡើងជាធុរៈសំខាន់ ។ បទថា **អស្សាមិកាយោ** បានដល់ មិនមានទាយកជាធំ អធិប្បាយថា វៀរចាកអ្នកសាងប្រគេន ។

បទថា **អត្តុទ្ទេសិកាយោ** បានដល់ ចំពោះខ្លួនឯង អធិប្បាយថា ភិក្ខុ ប្រារព្ធដើម្បីប្រយោជន៍ដល់ខ្លួន ។ បទថា **អប្បមាណិកាយោ** បានដល់ មិន កំណត់មានប្រមាណទុកយ៉ាងនេះថា នឹងដល់នូវការសម្រេចដោយគ្រឿង ឧបករណ៍ មានប្រមាណប៉ុណ្ណេះ ឬពង្រីកទទឹងបណ្តោយមិនមានប្រមាណ អធិប្បាយថា ធំហួសប្រមាណ ។

ភិក្ខុទាំងនេះ មានការសូមច្រើន ការងារដទៃមានតិច ព្រោះហេតុនោះ

ទើបឈ្មោះថា **យាចនពហុលា ។** ពួកភិក្ខុទាំងនោះ ជាអ្នកច្រើនដោយការសូម គប្បីជ្រាបយ៉ាងនេះ ។ តែដោយអត្ថក្នុងពីរបទថា **យាចនពហុលា វិញ្ញត្តិពហុលា** នេះ មិនមានហេតុផ្សេងគ្នាទេ ។ ពាក្យនោះ ជាឈ្មោះរបស់ពួកភិក្ខុដែលសូមច្រើនដងថា អ្នកចូរឲ្យបុរស ចូរឲ្យហត្ថកម្មដែលបុរសត្រូវធ្វើ ។ បណ្ដាបុរស និងហត្ថកម្មនោះ នឹងសូមបុរសដោយការដាច់មូលមិនគួរ ។ បើសូមថា ពួកអ្នកចូរឲ្យបុរសដើម្បីប្រយោជន៍ដល់ការរួមដៃ ដើម្បីប្រយោជន៍ដល់ការធ្វើការងារ គួរ ។ ការងារធ្វើដោយដៃដែលបុរសគប្បីធ្វើ លោកហៅថា ហត្ថកម្ម នឹងសូមហត្ថកម្មនោះ គួរ ។

## វិញ្ញត្តិកថា ពោលអំពីការហាមាត់សូម

ដែលឈ្មោះថា ហត្ថកម្ម មិនមែនជាវត្ថុណាមួយឡើយ ព្រោះហេតុនោះ ហត្ថកម្មនោះ វៀរការងារផ្ទាល់ខ្លួនរបស់ពួកព្រានម្រឹគ និងព្រានប្រមង់ជាដើមចេញ ដ៏សេសជាកប្បិយៈទាំងអស់ ។ កាលគេសួរថា លោកម្ចាស់មកធ្វើអ្វី មានការងារដែលបុគ្គលណានឹងត្រូវធ្វើឬ ឬមិនសួរ ហើយសូមក៏គួរ ។ មិនមានទោស ព្រោះការសូមជាបច្ច័យ ។ ព្រោះហេតុនោះ ពួកព្រានម្រឹគជាដើម ភិក្ខុមិនគួរសូមការងារផ្ទាល់ខ្លួនជនទាំងនោះឡើយ ។ ទាំងមិនបានកំណត់ឲ្យពិតប្រាកដ មិនគួរសូមថា ពួកអ្នកចូរឲ្យហត្ថកម្ម ព្រោះពួកព្រានម្រឹគជាដើមនោះ ត្រូវភិក្ខុសូមយ៉ាងនេះហើយ នឹងទទួលពាក្យថា បានលោកម្ចាស់ ហើយនិមន្តឲ្យភិក្ខុត្រឡប់ទៅ គប្បីសម្លាប់ម្រឹគមកប្រគេនបាន ។ តែគួរសូមកំណត់ថា ក្នុងវិហារមានការងារខ្លះត្រូវធ្វើ ពួកអ្នកចូរឲ្យហត្ថកម្ម

ក្នុងវិហារនោះ ។ ការដែលភិក្ខុនឹងសូមហត្ថកម្មខ្លះនឹងអ្នកស្រែក្តី អ្នកដទៃដែលជាអ្នកខ្វល់ខ្វាយក្នុងការងាររបស់ខ្លួន ដែលកាន់យកគ្រឿងឧបករណ៍ មានផាល និងនង្គ័លជាដើម កំពុងដើរទៅដើម្បីភ្ជួរស្រែក្តី ព្រោះក្តី ប្រតក្តី គួរ ។

ចំណែកបុគ្គលណាជាអ្នកស៊ីដៃល ឬ ជាអ្នកដាក់ការងារដទៃខ្លះ ដែលជជែកតែរឿងឥតប្រយោជន៍ ឬគិតតែដេក សូម្បីមិនសូមបុគ្គលបែបនេះ ទោះពោលថា វ៉ៃយ ចូរមកធ្វើការងារឈ្មោះនេះក្តី វត្ថុនេះក្តី ហើយឲ្យធ្វើការងារតាមដែលត្រូវការ គួរ ។ តែដើម្បីសម្តែងថា ហត្ថកម្ម ជាកប្បិយៈគ្រប់យ៉ាងទើបអាចារ្យទាំងឡាយពោលន័យនេះទុក ។

បើភិក្ខុបំណងឲ្យធ្វើប្រាសាទ គប្បីទៅកាន់ស្រុកនៃពួកជាងដាប់ថ្ម ដើម្បីត្រូវការសសរ ហើយពោលថា ឧបាសក ការបានហត្ថកម្ម គួរ ។ កាលឧបាសកសួរថា គួរធ្វើដូចម្តេចលោកម្ចាស់ គប្បីប្រាប់ថា គប្បីសែងសសរថ្មទៅឲ្យ ។ បើពួកជាងសែងទៅឲ្យ ឬប្រគេនសសររបស់ខ្លួន ដែលជញ្ជូនមករក្សាទុកហើយ គួរ ។ បើពួកជាងដាប់ពោលថា ពួកខ្ញុំមិនមានពេលនឹងធ្វើហត្ថកម្មទេលោកម្ចាស់ សូមលោកម្ចាស់ឲ្យអ្នកដទៃជញ្ជូនទៅចុះ ពួកខ្ញុំនឹងឲ្យតម្លៃដល់អ្នកជញ្ជូនឯង ដូច្នេះ នឹងប្រើឲ្យអ្នកដទៃជញ្ជូនទៅ ហើយប្រាប់ថាពួកអ្នក ចូរឲ្យតម្លៃដល់អ្នកជញ្ជូនថ្មចុះ ដូច្នេះ គួរ ។

ដោយឧបាយដូចគ្នានេះ ការដែលភិក្ខុទៅកាន់សម្នាក់ពួកមនុស្សដែលធ្វើការ គឺជាងសិប្បៈនោះៗ ដើម្បីបំណងគ្រប់វត្ថុដែល គឺទៅកាន់សម្នាក់ជាងឈើដើម្បីឈើធ្វើប្រាសាទ ទៅកាន់សម្នាក់ជាងឥដ្ឋ ដើម្បីឥដ្ឋទៅកាន់សម្នាក់ជាង

ប្រក់ដំបូល ដើម្បីប្រក់ដំបូល ទៅកាន់សម្នាក់ជាងគំនូរ ដើម្បីចិត្រកម្ម ហើយសូមហត្ថកម្ម គួរ ។ ហើយនឹងទទួលយកអ្វីដែលខ្លួនបាន ដោយអំណាចការសូមហត្ថកម្មក្តី ដោយការបន្ថែមឲ្យតម្លៃ និងប្រាក់បំណាច់ ដោយការដាច់មូលក្តី រមែងគួរគ្រប់យ៉ាង ហើយការនាំរបស់មកអំពីព្រៃ គួរឲ្យនាំរបស់ទាំងអស់ដែលបុគ្គលណាមួយ មិនបានគ្រប់គ្រង ( មិនហួងហែង ) មក ។

ម្យ៉ាងទៀត មិនមែនតែបំណងនឹងសាងប្រាសាទតែម្យ៉ាងទេ សូម្បីបំណងនឹងឲ្យធ្វើគ្រែ តាំង បាត្រ ធម្មក្រក និងចីវរជាដើម ក៏គប្បីឲ្យនាំមកបានឈើ លោហៈ និងអំបោះជាដើមហើយ ចូលទៅរកពួកជាងសិប្បៈនោះៗ គប្បីសុំហត្ថកម្ម តាមន័យដូចពោលហើយនោះឯង ។ ទ្រព្យដែលខ្លួនបានមកដោយអំណាចនៃការសុំហត្ថកម្មក្តី ដោយការបន្ថែមតម្លៃឈ្នួល និងប្រាក់បំណាច់ ដោយការដាច់មូលក្តី គប្បីទទួលយកទាំងអស់ ។

បើពួកកម្មករមិនប្រាថ្នានឹងធ្វើ ទារយកថ្លៃឈ្នួល និងប្រាក់បំណាច់របស់ដែលជាអកប្បិយៈ មានកហាបណៈជាដើម មិនគួរឲ្យ ត្រូវស្វែងរកអង្ករជាដើមដោយកិក្ខាចារវត្តឲ្យទៅ គួរ ។

ភិក្ខុឲ្យជាងបាត្រធ្វើបាត្រ ដោយអំណាចនៃហត្ថកម្ម ហើយឲ្យដុតទំនងដូចគ្នានោះ ហើយចូលទៅកាន់ខាងក្នុងស្រុក ដើម្បីប្រេងលាបបាត្រដែលដុតថ្មី កាលអ្នកស្រុកយល់ថា មកដើម្បីភិក្ខា ហើយនាំបបរ ឬបាយមក គប្បីយកដៃបិទបាត្រ ។ បើឧបាសិកាសួរថា ហេតុអ្វីលោកម្ចាស់ ភិក្ខុគប្បីប្រាប់

ថា បាត្រដុតថ្មី ត្រូវការប្រេងសម្រាប់លាប បើឧបាសិកានោះពោលថា សូមឲ្យបាត្រមកចុះលោកម្ចាស់ ហើយទទួលយកបាត្រទៅលាបប្រេង ដាក់បបរ ឬបាយឲ្យពេញ ហើយប្រគេន មិនឈ្មោះថា ជាវិញ្ញត្តិ ទោះបីទទួលគួរ ដូច្នេះឯង ។

ពួកភិក្ខុត្រាច់ទៅបិណ្ឌបាតអំពីព្រឹក ទៅដល់រោងឆាន់ មិនឃើញអាសនៈឈររង់ចាំ ។ បើរោងឆាន់នោះ ពួកឧបាសិកាឃើញពួកភិក្ខុឈរ នាំគ្នាយកអាសនៈមកឯង ។ ពួកភិក្ខុអង្គុយហើយ កាលនឹងទៅ គប្បីលាជាមុន ហើយសឹមទៅ កាលពួកភិក្ខុមិនពោលលា ហើយទៅ ទ្រព្យដែលវិនាស មិនមែនជាសំណាង តែកាលពោលលា ហើយទៅ ជាទំនៀម ។

បើអាសនៈជារបស់អ្នកស្រុក ដែលភិក្ខុទាំងឡាយប្រាប់ថា ពួកអ្នកចូរនាំយកអាសនៈមក ទើបនាំយកឲ្យ ភិក្ខុទាំងឡាយត្រូវពោលលា ហើយសឹមទៅ ។ កាលពួកភិក្ខុមិនពោលលា ជាការខូចទំនៀម ហើយរបស់វិនាសជាសំណាងផងដែរ សូម្បីក្នុងកម្រាលព្រំ ក៏មានន័យយ៉ាងនេះដូចគ្នា ។ មមង់ច្រើន គប្បីពោលថា ចូរយកផ្ចិតបក់មមង់ ។ ពួកអ្នកស្រុកនាំមែកស្តៅជា-ដើមមកឲ្យ គប្បីឲ្យធ្វើកប្បិយៈជាមុន ហើយសឹមទទួល ។ ភាជនៈទឹកត្រង់រោងឆាន់ទទេ មិនគួរពោលថា ចូរនាំធម្មក្រកមក ព្រោះកាលជ្រមុជធម្មក្រកចូលទៅក្នុងភាជនៈទទេ គប្បីធ្វើភាជនៈឲ្យបែក តែគួរទៅកាន់ស្ទឹង ឬបឹង ហើយពោលថា ចូរនាំយកទឹកមក គួរ បើពោលថា ចូរនាំមកអំពីផ្ទះ មិនគួរដូចគ្នា ។ កុំបរិភោគទឹកដែលគេនាំមកឲ្យ ។

ភិក្ខុទាំងឡាយដែលធ្វើភត្តកិច្ចត្រង់រោងឆាន់ ឬសេនាសនៈព្រៃក្តី ស្លឹកឈើ ឬផ្លែឈើ ដែលគួរបរិភោគជាមួយសម្ងុតត្តិកង្គឯណាមួយ ដែលមិនមានមនុស្សហួងហែង កើតក្នុងទីនោះ បើពួកភិក្ខុឲ្យមនុស្សធ្វើការងារណាមួយនាំមក គួរឲ្យនាំមកដោយអំណាចនៃហត្ថកម្ម ហើយឆាន់ តែមិនគួរប្រើពួកភិក្ខុ ឬសាមណេរ ដែលជាអលជ្ជីឲ្យធ្វើហត្ថកម្ម ។ ក្នុងរឿងបុរិសត្ថករ ( ការងារដែលបុរសគប្បីធ្វើដោយដៃ ) មានប្រមាណប៉ុណ្ណេះ ។

តែការដែលភិក្ខុឲ្យនាំគោមកអំពីស្ថានទីនៃបុគ្គលមិនមែនញាតិ និងមិនបានបវារណា មិនគួរ ។ ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលឲ្យនាំមក ។ បើសូមដោយដាច់មូលតម្លៃអំពីស្ថានទីនៃញាតិ និងមនុស្សបវារណាក៏មិនគួរ ។ បើសូមដោយន័យជារបស់ខ្ចី គួរគ្រប់អន្ទើ ។

គប្បីរក្សាថែទាំគោ ដែលឲ្យនាំមកហើយយ៉ាងនេះស្រេចហើយ គប្បីប្រគល់ឲ្យម្ចាស់ទ្រព្យវិញ ។ បើជើង ឬស្នែងរបស់វាបាក់បែក ឬវិនាសទៅ បើម្ចាស់ទ្រព្យព្រមទទួលយក ការយល់ព្រមទទួលនោះ យ៉ាងនោះជាការល្អ បើម្ចាស់ទ្រព្យមិនព្រមទទួល ភិក្ខុត្រូវសង ។ បើម្ចាស់ទ្រព្យពោលថា ពួកខ្ញុំប្រគេនលោកចុះ ភិក្ខុមិនគួរទទួល ។ តែបើម្ចាស់ទ្រព្យពោលថា ពួកខ្ញុំប្រគេនវត្ត គប្បីពោលថា ពួកអ្នកចូរប្រាប់ដល់បុគ្គលដែលធ្វើការវត្ត ដើម្បីប្រយោជន៍ដល់ការចិញ្ចឹមវា ។ បើពោលជាមួយពួកបុគ្គលដែលមិនមែនញាតិ និងមិនបានបវារណាថា ពួកអ្នកចូរឲ្យរទេះដូច្នេះក្តី មិនគួរ ។ រមែងជាវិញ្ញត្តិពិត គឺត្រូវអាបត្តិទុក្កដ ។ តែក្នុងឋានៈនៃញាតិ និងបុគ្គលបវារណា គួរ

សូមជារបស់ខ្ញុំ ក៏គួរដូចគ្នា ។ ធ្វើការងារស្រេចហើយ គប្បីសងដល់ម្ចាស់វិញ ។ បើខ្នងកង់ជាដើមបាក់បែកទៅ គប្បីធ្វើឲ្យដូចដើម ហើយសឹមសង ។ បើបាត់បង់ទៅជាភណ្ឌទេយ្យ បើម្ចាស់ទ្រព្យពោលថា ពួកខ្ញុំប្រគេនលោកម្ចាស់ចុះ ធម្មតាគ្រឿងឈើមិនគួរទទួលទុកឡើយ ។ ក្នុងរឿងកាំបិត ពូថៅ ដីង ចប និងពន្លាកក្តី ក្នុងព្រឹក្សាជាតិ មានវល្លិជាដើមក្តី ដែលម្ចាស់ទ្រព្យហួងហែង ក៏មានន័យនេះដូចគ្នា ។ ក្នុងពួកព្រឹក្សាជាតិ មានវល្លិជាដើមដែលល្មមជាគរុភណ្ឌបានប៉ុណ្ណោះ ទើបជាវិញ្ញត្តិ បើទាបជាងនោះ មិនជាវិញ្ញត្តិឡើយ ។

តែភិក្ខុនឹងឲ្យនាំយកទ្រព្យឯណាមួយ ដែលមិនមានមនុស្សហួងហែងមកគួរ ព្រោះថា ក្នុងទីដែលមានមនុស្សរក្សាគ្រប់គ្រងប៉ុណ្ណោះ លោកហៅថា វិញ្ញត្តិ ។ វិញ្ញត្តិនោះ រមែងមិនគួរក្នុងបច្ច័យទាំងពីរ ( គឺចីវរ និងបិណ្ឌបាត ) ដោយប្រការគ្រប់យ៉ាង ។ តែក្នុងសេនាសនប្បច្ច័យ បើហាមាត់សូមថា អ្នកចូរនាំមកឲ្យ មិនគួរ ។ បរិកថា ឱភាស និងនិមិត្តកម្ម គួរ ។

បណ្តាបរិកថា ឱភាស និងនិមិត្តកម្មនោះ ពាក្យពោលរបស់ភិក្ខុដែលត្រូវការរោងឧបោសថ រោងឆាន់ ឬសេនាសនៈណាដទៃ ដោយន័យជាដើមថា ការសាងសេនាសនៈបែបនេះ ក្នុងឱកាសនេះ គួរឬហ្ន៎ ប្រពៃឬហ្ន៎ សមគួរឬហ្ន៎ក្តី ដូច្នេះ ឈ្មោះថា បរិកថា ។ ភិក្ខុសួរថា ឧបាសក ពួកលោកនៅក្នុងទីណា ពួកឧបាសកឆ្លើយថា ឯប្រាសាទលោកម្ចាស់ ហើយភិក្ខុពោលតទៅថា ក៏ប្រាសាទមិនគួរដល់ភិក្ខុទាំងឡាយឬឧបាសក ពាក្យមានជាដើម

យ៉ាងនេះ ឈ្មោះថា ឱភាស ។ ឯការធ្វើមានជាដើមយ៉ាងនេះ គឺភិក្ខុឃើញពួកអ្នកស្រុកហើយ សន្ទឹងខ្សែ ឲ្យបោះបង្គោល ដើម្បីឲ្យពួកអ្នកស្រុកសួរថា លោកម្ចាស់ធ្វើអ្វី ទើបឆ្លើយថា ពួកអាត្មានឹងធ្វើលំនៅ អាស្រ័យទីនេះ ឈ្មោះថា និមិត្តកម្ម ។ ចំណែកក្នុងគិលានបច្ច័យ សូម្បីវិញ្ញត្តិក៏គួរ ចាំបាច់ពោលទៅថ្វីដល់បរិកថាជាដើមនោះ ។

ពាក្យថា **មនុស្សា ឧបទ្ទុតា យាចនាយ ឧបទ្ទុតា វិញ្ញត្តិយា** សេចក្តីថា ពួកអ្នកស្រុកត្រូវបៀតបៀនដោយការសូម និងដោយការហាមាត់សូមរបស់ភិក្ខុទាំងនោះ ។ បទថា **ឧព្ពិជ្ជន្តិបិ** សេចក្តីថា រមែងបានទទួលការភ័យខ្លាច គឺញាប់ញ័រថា នឹងនាំអ្វីទៅឲ្យហ្ន៎ ។ បទថា **ឧត្តសន្តិបិ** សេចក្តីថា ជួបភិក្ខុក៏ភ្ញាក់ភ័យខ្លាច ដូចជួបពស់ ដូច្នោះ ។ បទថា **បលាយន្តិបិ** សេចក្តីថា រមែងគេចទៅអំពីចម្ងាយ ដោយផ្លូវណាមួយ ។ ពីរបទថា **អញ្ញេនបិ គច្ឆន្តិ** សេចក្តីថា លះផ្លូវដែលភិក្ខុដើរទៅហើយ ត្រឡប់ដើរទៅផ្លូវខាងឆ្វេង ឬខាងស្តាំ បិទទ្វារចោលខ្លះក៏មាន ។

# រឿងមណិកណ្ឋនាគរាជ

[ ១៩៧ ] ពីរបទថា **ភូតបុព្វំ ភិក្ខវេ** ជាដើម សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់តិះដៀលភិក្ខុទាំងនោះដោយប្រការដូច្នេះហើយ ត្រាស់ធម្មីកថាឲ្យសមគួរដល់រឿងរ៉ាវនោះហើយ កាលទ្រង់ធ្វើទោសនៃវិញ្ញត្តិឲ្យប្រាកដច្បាស់ទៀត ទើបទ្រង់សម្តែង ៣ រឿងនេះ ដោយន័យជាដើមថា **ភូតបុព្វំ ភិក្ខវេ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **មណិកណ្ឋោ** សេចក្តីថា បានឮថា ស្តេចនាគនោះប្រដាប់កែវមណីមានតម្លៃច្រើន ដែលឲ្យសម្រេចវត្ថុប្រាថ្នាគ្រប់យ៉ាងត្រង់កគ្រាច់ទៅ ព្រោះដូច្នោះ ទើបប្រាកដឈ្មោះថា មណិកណ្ឋនាគរាជ ។

បទថា **ឧបរិមុទ្ធនិ មហាន្តំ ផណំ អដ្ឋាសិ** សេចក្តីថា បានឮថា បណ្តាឥសីទាំងពីរនោះ ឥសីប្អូនជាអ្នកមានប្រក្រតីនៅដោយមេត្តា ព្រោះហេតុនោះ ទើបស្តេចនាគឡើងមកអំពីទឹក និម្មិតភេទជាទេវតា អង្គុយក្នុងសម្នាក់នៃឥសីនោះ ពោលសម្មោទនីយកថា លះភេទទេវតាទាំងនោះហើយ ត្រឡប់ក្លាយជាភេទដើមរបស់ខ្លួននោះឯង ព័ទ្ធជុំវិញឥសីនោះ ដើម្បីនឹងធ្វើការជ្រះថ្លា ទើបបើកពពារធំ ខាងលើក្បាលនៃឥសីនោះ ដូចជាឆត្រ ស្នាក់នៅមួយស្របក់ហើយ ទើបចៀសចេញទៅ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បានឈរផ្សាយពពារធំខាងលើក្បាល ដូច្នេះ ។

បទថា **មណិមស្ស កណ្ឋេ បិលន្ធំ** សេចក្តីថា នូវកែវមណីដែលស្តេចនាគនោះប្រដាប់ គឺពាក់ត្រង់ក ។

ពីរបទថា **ឯកមន្តំ អដ្ឋាសិ** សេចក្តីថា ស្តេចនាគនោះមកហើយដោយភេទទេវតានោះ សរសើរតាបស បានឈរក្នុងចំណែកមួយ ។

បទថា **មមន្នបានំ** បានដល់ បាយ និងទឹករបស់ខ្ញុំ ។ បទថា **វិបុលំ** បានដល់ ច្រើនសន្ធឹកសន្ធាប់ ។ បទថា **ឧឡារំ** បានដល់ ប្រណីត ។

បទថា **អតិយាចកោសិ** បានដល់ ជាអ្នកសូមហួសប្រមាណ មានពាក្យអធិប្បាយថា លោកជាអ្នកសូមហើយសូមទៀត ។

បទថា **សុសូ** សេចក្ដីថា ជាយុវជន គឺជាអ្នកសម្បូរដោយកម្លាំង បានដល់ បុរសដែលនៅក្នុងវ័យកំលោះ ។

សិលាខ្មៅ លោកហៅថា ថ្មសំលៀង ដាវដែលគេសំលៀងលើថ្មសំលៀងនោះ លោកហៅថា **សក្ខរធោត ។** ដាវដែលសំលៀងល្អហើយលើថ្មសំលៀង មាននៅក្នុងដៃរបស់បុរសនោះ ហេតុនោះ ទើបបុរសនោះឈ្មោះថា អ្នកកាន់ដាវដែលសំលៀងល្អហើយ លើថ្មសំលៀង ។ អធិប្បាយថា មានដៃកាន់ដាវដែលខាត់ និងសំលៀងល្អហើយលើថ្ម ។ លោកសូមកែវជាមួយខ្ញុំ ធ្វើឲ្យខ្ញុំស្រៀវខ្លាច ដូចបុរសមានដាវក្នុងដៃនោះ ធ្វើឲ្យអ្នកដទៃតក់ស្លុត ដូច្នោះ ។ បទថា **សេលំ មំ យាចមានោ** សេចក្ដីថា ចេះតែសូមនូវកែវមណី ។ បទថា **ន តំ យាចេ** សេចក្ដីថា មិនគួរសូមរបស់នោះ ។

សួរថា សូមរបស់ណា ឆ្លើយថា សូមរបស់ដែលខ្លួនដឹងថា ជាទីស្រឡាញ់របស់បុគ្គលនោះ ។

បទថា **យស្ស បិយំ ជិគីសេ** សេចក្ដីថា ខ្លួនគប្បីដឹងថា វត្ថុណាជាទីស្រឡាញ់របស់សត្វនោះ ( មិនគួរសូមរបស់នោះ ) ។ បទថា **កិមង្គ បន មនុស្សភូតានំ** សេចក្ដីថា ក្នុងពាក្យថា ( ការសូមនោះ ) មិនជាទីពេញចិត្តរបស់ពួកសត្វតិរច្ឆាន នឹងពោលថ្វីដល់សត្វដែលជាមនុស្ស ។

## រឿង បក្សីមួយហ្វូងធំ

[ ១៩៨ ] ប្រើនបទថា **សកុណសង្ឃស្ស សទ្ទេន ឧព្វាឡ្ហោ** សេចក្ដីថា បានឮថា ហ្វូងបក្សីនោះធ្វើសំឡេងខ្ទៀវខ្ទារជាប់តគ្នាទៅ អស់បឋមយាម

និងបច្ឆិមយាម ភិក្ខុនោះជាអ្នកត្រូវរំខានដោយសំឡេងបក្សីនោះ ទើបទៅកាន់សម្នាក់ព្រះមានព្រះភាគ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ចូលមករកតថាគតដល់លំនៅ ។

ក្នុងបទថា **កុតោ ច ត្វំ ភិក្ខុ អាគច្ឆសិ** នេះ មានវិនិច្ឆ័យដូច្នេះថា ភិក្ខុនោះអង្គុយហើយ ( ក្នុងសម្នាក់នៃព្រះមានព្រះភាគនេះ ) មិនមែនគប្បីមក តែការដែលលោកពោលយ៉ាងនេះ ក្នុងអតីតកាលជិតបច្ចុប្បន្នកាលរមែងមាន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អ្នកមកអំពីទីណា អធិប្បាយថា អ្នកជាអ្នកមកហើយអំពីណា ។

សូម្បីក្នុងបទថា **តតោ អហំ ភគវា អាគច្ឆាមិ** នេះ ក៏មានន័យយ៉ាងនោះដូចគ្នា ។

បទថា **ឧព្ពាឡ្ហោ** សេចក្តីថា ជាអ្នកមានសំឡេងបៀតបៀន គឺញុំាងឲ្យកើតសេចក្តីរំខាន ។

ក្នុងបទថា **សោ សកុណសង្ឃោ ភិក្ខុ បត្តំ យាចតិ** នេះ មានវិនិច្ឆ័យដូច្នេះថា ហ្វូងបក្សីរមែងមិនដឹងវាចារបស់ភិក្ខុ តែព្រះមានព្រះភាគទ្រង់ធ្វើឲ្យបក្សីទាំងនោះដឹងដោយអានុភាពរបស់ព្រះអង្គ ។

## រឿងបិតារបស់រដ្ឋបាលកុលបុត្រ

[ ១៩៩ ] បទថា **អញាតកា ន ជានាមិ** សេចក្តីថា អើ ញោម ក៏មិនស្គាល់ជនទាំងនោះថា ជនទាំងនេះជាបុគ្គលពួកណា ឬជនពួកនេះ ជាមនុស្សរបស់អ្នកណា ។

ពីរបទថា **សង្គម្ម យាចន្តិ** សេចក្ដីថា ជនទាំងនោះនាំគ្នាមក គឺរួមគ្នា ជាពួកៗ សូម ។ បទថា **យាចកោ អប្បិយោ ហោតិ** សេចក្ដីថា បុគ្គល អ្នកសូម មិនជាទីស្រឡាញ់ ( របស់អ្នកឲ្យ ) ។

បទថា **យាចំ អទទមប្បិយោ** សេចក្ដីថា របស់ដែលអ្នកដទៃសុំ លោកហៅថា **យាចំ**។ បុគ្គលមិនឲ្យនូវប្រយោជន៍ដែលគេសូម រមែងមិនជា ទីស្រឡាញ់ ( របស់អ្នកសូម ) ។

ម្យ៉ាងទៀត បទថា **យាចំ** បានដល់ របស់បុគ្គលសូម ។ បទថា **អទទមប្បិយោ** សេចក្ដីថា អ្នកមិនឲ្យ រមែងមិនជាទីស្រឡាញ់នៃអ្នកសូម ។

បទថា **មា មេ វិទ្ទេសនា អហុ** សេចក្ដីថា ភាពជាអ្នកមិនជាទី ស្រឡាញ់កុំមានហើយដល់អាត្មា អធិប្បាយថា អាត្មាកុំបានជាទីស្អប់ គឺមិន ជាទីស្រឡាញ់របស់អ្នក ឬថា អ្នកកុំជាទីស្អប់ គឺមិនជាទីស្រឡាញ់របស់ អាត្មា ។

[ ២០០ ] បទថា **ទុស្សំហរានិ** សេចក្ដីថា របររួមបានមកដោយលំបាក ដោយឧបាយទាំងឡាយ មានកសិកម្ម និងគោរក្ខកម្មជាដើម ការបេះតែសូម ដែលភិក្ខុឲ្យប្រព្រឹត្តទៅឯង លោកហៅថា **សំយាចិកា** ក្នុងពាក្យថា **សំយា-ចិកាយ បន ភិក្ខុនា** នេះ ។ ព្រោះហេតុនោះ ទើបបទថា **សំយាចិកា** មានរូបដែលលោកពោលថា ដោយការសូមរបស់ខ្លួន អធិប្បាយថា ដោយ ឧបករណ៍ទាំងឡាយដែលខ្លួនសូមមកឯង ។ ព្រោះថា កុដិនោះ ឈ្មោះថា ភិក្ខុ ធ្វើដោយគ្រឿងឧបករណ៍ដែលខ្លួនសូមមកឯង គឺសូមយកមកធ្វើឯង ដូច្នោះ

ដើម្បីសម្ដែងបរិយាយនៃអត្ថនោះ ទើបលោកពោលបទភាជនីយ៍ នៃបទថា **សំយាចិកាយ** នោះ យ៉ាងនេះថា សូមឯងនូវបុរសខ្វះជាដើម ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃកុដិការសិក្ខាបទ

[ ២០១ ] បទថា **ឧល្លិត្តា** បានដល់ បូកលាបខាងក្នុង ។ បទថា **អវលិត្តា** បានដល់ បូកលាបខាងក្រៅ ។ បទថា **ឧល្លិត្តាវលិត្តា** មានពាក្យអធិប្បាយថា បូកលាបទាំងខាងក្នុង ទាំងខាងក្រៅ ។

ក្នុងបទភាជនីយ៍នៃបទថា **ការយមានេន** នេះ ពាក្យត្រឹមតែ **ការាបេន្តេន** នេះប៉ុណ្ណោះ ជាពាក្យដែលព្រះឧបាលីពោល ។

ព្រោះថា កាលមានពាក្យយ៉ាងនេះ ព្យញ្ជនៈរមែងស្មើគ្នា តែព្រោះភិក្ខុឲ្យសាងកុដិដោយអាការសូមមកឯង គប្បីបដិបត្តិដោយន័យដូចពោលហើយក្នុងសិក្ខាបទនេះឯង ដូច្នោះ ដើម្បីសម្ដែងអត្ថនេះ ភិក្ខុដែលធ្វើឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ទាំងពីរពួកនេះ សង្គ្រោះដោយបទថា **ការយមានេន** នេះឯង ទើបពោលថា **ករោន្តោ វា ការាបេន្តោ វា** ដូច្នេះជាដើម ។ បើព្រះឧបាលីគប្បីពោលថា **ករោន្តេន វា ការាបេន្តេន វា** ព្យញ្ជនៈនឹងត្រូវខុសទៅ ។ ព្រោះថា ភិក្ខុប្រើឲ្យគេធ្វើ ឈ្មោះថា ជាអ្នកធ្វើឯងមិនបាន ព្រោះដូច្នោះ គប្បីជ្រាបក្នុងបទភាជនីយ៍នេះថា ព្រះឧបាលីសម្ដែងត្រឹមតែអត្ថប៉ុណ្ណោះ ។

បទថា **អត្តុទ្ទេសំ** សេចក្តីថា ចំពោះខ្លួននៃកុដិនោះ យ៉ាងនេះថា កុដិ

នេះរបស់អញ ព្រោះដូច្នោះ ទើបកុដិនោះ ឈ្មោះថា ចំពោះខ្លួនឯង ។ នូវកុដិចំពោះខ្លួនឯងនោះ ។ ព្រោះកុដិមានខ្លួនជាទីឧទ្ទិសនោះ មានប្រយោជន៍ដល់ខ្លួន ដូច្នោះ ទើបព្រះឧបាលីកាលសម្តែងបរិយាយនៃអត្ថនោះ ពោលបទថា **អត្តុទ្ទេសំ** គឺដើម្បីប្រយោជន៍ដល់ខ្លួន ។

ពីរបទថា **បមាណិកា ការេតព្វា** គឺគប្បីសាងឲ្យមានប្រមាណ ។

ពីរបទថា **តត្រិទំ បមាណំ** នេះ គឺប្រមាណនៃកុដិនោះ ។

បទថា **សុគតវិទត្ថិយា** សេចក្តីថា ដែលមានឈ្មោះថា ១ ចំអាមព្រះសុគត គឺ ៣ ចំអាមរបស់មជ្ឈិមបុរសក្នុងបច្ចុប្បន្ននេះ ស្មើនឹង ១ ហត្ថ ១ ចំអាម ដោយហត្ថជាងឈើ ។

ពីរបទថា **ទាហិរិមេន មានេន** បានដល់ ១២ ចំអាម ដោយវាស់ខាងក្រៅជញ្ជាំងនៃកុដិ ។ តែកាលនឹងវាស់ មិនគប្បីកំណត់យកទីបំផុតដុំដីឥដ្ឋធំ ដែលខ្លួនឲ្យទុកអំពីជំបូងគេនោះឡើយ ។ គប្បីវាស់ដោយទីបំផុតដុំដីដែលផ្សំដោយអង្កាម ( ដុំឥដ្ឋ ) ។ ការបូកលាបកំបោរខាងលើនៃដុំឥដ្ឋ ជាអព្វោ-ហារិក ។ បើភិក្ខុមិនត្រូវការដោយដុំឥដ្ឋ ធ្វើឲ្យសម្រេចដោយដុំដីស្អិតធំប៉ុណ្ណោះ ដីស្អិតធំនោះឯង ជាដែនកំណត់ ។

បទថា **តិរិយំ** ប្រែថា ដោយចំណែកទទឹង ។ បទថា **សត្ត** ប្រែថា ៧ ចំអាមព្រះសុគត ។ បទថា **អន្តរា** នេះ មាននិទ្ទេសដូច្នេះថា ដោយការវាស់ ដែលមានខាងក្នុង អធិប្បាយថា កាលមិនកាន់យកទីបំផុតខាងក្រៅជញ្ជាំង វាស់យកទីបំផុតដោយការវាស់ផ្ទៃកខាងក្នុង បានប្រមាណដោយទទឹង ៧ ចំអាមព្រះសុគត ។

ចំណែកភិក្ខុអានលេសថា អញនឹងធ្វើឲ្យបានប្រមាណតាមដែលត្រាស់ទុកពិតៗ តែគប្បីធ្វើប្រមាណដោយបណ្តោយ ១១ ចំអាម ទទឹង ៨ ចំអាម ឬបណ្តោយ ១៣ ចំអាម ទទឹង ៦ ចំអាម ការធ្វើនោះ រមែងមិនសមគួរដល់ភិក្ខុនោះ ។ ពិតហើយ ប្រមាណដែលលើសទៅតែចំណែកម្ខាង ក៏រាប់ថា លើសប្រមាណដូចគ្នា ។ ចំអាមចូរលើកទុកសិន និងបន្ថយបណ្តោយបន្ថែមទទឹង ឬបន្ថយទទឹង បន្ថែមបណ្តោយសូម្បីមួយចម្រៀកសក់ក៏មិនគួរ ។ នឹងពោលទៅថ្វី ក្នុងការពង្រីកបន្ថែមទាំងពីរចំណែកនោះ ។

សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុធ្វើឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ( នូវកុដិ ) ឲ្យកន្លងប្រមាណទៅ ដោយបណ្តោយ ឬដោយទទឹង ដោយហោចសូម្បីត្រឹមមួយចុងសក់ ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគដូច្នេះជាដើម ។ កុដិមានប្រមាណតាមដែលពោលទុកប៉ុណ្ណោះ ទើបគួរ ។

ចំណែកកុដិណា បណ្តោយមានប្រមាណដល់ ៦០ ហត្ថ ទទឹងមានប្រមាណ ៣ ហត្ថ ឬក្រោម ៣ ហត្ថ ជាទីដែលគ្រែវិលមិនបាន កុដិនេះមិនដល់នូវការរាប់ថា កុដិឡើយ ព្រោះដូច្នោះ កុដិនេះ សមគួរ ។ តែក្នុងមហាបច្ចរីពោលកុដិទទឹង ៤ ហត្ថទុកដោយកំណត់យ៉ាងទាប ។ ខ្ពី ជាង ៤ ហត្ថនោះ មិនហៅថា កុដិឡើយ ឯកុដិសូម្បីបានប្រមាណ តែសង្ឃមិនទាន់បានសម្តែងទីឲ្យក្តី មានហេតុទាស់ក្តី មិនមានឧបចារៈដោយជុំវិញក្តី មិនគួរ ។ កុដិត្រូវប្រមាណ សង្ឃសម្តែងទីឲ្យហើយ មិនមានហេតុទាស់ មានទីឧបចារៈដោយជុំវិញ ទើបគួរ ។

កាលភិក្ខុសាងកុដិតូចជាងប្រមាណក្តី កុដិមានប្រមាណ ៤-៥ ហត្ថក្តី គប្បីសាងឲ្យជាកុដិ មានទីដែលសង្ឃសម្តែងឲ្យហើយប៉ុណ្ណោះ ។ កាលភិក្ខុធ្វើឲ្យកន្លងប្រមាណទៅ ត្រូវគរុកាបត្តិ ក្នុងវេលាបូកលាបស្រេច ។ ក្នុងអធិការនៃការធ្វើកុដិឲ្យកន្លងប្រមាណនោះ អ្នកសិក្សាគប្បីជ្រាបការបូកលាប ការមិនបូកលាប ដោយឱកាសគួរបូកលាប និងឱកាសមិនគួរបូកលាប ។

សួរថា សេចក្តីនេះដូចម្តេច ឆ្លើយថា ការបូកលាបនោះ បានដល់ការបូកលាប ២ យ៉ាង គឺការបូកលាបដោយដីស្អិត ១ ការបូកលាបដោយបាយអ ១ វៀរលែងការបូកលាប ២ យ៉ាងនេះចេញ ការបូកលាបដទៃមានបូកលាបដោយផេះ និងអាចម៍ជាដើម មិនរាប់ថា ជាការបូកលាបឡើយ ។ សូម្បីការបូកលាបដោយកក់ ក៏ឈ្មោះថា មិនជាការបូកលាបដូចគ្នា ។

ដែលឈ្មោះថា ឱកាសគួរបូកលាបនោះ បានដល់ ប្រភេទជញ្ជាំង និងដំបូល ។ ឱកាសមិនគួរបូកលាបដ៏សេស វៀរជញ្ជាំង និងដំបូលចេញ មានសសរ ធ្នឹម ទ្វារ បង្អួច និងបំពង់ផ្សែងជាដើម ទាំងអស់នេះ គប្បីជ្រាបថា ឱកាសមិនគួរបូកលាប ។

## ផ្ទៃដីដែលគួរធ្វើ និងមិនគួរធ្វើ

[ ២០២ ] បទថា **ភិក្ខូ អភិនេតព្វា វត្ថុទេសនាយ** សេចក្តីថា ភិក្ខុអ្នកធ្វើគប្បីនាំភិក្ខុទាំងឡាយទៅ ដើម្បីប្រយោជន៍ដល់ការសម្តែងទី ក្នុងទីដែលខ្លួនធ្វើកុដិ ។

បទថា **តេន កុដីការកេន** ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បី

សម្តែងវិធីដែលគប្បីនាំភិក្ខុទាំងនោះទៅដើម្បីសម្តែងទីធ្វើ ។

បណ្តាបទទាំងនោះ ដោយបទថា **កុដិវត្ថុំ សោធេត្វា** ព្រះមានព្រះភាគទ្រង់សម្តែងថា ភិក្ខុដែលធ្វើកុដិ កុំទាន់នាំភិក្ខុទាំងឡាយទៅកាន់ព្រៃ បើមានផ្ទៃដីមិនស្មើ គប្បីឲ្យជម្រះកន្លែងធ្វើជាមុន ពង្រាបដីឲ្យរាបស្មើ ដូចគ្នានឹងមណ្ឌលសីមាហើយ ខាងក្រោយមក ចូលទៅរកសង្ឃ សូមហើយ សឹមនាំទៅ ។

ពីរបទថា **ឯវមស្ស វចនីយោ** សេចក្តីថា សង្ឃគួរជាបុគ្គលដែលភិក្ខុនោះគប្បីប្រាប់យ៉ាងនេះ តែខាងមុខព្រះមានព្រះភាគទ្រង់សំដៅដល់ភិក្ខុច្រើនរូប ត្រាស់ពុទ្ធវចនៈថា **ឧុតិយម្បិ យាចិតព្វា**។

បទថា **សចេ សព្វោ សង្ឃោ ន ឧស្សហតិ** សេចក្តីថា បើសង្ឃទាំងពួងមិនប្រាថ្នា គឺភិក្ខុទាំងនោះ មិនជាអ្នកខ្វល់ខ្វាយក្នុងកិច្ច មានការស្វាធ្យាយនិងមនសិការជាដើម ។

ពីរបទថា **សារម្ភំ អនារម្ភំ** បានដល់ មានហេតុទាស់ មិនមានហេតុទាស់ ។ ពីរបទថា **សបរិក្កមនំ អរិក្កមនំ** បានដល់ មានឧបចារៈ មិនមានឧបចារៈ ។ បទថា **បត្តកាលំ** សេចក្តីថា វេលានៃការពិនិត្យមើលនេះដល់ហើយ ព្រោះហេតុនោះ ទើបឈ្មោះថា មានកាលដល់ហើយ ។ កាលគួរនោះឯង ឈ្មោះថា **បត្តកាលំ**។

ឯអបលោកនកម្មនេះសូម្បីអបលោកធ្វើដោយន័យនៃការសូធ្យប្រកាសសម្មតិកម្ម ដើម្បីពិនិត្យមើលផ្ទៃដី ក៏គួរ ។ តែតទៅខាងមុខ កម្មដែលធ្វើក្នុងការសម្តែងទី គួរធ្វើដោយញត្តិ និងអនុសាវនាតាមដែលពោលហើយ

ប៉ុណ្ណោះ នឹងធ្វើដោយអបលោកធ្វើ មិនគួរ ។

[ ២០៤ ] បទថា **កិបិល្លិកានំ** សេចក្ដីថា នៃស្រមោចទាំងឡាយ មានប្រភេទ ជាស្រមោចក្រហមក្ដី ស្រមោចខ្មៅក្ដី ស្រមោចលឿងជាដើមក្ដី ប្រភេទណាមួយ ។ បាឋៈថា **កបិលកានំ** ក៏មាន ។

បទថា **អាសយោ** ប្រែថា ស្ថានទីនៅប្រចាំ ។ គប្បីជ្រាបទីអាស្រ័យ គឺនៅជានិច្ចរបស់ពួកសត្វតូចតាច មានកណ្ដៀរជាដើម ដូចរបស់ពួកស្រមោច ដូច្នោះ តែពួកសត្វល្អិត មានស្រមោចក្រហមជាដើមនោះ មកដើម្បីរកចំណី ក្នុងទីណាមួយ ហើយទៅ បទេសដែលសញ្ចរទៅមកដូច្នោះ របស់សត្វគ្រប់ពួក លោកមិនហាមឃាត់ ។ ព្រោះដូច្នោះ ការកាប់ឆ្កាដើមឈើជាដើមក្នុងឱកាសនោះ ពង្រាបឲ្យរាប ហើយធ្វើ គួរ ។ ទី ៦ ស្ថាននេះ ព្រះមានព្រះភាគ ទ្រង់ហាម ព្រោះការអាណិតអាសូរសត្វ ។

បទថា **ហត្ថីនំ វា** សេចក្ដីថា ស្ថានទីនៅប្រចាំក្ដី ទីរកស៊ីប្រចាំក្ដី របស់ហ្វូងដំរី រមែងមិនគួរ ។ ទីអាស្រ័យរបស់សត្វសាហាវ មានសីហៈ ជាដើមក្ដី ផ្លូវដើរប្រចាំរបស់ពួកពាឡម្រឹគ មានសីហៈជាដើមក្ដី ទីចៀស ទៅរកចំណីក្ដី រមែងមិនគួរ តែលោកមិនបានសំដៅយកផ្ទៃដី ដែលជាទីត្រាច់ ទៅនៃសត្វសាហាវទាំងនោះ ។

ពីរបទថា **យេសំ កេសញ្ចិ** សេចក្ដីថា នៃសត្វតិរច្ឆានដែលកាចពួកដទៃ ។ ទី ៧ ស្ថាននេះ ជាទីមានភ័យចំពោះមុខ ទ្រង់ហាមដើម្បីប្រយោជន៍ដល់ការផុតចាកអន្តរាយនៃភិក្ខុទាំងឡាយ ។ ស្ថានទីដ៏សេស ជាស្ថានទីដែល

មានហេតុទាស់ ដោយហេតុទាស់នឹងរបស់ផ្សេងៗ ។

បណ្ដាបទទាំងនោះ បទថា **បុព្វណ្ណនិស្សិតំ** សេចក្ដីថា ដែលអាស្រ័យស្រែបុព្វណ្ណជាតិ គឺតាំងនៅក្បែរស្រែ ព្រោះដាំធញ្ញជាតិ ៧ ប្រការ ។ សូម្បី ក្នុងបទថា **អបរណ្ណនិស្សិតំ** ជាដើមក៏មានន័យយ៉ាងនេះដូចគ្នា ។ តែក្នុងបទថា **អបរណ្ណនិស្សិតំ** ជាដើមនេះ លោកពោលក្នុងអដ្ឋកថាទាំង-ឡាយ មានកុរុន្ទីជាដើមថា ដែលឈ្មោះថា ទីសម្លាប់នោះ បានដល់ ផ្ទះរបស់នាយក្នាក់ងារ គឺផ្ទះរបស់បុគ្គលមានពៀរ ដែលគេធ្វើដើម្បីប្រើជាទីសម្លាប់ពួកចោរ ។

ទីដីដែលដាក់អាជ្ញា អ្នកប្រព្រឹត្តខុស មានការកាត់ដៃ និងជើងជាដើម ហៅថា ទីសម្រាប់ផ្ដាលទោស ។ ព្រៃធំជាទីចោលសាកសព លោកហៅថា ស្មសាន ។ ផ្លូវដែលមនុស្សត្រូវដើរឆ្លងទៅ គឺផ្លូវទៅមក លោកហៅថា ផ្លូវសញ្ចរ ។ បទដ៏សេសជាក់ច្បាស់ទាំងអស់ហើយ ។

## លក្ខណៈការធ្វើកុដិ

[ ២០៥ ] បទថា **ន សក្កា ហោតិ យថាយុត្តេន សកដេន** សេចក្ដីថា ជាទីដែលរទេះទឹមដោយគោពីរ មិនអាចបតកង់ម្ខាងទុកក្នុងទីទឹកស្រក់អំពីសំយាបដំបូល កង់ម្ខាងទុកខាងក្រៅ ហើយវិលទៅបាន ។ តែក្នុងកុរុន្ទីពោលថា ទឹមដោយគោ ៤ ក៏មាន ។

ច្រើនបទថា **សមន្តា និស្សេណិយា អនុបរិគន្តុំ** សេចក្ដីថា ជាទីដែលមនុស្សទាំងឡាយឈរប្រេក់ផ្ទះ ត្រង់ជណ្ដើរ ឬបង្អោង មិនអាចវិលទៅ

ដោយជុំវិញ ដោយជណ្ដើរ ឬបង្អួចបាន ក្នុងទីមានទីទាស់ និងមិនមានឧបចារៈបែបនេះ ដូចពោលមកដូច្នេះ មិនគួរធ្វើកុដិឡើយ តែគួរឲ្យធ្វើក្នុងទីដែលមិនមានហេតុទាស់ និងមានឧបចារៈ ។

ពីរបទថា ( **អនារម្ភំ សបរិក្កមនំ** ) នោះ មកហើយក្នុងព្រះបាលីនោះឯង ដោយបដិបក្ខន័យនៃពាក្យពោលហើយ ។

[ ២០៨ ] បទជាដើមយ៉ាងនេះថា **សញ្ញាចិកា ឆាម** ព្រះមានព្រះភាគត្រាស់ដដែលទៀត ដើម្បីប្រកាសអត្ថនៃបទថា **សញ្ញាចិកា** ជាដើម ដែលត្រាស់យ៉ាងនេះថា បើភិក្ខុធ្វើកុដិ ដោយអាការសូមមកឯង ក្នុងផ្ទៃដីដែលមានហេតុទាស់ មិនមានឧបចារៈ ។

ពីរបទថា **បយោគេ ទុក្កដំ** សេចក្ដីថា ភិក្ខុត្រិះរិះថា អញនឹងឲ្យធ្វើកុដិដែលសង្ឃមិនសម្ដែងទីឲ្យ ឬឲ្យកន្លងប្រមាណ ដោយន័យដូចត្រាស់ទុកក្នុងបាលីយ៉ាងនេះ ហើយសំលៀងកាំបិត ឬពូថៅ ដើម្បីនាំឈើមកអំពីព្រៃ ត្រូវអាបត្តិទុក្កដ ចូលកាន់ព្រៃ ត្រូវអាបត្តិទុក្កដ កាប់ស្មៅស្រស់ក្នុងព្រៃនោះ ត្រូវអាបត្តិបាចិត្តិយ មួយអន្លើដោយទុក្កដ កាប់ស្មៅស្ងួត ត្រូវអាបត្តិទុក្កដ ជីសូម្បីក្នុងដើមឈើ ក៏មានន័យដូចគ្នា ។

ប្រយោគតាំងអំពីដើមយ៉ាងនេះ គឺភិក្ខុជម្រះផ្ទៃដី ជីក កោយ វាស់ជាដើមទៅ រហូតដល់បោះជញ្ជាំង ឈ្មោះថា បុព្វប្រយោគ ក្នុងបុព្វប្រយោគនេះ គ្រប់ៗ កន្លែងក្នុងឋានៈនៃបាចិត្តិយ ជាបាចិត្តិយ និងទុក្កដ ក្នុងឋានៈនៃទុក្កដ ត្រូវត្រឹមអាបត្តិទុក្កដ ចាប់ផ្ដើមពីបោះជញ្ជាំងនោះទៅ ឈ្មោះថា

សហប្បយោគ ។

ក្នុងសហប្បយោគនោះ មានវិនិច្ឆ័យដូច្នេះថា ក្នុងកុដិដែលគប្បីធ្វើដោយសសរច្រើនដើម ភិក្ខុឲ្យលើកសសរទីមួយក្នុងកុដិនោះ ត្រូវអាបត្តិទុក្កដ ។ ក្នុងកុដិដែលគប្បីកដោយឥដ្ឋច្រើនដុំ ភិក្ខុកឥដ្ឋទី ១ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រកបគ្រឿងឧបករណ៍ណាមួយ ដោយឧបាយយ៉ាងនេះ ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគនៃការប្រកបគ្រឿងឧបករណ៍នោះ ។ បើចាំងឈើ ត្រូវអាបត្តិទុក្កដគ្រប់ៗ គ្រាដែលលើកដៃ ។ កាលទៅដើម្បីចាំងឈើនោះ ត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន ។

កាលភិក្ខុគិតថា អញនឹងបូកលាបជញ្ជាំងកុដិឈើក្តី ជញ្ជាំងថ្មក្តី ជញ្ជាំងឥដ្ឋក្តី ដោចហោចសូម្បីបណ្ណសាលា ព្រមទាំងជញ្ជាំង និងដំបូលដែលធ្វើហើយយ៉ាងនេះ ហើយបូកលាបដោយបាយអ ឬដីស្អិត ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ត្រូវអាបត្តិទុក្កដរហូតដល់ពេលដែលមិនទាន់ត្រូវអាបត្តិថុល្លច្ច័យ ។ តែអាបត្តិទុក្កដនេះ ពង្រីកបន្ថែមឡើងដោយការបូកលាបច្រើនដងដូចគ្នា ។ តែមិនត្រូវអាបត្តិ ព្រោះការលាបពណ៌ស និងពណ៌ក្រហម ឬព្រោះចិត្រកម្ម ។

បទថា **ឯកំ បិណ្ឌំ អនាគតេ** សេចក្តីថា ក្នុងកាលការធ្វើកុដិមិនទាន់ដល់ដុំបាយអ បូកលាបមួយដុំ ដែលជាដុំចុងក្រោយគេទាំងអស់ មានពាក្យអធិប្បាយថា ក្នុងខណៈដែលគួរពោលបានថា កុដិនឹងដល់នូវការសម្រេចដោយបាយអពីរដុំក្នុងឥឡូវនេះ បណ្តាពីរដុំនោះ ដាក់ដុំទី ១ ត្រូវអាបត្តិ

ចុល្លច្ច័យ ។

បទថា **តស្មឹ បិណ្ឌេ អាគតេ** សេចក្ដីថា ក្នុងកាលកុដិកម្មមិនទាន់ដល់មួយដុំឯណា ត្រូវអាបត្តិថុល្លច្ច័យ កាលដុំនោះដែលជាដុំចុងក្រោយមកដល់ហើយ គឺដែលភិក្ខុដាក់ហើយ ដាក់ចុះហើយ ត្រូវសង្ឃាទិសេស ព្រោះការបូកភ្ជាប់គ្នាហើយ ។ ការដែលភិក្ខុបូកលាបយ៉ាងនេះ កាលភ្ជាប់ការបូកលាបខាងក្នុង ដោយការបូកលាបខាងក្នុង ធ្វើឲ្យជញ្ជាំង និងដំបូលជាប់ជាមួយគ្នា ឬកាលភ្ជាប់ការបូកលាបផ្នែកខាងក្រៅ ដោយការបូកលាបខាងក្រៅហើយ ទើបត្រូវអាបត្តិសង្ឃាទិសេស ។

បើភិក្ខុមិនទាន់តាំងក្របទ្វារ ( ធាត់ណា ) ឬ បង្អួចទេ បូកលាបដោយដីស្អិត កាលតាំងក្របទ្វារ និងបង្អួចនោះហើយ និងពង្រីកឱកាសនៃក្របទ្វារ និងបង្អួចនោះជាថ្មី ឬមិនពង្រីកក៏ដោយ ការបូកលាបនៅមិនទាន់ជាប់គ្នា នៅរក្សានៅឡើយ តែកាលបូកលាបជាថ្មី គ្រាន់តែជាប់គ្នា ត្រូវអាបត្តិសង្ឃាទិសេស ។

បើក្របទ្វារ និងក្របបង្អួចផ្សេងគ្នា ដែលភិក្ខុតាំងទុក តាំងនៅជាប់តគ្នា ដោយការបូកលាប ដែលឲ្យទុកតាំងអំពីដំបូងនោះឯង ត្រូវអាបត្តិសង្ឃាទិសេសតាំងអំពីដំបូងដូចគ្នា ។ ដើម្បីការពារកណ្ដៀរ បើបូកលាបជញ្ជាំងមិនឲ្យដល់ដំបូលប្រមាណ ៨ ធ្នាប់ មិនត្រូវអាបត្តិ ។ ដើម្បីការពារកណ្ដៀរដូចគ្នា បើធ្វើជញ្ជាំងថ្មខាងក្រោម មិនបូកលាបជញ្ជាំងនោះ បូកលាបតែខាងលើ ការបូកលាប ឈ្មោះថា មិនជាប់តគ្នា មិនត្រូវអាបត្តិដូចគ្នា ។

ភិក្ខុធ្វើបង្អួច និងបំពង់ភ្លើងដោយឥដ្ឋសុទ្ធក្នុងកុដិជញ្ជាំងឥដ្ឋ ត្រូវអាបត្តិដោយភ្ជាប់ការបូកលាបនោះឯង ភិក្ខុបូកលាបបណ្ណសាលា ត្រូវអាបត្តិព្រោះភ្ជាប់ការបូកលាបដូចគ្នា ។ ដើម្បីត្រូវការពន្លឺក្នុងបណ្ណសាលានោះ ទើបបូកលាបវៀរទុកទីប្រមាណ ៨ ធ្នាប់ ការបូកលាបឈ្មោះថា មិនជាប់តគ្នា មិនទាន់ត្រូវអាបត្តិដូចគ្នា ។

បើភិក្ខុធ្វើក្នុងចិត្តថា អញបានបង្អួចហើយ នឹងដាក់ត្រង់នេះ ហើយទើបធ្វើ កាលតាំងបង្អួចស្រេចហើយ បូកលាបភ្ជាប់ ត្រូវអាបត្តិព្រោះភ្ជាប់ដោយការបូកលាប ។ បើភិក្ខុធ្វើជញ្ជាំងដោយដីឥដ្ឋ ត្រូវអាបត្តិព្រោះការភ្ជាប់គ្នានិងការបូកលាបជំបូល ភិក្ខុមួយរូបបូកនៅសល់មួយដុំ ភិក្ខុមួយរូបទៀតឃើញកន្លែងដែលនៅសល់មួយដុំមិនទាន់បានបូកលាបនោះ គិតក្នុងចិត្តថា នេះជាវត្តុទុក្កដ ទើបលាបបង្ហើយ ដោយបំណងក្នុងសេនាសនវត្ត មិនត្រូវអាបត្តិទាំងពីរអង្គ ។

សិក្ខាបទវិភង្គនៃកុដិការសិក្ខាបទ ចប់

# អធិប្បាយ
# បទភាជនីយ៍នៃកុដិការសិក្ខាបទ

[ ២០៩ ] ៣៦ ចតុក្កៈ មានពាក្យថា **ភិក្ខុ កុដឹ ករោតិ** ជាដើម ព្រះមានព្រះភាគត្រាស់ដើម្បីទ្រង់សម្តែងប្រភេទនៃអាបត្តិ ។ ក្នុង ៣៦ ចតុក្កៈនោះ គប្បីជ្រាបអាបត្តិដែលលាយឡំគ្នា ដោយអំណាចនៃអាបត្តិទុក្កដ និងអាបត្តិសង្ឃាទិសេសទាំងនេះ គឺទុក្កដ ព្រោះមានហេតុទាស់ ទុក្កដ ព្រោះមិនមានឧបចារៈ សង្ឃាទិសេស ព្រោះធ្វើកន្លងប្រមាណ សង្ឃាទិសេស ព្រោះសង្ឃ មិនបានសម្តែងទីឲ្យ ។

[ ២១១ ] ក្នុងបទជាដើមថា **អាបត្តិ ទ្វិន្នំ សង្ឃាទិសេសេន ទ្វិន្នំ ទុក្កដានំ** បណ្ឌិតគប្បីជ្រាបអត្ថដោយន័យជាដើមថា ត្រូវអាបត្តិទុក្កដ ២ មួយអន្លើដោយសង្ឃាទិសេស ២ ។

[ ២១៨ ] ក្នុងបទជាដើមថា **សោ ចេ វិប្បកតេ អាគច្ឆតិ** មានអត្ថវិនិច្ឆ័យដូចតទៅនេះ បទថា **សោ** បានដល់ ភិក្ខុដែលប្រាប់ហើយ ចៀសចេញទៅ ។ បទថា **វិប្បកតេ** បានដល់ កាលការធ្វើកុដិមិនទាន់សម្រេច ។ ពីរបទថា **អញ្ញស្ស វា ទាតព្វា** សេចក្តីថា គប្បីលះបង់ឲ្យដល់បុគ្គលដទៃ ។

ពីរបទថា **ភិន្ទិត្វា វា បុន កាតព្វា** សេចក្តីថា កុដិ ឈ្មោះថា រើហើយ ដោយហេតុមានប្រមាណប៉ុនណា បើសសរដែលកប់ត្រង់ផែនដីគប្បីដកឡើង បើតាំងទុកលើថ្ម គប្បីនាំចេញ ។ គប្បីរើជញ្ជាំងនៃកុដិដែលកឥដ្ឋចេញ រហូតដល់ឥដ្ឋមង្គល( ថ្មគ្រឹះ ) ។ ដោយសង្ខេប កុដិដែលត្រូវទម្លាយឲ្យរាបស្មើនឹងផែនដី ឈ្មោះថា រើហើយ ។ លើផែនដីឡើងទៅ កាលនៅមាន

ជញ្ជាំងសល់មានប្រមាណ ៤ ធ្នាប់ កុដិ ឈ្មោះថា មិនបានរើឡើយ ។ ពាក្យដ៏សេសក្នុងគ្រប់ៗចតុក្កៈ ប្រាកដច្បាស់ហើយទាំងអស់ ។ ពិតហើយ ក្នុងចតុក្កៈទាំងពួងនេះ មិនមានពាក្យណាដទៃដែលគប្បីដឹងបានលំបាក តាមគន្លងនៃព្រះបាលីឡើយ ។

[ ២១៩ ] ក្នុងបទថា **អត្តនា វិប្បកតំ** ជាដើម មានវិនិច្ឆ័យដូច្នេះថា ដែលឈ្មោះថា ញ៉ាំងកុដិដែលខ្លួនផ្ដើមធ្វើឲ្យសម្រេចដោយខ្លួនឯង គឺកាលភិក្ខុដាក់ដុំចុងក្រោយចូលក្នុងកុដិ ដែលខ្លួនមានបំណងនឹងឲ្យដល់នូវភាពជារបស់ធ្វើហើយ សម្រេចដោយដីស្អិតចំនួនច្រើន ឬ ដោយឥដ្ឋ ឈ្មោះថា ឲ្យសម្រេច ។ ពីរបទថា **បរេហិ បរិយោសាបេតិ** សេចក្ដីថា ប្រើអ្នកដទៃឲ្យធ្វើសម្រេច ដើម្បីប្រយោជន៍ដល់ខ្លួន ។

ក្នុងពាក្យនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា កុដិដែលខ្លួនឯងក្ដី ដែលអ្នកដទៃក្ដី ខ្លួនឯង និងអ្នកដទៃក្ដី ធ្វើបន្សល់ទុកក្ដី ឯភិក្ខុញ៉ាំងកុដិនោះឲ្យសម្រេចឯងក្ដី ប្រើអ្នកដទៃឲ្យធ្វើសម្រេចក្ដី ប្រើមនុស្សដែលរួមជាគូ គឺខ្លួនឯង និងអ្នកដទៃធ្វើឲ្យសម្រេចក្ដី ដើម្បីប្រយោជន៍ដល់ខ្លួន ត្រូវអាបត្តិសង្ឃាទិសេសទាំងអស់ ។

តែក្នុងកុរុន្ទី ពោលថា ភិក្ខុ ២ , ៣ អង្គ រួមគ្នាធ្វើ ពោលថា ពួកយើងនឹងនៅ នៅរក្សានៅឡើយ មិនទាន់ត្រូវអាបត្តិ ព្រោះមិនទាន់ចែកគ្នា លុះចែកគ្នាថា ត្រង់នេះរបស់លោក ហើយនាំគ្នាធ្វើ ប្រព្រឹត្តជាអាបត្តិសាមណេរ និងភិក្ខុរួមគ្នាធ្វើ នៅរក្សារហូតដល់ពេលដែលមិនទាន់បែងចែកគ្នា ចែកគ្នាដោយន័យមុន ហើយនាំគ្នាធ្វើ ត្រូវអាបត្តិដល់ភិក្ខុ ដូច្នោះ ។

# អនាបត្តិវារៈ

[ ២២០ ] ក្នុងបទថា **អនាបត្តិ លេណេ** ជាដើម មានវិនិច្ឆ័យដូច្នេះថា មិនត្រូវអាបត្តិដល់ភិក្ខុដែលធ្វើឲ្យធំ ព្រោះការបូកលាបក្នុងគុហាមិនភ្ជាប់តគ្នា ។ សម្រាប់ភិក្ខុដែលធ្វើគុហា គឺគុហាកឥដ្ឋក្តី គុហាថ្មក្តី គុហាឈើក្តី គុហាដីក្តី សូម្បីធំហួសប្រមាណ ក៏មិនត្រូវអាបត្តិ ។

បទថា **តិណកុដិកាយោ** សេចក្តីថា ប្រាសាទ ៧ ជាន់ តែដំបូលប្រក់ដោយស្មៅ និងស្លឹកឈើ លោកហៅថា កុដិស្មៅ ។ តែក្នុងអដ្ឋកថាទាំងឡាយ លោកហៅកុដិដែលគេធ្វើដំបូលឲ្យប្រទាក់គ្នាដូចក្រឡាសំណាញ់ដោយដៃរណែងទាំងឡាយ ហើយប្រក់ដោយស្មៅ ឬស្លឹកឈើ នោះឯងថាទ្រុងមាន់ មិនជាអាបត្តិក្នុងកុដិដែលគេប្រក់ហើយនោះ ។ នឹងធ្វើផ្ទះដំបូលប្រក់ស្មៅ ឲ្យធំក៏គួរ ។ ព្រោះថា ភាវៈ មានការបូកលាបបាយអ ខាងក្នុងជាដើម ជាលក្ខណៈនៃកុដិ ។ ភាវៈ មានបូកលាបបាយអខាងក្នុងជាដើមនោះបណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សំដៅដល់ដំបូលប៉ុណ្ណោះ ។

ពាក្យថា កម្មេចស្មៅក៏ជ្រុះមកក្នុងរោងចង្ក្រម ។បេ។ ម្នាលភិក្ខុទាំងឡាយតថាគតអនុញ្ញាតឲ្យគាបដំបូល ហើយបូកទាំងខាងក្នុង ខាងក្រៅជាដើម ជាគ្រឿងសាធកៈក្នុងកុដិស្មៅនេះ ។ ព្រោះដូច្នោះ កុដិណា មានស្លាបសងខាង ឬជាប់កំពូលមូល ឬ ៤ ជ្រុង ជារបស់ដែលគេធ្វើដោយសង្ខេបថា នេះជាដំបូលរបស់កុដិ កាលការបូកលាបភ្ជាប់តគ្នានឹងការ បូកលាបជញ្ជាំងនៃកុដិនោះហើយ ត្រូវអាបត្តិ ។ បើភិក្ខុទាំងឡាយប្រក់ដោយស្មៅខាងលើ ដើម្បីរក្សាគ្រឿងបូកលាបរបស់កុដិដែលមានដំបូល បូកលាបដោយបាយអ ទាំង

ខាងក្នុង និងខាងក្រៅ មិនឈ្មោះថា ជាកុដិស្មៅដោយអាការ មានប្រមាណប៉ុណ្ណោះ ។ សួរថា ក្នុងកុដិស្មៅនេះ មិនត្រូវអាបត្តិ ព្រោះសង្ឃមិនបានសម្តែងទីឲ្យ និងធ្វើកន្លងប្រមាណជាបច្ច័យប៉ុណ្ណោះ ឬព្រោះមានហេតុទាស់ និងមិនមានឧបចារៈជាបច្ច័យទៅវិញ ឆ្លើយថា មិនត្រូវអាបត្តិសូម្បីគ្រប់ករណី ។

ពិតហើយ ទើបព្រះមានព្រះភាគ ទ្រង់សំដៅដល់កុដិដូច្នេះ ត្រាស់ទុកក្នុងគម្ពីរបរិវារថា

> ភិក្ខុធ្វើកុដិ ដោយការសូមគ្រឿងឧបករណ៍គេមកដោយខ្លួនឯង ឥតមានពួកភិក្ខុសម្តែងទីឲ្យ ធ្វើឲ្យកន្លងហួសប្រមាណ មានហេតុទាស់ មិនមានទីឧបចារៈ តែភិក្ខុនោះមិនត្រូវអាបត្តិ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

ចំណែកក្នុងពាក្យដែលព្រះមានព្រះភាគ ត្រាស់ទុកក្នុងបាលីជាដើមថា ភិក្ខុអ្នកធ្វើត្រូវអាបត្តិទុក្កដ ៣ ដូច្នេះ ត្រាស់ព្រោះការមិនធ្វើតាមពាក្យបង្គាប់ទុកជាបច្ច័យ ។ ពីរបទថា **អញ្ញស្សត្ថាយ** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុដែលធ្វើកុដិដើម្បីប្រយោជន៍អ្នកដទៃ គឺឧបជ្ឈាយ៍ក្តី អាចារ្យក្តី សង្ឃក្តី ទោះមិនត្រូវលក្ខណៈរបស់កុដិ ។

បទថា **វាសាគារំ ឋបេត្វា សព្វត្ថ** សេចក្តីថា ភិក្ខុឲ្យសាងអាគារដទៃ វៀរអាគារដើម្បីប្រយោជន៍ជាទីនៅរបស់ខ្លួនចេញ ដោយតាំងចិត្តថា ជារោងឧបោសថក្តី ផ្ទះជាទីរក្សាកាយក្តី ជារោងឆាន់ក្តី រោងភ្លើងក្តី មិនត្រូវអាបត្តិក្នុងអាគារទាំងអស់ មានរោងឧបោសថជាដើម ។ បើភិក្ខុនោះរំពឹងក្នុង

ចិត្តថា ជាភោជនឧបោសថផង អញនឹងនៅផងដូច្នេះក្តី ជាផ្ទះរក្សាកាយផង ជាសាលាឆាន់ផង ... និងជាភោជភ្លើងផង អញនឹងនៅផងដូច្នេះក្តី សូម្បីកាលឲ្យធ្វើរោងឧបោសថជាដើម ត្រូវអាបត្តិពិត ។ តែក្នុងមហាបច្ចរីពោលថា មិនត្រូវអាបត្តិ ហើយពោលថា ត្រូវអាបត្តិដល់ភិក្ខុដែលធ្វើដើម្បីប្រយោជន៍ដល់កុដិជាលំនៅរបស់ខ្លួនប៉ុណ្ណោះ ។

បទថា **អនាបត្តិ** សេចក្តីថា មិនត្រូវអាបត្តិដល់ភិក្ខុឆ្កួត និងដល់ពួកភិក្ខុអ្នកដែនអាឡវីដែលជាដើមបញ្ញត្តិជាដើម ។

ក្នុងសមុដ្ឋានជាដើម គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា សិក្ខាបទនេះ មានសមុដ្ឋាន ៦ ជាកិរិយា ។ ពិតហើយ សិក្ខាបទនេះ រមែងកើតដោយការធ្វើរបស់ភិក្ខុដែលឲ្យសង្ឃសម្តែងទីឲ្យ ហើយធ្វើឲ្យកន្លងប្រមាណ កើតដោយការធ្វើ និងមិនធ្វើរបស់ភិក្ខុ ដែលមិនឲ្យសង្ឃសម្តែងទី ហើយធ្វើ ជានោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

កុដិការសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ៧

[ ២២១ ] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅឃោសិតារាម ទៀបក្រុងកោសម្ពី ។ សម័យនោះឯង មានគហបតីជាឧបដ្ឋាកឆន្នភិក្ខុដ៏មានអាយុ បាននិយាយពាក្យនេះនឹងឆន្នភិក្ខុដ៏មានអាយុថា បពិត្រលោកដ៏ចម្រើន សូមលោកម្ចាស់ជ្រាប ទីសម្រាប់សង់វិហារ ខ្ញុំព្រះករុណានឹងឲ្យមនុស្សធ្វើវិហារប្រគេនលោកម្ចាស់ ។ ឆន្នភិក្ខុដ៏មានអាយុកាលដែលជម្រះទីសម្រាប់សង់វិហារ ក៏ឲ្យមនុស្សកាប់ឈើមួយដើម ដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុក អ្នកនិគម អ្នកក្រុង អ្នកជនបទ អ្នកដែនធ្លាប់គោរពបូជា ។ មនុស្សទាំងឡាយ ពោលទោស និន្ទា តិះដៀលថា ចុះហេតុអ្វី បានជាសមណៈទាំងឡាយជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឲ្យមនុស្សកាប់ឈើដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុក អ្នកនិគម អ្នកក្រុង អ្នកជនបទ អ្នកដែនធ្លាប់គោរពបូជា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធជាសក្យបុត្ត បៀតបៀនដើមឈើរស់ដែលមានឥន្ទ្រិយតែមួយ ។ ពួកភិក្ខុបានឮពាក្យមនុស្សទាំងឡាយនោះ ពោលទោស និន្ទា តិះដៀល ( ដូច្នោះ ) ពួកភិក្ខុណា ដែលមានសេចក្ដីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោសនិន្ទាតិះដៀលថា ចុះហេតុអ្វី បានជាឆន្នភិក្ខុដ៏មានអាយុឲ្យមនុស្សកាប់ឈើដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុកគេបូជា ។បេ។ អ្នកដែនធ្លាប់គោរពបូជា ។ គ្រានោះឯង ភិក្ខុទាំងឡាយនោះ ក្រាប

ទូលសេចក្ដីនុ៎ះ ដល់ព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាល ឆន្ន ឮថាអ្នកឯងឲ្យមនុស្សកាប់ឈើដែលគេសន្មតជាចេតិយ ដែលអ្នកស្រុកគេបូជា ។បេ។ អ្នកដែនធ្លាប់គោរពបូជាមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់តិះដៀលថា ។បេ។ នែបុរសទទេ ចុះហេតុអ្វី បានជាអ្នកឯងឲ្យមនុស្សកាប់ដើមឈើដែលគេសន្មតជាចេតិយ ជាឈើដែលអ្នកស្រុក អ្នកនិគម អ្នកក្រុង អ្នកជនបទ អ្នកដែនតែងគោរពបូជា ( ដូច្នោះ ) ម្នាលមោឃបុរស ព្រោះមនុស្សទាំងឡាយ មានសេចក្ដីសម្គាល់ថាឈើជាសភាវៈមានជីវិត នែបុរសសោះសូន្យ ហេតុនេះ មិននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្ដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើវិហារ[១]មានម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ត្រូវនាំភិក្ខុទាំងឡាយមកសម្ដែងទីឲ្យ ភិក្ខុទាំងឡាយនោះ ត្រូវសម្ដែងទីដែលមិនមានសេចក្ដីរង្កៀស មានឧបចារៈ ថាបើទីដីប្រកបដោយសេចក្ដីរង្កៀស មិនមានឧបចារៈហើយ ភិក្ខុគប្បីឲ្យធ្វើវិហារធំ ឬមិននាំភិក្ខុទាំងឡាយទៅដើម្បីសម្ដែងទីឲ្យ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ២២២ ] វិហារដែលមានម្ចាស់ តថាគតហៅថា វិហារធំ ។ ( ទីនៅរបស់សង្ឃ ) គឺទីដែលលាបខាងក្នុងក្ដី លាបខាងក្រៅក្ដី លាបទាំងខាងក្នុង

---

១- ពាក្យដែលហៅថា វិហារនោះ តាមភាសាបាលី សំដៅយកទីនៅទាំងអស់របស់សង្ឃ គឺកុដិដែលធំៗ សម្រាប់សង្ឃនៅ ឬទីវត្តទាំងមូលនោះឯង ហៅថា វិហារ ។

ទាំងខាងក្រៅក្ដី ហៅថា វិហារ ។ ត្រង់ពាក្យថា កាលឲ្យគេធ្វើ សេចក្ដីថា ធ្វើឯងក្ដី ប្រើអ្នកដទៃឲ្យធ្វើក្ដី ។ ត្រង់ពាក្យថា មានម្ចាស់ គឺអ្នកណាមួយដទៃ ទោះស្រីក្ដី ប្រុសក្ដី គ្រហស្ថក្ដី អ្នកបួសក្ដី ជាម្ចាស់ ។ ត្រង់ពាក្យថា ចំពោះជាទីនៅរបស់ខ្លួន គឺដើម្បីជាប្រយោជន៍ដល់ខ្លួន ។

[ ២២៣ ] ត្រង់ពាក្យថា ត្រូវនាំពួកភិក្ខុទាំងឡាយមកសម្ដែងទីឲ្យ គឺ ត្រូវភិក្ខុអ្នកធ្វើវិហារនោះ ជម្រះទីសម្រាប់ធ្វើវិហារ រួចហើយចូលទៅរកសង្ឃ ហើយធ្វើសំពត់ឧត្តរាសង្គ[១]ធៀងស្មាម្ខាង ហើយថ្វាយបង្គំជើងរបស់ភិក្ខុចាស់ ទាំងឡាយ ហើយអង្គុយច្រហោងផ្គងអញ្ជលី ហើយពោលយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំព្រះករុណាមានសេចក្ដីប្រាថ្នាដើម្បីធ្វើ វិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រលោកទាំង-ឡាយដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមសង្ឃត្រួតត្រាមើលទីសម្រាប់ធ្វើ វិហារឲ្យ ។ ភិក្ខុអ្នកធ្វើវិហារ ត្រូវសូមជាគម្រប់ពីរដងផង សូមជាគម្រប់បីដង ផង ។ បើសង្ឃទាំងអស់អាចត្រួតត្រាមើលទីសម្រាប់សង់វិហារបាន ត្រូវ សង្ឃទាំងអស់ត្រួតមើល ។ បើសង្ឃទាំងអស់មិនអាចត្រួតមើលទីសម្រាប់ សង់វិហារបានទេ ហើយក្នុងទីនោះ មានភិក្ខុទាំងឡាយណាឈ្លាសប្រតិពល ដឹងទីដែលមានសេចក្ដីរង្កៀស[២] ទីដែលមិនមានសេចក្ដីរង្កៀស ទីមានឧបចារៈ ទីមិនមានឧបចារៈ ភិក្ខុសង្ឃត្រូវសូមភិក្ខុទាំងឡាយនោះហើយសន្មត ។

---

១- សំពត់សម្រាប់ពាក់ព័ទ្ធធៀងលើស្មាខាងឆ្វេង ក្រោមស្មាស្តាំ, ( ចីពរ ) ។ ២- សព្ទនេះ ប្រែមកពីបាលីថា សារម្ភ ។ សារម្ភ នេះ ប្រែថា ប្រកបដោយសេចក្ដីអន្តរាយ ថាមានហេតុទាស់ ថាប្រកបដោយសេចក្ដីរង្កៀស ឬមានសេចក្ដីរង្កៀស ។

ម្នាលភិក្ខុទាំឡាយ ភិក្ខុទាំងនោះ សង្ឃត្រូវសន្មតយ៉ាងនេះ ។ ភិក្ខុអ្នកឈ្លាស ប្រតិពល ត្រូវឲ្យសង្ឃដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះ សូមសង្ឃត្រួតមើលទីសម្រាប់សង់វិហារឲ្យ ។ បើការត្រួតមើលទីសម្រាប់សង់វិហារ មានកាលដ៏គួរដល់សង្ឃហើយ សង្ឃគប្បីសន្មតនូវភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីត្រួតមើលនូវទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ ។ ពាក្យនេះ ជាពាក្យសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមការត្រួតមើលទីសម្រាប់ធ្វើវិហារនឹងសង្ឃ ។ ព្រះសង្ឃសន្មតនូវភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ ។ ការសន្មតិនូវភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀម ( បើ ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ភិក្ខុទាំងឡាយឈ្មោះនេះផង ឈ្មោះនេះផង សង្ឃបានសន្មតហើយ ដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ ។ ( ការសន្មតិដើម្បីត្រួតមើលទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ ) គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ។ ខ្ញុំព្រះករុណាចាំទុកនូវ

ដំណើរនេះ ដោយកិរិយាស្ងៀមយ៉ាងនេះ ។

[ ២២៤ ] ភិក្ខុទាំងឡាយដែលសង្ឃបានសន្មតហើយនោះ ត្រូវទៅក្នុងទីនោះ ហើយត្រួតមើលទីដីសម្រាប់សង់វិហារ ។ ភិក្ខុទាំងនោះ ត្រូវដឹងទីដែលមានសេចក្តីរង្កៀស និងទីដែលមិនមានសេចក្តីរង្កៀស ទីមានឧបចារៈ ទីមិនមានឧបចារៈ ។ បើទីមានសេចក្តីរង្កៀស មិនមានឧបចារៈ គប្បីប្រាប់ថា លោកកុំធ្វើក្នុងទីនេះ ។ បើទីមិនមានសេចក្តីរង្កៀស មានឧបចារៈ គប្បីប្រាប់ដល់សង្ឃថា ទីមិនមានសេចក្តីរង្កៀស មានឧបចារៈ ។ ភិក្ខុអ្នកធ្វើវិហារនោះ គប្បីចូលទៅរកសង្ឃ ហើយធ្វើនូវចីវរឆៀងស្មាម្ខាង ហើយថ្វាយបង្គំជើងនៃភិក្ខុចាស់ទាំងឡាយ រួចអង្គុយច្រហោងផ្គងអញ្ជលីពោលយ៉ាងនេះថា បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំព្រះករុណាមានសេចក្តីប្រាថ្នាធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំព្រះករុណានោះ សូមសង្ឃសម្តែងទីសម្រាប់សង់វិហារឲ្យ ។ ភិក្ខុអ្នកធ្វើវិហារត្រូវសូមជាគម្រប់ពីរដងផង សូមជាគម្រប់បីដងផង ។ ភិក្ខុអ្នកឈ្លាសប្រតិពលត្រូវឲ្យសង្ឃដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមឲ្យសង្ឃសម្តែងទីសម្រាប់សង់វិហារឲ្យ ។ បើការសម្តែងទីសម្រាប់សង់វិហារ មានកាលដ៏គួរដល់សង្ឃហើយ សង្ឃគប្បីសម្តែងទីសម្រាប់ធ្វើវិហាររបស់ភិក្ខុឈ្មោះនេះ ។ ពាក្យនេះជាពាក្យសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់

ពាក្យខ្ញុំ ភិក្ខុឈ្មោះនេះនេះចង់ធ្វើវិហារធំ មានទាយកជាម្ចាស់ ចំពោះជាទីនៅរបស់ខ្លួន ភិក្ខុនោះសូមសង្ឃសម្តែងទីសម្រាប់ធ្វើវិហារឲ្យ ។ ព្រះសង្ឃសម្តែងទីសម្រាប់ធ្វើវិហារដល់ភិក្ខុឈ្មោះនេះ ។ ការដែលសង្ឃសម្តែងទីសម្រាប់ធ្វើវិហាររបស់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀម ( បើ ) មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោលឡើង ។ ទីសម្រាប់សង់វិហាររបស់ភិក្ខុឈ្មោះនេះ សង្ឃបានសម្តែងហើយ ។ ការសម្តែងទីសម្រាប់សង់វិហារនេះ គួរដល់សង្ឃ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ។ ខ្ញុំព្រះករុណាចាំទុកនូវដំណើរនេះ ដោយកិរិយាស្ងៀមយ៉ាងនេះ ។

[ ២២៥ ] ទីដែលហៅថា ប្រកបដោយសេចក្តីរង្កៀស ( នោះ ) គឺទីជាលំនៅនៃពួកស្រមោចក្រហមក្តី ជាលំនៅនៃពួកកណ្តៀរក្តី ជាលំនៅនៃពួកកណ្តុរក្តី ជាលំនៅនៃពួកពស់ក្តី ជាលំនៅនៃពួកខ្ទួយក្តី ជាលំនៅនៃពួកខ្អែបក្តី ជាលំនៅនៃពួកដំរីក្តី ជាលំនៅនៃពួកសេះក្តី ជាលំនៅនៃពួកខ្លាធំក្តី ជាលំនៅនៃពួកខ្លាដំបងក្តី ជាលំនៅនៃពួកខ្លាឃ្មុំក្តី ជាលំនៅនៃពួកខ្លារខិន[១]ក្តី ជាលំនៅនៃពួកសត្វតិរច្ឆានឯណានីមួយក្តី ទីសម្រាប់ដាំបុព្វណ្ណជាតិក្តី ទីសម្រាប់ដាំអបរណ្ណជាតិក្តី កន្លែងសម្រាប់សម្លាប់ចោរក្តី កន្លែងសម្រាប់ផ្ចាលទោសក្តី កន្លែងព្រៃស្មសានក្តី កន្លែងឱទ្យានក្តី កន្លែងស្រែស្តេចក្តី កន្លែងរោងដំរីក្តី កន្លែងរោងសេះក្តី កន្លែងសម្រាប់ឃុំខាំងមនុស្សទោសក្តី កន្លែង

---

១- តរច្ឆ ជូនប្រែថា ខ្លាព្រៃ ។

រោងសុរាក្តី កន្លែងផ្ទះលក់សាច់ក្តី កន្លែងជាច្រកល្ហកក្តី កន្លែងវាលសម្រាប់លេងក្តី កន្លែងរោងប្រជុំនិយាយក្តី កន្លែងផ្លូវជាទីដើរទៅមកក្តី ទីទាំងប៉ុន្មាននេះ ហៅថា ទីប្រកបដោយសេចក្តីវង្វៀស ។

[ ២២៦ ] ទីដែលហៅថា មិនមានឧបចារៈ ( នោះ ) គឺទីដែលរទេះគេទឹមស្រេចហើយបត់មិនបាន ឬបន្ទិលបង្អោនជុំវិញមិនបាន ទីទាំងនេះហៅថា ទីមិនមានឧបចារៈ ។

[ ២២៧ ] ទីដែលហៅថា មិនមានសេចក្តីវង្វៀស ( នោះ ) គឺទីដែលមិនមែនជាលំនៅនៃពួកស្រមោចក្រហមក្តី ។បេ។ ទីមិនមែនជាផ្លូវដែលគេដើរទៅមកក្តី ទីទាំងនេះ ហៅថា ទីមិនមានសេចក្តីវង្វៀស ។

[ ២២៨ ] ទីដែលហៅថា មានឧបចារៈ ( នោះ ) គឺទីដែលរទេះគេទឹមស្រេចហើយបត់បាន ឬបន្ទិលបង្អោនជុំវិញបាន ទីទាំងនេះ ហៅថា ទីមានឧបចារៈ ។

[ ២២៩ ] វិហារដែលមានទាយកជាម្ចាស់ តថាគតហៅថា វិហារធំ ។ ទីដែលគេលាបខាងក្នុងក្តី លាបខាងក្រៅក្តី លាបទាំងខាងក្នុង ទាំងខាងក្រៅក្តី ហៅថា វិហារ ។ ត្រង់ពាក្យថា គប្បីឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ។ ត្រង់ពាក្យថា ឬមិននាំភិក្ខុទាំងឡាយទៅដើម្បីសម្តែងទីឲ្យ សេចក្តីថា ភិក្ខុអ្នកធ្វើវិហារមិនឲ្យភិក្ខុទាំងឡាយសម្តែងទីសម្រាប់សង់វិហារ ដោយកម្មមានញត្តិជាគម្រប់ពីរ ហើយធ្វើខ្លួនឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគនៅបាយអ ១ ដុំទៀតនឹងសម្រេច ត្រូវអាបត្តិថុល្លច្ច័យ លុះយកដុំនោះបូក

សម្រេច ត្រូវអាបត្តិសង្ឃាទិសេស ។ ត្រង់ពាក្យថា សង្ឃាទិសេស មានសេចក្តីអធិប្បាយក្នុងសង្ឃាទិសេសសិក្ខាបទទី ១ រួចហើយ ។

[ ២៣០ ] ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសម្តែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស ។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសម្តែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស តែជាទីមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសម្តែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស តែមិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។ ភិក្ខុធ្វើវិហារដែលសង្ឃមិនបានសម្តែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស មានឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសម្តែងទីឲ្យ ជាទីប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសម្តែងទីឲ្យ ជាទីប្រកបដោយសេចក្តីរង្កៀស តែមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសម្តែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស តែមិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុធ្វើវិហារដែលសង្ឃបានសម្តែងទីឲ្យ ជាទីមិនមានសេចក្តីរង្កៀស មានឧបចារៈ មិនត្រូវអាបត្តិឡើយ ។

[ ២៣១ ] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសម្តែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារៈ ( ភិក្ខុអ្នកប្រើនោះ ) ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារៈ

ត្រូវអាបត្តិសង្ឃាទិសេស និងអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តីរង្កៀស មិនមានឧបចារៈ ត្រូវទុក្កដ និងសង្ឃាទិសេស ។បេ។ មិនមានសេចក្តីរង្កៀស តែមានឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃបានសម្តែងទីឲ្យ ជាទីប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តីរង្កៀស មានឧបចារៈ មិនត្រូវអាបត្តិឡើយ ។

[ ២៣២ ] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយ ចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែមិនបានពន្យល់ថា វិហារនោះគួរជាវិហារដែលសង្ឃសម្តែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានទីឧបចារៈផង ។ ភិក្ខុទាំង-ឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះដែលសង្ឃមិនបានសម្តែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងសង្ឃា-ទិសេស ។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។ បេ ។ មិនមានសេចក្តីរង្កៀស មានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយ ចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែមិនបានពន្យល់ថា វិហារនោះ គួរជាវិហារដែលសង្ឃសម្តែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានឧបចារៈ

ផង ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃបានសម្តែងទីឲ្យ ប្រកប ដោយសេចក្តីរង្កៀស មិនមានឧបចារៈ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ប្រកប ដោយសេចក្តីរង្កៀស តែមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមាន សេចក្តីរង្កៀស តែមិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តី រង្កៀស មានទីឧបចារៈ មិនត្រូវអាបត្តិឡើយ ។

[ ២៣៣ ] ភិក្ខុបន្ទាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយ ចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបានពន្យល់ថា វិហារនោះ គួរជាវិហារមានសង្ឃ សម្តែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានឧបចារៈផង ។ ភិក្ខុទាំង-ឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ដែលសង្ឃមិនបានសម្តែងទីឲ្យ ប្រកបដោយ សេចក្តីរង្កៀស មិនមានឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា បានឮថា វិហារគេ ធ្វើឲ្យអាត្មាអញ សង្ឃមិនបានសម្តែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិន មានឧបចារៈ ។ ភិក្ខុនោះត្រូវទៅដោយខ្លួនឯងក្តី បញ្ជូនបម្រើឲ្យទៅក្តី ដោយ ពាក្យថា វិហារនោះ គួរជាវិហារដែលមានសង្ឃសម្តែងទីឲ្យផង មិនមាន សេចក្តីរង្កៀសផង មានទីឧបចារៈផង ។ បើភិក្ខុមិនបានទៅដោយខ្លួនឯងក្តី មិនបញ្ជូនបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។បេ។ វិហារនោះគួរជាវិហារដែល សង្ឃសម្តែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង ។បេ។ វិហារនោះ គួរជា វិហារដែលសង្ឃបានសម្តែងទីឲ្យផង មានឧបចារៈផង ។បេ។ វិហារនោះ គួរជាវិហារដែលសង្ឃសម្តែងទីឲ្យផង ។ បើភិក្ខុមិនទៅដោយខ្លួនឯងក្តី មិន បញ្ជូនបម្រើឲ្យទៅក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបន្ទាប់ភិក្ខុផងគ្នាថា អ្នកទាំង-

ទ្បាយ ចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែភិក្ខុនោះបានពន្យល់ថា វិហារនោះគួរជាវិហារដែលសង្ឃបានសម្ដែងទីឲ្យផង មិនមានសេចក្ដីរង្កៀសផង មានទីឧបចារៈផង ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសម្ដែងទីឲ្យ តែប្រកបដោយសេចក្ដីរង្កៀស មិនមានទីឧបចារៈ ។ ភិក្ខុនោះឮដំណឹងថា បានឮថា គេធ្វើវិហារឲ្យអាត្មាអញ ជាវិហារដែលសង្ឃបានសម្ដែងទីឲ្យ តែប្រកបដោយសេចក្ដីរង្កៀស មិនមានទីឧបចារៈ ។ ភិក្ខុនោះគប្បីទៅដោយខ្លួនឯង ឬប្រើបម្រើឲ្យទៅដោយពាក្យថា វិហារនោះគួរជាវិហារមិនមានសេចក្ដីរង្កៀសផង មានទីឧបចារៈផង ។បេ។ គួរជាវិហារមិនមានសេចក្ដីរង្កៀស ។ បេ ។ គួរជាវិហារមានទីឧបចារៈ ។ បេ ។ មិនត្រូវអាបត្តិឡើយ ។

[ ២៣៤ ] ភិក្ខុបង្គាប់ពួកភិក្ខុផងគ្នាថា អ្នកទាំងឡាយ ចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបានពន្យល់ថា វិហារនោះគួរជាវិហារដែលសង្ឃសម្ដែងទីឲ្យផង មិនប្រកបដោយសេចក្ដីរង្កៀសផង មានទីឧបចារៈផង ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃមិនបានសម្ដែងទីឲ្យ ប្រកបដោយសេចក្ដីរង្កៀស មិនមានទីឧបចារៈ ( ភិក្ខុទាំងឡាយអ្នកធ្វើ ) ត្រូវអាបត្តិទុក្កដបី ។ បេ ។ ប្រកបដោយសេចក្ដីរង្កៀស តែមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។បេ។ មិនមានសេចក្ដីរង្កៀស តែមិនមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។ បេ ។ មិនមានសេចក្ដីរង្កៀស មានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបង្គាប់ភិក្ខុផង

គ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ តែបានពន្យល់ថា វិហារនោះ គួរជាវិហារមានសង្ឃសម្តែងទីឲ្យផង មិនមានសេចក្តីរង្កៀសផង មានទីឧបចារៈផង ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសម្តែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តីរង្កៀស មិនមានទីឧបចារៈ ពួកភិក្ខុអ្នកធ្វើ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តីរង្កៀស មានទីឧបចារៈ មិនត្រូវអាបត្តិឡើយ ។

[ ២៣៥ ] ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយ ចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ ។ ភិក្ខុទាំងឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃមិនបានសម្តែងទីឲ្យ ប្រកបដោយសេចក្តីរង្កៀស មិនមានទីឧបចារៈ បើវិហារនោះមិនទាន់ហើយ ស្រាប់តែភិក្ខុនោះមកដល់ ។ ភិក្ខុនោះគប្បីឲ្យវិហារនោះទៅភិក្ខុដទៃ ឬរុះរើវិហារនោះធ្វើជាថ្មីទៀត។ បើភិក្ខុនោះមិនឲ្យវិហារនោះដល់ភិក្ខុដទៃទេ ឬមិនឲ្យគេរុះរើធ្វើជាថ្មីទៀតទេ ត្រូវអាបត្តិទុក្កដពីរ និងសង្ឃាទិសេស ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមានទីឧបចារៈ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។បេ។ មិនប្រកបដោយសេចក្តីរង្កៀស តែមិនមានឧបចារៈ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។ បេ ។ មិនមានសេចក្តីរង្កៀស មានទីឧបចារៈ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុបង្គាប់ភិក្ខុផងគ្នាថា អ្នកទាំងឡាយចូរធ្វើវិហារឲ្យខ្ញុំ ហើយចៀសចេញទៅ ។ ភិក្ខុទាំង-

ឡាយក៏ធ្វើវិហារឲ្យភិក្ខុនោះ ជាវិហារដែលសង្ឃបានសម្តែងទីឲ្យ តែប្រកប ដោយសេចក្តីរង្កៀស មិនមានទីឧបចារៈ ។ បើភិក្ខុនោះមកដល់ក្នុងពេលដែល វិហារមិនទាន់ហើយ ។ ភិក្ខុនោះគប្បីឲ្យវិហារនោះទៅភិក្ខុដទៃ ឬរុះរើធ្វើជាថ្មី ទៀត ។ បើភិក្ខុនោះមិនឲ្យវិហារនោះទៅភិក្ខុដទៃទេ ឬ មិនឲ្យគេរុះរើធ្វើជាថ្មី ទៀតទេ ត្រូវអាបត្តិទុក្កដពីរ ។បេ។ ប្រកបដោយសេចក្តីរង្កៀស តែមាន ទីឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តីរង្កៀស តែមិនមានទី ឧបចារៈ ត្រូវអាបត្តិទុក្កដ ។បេ។ មិនមានសេចក្តីរង្កៀស មានទីឧបចារៈ មិនត្រូវអាបត្តិឡើយ ។

[ ២៣៦ ] ភិក្ខុធ្វើ ( វិហារ ) ដោយខ្លួនឯងមិនទាន់ហើយ ( គ្រា ក្រោយ ) ក៏ធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុធ្វើ ( វិហារ ) ដោយខ្លួនឯង មិនទាន់ហើយ ឲ្យអ្នកដទៃធ្វើបង្ហើយ ត្រូវអាបត្តិ សង្ឃាទិសេស ។ អ្នកដទៃធ្វើ ( វិហារ ) មិនទាន់ហើយ ភិក្ខុ ( ម្ចាស់វិហារ ) ធ្វើបង្ហើយដោយខ្លួនឯង ត្រូវអាបត្តិសង្ឃាទិសេស ។ អ្នកដទៃធ្វើ ( វិហារ ) មិនទាន់ហើយ ភិក្ខុឲ្យអ្នកដទៃធ្វើបង្ហើយ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ២៣៧ ] ដំណើរដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើលេណ ( ទី សម្រាប់ជ្រកល្មមនៅបាន ) គុហា ( ទីបិទបាំងល្មមនៅបាន ) កុដិស្មៅ និង កុដិសម្រាប់ភិក្ខុដទៃមានឧបជ្ឈាយ៍ជាដើម ម្យ៉ាងទៀត ដំណើរដែលមិនត្រូវ អាបត្តិដល់ភិក្ខុអ្នកធ្វើសេនាសនៈ មានរោងឧបោសថជាដើម និងភិក្ខុឆ្កួត និង ភិក្ខុដើមបញ្ញត្តិ វៀរលែងតែធ្វើទីសម្រាប់នៅរបស់ខ្លួនចេញ ។

សង្ឃាទិសេសទី ៧ ចប់

## អដ្ឋកថា
## វិហារការសិក្ខាបទវណ្ណនា

[ ៧២១ ] វិហារការសិក្ខាបទ បទថា **តេន សមយេន** ជាដើម ខ្ញុំនឹងពោល តទៅថា

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវិហារការសិក្ខាបទនោះ ដូចតទៅនេះ បទថា **កោសម្ពិយំ** បានដល់ ជិតនគរដែលមានឈ្មោះយ៉ាងនេះ ។

បទថា **ឃោសិតារាមេ** បានដល់ អារាមរបស់ឃោសិតសេដ្ឋី ។ បានឮថា វិហារនោះ សេដ្ឋីឈ្មោះឃោសិតឲ្យធ្វើ ព្រោះដូច្នោះ ទើបហៅថា ឃោសិតារាម ។

បទថា **ឆន្នស្ស** បានដល់ ឆន្នភិក្ខុដែលធ្លាប់ជាឧបដ្ឋាក ក្នុងវេលាព្រះពុទ្ធអង្គនៅជាព្រះពោធិសត្វ ។

បទថា **វិហារវត្ថុំ ភន្តេ ជានាហិ** សេចក្តីថា បពិត្រលោកដ៏ចម្រើន សូមលោកពិនិត្យមើលទីកន្លែងធ្វើវិហារចុះ ។ ក្នុងបទថា **វិហារវត្ថុំ** នេះ ដែលឈ្មោះថា វិហារ មិនមែនវិហារទាំងមូល គឺអាវាស ( លំនៅ ) មួយខ្នងប៉ុណ្ណោះ ។ ដោយហេតុនោះឯង ទើបគហបតិឧបដ្ឋាករបស់ឆន្នភិក្ខុពោលថា ខ្ញុំនឹងធ្វើវិហារប្រគេនលោកម្ចាស់ ។

ក្នុងពាក្យថា **ចេតិយរុក្ខំ** នេះ មានវិនិច្ឆ័យដូច្នេះ ដែលឈ្មោះថា ចេតិយ ព្រោះអត្ថថា ដែលពពួកជនធ្វើការគោរព ។ បទថា **ចេតិយរុក្ខំ** នេះ ជាឈ្មោះនៃទេវស្ថានទាំងឡាយ ដែលគួរដល់ការបូជា ។ ដើមឈើ

ដែលសត្វលោកសន្មតថា ចេតិយ ឈ្មោះថា រុក្ខចេតិយ ។ ដែលអ្នកស្រុកបូជាហើយក្តី ជាទីបូជារបស់អ្នកស្រុកក្តី ព្រោះដូច្នោះ ទើបដើមឈើនោះឈ្មោះថា **គាមបូជិត** ( ដែលអ្នកស្រុកនាំគ្នាបូជា ) ។ ក្នុងបទដ៏សេស ក៏មានន័យដូច្នេះ ។

ម្យ៉ាងទៀត ក្នុងជនបទ និងរដ្ឋនេះ ចំណែកមួយក្នុងរដ្ឋសីមានៃព្រះរាជាមួយអង្គ គប្បីជ្រាបថា ជនបទ ។ ដែនទាំងមូលគប្បីជ្រាបថា រដ្ឋ ។ ពិតហើយ ក្នុងកាលខ្លះ អ្នកដែនទាំងមូលធ្វើការបូជាដើមឈើនោះ ដោយហេតុនោះ ទើបលោកពោលថា អ្នកដែននាំគ្នាបូជាហើយ ។

ដោយបទថា **ឯកិន្ទ្រិយំ** នេះ ពួកអ្នកស្រុកពោលសំដៅយកកាយិន្ទ្រិយ ។ បទថា **ជីវសញ្ញិនោ** គឺ មានការសម្គាល់ថា ជាសត្វ ។

# អធិប្បាយ
# សិក្ខាបទវិភង្គនៃវិហារការសិក្ខាបទ

[ ២២២ ] បទថា **មហល្លកំ** សេចក្តីថា ទីវិហារធំជាងកុដិ ដែលសូមខ្លួនឯង ព្រោះជាទីមានម្ចាស់ មានហើយដល់វិហារនោះ ព្រោះហេតុនោះទើបឈ្មោះថា **មហល្លក** ។ម្យ៉ាងទៀត ព្រោះឲ្យសង្ឃសម្តែងទីឲ្យហើយសូម្បី ធ្វើឲ្យលើសប្រមាណក៏គួរ ព្រោះដូច្នោះ ទើបវិហារនោះ ឈ្មោះថា **មហល្លក** ។ ព្រោះជារបស់ធំលើសប្រមាណផង វិហារនោះធំផង ។ ព្រោះវិហារនោះ មានការធំជាងប្រមាណនោះបាន ព្រោះជារបស់មានម្ចាស់នោះឯង ដូច្នោះ ដើម្បីសម្តែងអត្ថនោះ ទើបព្រះឧបាលីពោលបទភាជនីយ៍ថា វិហារមានម្ចាស់ ហៅថា វិហារធំ ។

ពាក្យដ៏សេសទាំងអស់ មួយអន្លើដោយសមុដ្ឋានជាដើម អ្នកសិក្សាគប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងកុដិការសិក្ខាបទនោះឯង ។ ពិតហើយ ក្នុងសិក្ខាបទនេះ មានសេចក្តីប្លែកគ្នាត្រឹមតែមានម្ចាស់ ការមិនមានសមុដ្ឋានចាកការធ្វើ និងការមិនមានកំណត់ប្រមាណប៉ុណ្ណោះ ហើយចតុក្កៈក៏ថយទៅ ព្រោះមិនមានកំណត់ប្រមាណ ដូច្នេះឯង ។

វិហារការសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ៨

[ ២៣៨ ] សម័យនោះ ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះទព្វមល្លបុត្ត[១] ដ៏មានអាយុ មានអាយុ ៧ ឆ្នាំ អំពីកំណើត បានសម្រេចព្រះអរហត្តផល គុណជាតឯណានីមួយដែលសាវកត្រូវដល់ គុណជាតទាំងអស់ ( នោះ ) ក៏ព្រះទព្វមល្លបុត្តនោះ បានដល់ដោយលំដាប់ហើយ កិច្ចអ្វីបន្តិចបន្តួច ( សោឡសកិច្ច ) ដែលព្រះទព្វមល្លបុត្រនោះគប្បីធ្វើតទៅទៀត ឬកិច្ចដែលព្រះទព្វមល្លបុត្របានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យបម្រើនឡើងទៅទៀត ក៏មិនមានឡើយ ។

[ ២៣៩ ] លំដាប់នោះ ព្រះទព្វមល្លបុត្តដ៏មានអាយុ ទៅកាន់ទីស្ងាត់សម្ងំនៅក្នុងកម្មដ្ឋាន មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា អញកើតឡើងបាន ៧ ឆ្នាំ បានសម្រេចអរហត្តផល គុណជាតឯណានីមួយដែលសាវកត្រូវដល់គុណជាតទាំងអស់ ( នោះ ) ក៏អញបានដល់ដោយលំដាប់ហើយ ម្យ៉ាងទៀត កិច្ចអ្វីនីមួយ ដែលអញត្រូវធ្វើតទៅទៀត ឬកិច្ចដែលអញបានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យបម្រើនឡើងទៅទៀតក៏មិនមានឡើយ ( បើដូច្នោះ ) អញគប្បីធ្វើការខ្វល់ខ្វាយបម្រើដល់សង្ឃឬអ្វីហ្ន ។ កាលនោះ ព្រះទព្វមល្លបុត្តដ៏មានអាយុបានត្រិះរិះដូច្នេះថា បើដូច្នោះ មានតែអញត្រូវរៀបចំ

---

១- ព្រះទព្វត្ថេរ ជាបុត្រស្តេចមល្ល ហៅដោយរួបរួមថា ទព្វមល្លបុត្រ ។

សេនាសនៈផង ត្រូវចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ចេញអំពីទីសម្ងំក្នុងកម្មដ្ឋាន នៅពេលសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងពេលនោះ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ លុះព្រះទព្វមល្លបុត្រដ៏មានអាយុ គង់ក្នុងទីដ៏សមគួរមួយហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទៅក្នុងទីស្ងាត់ សម្ងំនៅក្នុងកម្មដ្ឋានក្នុងថ្ងៃនេះ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា អាត្មាឯងកើតបាន ៧ ឆ្នាំ បានសម្រេចអរហត្តផល គុណជាតឯណានីមួយដែលសាវកត្រូវដល់គុណជាតទាំងអស់ ( នោះ ) ក៏អាត្មាបានដល់ដោយលំដាប់ហើយ ម្យ៉ាងទៀត កិច្ចអ្វីនីមួយ ដែលអាត្មាគប្បីធ្វើតទៅទៀត ឬកិច្ចដែលអាត្មាបានធ្វើរួចហើយ នឹងធ្វើកិច្ចនោះឲ្យចម្រើនឡើងតទៅទៀត ក៏មិនមានឡើយ ( បើដូច្នោះ ) អាត្មាគប្បីធ្វើការខ្វល់ខ្វាយបម្រើដល់សង្ឃ ឬអ្វីហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីត្រិះរិះនេះកើតមានដល់ខ្ញុំព្រះអង្គនោះថា បើដូច្នោះ មានតែអាត្មាត្រូវរៀបចំសេនាសនៈផង ត្រូវចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់រៀបចំសេនាសនៈផង ចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃ ។ ព្រះបរមគ្រូទ្រង់ត្រាស់ថា ម្នាលទព្វ ប្រពៃណាស់ហើយៗ បើដូច្នោះ អ្នកចូររៀបចំសេនាសនៈផង ចូរចាត់ចែងចង្ហាន់ទាំងឡាយផង ដល់ព្រះសង្ឃចុះ ។ ព្រះទព្វមល្លបុត្តដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគ ដោយ

ពាក្យថា ករុណាព្រះអង្គ ។

[ ២៤០ ] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម្មីកថាហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរសម្មតិទព្វមល្លបុត្រឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផងចុះ ។ ម្នាលភិក្ខុទាំងឡាយ ទព្វភិក្ខុត្រូវសង្ឃសម្មតិយ៉ាងនេះ មុនដំបូងត្រូវសង្ឃអង្វរទព្វភិក្ខុ លុះអង្វររួចហើយ ត្រូវភិក្ខុ ១ រូបដែលឆ្លាសវាងវៃផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ បើការសម្មតិ មានកាលដ៏គួរដល់សង្ឃហើយ សូមព្រះសង្ឃសម្មតិទព្វមល្លបុត្រដ៏មានអាយុ ឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផង ។ ពាក្យនេះជាពាក្យសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ព្រះសង្ឃសម្មតិទព្វមល្លបុត្រដ៏មានអាយុ ឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផង ។ ការសម្មតិទព្វមល្លបុត្រដ៏មានអាយុឲ្យជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផង គួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម ( បើ ) មិនគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវនិយាយឡើង ។ ទព្វមល្លបុត្រដ៏មានអាយុ ជាអ្នករៀបចំសេនាសនៈផង ជាអ្នកចាត់ចែងចង្ហាន់ផង សង្ឃបានសន្មតរួចហើយ ។ ការសម្មតិនេះ គួរដល់សង្ឃ ព្រោះហេតុនោះ ព្រះសង្ឃទើបស្ងៀម ។ ខ្ញុំព្រះករុណា ចាំទុកនូវសេចក្តីស្ងៀមរបស់សង្ឃនេះយ៉ាងនេះ ។

[ ២៤១ ] ទព្វមល្លបុត្រដ៏មានអាយុ ដែលសង្ឃបានសន្មតរួចហើយ ក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយដែលមានគុណធម៌ស្មើគ្នា ភិក្ខុទាំងឡាយឯណា ជាអ្នករៀនព្រះសូត្រ ទព្វមល្លបុត្រដ៏មានអាយុ ក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយនោះដោយគិតថា ភិក្ខុទាំងឡាយនោះនឹងរួបរួមគ្នាស្វាធ្យាយនូវព្រះសូត្រ ។ ភិក្ខុទាំងឡាយឯណា ជាអ្នកទ្រទ្រង់វិន័យ ព្រះទព្វមល្លបុត្រក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នកទ្រទ្រង់វិន័យទាំងឡាយនោះ នឹងវិនិច្ឆ័យវិន័យជាមួយគ្នាទៅវិញទៅមក ភិក្ខុទាំងឡាយឯណាជាអ្នករៀនព្រះអភិធម្ម ព្រះទព្វមល្លបុត្រក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នករៀនព្រះអភិធម្មនឹងសាកសួរព្រះអភិធម្មទៅវិញទៅមក ភិក្ខុទាំងឡាយឯណាជាអ្នកចម្រើនឈាន ព្រះទព្វមល្លបុត្រក៏រៀបចំសេនាសនក្នុងទីជាមួយគ្នា សម្រាប់ភិក្ខុទាំងឡាយនោះ ដោយគិតថា ភិក្ខុអ្នកចម្រើនឈានទាំងឡាយនោះ មិនបៀតបៀនគ្នាទៅវិញទៅមក ភិក្ខុទាំងឡាយឯណាជាអ្នកពោលតិរច្ឆានកថា[១] ច្រើនដោយការថ្នមខ្លួន ព្រះទព្វមល្លបុត្តក៏រៀបចំសេនាសនៈជាមួយគ្នា ដើម្បីភិក្ខុទាំងឡាយនោះ ដោយគិតថា លោកដ៏មានអាយុទាំងឡាយនេះ នឹងនៅទល់ក្លី ដោយពោលតិរច្ឆានកថានេះ ភិក្ខុទាំងឡាយឯណាមកដល់ក្នុងពេលដែលងងឹត ព្រះទព្វមល្លបុត្ត

១- ពាក្យពោលដូចជាពាក្យតិរច្ឆាន គឺនិយាយពាក្យឥតប្រយោជន៍ ជាពាក្យក្រៅធម៌វិន័យ ។

ក៏ចូលកាន់តេជោធាតុ[១] ហើយរៀបចំសេនាសនៈដោយពន្លឺនៃតេជោធាតុ ដើម្បីភិក្ខុទាំងឡាយនោះ ។ ជួនកាលមានភិក្ខុទាំងឡាយក្លែងក្លាយ ហើយមកក្នុងពេលងងឹត ដោយគិតថា យើងទាំងឡាយ នឹងឃើញឥទ្ធិបាដិហារិយ៍របស់ទព្វមល្លបុត្រដ៏មានអាយុ ។ ភិក្ខុទាំងនោះ ចូលទៅរកព្រះទព្វមល្លបុត្រដ៏មានអាយុ ហើយពោលយ៉ាងនេះថា ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈដើម្បីយើងទាំងឡាយ ។ ព្រះទព្វមល្លបុត្រដ៏មានអាយុ ក៏ពោលនូវពាក្យយ៉ាងនេះនឹងភិក្ខុទាំងឡាយនោះថា លោកទាំងឡាយដ៏មានអាយុចង់បានក្នុងទីណា ខ្ញុំត្រូវរៀបចំក្នុងទីដូចម្តេច ។ ភិក្ខុទាំងឡាយនោះ ( ខ្លះ ) ក៏ក្លែងចង្អុលទៅរកទីឆ្ងាយដោយពាក្យថា ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈលើភ្នំគិជ្ឈកូដ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោ ទព្វ លោកចូររៀបចំសេនាសនៈជិតជ្រោះសម្រាប់ទម្លាក់ចោរ ដើម្បីយើងទាំង-ឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈលើកាឡសិលានាខាងភ្នំឥសិគិលិ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងសត្តបណ្ណគុហា នាខាងភ្នំវេភារ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈទៀបញកភ្នំឈ្មោះសប្ប-សោណ្ឌិកក្នុងព្រៃត្រជាក់ ( ព្រៃជាំ ) ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈទៀបច្រកភ្នំឈ្មោះគោមដ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈទៀបច្រក

---

១- ព្រះទព្វមល្លបុត្តចូលឈានក្នុងពេលនោះ យកភ្លើងជាអារម្មណ៍ ឬជាកសិណ ។

ភ្នំឈ្មោះគិជ្ឈកូដ ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈ ទៀបប្រកភ្នំឈ្មោះកបោត ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងតបោទារាម ដើម្បីយើងទាំង-ឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងជីវកម្ពវ័ន ដើម្បីយើងទាំងឡាយចុះ ម្នាលអាវុសោទព្វ លោកចូររៀបចំសេនាសនៈក្នុងព្រៃឈ្មោះមទ្ទកុច្ឆិ ជាទីឲ្យអភ័យដល់ម្រឹគ ដើម្បីយើងទាំងឡាយចុះ ។ ព្រះទព្វមល្លបុត្រដ៏មានអាយុ ក៏ចូលកាន់តេជោធាតុ ( ចម្រើនតេជោកសិណ ) ហើយមានម្រាមដៃដ៏ភ្លឺរុងរឿង ដើរទៅក្នុងទីខាងមុខៗ ។ ភិក្ខុទាំងឡាយនោះក៏ដើរទៅអំពីខាងក្រោយៗ នៃព្រះទព្វមល្លបុត្រដោយពន្លឺនោះឯង ។ ព្រះទព្វមល្លបុត្រដ៏មានអាយុរៀបចំ ក្រាលសេនាសនៈដល់ភិក្ខុទាំងឡាយនោះដោយរបៀបយ៉ាងនេះ គឺនេះគ្រែ នេះតាំង នេះពូក នេះខ្នើយ នេះទីសម្រាប់ដោះទុក្ខសត្វធំ នេះទីសម្រាប់ដោះទុក្ខសត្វតូច នេះទឹកសម្រាប់ផឹក នេះទឹកសម្រាប់ប្រើប្រាស់ នេះឈើច្រត់ នេះទីកតិកសញ្ញារបស់សង្ឃ ពេលនេះត្រូវអ្នកទាំងឡាយចូល ពេលនេះ ត្រូវអ្នកទាំងឡាយចេញ ។ ព្រះទព្វមល្ល-បុត្រដ៏មានអាយុ រៀបចំសេនាសនៈយ៉ាងនេះដល់ភិក្ខុទាំងឡាយនោះ ហើយក៏និមន្តត្រឡប់មកវត្តវេឡុវ័នវិញ ។

[ ២៤២ ] សម័យនោះឯង មេត្តិយភិក្ខុ និងភុម្មជក[1] ភិក្ខុទាំងឡាយ

---

១- មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងពីររូបនេះ ជាមេពួកមួយៗ រាប់បញ្ចូលក្នុងឆព្វគ្គិយភិក្ខុ ប៉ុន្តែភិក្ខុពីររូបនេះ ជាមនុស្សរឹងត្អឹង ក្មៀវក្លាជាងគេ ។

ជាអ្នកបួសថ្មីផង មានបុណ្យតិចផង សេនាសនៈទាំងឡាយឯណាដែលថោកទាប ជាសេនាសនៈរបស់សង្ឃ សេនាសនៈទាំងឡាយនោះឯង បានមកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ទាំងភត្តណាដែលថោកទាប ក៏តែងបានមកភិក្ខុទាំងពីររូបនោះដែរ ។ សម័យនោះឯង មនុស្សទាំងឡាយ ក្នុងក្រុងរាជគ្រឹះ ចង់ឲ្យសប្បិផង ប្រេងផង សម្ពុឧត្តរិភង្គ[១] ផង ដែលគេតាក់តែងដើម្បីភិក្ខុទាំងឡាយជាថេរៈ តែមនុស្សទាំងឡាយនោះ ឲ្យបាយចុងអង្ករមានទឹកជ្រក់ជាគម្រប់ពីរ ដែលខ្លួនប្រារព្ធហើយយ៉ាងណាជាប្រក្រតី ដល់មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ឆាន់ចង្ហាន់រួចហើយ ក៏សួរភិក្ខុទាំងឡាយជាថេរៈថា ម្នាលអាវុសោទាំងឡាយ ក្នុងរោងភត្តរបស់ពួកលោកមានអ្វីខ្លះ ម្នាលអាវុសោទាំងឡាយ វត្ថុអ្វីខ្លះ មានក្នុងរោងភត្តរបស់លោកទាំងឡាយ ។ ព្រះថេរៈទាំងឡាយពួកខ្លះ ប្រាប់យ៉ាងនេះថា ម្នាលអាវុសោ ក្នុងរោងយើងមានសប្បិ ក្នុងរោងយើងមានប្រេង ក្នុងរោងយើងមានសម្ពុឧត្តរិភង្គ ។ ឯមេត្តិយភិក្ខុ និងភុម្មជកភិក្ខុនិយាយប្រាប់យ៉ាងនេះថា ម្នាលអាវុសោ យើងគ្មានវត្ថុអ្វីបន្តិចបន្តួចទេ មានតែបាយចុងអង្ករ និងទឹកជ្រក់ជាគម្រប់ពីរ តាមដំណើរដែលគេ ប្រារព្ធជាប្រក្រតីប៉ុណ្ណោះ ។

[ ២៤៣ ] សម័យនោះឯង មានគហបតី ( ម្នាក់ ) ឈ្មោះកល្យាណ-

---

១ - ប្រែតាមសព្ទថា សម្ពកាច់បង់នូវរសជាតិនៃសាច់ដ៏ក្រៃលែង ។ ជាឈ្មោះសម្លម្យ៉ាង ដែលអ្នកមជ្ឈិមបទេស ប្រើក្នុងជាន់នោះ ។

កត្តិក[១] តែងប្រគេននិច្ចភត្ត ( ក្នុងមួយថ្ងៃ ) ៤ សម្រាប់ដល់ព្រះសង្ឃ ។ គហបតីនោះ ព្រមទាំងកូនប្រពន្ធចូលទៅបម្រើអង្គាស ( ព្រះសង្ឃ ) ក្នុងរោងភត្ត ។ ភិក្ខុទាំងឡាយដទៃៗ ខ្លះសួររកបាយ ខ្លះសួររកសម្ល ខ្លះសួររកប្រេង ខ្លះសួររកសម្លឧត្តរិភង្គ ។ សម័យនោះឯង មេត្តិយ និងភុម្មជកភិក្ខុត្រូវនទទួលចង្ហាន់ក្នុងថ្ងៃស្អែករបស់គហបតីឈ្មោះកល្យាណភត្តិក ជាចង្ហាន់ដែលភត្តុទ្ទេសក[២]ភិក្ខុសម្តែងឲ្យ ។ គ្រានោះ គហបតីឈ្មោះកល្យាណភត្តិកបានទៅកាន់អារាមដោយមានកិច្ចការអ្វីមួយដែលខ្លួនត្រូវធ្វើ ។ គហបតីនោះចូលទៅរកព្រះទព្វមល្លបុត្រដ៏មានអាយុ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះទព្វមល្លបុត្រដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះទព្វមល្លបុត្រដ៏មានអាយុ បាននិយាយពន្យល់គហបតីឈ្មោះកល្យាណភត្តិកឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យខ្មីឃ្មាត ឲ្យរីករាយព្រម ដោយពាក្យដ៏ប្រកបដោយធម៌ ។ លំដាប់នោះ គហបតីឈ្មោះកល្យាណភត្តិក កាលដែលព្រះទព្វមល្លបុត្រដ៏មានអាយុ និយាយពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យខ្មីឃ្មាត ឲ្យរីករាយព្រម ដោយពាក្យដ៏ប្រកបដោយធម៌ ( ដូច្នោះ ) ពោលនូវពាក្យនេះនឹងព្រះទព្វមល្លបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ភត្តក្នុងផ្ទះរបស់យើងក្នុងថ្ងៃស្អែក លោកម្ចាស់បានចាត់ឲ្យលោកអង្គណា ។ ព្រះទព្វមល្លបុត្រឆ្លើយថា ម្នាលគហបតី ភត្តក្នុងផ្ទះរបស់អ្នក ក្នុងថ្ងៃស្អែក អាត្មា

---

១- គហបតីនេះ មានចង្ហាន់ឧត្តមប្រពៃ ឆ្ងាញ់ពិសាណាស់ ។ ២- ភិក្ខុដែលសង្ឃសន្មតឲ្យជាអ្នកសម្តែងភត្តដល់ភិក្ខុទាំងពួង ។

បានចាត់ឲ្យដល់មេត្តិយ និងភុម្មជកភិក្ខុទាំងឡាយ ។ គ្រានោះ គហបតីឈ្មោះកល្យាណភត្តិក ក៏មានសេចក្ដីអាក់អន់ចិត្ត ដោយគិតថា ចុះហេតុអ្វីបានជាភិក្ខុអាក្រក់ទាំងឡាយ នឹងត្រូវឆាន់ចង្ហាន់ក្នុងផ្ទះយើងនេះដែរ ( លុះគិតដូច្នេះហើយ ) ក៏ទៅផ្ទះបង្គាប់ទាសីថា នែហង ស្អែកត្រូវពួកលោកណាមកទទួលចង្ហាន់ ហងឯងចូរក្រាលអាសនៈក្នុងជង្រុក ហើយអង្គាសលោកទាំងនោះ ដោយបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ពីរចុះ ។ ខ្ញុំស្រីនោះទទួលស្ដាប់ពាក្យគហបតីឈ្មោះកល្យាណភត្តិកដោយពាក្យថា ចា៎ះអ្នកម្ចាស់ ។ កាលនោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយគិតគ្នាថា ម្នាលអាវុសោ ចង្ហាន់ក្នុងផ្ទះគហបតីឈ្មោះកល្យាណភត្តិក សង្ឃបានសម្ដែងឡើងដល់យើងទាំងឡាយអំពីថ្ងៃម្សិលមិញហើយ វេលាព្រឹកស្អែកគហបតីឈ្មោះកល្យាណ-ភត្តិក ព្រមទាំងកូនប្រពន្ធ នឹងចូលមកជិតបម្រើបម្រាស់អង្គាសយើង ភិក្ខុទាំងឡាយដទៃៗ ខ្លះនឹងសួររកបាយ ខ្លះនឹងសួររកសម្ល ខ្លះនឹងសួររកប្រេង ខ្លះនឹងសួររកសម្លឧត្តរិភង្គ ។ ដោយសេចក្ដីសោមនស្សនោះឯង មេត្តិយភិក្ខុ និងភុម្មជកភិក្ខុនោះ ទុកជាចង់ដេកយ៉ាងណា ក៏ដេកមិនលក់អស់មួយយប់ ។ គ្រានោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ព្រឹកឡើងក៏ស្លៀកដណ្ដប់ ហើយទ្រង់បាត្រ និងចីវរ ចូលទៅកាន់ទីលំនៅរបស់គហបតីឈ្មោះកល្យាណភត្តិក ។ ខ្ញុំស្រីនោះបានឃើញមេត្តិយភិក្ខុ និងភុម្មជកភិក្ខុតាំងពីនិមន្តមកពីចម្ងាយ លុះឃើញហើយក៏ក្រាលអាសនៈក្នុងជង្រុក ហើយបាននិយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុ ( ទាំងពីររូប ) ថា បពិត្រលោកដ៏ចម្រើន សូមលោក

ទាំងឡាយគង់ ( ក្នុងទីនេះ ) ចុះ ។ កាលនោះ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុ មានសេចក្តីត្រិះរិះថា ប្រហែលជាចង្ហាន់មិនទាន់ឆ្អិនទេដឹង បានជាគេឲ្យយើងអង្គុយក្នុងជង្រុក ( នេះ ) ។ ខ្ញុំស្រីនោះក៏លើកបាយចុងអង្ករជាគម្រប់ពីរមុខនឹងទឹកជ្រក់ ហើយនិយាយនឹងមេត្តិយភិក្ខុ និងភុម្មជកភិក្ខុក្នុងពេលនោះថា បពិត្រលោកដ៏ចម្រើន សូមលោកទាំងឡាយឆាន់ចុះ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី យើងទាំងឡាយសុទ្ធតែជាអ្នកត្រូវវេនបាននិច្ចភត្ត ។ ខ្ញុំស្រីនោះឆ្លើយថា ខ្ញុំព្រះករុណាដឹងថា លោកម្ចាស់ទាំងឡាយជាអ្នកត្រូវវេនបាននិច្ចភត្តហើយ តែថា ម្សិលមិញ គហបតីបង្គាប់ខ្ញុំព្រះករុណាថា នែហង លោកទាំងឡាយឯណា ត្រូវការដោយចង្ហាន់និមន្តមកក្នុងថ្ងៃស្អែក ហងឯងចូរក្រាលអាសនៈក្នុងជង្រុកចុះ ហើយអង្គាសលោកទាំងនោះ ដោយបាយចុងអង្ករជាគម្រប់ពីរមុខនឹងទឹកជ្រក់ ( ហេតុនោះ ) បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកឆាន់ចុះ ។ លំដាប់នោះមេត្តិយភិក្ខុ និងភុម្មជកភិក្ខុគិតគ្នាថា ម្នាលអាវុសោ កាលពីថ្ងៃម្សិល គហបតីឈ្មោះកល្យាណភត្តិក បានទៅកាន់សំណាក់ព្រះទព្វមល្លបុត្រឯអារាមយើង ប្រាកដជាព្រះទព្វមល្លបុត្រញុះញង់ក្នុងសំណាក់នៃគហបតីនោះហើយ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងនោះក៏ឆាន់ចង្ហាន់ដ៏សមគួរដល់ចិត្តមិនបាន ព្រោះតែសេចក្តីទោមនស្សនោះឯង ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆាន់ចង្ហាន់រួចហើយ ត្រឡប់ទៅអារាមក្នុងពេលនោះ ក៏រៀបទុកដាក់បាត្រ និងចីវរ ហើយអង្គុយរឹបសង្ឃាដី ខាងក្រៅខ្លោងទ្វារវត្តវេឡុវ័នអង្គុយស្ងៀម មានសេចក្តីអៀនអន់

ឱនកសំយុងមុខចុះជ្រប់ឥតមាននិយាយពីអ្វីសោះ ។

[ ២៤៤ ] គ្រានោះ មេត្តិយាភិក្ខុនីចូលទៅរកមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់សូមថ្វាយបង្គំ ។ កាលបើមេត្តិយាភិក្ខុនីនិយាយយ៉ាងនេះហើយ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតបតសោះឡើយ ។ មេត្តិយាភិក្ខុនីបាននិយាយពាក្យនេះនឹងមេត្តិយភុម្មជកភិក្ខុជាគម្រប់ពីរដង ។បេ។ ជាគម្រប់បីដងថា បពិត្រលោកម្ចាស់ទាំងឡាយ ខ្ញុំម្ចាស់សូមថ្វាយបង្គំ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុមិននិយាយតជាគម្រប់បីដងដែរ ។ ទើបមេត្តិយាភិក្ខុនីសួរថា ខ្ញុំម្ចាស់បានប្រទូស្តដល់លោកម្ចាស់រាល់អង្គដូចម្តេចខ្លះ បានជាលោកម្ចាស់រាល់អង្គមិននិយាយនឹងខ្ញុំម្ចាស់ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី បានជាយើងមិននិយាយនឹងនាង ព្រោះយើងទព្វមល្លបុត្រគេបៀតបៀន ហើយនាងឯងធ្វើព្រងើយកន្តើយ ។ មេត្តិយាភិក្ខុនីសួរថា ( បើដូច្នោះ ) លោកម្ចាស់ឲ្យខ្ញុំធ្វើដូចម្តេច ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី បើនាងចង់ឲ្យព្រះដ៏មានព្រះភាគធ្វើឲ្យទព្វមល្លបុត្រវិនាស ( នោះ ) ព្រះដ៏មានព្រះភាគ នឹងធ្វើទព្វមល្លបុត្រឲ្យវិនាសក្នុងថ្ងៃនេះពុំខាន ។ មេត្តិយាភិក្ខុនីសួរថា ចុះលោកម្ចាស់រាល់អង្គឲ្យខ្ញុំធ្វើដូចម្តេច ខ្ញុំអាចធ្វើម្តេច ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលប្អូនស្រី ចូរនាងមក ចូរនាងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅគាល់ហើយ ចូរនាងក្រាបទូលពាក្យយ៉ាងនេះនឹងព្រះដ៏មានព្រះភាគថា

បពិត្រព្រះអង្គដ៏ចម្រើន ការនេះ មិនមែនជាការបិទបាំង មិនមែនជាការសមគួរសោះឡើយ បពិត្រព្រះអង្គដ៏ចម្រើន ទិសណា ដែលមិនមានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះ ត្រឡប់ជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពវិញ ទីកន្លែងណាដែលមិនធ្លាប់មានខ្យល់ ទីកន្លែងនោះត្រឡប់ជាមានខ្យល់ទៅវិញ ដូចជាទឹកធ្លាប់ត្រជាក់ប្រែជាក្តៅ ឥឡូវ ព្រះទព្វមល្លបុត្រជាម្ចាស់លោកប្រទូស្ត[១] នឹងខ្ញុំម្ចាស់ហើយ ។ មេត្តិយាភិក្ខុនីទទួលស្តាប់ពាក្យមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ដោយពាក្យថា យ៉ាងហ្នឹងហើយលោកម្ចាស់ រួចហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយស្ថិតនៅក្នុងទីដ៏សមគួរ ។ មេត្តិយាភិក្ខុនីលុះស្ថិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ការនេះ មិនមែនជាការបិទបាំង មិនមែនជាការសមគួរសោះឡើយ បពិត្រព្រះអង្គដ៏ចម្រើន ទិសណាដែលមិនធ្លាប់មានភ័យ មិនមានចង្រៃ មិនមានឧបទ្រព ទិសនោះ ត្រឡប់ជាប្រកបដោយភ័យ ប្រកបដោយចង្រៃ ប្រកបដោយឧបទ្រពវិញ ទីកន្លែងណាដែលមិនធ្លាប់មានខ្យល់ ទីកន្លែងនោះត្រឡប់ជាមានខ្យល់ទៅវិញ ដូចជាទឹកធ្លាប់ត្រជាក់ប្រែជាក្តៅ ឥឡូវ ព្រះទព្វមល្លបុត្រជាម្ចាស់ លោកប្រទូស្តនឹងខ្ញុំព្រះអង្គហើយ ។

[ ២៨៥ ] ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់

---

១- ជាពាក្យបញ្ឆៀស សំដៅសេចក្តីថា សេពមេថុន ។

ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរបញ្ជាក់ព្រះទព្វមល្លបុត្រដ៏មានអាយុក្នុងពេលនោះថា ម្នាលទព្វៈ អ្នករឮកឃើញឬទេ នាងភិក្ខុនីនេះថាយ៉ាងណា អ្នកឯងបានធ្វើយ៉ាងនោះមែនឬទេ ។ ព្រះទព្វមល្លបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គដោយពិតហើយ ។ ព្រះដ៏មានព្រះភាគមានបន្ទូលសួរព្រះទព្វមល្លបុត្រដ៏មានអាយុជាគម្រប់ពីរដង ។បេ។ ជាគម្រប់បីដងថា ម្នាលទព្វៈ អ្នករឮកឃើញឬទេ នាងភិក្ខុនីនេះថាយ៉ាងណា អ្នកឯងបានធ្វើយ៉ាងនោះមែនឬទេ ។ ព្រះទព្វមល្លបុត្រក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គដោយពិតហើយ ។ ព្រះបរមគ្រូត្រាស់ថា ម្នាលទព្វៈ អ្នកប្រាជ្ញទាំងឡាយមិនពោលបណ្តោះបណ្តៃយ៉ាងនោះទេ បើអំពើដែលអ្នកបានធ្វើហើយ អ្នកចូរប្រាប់ថា ខ្ញុំធ្វើហើយ បើអំពើដែលអ្នកមិនបានធ្វើទេ អ្នកចូរប្រាប់ថា ខ្ញុំមិនបានធ្វើទេ ។ ព្រះទព្វមល្លបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតាំងពីដួចកើតមកសូម្បីតែយល់សប្តិសេពមេថុនធម្មក៏មិនដែលស្គាល់សោះឡើយ នឹងបាច់ពោលទៅថ្វីដល់ការរឮក ( នោះ ) ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយមកហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរឲ្យមេត្តិយាភិក្ខុនីសឹកចេញ ម្យ៉ាងទៀត អ្នកទាំង-ឡាយចូរសាកសួរភិក្ខុទាំងឡាយនេះមើល ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះហើយ ក៏ក្រោកចាកអាសនៈចូលទៅកាន់វិហារវិញ ។ ភិក្ខុទាំង-ឡាយនោះ ក៏ឲ្យមេត្តិយាភិក្ខុនីសឹកក្នុងពេលនោះ ។ ទើបមេត្តិយភិក្ខុ និង

កុម្មជកភិក្ខុនិយាយពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា ម្នាលអាវុសោ ចូរលោកកុំផ្សឹកមេត្តិយាភិក្ខុនីៗ នោះ ឥតមានកំហុសសោះទេ ( ហេតុដើមមកពី ) យើងទើងមិនសប្បាយចិត្ត ( យើង ) ចង់ឲ្យទព្វមល្លបុត្រឃ្លាតចាកសមណភេទ ទើបឲ្យមេត្តិយាភិក្ខុនីនោះប្រឹងប្រែងឡើង ។ ភិក្ខុទាំងឡាយសួរថា ម្នាលអាវុសោ អ្នកហ៊ានចោទព្រះទព្វមល្លបុត្រដ៏មានអាយុ ដោយអាបត្តិបារាជិកមិនមានមូល[១] ឬ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុឆ្លើយថា ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស និន្ទា តិះដៀលថា ចុះហេតុអ្វីបានជាមេត្តិយភិក្ខុ និងភុម្មជកភិក្ខុចោទព្រះទព្វមល្លបុត្រដ៏មានអាយុដោយអាបត្តិបារាជិកមិនមានមូល ( ដូច្នោះ ) ។ ទើបភិក្ខុទាំងឡាយនោះក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយសួរចំពោះមេត្តិយភិក្ខុនិងភុម្មជកភិក្ខុក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយចោទទព្វមល្លបុត្រដោយអាបត្តិ បារាជិកមិនមានមូល ពិតមែនឬ ។ មេត្តិយភិក្ខុ និងភុម្មជកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ដំណើរនោះពិតមែន ។ ព្រះសព្វញ្ញុពុទ្ធដ៏មានជោគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ចុះហេតុអ្វី បានជាអ្នកទាំងឡាយ ចោទទព្វមល្លបុត្រដោយអាបត្តិបារាជិកមិនមានមូល ( ដូច្នោះ ) ម្នាលមោឃបុរសទាំងឡាយ ហេតុ

---

១- មិនបានឃើញ ឬមិនបានឮ ឬក៏ឥតមានរង្កៀស ឡើយ ។

នេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែល មិនទាន់ជ្រះថ្លានោះទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ មានសេចក្តីក្រោធប្រទូស្ត មានចិត្តអាក់អន់ ចោទភិក្ខុផងគ្នាដោយអាបត្តិបារាជិកមិនមានមូល ដោយបំណងថា អញត្រូវធ្វើដូចម្តេច ឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌[1]នេះបាន ។ លុះសម័យខាងក្រោយតពីនោះមក ទោះគេសាកសួរក្តី គេមិនសាកសួរក្តី អធិករណ៍នោះប្រាកដជាគ្មានមូល ភិក្ខុអ្នកចោទនោះក៏ប្តេជ្ញាទោស ( ដោយខ្លួនឯង ) ត្រូវអាបត្តិសង្ឃាទិសេស ។

[ ២៨៦ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទខាងដើមរួចហើយ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ ត្រង់ពាក្យថា មានសេចក្តីក្រោធប្រទូស្ត អធិប្បាយថា ខឹងអន់ចិត្ត មិនត្រេកអរ មានចិត្ត គឺទោសខ្នាំងខ្ញប់ មានចិត្តចង្អៀតចង្អល់ ។ ត្រង់ពាក្យថា មានចិត្តអាក់អន់ គឺមានចិត្តមិនរីករាយ ព្រោះសេចក្តីខឹងនោះផង ព្រោះទោសនោះផង ព្រោះសេចក្តីអន់ចិត្តនោះផង ព្រោះសេចក្តីមិនត្រេកអរនោះផង ។ ដែលហៅថា មិនមានមូល គឺមិនឃើញ មិនឮ មិនរង្កៀស ។ ត្រង់ពាក្យថា ដោយអាបត្តិបារាជិក គឺបណ្តាអាបត្តិបារាជិក ទាំង ៤ អាបត្តិបារាជិកណាមួយ ។ ត្រង់ពាក្យថា ចោទ គឺចោទខ្លួនឯងក្តី ឲ្យអ្នកដទៃចោទក្តី ។ ពាក្យថា អញត្រូវធ្វើដូចម្តេចឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌នោះបាន អធិប្បាយថា អញគប្បីឲ្យភិក្ខុ

---

១- សាសនព្រហ្មចរិយៈ ។

នោះឃ្លាតចាកភិក្ខុភាព ឃ្លាតចាកសមណធម៌ ឃ្លាតចាកកងសីល ឃ្លាតចាកតបោគុណ[១] ។

[ ២៤៧ ] ត្រង់ពាក្យថា លុះសម័យខាងក្រោយតពីនោះមក សេចក្តីថា ( រូបភិក្ខុនោះ ) ចោទគេក្នុងខណៈណា ក្នុងខណៈនោះ ស្របក់នោះ ពេលនោះ កន្លងទៅ ។ ត្រង់ពាក្យថា ទោះគេសាកសួរក្តី សេចក្តីថា ( រូបភិក្ខុនោះ ) គេចោទដោយវត្ថុណា គេសាកសួរក្នុងវត្ថុនោះក្តី ។ ត្រង់ពាក្យថា គេមិនសាកសួរក្តី សេចក្តីថា ឥតមានអ្នកណាមួយសាកសួរ ។

[ ២៤៨ ] ដែលហៅថា អធិករណៈៗ នោះ មាន ៤ យ៉ាង គឺវិវាទាធិករណៈ ១ អនុវាទាធិករណៈ ១ អាបត្តាធិករណៈ ១ កិច្ចាធិករណៈ ១ ។

[ ២៤៩ ] ត្រង់ពាក្យថា ភិក្ខុអ្នកចោទនោះក៏ប្តេជ្ញាទោស ( ដោយខ្លួនឯង ) សេចក្តីថា អញពោលពាក្យទទេ អញពោលពាក្យព្រាង អញពោលពាក្យមិនពិត អញមិនដឹងហើយពោល ។ ត្រង់ពាក្យថា អាបត្តិសង្ឃាទិសេស មានអធិប្បាយក្នុងសង្ឃាទិសេសសិក្ខាបទទី ១ រួចហើយ ។

[ ២៥០ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញទេ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា ខ្ញុំបានឃើញអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ( ភិក្ខុចោទដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុ

---

១- ក្នុងអភិធានប្បទីបិកាសូចិ មានវិគ្រោះថា “គុណធម៌ជាគ្រឿងដុតកិលេសឲ្យរីងស្ងួតទៅ” ។

ត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា ខ្ញុំបានឮថាអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែន ជាសមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ( ភិក្ខុចោទដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែ ភិក្ខុអ្នកចោទនោះ មិនមានសេចក្តីរង្កៀស បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា ខ្ញុំមានសេចក្តីរង្កៀសថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជា សមណៈ មិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្រទេ ឧបោសថកម្មក្តី បវារណា កម្មក្តី សង្ឃកម្មក្តីជាមួយនឹងអ្នកឯងគ្មានទេ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវ អាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

[ ២៥១ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិក ហើយ ខ្ញុំបានឃើញហើយផង បានឮផង ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុ អ្នកចោទនោះមិនឃើញ បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯង ត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឃើញហើយផង រង្កៀសហើយផង អ្នកឯង មិនមែនជាសមណៈ ។បេ។ ( ភិក្ខុចោទដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ៗ ម៉ាត់ ។ ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ

ខ្ញុំឃើញហើយផង ឮហើយផង រង្កៀសហើយផង ។បេ។ ( ភិក្ខុអ្នកចោទ ដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិក ហើយ តែភិក្ខុអ្នកចោទមិនបានឮ ព្រោះហេតុនោះ ថាបើភិក្ខុអ្នកចោទ ចោទ ភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ យើងបានឮផង រង្កៀសផង ។ បេ ។ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ តែភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា យើង បានឮផង បានឃើញផងថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុ ចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិ បារាជិកហើយ ភិក្ខុអ្នកចោទនោះ មិនបានឮ បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុ នោះថា ខ្ញុំឮហើយផង រង្កៀសហើយផង ឃើញហើយផងថា អ្នកឯងត្រូវ អាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេស គ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបាន រង្កៀស បើភិក្ខុអ្នកចោទនោះចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិក ហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឃើញហើយផង ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិក ហើយភិក្ខុ អ្នកចោទនោះមិនបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទភិក្ខុនោះថា អ្នកឯង ត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឮហើយផង ។បេ។ ( ភិក្ខុ ចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិ បារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានរង្កៀស បើភិក្ខុអ្នកចោទនោះ ចោទ

ភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ខ្ញុំឃើញហើយផង ខ្ញុំឮហើយផង ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

[ ២៥២ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះ បានឃើញមែន បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឮហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទបានឃើញមែន បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយ ។បេ។ បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឮហើយផង រង្កៀសហើយផង ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ( ភិក្ខុអ្នកចោទនោះ ) បានឮ បើភិក្ខុអ្នកចោទនោះចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយ ។បេ។ បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយ ។បេ។ បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំរង្កៀសហើយផង ឃើញហើយផង ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះបានរង្កៀស បើភិក្ខុអ្នកចោទនោះចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយ ។បេ។ បើ

( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឮហើយ ។បេ។ បើ ( ភិក្ខុអ្នកចោទនោះ ) ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំឃើញហើយផង ខ្ញុំឮហើយផង អ្នកឯងមិនមែនជាសមណៈមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗម៉ាត់ ។

[ ២៥៣ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះបានឃើញមែន តែមានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនបានឃើញហើយ ( គឺ ) កំណត់មិនបាននូវភិក្ខុដែលខ្លួនឃើញហើយ វឭកមិនបាននូវភិក្ខុដែលខ្លួនឃើញហើយ ភ្លេចនូវភិក្ខុដែលខ្លួនឃើញហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឃើញផង ខ្ញុំបានឮផង ។បេ។ ខ្ញុំបានឃើញផង ខ្ញុំមានសេចក្តីរង្កៀសផង ។បេ។ ខ្ញុំបានឃើញផង ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង ។បេ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះបានឮ តែមានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនបានឮហើយ ( គឺ ) កំណត់មិនបាននូវភិក្ខុដែលខ្លួនឮហើយ វឭកមិនបាននូវភិក្ខុដែលខ្លួនឮហើយ ភ្លេចនូវភិក្ខុដែលខ្លួនឮហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង ។បេ។ ខ្ញុំបានឮផង ខ្ញុំបានឃើញផង ។បេ។ ខ្ញុំបានឮផង ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឃើញផង ។បេ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះ មាន

សេចក្តីសង្ស័យ ក៏មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនមានសេចក្តីរង្កៀស ហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ វេញកមិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ ភ្លេចនូវភិក្ខុដែលខ្លួនរង្កៀសហើយ បើភិក្ខុអ្នកចោទ ចោទភិក្ខុនោះថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឃើញផង ។បេ។ ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឮផង ។បេ។ ខ្ញុំមានសេចក្តីរង្កៀសផង ខ្ញុំបានឃើញផង ខ្ញុំបានឮផង អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូននៃព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

[ ២៥៤ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក តែភិក្ខុអ្នកចោទនោះមិនឃើញ បើ ( ភិក្ខុអ្នកចោទ ) ប្រើបុគ្គលដទៃឲ្យចោទភិក្ខុដែលត្រូវអាបត្តិបារាជិកនោះថា អ្នកឯងខ្ញុំឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ( ភិក្ខុអ្នកចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមិនបានឮ បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឮថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមិនបានរង្កៀស បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទភិក្ខុ

នោះថា អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

[ ២៥៥ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទមិនឃើញទេ បើ ( ភិក្ខុអ្នកចោទ ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ ។បេ។ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ ។បេ។ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទនោះមិនបានឮ បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទថា អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ ។បេ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំបានឃើញហើយ ។បេ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមិនបានរង្កៀស បើភិក្ខុអ្នកចោទ ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ ។បេ។ អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងខ្ញុំបានឮហើយ ។បេ។ អ្នកឯង ខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងខ្ញុំបានឮហើយ អ្នកឯង ត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិ

សង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

[ ២៥៦ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះបានឃើញហើយ បើ ( ភិក្ខុអ្នកចោទ ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុដែលត្រូវអាបត្តិបារាជិកនោះថា អ្នកឯងខ្ញុំបានឮហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ អ្នកឯងខ្ញុំបានឮហើយ អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ( ភិក្ខុអ្នកចោទ ) បានឮហើយ បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ ។បេ។ បើ ( ភិក្ខុអ្នកចោទ ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយ ។បេ។ បើ ( ភិក្ខុអ្នកចោទ ) ប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំមានសេចក្ដីរង្កៀសហើយ អ្នកឯងខ្ញុំបានឃើញហើយ អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។ ( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។ ភិក្ខុត្រូវអាបត្តិបារាជិកហើយ ភិក្ខុអ្នកចោទមានសេចក្ដីរង្កៀស បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំបានឃើញហើយថា អ្នកឯងត្រូវអាបត្តិបារាជិកហើយ ។ បេ ។ បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំឃើញហើយ អ្នកឯងខ្ញុំឮហើយ ។ បេ ។ បើភិក្ខុអ្នកចោទប្រើភិក្ខុដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំឃើញហើយ អ្នកឯងខ្ញុំឮហើយ ថាអ្នកឯងត្រូវអាបត្តិបារាជិកហើយ ។បេ។

( ភិក្ខុចោទគេដូច្នេះ ) ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

[ ២៥៧ ] ភិក្ខុកាលត្រូវអាបត្តិបារាជិក ភិក្ខុអ្នកចោទនោះក៏ឃើញមែន ( តែភិក្ខុអ្នកចោទ ) មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនឃើញហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនឃើញហើយ វឭកមិនបាននូវភិក្ខុដែលខ្លួនឃើញហើយ ភ្លេចនូវភិក្ខុដែលខ្លួនឃើញហើយ ។បេ។ មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនឮហើយ កំណត់មិនបាននូវភិក្ខុដែលខ្លួនឮហើយ វឭកមិនបាននូវភិក្ខុដែលខ្លួនឮហើយ ភ្លេចនូវភិក្ខុដែលខ្លួនឮហើយ ។បេ។ មានសេចក្តីសង្ស័យនឹងភិក្ខុដែលខ្លួនរង្កៀស កំណត់មិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ វឭកមិនបាននូវភិក្ខុដែលខ្លួនរង្កៀសហើយ ភ្លេចនូវភិក្ខុដែលខ្លួនរង្កៀសហើយ បើភិក្ខុអ្នកចោទប្រើបុគ្គលដទៃឲ្យចោទភិក្ខុនោះថា អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឃើញហើយ ។បេ។ អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឮហើយ ។បេ។ អ្នកឯងខ្ញុំរង្កៀសហើយ អ្នកឯងខ្ញុំឃើញហើយ អ្នកឯងខ្ញុំឮហើយ ថាអ្នកឯងត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តឡើយ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តីជាមួយនឹងអ្នកឯងគ្មានទេ ភិក្ខុចោទគេដូច្នេះនេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ ម៉ាត់ ។

( មាតិកានុក្រម គឺបញ្ជីរឿងដែលនឹងត្រូវសម្តែងតាមលំដាប់ហូរហែដូចមានខាងក្រោមនេះគឺ )

[ ២៥៨ ] ភិក្ខុយល់ឃើញថាបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ ១ យល់ឃើញថាមិនបរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ ១ យល់

ឃើញថាមិនបរិសុទ្ធ ក្នុងបុគ្គលដែលមិនបរិសុទ្ធ ១ យល់ឃើញថា បរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ ១ ។

[ ២៥៩ ] បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកឯណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថាភិក្ខុនោះបរិសុទ្ធល្អទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានសេចក្តីប្រាថ្នាឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទភិក្ខុនោះ ( ដោយអាបត្តិបារាជិក ភិក្ខុអ្នកចោទ ) ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថាភិក្ខុនោះបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទភិក្ខុនោះ ( ដោយអាបត្តិបារាជិក ភិក្ខុអ្នកចោទ ) ត្រូវអាបត្តិសង្ឃាទិសេស ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថាភិក្ខុនោះបរិសុទ្ធល្អទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងជេរភិក្ខុនោះ ទើបជេរ ( ភិក្ខុអ្នកជេរ ) ត្រូវអាបត្តិទុក្កដ និងបាចិត្តិយ ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ ។

[ ២៦០ ] បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នក

បរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ថា ភិក្ខុនោះមិនបរិសុទ្ធទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទត្រូវអាបត្តិទុក្កដ ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាទីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នានឹងឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ មិនត្រូវអាបត្តិ ។ បុគ្គលគឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាទីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីនឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដ និងបាចិត្តិយ ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណាទីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីនឹងជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ ។

[ ២៦១ ] បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាទីមួយ ជាអ្នកមិនបរិសុទ្ធហើយ ភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ហើយមិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិទុក្កដ ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណាទីមួយ ជាអ្នកមិនបរិសុទ្ធ

ហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទមិនត្រូវអាបត្តិឡើយ ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដ និងបាចិត្តិយ ។ បុគ្គល គឺភិក្ខុដែលត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកមិនបរិសុទ្ធ ហើយភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះមិនបរិសុទ្ធល្អទេ ហើយឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ ។

[ ២៦២ ] បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិទុក្កដ និងសង្ឃាទិសេស ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយធម៌ ទើបពោលចោទ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិ-សេស ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធ

ហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ មិនឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិទុក្កដ និងបាចិត្តិយ ។ បុគ្គល គឺភិក្ខុដែលមិនត្រូវអាបត្តិបារាជិកណានីមួយ ជាអ្នកបរិសុទ្ធហើយ បើភិក្ខុអ្នកចោទយល់ឃើញថា ភិក្ខុនោះបរិសុទ្ធល្អទេ ឲ្យភិក្ខុនោះធ្វើឱកាសដោយសមគួរជាមុន ហើយមានប្រាថ្នាដើម្បីជេរភិក្ខុនោះ ទើបជេរ ភិក្ខុអ្នកជេរ ត្រូវអាបត្តិបាចិត្តិយ ។

[ ២៦៣ ] អាបត្តិមិនមានដល់ភិក្ខុដែលយល់ឃើញថា មិនបរិសុទ្ធក្នុងបុគ្គលដែលបរិសុទ្ធ ដល់ភិក្ខុដែលយល់ឃើញថាមិនបរិសុទ្ធក្នុងបុគ្គលដែលមិនបរិសុទ្ធ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សង្ឃាទិសេសទី ៨ ចប់

# អដ្ឋកថា
# បឋមទុដ្ឋទោសសិក្ខាបទវណ្ណនា[១]
# ប្រវត្តិ វេឡុវ័នវិហារ

[ ២៣៨ ] ទុដ្ឋទោសសិក្ខាបទ ត្រង់បទថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅថា គប្បីជ្រាបវិនិច្ឆ័យក្នុងទុដ្ឋទោសសិក្ខាបទនោះ ដូច្នេះ

បទថា **វេឡុវន** ក្នុងបទថា **វេឡុវនេ កលន្ទកនិវាបេ** ជាឈ្មោះនៃឧទ្យាននោះ ។ បានឮថា ឧទ្យាននោះ បានហ៊ុមព័ទ្ធទៅដោយគុម្ពឫស្សីផង កំពែងខ្ពស់ប្រមាណ ១៨ ហត្ថផង ប្រកបដោយខ្លោងទ្វារ និងប៉ម មានពណ៌ខៀវស្រងាត់ ជាទីរីករាយចិត្ត ព្រោះហេតុនោះ ទើបហៅថា **វេឡុវន** ។ ម្យ៉ាងទៀត ជនទាំងឡាយបានឲ្យចំណីដល់ពួកកង្ហែនក្នុងឧទ្យាននេះ ដោយហេតុនោះ ទើបឧទ្យាននេះ ឈ្មោះថា **កលន្ទនិវាប**។

បានឮថា ក្នុងកាលមុន ព្រះរាជាមួយអង្គទ្រង់បានប្រពាតក្នុងឧទ្យាននោះ ទ្រង់ស្រវឹងព្រោះទឹកចណ្ឌហើយ ផ្ទំលក់នៅពេលថ្ងៃ ។ បរិវាររបស់ព្រះអង្គក៏និយាយគ្នាថា ព្រះរាជាផ្ទំលក់ហើយ ត្រូវផ្កា និងផ្លែឈើទាក់ទាញចិត្ត ទើបនាំគ្នាចៀសទៅកាន់ទីផ្សេងៗ ។ ខណៈនោះ ពស់វែកលូនមកអំពីព្រងឈើមួយដើម ព្រោះក្លិនសុរា លូនតម្រង់មករកព្រះរាជា រុក្ខទេវតាឃើញពស់នោះហើយ គិតថា អញនឹងឲ្យជីវិតដល់ព្រះរាជា ទើបកាឡាជាសត្វកង្ហែន មកធ្វើសំឡេងស្រែកត្រង់ទីជិតព្រះកាណ៌នៃព្រះរាជា ព្រះរាជាទ្រង់

---

១- ក្នុងទី២ះ ហៅថា ទុដ្ឋទោសសិក្ខាបទ ។

ភ្ញាក់ឡើង ពស់ក៏លូនត្រឡប់ទៅ ។ ព្រះរាជាទតឃើញហេតុនោះហើយ ទ្រង់ត្រិះរិះថា កង្កែននេះឲ្យជីវិតដល់អញ ទើបផ្ដើមឲ្យចំណីដល់កង្កែនទាំងឡាយ ហើយទ្រង់ឲ្យប្រកាសព្រះរាជទានអភ័យ ដល់ហ្វូងកង្កែនក្នុងឧទ្យាននោះ ព្រោះដូច្នោះ ទើបវេឡុវ័ននោះ ដល់នូវការរាប់ថា **កលន្ទកនិវាប** ចាប់តាំងពីពេលនោះមក ។ ពិតហើយ បទថា **កលន្ទក** នេះ ជាឈ្មោះ របស់ពួកកំប្រុក កង្កែននោះឯង ។

# រឿង ព្រះឆព្វមល្លបុត្រ

ពាក្យថា **ឆព្វ** ជាឈ្មោះនៃព្រះថេរៈ ។ បទថា **មល្លបុត្តោ** ប្រែថា ជាឱរសរបស់ស្ដេចមល្លរាជ ។ បទថា **ជាតិយា សត្តវស្សេន អរហត្តំ សច្ឆិកតំ** សេចក្ដីថា បានឮថា ព្រះថេរៈ បណ្ឌិតគប្បីជ្រាបថា មានអាយុ ៧ ឆ្នាំ កាលបព្វជ្ជាបាននូវសេចក្ដីសង្វេគហើយ សម្រេចអរហត្តផលក្នុងខណៈកោរសក់ហើយនោះឯង ។

បទថា **យំកិញ្ចិ សាវកេន បត្តព្វំ សព្វំ តេន អនុប្បត្តំ** សេចក្ដីថា គុណជាតិនេះ គឺ វិជ្ជា ៣ បដិសម្ភិទា ៤ អភិញ្ញា ៦ លោកុត្តរធម៌ ៩ ឈ្មោះថា ដែលសាវកគប្បីសម្រេច គុណជាតិនោះ ព្រះថេរៈនោះសម្រេចហើយគ្រប់យ៉ាង ។

បទថា **ឆត្ថិ ចស្ស កិញ្ចិ ឧត្តរឹ ករណីយំ** សេចក្ដីថា ឥឡូវនេះ កិច្ចដែលគប្បីធ្វើឲ្យក្រៃលែងឡើងទៅ សូម្បីតិចតួច មិនមានដល់ព្រះថេរៈនោះ ព្រោះកិច្ច ១៦ យ៉ាង ក្នុងអរិយសច្ច ៤ ព្រះថេរៈធ្វើសម្រេចហើយ ដោយមគ្គ ៤ ។

បទថា **កតស្ស វា បតិចយោ** សេចក្ដីថា សូម្បីការនឹងបន្ថែមកិច្ចដែលធ្វើស្រេចហើយនោះក៏មិនមាន ដូចសំពត់ដែលបោកគក់ហើយ មិនត្រូវបោកគក់ដដែលទៀត ដូចគ្រឿងក្រអូបដែលបុកហើយ មិនចាំបាច់បុកទៀត និងដូចផ្កាដែលរីកហើយ មិនត្រឡប់រីកទៀតដូច្នោះឯង ។

[ ២៣៩ ] បទថា **រហោគតស្ស** បានដល់ ទៅក្នុងទីស្ងាត់ ។

បទថា **បដិសល្លីនស្ស** បានដល់ ចៀសចេញអំពីអារម្មណ៍នោះៗ ហើយសម្ងំ មានពាក្យអធិប្បាយថា ដល់នូវភាពជាបុគ្គលម្នាក់ឯង ។

បទថា **អជ្ជ ខោ អយស្មតោ ធព្ពស្ស មល្លបុត្តស្ស ឯតទហោសិ យន្នូនាហំ សង្ឃស្ស សេនាសនញ្ច បញ្ញាបេយ្យំ ភត្តានិ ច ឧទ្ទិសេយ្យំ** សេចក្ដីថា ព្រះថេរៈគិតថា កិច្ចរបស់អញធ្វើស្រេចហើយ ទើបត្រិះរិះថា អញទ្រទ្រង់នូវសរីរៈចុងក្រោយនេះ ឯសរីរៈចុងក្រោយនេះ តាំងនៅក្នុងផ្លូវនៃអនិច្ចតា មិនយូរមិនឆាប់ នឹងរលត់ទៅជាធម្មតា ដូចប្រទីបតាំងនៅក្នុងខ្យល់ ដូច្នោះ អញគួរធ្វើការខ្វល់ខ្វាយដល់សង្ឃ ទាន់មិនទាន់រលត់ដោយប្រការណាហ្ន៎ ទើបពិចារណាឃើញយ៉ាងនេះថា ពួកកុលបុត្រច្រើនណាស់ ក្នុងដែនក្រៅទាំងឡាយ បួសមិនបានឃើញព្រះមានព្រះភាគសោះ លោកទាំងនោះរមែងនាំគ្នាមកអំពីចម្ងាយ ដោយបំណងថា យើងទាំងឡាយនឹងគាល់ព្រះមានព្រះភាគ នឹងថ្វាយបង្គំព្រះមានព្រះភាគ បណ្ដាកុលបុត្រនោះ សេនាសនៈមិនគ្រប់គ្រាន់ដល់លោកពួកណា លោកពួកនោះត្រូវដេកលើផ្ទាំងថ្ម ឯអញអាចនិមិត្តសេនាសនៈ មានប្រាសាទ វិហារ អឌ្ឍយោគជាដើម ព្រមទាំងគ្រែតាំង

និងកម្រាល ឲ្យតាមអំណាចការប្រាថ្នារបស់កុលបុត្រដ៏ច្រើនទាំងនោះ ដោយអានុភាពរបស់ខ្លួន ហើយក្នុងថ្ងៃរះឡើង បណ្តាកុលបុត្រទាំងនេះ អង្គខ្លះមានកាយហត់នឿយពន់ពេក កុលបុត្រពួកនោះ នឹងឈរមុខភិក្ខុទាំងឡាយ ហើយមិនមានបុគ្គលណាដែលចែកនូវភត្តាហារដោយគោរពបាន ឯអញអាចចែកនូវភត្តាហារដល់កុលបុត្រទាំងនោះបាន ។ គ្រានោះឯង ទព្វមល្លបុត្តភិក្ខុកំពុងពិចារណាយ៉ាងនេះ ទើបមានការសម្រេចចិត្តថា បើដូច្នោះ អញគួរតែរៀបចំសេនាសនៈ និងចែកភត្តាហារដល់សង្ឃ ។

សួរថា ឯឋានៈទាំងពីរប្រការនេះ គួរដល់ភិក្ខុដែលតាមប្រកបតែក្នុងការត្រេកអរ ដោយការនិយាយជាដើម មិនមែនឬ ចំណែកព្រះទព្វមល្លបុត្រនេះជាព្រះខីណាស្រព មិនមានសេចក្តីត្រេកអរក្នុងធម៌ជាគ្រឿងយឺតយូរ ព្រោះហេតុអ្វី ទើបឋានៈ ២ ប្រការនេះ ប្រាកដជាក់ច្បាស់ដល់ព្រះថេរៈអង្គនេះ ។

ឆ្លើយថា ព្រោះសេចក្តីប្រាថ្នាក្នុងកាលមុនជាស់តឿន ។

បានឮថា ព្រះពុទ្ធអង្គទ្រង់មានពួកសាវ័កដែលសម្រេចឋានន្តរនេះដូចគ្នា តែព្រះទព្វមល្លបុត្រនេះ កើតជាតិមុនក្នុងត្រកូលមួយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ឃើញអានុភាពរបស់ភិក្ខុដែលសម្រេចតំណែងនេះ និមន្តព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុប្រមាណ ៦៨០០០០ អង្គ ថ្វាយមហាទានអស់ ៧ ថ្ងៃ ហើយក្រាបចុះទៀបបាទមូល ធ្វើសេចក្តីប្រាថ្នាថា ក្នុងកាលនៃព្រះពុទ្ធដូចព្រះអង្គកើតឡើងក្នុងអនាគត ខ្ញុំព្រះអង្គគប្បីជាអ្នករៀបចំសេនាសនៈផង ជាភត្តុទ្ទេសកៈផង ដូចសាវ័ករបស់ព្រះអង្គនេះ ។

ព្រះមានព្រះភាគ ទ្រង់បញ្ជូនអនាគតំសញ្ញាណទៅ បានឃើញហើយ ។ កាលឃើញហើយ ទើបទ្រង់ព្យាករថា ក្នុងកាលកន្លងទៅមួយសែនកប្បអំពីកប្បនេះ ព្រះពុទ្ធព្រះនាមថាគោតម ទ្រង់នឹងកើតឡើងក្នុងកាលនោះ អ្នកនឹងកើតជាកូនរបស់មល្លក្សត្រ ឈ្មោះថា ទព្វៈ មានអាយុ ៧ ឆ្នាំអំពីកំណើតនឹងចេញបព្វជ្ជា ហើយធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល អ្នកនឹងបានតំណែងនេះ ។ ចាប់តាំងអំពីនោះមក កុលបុត្រនោះបំពេញកុសល មានទាន សីលជាដើម បានសោយសម្បត្តិក្នុងទេវតា និងមនុស្សក្នុងកាលនៃព្រះមានព្រះភាគរបស់យើង បានធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ដូចព្រះមានព្រះភាគអង្គនោះព្យាករហើយនោះឯង ។ លំដាប់នោះ កាលព្រះទព្វមល្លបុត្រអ្នកនៅក្នុងទីស្ងាត់ត្រិះរិះថា អញគប្បីធ្វើការខ្វល់ខ្វាយដល់សង្ឃដូចម្តេចហ្ន៎ ឋានៈ ២ នេះប្រាកដជាក់ច្បាស់ហើយ ព្រោះសេចក្តីប្រាថ្នាក្នុងកាលមុននោះជាស់តឿនដូច្នេះឯង ។

គ្រានោះ លោកមានការត្រិះរិះយ៉ាងនេះថា អាត្មាអញ មិនជាឥស្សរៈក្នុងខ្លួនឯង អាត្មាអញនៅក្នុងសម្នាក់ជាមួយព្រះសាស្តា បើព្រះមានព្រះភាគទ្រង់អនុញ្ញាតឲ្យអាត្មាអញសោត អាត្មាអញនឹងសមាទានឋានៈទាំងពីរនេះហើយបានចូលទៅគាល់ព្រះមានព្រះភាគ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា **អថខោ អាយស្មា ទព្វោ មល្លបុត្តោ ។បេ។ ភត្តានិ ច ឧទ្ទិសិតុំ** ដូច្នេះ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ញាំងព្រះទព្វមល្លបុត្រនោះឲ្យរីករាយ

ដោយព្រះតម្រាស់ថា សាធុ ល្អហើយ ទព្វៈ ទើបត្រាស់ថា ម្នាលទព្វៈ បើដូច្នោះ អ្នកចូររៀបចំសេនាសនៈ និងចែកភត្តដល់សង្ឃចុះ ព្រោះថា ភិក្ខុដែលឆ្ងាយចាកការលំអៀង ព្រោះអគតិបែបនេះ រមែងសមគួរបាត់ការក្នុងឋានៈទាំងពីរនេះ ។

ពីរបទថា **ភគវតោ បច្ចស្សោសិ** សេចក្តីថា ព្រះទព្វមល្លបុត្រទទួលព្រះតម្រាស់របស់ព្រះមានព្រះភាគ គឺទទួលចំពោះព្រះភក្ត្រ អធិប្បាយថា ទូលទទួលព្រះពុទ្ធដីកា ។

[ ២៨០ ] ក្នុងបទថា **បឋមំ ឧព្វោ យាចិតព្វោ** នេះ សេចក្តីថា ព្រះមានព្រះភាគទ្រង់ឲ្យអង្វរ ព្រោះហេតុអ្វី ឆ្លើយថា ដើម្បីការពារពាក្យនិន្ទា ។

ពិតហើយ ព្រះមានព្រះភាគ ទ្រង់ឃើញថា ក្នុងអនាគតឧបទ្ទវធំ នឹងកើតដល់ទព្វៈ ដោយអំណាចនៃភិក្ខុឈ្មោះមេត្តិយ្យ និងភុម្មជក ព្រោះអាស្រ័យឋានៈនេះ បណ្តាភិក្ខុទាំងនោះ ពួកខ្លះតិះដៀលថា ព្រះទព្វៈនេះ ជាអ្នកព្រងើយកន្តើយ មិនធ្វើការងាររបស់ខ្លួន មករៀបចំឋានៈដូច្នេះ ព្រោះហេតុអ្វី លំដាប់នោះ ភិក្ខុពួកដទៃពោលថា ទោសអ្វីរបស់លោកអង្គនេះៗ ដែលភិក្ខុទាំងនោះអង្វរហើយ លោកនឹងផុតចាកការនិន្ទាដោយអាការយ៉ាងនេះ ។ លុះឲ្យអង្វរដើម្បីដោះការនិន្ទាយ៉ាងនេះហើយ ព្រោះកាលភិក្ខុសង្ឃមិនបានសន្មតដដែលទៀត ពោលពាក្យណាមួយក្នុងជំនុំសង្ឃ នឹងកើតការពោលទោសជាធម្មតាថា ព្រោះហេតុអ្វី ទើបភិក្ខុនេះធ្វើសំឡេងខ្លាំង សម្តែង

កាពជាធំក្នុងកណ្តាលជំនុំសង្ឃទៅវិញ តែកាលភិក្ខុដែលសង្ឃសន្មតហើយពោល ទោះបីមានអ្នកពោលថា ពួកលោកកុំពោលពាក្យណាមួយ ភិក្ខុនេះសង្ឃសន្មតហើយ ចូរពោលតាមសប្បាយចុះ ហើយភិក្ខុដែលពោលចោទភិក្ខុដែលសង្ឃមិនបានសន្មតដោយពាក្យមិនពិត ជាអាបត្តិស្រាល ត្រឹមទុក្កដ តែបុគ្គលពោលចោទ ភិក្ខុដែលសង្ឃសន្មតហើយ ត្រូវអាបត្តិបាចិត្តិយ ភិក្ខុដែលសង្ឃសន្មតហើយ ទោះជាត្រូវពួកភិក្ខុដែលចង់ពៀរចង់កម្ចាត់ ក៏លំបាកក្រៃលែង ព្រោះជាអាបត្តិធ្ងន់ ដូច្នោះ ដើម្បីឲ្យសង្ឃសន្មតព្រះថេរៈនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ព្យត្តេន ភិក្ខុនា** ជាដើម ។

សួរថា ការឲ្យសម្មតិ ២ យ៉ាង ដល់ភិក្ខុមួយអង្គគួរឬ ឆ្លើយថា មិនមែនត្រឹមតែ ២ យ៉ាងប៉ុណ្ណោះទេ បើអាចនឹងឲ្យសម្មតិទាំង ១៣ យ៉ាងក៏គួរ តែបើភិក្ខុទាំងឡាយមិនអាច សូម្បីសន្មតតែមួយ៉ាងក៏មិនគួរដល់ភិក្ខុ ២-៣ អង្គ ។

[ ២៤១ ] បទថា **សភាគានំ** សេចក្តីថា បុគ្គលស្មើគ្នាដោយគុណ មិនមែនស្មើគ្នាដោយជាមិត្រស្និទ្ធស្នាលនោះឡើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **យេ តេ ភិក្ខូ សុត្តន្តិកា តេសំ ឯកជ្ឈំ** ជាដើម ។ ភិក្ខុដែលទ្រទ្រង់ព្រះសូត្រមានចំនួនប៉ុន្មាន ព្រះទព្វៈជ្រើសរើសភិក្ខុទាំងនោះរៀបចំសេនាសនៈដែលសមគួរដល់ភិក្ខុទាំងនោះឯងរួមគ្នា ដល់ពួកភិក្ខុដ៏សេសក៏យ៉ាងនោះ ។

បទថា **កាយទឡ្ហីពហុលា** បានដល់ ដែលច្រើនទៅដោយការធ្វើរាងកាយឲ្យរឹងមាំ អធិប្បាយថា ជាអ្នកច្រើនទៅដោយការទំនុកបម្រុងរាងកាយ ។

បទថា **ឥមាយបិមេ អាយស្មន្តោ រតិយា** បានដល់ ដោយការត្រេកអរក្នុងតិរច្ឆានកថា ដែលជាហេតុរាំងចំពោះសួគ៌នេះ ។

បទថា **អច្ចិស្សន្តិ** ប្រែថា នឹងនៅ ។

បទថា **តេជោធាតុំ សមាបជ្ជិត្វា ទេវេហាលោកេន** សេចក្តីថា លោកដ៏មានអាយុនោះ ចូលចតុត្ថជ្ឈាន មានតេជោកសិណជាអារម្មណ៍ ចេញហើយអធិដ្ឋានម្រាមដៃ ឲ្យភ្លឺដោយអភិញ្ញាញាណ ( រៀបចំសេនាសនៈ ) ដោយពន្លឺដែលចេញចាំងអំពីម្រាមដៃ ដែលតេជោធាតុសមាបត្តិ ឲ្យកើតហើយនោះ ។ ឯអានុភាពរបស់ព្រះថេរៈយ៉ាងនេះ បានប្រាកដហើយ ក្នុងសកលជម្ពូទ្វីបក្នុងកាលមិនយូរប៉ុន្មានឡើយ ។ ជនទាំងឡាយ ឮដំណឹងនោះ ចង់ឃើញបាដិហារ្យរបស់លោក បាននាំគ្នាមក ។ ពួកភិក្ខុក្មេងមកក្នុងវេលាវិកាលខ្លះក៏មាន ។ បទថា **តេ សញ្ចិច្ច ថេរេ អបធិសន្តិ** សេចក្តីថា ភិក្ខុទាំងនោះ ទាំងដែលកំពុងដឹង ក៏នាំគ្នាអាងដល់ទីកន្លែងឆ្ងាយៗ ។ សេចក្តីនេះដូចម្តេច គឺភិក្ខុខ្លះអាងដោយន័យថា អាវុសោ ទព្វៈ សូមលោករៀបចំសេនាសនៈឲ្យពួកខ្ញុំត្រង់ភ្នំគិជ្ឈកូដ ដូច្នេះជាដើម ។

បទថា **អង្គុលិយា ជលមានាយ បុរតោ បុរតោ គច្ឆតិ** សេចក្តីថា បើមានភិក្ខុមួយអង្គ លោកទៅឯង បើមានច្រើនអង្គ លោកនិមិត្តអត្តភាពជាច្រើនឲ្យដូចគ្នានឹងលោកទាំងអស់ ។ ក្នុងបទថា **សេនាសនំ បញ្ញាបេតិ អយំ មញ្ចោ** ជាដើម មានវិនិច្ឆ័យដូច្នេះ កាលព្រះថេរៈពោលថា នេះគ្រែ អត្តភាពដែលនិម្មិត ក៏ពោលថា នេះគ្រែ ក្នុងទីកន្លែងរៀងៗ ខ្លួន ដែលទៅដល់

ហើយ ។ សូម្បីក្នុងបទទាំងពួង ក៏យ៉ាងនេះ ។ ពិតហើយ ប្រក្រតីនេះ ជាធម្មតារបស់អត្តភាពនិម្មិត គឺ

កាលបុគ្គលមានឫទ្ធិម្នាក់ពោល អត្តភាពនិម្មិតទាំងអស់ ក៏ពោលផងដែរ កាលអ្នកមានឫទ្ធិម្នាក់អង្គុយស្ងៀម អត្តភាពនិម្មិតទាំងអស់នោះ ក៏អង្គុយស្ងៀមផងដែរ ។

ក្នុងវិហារណា គ្រែ តាំងជាដើម មិនសម្បូរ លោករមែងឲ្យសម្បូរ ដោយអានុភាពរបស់ខ្លួន ការនិយាយក្រៅរឿងរបស់អត្តភាពដែលព្រះថេរៈនោះនិម្មិត រមែងមិនមាន ។

បទថា **សេនាសនំ បញ្ញាបេត្វា បុន តេន វេឡុវនំ បច្ចាគច្ឆតិ** សេចក្តីថា លោករមែងមិនអង្គុយនិយាយរឿងជនបទជាមួយភិក្ខុទាំងនោះ ត្រឡប់មកលំនៅរបស់ខ្លួនមួយរំពេច ។

## រឿង មេត្តិយ និងភុម្មជកភិក្ខុ

[ ២៤២ ] បទថា **មេត្តិយភុម្មជកា** បានដល់ ភិក្ខុទាំងនេះ គឺភិក្ខុឈ្មោះមេត្តិយ ១ ភិក្ខុឈ្មោះភុម្មជក ១ ជាប្រធានបុរសនៃពួកឆព្វគ្គិយភិក្ខុ ។

ពីរបទថា **លាមកានិ ច ភត្តានិ** បានដល់ សេចក្តីនេះ គឺសេនាសនៈដែលថោកថយដល់ពួកភិក្ខុថ្មីមុន មិនជាប្រការដែលគួរអស្ចារ្យឡើយ ។ តែភិក្ខុទាំងឡាយ ប្រើស្លាកទុកក្នុងល្អី ឬថ្នក់ចីវរ ច្របល់គ្នាហើយចាប់មួយអង្គមួយៗ ចែកភត្តឲ្យទៅ ភត្តទាំងនោះ ជារបស់អាក្រក់ អន់ជាងគេបង្អស់ រមែងដល់មេត្តិយភិក្ខុ និងភុម្មជកនោះ ព្រោះជាអ្នកមានបុណ្យតិច ។

ភត្តដែលគួរចែកឲ្យតាមលំដាប់គ្រាណា ឈ្មោះថា **ឯកវារិកភត្ត** ជារបស់ដ៏ប្រណីត គប្បីប្រមូលចែកតាំងអំពីព្រះថេរៈ រហូតដល់នវកភិក្ខុ សូម្បីភត្តនោះ ក្នុងថ្ងៃដែលដល់មេត្តិយ និងភុម្មជកនេះ ក៏ក្លាយជារបស់អាក្រក់ ឬពួកអ្នកស្រុកគ្រាន់តែឃើញភិក្ខុពីរអង្គនោះ មិនប្រគេនរបស់ប្រណីត បែរជាប្រគេនរបស់អន់ៗ ។

បទថា **អភិសង្ខារិកំ** បានដល់ ដែលគេតាក់តែងផ្សំដោយគ្រឿងផ្សំផ្សេងៗ អធិប្បាយថា ដែលគេត្រៀមរៀបចំដោយល្អ គឺឲ្យសម្រេចដោយល្អ ។ បទថា **កាណាជកំ** បានដល់ បាយចុងអង្ករ ។ បទថា **ពិលង្គទុតិយំ** បានដល់ មានទឹកជ្រក់ជាគម្រប់ពីរ ។

[ ២៤៣ ] បទថា **កល្យាណភត្តិកោ** សេចក្ដីថា ភត្តយ៉ាងល្អ គឺដ៏ឆ្ងាញ់ និងប្រណីតរបស់ឧបាសកនោះ មានហើយ ព្រោះហេតុនោះ ទើបឧបាសកឈ្មោះថា **កល្យាណភត្តិក** ឧបាសកនោះ ប្រាកដឈ្មោះតាមភត្តនោះឯង ព្រោះជាអ្នកប្រគេនភត្តប្រណីត ។

ពីរបទថា **ចតុក្កភត្តំ ទេតិ** បានដល់ ថ្វាយភត្តាហារមួយថ្ងៃ ៤ សម្រាប់ ។ តែដោយតទ្ធិតវោហារ លោកពោលថា ចតុក្កភត្ត ។

ពីរបទថា **ឧបតិដ្ឋិត្វា បរិវិសតិ** សេចក្ដីថា ឧបាសកនោះ លះបង់ការងារទាំងអស់ ធ្វើការបូជា និងសក្ការៈ ហើយឈរអង្គាសក្នុងទីជិតនោះ ។

ពីរបទថា **ឱទនេន បុច្ឆន្តិ** សេចក្ដីថា ពួកមនុស្សគ្រាន់បាយចូលទៅរកហើយ សួរថា ខ្ញុំនឹងប្រគេនបាយ ឬលោកម្ចាស់ យ៉ាងនេះ ជាតតិយាវិភត្តិ

ចុះក្នុងអត្ថនៃករណៈ ។ ក្នុងសូបៈជាដើមក៏មានន័យយ៉ាងនេះ ។

បទថា **ស្វាតនាយ** សេចក្តីថា ការឆាន់កត្តាហារដែលមានក្នុងថ្ងៃស្អែកនេះ ឈ្មោះថា **ស្វាតន**។ ដើម្បីប្រយោជន៍ដល់ការឆាន់កត្តាហារក្នុងថ្ងៃស្អែកនោះ ឈ្មោះថា **ស្វាតនាយ** មានពាក្យអធិប្បាយថា ដើម្បីប្រយោជន៍ដល់ការឆាន់កត្តាហារដែលគួរធ្វើក្នុងថ្ងៃស្អែក ។

ពីរបទថា **ឧទ្ទិដ្ឋំ ហោតិ** បានដល់ ជារបស់ដែលកត្តុទ្ទេសក៍ សម្តែងឲ្យហើយ ។ ព្រះថេរៈមិនគិតដល់ ទើបពោលពាក្យនេះថា **មេត្តិយភុម្មជកានំ ខោ គហបតិ** ដូច្នេះ ។ ពិតហើយ មេត្តិយភិក្ខុ និងភុម្មជកនោះ ជាអ្នកមានបុណ្យតិច មានកម្លាំងយ៉ាងនេះ សូម្បីព្រះអរហន្តទាំងឡាយ ជាអ្នកដល់ព្រមដោយសតិដ៏បរិបូណ៌ ក៏មិនមានការគិតដល់ ។ ដោយបទថា **ផេ** ក្នុងពាក្យថា **យេ ផេ** នេះ គហបតីហៅទាសី ។ បទថា **ហិយ្យោ ខោ អាវុសោ អម្ហាកំ** សេចក្តីថា មេត្តិយភិក្ខុ និងភុម្មជកប្រឹក្សាគ្នាអស់មួយរាត្រី ពោលសំដៅដល់ចំណែកនៃថ្ងៃដែលកន្លង ហើយថា **ហិយ្យោ** ( ម្សិលមិញ ) ។

បទថា **ន ចិត្តរូបំ** បានដល់ មិនសមដូចបំណង ។ ភិក្ខុទាំងពីរនោះដេកមិនលក់ដូចដែលខ្លួនធ្លាប់ដេក តាមដែលត្រូវការក្នុងកាលមុន ។ មានពាក្យអធិប្បាយថា ដេកបានបន្តិចបន្តួចប៉ុណ្ណោះ។ បទថា **ពហារាមកោដ្ឋកេ** បានដល់ ខាងក្រៅខ្លោងទ្វារនៃវេឡុវនមហាវិហារ ។ បទថា **បត្តក្ខន្ធា** បានដល់ មានកឱន គឺអន្ទុយសំយុងកចុះ ។ បទថា **បជ្ឈាយន្តា** បានដល់ សោកសៅហើយ ។

[ ២៨៤ ] បទថា **យតោ និវាតំ តតោ បវាតំ** សេចក្តីថា ក្នុងទីទីណាដែលហប់ខ្យល់ គឺមិនមានខ្យល់តិចតួចក្នុងទីនោះ កើតមានខ្យល់បក់ខ្លាំងឡើង ។ បទថា **ឧទកំ មញ្ញេ អាទិត្តំ** បានដល់ ដូចទឹកដែលត្រូវដាំឲ្យក្តៅ ។

[ ២៨៥ ] បទថា **សរសិ ត្វំ ទព្វ ឯវរូបំ កត្តា** សេចក្តីថា ម្នាលទព្វៈ អ្នកធ្វើកម្មបែបនេះ គង់រឭកបានឬ ម្យ៉ាងទៀត សេចក្តីថា ម្នាលទព្វៈ អ្នកគង់រឭក ពាក្យដូចដែលភិក្ខុនីពោលចោទបានឬ ឯពាក្យនេះ បណ្ឌិតគប្បីប្រកបអត្ថយ៉ាងនេះថា អ្នកជាបុគ្គលធ្វើកម្មដូចដែលភិក្ខុនីនេះចោទឬ តែបាឋៈរបស់ពួកអាចារ្យសូធ្យថា **កត្វា** ប្រាកដត្រង់នោះឯង ។

ដោយពាក្យថា **យថា មំ ភន្តេ ភគវា ជានាតិ** នេះ ព្រះថេរៈទូលប្រាប់ដូចម្តេច ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ជាសព្វញ្ញូ ហើយព្រះអង្គក៏ជាខីណាសវៈ ការសេពវត្ថុកាម មិនមានដល់ខ្ញុំព្រះអង្គឡើយ ព្រះមានព្រះភាគ ទ្រង់រមែងជ្រាបខ្ញុំព្រះអង្គនោះៗ នឹងត្រូវពោលថ្វី ក្នុងការសេពវត្ថុកាមនោះ គប្បីជ្រាបខ្ញុំព្រះអង្គ ដូចដែលព្រះមានព្រះភាគទ្រង់ជ្រាបនោះឯង ។

ក្នុងបទថា **ន ខោ ទព្វ ទព្វា ឯវំ និព្វេឋេន្តិ** នេះ បណ្ឌិតគប្បីឃើញអត្ថយ៉ាងនេះថា ម្នាលទព្វៈ អ្នកប្រាជ្ញ គឺបណ្ឌិត រមែងមិនពោលបណ្តោះបណ្តៃដូចអ្នកពោលពាក្យបណ្តោះបណ្តៃ ព្រោះមានអ្នកដទៃជាបច្ច័យ ( ព្រោះជឿអ្នកដទៃ ) ម្យ៉ាងវិញទៀត បណ្ឌិតទាំងឡាយ រមែងពោលដោះស្រាយ

ដោយកម្មដែលខ្លួនដឹងទាំងនោះ ។

ដោយបទថា **សចេ តយា កតំ កតំ** នេះ ព្រះមានព្រះភាគទ្រង់សម្តែងដូចម្តេច ទ្រង់សម្តែងថា ព្រោះថា បុគ្គលណាមួយ មិនអាចធ្វើបុគ្គលដែលមិនធ្វើ ( ខុស ) ឲ្យជាអ្នកធ្វើ ( ខុស ) ឬអ្នកធ្វើ ( ខុស ) ឲ្យជាអ្នកមិនធ្វើ ( ខុស ) ដោយកម្លាំងបុគ្គល ឬដោយកម្លាំងគាំទ្ររបស់បក្ខពួកបានឡើយ ព្រោះហេតុនោះ កម្មណាដែលខ្លួនធ្វើឯងក្តី មិនបានធ្វើក្តី គួរពោលតែកម្មនោះប៉ុណ្ណោះ ។

សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគ សូម្បីទ្រង់ជ្រាប តែមិនត្រាស់ថា តថាគតដឹង អ្នកជាវិណាសវៈ ទោសរបស់អ្នកមិនមាន ភិក្ខុនីនេះពោលកុហក ឆ្លើយថា ព្រោះទ្រង់មានករុណាបុគ្គលដទៃ ។ បើព្រះមានព្រះភាគគប្បីត្រាស់គ្រប់ៗ រឿងដែលព្រះអង្គទ្រង់ជ្រាប ព្រះអង្គត្រូវអ្នកដទៃដែលត្រូវអាបត្តិបារាជិកហើយសួរ ចាំបាច់ត្រាស់ពាក្យថា តថាគតដឹង អ្នកត្រូវអាបត្តិបារាជិក ។ បន្ទាប់ពីនោះ បុគ្គលនោះ គប្បីចងអាឃាតថា កាលមុនព្រះមានព្រះភាគអង្គនេះ ទ្រង់ធ្វើឲ្យព្រះទព្វមល្លបុត្របរិសុទ្ធបាន ឥឡូវនេះ ទ្រង់ធ្វើអញឲ្យជាអ្នកបរិសុទ្ធមិនបាន តទៅនេះ អញនឹងនិយាយអ្វីដល់បុគ្គលណាបាន ក្នុងឋានៈដែលព្រះសាស្តា ទ្រង់នៅមានលំអៀងក្នុងពពួកសាវ័ក ភាពជាសព្វញ្ញូរបស់ព្រះសាស្តានេះ នឹងមានអំពីទីណា ដូច្នេះហើយ ត្រូវជាបុគ្គលចូលដល់អបាយ ។ ព្រោះហេតុនោះ សូម្បីព្រះមានព្រះភាគទ្រង់ជ្រាបក៏មិនត្រាស់ ព្រោះទ្រង់មានមេត្តាសត្វដទៃនេះ ។ មានពាក្យពោលបន្ថែមបន្តិច

បន្តួចទៀតថា ព្រះមានព្រះភាគមិនត្រាស់ ព្រោះទ្រង់ចៀសវាងពាក្យតិះដៀល ។

បើព្រះមានព្រះភាគគប្បីត្រាស់យ៉ាងនេះ នឹងគប្បីមានការពោលនិន្ទាយ៉ាងនេះថា ឈ្មោះថា ការចេញចាកអាបត្តិរបស់ព្រះទព្វមល្លបុត្រធ្ងន់ពេកណាស់ តែបានព្រះសម្មាសម្ពុទ្ធជាបន្ទាល់សាក្សី ទើបចេញបាន ។ ហើយពួកបាបភិក្ខុយល់លក្ខណៈនៃការចេញចាកអាបត្តិនេះ យ៉ាងនេះថា សូម្បីក្នុងសម័យពុទ្ធកាល ការបរិសុទ្ធ ឬមិនបរិសុទ្ធ រមែងមានដោយសាក្សី ពួកយើងដឹង បុគ្គលនេះជាអ្នកមិនបរិសុទ្ធ ដូច្នេះ គប្បីធ្វើឲ្យភិក្ខុដែលជាលជ្ជីវិនាស ដូច្នេះ ។ ន័យម្យ៉ាងទៀត ក្នុងអនាគត ពួកភិក្ខុ កាលវិនិច្ឆ័យរឿងហើយ នឹងឲ្យដើមចោទៗ ហើយឲ្យចុងចោទឆ្លើយ បើលោកធ្វើ ចូរពោលថា ខ្ញុំធ្វើ ហើយកាន់យកតែប្បដ្ឋារបស់ពួកលជ្ជីភិក្ខុធ្វើកម្មចុះ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់តាំងបែបផែនក្នុងលក្ខណៈនៃព្រះវិន័យ ទើបមិនត្រាស់ថា តថាគតដឹង តែត្រឡប់ជាត្រាស់ថា បើអ្នកធ្វើ ចូរពោលថា ខ្ញុំធ្វើ ដូច្នេះ ។

បទថា **ឆាភិជាឆាមិ សុបិនន្តេនបិ មេថុនំ ធម្មំ បដិសេវិតា** សេចក្តីថា សូម្បីដោយការយល់សប្តិ ខ្ញុំព្រះអង្គក៏មិនដែលយល់សប្តិសេពមេថុនធម្មឡើយ ។ មានពាក្យអធិប្បាយថា ខ្ញុំព្រះអង្គមិនបានសេព ។ ម្យ៉ាងទៀត មានរូបអត្ថដែលលោកពោលទុកថា ខ្ញុំព្រះអង្គមិនស្គាល់មេថុនធម្ម សូម្បីដោយការយល់សប្តិថាជាអ្នកសេព ។ តែបាឋៈរបស់ពួកអាចារ្យអ្នកសូធ្យ

ពោលថា **បដិសេវិត្វា** ប្រាកដត្រង់នោះឯង ។ បទថា **បគេវ ជាគរោ** សេចក្ដីថា ខ្ញុំព្រះអង្គរឮកមិនឃើញសូម្បី ពីមុនមក ។

បទថា **តេនហិ ភិក្ខវេ មេត្តិយំ ភិក្ខុនឹ នាសេថ** មានពាក្យអធិប្បាយថា ព្រោះពាក្យរបស់ព្រះទព្វមល្លបុត្រ និងមេត្តិយាភិក្ខុនីនេះ មិនស៊ីសេចក្ដីគ្នា ដូច្នោះ ពួកអ្នកចូរឲ្យមេត្តិយាភិក្ខុនីវិនាសបង់ ។ ក្នុងពាក្យនោះ នាសនៈមាន ៣ យ៉ាង គឺលិង្គនាសនៈ ១ សំវាសនាសនៈ ១ ទណ្ឌកម្មនាសនៈ ១ បណ្ដានាសនៈទាំងនោះ នាសនៈថា សាមណេរប្រទូស្ត ( ភិក្ខុនី ) សង្ឃគប្បីឲ្យវិនាសបង់ ឈ្មោះថា លិង្គនាសនៈ ។ ពួកភិក្ខុធ្វើឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិក្ដី មិនសម្ដែងអាបត្តិក្ដី ព្រោះមិនលះបង់ទិដ្ឋិលាមកចេញក្ដីនេះឈ្មោះថា សំវាសនាសនៈ ។ ពួកភិក្ខុធ្វើទណ្ឌកម្ម ( ដល់សមណុទ្ទេស ) ថា នែ មនុស្សក្រៅការ អ្នកឯងចូរចៀសចេញទៅ ចូរវិនាសទៅ នេះឈ្មោះទណ្ឌកម្មនាសនៈ តែក្នុងឋានៈនេះ ព្រះមានព្រះភាគទ្រង់សំដៅយកលិង្គ-នាសនៈ ទើបត្រាស់ថា ពួកអ្នកចូរនាសនៈមេត្តិយាភិក្ខុនីចេញ ដូច្នេះ ។

ដោយបទថា **ឥមេ ច ភិក្ខូ អនុយុញ្ជថ** នេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងព្រះបំណងនេះថា ភិក្ខុនីនេះមិនមែនធ្វើតាមធម្មតារបស់ខ្លួន គង់ត្រូវពួកភិក្ខុដទៃញុះញង់ពិតប្រាកដ ព្រោះហេតុនោះ ពួកអ្នកចូរផ្ទៀងផ្ទាត់ គឺសាកសួរ ចូរស្គាល់ភិក្ខុដែលញុះញង់ទាំងនោះ ។

សួរថា មេត្តិយាភិក្ខុនី ព្រះមានព្រះភាគទ្រង់ប្រើឲ្យសឹកដោយប្ដេជ្ញា ឬទ្រង់ឲ្យសឹកដោយមិនប្ដេជ្ញា ឆ្លើយថា ក្នុងការទាក់ទងគ្នានេះ មានពាក្យដែល

ត្រូវពោលបន្ថែមខ្លះតិចតួច ដំបូង បើទ្រង់ឲ្យសឹកដោយបដិញ្ញា ( ព្រះថេរៈនឹងជាអ្នកធ្វើខុស ) បើទ្រង់ឲ្យសឹកដោយមិនបដិញ្ញា ព្រះថេរៈជាអ្នកមិនធ្វើ ( ខុស ) មិនមានទោស ។

ក្នុងរជ្ជកាលនៃព្រះបាទកាតិយរាជ ព្រះថេរៈសម្នាក់មហាវិហារ និងសម្នាក់អភយគិរីវិហារ មានការវិវាទគ្នា ( ជជែកដេញដោលគ្នា ) ព្រោះវាទៈនេះឯង ។ សម្នាក់អភយគិរីវិហារអាងសូត្ររបស់ខ្លួន ពោលថា ក្នុងវាទៈរបស់ពួកលោក ព្រះថេរៈជាអ្នកធ្វើ ( ខុស ) ។ ខាងសម្នាក់មហាវិហារអាងសូត្ររបស់ខ្លួន ពោលថា ក្នុងវាទៈរបស់ពួកលោក ព្រះថេរៈជាអ្នកមិនធ្វើ ( ខុស ) ។ ទើបបញ្ហាមិនចុះសម្រុងគ្នា ។ ព្រះរាជាទ្រង់ជ្រាប ហើយប្រាប់ឲ្យព្រះថេរៈទាំងឡាយប្រជុំគ្នា ទ្រង់ប្រើអមាត្យជាតិព្រាហ្មណ៍ ឈ្មោះទីឃការាយនៈថា អ្នកចូរស្តាប់ពាក្យសម្តីរបស់ព្រះថេរៈទាំងឡាយ ។ បានឮថា អមាត្យជាបណ្ឌិត ឈ្លាសក្នុងភាសាដទៃ ។ អមាត្យនោះ ពោលថា បពិត្រលោកម្ចាស់ សូមព្រះថេរៈពោលសូត្រចុះ ។ លំដាប់នោះ ព្រះថេរៈសម្នាក់អភយគិរីវិហារ បានពោលសូត្ររបស់ខ្លួនថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ពួកអ្នកចូរឲ្យមេត្តិយាភិក្ខុនីសឹកចេញដោយបដិញ្ញារបស់ខ្លួន ។ អមាត្យប្រាប់ថា លោកម្ចាស់ដ៏ចម្រើន ក្នុងវាទៈរបស់ពួកលោកម្ចាស់ ព្រះថេរៈជាអ្នកធ្វើ ( ខុស ) មានទោស ។

ចំណែកព្រះថេរៈសម្នាក់មហាវិហារ បានពោលសូត្ររបស់ខ្លួនថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ពួកអ្នកចូរឲ្យមេត្តិយាភិក្ខុនីសឹកចេញ អមាត្យប្រាប់

ថា លោកម្ចាស់ដ៏ចម្រើន ក្នុងវាទៈរបស់ពួកលោកម្ចាស់ ព្រះថេរៈមិនមែនជាអ្នកធ្វើ ( ខុស ) មិនមានទោស ។ ក្នុង ២ សូត្រនេះ សូត្រណាត្រឹមត្រូវ សូត្រដែលពោលខាងក្រោយត្រឹមត្រូវ ព្រោះសូត្រនេះ អដ្ឋកថាចារ្យទាំង-ឡាយ ពិចារណាហើយ ។

ភិក្ខុចោទភិក្ខុផងគ្នា ដោយអន្ទិមវត្ថុ ដែលមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស ចោទភិក្ខុនី ត្រូវអាបត្តិទុក្កដ តែក្នុងកុរុន្ទីថា ត្រូវអាបត្តិបាចិត្តិយ ព្រោះមុសាវាទ ។ ក្នុងន័យមុន និងន័យក្រោយនោះ មានការវិភាគពិចារណាដូចតទៅនេះថា ន័យខាងដើម ត្រូវត្រឹមអាបត្តិទុក្កដប៉ុណ្ណោះ ត្រឹមត្រូវ ព្រោះមានបំណងចោទ ។ សូម្បីកាលមានការពោលកុហក ក៏ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុ ព្រោះ ( ចោទ ) ភិក្ខុផងគ្នា ហើយសូម្បីមានការពោលកុហក ត្រូវអាបត្តិបាចិត្តយ ព្រោះឱមសវាទប៉ុណ្ណោះ ដល់ភិក្ខុដែលមានការឃើញថា បរិសុទ្ធ ចោទភិក្ខុមិនបរិសុទ្ធ ដោយបំណងនឹងជេរ មិនមែនអាបត្តិបាចិត្តិយ ព្រោះសម្បជានមុសាវាទ យ៉ាងណា សូម្បីក្នុងអធិការនេះ ក៏ដូច្នោះ ត្រូវអាបត្តិបាចិត្តិយ ព្រោះសម្បជានមុសាវាទ មិនត្រូវព្រោះមានបំណងចោទ ត្រូវត្រឹមអាបត្តិទុក្កដប៉ុណ្ណោះ ត្រឹមត្រូវហើយ ។ សូម្បីក្នុងន័យក្រោយ ត្រូវអាបត្តិបាចិត្តិយតែម្យ៉ាង ក៏ត្រឹមត្រូវ ព្រោះជាមុសាវាទ តែក្នុងគោលព្រះបាលី មិនមានពាក្យថា ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុ ព្រោះ ( ចោទ ) ភិក្ខុផងគ្នា ដោយការចោទ ត្រូវសង្ឃាទិសេសក្នុងភិក្ខុផងគ្នា ដល់ភិក្ខុដែលមានបំណងនឹងជេរ ព្រោះមុសាវាទ តែត្រូវទុក្កដដល់ភិក្ខុដែលមាន

បំណងនឹងជេរ ក្នុងឱមសវាទ និងព្រោះតាមចោទភិក្ខុនី មានពាក្យថា ត្រូវអាបត្តិបាចិត្តិយ ក្នុងសម្បជានមុសាវាទ ព្រោះហេតុនោះ ត្រូវអាបត្តិបាចិត្តិយតែម្យ៉ាង ទើបត្រឹមត្រូវ ។ ក្នុងវាទៈនោះ បណ្ឌិតគួរពិចារណាដូចតទៅនេះ សួរថា កាលមិនមានបំណងនឹងចោទ ត្រូវអាបត្តិបាចិត្តិយ បើមានបំណងនឹងចោទនោះ គប្បីត្រូវអាបត្តិអ្វី ឆ្លើយថា បណ្តាអាបត្តិបាចិត្តិយ និងសង្ឃាទិ-សេសនោះ ព្រោះកាលសម្រេចជាបាចិត្តិយដល់ភិក្ខុដែលពោលកុហក ព្រះមានព្រះភាគ ទ្រង់កាត់អាបត្តិបាចិត្តិយនោះ ព្រោះការចោទសង្ឃាទិសេសមិនមានមូល ព្រោះដូច្នោះ កាលមានបំណងនឹងចោទ ឱកាសនៃបាចិត្តិយ ព្រោះសម្បជានមុសាវាទ ទើបមិនប្រាកដ និងមិនអាចមិនត្រូវអាបត្តិដល់ភិក្ខុអ្នកចោទ ព្រោះដូច្នោះ បណ្តាន័យទាំង ២ នេះ ន័យទី ១ នោះឯង ប្រាកដបរិសុទ្ធជាង ។

ម្យ៉ាងទៀត ភិក្ខុនីចោទភិក្ខុនីផងគ្នា ដោយអន្តិមវត្ថុដែលមិនមានមូល ត្រូវអាបត្តិសង្ឃាទិសេស ចោទភិក្ខុ ត្រូវអាបត្តិទុក្កដ ។ បណ្តាសង្ឃាទិសេស និងទុក្កដនោះ សង្ឃាទិសេសជាវុដ្ឋានគាមិនី ( ចេញដោយការធ្វើកម្ម ) ។ អាបត្តិទុក្កដជាទេសនាគាមិនី ( ចេញបានដោយការសម្តែង ) ការផ្សឹកភិក្ខុនី ព្រោះសង្ឃាទិសេស និងទុក្កដទាំងនេះ ទើបមិនមាន ។

ម្យ៉ាងទៀត មេត្តិយាភិក្ខុនីឈរពោលកុហកចំពោះព្រះភក្ត្រព្រះមានព្រះភាគដោយហេតុណា ហេតុនោះ ទើបនាងត្រូវអាបត្តិបាចិត្តិយ ព្រោះសម្ប-ជានមុសាវាទ ព្រោះបាចិត្តិយនេះ នាសនៈក៏មិនមាន ។ តែព្រោះមេត្តិយា-

*ភិក្ខុនីនោះ តាមធម្មតាជាភិក្ខុនីអាក្រក់លាមកទ្រុស្តសីល ហើយឥឡូវនេះ នាងក៏ពោលដោយការសម្គាល់ថា អញនេះឯងជាអ្នកទ្រុស្តសីល ព្រោះហេតុនោះទើបព្រះមានព្រះភាគឲ្យផ្សឹកនាងភិក្ខុនីនោះចេញ ព្រោះភាពជាអ្នកមិនបរិសុទ្ធនោះឯង ។*

*បទថា* **អថខោ មេត្តិយភុម្មជកា** *សេចក្តីថា កាលព្រះមានព្រះភាគត្រាស់ថា ពួកអ្នកចូរឲ្យនាងមេត្តិយាភិក្ខុនីសឹកចេញយ៉ាងនេះ ហើយសាកសួរភិក្ខុទាំងនេះ ហើយទ្រង់ក្រោកចាកអាសនៈ ចូលទៅកាន់វិហារ ។ ភិក្ខុទាំងនោះ ឃើញភិក្ខុនីនោះ ត្រូវភិក្ខុទាំងនោះឲ្យសឹក ដោយពាក្យថា ពួកលោកចូរឲ្យសំពត់សជល់ភិក្ខុនីនេះឥឡូវនេះ ទើបបានប្រកាសកំហុសរបស់ខ្លួន ព្រោះបំណងនឹងជួយភិក្ខុនីនោះឲ្យផុតទោស កាលសម្តែងអត្ថនេះ ទើបធម្មសង្គាហកាចារ្យទាំងឡាយពោលពាក្យថា* **អថខោ មេត្តិយភុម្មជកា** *ជាដើម ។*

# អធិប្បាយ

## សិក្ខាបទទី៨ក្នុងបឋមទុដ្ឋទោសសិក្ខាបទ

[ ២៤៦ ] ពីរបទថា **ទុដ្ឋោ ទោសោ** បានដល់ ជាអ្នកត្រូវទោសៈប្រទូស្តផង ជាអ្នកប្រទូស្តហើយផង ។ ពិតហើយ កាលទោសៈកើតឡើងហើយ បុគ្គលរមែងឈ្មោះថា ត្រូវទោសៈនោះប្រទូស្តហើយ គឺឲ្យលះភាពជាប្រក្រតីហើយ ព្រោះដូច្នោះ ទើបលោកហៅថា **ទុដ្ឋ** ។ បុគ្គលមានការអាក់អន់នោះ រមែងប្រទូស្តអ្នកដទៃ គឺធ្វើអ្នកដទៃឲ្យវិនាស ព្រោះដូច្នោះ ទើបលោកហៅថា **ទោស** ។ ដោយប្រការយ៉ាងនេះ ពាក្យថា **ទុដ្ឋោ ទោសោ** នេះសម្តែងដោយការផ្សេងគ្នានៃអាការរបស់បុគ្គលត្រឹមតែម្នាក់ ដោយហេតុនោះទើបលោកពោលថា **ទុដ្ឋោ ទោសោតិ ទូសិតោ ចេវ ទូសកោ ច** ។ ក្នុងពាក្យថា **ទុដ្ឋោ ទោសោ** នោះ អ្នកសិក្សាគួរពិចារណាលក្ខណៈនៃសព្ទ ។ ព្រោះថា បុគ្គលដែលដល់ព្រមដោយការអាក់អន់នោះ ដល់នូវការរាប់ថាថ្នាំងថ្នាក់ មានទោសៈ រមែងជាអ្នកតាំងនៅក្នុងភាពជាអ្នកក្រោធជាដើមនោះឯង ព្រោះហេតុនោះ ក្នុងបទភាជនីយ៍នៃបទពីរថា **ទុដ្ឋោ ទោសោ** នោះ ទើបលោកពោលពាក្យជាដើមថា **កុបិតោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **កុបិតោ** បានដល់ ដល់នូវភាវៈកម្រើក គឺឃ្លាតទៅអំពីប្រក្រតី ។

បទថា **អនត្តមនោ** បានដល់ បុគ្គលមិនមានចិត្តជារបស់ខ្លួន គឺមានចិត្តមិនតាំងនៅក្នុងអំណាចរបស់ខ្លួន ។ ម្យ៉ាងទៀត បុគ្គលមានចិត្តដែលបីតិនិងសុខមិនជ្រួតជ្រាប គឺ មានចិត្តប្រាសចាកបីតិ និងសុខ ព្រោះហេតុនោះ

ទើបឈ្មោះថា **អនត្តមន** ( មិនត្រូវចិត្ត ) ។ បទថា **អនភិរទ្ធោ** គឺមិនជួប នូវសេចក្តីសុខ ម្យ៉ាងទៀត បុគ្គលមិនដល់នូវភាពជ្រះថ្លា ដូច្នោះ ទើបឈ្មោះ ថា **អនភិរទ្ធ** ( មិនពេញចិត្ត ) ។ ចិត្តរបស់បុគ្គលនោះត្រូវបដិឃៈប៉ះខ្ទប់ ហើយ ហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា **អាហតចិត្ត** ( ការចង្អៀត ចង្អល់ចិត្ត ) ។ បង្គោលស្ទឹង គឺបដិឃៈ ពោល គឺភាពដែលចិត្តរឹងត្អឹង និង ចិត្តស្មោកគ្រោក ដូចសំរាមកើតហើយដល់បុគ្គលនោះ ព្រោះដូច្នោះ ទើប បុគ្គលនោះឈ្មោះថា **ខិលជាត** ( ការឈឺចិត្ត ) ។

បទថា **អប្បតីតោ** បានដល់ មិនដល់ចំពោះ ( មិនត្រេកអរ ) គឺ វៀរចាកបីតិ និងសុខជាដើម សេចក្តីថា ដែលបីតិ និងសុខជាដើមមិនជ្រួត ជ្រាប តែក្នុងបទភាជនីយ៍ ព្រះឧបាលីពោលថា **តេន ច កោបេន** ជាដើម ដើម្បីសម្តែងធម៌ទាំងឡាយដែលមានអំណាចធ្វើឲ្យមិនត្រេកអរ ។

បណ្តាបទទាំងនោះ បទថា **តេន ច កោបេន** បានដល់ ព្រោះការ ក្រោធដែលជាហេតុឲ្យហៅភិក្ខុនោះថា បុគ្គលមានការអាក់អន់ និងបុគ្គល ក្រោធ ។ ពិតហើយ ពាក្យទាំង ២ នេះ មានអាការដូចគ្នា ព្រោះឲ្យលះ បកតិភាព ។ បទថា **តេន ច ទោសេន** បានដល់ ព្រោះទោសៈដែលជា ហេតុឲ្យហៅភិក្ខុនោះថា មានទោសៈ ។ ដោយបទទាំង ២ នេះ ព្រះឧបាលី សម្តែងសង្ខារក្ខន្ធដូចគ្នា ។ បទថា **តាយ ច អនត្តមនតាយ** បានដល់ ព្រោះការមិនត្រូវចិត្ត ដែលជាហេតុឲ្យហៅភិក្ខុនោះថា អ្នកអន់ចិត្ត ។ បទថា **តាយ ច អនភិរទ្ធិយា** បានដល់ ព្រោះការមិនពេញចិត្ត ដែលជាហេតុឲ្យ

ហៅភិក្ខុនោះថា អ្នកមិនត្រេកអរ ។ ដោយពាក្យទាំង ២ នេះ ព្រះឧបាលី សម្ដែងវេទនាខន្ធ ។

## អធិករណ៍មានមូល និងមិនមានមូល

ក្នុងបទថា **អមូលកេន ចាវាជិកេន** នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បារាជិកនោះមិនមានមូល ព្រោះហេតុនោះ ទើបឈ្មោះថា **អមូលក** ។ ឯភាពដែលបារាជិកនោះមិនមានមូលនោះ ទ្រង់បំណងយកដោយអំណាចនៃការចោទ មិនមែនដោយអំណាចនៃចម្ងើយ ព្រោះដូច្នោះ ដើម្បីសម្ដែងអត្ថនោះក្នុងបទភាជនីយ៍ ទើបព្រះឧបាលីពោលថា ដែលឈ្មោះថាមិនមានមូល គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស ។

ដោយបទភាជនីយ៍ថា **អទិដ្ឋំ** ជាដើមនោះ លោកសម្ដែងអធិប្បាយទុកថា បារាជិកដែលចោទដោយមិនបានឃើញ មិនបានឮ មិនបានរង្កៀស ក្នុងបុគ្គលដែលជាអ្នកត្រូវចោទឡើយ ឈ្មោះថា មិនមានមូល ព្រោះមិនមានមូល ពោលគឺ ការឃើញ ការឮ និងការរង្កៀសនេះ ។ ឯអ្នកចុងចោទនោះ ទោះត្រូវបារាជិកក្ដី ឬមិនត្រូវក្ដី ការដែលអ្នកចុងចោទត្រូវ ឬមិនត្រូវនេះមិនជាប្រមាណក្នុងសិក្ខាបទនេះ ។

ក្នុងបទថា **អទិដ្ឋំ** ជាដើមនោះ ដែលឈ្មោះថា មិនបានឃើញ គឺមិនបានឃើញដោយចក្ខុប្បសាទក្ដី ដោយទិព្វចក្ខុរបស់ខ្លួនក្ដី ។ ឈ្មោះថា មិនបានឮ គឺមិនបានឮបុគ្គលណាមួយ គេនិយាយគ្នាយ៉ាងនោះ ។ ដែលឈ្មោះថា មិនបានរង្កៀស គឺមិនបានរង្កៀសដោយចិត្ត ។

ដែលឈ្មោះថា **ទិដ្ឋំ** គឺខ្លួនឯងក្តី អ្នកដទៃបានឃើញដោយចក្ខុប្បសាទក្តី ដោយទិព្វចក្ខុក្តី ។ ដែលឈ្មោះថា បានឮ គឺបានឮមកដូចដែលបានឃើញនោះឯង ។ ដែលឈ្មោះថា បានរង្កៀស គឺខ្លួនឯងក្តី អ្នកដទៃក្តី រង្កៀស ។ ក្នុងរឿងបានឃើញជាដើម ខ្លួនឯងបានឃើញមក ទើបឈ្មោះថា បានឃើញ ។ ក្នុងលក្ខណៈទាំងអស់នេះ គឺអ្នកដទៃបានឃើញ ខ្លួនឯងបានឮ អ្នកដទៃបានឮ អ្នកដទៃបានរង្កៀស តាំងនៅក្នុងឋានៈដែលខ្លួនបានឮមកប៉ុណ្ណោះ ។ ឯរឿងរង្កៀសមាន ៣ យ៉ាង គឺរង្កៀសដោយអំណាចបានឃើញ ១ រង្កៀសដោយអំណាចបានឮ ១ រង្កៀសដោយអំណាចបានដឹង ១ ក្នុងរឿងរង្កៀស ៣ យ៉ាងនោះ ដែលឈ្មោះថា រង្កៀសដោយអំណាចបានឃើញ គឺ ភិក្ខុមួយអង្គចូលទៅកាន់គុម្ពោតឈើមួយចំណែកក្បែរស្រុក ដោយការបន្ទោបង់ឧច្ចារៈ និង បស្សាវៈ ខណៈនោះ មានស្រីម្នាក់ ក៏ចូលទៅកាន់គុម្ពោតឈើនោះ ដោយករណីយកិច្ចឯណាមួយដូចគ្នា ហើយត្រឡប់ទៅ ទាំងភិក្ខុក៏មិនបានឃើញស្រីនោះ ទាំងស្រីក៏មិនបានឃើញភិក្ខុ ទាំងពីរនាក់ក៏ចៀសចេញទៅតាមការពេញចិត្ត មិនបានឃើញគ្នាឡើយ ភិក្ខុមួយអង្គទៀតកំណត់ ដោយកអាការដែលអ្នកទាំងពីរចេញទៅអំពីគុម្ពោតព្រៃនោះ ទើបរង្កៀសថា ជនទាំងនេះធ្វើកម្មហើយ ឬនឹងធ្វើដោយពិត នេះឈ្មោះថា រង្កៀសដោយអំណាចបានឃើញ ។

ដែលឈ្មោះថា រង្កៀសដោយអំណាចបានឮ គឺបុគ្គលខ្លះក្នុងលោកនេះ បានឮពាក្យបដិសណ្ឋារៈដូច្នេះ របស់ភិក្ខុជាមួយនឹងមាតុគ្រាម ក្នុងឱកាស

ដែលងងឹត ឬកំបាំង អ្នកដទៃដែលនៅក្នុងទីជិត ក៏មិនជ្រាបថា មាន ឬមិន មាន បុគ្គលនោះរង្កៀសថា ជនទាំងនេះធ្វើកម្មហើយ ឬថា នឹងធ្វើពិតប្រាកដ នេះឈ្មោះថា រង្កៀសដោយអំណាចបានឮ ។

ដែលឈ្មោះថា រង្កៀសដោយអំណាចបានដឹង គឺកណ្តាលរាត្រី ពួកអ្នកលេងជាច្រើនកាន់យកផ្កា គ្រឿងក្រអូប សាច់ និងស្រាជាដើមហើយ ទៅកាន់វិហារដោយដៃនមួយកន្ទែងមួយអន្ទើដោយពួកស្រី លេងតាមសប្បាយ ត្រង់មណ្ឌប ឬត្រង់សាលាឆាន់ជាដើម ចោលផ្កាជាដើម ឲ្យរាត់រាយ ហើយនាំគ្នាទៅ ក្នុងថ្ងៃរះឡើង ពួកភិក្ខុឃើញអាការប្លែកនោះហើយ នាំគ្នាសុីបសួរថា នេះជាកម្មរបស់អ្នកណា ក្នុងបណ្តាភិក្ខុទាំងនោះ ភិក្ខុអង្គខ្លះ ក្រោកឡើងអំពីព្រលឹម ប្រតិបត្តិមណ្ឌប ឬសាលាឆាន់ ដោយមហាសេនាសនវត្ត ចាំបាច់ត្រូវចាប់ផ្កាជាដើម អង្គខ្លះត្រូវការបូជាដោយផ្កាជាដើម ដែលខ្លួនយកមកអំពីត្រកូលឧបដ្ឋាក អង្គខ្លះត្រូវផឹកថ្នាំត្រាំ ឈ្មោះអារិដ្ឋ ដើម្បីជាភេសជ្ជៈ ។ គ្រានោះ ពួកភិក្ខុទាំងនោះ សុីបសួរថា កម្មនេះរបស់បុគ្គលណា ទើបហិតក្លិនដៃ និងក្លិនមាត់ ហើយរង្កៀសភិក្ខុទាំងនោះ នេះឈ្មោះថា រង្កៀសដោយអំណាចបានដឹង ។

ក្នុងរឿងបានឃើញជាដើមនោះ រឿងបានឃើញដែលមានមូលក៏មាន មិនមានមូលក៏មាន រឿងបានឃើញនោះឯង មានមូលដោយអំណាចនៃសញ្ញាក៏មាន មិនមានមូលដោយអំណាចនៃសញ្ញាក៏មាន ។ សូម្បីក្នុងរឿងបានឮ ក៏ន័យនេះ ។ តែក្នុងរឿងដែលរង្កៀស រឿងដែលរង្កៀសដោយ

អំណាចបានឃើញ មានមូលក៏មាន មិនមានមូលក៏មាន រឿងដែលរង្កៀសដោយអំណាចបានឃើញនោះឯង មានមូលដោយអំណាចនៃសញ្ញាក៏មាន មិនមានមូលដោយអំណាចនៃសញ្ញាក៏មាន ។ ក្នុងរឿងរង្កៀសដោយការបានឮ និងការបានដឹងក៏ន័យនេះ ។

ក្នុងពាក្យថា មានមូលជាដើមនោះ រឿងបានឃើញដែលឈ្មោះថាមានមូល គឺភិក្ខុនោះបានឃើញភិក្ខុត្រូវអាបត្តិបារាជិកពិតៗ ហើយពោលថា ខ្ញុំឃើញ ។ ដែលឈ្មោះថា មិនមានមូល គឺបុគ្គលនោះ ឃើញភិក្ខុចេញមកអំពីឱកាសកំបាំង តែមិនឃើញការកន្លងល្មើស ពោលថា ខ្ញុំឃើញ ។ រឿងដែលឃើញនោះឯង ឈ្មោះថា មានមូលដោយអំណាចនៃសញ្ញា គឺបុគ្គលនោះត្រឹមតែបានឃើញប៉ុណ្ណោះ ជាអ្នកសម្គាល់ថា បានឃើញ ហើយចោទ ។ ដែលឈ្មោះថា មិនមានមូលដោយអំណាចនៃសញ្ញា គឺខាងដើម បុគ្គលនោះឃើញការកន្លងល្មើសដោយបារាជិក ខាងក្រោយត្រឡប់កើតមានការសម្គាល់ថា មិនបានឃើញ ។ បុគ្គលនោះធ្វើឲ្យមិនមានមូលដោយសញ្ញា ហើយចោទថា ខ្ញុំឃើញ ។ សូម្បីរឿងដែលរង្កៀសដោយអំណាចនៃការបានឮ និងបានជ្រាប ក៏គប្បីជ្រាបដោយពិស្តារតាមន័យនេះឯង ។ ក្នុងសិក្ខាបទនេះ កាលភិក្ខុចោទភិក្ខុដែលខ្លួនឃើញដោយអាការគ្រប់យ៉ាង ដោយបារាជិកដែលមានមូលក្តី មានមូលដោយអំណាចនៃសញ្ញាក្តី មិនត្រូវអាបត្តិ ។ ត្រូវអាបត្តិចំពោះតែភិក្ខុអ្នកចោទដោយបារាជិកដែលមិនមានមូល ឬមិនមានមូលដោយអំណាចនៃសញ្ញា ។

បទថា **អនុទ្ធំសេយ្យ** សេចក្តីថា បានដល់ គប្បីកម្ចាត់ គឺគប្បីកម្ចាត់សង្កត់សង្កិន គ្របសង្កត់ ។ ព្រោះភិក្ខុចោទដោយខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃចោទក្តី ឈ្មោះថា រមែងធ្វើការចោទនោះទាំងអស់ ដូច្នោះ ក្នុងបទភាជនីយ៍ ទើបព្រះឧបាលីពោលថា ចោទឯងក្តី ឲ្យអ្នកដទៃចោទក្តី ។

ក្នុងពីរបទថា **ចោទេតិ វា ចោទាបេតិ វា** នោះ បទថា **ចោទេតិ** សេចក្តីថា ភិក្ខុចោទឯង ដោយពាក្យជាដើមថា លោកជាអ្នកត្រូវធម៌ដល់បារាជិកដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុនោះគ្រប់ៗ ម៉ាត់ ។

បទថា **ចោទាបេតិ** សេចក្តីថា ប្រើភិក្ខុដទៃដែលឈរនៅជិតៗ នឹងខ្លួន ភិក្ខុទទួលប្រើនោះចោទភិក្ខុនោះ តាមពាក្យរបស់ភិក្ខុអ្នកប្រើនោះ ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុអ្នកប្រើឲ្យចោទគ្រប់ៗ វាចាដូចគ្នា ។ ចំណែកភិក្ខុអ្នកទទួលប្រើនោះចោទថា រឿងដែលខ្ញុំបានឃើញ បានឮមាន ដូច្នេះ ក៏ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុទាំងពីរអង្គគ្រប់ៗ វាចាដូចគ្នា ។

## អធិប្បាយ លក្ខណៈនៃការចោទផ្សេងៗ

ដើម្បីការឈ្លាសក្នុងប្រភេទនៃការចោទ ក្នុងសិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបចតុក្កៈជាដើមថា វត្ថុមួយ និងអ្នកចោទក៏ម្នាក់ជាមុនសិន ។ បណ្តាចតុក្កៈទាំងនោះ ភិក្ខុមួយរូប ចោទភិក្ខុមួយរូប ដោយវត្ថុមួយ ។ ការចោទនេះមានវត្ថុមួយ អ្នកចោទក៏មានម្នាក់ ។ ភិក្ខុមានចំនួនច្រើន ចោទភិក្ខុមួយរូប ដោយវត្ថុមួយ ដូចពួកឆព្វគ្គិយភិក្ខុ ៥០០ រូប មានមេត្តិយ និងភុម្មជកភិក្ខុជាប្រធាន ចោទព្រះទព្វមល្លបុត្រដូច្នោះ ការចោទនេះ មានវត្ថុមួយ មានអ្នក

ចោទផ្សេងៗ គ្នា ។ ភិក្ខុមួយរូប ចោទភិក្ខុមួយរូប ដោយវត្ថុច្រើន ចោទនេះ មានវត្ថុផ្សេងៗ គ្នា មានអ្នកចោទម្នាក់ ។ ភិក្ខុមានចំនួនច្រើន ចោទភិក្ខុច្រើនរូបផងគ្នាដោយវត្ថុច្រើន ការចោទនេះមានវត្ថុផ្សេងគ្នា មានអ្នកចោទផ្សេងគ្នា ។

សួរថា បុគ្គលណា រមែងបានដើម្បីចោទ បុគ្គលណា រមែងមិនបាន ឆ្លើយថា ភិក្ខុរូបខ្លះ ជឿពាក្យរបស់អ្នកចោទដែលល្ងង់ រមែងមិនបាន ដើម្បីនឹងចោទ ។

ដែលឈ្មោះថា អ្នកចោទល្ងង់ គឺកាលភិក្ខុច្រើនរូបអង្គុយ ប្រជុំសន្ទនាគ្នា ភិក្ខុមួយរូបពោលដល់វត្ថុបារាជិក ប្រារព្ធដល់ភិក្ខុមួយរូប មិនចំពោះ ។ ភិក្ខុដទៃបានឮពាក្យរបស់ភិក្ខុនោះ ទើបទៅប្រាប់ដល់ភិក្ខុមួយអង្គដទៃ ។ ទើបភិក្ខុរូបនោះទៅរកភិក្ខុនោះ ពោលថា បានឮថា លោកពោលយ៉ាងនេះៗ ដល់ខ្ញុំឬ ទើបភិក្ខុនោះឆ្លើយថា ខ្ញុំមិនដឹងហេតុការណ៍នេះ តែក្នុងខណៈដែលនិយាយ មានពាក្យសម្តីដែលខ្ញុំពោលមិនចំពោះ បើខ្ញុំដឹងថា ពាក្យសម្តីនេះនឹងកើតទុក្ខដល់លោក ខ្ញុំនឹងមិនពោលពាក្យនេះឡើយ នេះឈ្មោះថា អ្នកចោទល្ងង់ ។ អ្នកចោទរូបខ្លះ កាន់យកពាក្យសន្ទនានោះរបស់ភិក្ខុនោះ មិនបានដើម្បីចោទភិក្ខុនោះ ។ តែព្រះមហាបទុម មិនជឿពាក្យសម្តីនេះពោលថា ភិក្ខុដែលសម្បូរដោយសីល រមែងបានដើម្បីនឹងចោទភិក្ខុ ឬភិក្ខុនី និងភិក្ខុនីអ្នកមានសីលបរិបូណ៌ រមែងបានដើម្បីចោទចំពោះភិក្ខុនីប៉ុណ្ណោះ ដូច្នេះ ។ ចំណែកព្រះមហាសុមត្ថេរពោលថា សហធម្មិកទាំង ៥ រមែងបានដូច្នេះ ។ ចំណែកព្រះគោទត្តត្ថេរពោលថា បុគ្គលណាមួយ មិនបានដើម្បីនឹងចោទមិន

មាន ហើយពោលអាងសូត្រនេះថា ស្តាប់ពាក្យរបស់ភិក្ខុហើយ ទើបចោទ ស្តាប់ពាក្យរបស់ភិក្ខុនីហើយ ទើបចោទ ។បេ។ ស្តាប់ពាក្យរបស់សាវកពួកតិរ្ថិយហើយ ទើបចោទ ។ ក្នុងវាទៈរបស់ព្រះថេរៈទាំង ៣ រូប គប្បីកាត់អាបត្តិតាមពាក្យប្តេជ្ញារបស់ចុងចោទប៉ុណ្ណោះ ។

ធម្មតាការចោទនេះ កាលភិក្ខុបញ្ជូនទូតក្តី សំបុត្រក្តី ដំណឹងក្តី ទៅចោទ មិនទាន់ដល់ទីបំផុត ។ តែកាលភិក្ខុឈរនៅក្នុងទីជិត ចោទដោយមេដៃ ឬដោយការបទ្ទឹវាចាប៉ុណ្ណោះ ទើបដល់ទីបំផុត ។ ពិតហើយ ការពោលលាសិក្ខាតែម្យ៉ាង មិនដល់ទីបំផុតដោយមេដៃ ។ ចំណែកការចោទនេះ និងការអួតឧត្តរិមនុស្សធម្មដែលមិនមានពិត រមែងដល់សូម្បីដោយមេដៃនោះឯង ។ ភិក្ខុណា បំណងចោទភិក្ខុមួយអង្គ ក្នុងទីដែលភិក្ខុពីរអង្គនៅឈរជាមួយគ្នា បើភិក្ខុមួយអង្គ ដែលគេបំណងចោទនោះដឹងខ្លួន ការចោទនោះរមែងដល់ទីបំផុត មួយអង្គទៀតដឹង មិនទាន់ដល់ទីបំផុតឡើយ ។ អ្នកចោទបំណងចោទទាំងពីរអង្គ មួយអង្គដឹងក្តី ដឹងទាំងពីរអង្គក្តី រមែងដល់ទីបំផុត ។ ក្នុងការចោទច្រើនរូប ក៏ន័យនេះ ។ ធម្មតាដឹងបានភ្លាមៗ នោះ ធ្វើបានលំបាក តែកាលគិតតាមការដឹងរូបប្រក្រតី ទើបដឹង ក៏រាប់ថា ជាការដឹងបានដូចគ្នា ។ បើដឹងបានក្នុងកាលជាក្រោយ មិនទាន់ដល់ទីបំផុត ។ ពិតហើយ សិក្ខាបទទាំងនេះ គឺការពោលលាសិក្ខាអភូតារោចនសិក្ខាបទ ទុដ្ឋុល្លវាចាសិក្ខាបទ អត្តកាមសិក្ខាបទ ទុដ្ឋទោសសិក្ខាបទ និងភូតារោចនសិក្ខាបទទាំងអស់ មានមាតិកាតែម្យ៉ាងដូចគ្នាទាំងអស់ ។

## ការចោទ ២ យ៉ាង និង ៤ យ៉ាង

ការចោទទាំងពីរនេះ ដោយអំណាចកាយ និងវាចាយ៉ាងនេះ ដែលចែកជា ៣ យ៉ាងបានទៀត គឺចោទតាមដែលបានឃើញ ចោទតាមដែលបានឮ ចោទតាមដែលរង្កៀស ។

នៅមានការចោទ ៤ យ៉ាងទៀត គឺចោទដោយសីលវិបត្តិ ១ ចោទដោយអាចារវិបត្តិ ១ ចោទដោយទិដ្ឋិវិបត្តិ ១ ចោទដោយអាជីវវិបត្តិ ១ ។ បណ្តាការចោទ ៤ យ៉ាងនោះ ការចោទដោយសីលវិបត្តិ គប្បីជ្រាបដោយអំណាចនៃកងអាបត្តិធ្ងន់ ២ កង ។ ចោទដោយអាចារវិបត្តិ គប្បីជ្រាបដោយអំណាចនៃកងអាបត្តិដ៏សេស ។ ចោទដោយទិដ្ឋិវិបត្តិ គប្បីជ្រាបដោយអំណាចនៃមិច្ឆាទិដ្ឋិ និងអន្តគាហិកទិដ្ឋិ ។ ចោទដោយអាជីវវិបត្តិ គប្បីជ្រាបដោយសិក្ខាបទ ៦ ដែលទ្រង់បញ្ញត្តព្រោះអាជីវៈជាហេតុ ។

ការចោទមាន ៤ យ៉ាងទៀត គឺចោទប្រារព្ធវត្ថុ ១ ចោទប្រារព្ធអាបត្តិ ១ ការហាមសង្វាស ១ ការហាមសាមីចិកម្ម ១ ។ បណ្តាការចោទ ៤ យ៉ាងនោះ ការចោទដែលប្រព្រឹត្តទៅយ៉ាងនេះថា លោកសេពមេថុនធម្ម លោកលួចទ្រព្យ លោកសម្លាប់មនុស្ស លោកអួតគុណវិសេសដែលមិនមានពិត ឈ្មោះថា ចោទប្រារព្ធវត្ថុ ។ ការចោទដែលប្រព្រឹត្តទៅដោយន័យថា លោកត្រូវមេថុនធម្មបារាជិកាបត្តិ ឈ្មោះថា ចោទប្រារព្ធអាបត្តិ ។ ការចោទដែលប្រព្រឹត្តទៅយ៉ាងនេះថា ឧបោសថក្តី បវារណាក្តី សង្ឃកម្មក្តី រួមជាមួយលោក មិនមាន ឈ្មោះថា ការហាមសង្វាស ។ តែដោយអាការមានប្រមាណប៉ុណ្ណេះ ការចោទមិនទាន់ដល់ទីបំផុត ។ បើពោលភ្ជាប់ជាមួយពាក្យ

ជាដើមថា លោកមិនមែនជាសមណៈ មិនមែនជាពូជពង្សនៃសក្យបុត្រ ទើបដល់ទីបំផុត ។ ការមិនធ្វើកម្ម មានអភិវាទនកម្ម សាមីចិកម្ម អញ្ជលិកម្ម និង ការបក់ផ្លិតជាដើម ឈ្មោះថា ការហាមសាមីចិកម្ម ។

ការមិនធ្វើសាមីចិកម្មនោះ គប្បីជ្រាបក្នុងវេលាភិក្ខុកំពុងធ្វើអភិវាទនកម្មជាដើមតាមលំដាប់ មិនធ្វើដល់ភិក្ខុមួយរូប ធ្វើដល់ភិក្ខុដ៏សេសប៉ុណ្ណោះៗ ដោយអាការមានប្រមាណប៉ុណ្ណោះ ឈ្មោះថា ចោទ ។ ចំណែកអាបត្តិមិនទាន់ដល់ទីបំផុត ។ តែកាលសួរថា ហេតុអ្វី ទើបលោកមិនធ្វើអភិវាទនកម្មជាដើមដល់ខ្ញុំ ហើយពោលភ្ជាប់ដោយពាក្យជាដើមថា ព្រោះលោកមិនមែនជាសមណៈ លោកមិនមែនពូជពង្សនៃសក្យបុត្រនោះឯង ដូច្នេះ ទើបអាបត្តិដល់ទីបំផុត ។ ភិក្ខុប្រាប់វត្ថុដែលខ្លួនត្រូវការដោយបបរ និងបាយជាដើមដោយពាក្យប្រមាណប៉ុណ្ណោះ មិនទាន់រាប់ថា ជាការចោទ ។

ក្នុងបាតិមោក្ខដ្ឋបនក្ខន្ធកៈ ព្រះឧបាលីពោលការចោទទុកដទៃទៀតដល់ទៅ ១១០ យ៉ាង គឺការចោទដែលមិនជាធម៌ ៥៥ ដែលជាធម៌ ៥៥ យ៉ាងនេះ គឺចាប់តាំងពីព្រះតម្រាស់ដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការបញ្ឈប់បាតិមោក្ខដែលមិនជាធម៌មាន ១ ការបញ្ឈប់បាតិមោក្ខដែលជាធម៌មាន ១ រហូតដល់ការបញ្ឈប់បាតិមោក្ខដែលមិនជាធម៌ ១០ ការបញ្ឈប់បាតិមោក្ខដែលជាធម៌ ១០ ។ ការចោទទាំងនោះ ជា ៣៣០ គឺរបស់ភិក្ខុដែលចោទដោយការបានឃើញឯង ១១០ របស់ភិក្ខុដែលចោទដោយការបានឮ ១១០ របស់ភិក្ខុដែលចោទដោយការរង្កៀស ១១០ ។ ការចោទទាំងនោះ គុណនឹង ៣

គឺសម្រាប់ភិក្ខុដែលចោទដោយកាយ ដោយវាចា ដោយកាយ និងវាចា ទើបរួមជា ៩៩០ ។ ការចោទ ៩៩០ នោះ របស់ភិក្ខុដែលចោទឯងក្តី ឲ្យអ្នកដទៃចោទក្តី មានចំនួនប៉ុណ្ណោះដូចគ្នា ព្រោះដូច្នោះ ទើបមាន ១៩៨០ យ៉ាង ។ បណ្ឌិតគប្បីជ្រាបទៀតថា ការចោទមានច្រើនពាន់ ដោយអំណាចចោទដែលមានមូល និងមិនមានមូល ក្នុងការផ្សេងគ្នានៃមូល មានរឿងដែលឃើញជាដើម ។

## អធិប្បាយ ដើមចោទ និងចុងចោទ តាមន័យអដ្ឋកថា

ម្យ៉ាងទៀត ព្រះអដ្ឋកថាចារ្យតាំងនៅក្នុងឋានៈនេះហើយ នាំយកសូត្រជាច្រើន ដែលព្រះដ៏មានព្រះភាគត្រាស់ហើយ ក្នុងឧបាលិបញ្ចកៈជាដើមយ៉ាងនេះថា ម្នាលឧបាលី ( បើ ) ភិក្ខុមានសេចក្តីប៉ុនប៉ងនឹងកាន់យកនូវអត្តាទាន ( អធិករណ៍ ) ត្រូវប្រកាន់យកនូវអត្តាទានដែលប្រកបដោយអង្គ ៥ និងត្រាស់ថា ម្នាលឧបាលី ភិក្ខុអ្នកចោទ បើមានប្រាថ្នានឹងចោទភិក្ខុដទៃ លុះតែតាំងធម៌ ៥ ប្រការក្នុងខ្លួនឯង ទើបគួរចោទភិក្ខុដទៃបាន ដូច្នេះហើយ ពោលលក្ខណៈអធិករណ៍ ទំនៀមរបស់អ្នកចោទ ទំនៀមរបស់អ្នកជាប់ចោទ កិច្ចដែលសង្ឃគប្បីធ្វើ និងទំនៀមរបស់ភិក្ខុអ្នកពោល ( អ្នកសាកសួរ ) ទាំងអស់ដោយពិស្តារទុកក្នុងអដ្ឋកថា ។ ខ្ញុំនឹងពណ៌នាលក្ខណៈអធិករណ៍ជាដើមនោះ ក្នុងទីតាមដែលពោលមកហើយនោះឯង ។

កាលរឿងត្រូវនាំចូលទៅក្នុងជំនុំសង្ឃហើយ ដោយអំណាចនៃពាក្យចោទឯណានីមួយ បណ្តាពាក្យចោទ ដែលមានប្រភេទដូចពោលហើយនេះ សង្ឃគប្បីសួរដើមចោទ និងចុងចោទថា ពួកលោកពេញចិត្តក្នុងការវិនិច្ឆ័យ

របស់ពួកខ្ញុំឬ បើដើមចោទ និងចុងចោទពោលថា ពួកខ្ញុំពេញចិត្ត សង្ឃគប្បីទទួលអធិករណ៍នោះ ។ តែបើបុគ្គលទាំងពីរចំណែកពោលថា សូមពួកលោកវិនិច្ឆ័យសាកមើលសិនចុះ បើការវិនិច្ឆ័យនោះ គួរដល់ពួកខ្ញុំៗ នឹងព្រមទទួល គប្បីពោលពាក្យជាដើមថា ពួកលោកចូរថ្វាយបង្គំព្រះចេតិយជាមុន ហើយគប្បីវិសជ្ជនាធ្វើព្រះសូត្រឲ្យវែង ។ បើពួកភិក្ខុហាត់នឿយអស់កាលយូរ ជាអ្នកមានបរិស័ទចៀសចេញទៅ ដាច់បក្ខពួក ទើបអង្វរជាថ្មី ព្រះវិនយធរគប្បីឃាត់អស់វារៈ ៣ ដង ហើយគប្បីវិនិច្ឆ័យអធិករណ៍របស់ពួកភិក្ខុ ក្នុងវេលាពួកភិក្ខុអស់មានះរឹងត្អឹង ។ ពួកភិក្ខុដែលសង្ឃសន្មត កាលនឹងវិនិច្ឆ័យ បើមានបរិស័ទច្រើនដោយពួកអលជ្ជី គប្បីវិនិច្ឆ័យអធិករណ៍នោះ ដោយឧព្វាហិកាញត្តិ បើបរិស័ទច្រើនដោយពួកបុគ្គលពាល គប្បីពោលថា ពួកលោកចូរស្វែងរកព្រះវិនយធរដែលពេញចិត្តរបស់ពួកលោករៀងៗ ខ្លួនចុះ ឲ្យស្វែងរកព្រះវិនយធរដោយខ្លួនឯង ហើយគប្បីរម្ងាប់អធិករណ៍នោះដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនៈ ទើបជាគ្រឿងរម្ងាប់អធិករណ៍នោះ ។

ក្នុងធម្មវិន័យ និងសត្ថុសាសនៈនោះ រឿងដែលពិត ឈ្មោះថា ធម៌ ។ ការចោទ និងការឲ្យរឭក ឈ្មោះថា វិន័យ ។ ញត្តិសម្បត្តិ និងអនុសាវនាសម្បត្តិ ឈ្មោះថា សត្ថុសាសនៈ ។ ព្រោះដូច្នោះ កាលដើមចោទលើករឿងឡើង ព្រះវិនយធរគប្បីសួរចុងចោទថា រឿងនេះពិត ឬមិនពិត ព្រះវិនយធរសាកសួររឿងយ៉ាងនេះហើយ ចោទដោយរឿងដែលមិនពិត ឲ្យចុងចោទរឭកហើយ គប្បីរម្ងាប់អធិករណ៍នោះដោយញត្តិសម្បត្តិ និងអនុសាវនាសម្បត្តិ ។

បើដើមចោទ និងចុងចោទនោះ ដើមចោទជាអលជ្ជី ចុងចោទជាលជ្ជី និងដើមចោទអលជ្ជីនោះ ជាបុគ្គលពាល មិនឈ្លាស ព្រះវិនយធរមិនគប្បីឲ្យវព្រកសាកសួរដល់លោក ។ តែគប្បីពោលយ៉ាងនេះ **កិម្ហិ្ហំ** ( លោកចោទភិក្ខុនោះព្រោះរឿងអ្វី ) ពិតហើយ ដើមចោទនោះនឹងពោលថា លោកដ៏ចម្រើន ដែលឈ្មោះថា **កិម្ហិ្ហំ** នេះ គឺអ្វី គប្បីបញ្ជូនលោកទៅដោយពាក្យថា លោកមិនស្គាល់សូម្បីពាក្យថា **កិម្ហិ្ហំ** ( លោកចោទភិក្ខុនោះព្រោះរឿងអ្វី ) លោកជាបុគ្គលល្ងង់យ៉ាងនេះ មិនគួរចោទអ្នកដទៃ ។ ព្រះវិនយធរមិនគប្បីឲ្យការសាកសួរដល់លោក ។ តែបើដើមចោទជាអលជ្ជីនោះជាបណ្ឌិតឈ្លាសវៃ អាចនឹងគ្របសង្កត់ឲ្យសម្រេចបានដោយរឿងដែលបានឃើញក្តី ដោយរឿងដែលបានឮក្តី គប្បីឲ្យការសាកសួរដល់ដើមចោទនោះ ហើយធ្វើកម្មតាមបដិញ្ញារបស់ចុងចោទដែលជាលជ្ជីនោះឯង ។ បើលជ្ជីចោទអលជ្ជី ហើយលជ្ជីនោះជា បុគ្គលល្ងង់ មិនឈ្លាសវៃ មិនអាចឲ្យពាក្យឆ្លើយក្នុងការសាកសួរបាន ព្រះវិនយធរគប្បីឲ្យន័យដល់លោកថា **កិម្ហិ្ហំ** ព្រោះរឿងនៃសីលវិបត្តិ ឬព្រោះរឿងនៃវិបត្តិឯណាមួយ ក្នុងបណ្តាអាចារវិបត្តិជាដើម ។

សួរថា ព្រោះហេតុអ្វី ទើបគួរឲ្យន័យយ៉ាងនេះដល់លជ្ជីប៉ុណ្ណោះ មិនគួរឲ្យដល់អលជ្ជីក្រៅអំពីនេះ ការលំអៀងព្រោះអគតិ មិនសមគួរដល់ព្រះ-វិនយធរមិនមែនឬ ឆ្លើយថា ការលំអៀងព្រោះអគតិ មិនគួរឡើយ តែការឲ្យន័យនេះ មិនរាប់ថាជាលំអៀងព្រោះអគតិ ។ ការនេះ ឈ្មោះថា **ធម្មា-នុគ្គហោ** ជាការអនុគ្រោះធម៌ ។ ពិតហើយ សិក្ខាបទព្រះមានព្រះភាគទ្រង់បញ្ញត្តទុកដើម្បីសង្កត់សង្កិនអលជ្ជី និងដើម្បីលើកសរសើរពួកលជ្ជី ។

ក្នុងលជ្ជី និងអលជ្ជីទាំងនោះ អលជ្ជីបានន័យហើយ នឹងគ្របសង្កត់ ។ ចំណែកលជ្ជីបានន័យហើយ ទើបពោលបញ្ជាក់ក្នុងរឿងដែលបានឃើញ ដោយការបន្តគ្នាជាមួយរឿងដែលបានឃើញ ក្នុងរឿងដែលបានឮ ដោយការបន្តគ្នាជាមួយរឿងដែលបានឮ ព្រោះដូច្នោះ ការអនុគ្រោះធម៌ ទើបសមគួរដល់លជ្ជីនោះ ។ បើលជ្ជីនោះជាបណ្ឌិត ឈ្លាសវៃ ពោលបញ្ជាក់ តែអលជ្ជីមិនឲ្យបដិញ្ញា ដោយបដិសេធថា រឿងនេះក៏មិនមាន រឿងនោះក៏មិនមាន ទើបកាត់អាបត្តិតាមបដិញ្ញារបស់អលជ្ជីដូចគ្នា ។

## វិនយធរគប្បីធ្វើតាមពាក្យបដិញ្ញា

ដើម្បីសម្តែងអត្ថនោះ អ្នកសិក្សាគប្បីជ្រាបរឿងដូចតទៅនេះ បានឮថា ព្រះតេបិដកចូឡាភយត្ថេរ សម្តែងវិន័យដល់ភិក្ខុទាំងឡាយ ខាងក្រោមលោហប្រាសាទ ផ្អាកក្នុងវេលាល្ងាច ។ ក្នុងវេលាព្រះថេរៈនោះផ្អាក ភិក្ខុពីរអង្គជាអ្នកទាស់គ្នាក្នុងអត្តក្តី ក៏ញ៉ាំងពាក្យសម្តីឲ្យប្រព្រឹត្តទៅ ។ មួយអង្គមិនបានបដិញ្ញាដោយបដិសេធថា រឿងនេះក៏មិនមាន រឿងនោះក៏មិនមាន ។ គ្រានោះកាលបឋមយាមនៅសល់បន្តិចបន្តួច ព្រះថេរៈកើតការយល់ថា មិនបរិសុទ្ធក្នុងបុគ្គលនោះថា បុគ្គលនេះនៅតែពោលបញ្ជាក់ តែបុគ្គលនេះមិនឲ្យនូវបដិញ្ញា និងរឿងនាំមកជាឧទាហរណ៍មានច្រើន កម្មនេះនឹងជារបស់ដែលបុគ្គលនោះធ្វើហើយពិតប្រាកដ ។ គ្រានោះ ព្រះថេរៈបានឲ្យសញ្ញាត្រង់បន្ទះអំបែងដុតជើងដោយដងផ្លិត ហើយពោលថា លោកម្ចាស់ទាំងឡាយ ខ្ញុំមិនសមគួរនឹងវិនិច្ឆ័យ លោកចូរឲ្យអ្នកដទៃវិនិច្ឆ័យចុះ ពួកភិក្ខុសួរថា ព្រោះ

ហេតុអ្វី លោកម្ចាស់ ព្រះថេរៈបានប្រាប់សេចក្ដីនោះ ។ ការក្ដៅក្រហាយកើតឡើងក្នុងកាយរបស់បុគ្គលដែលជាចុងចោទ ។ គ្រានោះ ភិក្ខុចុងចោទថ្វាយបង្គំព្រះថេរៈហើយ ពោលថា ធម្មតាវិនយធរដែលសមគួរដើម្បីវិនិច្ឆ័យគួរជាបុគ្គលដូចលោកម្ចាស់នោះឯង ហើយបុគ្គលដើមចោទ ក៏គួរជាបុគ្គលដូចលោកម្ចាស់នេះឯង ហើយស្លៀកសំពត់សពោលថា ខ្ញុំធ្វើឲ្យលោកម្ចាស់លំបាកយូរហើយ សូមខមាទោសព្រះថេរៈហើយចៀសចេញទៅ ។

អលជ្ជីភិក្ខុ ត្រូវលជ្ជីភិក្ខុចោទយ៉ាងនេះ កាលរឿងជាច្រើនកើតឡើងហើយ ក៏មិនឲ្យនូវបដិញ្ញា ។ អលជ្ជីភិក្ខុនោះ ព្រះវិនយធរមិនគួរពោលថា ជាអ្នកបរិសុទ្ធ ទាំងមិនគួរពោលថា ជាអ្នកមិនបរិសុទ្ធ ។ បុគ្គលនេះ ឈ្មោះថា ស្លាប់ទាំងរស់ ឈ្មោះថា ស្អុយទាំងស្រស់ ។ បើរឿងដទៃដូច្នោះកើតឡើងដល់បុគ្គលនោះ ព្រះវិនយធរមិនត្រូវវិនិច្ឆ័យឡើយ ។ បុគ្គលនោះ នឹងត្រូវវិនាសទៅយ៉ាងនោះឯង ។

ម្យ៉ាងទៀត បើអលជ្ជីភិក្ខុចោទអលជ្ជីភិក្ខុ ព្រះវិនយធរគួរពោលណែនាំភិក្ខុដើមចោទនោះថា នែលោក ភិក្ខុនេះ បុគ្គលណាមួយ មិនអាចពោលអ្វីតាមពាក្យរបស់លោកបាន ពោលយ៉ាងនោះ ដូចគ្នានឹងភិក្ខុចុងចោទ ហើយបញ្ជូនទៅដោយពាក្យថា ពួកលោកទាំងពីរចូររួមសម្ភោគ គឺបរិភោគរួមគ្នាចុះ មិនគប្បីធ្វើការវិនិច្ឆ័យ ដល់អលជ្ជីទាំងពីរនោះ ដើម្បីប្រយោជន៍ដល់សីល តែដើម្បីប្រយោជន៍ដល់បាត្រ និងចីវរ និងបរិវេណជាដើម បានសាក្សីសមគួរហើយ ទើបគួរធ្វើ ។

*បើលជ្ជីភិក្ខុចោទលជ្ជីភិក្ខុ ហើយការវិវាទរបស់ពួកលោក មានត្រឹមបន្តិចបន្តួចក្នុងរឿងខ្លះប៉ុណ្ណោះ ព្រះវិនយធរគប្បីសម្រុះសម្រួល ឲ្យសម្តែងទោសដែលប្រព្រឹត្តកន្លង ហើយបញ្ចូនទៅដោយពាក្យថា ពួកលោកចូរកុំធ្វើយ៉ាងនេះ ។ បើក្នុងភិក្ខុដើមចោទ និងចុងចោទនោះ ចុងចោទពោលភ្ញាត់ខុសទៅតាំងអំពីដើម ចុងចោទមិនទាន់ឈ្មោះថា ជាអលជ្ជី ហើយចុងចោទនោះមិនឲ្យប្តេជ្ញាដើម្បីរក្សាបក្ខពួក ។ ពួកភិក្ខុជាច្រើនក្រោកឡើង ដោយពោលថា ពួកយើងមិនជឿ ពួកយើងមិនជឿ ។ ចុងចោទនោះជាអ្នកបរិសុទ្ធម្តង ឬពីរដង តាមប្តេជ្ញារបស់ពួកភិក្ខុច្រើននោះចុះ ។ តែបើលោកមិនតាំងនៅក្នុងឋានៈ ( ជាលជ្ជី ) ចាប់តាំងអំពីពេលពោលខុសទៅ ។ គប្បីឲ្យនូវការវិនិច្ឆ័យ ។*

## អង្គនៃដើមចោទ និងចុងចោទ

*កាលរឿងត្រូវនាំមកសំណូមពរក្នុងទីប្រជុំ កណ្តាលជំនុំសង្ឃ ដោយអំនាចនៃការចោទណាមួយ ដូច្នេះ ព្រះវិនយធរជ្រាបការបដិបត្តិក្នុងភិក្ខុចុងចោទ និងដើមចោទហើយ គប្បីជ្រាបវិនិច្ឆ័យ ដោយអំណាចន័យខាងដើមកណ្តាល ខាងចុងជាដើម ដើម្បីស្គាល់សម្បត្តិ និងវិបត្តិនៃការចោទនោះឯង ។ សេចក្តីនេះដូចម្តេច គឺការចោទមានអ្វីជាខាងដើម មានអ្វីជាកណ្តាល មានអ្វីជាខាងចុង ការសូមឱកាសថា ខ្ញុំប្រាថ្នានឹងពោលចំពោះលោក សូមលោកដ៏មានអាយុធ្វើឱកាសឲ្យដល់ខ្ញុំ ដូច្នេះ ឈ្មោះថា ខាងដើមនៃការចោទ ។*

*ការចោទហើយ ឲ្យចុងចោទរឭកតាមវត្ថុ ដែលលើកឡើងបរិយាយ*

រ៉ាយរ៉ាប់ ហើយវិនិច្ឆ័យ ឈ្មោះថា ជាកណ្ដាលនៃការចោទ ។

ការរម្ងាប់ដោយឲ្យចុងចោទតាំងនៅក្នុងអាបត្តិក្តី អនាបត្តិក្តី ឈ្មោះថា ខាងចុងនៃការចោទ ។

សួរថា ការចោទមានមូលប៉ុន្មាន មានវត្ថុប៉ុន្មាន មានភូមិប៉ុន្មាន ឆ្លើយថា ការចោទមានមូល ២ គឺមូលមានហេតុ ១ មូលមិនមានហេតុ ១ ។ មានវត្ថុ ៣ គឺបានឃើញ ១ បានឮ ១ បានរង្កៀស ១ ។ មានភូមិ ៥ គឺពោលតាមកាល មិនពោលដោយកាលមិនគួរ ១ ពោលតាមពិត មិនពោលដោយពាក្យមិនពិត ១ ពោលដោយពាក្យទន់ភ្លន់ មិនពោលដោយពាក្យគ្រោតគ្រាត ១ ពោលពាក្យប្រកបដោយប្រយោជន៍ មិនពោលពាក្យដែលមិនប្រកបដោយប្រយោជន៍ ១ ពោលដោយចិត្តប្រកបដោយមេត្តា មិនពោលសម្លឹងទោស ១ ។ ក្នុងការចោទនេះ បុគ្គលដើមចោទគប្បីតាំងនៅក្នុងធម៌ ១៥ យ៉ាង ដែលមានព្រះតម្រាស់ទុកក្នុងឧបាលិបញ្ចកៈ ដោយន័យជាដើមថា យើងជាបុគ្គលមានកាយសមាចារបរិសុទ្ធឬទេហ្ន៎ ។ បុគ្គលជាចុងចោទ គប្បីតាំងនៅក្នុងធម៌ ២ យ៉ាង គឺក្នុងសច្ចៈ និងអទោសៈ ។

បទថា **អប្បេវ នាម នំ ឥមម្ហា ព្រហ្មចរិយា ចាវេយ្យំ** សេចក្តីថា ធ្វើម្តេចហ្ន៎ អញនឹងគប្បីឲ្យបុគ្គលនោះឃ្លាតចាកការប្រព្រឹត្តធម៌ដ៏ប្រសើរនេះបាន ។ មានពាក្យអធិប្បាយថា គប្បីតាមចោទដោយបំណងយ៉ាងនេះថា ជាការល្អហ្ន៎ បើអញគប្បីឲ្យបុគ្គលនេះឃ្លាតចាកព្រហ្មចរិយៈនេះបាន ។ តែក្នុងបទភាជនីយ៍ ព្រះឧបាលីពោលពាក្យជាដើមថា គប្បីឲ្យឃ្លាតចាកភាពជាភិក្ខុ

ដើម្បីសម្តែងត្រឹមបរិយាយនៃពាក្យថា គប្បីឲ្យឃ្លាតចាកព្រហ្មចរិយៈនេះប៉ុណ្ណោះ ។

[ ២៤៧ ] បទទាំងឡាយ មានខណៈជាដើម ជាវេវចនៈរបស់សម័យ ។ ប្រើនបទថា **តំ ខណំ តំ លយំ តំ មុហុត្តំ វីតិវត្តេ** បានដល់ កាលខណៈនោះ កាលមួយស្របក់នោះ កាលយាមនោះកន្លងទៅហើយ ពិតហើយពាក្យថា **តំ ខណំ** ជាដើមនេះ ជាទុតិយាវិភត្តិ ដើម្បីកើតជាសត្តមីវិភត្តិ ( ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ) ។ ក្នុងសមនុគ្គាហិយមាននិទ្ទេស បទថា **យេន វត្ថុនា អនុធំសិតោ ហោតិ** សេចក្តីថា ភិក្ខុចុងចោទត្រូវដើមចោទតាមចោទគឺគំរាមកំហែងគ្របសង្កត់ដោយវត្ថុណា ក្នុងបណ្តានៃបារាជិក ៤ ។ បទថា **តស្មឹ វត្ថុស្មឹ សមនុគ្គាហិយមានោ** សេចក្តីថា ក្នុងរឿងដែលដើមចោទពោលចោទនោះ ដើមចោទនោះ ត្រូវព្រះវិនយធរពោលសាកសួរដេញដោលគឺពិចារណាដោយន័យជាដើមថា លោកឃើញអ្វី លោកឃើញដូចម្តេច ។

ក្នុងអសមនុគ្គាហិយមាននិទ្ទេស បទថា **ន កេនចិ វុច្ចមានោ** គឺអ្នកសម្រេចក្តី ឬបុគ្គលណាមួយ ( មិនសាកសួរ ) ។ ម្យ៉ាងទៀត សេចក្តីថា មិនត្រូវអ្នកកាត់ក្តីសាកសួរដោយបណ្តាវត្ថុ ដែលបានឃើញជាដើមណាមួយឡើយ ។ បណ្ឌិតគប្បីជ្រាបការសម្ពន្ធនៃបទមាតិកាទាំង ២ នេះ ដោយពាក្យថា **ភិក្ខុ ច ទោសំ បតិដ្ឋាតិ** នេះខាងមុខ ។ ពិតហើយ មានអត្ថដែលលោកពោលដូច្នេះថា ភិក្ខុណាមួយ កាន់យកតាមក្តី មិនកាន់យកតាមក្តីយ៉ាងនេះ អះអាង អាស្រ័យទោសៈ គឺប្តេជ្ញា ត្រូវអាបត្តិសង្ឃាទិសេស ។

ពាក្យនេះ ព្រះមានព្រះភាគត្រាស់ទុកដើម្បីសម្តែងកាលប្រាកដអធិករណ៍មិនមានមូលប៉ុណ្ណោះ ។ តែភិក្ខុអ្នកចោទ រមែងត្រូវអាបត្តិខណៈដែលខ្លួនចោទនោះឯង ។

## អធិប្បាយ ពាក្យថា អធិករណ៍ជាដើម

[ ២៤៨ ] ឥឡូវនេះ ព្រះមានព្រះភាគត្រាស់ពាក្យថា **អធិករណំ នាម** ជាដើម ដើម្បីមិនត្រាស់លក្ខណៈអធិករណ៍មិនមានមូលនោះ សម្តែងតែទីមិនទាន់ធ្លាប់មានប៉ុណ្ណោះ ព្រោះលក្ខណៈនៃអធិករណ៍មិនមានមូល បានត្រាស់ហើយខាងដើម ក្នុងពាក្យថា **អមូលកញ្ចេវ តំ អធិករណំ ហោតិ** នេះ ។

ព្រោះអធិករណ៍ក្នុងបទថា **អធិករណំ នាម** នោះ ដោយអត្ថ គឺហេតុរមែងមានតែមួយ ដោយអំណាចវត្ថុផ្សេងៗគ្នា ព្រោះហេតុនោះ ដើម្បីសម្តែងការផ្សេងគ្នានៃអធិករណ៍នោះ ទើបព្រះមានព្រះភាគត្រាស់បទថា **ចត្តារិ អធិករណានិ វិវាទាធិករណំ** ដូច្នេះជាដើម ។

សួរថា ក្នុងអធិករណ៍នោះ ជាភាពតែមួយ ដោយអត្ថ គឺហេតុឯណា អត្ថ គឺហេតុនោះដូចម្តេច ឆ្លើយថា អត្ថ គឺហេតុនោះ ប្រការដែលអធិករណ៍ជាហេតុដែលនឹងគប្បីធ្វើក្រែលែង ( រម្ងាប់ ) ដោយសមថៈទាំងឡាយ ។ ព្រោះហេតុនោះ សមថៈទាំងឡាយនោះឯង ប្រារព្ធ គឺអាស្រ័យ សំដៅយកអធិកិច្ចឯណាប្រព្រឹត្តទៅ អធិកិច្ចនោះ គប្បីជ្រាបថា ជាអធិករណ៍ ។ តែក្នុងអដ្ឋកថាទាំងឡាយពោលថា អាចារ្យពួកខ្លះ ពោលការប្រកាន់ថា ជាអធិករណ៍ អាចារ្យពួកខ្លះ ពោលចេតនា ថាជាអធិករណ៍ អាចារ្យពួកខ្លះ ពោលការមិន

ពេញចិត្ត ថាជាអធិករណ៍ អាចារ្យពួកខ្លះ ពោលវោហារ ថាជាអធិករណ៍ ពួកខ្លះពោលបញ្ញត្តិ ថាជាអធិករណ៍ ។

អដ្ឋកថាចារ្យទាំងនោះ ពិចារណាដដែលយ៉ាងនេះថា បើការប្រកាន់គប្បីជាអធិករណ៍សោត ភិក្ខុមួយអង្គកាន់យកក្តី ប្រឹក្សាគ្នាជាមួយភិក្ខុដែលជាសភាគគ្នា ឃើញទោសក្នុងក្តីនោះហើយ លះបង់ចោលទៀត អធិករណ៍នោះរបស់ភិក្ខុនោះ នឹងដល់នូវការរម្ងាប់ទៅ ។ បើចេតនាគប្បីជាអធិករណ៍សោត ចេតនាដែលកើតឡើងថា អញនឹងកាន់យកក្តីនេះ រមែងរលត់ទៅ ។ បើការមិនពេញចិត្តគប្បីជាអធិករណ៍សោត ភិក្ខុសូម្បីកាន់យកក្តីដោយការពេញចិត្ត ខាងក្រោយមិនបានការវិនិច្ឆ័យ ឬភាគីចុងចោទសូមខមាទោសហើយ រមែងលះបង់ ។ បើវោហារគប្បីជាអធិករណ៍សោត ភិក្ខុត្រាច់ពោល រមែងជាអ្នកស្ងៀម មិនមានសំឡេងក្នុងកាលក្រោយ អធិករណ៍នោះរបស់លោកនឹងជាការដល់នូវការរម្ងាប់ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបបញ្ញត្តិ ចាត់ជាអធិករណ៍ ។

តែពាក្យរបស់អដ្ឋកថាទាំងឡាយនោះ ជំទាស់នឹងព្រះបាលី មានជាដើមយ៉ាងនេះថា មេថុនធម្មបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងមេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិក មានចំណែកជាមួយគ្នានឹងអទិន្នាទានបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងមនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងឧត្តរិ-

មនុស្សធម្មបារាជិកាបត្តិ ។ អាបត្តាធិករណ៍យ៉ាងនេះ ( ហៅថា ) មានចំណែកជាមួយគ្នានឹងអាបត្តាធិករណ៍ និងថា វិវាទាធិករណ៍ ជាកុសលក៏មាន ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ដូច្នេះ ។

ការពិត ព្រះអដ្ឋកថាចារ្យទាំងនោះ មិនបានបំណងបញ្ញត្តិជាកុសលជាដើម ហើយធម៌ គឺបារាជិកដែលមកក្នុងពាក្យថា **អមូលកេន ចារាជិកេន ធម្មេន** នេះ នឹងបានឈ្មោះថាជាបញ្ញត្តិក៏មិនមែន ព្រោះហេតុអ្វី ព្រោះជាអកុសល ដោយចំណែកមួយ ។

ពិតហើយ សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនេះហើយថា អាបត្តាធិករណ៍ ជាអកុសលក៏មាន ជាអព្យាកតៈក៏មាន ។ ហើយបារាជិកមិនមានមូលនោះ ដែលទ្រង់និទ្ទេសទុក ក្នុងព្រះបាលីនេះថា **អមូលកេន ចារាជិកេន** ដូច្នេះ ។ ព្រះបាលីថា **អមូលកញ្ចេវ តំ អធិករណំ ហោតិ** នេះ ជាបដិនិទ្ទេសនៃបារាជិកមិនមានមូលនោះឯង មិនមែនបញ្ញត្តិ ។ ពិតហើយ ព្រះមានព្រះភាគ ទ្រង់បាននិទ្ទេសបារាជិកដទៃ ហើយទ្រង់បដិនិទ្ទេសបារាជិដទៃក៏មិនមែន ។ តែបុគ្គលនោះត្រូវដើមចោទពោលបង្កាច់ថា កន្លងធម៌ គឺបារាជិកដោយបញ្ញត្តិណា គឺដោយការចោទប្រកាន់ណា បញ្ញត្តិនោះ រាប់ថាមិនមានមូល ព្រោះអធិករណ៍ ពោល គឺបារាជិកជារបស់មិនមានមូល តែរាប់ថា ជាអធិករណ៍ ព្រោះបញ្ញត្តិនោះប្រព្រឹត្តទៅក្នុងអធិករណ៍ ព្រោះហេតុនោះ ពាក្យថា បញ្ញត្តិជាអធិករណ៍ គួរត្រឹមត្រូវដោយបរិយាយនេះ ។ តែអធិករណ៍ដែលរាប់ថាមិនមានមូល រមែងមិនមានដោយប្រក្រតីរបស់ខ្លួន នឹង

មានត្រឹមតែជាបញ្ញត្តិប៉ុណ្ណោះ ព្រោះហេតុនោះ ពាក្យថា បញ្ញត្តិ ចាត់ជាអធិករណ៍ គួរជាពាក្យត្រឹមត្រូវ ។

ឯប្រការដែលបញ្ញត្តិ រាប់ថា ជាអធិករណ៍ដោយបរិយាយដូចពោលមកនោះ ត្រូវក្នុងសិក្ខាបទនេះប៉ុណ្ណោះ មិនត្រូវគ្រប់សិក្ខាបទទាំងអស់ឡើយ ។ ពិតហើយ ការបញ្ញត្តអធិករណ៍ មានវិវាទាធិករណ៍ជាដើម មិនមែនអត្ថ គឺហេតុឡើយ តែអត្ថ គឺហេតុ បានដល់ ការដែលអធិករណ៍នោះ ជាហេតុដែលគប្បីធ្វើក្រៃលែង ( រម្ងាប់ ) ដោយសមថៈទាំងឡាយ ដូចពោលហើយខាងដើម ។ ដោយអត្ថ គឺហេតុដូចពោលមកនេះ វិវាទខ្លះក្នុងលោកនេះ ជាវិវាទផង ជាអធិករណ៍ផង ព្រោះហេតុនោះ ទើបឈ្មោះថា វិវាទាធិករណ៍ ។ ក្នុងអធិករណ៍ដ៏សេស ក៏មានន័យដូច្នេះ ។

បណ្ដាអធិករណ៍ ៤ មានវិវាទាធិករណ៍ជាដើមនោះ វិវាទដែលអាស្រ័យភេទករវត្ថុ ១៨ យ៉ាង កើតឡើងយ៉ាងនេះ គឺពួកភិក្ខុក្នុងធម្មវិន័យនេះវិវាទគ្នាថាជាធម៌ក្ដី មិនមែនធម៌ក្ដី ឈ្មោះថា វិវាទាធិករណ៍ ។

ការពោលចោទគ្នាអាស្រ័យវិបត្តិ ៤ កើតឡើងយ៉ាងនេះ គឺភិក្ខុក្នុងធម្មវិន័យនេះ រមែងពោលចោទភិក្ខុ ដោយសីលវិបត្តិជាដើម ឈ្មោះថា អនុវាទាធិករណ៍ ។

ចំពោះអាបត្តិប៉ុណ្ណោះ ឈ្មោះថា អាបត្តាធិករណ៍យ៉ាងនេះ គឺកងអាបត្តិទាំង ៥ ឈ្មោះថា អាបត្តាធិករណ៍ ។ កងអាបត្តិទាំង ៧ ឈ្មោះថា អាបត្តាធិករណ៍ ។

ករណីយកិច្ចរបស់សង្ឃ គឺកិច្ចដែលសង្ឃត្រូវធ្វើ បានដល់ សង្ឃកិច្ច ៤ យ៉ាង គឺអបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិ-ចតុត្ថកម្ម ១ គប្បីជ្រាបថា ជាកិច្ចាធិករណ៍ តែក្នុងអត្ថនេះ បំណងយក អាបត្តាធិករណ៍ ពោល គឺអាបត្តិបារាជិកប៉ុណ្ណោះ ។ អធិករណ៍ដ៏សេស មាន វិវាទាធិករណ៍ជាដើម លោកពោលទុកដោយអំណាចនៃការពង្រីកសេចក្តី ។ ពិតហើយ អត្ថនៃសព្ទថា អធិករណ៍មានប៉ុណ្ណោះ ។ ក្នុងអត្ថទាំងនោះ បារាជិក ប៉ុណ្ណោះ បំណងយកក្នុងអធិការនេះ ។ បារាជិកនោះ ជាអធិករណ៍មិនមាន មូល ដោយមូល មានការបានឃើញជាដើមនោះឯង ។ ហើយភិក្ខុនេះ អះអាងអាស្រ័យទោសៈ គឺ កាលពោលពាក្យជាដើមថា ខ្ញុំនិយាយលេង ទទេៗ ឈ្មោះថា រមែងប្តេជ្ញា ។ ត្រូវអាបត្តិសង្ឃាទិសេសដល់ភិក្ខុនោះ ក្នុង ខណៈដែលខ្ជួនចោទនោះឯង ។ នេះជាអត្ថក្នុងសិក្ខាបទនោះ ដែលមាន និទ្ទេសតាមលំដាប់នៃបទ ។

សិក្ខាបទវិភង្គនៃបឋមទុដ្ឋទោសសិក្ខាបទ ចប់

## អធិប្បាយ
## បទភាជនីយ៍នៃបឋមទុដ្ឋទោសសិក្ខាបទ

[ ២៥០-២៥៧ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់លើកអាបត្តិឡើងសម្តែងដោយពិស្តារ ដោយអំណាចនៃការចោទ មានរឿងដែលមិនបានឃើញជាដើម ដែលត្រាស់ទុកដោយសង្ខេបហើយនោះ ទើបត្រាស់បទថា **អទិដ្ឋស្ស ហោតិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អទិដ្ឋស្ស ហោតិ** បានដល់ ( ចុងចោទ ) នោះ ដែលដើមចោទមិនបានឃើញ អធិប្បាយថា បុគ្គលដែលត្រូវធម៌ដល់បារាជិកនោះ ដើមចោទមិនបានឃើញ ។ សូម្បីក្នុងបទថា **អស្សុតស្ស ហោតិ** ជាដើមក៏មានន័យដូចគ្នាដែរ ។

ពីរបទថា **ទិដ្ឋោ មយា** មានពាក្យអធិប្បាយថា លោកជាបុគ្គលដែលខ្ញុំឃើញហើយ ។ សូម្បីក្នុងបទថា **សុតោ មយា** ជាដើមក៏មានន័យដូច្នេះ ។ បទដ៏សេសក្នុងអធិករណ៍ មានរឿងដែលមិនបានឃើញជាមូលជាក់ច្បាស់នោះឯង ។ ឯក្នុងអធិករណ៍ដែលមានមូលដោយរឿងដែលបានឃើញ គប្បីជ្រាបជាអធិករណ៍មិនមានមូល ព្រោះការមិនមាននៃមូល មានរឿងដែលបានឮជាដើម ដែលត្រាស់ទុកយ៉ាងនេះថា បើភិក្ខុដើមចោទៗ ភិក្ខុនោះថា ខ្ញុំបានឮជាដើម ។

ក្នុងវារៈរបស់ដើមចោទនេះទាំងអស់នោះឯង រមែងត្រូវអាបត្តិសង្ឃាទិ-សេសដូចគ្នាគ្រប់ៗ វាចា ដោយអំណាចនៃពាក្យពោលមួយម៉ាត់ៗ ក្នុងបណ្តាពាក្យទាំងនេះដែលមកហើយក្នុងទីដទៃថា លោកជាបុគ្គលទ្រុស្តសីល មាន

ធម៌លាមក មានសមាចារមិនស្អាត គួរឲ្យគេរង្កៀស មានអំពើអាក្រក់បិទបាំង មិនមែនសមណៈ ប្តេជ្ញាថាជាសមណៈ មិនមែនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ប្តេជ្ញាថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ជាបុគ្គលស្អុយក្នុង មានចិត្តជោកជាំដោយរាគៈ កខ្វក់ដូចជាសំរាម ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចាដោយអំណាចពាក្យនីមួយៗ ក្នុងបណ្តាពាក្យទាំងនេះ ដែលមកហើយក្នុងសិក្ខាបទនេះថា លោកជាអ្នកត្រូវអាបត្តិបារាជិក មិនមែនជាសមណៈ មិនមែនជាវង្សនៃសក្យបុត្រ ដូច្នោះ ។

ចំណែកពាក្យសុទ្ធៗ ទាំងនេះ គឺឧបោសថក្តី បវារណាក្តី សង្ឃកម្មក្តី រួមជាមួយលោក រមែងមិនមាន អាបត្តិមិនទាន់ដល់ទីបំផុត ។ តែវាចាដែលភ្ជាប់ជាមួយបទណានីមួយហើយប៉ុណ្ណោះ ក្នុងបណ្តាបទថា ទ្រុស្តសីលជាដើមយ៉ាងនេះថា លោកជាអ្នកទ្រុស្តសីល ឧបោសថក្តី រួមជាមួយលោកមិនមាន និងបណ្តាបទថា លោកត្រូវធម៌ដល់បារាជិកជាដើម រមែងដល់ទីបំផុត គឺធ្វើឲ្យដល់សង្ឃាទិសេស ។

តែព្រះបទុមត្ថេរពោលថា ចំពោះបទដើមថា ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមកតែម្យ៉ាង ដែលមិនបានមកក្នុងព្រះបាលីក្នុងសិក្ខាបទនេះ រមែងមិនដល់ទីបំផុត សូម្បីបទទាំងនេះ គឺលោកជាមនុស្សអាក្រក់ លោកជាសាមណេរធំ ជាមហាឧបាសក លោកជាអ្នកប្រកបវត្តនៃព្រះម៉ែកាឡីទេវីដ៏ប្រសើរ លោកជានិគណ្ឋ លោកជាអាជីវក លោកជាតាបស លោកជាបរិព្វាជក លោកជាខ្ទើយ លោកជាថេយ្យសង្វាស លោកជាអ្នកចូលលទ្ធិ

ត្ថិយ លោកជាតិរច្ឆាន លោកជាអ្នកសម្លាប់ម្តាយ លោកជាអ្នកសម្លាប់បិតា លោកជាអ្នកសម្លាប់ព្រះអរហន្ត លោកជាអ្នកធ្វើសង្ឃភេទ លោកជាអ្នកធ្វើលោហិតុប្បាទ លោកជាភិក្ខុនីទូសកៈ លោកជាមនុស្សមានភេទពីរ រមែងដល់ទីបំផុតនោះឯង ហើយព្រះមហាបទុមត្ថេរនោះឯង ពោលទុកក្នុងបទថា **ធិដ្ឋេវេមតិកោ** ជាដើមថា ជាអ្នកសង្ស័យដោយចំណែកណា រមែងមិនជឿដោយចំណែកនោះ មិនជឿដោយចំណែកណា រមែងរឭកមិនបាន ដោយចំណែកនោះ រឭកមិនបានដោយចំណែកណា រមែងជាអ្នកភ្លេចភ្លាំង ដោយចំណែកនោះ ។

ចំណែកព្រះមហាសុមត្ថេរចែកបទនីមួយៗ ចេញជា ២ បទ ហើយសម្តែងន័យចំពោះបទទាំង ៤ ។ លោកសម្តែងដូចម្តេច គឺគប្បីជ្រាបន័យថា **ធិដ្ឋេវេមតិកោ** នេះជាមុន ភិក្ខុជាអ្នកសង្ស័យក្នុងការឃើញក្តី ក្នុងបុគ្គលក្តី បណ្តាការឃើញ និងបុគ្គលនោះ រមែងជាអ្នកសង្ស័យក្នុងការឃើញយ៉ាងនេះថា ជាបុគ្គលដែលអញឃើញក្តី មិនមែនបុគ្គលដែលអញឃើញក្តី ជាអ្នកមានសេចក្តីសង្ស័យក្នុងបុគ្គលយ៉ាងនេះថា បុគ្គលនេះឬដែលអញឃើញ ឬក៏អ្នកដទៃទេ ។ រមែងមិនឈ្មោះថា ការឃើញខ្លះ បុគ្គលខ្លះ រមែងរឭកមិនបាននូវការឃើញខ្លះ បុគ្គលខ្លះ រមែងជាអ្នកភ្លេចការឃើញខ្លះ បុគ្គលខ្លះ ដោយប្រការយ៉ាងនេះ ។

បណ្តាបទទាំងនេះ បទថា **វេមតិកោ** បានដល់ កើតសេចក្តីសង្ស័យ ។ ពីរបទថា **នោ កប្បេតិ** បានដល់ រមែងមិនជឿ ។ បទថា **ន សរតិ** សេចក្តីថា

កាលបុគ្គលជនទៃមិនជាស់តឿន ក៏រឭក មិនបាន តែកាលអ្នកដទៃជាស់តឿន លោកឲ្យរឭកថា ក្នុងទីកន្លែងឈ្មោះនោះ ក្នុងវេលានោះ កាលនោះ ទើបរឭក បាន ។

បទថា **បមុដ្ឋោ** សេចក្តីថា បុគ្គល សូម្បីអ្នកដទៃជាស់តឿនឲ្យរឭក ដោយឧបាយនោះៗ ក៏រឭកមិនបាន ។ សូម្បីវារៈនៃបុគ្គលអ្នកឲ្យចោទ ក៏គប្បី ជ្រាបដោយឧបាយនេះ ។ ក្នុងចោទាបកវារៈនោះ លុបបទថា **មយា** ចេញ បទដ៏សេសក៏ដូចគ្នានឹងចោទកៈនោះឯង ។

[ ២៥៨-២៦២ ] បន្ទាប់អំពីចោទាបកវារៈនោះ ដើម្បីសម្តែងប្រភេទនៃ អាបត្តិ និងប្រភេទ នៃអនាបត្តិ ទើបទ្រង់តាំងចតុក្កៈថា **អសុទ្ធេ សុទ្ធទិដ្ឋិ** ជា ដើមហើយ ទ្រង់សម្តែងពង្រីកតែមួយបទចេញទៅតាមប្រភេទនីមួយៗ ៤ ប្រភេទ ។ ចតុក្កៈទាំងអស់នោះ អ្នកសិក្សាអាចនឹងដឹងបាន តាមន័យនៃ ព្រះបាលីនោះឯង ។ ក្នុងការចោទនេះ គប្បីជ្រាបការផ្សេងគ្នានៃបំណង តែម្យ៉ាង ។ ពិតហើយ ធម្មតាបំណងនេះ មានច្រើនយ៉ាង គឺបំណងក្នុង ការឲ្យឃ្លាត បំណងក្នុងការជេរ បំណងក្នុងការងារ បំណងក្នុងការចេញ ( ចាក អាបត្តិ ) បំណងក្នុងការបញ្ឈប់ឧបោសថ និងបវារណា បំណងក្នុងការ សាកសួរ បំណងក្នុងការពោលធម៌ ។

បណ្តាបំណងទាំងនោះ ក្នុងបំណង ៤ យ៉ាងខាងដើម ត្រូវអាបត្តិ ទុក្កដ ដល់ភិក្ខុដែលមិនសូមឱកាស និងត្រូវអាបត្តិសង្ឃាទិសេស សូម្បីដល់ភិក្ខុ ដែលសូមឱកាស ហើយចោទដោយអាបត្តិបារាជិកដែលមិនមានមូលក្នុងទី

ចំពោះមុខ ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុអ្នកចោទ ដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលចោទ ដោយអាចារវិបត្តិ ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុ ដែលពោលដោយបំណងនឹងជេរ ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលពោលដោយកងអាបត្តិទាំង ៧ កង ក្នុងទីកំបាំងមុខ ត្រូវអាបត្តិទុក្កដតែម្យ៉ាងដល់ភិក្ខុដែលធ្វើកម្មទាំង ៧ យ៉ាង ក្នុងទីកំបាំងមុខ ។ ឯក្នុងកុរុន្ទីពោលថា កិច្ចដោយការសូមឱកាស រមែងមិនមានដល់ភិក្ខុដែលពោលថា លោកត្រូវអាបត្តិឈ្មោះនេះ ចូរធ្វើការសម្តែងអាបត្តិនោះចេញ ដោយបំណងឲ្យចេញចាកអាបត្តិ ។ ក្នុងអដ្ឋកថាគ្រប់ៗ អដ្ឋកថាទាំងអស់ មិនមានការសូមឱកាសសម្រាប់ភិក្ខុដែលបញ្ឈប់ឧបោសថ និងបវារណា ។ តែគប្បីដឹងខេត្តនៃការបញ្ឈប់ដូច្នេះថា កាលសូធ្យមិនទាន់ហួស រេ អក្ខរៈ នេះថា **សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ បណ្ណរសោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេ** ដូច្នេះទៅ រមែងបានដើម្បីបញ្ឈប់ ។ តែបន្ទាប់អំពីនោះទៅ កាលដល់ **យ** អក្ខរៈហើយ រមែងមិនបានដើម្បីបញ្ឈប់ ក្នុងបវា-រណាក៏មានន័យយ៉ាងនេះ ។

ឱកាសកម្ម រមែងមិនមានដល់ភិក្ខុដែលសាកសួរក្នុងកាលរឿងត្រូវនាំចូលសំណូមពរហើយ ពោលដោយបំណងសាកសួរថា រឿងយ៉ាងនេះមានដល់លោកឬ សូម្បីសម្រាប់ព្រះធម្មកថិក ដែលអង្គុយលើធម្មាសនៈ ពោលធម៌មិនចំពោះ ដោយន័យជាដើមថា ភិក្ខុណាធ្វើយ៉ាងនេះ និងយ៉ាងនេះ ភិក្ខុនេះមិនមែនសមណៈ ដូច្នេះ ក៏មិនចាំបាច់សូមឱកាស ។ តែបើពោលកំណត់

ចំពោះថា បុគ្គលនោះៗ មិនមែនសមណៈ មិនមែនឧបាសក ដូច្នេះ ចុះអំពីធម្មាសនៈហើយ គួរសម្ដែងអាបត្តិសិន សឹមទៅ ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃពាក្យដែលលោកពោលទុកក្នុងទីនោះថា **អនោកាសំ ការេត្វា** យ៉ាងនេះថា **ឱកាសំ អការេត្វា** ប្រែថា មិនឲ្យធ្វើឱកាស ។ ពិតហើយ ឈ្មោះថា ឱកាសមិនសមគួរក្នុងកាលខ្លះ ដែលដើមចោទឲ្យចុងចោទធ្វើឱកាសហើយ នៅតែត្រូវអាបត្តិមិនមាន តែដើមចោទមិនឲ្យចុងចោទធ្វើឱកាស ទើបត្រូវអាបត្តិ ដូច្នេះឯង ពាក្យដ៏សេសរាក់ទាំងអស់ហើយ ។

បណ្ដាសមុដ្ឋានជាដើម សិក្ខាបទនេះមានសមុដ្ឋាន ៣ គឺកើតឡើងតាមកាយ និងចិត្ត ១ វាចា និងចិត្ត ១ កាយវាចា និងចិត្ត ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម វចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ដូច្នេះឯង ។

បឋមទុដ្ឋទោសសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ៩

[ ២៦៤ ] សម័យនោះ ព្រះពុទ្ធដ៏មានជោគជាម្ចាស់ ទ្រង់គង់នៅក្នុងអារាមវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯងមេត្តិយភិក្ខុ និងភុម្មជកភិក្ខុទាំងឡាយ កាលនាំគ្នាចុះអំពីភ្នំគិជ្ឈកូដ បានឃើញពពែឈ្មោល កំពុងរួមសន្ធវៈនឹងពពែញី លុះឃើញហើយ ទើបនិយាយគ្នាយ៉ាងនេះថា អើអាវុសោ ពួកយើងនឹងសន្មតពពែឈ្មោលនេះឲ្យជាឈ្មោះទព្វមល្លបុត្រ ( បុត្រមល្លក្សត្រ ) សន្មតពពែញីនេះឲ្យជាឈ្មោះនាងមេត្តិយាភិក្ខុនី យើងនឹងនាំគ្នាហៅយ៉ាងនេះ ម្នាលអាវុសោ កាលអំពីដើមយើងបានចោទទព្វមល្លបុត្រដោយពាក្យថា យើងបានឮ ប៉ុន្តែឥឡូវនេះទព្វមល្លបុត្រសេពមេថុនធម្មនឹងនាងមេត្តិយាភិក្ខុនី យើងបានឃើញដោយខ្លួនឯង ។ ភិក្ខុទាំងពីររូបនោះ ក៏បានតាំងសន្មតពពែឈ្មោលនោះ ជាឈ្មោះទព្វមល្លបុត្រសន្មតពពែញីនោះ ជាឈ្មោះនាងមេត្តិយាភិក្ខុនី ។ ភិក្ខុទាំងនោះទៅនិយាយប្រាប់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ កាលពីដើមយើងបានចោទទព្វមល្លបុត្រ ដោយបានឮ ប៉ុន្តែឥឡូវនេះ ទព្វមល្លបុត្រសេពមេថុនធម្មនឹងនាងមេត្តិយាភិក្ខុនី យើងបានឃើញដោយខ្លួនឯង ។ ភិក្ខុទាំងឡាយបានឆ្លើយយ៉ាងនេះថា នែអាវុសោ លោកកុំនិយាយយ៉ាងហ្នឹង ឯទព្វមល្លបុត្រដ៏មានអាយុ មុខជានឹងមិនធ្វើដូចលោកថាទេ ។ គ្រានោះ ពួកភិក្ខុទាំងនោះ ក៏ក្រាបទូលសេចក្តីនុ៎ះដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះដំណើរនេះ រឿងនេះទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់

ទព្វមល្លបុត្រដ៏មានអាយុថា នែទព្វៈ អ្នករឭកឃើញឬទេ ពួកភិក្ខុទាំងនេះ ពោលយ៉ាងណា អ្នកបានធ្វើយ៉ាងនោះឬទេ ។ ទព្វមល្លបុត្តទូលថា បពិត្រព្រះអង្គដ៏ចម្រើន ( រឿងអ្វីៗ ) ព្រះដ៏មានព្រះភាគទ្រង់ជ្រាបខ្ញុំព្រះអង្គដោយពិតហើយ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សួរពាក្យនេះនឹងទព្វ-មល្លបុត្រដ៏មានអាយុជាគម្រប់ពីរដងផង ។បេ។ ជាគម្រប់បីដងផងថា នែទព្វៈ អ្នករឭកបានឬទេ ពួកភិក្ខុទាំងនេះពោលយ៉ាងណា អ្នកបានធ្វើយ៉ាងនោះឬ ។ ទព្វមល្លបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបខ្ញុំព្រះអង្គដោយពិតហើយ ។ ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថា នែទព្វៈ អ្នកប្រាជ្ញទាំងឡាយ មិនពោលបណ្តោះបណ្តោយយ៉ាងនេះទេ ( បើអំពើអ្វី ) ដែលអ្នកបានធ្វើហើយ អ្នកចូរឆ្លើយថា ខ្ញុំបានធ្វើហើយ បើអ្នកមិនបានធ្វើទេ អ្នកចូរឆ្លើយថា ខ្ញុំមិនបានធ្វើទេ ។ ទព្វមល្លបុត្តទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតាំងពីដួចកើតមកវេលាណា មិនដែលសេពមេថុនធម្មទេ សូម្បីតែយល់សប្តិក៏មិនដែលឃើញទេ ចាច់និយាយថ្វីដល់ការភ្ញាក់រឭក ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរជម្រះសួរភិក្ខុពួកនេះមើល ។ លុះព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ទ្រង់ក៏ក្រោកចាកអាសនៈ ចូលទៅកាន់ព្រះវិហារ ។ គ្រានោះ ភិក្ខុទាំងឡាយបានជម្រះសួរមេត្តិយភិក្ខុ និងភុម្មជកភិក្ខុ ។ ភិក្ខុទាំងនោះ កាលបើភិក្ខុទាំងឡាយជម្រះសួរ ទើបប្រាប់សេចក្តីនេះដល់ភិក្ខុទាំងឡាយ ( តាមពិតត្រង់ ) ។ ភិក្ខុទាំងឡាយសួរថា នែអាវុសោ

អ្នកទាំងពីរកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ដ៏ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្រដ៏មានអាយុ ដោយអាបត្តិបារាជិកឬ ។ ភិក្ខុទាំងពីររូបឆ្លើយថា យ៉ាងហ្នឹងហើយអាវុសោ ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះពោលទោស តិះដៀល និន្ទាថា មេត្តិយភិក្ខុនិងភុម្មជកភិក្ខុមិនសមបីបើនឹងកាន់យកហេតុបន្តិចបន្តួច របស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្រ ដោយអាបត្តិបារាជិកសោះ ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែភិក្ខុទាំងឡាយ ឮថាអ្នករាល់គ្នាកាន់យកហេតុ បន្តិចបន្តួចរបស់អធិករណ៍ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្រ ដោយអាបត្តិបារាជិកពិតមែនឬ ។ ភិក្ខុទាំងពីររូបក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អ្នករាល់គ្នា មិនសមបីបើនឹងកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ ដ៏ជាចំណែកខាងក្រៅមកជាគ្រឿងអាង ហើយចោទទព្វមល្លបុត្រ ដោយអាបត្តិបារាជិកសោះ នែមោឃបុរស អំពើដែលអ្នកបានធ្វើមកនេះ មិននាំឲ្យកើតជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ មានទោសទ្រុស្តហើយ មានសេចក្តីក្រោធ មានចិត្តមិនរីករាយ បានកាន់យកហេតុបន្តិចបន្តួចរបស់អធិករណ៍ជាចំណែកដទៃមកជាគ្រឿងអាង ហើយចោទភិក្ខុដោយអាបត្តិបារាជិក ដោយ

បំណងថា ធ្វើម្តេចហ្ន៎ អញគប្បីញ៉ាំងភិក្ខុនោះ ឲ្យឃ្លាតចាកព្រហ្មចរិយធម៌ ( សាសនា ) នេះបាន លុះសម័យខាងក្រោយតពីនោះមក ភិក្ខុអ្នកចោទនោះ មានគេសាកសួរក្តី មិនមានគេសាកសួរក្តី តែអធិករណ៍នោះជាចំណែកដទៃទេ ភិក្ខុកាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង ហើយភិក្ខុប្តេជ្ញាទោស ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។

[ ២៦៥ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌរួចហើយ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ ពាក្យថា មានទោសទ្រុស្តហើយ មានសេចក្តីក្រោធ គឺមានចិត្តក្រោធខឹង មានចិត្តមិនជារបស់ខ្លួន មិនត្រេកអរ មានចិត្តគុំគួន ចង្អៀតចង្អល់ ។ ពាក្យថា មានចិត្តមិនរីករាយ គឺមានចិត្តអាក់អន់ ព្រោះក្រោធខឹងនោះផង ព្រោះទោសនោះផង ព្រោះសេចក្តីអន់ចិត្តនោះផង ព្រោះសេចក្តីមិនត្រេកអរនោះផង ។

[ ២៦៦ ] ពាក្យថា របស់អធិករណ៍ជាចំណែកដទៃ គឺចំណែកដទៃនៃអាបត្តិ ឬចំណែកដទៃនៃអធិករណ៍ ។

[ ២៦៧ ] ( សួរថា ) អធិករណ៍ដែលមានចំណែកផ្សេងពីអធិករណ៍នោះដូចម្តេច ។ ( ប្រាប់ថា ) វិវាទាធិករណ៍មានចំណែកផ្សេងអំពីអនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ អនុវាទាធិករណ៍ ចាត់ដោយឡែកផ្សេងអំពីអាបត្តាធិករណ៍ កិច្ចាធិករណ៍ វិវាទាធិករណ៍ និងអនុវាទាធិករណ៍ កិច្ចាធិករណ៍ចាត់ដោយឡែកផ្សេងអំពីវិវាទាធិករណ៍ អនុវាទាធិករណ៍ និងអាបត្តាធិករណ៍ ។ អធិករណ៍យ៉ាងនេះ ហៅថា មានចំណែកផ្សេងគ្នាអំពី

អធិករណ៍ ។

[ ២៦៨ ] ( សួរថា ) អធិករណ៍ដែលមានចំណែកដូចគ្នានឹងអធិករណ៍នោះដូចម្តេច ។ ( ប្រាប់ថា ) វិវាទាធិករណ៍មានចំណែកដូចគ្នានឹងវិវាទាធិករណ៍ អនុវាទាធិករណ៍មានចំណែកដូចគ្នានឹងអនុវាទាធិករណ៍ អាបត្តាធិករណ៍មានចំណែកដូចគ្នានឹងអាបត្តាធិករណ៍ក៏មាន មានចំណែកផ្សេងអំពីគ្នាក៏មាន ។ ( សួរថា ) អាបត្តាធិករណ៍មានចំណែកផ្សេងគ្នាអំពីអាបត្តាធិករណ៍នោះដូចម្តេច ។ ( ប្រាប់ថា ) មេថុនធម្មបារាជិកាបត្តិមានចំណែកផ្សេងគ្នាអំពីអទិន្នាទានបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិ និងឧត្តរិមនុស្សធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិមានចំណែកផ្សេងគ្នាអំពីមនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិ និងមេថុនធម្មបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិ មានចំណែកផ្សេងគ្នាអំពីឧត្តរិមនុស្សធម្មបារាជិកាបត្តិ មេថុនធម្មបារាជិកាបត្តិ និងអទិន្នាទានបារាជិកាបត្តិ ឧត្តរិមនុស្សធម្មបារាជិកាបត្តិមានចំណែកផ្សេងគ្នាអំពីមេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិ និងមនុស្សវិគ្គហបារាជិកាបត្តិ ។ អាបត្តាធិករណ៍យ៉ាងនេះ ( ហៅថា ) មានចំណែកផ្សេងគ្នាអំពីអាបត្តាធិករណ៍ ។ ( សួរថា ) អាបត្តាធិករណ៍មានចំណែកដូចគ្នានឹងអាបត្តាធិករណ៍នោះដូចម្តេច ។ ( ប្រាប់ថា ) មេថុនធម្មបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងមេថុនធម្មបារាជិកាបត្តិ អទិន្នាទានបារាជិកាបត្តិមានចំណែកជាមួយគ្នានឹងអទិន្នាទានបារាជិកាបត្តិ មនុស្សវិគ្គហបារាជិកាបត្តិមានចំណែកជាមួយគ្នានឹងមនុស្សវិគ្គហបារាជិកាបត្តិ ឧត្តរិ-

មនុស្សធម្មបារាជិកាបត្តិ មានចំណែកជាមួយគ្នានឹងឧត្តរិមនុស្សធម្មបារាជិកា-បត្តិ ។ អាបត្តាធិករណ៍យ៉ាងនេះ ( ហៅថា ) មានចំណែកជាមួយគ្នានឹងអាបត្តាធិករណ៍ ។ កិច្ចាធិករណ៍ក៏មានចំណែកជាមួយគ្នានឹងកិច្ចាធិករណ៍ដែរ ។ អធិករណ៍យ៉ាងនេះ ( ហៅថា ) មានចំណែកជាមួយគ្នានឹងអធិករណ៍ ។

[ ២៦៩ ] ត្រង់ពាក្យថា កាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង ដែលហៅថាគ្រឿងអាងនោះ បានដល់គ្រឿងអាង ១០ យ៉ាង គឺគ្រឿងអាងជាតិ ១ នាម ១ គោត្រ ១ ភេទ ១ អាបត្តិ ១ បាត្រ ១ ចីវរ ១ ឧបជ្ឈាយ៍ ១ អាចារ្យ ១ សេនាសនៈ ១ ។

[ ២៧០ ] ដែលហៅថា គ្រឿងអាង គឺជាតិនោះ បានដល់ភិក្ខុអ្នកចោទឃើញភិក្ខុជាក្សត្រ ត្រូវអាបត្តិបារាជិក ( តែមិនបានចោទភិក្ខុជាក្សត្រនោះក្នុងខណៈនោះ ) លុះបានឃើញភិក្ខុដទៃជាក្សត្រដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំបានឃើញលោកជាក្សត្រ ត្រូវអាបត្តិបារាជិកហើយលោកមិនមែនជាសមណៈ លោកមិនមែនជាកូនចៅព្រះពុទ្ធបុត្តសក្យរាជ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី មិនមានជាមួយនឹងអ្នកទេ ដូច្នេះ ភិក្ខុអ្នកចោទត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។ ភិក្ខុអ្នកចោទ ឃើញភិក្ខុជាតិជាព្រាហ្មណ៍ ។បេ។ ឃើញភិក្ខុជាវេស្ស ( អ្នកជំនួញ ) ។បេ។ ឃើញភិក្ខុជាសុទ្ទ ( អ្នកធ្វើការគូលី ) ត្រូវអាបត្តិបារាជិក ( តែអ្នកចោទមិនបានចោទ ) លុះបានឃើញភិក្ខុដទៃជាជាតិសុទ្ទដែរ ទើប ( ក្លែង ) ចោទថា ខ្ញុំបានឃើញ អ្នកជាតិជាសុទ្ទ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ

អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធបុត្តសក្យរាជទេ ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៧១ ] ដែលហៅថា គ្រឿងអាងគឺនាមនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុឈ្មោះពុទ្ធរក្ខិត ។បេ។ ឃើញភិក្ខុឈ្មោះធម្មរក្ខិត ។បេ។ ឃើញភិក្ខុឈ្មោះសង្ឃរក្ខិតត្រូវអាបត្តិបារាជិក ( តែភិក្ខុអ្នកចោទមិនបានចោទ ) លុះបានឃើញភិក្ខុដទៃឈ្មោះសង្ឃរក្ខិតដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំឃើញអ្នកឈ្មោះសង្ឃរក្ខិត ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៧២ ] ដែលហៅថា គ្រឿងអាងគឺគោត្រនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុដែលមានគោត្រជាគោតម ។បេ។ ឃើញភិក្ខុមានគោត្រជាមោគ្គល្លាន ។បេ។ ឃើញភិក្ខុមានគោត្រជាកច្ចាយន ។បេ។ ឃើញភិក្ខុមានគោត្រជាវាសិដ្ឋ ត្រូវអាបត្តិបារាជិក ( តែមិនបានចោទ ) លុះបានឃើញ ភិក្ខុដទៃមានគោត្រជាវាសិដ្ឋដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំបានឃើញអ្នក មានគោត្រជាវាសិដ្ឋ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ ។បេ។ ដូច្នេះ ភិក្ខុអ្នកចោទ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៧៣ ] ដែលហៅថា គ្រឿងអាងគឺភេទនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុមានរាងខ្ពស់ ។បេ។ ឃើញភិក្ខុមានរាងទាប ។បេ។ ឃើញភិក្ខុមានសម្បុរ

ខ្មៅ ។បេ។ ឃើញភិក្ខុមានសម្បុរ ស ត្រូវអាបត្តិបារាជិក ( តែមិនបានចោទ ) លុះឃើញភិក្ខុដទៃមានសម្បុរ សដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំបានឃើញអ្នកមានសម្បុរ ស ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈទេ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្តទេ ។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៧៤ ] ដែលហៅថា គ្រឿងអាងគឺអាបត្តិនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុត្រូវអាបត្តិស្រាល បើភិក្ខុអ្នកចោទៗ ភិក្ខុនោះដោយអាបត្តិបារាជិកថា ខ្ញុំបានឃើញលោកត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃា-ទិសេសគ្រប់ៗ វាចា ។

[ ២៧៥ ] ដែលហៅថា គ្រឿងអាងគឺបាត្រនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុប្រើបាត្រទង់ដែង ។បេ។ ឃើញភិក្ខុប្រើបាត្រដី ។បេ។ ឃើញភិក្ខុប្រើបាត្រសំពត់សាដក[១] ។បេ។ ឃើញភិក្ខុប្រើបាត្រដី[២]ដែលមានសម្បុរលើប ត្រូវអាបត្តិបារាជិក ( តែមិនបានចោទ ) លុះឃើញភិក្ខុដទៃប្រើ បាត្រដីដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំឃើញអ្នកឯងប្រើបាត្រដី ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។ បេ ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

---

១- តាមអដ្ឋកថាសមន្តបា្ទសាទិកាថា បាត្រដីនោះឯង តែមានទ្រង់ទ្រាយល្អ មានសម្បុរលោងហាក់ដូចពណ៌សត្វកំភេម រលើងស្អាតដូចបាត្រទង់ដែងដែរ ។ ២- បាលីថា សុម្ភកបត្ត តាមអដ្ឋកថាថា បានដល់ បាត្រដីតាមធម្មតានោះឯង ។

[ ២៧៦ ] ដែលហៅថា គ្រឿងអាងគឺចីវរនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុប្រើចីវរបង្សុកូល ។បេ។ ឃើញភិក្ខុប្រើចីវររបស់គហបតី ត្រូវអាបត្តិបារាជិក ( តែមិនបានចោទ ) លុះបានឃើញភិក្ខុដទៃប្រើចីវររបស់គហបតីដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំបានឃើញអ្នកឯងប្រើចីវររបស់គហបតី ត្រូវអាបត្តិបារាជិក អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៧៧ ] ដែលហៅថា គ្រឿងអាងគឺព្រះឧបជ្ឈាយ៍នោះ គឺភិក្ខុអ្នកចោទ បានឃើញសទ្ធិវិហារិករបស់ព្រះឧបជ្ឈាយ៍មានឈ្មោះយ៉ាងនេះ ត្រូវអាបត្តិបារាជិក ( តែមិនបានចោទ ) លុះបានឃើញភិក្ខុដទៃជាសទ្ធិវិហារិករបស់ព្រះឧបជ្ឈាយ៍មានឈ្មោះយ៉ាងហ្នឹងដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំបានឃើញអ្នកឯងជាសទ្ធិវិហារិករបស់ឧបជ្ឈាយ៍ឈ្មោះនេះ ត្រូវអាបត្តិបារាជិក ហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៧៨ ] ដែលហៅថា គ្រឿងអាងគឺអាចារ្យនោះ គឺភិក្ខុអ្នកចោទបានឃើញអន្តេវាសិករបស់អាចារ្យឈ្មោះនេះ ត្រូវអាបត្តិបារាជិក ( តែមិនចោទ ) លុះឃើញភិក្ខុដទៃជាអន្តេវាសិករបស់លោកអាចារ្យឈ្មោះហ្នឹងដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំបានឃើញអ្នកឯងជាអន្តេវាសិករបស់លោកអាចារ្យឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ។បេ។ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិ-

សេសគ្រប់ៗ វាចា ។

[ ២៧៩ ] ដែលហៅថា គ្រឿងអាងគឺសេនាសនៈនោះ គឺភិក្ខុអ្នកចោទឃើញភិក្ខុនៅក្នុងសេនាសនៈរបស់ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិក ( តែមិនចោទ ) លុះឃើញភិក្ខុដទៃជាអ្នកនៅក្នុងសេនាសនៈរបស់ភិក្ខុឈ្មោះហ្នឹងដែរ ហើយ ( ក្លែង ) ចោទថា ខ្ញុំបានឃើញអ្នកឯងនៅក្នុងសេនាសនៈរបស់ភិក្ខុឈ្មោះនេះ ត្រូវអាបត្តិបារាជិកហើយ អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី មិនមានជាមួយនឹងអ្នកឯងទេ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៨០ ] ពាក្យថា ដោយអាបត្តិបារាជិក គឺបានដល់អាបត្តិបារាជិកទាំង ៤ អាបត្តិបារាជិកណាមួយ ។ ពាក្យថា ចោទ គឺចោទឯងក្តី ឲ្យអ្នកដទៃចោទក្តី ។ ពាក្យថា ធ្វើដូចម្តេចហ្ន៎ អញគប្បីញ៉ាំងភិក្ខុនោះឲ្យឃ្លាតចាកព្រហ្មចរិយធម៌នេះ គឺថា អញគប្បីញ៉ាំងភិក្ខុនេះឲ្យឃ្លាតចាកភាវៈជាភិក្ខុ ឲ្យឃ្លាតចាកសមណធម៌ ឲ្យឃ្លាតចាកសីលក្ខន្ធ ឲ្យឃ្លាតចាកគុណ គឺធម៌ជាគ្រឿងដុតកិលេស ។

[ ២៨១ ] ពាក្យថា លុះសម័យខាងក្រោយតអំពីនោះមក គឺភិក្ខុចោទគេក្នុងខណៈណា ខណៈនោះ ពេលនោះ ស្របក់នោះកន្លងទៅហើយ ។ ពាក្យថា មានគេសាកសួរ គឺថាភិក្ខុចោទគេដោយវត្ថុណា គេសាកសួរចំពោះវត្ថុនោះ ។ ពាក្យថា មិនមានគេសាកសួរ គឺមិនមានអ្នកណាមួយនិយាយឡើយ ។

[ ២៨២ ] ដែលហៅថា អធិករណ បានដល់អធិករណៈ ៤ គឺវិវាទាធិករណៈ ១ អនុវាទាធិករណៈ ១ អាបត្តាធិករណៈ ១ កិច្ចាធិករណៈ ១ ។

[ ២៨៣ ] ពាក្យថា កាន់យកហេតុបន្តិចបន្តួចមកជាគ្រឿងអាង គឺបណ្តាគ្រឿងអាងទាំង ១០ យ៉ាងនោះ ភិក្ខុកាន់យកគ្រឿងអាងណាមួយ ។

[ ២៨៤ ] ពាក្យថា ភិក្ខុប្តេជ្ញាទោស គឺ ( ភិក្ខុប្តេជ្ញាថា ) ខ្ញុំនិយាយពាក្យទទេសោះ ខ្ញុំនិយាយពាក្យកុហក ខ្ញុំនិយាយពាក្យមិនពិត ខ្ញុំនិយាយដោយមិនដឹង ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយពិស្តារក្នុងសង្ឃាទិសេសសិក្ខាបទទី ១ រួចហើយ ។

[ ២៨៥ ] ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញនិងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិសង្ឃាទិសេសមែនតែបើ ក្លែងចោទភិក្ខុនោះ ដោយអាបត្តិបារាជិកវិញថា អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ ឯអធិករណៈយ៉ាងនេះក៏ឈ្មោះថា ចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេស[១]សោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិថុល្លច្ច័យវិញ តែបើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ ។បេ។ ឯអធិករណៈយ៉ាងនេះ

---

១- លិសធាតុ ក្នុងអត្ថថា តិច-តួច គឺជាការបន្ទាប់សន្សំ ។

ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាចិត្តិយវិញ តែបើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ ។បេ។ ឯអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិបាដិទេសនីយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុក្កដវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថាជាអាបត្តិទុព្ភាសិតវិញ តែបើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ ។បេ។ ឯអធិករណៈយ៉ាងនេះក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៨៦ ] ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិថុល្លច្ច័យ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាចិត្តិយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាដិទេសនីយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុក្កដវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិ

ថុល្លច្ច័យថា ជាអាបត្តិទុព្ភាសិតវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិសង្ឃាទិសេសវិញ បើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ ។បេ។ សូម្បីអធិករណៈយ៉ាងនេះក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុអ្នកចោទក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ។បេ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយ ។បេ។ ភិក្ខុ ត្រូវអាបត្តិទុក្កដ ។បេ។ ភិក្ខុត្រូវអាបត្តិទុព្ភាសិត ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុព្ភាសិត ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិសង្ឃាទិសេស ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិថុល្លច្ច័យ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាចិត្តិយ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថា ជាអាបត្តិបាដិទេសនីយ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុក្កដទៅវិញ បើក្លែងចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

បណ្ឌិតគប្បីធ្វើអធិករណៈនោះៗ ឲ្យមានមូលមួយៗ ហើយចងជាចក្ក ( ដូចគ្នា ) ។

[ ២៨៧ ] ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិសង្ឃាទិសេសដែរ បើ

ឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ ។ បេ ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណ៍ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។ ភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិថុល្លច្ច័យទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិបាចិត្តិយវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិបាដិទេសនីយទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេសថា ជាអាបត្តិទុក្កដទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិសង្ឃាទិសេស ថាជាអាបត្តិទុព្ភាសិតទៅវិញ បើឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈទេ ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះ ក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៨៨ ] ភិក្ខុត្រូវអាបត្តិថុល្លច្ច័យ ភិក្ខុអ្នកចោទក៏បានឃើញនិងមានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិថុល្លច្ច័យ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាចិត្តិយទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិបាដិទេសនីយទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុក្កដទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិថុល្លច្ច័យថាជាអាបត្តិទុព្ភាសិតទៅវិញ ។ បេ។ មានសេចក្តីយល់ក្នុង

អាបត្តិថុល្លច្ច័យថាជាអាបត្តិសង្ឃាទិសេសទៅវិញ បើឲ្យអ្នកដទៃចោទភិក្ខុនោះ ដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ ។បេ។ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោត ភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ អ្នកចោទក៏បានឃើញ ។បេ។ ភិក្ខុត្រូវអាបត្តិបាដិ-ទេសនីយ ។បេ។ ភិក្ខុត្រូវអាបត្តិទុក្កដ ។បេ។ ភិក្ខុត្រូវអាបត្តិទុព្ភាសិត ភិក្ខុអ្នកចោទក៏បានឃើញ និងមានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិត ថាជាអាបត្តិទុព្ភាសិតដែរ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថា ជាអាបត្តិសង្ឃាទិសេសទៅវិញ ។បេ។មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិត ថាជាអាបត្តិថុល្លច្ច័យទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថា ជាអាបត្តិបាចិត្តិយទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិបាដិទេសនីយទៅវិញ ។បេ។ មានសេចក្តីយល់ក្នុងអាបត្តិទុព្ភាសិតថាជាអាបត្តិទុក្កដទៅវិញ បើឲ្យអ្នកដទៃចោទភិក្ខុនោះដោយអាបត្តិបារាជិកថា អ្នកឯងមិនមែនជាសមណៈ អ្នកឯងមិនមែនជាកូនចៅព្រះពុទ្ធ ជាសក្យបុត្តិ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី ជាមួយនឹងអ្នកឯងគ្មានទេ សូម្បីអធិករណៈយ៉ាងនេះ ក៏ឈ្មោះថាចំណែកដទៃនៃអាបត្តាធិករណៈ ទាំងលេសសោតភិក្ខុនោះក៏នៅប្រកាន់ ដូច្នេះ ត្រូវអាបត្តិសង្ឃាទិសេសគ្រប់ៗ វាចា ។

[ ២៨៩ ] អាបត្តិមិនមានដល់ភិក្ខុអ្នកចោទមានសេចក្តីសម្គាល់ពិតហើយចោទឯង ឬឲ្យអ្នកដទៃចោទ ដល់ភិក្ខុឧម្មត្តកៈ ដល់ភិក្ខុជាអាទិកម្មិក។

# សង្ឃាទិសេសទី ៩ ចប់

# អដ្ឋកថា

## ទុតិយទុដ្ឋទោសសិក្ខាបទវណ្ណនា[១]

[ ២៦៤ ] ទុតិយទុដ្ឋទោសសិក្ខាបទ បទថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅថា គប្បីជ្រាបវិនិច្ឆ័យក្នុងទុដ្ឋទោសសិក្ខាបទនោះ ដូចតទៅ

បទថា **ហន្ទ មយំ អាវុសោ ឥមំ ឆកលកំ ធម្មំ មល្លបុត្តំ ឆាម ករោម** សេចក្ដីថា បានឮថា មេត្តិយ និងភុម្មជកភិក្ខុនោះ មិនអាចឲ្យមានោរថរបស់ខ្លួនសម្រេចក្នុងរឿងដំបូង បានទទួលនូវការតិះដៀល ដល់នូវការអាក់អន់ ពោលថា ណ្ហើយចុះ ពួកយើងនឹងដឹងគ្នា ហើយសម្លឹងរំពៃរករឿងរ៉ាវដូច្នោះ ។ សម័យថ្ងៃមួយ បានឃើញហើយ ត្រេកអរក្នុងចិត្ត សម្លឹងមើលគ្នានិងគ្នា ហើយបានពោលយ៉ាងនេះថា ណ្ហើយចុះ អាវុសោ ពួកយើងសន្មតពពែឈ្មោលនេះ ឲ្យឈ្មោះថា ទព្វមល្លបុត្រ ។ មានពាក្យអធិប្បាយថា ពួកយើងនឹងតាំងឈ្មោះឲ្យពពែឈ្មោលនេះ យ៉ាងនេះថា ពពែនេះឈ្មោះថា ទព្វមល្លបុត្រ សូម្បីក្នុងពាក្យថា **មេត្តិយំ ឆាម ភិក្ខុនឹ** នេះ ក៏ន័យនេះ ។

បទថា **តេ ភិក្ខូ មេត្តិយភុម្មជកេ ភិក្ខូ អនុយុញ្ជិសុ** សេចក្ដីថា ពួកភិក្ខុទាំងនោះ សាកសួរយ៉ាងនេះថា លោកដ៏មានអាយុទាំងឡាយ ពួកលោកឃើញព្រះទព្វមល្លបុត្រ និងមេត្តិយាភិក្ខុនី ក្នុងទីណាហ្ន៎ ពួកលោកឆ្លើយថា ត្រង់ជើងភ្នំគិជ្ឈកូដ ភិក្ខុទាំងឡាយសួរថា ក្នុងពេលណា ពួកលោក

---

១- ក្នុងទីខ្លះ សិក្ខាបទនេះហៅថា អញ្ញភាគិយសិក្ខាបទ ។

ឆ្លើយថា ក្នុងវេលាទៅភិក្ខាចារ ពួកភិក្ខុសួរព្រះទព្វមល្លបុត្រថា អាវុសោ ទព្វៈ ពួកភិក្ខុទាំងនេះពោលយ៉ាងនេះ លោកនៅទីណា ក្នុងវេលានោះ ព្រះទព្វមល្លបុត្រឆ្លើយថា ខ្ញុំចែកភត្តាហារនៅក្នុងវត្តវេឡុវ័ន ។ បុគ្គលណាខ្លះដឹងថា លោកនៅក្នុងវេឡុវ័នក្នុងពេលនោះ ព្រះទព្វៈឆ្លើយថា ភិក្ខុសង្ឃ លោកម្ចាស់ ទើបពួកភិក្ខុទាំងនោះសួរសង្ឃថា លោកទាំងឡាយជ្រាបទេថា អ្នកមានអាយុទព្វៈនេះនៅឯវេឡុវ័នក្នុងវេលានោះ ភិក្ខុសង្ឃប្រាប់ថា លោកដ៏មានអាយុទាំងឡាយ ពួកខ្ញុំដឹងថា ព្រះថេរៈនៅឯវេឡុវ័នប៉ុណ្ណោះ តាំងអំពីថ្ងៃដែលលោកបានទទួកសន្មតហើយ ។

លំដាប់នោះ ទើបភិក្ខុទាំងឡាយ ពោលនឹងមេត្តិយ និងភុម្មជកភិក្ខុថា អាវុសោ ពាក្យសម្តីរបស់លោកទាំងពីរមិនត្រូវគ្នា លោកអាងលេស ពោលនឹងពួកខ្ញុំទេដឹង ។

មេត្តិយ និងភុម្មជកភិក្ខុ ទាំងពីររូបនោះ ត្រូវពួកភិក្ខុទាំងនោះ ដេញដោលយ៉ាងនោះ បានពោលថា មែនហើយ អាវុសោ ទើបបានប្រាប់រឿងរ៉ាវនោះ ។

ក្នុងពាក្យថា **កិម្បន ។បេ។ អធិករណស្ស** នេះ មានវិនិច្ឆ័យដូច្នេះថា ពពែនេះនៃចំណែកដទៃ ឬចំណែកដទៃនៃពពែនេះ មាន ព្រោះហេតុនោះ ទើបពពែនោះឈ្មោះថា **អញ្ញភាគិយ** ( មានចំណែកដទៃ ) ។ សត្វដែលទទួល គប្បីជ្រាបថា អធិករណ៍ ។ អធិប្បាយថា ទីតាំងនៃរឿង ។ ព្រោះថាពពែដែលពួកមេត្តិយ និងភុម្មជកភិក្ខុ ពោលថា ឈ្មោះថា ទព្វមល្លបុត្រនោះ

រមែងមានដល់ចំណែក គឺកោដ្ឋាស បក្ខពួក ពោល គឺកំណើតសត្វតិរច្ឆាន និងភាពជាពពែដទៃចាកចំណែក គឺកោដ្ឋាស បក្ខពួក ពោល គឺកំណើតមនុស្ស និងភាពជាភិក្ខុរបស់ព្រះទព្វមល្លបុត្រ ម្យ៉ាងទៀត ចំណែកដទៃនោះមានដល់ពពែនោះ ព្រោះហេតុនោះ ទើបពពែនោះដល់នូវការរាប់ថា មានចំណែកដទៃ ។ ក៏ព្រោះពពែនោះ ជាទីទទួល ជាទីតាំងនៃរឿងរបស់សញ្ញា គឺការតាំងឈ្មោះនៃពួកភិក្ខុមេត្តិយ និងភុម្មជកភិក្ខុនោះ ដែលកំពុងពោលថា ពួកយើងសន្មតពពែនេះ ឲ្យឈ្មោះថា ទព្វមល្លបុត្រ ព្រោះដូច្នោះ ពពែនោះគប្បីជ្រាបថា អធិករណ៍ ។ ពិតហើយ ភិក្ខុទាំងនោះ សំដៅដល់ពពែនោះ ទើបពោលថា **អញ្ញភាគិយស្ស អធិករណស្ស** ជាដើម មិនបានពោលសំដៅអធិករណ៍ឯណាមួយ មានវិវាទាធិករណ៍ជាដើមឡើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអធិករណ៍ទាំងនោះមិនមាន ។

ព្រោះថា ភិក្ខុទាំងនោះ មិនបានកាន់យកឯកទេសឯណាមួយឲ្យត្រឹមតែជាលេសនៃអធិករណ៍ ៤ យ៉ាង អធិករណ៍ណាមួយដែលមានចំណែកដទៃ ។ ហើយឈ្មោះថា លេសនៃអធិករណ៍ ៤ ក៏មិនមាន ។ ពិតហើយ លេសទាំងឡាយ មានលេសដោយជាតិជាដើម ព្រះមានព្រះភាគត្រាស់ទុកសម្រាប់បុគ្គលទាំងនោះ មិនបានត្រាស់សម្រាប់អធិករណ៍ មានវិវាទាធិករណ៍ជាដើមឡើយ ។ ហើយឈ្មោះថា ទព្វមល្លបុត្រនេះ ជាឯកទេសឯណាមួយនៃពពែនោះ ដែលតាំងនៅក្នុងភាពជាអធិករណ៍ មានចំណែកដទៃ និងគ្រាន់តែជាលេសដើម្បីតាមចោទព្រះថេរៈ ដោយបារាជិកដែលមិនមានមូល ។

បណ្តាទេស និងលេសនេះ ចំណែកដែលឈ្មោះថា ទេស ព្រោះអត្ថប្រាកដ គឺត្រូវអាងដល់ ត្រូវហៅថា ពពែនេះ មានការសម្ពន្ធដល់ចំណែកដទៃនោះ ។ ពាក្យថា ទេស នេះ ជាឈ្មោះនៃចំណែកណាមួយ បណ្តាចំណែក មានជាតិជាដើម ។ ដែលឈ្មោះថា លេស ព្រោះអត្ថថា រួម គឺទាញវត្ថុដទៃទុក បានដល់ ជាប់នៅត្រឹមបន្តិចបន្តួច ដោយត្រឹមតែជាវោហារប៉ុណ្ណោះ ។ ពាក្យថា លេស នេះ ជាឈ្មោះនៃចំណែកណាមួយ បណ្តាចំណែក មានជាតិជាដើមដូចគ្នា ពាក្យដទៃក្រៅអំពី ២ ពាក្យនោះ មានអត្ថជាក់ច្បាស់ទាំងអស់ ។ ក្នុងសិក្ខាបទបញ្ញត្តិនេះ ក៏មានអត្ថយ៉ាងនេះដូចគ្នា ។

## អធិប្បាយ

## សិក្ខាបទវិភង្គនៃទុតិយទុដ្ឋទោសសិក្ខាបទ

## អធិករណ៍ជាចំណែកដទៃ

[ ២៦៦-២៦៧ ] បណ្ឌិតគប្បីជ្រាបសន្និដ្ឋាន ក្នុងបទភាជនីយ៍ថា ភិក្ខុគប្បីកាន់យកឯកទេស ណាមួយរបស់អធិករណ៍ ដែលជារឿងដទៃណា ឲ្យត្រឹមតែជាលេស តាមចោទភិក្ខុដោយធម៌ ដែលមានទោសដល់បារាជិក អធិករណ៍ដែលជារឿងដទៃនោះជាក់ច្បាស់ហើយ ដោយអំណាចនៃហេតុដែលកើតឡើងនោះឯង ព្រោះហេតុនោះ ទើបអធិករណ៍ដែលជារឿងដទៃនោះ ព្រះមានព្រះភាគ ទ្រង់មិនចែកទុកក្នុងបទភាជនីយ៍ ។ ឯអធិករណ៍ទាំង ៤ ណា ដែលព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃការលើកអត្ថឡើង ដោយសាមញ្ញថា អធិករណ៍ ។ អធិករណ៍ទាំងនោះជារឿងដទៃ

ហើយការដែលអធិករណ៍ទាំងនោះជារឿងនោះ មិនទាន់ប្រាកដផង ដែលព្រះវិនយធរទាំងឡាយគួរជ្រាបផង ព្រោះហេតុនោះ កាលព្រះអង្គទ្រង់អាស្រ័យអធិករណ៍ដែលបានដោយសាមញ្ញ ធ្វើភាពដែលអធិករណ៍ទាំងនោះជារឿងដទៃ និងជារឿងនោះៗ ឲ្យជាក់ច្បាស់ ទើបត្រាស់បទភាជនីយ៍ថា **អញ្ញាភាគិយស្ស អធិករណស្សាតិ អាបត្តញ្ញភាគិយំ វា ហោតិ អធិករណាញ្ញ ភាគិយំ វា** ជាដើម ។

ឯអធិករណ៍ទាំងពួងជារឿងនោះ និងជារឿងដទៃនេះ អ្នកសិក្សាគប្បីជ្រាបថា ទ្រង់ប្រមូលមកហើយ ដើម្បីសម្តែងនូវពាក្យចោទដោយអំណាចនៃអធិករណ៍ដែលជារឿងដទៃនៃអាបត្តិ ដែលត្រាស់ទុកហើយក្នុងទីបំផុតនោះឯង ។ ឯសេចក្តីពិត កាលនិទ្ទេសថា **កថញ្ច អាបត្តិ អាបត្តិយា អញ្ញភាគិយា ហោតិ** ដូច្នេះ ដែលព្រះអង្គទ្រង់ប្រារព្ធដល់ ព្រោះក្នុងឧទ្ទេសនោះ ទ្រង់បានលើកឡើងទុកមុនថា **អាបត្តញ្ញភាគិយំ វា** ជាដើម អត្ថនេះនឹងមកក្នុងគ្រាពិចារណាអធិករណ៍ជាចំណែកនោះ នៃអាបត្តាធិករណ៍នោះឯង ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់មិនបានប្រារព្ធយ៉ាងនោះ ទ្រង់កំណត់យកបទចុងក្រោយនោះឯង ប្រារព្ធនិទ្ទេសថា **កថញ្ច អធិករណំ អធិករណស្ស អញ្ញភាគិយំ** ដូច្នេះ ។

ក្នុងវារៈទាំងពីរនោះ **អញ្ញភាគិយវារ** មានអត្ថរាក់ហើយនោះឯង ។ ពិតហើយ អធិករណ៍នីមួយៗ ចាត់ជារឿងដទៃ គឺចំណែកដទៃ ជាចំណែកដទៃនៃអធិករណ៍ ៣ យ៉ាងក្រៅអំពីនេះ ព្រោះមានវត្ថុជាវិសភាគគ្នា ។

ឯក្នុង **តព្ភាគិយវារ** មានវិនិច្ឆ័យថា វិវាទាធិករណ៍ ចាត់ជារឿងនោះ ជាចំណែកនោះ ជាចំណែកនោះនៃវិវាទាធិករណ៍ ព្រោះមានវត្ថុជាសភាគគ្នា ។ អនុវាទាធិករណ៍ ជារឿងនោះនៃអនុវាទាធិករណ៍ក៏ដូចគ្នា ។ សេចក្តីនេះដូចម្តេច ព្រោះថា វិវាទដែលអាស្រ័យភេទករវត្ថុ ១៨ កើតឡើង តាំងអំពីសម័យពុទ្ធកាល ហើយវិវាទដែលអាស្រ័យភេទករវត្ថុកើតឡើងក្នុងឥឡូវនេះ រមែងជាវិវាទាធិករណ៍ដូចគ្នាពិត ព្រោះមានវត្ថុជាសភាគគ្នា ។

ម្យ៉ាងទៀត អនុវាទដែលអាស្រ័យវិបត្តិ ៤ កើតឡើងតាំងអំពីពុទ្ធកាល ហើយអនុវាទដែលអាស្រ័យវិបត្តិ ៤ កើតក្នុងឥឡូវនេះ រមែងឈ្មោះថា ជាអនុវាទាធិករណ៍ដូចគ្នាពិត ព្រោះមានវត្ថុជាសភាគគ្នា ។ ចំណែកអាបត្តាធិករណ៍ មិនរាប់ថាជារឿងនោះដោយចំណែកមួយ នៃអាបត្តាធិករណ៍ឡើយ ព្រោះមានវត្ថុជាសភាគគ្នាផង ជាវិសភាគគ្នាផង និងព្រោះគប្បីឃើញដូចការកើតឯង ព្រោះហេតុនោះ ទើបអាបត្តាធិករណ៍ លោកពោលថា ជារឿងនោះនៃអាបត្តាធិករណ៍ក៏មាន ជារឿងដទៃនៃអាបត្តាធិករណ៍ក៏មាន ។ ក្នុងតព្ភាគិយៈ និងអញ្ញភាគិយៈនោះ អញ្ញភាគិយៈនោះឯង ទ្រង់អធិប្បាយមុន ក្នុងអាបត្តាធិករណ៍និទ្ទេសនេះ ព្រោះអញ្ញភាគិយៈ ទ្រង់បានអធិប្បាយមកមុនហើយ តាំងអំពីដើម ។ អាបត្តាធិករណ៍ជារឿងដទៃ ក្នុងអាបត្តាធិករណនិទ្ទេសនោះ អាបត្តាធិករណ៍ជារឿងនោះ ( ដែលពោលទុក ) ខាងដើម អ្នកសិក្សាគប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។

[ ២៦៨ ] ក្នុងបទថា **កិច្ចាធិករណំ កិច្ចាធិករណស្ស តព្ភាគិយំ**

នេះ មានវិនិច្ឆ័យដូច្នេះថា អធិករណ៍ដែលអាស្រ័យសង្ឃកម្ម ៤ កើតឡើង តាំងអំពីសម័យពុទ្ធកាល និងអធិករណ៍ដែលអាស្រ័យសង្ឃកម្ម ៤ កើតឡើងក្នុងឥឡូវនេះ រមែងជាកិច្ចាធិករណ៍ដូចគ្នាពិត ព្រោះជាសភាគគ្នា និងព្រោះឃើញបានដូចគ្នា ។

សួរថា អធិករណ៍ដែលអាស្រ័យសង្ឃកម្មកើតឡើង ឈ្មោះថា កិច្ចា-ធិករណ៍ ឬមាតិកានោះ ជាឈ្មោះនៃសង្ឃកម្មទាំងឡាយប៉ុណ្ណោះ ឆ្លើយថា សេចក្ដីនោះ ជាឈ្មោះសង្ឃកម្មទាំងឡាយប៉ុណ្ណោះ ។ ទោះបីដូច្នេះ ព្រះមានព្រះភាគក៏ត្រាស់ហៅអធិករណ៍ ដែលអាស្រ័យសង្ឃកម្មកើតឡើងថា កិច្ចាធិករណ៍ ព្រោះអាស្រ័យកម្មលក្ខណៈដែលភិក្ខុដាក់ចិត្តដល់ ដែលត្រាស់ទុកថា ឈ្មោះថា សង្ឃកម្មនេះឯង គួរធ្វើយ៉ាងនេះ កើតឡើង និងព្រោះអាស្រ័យសង្ឃកម្មមុនៗ កើតឡើង ។

[ ២៦៩ ] ព្រោះពីរបទថា **លេសោ** ក្តី **លេសមត្តោ** ក្តី ដែលមាននៅក្នុងពាក្យថា **កិញ្ចិ ទេសំ លេសមត្តំ ឧបាទាយ** នេះ ផ្សេងគ្នាតែព្យញ្ជនៈ តែអត្ថដូចគ្នា ដោយន័យដូចពោលហើយពីមុននោះឯង ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **លេសោតិ ទស លេសា ជាតិលេសោ នាមលេសោ** ជាដើម ។ បណ្ដាលេស គឺជាតិជាដើមនោះ ជាតិនោះឯង ឈ្មោះថា លេស គឺជាតិ ។ ក្នុងលេសដ៏សេសក៏មានន័យដូច្នេះ ។

[ ២៧០ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែងលេសនោះឯងឲ្យពិស្ដារ សម្ដែងឲ្យឃើញព្រមទាំងវត្ថុ ដោយប្រការដែលទីងមានការ

អាងលេសនោះ តាមចោទ ទើបត្រាស់ពាក្យជាដើមថា **ជាតិលេសោ នាម ខត្តិយោ ទិដ្ឋោ ហោតិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ខត្តិយោ ទិដ្ឋោ ហោតិ** សេចក្តីថា បុគ្គលដទៃខ្លះ ជាខ្សែស្រឡាយក្សត្រ ដែលអ្នកចោទនេះឃើញហើយ ។

បទថា **ចារាជិកំ ធម្មំ អជ្ឈាបជ្ជន្តោ** បានដល់ ជាបុគ្គលត្រូវបណ្តាបារាជិក មានមេថុនធម្មជាដើមឯណានីមួយ ។

បទថា **អញ្ញំ ខត្តិយំ បស្សិត្វា ចោទេតិ** សេចក្តីថា ក្រោយមកដើមចោទនោះឃើញភិក្ខុមានជាតិជាក្សត្រដែលជាសត្រូវរបស់ខ្លួន ហើយកាន់យកលេស គឺជាតិក្សត្រនោះចោទយ៉ាងនេះថា ក្សត្រត្រូវធម៌ គឺបារាជិក ខ្ញុំបានឃើញហើយ លោកជាក្សត្រ ជាអ្នកត្រូវធម៌ គឺបារាជិក ។ម្យ៉ាងទៀត ចោទថា លោក គឺក្សត្រនោះ មិនមែនអ្នកដទៃជាអ្នកត្រូវធម៌ គឺបារាជិក លោកមិនមែនសមណៈ មិនមែនជាពូជពង្សនៃសក្យបុត្រ ឧបោសថកម្មក្តី បវារណាកម្មក្តី សង្ឃកម្មក្តី មិនមានជាមួយលោកទេ ត្រូវសង្ឃាទិសេសគ្រប់ៗ វាចា ។

ក្នុងបទថា **ខត្តិយោ មាយា ទិដ្ឋោ** ជាដើមនេះ អ្នកសិក្សាគប្បីជ្រាបភាពដែលក្សត្រទាំងនោះជាអ្នកមានចំណែកដទៃ ដោយអំណាចនៃក្សត្រដែលមិនដូចគ្នានិងគ្នានោះៗ មានកម្ពស់ដែលខ្លួនបានឃើញហើយជាដើម ហើយភាពដែលជាក្សត្រទាំងនោះជាអធិករណ៍ ដោយអំណាចនៃភាពជាអ្នកទទួលបញ្ញត្តិ គឺជាតិក្សត្រ ។ អ្នកសិក្សាគប្បីជ្រាបយោជនាក្នុងបទទាំងពួង ដោយ

ឧបាយនេះឯង ។

[ ២៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុង **បត្តលេសនិទ្ទេស** ដូច្នេះថា បាត្រដីស្អិត មានសណ្ឋានល្អ មានផ្ទៃរាបល្អ មានពណ៌ដូចស្លាបកំភេម ដូចគ្នានឹងបាត្រលោហៈ លោកហៅថា បាត្រសំពត់សាដក ។ បាត្រដីតាមប្រក្រតីលោកហៅថា បាត្រដី ក៏ព្រោះនិទ្ទេសនៃលេស គឺត្រាស់អាបត្តិទុកដោយសង្ខេប ដោយបទដូចគ្នាប៉ុណ្ណោះ ដូច្នោះ ដើម្បីសម្តែងលេស គឺអាបត្តិនោះដោយពិស្តារ ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា ខ្ញុំបានឃើញភិក្ខុត្រូវអាបត្តិសង្ឃាទិសេស ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគមិនត្រាស់និទ្ទេសនៃលេស គឺអាបត្តិនោះទុកក្នុងអធិការនៃលេស គឺអាបត្តិនោះតែម្តងទៅ តែត្រឡប់មកត្រាស់ទុកឯណោះ ក្នុងនិទ្ទេសនៃបទថា **សង្ឃាទិសេសោ** ទៅវិញ ឆ្លើយថា ព្រោះនិទ្ទេសនៃលេសមិនមានសភាគគ្នា ។

ពិតហើយ និទ្ទេសនៃលេសទាំងឡាយ ត្រាស់ទុកដោយអំណាចនៃការឃើញភិក្ខុអង្គដទៃ ហើយចោទភិក្ខុមួយអង្គទៀត ។ តែក្នុងនិទ្ទេសនៃលេស គឺអាបត្តិនេះ ត្រាស់ដោយអំណាចការឃើញភិក្ខុមួយអង្គនោះឯង ត្រូវអាបត្តិដទៃ ហើយចោទដោយអាបត្តិដទៃ ។

សួរថា បើដូច្នោះ អធិករណ៍មានចំណែកដទៃ នឹងមានដូចម្តេច ឆ្លើយថា មានព្រោះអាបត្តិ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា អធិករណ៍ជាចំណែកដទៃនៃអាបត្តិ និងលេសដែលចោទអាងហើយ ដោយ

អាការយ៉ាងនេះ ។ ពិតហើយ ភិក្ខុនោះត្រូវសង្ឃាទិសេសណា អធិករណ៍ គឺសង្ឃាទិសេសនោះ ជាអធិករណ៍មានចំណែកដទៃនៃបារាជិក ។ ឈ្មោះថា លេសនៃអធិករណ៍មានចំណែកដទៃនោះ គឺភាពជាអាបត្តិទូទៅដល់អាបត្តិទាំងពួង ដូចជាក្សត្រទូទៅដល់ក្សត្រទាំងពួង ដូច្នោះ ។ ន័យទាំងឡាយ មានអាបត្តិដ៏សេសជាមូល និងចោទាបកវារៈ អ្នកសិក្សាគប្បីជ្រាបដោយឧបាយនេះ ។

[ ២៨៩ ] បទថា **អនាបត្តិ តថាសញ្ញី ចោទេតិ វា ចោទាបេតិ វា** សេចក្តីថា ភិក្ខុណា មានការសម្គាល់យ៉ាងនេះថា បុគ្គលនេះ ត្រូវអាបត្តិបារាជិកនោះឯង ចោទឯងក្តី ឲ្យអ្នកដទៃចោទក្តី យ៉ាងនោះ មិនត្រូវអាបត្តិដល់ភិក្ខុនោះ ។ បទដ៏សេសទាំងអស់រាក់ហើយ ។

សមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមទុដ្ឋទោសសិក្ខាបទនោះឯង ។ — correction: សម្បីបកិណ្ណកៈ មានសមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមទុដ្ឋទោស-សិក្ខាបទនោះឯង ។

ទុតិយទុដ្ឋទោសសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ១០

[ ២៩០ ] សម័យនោះ ព្រះពុទ្ធដ៏ទ្រង់ជោគប្រថាប់នៅក្នុងអារាម វេឡុវ័ន ជាទីដែលស្តេចប្រទានចំណីដល់សត្វកង្ហែន ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះ ភិក្ខុឈ្មោះទេវទត្តបានចូលទៅរកភិក្ខុឈ្មោះកោកាលិក ភិក្ខុឈ្មោះកដមោរកតិស្សក ភិក្ខុឈ្មោះខណ្ឌទេវីបុត្ត និងភិក្ខុឈ្មោះសមុទ្ទទត្ត ហើយបាននិយាយពាក្យនេះនឹងភិក្ខុឈ្មោះកោកាលិក ភិក្ខុឈ្មោះកដមោរកតិស្សក ភិក្ខុឈ្មោះខណ្ឌទេវីបុត្ត និងភិក្ខុឈ្មោះសមុទ្ទទត្តថា ម្នាលអាវុសោ អ្នកទាំងឡាយចូរមក ពួកយើងនឹងធ្វើការបំបែកសង្ឃ នឹងទំលាយចក្រ[១] របស់ព្រះ-សមណគោតម ។ កាលទេវទត្តពោលយ៉ាងនេះហើយ ទើបភិក្ខុឈ្មោះកោកាលិកនិយាយពាក្យនេះនឹងទេវទត្តថា អាវុសោ ព្រះសមណគោតមមានឫទ្ធិច្រើន មានអានុភាពធំ ពួកយើងនឹងធ្វើការបំបែកសង្ឃនឹងទំលាយចក្ររបស់ព្រះសមណគោតមដូចម្តេចបាន ។ ទេវទត្តឆ្លើយថា ម្នាលអាវុសោ អ្នកទាំងឡាយចូរមក ពួកយើងនាំគ្នាចូលទៅគាល់ព្រះសមណគោតម ទូលសូមវត្ថុ ៥ ប្រការថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះដ៏មានព្រះភាគទ្រង់សរសើរគុណនៃបុគ្គលអ្នកប្រាថ្នាតិច ជាអ្នកសន្តោស ជុសខាត់ចិត្ត ទ្រទ្រង់ធុតង្គវត្ត ប្រកបដោយសេចក្តីជ្រះថ្លា មិនចម្រើនកិលេសវដ្ត ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ ៥ ប្រការ

---

១- បំបែកផ្លូវប្រតិបត្តិផ្សេងចាកធម្មវិន័យរបស់ព្រះសម្ពុទ្ធ ។

នេះប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសន្តោស ដើម្បីជុសខាត់ចិត្ត ដើម្បីធុតង្គវត្ត ដើម្បីសេចក្តីជ្រះថ្លា ដើម្បីមិនចម្រើនកិលេសវដ្ត ដើម្បីប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមទ្រង់ព្រះមេត្តាករុណាចុះ សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណានៅក្នុងស្រុកភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្តភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ ប្រើប្រាស់សំពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយគហបតីចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំង-ឡាយនៅទៀបគល់ឈើជាវត្តអស់មួយជីវិត ភិក្ខុណាទៅនៅក្នុងទីប្រក់ទីបាំងភិក្ខុនោះត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រីនិងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស បើយើងសូមយ៉ាងនេះ ព្រះសមណ-គោតមមុខជានឹងមិនអនុញ្ញាតឲ្យទេ ហើយពួកយើងឯងនឹងពន្យល់ជន ( ឲ្យត្រេកអរនឹងយើង ) ដោយវត្ថុ ៥ ប្រការទាំងនេះ ។ ទើបកោកាលិកភិក្ខុពោលថា ម្នាលអាវុសោ ពួកយើងអាចនឹងធ្វើការបំបែកសង្ឃ នឹងទម្លាយចក្ររបស់ព្រះសមណគោតម ដោយវត្ថុ ៥ ប្រការនេះបាន ព្រោះមនុស្សទាំងឡាយដែលជ្រះថ្លាក្នុងវត្ថុសៅហ្មង ( មានច្រើន ) អាវុសោ ។

[ ២៩១ ] គ្រានោះ ទេវទត្តភិក្ខុព្រមទាំងបរិសទ្យចូលទៅគាល់ព្រះដ៏មានព្រះភាគម្ចាស់ ហើយក្រាបថ្វាយបង្គំរួចអង្គុយក្នុងទីដ៏សមគួរ ។ លុះទេវទត្តភិក្ខុអង្គុយស្រួលបួលហើយ ក៏ក្រាបទូលពាក្យនេះ នឹងព្រះដ៏មានព្រះ

ភាគម្ចាស់ថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គដ៏ទ្រង់ជោគ ទ្រង់សរសើរគុណរបស់បុគ្គលប្រាថ្នាតិច ជាអ្នកសន្តោស ជុសខាត់ចិត្ត ទ្រទ្រង់ធុតង្គ មានសេចក្តីជ្រះថ្លា មិនចម្រើនកិលេសវដ្ត ប្រារព្ធសេចក្តីព្យាយាម ដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ ៥ ប្រការទាំងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច សន្តោស ជុសខាត់ចិត្ត កម្ចាត់ធម៌គ្រឿងសៅហ្មង ដើម្បីសេចក្តីជ្រះថ្លា មិនចម្រើនកិលេសវដ្ត ប្រារព្ធសេចក្តីព្យាយាម បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមទានទ្រង់ព្រះមេត្តាករុណាចុះ សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណាចូលមកកាន់ស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ កាន់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់សំពត់បង្សុកូលជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយគហបតីចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយ នៅទៀបគល់ឈើអស់មួយជីវិត ភិក្ខុណាចូលជ្រកទីប្រក់ទីបាំង ភិក្ខុនោះត្រូវទោស សូមកុំឲ្យភិក្ខុទាំងឡាយឆាន់ត្រី និងសាច់អស់មួយជីវិត ភិក្ខុណាឆាន់ត្រី និងសាច់ ភិក្ខុនោះត្រូវទោស ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា កុំទេវទត្ត ភិក្ខុណាចង់នៅព្រៃ ភិក្ខុនោះចូរនៅចុះ ភិក្ខុណាចង់នៅស្រុក ភិក្ខុនោះចូរនៅចុះ ភិក្ខុណាចង់ប្រព្រឹត្តបិណ្ឌបាតជាវត្ត ភិក្ខុនោះ ចូរប្រព្រឹត្តចុះ ភិក្ខុណាត្រូវការដោយកិច្ចនិមន្ត ភិក្ខុនោះ ចូរត្រេកអរចុះ ភិក្ខុណាចង់ប្រើប្រាស់សំពត់បង្សុកូលភិក្ខុនោះចូរប្រើប្រាស់ចុះ ភិក្ខុណាចង់បានគហបតិចីវរ ភិក្ខុនោះចូរត្រេកអរនូវចីវរនោះចុះ នែទេវទត្ត តថាគត

អនុញ្ញាតសេនាសនៈទៀបគល់ឈើអស់កាល ៨ ខែ អនុញ្ញាតត្រីសាច់ដែលបរិសុទ្ធដោយទីបំផុត ៣ ប្រការ គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស ( ឲ្យភិក្ខុទាំងឡាយឆាន់បាន ) ។

[ ២៩២ ] លំដាប់នោះ ទេវទត្តភិក្ខុព្រមទាំងបរិសទ្យត្រេកអររីករាយថា ព្រះដ៏មានព្រះភាគមិនព្រមអនុញ្ញាតវត្ថុ ៥ ប្រការនេះទេ ហើយក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណាចៀសចេញទៅ ។ ទើបទេវទត្តភិក្ខុព្រមទាំងបរិសទ្យចូលទៅក្រុងរាជគ្រឹះ ញុំាងជនឲ្យយល់ដោយវត្ថុ ៥ ប្រការហើយពោលថា អាវុសោទាំងឡាយ ពួកយើងបានចូលទៅគាល់ព្រះសមណគោតមហើយទូលសូមវត្ថុ ៥ ប្រការថា បពិត្រព្រះសម្ពុទ្ធជាម្ចាស់ ព្រះដ៏មានព្រះភាគ មានប្រក្រតីសរសើរគុណ របស់បុគ្គលអ្នកប្រាថ្នាតិច សន្តោស ជុសខាត់ចិត្ត កម្ចាត់ធម៌គ្រឿងសៅហ្មង មានសេចក្តីជ្រះថ្លា មិនចម្រើនកិលេសវដ្ត ប្រារព្ធសេចក្តីព្យាយាមដោយបរិយាយជាច្រើន បពិត្រព្រះសម្ពុទ្ធជាម្ចាស់ វត្ថុ ៥ ប្រការនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច ដើម្បីសេចក្តីសន្តោស ដើម្បីសេចក្តីប្រតិបត្តិដ៏ផូរផង់ ដើម្បីកម្ចាត់កិលេសធម៌ ដើម្បីសេចក្តីជ្រះថ្លា ដើម្បីមិនចម្រើនកិលេសវដ្ត ដើម្បីប្រារព្ធសេចក្តីព្យាយាម បពិត្រព្រះសម្ពុទ្ធជាម្ចាស់ សូមទ្រង់ព្រះមេត្តា សូមឲ្យភិក្ខុទាំងឡាយនៅតែក្នុងព្រៃជាវត្តអស់មួយជីវិត ភិក្ខុណាចូលមកកាន់ស្រុក ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយត្រាច់បិណ្ឌបាតជាវត្តអស់មួយជីវិត ភិក្ខុណាត្រេកអរដោយការនិមន្ត ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយប្រើប្រាស់សំពត់បង្សុកូល

ជាវត្ថុអស់មួយជីវិត ភិក្ខុណាត្រេកអរចំពោះគហបតីចីវរ ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយនៅក្បែរគល់ឈើជាវត្ថុអស់មួយជីវិត ភិក្ខុណាចូលជ្រក ទីប្រក់ទីបាំង ភិក្ខុនោះត្រូវទោស សូមឲ្យភិក្ខុទាំងឡាយកុំឆាន់ត្រីនិងសាច់អស់ មួយជីវិត ភិក្ខុណាឆាន់ត្រីនិងសាច់ ភិក្ខុនោះត្រូវទោស ព្រះសមណគោតម មិនទ្រង់អនុញ្ញាតវត្ថុ ៥ ប្រការនេះទេ តែពួកយើងទាំងនោះនាំគ្នាសមាទាន វត្ថុ ៥ នេះវិញ ។

[ ២៩៣ ] បណ្តាមនុស្សទាំងនោះ មនុស្សទាំងឡាយណាជាអ្នកឥត សទ្ធា មិនជ្រះថ្លា មានប្រាជ្ញាថោកថយ ទើបមនុស្សទាំងនោះពោលយ៉ាងនេះ ថា ពួកសមណៈទាំងនេះឯងជាកូនចៅព្រះពុទ្ធជាសក្យបុត្ត ជាអ្នកកម្ចាត់ កិលេសធម៌ ជាអ្នកប្រព្រឹត្តក្នុងធម៌ដ៏ផូរផង់ ចំណែកព្រះសមណគោតមជាអ្នក ប្រព្រឹត្តល្មោភដោយបច្ច័យមានចីវរបច្ច័យជាដើម តែងត្រិះរិះដោយបច្ច័យមាន ចីវរបច្ច័យជាដើមដ៏ច្រើន ។ ពួកមនុស្សណា ជាអ្នកមានសទ្ធាជ្រះថ្លា ជា បណ្ឌិតមានប្រាជ្ញា ពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ ថា ទេវទត្តភិក្ខុមិនគួរសោះនឹងខំប្រឹងទម្លាយសង្ឃ ទម្លាយចក្ររបស់ព្រះដ៏ មានព្រះភាគជាម្ចាស់ ។ ពួកភិក្ខុ បានឮពួកមនុស្សទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ ( ដូច្នោះ ) ។ ភិក្ខុទាំងឡាយឯណាជាអ្នកប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តភិក្ខុ មិនសមបីបើខំខ្នះខ្នែងដើម្បីទំលាយសង្ឃ ដើម្បីទំលាយចក្រសោះ ។ ទើប ភិក្ខុទាំងនោះ ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះ

ហេតុនេះ ដំណើរនេះ ព្រះដ៏ទ្រង់ជោគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ទេវទត្តក្នុងពេលនោះ ។បេ។ នែទេវទត្ត គេថា អ្នកឯងព្យាយាមទម្លាយសង្ឃ ទម្លាយចក្រ ពិតមែនឬ ។ ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគតិះដៀលថា នែមោឃបុរស មិនសមគួរសោះ ។បេ។ មោឃបុរស ហេតុម្តេចហ្ន៎បានជាអ្នកឯងខំព្យាយាមទម្លាយសង្ឃ ទម្លាយចក្រ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ ព្យាយាមដើម្បីទម្លាយសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នាហើយតាំងនៅ ភិក្ខុទាំងឡាយ ត្រូវពោល ( ហាម ) ភិក្ខុនោះដោយពាក្យយ៉ាងនេះថា លោកម្ចាស់កុំព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នាឡើយ ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នាហើយតាំងនៅ សូមលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះថាព្រះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ។ ភិក្ខុនោះ កាលភិក្ខុទាំងឡាយពោល ( ហាម ) យ៉ាងនេះហើយ នៅប្រកាន់លទ្ធិយ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ( ពោលប្រដៅហាមប្រាម ) ជាកំណត់បីដង ដើម្បីឲ្យលះបង់សង្ឃភេទកម្មនោះ ។ កាលបើភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ( ហាមប្រាម ) ជាគម្រប់បីដង

ហើយ ភិក្ខុនោះបានលះបង់សង្ឃភេទកម្មនោះចេញ ការលះបង់បាននេះជាការប្រពៃ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ២៩៤ ] ត្រង់ពាក្យថា ភិក្ខុណាមួយ មានអធិប្បាយពិស្តារក្នុងបារាជិកកណ្ឌសិក្ខាបទទី ១ រួចហើយ ។ សង្ឃដែលមានសំវាសស្មើគ្នា ស្ថិតនៅក្នុងសីមាជាមួយគ្នា ហៅថា ព្រមព្រៀងគ្នា ។ ពាក្យថា ព្យាយាមដើម្បីបំបែក គឺភិក្ខុស្វែងរកបក្ខពួកបង្កជាគណៈដោយចិត្តបំណងថា ធ្វើម្តេចឲ្យភិក្ខុពួកនេះនៅផ្សេងៗ គ្នា បែកគ្នាជាពួកជាកង ។ ពាក្យថា អធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នា គឺបានដល់រឿងដែលជាហេតុធ្វើឲ្យបែកគ្នា មាន ១៨[១] ប្រការ ។ ពាក្យថា ប្រកាន់ គឺកាន់យក ។ ពាក្យថា ផ្គងឡើង គឺសម្តែង ។ ពាក្យថា តាំងនៅ គឺមិនលះបង់ ។

[ ២៩៥ ] ពាក្យថា ភិក្ខុនោះ គឺភិក្ខុអ្នកបំបែកសង្ឃនោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយឯទៀត ( ក្រៅអំពីភិក្ខុដែលបំបែកសង្ឃនោះ ) ។ ភិក្ខុណាបានឃើញ ឬបានឮពួកភិក្ខុទាំងនោះ ត្រូវនិយាយនឹងភិក្ខុដែលបំបែកសង្ឃនោះថា លោកម្ចាស់កុំព្យាយាមដើម្បីបំបែកសង្ឃដែលព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈ ដែលដឹកនាំឲ្យសង្ឃបែកគ្នា សូមលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយត្រូវពោល ( ហាម ) ជាគម្រប់ពីរដងផង ត្រូវពោល ( ហាម )

---

១- មានក្នុងគម្ពីរចុល្លវគ្គត្រង់សង្ឃភេទក្ខន្ធក ។

ជាគម្រប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការល្អណាស់ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយបានឮ ហើយមិនពោល ( ហាម ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវតែភិក្ខុទាំងឡាយចាប់ទាញមកកាន់កណ្ដាលជំនុំសង្ឃ ហើយពោល ( ហាម ) ថា លោកម្ចាស់កុំព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ឬប្រកាន់ផ្គងឡើងនូវអធិករណៈដែលដឹកនាំឲ្យសង្ឃបែកគ្នាឡើយ សូមឲ្យលោកម្ចាស់ព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយត្រូវពោល ( ហាម ) ភិក្ខុជាអ្នកបំបែកសង្ឃនោះ ជាគម្រប់ពីរដងផង ត្រូវពោល ( ហាម ) ជាគម្រប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះ ជាការប្រពៃ បើមិនលះបង់ទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

[ ២៩៦ ] ភិក្ខុទាំងឡាយ គប្បីសូត្រសមនុភាសនកម្មដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសូត្រសមនុភាសនកម្មយ៉ាងនេះ គឺភិក្ខុដែលឆ្លៀវឆ្លាសអង់អាច គប្បីប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ បើកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុឈ្មោះនេះដើម្បីឲ្យលះបង់រឿងនោះ ។ នេះជាញត្តិ ( វាចាប្រកាសដល់សង្ឃ ) ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ

មានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ។ ភិក្ខុនោះ មិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុមានឈ្មោះនេះដើម្បីឲ្យលះបង់រឿងនោះ ។ ការសូត្រសមនុភាសនកម្មដល់ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកម្ចាស់អង្គណា សូមឲ្យលោកម្ចាស់អង្គនោះ ពោលឡើង ។ ខ្ញុំពោលសេចក្ដីនេះជាគម្រប់ពីរដងផង ។បេ។ ខ្ញុំពោល សេចក្ដីនេះជាគម្រប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចម្រើន ព្រះសង្ឃចូរស្ដាប់ពាក្យខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ ព្យាយាមដើម្បីបំបែកសង្ឃដ៏ព្រមព្រៀងគ្នា ។ ភិក្ខុនោះ មិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះចេញ ។ ការសូត្រប្រាប់ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ សមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវពោលឡើង ។ ភិក្ខុឈ្មោះនេះ ព្រះសង្ឃបានសូត្រសមនុភាសនកម្មហើយ ដើម្បីឲ្យលះបង់រឿងនោះ ។ សមនុភាសនកម្មនេះសមគួរដល់សង្ឃ ហេតុនោះព្រះសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវពាក្យនេះដោយកិរិយា ស្ងៀមនៅយ៉ាងនេះ ។

[ ២៩៧ ] ( កាលសង្ឃ ) សូត្រញត្តិចប់ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ ។ ( កាលសង្ឃ ) សូត្រកម្មវាចាពីរដង ( ភិក្ខុនោះ ) ត្រូវអាបត្តិថុល្លច្ច័យ ( កាលសង្ឃ ) សូត្រកម្មវាចាចប់ ( ភិក្ខុនោះ ) ត្រូវអាបត្តិ

សង្ឃាទិសេស ។ កាលបើភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដ ដែលភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះត្រូវ ក្នុងខណៈចប់កម្មវាចាជាគម្រប់ពីរជងក្តី ក៏តែងរម្ងាប់ទៅឯង ។ ពាក្យថា អាបត្តិសង្ឃាទិសេស មានអធិប្បាយក្នុងសិក្ខាបទទី ១ សង្ឃាទិសេសខាងដើមមកហើយ ។

[ ២៩៨ ] ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្ម ដែលសង្ឃធ្វើត្រូវតាមធម៌ ថាកម្មធ្វើត្រូវតាមធម៌ តែមិនលះបង់ ( សង្ឃភេទកម្មនោះ ) ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ តែមិនលះបង់ ( គឺនៅប្រកាន់ ) ភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ ថាកម្មមិនត្រូវតាមធម៌ មិនលះបង់ ភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើមិនត្រូវតាមធម៌ ថាកម្មធ្វើត្រូវតាមធម៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនមែនជាធម៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដដែល ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មមិនមែនជាធម៌ថា កម្មមិនមែនជាធម៌ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

[ ២៩៩ ] អាបត្តិមិនមានដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រប្រកាសហាម ដល់ភិក្ខុដែលបានលះបង់ ( សង្ឃភេទកម្ម ) ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

សង្ឃាទិសេសទី ១០ ចប់

# អដ្ឋកថា

## បឋមសង្ឃភេទសិក្ខាបទវណ្ណនា

[ ២៩០ ] *សង្ឃភេទសិក្ខាបទ បទថា* **តេន សមយេន ពុទ្ធោ ភគវា** *ជាដើម ខ្ញុំនឹងពោលក្នុងសង្ឃភេទសិក្ខាបទនោះ ដូចមានវិនិច្ឆ័យតទៅនេះ*

*ក្នុងបទថា* **អថខោ ទេវទត្តោ** *ជាដើមនេះ មានវិនិច្ឆ័យដូច្នេះថា រឿងភិក្ខុទេវទត្ត រឿងដែលទេវទត្តបួស និងហេតុដែលឈានទៅរកបក្ខពួក មានកោកាលិកភិក្ខុជាដើម ហើយពោលបបួលថា មកចុះអ្នកមានអាយុ ពួកយើងនឹងធ្វើសង្ឃភេទ ចក្កភេទដល់ព្រះសមណគោតម ដូច្នេះជាដើម ទាំងអស់មកហើយ ក្នុងសង្ឃភេទក្ខន្ធកៈនោះឯង ។*

*ចំណែកក្នុងរឿងសូមវត្ថុ ៥ ក៏មកក្នុងសង្ឃភេទក្ខន្ធកៈដូចគ្នា តែខ្ញុំនឹងពោលក្នុងរឿងសូមវត្ថុ ៥ នេះមុន ហើយនឹងរំលងទៅ ព្រោះរឿងមកក្នុងសង្ឃភេទសិក្ខាបទនេះក៏មាន ។ បទថា* **សាធុ ភន្តេ** *បានដល់ ការទូលសូមព្រះឱកាស ។ បទថា* **ភិក្ខូ យាវជីវំ អារញ្ញិកា អស្សុ** *សេចក្តីថា ភិក្ខុទាំងអស់សមាទានអារញ្ញិកធុតង្គហើយ ចូរជាអ្នកនៅព្រៃជាវត្ត គឺចូរនៅតែក្នុងព្រៃប៉ុណ្ណោះ ដរាបអស់ជីវិត ។*

*ដោយបទថា* **យោ គាមន្តំ ឱសរេយ្យ វជ្ជំ នំ ផុសេយ្យ** *ទេវទត្តពោលដោយបំណងថា ភិក្ខុណា គឺសូម្បីភិក្ខុមួយអង្គ លះព្រៃចូលកាន់ស្រុក ដើម្បីនឹងនៅ ទោសគប្បីត្រូវភិក្ខុនោះ គឺទោសចូរត្រូវភិក្ខុនោះ បានដល់ សូមព្រះមានព្រះភាគទ្រង់កាត់អាបត្តិភិក្ខុនោះ សូម្បីក្នុងវត្ថុដ៏សេស ក៏មានន័យនេះដូចគ្នា ។*

ពីរបទថា **ជនំ សញ្ញាបេស្សាម** សេចក្តីថា ពួកយើងនឹងញុំាងមហាជនឲ្យយល់ថា ពួកយើងជាអ្នកមានសេចក្តីប្រាថ្នាតិចជាដើម ។ ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ពួកយើងនឹងឲ្យមហាជនត្រេកអរពេញចិត្ត គឺនឹងឲ្យជ្រះថ្លា ។

[ ២៩១ ] ចំណែកព្រះមានព្រះភាគ លុះទ្រង់ស្តាប់ពាក្យរបស់ទេវទត្តទូលសូមវត្ថុ ៥ នេះប៉ុណ្ណោះ ទ្រង់ក៏ជ្រាបបានថា ទេវទត្តនេះ ត្រូវការដើម្បីបំបែកសង្ឃ ទើបសូម ។ ព្រោះវត្ថុ ៥ នោះ បើព្រះមានព្រះភាគ ទ្រង់អនុញ្ញាត រមែងប្រព្រឹត្តទៅដើម្បីអន្តរាយដល់មគ្គ របស់ពួកកុលបុត្រជាច្រើន ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់បដិសេធថា កុំឡើយ ទេវទត្ត ហើយត្រាស់ថា ភិក្ខុណា ប្រាថ្នា ភិក្ខុនោះ ចូរជាអ្នកនៅព្រៃចុះ ដូច្នេះជាដើម ។

ម្យ៉ាងទៀត ក្នុងបទថា **យោ ឥច្ឆតិ** ជាដើមនេះ កុលបុត្រគួរជ្រាបព្រះបំណងរបស់ព្រះមានព្រះភាគ ហើយជ្រាបការសមគួរដល់ខ្លួន ។ ពិតហើយ បំណងរបស់ព្រះមានព្រះភាគ ក្នុងបទថា **យោ ឥច្ឆតិ** ជាដើមនេះ ដូចតទៅនេះថា ភិក្ខុមួយអង្គ មានអធ្យាស្រ័យធំ មានឧស្សាហ៍ច្រើន រមែងអាចដើម្បីវៀរសេនាសនៈជិតស្រុកចេញហើយ នៅក្នុងព្រៃ ធ្វើទីបំផុតនៃទុក្ខបាន ។ ភិក្ខុមួយអង្គដែលមានកម្លាំងទុព្វល មានកម្លាំងតិច រមែងមិនអាចនៅក្នុងព្រៃ ( ធ្វើទីបំផុតទុក្ខ ) តែអាចនៅក្នុងគាមខេត្តប៉ុណ្ណោះ ។ ភិក្ខុមួយអង្គមានកម្លាំងច្រើន មានធាតុប្រព្រឹត្តទៅស្មើ សម្បូរអធិវាសនខន្តី មានចិត្តមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ រមែងអាចទាំងក្នុងព្រៃ ទាំងក្នុង

គាមខេត្តបានទាំងអស់ ។ ភិក្ខុអង្គខ្លះ មិនអាចទាំងក្នុងគាមខេត្ត ទាំងក្នុងព្រៃ គឺជាបទបរមបុគ្គល ។

បណ្ដាភិក្ខុទាំងនោះ ភិក្ខុណា មានអធ្យាស្រ័យធំ មានឧស្សាហ៍ច្រើន រមែងអាចដើម្បីវៀរសេនាសនៈក្នុងស្រុកចេញ ហើយនៅក្នុងព្រៃ ធ្វើទីបំផុតទុក្ខបាន ភិក្ខុរូបនោះ ចូរនៅក្នុងព្រៃប៉ុណ្ណោះចុះ ការនៅក្នុងព្រៃនេះ រមែងគួរដល់លោក ។ សូម្បីពួកសទ្ធិវិហារិករបស់លោក ជាអ្នកសិក្សាតាម នឹងសម្គាល់ការដែលខ្លួនគួរនៅក្នុងព្រៃផងដែរ ។ មួយវិញទៀត ភិក្ខុរូបណា មានកម្លាំងទុព្វល មានកម្លាំងតិច រមែងអាចធ្វើទីបំផុតទុក្ខបានក្នុងគាមខេត្តប៉ុណ្ណោះ ក្នុងព្រៃមិនអាចឡើយ ភិក្ខុនោះ ចូរនៅតែក្នុងគាមខេត្តនោះក៏បាន ។ ឯភិក្ខុណាដែលមានកម្លាំងរឹងប៉ឹង មានធាតុប្រព្រឹត្តទៅស្មើ សម្បូរដោយអធិវាសនខន្តី មានចិត្តមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ រមែងអាចទាំងក្នុងព្រៃ ទាំងក្នុងស្រុកនោះឯង ។ ភិក្ខុនេះចូរលះសេនាសនៈក្នុងស្រុក ហើយនៅក្នុងព្រៃចុះ ការនៅព្រៃនេះ សមគួរដល់លោក ។ សូម្បីពួកសទ្ធិវិហារិកជាដើមរបស់ពួកលោកដែលសិក្សាតាម នឹងសម្គាល់ការដែលខ្លួនគួរនៅក្នុងព្រៃបាន ។

ចំណែកភិក្ខុណា ដែលមិនអាចទាំងក្នុងស្រុក មិនអាចទាំងក្នុងព្រៃ ជាបទបរមបុគ្គល ភិក្ខុរូបនេះក៏ចូរនៅព្រៃនោះចុះ ព្រោះការសេពធុតង្គគុណ និងការបម្រើនកម្មដ្ឋាននេះរបស់លោក នឹងជាឧបនិស្ស័យដើម្បីមគ្គ និងផលតទៅ ( ក្នុងអនាគត ) ។ សូម្បីពួកសទ្ធិវិហារិកជាដើមរបស់លោក កាលសិក្សាតាម នឹងសម្គាល់កាលដែលខ្លួនគួរនៅព្រៃ ដូច្នេះឯង ។ ភិក្ខុណា ដែលជា

អ្នកមានកម្លាំងទុព្វល មានកម្លាំងតិចតួចយ៉ាងនេះ កាលនៅស្រុកប៉ុណ្ណោះ ទើបអាចធ្វើទីបំផុតទុក្ខបាន ក្នុងព្រៃមិនអាចឡើយ ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់បុគ្គលដូច្នេះ ទើបត្រាស់ថា **យោ ឥច្ឆតិ គាមន្តេ វិហរតុ** ( ភិក្ខុណាប្រាថ្នា ភិក្ខុនោះ ចូរនៅក្នុងស្រុកចុះ ) ដូច្នេះ ហើយបុគ្គលនេះ បានឲ្យឱកាសដល់ជនដទៃ ។

បើព្រះមានព្រះភាគទ្រង់គប្បីទទួលពាក្យរបស់ទេវទត្តសោត បុគ្គលនេះដែលមានកម្លាំងទុព្វល មានកម្លាំងតិចតាមប្រក្រតី សូម្បីបុគ្គលណាអាចនៅក្នុងព្រៃ សម្រេចបានតែក្នុងវេលាដែលនៅជាកំលោះ តមកក្នុងវេលាដែលខូនចាស់ ឬក្នុងវេលាជាតុកម្រើក ព្រោះខ្យល់ និងប្រមាត់ជាដើម នៅក្នុងព្រៃមិនសម្រេច តែកាលនៅក្នុងស្រុកប៉ុណ្ណោះ ទើបអាចធ្វើទីបំផុតទុក្ខបាន ។ បុគ្គលទាំងនោះ គប្បីសូន្យបង់នូវអរិយមគ្គទៅ មិនគប្បីសម្រេចអរហត្តផលបាន សត្ថុសាសនៈ គប្បីក្លាយជាក្រៅធម៌ ក្រៅវិន័យ ស្មុគស្មាញ មិនប្រព្រឹត្តទៅដើម្បីនាំចេញចាកទុក្ខ ហើយព្រះសាស្តា គប្បីជាបុគ្គលមិនមែនជាព្រះ-សព្វញ្ញូរបស់បុគ្គលជំពូកនោះ ទាំងគប្បីត្រូវពាក្យតិះដៀលថា ទ្រង់លះបង់វាទៈរបស់ព្រះអង្គចោល ទៅតាំងនៅក្នុងវាទៈរបស់ទេវទត្ត ដូច្នេះ ។

ព្រោះដូច្នោះ កាលព្រះដ៏មានព្រះភាគ ទ្រង់អនុគ្រោះបុគ្គលទាំងឡាយ ទើបទ្រង់បដិសេធវាទៈរបស់ទេវទត្តភិក្ខុ ។ ក្នុងរឿងនៃភិក្ខុដែលកាន់បិណ្ឌបាតជាវត្តក្តី ក្នុងរឿងនៃភិក្ខុដែលកាន់យកសំពត់បង្សុកូលជាវត្តក្តី ក្នុងរឿងនៃភិក្ខុដែលកាន់ការនៅគល់ឈើជាវត្តអស់ ៨ ខែក្តី គប្បីជ្រាបវិនិច្ឆ័យដោយឧបាយ

នោះឯង ។ តែព្រះមានព្រះភាគទ្រង់ហាមសេនាសនៈគល់ឈើ ៤ ខែ ( រដូវភ្លៀងប៉ុណ្ណោះ ) ។

## ត្រីសាច់បរិសុទ្ធដោយចំណែក ៣ យ៉ាង

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងត្រី និងសាច់ ដូច្នេះ បទថា **តិកោដិ-បរិសុទ្ធំ** បានដល់ បរិសុទ្ធដោយចំណែក ៣ អធិប្បាយថា វៀរចាកទីមិនបរិសុទ្ធ មានការឃើញជាដើម ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មិនបានឃើញ មិនបានឮ មិនបានរង្កៀស ។

បណ្ដាមំសៈ ៣ យ៉ាងនោះ មំសៈដែលឈ្មោះថា មិនបានឃើញ គឺឃើញអ្នកស្រុកសម្លាប់ម្រឹគ និងត្រី យកមកដើម្បីប្រយោជន៍ដល់ពួកភិក្ខុ ។ ដែលឈ្មោះថា មិនបានឮ គឺមិនបានឮថា ពួកអ្នកស្រុកសម្លាប់ម្រឹគ ត្រី យកមកដើម្បីជាប្រយោជន៍ដល់ពួកភិក្ខុ ចំណែកមិនបានរង្កៀស អ្នកសិក្សាគួរស្គាល់សាច់ដែលរង្កៀសដោយការឃើញ រង្កៀសដោយការឮ និងរង្កៀសផុតចាកហេតុទាំង ២ នោះ ហើយគប្បីជ្រាបដោយចំណែកផ្ទុយគ្នាអំពី ៣ យ៉ាងនោះ ។

សេចក្ដីនេះដូចម្ដេច គឺពួកភិក្ខុក្នុងធម្មវិន័យនេះ ឃើញពួកអ្នកស្រុកកាន់សំណាញ់ និងអន្ទាក់ជាដើម កំពុងចេញទៅអំពីស្រុក ឬកំពុងត្រាច់ទៅក្នុងព្រៃ ។ ក្នុងថ្ងៃស្អែកឡើង ពួកអ្នកស្រុកនាំបិណ្ឌបាត មានត្រី និងសាច់ជាដើមមកប្រគេនដល់ភិក្ខុទាំងនោះ ដែលចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ភិក្ខុទាំងនោះ រង្កៀសដោយការបានឃើញនោះថា ពួកអ្នកស្រុកធ្វើម្រឹគដើម្បី

ប្រយោជន៍ដល់ពួកភិក្ខុឬហ្ន៎ សាច់នេះ ឈ្មោះថា រង្កៀសដោយបានឃើញ ភិក្ខុទទួលសាច់ដូច្នោះ មិនគួរ ។ មំសៈដែលមិនបានរង្កៀស ដូច្នោះ បើទទួល គួរ ។ បើពួកអ្នកស្រុកទាំងនោះសួរថា ហេតុអ្វី ទើបលោកម្ចាស់មិនទទួល បានស្ដាប់សេចក្ដីនោះហើយ ពោលថា សាច់នេះ ពួកខ្ញុំមិនបានធ្វើដើម្បី ប្រយោជន៍ដល់ភិក្ខុទាំងឡាយទេ ពួកខ្ញុំធ្វើដើម្បីជាប្រយោជន៍ដល់ខ្លួនឯងខ្លះ ដើម្បីជាប្រយោជន៍ដល់ពួករាជការជាដើមខ្លះ ដូច្នេះ សាច់នោះ គួរ ។

ភិក្ខុទាំងឡាយ មិនបានឃើញឡើយ តែបានឮថា ពួកអ្នកស្រុកមានដៃ កាន់សំណាញ់ និងអន្ទាក់ចេញពីស្រុកក្ដី ត្រាច់ទៅក្នុងព្រៃក្ដី ក្នុងថ្ងៃស្អែក ឡើង ភិក្ខុចូលទៅកាន់ស្រុកនោះដើម្បីបិណ្ឌបាត ពួកអ្នកស្រុកនាំបិណ្ឌបាត មានត្រី និងសាច់មកប្រគេនដល់ភិក្ខុទាំងនោះ ។ ពួកភិក្ខុសង្ស័យដោយការ បានឮនោះថា អ្នកស្រុកធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ឬយ៉ាងណាហ្ន៎ សាច់នេះ ឈ្មោះថា រង្កៀសដោយបានឮ បើទទួលសាច់នោះ មិនគួរ ។ សាច់ដែលមិនបានសង្ស័យយ៉ាងនេះ បើទទួល គួរ ។ បើអ្នកស្រុកទាំងនោះ សួរថា ហេតុអ្វី ទើបលោកម្ចាស់មិនទទួល បានស្ដាប់សេចក្ដីនោះហើយ ទើប ពោលថា សាច់នេះ ពួកខ្ញុំមិនបានធ្វើដល់ភិក្ខុទាំងឡាយទេ ពួកខ្ញុំធ្វើដើម្បីជា ប្រយោជន៍ដល់ខ្លួនឯងខ្លះ ដើម្បីប្រយោជន៍ដល់ពួករាជការខ្លះ ដូច្នេះ សាច់ នោះ គួរ ។

ម្យ៉ាងទៀត ភិក្ខុទាំងឡាយមិនបានឃើញ មិនបានឮឡើយ តែកាលពួក ភិក្ខុទាំងនោះចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត អ្នកស្រុកទទួលបាត្រ ទៅហើយ

រៀបចំបិណ្ឌបាត មានត្រី សាច់ នាំមកប្រគេន ពួកភិក្ខុវៀរវៀស សាច់នេះគេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ឬក៏យ៉ាងណាហ្ន៎ នេះឈ្មោះថា សាច់ដែលវៀរវៀសផុតចាកហេតុទាំង ២ នោះ ។ សូម្បីសាច់ដូច្នោះ ក៏មិនគួរទទួល ។ សាច់ដែលមិនបានវៀរវៀសយ៉ាងនោះ ទោះទទួលក៏គួរ ។ បើពួកអ្នកស្រុកទាំងនោះសួរថា ហេតុអ្វី ទើបពួកលោកម្ចាស់មិនទទួល ហើយបានស្តាប់សេចក្តីនោះ ទើបនិយាយថា ពួកខ្ញុំមិនបានធ្វើដើម្បីជាប្រយោជន៍ដល់ភិក្ខុទាំងឡាយឡើយ ពួកខ្ញុំធ្វើដើម្បីជាប្រយោជន៍ដល់ខ្លួនខ្លះ ដើម្បីជាប្រយោជន៍ដល់ពួករាជការជាដើមខ្លះក្តី ពួកខ្ញុំបានបវត្តមំសៈចំពោះទីជាកប្បិយៈប៉ុណ្ណោះ ទើបផ្សំឲ្យសម្រេចដើម្បីជាប្រយោជន៍ដល់ភិក្ខុទាំងឡាយក្តី សាច់នោះ គួរ ។ សូម្បីសាច់ដែលគេធ្វើដើម្បីជាប្រយោជន៍ដល់បេតកិច្ចក្តី ដល់អ្នកស្លាប់ទៅហើយក្តី ដើម្បីជាប្រយោជន៍ដល់ការរោងមង្គលជាដើមក្តី ក៏មានន័យយ៉ាងនេះដូចគ្នា ។ ពិតហើយ សាច់ប្រភេទណាក៏ដោយ ដែលគេមិនបានធ្វើដើម្បីភិក្ខុទាំងឡាយ ហើយភិក្ខុក៏មិនមានការសង្ស័យក្នុងសាច់ណាទីមួយ សាច់នោះ គួរទាំងអស់ ។

បើសាច់ដែលគេធ្វើឧទ្ទិសចំពោះពួកភិក្ខុក្នុងវិហារមួយ ហើយពួកភិក្ខុមិនជ្រាបថា គេធ្វើដើម្បីប្រយោជន៍ខ្លួន តែភិក្ខុពួកដទៃដឹង ពួកភិក្ខុណាដឹង មិនគួរដល់ពួកភិក្ខុនោះ ពួកដទៃមិនដឹង តែពួកភិក្ខុនោះប៉ុណ្ណោះដឹង រមែងមិនគួរចំពោះពួកភិក្ខុនោះ តែគួរសម្រាប់ពួកភិក្ខុដទៃ ។ ពួកភិក្ខុដឹងថា អ្នកស្រុកធ្វើដើម្បីប្រយោជន៍ដល់ពួកលោក ហើយភិក្ខុពួកដទៃក៏ដឹងថា គេធ្វើដើម្បីប្រយោជន៍ដល់ភិក្ខុពួកនេះ មិនគួរដល់ពួកលោកទាំងអស់គ្នា ។ ពួកភិក្ខុទាំង

អស់ មិនដឹង រមែងគួរដល់ពួកលោកទាំងអស់ ។ បណ្ដាសហធម្មិកទាំង ៥ សាច់ដែលគេធ្វើឧទ្ទិសចំពោះដើម្បីជាប្រយោជន៍ ដល់សហធម្មិកអង្គណាទីមួយក៏ដោយ រមែងមិនគួរដល់សហធម្មិកទាំងអស់នោះ ។

សួរថា បើមានបុគ្គលសម្លាប់សត្វឧទ្ទិសភិក្ខុមួយរូប ដាក់ក្នុងបាត្រឲ្យពេញ ហើយប្រគេនដល់ភិក្ខុអង្គនោះ ហើយភិក្ខុដឹងដែរថា សាច់គេធ្វើដើម្បីខ្លួន ទទួលទៅហើយប្រគេនដល់ភិក្ខុអង្គដទៃ ភិក្ខុអង្គដទៃនោះ ឆាន់ដោយជឿភិក្ខុនោះ នរណាត្រូវអាបត្តិ ឆ្លើយថា មិនត្រូវអាបត្តិទាំងពីរអង្គ ។ ព្រោះថាសាច់ដែលគេធ្វើចំពោះភិក្ខុណា មិនត្រូវអាបត្តិដល់ភិក្ខុនោះ ព្រោះលោកមិនបានឆាន់ ហើយមិនត្រូវអាបត្តិដល់ភិក្ខុក្រៅអំពីនេះ ព្រោះលោកមិនដឹង ។ ពិតហើយ ក្នុងការទទួលកប្បិយមំសៈ មិនត្រូវអាបត្តិ ។ តែភិក្ខុមិនដឹងឆាន់សាច់ដែលគេធ្វើចំពោះ ខាងក្រោយទើបដឹង កិច្ចដោយការសម្ដែងអាបត្តិមិនមាន ។ ចំណែកភិក្ខុមិនដឹង ឆាន់អកប្បិយមំសៈ សូម្បីក្រោយមកទើបដឹង គប្បីសម្ដែងអាបត្តិ ។ ពិតហើយ ត្រូវអាបត្តិដល់ភិក្ខុដែលដឹង ហើយឆាន់សាច់ដែលគេធ្វើចំពោះ ។ ត្រូវអាបត្តិដូចគ្នា ដល់ភិក្ខុដែលមិនដឹង ឆាន់អកប្បិយមំសៈ ។ ព្រោះហេតុនោះ ភិក្ខុខ្លាចចំពោះអាបត្តិ កាលកំណត់រូបការណ៍ គប្បីសួរជាមុន សឹមទទួលសាច់ដែលគេប្រគេន និងទទួលប្រគេនដោយតាំងចិត្តថា ក្នុងវេលាឆាន់ អញនឹងសួរហើយ ទើបឆាន់ គួរសួរជាមុនហើយ សឹមឆាន់ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសាច់ដឹងបានលំបាក ។ សេចក្ដី

ពិត សាច់ខ្លាឃ្មុំ ដូចគ្នានឹងសាច់ជ្រូក សាច់ខ្លាដំបងជាដើម ក៏ដូចគ្នានឹងសាច់ម្រឹគជាដើម ព្រោះហេតុនោះ ទើបអាចារ្យទាំងឡាយពោលថា ការសួរហើយសឹមទទួលប្រគេននោះឯង ជាទំនៀម ។

## អធិប្បាយ ខណៈនៅឧត្តរទូលសូមវត្ថុ ៥

[ ២៩២ ] ពីរបទថា **ហដ្ឋោ ឧទគ្គោ** បានដល់ ជាអ្នកត្រេកអរហើយ មានកាយ និងចិត្តផុសឡើងហើយ ។

បានឮថា ទេវទត្តគិតថា ព្រះមានព្រះភាគទ្រង់មិនអនុញ្ញាតវត្ថុ ៥ នេះ ឥឡូវនេះ អញនឹងអាចដើម្បីធ្វើសង្ឃភេទ ដូច្នេះ ទើបសម្តែងអាការលោតកញ្ឆេងដល់កោកាលិកភិក្ខុ មិនដឹងថា ទុក្ខដែលខ្លួនគប្បីសោយក្នុងអវិចីខិតជិតចូលមក ព្រោះសង្ឃភេទជាបច្ច័យ រីករាយសប្បាយចិត្តថា ឥឡូវនេះ យើងបានឧបាយដើម្បីបំបែកសង្ឃ ប្រៀបដូចបុរសដែលបំណងនឹងបរិភោគថ្នាំពិសក្តី បំណងនឹងយកខ្សែមកចងកក្តី បំណងយកសស្ត្រាមកសម្លាប់ខ្លួនឲ្យស្លាប់ក្តី បានវត្ថុឯណាមួយ មានថ្នាំពុលជាដើម មិនស្គាល់ទុក្ខ គឺការស្លាប់ដែលខិតជិតចូលមក ព្រោះការបរិភោគថ្នាំពិសជាដើមនោះជាបច្ច័យ ជាអ្នករីករាយ សប្បាយចិត្ត ដូច្នោះ ទើបព្រមដោយបរិស័ទ ក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះមានព្រះភាគ ដោយភាពជាអ្នកត្រេកអរនោះឯង បានធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។

ក្នុងបទថា **តេ មយំ ឥមេហិ បញ្ចហិ វត្ថូហិ សមាទាយ វត្តាម** នេះ កាលទេវទត្តពោលបទថា **ឥមានិ បញ្ច វត្ថូនិ** ដូច្នេះ មិនទាន់បាន

សង្កេតការខុសក្លាំងក្លាត់នៃវិកត្តិ ដោយអំណាចនៃវិតក្ករឿយៗ ថា **តេ មយំ ឥមេហិ បញ្ចហិ វត្ថូហិ ជនំ សញ្ញាបេស្សាម** ( ពួកយើងនឹងញុំាងមហាជនឲ្យត្រេកអរដោយវត្ថុទាំង ៥ នេះ ) ដូច្នេះ ទើបពោលតាមគួរដល់ការរំពឹងរឿយៗ នោះឯងថា **តេ មយំ ឥមេហិ បញ្ចហិ វត្ថូហិ ...** ( ពួកយើងនឹងសមាទាន ប្រព្រឹត្តដោយវត្ថុទាំង ៥ នេះ ) ដូចគ្នានឹងបុគ្គលមានចិត្តរាយមាយ ដូច្នោះឯង ។

[ ២៩៣ ] ពីរបទថា **ធុតា សល្លេខវុត្តិនោ** សេចក្តីថា បុគ្គលឈ្មោះថា **ធុត** ព្រោះជាបុគ្គលប្រកបដោយបដិបទា ដែលកម្ចាត់បង់នូវកិលេស បុគ្គលឈ្មោះថា មានការជុសខាត់កិលេស ព្រោះភិក្ខុទាំងនេះ មានការប្រព្រឹត្តជុសខាត់កិលេសទាំងឡាយ ។

បទថា **ពាហុល្លិកោ** សេចក្តីថា ភាវៈដែលបច្ច័យ ៤ មានចីវរជាដើមមានច្រើន ឈ្មោះថា **ពាហុល្ល** ។ ភាវៈដែលបច្ច័យ ៤ មានច្រើន មានដល់ព្រះគោតមនោះ ឈ្មោះថា **ពាហុល្លិក** ។ ម្យ៉ាងទៀត ព្រះគោតមនោះជាអ្នកប្រកប គឺតាំងនៅក្នុងភាពជាអ្នកមានបច្ច័យច្រើននោះ ហេតុនោះ ទើបឈ្មោះថា **ពាហុល្លិក** ( ភាពជាអ្នកប្រាថ្នាច្រើន ) ។

ពីរបទថា **ពាហុល្លាយ ចេតេតិ** សេចក្តីថា រមែងគិត រមែងត្រិះរិះ រមែងសញ្ចឹងគិត ដើម្បីបានបច្ច័យច្រើន ។ អធិប្បាយថា បុគ្គលដល់នូវការខ្វល់ខ្វាយយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ភាពជាអ្នកមានបច្ច័យ មានចីវរជាដើមច្រើន នឹងគប្បីមានដល់តថាគត និងសាវករបស់តថាគត ។

ច្រើនបទថា **ធម្មឹ កថំ កត្វា** សេចក្តីថា ទ្រង់ធ្វើធម្មីកថាដែលសមគួរក្នុងខណៈនោះ គឺសមរម្យក្នុងខណៈនោះ ដល់ទេវទត្ត និងដល់ភិក្ខុទាំងឡាយជាអនេកប្រការ ដោយន័យដែលត្រាស់ទុកក្នុងខន្ធកៈ មានជាដើមយ៉ាងនេះថា កុំឡើយទេវទត្ត ការបំបែកសង្ឃ កុំជាទីពេញចិត្តដល់អ្នកឡើយ ម្នាលទេវទត្ត ការបំបែកសង្ឃមានទោសធ្ងន់ ដូច្នេះ ។ ម្នាលទេវទត្ត បុគ្គលណាបំបែកសង្ឃដែលព្រមព្រៀងគ្នា បុគ្គលនោះនឹងជួបប្រទះនូវកម្មដ៏គ្រោតគ្រាត តាំងនៅអស់កប្ប ម្នាលទេវទត្ត ចំណែកបុគ្គលណា ធ្វើសង្ឃដែលបែកគ្នាហើយឲ្យរួបរួមគ្នា បុគ្គលនោះ រមែងជួបនូវបុណ្យដ៏ប្រសើរ រីករាយក្នុងស្ថានសួគ៌អស់កប្ប ដូច្នេះ ។

# អធិប្បាយ

# សិក្ខាបទវិភង្គនៃបឋមសង្ឃភេទសិក្ខាបទ

[ ២៩៤ ] បទថា **សមគ្គស្ស** បានដល់ អ្នករួមគ្នា អធិប្បាយថា ដែលមិនបែកគ្នា ផ្លូវចិត្ត និងកាយ ។ ពិតហើយ សូម្បីក្នុងបទភាជនីយ៍ព្រះមានព្រះភាគ ក៏ទ្រង់បានសម្តែងអត្ថយ៉ាងនេះដូចគ្នា ។

ពិតហើយ ព្រះមានព្រះភាគ កាលត្រាស់ថា **សមានសំវាសកោ** រមែងជាអ្នកដែលទ្រង់សម្តែងការមិនបែកគ្នាផ្លូវចិត្ត ។

កាលត្រាស់ថា **សមានសីមាយំ ឋិតោ** គឺទ្រង់សម្តែងការមិនបែកគ្នាតាមផ្លូវកាយ ។ សេចក្តីនេះដូចម្តេច គឺភិក្ខុដែលមានសង្វាសស្មើគ្នា វៀរចាកបុគ្គលមានសង្វាសផ្សេងគ្នាដោយលទ្ធិ ឬដែលមានសង្វាសផ្សេងគ្នាដោយ

កម្ម ឈ្មោះថា ជាអ្នកមិនបែកគ្នាតាមផ្លូវចិត្ត ព្រោះមានចិត្តស្មើគ្នា បុគ្គលតាំងនៅក្នុងសីមាស្មើគ្នា ឈ្មោះថា ជាបុគ្គលមិនបែកគ្នាផ្លូវកាយ ព្រោះដោយកាយសាមគ្គី ។

ពីរបទថា **ភេទនសំវត្តនិកំ វា អធិករណំ** បានដល់ ហេតុដែលប្រព្រឹត្តទៅដើម្បីបែកបាក់គ្នា គឺដើម្បីបំបែកសង្ឃ ។

ពិតហើយ ក្នុងឱកាសនេះ ហេតុលោកបំណងយកថា អធិករណ៍ ដូចក្នុងប្រយោគថា **កាមហេតុ កាមនិទានំ កាមាធិករណំ** ប្រែថា មានកាមជាហេតុ មានកាមជានិទាន មានកាមជាមូលហេតុ ។ ព្រោះអធិករណ៍នោះមាន ១៨ ប្រការដូច្នោះ ទើបក្នុងបទភាជនីយ៍ ព្រះមានព្រះភាគត្រាស់ថា ភេទករវត្ថុមាន ១៨ យ៉ាង ។ ឯភេទករវត្ថុទាំងនោះ មកហើយក្នុងខន្ធកៈដោយន័យជាដើមថា ម្នាលឧបាលិ ភិក្ខុក្នុងធម្មវិន័យនេះ រមែងសម្តែងអធម៌ថា ធម៌ ដូច្នេះ ព្រោះហេតុនោះ ខ្ញុំនឹងពណ៌នាអត្ថនៃភេទករវត្ថុទាំងនោះក្នុងសង្ឃភេទក្ខន្ធកៈនោះឯង ។ ម្យ៉ាងទៀត សង្ឃភេទនេះអាស្រ័យវត្ថុទាំងនេះរមែងមានដោយហេតុដទៃទៀត ៥ ប្រការ គឺដោយកម្ម ១ ដោយឧទ្ទេស ១ ដោយវោហារ ១ ដោយអនុសាវនា ១ ដោយការចាប់ស្លាក ១ ខ្ញុំនឹងប្រកាសសង្ឃភេទនោះ ក្នុងអគតដ្ឋាននោះឯង ។ តែដោយសង្ខេប ក្នុងពាក្យថា កាន់យកអធិករណ៍ដែលប្រព្រឹត្តទៅដើម្បីការបែកគ្នានេះ អ្នកសិក្សាគប្បីជ្រាបអត្ថយ៉ាងនេះថា កាន់យកហេតុដែលប្រព្រឹត្តទៅដើម្បីបំបែកសង្ឃ គឺដែលអាចឲ្យសម្រេចក្នុងការទម្លាយសង្ឃបាន ។

*បទថា* **បគ្គយ្ហ** *បានដល់ ផ្គង គឺលើកឡើងធ្វើឲ្យប្រាកដ ។ បទថា* **តិដ្ឋេយ្យ** *សេចក្ដីថា បញ្ឈាក់ឲ្យដូចដែលខ្ញុំនកាន់យកហើយ គឺដែលដូចខ្ញុំន លើកឡើងហើយនោះឯង ។ ព្រោះអធិករណ៍នោះ គឺភិក្ខុដែលផ្គង និងលើក ឡើងយ៉ាងនោះសម្ដែងហើយ និងមិនលះបង់ ដូច្នោះ ទើបក្នុង បទភាជនីយ៍ ព្រះមានព្រះភាគត្រាស់ថា គប្បីសម្ដែង នឹងមិនគប្បីលះបង់ ដូច្នេះ ។*

[ ២៩៥ ] *បទថា* **ភិក្ខូហិ ឯវមស្ស វចនីយោ** *សេចក្ដីថា ភិក្ខុនោះ ជាបុគ្គល ដែលពួកលជ្ជីភិក្ខុដទៃ គប្បីពោលយ៉ាងនេះ ។*

*ក្នុងបទភាជនីយ៍នៃបទថា* **ភិក្ខូហិ** *នោះ មានវិនិច្ឆ័យដូច្នេះ ពាក្យថា* **យេ បស្សន្តិ** *សេចក្ដីថា ភិក្ខុណាឃើញភិក្ខុនោះកំពុងនិយាយ ( បំបែកសង្ឃ ) នៅចំពោះមុខ ។ បទថា* **យេ សុណន្តិ** *សេចក្ដីថា ភិក្ខុពួកណា បានឮថា ពួកភិក្ខុក្នុងវិហារឈ្មោះនោះ កាន់យកអធិករណ៍ ដែលប្រព្រឹត្តទៅដើម្បីការ បែកគ្នា កំពុងពោល ។*

*បទថា* **សមេតាយស្មា សង្ឃេន** *សេចក្ដីថា លោកដ៏មានអាយុ សូម លោករួបរួម សូមសមាគម សូមជាអ្នកមានលទ្ធិតែមួយក្នុងសង្ឃចុះ ។*

*សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា សង្ឃដែលព្រមព្រៀងគ្នា ត្រូវរ៉ូវគ្នា មិនវិវាទគ្នា មានឧទ្ទេសដូចគ្នា រមែងនៅជាផាសុក ។*

*បណ្ដាបទទាំងនោះ បទថា* **សម្មោទមានោ** *សេចក្ដីថា រីករាយដោយ ល្អ ដោយសម្បត្តិ ( មានសីលជាដើម ) នៃគ្នានឹងគ្នា ។*

*បទថា* **អវិវទមានោ** *សេចក្ដីថា មិនវិវាទគ្នាយ៉ាងនេះថា នេះធម៌ នេះ*

មិនមែនធម៌ ។ សង្ឃនោះ មានឧទ្ទេសតែមួយ ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកុទ្ទេស** អធិប្បាយថា មានបាតិមោក្ខុទ្ទេសប្រព្រឹត្តទៅរួមគ្នា មិនបែកគ្នា ។ ពីរបទថា **ផាសុវិហរតិ** បានដល់ រមែងនៅជាសុខ ។

បទថា **ឥច្ចេតំ កុសលំ** សេចក្តីថា ការលះបង់បាននោះ ជាកុសល គឺផុតចាកភ័យ បានដល់ មានសុវត្ថិភាពដល់ភិក្ខុនោះ ។ បទថា **នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស** បានដល់ ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលសង្ឃសូធ្យ ៣ ដង ហើយមិនលះបង់ ។

បទថា **សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស** សេចក្តីថា ត្រូវអាបត្តិទុក្កដដល់ពួកភិក្ខុដែលបានឮហើយ មិនពោលហាម ។ ក្នុងទីចម្ងាយប៉ុនណាទើបត្រូវអាបត្តិទុក្កដដល់ពួកភិក្ខុដែលបានឮហើយ មិនហាម ឆ្លើយថា ក្នុងវិហារជាមួយគ្នា មិនចាំបាច់ពោលឡើយ ។ ឯក្នុងអដ្ឋកថា ពោលថា ក្នុងរយៈផ្លូវកន្លះយោជន៍ដោយជុំវិញ ចាត់ជាភារៈរបស់ភិក្ខុទាំងឡាយនោះ ។ ការផុតរួចចាកអាបត្តិ រមែងមិនមានដល់ភិក្ខុដែលបញ្ជូនទូត ឬសំបុត្រទៅប្រាប់ ។ គប្បីទៅហាមឯងនោះឯងថា លោកដ៏មានអាយុ ការទម្លាយសង្ឃជាទោសធ្ងន់ លោកកុំព្យាយាមដើម្បីបំបែកសង្ឃឡើយ ។ តែភិក្ខុដែលអាចសូម្បីនៅឆ្ងាយក៏គួរទៅ ។ ពិតហើយ សូម្បីទីឆ្ងាយក៏រាប់ថា ជាភារៈរបស់ពួកភិក្ខុមិនអាពាធនោះឯង ។ ឥឡូវនេះ ដើម្បីទ្រង់សម្តែងត្រឹមតែអត្ថប៉ុណ្ណោះ ក្នុងពាក្យថា ភិក្ខុនោះដែលភិក្ខុទាំងឡាយ ពោលយ៉ាងនេះជាដើម ទើបព្រះដ៏មានព្រះភាគត្រាស់ពាក្យជាដើមថា ភិក្ខុនោះ ដែលភិក្ខុទាំងឡាយ គប្បីទាញមកកាន់ជំនុំ

សង្ឃ ហើយគប្បីពោលដូច្នេះ ។

បណ្តាបទទាំងនោះ ពីរបទថា **សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា** សេចក្តីថា បើភិក្ខុនោះដែលភិក្ខុពោលប្រដៅដោយន័យមុន នៅតែមិនលះបង់ សូម្បីពួកភិក្ខុចាប់ត្រង់ដើមដៃ និងជើង អូសមកកាន់ជំនុំសង្ឃ ហើយគប្បីពោលប្រដៅលោកដល់ទៅ ៣ ដងទៀត ដោយន័យជាដើមថា **មា អាយស្មា** ដូច្នេះ ។

[ ២៩៦ ] ពីរបទថា **យាវតតិយំ សមនុភាសិតព្វោ** សេចក្តីថា សង្ឃគប្បីសូធ្យសមនុភាសដល់ ៣ ដងសិន ។ មានពាក្យអធិប្បាយថា សង្ឃគប្បីធ្វើកម្ម ដោយសមនុភាសនកម្មវាចា ៣ ដង ។ ក្នុងបទភាជនីយ៍នៃបទថា **យាវតតិយំ សមនុភាសិតព្វោ** នោះ ដើម្បីកាន់យកតែអត្ថ សម្តែងសមនុភាសនវិធី ទើបព្រះមានព្រះភាគត្រាស់ពាក្យថា **សោ ភិក្ខុ សមនុភាសិតព្វោ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វោ** ដូច្នេះជាដើម ។

[ ២៩៧ ] ក្នុងបទថា **សមនុភាសិតព្វោ** ជាដើមនោះ បទថា **ញត្តិយា ទុក្កដំ ទ្វីហិ កម្មវាចាហិ ថុល្លច្ចយា បដិប្បស្សម្ភន្តិ** សេចក្តីថា អាបត្តិទាំង ៣ គឺទុក្កដដែលភិក្ខុត្រូវក្នុងទីបំផុតញត្តិ និងថុល្លច្ច័យ ដែលត្រូវព្រោះកម្មវាចា ២ ដង រមែងរម្ងាប់ទៅដោយកម្មវាចាលើកទី ៣ កាលសូធ្យដល់ **យ** អក្ខរៈយ៉ាងនេះថា **យស្ស ខក្ខមតិ សោ ភាសេយ្យ** ភិក្ខុនោះ រមែងតាំងនៅក្នុងសង្ឃាទិសេសនោះឯង ។

សួរថា អាបត្តិដែលត្រូវហើយ រម្ងាប់ទៅក្តី អាបត្តិដែលមិនបានត្រូវរម្ងាប់ក្តី ដូចម្តេច ឆ្លើយថា ព្រះមហាសុមត្ថេរពោលទុកមុនថា ភិក្ខុណាលះ

កម្មនោះក្នុងវេលាចប់ ភិក្ខុនោះរមែងមិនត្រូវអាបត្តិទាំងនោះ ព្រោះហេតុនោះ អាបត្តិដែលមិនបានត្រូវ ទើបរម្ងាប់ទៅ ចំណែកព្រះមហាបទុមត្ថេរពោលថា អាបត្តិដែលត្រូវហើយ រម្ងាប់ទៅ ដូចអសាធារណាបត្តិរម្ងាប់ទៅ ព្រោះក្លាយភេទដូច្នោះ នឹងប្រយោជន៍អ្វីដោយអាបត្តិដែលមិនទាន់ត្រូវ រម្ងាប់ទៅនោះ ។

សិក្ខាបទវិភង្គនៃបឋមសង្ឃភេទសិក្ខាបទ ចប់

# អធិប្បាយ

## បទភាជនីយ៍នៃបឋមសង្ឃាទិសេសសិក្ខាបទ

[ ២៩៨ ] ពីរបទថា **ធម្មកម្មេ ធម្មកម្មសញ្ញី** សេចក្តីថា បើសមនុ-ភាសនកម្មនោះ ជាកម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសម្គាល់ក្នុងសមនុ-ភាសនកម្មនោះថា ជាកម្មប្រកបដោយធម៌ ។ ក្នុងបទទាំងពួង ក៏មានន័យដូចគ្នានេះ ។ ការសម្គាល់ក្នុងបទថា **កម្មសញ្ញី** នេះ រក្សាមិនបាន ព្រោះកម្មជារបស់ប្រកបដោយធម៌ កាលមិនលះបង់យ៉ាងនោះ រមែងត្រូវអាបត្តិ ។

[ ២៩៩ ] បទថា **អសមនុភាសន្តស្ស** សេចក្តីថា កាលមិនត្រូវសូធ្យសមនុភាស សូម្បីមិនព្រមលះបង់ ក៏មិនត្រូវអាបត្តិសង្ឃាទិសេស ។

បទថា **បដិនិស្សជ្ជន្តស្ស** សេចក្តីថា មិនត្រូវដោយអាបត្តិសង្ឃាទិសេសដល់ភិក្ខុដែលលះបង់មុនញត្តិក្តី ក្នុងខណៈញត្តិក្តី ក្នុងវេលាចប់ញត្តិក្តី ត្រឹមដែលសូធ្យមិនដល់ **យ** អក្ខរៈ នៃអនុសាវនាទី ១-២-៣ ក្តី ។

បទថា **អាទិកម្មិកស្ស** សេចក្តីថា ក្នុងសិក្ខាបទនេះ ទេវទត្តភិក្ខុជាដើមបញ្ញត្តិ ព្រោះបាលីដែលមកក្នុងគម្ពីរបរិវារថា ទេវទត្តភិក្ខុបានព្យាយាមបំបែកសង្ឃដែលព្រមព្រៀងគ្នា ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ព្រោះរឿងនោះ ។ ទេវទត្តនោះឯងជាដើមបញ្ញត្តិនៃការព្យាយាមដើម្បីបំបែកសង្ឃប៉ុណ្ណោះ មិនបានជាដើមបញ្ញត្តិនៃការមិនព្រមលះបង់ឡើយ ។ ព្រោះថា កម្មនោះ សង្ឃមិនបានធ្វើដល់លោក ។

បើមានពាក្យសួរថា ពាក្យដែលពោលនេះ គប្បីជ្រាបបានដូចម្តេច ឆ្លើយថា គប្បីជ្រាបបានដោយព្រះសូត្រថា កម្មរមែងប្រាកដថា សង្ឃធ្វើ

ហើយដល់អាទិកម្មិកភិក្ខុ ព្រោះបាលីដែលមកក្នុងគម្ពីរបរិវារថា អាទិកម្មិកភិក្ខុ មានបុព្វបុរសជាអ្នកសម្លាប់ត្នោត មិនព្រមលះបង់ដោយសមនុភាសនៈ រហូតដល់ ៣ ដង ទ្រង់ប្រារព្ធអាទិកម្មិកភិក្ខុព្រោះរឿងនោះ ដូច្នេះ យ៉ាងណា កម្មមិនបានប្រាកដថា សង្ឃធ្វើដល់ភិក្ខុទេវទត្តដូច្នេះឡើយ ។ បើបុគ្គលណាមួយ គប្បីពោលដោយហេតុត្រឹមតែការពេញចិត្តរបស់ខ្លួនប៉ុណ្ណោះថា កម្មដែលសង្ឃធ្វើហើយដល់ទេវទត្តនោះ គប្បីមានសោត សូម្បីយ៉ាងនោះ ដែលឈ្មោះថាអាបត្តិ រមែងមិនមានដល់ភិក្ខុដែលជាដើមបញ្ញត្តិ ព្រោះមិនលះបង់ ។ ពិតហើយ ដែលឈ្មោះថា អនាបត្តិរមែងមិនប្រាកដដល់ភិក្ខុដែលកន្លងសិក្ខាបទដែលទ្រង់បញ្ញត្តិហើយ ក្រៅអំពីសិក្ខាបទដែលទ្រង់អនុញ្ញាតដោយចំពោះ ។

សូម្បីពាក្យថា **អាទិកម្មិកស្ស** ក្នុងអនាបត្តិវារៈនៃអាទិកម្មិកសិក្ខាបទដែលលោករចនាទុកក្នុងគម្ពីរទាំងឡាយ ក៏រចនាទុកដោយការភ្លាំងភ្លាត់ ។ ឯសេចក្តីនៃពាក្យនោះ គឺលោករចនាទុកដោយការភ្លាំងភ្លាត់ គប្បីជ្រាបដោយព្រះបាលីសម្រាប់លើកអាបត្តិក្នុងកម្មក្ខន្ធកៈយ៉ាងនេះថា អាទិកម្មិកភិក្ខុដែលសង្ឃគប្បីចោទមុន កាលចោទហើយ គប្បីឲ្យលោករឭក កាលឲ្យលោករឭកហើយ គប្បីលើកអាបត្តិឡើងកាត់ ។ កម្មនោះ សង្ឃមិនបានធ្វើដល់ទេវទត្ត ដែលជាអាទិកម្មិក ព្រោះព្យាយាមដើម្បីបំបែកសង្ឃ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អាបត្តិនោះឯង ឈ្មោះថា មិនទាន់កើត តែទេវទត្តភិក្ខុនោះ ហៅថា ជាបុគ្គលដើមបញ្ញត្តិ ព្រោះធ្វើការយល់ថា ព្រះមានព្រះភាគ ទ្រង់ប្រារព្ធលោកបញ្ញត្តិសិក្ខាបទ អនាបត្តិលោកពោលហើយសម្រាប់ទេវទត្តនោះ ព្រោះមិន

*មានអាបត្តិនោះឯង ដោយប្រការដូច្នេះ ។*

*ឯអនាបត្តិនោះ សម្រេចដោយបទនេះឯងថា* **អសមនុភាសន្តស្ស** *តែ សូម្បីដូច្នោះ សង្ឃមិនបានធ្វើសមនុភាសនកម្មតែម្យ៉ាងដល់ភិក្ខុណា ភិក្ខុនោះ លោកហៅថា ជាអ្នកមិនត្រូវសូត្រសមនុភាស មិនហៅថា បុគ្គលជាដើមបញ្ញត្តិ ។ ឯទេវទត្តនេះ គង់ជាដើមបញ្ញត្តិពិត ព្រោះហេតុនោះ ទើបលោកពោលបទថា* **អាទិកម្មិកស្ស** *ទុក ។ វិនិច្ឆ័យក្នុងសមនុភាសនៈនៃសិក្ខាបទទាំងពួង វៀរតែអារិដ្ឋភិក្ខុចេញ គប្បីជ្រាបដោយឧបាយនេះ ។ ពាក្យដ៏សេសក្នុងបទទាំងពួង រាក់ទាំងអស់ហើយ ។*

*បណ្ណាបកិណ្ណកៈ មានសមុដ្ឋានជាដើម សិក្ខាបទនេះមានអង្គ ៣ មានសមុដ្ឋាន ១ ឈ្មោះថា សមនុភាសនសមុដ្ឋាន រមែងតាំងឡើងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត តែជាអកិរិយា ព្រោះកាលភិក្ខុមិនធ្វើកាយវិការ ឬបន្លឺវាចាថា ខ្ញុំនឹងលះបង់ ទើបត្រូវនោះឡើយ ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម វចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ដោយប្រការដូច្នេះ ។*

*បឋមសង្ឃភេទសិក្ខាបទវណ្ណនា ចប់*

# វិនយបិដក

# សង្ឃាទិសេសទី ១១

[ ៣០០ ] សម័យនោះ ព្រះពុទ្ធដ៏មានឥស្សរិយយស ទ្រង់ប្រថាប់ក្នុងវត្តវេឡុវ័ន ជាទីដែលស្តេចប្រទានចំណីដល់សត្វកង្ហែន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ទេវទត្តភិក្ខុព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រ ។ ភិក្ខុទាំងឡាយពោលយ៉ាងនេះថា ទេវទត្តជាអ្នកពោលខុសធម៌ ទេវទត្តជាអ្នកពោលខុសវិន័យ ទេវទត្តមិនគួរបើនឹងព្យាយាមដើម្បីបំបែកសង្ឃ ដើម្បីបំបែកចក្រ ។ កាលភិក្ខុទាំងឡាយ ពោលយ៉ាងនេះហើយ ទើបកោកាលិកភិក្ខុ កដមោរកតិស្សកភិក្ខុ ខណ្ឌទេវីបុត្តភិក្ខុ និងសមុទ្ទទត្តភិក្ខុ ក៏ពោលពាក្យនេះនឹងភិក្ខុទាំងនោះថា សូមលោកម្ចាស់ទាំងឡាយ កុំពោលយ៉ាងហ្នឹង ទេវទត្តពោលត្រូវតាមធម៌ ទេវទត្តពោលត្រូវតាមវិន័យ ម្យ៉ាងទៀតទេវទត្តកាន់យកសេចក្តីពេញចិត្តនិងសេចក្តីគាប់ចិត្តរបស់ពួកយើងហើយទើបពោល លោកដឹង ( សេចក្តីពេញចិត្តជាដើមរបស់ពួកយើង ) ទើបពោល អំពើដែលលោកបានធ្វើមកនេះ ក៏សមគួរដល់យើងទាំងឡាយ ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្ទះបន្អាប់ថា ហេតុម្តេចហ្ន៎ បានជាភិក្ខុទាំងឡាយប្រព្រឹត្តតាមទេវទត្ត ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ។ ខណៈនោះ ពួកភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ភិក្ខុ

ទាំងឡាយក្នុងខណៈនោះថា នែ ភិក្ខុទាំងឡាយ ឮថា មានពួកភិក្ខុប្រព្រឹត្ត តាមទេវទត្តភិក្ខុ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់មានឥស្សរិយយស ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំង-ឡាយ អំពើដែលមោឃបុរសទាំងនោះបានធ្វើ មិនសមគួរទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ហេតុម្តេច ក៏ពួកមោឃបុរសទាំងនោះប្រព្រឹត្តតាមទេវទត្តជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក នែភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុទាំងឡាយមួយរូបក្តី ពីររូបក្តី បីរូបក្តី ជាអ្នកប្រព្រឹត្តតាមភិក្ខុដែលបំបែកសង្ឃនោះឯង និងជាអ្នកពោលប្រកាន់ពួក ហើយពួកភិក្ខុទាំងនោះពោលហាមភិក្ខុទាំងឡាយ ( ដែលជាភិក្ខុបរិសុទ្ធ ) យ៉ាងនេះថា ម្នាលលោកម្ចាស់ទាំងឡាយ លោកទាំងឡាយកុំពោលពាក្យបន្តិចបន្តួចនឹងភិក្ខុនេះ ព្រោះភិក្ខុនេះជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះ ជាអ្នកពោលត្រូវតាមវិន័យផងម្យ៉ាងទៀត ភិក្ខុនេះកាន់យកសេចក្តីពេញចិត្ត និងសេចក្តីគាប់ចិត្តរបស់ពួកយើង ទើបពោលលោកដឹងសេចក្តីពេញចិត្តជាដើមរបស់ពួកយើង ទើបពោល អំពើនេះក៏គាប់ចិត្តដល់យើងទាំងឡាយ ។ ពួកភិក្ខុទាំងនោះត្រូវតែភិក្ខុទាំងឡាយ ( ដែលបរិសុទ្ធ ) ពោលយ៉ាងនេះថា ម្នាលលោកម្ចាស់ទាំង-ឡាយ លោកកុំពោលយ៉ាងហ្នឹង ព្រោះភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាម

ធម៌ផង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យផង សូមលោកម្ចាស់ទាំង-ឡាយកុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះព្រះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅសប្បាយ ។ ពួកភិក្ខុទាំងនោះ កាលដែលភិក្ខុទាំងឡាយពោលហាមយ៉ាងនេះ ក៏នៅប្រកាន់លទ្ធិយ៉ាងនោះដដែល ពួកភិក្ខុទាំងនោះ ត្រូវភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្មអស់វារៈគម្រប់បីដង ដើម្បីឲ្យលះបង់នូវកម្មនោះ ។ កាលបើភិក្ខុទាំងឡាយសូត្រសមនុភា-សនកម្មដល់គម្រប់បីដងហើយ ពួកភិក្ខុទាំងនោះលះបង់នូវរឿងនោះចេញ ការលះបង់បានយ៉ាងនេះជាការល្អណាស់ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃា-ទិសេស ។

[ ៣០១ ] ត្រង់ពាក្យថា ភិក្ខុនោះឯង គឺភិក្ខុជាអ្នកបំបែកសង្ឃនោះ ។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ពួកភិក្ខុដទៃ ។ ពាក្យថា ជាអ្នកប្រព្រឹត្តតាម គឺភិក្ខុអ្នកបំបែកសង្ឃយល់ឃើញ ត្រូវចិត្ត គាប់ចិត្តកម្មណា ភិក្ខុទាំងនោះក៏យល់តាម ត្រូវចិត្តតាម គាប់ចិត្តតាមនូវកម្មនោះដែរ ។ ពាក្យថា ជាអ្នកពោលប្រកាន់ពួក គឺតាំងនៅក្នុងសេចក្តីសរសើរនូវភិក្ខុជាអ្នកបំបែកសង្ឃនោះផង ក្នុងពួកនៃភិក្ខុនោះផង ។ ពាក្យថា មួយរូបក្តី ពីររូបក្តី បីរូបក្តី គឺភិក្ខុមួយរូបក្តី ពីររូបក្តី បីរូបក្តី ភិក្ខុទាំងនោះពោលនឹងភិក្ខុទាំងឡាយយ៉ាងនេះថា នៃលោកម្ចាស់ទាំងឡាយ លោកកុំពោលពាក្យបន្តិចបន្តួចនឹងភិក្ខុនេះ ភិក្ខុនេះជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះ ជាអ្នកពោលត្រូវតាមវិន័យផង ម្យ៉ាង

ទៀត ភិក្ខុនេះ កាន់យកសេចក្ដីពេញចិត្ត និងសេចក្ដីគាប់ចិត្តរបស់ពួកយើង ហើយ ទើបពោល លោកដឹង ( សេចក្ដីពេញចិត្តជាដើម ) របស់ពួកយើង ហើយ ទើបពោល អំពើដែលលោកធ្វើនេះ ក៏សមគួរដល់ពួកយើង ។

[ ៣០២ ] ពាក្យថា ភិក្ខុទាំងនោះ គឺពួកភិក្ខុអ្នកប្រព្រឹត្តតាមអម្បាល នោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ភិក្ខុឯទៀត ( ក្រៅពីសង្ឃ-ភេទកភិក្ខុនោះ ) ។ ពួកភិក្ខុដែលបានឃើញ បានឮ គប្បីពោលថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមធម៌ផង ភិក្ខុនេះ មិនមែនជាអ្នកពោលត្រូវតាមវិន័យផង សូមលោកម្ចាស់ទាំងឡាយ កុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះសង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយត្រូវពោលជាគម្រប់ពីរដងផង ត្រូវពោលជាគម្រប់បីដងផង ។ បើពួកភិក្ខុទាំងនោះលះបង់រឿងនោះបាន ការលះបង់បានយ៉ាងនេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ពួកភិក្ខុឯទៀតឮហើយ មិនពោលហាមប្រាមត្រូវអាបត្តិទុក្កដដែល ។ ភិក្ខុទាំងឡាយត្រូវនាំគ្នាចាប់ទាញភិក្ខុទាំងនោះមកកាន់កណ្ដាលជំនុំសង្ឃ ហើយពោលហាមថា នែលោកម្ចាស់ទាំងឡាយ លោកកុំពោលយ៉ាងហ្នឹង ភិក្ខុនេះ មិនមែនជាអ្នកពោលត្រូវតាមធម៌ទេ ភិក្ខុនេះមិនមែនជាអ្នកពោលត្រូវតាមវិន័យទេ សូមលោកម្ចាស់ទាំងឡាយកុំគាប់ចិត្តនឹងសង្ឃភេទឡើយ សូមលោកម្ចាស់ទាំងឡាយព្រមព្រៀងជាមួយនឹងសង្ឃទៅ ព្រោះ

សង្ឃព្រមព្រៀងគ្នា រីករាយរកគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា តែងនៅជាសុខសប្បាយ ។ ភិក្ខុទាំងឡាយ គប្បីពោលហាមជាគម្រប់ពីរដងផង ជាគម្រប់បីដងផង ។ បើលោកទាំងនោះលះបង់រឿងនោះបាន ការលះបង់បាននេះ ជាការឥតទោស បើលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ ។

[ ៣០៣ ] ភិក្ខុទាំងឡាយ គប្បីសូត្រសមនុភាសនកម្មហាមពួកភិក្ខុទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុទាំងនោះ គឺភិក្ខុសង្ឃគប្បីសូត្រសមនុភាសនកម្មយ៉ាងនេះ គឺភិក្ខុដែលឆ្លាសប្រតិពលគប្បីផ្ទៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុទាំងឡាយមានឈ្មោះនេះផង ឈ្មោះនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ហើយជាអ្នកពោលប្រកាន់ពួក ។ ពួកភិក្ខុទាំងនោះមិនលះបង់វត្ថុនោះទេ ។ បើសមនុភាសនកម្មមានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្មហាមពួកភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះលែងនូវរឿងនោះចេញ ។ វាចានេះសម្រាប់ញ៉ាំងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុទាំងឡាយមានឈ្មោះនេះផង ឈ្មោះនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ។ ពួកភិក្ខុទាំងនោះ មិនលះបង់នូវរឿងនោះទេ ។ សង្ឃសូត្រសមនុភាសនកម្មហាមភិក្ខុមានឈ្មោះនេះផង មានឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ ។ ការសូត្រសមនុភាសនកម្មដល់ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះសមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះ

ស្ងៀមនៅ មិនសមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង ។ ខ្ញុំពោលសេចក្តីនេះ ជាគម្រប់ពីរដងផង ។បេ។ ខ្ញុំពោលសេចក្តីនេះ ជាគម្រប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ជាអ្នកប្រព្រឹត្តតាមភិក្ខុមានឈ្មោះនេះ ជាអ្នកព្យាយាមដើម្បីបំបែកសង្ឃ ជាអ្នកពោលប្រកាន់ពួក ។ ពួកភិក្ខុទាំងនោះ មិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្មហាមភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ ។ ការសូត្រសមនុភាសនកម្មហាមភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង ដើម្បីឲ្យលះបង់នូវរឿងនោះ សមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនសមគួរដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះ ពោលឡើង ។ ភិក្ខុមានឈ្មោះនេះផង ឈ្មោះនេះផង គឺព្រះសង្ឃបានសូត្រសមនុភាសនកម្មរួចហើយ ដើម្បីឲ្យលះបង់នូវរឿងនោះ ។ ( សមនុភាសនកម្មនោះ ) សមគួរដល់សង្ឃ ហេតុនោះព្រះសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

[ ៣០៤ ] ( កាលសង្ឃ ) សូត្រញត្តិចប់ ( ភិក្ខុទាំងនោះ ) ត្រូវអាបត្តិទុក្កដ ( កាលសង្ឃ ) សូត្រកម្មវាចាពីរដង ភិក្ខុទាំងនោះ ត្រូវអាបត្តិថុល្លច្ច័យ ( កាលសង្ឃ ) សូត្រកម្មវាចាចប់ ( ភិក្ខុទាំងនោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។ កាលបើភិក្ខុទាំងនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលភិក្ខុទាំងនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុទាំងនោះត្រូវក្នុងខណៈចប់កម្មវាចាពីរដងក្តី ក៏តែងរម្ងាប់

ទៅឯង ។ សង្ឃគប្បីសូត្រសមនុភាសនកម្មហាមប្រាមភិក្ខុពីរ ( ឬ ) បីអង្គ ក្នុងទីជាមួយគ្នាបាន បើភិក្ខុច្រើនជាងចំនួននោះឡើងទៅ សង្ឃមិនគប្បីសូត្រទេ ។ ពាក្យថា សង្ឃាទិសេស មានអធិប្បាយពិស្តារ ក្នុងសិក្ខាបទទី ១ ខាងដើមរួចហើយ ។

[ ៣០៥ ] ភិក្ខុទាំងឡាយ ( ជាអ្នកប្រព្រឹត្តតាមភិក្ខុបំបែកសង្ឃ ) មានសេចក្តីសំគាល់ក្នុងកម្មដែលសង្ឃធ្វើត្រូវតាមធម៌ថា កម្មធ្វើត្រូវតាមធម៌ តែមិនលះបង់ចោល ( គឺនៅប្រព្រឹត្តដដែល ) ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុទាំងនោះមានសេចក្តីសង្ស័យក្នុងកម្មដែលត្រូវតាមធម៌ តែមិនលះបង់ចោល ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុទាំងនោះមានសេចក្តីសំគាល់ក្នុង កម្មដែលត្រូវតាមធម៌ថា កម្មមិនត្រូវតាមធម៌វិញ តែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុទាំងនោះ មានសេចក្តីសំគាល់ក្នុងកម្មដែលមិនត្រូវតាមធម៌ ថាកម្មត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងនោះ មានសេចក្តីសង្ស័យក្នុងកម្មមិនត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងនោះមានសេចក្តីសំគាល់ក្នុងកម្មដែលមិនត្រូវតាមធម៌ថា កម្មមិនត្រូវតាមធម៌ ត្រូវអាបត្តិទុក្កដដែរ ។

[ ៣០៦ ] អាបត្តិមិនមានដល់ពួកភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុ-ភាសនកម្ម ដល់ពួកភិក្ខុដែលបានលះបង់ ដល់ពួកភិក្ខុឆ្កួត ដល់ពួកភិក្ខុមានចិត្តរវើរវាយ ដល់ពួកភិក្ខុមានទុក្ខវេទនាគ្របសង្កត់ ដល់ពួកភិក្ខុជាអាទិកម្មិក ។

សង្ឃាទិសេសសិក្ខាបទទី ១១ ចប់

# អដ្ឋកថា

# ទុតិយសង្ឃភេទសិក្ខាបទវណ្ណនា[១]

[ ៣០០ ] ទុតិយសង្ឃភេទសិក្ខាបទ ត្រង់ពាក្យថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅក្នុងទុតិយសង្ឃភេទសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះ

បទថា **អនុវត្តកា** សេចក្តីថា អ្នកបដិបត្តិតាម ដោយកាន់ការឃើញ ការគាប់ចិត្ត និងការពេញចិត្តនៃទេវទត្តភិក្ខុនោះ ។ ភិក្ខុណាពោលពាក្យជាបក្ខពួក គឺមានពាក្យក្នុងចំណែកនៃការមិនសាមគ្គីគ្នា ហេតុនោះ ទើបភិក្ខុទាំងនោះ ឈ្មោះថា ជាអ្នកពោលពាក្យជាបក្ខពួក ។

# អធិប្បាយ

# សិក្ខាបទវិភង្គនៃទុតិយសង្ឃភេទសិក្ខាបទ

[ ៣០១ ] ក្នុងការចែកបទ ព្រះមានព្រះភាគត្រាស់ទុកថា រមែងជាអ្នកតាំងនៅក្នុងវាចាជាចំណែកសរសើរទេវទត្តនោះ អធិប្បាយថា តាំងនៅហើយដើម្បីសរសើរ និងដើម្បីភាពចម្រើននៃបក្ខពួកដល់ទេវទត្តនោះ ដែលព្យាយាមដើម្បីបំបែកសង្ឃ ។ ពួកភិក្ខុដែលពោលពាក្យជាបក្ខពួក រមែងជាបុគ្គលដូច្នេះដោយនិយម ព្រោះដូច្នោះ ទើបលោកពោលពាក្យនេះ ។ តែព្រោះភិក្ខុច្រើនជាង ៣ រូប ជាអ្នកមិនគួរដល់កម្ម ព្រោះសង្ឃនឹងធ្វើកម្មដល់សង្ឃមិនបាន ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឯកោ វា ទ្វេ វា**

១- ទីខ្លះ សិក្ខាបទនេះ ហៅថា ភេទានុវត្តកសិក្ខាបទ ។

**តយោ វា** ដូច្នេះ ។

បទថា **ជានាតិ នោ** សេចក្តីថា លោកដ៏មានអាយុនោះ រមែងដឹង សូម្បីការពេញចិត្តជាដើមរបស់ពួកយើង ។

បទថា **ភាសតិ** សេចក្តីថា រមែងពោលនឹងពួកយើងថា ពួកខ្ញុំនឹងធ្វើ យ៉ាងនេះ ។

បទថា **អម្ហាកមេ្បតំ ខមតិ** សេចក្តីថា លោកដ៏មានអាយុនោះ រមែងធ្វើវត្ថុណា វត្ថុនោះ រមែងជាទីពេញចិត្តដល់ពួកយើង ។

[ ៣០២ ] បទថា **សមេតាយស្មន្តានំ សង្ឃេន** សេចក្តីថា ចិត្តរបស់ លោកដ៏មានអាយុទាំងឡាយ ចូរដល់ព្រម គឺ ចូរមកព្រម អធិប្បាយថា ចូរ ដំណើរទៅកាន់ភាពតែមួយជាមួយសង្ឃ ។

ពាក្យដ៏សេសក្នុងសិក្ខាបទនេះ ប្រាកដច្បាស់ហើយទាំងអស់ ព្រោះមាន ន័យដូចពោលហើយក្នុងសិក្ខាបទមុន និងព្រោះមានអត្ថងាយយល់ហើយ ។ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងសិក្ខាបទមុននោះឯង ។

ទុតិយសង្ឃភេទសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ១២

[ ៣០៧ ] សម័យនោះ ព្រះសម្ពុទ្ធអ្នកមានឥស្សរិយយស ទ្រង់ប្រថាប់នៅឃោសិតារាម ក្បែរក្រុងកោសម្ពី ។ សម័យនោះឯង ឆន្នភិក្ខុដ៏មានអាយុប្រព្រឹត្តអនាចារ ( មារយាទមិនសមគួរផ្សេងៗ ) ។ ភិក្ខុទាំងឡាយពោលប្រដៅយ៉ាងនេះថា ម្នាលអាវុសោឆន្ន លោកកុំធ្វើអំពើមានសភាពយ៉ាងនេះ អំពើនេះមិនសមគួរទេ ឆន្នភិក្ខុនោះឆ្លើយទៅវិញថា អាវុសោ លោកទាំងឡាយសំគាល់ថាលោកត្រូវពោលប្រដៅខ្ញុំឬ ខ្ញុំឯងទេតើ ទើបត្រូវប្រដៅលោកទាំង-ឡាយ ( ព្រោះថា ) ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះអយ្យបុត្តរបស់យើង បានត្រាស់ដឹងនូវព្រះធម៌ដូចខ្យល់ព្យុះធំបក់បោកប្រមូលយកស្មៅ កំណាត់ឈើ ស្លឹកឈើ និងសំណាត់មកមូលជាមួយគ្នា ឬថាដូចជាទឹកស្ទឹងដែលហូរចុះចាកភ្នំតែងប្រមូលក្ជួចយកនូវចកធំ សារាយ និងចកបាយទាមករួមជាមួយគ្នាបាន មានឧបមាយ៉ាងណាមិញ លោកទាំងឡាយមានឈ្មោះផ្សេងៗ មានគោត្រផ្សេងៗ មានជាតិផ្សេងៗ ចេញចាកត្រកូលផ្សេងៗ ហើយបួស គឺគេប្រមូលមកឲ្យមូលត្រកូលគ្នា ក៏មានឧបមេយ្យដូច្នោះឯង នៃអាវុសោទាំងឡាយ លោកទាំងឡាយនៅសំគាល់ថាលោកត្រូវពោលប្រដៅខ្ញុំឬ ខ្ញុំឯងទេតើទើបត្រូវប្រដៅលោកទាំងឡាយ ( ព្រោះថា ) ព្រះពុទ្ធរបស់យើង ព្រះធម៌របស់យើង ព្រះអយ្យបុត្តរបស់យើង បានត្រាស់ដឹងនូវព្រះធម៌ ។ ភិក្ខុទាំងឡាយណាជាអ្នកប្រាថ្នាតិច មានសេចក្តីសន្តោស មានសេចក្តីអៀនខ្មាស មានសេចក្តីរំខាន ប្រាថ្នាការសិក្សា ភិក្ខុទាំងឡាយនោះ

ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ កាលភិក្ខុទាំង-ឡាយពោលប្រដៅដោយធម៌ ឬដោយសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្តទុក មិនសមបីបើនឹងធ្វើខ្លួនឲ្យគេពោលប្រដៅមិនបាន ។ ទើបភិក្ខុទាំងនោះ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរបញ្ជាក់ឆន្នភិក្ខុដ៏មានអាយុក្នុងពេលនោះថា ឆន្ន ឮថា អ្នកឯងកាលពួកភិក្ខុពោលប្រដៅដោយធម៌ត្រឡប់ធ្វើខ្លួនឲ្យគេប្រដៅមិនបានវិញ មែនឬ ។ ឆន្នភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធអ្នកមានឥស្សរិយយសទ្រង់តិះដៀលថា នែមោឃបុរស អំពើនេះ មិនទំនងសោះ ។បេ។ មិនគួរធ្វើសោះ នែមោឃបុរស ហេតុម្តេច បានជាអ្នកឯង កាលពួកភិក្ខុពោលប្រដៅដោយធម៌ ( ត្រឡប់ ) ជាធ្វើខ្លួនឲ្យគេពោលប្រដៅមិនបានទៅវិញ នែមោឃបុរស អំពើនេះ មិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសម្តែងឡើងនូវសិក្ខា-បទនេះយ៉ាងនេះថា ភិក្ខុមានជាតិដែលគេប្រដៅក្រ កាលភិក្ខុទាំងឡាយពោលប្រដៅ ( ខ្លួន ) ដោយធម៌ ក្នុងសិក្ខាបទទាំងឡាយដែលរាប់ចូលក្នុងឧទ្ទេស ( បាតិមោក្ខ ) ធ្វើខ្លួនឲ្យគេប្រដៅមិនបាន ដោយពាក្យថា លោកម្ចាស់ទាំង-ឡាយ លោកកុំនិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងខ្ញុំឡើយ ចំណែកខ្ញុំក៏នឹងមិនពោលពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តី នឹងលោកម្ចាស់ទាំងឡាយដែរ បពិត្រលោកម្ចាស់ទាំងឡាយ ចូរលោកលែងនិយាយ

ប្រដៅខ្ញុំទៅ ។ ភិក្ខុនោះត្រូវភិក្ខុទាំងឡាយពោល ( ហាម ) យ៉ាងនេះថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេប្រដៅមិនបានឡើយ លោកម្ចាស់ត្រូវតែធ្វើខ្លួនឲ្យគេពោលប្រដៅបានផង ចំណែកលោកម្ចាស់ ចូរប្រដៅភិក្ខុទាំងឡាយដោយសហធម៌ ( ពុទ្ធបញ្ញត្តិ ) សូម្បីពួកភិក្ខុក៏ពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិសទ្យរបស់ព្រះដ៏មានព្រះភាគជាម្ចាស់នោះ តែងចម្រើនឡើងដោយពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា និងដោយញុំាងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិយ៉ាងនេះ ។ កាលភិក្ខុទាំងឡាយ ពោលប្រដៅភិក្ខុនោះយ៉ាងនេះ ( ភិក្ខុនោះ ) ក៏នៅប្រកាន់យ៉ាងហ្នឹងដដែល ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ( ហាម ) ជាគម្រប់បីដង ដើម្បីឲ្យលះបង់នូវកម្មនោះ បើភិក្ខុនោះ កាលពួកភិក្ខុសូត្រសមនុភាសនកម្មជាគម្រប់បីដង ហើយលះបង់រឿងបាននោះ ការលះបង់បានយ៉ាងនេះ ជាការរួចទោស បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ៣០៨ ] ត្រង់ពាក្យថា ភិក្ខុមានជាតិដែលគេប្រដៅក្រ គឺជាអ្នកដែលគេស្តីប្រដៅបានដោយកម្រ ប្រកបដោយធម៌ជាហេតុធ្វើឲ្យប្រដៅក្រ មិនអត់ធន់ មិនកាន់យកពាក្យប្រៀនប្រដៅដោយខាងស្តាំ ( មិនកាន់យកពាក្យប្រៀនប្រដៅដោយគោរព ) ។ ពាក្យថា ក្នុងសិក្ខាបទទាំងឡាយដែលរាប់បញ្ចូលក្នុងឧទ្ទេស គឺក្នុងសិក្ខាបទទាំងឡាយ ដែលរាប់បញ្ចូលក្នុងព្រះបាតិមោក្ខ ។ ពាក្យថា ពួកភិក្ខុ គឺភិក្ខុទាំងឡាយដទៃ ។ បទដែលឈ្មោះថាសហធម៌ គឺសិក្ខាបទណា ដែលព្រះដ៏មានព្រះភាគបញ្ញត្តទុក សិក្ខាបទនេះ

ឈ្មោះថា សហធម៌ ។ ភិក្ខុនោះគេស្តីប្រដៅដោយសហធម៌នោះ ត្រឡប់ជាធ្វើខ្លួនមិនឲ្យគេស្តីប្រដៅបាន ដោយពាក្យថា បពិត្រលោកម្ចាស់ទាំងឡាយ លោកទាំងឡាយកុំនិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តីនឹងខ្ញុំ ចំណែកខ្ញុំក៏មិននិយាយពាក្យបន្តិចបន្តួច ទោះល្អក្តី អាក្រក់ក្តីនឹងពួកលោកម្ចាស់ សូមពួកលោកម្ចាស់វៀរចាកការពោលប្រដៅខ្ញុំ ។

[ ៣០៩ ] ពាក្យថា ភិក្ខុនោះ គឺភិក្ខុមានជាតិដែលគេប្រដៅបានដោយក្រនោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ បានដល់ពួកភិក្ខុដទៃ ។ មានអធិប្បាយថា ពួកភិក្ខុណាឃើញ ពួកភិក្ខុណាបានស្តាប់ ( ដំណឹង ) ពួកភិក្ខុទាំងនោះត្រូវពោលថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន លោកម្ចាស់ត្រូវតែធ្វើខ្លួនឲ្យគេស្តីប្រដៅបាន សូម្បីលោកម្ចាស់សោត ក៏ចូរពោលប្រដៅភិក្ខុទាំងឡាយដោយសហធម៌ សូម្បីភិក្ខុទាំងឡាយ ក៏នឹងពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិសទ្យរបស់ព្រះដ៏មានព្រះភាគនោះ តែងចម្រើនឡើងដោយអាការយ៉ាងនេះ គឺដោយកិរិយាពោលជាប្រយោជន៍ដល់គ្នានឹងគ្នា ដោយញុំាងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិ ។ ភិក្ខុនោះត្រូវភិក្ខុទាំងឡាយពោល ( ហាម ) ជាគម្រប់ពីរដងផង ត្រូវពោល ( ហាម ) ជាគម្រប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បានយ៉ាងនេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយ បានឮហើយមិនពោល ( ហាម ) ត្រូវអាបត្តិទុក្កដដែល ។ ភិក្ខុទាំងឡាយគប្បីចាប់ភិក្ខុនោះមកកាន់កណ្តាលប្រជុំសង្ឃ ហើយពោល ( ហាម ) ថា លោកម្ចាស់កុំធ្វើខ្លួនឲ្យគេ

ស្តីប្រដៅមិនបាន លោកម្ចាស់ចូរធ្វើខ្លួនឲ្យគេស្តីប្រដៅបានផង សូម្បីលោកម្ចាស់សោត ក៏ចូរពោលប្រដៅពួកភិក្ខុដោយសហធម៌ ចំណែកពួកភិក្ខុវិញក៏នឹងពោលប្រដៅលោកម្ចាស់ដោយសហធម៌ដែរ ព្រោះបរិសទ្យរបស់ព្រះដ៏មានព្រះភាគជាម្ចាស់នោះ តែងចម្រើនដោយអាការយ៉ាងនេះ គឺដោយកិរិយាពោលពាក្យជាប្រយោជន៍ដល់គ្នានឹងគ្នា ដោយកិរិយាញុំាងគ្នីគ្នាឲ្យចេញចាកអាបត្តិ ។ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយពោលហាមជាគម្រប់ពីរដងផង ត្រូវពោលហាមជាគម្រប់បីដងផង ។ បើភិក្ខុលះបង់បាន ការលះបង់យ៉ាងនេះ ជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

[ ៣១០ ] ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុត្រូវសូត្រសមនុភាសនកម្មយ៉ាងនេះ ។ គឺភិក្ខុដែលឆ្លាសអង់អាច គប្បីប្រកាសឲ្យសង្ឃជ្រាបដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ កាលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ ត្រឡប់ជាធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបានវិញ ។ ភិក្ខុនោះ មិនលះបង់រឿងនោះទេ ។ ថាបើកម្មមានកាលសមគួរដល់សង្ឃហើយ ព្រះសង្ឃគប្បីសូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ ។ នេះជាញត្តិ ( គឺវាចាប្រកាសឲ្យសង្ឃដឹង ) ។ បពិត្រព្រះសង្ឃដ៏ចម្រើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ កាលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ ត្រឡប់ជាធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ ព្រះសង្ឃ

សូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿង នោះ ។ ការសូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់រឿងនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះស្ងៀមនៅ មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង ។ ខ្ញុំពោលសេចក្តីនេះជាគម្រប់ពីរដងផង ។បេ។ ខ្ញុំពោលសេចក្តីនេះជាគម្រប់បីដងផង ។ បពិត្រព្រះសង្ឃដ៏ចម្រើន ព្រះសង្ឃចូរស្តាប់ពាក្យរបស់ខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ កាលភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ នៅធ្វើខ្លួនឲ្យគេស្តីប្រដៅមិនបាន ។ ភិក្ខុនោះមិនលះបង់រឿងនោះទេ ។ ព្រះសង្ឃសូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់នូវរឿងនោះ ។ ការសូត្រសមនុភាសនកម្ម ( ហាម ) ភិក្ខុមានឈ្មោះនេះ ដើម្បីឲ្យលះបង់នូវរឿងនោះ គាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះ ស្ងៀមនៅ មិនគាប់ចិត្តដល់លោកម្ចាស់អង្គណា សូមលោកម្ចាស់អង្គនោះពោលឡើង ។ ភិក្ខុមានឈ្មោះនេះ គឺព្រះសង្ឃបានសូត្រសមនុភាសនកម្មហើយ ដើម្បីឲ្យលះបង់នូវរឿងនោះ ។ សមនុភាសនកម្មនោះ គាប់ចិត្តដល់ព្រះសង្ឃ ហេតុនោះព្រះសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយកិរិយាស្ងៀមនៅយ៉ាងនេះ ។

[ ៣១១ ] ( កាលសង្ឃ ) សូត្រញត្តិចប់ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ ( កាលសង្ឃ ) សូត្រកម្មវាចាពីរដង ( ភិក្ខុនោះ ) ត្រូវអាបត្តិថុល្លច្ច័យ ( កាលសង្ឃ ) សូត្រកម្មវាចាចប់ ( ភិក្ខុនោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។

កាលបើភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដ ដែលភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះត្រូវក្នុងខណៈចប់កម្មវាចាពីរដងក្តី ក៏តែងរម្ងាប់ទៅឯង ។ ពាក្យថា អាបត្តិសង្ឃាទិសេស មានអធិប្បាយពិស្តារក្នុងសិក្ខាបទខាងដើមរួចហើយ ។

[ ៣១២ ] ភិក្ខុមានសេចក្តីសម្គាល់ក្នុងកម្ម ដែលប្រកបដោយធម៌ថា កម្មប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មដែលប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុមានសេចក្តីសំគាល់ក្នុងកម្មប្រកបដោយធម៌ថា កម្មមិនប្រកបដោយធម៌ មិនលះបង់ត្រូវអាបត្តិសង្ឃាទិសេសដែរ ។ ភិក្ខុមានសេចក្តីសម្គាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសម្គាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដដែល ។

[ ៣១៣ ] អាបត្តិមិនមានដល់ភិក្ខុ ដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ភិក្ខុលះបង់ស្រឡះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

សង្ឃាទិសេសទី ១២ ចប់

# អដ្ឋកថា
# ទុព្វចសិក្ខាបទវណ្ណនា

[ ៣០៧ ] ក្នុងទុព្វចសិក្ខាបទ បទថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងទុព្វចសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះ

ពីរបទថា **អនាចារំ អាចរតិ** សេចក្តីថា រមែងធ្វើការបំពានតាមកាយទ្វារ និងវចីទ្វារ ដោយប្រការដ៏ច្រើន ។

បទថា **កឹ នុ ខោ នាម** នេះ ជាការពោលសម្មត ( អ្នកដទៃ ) ។

បទថា **អហំ ខោ នាម** ជាពាក្យលើក ( ខ្លួន ) ។

ដោយបទថា **តុម្ហេ វទេយ្យំ** លោកសម្តែងថា ខ្ញុំគួរនឹងពោលប្រៀនប្រដៅពួកលោកថា ពួកលោក ចូរធ្វើយ៉ាងនេះ កុំធ្វើយ៉ាងនេះ ។

បើមានពាក្យសួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះឆន្នភិក្ខុពោលសំដៅយកបំណងជាដើមយ៉ាងនេះថា ព្រះមានព្រះភាគ ទ្រង់សេះកណ្ឋកៈ យាងចេញព្រមជាមួយខ្ញុំ ទ្រង់បួសហើយ ។ កាលពោលថា ព្រះធម៌របស់ខ្ញុំ ហើយកាលនឹងសម្តែងយុត្តិ ក្នុងភាពជារបស់ខ្លួនទៀត ទើបពោលថា ព្រះធម៌នេះ ព្រះអយ្យបុត្ររបស់ខ្ញុំបានត្រាស់ដឹងហើយ ដូច្នេះ ។ មានពាក្យអធិប្បាយថា សច្ចៈ ៤ ដែលព្រះអយ្យបុត្ររបស់ខ្ញុំត្រាស់ដឹងហើយ ដូច្នោះ សូម្បីព្រះធម៌ក៏ជារបស់ខ្ញុំ ។ តែសម្គាល់ព្រះសង្ឃថា តាំងនៅក្នុងចំណែកជាសត្រូវរបស់ខ្លួន ទើបមិនពោលថា ព្រះសង្ឃរបស់ខ្ញុំ ។ តែប្រាថ្នានឹងពោលចាក់ដោតរុករានសង្ឃ ទើបពោលពាក្យជាដើមថា **សេយ្យថាបិ នាម** ដូច្នេះ ។

បទថា **តិណាកដ្ឋបណ្ណាសដំ** បានដល់ ស្មៅ ឈើ និងស្លឹកឈើស្ងួត ដែលជ្រុះទៅក្នុងទីកន្លែងនោះៗ ។ម្យ៉ាងទៀត ស្មៅផង ឈើស្រោលមិនមានខ្លឹមផង ហេតុនោះ ទើបឈ្មោះថា ស្មៅ និងឈើ ។ ស្លឹកឈើស្ងួត ឈ្មោះថា **បណ្ណាសដ** ។

បទថា **ឧស្សារេយ្យ** បានដល់ បក់ទៅគរទុក ។

បទថា **បត្តេយ្យ** សេចក្ដីថា បានដល់ កើតអំពីក្អំ ។ ពិតហើយ ស្លឹងនោះមានក្រសែហូរខ្លួល ព្រោះដូច្នោះ ទើបលោកប្រារព្ធយកតែស្លឹងនោះប៉ុណ្ណោះ ។

ក្នុងបទថា **សង្ខសេវាលបណាកំ** នេះ មានវិនិច្ឆ័យដូច្នេះថា សារាយដែលមានស្លឹក មានឫសវែង ហៅថា ចកធំ ។ សារាយពណ៌ខៀវ ហៅថា សារាយ ។ សារាយដ៏សេស មានវៃទឹក និងចកបាយទាជាដើមទាំងអស់ រាប់ថា ចកតូច ។

ដោយបទថា **ឯករតោ ឧស្សារិតា** លោកសម្ដែងថា ដែលបុគ្គលណាមួយ ប្រមូលមកហើយ គឺធ្វើជាគំនរទុកក្នុងទីតែមួយ ។

# អធិប្បាយ
# សិក្ខាបទវិភង្គនៃឧត្ចចសិក្ខាបទ

[ ៣០៨ ] បទថា **ឧត្ចចជាតិកោ** បានដល់ មានការៈនៃបុគ្គលប្រដៅក្រ អធិប្បាយថា បុគ្គលដែលនរណាមួយ មិនអាចស្ដីប្រដៅបាន ។ សូម្បីក្នុងការបែកបទនៃបទថា **ឧត្ចចជាតិកោ** នោះ បទថា **ឧត្ចចោ** បានដល់ ដែល

គេប្រៀនប្រដៅបានដោយលំបាក គឺដោយក្រ មានពាក្យអធិប្បាយថា ដែលបុគ្គលណាមួយ មិនអាចស្តីថាបានដោយងាយ ។

បទថា **ទោវចស្សករណេហិ** គឺ ( ដោយធម៌ ) ដែលធ្វើភាពជាអ្នកប្រដៅក្រ អធិប្បាយថា ធម៌ទាំងឡាយណា រមែងធ្វើបុគ្គលឲ្យជាអ្នកប្រដៅក្រ ជាអ្នកប្រកបដោយធម៌នោះ ។

បណ្ឌិតគប្បីជ្រាបធម៌ទាំងនោះ មាន ១៨ យ៉ាង[១] គឺជាអ្នកមានការប្រាថ្នាលាមក ១ លើកខ្លួនសង្កត់សង្កិនអ្នកដទៃ ១ ជាអ្នកច្រើនដោយសេចក្តីក្រោធ ១ ជាអ្នកចងក្រោធ ព្រោះមានការក្រោធជាហេតុ ១ ច្រើនដោយសេចក្តីសង្ស័យ ព្រោះសេចក្តីក្រោធជាហេតុ ១ ជាអ្នកបន្លឺវាចាជិតចំពោះសេចក្តីក្រោធ ព្រោះសេចក្តីក្រោធជាហេតុ ១ ជាអ្នកប្រកែកតវ៉ានឹងអ្នកចោទ ១ ជាអ្នកត្រឡប់រុករានអ្នកចោទ ១ ជាអ្នកចោទត្រឡប់ទៅរកអ្នកចោទ ១ ជាអ្នកបិទបាំងរឿងដទៃដោយរឿងដទៃ ១ ជាអ្នកមិនពេញចិត្តឆ្លើយដោយការប្រព្រឹត្ត ១ ជាអ្នកលុបគុណវាយឫកស្មើ ១ ជាអ្នកច្រណែនកំណាញ់ ១ ជាអ្នកអួតអាងមាយា ១ ជាអ្នករឹងត្អឹងមើលងាយអ្នកដទៃ ១ ជាអ្នកប្រកាន់តែការយើញរបស់ខ្លួន ១ ជាអ្នកចចេសរឹងរូស ១ ជាអ្នកដកបានលំបាក ១ ដែលមកហើយក្នុងអនុមានសូត្រតាមលំដាប់ ដោយន័យជាដើមថា ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ តើដូចម្តេចខ្លះ ។ ម្នាលអាវុសោ ( ធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រនោះ មាន ១៦ យ៉ាងគឺ ) ភិក្ខុក្នុងសាសនា

---

១- ក្នុងមជ្ឈិមនិកាយ អនុមានសូត្រ មានត្រឹមតែ ១៦ ។

នេះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ... ដូច្នេះជាដើម ។

បុគ្គលណា មិនអត់ មិនធន់ចំពោះឱវាទ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **អក្ខម** ។ បុគ្គលណា កាលមិនបដិបត្តិតាមដែលលោកប្រៀនប្រដៅ មិនទទួលអនុសាសនីដោយចំណែកខាងស្តាំ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា មានប្រក្រតីមិនទទួលដោយចំណែកខាងស្តាំនូវអនុសាសនី ។

បទថា **ឧទ្ទេសបរិយាបន្នេសុ** បានដល់ ទាក់ទងក្នុងនិទ្ទេស គឺសង្គ្រោះចូលខាងក្នុង សេចក្តីថា ប្រព្រឹត្តទៅខាងក្នុងបាតិមោក្ខុទ្ទេស ព្រោះលោកសង្គ្រោះយ៉ាងនេះថា អាបត្តិមានដល់បុគ្គលណា បុគ្គលនោះ គប្បីបើកផ្ងារ ។

[ ៣០៩-៣១០ ] ពីរបទថា **សហធម្មិកំ វុច្ចមានោ** បានដល់ ដែលភិក្ខុទាំងឡាយស្តីប្រដៅដោយប្រពៃក្នុងសហធម៌ ។ នេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្ត ។ អធិប្បាយថា ដែលភិក្ខុទាំងឡាយកំពុងប្រដៅដោយសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្តទុក ដែលបានឈ្មោះថា **សហធម្មិក** ព្រោះជាសិក្ខាដែលសហធម្មិកទាំង ៥ គប្បីសិក្សា ឬព្រោះជារបស់សហធម្មិក ៥ ទាំងនោះ ។ បទថា **វិរមថាយស្មន្តោ មម វចនាយ** សេចក្តីថា ពួកលោកពោលប្រដៅខ្ញុំដោយពាក្យណា ចូរលើកចាកពាក្យនោះតាមពាក្យរបស់ខ្ញុំ អធិប្បាយថា ពួកលោកកុំពោលពាក្យនោះនឹងខ្ញុំ ។

បទថា **វទេតុ សហធម្មេន** សេចក្តីថា លោកដ៏មានអាយុ ចូរពោលប្រដៅដោយសិក្ខាបទដែលជាសហធម៌ ឬ ដោយពាក្យដទៃដែលជាសហធម៌ គឺ ប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លា ។

សព្វថា **យទិទំ** ជានិបាត ចុះក្នុងអត្ថ គឺសម្ដែងហេតុនៃការចម្រើន ។ ដោយបទថា **យទិទំ** នោះ គឺលោកសម្ដែងហេតុនៃការចម្រើនរបស់បរិស័ទ យ៉ាងនេះថា ការពោលដឹកនាំក្នុងប្រយោជន៍ដល់គ្នានឹងគ្នា និងការញ៉ាំងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិណា បរិស័ទចម្រើនហើយ ដោយការពោលប្រដៅគ្នានឹងគ្នា ដោយការញ៉ាំងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិនោះ ។

ពាក្យដ៏សេសក្នុងទីទាំងពួង រាក់ទាំងអស់ហើយ សូម្បីសមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមសង្ឃភេទសិក្ខាបទនោះឯង ។

ទុព្វចសិក្ខាបទវណ្ណនា ចប់

# វិនយបិដក

## សង្ឃាទិសេសទី ១៣

[ ៣១៤ ] សម័យនោះ ព្រះពុទ្ធជាម្ចាស់ដ៏មានបុណ្យសិរី គង់នៅក្នុងវត្តជេតពន ជារបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុពីររូបឈ្មោះអស្សជិ និងបុនព្វសុក ជាអ្នកនៅក្នុងអាវាសទៀបកិដាគិរីជនបទ ជាភិក្ខុលាមកឥតខ្មាស ។ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះ ប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាដោយខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទង[១] ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើដែលដោតជាចង្កោមខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះធ្វើផ្កាកម្រងសម្រាប់ប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។ អស្សជិភិក្ខុ និងបុនព្វសុកភិក្ខុនោះ នាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ ដើម្បីស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ នាំផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើចាក់រំលេចទងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើដែលដោតជាចង្កោមទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅ

---

១- តាមក្នុងអដ្ឋកថាគូប្រែថា ក្បាច់ក្បូរផ្កាដែលគេធ្វើឲ្យដូចជាវល្លិដែលមានផ្កា ។

ឲ្យខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ក្បាលទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ នាំផ្កាកម្រងសម្រាប់ប្រដាប់ត្រចៀកទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ នាំផ្កាកម្រងប្រដាប់ទ្រូងទៅខ្លួនឯងខ្លះ ប្រើគេនាំទៅឲ្យខ្លះ ។ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុនោះឆាន់ ( ភោជន ) ក្នុងភាជន៍មួយជាមួយនឹងស្រីនៃត្រកូល ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំង-ឡាយខ្លះ ផឹក ( ទឹក ) ក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ ដេកលើកម្រាលនិងដណ្តប់ជាមួយគ្នាខ្លះ ស៊ីខុសពេលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា ៨[១] ខ្លះ លេងបស្កាមានក្រឡា ១០[២] ខ្លះ លេងផ្លូវវាងដែលខ្លួនគូរវាង[៣] ខ្លះ

---

១- ចត្រង្គមានក្រឡា ៨ ។ ២- ចត្រង្គមានក្រឡា ១០ ន័យខ្លះប្រែថាបាយខុម ។

៣- ប្រហែលជាលេងបិទមុខ-បិទពួន ។

លេងផ្ចាត់គ្រាប់មានក្រួសជាដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហឹងខ្លះ លេងដោយរលាស់ទឹកលាក់ ឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងនង្គ័លតូចខ្លះ លេងជាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ ( បាយឡុកបាយឡ ) ខ្លះ លេងរថតូចខ្លះ លេងធ្នូតូចខ្លះ លេងសរសេរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត ( ស្តេចចង់ ) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់ដំរីខ្លះ ហាត់សេះខ្លះ ហាត់រថខ្លះ ហាត់ធ្នូខ្លះ ហាត់ដងមានដងដាវជាដើមខ្លះ ស្ទុះរត់ពីមុខដំរីខ្លះ ស្ទុះរត់ពីមុខសេះខ្លះ ស្ទុះរត់ពីមុខរថខ្លះ ស្ទុះរត់ទៅខ្លះ ស្ទុះរត់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់គ្នាខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំហើយ និយាយនឹងស្រីដែលរាំយ៉ាងនេះថា ម្នាលប្អូនស្រី នាងចូររាំក្នុងទីនេះខ្លះ ដាក់ម្រាមដៃលើថ្ងាសខ្លួន និងលើថ្ងាសស្រីរបាំខ្លះ ប្រព្រឹត្តអនាចារផ្សេងៗ ខ្លះ ។

[ ៣១៥ ] សម័យនោះឯង ភិក្ខុមួយរូប ចាំវស្សាក្នុងដែនឈ្មោះកាសីរួចហើយទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ក៏ដើរទៅត្រង់កិដាគិរិជនបទ ។ ភិក្ខុនោះឯង ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងពេលព្រឹកព្រហាម មានដំណើរឈានដើរទៅមុខ ឈានថយក្រោយ ក្រឡេកមើលទៅមុខ ក្រឡេកមើលចំហៀង បត់ចូល និងលាចេញ គួរជាទីជ្រះថ្លា ព្រោះភិក្ខុអង្គនោះមានភ្នែកសង្រួមចុះ និងមានឥរិយាបថរម្យទមចូលទៅកាន់កិដាគិរិជនបទដើម្បីបិណ្ឌបាត ។ មនុស្សទាំងឡាយ ឃើញភិក្ខុនោះហើយនិយាយយ៉ាងនេះថា លោកអ្វីនេះ ដូចជាសង្រួមហួស ដូចជាទន់ល្វន់ពេក ដូចជាមុខ

ស្រពោនពេក អ្នកណាគេនឹងឲ្យដុំបាយដល់លោកនេះដែលចូលទៅរក ( គេនោះ ) ចំណែកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុជាម្ចាស់យើងពោលពាក្យផ្អែម ពោលពាក្យពីរោះ ពោលពាក្យជាសុខ មានញញឹមញញែមជាមុន តែងនិយាយថា អ្នកចូរមក អ្នកមកល្អហើយ មានមុខមិនស្រពោន មានមុខរើប តែងនិយាយមុន យើងគួរប្រគេនដុំបាយដល់លោកម្ចាស់អស់នោះ ។ ឧបាសកមួយនាក់ បានឃើញភិក្ខុនោះត្រាច់ទៅក្នុងកិដាគិរិជនបទដើម្បីបិណ្ឌបាត លុះឃើញហើយ ក៏ចូលទៅរកភិក្ខុនោះ ថ្វាយបង្គំហើយនិយាយពាក្យនេះថា មេត្តាប្រោសលោកម្ចាស់បានអាហារបិណ្ឌបាតខ្លះដែរឬ ។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ អាហារបិណ្ឌបាតមិនទាន់បានទេ ។ ឧបាសកនោះនិយាយថា លោកម្ចាស់សូមនិមន្តមក យើងនឹងទៅផ្ទះ ។ ទើបឧបាសកនោះ នាំភិក្ខុនោះទៅផ្ទះឲ្យឆាន់ហើយ និយាយពាក្យនេះថា លោកម្ចាស់នឹងនិមន្តទៅក្នុងទីណា ។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ អាត្មានឹងទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះដ៏មានព្រះភាគ ។ ឧបាសកនោះពោលថា បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទនៃព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យនៃខ្ញុំ ម្យ៉ាងទៀត សូមលោកម្ចាស់ក្រាបទូលយ៉ាងនេះថា សូមទ្រង់មេត្តាប្រោស អាវាសក្នុងកិដាគិរិជនបទខូចហើយ ព្រោះភិក្ខុឈ្មោះអស្សជិ និងភិក្ខុឈ្មោះបុនព្វសុកជាចៅអាវាសក្នុងកិដាគិរិជនបទ ជាភិក្ខុលាមក ឥតខ្មាស ភិក្ខុពីររូបនេះ ប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រង

ខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។បេ។ ប្រព្រឹត្តអនាចារមានប្រការផ្សេងៗ ទៀត សូមទ្រង់ព្រះមេត្តាប្រោស ពួកមនុស្សណាមានសទ្ធាជ្រះថ្លាក្នុងកាលមុន ឥឡូវនេះ មនុស្សអស់នោះគ្មានសទ្ធា មិនជ្រះថ្លាហើយ ទានទាំងឡាយណា ( ដែលគេធ្លាប់ឲ្យ ) ដល់សង្ឃក្នុងកាលមុន ឥឡូវនេះទានទាំងនោះ គេឈប់ឲ្យហើយ ភិក្ខុមានសីលជាទីស្រឡាញ់ក៏រត់ខ្ចាត់ខ្ចាយ នៅតែពួកភិក្ខុលាមក សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគបញ្ជូនពួកភិក្ខុទៅកិដាគិរីជនបទ ប្រយោជន៍ឲ្យអាវាសក្នុងកិដាគិរីជនបទនេះរៀបរយល្អឡើងវិញ ។ ភិក្ខុនោះទទួលស្តាប់ពាក្យឧបាសកនោះហើយថា អើអាវុសោ រួចក៏ចៀសចេញទៅកាន់ក្រុងសាវត្ថី ដោយលំដាប់ ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងវត្តព្រះជេតពន ជារបស់អនាថបិណ្ឌិកគហបតី ទៀបក្រុងសាវត្ថី លុះចូលទៅហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[ ៣១៦ ] ព្រះពុទ្ធទាំងឡាយដ៏មានព្រះភាគ ព្រះអង្គតែងធ្វើសេចក្តីរីករាយជាមួយនឹងភិក្ខុជាអាគន្តុកទាំងឡាយយ៉ាងនេះ ។ ហេតុដូច្នោះបានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ សរីរយន្តអ្នកល្មមអត់ធន់បានឬ អ្នកល្មមប្រព្រឹត្តទៅបានស្រួលឬទេ អ្នកមកកាន់ផ្លូវឆ្ងាយដោយមិនសូវនឿយហត់ទេឬ ម្យ៉ាងទៀត អ្នកទើបនឹងមកពីទីណា ។ ភិក្ខុនោះឆ្លើយថា បពិត្រព្រះដ៏មានព្រះភាគ សរីរយន្តខ្ញុំព្រះអង្គល្មមអត់ធន់បាន

ខ្ញុំព្រះអង្គល្មមប្រព្រឹត្តទៅបានស្រួលទេ បពិត្រព្រះអង្គដ៏ចម្រើន ម្យ៉ាងទៀត ខ្ញុំព្រះអង្គមកកាន់ផ្លូវឆ្ងាយដោយមិនសូវនឿយហត់ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនៅចាំវស្សាក្នុងដែនកាសីនេះ ហើយមកកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ បានដើរទៅត្រង់កិដាគិរិជនបទ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងគ្រានោះ ខ្ញុំព្រះអង្គស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រ និងចីវរ ចូលទៅកាន់កិដាគិរិជនបទ ដើម្បីបិណ្ឌបាតក្នុងពេលព្រឹកព្រហាម សូមទ្រង់ព្រះមេត្តាប្រោស ឧបាសកមួយនាក់ បានឃើញខ្ញុំព្រះអង្គកំពុងត្រាច់ទៅបិណ្ឌបាត ក្នុងកិដាគិរិជនបទ លុះឃើញហើយក៏ចូលមករកខ្ញុំព្រះអង្គ លុះចូលមកហើយថ្វាយបង្គំខ្ញុំព្រះអង្គ រួចនិយាយពាក្យនេះថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់បានអាហារបិណ្ឌបាតខ្លះដែរឬ ខ្ញុំព្រះអង្គនិយាយថា ម្នាលអាវុសោ អាត្មាមិនទាន់បានអាហារបិណ្ឌបាតទេ ឧបាសកនោះនិយាយថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ចូរនិមន្តមក យើងនឹងទៅផ្ទះ សូមទ្រង់ព្រះមេត្តាប្រោស ទើបឧបាសកនោះនាំខ្ញុំព្រះអង្គទៅផ្ទះ ហើយឲ្យឆាន់ រួចហើយប្រាប់ពាក្យនេះថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់នឹងទៅក្នុងទីណា ខ្ញុំព្រះអង្គប្រាប់ថា ម្នាលអាវុសោ អាត្មានឹងទៅក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ ឧបាសកនោះពោលថា បពិត្រលោកដ៏ចម្រើន បើដូច្នោះ សូមលោកម្ចាស់ថ្វាយបង្គំព្រះបាទនៃព្រះដ៏មានព្រះភាគដោយត្បូងតាមពាក្យនៃខ្ញុំ ម្យ៉ាងទៀត សូមលោកម្ចាស់ទូលព្រះដ៏មានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោស អាវាសក្នុងកិដាគិរិជនបទវិនាសខូចអស់ហើយ ព្រោះភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ជាចៅ

អាវាសក្នុងកិដាគិរិជនបទ ជាភិក្ខុលាមក ឥតខ្មាស ភិក្ខុពីររូបនោះប្រព្រឹត្ត អនាចារមានសភាពយ៉ាងនេះគឺ ដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេស្រោចខ្លះ ។បេ។ ប្រព្រឹត្តអនាចារមានប្រការផ្សេងទៀត សូមទ្រង់ព្រះមេត្តាប្រោស កាលមុនមនុស្សទាំងឡាយណា ធ្លាប់មានសទ្ធាជ្រះថ្លាហើយ ឥឡូវនេះ មនុស្សអម្បាលនោះ មិនមានសទ្ធា មិនជ្រះថ្លាទេ ទានទាំងឡាយណា ដែលទាយកធ្លាប់ឲ្យដល់សង្ឃ ក្នុងកាលមុន ឥឡូវនេះ ទានទាំងនោះ គេឈប់ឲ្យហើយ ភិក្ខុទាំងឡាយ មានសីលបរិសុទ្ធស្អាត ចៀសចេញទៅ ចំណែកពួកភិក្ខុលាមកក៏នៅ ( ក្នុងទីនោះ ) សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះដ៏មានព្រះភាគចាត់ពួកភិក្ខុ ( ពីសំណាក់ព្រះអង្គ ) ទៅកិដាគិរិជនបទ ប្រយោជន៍ឲ្យអាវាសក្នុងកិដាគិរិជនបទបានរៀបរយល្អ បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គទើបនឹងមកពីកិដាគិរិជនបទនោះ ។

[ ៣១៧ ] ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុពីររូបឈ្មោះអស្សជិ និងបុនព្វសុក ជាចៅអាវាសក្នុងកិដាគិរិជនបទ ជាភិក្ខុលាមក ឥតខ្មាស ភិក្ខុពីររូបនោះប្រព្រឹត្តអនាចារមានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងមានទងទាំងពីរ ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើចាក់រំលេចទងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ

ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ។បេ។ ប្រព្រឹត្តអនាចារផ្សេងទៀត មនុស្សទាំងឡាយណា ធ្លាប់មានសទ្ធាជ្រះថ្លាហើយក្នុងកាលមុន ឥឡូវនេះមនុស្សទាំងឡាយនោះ មិនមានសទ្ធា មិនជ្រះថ្លាទេ ទានទាំងឡាយណា ដែលទាយកគេធ្លាប់ប្រគេនដល់សង្ឃក្នុងកាលមុន ឥឡូវនេះទានទាំងនោះ គេឈប់ឲ្យអស់ហើយ ភិក្ខុទាំងឡាយមានសីលស្អាតបរិសុទ្ធចៀសចេញទៅ ចំណែកខាងពួកភិក្ខុលាមកក៏នៅក្នុងទីនោះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ រឿងនោះ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះ មិនសមគួរទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ ម្តេចឡើយ ពួកមោឃបុរសនោះប្រព្រឹត្តអនាចារ មានសភាពយ៉ាងនេះ គឺដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ធ្វើផ្កាកម្រងមានទងតែម្ខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាមានទងទាំងពីរខាងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាចាក់រំលេចទងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ក្បាលខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាសម្រាប់ប្រដាប់ត្រចៀកខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ធ្វើផ្កាកម្រងប្រដាប់ទ្រូងខ្លួនឯងខ្លះ ប្រើគេឲ្យធ្វើខ្លះ ភិក្ខុទាំងឡាយនោះ

នាំផ្កាកម្រងមានទងតែម្ខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅខ្លះ ដើម្បីស្រីនៃត្រកូលទាំងឡាយ ធីតានៃត្រកូល កុមារីនៃត្រកូល ស្រីជាកូនប្រសានៃត្រកូល ទាសីនៃត្រកូលទាំងឡាយ នាំផ្កាកម្រងមានទងទាំងពីរខាងទៅខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាចាក់រំលេចទងទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាឈើសម្រាប់ស៊កក្នុងបំពង់ខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាសម្រាប់ប្រដាប់ក្បាលទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាសម្រាប់ប្រដាប់ត្រចៀកទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ នាំផ្កាកម្រងប្រដាប់ទ្រូងទៅឲ្យខ្លួនឯងខ្លះ ប្រើគេឲ្យនាំទៅឲ្យខ្លះ កិត្តុអម្បាលនោះ ឆាន់ក្នុងភាជន៍មួយជាមួយនឹងពួកស្រីនៃត្រកូល ពួកធីតានៃត្រកូល ពួកកុមារីនៃត្រកូល ពួកស្រីជាកូនប្រសានៃត្រកូល ពួកទាសីនៃត្រកូលខ្លះ ផឹកក្នុងផ្តិលជាមួយគ្នាខ្លះ អង្គុយលើអាសនៈជាមួយគ្នាខ្លះ ដេកលើគ្រែជាមួយគ្នាខ្លះ ដេកលើកម្រាលជាមួយគ្នាខ្លះ ដេកដណ្តប់ជាមួយគ្នាខ្លះ មានគ្រឿងកម្រាល និងដេកដណ្តប់ជាមួយគ្នាខ្លះ ស៊ីខុសពេលខ្លះ ផឹកទឹកស្រវឹងខ្លះ ទ្រទ្រង់ផ្កាកម្រងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ រាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ កែក្រាយខ្លះ រាំជាមួយនឹងស្រីកំពុងរាំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងរាំខ្លះ ប្រគំជាមួយនឹងស្រីកំពុងរាំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងរាំខ្លះ រាំជាមួយនឹងស្រីកំពុងច្រៀងខ្លះ ច្រៀងជាមួយនឹងស្រីកំពុងច្រៀងខ្លះ ប្រគំជាមួយនឹងស្រីកំពុងច្រៀងខ្លះ កែក្រាយជាមួយនឹងស្រីកំពុងច្រៀងខ្លះ រាំជាមួយនឹងស្រីកំពុងប្រគំខ្លះ ច្រៀងជាមួយនឹងស្រីកំពុងប្រគំខ្លះ ប្រគំជាមួយនឹងស្រីកំពុងប្រគំខ្លះ កែក្រាយជាមួយនឹងស្រីកំពុងប្រគំខ្លះ រាំ

ជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ច្រៀងជាមួយនឹងស្រីកំពុងកែក្រាយខ្លះ ប្រគំជាមួយនឹងស្រីកំពុងកែក្រាយខ្លះ កែក្រាយជាមួយនឹងស្រីកំពុងកែក្រាយខ្លះ លេងបាស្កាមានក្រឡា ៨ ខ្លះ លេងបាស្កាមានក្រឡា ១០ ខ្លះ លេងបាស្កាក្នុងអាកាសខ្លះ លេងផ្លូវវាងដែលខ្លួនគួរវាងខ្លះ លេងផ្ងាត់គ្រាប់មានក្រួសជា-ដើមខ្លះ លេងបាស្កាក្នុងលានសម្រាប់លេងខ្លះ លេងហឹងខ្លះ លេងវលាស់ទឹកល័ក្តឲ្យទាយរូបខ្លះ លេងអង្គញ់ខ្លះ លេងផ្លុំប៉ីស្លឹកខ្លះ លេងកូននង្គ័លខ្លះ លេងដាំដូងខ្លះ លេងកង្ហារខ្លះ លេងវាល់ដីខ្សាច់ ( បាយឡុកបាយឡ ) ខ្លះ លេងដោយរថតូចខ្លះ លេងដោយធ្នូតូចខ្លះ លេងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ លេងទាយចិត្ត ( ស្តេចចង់ ) ខ្លះ លេងកំប្លែងត្រាប់គេខ្លះ ហាត់វិជ្ជាដំរីខ្លះ ហាត់វិជ្ជាសេះខ្លះ ហាត់វិជ្ជារថខ្លះ ហាត់វិជ្ជាធ្នូខ្លះ ហាត់ជងមានជងដាវជាដើមខ្លះ រត់ពីមុខដំរីខ្លះ រត់ទៅពីមុខសេះខ្លះ រត់ទៅពីមុខរថ រត់ទៅខ្លះ រត់ត្រឡប់មកខ្លះ ស្រែកហ៊ោខ្លះ ទះដៃខ្លះ ចំបាប់ខ្លះ ដាល់គ្នាខ្លះ ក្រាលសង្ឃាដិក្នុងកណ្តាលរោងរាំ ហើយនិយាយនឹងស្រីដែលរាំយ៉ាងនេះថា នែប្អូនស្រី នាងចូររាំក្នុងទីនេះចុះខ្លះ ដាក់ម្រាមដៃលើថ្ងាស ( ខ្លួននឹងថ្ងាសស្រីរបាំ ) ខ្លះ ប្រព្រឹត្តអនាចារផ្សេងទៀត ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់មនុស្សដែលមិនទាន់ជ្រះថ្លាហើយផង ។បេ។

[ ៣១៨ ] លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ដោយបរិយាយច្រើន ហើយព្រះអង្គសម្តែងធម្មីកថារួចទ្រង់ហៅព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរមក ហើយត្រាស់ថា ម្នាល

សារីបុត្រ និងមោគ្គល្លាន អ្នកទាំងឡាយ ចូរទៅកាន់កិដាគិរីជនបទ លុះទៅហើយ ចូរធ្វើបព្វាជនីយកម្ម[១] ភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកចេញពីកិដាគិរីជនបទ ( ព្រោះ ) ភិក្ខុអម្បាលនោះ ជាសទ្ធិវិហារិករបស់អ្នកទាំង-ឡាយ ។ ព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរក្រាបទូលសួរថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គទាំងឡាយ នឹងធ្វើបព្វាជនីយកម្មភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកចេញពីកិដាគិរីជនបទដូចម្ដេចបាន ( ព្រោះ ) ភិក្ខុទាំងនោះ ជាមនុស្សកាចអាក្រក់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលសារីបុត្រ និងមោគ្គល្លាន បើដូច្នោះអ្នកទាំងឡាយ ចូរទៅជាមួយនឹងភិក្ខុជាច្រើនរូប ។ ព្រះសារីបុត្តត្ថេរ និងព្រះមោគ្គល្លានត្ថេរ ទទួលស្ដាប់ព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគហើយឆ្លើយថា យ៉ាងហ្នឹងហើយព្រះអង្គ ។

[ ៣១៩ ] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវធ្វើយ៉ាងនេះគឺ ដំបូងពួកអ្នកត្រូវដាស់តឿនភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកសិន លុះដាស់តឿនហើយ គួរឲ្យរឭក លុះឲ្យរឭកហើយ គួរលើកអាបត្តិឡើង លុះលើកអាបត្តិឡើងហើយ ភិក្ខុដែលឆ្លាសអង់អាច គួរឲ្យសង្ឃដឹងដោយពាក្យថា បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្ដាប់ពាក្យខ្ញុំ ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកនេះ ជាអ្នកទ្រុស្ដត្រកូល គឺញុំាងសេចក្ដីជ្រះថ្លារបស់ត្រកូលឲ្យវិនាស ព្រោះសេចក្ដីប្រព្រឹត្តអាក្រក់ ។ សេចក្ដីប្រព្រឹត្តអាក្រក់របស់ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកនេះ ប្រាកដជាគេឃើញផង គេឮផង

---

១- ការបណ្ដេញភិក្ខុអលជ្ជី មិនប្រព្រឹត្តតាមធម៌ វិន័យឲ្យចេញពីទីកន្លែង ។

ម្យ៉ាងទៀត ត្រកូលទាំងឡាយដែលពួកភិក្ខុនេះទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង ។ បើបញ្ជាជនីយកម្មមានកាលគួរដល់សង្ឃហើយ សង្ឃត្រូវធ្វើបញ្ជាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ឲ្យចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃចូរស្តាប់ពាក្យខ្ញុំ ពួកភិក្ខុឈ្មោះអស្សជិនិងបុនព្វសុកជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ ។ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកអម្បាលនេះ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលភិក្ខុអម្បាលនេះទ្រុស្តហើយសោត ប្រាកដជាគេឃើញផង គេឮផង ។ សង្ឃធ្វើបញ្ជាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកឲ្យចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ ។ ការធ្វើបញ្ជាជនីយកម្មពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកឲ្យចេញពីកិដាគិរិជនបទថា ភិក្ខុទាំងឡាយជាពួកភិក្ខុអស្សជិ និងបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ សមគួរដល់លោកដ៏មានអាយុអង្គណា លោកអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកអង្គណា លោកអង្គនោះ ត្រូវពោលឡើង ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈពីរដងផង ។បេ។ ខ្ញុំសូត្រសេចក្តីនេះអស់វារៈបីដងផង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ។បេ។ លោកអង្គនោះត្រូវពោលឡើង ។ សង្ឃបានធ្វើបញ្ជាជនីយកម្ម ដល់ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកឲ្យចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ ។ ការធ្វើបញ្ជាជនីយកម្មនោះ

សមគួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀមនៅ ។ ខ្ញុំចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៣២០] លំដាប់នោះ ភិក្ខុសង្ឃមានព្រះសារីបុត្ត និងព្រះមោគ្គល្លានត្ថេរជាប្រធាន ទៅកាន់កិដាគិរិជនបទ ហើយបានធ្វើបព្វាជនីយកម្មដល់ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ចេញពីកិដាគិរិជនបទថា ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក មិនត្រូវនៅក្នុងកិដាគិរិជនបទទេ ។ ភិក្ខុអម្បាលនោះដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល មិនសម្ងបរោម គឺមិនព្រមតាម មិនព្រមប្រតិបត្តិតាមទំនងជាទីវៀរខ្លួនចេញ មិនអង្វរភិក្ខុទាំងឡាយឲ្យអត់ទោស ត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃថា សង្ឃលុះក្នុងសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីល្ងង់ សេចក្តីខ្លាច ហើយភិក្ខុទាំងនោះចៀសចេញទៅខ្លះ សឹកទៅខ្លះ ។ ពួកភិក្ខុណាប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ហេតុដូចម្តេច ក៏ពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល មិនសម្ងបរោម មិនព្រមប្រតិបត្តិតាមទំនងជាទីរលាស់ខ្លួនចេញ មិនអង្វរភិក្ខុទាំងឡាយឲ្យអត់ទោស ត្រឡប់ជាជេរប្រទេចបន្ទោសការកសង្ឃថា សង្ឃលុះក្នុងសេចក្តីស្រឡាញ់ សេចក្តីស្អប់ សេចក្តីល្ងង់ សេចក្តីខ្លាច ហើយភិក្ខុទាំងនោះចៀសចេញទៅខ្លះ សឹកទៅខ្លះ ។

[ ៣២១ ] លំដាប់នោះ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះហេតុនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុ

សង្ឃហើយត្រាស់សួរបញ្ជាក់ភិក្ខុទាំងឡាយក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុឈ្មោះអស្សជិ និងបុនព្វសុក ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល ។បេ។ ហើយភិក្ខុទាំងនោះសឹកទៅខ្លះ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានបុញ្ញសិរីតិះដៀលថា ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងនោះមិនសមគួរ ។បេ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេចក៏មោឃបុរសទាំងនោះ ដែលសង្ឃធ្វើបព្វាជនីយកម្មហើយ មិនប្រព្រឹត្តតាមដោយស្រួល ។បេ។ ភិក្ខុទាំងនោះសឹកទៅខ្លះ ម្នាលភិក្ខុទាំងឡាយ អំពើរបស់មោឃបុរសទាំងឡាយនេះ មិននាំឲ្យកើតសេចក្តីជ្រះថ្លា ដល់ជនទាំង-ឡាយដែលមិនទាន់ជ្រះថ្លាហើយផង ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយគប្បីសម្តែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុចូលទៅជិតអាស្រ័យស្រុក ឬនិគម កន្លែងណាមួយ ហើយនៅ ជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ ។ សេចក្តីប្រព្រឹត្តអាក្រក់របស់ភិក្ខុនោះឯង ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលភិក្ខុនោះទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយស្តីឲ្យយ៉ាងនេះថា លោកដ៏មានអាយុជាអ្នកទ្រុស្តត្រកូល មានសេចក្តីប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយដែលលោកដ៏មានអាយុទ្រុស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរ

នៅក្នុងទីនេះទេ ។ ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ ត្រឡប់ថាឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះវិញថា ភិក្ខុទាំងឡាយលុះក្នុងសេចក្ដីស្រឡាញ់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្ដីខឹងផង ភិក្ខុទាំងឡាយលុះក្នុងសេចក្ដីល្ងង់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្ដីខ្លាចផង ( ព្រោះ ) ភិក្ខុទាំង-ឡាយនោះ បណ្ដេញភិក្ខុពួកខ្លះ មិនបណ្ដេញភិក្ខុពួកខ្លះ ដោយអាបត្តិដូចគ្នាទេ ។ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះថា លោកដ៏មានអាយុ ចូរកុំនិយាយយ៉ាងនេះ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្ដីស្រឡាញ់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្ដីស្អប់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្ដីល្ងង់ ភិក្ខុទាំងឡាយមិនលុះក្នុងសេចក្ដីខ្លាច លោកដ៏មានអាយុឯង ជាអ្នកទ្រុស្តត្រកូល មានសេចក្ដីប្រព្រឹត្តអាក្រក់ សេចក្ដីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុទ្រុស្តហើយ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុ ចូរចៀសចេញចាកអាវាសនេះទៅ លោកកុំនៅក្នុងអាវាសនេះ ។ ភិក្ខុនោះដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះនៅតែប្រកាន់លទ្ធិយ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយ សូត្រសមនុភាសនកម្មប្រកាសហាម ដើម្បីឲ្យលះបង់អំពើអាក្រក់នោះកំណត់បីដង ។ ភិក្ខុនោះ បើភិក្ខុទាំងឡាយសូត្រសមនុ-ភាសនកម្មកំណត់បីដង លះអំពើអាក្រក់នោះបាន សេចក្ដីលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិសង្ឃាទិសេស ។

[ ៣២២ ] ត្រង់ពាក្យថា ភិក្ខុ ( ចូលទៅជិតអាស្រ័យនៅ ) ស្រុក ឬ

និគម កន្លែងណាមួយ សេចក្តីថា ស្រុកក្តី និគមក្តី នគរក្តី ក៏គឺស្រុក គឺនិគមហ្នឹងឯង ។ ពាក្យថា ចូលទៅជិតអាស្រ័យនៅ ( គឺភិក្ខុចូលទៅជិតអាស្រ័យនៅក្នុងស្រុកនិគមណា ) ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារជាប់ចំពោះមាននៅហើយ ក្នុងស្រុក និងនិគមនោះ ។ ត្រកូល ៤ ពួក គឺត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ត្រកូលអ្នកឈ្មួញ ( ត្រកូលអ្នករកស៊ីធម្មតា ) ត្រកូលអ្នកគ្រួ ( អ្នកស៊ីឈ្នួល ) ហៅថាត្រកូល ។ ពាក្យថា ជាអ្នកទ្រុស្តត្រកូល គឺភិក្ខុទ្រុស្តត្រកូលទាំងឡាយដោយ ( ឲ្យ ) ផ្កាខ្លះ ( ឲ្យ ) ផ្លែខ្លះ ( ឲ្យ ) គ្រឿងលំអិតសម្រាប់ងូតខ្លះ ( ឲ្យ ) ដីស្អិតខ្លះ ( ឲ្យ ) ឈើស្ទន់ខ្លះ ( ឲ្យ ) ឫស្សីខ្លះ ដោយកិរិយាធ្វើពេទ្យខ្លះ ដោយការបម្រើដោយស្មងខ្លះ ។ ពាក្យថា មានសេចក្តីប្រព្រឹត្តអាក្រក់ គឺភិក្ខុដាំកូនឈើផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះ ស្រោចខ្លួនឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ បេះខ្លួនឯងខ្លះ ប្រើគេឲ្យបេះខ្លះ ក្រងខ្លួនឯងខ្លះ ប្រើគេឲ្យក្រងខ្លះ ។

[ ៣២៣ ] ពាក្យថា ប្រាកដជាគេឃើញផង គេឮផង គឺអ្នកណានៅក្នុងទីចំពោះមុខ អ្នកនោះឃើញ អ្នកណានៅក្នុងទីកំបាំងមុខ អ្នកនោះឮ ។ ពាក្យថា ត្រកូលទាំងឡាយសោត ដែលភិក្ខុនោះទ្រុស្តហើយ គឺពីមុនមនុស្សទាំងឡាយមានសទ្ធា ឥឡូវនេះជាមនុស្សមិនមានសទ្ធាវិញ ធ្លាប់ជ្រះថ្លាលែងជ្រះថ្លាទៅវិញ ព្រោះអាស្រ័យនឹងភិក្ខុនោះ ។ ពាក្យថា ប្រាកដជាគេឃើញផង គេឮផង គឺអ្នកណានៅក្នុងទីចំពោះមុខ អ្នកនោះឃើញ អ្នកណានៅក្នុងទីកំបាំងមុខ អ្នកនោះឮ ។

[ ៣២៤ ] ពាក្យថា ភិក្ខុនោះ គឺភិក្ខុណាមួយជាអ្នកទ្រុស្តត្រកូល ។ ពាក្យថា គឺភិក្ខុទាំងឡាយ បានដល់ភិក្ខុទាំងឡាយដទៃ ។ ភិក្ខុទាំងឡាយណាឃើញ ណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយប្រដៅថា លោកដ៏មានអាយុជាអ្នកទ្រុស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោតដែលលោកដ៏មានអាយុទ្រុស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុ ចូរចៀសចេញពីអាវាសនេះ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ ម្យ៉ាងទៀត ភិក្ខុនោះ ដែលភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះហើយ ត្រឡប់ថាឲ្យភិក្ខុទាំងឡាយនោះយ៉ាងនេះថា ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្រឡាញ់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីស្អប់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីល្ងង់ផង ភិក្ខុទាំងឡាយលុះក្នុងសេចក្តីខ្លាចផង ទើបបណ្តេញភិក្ខុពួកខ្លះ មិនបណ្តេញភិក្ខុពួកខ្លះ ព្រោះអាបត្តិដូចគ្នាទេ ។

[ ៣២៥ ] ពាក្យថា ភិក្ខុនោះ គឺភិក្ខុដែលបានធ្វើកម្មនោះ ។ ពាក្យថា គឺភិក្ខុទាំងឡាយ បានដល់ភិក្ខុទាំងឡាយឯទៀត ។ ភិក្ខុណាឃើញ ភិក្ខុណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយប្រដៅថា លោកដ៏មានអាយុចូរកុំនិយាយយ៉ាងនេះ ភិក្ខុទាំងឡាយមិនលុះក្នុងឆន្ទាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងទោសាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងមោហាគតិ ភិក្ខុទាំងឡាយមិនលុះក្នុងភយាគតិ លោកដ៏មានអាយុ ជាអ្នកទ្រុស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុទ្រុស្តហើយ ប្រាកដជាគេ

ឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ ភិក្ខុទ្រុស្តត្រកូលនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយប្រដៅអស់វារៈជាគម្រប់ពីរដងផង ត្រូវនិយាយប្រដៅអស់វារៈជាគម្រប់បីដងផង ។ បើភិក្ខុនោះលះបង់ ( កម្មនោះ ) បាន ការលះបាននោះជាការល្អ បើភិក្ខុនោះមិនលះបង់ទេ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ពួកភិក្ខុឮហើយមិននិយាយប្រដៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុ ( ទ្រុស្តត្រកូល ) នោះ គឺភិក្ខុទាំងឡាយត្រូវទាញមកកាន់ទីកណ្តាលសង្ឃ ហើយនិយាយប្រដៅថា លោកដ៏មានអាយុ កុំពោលពាក្យយ៉ាងនេះ ភិក្ខុទាំងឡាយ មិនមែនលុះក្នុងឆន្ទាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងទោសាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងមោហាគតិទេ ភិក្ខុទាំងឡាយមិនមែនលុះក្នុងភយាគតិទេ លោកដ៏មានអាយុ ជាអ្នកទ្រុស្តត្រកូល ជាអ្នកប្រព្រឹត្តអាក្រក់ សេចក្តីប្រព្រឹត្តអាក្រក់របស់លោកដ៏មានអាយុ ប្រាកដជាគេឃើញផង គេឮផង ត្រកូលទាំងឡាយសោត ដែលលោកដ៏មានអាយុទ្រុស្តហើយនោះ ប្រាកដជាគេឃើញផង គេឮផង លោកដ៏មានអាយុចូរចៀសចេញពីអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ ភិក្ខុនោះ គឺភិក្ខុទាំងឡាយត្រូវនិយាយប្រដៅអស់វារៈជាគម្រប់ពីរដងផង ត្រូវនិយាយប្រដៅអស់វារៈជាគម្រប់បីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើភិក្ខុនោះលះបង់មិនបានទេ ត្រូវអាបត្តិទុក្កដ ។

[ ៣២៦ ] ភិក្ខុនោះសង្ឃត្រូវសូត្រប្រកាសហាម ។ ម្នាលភិក្ខុទាំង-

ឡាយ ភិក្ខុនោះ សង្ឃត្រូវសូត្រប្រកាសហាមយ៉ាងនេះ ។ ភិក្ខុដ៏ឆ្លាសអង់អាចត្រូវប្រកាសសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ភិក្ខុនេះ មានឈ្មោះនេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជាបន្ទោសភិក្ខុសង្ឃថា ភិក្ខុសង្ឃលុះក្នុងឆន្ទាគតិ លុះក្នុងទោសាគតិ លុះក្នុងមោហាគតិ លុះក្នុងភយាគតិ ។ ភិក្ខុ ( អ្នកទ្រុស្តត្រកូល ) នោះ មិនលះបង់វត្ថុនោះ ។ បើកម្មរបស់សង្ឃមានកាលដ៏គួរដល់ហើយ សង្ឃគប្បីសូត្រប្រកាសហាមភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ ។ នេះញត្តិ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ភិក្ខុនេះមានឈ្មោះនេះ សង្ឃបានធ្វើបព្វាជនីយកម្មហើយ ត្រឡប់ជាបន្ទោសភិក្ខុសង្ឃថា ភិក្ខុសង្ឃ លុះក្នុងសេចក្តីស្រឡាញ់ លុះក្នុងសេចក្តីស្អប់ លុះក្នុងសេចក្តីល្ងង់ លុះក្នុងសេចក្តីខ្លាច ។ ភិក្ខុ ( អ្នកទ្រុស្តត្រកូល ) នោះ មិនលះបង់វត្ថុនោះ ។ សង្ឃសូត្រសមនុភាសនកម្ម ( ប្រកាសហាម ) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ ។ ការសូត្រសមនុភាសនកម្ម ( ប្រកាសហាម ) ភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់វត្ថុនោះ សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំពោលសេចក្តីនេះអស់វារៈពីរដងផង ។បេ។ ខ្ញុំពោលសេចក្តីនេះអស់វារៈបីដងផង ។ បពិត្រព្រះសង្ឃដ៏ចម្រើន សង្ឃសូមស្តាប់ពាក្យខ្ញុំ ។បេ។ លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ភិក្ខុឈ្មោះនេះ សង្ឃសូត្រសមនុភាសនកម្ម ( ប្រកាសហាម ) ដើម្បីឲ្យលះបង់វត្ថុនោះហើយ ។ សមនុភាសនកម្មនោះ សមគួរដល់សង្ឃហើយ ហេតុនោះ សង្ឃ

ស្មៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្មៀមនៅយ៉ាងនេះ ។

[ ៣២៧ ] ( កាលសង្ឃ ) សូត្រញត្តិចប់ ( ភិក្ខុអ្នកទ្រុស្តត្រកូលនោះ ) ត្រូវអាបត្តិទុក្កដ ( កាលសង្ឃ ) សូត្រកម្មវាចាចប់ជាគម្រប់ពីរដង ( ភិក្ខុអ្នកទ្រុស្តត្រកូលនោះ ) ត្រូវអាបត្តិថុល្លច្ច័យ ( កាលសង្ឃ ) សូត្រកម្មវាចាចប់ ( ភិក្ខុអ្នកទ្រុស្តត្រកូលនោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។ កាលបើភិក្ខុនោះ ត្រូវអាបត្តិសង្ឃាទិសេសហើយ ឯអាបត្តិទុក្កដដែលភិក្ខុនោះត្រូវក្នុងខណៈចប់ញត្តិក្តី និងអាបត្តិថុល្លច្ច័យទាំងឡាយដែលភិក្ខុនោះត្រូវក្នុងខណៈចប់កម្មវាចា ជាគម្រប់ពីរដងក្តី ក៏តែងរម្ងាប់ទៅឯង ។ ត្រង់ពាក្យថា សង្ឃាទិសេស គឺសង្ឃ[1]ពិត ទើបឲ្យបរិវាសដើម្បីអាបត្តិនោះ បានរើចេញចាកអាបត្តិខាងដើម ឲ្យនូវមានត្ត សូត្រអព្ភាន ( រាប់ភិក្ខុនោះចូលពួកកង ) គណៈ[2] ឲ្យមិនបាន បុគ្គល[3]ម្នាក់ឲ្យមិនបាន ហេតុនោះ ព្រះដ៏មានព្រះភាគត្រាស់ថា សង្ឃាទិសេស ។ នាមកម្ម[4] ជាឈ្មោះពួកអាបត្តិនោះឯង ហេតុនោះបានជាព្រះដ៏មានព្រះភាគត្រាស់ថា សង្ឃាទិសេស ។

[ ៣២៨ ] ភិក្ខុសម្គាល់ក្នុងកម្មប្រកបដោយធម៌ ថាកម្មប្រកបដោយធម៌ តែមិនលះបង់ ( សេចក្តីប្រព្រឹត្តអាក្រក់នោះ ) ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងកម្មប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិ

---

១- ភិក្ខុ ៤ រូបឡើងទៅ ហៅថា សង្ឃ ។ ២- ភិក្ខុ ២ រូប ឬ ៣ រូប ហៅថា គណៈ ។ ៣- សំដៅយកភិក្ខុតែមួយរូប ។ ៤- ពួកអាបត្តិទាំង ១៣ សិក្ខាបទ តាំងអំពីសញ្ចេតនិកសិក្ខាបទ រហូតដល់កុលទូសកសិក្ខាបទនោះ ព្រះដ៏មានព្រះភាគឲ្យឈ្មោះថា សង្ឃាទិសេស ។

សង្ឃាទិសេស ។ ភិក្ខុសម្គាល់ក្នុងកម្មប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ មិនលះបង់ ត្រូវអាបត្តិសង្ឃាទិសេស ។ ភិក្ខុសម្គាល់ក្នុងកម្មមិនប្រកបដោយធម៌ថា កម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសម្គាល់ក្នុងកម្មមិនប្រកបដោយធម៌ ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[ ៣២៩ ] អាបត្តិមិនមាន ដល់ភិក្ខុដែលសង្ឃមិនទាន់សូត្រសមនុភាសនកម្ម ដល់ភិក្ខុដែលបានលះបង់ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុមានចិត្តរវើរវាយ ដល់ភិក្ខុមានទុក្ខវេទនាគ្របសង្កត់ ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សង្ឃាទិសេសទី ១៣ ចប់

[ ៣៣០ ] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិទាំងឡាយឈ្មោះសង្ឃាទិសេសទាំង ១៣ ខ្ញុំសម្តែងឡើងហើយ អាបត្តិទាំងឡាយ ៩ ហៅថា បឋមាបត្តិកា គឺត្រូវអាបត្តិក្នុងវេលាធ្វើឲ្យកន្លងបញ្ញត្តិជាដំបូង អាបត្តិទាំងឡាយ ៤ ហៅថា យាវតតិយកា គឺត្រូវអាបត្តិក្នុងវេលាដែលសង្ឃសូត្រប្រកាសហាមជាគម្រប់បីដង ហើយមិនលះបង់ការអាក្រក់នោះ បណ្តាអាបត្តិទាំង ១៣ បើភិក្ខុណាត្រូវអាបត្តិណានីមួយ ហើយដឹងច្បាស់ បិទបាំងទុកអស់ប៉ុន្មានថ្ងៃ ភិក្ខុនោះ ត្រូវនៅបរិវាសអស់ប៉ុណ្ណោះថ្ងៃ ព្រោះខ្លួនមិនមានសេចក្តីប្រាថ្នានឹងនៅបរិវាស ។ ភិក្ខុដែលនៅបរិវាសហើយ ត្រូវប្រព្រឹត្តភិក្ខុមានត្ត[១]

---

១- កម្មជាគ្រឿងប្រព្រឹត្តដើម្បីឲ្យជាទីរាប់អានរបស់ភិក្ខុ ។

អស់ ៦ រាត្រីតទៅទៀត ។ ភិក្ខុប្រព្រឹត្តមានត្តហើយ ភិក្ខុសង្ឃពួក ២០ រូប មានក្នុងទីណា ភិក្ខុនោះ គឺភិក្ខុសង្ឃពួក ២០ រូបគប្បីឲ្យអព្ភាន(១)កម្មក្នុងទីនោះ ។ បើភិក្ខុសង្ឃមិនគ្រប់ ២០ រូបទេ សូម្បីខ្វះតែមួយរូប ហើយខំតែឲ្យអព្ភានកម្មដល់ភិក្ខុនោះ ។ ឯភិក្ខុនោះ មិនបានឈ្មោះថា សង្ឃឲ្យអព្ភានកម្មផង ទាំងពួកភិក្ខុ ( ជាការកសង្ឃ ) នោះ ឈ្មោះថា ត្រូវព្រះពុទ្ធជាម្ចាស់តិះដៀលបានផង ។ សេចក្តីប្រតិបត្តិនេះ ជាការដ៏សមគួរក្នុងកម្មនោះ ។ ខ្ញុំសូមសួរលោកដ៏មានអាយុទាំងឡាយក្នុងរឿងនោះ លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ ខ្ញុំសួរអស់វារៈពីរដងផង លោកទាំងឡាយជាភិក្ខុបរិសុទ្ធហើយឬ ខ្ញុំសួរអស់វារៈបីដងផង លោកទាំងឡាយ ជាភិក្ខុបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយ ជាភិក្ខុបរិសុទ្ធក្នុងរឿងនេះហើយ ហេតុនោះបានជាស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវដំណើរនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

សង្ឃាទិសេសទាំង ១៣ ចប់

## បញ្ជីរឿងនៃសង្ឃាទិសេសនោះ

## សង្ឃាទិសេសទាំង ១៣ គឺ

| | | |
|---|---|---|
| វិសដ្ឋិ | ការបញ្ចេញទឹកសុក្ក | ១ |
| កាយសំសគ្គោ | ស្ទាបអង្អែលកាយស្រី | ១ |
| ទុដ្ឋុល្លំ | ពោលពាក្យអាក្រក់ | ១ |
| អត្តកាមំ | ឲ្យស្រីបម្រើខ្លួនដោយកាម | ១ |
| សញ្ចរិត្តំ | ដឹកនាំបុរសស្ត្រីឲ្យបានគ្នាជាប្តីប្រពន្ធ | ១ |
| កុដិ | ធ្វើកុដិ | ១ |
| វិហារោ | ធ្វើលំនៅ | ១ |
| អមូលកំ | ចោទដោយអាបត្តិរកដើមហេតុគ្មាន | ១ |
| កិញ្ចិលេសំ | ចោទអាងលេសនីមួយ | ១ |
| ភេទោ | បំបែកសង្ឃ | ១ |
| តស្សេវអនុវត្តកា | ពួកភិក្ខុប្រព្រឹត្តតាមភិក្ខុអ្នកបំបែកសង្ឃនោះឯង | ១ |
| ទុព្វចំ | ប្រដៅក្រ | ១ |
| កុលទូសំ | ទ្រុស្តត្រកូល | ១ |

---

២- កម្មដែលសង្ឃសូត្រប្រកាសហៅភិក្ខុដែលបានបរិវាសហើយនោះ មកបញ្ចូលជាពួកវិញ ។

# អដ្ឋកថា

## កុលទូសកសិក្ខាបទវណ្ណនា

[ ៣១៤ ] កុលទូសកសិក្ខាបទ បទថា **តេន សមយេន ពុទ្ធោ ភគវា** ជាដើម ខ្ញុំនឹងពោលតទៅ ក្នុងកុលទូសកសិក្ខាបទនោះ មានវិនិច្ឆ័យដូច្នេះថា

បទថា **អស្សជិបុនព្វសុកា នាម** បានដល់ ភិក្ខុឈ្មោះអស្សជិ និង បុនព្វសុក ។ បទថា **កិដាគិរិស្មឹ** បានដល់ ក្នុងជនបទដែលមានឈ្មោះ យ៉ាងនោះ ។ ក្នុងបទថា **អាវាសិកា ហោន្តិ** នេះ មានវិនិច្ឆ័យដូច្នេះថា អាវាសរបស់ភិក្ខុទាំងនេះមាន ហេតុនោះ ទើបភិក្ខុទាំងនេះឈ្មោះថា អាវាសិក ( មេវត្ត ) ។ វិហារលោកហៅថា អាវាស ។ វិហារនោះទាក់ទងដល់ភិក្ខុពួកណា ដោយភាពជាអ្នកដើរមុខ មានការកសាងវត្ថុថ្មីៗ និងការជួសជុលរបស់ចាស់ជាដើម ភិក្ខុទាំងនោះឈ្មោះថា **អាវាសិក។** តែភិក្ខុពួកណាត្រឹមតែនៅក្នុងវិហារតែម្យ៉ាង ភិក្ខុទាំងនោះ លោកហៅថា **នេវាសិក** ( មេកុដិ ) ។ អស្សជិ និងបុនព្វសុកនេះបានជាមេវត្ត ។

ពីរបទថា **អលជ្ជិនោ បាបភិក្ខូ** បានដល់ ជាពួកភិក្ខុលាមក មិនមានការខ្មាស ។ ព្រោះថា អស្សជិ និងបុនព្វសុកភិក្ខុនោះ ជាមេឆព្វគ្គិយ នៃឆព្វគ្គិយភិក្ខុទាំងឡាយ ។

## ប្រវត្តិរបស់ឆព្វគ្គិយភិក្ខុ

បានឮថា ជន ៦ នាក់ ( គឺបណ្ឌុកៈ ១ លោហិតកៈ ១ មេត្តិយ ១ កុម្មជក ១ អស្សជិ ១ បុនព្វសុក ១ ) ក្នុងក្រុងសាវត្ថី ជាសម្លាញ់នឹងគ្នា

ប្រឹក្សាគ្នាថា ការធ្វើកសិកម្មជាដើម ជាការងារដែលលំបាក ណ្ហើយចុះ សម្លាញ់ទាំងឡាយ ពួកយើងនាំគ្នាបួស ហើយពួកយើងកាលនឹងបួស គួរបួសក្នុងឋានៈជាអ្នកជួយរលាស់ចេញ ក្នុងកាលមានកិច្ចកើតឡើង ដូច្នេះហើយ បានបួសក្នុងសម្នាក់នៃអគ្គសាវកទាំងពីរ ។ ពួកលោកមានវស្សាគ្រប់ ៥ ទន្ទេញមាតិកាបានស្ទាត់ហើយ ប្រឹក្សាគ្នាថា ជម្ពូតាជនបទ គ្រាខ្លះ ក៏មានភិក្ខាសម្បូរ គ្រាខ្លះមានភិក្ខាអត្តខាត់ ពួកយើង កុំនៅរួមគ្នាក្នុងទីជាមួយគ្នាឡើយ ចូរបែកគ្នានៅក្នុងទី ៣ កន្លែង លំដាប់នោះ ទើបពួកលោកពោលនឹងភិក្ខុឈ្មោះបណ្ឌុកៈ និងលោហិតកៈថា លោកដ៏មានអាយុទាំងឡាយ ឈ្មោះថាក្រុងសាវត្ថី មានត្រកូល ៥ លាន ៧ សែនត្រកូលនៅគ្រប់គ្រង ជាប្រកនៃការរីកចម្រើនរបស់ដែនកាសី និងកោសលទាំងពីរ ទំហំប្រមាណ ៣០០ យោជន៍ ប្រដាប់ដោយភូមិ ៨ ម៉ឺនតំបន់ ពួកលោកចូរសាងសម្នាក់ក្នុងទីកន្លែងជិតៗ ក្រុងសាវត្ថីនោះឯង ហើយដាំស្វាយ ខ្នុរ និងដូងជាដើម សង្គ្រោះត្រកូលដោយផ្កា និងផ្លែឈើទាំងនោះ ឲ្យពួកក្មេងរបស់ត្រកូលបួស ហើយពង្រីកបរិស័ទឲ្យចម្រើនចុះ ។

ពោលនឹងពួកភិក្ខុឈ្មោះមេត្តិយ និងភុម្មជកថា លោកដ៏មានអាយុ ឈ្មោះថា ក្រុងរាជគ្រឹះ មានមនុស្ស ១៨ កោដិនៅគ្រប់គ្រង ជាប្រកនៃការចម្រើនរបស់ដែនអង្គៈ និងមគធៈទាំងពីរ ទំហំ ៣០០ យោជន៍ ប្រដាប់ដោយភូមិ ៨ ម៉ឺនតំបន់ ពួកលោកចូរសាងសម្នាក់ក្នុងទីជិតៗ ក្រុងរាជគ្រឹះនោះហើយដាំស្វាយ ខ្នុរ និងដូងជាដើម សង្គ្រោះត្រកូលដោយផ្កា និងផ្លែឈើទាំងនោះ ឲ្យពួកក្មេងកំលោះរបស់ត្រកូលបួស ហើយពង្រីកបរិស័ទឲ្យចម្រើនចុះ។

ពោលនឹងភិក្ខុឈ្មោះអស្សជិ និងបុនព្វសុកថា លោកដ៏មានអាយុ ឈ្មោះថា កិដាគិរីជនបទ ដែលមេឃ ( ភ្លៀង ) ២ រដូវ អំណោយផលហើយ រមែងបានស្រូវ ៣ ដង ពួកលោកចូរសាងសម្នាក់ក្នុងទីជិតៗ កិដាគិរីជនបទនោះឯង ដាំស្វាយ ខ្នុរ និងដូងជាដើម សង្គ្រោះត្រកូលដោយផ្កា និងផ្លែឈើទាំងនោះ ឲ្យពួកយុវជនរបស់ត្រកូលបួស ហើយពង្រីកបរិស័ទឲ្យចម្រើនចុះ ។

ពួកឆព្វគ្គិយភិក្ខុបានធ្វើយ៉ាងនោះហើយ បណ្ដាពួកភិក្ខុឆព្វគ្គិយទាំងនោះ មួយចំណែកៗ មានភិក្ខុជាបរិវារ ៥០០ អង្គ រួមជាចំនួនភិក្ខុ ១៥០០ អង្គ ជាង ដោយប្រការយ៉ាងនេះ ។

បណ្ដាភិក្ខុទាំងនោះ ភិក្ខុឈ្មោះបណ្ឌុកៈ និងលោហិតកៈ ព្រមទាំងបរិវារជាអ្នកមានសីល ត្រាច់ទៅកាន់ជនបទ ចារិករួមជាមួយព្រះមានព្រះភាគ ។ ពួកលោកញុំាងឲ្យកើតរឿងថ្មីៗ ដែលនៅមិនទាន់មាននរណាធ្វើ តែមិនញុំាញីសិក្ខាបទដែលព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ ។ ឯពួកឆព្វគ្គិយភិក្ខុក្រៅអំពីនេះទាំងអស់ ជាអលជ្ជី រមែងញុំាងឲ្យកើតរឿងថ្មីៗ ដែលមិនធ្លាប់មាននរណាធ្វើផង រមែងនាំគ្នាញុំាញីសិក្ខាបទដែលទ្រង់បញ្ញត្តហើយផង ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកៈទាំងឡាយ ពោលថា **អលជ្ជិនោ ចាបភិក្ខូ** ដូច្នេះ ។

បទថា **ឯវរូបំ** បានដល់ មានកំណើតយ៉ាងនេះ ។

ពីរបទថា **អនាចារំ អាចរន្តិ** សេចក្ដីថា រមែងប្រព្រឹត្តកន្លងមារយាទដែលមិនគួរប្រព្រឹត្ត គឺធ្វើវត្ថុដែលមិនគួរធ្វើ ។

បទថា **មាលាវច្ឆំ** បានដល់ ដើមឈើ មានផ្កាក្រពុំ ។

ពិតហើយ ដើមឈើផ្កាក្តី គុម្ពឈើផ្កាក្តី ដែលផ្កានៅក្រពុំ លោកហៅថា គុម្ពផ្កាទាំងអស់ ។ ភិក្ខុទាំងនោះ ដាំឯងខ្លះ ឲ្យអ្នកដទៃដាំខ្លះ នូវគុម្ពផ្កាមានប្រភេទផ្សេងៗ គ្នាជាច្រើន ។ ដោយហេតុនោះ ទើបធម្មសង្គាហកៈទាំងឡាយពោលថា **មាលាវច្ឆំ រោបេន្តិបិ រោបាបេន្តិបិ** ដូច្នេះ ។

បទថា **សិញ្ចន្តិ** បានដល់ រមែងស្រោចទឹកឯងខ្លះ ។

បទថា **សិញ្ចាបេន្តិ** បានដល់ រមែងប្រើឲ្យអ្នកដទៃស្រោចខ្លះ ។

## លក្ខណៈ ៥ មានអកប្បិយវោហារជាដើម

ក្នុងអធិការនេះ អ្នកសិក្សាគប្បីជ្រាបលក្ខណៈ ៥ យ៉ាង គឺអកប្បិយ-វោហារ ១ កប្បិយវោហារ ១ បរិយាយ ១ ឱកាស ១ និមិត្តកម្ម ១ ។ បណ្តាលក្ខណៈ ៥ នោះ ឈ្មោះថា **អកប្បិយវោហារ** បានដល់ ការកាត់ឯង ការប្រើឲ្យកាត់ប្រភេទរបស់ពណ៌ខៀវ ការជីកឯង ការប្រើឲ្យជីករណ្តៅ ការដាំឯង ការប្រើឲ្យដាំគុម្ពផ្កា ការពូនឯង ការឲ្យពូនទំនប់ការពារ ការស្រោចទឹកឯង ការឲ្យស្រោចទឹក ការធ្វើប្រឡាយឲ្យត្រង់ទៅ ការស្រោចទឹកដែលជាកប្បិយៈ ការស្រោចដោយទឹកលាងដៃ លាងមុខ លាងជើង និងងូត ។ ដែលឈ្មោះថា **កប្បិយវោហារ** បានដល់ ពាក្យថា ចូរដឹងដើមឈើនេះ ចូរដឹងរណ្តៅនេះ ចូរដឹងគុម្ពផ្កានេះ ចូរដឹងទឹកក្នុងទីនេះ និងការធ្វើប្រឡាយទឹកដែលស្ងួតឲ្យត្រង់ ។

ដែលឈ្មោះថា **បរិយាយ** បានដល់ មានពាក្យជាដើមថា បណ្ឌិតគួរឲ្យដាំដើមឈើទាំងឡាយ មានឈើផ្កាជាដើម នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍

ចំពោះកាលមិនយូរឡើយ ។

ដែលឈ្មោះថា **ឱភាស** បានដល់ ការឈរកាន់ចប និងចបជីកជាដើម និងគុម្ពផ្កាទាំងឡាយ ។ ពិតហើយ ពួកសាមណេរជាដើម ឃើញព្រះថេរៈឈរនៅយ៉ាងនោះដឹងថា ព្រះថេរៈបំណងឲ្យធ្វើ ហើយនឹងមកធ្វើឲ្យ ។

ដែលឈ្មោះថា **និមិត្តកម្ម** បានដល់ នាំយកចប ចបជីក កាំបិតពូថៅ និងភាជនៈទឹក មកទុកក្នុងទីជិតៗ ។

លក្ខណៈទាំង ៥ ប្រការនេះ រមែងមិនគួរក្នុងការដាំដើម្បីជាប្រយោជន៍ដល់ការសង្គ្រោះត្រកូល ។ ដើម្បីប្រយោជន៍ដល់ការបរិភោគផ្លែ កិច្ច ២ យ៉ាង គឺអកប្បិយវោហារ និងកប្បិយវោហារប៉ុណ្ណោះ មិនគួរ ។ កិច្ច ៣ យ៉ាងដទៃក្រៅអំពីនេះ គួរ ។ តែក្នុងមហាបច្ចរីពោលថា សូម្បីកប្បិវោហារក៏គួរ ។ ហើយការដាំណា រមែងគួរដើម្បីប្រយោជន៍ដល់ការបរិភោគរបស់ខ្លួន ការដាំនោះ ក៏គួរដើម្បីប្រយោជន៍ដល់បុគ្គលដទៃដល់សង្ឃ ឬដល់ចេតិយផងដែរ ។ តែការប្រើឲ្យដាំដើម្បីអារាម ដើម្បីព្រៃ និងដើម្បីម្លប់ អកប្បិ-វោហារតែម្យ៉ាងប៉ុណ្ណោះ មិនសមគួរ ។ លក្ខណៈដ៏សេស គួរ ។ និងមិនមែនគួរតែកិច្ចដ៏សេសតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីការធ្វើប្រឡាយឲ្យត្រង់ក្តី ការស្រោចទឹកដែលជាកប្បិយក្តី ធ្វើបន្ទប់ទឹកហើយងូតឯងក្តី និងការចាក់ទឹកលាងដៃ លាងជើង និងលុបមុខ ចុះក្នុងទីដាំដើមឈើនោះក្តី ឯណានីមួយរមែងគួរ ។ តែក្នុងមហាបច្ចរី និងកុរុន្ទីពោលថា សូម្បីដាំឯងក្នុងកប្បិយបឋវីក៏គួរ ។ សូម្បីបរិភោគផ្លែឈើដែលដាំឯងក្តី ប្រើអ្នកដទៃឲ្យដាំដើម្បីប្រយោជន៍

ដល់អារាមជាដើមក្តី ក៏គួរ ។ ក្នុងការបេះឯង និងក្នុងការប្រើឲ្យអ្នកដទៃឲ្យបេះតាមប្រក្រតី ក៏ត្រូវអាបត្តិបាចិត្តិយ ។ តែ ( ក្នុងការបេះ និងក្នុងការប្រើឲ្យបេះ ) ដើម្បីសង្គ្រោះត្រកូល ត្រូវអាបត្តិបាចិត្តិយផង ទុក្កដផង ។ ក្នុងការក្រងផ្កា មានការក្រងឲ្យមានទងតែម្ខាងជាដើម មានកម្រងផ្កាសម្រាប់ប្រដាប់ទ្រូងខាងចុងបំផុត ត្រូវអាបត្តិទុក្កដតែម្យ៉ាងដល់ភិក្ខុ ដែលធ្វើដើម្បីសង្គ្រោះត្រកូល ឬដើម្បីប្រការដទៃ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាអនាចារ និងព្រោះជាបាបសមាចារ ដូចត្រាស់ទុកក្នុងពាក្យថា **ចាបសមាចារោ** នេះ ។

បើចោទសួរថា ហេតុអ្វី ក្នុងការដាំដើមឈើ ដើម្បីប្រយោជន៍ដល់ការបូជាព្រះរតនត្រ័យ ទើបមិនជាអនាបត្តិ ដូចក្នុងការដាំដើម្បីប្រយោជន៍ដល់អារាមជាដើម ឆ្លើយថា ជាអនាបត្តិដូចគ្នា ដូចក្នុងការដាំដើមឈើដើម្បីប្រយោជន៍ដល់អារាមជាដើមនោះ ជាអនាបត្តិ ព្រោះកប្បិយវោហារ និងអាការមានបរិយាយជាដើម យ៉ាងណា សូម្បីក្នុងការដាំដើមឈើដើម្បីប្រយោជន៍ដល់ការបូជាព្រះរតនត្រ័យ ក៏គង់ជាអនាបត្តិ ដូច្នោះ ។

សួរថា ក្នុងការដាំដើមឈើនោះ សូម្បីដាំឯង ក្នុងកប្បិយបឋវី សមគួរមិនមែនឬ ឆ្លើយថា ពាក្យនោះ លោកពោលហើយ ក្នុងមហាបច្ចរី និងកុរុន្ទី តែក្នុងមហាអដ្ឋកថា មិនបានពោលទុកទេ ។ ទោះបីលោកធ្លាប់ថា ពាក្យដែលពោលហើយ ក្នុងអដ្ឋកថាក្រៅអំពីនេះ ជាប្រមាណបានពិត តែការស្រោចទឹកដែលជាកប្បិយ លោកបានពោលទុកក្នុងមហាអដ្ឋកថា ការស្រោច

ទឹកដែលជាកប្បិយនោះដូចម្ដេច សូម្បីការស្រោចទឹកដែលជាកប្បិយនោះ ក៏មិនខុស ។

ឯសេចក្ដីពិត ក្នុងការដាំ និងការស្រោចនេះ បើលោកពោលនូវឈើផ្កាដូច្នេះ ក្នុងកាលលោកគួរនឹងពោលដោយមិនប្លែកគ្នាថា ដាំឯងខ្លះ ឲ្យអ្នកដទៃដាំខ្លះ ស្រោចឯងខ្លះ ឲ្យអ្នកដទៃស្រោចខ្លះ នូវដើមឈើ ដូច្នេះ ឈ្មោះថារមែងឲ្យជ្រាប អធិប្បាយថា ពាក្យថា គុម្ពឈើផ្កានេះ ពោលសំដៅយកដើមឈើដែលមានផ្កា និងផ្លែ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូលប៉ុណ្ណោះតែនៅមានបរិយាយក្នុងការដាំ ដើម្បីប្រយោជន៍ដល់អារាមជាដើមដទៃឯទៀត ព្រោះហេតុនោះ ពាក្យណាដែលអដ្ឋកថាចារ្យទាំងឡាយជ្រាបសេចក្ដី មានបរិយាយក្នុងការដាំ ដើម្បីប្រយោជន៍ដល់អារាមជាដើមនោះ និងការមានបរិយាយក្នុងការដាំដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូលនេះហើយ ពោលទុកក្នុងអដ្ឋកថាទាំងឡាយ ពាក្យនោះ គឺលោកពោលប្រពៃពិត ។ ពិតហើយ ពាក្យនេះ ខ្ញុំក៏បានពោលហើយថា

> ព្រះអដ្ឋកថាចារ្យទាំងឡាយ ក្នុងកាលមុន បានរចនាអដ្ឋកថាទាំងឡាយ មិនបានលះមតិរបស់សាវកទាំងឡាយ ដែលដឹងធម៌ និងវិន័យ ដូចដែលព្រះសម្ពុទ្ធត្រាស់ហើយនោះឯង ព្រោះហេតុនោះឯង ពាក្យណា ដែលពោលហើយក្នុងអដ្ឋកថាទាំងឡាយ ពាក្យទាំងអស់នោះ វៀរតែពាក្យដែលសរសេរភ្លាំងភ្លាត់ចេញហើយ រមែងជាប្រមាណរបស់បណ្ឌិតទាំងឡាយ ដែលមានការគោរពក្នុងសិក្ខារបស់ព្រះសាសនា ។

ការដាំជាដើម និងការស្រោចជាដើម គ្រប់ៗ យ៉ាងគប្បីជ្រាបតាមន័យដែលពោលហើយ ។ ក្នុងវិស័យ មានការស្រោចជាដើមនោះ គប្បីមានពាក្យសួរថា បើត្រូវអាបត្តិក្នុងការក្រេងជាដើម ដើម្បីប្រយោជន៍ដល់ការបូជាព្រះ-រតនត្រ័យហើយ ព្រោះហេតុអ្វី ទើបការនាំទៅជាដើមជាអនាបត្តិទៅវិញ មានពាក្យឆ្លើយថា ព្រោះនាំទៅដើម្បីប្រយោជន៍ដល់ស្រីក្នុងត្រកូលជាដើម ទើបជាអាបត្តិ ។ ពិតហើយ ក្នុងហរណាធិការ ព្រះធម្មសង្គាហកាចារ្យទាំងឡាយបានពោលទុកឲ្យពិសេសហើយថា **តេ កុលិត្ថីនំ** ជាដើម ។ ព្រោះហេតុនោះទើបមិនត្រូវអាបត្តិដល់ភិក្ខុដែលនាំទៅដើម្បីប្រយោជន៍ដល់ព្រះពុទ្ធជាដើម ។

បណ្ដាបទទាំងនោះ បទថា **ឯកតោ វណ្ដិកំ** បានដល់ កម្រងផ្កាដែលរបនាទងផ្កាចូលជាមួយគ្នា ( មានទងតែម្ខាង ) ។

បទថា **ឧភតោ វណ្ដិកំ** បានដល់ កម្រងដែលធ្វើញែកទងផ្កាទុកទាំងពីរខាង ( កម្រងមានទងទាំងសងខាង ) ។

ចំណែកក្នុងបទថា **មញ្ជរិកំ** ជាដើម មានវិនិច្ឆ័យថា បុប្ផវិកតិដែលធ្វើស្រដៀងកងដៃ ហៅថា **មញ្ជរិកា** ( សំណុំផ្កាចាក់រំលេចទង ) ។

កម្រងផ្កាដែលប្រើម្ជុល ឬកន្ទុះដោត ដូចផ្កាសិន្ទុវារៈជាដើម ឈ្មោះថា **វិទ្ធតិកា** ។

បទថា **វដំសកោ** បានដល់ មកុដផ្កា ( កម្រងផ្កាសម្រាប់ប្រដាប់ក្បាល ) ។ កម្រងផ្កាសម្រាប់ប្រដាប់ត្រចៀក ឈ្មោះថា **អាវេឡា** ។

កម្រងផ្កាដែលតាំងនៅត្រង់ទ្រូង ដូចគ្នានឹងកែវមុក្ដាហារ ឈ្មោះថា

**ឱរជ្ជន** ( កម្រងសម្រាប់ប្រដាប់ទ្រូង ) ។ ពណ៌នាចំពោះបទក្នុងព្រះបាលីនេះ មានប្រមាណប៉ុណ្ណេះសិន ។

## ការវិនិច្ឆ័យអាបត្តិ

គប្បីជ្រាបវិនិច្ឆ័យអាបត្តិដោយពិស្តារ តាំងអំពីដើមដូចតទៅនេះថា ត្រូវអាបត្តិបាចិត្តិយ និងទុក្កដ ដល់ភិក្ខុដែលដាំឈើផ្កាឯង ក្នុងអកប្បិយបឋវី ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល ។ ភិក្ខុប្រើអ្នកដទៃឲ្យដាំ ដោយអកប្បិវោហារ ក៏ដូចគ្នា ការដាំឯងក្តី ប្រើអ្នកដទៃឲ្យដាំក្តី ក្នុងកប្បិយបឋវី ត្រូវអាបត្តិទុក្កដតែម្យ៉ាង ។ ក្នុងបឋវីទាំងពីរ ព្រោះប្រើឲ្យអ្នកដទៃដាំឈើផ្កាសូម្បីច្រើនដោយការប្រើតែម្តង ត្រូវអាបត្តិបាចិត្តិយ និងទុក្កដ ឬទុក្កដសុទ្ធ ដល់ភិក្ខុនោះតែមួយប៉ុណ្ណោះ មិនត្រូវអាបត្តិក្នុងការប្រើឲ្យអ្នកដទៃដាំ ដោយកប្បិយវោហារ ក្នុងដីដែលជាកប្បិយ ឬដីដែលជាអកប្បិយ ដើម្បីប្រយោជន៍ដល់ការបរិភោគ ។ ដើម្បីប្រយោជន៍ដល់អារាមជាដើម ក្នុងអកប្បិយបឋវី ក៏គង់ត្រូវអាបត្តិបាចិត្តិយដល់ភិក្ខុដែលដាំឯង ឬឲ្យអ្នកដទៃដាំដោយវាចាដែលជាអកប្បិយ ។ តែក្នុងន័យនេះ លោកមិនបានធ្វើការចែកទុកឲ្យល្អិតល្អន់ក្នុងមហាអដ្ឋកថាឡើយ តែចែកទុកក្នុងមហាបច្ចរីដូច្នេះឯង ។

ក្នុងការស្រោចឯង និងការប្រើឲ្យស្រោច មានវិនិច្ឆ័យអាបត្តិដូច្នេះថា ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ អន្ទើ ដោយទឹកដែលជាអកប្បិយ ។ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល និងបរិភោគ ត្រូវអាបត្តិទុក្កដក៏មាន ។ តែដើម្បីប្រយោជន៍ដល់ប្រការទាំងពីរនោះប៉ុណ្ណោះ ត្រូវអាបត្តិទុក្កដ ដោយទឹក

ដែលជាកប្បិយ ក្នុងការទ្រុស្តត្រកូល និងបរិភោគនេះ ដើម្បីបរិភោគ មិនត្រូវអាបត្តិ ក្នុងការប្រើឲ្យស្រោចទឹកដោយកប្បិយវោហារ តែក្នុងឋានៈនៃអាបត្តិ អ្នកសិក្សាគប្បីជ្រាបការត្រូវអាបត្តិច្រើន ព្រោះប្រយោគច្រើន ដោយអំណាចខ្សែទឹកដាច់ ។ ក្នុងការបេះឯង ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល ត្រូវអាបត្តិទុក្កដ និងបាចិត្តិយតាមចំនួនផ្កា ។ ក្នុងការបូជាព្រះរតនត្រ័យជាដើម ត្រូវអាបត្តិបាចិត្តិយតែម្យ៉ាង ។ តែភិក្ខុដែលបេះផ្កាជាច្រើន ដោយប្រយោគតែមួយ ព្រះវិនយធរគប្បីកាត់អាបត្តិដោយអំណាចនៃប្រយោគ ។ ក្នុងការប្រើឲ្យបេះដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល បុគ្គលដែលភិក្ខុប្រើតែម្តង បេះសូម្បីច្រើនដង ក៏ត្រូវអាបត្តិបាចិត្តិយ និងទុក្កដដល់ភិក្ខុទាំងនោះមួយប៉ុណ្ណោះ ។ ក្នុងការបេះដើម្បីបូជាព្រះរតនត្រ័យជាដើម ត្រូវអាបត្តិបាចិត្តិយតែម្យ៉ាង ។

## អធិប្បាយ បុប្ផវិកតិ ៦ ប្រភេទ

ក្នុងការក្រងផ្កាទាំងឡាយ មាន **គណ្ឋិមំ** ជាដើម អ្នកសិក្សាគប្បីជ្រាបបុប្ផវិកតិ ៦ ប្រភេទ គឺ **គណ្ឋិមំ** ដោតក្រង ១ **គោប្ផិមំ** ផ្គុំជាបាច់ ១ **វេធិមំ** ចោះដោត ១ **វេធិមំ** ចងព័ន្ធព័ទ្ធ ១ **បូរិមំ** បង្វង់ធ្វើឲ្យពេញ ១ **វាយិមំ** ប្រទាក់ស្រែះដូចក្រឡាសំណាញ់ ១ ។ បណ្តាបុប្ផវិកតិ ៦ ប្រភេទនោះ ឈ្មោះថា **គណ្ឋិម** គប្បីឃើញក្នុងផ្កាឧប្បល និងឈូកជាដើម ដែលមានទង ឬក្នុងផ្កាទាំងឡាយដទៃ ដែលមានទងវែង ។ ពិតហើយ ផ្កាដែលដោតក្រងទងនិងទង ឬធាងនិងធាងនោះឯង ឈ្មោះថា **គណ្ឋិម** ។ គណ្ឋិម

នោះ ភិក្ខុ ឬភិក្ខុនីធ្វើឯងក្តី ប្រើឲ្យអ្នកដទៃធ្វើដោយពាក្យជាអកប្បិយក្តី រមែងមិនគួរ តែប្រើឲ្យធ្វើដោយកប្បិយវាចាជាដើម មានពាក្យថា អ្នកចូរដឹងយ៉ាងនេះ អ្នកធ្វើយ៉ាងនេះហើយ នឹងគប្បីស្អាត ចូរធ្វើផ្កាទាំងឡាយនេះ កុំឲ្យខ្ចាត់ខ្ចាយរាត់រាយ ដូច្នេះ គួរ ។

ការយកអំបោះ ឬសម្បកឈើជាដើមដោតផ្កា មានផ្កាម្លិះជាដើម ដោយអំណាចកម្រងផ្កា មានទងតែម្ខាង និងមានទងសងខាង ឈ្មោះថា **គោប្ផិម** ។ មនុស្សទាំងឡាយវេញឈើ ឬខ្សែពីរសរសៃ ហើយដោតផ្កាដែលមិនមានទងជាដើមក្នុងឈើ ឬខ្សែ ហើយសន្ធឹងទុកតាមលំដាប់ សូម្បីផ្កានេះ ក៏ឈ្មោះថា **គោប្ផិម** ដូចគ្នា ។ គោប្ផិមទាំងអស់មិនគួរដោយន័យមុនដូចគ្នា ។

ដែលឈ្មោះថា **វេធិម** គឺផ្កាដែលមនុស្សទាំងឡាយ ដោតផ្កាដែលមានទង មានផ្កាម្លិះជាដើមត្រង់ទង ឬដោតផ្កាដែលមិនមានទង មានផ្កាពកុលជាដើម ខាងក្នុងប្រហោងផ្កា ដោយដក់ស្នោតជាដើម ហើយក្រងទុក នេះឈ្មោះថា **វេធិម** ។ ផ្កានោះមិនសមគួរដោយន័យមុនដូចគ្នា ។

បុគ្គលពួកខ្លះ យកបន្ទា ឬដក់ស្នោតជាដើម ដោតត្រង់ដើមចេកហើយដោតផ្កាទុកត្រង់បន្ទាជាដើមនោះ ។ ពួកខ្លះដោតផ្កាទុកត្រង់មែកឈើមានបន្ទា ។ ពួកខ្លះដោតផ្កាទុកត្រង់បន្ទាដែលដោតទុកត្រង់ឆត្រ និងជញ្ជាំង ដើម្បីធ្វើឆត្រផ្កា និងប្រាសាទផ្កា ។ ពួកខ្លះដោតផ្កាទុកត្រង់បន្ទាដែលចងទុកត្រង់ពិតានធម្មាសនៈ ។ ពួកខ្លះដោតផ្កា មានផ្កាកណិការជាដើម ដោយចម្រៀកឈើ និងធ្វើឲ្យដូចឆត្ររួត ។ ផ្កាដែលធ្វើយ៉ាងនោះឱឡារិកក្រៃលែងពន់ពេក ។

ការដែលចងបន្ទាទុកត្រង់ពិតានធម្មាសនៈ ដើម្បីដោតផ្កាក្តី ទោះដោតផ្កាមួយដោយបន្ទាជាដើមក្តី និងយកផ្កាដោតក្នុងផ្កាជាមួយគ្នាក្តី មិនគួរ ។ ការសៀត ផ្កាទាំងឡាយទុកក្នុងប្រហោងនៃពិតានក្រឡាសំណាញ់ វេទិកា ដៃកែវដែលដាក់ផ្កា និងរំយោលស្លឹកត្នោតជាដើម ឬក្នុងរវាងរំយោលផ្កាអសោក មិនមានទោស ។ ព្រោះផ្កាយ៉ាងនោះ មិនចាត់ជាវេធិមៈ សូម្បីក្នុងខ្សែធម្មតា ( ខ្សែសម្រាប់ដោតផ្កា ) ក៏មានន័យយ៉ាងនេះដូចគ្នា ។

ការដែលមានឈ្មោះថា **វេធិម** គប្បីឃើញកម្រងផ្កា និងបាច់ផ្កា ។ អធិប្បាយថា មនុស្សពួកខ្លះ កាលនឹងធ្វើកម្រងផ្កាព្យួរត្រង់ធម្មាសនៈ ទើបក្រងផ្កាទាំងឡាយ ដើម្បីសម្តែងអាការជាបាច់នៅខាងក្រោម ពួកខ្លះ ចងផ្កាឧប្បលជាដើមត្រង់ទងមួយបាច់ ៨ ផ្កាខ្លះ មួយបាច់ ១០ ផ្កាខ្លះ ដោយអំបោះ ឬដោយធ្មៃ ធ្វើឲ្យជាបាច់ផ្កាឧប្បល ឬជាបាច់ផ្កាឈូក ។ ការធ្វើផ្កាយ៉ាងនោះ មិនគួរទាំងអស់ ដោយន័យមុនដូចគ្នា សូម្បីយកសំពត់កាសាវៈចងផ្កាឧប្បលជាដើម ដែលពួកសាមណេរដកឡើងទុកលើគោកឲ្យជាបង្វេច ក៏មិនគួរ ។ តែយកធ្មៃ ឬទងរបស់ឧប្បលនោះឯងរុំចូលគ្នា ឬធ្វើឲ្យជាសម្ពាយសម្រាប់ស្ពាយ គួរ ។ ដែលឈ្មោះថា សម្ពាយនោះ គឺពួកកិក្ខុរមយកជាយទាំងពីររបស់សំពត់កាសាវៈដែលពាក់លើ ក មក ហើយធ្វើឲ្យជាថង់ ដាក់ផ្កាក្នុងថង់នោះដូចជាបាវ នេះលោកហៅថា សម្ពាយ ។ ការធ្វើផ្កាដូច្នោះ គួរ ។ មនុស្សទាំងឡាយយកទងចាក់ស្លឹកឈូក ហើយយកស្លឹកខ្ចប់ផ្កាឧប្បលជាដើមកាន់ទៅ ។ សូម្បីក្នុងវិស័យដែលយកស្លឹកឧប្បលជាដើមខ្ចប់ កាន់ទៅនោះ ទោះ

ចងស្លឹកបទុមខាងលើផ្កាទាំងឡាយប៉ុណ្ណោះ គួរ ។ តែចងបទុមមិនគួរចងទុកខាងក្រោមផ្កា ( ការចងបទុមទុកខាងក្រោមផ្កាមិនគួរ ) ។

ដែលឈ្មោះថា **បូរិម** គប្បីឃើញក្នុងកម្រង និងផ្នាំងផ្កា អធិប្បាយថា បុគ្គលណា យកកម្រងផ្កាពាក់ជុំវិញចេតិយក្តី គល់ពោធិ៍ក្តី វេទិកាក្តី នាំវង្វង់ត្រឡប់មកឲ្យហួសទីដើម ( ឋានដើម ) ទៅ សូម្បីដោយការព័ទ្ធត្រឹមជុំវិញប៉ុណ្ណោះ ផ្ការបស់បុគ្គលនោះ ឈ្មោះថា **បូរិម** នឹងពោលថ្វីសម្រាប់បុគ្គលដែលព័ទ្ធច្រើនជុំ ។ កាលស៊កចូលទៅចន្លោះដៃកែវ ទម្លាក់ឲ្យសំយុងចុះមក ហើយត្រឡប់ព័ទ្ធជុំវិញដៃកែវទៀត សូម្បីផ្កានេះ ក៏ឈ្មោះថា **បូរិម** ។ តែនឹងស៊កកងផ្កាចូលទៅក្នុងដៃកែវ គួរ ។ មនុស្សទាំងឡាយរមែងធ្វើផ្នាំងផ្កាដោយកម្រង សូម្បីក្នុងវិស័យបទុះផ្កានោះ ទោះសន្ទឹងកម្រងទៅត្រឹមម្តង គួរ ។ កាលនាំត្រឡប់មកទៀត ចាត់ជាការក្រងវង្វង់នោះឯង ។ ផ្កាប្រភេទនោះមិនគួរគ្រប់យ៉ាង ដោយន័យមុនដូចគ្នា ។ ឯការបានកម្រងផ្កាដែលគេធ្វើជាកម្រងសូម្បីច្រើនហើយ ទុកខាងលើអាសនៈជាដើម គួរ ។

ឯការយកកម្រងផ្កាដែលវែងចងសន្ទឹង ឬព័ទ្ធរុំទៅម្តងហើយ ( កាលដល់ចំណុចដើម ) ទៀត ឲ្យដល់ភិក្ខុដទៃ រមែងគួរ ។ សូម្បីភិក្ខុនោះ ក៏គួរធ្វើយ៉ាងនោះដូចគ្នា ។

ដែលឈ្មោះថា **វាយិម** គប្បីឃើញក្នុងផ្កាក្រឡាសំណាញ់ ផ្កាបទុះ និងផ្ការូបភាព ។ កាលភិក្ខុធ្វើសំណាញ់ផ្កា សូម្បីលើព្រះចេតិយត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រហោងក្រឡានីមួយៗ ។ ក្នុងជញ្ជាំង ឆត្រ ដើមពោធិ៍ និង

សសរជាដើមក៏មានន័យយ៉ាងនេះដូចគ្នា ។ ឯការដែលភិក្ខុក្រងកម្រងបន្ទះផ្កា ដែលអ្នកដទៃធ្វើឲ្យពេញហើយ ក៏មិនបាន ។ មនុស្សទាំងឡាយរមែងធ្វើរូបដំរី និងរូបសេះជាដើម ដោយផ្កាដែលជោតផ្គុំទាំងឡាយនោះឯង សូម្បីរូបដំរី និងរូបសេះជាដើមនោះ ក៏តាំងនៅក្នុងឋាននៃ **វាយិម** ផ្កានោះរមែងមិនគួរទាំងអស់ ដោយន័យមុនដូចគ្នា ។

តែកាលដាក់ផ្កា ( តាមប្រក្រតី មិនបានក្រង ) ក្នុងពេលដែលមនុស្សដទៃធ្វើទុកហើយ ធ្វើឲ្យជារូបដំរី និងរូបសេះជាដើម គួរ ។ តែក្នុងមហាបច្ចរី ពោលបុប្ផវិកតិទុក ៨ ប្រភេទ រួមទាំងកម្រងសំយុង និងកម្រងដូចព្រះចន្ទមួយចំហៀង ។ បណ្ដាកម្រងសំយុង និងកម្រងដូចព្រះចន្ទមួយចំហៀងនោះ កម្រងសំយុងដែលព្យួរក្នុងរវាងកម្រងព្រះចន្ទពាក់កណ្ដាល លោកហៅឈ្មោះថា **កលម្ពក** ។ ការព័ទ្ធជុំវិញកម្រងត្រឡប់ទៅត្រឡប់មក ( ដែលគេធ្វើ ) ដោយអាការដូចព្រះចន្ទពាក់កណ្ដាល លោកហៅថា **អឌ្ឍចន្ទក** ។ សូម្បីផ្កាទាំងពីរប្រភេទនោះ ក៏ចាត់ចូលក្នុង **បូរិម** ដូចគ្នា ។ ឯក្នុងកុរុន្ទីពោលថា សូម្បីការក្រង ២-៣ កម្រងចូលជាមួយគ្នា ធ្វើឲ្យជាកម្រងផ្កា ឈ្មោះថា **វាយិម** ដូចគ្នា ។ សូម្បីការធ្វើកម្រងផ្កានោះ ក្នុងមហាអដ្ឋកថានេះ ក៏ចាត់ចូលក្នុងឋាននៃ **បូរិម** ដូចគ្នា ។ មិនមែនតែកម្រងផ្កាតែម្យ៉ាងប៉ុណ្ណោះទេ កម្រងផ្កាធ្វើដោយម្សៅក្ដី កម្រងផ្កាធ្វើស្រដៀងគ្រាប់ឃ្មុំក្ដី កម្រងផ្កាដែលធ្វើដូចធ្មេញក្ដែ ដែលលោកពោលទុកក្នុងកុរុន្ទីក្ដី ពួកភិក្ខុក្ដី ពួកភិក្ខុនីក្ដី ធ្វើឯងមិនគួរ ប្រើឲ្យអ្នកដទៃធ្វើមិនគួរ ព្រោះសិក្ខាបទនេះ ជាសាធារណបញ្ញត្តិ ។

តែបើពោលពាក្យដែលជាកប្បិយ មានការបូជាគ្រឿង ចំណាំ សមគួរគ្រប់ៗ អន្ទើ ។ បរិយាយ ឱកាស និងនិមិត្តកម្ម សមគួរទាំងអស់ ដូច្នេះ ។

## អធិប្បាយ អនាចារផ្សេងៗ

បទថា **តុវដ្ដន្តិ** ប្រែថា រមែងដេក ។ បទថា **លាសេន្តិ** សេចក្ដីថា ពួកអស្សជិ និងបុនព្វសុកភិក្ខុនោះក្រោកឡើង ដូចអណ្ដែតខ្លួនព្រោះបីតិ ហើយស្រីរបាំដែលជំនាញក្នុងការរាំ រាំពត់ពេន ឲ្យចង្វាក់ គឺបង្រៀនឲ្យរាំ ។

ពីរបទថា **នច្ចន្តិយាបិ នច្ចន្តិ** សេចក្ដីថា ក្នុងពេលដែលស្រីរបាំរេរាំ សូម្បីអស្សជិ និងបុនព្វសុកភិក្ខុនោះ ក៏រាំទៅខាងមុខ ឬខាងក្រោយនៃស្រីរបាំនោះ ។ ពីរបទថា **នច្ចន្តិយាបិ គាយន្តិ** សេចក្ដីថា ក្នុងខណៈដែលស្រីនោះកំពុងរាំ ពួកភិក្ខុទាំងនោះ រមែងច្រៀងបន្ទរទៅតាមការរាំ ។ ក្នុងគ្រប់ៗបទ ក៏មានន័យយ៉ាងនេះ ។ ពីរបទថា **អដ្ឋបទេបិ កីឡន្តិ** សេចក្ដីថា រមែងលេងបាស្កាលើក្ដារ គឺបាស្កាក្រឡា ៨ ក្នុងក្ដារបាស្កាក្រឡា ១០ ក៏ដូចគ្នា ។

បទថា **អាកាសេបិ** សេចក្ដីថា លេងបាស្កាក្នុងអាកាស ដូចលេងបាស្កាក្រឡា ៨ និងក្រឡា ១០ ដូច្នោះ ។

បទថា **បរិហារបថេ** សេចក្ដីថា ធ្វើរង្វង់វិល មានខ្សែផ្សេងៗ លើផែនដី ហើយលេងរត់វិលទៅតាមគំនូស ក្នុងរង្វង់នោះ ។

ពីរបទថា **សន្តិកាយបិ កីឡន្តិ** បានដល់ លេងបាស្កាកម្រើកខ្លះ អធិប្បាយថា តួបាស្កា និងដុំថ្ម ដុំក្រួសជាដើមដែលទុករួមគ្នា យកក្រចកប៉ុណ្ណោះគ្ជឹះចេញ និងគ្ជឹះចូលមិនឲ្យកម្រើក ។ បើគ្រាប់បាស្កា ឬដុំថ្ម ដុំក្រួស

ឯណាមួយកម្រើកជាការចាញ់ ។

បទថា **ខលិកាយ** បានដល់ លេងបោះអន្ទាក់លើក្តារបាស្កា ។

បទថា **ឃដិកាយ** សេចក្តីថា លេងហឹង លោកហៅថា **ឃដិកា** លេងដោយហឹងនោះ សេចក្តីថា យកឈើវែងវាយឈើខ្លីលេង ។ បទថា **សលាកហត្ថេន** សេចក្តីថា លេងយកជក់ជ្រលក់ដោយទឹកល័ខ ទឹកចត់ ឬ ទឹកលាយម្សៅ ហើយសួរថា នឹងកើតជារូបអ្វី ទើបរលាស់លើផែនដី ឬ ជញ្ជាំង បង្ហាញរូបដំរី និងរូបសេះជាដើម ។

បទថា **អក្ខេន** ប្រែថា គ្រាប់បាស្កា ( អន្គញ់ ) ។

បទថា **បង្គចិរេន** សេចក្តីថា បំពង់ស្លឹកឈើ លោកហៅថា **បង្គចិរ** លេងផ្លុំបំពង់ស្លឹកឈើនោះ ( លេងផ្លុំស្លឹក ផ្លុំប៉ី ) ។

បទថា **វង្កកេន** បានដល់ នង្គ័លតូចៗ ជាគ្រឿងលេងរបស់ពួកក្មេងអ្នកស្រុក ។ បទថា **មោក្ខចិកាយ** សេចក្តីថា លេងដាំដូង ។ អធិប្បាយថា លេងទល់ឈើលើអាកាស ឬ ដាក់ក្បាលចុះត្រង់ផែនដី ហើយបង្វិលខ្លួនទៅជុំវិញ ទាំងខាងក្រោម និងខាងលើ ( លេងត្រឡប់ខ្លួន ) ។

បទថា **ចិង្គុលេន** សេចក្តីថា កង្ហារដែលវិលទៅដោយត្រូវខ្យល់ផាត់ ដែលធ្វើដោយស្លឹកត្នោតជាដើម ហៅថា **ចិង្គុលក** លេងដោយកង្ហារនោះ ។

បទថា **បត្តាឡ្ហកេន** សេចក្តីថា កន្ទោងស្លឹកឈើ លោកហៅថា **បត្តាឡ្ហក** លេងវាល់ខ្សាច់ជាដើម ដោយកន្ទោងស្លឹកឈើនោះ ។

បទថា **រថកេន** បានដល់ រថតូចៗ ។ បទថា **ធនុកេន** បានដល់ ធ្នូ

តូចៗ ។ បទថា **អក្ខរិកាយ** សេចក្ដីថា លេងទាយអក្សរត្រង់អាកាស ឬត្រង់ខ្នង ហៅថា **អក្ខរិកា** លេងទាយអក្សរនោះ ។

បទថា **មនេសិកាយ** សេចក្ដីថា លេងដោយការទាយចិត្ត ( ស្ដេចចង់ ) លោកហៅថា **មនេសិកា** ។ បទថា **យថាវជ្ជេន** សេចក្ដីថា ការលេងសម្ដែងប្រកបអាកប្បកិរិយារបស់មនុស្សពិការ មានមនុស្សខ្វាក់ខ្វែក មនុស្សខ្វិក និងមនុស្សគមជាដើម លោកហៅថា លេងត្រាប់មនុស្សពិការ ។ អស្សជិ និងបុនព្វសុក លេងដោយការលេងត្រាប់មនុស្សពិការ ដូចពួកជនអ្នកវេលម្ពកៈលេង ដូច្នោះ ។

ពីរបទថា **ហត្ថិស្មិម្បិ សិក្ខន្តិ** សេចក្ដីថា រមែងសិក្សាសិប្បៈដែលគួរសិក្សាមានដំរីជានិមិត្ត ។ ក្នុងសិប្បៈ មានសេះជាដើម ក៏មានន័យយ៉ាងនេះ ។

បទថា **ធាវន្តិបិ** បានដល់ រត់ដេញទៅតាមក្រោយ ។ បទថា **អាធាវន្តិបិ** សេចក្ដីថា រត់បែរមុខត្រឡប់មក អស់រយៈផ្លូវ ដែលខ្លួនរត់ទៅ ( ស្ទុះរត់ត្រឡប់ ) ។ បទថា **និព្វុជ្ឈន្តិ** បានដល់ រមែងធ្វើការចំបាប់គ្នា ។

ពីរបទថា **ឧលាដិកម្បិ ទេន្តិ** សេចក្ដីថា ផ្ដិតម្រាមត្រង់ថ្ងាសរបស់ខ្លួន ហើយផ្ដិតត្រង់ថ្ងាសរបស់ស្រីរបាំនោះ មួយអន្លើដោយវាចាថា ល្អ ល្អហើយ ប្អូនស្រី ។ ពីរបទថា **វិវិធម្បិ អនាចារំ** សេចក្ដីថា ប្រព្រឹត្តអនាចារផ្សេងៗ មានស្គរមាត់ជាដើម ( ពិណពាទ្យមាត់ ហួចជាដើម ) ដទៃៗ ដែលមិនបានមកក្នុងព្រះបាលី ។

[ ៣១៥ ] បទថា **បសាទិកេន** បានដល់ ដែលនាំមកនូវសេចក្ដីជ្រះថ្លា

គឺសមគួរសមរម្យដល់សមណៈ ។

បទថា **អភិក្កន្តេន** គឺមានការដើរទៅមុខ ។ បទថា **បដិក្កន្តេន** គឺមានការឈានថយក្រោយ ។ បទថា **អាលោកិតេន** គឺការសម្លឹងទៅខាងមុខ ។ បទថា **វិលោកិតេន** គឺមើលឆ្វេងស្តាំ ។ បទថា **សម្មិញ្ជិតេន** គឺការបត់អវយវៈចូល ។ បទថា **បសារិតេន** គឺការលាអវយវៈទាំងនោះឯងចេញ ។ ក្នុងបទទាំងពួង ជាតតិយាវិភត្តិ ចុះក្នុងអត្ថប្រាប់ឥត្ថម្ភូត ។ អធិប្បាយថា ជាអ្នកមានការឈានទៅមុខ ឈានថយក្រោយ ក្រឡេកឆ្វេង ក្រឡេកស្តាំ បត់ចូល លាចេញ ដ៏គួរជ្រះថ្លា ព្រោះត្រូវគ្រប់គ្រងដោយសតិសម្បជញ្ញៈ ។ បទថា **ឱក្ខិត្តចក្ខុ** គឺមានភ្នែកដាក់ចុះ ។

បទថា **ឥរិយាបថសម្បន្នោ** សេចក្តីថា មានឥរិយាបថសមរម្យ មានកិរិយាឈានទៅខាងមុខជាដើម ដែលគួរជ្រះថ្លានោះ ។

បទថា **ក្វាយំ** កាត់បទជា **កោ អយំ** ប្រែថា ភិក្ខុនេះជានរណា ។

បទថា **អពលពលោ វិយ** សេចក្តីថា បានឮថា ជនទាំងឡាយហៅមនុស្សដែលទន់ខ្សឹថា អពលៈ ។ ឯពាក្យពោលត្រួតនេះ ប្រព្រឹត្តទៅក្នុងអត្ថថា យ៉ាងក្រៃលែង ព្រោះដូច្នោះ ទើបមានពាក្យអធិប្បាយថា ដូចជាទន់ខ្សោយហួសពេក ។

ដោយបទថា **មន្ទមន្ទោ** អ្នកស្រុករមែងសម្តែងគុណពិតៗ ថាជាទោសយ៉ាងនេះថា ជាអ្នកទន់ខ្សោយពេក គឺជ្រាយពេក ព្រោះជាអ្នកមានឥរិយាបថមានការឈានទៅមុខជាដើមមិនរហ័សរហួន ។

*បទថា* **ភាកុដិកភាកុដិកោ វិយ** *សេចក្តីថា ព្រោះលោកជាអ្នកមានភ្នែកដាក់ចុះ ទើបអ្នកស្រុកសម្គាល់ និយាយគ្នាថា ភិក្ខុនេះធ្វើមុខស្រពោន មានមុខជ្រួញចិញ្ចើម ត្រាច់ទៅដូចជាអ្នកក្រោធ ។*

*បទថា* **សណ្ហា** *គឺជាអ្នកល្អិតល្អន់ អធិប្បាយថា ជាអ្នកឈ្លាសក្នុងការដឹកនាំឧបាសក ឬជនក្នុងឋានៈដែលគួរយ៉ាងនេះថា នែញោមស្រី ញោមប្រុស បងស្រី ប្អូនស្រី លោកមិនមែនជាមនុស្ស មិនមានកម្លាំងកំហែងដូចភិក្ខុអង្គនេះឡើយ ។*

*បទថា* **សខិលា** *បានដល់ ជាអ្នកប្រកបដោយភាពជាអ្នកមានវាចាទន់ភ្លន់ ។ បទថា* **សុខសំភាសា** *នេះ ជាពាក្យសម្តែងហេតុនៃពាក្យមុន ។ ពិតហើយ ជនដែលមានការនិយាយផ្អែមល្ហែម ជាសម្មោទនីយកថា មិនគ្រោតគ្រាត ពីរោះត្រចៀក លោកហៅថា អ្នកមានវាចាពីរោះ ។ ដោយហេតុនោះ ទើបអ្នកស្រុកពោលថា ( លោកម្ចាស់របស់ពួកយើង ) ជាអ្នកមានសម្តីពីរោះ ពោលពាក្យផ្អែមល្ហែម ។ ក្នុងពាក្យនេះ មានពាក្យអធិប្បាយដូច្នេះថា លោកម្ចាស់របស់ពួកយើង ឃើញពួកឧបាសក ឧបាសិកាហើយ ពោលសម្មោទនីយកថាពីរោះ ព្រោះដូច្នោះ ទើបលោកជាអ្នកនិយាយពីរោះ ផ្អែមល្ហែម មិនជាមនុស្សទន់ខ្សោយ និងទន់ជ្រាយ ដូចភិក្ខុនេះឡើយ ។*

*បទថា* **មិហិតបុព្វង្គមា** *មានវិគ្គហៈថា ភិក្ខុទាំងនេះ មានការញញឹមញញែម ប្រព្រឹត្តទៅមុនពោល ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកមានការញញឹមញញែមជាទីទៅខាងមុខ សេចក្តីថា ភិក្ខុទាំងនោះញញឹមញញែមមុន ទើបនិយាយជាក្រោយ ។*

បទថា **ឯហិស្វាគតវាទិនោ** សេចក្ដីថា ឃើញឧបាសកហើយ រមែងពោលយ៉ាងនេះថា មកចុះ អ្នកមកល្អហើយ មិនជាអ្នកមានមុខស្រពោន ព្រោះជាអ្នកមានមុខចង់ចិញ្ចើមដូចភិក្ខុនេះឡើយ ។ ពួកអ្នកកិជាតិរីជនបទកាលសម្ដែងភាពជាអ្នកមានមុខមិនស្រពោន ព្រោះជាអ្នកមានប្រក្រតីញញឹមញញែមមុនជាដើម ដោយអត្ថយ៉ាងនេះហើយ កាលនឹងសម្ដែងដោយសរុបទៀត ទើបពោលថា មានមុខមិនស្រពោន មានមុខរីករាយ មុននឹងពោល ។

ម្យ៉ាងទៀត អ្នកសិក្សាគប្បីជ្រាបថា បទទាំង ៣ មានបទថា **អភា-កុដិកា** ជាដើមនេះ សម្ដែងការមិនមាននៃអាការទាំង ៣ ដោយមកបួរលំដាប់គ្នា ។

សេចក្ដីនេះដូចម្ដេច គឺបណ្ដាបទទាំង ៣ មានបទថា **អភ្ភាកុដិកា** ជាដើមនោះ ដោយបទថា **អភ្ភាកុដិកា** នេះ លោកសម្ដែងការមិនមានអាការជ្រួញចិញ្ចើមជ្រួញភ្នែក ។

ដោយបទថា **ឧត្តានមុខា** នេះ លោកសម្ដែងការមិនមាននៃអាការទន់ខ្សោយ និងទន់ជ្រាយ ។ ភិក្ខុពួកណា ជាអ្នកមានមុខរីករាយ ដោយការបើកភ្នែកទាំងពីរមើល ។ ភិក្ខុទាំងនោះ ឈ្មោះថា មិនជាអ្នកទន់ខ្សោយ និងទន់ជ្រាយ ។ ដោយបទថា **បុព្វភាសិនោ** នេះ លោកសម្ដែងការមិនមាននៃអាការទន់ខ្សោយ និងទន់ជ្រាយ ។ ភិក្ខុពួកណា រមែងរាក់ទាក់មុនថា នែញោមស្រី ញោមប្រុស ដូច្នេះ ព្រោះជាអ្នកឈ្លាសក្នុងការឱកាសប្រាស្រ័យ ភិក្ខុទាំងនោះ មិនជាបុគ្គលមិនមានកម្លាំងនោះឡើយ ដូច្នេះឯង ។

*បទថា* **ឯហិ ភន្តេ យាំ គមិស្សាម** *សេចក្តីថា បានឮថា ឧបាសកនោះ កាលភិក្ខុឆ្លើយថា នែអាវុសោ អាត្មាមិនទាន់បានបិណ្ឌបាតឡើយ ដូច្នេះ ទើបពោលថា ពួកភិក្ខុនោះឯង ធ្វើឲ្យលោកមិនបានបិណ្ឌបាតនោះ សូម្បីលោកនឹងត្រាច់ទៅទូទាំងភូមិ ក៏មិនបានឡើយ បំណងនឹងប្រគេនបិណ្ឌបាត ទើបពោលថា មកចុះ លោកម្ចាស់ ពួកយើងទៅផ្ទះជាមួយគ្នា ។*

*សួរថា វាចានេះ ជាវិញ្ញត្តិវាចា ឬមិនមែន ឆ្លើយថា មិនមែន ។ ធម្មតាបញ្ហាដែលគេសួរហើយនេះ គួរនឹងឆ្លើយតប ។ ព្រោះដូច្នោះ សូម្បីសព្វថ្ងៃនេះ បុគ្គលណាមួយ សួរភិក្ខុដែលចូលទៅកាន់ចន្លោះស្រុក ក្នុងវេលាព្រឹកក្តី ក្នុងវេលាល្ងាចក្តីថា លោកម្ចាស់ទៅធ្វើអ្វី ការដែលភិក្ខុប្រាប់បំណងដែលខ្លួនត្រាច់ទៅហើយ កាលបុគ្គលសួរថា បានហើយ ឬមិនទាន់បាន បើមិនទាន់បាន ប្រាប់ថា មិនទាន់បាន ហើយទទួលយកវត្ថុដែលគេប្រគេន គួរ ។*

*បទថា* **ធុរេជ្ជា** *សេចក្តីថា មិនបានទ្រុឌទ្រោមចុះ ដោយការញុំាងការជ្រះថ្លាជាដើមឲ្យវិនាសទៅ តែទ្រុឌទ្រោមចុះដោយអំណាចនៃបុគ្គលអ្នកទ្រុឌទ្រោម ។ ទានទាំងឡាយនោះឯង លោកហៅថា* **ធានបថ** *។ មួយវិញទៀត ការឲ្យទានជាប្រចាំ លោកហៅថា* **ធានបថ** *។ មានពាក្យអធិប្បាយថា ទានវត្ត ។ បទថា* **ឧបច្ឆិន្នានិ** *បានដល់ ត្រូវពួកទាយកកាត់ដាច់ហើយ ។ អធិប្បាយថា ឥឡូវនេះ ពួកទាយកទាំងនោះ មិនឲ្យទាននោះ ។*

*បទថា* **វិភេន្តិ** *សេចក្តីថា ពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ជាអ្នកបែកគ្នា គឺបែកបាក់គ្នា មានពាក្យអធិប្បាយថា រមែងនាំគ្នាចៀសចេញទៅ ។*

បទថា **សណ្ឋហេយ្យ** សេចក្តីថា គប្បីតាំងនៅ គឺគប្បីជាទីពឹងពំនាក់របស់ភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។

ភិក្ខុនោះ ទទួលពាក្យរបស់ឧបាសកអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លាដោយពាក្យថា **ឯវមាវុសោ** ដូច្នេះឯង បានឮថា ការទទួលពាក្យដែលជាកប្បិយបែបនេះ រមែងគួរ ។ ព្រោះដូច្នោះ ភិក្ខុមិនគប្បីធ្វើសេចក្តីវង្វៀសក្នុងពាក្យផ្តាំផ្ញើទាំងឡាយដូច្នេះថា សូមលោកថ្វាយបង្គំព្រះយុគលបាទរបស់ព្រះមានព្រះភាគតាមពាក្យរបស់ខ្ញុំផង ដូច្នេះក្តី ឬថា សូមលោកថ្វាយបង្គំព្រះចេតិយ ព្រះបដិមា ដើមពោធិ៍ ព្រះសង្ឃត្ថេរ ដូច្នេះក្តី ឬថា សូមលោកធ្វើការបូជាដោយគ្រឿងក្រអូប ការបូជាដោយផ្កា ត្រង់ព្រះចេតិយ ដូច្នេះក្តី ឬថា សូមលោកនិមន្តឲ្យភិក្ខុទាំងឡាយប្រជុំគ្នា ពួកខ្ញុំនឹងថ្វាយទាន នឹងស្តាប់ធម៌ដូច្នេះក្តី ពាក្យផ្តាំផ្ញើទាំងនេះ ជាកប្បិយសាសន៍ មិនទាក់ទងដោយគហិកម្មរបស់ពួកគ្រហស្ថ ដោយប្រការដូច្នេះឯង ។

[ ៣១៦ ] បទថា **កុតោ ច ត្វំ ភិក្ខុ អាគច្ឆតិ** សេចក្តីថា ភិក្ខុនោះអង្គុយហើយ មិនមែនកំពុងមក ។ តែដោយអត្ថ ភិក្ខុនោះជាអ្នកមកហើយ ។ កាលបើយ៉ាងនេះ ពាក្យបច្ចុប្បន្នកាល ក្នុងអត្ថអតីត ដែលជិតចំពោះបច្ចុប្បន្នកាល រមែងមាន ព្រោះដូច្នោះ ទើបមិនមានការខុស ។ សូម្បីក្នុងបទថា **តតោ អហំ ភគវា អាគច្ឆាមិ** នេះ ក្នុងទីបំផុត ក៏មានន័យនេះដូចគ្នា ។

[ ៣១៧ ] ក្នុងបទថា **បឋមំ អស្សជិបុនព្វសុកា ភិក្ខូ ចោទេតព្វា**

នេះ មានវិនិច្ឆ័យដូចតទៅ អស្សជិ និងបុនព្វសុកភិក្ខុ ដែលសង្ឃគប្បីឲ្យធ្វើឱកាសថា ពួកខ្ញុំនឹងនិយាយជាមួយពួកលោក ហើយគប្បីចោទដោយវត្ថុ និងអាបត្តិ កាលចោទហើយ គប្បីឲ្យរឭកដល់អាបត្តិដែលពួកលោកមិនទាន់រឭកបាន ។ បើពួកលោកប្តេជ្ញាវត្ថុ និងអាបត្តិ ឬប្តេជ្ញាចំពោះអាបត្តិ មិនប្តេជ្ញាវត្ថុ គប្បីលើកអាបត្តិឡើងកាត់ ។ បើប្តេជ្ញាចំពោះវត្ថុ មិនប្តេជ្ញាអាបត្តិ សូម្បីក្នុងការប្តេជ្ញាយ៉ាងនេះ ក៏គប្បីលើកអាបត្តិឡើងនោះឯងថា ជាអាបត្តិឈ្មោះនេះ ព្រោះវត្ថុនេះ ។ បើពួកលោកមិនប្តេជ្ញាទាំងវត្ថុ មិនប្តេជ្ញាទាំងអាបត្តិ មិនគប្បីលើកអាបត្តិឡើង កាត់ឡើយ ។

ព្រះមានព្រះភាគ ទ្រង់កាត់អាបត្តិតាមប្តេជ្ញាហើយ កាលទ្រង់សម្តែងថា សង្ឃគប្បីដាក់បព្វាជនីយកម្មយ៉ាងនេះ ទើបត្រាស់ពាក្យជាដើមថា **ព្យត្តេន ភិក្ខុនា** ដូច្នេះ ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។ ភិក្ខុត្រូវសង្ឃដាក់បព្វាជនីយកម្មយ៉ាងនេះហើយ មិនគួរនៅក្នុងវត្តដែលខ្លួនធ្លាប់នៅ ឬក្នុងស្រុកដែលខ្លួនធ្វើកុលទូសកកម្ម ។ បើនៅក្នុងវត្តនោះ មិនគប្បីត្រាច់ទៅបិណ្ឌបាតក្នុងស្រុកជិតខាង ។ សូម្បីនៅក្នុងវត្តជិតខាង ក៏មិនគួរត្រាច់ទៅបិណ្ឌបាតក្នុងស្រុកនោះ តែព្រះឧបតិស្សត្ថេរត្រូវពួកអន្តេវាសិកជំទាស់ថា បពិត្រលោកម្ចាស់ ធម្មតានគរធំ មានប្រមាណដល់ទៅ ១២ យោជន៍ ដូច្នេះហើយ ទើបពោលថា ភិក្ខុធ្វើកុលទូសកកម្មក្នុងផ្លូវណា លោកហាមតែផ្លូវនោះ ។ លំដាប់នោះ លោកត្រូវពួកអន្តេវាសិកជំទាស់ថា សូម្បីផ្លូវធំ មានប្រមាណប៉ុននគរ ទើបពោលថា ភិក្ខុធ្វើកុលទូសកកម្មក្នុងលំដាប់ផ្ទះជួរណា

លោកហាមលំដាប់ផ្ទះជួរនោះ ដូច្នេះ ។ លោកត្រូវពួកអន្តេវាសិកជំទាស់ទៀតថា សូម្បីលំដាប់ផ្ទះ ក៏មានទំហំប៉ុនថ្នល់នោះឯង ទើបពោលថា ហាមផ្ទះ ៧ ខ្នងខាងឆ្វេង និងខាងស្តាំ ។ ឯពាក្យទាំងអស់នោះ ត្រឹមតែជាមនោរថរបស់ព្រះថេរៈប៉ុណ្ណោះ ។ បើវត្តធំមានទំហំ ៣ យោជន៍ និងនគរធំទំហំ ១២ យោជន៍ ភិក្ខុដែលធ្វើកុលទូសកកម្ម នឹងនៅក្នុងវត្តក្តី ត្រាច់ទៅក្នុងនគរក្តី មិនបានឡើយ ដូច្នេះឯង ។

[ ៣២០ ] បទថា **តេ សង្ឃេន បព្វាជនីយកម្មកតា** សេចក្តីថា សួរថា សង្ឃ បានធ្វើកម្មដល់ពួកអស្សជិ និងបុនព្វសុកនោះដូចម្តេច ឆ្លើយថា សង្ឃមិនបានទៅសង្កត់សង្កិនធ្វើកម្មឡើយ ដោយពិតនោះ កាលពួកត្រកូលអារាធនានិមន្តមកហើយ ធ្វើកត្តដើម្បីសង្ឃ ព្រះថេរៈទាំងឡាយក្នុងទីនោះសម្តែងបដិបទារបស់សមណៈ ឲ្យពួកមនុស្សយល់ថា នេះជាសមណៈ នេះមិនមែនសមណៈ ហើយឲ្យភិក្ខុ ១-២ អង្គ ចូលកាន់សីមា ហើយបានធ្វើបព្វាជនីយកម្មដល់ពួកភិក្ខុទាំងអស់ ដោយឧបាយនេះឯង ។

កាលភិក្ខុត្រូវសង្ឃដាក់បព្វាជនីយកម្មយ៉ាងនេះហើយ បំពេញវត្ត ១៨ ប្រការឲ្យបរិបូណ៌ កម្មដែលសង្ឃគប្បីរម្ងាប់ ដូច្នេះ ។ កាលភិក្ខុមានកម្មរម្ងាប់ហើយនោះ ខ្លួនធ្វើកុលទូសកកម្មទុកក្នុងត្រកូលណាអំពីមុន មិនគួរទទួលបច្ច័យអំពីត្រកូលទាំងនោះ ។ សូម្បីសម្រេចការអស់ទៅនៃអាសវៈ ហើយក៏មិនគួរទទួល បច្ច័យទាំងនោះ ចាត់ជារបស់មិនសមគួរពិត ។

កាលភិក្ខុត្រូវពួកទាយកសួរថា ហេតុអ្វី ទើបលោកមិនទទួល ឆ្លើយថា

ព្រោះបានធ្វើទុកយ៉ាងនេះក្នុងកាលមុន ដូច្នេះ បើពួកអ្នកស្រុកពោលថា ពួកខ្ញុំមិនប្រគេនដោយហេតុយ៉ាងនោះ ប្រគេនព្រោះលោកមានសីលក្នុងឥឡូវនេះ ( ឯណោះទេ ) ដូច្នេះ គួរទទួលបាន ។ កុលទូសកកម្ម ជាកម្មដែលភិក្ខុធ្វើចំពោះទឹកខ្ទែងឲ្យទានតាមប្រក្រតី និងទទួលទានតាមប្រក្រតីអំពីទឹកខ្ទែងនោះឯង គួរ ។ ទានដែលទាយកប្រគេនដើម្បីបន្ថែម មិនគួរទទួល ។

បទថា **ន សម្មា វត្តន្តិ** សេចក្ដីថា ឯពួកអស្សជិបុនព្វសុកភិក្ខុទាំងនោះរមែងមិនប្រព្រឹត្តដោយប្រពៃក្នុងវត្ត ១៨ ប្រការ ។

បទថា **ន លោមំ ចាតេន្តិ** សេចក្ដីថា ឈ្មោះថា ជាអ្នកមិនបោះបង់ពុត ព្រោះមិនបដិបត្តិតាមបដិបទាដែលសមគួរ ។

បទថា **ន នេត្ថារំ វត្តន្តិ** សេចក្ដីថា រមែងមិនបដិបត្តិតាមផ្លូវ ជាគ្រឿងជួយដកខ្លួនឯងឡើង ។ បទថា **ន ភិក្ខូ ខមាបេន្តិ** សេចក្ដីថា រមែងមិនធ្វើឲ្យភិក្ខុទាំងឡាយ អត់ទោសយ៉ាងនេះថា បពិត្រលោកម្ចាស់ ពួកខ្ញុំធ្វើខុស តែពួកខ្ញុំនឹងមិនធ្វើដូច្នេះទៀតឡើយ សូមលោកម្ចាស់ទាំងឡាយ អត់ទោសដល់ពួកខ្ញុំចុះ ។ បទថា **អក្កោសន្តិ** គឺរមែងជេរការកសង្ឃ ដោយអក្កោសវត្ថុ ១០ ។ បទថា **បរិភាសន្តិ** គឺរមែងសម្ដែងភ័យដល់ភិក្ខុទាំងនោះ ។ បទថា **ឆន្ទគាមិតា ។បេ។ ភយគាមិតា ចាបេន្តិ** សេចក្ដីថា រមែងឲ្យដល់ គឺប្រកបដោយការលំអៀង ព្រោះស្រឡាញ់ខ្លះ ។បេ។ ដោយការលំអៀងព្រោះខ្លាចខ្លះ យ៉ាងនេះថា ភិក្ខុទាំងនេះ ជាអ្នកមានសេចក្ដីលំអៀងព្រោះស្រឡាញ់ ។បេ។ និងមានសេចក្ដីលំអៀងព្រោះខ្លាច ។

បទថា **បក្កមន្តិ** សេចក្តីថា បណ្តាសមណៈ ៥០០ ដែលជាបរិវារ របស់អស្សជិ និងបុនព្វសុកភិក្ខុនោះ ពួកខ្លះក៏ចៀសទៅកាន់ទិស ។

បទថា **វិព្ភមន្តិ** គឺពួកខ្លះសឹកជាគ្រហស្ថ ។ ក្នុងបទថា **កថំ ហិ នាម អស្សជិបុនព្វសុកា** នេះ លោកហៅភិក្ខុទាំងអស់ថា អស្សជិបុនព្វសុក ដោយអំណាចនៃភិក្ខុទាំងពីររូប ដែលជាប្រធាន ។

# អធិប្បាយ កុលទូសកកម្ម

[ ៣២១ ] ក្នុងបទថា **គាមំ** នេះ សូម្បីនគរ លោកក៏សង្គ្រោះដោយ **គាម** សព្ទដូចគ្នា ។ ដោយហេតុនោះ ទើបក្នុងការចែកបទនោះ លោកពោលថា ស្រុកក្តី និគមក្តី នគរក្តី ឈ្មោះថា គាម និងនិគម ។ បណ្តាស្រុកជាដើមនោះ ភូមិដែលមិនមានកំពែងជាគ្រឿងព័ទ្ធ មានរានផ្សារជាដើម គប្បីជ្រាបថា **និគម** ។

ភិក្ខុណាប្រទូស្តនូវត្រកូលទាំងឡាយ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា **កុលទូសក** ។ កាលនឹងប្រទូស្ត មិនមែនប្រទូស្តដោយរបស់អាក្រក់ មានរបស់មិនស្អាត និងកក់ជាដើមឡើយ ដោយពិត រមែងធ្វើសេចក្តីជ្រះថ្លារបស់ត្រកូលទាំងឡាយឲ្យវិនាសទៅ ដោយការបដិបត្តិអាក្រក់របស់ខ្លួន ដោយហេតុនោះ ទើបក្នុងការចែកបទនោះ លោកពោលថា **បុប្ផេន វា** ជាដើម ។

[ ៣២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បុប្ផេន** ជាដើមដូច្នេះថា ភិក្ខុណានាំទៅឲ្យឯងក្តី ឲ្យអ្នកដទៃនាំទៅឲ្យក្តី ហៅមកឲ្យឯងក្តី ឲ្យអ្នកដទៃហៅមកឲ្យក្តី ឬឲ្យផ្កាដែលជារបស់ខ្លួនឯណានីមួយ ដល់បុគ្គលទាំងឡាយ

ដែលចូលទៅរកឯង ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។ ឲ្យផ្កាបស់អ្នកដទៃ ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។ ឲ្យដោយថេយ្យចិត្ត ព្រះវិនយធរគប្បីកាត់អាបត្តិតាមតម្លៃទ្រព្យ ។ សូម្បីក្នុងរបស់សង្ឃក៏មានន័យយ៉ាងនេះដូចគ្នា ។ ឯការប្លែកគ្នា មានដូចតទៅនេះថា ត្រូវអាបត្តិថុល្លច្ច័យដល់ភិក្ខុដែលឲ្យផ្កាជារបស់គេកំណត់ទុក ដើម្បីប្រយោជន៍ដល់សេនាសនៈ ដោយអាងថា ខ្លួនជាធំ ។

សួរថា ឈ្មោះថា ផ្កា គួរឲ្យដល់បុគ្គលណា មិនគួរឲ្យដល់បុគ្គលណា ឆ្លើយថា កាលនឹងឲ្យដល់មាតាបិតាមុន នាំទៅឲ្យឯងក្តី ប្រើឲ្យនាំទៅឲ្យក្តី ហៅមកឲ្យឯងក្តី ប្រើឲ្យហៅមកឲ្យក្តី គួរទាំងអស់ ។ សម្រាប់ញាតិដ៏សេសឲ្យហៅមកឲ្យប៉ុណ្ណោះ ទើបគួរ ។ ឯការឲ្យផ្កានោះ ដើម្បីប្រយោជន៍ដល់ការបូជាព្រះរតនត្រ័យ ទើបគួរ ។ តែនឹងឲ្យផ្កាដល់បុគ្គលណាមួយដើម្បីប្រយោជន៍ដល់ការប្រដាប់តាក់តែង ឬដើម្បីប្រយោជន៍ដល់ការបូជាសិវលិង្គជាដើម មិនគួរ ។ កាលនឹងឲ្យនាំទៅឲ្យដល់មាតាបិតា គួរប្រើសាមណេរដែលជាញាតិប៉ុណ្ណោះឲ្យនាំទៅឲ្យ ។ សាមណេរដែលមិនមែនញាតិក្រៅអំពីនោះ បើប្រាថ្នានឹងនាំទៅឯងប៉ុណ្ណោះ ទើបគួរឲ្យនាំទៅ ។ ភិក្ខុអ្នកចែកផ្កា ដែលបានទទួលសន្មត ទោះឲ្យចំណែកពាក់កណ្តាលដល់ពួកសាមណេរ ដែលមកដល់ក្នុងវេលាចែក ក៏គួរ ។

ក្នុងកុរុន្ទីពោលថា គួរឲ្យពាក់កណ្តាលចំណែកដល់គ្រហស្ថដែលមកដល់ក្នុងមហាបច្ចរីពោលថា គួរឲ្យតែបន្តិចបន្តួច ។ ភិក្ខុដែលមិនបានទទួលសម្មតិ

គួរអបលោកឲ្យ ពួកសាមណេរដែលមានការគោរពក្នុងអាចារ្យ និងឧបជ្ឈាយ៍ បាននាំផ្កាជាច្រើនមកគរទុក ។ ព្រះថេរៈទាំងឡាយឲ្យដល់ពួកសទ្ធិវិហារិកជាដើម ឬដល់ពួកឧបាសក ដែលមកដល់អំពីព្រលឹម ដោយពោលថា អ្នកចូរកាន់យកផ្កានេះចុះ អ្នកចូរកាន់យកផ្កានេះចុះ មិនរាប់ថា ជាការឲ្យផ្កាឡើយ ។ ពួកភិក្ខុដែលកាន់យកទៅដោយគិតថា ពួកយើងនឹងបូជាព្រះចេតិយក្តី កំពុងធ្វើការបូជាក្តី ឲ្យដល់ពួកគ្រហស្ថដែលមកដល់ក្នុងទីនោះៗ ដើម្បីប្រយោជន៍ការបូជាព្រះចេតិយ សូម្បីការឲ្យនេះ ក៏មិនរាប់ថា ជាការឲ្យផ្កាឡើយ សូម្បីឃើញពួកឧបាសកកំពុងបូជាដោយផ្ការក់ជាដើម ហើយពោលថា ឧបាសកទាំងឡាយ ផ្កាកណិការជាដើមឯវត្តមាន ពួកអ្នកចូរទៅបេះផ្កាកណិការជា-ដើម មកបូជាចុះ ដូច្នេះក៏គួរ ។

ពួកអ្នកស្រុកសួរភិក្ខុទាំងឡាយ ដែលធ្វើការបូជាដោយផ្កា ហើយចូលទៅកាន់ស្រុកយឺតពេលថា ព្រោះហេតុអ្វី ទើបពួកលោកម្ចាស់ មកយឺតម៉្លេះ ពួកភិក្ខុឆ្លើយថា ឯវត្តមានផ្កាច្រើន ពួកអាត្មាបានធ្វើការបូជា ។ ពួកអ្នកស្រុកដឹងថា បានឮថា ក្នុងវត្តមានផ្កាច្រើន ស្អែកឡើង ទើបកាន់យករបស់ទំពាររបស់បរិភោគជាច្រើនទៅកាន់វត្ត ធ្វើការបូជាដោយផ្កា និងថ្វាយទាន ការពោលនោះក៏គួរ ។

ពួកអ្នកស្រុកសូមវារៈផ្កាថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងបូជាក្នុងថ្ងៃឯណោះ ហើយមកក្នុងថ្ងៃដែលអនុញ្ញាត ។ ពួកសាមណេរបានបេះផ្កាទុកអំពីព្រលឹម ។ ពួកអ្នកស្រុក កាលមិនឃើញផ្កាជាដើម ទើបនិយាយថា បពិត្រ

លោកម្ចាស់ ផ្កានៅឯណា ។ ព្រះថេរៈទាំងឡាយឆ្លើយថា ពួកសាមណេរបេះទុក ពួកអ្នកចូរទៅបូជាចុះ សង្ឃនឹងបូជាក្នុងថ្ងៃដទៃ ។ ពួកអ្នកស្រុកទាំងនោះ នាំគ្នាបូជា ថ្វាយទាន ហើយទៅ ការពោលយ៉ាងនោះ ក៏គួរ ។

តែក្នុងមហាបច្ចរី និងកុរុន្ទី ពោលថា ព្រះថេរៈទាំងឡាយរមែងមិនបាន ដើម្បីនឹងប្រើឲ្យពួកសាមណេរឲ្យ បើពួកសាមណេរឲ្យផ្កាទាំងនោះដល់ពួកអ្នកស្រុកទាំងនោះដោយខ្លួនឯងនោះឯង ការឲ្យនោះសមគួរ តែព្រះថេរៈទាំង-ឡាយ គួរពោលពាក្យត្រឹមប៉ុណ្ណោះថា ពួកសាមណេរបេះផ្កាទាំងនេះទុក ។

តែបើពួកអ្នកស្រុកសូមវារៈផ្កាហើយ កាលពួកសាមណេរមិនបានបេះផ្កាទុក កាន់យកយាគូ និងភត្តជាដើមមកហើយ ពោលថា លោកម្ចាស់ទាំង-ឡាយ សូមឲ្យសាមណេរទាំងឡាយបេះឲ្យផង ការប្រើឲ្យពួកសាមណេរដែលជាញាតិប៉ុណ្ណោះបេះឲ្យ ទើបគួរ ។ ព្រះថេរៈទាំងឡាយ លើកពួកសាមណេរដែលមិនមែនជាញាតិឡើងទុកខាងលើមែកឈើ ពួកសាមណេរមិនគួរចុះ ហើយគេចទៅឡើយ គួរបេះឲ្យ ។

ក្នុងមហាបច្ចរី និងកុរុន្ទីពោលថា បើព្រះធម្មកថិកអង្គខ្លះ ពោលថាឧបាសក និងឧបាសិកាទាំងឡាយ ផ្កាឯវត្តមានច្រើន ពួកអ្នកចូរកាន់យកបបរ និងភត្តជាដើមទៅធ្វើការបូជាដោយផ្កាចុះ យាគូ និងភត្តជាដើមនោះរមែងមិនគួរដល់ព្រះធម្មកថិកប៉ុណ្ណោះ ។ តែក្នុងមហាអដ្ឋកថា ពោលទុកដោយមិនប្លែកគ្នាថា យាគូ និងភត្តជាដើមនោះជាអកប្បិយ គឺមិនគួរ ។

សូម្បីផ្លែឈើដែលជារបស់ខ្លួន ឲ្យដល់មាតាបិតា និងពួកញាតិដ៏សេស

រមែងគួរ ដោយន័យដូចពោលហើយនោះឯង ។ តែកាលភិក្ខុឲ្យដើម្បីប្រយោជន៍ដោយការសង្គ្រោះត្រកូល គប្បីជ្រាបថា ត្រូវអាបត្តិទុក្កដជាដើម ព្រោះផ្លែឈើរបស់ខ្លួន របស់អ្នកដទៃ របស់សង្ឃ និងរបស់ដែលគេកំណត់ទុកដើម្បីប្រយោជន៍ដល់សេនាសនៈ ដោយន័យដូចពោលហើយនោះឯង ។ ចំពោះផ្លែឈើដែលជារបស់ខ្លួន ទោះឲ្យដល់អ្នកជំងឺ ឬដល់ពួកឥស្សរជនដែលមកដល់ ហើយអស់ស្បៀង ក៏គួរ ។ មិនរាប់ថា ជាការឲ្យផ្លែឈើឡើយ ។ សូម្បីភិក្ខុអ្នកចែកផ្លែឈើដែលសង្ឃសន្មត ទោះឲ្យចំណែកពាក់កណ្ដាលដល់ពួកអ្នកស្រុកដែលមកដល់ក្នុងវេលាចែកផ្លែឈើដល់សង្ឃ ក៏គួរ ។ ភិក្ខុមិនបានទទួលសម្មតិ គួរអបលោកឲ្យ ។

សូម្បីក្នុងសង្ឃារាម សង្ឃក៏គួរធ្វើកតិកាទុក ដោយការកំណត់ផ្លែឈើ ឬដោយការកំណត់ដើមឈើ កាលពួកមនុស្សឈឺ ឬពួកមនុស្សដទៃ សូមផ្លែឈើអំពីផ្លែ ឬអំពីដើមឈើ ដែលកំណត់ទុកនោះ គប្បីឲ្យ ៤-៥ ផ្លែ ឬគប្បីបង្ហាញដើមឈើតាមដែលកំណត់ទុកថា ពួកអ្នកកាន់យកអំពីដើមនេះបាន តែមិនគួរពោលថា ផ្លែឈើត្រង់ដើមនេះល្អ ពួកអ្នកចូរកាន់យកអំពីដើមនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចុណ្ណេន** នេះ ដូចតទៅនេះថា ភិក្ខុឲ្យលម្អិតដំរស្រល់ ឬទឹកចត់ដទៃរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់ការសង្គ្រោះត្រកូល ត្រូវអាបត្តិទុក្កដ ។ សូម្បីក្នុងរបស់នៃអ្នកដទៃជាដើម ក៏គប្បីជ្រាបវិនិច្ឆ័យដោយន័យដូចពោលមកហើយ ។ ចំណែកការប្លែកគ្នា មានដូចតទៅនេះថា ក្នុងចុណ្ណវិស័យនេះ សម្បកឈើដែលសង្ឃរក្សា និងបម្រុងទុក ក៏

ចាត់ជាគរុភណ្ឌពិត ។ សូម្បីក្នុងជីស្អិត ឈើស្ងួន និងឫស្សី បណ្ឌិតស្គាល់របស់ដែលគួរជាគរុភណ្ឌហើយ គប្បីជ្រាបវិនិច្ឆ័យដូចពោលហើយ ក្នុងលម្អិតនោះឯង ។ តែការឲ្យស្ទីកឈើមិនមកក្នុងបាលីនេះ ។ សូម្បីការឲ្យស្ទីកឈើនោះ ក៏គប្បីជ្រាបដោយន័យដូចពោលហើយដូចគ្នា ។ ខ្ញុំនឹងពណ៌នាការឲ្យស្ទីកឈើទាំងអស់ដោយពិស្តារ ក្នុងការវិនិច្ឆ័យគរុភណ្ឌខាងមុខ ។

វេជ្ជកម្មវិធីក្នុងបទថា **វេជ្ជកាយ វា** នេះ បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងតតិយបារាជិកវណ្ណនានោះឯង ។

កម្ម គឺការងាររបស់ទូត និងការបញ្ជូនដំណឹងរបស់ពួកគ្រហស្ថ លោកហៅថា **ជង្ឃបេសនិយ** ក្នុងបទថា **ជង្ឃបេសនិកេន** នេះ សេចក្តីនោះ ភិក្ខុមិនគួរធ្វើឡើយ ព្រោះថា កាលភិក្ខុទទួលបម្រើរបស់គ្រហស្ថ ហើយដើរទៅត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន ។ កាលបើបាន់កោជនដែលបានមកអាស្រ័យកម្មនោះ ត្រូវអាបត្តិទុក្កដគ្រប់ៗ ពំនូត កាលមិនទទួលធ្វើជាទូតជំបូង លុះក្រោយមក ដាក់ចិត្តថា ឥឡូវនេះ នេះ គឺស្រុកនោះ ណ្ហើយចុះ អញនឹងប្រាប់ដំណឹងនោះ ហើយចៀសចេញអំពីផ្លូវ ត្រូវអាបត្តិទុក្កដគ្រប់ៗ ជំហាន ។ កាលបាន់កោជនដែលបានដោយការប្រាប់ដំណឹងនោះ ត្រូវអាបត្តិទុក្កដដោយន័យមុនដូចគ្នា ។ តែភិក្ខុមិនទទួលធ្វើជាទូតមក កាលត្រូវគ្រហស្ថសួរថា បពិត្រលោកម្ចាស់ បុគ្គលមានឈ្មោះនេះ ក្នុងស្រុកឈ្មោះនោះ មានដំណឹងដូចម្តេច ដូច្នេះ ទោះបីប្រាប់ក៏គួរ ។ ក្នុងបញ្ហាដែលគេសួរ មិនមានទោសឡើយ ។

តែបើនាំដំណើររបស់ពួកសហធម្មិក ៥ របស់មាតាបិតា របស់បណ្ឌុ-បលាស និងវេយ្យាវច្ចៈរបស់ខ្លួន គួរ ។ ភិក្ខុនាំដំណើរដែលសមគួរ មានប្រការដូចពោលហើយអំពីមុន របស់ពួកគ្រហស្ថ គួរ ។ ព្រោះដំណើរដែលសមគួរនេះ រមែងមិនឈ្មោះថា ជាកម្ម គឺការរត់ដំណើរ ។ ឯបច្ច័យដែលកើតឡើងអំពីកុលទូសកកម្ម ៨ យ៉ាងនេះ រមែងមិនគួរដល់សហធម្មិកទាំង ៥ ដូចគ្នានឹងបច្ច័យដែលកើតឡើងអំពីការអួតឧត្តរិមនុស្សធម្ម ដែលមិនមានពិត និងការទិញដូរដោយរូបិយនោះឯង ។

ភិក្ខុនោះមានការប្រព្រឹត្តលាមក ព្រោះហេតុនោះ ទើបឈ្មោះថា **បាប-សមាចារ** ។ ក៏ព្រោះបាបសមាចារ មានការដាំឈើផ្កាជាដើម ដែលព្រះមានព្រះភាគទ្រង់បំណងយកហើយក្នុងសិក្ខាបទនេះ ដូច្នោះ ទើបទ្រង់ត្រាស់ក្នុងបទភាជនៈនៃបទថា **បាបសមាចារ** នេះ ដោយន័យជាដើមថា **មាលា-វច្ចំ រោបេតិបិ** ដូច្នេះ ។

[ ២២៣ ] បទថា **តិរោក្ខា** ប្រែថា ទីកំបាំង ។

ក្នុងបទថា **កុលានិ** នេះ ក្នុងបទថា **កុលានិ ច តេន ទុដ្ឋានិ** នេះ ត្រឹមតែជាវោហារ តែដោយអត្ថ ពួកអ្នកស្រុកត្រូវភិក្ខុនោះប្រទូស្ត ដូច្នោះ ទើបក្នុងបទភាជនៈនៃបទថា **កុលានិ ច តេន ទុដ្ឋានិ** ព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា **បុព្វេ សទ្ធា ហុត្វា** ដូច្នេះ ។

[ ២២៤ ] បទថា **ឆន្ទគាមិនោ** មានវិគ្គហៈថា បុគ្គលឈ្មោះថា មានឆន្ទគាមិនៈ ព្រោះអត្ថថា រមែងលំអៀង ព្រោះការស្រឡាញ់ ។ ក្នុងបទ

ដ៏សេស ក៏មានន័យយ៉ាងនេះ ។

ក្នុងបទថា **សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ** នេះ បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះថា ត្រូវអាបត្តិទុក្កដតែម្យ៉ាង ព្រោះកុលទូសកកម្មតែកិត្តុនោះ ចៀសវាងពោលពាក្យណានីងសង្ឃថា ជាអ្នកមានការលំអៀង ព្រោះស្រឡាញ់ជាដើម សង្ឃគប្បីធ្វើសមនុភាសនកម្មដើម្បីលះបង់នូវពាក្យថា ជាអ្នកមានការលំអៀង ព្រោះស្រឡាញ់ជាដើមនោះឯង ។ ពាក្យដ៏សេសគ្រប់អន្លើ មានអត្ថពាក់ទាំងអស់ហើយ ។ សមុដ្ឋានជាដើម ក៏ដូចគ្នានឹងបឋមសង្ឃភេទសិក្ខាបទនោះឯង ។

កុលទូសកសិក្ខាបទវណ្ណនា ចប់

# អធិប្បាយ សរុបសង្ឃាទិសេស

[ ២៣០ ] ក្នុងបទថា **ឧទ្ទិដ្ឋា ខោ ។បេ។ ឯវមេតំ ធារយាមិ** នេះ មានវិនិច្ឆ័យដូច្នេះថា ធម៌ទាំងនេះមានការត្រូវពីដំបូង ព្រោះដូច្នោះ ទើបឈ្មោះថា **បឋមាបត្តិក** អធិប្បាយថា គប្បីត្រូវក្នុងគ្រាដំបូង គឺក្នុងខណៈដែលប្រព្រឹត្តកន្លងនោះឯង ឯធម៌ទាំងឡាយក្រៅអំពីនេះ គប្បីជ្រាបថា **យាវតតិយក** ដោយ អត្ថថា មាន ( ត្រូវអាបត្តិ ) ក្នុងសមនុភាសនកម្មជាគម្រប់ ៣ ដូចរោគ ស្តាំងស្តម មាន ( កើត ) ក្នុងថ្ងៃទី ៣ និងទី ៤ គេ

ហៅថា ភាគទី ៣-៤ ដូច្នេះ ។

បទថា **យាវតិហំ ជានំ បដិច្ឆាទេតិ** សេចក្តីថា កំពុងដឹង បិទបាំងទុក គឺមិនប្រាប់ដល់សព្រហ្មចារីទាំងឡាយថា ខ្ញុំត្រូវអាបត្តិឈ្មោះនេះ អស់ថ្ងៃមានប្រមាណប៉ុណ្ណេះ ។

បទថា **តាវតិហំ** សេចក្តីថា ( ត្រូវនៅបរិវាសដោយការមិនប្រាថ្នា ) អស់ថ្ងៃមានប្រមាណប៉ុណ្ណោះ ។

បទថា **អកាមា បរិវត្ថព្វំ** សេចក្តីថា មិនមែនដោយការប្រាថ្នា គឺមិនមែនដោយអំណាច ( របស់ខ្លួន ) ដែលពិតនោះ គប្បីសមាទានបរិវាសដោយការមិនប្រាថ្នា គឺដោយមិនមែនអំណាច ។

ពីរបទថា **ឧត្តរឹ ឆារត្តំ** គឺអស់ ៦ រាត្រី បន្ថែមពីលើបរិវាស ។

បទថា **ភិក្ខុមានត្តាយ** បានដល់ ការរាប់អានរបស់ភិក្ខុទាំងឡាយ មានពាក្យអធិប្បាយថា ដើម្បីជាប្រយោជន៍ឲ្យភិក្ខុទាំងឡាយត្រេកអរ ។

ភិក្ខុសង្ឃនោះ ឈ្មោះថា **វីសតិគណោ** ព្រោះមានគណៈជាគម្រប់ ២០ អង្គ ។ បទថា **តត្ថ** សេចក្តីថា ក្នុងសីមាដែលភិក្ខុសង្ឃមានគណៈ ២០ អង្គ ដោយកំណត់យ៉ាងទាបបំផុត ។

បទថា **អព្ភេតព្វោ** សេចក្តីថា ដែលភិក្ខុសង្ឃគប្បីអព្ភាន គឺគប្បីទទួល មានពាក្យអធិប្បាយថា គប្បីហៅចូលដោយអំណាចនៃអព្ភានកម្ម ម្យ៉ាងទៀត មានអត្ថថា សង្ឃគប្បីហៅចូលក្រុម ។

បទថា **អនព្ភិតោ** បានដល់ ជាបុគ្គលដែលសង្ឃមិនបានអព្ភាន គឺមិន

បានទទួល ។ មានពាក្យអធិប្បាយថា មិនទាន់បានធ្វើអព្ភានកម្ម ។ម្យ៉ាង ទៀត មានអត្ថថា សង្ឃមិនទាន់បានហៅចូលក្រុម ។

បទថា **សាមីចិ** ប្រែថា តាមធម្មតា ។ មានពាក្យអធិប្បាយថា ឱវាទា-នុសាសនីដែលអនុលោមតាមលោកុត្តរធម៌ ជាសាមីចិ គឺជាធម្មតា ។ បទដ៏សេស ក្នុងបទថា **ឧទ្ទិដ្ឋា ខោ** ជាដើមនេះ មានន័យដូចពោលហើយនោះឯង ។

តេរសកណ្ឌវណ្ណនា ក្នុងអដ្ឋកថា ព្រះវិន័យ

ឈ្មោះ សមន្តប្បាសាទិកា ចប់

# ក្បាលទី២

# វិនយបិដក ពាលីប្រែ -១

## សន្ទឹកចង្អុលប្រាប់មាតិកា


| មាតិកា | លេខទំព័រ |
|---|---|
| **វិនយបិដក** | |
| បារាជិកកណ្ឌសិក្ខាបទទី ២ | ២ |
| **អដ្ឋកថា** | |
| អទិន្នាទានសិក្ខាបទវណ្ណនា | ៧០ |
| អនុប្បញ្ញត្តិទុតិយបារាជិក | ៩៧ |
| សិក្ខាបទវិភង្គនៃទុតិយបារាជិក | ៩៨ |
| អវហារ ២៥ | ១០៩ |
| បទភាជនីយ៍នៃទុតិយបារាជិក | ១២២ |
| អាបត្តិទុក្កដ ៨ យ៉ាង | ១២៧ |
| ឋាននៃទ្រព្យ ៦ យ៉ាង | ១៣២ |
| វិនីតវត្ថុក្នុងទុតិយបារាជិក | ២៥៤ |
| អវហារ ៥ យ៉ាង | ២៥៧ |
| **វិនយបិដក** | |
| បារាជិកកណ្ឌសិក្ខាបទទី ៣ | ២៩៤ |
| **អដ្ឋកថា** | |
| មនុស្សវិគ្គហសិក្ខាបទវណ្ណនា | ៣៤៤ |
| អធិប្បាយអានាបានស្សតិសមាធិ | ៣៦២ |
| អនុប្បញ្ញត្តិនៃតតិយបារាជិក | ៤២៣ |
| សិក្ខាបទវិភង្គនៃតតិយបារាជិក | ៤២៦ |
| ប្រយោគនៃបាណាតិបាត ៦ យ៉ាង | ៤៣១ |

បទភាជនីយ៍នៃតតិយបារាជិក .... ...... ...... ...... ...... ...... .... ៤៣៩
អំពីអនន្តរិយកម្ម និងបារាជិក .. ...... ...... ...... ...... ...... ...... ៤៤១
វិនីតវត្ថុក្នុងតតិយបារាជិក ...... ...... ...... ...... ...... ...... ... ៤៨០

### វិនយបិដក

បារាជិកកណ្ឌសិក្ខាបទទី ៤ ... ...... ...... ...... ...... ...... ...... ...... ៥០៩

### អដ្ឋកថា

ឧត្តរិមនុស្សធម្មសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ៥៨១
មហាចោរ ៥ ពួក ... ...... ...... ...... ...... ...... ...... ...... ៥៨៤
អនុប្បញ្ញត្តិចតុត្ថបារាជិក ... ...... ...... ...... ...... ...... ...... ...... ៥៩៦
សិក្ខាបទវិភង្គនៃចតុត្ថបារាជិក ...... ...... ...... ...... ...... ...... ...... ... ៥៩៩
បទភាជនីយ៍នៃចតុត្ថបារាជិក ...... ...... ...... ...... ...... ...... ...... ... ៦០៩
វិនីតវត្ថុក្នុងចតុត្ថបារាជិក ...... ........ ...... ...... ...... ...... ....... ៦២៨
បារាជិក ២៤ ..... ...... ...... ..... ...... ...... ...... ...... ៦៥០

## វិនយបិដក បាលីប្រែ -២

សង្ឃាទិសេសទី ១ . ...... ...... ...... ...... ...... ...... ៦៥៤

### អដ្ឋកថា

សុក្កវិសដ្ឋិសិក្ខាបទវណ្ណនា ......... ...... ...... ...... ...... ...... ៦៩៥
សិក្ខាបទវិភង្គនៃសុក្កវិសដ្ឋិសិក្ខាបទ ...... ...... ...... ...... ...... ......... ៦៩៨
អធិប្បាយហេតុឲ្យយល់សប្តិ ៤ យ៉ាង ... ...... ...... ...... .......... ៧០១
បទភាជនីយ៍នៃសុក្កវិសដ្ឋិសិក្ខាបទ ...... ...... ...... ...... ...... .......... ៧០៧
វិនីតវត្ថុក្នុងសុក្កវិសដ្ឋិសិក្ខាបទ ...... ...... ...... ...... ...... ........... ៧២៤

### វិនយបិដក

សង្ឃាទិសេសទី ២ ... ...... ...... ...... ...... ...... ..... ៧២៨

### អដ្ឋកថា

កាយសំសគ្គសិក្ខាបទវណ្ណនា .... ...... ...... ...... ...... ...... ... ៧៥២

សិក្ខាបទវិភង្គនៃកាយសំសគ្គសិក្ខាបទ ... ...... ...... ...... .......... ៧៥៣
បទភាជនីយ៍នៃកាយសំសគ្គសិក្ខាបទ ... ...... ...... ...... .......... ៧៥៩
វិនីតវត្ថុក្នុងកាយសំសគ្គសិក្ខាបទ ... ...... ...... ...... .......... ៧៧៣
អធិប្បាយអនាមាសវត្ថុ ... ...... ...... ...... ...... .. ៧៧៤

**វិនយបិដក**

សង្ឃាទិសេសទី ៣ ... ...... ...... ...... ...... ...... ... ៧៨២

**អដ្ឋកថា**

ទុដ្ឋុល្លវាចាសិក្ខាបទវណ្ណនា .... ...... ...... ...... ...... ...... ... ៧៩៧
សិក្ខាបទវិភង្គនៃទុដ្ឋុល្លវាចាសិក្ខាបទ .... ...... ...... ...... ...... ...... ... ៧៩៧
បទភាជនីយ៍នៃទុដ្ឋុល្លវាចាសិក្ខាបទ ...... ...... ...... ...... ...... .... ... ៧៩៩
វិនីតវត្ថុក្នុងទុដ្ឋុល្លវាចាសិក្ខាបទ ...... ...... ...... ...... ...... ...... ... ៨០៤

**វិនយបិដក**

សង្ឃាទិសេសទី ៤ ... ...... ...... ...... ...... ...... ...... ...... ៨០៦

**អដ្ឋកថា**

អត្តកាមបារិចរិយសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ៨១៩
សិក្ខាបទវិភង្គនៃអត្តកាមបារិចរិយសិក្ខាបទ ..... ...... ...... .......... ៨២២

**វិនយបិដក**

សង្ឃាទិសេសទី ៥ ... ...... ...... ...... ...... ...... ...... ...... ៨២៤

**អដ្ឋកថា**

សញ្ចរិត្តសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ៨៧៣
សិក្ខាបទវិភង្គនៃសញ្ចរិត្តសិក្ខាបទ ..... ...... ...... ..... ........ .... ៨៧៦
បទភាជនីយ៍នៃសញ្ចរិត្តសិក្ខាបទ ..... ...... ...... ..... ........ .... ៨៧៩
វិនីតវត្ថុក្នុងសញ្ចរិត្តសិក្ខាបទ ..... ...... ...... ..... ........ .... ៨៩២

**វិនយបិដក**

សង្ឃាទិសេសទី ៦ ... ...... ...... ...... ...... ...... ...... ...... ៨៩៣

**អដ្ឋកថា**

កុដិការសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ៩២៩
វិញ្ញត្តិកថា ពោលអំពីការហាមាត់សូម .. ...... ...... ...... .......... ៩៣០
សិក្ខាបទវិភង្គនៃកុដិការសិក្ខាបទ ...... ...... ...... ...... ...... .......... ៩៤១
បទភាជនីយ៍នៃកុដិការសិក្ខាបទ .... ...... ...... ...... ...... ...... .... ៩៥២

**វិនយបិដក**

សង្ឃាទិសេសទី ៧ ... ...... ...... ...... ...... ...... ...... ...... ៩៥៧

**អដ្ឋកថា**

វិហារការសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ៩៧០
សិក្ខាបទវិភង្គនៃវិហារការសិក្ខាបទ ...... ...... ...... ...... ...... .......... ៩៧២

**វិនយបិដក**

សង្ឃាទិសេសទី ៨ ... ...... ...... ...... ...... ...... ...... ...... ៩៧៣

**អដ្ឋកថា**

បឋមទុដ្ឋទោសសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ១០០១
សិក្ខាបទវិភង្គនៃបឋមទុដ្ឋទោសសិក្ខាបទ .. ...... ...... ...... .......... ១០២០
អធិប្បាយលក្ខណៈនៃការចោទផ្សេងៗ ...... ...... ...... ...... ...... ១០២៦
បទភាជនីយ៍នៃបឋមទុដ្ឋទោសសិក្ខាបទ ...... ...... ...... ...... ...... ១០៤៤

**វិនយបិដក**

សង្ឃាទិសេសទី ៩ ... ...... ...... ...... ...... ...... ...... ...... ១០៥០

**អដ្ឋកថា**

ទុតិយទុដ្ឋទោសសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ១០៦៦
សិក្ខាបទវិភង្គនៃទុតិយទុដ្ឋទោសសិក្ខាបទ .. ...... ...... ...... .......... ១០៦៩

**វិនយបិដក**

សង្ឃាទិសេសទី ១០ ... ...... ...... ...... ...... ...... ...... ...... ១០៧៦

**អដ្ឋកថា**

បឋមសង្ឃាទិសេសសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ១០៨៦
ត្រីសាច់បរិសុទ្ធដោយចំណែក ៣ យ៉ាង ..... ...... ...... ...... ...... ១០៩០
សិក្ខាបទវិភង្គនៃបឋមសង្ឃាទិសេសសិក្ខាបទ .. ...... ...... ...... .......... ១០៩៦
បទភាជនីយ៍នៃបឋមសង្ឃាទិសេសសិក្ខាបទ ... ...... ...... ...... ....... ១១០២

វិនយបិដក

សង្ឃាទិសេសទី ១១ ... ...... ...... ...... ...... ...... ...... ...... ១១០៥

អដ្ឋកថា

ទុតិយសង្ឃាទិសេសសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ១១១២
សិក្ខាបទវិភង្គនៃទុតិយសង្ឃាទិសេសសិក្ខាបទ .. ...... ...... ...... .......... ១១១២

វិនយបិដក

សង្ឃាទិសេសទី ១២ ... ...... ...... ...... ...... ...... ...... ...... ១១១៤

អដ្ឋកថា

ទុព្វចសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ១១២១
សិក្ខាបទវិភង្គនៃទុព្វចសិក្ខាបទ ......... ...... ...... ...... ...... ..... ១១២២

វិនយបិដក

សង្ឃាទិសេសទី ១៣ ... ...... ...... ...... ...... ...... ...... ...... ១១២៦

អដ្ឋកថា

កុលទូសកសិក្ខាបទវណ្ណនា ...... ...... ...... ...... ...... ...... ១១៤៩
ប្រវត្តិរបស់ធព្វគ្គិយភិក្ខុ ......... ...... ...... ...... ...... ..... ១១៤៩
លក្ខណៈ ៥ យ៉ាង មានអកប្បិយវោហារជាដើម .. ...... ...... ...... ១១៥២
អធិប្បាយបុប្ផវិកតិ ៦ ប្រភេទ ......... ...... ...... ...... ...... ..... ១១៥៨
អធិប្បាយអនាចារផ្សេងៗ ......... ...... ...... ...... ...... ..... ១១៦៣
អធិប្បាយកុលទូសកកម្ម ......... ...... ...... ...... ...... ..... ១១៧៤